Khmer Original Book

# ប្រព័ន្ធអប់រំល្បីៗលើពិភពលោក ដំណើរវិវឌ្ឍន៍ និងបញ្ហាប្រឈម នៃការអប់រំនៅកម្ពុជា

- ចំណេះដឹងវិទ្យាសាស្ត្រអប់រំ
- បទពិសោធជោគជ័យប្រព័ន្ធអប់រំប្រទេសនានា
- ការវិភាគ និងសិក្សាប្រៀបធៀប
- សាលារៀនស្តង់ដារលំដាប់អន្តរជាតិ






និពន្ធដោយ៖ ចៅ ឧស្សាហ៍

អធិការអប់រំ-បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ

(២០២១)

Khmer Original Book

# ប្រព័ន្ធអប់រំល្បីៗលើពិភពលោក ដំណើរវិវត្តន៍ និងបញ្ហាប្រឈម នៃការអប់រំនៅកម្ពុជា

*ឯកសារនេះមានប្រយោជន៍ជាខ្លាំងសម្រាប់៖*

- *ថ្នាក់ដឹកនាំ និងគ្រប់គ្រងអប់រំនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន*
- *អ្នកអប់រំគ្រប់លំដាប់ថ្នាក់*
- *គ្រូបង្រៀន សាស្ត្រាចារ្យ*
- *និស្សិតរៀនផ្នែកគ្រប់គ្រងអប់រំ*
- *អ្នកអាន អ្នកសិក្សានានា*

**រក្សាសិទ្ធិគ្រប់យ៉ាង** ( Copy Right) 2020

*ដោយ៖ ចៅ ឧស្សាហ៍ (អធិការអប់រំ-អនុបណ្ឌិតគ្រប់គ្រងអប់រំ)*

សៀវភៅនេះមិនអនុញ្ញាតឱ្យធ្វើការបោះពុម្ពដោយគ្មានការយល់ព្រម ជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធឡើយ។

# មាតិកាសង្ខេប

## ផ្នែកទី១

## ប្រព័ន្ធអប់រំប្រទេសនានានៅលើពិភពលោក


I. ប្រព័ន្ធអប់រំ ប្រទេសសិង្ហបុរី......................................1

II. ប្រព័ន្ធអប់រំប្រទេសជប៉ុន........................................48

III. ការសិក្សាពីប្រព័ន្ធអប់រំកោះតៃវ៉ាន់.....................130

IV. ការសិក្សាពីប្រព័ន្ធអប់រំប្រទេសកូរ៉េ......................208

V. ភាពល្អេចឆ្នៃនៃប្រព័ន្ធអប់រំក្រុងសៀងហៃ..........268

VI. លទ្ធផល PISAទាប! ហេតុអ្វីទៅដែលធ្វើឲ្យអ៊ីស្រាអែលអាចជាប់ចំណាត់ថ្នាក់លេខ២ ជាកន្លែងដ៏ល្អបំផុតសម្រាប់ការច្នៃប្រឌិត?…………………….....289

VII. ហេតុអ្វីវៀតណាមមានភាពលេចធ្លោខ្លាំងលើលទ្ធផលតេស្ត PISA អន្តរជាតិ?…………….....................292


## ផ្នែកទី២


“សាលារៀនស្តង់ដារលំដាប់ខ្ពស់ (កម្រិតអន្តរជាតិ)”........298


## ផ្នែកទី៣

## “ដំណើរវិវត្តន៍ និងបញ្ហាប្រឈមនានានៃការអប់រំនៅកម្ពុជា”

I- ប្រវត្តិអប់រំសង្ខេបកម្ពុជា........................................317
II- អត្ថប្រយោជន៍នៃការអប់រំសម្រាប់កម្ពុជា....................323
III- ដំណើរវិវត្ត ស្ថានភាពវិស័យអប់រំ និងកំណែទម្រង់តាម
ដំណាក់កាលនីមួយ..............................................327
IV- សាកល្បងសិក្សាពីបញ្ហាប្រឈមនៃការអប់រំ................410
V- និន្នាការអប់រំថ្មីសម្រាប់កម្ពុជា..................................462

# សន្និដ្ឋាន

# មាតិកាលម្អិត

## ផ្នែកទី១

## ប្រព័ន្ធអប់រំប្រទេសនានានៅលើពិភពលោក

### I. ប្រព័ន្ធអប់រំ ប្រទេសសឹង្ហបូរី

1.1) ទិដ្ឋភាពសង្គម សេដ្ឋកិច្ច នយោបាយសឹង្ហបូរី..................2

1.2) ការសិក្សាពីប្រព័ន្ធអប់រំប្រទេសសឹង្ហបូរី.........................6

1.3) ដំណើរវិវត្តប្រព័ន្ធអប់រំសឹង្ហបូរី...................................11

1.4) លក្ខណៈពិសេសនៃប្រព័ន្ធអប់រំសឹង្ហបូរី......................22

1.5) សង្ខេបការសិក្សាប្រៀបធៀបប្រព័ន្ធអប់រំសឹង្ហបូរី និងកម្ពុជា ..........................................................................26

1.6) កំណែទម្រង់គ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ..........................................................................30

1.7) សន្និដ្ឋានរួម និងសង្ខេបគំនិតសំខាន់ៗ......................39

### II. ប្រព័ន្ធអប់រំប្រទេសជប៉ុន

2.1) ទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងនយោបាយប្រទេសជប៉ុន..49

2.2) ការសិក្សាពីប្រព័ន្ធអប់រំប្រទេសជប៉ុន..........................66

2.3) ដំណើរវិវត្តន៍ និងផ្លាស់ប្តូរប្រព័ន្ធអប់រំប្រទេសជប៉ុន........69

2.4) ការពិភាក្សាពីប្រព័ន្ធអប់រំប្រទេសជប៉ុនបច្ចុប្បន្ន............72

2.5) ការអប់រំកម្រិតមត្តេយ្យសិក្សា.................................88

2.6) ការអប់រំកម្រិតបឋមសិក្សា....................................90

2.7) ការអប់រំកម្រិតមធ្យមសិក្សា..................................95

2.8) ការអប់រំជំនាញវិជ្ជាជីវៈ.........................................99

2.9) ការអប់រំកម្រិតកឧត្តមសិក្សា................................100

2.10) លក្ខណៈពិសេសនៃប្រព័ន្ធអប់រំប្រទេសជប៉ុន...........103

2.11) ច្បាប់ទាក់ទងនឹងការបណ្ដុះបណ្ដាលគ្រូបង្រៀន........112

2.12) ដំណើរការជ្រើសរើសគ្រូបង្រៀន..........................115

2.13) ការបណ្ដុះបណ្ដាលគ្រូបង្រៀនចេញថ្មី....................117

2.14) ការរៀបចំអប់រំគ្រូបង្រៀន...................................118

2.15) ការអភិវឌ្ឍបំណិនវិជ្ជាជីវៈ និងគុណវុឌ្ឍិគ្រូបង្រៀន....119

2.16) បញ្ហាប្រឈមនៃការអប់រំនៅប្រទេសជប៉ុន...............123

**III. ការសិក្សាពីប្រព័ន្ធអប់រំកោះតៃវ៉ាន់**

3.1) ទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងនយោបាយកោះតៃវ៉ាន់
..................................................................131

3.2) ប្រព័ន្ធអប់រំកោះតៃវ៉ាន់.................................148

3.3) ការអភិវឌ្ឍសមត្ថភាពសតវត្សរ៍ទី២១របស់តៃវ៉ាន់
..........................................................................161

3.4) គោលបំណងរបស់ក្រសួងអប់រំតៃវ៉ាន់សម្រាប់ឆ្នាំ
២០១៥.................................................................169

3.5) លក្ខណៈពិសេសនៃប្រព័ន្ធអប់រំតៃវ៉ាន់ដែលយើងអាច
រៀនសូត្របាន......................................................175

3.6) ប្រព័ន្ធអប់រំសាធារណៈ....................................183

3.7) ការអប់រំកម្រិតបឋមសិក្សា..............................185

3.8) ការអប់រំកម្រិតមធ្យមសិក្សា............................186

3.9) សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ..........................189

3.10) ទំនាក់ទំនងរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងការអប់រំ
ជំនាញវិជ្ជាជីវៈ បច្ចេកទេសតៃវ៉ាន់...........................191

3.11) ប្រៀបធៀបការបណ្តុះបណ្តាលបច្ចេកទេស ជំនាញ
វិជ្ជាជីវៈ និងទីផ្សារការងាររវាងកោះតៃវ៉ាន់ និងជប៉ុន
..........................................................................197

3.12) ការអប់រំជាន់ខ្ពស់..........................................200

3.13) ការអប់រំឯកជន.............................................204

3.14) ការបណ្តុះបណ្តាល និងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន..........................................................205

3.15) ព័ត៌មាន និងធនធានលើកកម្ពស់ការអប់រំ គ្រូបង្រៀនដែលកំពុងបំពេញការងារ...........................206

IV. ការសិក្សាពីប្រព័ន្ធអប់រំប្រទេសកូរ៉េ

4.1) ទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងនយោបាយប្រទេសកូរ៉េ..................................................................209

4.2) ប្រព័ន្ធអប់រំប្រទេសកូរ៉េ................................221

4.3) គន្លឹះជោគជ័យនៃប្រព័ន្ធអប់រំប្រទេសកូរ៉េ..........225

4.4) ដំណើរវិវត្ត និងកំណែទម្រង់ប្រព័ន្ធអប់រំប្រទេសកូរ៉េ..................................................................235

4.5) ការសិក្សាពីការអប់រំតាមកម្រិតថ្នាក់នីមួយៗ......246

4.6) ការបណ្តុះបណ្តាលវិជ្ជាជីវៈ............................257

4.7) ការអប់រំកម្រិតឧត្តមសិក្សា............................262

4.8) គ្រូបង្រៀន...........................................265

V. ភាពល្អចង្គោរនៃប្រព័ន្ធអប់រំក្រុងសៀងហៃ

5.1) ទស្សនៈគំនិតរបស់លោក Minxuan Zhang.....268

5.2)-ទស្សនៈគំនិតរបស់លោក Vivien Stewart ......280

5.3)-ប្រព័ន្ធអភិវឌ្ឍន៍គ្រូបង្រៀននៅក្រុងសៀងហៃ.....285

VI. លទ្ធផល PISA ទាប! ហេតុអ្វីទៅដែលធ្វើឲ្យអ៊ីស្រាអែលអាចជាប់ចំណាត់ថ្នាក់លេខ២ជាកន្លែងដ៏ល្អបំផុតសម្រាប់ការច្នៃប្រឌិត?

.......................................................289

VII. ហេតុអ្វីវៀតណាមមានភាពលេចធ្លោខ្លាំងលើលទ្ធផលតេស្ត PISA អន្តរជាតិ?

.......................................................292

# ផ្នែកទី២

# សាលារៀនស្តង់ដារលំដាប់ខ្ពស់ (កម្រិតអន្តរជាតិ)

1) ការងារគ្រប់គ្រង និងដឹកនាំ.......................299

2) ការបង្រៀន និងរៀន.............................304

3) លទ្ធផលសិក្សារបស់សិស្ស........................314

4) ការវាយតម្លៃ និងកិច្ចសហការ.....................315

# ផ្នែកទី៣

# ដំណើរវិវត្តន៍និងបញ្ហាប្រឈមនានានៃការអប់រំនៅកម្ពុជា

I- ប្រវត្តិអប់រំសង្ខេបកម្ពុជា......................................317
II- អត្ថប្រយោជន៍នៃការអប់រំសម្រាប់កម្ពុជា...................323
III- ដំណើរវិវត្ត ស្ថានភាពវិស័យអប់រំ និងកំណែទម្រង់តាម ដំណាក់កាលនីមួយ...........................................327
1. គោលនយោបាយក្រសួងអប់រំយុវជន និងកីឡា (១៩៩៦)..................................................327
2. ការអប់រំសម្រាប់ទាំងអស់គ្នា ២០០៣-២០១៥ (២០០៣)..................................................328
3. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ (២០០៥)..................................................339
4. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ..................................................................352
5. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០១៤-២០១៨ ..................................................................369
6. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ..................................................................409
IV- សាកល្បងសិក្សាពីបញ្ហាប្រឈមនៃការអប់រំ................410
1) បញ្ហាទំនាស់ផលប្រយោជន៍ និងបញ្ហាបក្សពួកនិយម ................................................................411
2) ការតែងតាំង តំលើងតួនាទី និងមុខតំណែង........414
3) កាសរសេរបាយការណ៍.................................416
4) អំពើពុករលួយ..............................................417

5) ការដណ្តើមទីផ្សារការងារសម្រាប់វិស័យអប់រំផ្នែកឯកជន ........................................................422
6) កម្មវិធីសិក្សាថ្នាក់កម្រិតឧត្តមសិក្សាមួយចំនួននៅសតវត្សរ៍ទី២០នៅឡើយ....................................424
7) ការសិក្សាពីចម្ងាយ.......................................428
8) បញ្ហាប្រឈមកម្រិតសាលារៀន.......................430
ក-ការគ្រប់គ្រង និងដឹកនាំ.........................434
ខ-ការបង្រៀន និងរៀន..............................438
គ-លទ្ធផលសិក្សាសិស្ស............................438
ឃ-ស្វ័យវាយតម្លៃ....................................439
9) ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន..............439
10) ការបង្រៀនគួរក្រៅម៉ោង................................447
11) បញ្ហាខ្វះ និងលើសគ្រូបង្រៀន.........................453
12) ការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន.......................455
13) វិធីសាស្ត្របង្រៀន........................................458
14) ស្ថានភាពនៃការអប់រំកុមារនៅជនបទ...............459
15) ជំនាញទន់(Soft skill) របស់គ្រូបង្រៀន............461
**V- និន្នាការអប់រំថ្មីសម្រាប់កម្ពុជា..................................464**
ទិដ្ឋភាពទូទៅផ្នែកសង្គម សេដ្ឋកិច្ច និងបញ្ហាប្រឈម ....................................................................466
**សន្និដ្ឋាន**...............................................................470

# អារម្ភកថា

តាំងពីអតីតកាលរហូតដល់បច្ចុប្បន្ននេះ សង្គមខ្មែរយើងហាក់មិនសូវសម្បូរការសិក្សាស្រាវជ្រាវ ការវិភាគ និងសិក្សាប្រៀបធៀបពីប្រព័ន្ធអប់រំរបស់បណ្តាប្រទេសនានាដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញលើឆាកអន្តរជាតិ និងជាប្រទេសដែលមានលទ្ធផលតេស្ត PISA ខ្ពស់នៅឡើយទេ ទោះបីជាមាននិស្សិតបញ្ញវន្តបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតជាច្រើននាក់យ៉ាងណាក៏ដោយ ហើយក្នុងនោះក៏មានសិស្ស-និស្សិតមួយចំនួនបានបញ្ចប់ការសិក្សាពីបរទេសថែមទៀត។ ការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារដោយពាំនាំបទពិសោធជោគជ័យ លក្ខណៈពិសេស ចំណុចខ្លាំង និងមេរៀនរៀនសូត្រពីប្រទេសទាំងនោះមកបម្រើដល់ផលប្រយោជន៍ជាតិ និងទុកជាជំនួយស្មារតីដល់អ្នកអាន-អ្នកសិក្សាហាក់មិនសូវផុលផុសនៅឡើយ។ ប្រទេសយើងពិតជាមានកង្វះខាតឯកសារសិក្សាស្រាវជ្រាវច្រើនណាស់សម្រាប់អភិវឌ្ឍន៍ធនធានមនុស្សដែលជាកត្តាអាទិភាពក្នុងការអភិវឌ្ឍប្រទេស។ តម្រូវការធនធានផ្នែកអប់រំជាកូនសោក្នុងបើកទ្វារវឌ្ឍនភាព វិបុលភាព ភាពសុដុមរម្យនា និងការអភិវឌ្ឍប្រកបដោយចេរភាពដែលយើងទាំងអស់គ្នាត្រូវយកចិត្តទុកដាក់។ ជាទូទៅ យើងសង្កេតឃើញថាសង្គមយើងសម្បូរ*ធនធានមនុស្សដែលមានសមត្ថភាពនិយាយ ច្រើនជាងមនុស្សមានសមត្ថភាពសរសេរ* ដោយសារប្រជាជនភាគច្រើនហាក់មិនចាប់អារម្មណ៍ខ្លាំងក្លានឹងការអាន និងសរសេរនៅឡើយ ព្រមទាំងមិនទាន់យល់ពីគុណតម្លៃនៃការនិពន្ធចងក្រងបន្សល់ទុកចំណេះដឹងរបស់ខ្លួនទុកជាស្នាដៃដ៏ថ្លៃថ្លា និងម្យ៉ាងទៀតដោយសារហេតុផលសង្គមហាក់មិនសូវលើកកម្ពស់ឲ្យតម្លៃ និងលើកទឹកចិត្តខ្លាំងក្លាដល់ការងារនេះ ពិសេសការការពារកម្មសិទ្ធិបញ្ញា និងលើកកម្ពស់វប្បធម៌នៃការអាន និងសរសេរសៀវភៅឬអត្ថបទផ្សេងៗ។ វាការពិតណាស់សមិទ្ធផលស្នាដៃនិពន្ធមានសារៈសំខាន់ណាស់ ព្រោះវាជាសក្ខីកម្មឆ្លុះបញ្ចាំងពីសមត្ថភាព និងគុណធម៌បុគ្គលយ៉ាង

ពិតប្រាកដ និងជាមធ្យោបាយលើកកម្ពស់គុណតម្លៃខ្លួនឯងយ៉ាងប្រក្សត្រ។ ស្នាដៃដែលល្អនឹងរក្សាតម្លៃខ្លួនជាអមតៈព្រោះវាមានតម្លៃសច្ចភាព និង បម្រើឲ្យផលប្រយោជន៏មនុស្សជាតិគ្រប់សម័យកាល។ ***ដូច្នេះ! ឱសថទិព្វដែលធ្វើឲ្យអ្នកមិនស្លាប់បាត់បង់សាបសូន្យនោះគឺ ស្នាដៃរបស់អ្នកនេះឯងតួយ៉ាងដូចសម្តេចសង្ឃរាជ ជួត ណាតជាដើម***។ យើងខ្ញុំសូមលើកទឹកចិត្តឱ្យមានការនិពន្ធស្នាដៃឱ្យបានច្រើនថែមទៀត ដើម្បីទុកជាគុណប្រយោជន៍ដល់ជនរួមជាតិតទៅអនាគត។ ពិតណាស់គុណតម្លៃនេះ កូនខ្មែរជំនាន់ក្រោយគ្រប់រូបនឹងស្គាល់ឈ្មោះអ្នក និងមានមោទនភាពចំពោះការលះបង់របស់អ្នក ហើយគោលគំនិតរបស់អ្នកក៏មិនរលាយសាបសូន្យដែរ។ បើសិនពន្លកនៃស្នាដៃនិពន្ធត្រូវបានជ្រួយដីដាក់ជីស្រោចទឹក ការពារគត់ហ្មត់ និងផ្តល់ផលប្រយោជន៏ដល់អ្នកដាំវិញជាក់លាក់នោះប្រទេសកម្ពុជានឹងសម្បូរធនធានអ្នកនិពន្ធជាក់ជាមិនខានឡើយ។

ដោយមើលឃើញគុណតម្លៃភាពជាមនុស្សនេះ និងស្ថានភាពនិស្សិតបញ្ញវន្តខ្មែរជាច្រើននាពេលបច្ចុប្បន្ននេះដែលកំពុងស្រេកឃ្លានចំណេះដឹង និងខ្វះខាតឯកសារសិក្សាស្រាវជ្រាវដោយឯកសារភាគច្រើនជាភាសាបរទេសដែលជាហេតុធ្វើឲ្យមានការលំបាកក្នុងការស្វែងយល់ពីអត្ថន័យខ្លឹមសាររបស់វា ទើបយើងខ្ញុំខិតខំយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីសិក្សាស្រាវជ្រាវប្រមែប្រមូលឯកសារទាំងខ្មែរ ទាំងបរទេសដើម្បីចងក្រងសៀវភៅនេះឡើង។ យ៉ាងណាក៏ដោយ យើងខ្ញុំពិតជាមានមោទនភាពជាខ្លាំងដែលសន្ទុះនៃការនិពន្ធចងក្រងរៀបរៀងស្នាដៃនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នមានលក្ខណៈខ្លាំងក្លាជាងមុនគួរឲ្យកត់សម្គាល់ បើទោះបីអ្នកនិពន្ធមួយចំនួនបានព្យាយាមប្រឹងប្រែងបកប្រែពីសៀវភៅបរទេសក៏ដោយក៏វាពិតជាផ្តល់ផលប្រយោជន៏ដ៏ធំធេងមួយដែរ៕

**អ្នកនិពន្ធ**

# សេចក្តីផ្តើម

ឈានដល់យុគ្គសម័យបដិវត្តន៍ឧស្សាហកម្មទី៤ ដោយផ្តោតខ្លាំងលើបច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗ ដូចជាបច្ចេកវិទ្យាបញ្ញាសប្បនិមិត្ត និងរ៉ូបូតជាដើមដែលជះឥទ្ធិពលខ្លាំងលើគ្រប់ទិដ្ឋភាពជីវិតរស់នៅរបស់មនុស្ស។ និន្នាការអប់រំសតវត្សរ៍ទី២១ ការផ្លាស់ប្តូរជាខ្លាំងលើការផលិតមូលធនមនុស្សដើម្បីឆ្លើយតបទៅនឹងដំណើរវិវត្តន៍របស់សង្គមនេះ និងការប្រកួតប្រជែង។ ស្របតាមនិន្នាការនេះ ប្រទេសទាំងឡាយនៅលើពិភពលោកយកចិត្តទុកដាក់ខ្លាំងក្នុងការធ្វើកំណែទម្រង់ និងទំនើបកម្មប្រព័ន្ធអប់រំរបស់ខ្លួនឱ្យមានលក្ខណៈសមស្របក្នុងការផលិតមូលធនមនុស្ស ដើម្បីទទួលយកផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមក្នុងបរិបទថ្មីនេះ។ សម្រាប់ប្រទេសកម្ពុ-ជា រាជរដ្ឋាភិបាលក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងយកចិត្តទុកដាក់ជាខ្លាំងលើការកែទម្រង់ប្រព័ន្ធអប់រំតាមរយៈការបង្កើនថវិកាចំណាយប្រចាំឆ្នាំដល់វិស័យនេះពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីផលិតធនធានមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពេញលេញក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេស។ ជាមួយគ្នានេះ ក្រសួងបានប្តេជ្ញាចិត្តធ្វើឱ្យសម្រេចនូវគោលដៅរួមរបស់ SDG4 គឺធានាឱ្យបាននូវការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ប្រទេសកម្ពុជាមានគោលដៅប្រែក្លាយប្រទេសទៅប្រទេសឧស្សាហកម្មនៅឆ្នាំ២០២៥ តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២០២៥ និងជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងយកចិត្តទុកដាក់ជាខ្លាំងក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអប់រំដែលមានស្តង់ដារឆ្លើយតប

ទៅនឹងត្រូវការជាចាំបាច់នៃការអភិវឌ្ឍជាតិ និងសង្គមនាពេលបច្ចុប្បន្ន និងតទៅអនាគត។ វិស័យអប់រំត្រូវបានចាត់ទុកជាឆ្អឹងខ្នងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ហើយប្រព័ន្ធអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិតមូលធនមនុស្សប្រកបដោយសក្តានុពលសម្រាប់បម្រើដល់ការរីកចម្រើនលូតលាស់ផ្នែកសេដ្ឋកិច្ច និងសង្គម។ ក្នុងន័យនេះ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្សឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ជាតិដែលចង់បាន គេត្រូវការប្រព័ន្ធអប់រំដ៏ល្អមួយជាការចាំបាច់បំផុត។ ហេតុដូច្នេះហើយបានជាសៀវភៅមួយក្បាលដែលអ្នកកំពុងកាន់ក្នុងដៃនេះចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនការយល់ដឹងពីប្រព័ន្ធអប់រំយ៉ាងស៊ីជម្រៅទាំងកម្រិតជាតិ និងអន្តរជាតិ។ ការយល់ដឹងពីប្រព័ន្ធអប់រំល្បីៗរបស់ប្រទេសនានានេះ គន្លឹះដ៏សំខាន់ក្នុងការបើកចំហាជើងមេឃ សម្លឹងមើលពិភពលោកដ៏ទូលំទូលាយ និងងាកចេញពីស្ថានភាពដូចកង្កែបក្នុងអណ្តូង។

ជាការពិត ដោយសារប្រទេសយើងនៅកង្វះឯកសារស្រាវជ្រាវជាច្រើនទាក់ទងនឹងប្រព័ន្ធអប់រំ ពិសេសការសិក្សាស្វែងយល់ និងសិក្សាប្រៀបធៀបប្រព័ន្ធអប់រំរបស់ប្រទេសនានានៅលើពិភពលោក ដែលទទួលជោគជ័យខ្លាំង និងអាចចាត់ទុកថាជាគំរូដ៏ល្អក្នុងការផ្តល់ចំណេះដឹង មេរៀនរៀនសូត្រ និងបទពិសោធសម្រាប់ប្រទេសដទៃទៀតបាន ហើយដែលចំណុចទាំងអស់នេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជាយើងក្នុងការសិក្សាស្វែងយល់ និងទាញយកមកបម្រើដល់វិស័យអប់រំខ្លួន។ គោលបំណងនៃការនិពន្ធចងក្រងសៀវភៅនេះឡើងគឺ ដើម្បីទុកជាវិភាគទានមួយសម្រាប់អ្នកអាន-អ្នកសិក្សាស្វែងយល់ពីប្រព័ន្ធអប់រំល្បីៗនៅលើពិភពលោកដោយធ្វើការប្រមូលផ្តុំនូវចំណេះដឹង និងបទពិសោធល្អៗ សិក្សាពីលក្ខណៈពិសេសនៃសាលារៀនដែលមានស្តង់ដារអន្តរជាតិលំដាប់ខ្ពស់ និងសិក្សាស្វែងយល់ពីបញ្ហាប្រឈមនានានៃប្រព័ន្ធអប់រំប្រទេសយើង ពោលគឺ

យើងសិក្សាពីចំណុចខ្លាំងរបស់ប្រទេសដទៃ និងឆ្លុះបញ្ចាំងចំណុចខ្សោយរបស់យើង។ សម្រាប់ការសិក្សាពីប្រព័ន្ធអប់រំប្រទេសនានានៅលើពិភពលោក អ្នកនិពន្ធមិនបានទៅសិក្សាស្រាវជ្រាវ និងស្វែងយល់ដោយផ្ទាល់នៅលើទឹកដីប្រទេសទាំងនោះទេគឺ ចំណេះដឹងទាំងអស់នេះបានមក តាមរយៈការសិក្សាស្រាវជ្រាវពីឯកសារនានានិងការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យមួយចំនួនប៉ុណ្ណោះ ហើយអត្ថបទស្រាវជ្រាវផ្នែកនេះមានបញ្ជាក់ឯកសារយោងច្បាស់លាស់។ ប្រទេសដែលយើងលើកយកមកធ្វើការសិក្សា វិភាគ និងបង្ហាញគឺ ប្រទេសដែលមានលទ្ធផលតេស្ត PISA ខ្ពស់ដែលផ្ដល់នូវបទពិសោធល្អៗ និងមេរៀនរៀនសូត្រនានាដែលយើងអាចយកមកអនុវត្តបាន និងមិនគួរយកអនុវត្ត។ មួយវិញទៀត ដើម្បីឱ្យអ្នកអាន-អ្នកសិក្សាងាយស្រួលយល់ និងកាន់តែយល់ដឹងទូលំទូលាយស៊ីជម្រៅថែមទៀត យើងបានដាក់បញ្ចូលនូវទិដ្ឋភាពសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសទាំងអស់នោះព្រមទាំងបម្លែងពីភាសាបច្ចេកទេសមកសរសេរដោយប្រើប្រាស់ពាក្យពេចន៍សាមញ្ញៗ និងលើកយកឧទាហរណ៍ជាក់ស្ដែងនៅសង្គមខ្មែរមកបញ្ជាក់បន្ថែមដោយធ្វើការបកស្រាយ ឬប្រៀបធៀបដើម្បីរំលេចខ្លឹមសារឱ្យកាន់តែច្បាស់លាស់។ អ្នកនិពន្ធសូមបញ្ជាក់ថា ប្រព័ន្ធអប់រំរបស់ប្រទេសមួយចំនួនធ្វើបច្ចុប្បន្នភាព និងទំនើបកម្មលឿនណាស់ ហើយខ្លឹមសារនៅក្នុងនេះសៀវភៅអាចហួសសម័យក្នុងរយៈពេលដ៏ខ្លីតួយ៉ាងដូចប្រទេសសឹង្ហបូរីជាដើម។ ចំណែកឯ ការសិក្សាពីលក្ខណៈស្ដង់ដាររបស់សាលារៀនលំដាប់អន្តរជាតិ និងបញ្ហាប្រឈមនៃការអប់រំនៅកម្ពុជា គឺភាគច្រើនផ្អែកលើការអង្កេតជាក់ស្ដែង ចំណេះដឹង និងបទពិសោធការងារផ្ទាល់ខ្លួនរបស់អ្នកនិពន្ធដែលប្រឡូកក្នុងវិស័យអប់រំជិតម្ភៃឆ្នាំកន្លងមកនេះទាំងការងាររដ្ឋការងារបង្រៀនក្រៅម៉ោងនៅសាលាឯកជន និងការងារនៅអង្គការក្រៅរដ្ឋាភិបាលទាំងជាតិ និងអន្តរជាតិ។ ចំណុចមួយចំនួនដែលបានលើកឡើងក្នុង

ផ្នែកខាងលើនេះ វាគ្រាន់តែជាសម្មតិកម្មប៉ុណ្ណោះ ដោយមិនទាន់មានលក្ខណៈជាការស្រាវជ្រាវបែបវិទ្យាសាស្ត្រនៅឡើយ។ ជាមួយគ្នានេះ យើងក៏មិនបានដាក់បញ្ចូលនូវគន្លឹះដោះស្រាយបញ្ហាប្រឈមទាំងនោះទេ ព្រោះផ្នែកនេះតម្រូវសម្រាប់តែការស្រាវជ្រាវបែបវិទ្យាសាស្ត្រត្រឹមត្រូវប៉ុណ្ណោះ ពោលគឺយើងសាកល្បងបង្ហាញពីរោគសញ្ញាសង្ស័យរបស់ជំងឺនៃការប្រព័ន្ធអប់រំ តែមិនចេញវេជ្ជបញ្ជា ឬផ្សំថ្នាំសម្រាប់ព្យាបាលជំងឺឡើយ។

ចំណុចបន្ថែមមួយទៀត ដោយមើលឃើញពីសារៈសំខាន់ និងគុណតម្លៃនៃចំណេះដឹងពីប្រព័ន្ធអប់រំ និងការគ្រប់គ្រងអប់រំ ក្នុងនាមជាកូនខ្មែរម្នាក់ យើងខ្ញុំមានសោមនស្សរីករាយឥតឧបមាក្នុងការបំពេញភារកិច្ចដ៏ល្អនេះ ដោយចំណាយពេលវេលា កម្លាំងកាយចិត្ត និងខិតខំសិក្សាស្រាវជ្រាវចងក្រងសៀវភៅនេះឡើងដើម្បីគ្រាន់ទុកជាវិភាគទានមួយសម្រាប់អ្នកអានអ្នកសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ និងទូលំទូលាយ។ នេះជាបុព្វហេតុដ៏ចម្បងមួយនៃការនិពន្ធស្នាដៃនេះឡើង។ អ្នកនិពន្ធមានក្តីស្រមៃចង់ឃើញប្រព័ន្ធអប់រំរបស់យើងមានការអភិវឌ្ឍន៍រីកចម្រើនខ្លាំង អាចផលិតមូលធនមនុស្សបានគ្រប់គ្រាន់ពេញលេញ ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ជាតិ និងសម្រេចបំណងប្រាថ្នារបស់ខ្លួននាពេលអនាគតសម្រាប់យុគសម័យនៃការប្រកួតប្រជែងសេដ្ឋកិច្ចមានមូលដ្ឋានផ្អែកលើចំណេះដឹងដ៏ខ្លាំងក្លានេះ។ ដើម្បីសម្រេចបានទស្សនវិស័យនេះ អ្នកនិពន្ធបានកំណត់បេសកកម្មរបស់ខ្លួនចូលរួមចំណែកធ្វើការសិក្សាស្រាវជ្រាវ ចងក្រងចំណេះដឹងដើម្បីចែករំលែកគ្នាទៅវិញទៅមកក្នុងស្មារតីស្រលាញ់ជាតិមាតុភូមិ។ វិធីសាស្ត្ររបស់អ្នកនិពន្ធគឺសាកល្បងសិក្សាពីកម្រិតអន្តរជាតិ និងឆ្លុះបញ្ចាំងមកកម្រិតមូលដ្ឋាន ដើម្បីឱ្យមានលក្ខណៈស៊ីជម្រៅ និងទូលំទូលាយ។ យើងប្រើប្រាស់ពាក្យ "អ្នកនិពន្ធ" ព្រោះសៀវភៅនេះ មិនមែនជាសៀវភៅបកប្រែពីសៀវភៅណាមួយឡើយ។ វាជាការប្រមែប្រមូលទស្សនៈគំនិតពី

សៀវភៅជាច្រើន ដោយសរសេរឆ្លុះបញ្ចាំង វិភាគ សិក្សាប្រៀបធៀប ព្រមទាំងធ្វើសេចក្ដីសន្និដ្ឋានដោយប្រើប្រាស់ភាសារបស់អ្នកសរសេរផ្ទាល់ ពិសេសឆ្លុះបញ្ចាំងមកស្ថានភាពជាក់ស្ដែងមួយចំនួននៅក្នុងប្រព័ន្ធអប់រំប្រទេសកម្ពុជា។

សៀវភៅនេះជាការបោះជំហានទីមួយរបស់យើងខ្ញុំ ហើយយើងទទួលស្គាល់ថា ចំណេះដឹង និងបទពិសោធពិតជានៅមានកម្រិតនៅឡើយ និងអាចបង្កជាកំហុសដោយអចេតនាជាក់ជាមិនខាន។ ជាការពិត ចំណុចខ្វះខាតរបស់សៀវភៅនេះគឺ មិនទាន់មានមូលដ្ឋានវិទ្យាសាស្ត្រ និងរចនាសម្ព័ន្ធពេញលេញគ្រប់ផ្នែកទាំងអស់នៅឡើយ ហើយផ្នែកខ្លះគ្រាន់តែជាការសិក្សាសាកល្បងប៉ុណ្ណោះ។ ការបកស្រាយមួយចំនួន ពិសេសទាក់ទងនឹងបញ្ហាប្រឈមនៃការអប់រំនៅកម្ពុជា អ្នកនិពន្ធហាក់ប្រើប្រាស់ទស្សនៈយោបល់ និងការយល់ឃើញបែបអត្តោម័តផ្ទាល់ខ្លួនទៅលើតថភាពមួយចំនួនដែលជាចំណុចរសើប ជំរុញឱ្យមានការយល់ច្រឡំពីចេតនាពិតប្រាកដរបស់អ្នកនិពន្ធ។ ទោះបីយ៉ាងណាក៏ដោយ អ្នកនិពន្ធសង្ឃឹមថាសៀវភៅនេះនឹងជួយដល់កុលបុត្រកុលធីតាខ្មែរមានការយល់ដឹង បណ្ដុះស្មារតី និងការប្ដេជ្ញាចិត្តខ្ពស់យកចិត្តទុកដាក់ធ្វើការរួមគ្នាក្នុងគោលដៅរួមគឺដើម្បីអភិវឌ្ឍន៍វិស័យអប់រំ និងខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវឲ្យកាន់តែផុលផុសថែមទៀត។ មិត្តអ្នកអាន-អ្នកសិក្សា និងបងប្អូនជនរួមជាតិអាចធ្វើការរិះគន់កែលម្អមកយើងខ្ញុំបាន បើខ្លឹមសារនៅក្នុងសៀវភៅនេះប្រាសចាកពីតម្លៃសច្ចភាពប្រាកដភាព គុណតម្លៃ និងគ្មានមូលដ្ឋានវិចារណញាណច្បាស់លាស់នោះ។ យើងខ្ញុំរង់ចាំដោយសោមនស្សរីករាយបំផុតចំពោះទស្សនៈ យោបល់រិះគន់ និងកែលម្អទាំងឡាយដើម្បីអភិវឌ្ឍន៍សៀវភៅនេះឲ្យកាន់តែល្អប្រសើរថែមទៀត។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណដល់សាស្ត្រាចារ្យ Ogawa Yoshikazu មកពីសាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ាប្រទេសជប៉ុនដែលបានចំណាយពេលដ៏មានតម្លៃមកបង្ហាត់បង្រៀនពីប្រព័ន្ធអប់រំប្រទេសនានាលើពិភពលោក សាស្ត្រាចារ្យបង្រៀននៅវិទ្យាស្ថានជាតិអប់រំ ( NIE ) និងសាស្ត្រាចារ្យដែលជាថ្នាក់ដឹកនាំមកពីក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំជំនាន់ទី៥ដែលបានបង្ហាត់បង្រៀនព្រមទាំងផ្តល់ចំណេះដឹង និងបទពិសោធល្អទាក់ទងនឹងការគ្រប់គ្រងអប់រំដែលចំណេះដឹងទាំងអស់នោះពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការនិពន្ធចងក្រងសៀវភៅនេះឡើង៕

**អ្នកនិពន្ធ**

# ផ្នែកទី១

# ប្រព័ន្ធអប់រំប្រទេសនានា

# នៅលើពិភពលោក

## I. ប្រព័ន្ធអប់រំប្រទេសសឹង្ហបុរី

**សំណួរត្រិះរិះ**

*១-តើប្រព័ន្ធអប់រំប្រទេសសឹង្ហបុរីមានលក្ខណៈដូចម្ដេច? មានកំណែទម្រង់ប្រព័ន្ធអប់រំអ្វីខ្លះទើបអាចក្លាយជាភាពគំរូមួយរបស់ពិភពលោក និងធ្វើឱ្យប្រទេសរីកចម្រើនក្លាយជានាគសេដ្ឋកិច្ច?*

*២-ហេតុអ្វីបានជាប្រទេសសឹង្ហបុរី ទទួលលទ្ធផលតេស្ដPISAខ្ពស់?*

*៣-តើអ្វីខ្លះដែលប្រទេសកម្ពុជា អាចរៀនសូត្របានពីសឹង្ហបុរី? អ្វីដែលអាចឱ្យប្រទេសកម្ពុជាយកជាគំរូបាន ហើយអ្វីដែលយើងមិនអាចយកបាន?*

## 1.1) ទិដ្ឋភាពទូទៅរបស់ប្រទេសសឹង្ហបុរី



សឹង្ហបុរីជាប្រទេសកោះស្ថិតនៅចុងខាងត្បូងនៃឧបទ្វីបម៉ាឡេ។ វាស្ថិតនៅចម្ងាយ១៣៧ គីឡូម៉ែត្រខាងជើងខ្សែរអេក្វាទ័រ។ សិង្ហបុរីមានផ្ទៃដី៧១០,២ គ.ម២ និងជាប្រទេសតូចជាងគេនៅអាស៊ីអាគ្នេយ៍។ សិង្ហបុរីជាមជ្ឈមណ្ឌលហិរញ្ញវត្ថុឈានមុខគេចំណាត់ថ្នាក់លេខ៤នៅលើពិភពលោកដែលដើរតួនាទីយ៉ាងចម្បងក្នុងវិស័យពាណិជ្ជកម្ម និងហិរញ្ញវត្ថុអន្តរជាតិ[(1)]។ កំពង់ផែសឹង្ហបុរីជាកំពង់ផែដែលមមាញឹកជាងគេទាំង៥នៅលើពិភពលោក[(2)]។ សិង្ហបុរីមានប្រវត្តិយូរអង្វែងអំពីជនចំណូលស្រុក។ ក្នុងចំណោមប្រជាជន៥,១៨៣លាននាក់របស់សិង្ហបុរីមានតែ២,៩១លាននាក់ទេដែលកើតនៅទីនោះ។ នេះមានន័យថាប្រជាជនសិង្ហបុរី៤៣%មកពីបរទេស[(3)] ក្នុងនោះជនជាតិចិនមានប្រមាណ៧៤,១% ឥណ្ឌា៩,២% និងម៉ាឡេ១៣,៤%។ ភាសាផ្លូវការមាន៤គឺ៖ ភាសាអង់គ្លេស ចិន ម៉ាឡេ និងតាមិល។ តាមការប៉ាន់ប្រមាណនៅឆ្នាំ២០១៩ អត្រាប្រជាជនអាចកើនឡើងដល់៥,៨លាននាក់។ ប្រទេសនេះ គ្មានតំបន់ជនបទទេ ហើយមានស្ថិតិប្រជាជនប្រមាណ៧,៦១៥នាក់ក្នុង១គីឡូម៉ែត្រការដែលជាចំនួនច្រើនបំផុតមួយនៅលើពិភពលោក។ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់(ផ.ស.ស GDP per capita) របស់សឹង្ហបុរីមានចំនួន៥១៦ដុល្លារក្នុងឆ្នាំ១៩៦៥)

៤៣,៨៦៧ដុល្លារ[(4)]ក្នុងឆ្នាំ២០១០ហើយ៥៤,៤៧០ដុល្លារក្នុងឆ្នាំ២០១៤ និងអាចកើនឡើងដល់ ៦៦,០១០ដុល្លារនៅឆ្នាំ២០១៩។ ដោយផ្អែកលើប្រាក់ចំណូលជាតិដ៏ខ្ពស់នេះ សឹង្ហបុរីជាប្រទេសអ្នកមានបំផុតមួយនៅលើពិភពលោកដែលមានអត្រាប្រជាជនតិច ហើយសេដ្ឋកិច្ចមានភាពរឹងមាំខ្លាំង។ កម្លាំងពលកម្មមានចំនួន៣,៥លាននាក់ក្នុងឆ្នាំ២០១៤ និងអាចកើនឡើងដល់៣,៨លាននាក់ក្នុងឆ្នាំ២០១៩។ អត្រាគ្មានការងារធ្វើជាមធ្យម២% ដែលជាមធ្យមភាគថេរតាំងពីឆ្នាំ២០១០មក។ ការចំណាយសាធារណៈលើវិស័យអប់រំមានចំនួន៤% នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០១៤ និង១២,៧%នៃការចំណាយរបស់រដ្ឋាភិបាលសរុបដែលជាការចំណាយធំទី២បន្ទាប់ពីក្រសួងការពារជាតិ។ ប្រជាជនអាយុចន្លោះ៧ឆ្នាំដល់៣៤ឆ្នាំស្ទើរតែ១០០% អាចប្រើប្រាស់កុំព្យូទ័រ និងសេវាអីនធ័រណេតអាយុចន្លោះ៥០-៥៩ឆ្នាំមានប្រមាណ៥០% ហើយប្រហែល១៦%ពីអាយុលើស ៦០ឆ្នាំឡើងទៅ។ ចំនួនសិស្សចូលរៀនអប់រំកម្រិតខ្ពស់មានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយក្នុងនោះសិស្សស្រីមានច្រើនជាង៥០%។សឹង្ហបុរីមិនត្រឹមតែប្រែក្លាយប្រទេសខ្លួនជាគោលដៅសិក្សាសម្រាប់សិស្ស-និស្សិតបរទេស និងស្រូបយកប្រាក់ចំណូលជាតិដ៏ច្រើនសន្ធឹកសន្ធាប់ប៉ុណ្ណោះទេ ប៉ុន្តែក៏បានបញ្ជូនសិស្ស-និស្សិតខ្លួនទៅសិក្សានៅឯបរទេសជាច្រើនផងដែរ ពិសេសសាកលវិទ្យាល័យល្បីៗនៅលើពិភពលោក តួយ៉ាងដូចជាសាកលវិទ្យាហារីត (Harward University)ដ៏ល្បីល្បាញបំផុតមួយនៅលើពិភពលោកជាដើម ដែលមាននិស្សិតបញ្ចប់ការសិក្សានៅទីនោះរាប់ពាន់នាក់ ទន្ទឹមនឹងប្រទេ-សកម្ពុជាមាននិស្សិតមិនដល់ ១០នាក់ផង។ នៅឆ្នាំ២០១២ មានសិស្ស-និស្សិតបរទេសមកសិក្សានៅសឹង្ហបុរីចំនួន៨៤,០០០នាក់ និងនៅឆ្នាំ២០១៤មានចំនួន៧៥,០០០នាក់។ **របបនយោបាយ**សឹង្ហបុរី ប្រកាន់របបប្រជាធិបតេយ្យអាស្រ័យសភា ដោយសារមានសភាតែមួយ ហើយ**គណបក្សសកម្មភាពប្រជាជន**តែងតែឈ្នះរាល់

ការបោះឆ្នោះតាំងពីសម័យលោក **លី ក្វាន់យូ** រហូតដល់ពេលនេះ ដោយកាន់កាប់អាសនៈទាំងស្រុងនៅក្នុងសភា។ យោងតាមបទវិភាគរបស់លោក **ហ្សង់ ហ្វ្រង់ស័រតាន់** បានគូសបញ្ជាក់ថា សឹង្ហបុរី ប្រកាន់យករបបផ្ដាច់ការភ្លឺស្វាង មិនគោរពសិទ្ធិមនុស្ស និងមានឈ្មោះជាលទ្ធិប្រជាធិបតេយ្យតែនៅលើក្រដាស។ ក្នុងន័យនេះ លោក **លី ក្វាន់យូ** បានបង្កើត និងពង្រឹងម៉ាស៊ីនសន្តិសុខមួយ ដោយកាត់បន្ថយទាល់តែអស់រលីងនូវឥទ្ធិពលពួកប្រឆាំង និងដើម្បីធ្វើឱ្យគណបក្សរបស់លោកមានអំណាចខ្លាំងផ្ដាច់មុខតែឯកឯង នៅលើឆាកនយោបាយ។ យុទ្ធសាស្ត្រនយោបាយបីយ៉ាងដែលប្រើប្រាស់ដើម្បីរំលាយអ្នកប្រឆាំងគឺ (១)ការពុះចែកមណ្ឌលបោះឆ្នោតឡើងវិញដើម្បីរំសាយដែនអំណាចរបស់បក្សប្រឆាំង (២)ការប្រើប្រាស់ធនធាន និងស្ថាប័នរដ្ឋសម្រាប់ប្រយោជន៍គណបក្ស និង(៣)ការប្ដឹងប្ដល់ឡើងតុលាការប្រឆាំងនឹងពួកជំទាស់ក្នុងបទបង្ខូចកេរ្តិ៍ឈ្មោះ ពោលគឺប្រើច្បាប់ដើម្បីបិទមាត់អ្នកជំទាស់ និងក្រុមប្រឆាំង ព្រមទាំងរុញអ្នកនយោបាយប្រឆាំងទាំងនោះចេញពីសៃវៀននយោបាយ។ ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ស្ថិតក្រោមឥទ្ធិពល និងបម្រើឱ្យផលប្រយោជន៍បក្សកាន់អំណាចតែមួយប៉ុណ្ណោះ ហើយស្ថានភាពនេះ អូសបន្លាយរហូតដល់រដ្ឋាភិបាលលោក **លី សៀនឡុង** កូនប្រុសលោក **លី ក្វាន់យូ**។ **សេដ្ឋកិច្ច**សឹង្ហបុរីពឹងផ្អែកលើការធ្វើជំនួញ ពាណិជ្ជកម្ម ការនាំចេញផលិតផលសម្រេច ពិសេសផលិតផលឧស្សាហកម្ម សេវាកម្ម និងរោងចក្របច្ចេកវិទ្យាខ្ពស់។ ក្នុងឆ្នាំ១៩៦០ សេដ្ឋកិច្ចមានមូលដ្ឋានសំខាន់ផ្ដោតលើការធ្វើពាណិជ្ជកម្ម។ នៅឆ្នាំ១៩៨០ សេដ្ឋកិច្ចបានងាកមកផ្ដោតសំខាន់លើភាពសម្បូរបែបនៃការវិនិយោគ សេវាហិរញ្ញវត្ថុ ការចម្រាញ់ប្រេងកាត ហើយនៅក្នុងឆ្នាំ២០១០ សេដ្ឋកិច្ចសឹង្ហបុរីផ្ដោតជាសំខាន់លើមូលដ្ឋានទីផ្សារអភិវឌ្ឍន៍កម្រិតខ្ពស់ ជាមួយនឹងការវិនិយោគ សេវាកម្ម រោងចក្រដែលដំណើរការដោយបច្ចេកវិទ្យាខ្ពស់ ការធ្វើពាណិជ្ជកម្មកម្រិតខ្ពស់បំផុត ជាមួយផលប្រៀបធៀប ផ.ស.ស(GDP)

ពិភពលោក ដោយមានសាជីវកម្មចម្រុះជាតិសាសន៍ចំនួនជាង៧០០០(5) ។ សេដ្ឋកិច្ចសឹង្ហបុរីឆ្លងកាត់ពីសេដ្ឋកិច្ចឃ្លាំងស្តុក ទៅសេដ្ឋកិច្ចផ្អែកលើការនាំចេញ និងបើកចំហ។ លក្ខណៈនេះតម្រូវឱ្យសឹង្ហបុរីត្រូវការកម្លាំងពលកម្មដែលមានជំនាញឧស្សាហកម្មពាក់ព័ន្ធ ភាសាបរទេសដែលជួយសម្រប សម្រួលទំនាក់ទំនងជាមួយវិនិយោគិន និងស្វែងរកទីផ្សារនាំចេញ ឆន្ទៈនយោបាយ និងជំនាញក្នុងការដោះស្រាយបញ្ហាជាតិ។ ដោយសារគោលនយោបាយនេះ សឹង្ហបុរីបានស្រូបយកការវិនិយោគដោយផ្ទាល់ពីបរទេស (Foreign Direct Investment-FDI) នូវទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចខ្លួន។ សឹង្ហបុរីស្ថិតក្នុងចំណោមកូននាគទាំង៤ នៅអាស៊ី ដែលក្នុងនោះមាន៖ ក្រុង**ហុងកុង កូរ៉េខាងត្បូង និង កោះតៃវ៉ាន់** ផងដែរ។ វិស័យឧស្សាហកម្មសឹង្ហបុរីចែកចេញជា៖ វិស័យអេឡិចត្រូនិច ការចម្រាញ់ប្រេងកាត វិស័យគីមី វិស្វកម្មមេកានិកនិងបច្ចេកទេសជីវវេជ្ជសាស្ត្រ ។ សឹង្ហបុរីជាមជ្ឈមណ្ឌលពាណិជ្ជកម្មរូបិយប័ណ្ណបរទេសធំទីបួនលើពិភពលោក បន្ទាប់ពីក្រុង**ឡុងដ៍ន ញូយ៉ក** និង**តូក្យូ**។ ជាមួយគ្នានេះ សឹង្ហបុរីក៏ជាគោលដៅ**ទេសចរ**ដ៏ពេញនិយមមួយនៅលើពិភពលោកផងដែរ ហើយវិស័យនេះជាឧស្សាហកម្មដ៏ធំមួយដែលផ្តល់ប្រភពប្រាក់ចំណូលជាតិដ៏ច្រើន សន្ធឹកសន្ធាប់។ មានអ្នកទេសចរចំនួន១០,២លាននាក់បានមកទស្សនាសឹង្ហបុរីក្នុងឆ្នាំ២០០៧។ កន្លែងដែលទាក់ទាញទេសចរណ៍ល្បីជាងគេនៅសឹង្ហបុរីគឺ ទីប្រជុំហាងលក់ទំនិញនៅផ្លូវអេកឆាដ (Orchad Road shopping districts)។ ដើម្បីទាក់ទាញភ្ញៀវទេសចរបន្ថែម រដ្ឋាភិបាលបានសម្រេចចិត្តក្នុងឆ្នាំ២០០៥ អនុញ្ញាតឱ្យការលេងល្បែងស៊ីសងក្លាយជាស្របច្បាប់។ រដ្ឋបានអនុញ្ញាតអោយមានការបើកបនល្បែង២នៅ តំបន់ម៉ារីណាខាងត្បូង (Marina South) និងតំបន់សេនតូសា(Sentosa)ដើម្បីប្រកួតប្រជែងជាមួយទីក្រុងផ្សេងទៀតក្នុងតំបន់ដូចជា៖ហុងកុង តូក្យូ និងសៀងហៃ។ រដ្ឋបានប្រកាសបង្កើនភាពទាក់ទាញតាមរយៈការបំភ្លឺដោយភ្លើងព៌ណលម្អ

អគារនានា ដើម្បីបង្កើនសោភណភាពទីក្រុង។ **ចំណីអាហារ**ក៏ត្រូវបានជំរុញឱ្យក្លាយជាធនធានទេសចរណ៍ផងដែរ ដោយរដ្ឋរៀបចំអោយមានបុណ្យម្ហូបអាហារនៅរាល់ខែមិថុនា។ ព្រឹត្តិការណ៍ប្រចាំឆ្នាំផ្សេងៗទៀតមានដូចជា៖បុណ្យព្រះអាទិត្យ ការតុបតែងភ្លើងលម្អបុណ្យណូអែល និងបុណ្យអលង្ការជាដើម[6]។ ប្រទេសសឹង្ហបុរីគឺជាកន្លែងមួយដែលមានលក្ខណៈសាកលភាវូបនីយកម្មបំផុតនៅលើផែនដី។ វាជាទីក្រុងកំពង់ផែមួយដែលបានទាក់ទាញអ្នកជំនួញ និងអ្នកដំណើរមកពីប្រទេសឥណ្ឌា ចិន អាស៊ីអាគ្នេយ៍ និងប្រទេសផ្សេងៗទៀត។ ជាលទ្ធផល សេដ្ឋកិច្ច និងប្រជាជនរបស់សឹង្ហបុរីមានទំនាក់ទំនងយូរអង្វែងជាមួយពិភពលោក។ប្រទេសសឹង្ហបុរីបានទទួលយកនូវការពិតមួយនេះ ហើយបានបង្កើតប្រព័ន្ធអប់រំថ្នាក់ពិភពលោកមួយដើម្បីបន្ស៊ីនឹងស្ថានភាពសេដ្ឋកិច្ច-សង្គមខ្លួនយ៉ាងមានប្រសិទ្ធភាព។

## 1.2) ប្រព័ន្ធអប់រំប្រទេសសឹង្ហបុរី

ប្រទេសសឹង្ហបុរីបានយកចិត្តទុកជាខ្លាំងក្នុងការអភិវឌ្ឍវិស័យអប់រំ ដើម្បីផលិតមូលធនមនុស្សប្រកបដោយសក្តានុពលដើម្បីចូលរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចជាតិឱ្យក្លាយជាកូននាគនៅអាស៊ី។ មកដល់ពេលនេះ ប្រទេសជាច្រើនទទួលស្គាល់ថា សឹង្ហបុរីជាប្រទេសមួយដែលប្រព័ន្ធអប់រំមួយល្អត្រចះត្រចង់ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការកសាងមូលធនមនុស្សឆ្ពោះទៅរកស្តង់ដារអន្តរជាតិ និងអាចធ្វើការបានក្នុងកម្រិតអន្តរជាតិផងដែរ។ គេចាត់ទុកថាជាប្រព័ន្ធអប់រំដែលស្តង់ដារខ្ពស់បំផុតមួយដែល ប្រទេសជាច្រើនធ្វើសិក្សាស្វែងយល់ និងយកជាគំរូតួយ៉ាងដូចប្រទេសកម្ពុជានេះជាដើម។ ប្រព័ន្ធអប់រំសឹង្ហបុរីមានដំណើរវិវត្តិជាច្រើនលើកច្រើនសារតាមការកំណែទម្រង់នានារបស់រដ្ឋាភិបាល។ ជាដំបូង យុទ្ធ

សាស្ត្រអភិវឌ្ឍន៍វិស័យអប់រំ គឺទទួលឥទ្ធិពលយ៉ាងខ្លាំងពីស្ថេរភាពដឹកនាំនយោបាយរបស់លោក **លី ក្វាន់យូ** នាយករដ្ឋមន្ត្រីទី១ ដែលកាន់អំណាចជិតបីទស្សវត្សរ៍។ លោក **លី** យល់ឃើញថា៖ **អស្ថេរភាពនយោបាយ និងសង្គមជាមូលហេតុចម្បងដែលធ្វើឱ្យការអភិវឌ្ឍវិស័យអប់រំមានការយឺតយ៉ាវ**។ ដូច្នេះ ទើបលោកកំណត់ថា៖ **ប្រទេសសឹង្ហបុរីត្រូវការវិន័យជាងលទ្ធិប្រជាធិបតេយ្យដែលជាមាគ៌ាមួយក្នុងការរក្សាឱ្យមានស្ថេរភាពជាតិ ដើម្បីងាយស្រួលក្នុងការអភិវឌ្ឍជាតិ ពិសេសវិស័យអប់រំ**។ ដោយសារប្រទេសសឹង្ហបុរីសម្បូរជាតិសាសន៍ផ្សេងៗរស់នៅ មានការប្រើប្រាស់ភាសាច្រើន តាមជនជាតិនីមួយៗ និងមានសាសនាចម្រុះ ដូច្នេះការជំរុញឱ្យមានការឯកភាពជាតិជារឿងចាំបាច់បំផុត នៅមុនការចាប់ផ្តើមធ្វើកំណែទម្រង់នានា ពិសេសកំណែទម្រង់លើកកម្ពស់វិស័យអប់រំនេះជាដើម។ ដោយសារមានភាសាប្រើប្រាស់នៅក្នុងប្រទេសច្រើនបែបនេះ ការសិក្សាភាសាអង់គ្លេសត្រូវបានកំណត់ជាលក្ខណៈរួមតែមួយសម្រាប់ប្រជាជាតិសឹង្ហបុរី ឯការសិក្សាភាសាទី២ ជាលក្ខណៈដោយឡែកនៃជាតិសាសន៍នានាដែលរស់នៅក្នុងសឹង្ហបុរីដើម្បីរក្សាអត្តសញ្ញាណរបស់ពួកគេ។ ការសិក្សាភាសាទី២ ត្រូវបានកំណត់ជាកាតព្វកិច្ចនៅគ្រប់សាលាបឋមសិក្សាតាំងពីឆ្នាំ១៩៦០ ហើយគោលនយោបាយនេះ បានបន្តអនុវត្តដល់មធ្យមសិក្សានៅឆ្នាំ១៩៦៦។ រដ្ឋាភិបាលសឹង្ហបុរីមើលឃើញថា ការនិយមប្រើប្រាស់ភាសាពីរជាសមាសភាពសំខាន់នៃប្រព័ន្ធអប់រំដើម្បីពង្រឹងការទំនាក់ទំនងស្និតរមួត និងវិបុលភាពសេដ្ឋកិច្ចនៅក្នុងសង្គមដែលមានលក្ខណៈចម្រុះជាតិសាសន៍(7)។ បើសិនមិនមានឯកភាពជាតិ និងស្ថេរភាពជាតិជាមុននោះទេជំលោះជាតិសាសន៍ពុំអាចកើតមានឡើងមិនឈប់ឈរ ហើយបង្កការរាំងស្ទះដល់

ដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ និងការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំសម្រាប់ទាំងអស់គ្នា តួយ៉ាងដូចប្រទេសមួយចំនួននៅតំបន់អាស៊ីអាគ្នេយ៍ជាឧទាហរណ៍ស្រាប់ដូចជា៖ ភូមា ហ្វីលីពីន និងប្រទេសថៃឡង់ភាគខាងត្បូងជាដើម នៅតែមានជំលោះជាតិសាសន៍ បន្តរហូតមកដល់ពេលបច្ចុប្បន្ននេះ បង្កការលំបាកជាច្រើនដល់សង្គម និងការអភិវឌ្ឍ។ ការរក្សាឯកភាព និងស្ថេរភាពជាតិនៅទីនេះ មានន័យច្រើនជាងការការពារជំលោះជាតិសាសន៍ទៅទៀតដូចជា៖ ការពង្រឹងសន្តិសុខជាតិ រក្សាស្ថេរភាពនយោបាយ ទប់ស្កាត់ភាពចលាចលផ្នែកនយោបាយ អំពើឧបាយមុខ បទឧក្រិដ្ឋ និងអំពើអសន្តិសុខផ្សេងៗទៀតជាដើម។ល។ ដើម្បីសម្រេចគោលដៅ និងមហិច្ចតានេះ ទើបសឹង្ហបុរីព្យាយាមប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង និងដឹកនាំប្រទេសដោយគណបក្សតែមួយ។ យុទ្ធសាស្រ្តនៅដំណាក់កាលដំបូងគឺ ធ្វើឱ្យសឹង្ហបុរីមានលក្ខណៈរួមមួយដែលជាតម្លៃស្នូលរបស់ជាតិខ្លួន និងលក្ខណៈដោយឡែករបស់ជាតិសាសន៍នានាដែលរស់នៅក្នុងសឹង្ហបុរី ដើម្បីធ្វើឱ្យមានការឯកភាពជាតិស្របតាមគោលនយោបាយនៃការអភិវឌ្ឍវិស័យអប់រំ និងសេដ្ឋកិច្ច ព្រមទាំងធ្វើឱ្យជនជាតិទាំងអស់នោះ រស់នៅជាមួយគ្នាប្រកបដោយភាពសុខុដមរម្យនា មិនមានការរើសអើងជាតិសាសន៍ និងប្រកាន់និន្នាការនយោបាយ។ មួយវិញទៀត ដោយសារ **សឹង្ហបុរីជាប្រទេសមិនមានធនធានធម្មជាតិ** ដូច្នេះការអភិវឌ្ឍមូលធនមនុស្ស និងវិស័យអប់រំត្រូវបានចាត់ទុកជាកត្តាអាទិភាពបំផុតចាប់តាំងពីទទួលបានឯករាជ្យពីចក្រភពអង់គ្លេសក្នុងឆ្នាំ១៩៦៥មក[(8)]។ ការអភិវឌ្ឍវិស័យអប់រំ ត្រូវបានកំណត់តាមរយៈការផ្លាស់ប្តូរលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយសមភាព ប្រសិទ្ធភាព និងគុណភាពអប់រំ ព្រមទាំងរក្សាបាននូវ

តុល្យភាព តាមរយៈការចងភ្ជាប់យ៉ាងជិតស្និទ្ធរវាងការអភិវឌ្ឍវិស័យអប់រំ សេដ្ឋកិច្ច និងការអភិវឌ្ឍជាតិ។ នេះមានន័យថា វិស័យអប់រំផលិតមូលធនមនុស្សដែលមានលក្ខណៈសម្បត្តិសមស្របដើម្បីឆ្លើយតបទៅនឹងដំណើរវិវត្តសេដ្ឋកិច្ច និងតម្រូវការអភិវឌ្ឍន៍ជាក់ស្តែងរបស់ខ្លួន។ អ្នកដឹកនាំសឹង្ហបុរីយកចិត្តទុកដាក់ជាខ្លាំងក្នុងការផ្សារភ្ជាប់ការអប់រំទៅនឹងទីផ្សារការងារ តាមរយៈការអនុវត្តយុទ្ធសាស្ត្រវិជ្ជាជីវៈ ពោលគឺមិនបណ្តោយឱ្យគ្រឹះស្ថានសិក្សានានាផលិតធនធានមនុស្សច្រើនលើសលុប ខុសពីតម្រូវការទីផ្សារការងារ ឬនាំឱ្យមានអតិផរណាជំនាញវិជ្ជាជីវៈណាមួយឡើយ។ ជាក់ស្តែងប្រទេ-សសឹង្ហបុរីមានសេដ្ឋកិច្ចផ្តោតលើ ការធ្វើជំនួញ ការវិនិយោគ ពាណិជ្ជកម្ម សេវាកម្ម និងរោងចក្របច្ចេកវិទ្យាខ្ពស់ ដូច្នេះការបណ្តុះបណ្តាលធនធានមនុស្សត្រូវផ្តោតសំខាន់លើជំនាញទាំងនេះ មិនមែនជំនាញកសិកម្ម ឬជំនាញបច្ចេកទេសដូចប្រទេសកម្ពុជាឡើយ។ ចំណុចនេះ សឹង្ហបុរីមានការរៀបចំបានល្អក្នុងធានាបាននូវតុល្យភាពធនធានមនុស្ស និងបំពេញបាននូវតម្រូវការទីផ្សារពលកម្ម។ ជាទូទៅអ្នកដឹកនាំសឹង្ហបុរីមានមហិច្ឆតាធំ បង្កើតទស្សនវិស័យចំពោះសេដ្ឋកិច្ចរបស់ខ្លួននាពេលអនាគត ហើយរៀបចំផែនការ និងកំណែទម្រង់អប់រំបាញ់ឆ្ពោះទៅរកទិសដៅនោះ ពោលគឺមិនមែនវិស័យសេដ្ឋកិច្ច-សង្គមវិវត្តន៍ដល់ដំណាក់កាលថ្មីមួយហើយ ទើបកែទម្រង់ វិស័យអប់រំតាមក្រោយនោះទេ។ អ្វីដែលកាន់តែពិសេសថែមទៀតនោះ សឹង្ហបុរីរៀបចំផែនការយុទ្ធសាស្ត្រកែទម្រង់វិស័យអប់រំដោយមានការចូលរួមពីក្រសួង និងស្ថាប័នពាក់ព័ន្ធនានាជាច្រើន ព្រមទាំងធ្វើការសហការគ្នាយ៉ាងស្អិតរមួតដើម្បីសម្រេចគោលដៅរួមនៃការអភិវឌ្ឍវិស័យនេះ។

សម្រាប់ប្រទេសកម្ពុជានៅតែមានបញ្ហាប្រឈមច្រើន ទាក់ទងនឹងការផលិ

តជនជានមនុស្សឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ច និងតម្រូវការអភិវឌ្ឍន៍របស់ខ្លួន។ រយៈពេលកន្លងមក យើងសង្កេតឃើញថា សិស្ស-និស្សិតមួយចំនួនធំចាប់អារម្មណ៍ច្រើនលើសលប់លើការសិក្សាមុខជំនាញ គណនេយ្យ ឬគ្រប់គ្រង...តែស្ថានភាពប្រទេសត្រូវការធនធានមនុស្សដែលមានជំនាញ វិស្វករ ជំនាញបច្ចេកទេស ទេសចរ ឬកសិកម្ម...ទៅវិញ។ នេះបង្ហាញពីភាពមិនស៊ី សង្វាក់គ្នារវាងការអភិវឌ្ឍវិស័យអប់រំ និងសេដ្ឋកិច្ចជាតិរបស់ប្រទេសយើង ដែលបណ្តាលឱ្យខ្វះធនជានមនុស្សក្នុងផ្នែកសំខាន់ៗដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារក្នុងប្រទេស។ ទាក់ទងនឹងការធ្វើការរួមគ្នារវាងស្ថាប័នមួយទៅស្ថាប័នមួយរបស់ប្រទេសយើង ក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ និងរៀបចំផែនការយុទ្ធសាស្ត្រជាតិក្នុងការលើកកម្ពស់គុណភាពអប់រំក៏ដូចវិស័យនានាដែរ ហាក់នៅមិនទាន់ផុលផុស និងមានប្រសិទ្ធភាពខ្លាំងក្លានៅឡើយ។ ឧទាហរណ៍ជាក់ស្តែង ការអប់រំកម្រិតឧត្តមសិក្សាមានការគ្រប់គ្រងតាមបែបផែនផ្សេងៗគ្នា ទៅតាមស្ថាប័នរដ្ឋផ្សេងៗគ្នា ហើយកិច្ចសហការ និងធ្វើការរួមគ្នាហាក់នៅមានកម្រិតនៅឡើយតួយ៉ាង៖ សាកលវិទ្យាល័យភូមិន្ទកសិកម្មស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សាលាបណ្តុះបណ្តាលគិលានុបដ្ឋាយិកា និងវេជ្ជបណ្ឌិត ត្រូវបានគ្រប់គ្រងដោយក្រសួងសុខាភិបាល សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡាក៏មាន និងដោយក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈក៏មាន...យើងពិបាកធ្វើការវាយតម្លៃថា តើកិច្ចសហការ និងការធ្វើការរួមគ្នាក្នុងការអភិវឌ្ឍប្រព័ន្ធអប់រំ ការផ្សារភ្ជាប់ការអប់រំនឹងសេដ្ឋកិច្ច និងតម្រូវការសង្គមបានកម្រិតណា? ចំណុចដែលសំខាន់គឺ កំណែទម្រង់ការអប់រំត្រូវតែ

ដើរស្របគ្នាទៅនឹងកំណែទម្រង់សេដ្ឋកិច្ចជាមេរៀនរៀនសូត្រមួយ(Lesson learnt) ដែលកម្ពុជាត្រូវស្វែងយល់ពីបទពិសោធរបស់ប្រទេសមួយនេះ ហើយត្រូវយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាបន្ថែមទៀតសម្រាប់ទិសដៅអភិវឌ្ឍន៍ប្រទេសក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០[(9)]។ ស្ថិតក្នុងបរិបទសហវត្សរ៍ថ្មីនេះ មានទំនោរកើនឡើងនូវតម្រូវការចំណេះដឹងផ្នែកសេដ្ឋកិច្ចដែលតម្រូវឱ្យប្រទេសទាំងឡាយតម្រង់ទិសប្រព័ន្ធអប់រំរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងសេដ្ឋកិច្ចសាកល[(10)]ហើយប្រទេសសឹង្ហបុរីត្រៀមលក្ខណៈបានល្អជាងគេក្នុងការទទួលយកផលប្រយោ-ជន៍ពីសាកលភាវូបនីយកម្មនេះ ដែលមិនត្រឹមតែត្រៀមលក្ខណៈដើម្បីឆ្លើយតបទៅនឹងសេដ្ឋកិច្ចក្នុងប្រទេសប៉ុណ្ណោះទេ តែក៏ត្រៀមលក្ខណៈសម្រាប់សេដ្ឋកិច្ចសាកលផងដែរតួយ៉ាងដូចជា៖ ការអប់រំដោយប្រើប្រាស់ភាសាអង់គ្លេសជាយាន ការសិក្សាភាសាបរទេសផ្សេងៗទៀតយ៉ាងទូលំទូលាយចាប់តាំងពីកម្រិតមធ្យមសិក្សា ការយកចិត្តទុកដាក់លើការអប់រំ STEM ជាដើម។ សឹង្ហបុរីមិនត្រឹមតែបានធ្វើការកំណែទម្រង់វិស័យអប់រំទាន់ពេលវេលាប៉ុណ្ណោះទេ តែក៏បានអនុវត្តន៍ស្របតាមស្ថានភាពវិវត្តន៍ផ្លាស់ប្តូររបស់ខ្លួន។ ដើម្បីយល់កាន់តែច្បាស់ពីប្រព័ន្ធអប់រំសឹង្ហបុរី ជាបន្តបន្ទាប់ទៅទៀតនេះ យើងសូមធ្វើការបកស្រាយដោយសង្ខេបពីដំណើរវិវត្តិប្រព័ន្ធអប់រំសំខាន់ៗ ពីមួយដំណាក់កាលទៅមួយដំណាក់កាលចាប់ពីអតីតកាលរហូតដល់បច្ចុប្បន្ន។

## 1.3) ដំណើរវិវត្តន៍ប្រព័ន្ធអប់រំសឹង្ហបូរី

ពីឆ្នាំ១៩៥៩ ដល់១៩៧៨ សឹង្ហបុរីចាប់ផ្តើមធ្វើកំណែទម្រង់ពី "**ការអប់រំជំរុញការរស់រានមានជីវិត**" (Survival-driven education) ដោយរួមបញ្ចូលចរន្តអប់រំបែបផែនផ្សេងៗតាមជាតិសាសន៍នីមួយៗ មកប្រព័ន្ធអប់រំជាតិតែមួយ (ការធ្វើឱ្យមានឯកភាពជាតិលើប្រព័ន្ធអប់រំ) សម្រាប់ការអប់រំពីរភាសា (ភាសាអង់គ្លេស និងភាសាកំណើត) លទ្ធភាពទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា កសាងសាលារៀនដ៏ឆាប់រហ័ស និងជ្រើសរើសគ្រូបង្រៀនដ៏ច្រើន កម្មវិធីសិក្សាផ្តោតលើការអប់រំភាសា វិទ្យាសាស្រ្ត គណិតវិទ្យា និងការអប់រំសីលធម៌ ការវិនិយោគលើការអប់រំបច្ចេកទេស ជំនាញវិជ្ជាជីវៈ និងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនតាមរយៈការបង្កើតវិទ្យាស្ថានអប់រំក្នុងឆ្នាំ១៩៧៣។ បើនិយាយពីកម្ពុជា ការអប់រំភាសាមានលក្ខណៈខុសពីប្រទេសសឹង្ហបុរី ដោយសារប្រព័ន្ធអប់រំមានតែមួយភាសាទេគឺ **ភាសាខ្មែរ** ហើយទើបតែចាប់ផ្តើមដាក់បញ្ចូលការអប់រំភាសាអង់គ្លេសនៅកម្រិតបឋមសិក្សានាពេលថ្មីៗនេះប៉ុណ្ណោះ(ឆ្នាំ២០១៧)។ ការអប់រំដោយប្រើប្រាស់ប្រព័ន្ធពីរភាសានេះ ផ្តល់អត្ថប្រយោជន៍ច្រើនដល់ប្រទេសសឹង្ហបុរីក្នុងការបន្ស៊ីប្រព័ន្ធអប់រំជាមួយនឹងផែនការយុទ្ធសាស្រ្តលើកកម្ពស់សេដ្ឋកិច្ចដែលផ្តោតសំខាន់លើការវិនិយោគផ្នែកធុរៈកិច្ច សេវាកម្មទាំងក្នុង និងក្រៅប្រទេសដែលនាំឱ្យមានការផលិតមូលធនមនុស្សពោរពេញទៅដោយ សមត្ថភាពភាសាអង់គ្លេស និងភាសាបរទេសផ្សេងៗទៀតជួយសម្រួលច្រើនដល់ការងារទំនាក់ទំនង ការធ្វើពាណិជ្ជកម្ម និងការធ្វើការងារទាំងកម្រិតជាតិ និងអន្តរជាតិ។

ពីឆ្នាំ១៩៧៩ ដល់១៩៩៦ បានអនុវត្តកំណែទម្រង់"**ការអប់រំជំរុញប្រសិទ្ធភាព**" (Efficiency-driven education) ហើយនៅដើមទស្សវត្សរ៍ទី៨០ ប្រទេសសឹង្ហបុរីមានការរីកចម្រើនខ្លាំង ក្លាយជាប្រទេសសេដ្ឋកិច្ចឧស្សាហកម្មថ្មីដែលប្រព័ន្ធអប់រំមិនអាចផ្គត់ផ្គង់គ្រប់គ្រាន់នូវតម្រូវការជំនាញនៅក្នុងវិស័យសេដ្ឋកិច្ច។ ស្ថានភាពនេះតម្រូវឱ្យសឹង្ហបុរីធ្វើកំណែទម្រង់ប្រព័ន្ធអប់រំពី "**ប្រព័ន្ធមួយឆ្លើយតបទៅគ្រប់ផ្នែក**" (One-size-fits-all) ទៅវិធីសាស្ត្រផ្សេងៗដែលអាចឱ្យសិស្សានុសិស្ស និងនិស្សិតមានសមត្ថភាព និងសម្បទាផ្សេងៗគ្នាក្នុងការអភិវឌ្ឍដោយខ្លួនគេផ្ទាល់ ពោលគឺមូលធនមនុស្សមានជំនាញឯកទេសមួយច្បាស់លាស់ និងបង្កលក្ខណៈក្នុងការសម្រួចសមត្ថភាព និងជំនាញរបស់ខ្លួន។ ប្រព័ន្ធអប់រំបែបនេះបានបែងចែកសិស្សានុសិស្សទៅតាមសមត្ថភាព និងសម្បទា (Streaming) របស់ពួកគេ ហើយលទ្ធផលនៃការអប់រំជំរុញប្រសិទ្ធភាពបានផ្តល់ដល់សិស្សានុសិស្សជាច្រើននូវឱកាសសិក្សាជំនាញបច្ចេកទេស ជំនាញវិជ្ជាជីវៈ និងកាន់តែមានលក្ខណៈស៊ីសង្វាក់គ្នាថែមទៀតរវាងការអប់រំ និងសេដ្ឋកិច្ច។

នៅចុងឆ្នាំ១៩៩០ ប្រព័ន្ធអប់រំសឹង្ហបុរី ត្រូវតែរៀបចំជាថ្មីដើម្បីឆ្លើយតបទៅនឹងការកើនឡើងនូវផលប៉ះពាល់នៃសេដ្ឋកិច្ចថ្មីដែលផ្អែកលើមូលដ្ឋានចំណេះដឹង (Knowledge Based)។ ពី១៩៩៧ដល់បច្ចុប្បន្ន "**ការអប់រំដើម្បីជំរុញសមត្ថភាព**" (Ability-Driven-Education) មានការផ្តួចផ្តើមថ្មី "**គិតពីសាលា សិក្សាពីជាតិ**" (Thinking school learning nation) បានចាប់ផ្តើមនៅខែមិថុនា ឆ្នាំ១៩៩៧ ដើម្បីរៀបចំប្រព័ន្ធអប់រំមួយឆ្ពោះទៅរកការចិញ្ចឹមបីបាច់សង្គមប្រកបដោយភាពច្នៃប្រឌិតនៅក្នុងសហវត្សរ៍ថ្មី ផ្ត

ល់ដល់គ្រូបង្រៀន និងសិស្សានុសិស្សនូវឱកាសចូលរួមអនុវត្តន៍វិធីសាស្ត្រន វានុវត្តន៍ក្នុងការបង្រៀន និងរៀនព្រមទាំងអភិវឌ្ឍន៍ទម្លាប់ត្រិះពិចារ-ណា ដោយខ្លួនឯងផ្ទាល់ និងផ្តល់នូវមធ្យោបាយផ្សេងៗគ្នាកាន់តែច្រើនដែល មានទេពកោសល្យខុសៗគ្នាដើម្បីអភិវឌ្ឍន៍ចំណេះដឹង ជំនាញ និងឥរិយាប ថ។ សឹង្ហបុរីបានរៀបចំផែនការមេសម្រាប់បច្ចេកវិទ្យាព័ត៌មាន (IT master plan) ក្នុងគោលបំណងទាញយកសក្តានុពលបច្ចេកវិទ្យាទំនាក់ទំនង និង ព័ត៌មាន(ICT) ដើម្បីផ្តល់ដល់សិស្សនូវលទ្ធភាពទទួលបានប្រភពព័ត៌មាន ថ្មីៗកាន់តែសម្បូរបែបនិងផ្តល់លទ្ធភាពដល់ពួកគេអាចសិក្សារៀនសូត្រ បានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ពោលគឺរៀនសូត្រពេញមួយជីវិត។ សឹង្ហបុរីបានចាប់ផ្តើមគិតគូរ និងផ្តើមផ្សារភ្ជាប់ការអប់រំទៅនឹងបច្ចេកវិទ្យា តាំងពីឆ្នាំ១៩៩៧ បើប្រៀបធៀបនឹងកម្ពុជា ពួកគេបានដើរដាច់ឆ្ងាយពី យើងណាស់ទៅហើយ ហើយពេលនេះកម្រិតយល់ដឹងពីបច្ចេកវិទ្យា និង ទាញផលប្រយោជន៍ពីវាសម្រាប់បម្រើដល់ការអប់រំនៅទាបនៅឡើយ។ ជាមួយគ្នានេះ សឹង្ហបុរីបានរៀបចំ "**ការអប់រំជាតិ**" (National Education) ដើម្បីជួយសិស្សឱ្យមានចំណេះដឹងកាន់តែប្រសើរអំពីប្រវត្តិ-សាស្ត្ររបស់ ខ្លួន ពង្រឹងនូវការប្តេជ្ញាចិត្តរបស់ពលរដ្ឋ និងការពារតម្លៃស្នូលរបស់សិង្ហបុរី និងការបណ្តុះឆន្ទៈស្រឡាញ់ជាតិមាតុភូមិ។ វាជាការដាក់បញ្ចូលនូវគំនិត ជាតិនិយមនៅក្នុងកម្មវិធីសិក្សាដើម្បីពង្រឹងការរួបរួមគ្នា និងឯកភាពជាតិ។ ចំណុចនេះគ្មានអ្វីចម្លែកទេដែលសឹង្ហបុរីចាំបាច់ត្រូវដាក់បញ្ចូលគោលដៅ អប់រំនេះ គឺដើម្បីរក្សាស្ថេរភាពនយោបាយ តាមរយៈការប្រើប្រាស់ប្រព័ន្ធ អប់រំដើម្បីពង្រឹងស្មារតីឯកភាពជាតិដល់សិស្សានុសិស្ស រក្សាស្ថេរភាពជាតិ និងចេះឱ្យតម្លៃលើអ្នកដឹកនាំខ្លួន ដែលជាទូទៅស្ថិតក្រោមការដឹកនាំរបស់

គណបក្សសកម្មភាពប្រជាជនតែមួយប៉ុណ្ណោះ។ កម្មវិធីសិក្សាប្រទេសសឹង្ហបុរីមិនត្រឹមតែដាក់បញ្ចូលគំនិតជាតិនិយមប៉ុណ្ណោះទេតែក៏ដាក់បញ្ចូលផងដែរនូវសាកលភាវូបនីយកម្មក្នុងគោលបំណងប្រកួតប្រជែងសេដ្ឋកិច្ចក្នុងតំបន់ និងសាកលតួយ៉ាងដូចការលើកកម្ពស់ការអប់រំភាសាបរទេស និងការអប់រំSTEMជាដើម។ ជាឧទាហរណ៍ ការបំផុសគំនិតជាតិនិយម អាចត្រូវបានមើលឃើញតាមរយៈការសិក្សាប្រវត្តិសាស្ត្រជាតិ គោរពទង់ជាតិ និងការស្បថ( សច្ចាប្រណិធាន )របស់សិស្សានុសិស្សនៅតាមសាលារៀនជាដើម។ ការអនុវត្តសច្ចាប្រណិធានរបស់សិស្សានុសិស្សក្នុងនាមជាជនជាតិសឹង្ហបុរីជាលក្ខណៈពិសេសមួយដែលមិនទាន់មាននៅកម្ពុជានៅឡើយ។ ប្រព័ន្ធអប់រំសឹង្ហបុរីបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបណ្តុះគំនិតជាតិនិយមឱ្យចេះស្រឡាញ់ និងធ្វើពលីកម្មដើម្បីជាតិ ផ្សារភ្ជាប់នឹងសាកលភាវូបនីយកម្ម និងភាពជាពលរដ្ឋសាកល ( Global citizenship )។

ចំណែកឯម៉ោងសិក្សានៅប្រទេសសឹង្ហបូរីចូលម៉ោង៨ព្រឹក ចេញម៉ោង២កន្លះ ឬម៉ោង៣រសៀល បើប្រៀបធៀបម៉ោងសិក្សាជាមួយប្រទេស និងតំបន់អាស៊ីខាងកើតដូចជា៖ ក្រុងសៀងហៃ ក្រុងហុងកុង ប្រទេសកូរ៉េ ជប៉ុនដែលមានលទ្ធផលតេស្ត PISA ខ្ពស់ដែរនោះ គឺសឹង្ហបុរីមានចំនួនម៉ោងតិចជាង តែលទ្ធផលតេស្តបែរជាល្អប្រសើរជាងគេទៅវិញ។ **សម្រាប់ចំណុចនេះ យើងអាចកត់សម្គាល់បានថា ចំនួនម៉ោងសិក្សាច្រើនហាក់មិនមែនជាមូលហេតុចម្បងដែលធ្វើឱ្យការអប់រំមានគុណភាពទេ។ វាអាចមកពីកត្តាផ្សេងៗទៀតគួបផ្សំដែលយើងត្រូវសិក្សាស្វែងយល់បន្ថែម ដូចករណីប្រទេសសឹង្ហបុរីនេះស្រាប់។** ករណីចំនួនម៉ោងសិក្សាតិចនេះ ខុសស្រឡះពី

ទស្សនវិជ្ជារបស់ប្រទេសនៅអាស៊ីខាងកើតមួយចំនួនដែលយល់ថាការបង្កើនម៉ោងសិក្សាជាគន្លឹះសំខាន់ក្នុងការលើកកម្ពស់គុណភាពអប់រំ។ ក្រៅពីការផ្លាស់ប្តូរប្រព័ន្ធសាលារៀនសមាសធាតុសំខាន់ៗបីទៀតក៏មានការផ្លាស់ប្តូរផងដែរៈ (ការអប់រំគ្រូបង្រៀនៈ សឹង្ហបុរីយល់ឃើញថា បើគ្រូបង្រៀនមានគុណភាពក៏នាំឱ្យការអប់រំមានគុណភាពផងដែរ។ ស្ថានភាពនៃការបង្រៀនជាអាជីពបានកើនឡើងយ៉ាងខ្លាំងចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៦០មក។ ឧត្តមភាពផ្នែកអប់រំគឺ មាននិរន្តរភាពទៅបានតាមរយៈការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូបង្រៀនដែលមានគុណភាព និងថ្នាក់ដឹកនាំសាលារៀនឆ្នើមៗ គំនិតនៃការបណ្តុះបណ្តាល " **ពេញមួយជីវិត**" (Lifelong learner) និងការបណ្តុះបណ្តាលឡើងវិញសម្រាប់គ្រូបង្រៀន និងនាយកសាលាទាំងអស់)(ការអប់រំវិជ្ជាជីវៈ និងបច្ចេកវិទ្យាៈ រូបភាព / ស្ថានភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកវិទ្យាមានការរីកចម្រើនយ៉ាងខ្លាំងក្នុងទសវត្សរ៍ឆ្នាំ១៩៩០ដោយវិទ្យាស្ថានបច្ចេក-ទេសអប់រំ និងពហុបច្ចេកទេសដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតផ្នែកអប់រំបច្ចេកទេស និងជំនាញវិជ្ជាជីវៈដែលមានមូលដ្ឋានទូលំទូលាយ ស្ថាប័នទាំងនេះផ្តល់ឱ្យជនជាតិសិង្ហបុរីយ៍ក្មេងនូវជំនាញសម្រាប់ការងារ ឬភាពជាសហគ្រិននៅក្នុងសេដ្ឋកិច្ចដែលមានគុណតម្លៃខ្ពស់ (high value economy)។

ជាមួយគ្នានេះ នៅឆ្នាំ២០០៤លោកនាយករដ្ឋមន្ត្រី **លី សៀនឡុង** បានណែនាំនូវក្របខណ្ឌការងារ "**បង្រៀនតិច រៀនច្រើន**" (Teach less, learn more) ដើម្បីជំរុញឱ្យប្រព័ន្ធអប់រំមានផ្លាស់ប្តូរ និងកាន់តែរីកចម្រើនថែមទៀត ដោយតម្រូវឱ្យគ្រូបង្រៀនផ្តោតសំខាន់លើគុណភាពនៃ

ការសិក្សា និងការដាក់បញ្ចូលនូវបច្ចេកវិទ្យាទៅក្នុងថ្នាក់រៀន ដោយងាកចេញពីការផ្តោតតែទៅលើបរិមាណ និងការរៀបចំតេស្តប្រឡងដែលបានអនុវត្តកន្លងមក។ **និន្នាការអប់រំសតវត្សរ៍ទី២១សឹង្ហបុរីបណ្តុះការអប់រំផ្តោតសំខាន់លើបំណិនជីវិត** និង**ការសិក្សាមានមូលដ្ឋានផ្អែកលើគម្រោង** (Project Based learning) ដោយឱ្យសិស្សធ្វើការសិក្សាស្រាវជ្រាវ និងធ្វើបទបង្ហាញ។

ការសិក្សានៅកម្រិតបឋមសិក្សាមានរយៈពេល៦ឆ្នាំ ហើយត្រូវបែងចែកជាពីរដំណាក់កាលគឺៈ (ទីមួយ) រយៈ៤ឆ្នាំសម្រាប់ដំណាក់កាលមូលដ្ឋាន និង (ទីពីរ) ២ឆ្នាំដំណាក់កាលតម្រង់ទិស។ បន្ទាប់ពីសិក្សារយៈពេល៦ឆ្នាំ សិស្សានុសិស្សត្រូវធ្វើការប្រឡងបញ្ចប់ថ្នាក់បឋមសិក្សា (Primary School Leaving Examination) ដែលកំណត់វាសនារបស់ពួកគេក្នុងការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ ដោយបែងចែកទៅតាមកម្រិតសមត្ថភាព និងឧបនិស្ស័យ ថាតើត្រូវរៀនថ្នាក់វិទ្យាសាស្ត្រពិត ឬវិទ្យាសាស្ត្រសង្គម។ នៅមធ្យមសិក្សាបឋមភូមិមានការបែងចែកជា៤ប្រភេទៈ (១)**ថ្នាក់ពិសេស** (Special-សម្រាប់សិស្សដែលមានសមត្ថភាពពិសេស-ពូកែខ្លាំង)(២) **ថ្នាក់សិស្សពូកែ អិចស្ព្រេស** (Express) (៣) **កម្រិតធម្មតា-សិក្សាធិកា** (Normal Academic) និង(៤)**កម្រិតធម្មតា-បច្ចេកទេស** (Normal Technical)។ សម្រាប់សិស្សពូកែខ្លាំងផ្អែកលើលទ្ធផលប្រឡងបញ្ចប់បឋមសិក្សាត្រូវរៀន៤ឆ្នាំ ហើយនៅពេលបញ្ចប់ត្រូវប្រឡងតេស្ត "អូ" (O)ដើម្បីបន្តចូលរៀននៅវិទ្យាល័យរយៈពេល២ឆ្នាំទៀត។ ក្រុមកម្រិតធម្មតា-សិក្សាធិកា(ក្រុមនេះខ្សោយជាងក្រុមថ្នាក់ពិសេស និង

អិចស្រ្តែស ត្រូវរៀនបាន៤ឆ្នាំហើយត្រូវប្រឡងបញ្ចប់ រួចរៀនមួយឆ្នាំទៀត ទើបមានសិទ្ធិប្រឡងតេស្ត "អូ" (O) ចូលរៀនវិទ្យាល័យដូចក្រុមខ្លាំងទាំងពីរខាងលើ ហើយសម្រាប់កម្រិតធម្មតា-បច្ចេកទេសត្រូវរៀនតែ១០ឆ្នាំ ដោយមិនបាច់រៀនវិទ្យាល័យ និងចូលធ្វើការជាកម្មករជំនាញតែម្តង។ សម្រាប់សិស្សដែលមានកំសោយភាព ឬពិការភាពត្រូវចូលរៀនថ្នាក់អប់រំពិសេស និងក៏មានការបែងចែកទៅតាមសមត្ថភាព និងឧបនិស្ស័យដូចគ្នាដែរ។ នៅពេលប្រឡងបញ្ចប់កម្រិតវិទ្យាល័យ បើប្រឡងបាននិទ្ទេស "អេ" (A)ទើបអាចចូលរៀននៅថ្នាក់មហាវិទ្យាល័យបាន ហើយប្រទេសអង់គ្លេសជាអ្នកពិនិត្យ និងកែ។ កម្រិតមហាវិទ្យាល័យ និស្សិតត្រូវរៀនពី៣ ទៅ៥ឆ្នាំ ។ ដោយសារតែការប្រឡងនៅបញ្ចប់ថ្នាក់វិទ្យាល័យប្រទេសអង់គ្លេសជាអ្នកកែ ដូច្នេះវាមានកម្រិតស្តង់ដារស្មើគ្នាទៅនឹងប្រទេសអង់គ្លេសដែរ ពោលគឺប្រទេសអង់គ្លេសទទួលស្គាល់ស្តង់ដារអប់រំ និងអាចបន្តការសិក្សានៅអង់គ្លេសបាន។ ករណីនេះ សម្រាប់កម្ពុជា ពិបាកឱ្យគេទទួលស្គាល់គុណភាពអប់រំដូចសឹង្ហបុរីណាស់ ព្រោះមិនមានភ្ជាប់ទៅនឹងស្តង់ដារអន្តរជាតិណាមួយនៅឡើយ ហើយសូម្បីតែការវាយតម្លៃPISAយើងទើបតែអនុវត្តន៍នៅចុងឆ្នាំ២០១៧ថ្មីៗនេះប៉ុណ្ណោះ។

ចាប់ពីឆ្នាំ២០១៩ ប្រព័ន្ធអប់រំសឹង្ហបូរីបានសម្រួលរចនាសម្ព័ន្ធវាយតម្លៃមានមូលដ្ឋានផ្អែកសាលារៀន(School-Based Assessment Structure) ដោយដកចេញការវាយតម្លៃ និងការប្រឡងនានាជាច្រើនដែលបានអនុវត្តកន្លងមកក្នុងមួយឆ្នាំសិក្សា។ ការវាយតម្លៃ និងការប្រឡងទាំងអស់ត្រូវដកចេញពីកម្រិតបឋមសិក្សាទី១ និងទី២ ហើយពីទី៣ដល់

ដល់កម្រិតមធ្យមសិក្សាទី៤/៥ បានផ្លាស់ប្តូរមកអនុវត្តការវាយតម្លៃមួយប៉ុណ្ណោះលើមុខវិជ្ជានីមួយៗសម្រាប់មួយត្រីមាសម្តងៗ ពោលគឺលែងមានការប្រឡងប្រចាំខែ។ ការអនុវត្តបែបនេះដើម្បីកាត់បន្ថយសម្ពាធសិក្សារបស់សិស្ស និងការប្រកួតប្រជែងគ្នា។ វាជាឱ្យតម្លៃទៅលើការបណ្តុះឥរិយាបថ និងសីលធម៌ល្អរបស់សិស្ស ជាជាងការប្រកួតប្រជែងយកឈ្នះគ្នាទៅវិញទៅមក។

សាលារៀនមួយចំនួននៅសិង្ហបុរីមាន**សេរីភាពក្នុងការរៀបចំកម្មវិធីសិក្សា** ហើយត្រូវបានគេស្គាល់ថាជាសាលារៀន**ស្វយ័ត**សម្រាប់កម្រិតមធ្យមសិក្សា និងខ្ពស់ជាងនេះដែលជាគន្លឹះដ៏សំខាន់មួយទៀតធ្វើឱ្យវិស័យអប់រំសិង្ហបុរីមានការរីកចម្រើនខ្លាំង។ សម្រាប់កម្ពុជា យើងក៏ទទួលស្គាល់ផងដែរពីស្វ័យភាព និងឯករាជ្យភាពលើការគ្រប់គ្រង និងដឹកនាំសាលារៀនដែលជាករណីសិក្សាដ៏ល្អមួយស្តីពីភាពលេចធ្លោនៃភាពរីកចម្រើនខ្លាំងរបស់សាលារៀន ដូចករណី **សាលាបឋមសិក្សាវត្តបូព៌** នៅខេត្តសៀមរាបស្រាប់។ ករណីសាលាវត្តបូព៌ នាំឱ្យមានការចោទសួរជាច្រើនពីការអនុវត្តតាមគោលនយោ-បាយអប់រំជាតិ និងការគ្រប់គ្រងមានមូលដ្ឋានផ្អែកលើសាលារៀន (School Based Management)។ ចម្ងល់សំខាន់មួយដែលធ្វើឱ្យយើងឆ្ងល់នោះគឺ ហេតុអ្វីសាលាវត្តបូព៌រីកចម្រើនខ្លាំង បើចំណុចខ្លះមិនបានអនុវត្តមានគោលនយោបាយអប់រំជាតិផងនោះ ដូចករណីការតម្រូវឱ្យបង់ថ្លៃសិក្សាជាដើម?

គ្រឹះស្ថានអប់រំក្រោយមធ្យមសិក្សារួមមាន៖ ពហុបច្ចេក-ទេសចំនួន៥ វិទ្យាស្ថានអប់រំបច្ចេកទេស (ITEs) សាកលវិទ្យាល័យសាធារណៈ

ចំនួន៦ ដែលក្នុងនោះសាកលវិទ្យាល័យជាតិសឹង្ហបុរី និងសាកលវិទ្យាល័យបច្ចេកវិទ្យាNanyangស្ថិតនៅក្នុងចំណោមសាកលវិទ្យាល័យកំពូលទាំង ២០ នៅលើពិភពលោក(11)។

ការសិក្សានៅ**មធ្យមសិក្សាចំណេះទូទៅ និងមធ្យមសិក្សាបច្ចេកទេស** មានប្រជាប្រិយភាពដូចគ្នានៅសឹង្ហបុរី តែនៅកម្ពុជា សិស្ស-និស្សិតភាគច្រើនចាប់អារម្មណ៍ការសិក្សានៅសាលាចំណេះទូទៅ និងសាកលវិទ្យាល័យច្រើនជាងសាលាបណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈ។ ដើម្បីឱ្យសិស្សចាប់អារម្មណ៍រៀនជំនាញវិជ្ជាជីវៈដូចសឹង្ហបុរី កម្ពុជាគួរតែមានយុទ្ធសាស្ត្រច្បាស់លាស់ដោយយកគំរូតាមប្រទេសមួយនេះ។ សឹង្ហបុរីក៏ធ្លាប់មានស្ថានភាពដូចកម្ពុជាយើងដែរ ពីដំបូងសិស្សក៏មិនសូវចាប់អារម្មណ៍ការសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ តែសឹង្ហបុរីមានយុទ្ធសាស្ត្រអូសទាញ និងលើកទឹកចិត្ត ដោយត្រូវប្រើប្រាស់ពេលវេលាអស់ជិតមួយទសវត្សរ៍។ សឹង្ហបុរីធ្វើការផ្សព្វផ្សាយតាមសាលាមធ្យមសិក្សាចំណេះទូទៅ និងការតាំងពិពណ៌នានាដើម្បីអូសទាញ។ ហេតុផលសំខាន់មួយសម្រាប់ភាពជោគជ័យនៃការអប់រំបច្ចេកទេសនៅ Institute for Technical Education (ITE) គឺថាសិស្សានុសិស្សទទួលបាននូវមូលដ្ឋានគ្រឹះដ៏រឹងមាំនៅដើមដំបូងនៅក្នុងអាជីពសិក្សារបស់ពួកគេ ដូច្នេះពួកគេអាចទទួលបាននូវជំនាញមានលក្ខណៈស្មុគស្មាញច្រើនដែលតម្រូវដោយនិយោជកឈានមុខ។ នៅកម្ពុជា សិស្សានុសិស្សបោះបង់ការសិក្សានៅមានអត្រាខ្ពស់នៅឡើយ ប្រមាណ៦,២%នៅបឋមសិក្សា១៩,២%មធ្យមសិក្សាបឋមភូមិ និង ២៣,៨%នៅមធ្យមសិក្សាទុតិយភូមិ(12) ចំណែកនៅប្រទេសសឹង្ហបុរី សិស្ស

៩០%បញ្ចប់ការសិក្សា២៥% បានបញ្ចប់ការសិក្សាពី ITE ហើយមានការងារល្អ។ កម្ពុជាត្រូវរកវិធីដើម្បីបិទគម្លាតរវាងជំនាញដែលនិយោជកត្រូវការ និងលទ្ធផលនៃប្រព័ន្ធអប់រំដើម្បីបំពេញនូវសេចក្តីត្រូវការរបស់អ្នកដែលបានបោះបង់ការសិក្សានៅមធ្យមសិក្សា និងដើម្បីយកគំរូតាមការអប់រំបច្ចេកទេសសម្រាប់ការងារថ្មីនាពេលអនាគត។ កម្មករខ្មែរភាគច្រើនជាពលករប្រើកម្លាំង នៅមិនទាន់មានជំនាញជាក់លាក់នៅឡើយដែលជាបញ្ហា គប្បីត្រូវយកចិត្តទុកដាក់ដោះស្រាយជាបន្ទាន់។ ជាមួយគ្នានេះ យើងក៏ត្រូវគិតគូរផងដែរ ចំពោះសិស្សដែលបោះបង់ការសិក្សានៅកម្រិតបឋមសិក្សានិងបោះបង់នៅដំណាក់កាលមុនបញ្ចប់មធ្យមសិក្សាបឋមភូមិ ពោលគឺផ្តល់លទ្ធភាពដល់ពួកគាត់ទទួលបានសេវាបណ្តុះបណ្តាលបច្ចេកទេសជំនាញវិជ្ជាជីវៈ ឬធ្វើយ៉ាងណាដើម្បីសមាហរណកម្មពួកគេចូលក្នុងប្រព័ន្ធ។

តាំងពីឆ្នាំ២០០០ សឹង្ហបុរីបានកំណត់ទីតាំងខ្លួនជាមជ្ឈមណ្ឌលអប់រំ ដើម្បីទាក់ទាញនិស្សិតបរទេស និងសាកលវិទ្យាល័យអន្តរជាតិល្បីៗជាផ្នែកសេវាកម្មនៃកំណើតសេដ្ឋកិច្ច[13]។ និស្សិតសឹង្ហបុរីមានកម្រិតខ្ពស់បំផុតក្នុងការធ្វើតេស្តលើមុខវិជ្ជាគណិតវិទ្យា ផ្នែកវិទ្យាសាស្ត្រ និងការអាន។ នៅឆ្នាំ២០១៥ទាំងសិស្សកម្រិតបឋមសិក្សា និងមធ្យមសិក្សាទទួលបានចំណាត់ថ្នាក់លេខ១ ក្នុងការបំពេញការងាររបស់សាលារៀនជាសាកលរបស់អង្គការសម្រាប់សហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ក្នុងចំណោមប្រទេសចំនួន៧៦ ដែលត្រូវបានគេចាត់ទុកថាជាផែនទីសិក្សាមានលក្ខណៈស្តង់ដារអប់រំពេញលេញបំផុតនៅលើពិភពលោក[14]។ នៅឆ្នាំ២០១៦ និស្សិតសឹង្ហបុរីជាប់ចំណាត់ថ្នាក់ទាំងកម្មវិធីវាយតម្លៃសិស្ស-

និស្សិតអន្តរជាតិ (PISA) និងវាយតម្លៃនិន្នាការសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រអន្តរជាតិ(TIMSS)។ ក្នុងការប្រឡងបាក់ឌុបអន្តរជាតិឆ្នាំ២០១៥ ដែលត្រូវបានធ្វើឡើងនៅក្នុងប្រទេសចំនួន១០៧ និស្សិតសឹង្ហបិរីទទួលបានពិន្ទុល្អបំផុតជាមួយចំនួនជាងពាក់កណ្តាលនៃអ្នកបានពិន្ទុដ៏ល្អឥតខ្ចោះលំដាប់ពិភពលោក៨១នាក់ និងអត្រាប្រឡងជាប់៩៨%[15]។

នៅក្នុងសន្ទស្សន៍ភាសាអង់គ្លេស EF ឆ្នាំ២០១៦ ដែលបានអនុវត្តនៅក្នុងប្រទេសចំនួន៧២ ប្រទេសសឹង្ហបុរីបានឈរចំ-ណាត់ថ្នាក់លេខ៦ និងជាប្រទេសអាស៊ីតែមួយគត់ស្ថិតនៅលំដាប់កំពូលទាំង១០នៅលើកម្រិតពិភពលោក។ និស្សិតផ្នែកអក្សរសាស្ត្រសិង្ហបុរីបានឈ្នះពានរង្វាន់ Angus Ross តាមរយៈការចូលរួមប្រឡង Cambridge ជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ១៩៨៧ (លើកលែងតែក្នុងឆ្នាំ២០០០) ដែលបានប្រគល់ជូននិស្សិតអក្សរសាស្ត្រអង់គ្លេសមានសមត្ថភាពខ្ពស់ផ្នែកភាសាអង់គ្លេសកម្រិតA ក្រៅពីចក្រភពអង់គ្លេសដោយមានបេក្ខជនអន្តរជាតិចូលរួមប្រហែល ១២.០០០ នាក់ទូទាំងពិភពលោក[16]

កម្រិតសិក្សារបស់សិស្សសឹង្ហបូរី បើតាមទ្រឹស្តីBloom Taxonomy (១-ចេះ/ចងចាំ ២-យល់ដឹង ៣-អនុវត្ត ៤-វិភាគ ៥-សំយោគ និង៦-វាយតម្លៃ/ច្នៃបង្កើតថ្មី) គឺសិស្សភាគច្រើនបានឈានដល់ចំណុចកំពូលនៃសមត្ថភាពវាយតម្លៃ និងច្នៃបង្កើតថ្មីដែលប្រទេសជាច្រើនមិនអាចធ្វើបាន។

## 1.4) លក្ខណៈពិសេសនៃប្រព័ន្ធអប់រំសឹង្ហបុរី

- ***ភាសាអង់គ្លេសជាភាសាផ្លូវការទី១***

ភាសាអង់គ្លេសជាភាសាទី១ដែលក្មេងៗពាក់កណ្ដាលបានរៀនតាំងមុនចូលរៀនសាលាបឋមសិក្សាមកម្ល៉េះ។ ចាប់ពីសាលាបឋមសិក្សាទៅ ភាសាអង់គ្លេសត្រូវបានប្រើជាភាសាយានក្នុងការបង្រៀន និងរៀននៅសាលាសាធារណៈ (សាលារដ្ឋ) ដោយគ្រប់មុខវិជ្ជាត្រូវបានបង្រៀន និងប្រឡងជាភាសាអង់គ្លេស (លើកលែងតែមុខវិជ្ជា«ភាសាកំណើត»)។ នៅបណ្ដាប្រទេសដទៃ ពាក្យ«ភាសាកំណើត» ជាទូទៅសំដៅលើភាសាទី១ ប៉ុន្តែសម្រាប់ប្រព័ន្ធអប់រំនៅសឹង្ហបុរីវិញ វាសំដៅលើភាសាទី២ ដោយភាសាអង់គ្លេសជាភាសាទី១។ សិស្សដែលស្នាក់នៅបរទេសមួយរយៈ ឬមានការលំបាកខ្លាំងជាមួយ«ភាសាកំណើត»នេះ ត្រូវតម្រូវឱ្យរៀនតាមកម្មវិធីសិក្សាស្រួលជាងនេះ ឬបោះបង់មុខវិជ្ជានេះចោលក៏បាន។ ប្រព័ន្ធអប់រំចែកចេញជាពាកម្រិត «**កម្រិតបឋមសិក្សា**» (ចាំបាច់) «**កម្រិតមធ្យមសិក្សា**» និង «**កម្រិតត្រៀមមហាវិទ្យាល័យ**»។

## ❖ <u>ប្រព័ន្ធបែងចែកសិស្សតាមសមត្ថភាព និងឧបនិស្ស័យ</u>

សិស្សចូលសាលាបឋមសិក្សានៅអាយុ៦ឆ្នាំ ហើយចែកចេញជា២ផ្នែក ៖ ៤ឆ្នាំដំបូងជា**ថ្នាក់មូលដ្ឋាន** និង២ឆ្នាំទៀតជា**ថ្នាក់តម្រង់ទិស**។ កម្មវិធីសិក្សាសង្កត់ធ្ងន់លើមុខវិជ្ជាស្ដង់ដារ៤គឺ៖ ភាសាអង់គ្លេ-ស ភាសាកំណើត គណិតវិទ្យា និងវិទ្យាសាស្ត្រ។ សិស្សរៀនចំណេះដឹងមូលដ្ឋាននៅក្នុងដំណាក់កាលមូលដ្ឋាននូវមុខវិជ្ជាដូចជា៖ គណិតវិទ្យា ភាសាកំណើត (ចិន ម៉ាឡេ តាមិល ឬភាសាឥណ្ឌាមិនមែនតាមិល)។ ក្នុងដំណាក់កាលតម្រង់ទិស សិស្សត្រូវធ្វើតេស្តយកកៅអី និងបែងចែកជាបីកម្រិតផ្អែកលើលទ្ធផលតេស្តមាន៖ កម្រិតទី១ ទី២ និងទី៣។ កម្រិតទី១ និងទី២ រៀនមុខ

វិជ្ជាភាសាអង់គ្លេសកម្រិតខ្ពស់ គណិតវិទ្យា និងភាសាកំណើត។ ក្រៅពីនេះ ពួកគេក៏រៀនវិទ្យាសាស្ត្របន្ថែម និងថ្នាក់សង្គម។ កម្រិត៣សិស្សរៀនតែភាសាអង់គ្លេសធម្មតាៗ គណិតវិទ្យា និងភាសាកំណើត(17)។ អ្វីដែលជា**លក្ខណៈពិសេស**របស់ប្រព័ន្ធអប់រំប្រទេសសឹង្ហបូរីនោះ គឺជាប្រព័ន្ធមួយដែលធ្វើការបែងចែកសិស្សទៅតាមសមត្ថភាព និងឧបនិស្ស័យតាំងពីនៅកម្រិតបឋមសិក្សា។ គ្រូបង្រៀនបានប្រមូល និងគ្រប់គ្រងកម្រងព័ត៌មាន និងរបាយការណ៍វឌ្ឍនភាពរបស់សិស្សគ្រប់គ្រាន់ ដែលងាយស្រួលក្នុងតាមដានការសិក្សា វាយតម្លៃលទ្ធផលសិក្សា និងវិនិច្ឆ័យសមត្ថភាព ព្រមទាំងឧបនិស្ស័យរបស់កុមារពីកម្រិតថ្នាក់មួយ ទៅកម្រិតថ្នាក់មួយទៀត ដែលវាមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ដំណាក់កាលតម្រង់ទិសវិជ្ជាជីវៈ និងឆ្លងភូមិសិក្សាចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ។ នៅពេលបញ្ចប់កម្រិតបឋមសិក្សា៦ឆ្នាំ សិស្សតម្រូវឱ្យធ្វើការប្រឡងបញ្ចប់កម្រិតបឋមសិក្សា(Primary School Leaving Examination) ដែលលទ្ធផលនៃប្រឡងនេះ កំណត់វាសនារបស់ពួកគេ ថាតើត្រូវរៀននៅកម្រិតណាមួយនៅសាលាមធ្យមសិក្សាបឋមភូមិផ្អែកលើសមត្ថភាព និងឧបនិស្ស័យរបស់ពួកគេ។ នេះមានន័យថាសិស្សពូកែ ត្រូវរៀនជាមួយសិស្សពូកែដូចគ្នា ថ្នាក់ជាមួយគ្នា កម្មវិធីសិក្សាសម្រាប់តែសិស្សពូកែ សិស្សនិទ្ទេសមធ្យម រៀនជាមួយសិស្សមធ្យមដូចគ្នា ហើយសិស្សខ្សោយ រៀនជាមួយអ្នកខ្សោយដូចគ្នា។ នៅសឹង្ហបូរីគេសម្រួចកុមារតាំងពីកម្រិតបឋមសិក្សាឡើងទៅ ដែលលក្ខណៈពិសេសនេះ ខុសដាច់ពីប្រទេសកម្ពុជា ហើយសូម្បីតែប្រទេសជប៉ុន ក៏មិនបានអនុវត្តតាមវិធានបែបនេះដែរ ព្រោះប្រព័ន្ធអប់រំកម្ពុជា ក៏ដូចជាជប៉ុនចង់ឱ្យកុមារទាំងអស់មានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំ

ទទួលបានអប់រំដូចៗគ្នានៅកម្រិតភូមិសិក្សាមួយ។ ទន្ទឹមនឹងមានគុណសម្បត្តិដ៏ច្រើនអនេក ប្រព័ន្ធបែបនេះក៏មានគុណវិបត្តិរបស់វាផងដែរព្រោះវាអាចនាំឱ្យមានការរើសអើង និងកំហុសឆ្គងដោយសារភាពប្រញាប់ប្រញាល់វិនិច្ឆ័យសមត្ថភាព និងឧបនិស្ស័យរបស់កុមារលឿនពេកនៅត្រឹមតែកម្រិតបឋមសិក្សា។ លក្ខណៈពិសេសនេះ វាពិតជាល្អសម្រាប់សឹង្ហបូរី តែសម្រាប់កម្ពុជា ពិបាកក្នុងការយកមកអនុវត្តតាម ព្រោះមិនទាន់ធនធាន និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ក្នុងអនុវត្តតាមគំរូបែបនេះណាស់។ ចំណុចនេះ យើងឃើញថាប្រព័ន្ធអប់រំប្រទេសជប៉ុនមានលក្ខណៈសមស្របច្រើនសម្រាប់កម្ពុជាជាង ដែលខ្លឹមសារលម្អិតយើងបានធ្វើការវិភាគរួចហើយនៅក្នុងការសិក្សាពីប្រព័ន្ធអប់រំប្រទេសជប៉ុន។ យើងក៏មើលឃើញពីគុណសម្បត្តិនៃប្រព័ន្ធអប់រំរបស់សឹង្ហបូរីបែបនេះដែរដូចជា៖ ក្រុមសិស្សខ្លាំង រៀបចំកម្មវិធីសម្រាប់សិស្សខ្លាំង ហើយបើសិស្សខ្សោយ រៀបចំកម្មវិធីសម្រាប់សិស្សខ្សោយតែម្តង ជៀសវាងសិស្សខ្លាំងរៀនកម្មវិធីសិក្សាខ្សោយនាំឱ្យសិស្សខ្លាំងធុញទ្រាន់ និងខាតបង់ធនធានសក្តានុពល។ អំណះអំណាងរបស់សឹង្ហបូរី ធ្វើដូច្នេះ គឺផ្តល់ភាពងាយស្រួលក្នុងការរៀបចំផែនការ ការអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធអប់រំទាំងមូល ព្រមទាំងដើម្បីជួយសិស្សបានគ្រប់ជ្រុងជ្រោយតែប៉ុណ្ណោះ ពោលគឺបើសិស្សខ្លាំងអ្វីអភិវឌ្ឍន៍ផ្នែកនឹងតែម្តង។ សម្រាប់ជប៉ុនយល់ឃើញផ្សេងពីនេះ ការឆាប់វាយតម្លៃសមត្ថភាពសិស្សអាចនាំឱ្យមានកំហុស ព្រោះនៅថ្នាក់ទី៩ ឬទី១០ សិស្សអាចមានការផ្លាស់ប្តូរ ឬមានអ្វីមករំញោចឱ្យគេចាប់អារម្មណ៍ ឬខំសិក្សាខុសប្លែកពីកាលពួកគេនៅកម្រិតបឋមសិក្សា។ **ដូច្នេះ ការតម្រង់ទិស**

វិជ្ជាសិស្សនៅពេលបញ្ចប់មធ្យមសិក្សាបឋមភូមិ ក៏មិនយឺតពេលដែរ ហើយជាអ្វីដែលកម្ពុជា និងជប៉ុនបានអនុវត្តរួចមកហើយ។

## 1.5) សង្ខេបការសិក្សាប្រៀបធៀបគុណសម្បត្តិ និងគុណវិបត្តិការអប់រំ (សឹង្ហបូរី-កម្ពុជា)

### ការអប់រំកម្រិតបឋមសិក្សា

<u>ចំណុចល្អរបស់សឹង្ហបូរី</u>

- **បែងចែកតាមភាពអំណោយផលរបស់សិស្សម្នាក់ៗ៖** សិស្សគ្រប់គ្នាអាចរៀនពីអ្វីដែលពួកគេចង់បានតាមសមត្ថភាពរបស់ខ្លួន នេះហៅថា **ការអប់រំបែបបន្សុី** ពោលគឺសិស្សពូកែត្រូវរៀនជាមួយកម្មវិធីសិក្សាកម្រិតខ្ពស់ ហើយសិស្សមធ្យមត្រូវរៀនជាមួយកម្មវិធីសិក្សាកម្រិតមធ្យមដូចគ្នា ហើយសិស្សដែលមានសមត្ថភាពខ្សោយក៏ដូចគ្នានេះដែរ។
- **បទដ្ឋានមុខវិជ្ជា៖** ផ្តល់ដល់កុមារនូវមូលដ្ឋានគ្រឹះល្អប្រសើរជាងមុននូវមុខវិជ្ជានីមួយៗ
- **ប្រទេសកម្ពុជា៖** សិស្សរៀនដោយគ្មានសម្ពាធ ព្រោះគ្មានការប្រឡងយកកៅអីកម្រិតថ្នាក់ សិស្សរៀនមុខវិជ្ជាផ្សេងៗក្នុងដំណាក់អភិវឌ្ឍន៍របស់ពួកគេស្មើៗគ្នា និងមានឱកាសស្មើភាពក្នុងការសិក្សានៅកម្រិតបឋមសិក្សាដូចគ្នា ដោយគ្មានការបែងចែកទៅតាមកម្រិតសមត្ថភាពឡើយដូចសឹង្ហបុរីឡើយ។

## គុណវិបត្តិការអប់រំកម្រិតបឋមសិក្សារបស់សឹង្ហបូរី

- **សិស្សបាត់បង់ជំនឿលើខ្លួនឯង៖** ដោយសារការបែងចែកសិស្ស ធ្វើឱ្យសិស្សដែលមានកម្រិតទាបងាយបាត់បង់ជំនឿលើខ្លួនឯង ដោយការការបែងចែកនេះបានកំណត់ថាសមត្ថភាពពួកគេទាប។
- **ស្ថានភាពអាងយ៉ាង៖** សិស្សដែលសិក្សានៅកម្រិតខ្ពស់គិតថាខ្លួនពូកែ និងស្ថិតនៅក្នុងក្រុមកម្រិតខ្ពស់។ ជាលទ្ធផល ស្ថានភាពនៃការអាងយ៉ាងចំពោះសិស្សកម្រិតទាបនឹងអាចកើតមានយ៉ាងធ្ងន់ធ្ងរ និងបង្កើតឱ្យសកម្មភាពនៃការរើសអើងនៅក្នុងប្រព័ន្ធអប់រំ។
- **កម្ពុជាៈ**ផ្តោតលើការសិក្សាដោយមិនមានការគិតបែបច្នៃប្រឌិត មិនមានកត្តាជំរុញខ្លាំង និងការត្រៀមសម្ភារៈអប់រំ និងគ្រឿងបរិក្ខារមិនបានល្អ និងគ្រប់គ្រាន់ដូចប្រទេសសឹង្ហបុរី។

ជារួមការសិក្សានៅកម្ពុជា គួរពង្រឹងសមត្ថភាពគិតរបស់សិស្ស។ ការច្នៃប្រឌិត និងការសិក្សាទាំងពីរនេះ មានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍកុមារ។ រាជរដ្ឋាភិបាលគួររៀបចំកម្មវិធីបំណិនអាន ចាប់អារម្មណ៍លើការអានឱ្យបានច្រើនដើម្បីបង្កើនភាពច្នៃប្រឌិត និងភាពប៉ិនប្រសប់របស់កុមារ។ កម្ពុជាគួរដោះស្រាយបញ្ហាកង្វះគំនិតច្នៃប្រឌិត។

## ការអប់រំ កម្រិតមធ្យមសិក្សាបឋមភូមិ

### ចំណុចល្អសឹង្ហបូរី

- **ភាសាផ្សេងៗក្រៅពីភាសាកំណើត៖** ក្រៅពីភាសាកំណើត សិស្សសិង្ហបុរីរៀនភាសាផ្សេងៗបន្ថែមទៀតដូចជា៖ បារាំង អាល្លឺម៉ង់ និងជប៉ុន។ វាមិនគ្រាន់តែជាការប្រមើលវែងឆ្ងាយទូលំទូលាយ ប៉ុន្តែក៏សម្រួលនឹងបរិស្ថានសិង្ហបុរីផ្នែកទំនាក់ទំនង និងពាណិជ្ជកម្ម។ សម្រាប់កម្ពុជា៖ គុណភាពគ្រូនៅមានកម្រិត គ្រូបង្រៀនភាសាបរទេសនៅមានចំនួនតិច សូម្បីតែនៅភាសាអង់គ្លេសមួយក៏មិនគ្រប់គ្រាន់ផង គុណវុឌ្ឍិគ្រូបង្រៀននៅមានទាបនៅឡើយ សម្ភារបង្រៀន និងរៀនមានតិចតួចមិនគ្រប់គ្រាន់ ...។
- **ជម្រើសច្រើន៖** សិស្សអាចប្រមូលផ្តុំនូវចំណាប់អារម្មណ៍ផ្ទាល់របស់ខ្លួនគេ។ សិង្ហបុរីក៏ផ្តល់នូវវគ្គសិក្សាបច្ចេកទេសដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់សិស្ស។

## គុណវិបត្តិ

- **ការដាក់សម្ពាធ៖** ដោយទទួលឥទ្ធិពលពីលទ្ធិខុងជឺ មាតាបិតាសិស្សមួយចំនួនធំយកចិត្តទុកដាក់ខ្លាំងដល់ការសិក្សារបស់កូន។ ពួកគាត់ខ្វល់ខ្វាយច្រើនពីគុណភាព និងកម្រិតសមត្ថភាពកូន។ នេះប្រហែលធ្វើឱ្យសិស្សទទួលរងសម្ពាធច្រើនពីមាតាបិតារបស់ពួកគេ។
- **មុខវិជ្ជាសិក្សាច្រើន៖** សិង្ហបុរីតែងតែបន្ថែមហើយបន្ថែមទៀតនូវមុខវិជ្ជាផ្សេងៗដល់សិស្ស ដូចជា៖ ល្បែងចិន ល្បែងអង់គ្លេសជាដើម។

**ថ្នាក់មុនចូលមហាវិទ្យាល័យ** (សម្រាប់ថ្នាក់សិក្សាមុនចូលមហាវិទ្យាល័យមានបីគឺះវិទ្យាល័យ វិទ្យាស្ថានមជ្ឈមណ្ឌល និងវិទ្យាស្ថានអប់រំបច្ចេកទេស)

**ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ** (Junior college)

ថ្នាក់វិទ្យាល័យផ្តល់ការសិក្សារយៈ ពេល២ឆ្នាំ ហើយចុងក្រោយធ្វើតេសកម្រិតខ្ពស់សឹង្ហបូរី -ខាមប្រ៊ីត GCE (Singapore-Cambridge GCE Advanced Level test)។ ដោយសារមានស្តង់ដារតេស្តនេះ ធ្វើឱ្យកម្រិតសិក្សានៅសឹង្ហបូរីស្មើគ្នានឹងប្រទេសអង់គ្លេស។ កម្រិតវិទ្យាល័យសឹង្ហបូរីចាប់បំពាក់បំប៉នសិស្សនូវជំនាញចាំបាច់ និងចំណេះដឹងដែលត្រូវការសម្រាប់ការអប់រំកម្រិតឧត្តមសិក្សា។ សិស្សអាចជ្រើសរើសមុខវិជ្ជាជាច្រើនពីការសិក្សាខុសៗគ្នាដូចជា៖ មនុស្សសាស្ត្រ សិល្បៈ ភាសា គណិតវិទ្យា និងវិទ្យាសាស្ត្រ។

**ចំណុចល្អ**

- **កំណត់នូវអ្វីដែលត្រូវរៀននៅមហាវិទ្យាល័យ៖** សិស្សអាចប្រាកដថាអ្វីដែលគេចង់រៀនសម្រាប់អនាគតជីវិតរបស់គេ។
- **មិនចំណាយពេលអត់ប្រយោជន៍ច្រើនលើមុខវិជ្ជាដទៃទៀត៖** សិស្សអាចផ្តោតលើមុខវិជ្ជាដែលបានជ្រើស។

**ចំណុចគុណវិបត្តិ**

- កង្វះសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ៖ គេមិនអាចរៀនជំនាញបច្ចេកទេសបើសិនសិស្សចាប់អារម្មណ៍នឹងជំនញវិជ្ជាជីវៈ

**កម្ពុជា៖** ផ្តល់ជម្រើសច្រើន ព្រមទាំងធនធានច្រើនសម្រាប់សិស្សក្នុងការឆ្លើយតបទៅនឹងតម្រូវការខុសៗគ្នារបស់សិស្ស។ សិស្សអាចជ្រើសរើសមុខវិជ្ជាដែលល្អប្រសើរបំផុតដែលគេចង់។ **បញ្ហារបស់**

**កម្ពុជា៖** មាតាបិតាសិស្ស ក៏ដូចជាសិស្សានុសិស្សគិតថា៖ ការសិក្សានៅសាកលវិទ្យាល័យគឺល្អជាងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ។

## 1.6) គំរែលទម្រង់ និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន

នៅពេលប្រទេសសឹង្ហបុរីបានទទួលឯករាជ្យពីចក្រភពអង់គ្លេសក្នុងឆ្នាំ ១៩៦៥ វាគឺជាកន្លែងក្រីក្រដែលមាន ធនធានធម្មជាតិតិចតួច ហើយមានតែក្រុមជនជាតិភាគតិច និងក្រុមសាសនារស់នៅ។ ភាគច្រើននៃពួកគេមិនទទួលបានការអប់រំជ្រៅជ្រះអ្វីទេ ពោរពេញទៅដោយជំលោះជាតិសាសន៍ ហើយមិនតែប៉ុណ្ណោះប្រឈមនឹងជំងឺដង្កាត់ផ្សេងៗពិសេសជំងឺគ្រុនចាញ់។ សព្វថ្ងៃនេះ សឹង្ហបូរីបានក្លាយជាមជ្ឈមណ្ឌលពាណិជ្ជកម្មហិរញ្ញវត្ថុ និងមធ្យោបាយដឹកជញ្ជូនដ៏សំខាន់មួយដែលជាចំណុចស្នូលនៃជោគជ័យរបស់អាស៊ី។ សាលារៀនឈរនៅកម្រិតខ្ពស់នៅក្នុងបញ្ជីប្រព័ន្ធសាលារៀនល្អបំផុតរបស់ពិភពលោក។ អ្នកអប់រំជាច្រើនមកពីជុំវិញពិភពលោក ឥឡូវនេះចូលមកសឹង្ហបូរី ដើម្បីស្វែងយល់ ថាតើប្រទេសនេះ អនុវត្តបែបណាខ្លះបានជាទទួលជោគជ័យយ៉ាងធំធេងលើវិស័យអប់រំទាក់ទងនឹងការអនុវត្តផ្នែកគណិត វិទ្យាវិទ្យាសាស្ត្រ និងអក្ខរកម្មរបស់ខ្លួន។ បើយោងតាមអ្នកអប់រំប្រទេសសឹង្ហបូរី ចម្លើយរបស់វាមានលក្ខណៈសាមញ្ញគឺ**កម្មវិធីសិក្សាដែលមានលក្ខណៈសមស្របត្រូវបានផ្តល់ឱ្យគ្រប់គ្រូបង្រៀនដែលមានគុណភាពខ្ពស់**។ ដោយទទួលស្គាល់ថា ខ្លួនមានធនធានដទៃទៀតតិចតួច

អ្នកបង្កើតគោលនយោបាយសិង្ហបុរីបានសម្រេចចិត្តយ៉ាងឆាប់រហ័សក្នុងការការវិនិយោគលើធនធានមនុស្ស ដោយបង្កើតក្ដីស្រមៃ ការរៀបចំ និងផ្ដល់ការអប់រំរឹងមាំមួយដល់កុមារគ្រប់រូប។ **គ្រូបង្រៀនល្អ និងថ្នាក់ដឹកនាំសាលា**ដែលមានប្រសិទ្ធភាពគឺជាគ្រឹះដ៏សំខាន់នៃប្រព័ន្ធនេះ។ គ្រូបង្រៀនដែលមានគុណវុឌ្ឍិខ្ពស់ជាកម្លាំងស្នូលដែលមិនមែន កើតឡើងដោយភាពចៃដន្យ ឬជាលទ្ធផលនៃការគោរពវប្បធម៌សម្រាប់ការបង្រៀនប៉ុណ្ណោះទេ។ វាគឺជាលទ្ធផលនៃជម្រើសគោលនយោបាយដោយចេតនាសុទ្ធសាធ។ សិង្ហបុរីបានបង្កើតប្រព័ន្ធទូលំទូលាយសម្រាប់ធ្វើការជ្រើសរើស បណ្ដុះបណ្ដាល ការផ្ដល់សំណង (អត្ថប្រយោជន៍) និងអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន និងនាយកសាលា។ គ្រូបង្រៀន និងនាយកសាលាល្អគឺជាបេះដូងនៃយុទ្ធសាស្ត្រលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ។ ចំណែកឯនៅកម្ពុជាវិញកម្រិតគុណវុឌ្ឍិគ្រូបង្រៀននៅទាបណាស់ ពិសេសនៅតាមតំបន់ជនបទ ដោយមានគ្រូបង្រៀន១,០៤%មិនដែលឆ្លងកាត់ការបណ្ដុះបណ្ដាល គរុកោសល្យ ១,៨២%មិនមានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ២៣,១៨% មិនមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង៥៥,៧៦% ជាគ្រូបង្រៀនដែលមានកម្រិតសញ្ញាប័ត្រត្រឹមមធ្យមសិក្សាទុតិយភូមិ(18)។ ជារួម ប្រមាណជាង៧៨%នៃគ្រូបង្រៀនមានកម្រិតគុណវុឌ្ឍិទាប ដែលបញ្ហានេះ កម្ពុជាត្រូវដោះស្រាយដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពការអប់រំ។

ដើម្បីក្លាយជានាយកសាលាគឺ មិនងាយស្រួលនោះទេនៅសឹង្ហបូរី។ បេក្ខជនដែលត្រូវតែងតាំងនេះត្រូវតែមានកំណត់ត្រាដែលទទួលបានជោគជ័យក្នុងនាមជាគ្រូបង្រៀន (master teacher) ឆ្លងកាត់ការធ្វើតេស្ត និងត្រូវចូលរួមការហ្វឹកហាត់ផ្លូវការ។ វគ្គបណ្ដុះបណ្ដាលនេះមានរយៈពេល ៦ ខែដែលក្នុងរយៈពេលពីរសប្ដាហ៍ត្រូវបានចំណាយនៅក្រៅប្រទេសដើម្បី

ពិនិត្យមើលការអនុវត្តល្អបំផុតក្នុងបរិបទផ្សេងទៀតហើយពេលត្រឡប់មកប្រទេសវិញត្រូវចែករំលែកការរកឃើញនោះ។ ដើម្បីអនុវត្តវិធានការលើកកម្ពស់គុណភាពអប់រំ សឹង្ហបូរីបានខិតខំប្រឹងប្រែងដើម្បីផ្តល់នូវស្វ័យភាពបន្ថែមទៀតកាន់តែច្រើនដល់សាលារៀនដើម្បីឱ្យពួកគេធ្វើការដោយឯករាជ្យ និង បង្កើតកម្រងសាលារៀនដែលមានសាលារៀនប្រហែល១២ ទៅ ១៤ជាសមាជិក ដើម្បីជំរុញការចែករំលែក និងការរៀនសូត្រពីគ្នាទៅវិញទៅមក ។ សម្រាប់ការបង្កើតកម្រងសាលារៀននេះ នៅកម្ពុជាក៏មានដែរ តែដំណើរការហាក់នៅរប៉ាក់រពើកនៅឡើយ និងនៅជួបប្រទះនូវបញ្ហាប្រឈមច្រើន ដូចជា៖ សាលាដឹកនាំកម្រងមានការលំបាកក្នុងការរៀបចំការប្រជុំការចំណាយថវិកា ឆន្ទៈនិងសមត្ថភាពនៃការគ្រប់គ្រង និងដឹកនាំសកម្មភាពកម្រងជាដើម។

ប្រទេសសឹង្ហបូរីក៏បានបង្កើត និងផ្សព្វផ្សាយជាសាធារណៈនៃប្រព័ន្ធទទួលស្គាល់គុណភាពអប់រំសម្រាប់សាលារៀនដែលទទួលបានជោគជ័យ។ ពានរង្វាន់សាលារៀនរួមមានពានរង្វាន់សមិទ្ធិផល និងពានរង្វាន់អភិវឌ្ឍន៍។ កម្រិតបន្តបន្ទាប់ទៀតផ្តល់ជូននូវពានរង្វាន់សម្រាប់ការអនុវត្តល្អបំផុត-ពានរង្វាន់សមិទ្ធិផលប្រកបដោយនិរន្តភាព និងពានរង្វាន់អភិវឌ្ឍន៍ដ៏លេចធ្លោ។

ផ្អែកតាមប្រសាសន៍របស់សាស្ត្រាចារ្យ **លី ស៊ីងគង់** (Dr.Lee Sing Kong) អតីតនាយកវិទ្យាស្ថានជាតិអប់រំសឹង្ហបូរី ស្តីពី "**បណ្តុះបណ្តាលគ្រូបង្រៀនសតវត្សរ៍ទី២១ ករណីសិក្សាប្រទេសសឹង្ហបូរី**" កាលពីថ្ងៃទី១៥ ដល់ទី១៩ ខែឧសភា ឆ្នាំ២០១៧ លោកបានបញ្ជាក់ថា ការអប់រំចំណោះទូទៅការបណ្តុះបណ្តាលគ្រូបង្រៀន ក៏ដូចជាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀននៅតែបន្តធ្វើការផ្លាស់ប្តូរកែលម្អជាបន្តបន្ទាប់ ដើម្បីឆ្លើយតបនឹងនិន្នាការផ្លាស់ប្តូរ

នៅក្នុងទីផ្សារពិភពលោក។ ស្ថិតក្នុងបរិបទនៃប្រព័ន្ធអប់រំថ្នាក់ជាតិដែលគ្រប់គ្រងដោយថ្នាក់កណ្តាល(ថ្នាក់ជាតិ) កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបានធ្វើកំណែទម្រង់ជាច្រើនលើកច្រើនសារ នៅប៉ុន្មានទសវត្សរ៍ចុងក្រោយនេះដើម្បីអភិវឌ្ឍន៍ឱ្យមានភាពល្អប្រសើរ មិនត្រឹមតែឆ្លើយតបទៅនឹងការផ្លាស់ប្តូរបរិស្ថានអប់រំប៉ុណ្ណោះទេ ប៉ុន្តែក៏ក្បាលម៉ាស៊ីននៃការផ្លាស់ប្តូរវិស័យនេះទាំងមូល។ លោកបានលើកឡើងពីតួនាទី និងការទទួលខុសត្រូវរបស់វិទ្យាស្ថានជាតិអប់រំ-បណ្ឌិតសភាគ្រូបង្រៀន (the Academy of Singapore Teachers-AST) ទំនាក់ទំនងត្រីភាគី (ក្រសួងអប់រំ វិទ្យាស្ថានជាតិអប់រំ និងសាលារៀន)និងកំណែទម្រង់នានាក្នុងការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន និងគុណភាពអប់រំ [19]។

**វិទ្យាស្ថានជាតិអប់រំ** (NIE) គឺគ្រឹះស្ថានអប់រំគ្រូបង្រៀនតែមួយគត់នៅក្នុងប្រទេសសឹង្ហបូរី ហើយគ្រូបង្រៀនមុនពេលបម្រើការងារត្រូវបានបណ្តុះបណ្តាលនៅស្ថាប័នមួយនេះ។ គ្រូបង្រៀនត្រូវបានបំពាក់បំប៉នសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញតួនាទី និងការទទួលខុសត្រូវរបស់ពួកគេនៅក្នុងថ្នាក់រៀន និងចូលរួមចំណែកពង្រឹងគុណភាពអប់រំ។ ជានិច្ចកាលសឹង្ហបូរីយកចិត្តទុកដាក់ខ្លាំង ក្នុងការបណ្តុះបណ្តាលកសាងសមត្ថភាពគ្រូបង្រៀនបង្កើតនូវគុណតម្លៃ និងឥរិយាបថត្រឹមត្រូវ ដែលគន្លឹះស្នូលក្នុងការអនុវត្តកំណែទម្រង់ប្រព័ន្ធអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាព។ NIE មានតួនាទី និងការទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនមុនបម្រើការងារ (Pre-service teacher) អភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនដែលកំពុងបំពេញការងារ (In-service teacher) និងកម្មវិធីសិក្សាកម្រិតសញ្ញាប័ត្រ

(Degree program)។ សាស្ត្រាចារ្យ **លី** បានបន្តសង្កត់ធ្ងន់ពីតួនាទី និងភារកិច្ចរបស់គ្រូបង្រៀន / អ្នកឯកទេសអប់រំក្នុងការជំរុញឱ្យសិស្សានុសិស្សយល់ពីអត្ថន័យនៃការអប់រំ។ ដូច្នេះពួកគេត្រូវមានការលើកទឹកចិត្តឱ្យចូលរួមយ៉ាងពេញលេញក្នុង **"ការរៀនតាមរយៈការលើកទឹកចិត្ត និងការបំផុសគំនិត"**

**ជារួមគឺធ្វើឱ្យសិស្សយល់ដឹងច្បាស់ពី៖**

- ការអប់រំគឺជាកាតព្វកិច្ចរបស់ពលរដ្ឋដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។
- ការអប់រំគឺជាដំណើរការនៃការទទួលបានចំណេះដឹង ជំនាញ និងអាកប្បកិរិយា។
- ការអប់រំគឺជារតនសម្បត្តិដ៏មានតម្លៃដែលដូនតាបន្សល់ទុកជាកេរ្តិ៍ដំណែលសម្រាប់អនុជនជំនាន់ក្រោយ។
- ការអប់រំគឺជាភាពចាំបាច់ដែលឆ្លើយតបទៅនឹងនិន្នាការសង្គម និងសកល។
- ការអប់រំមិនមែនផ្តោតតែជាការសិក្សា និងការទទួលបានពិន្ទុល្អនោះទេ។ វាជាមធ្យោបាយមួយដ៏ពិតប្រាកដក្នុងការរកឃើញនូវអ្វីដែលថ្មី និងមិនដឹង។
- ការអប់រំមិនមែនមានន័យថា នឹងទៅរៀននៅសាកលវិទ្យាល័យល្បីៗ ឬសាលាដែលមានតម្លៃថ្លៃនោះទេ ។

**លើសពីនេះទៀត លោកបានលើកឡើងបន្ថែមទៀតពីសារៈសំខាន់នៃការអប់រំរបស់សឹង្ហបូរីដូចខាងក្រោម៖**

- ការអប់រំផ្តល់ឱ្យយើងនូវចំណេះដឹងកាន់តែស៊ីជម្រៅ និងទូលំទូលាយនៃពិភពលោកជុំវិញខ្លួន
- ការអប់រំផ្តល់ឱ្យនូវជំនាញក្នុងការដោះស្រាយបញ្ហាដែលកើតឡើងដោយឥតព្រៀងទុក
- ការអប់រំជួយឱ្យរួចផុតពីការភ័យខ្លាចដោយមិនសមហេតុផល
- ការអប់រំជួយឱ្យមានគុណតម្លៃខ្ពស់នៃជីវិតរស់នៅ និងជីវិតផ្សេងៗទៀត
- ការអប់រំផ្តល់ឱ្យយើងនូវឱកាសការងារជាច្រើនរាប់មិនអស់ហើយជំរុញភាពរីកចម្រើនសេដ្ឋកិច្ច
- ការអប់រំគឺជាលិខិតឆ្លងដែនដែលអនុញ្ញាតឱ្យធ្វើដំណើរហួសលើសពីការរំពឹងទុកដើម្បីជាប្រយោជន៍ដល់ការលម្ហែកំសាន្ត ការសិក្សារៀនសូត្របន្ថែម ការលើកតំកើង ឬការតែងតាំងជាដើម។
- ការអប់រំជួយយើងរក្សាអត្តសញ្ញាណជាតិសាសន៍

**សឹង្ហបូរីបានយកចិត្តទុកដាក់ខ្លាំងក្នុងការលើកកម្ពស់គុណវុឌ្ឍិ និងអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនដូចការបកស្រាយសង្ខេបខាងក្រោម៖**

**ការជ្រើសរើសគ្រូបង្រៀន**

នៅសឹង្ហបូរីការជ្រើសរើសគ្រូបង្រៀនដែលមានលទ្ធផលសិក្សាខ្ពស់ជាជម្រើសល្អមួយ តែការប្តេជ្ញាចិត្តប្រកបដោយមនសិការវិជ្ជាជីវៈគ្រូបង្រៀន និងការបម្រើសេវាកម្មក្នុងអាជីពគ្រូបង្រៀនចំពោះសិស្សដែលមាន

ភាពផ្សេងៗគ្នាជាផ្នែកសំខាន់។ ក្នុងពេលហ្វឹកហាត់ការងារ គ្រូបង្រៀនទទួលប្រាក់ឧបត្ថម្ភស្មើនឹង ៦០% នៃប្រាក់ខែគ្រូបង្រៀនសរុប ហើយត្រូវប្តេជ្ញាចិត្តក្នុងការបង្រៀនសិស្សយ៉ាងហោចណាស់៣ឆ្នាំ។ ក្នុងអំឡុងពេលហ្វឹកហាត់ការងារ ពួកគេនឹងត្រូវបានគេវាយតម្លៃការបំពេញការងាររបស់ខ្លួនប្រចាំឆ្នាំ ក្នុងរយៈ ពេល៣ឆ្នាំដើម្បីក្លាយជាគ្រូពេញសិទ្ធិ និងបែងចែកទៅតាមគន្លងអាជីពដែលបានកំណត់ ព្រមទាំងទទួលបានប្រាក់បៀវត្ស ១០០%ពេញ។

## អត្ថប្រយោជន៍ទទួលបាន

ជារៀងរាល់ឆ្នាំ ក្រសួងអប់រំពិនិត្យលើប្រាក់កម្រៃចាប់ផ្តើមការងារ និងអាចកែប្រែប្រាក់ខែរបស់គ្រូបង្រៀនដើម្បីធានាថាការបង្រៀនត្រូវបានគេមើលឃើញថាមានភាពទាក់ទាញស្មើភាពគ្នាចំពោះមុខរបរផ្សេងៗទៀតសម្រាប់និស្សិតទើបបញ្ចប់ការសិក្សា។ ប្រាក់ខែគ្រូបង្រៀនមិនមានការកើនឡើងច្រើនជាងអាជីពផ្សេងទៀតទេប៉ុន្តែមានឱកាសជាច្រើនសម្រាប់គ្រូបង្រៀន អនុគ្រោះក្នុងតួនាទីផ្សេងទៀតដូចបានរៀបរាប់ខាងក្រោម។

## ការអភិវឌ្ឍវិជ្ជាជីវៈ

នៅប្រទេសសិង្ហបុរីសាលារៀនគឺជាមជ្ឈមណ្ឌលនៃការបង្រៀនពីនវានុវត្តន៍ (ការច្នៃបង្កើតថ្មី-Innovation)។ ការអភិវឌ្ឍវិជ្ជាជីវៈទាំងអស់ត្រូវបានរៀបចំ និងអនុវត្តដោយគ្រូបង្រៀនដើម្បីគ្រូបង្រៀនសម្រាប់ទាំងអស់គ្នា។ គ្រូបង្រៀនមានពេលវេលាច្រើនដើម្បីធ្វើការលើកកម្ពស់ជំនាញវិជ្ជាជីវៈផ្ទាល់ខ្លួន។ គ្រូបង្រៀនមានសិទ្ធិទទួលបានការបណ្តុះបណ្តាលជំនាញរយៈពេល១០០ម៉ោងក្នុងមួយឆ្នាំដែលអាចបានអនុវត្តតាមវិធីផ្សេងៗជាច្រើន។ វគ្គសិក្សានៅវិទ្យាស្ថានអប់រំជាតិផ្តោតលើបញ្ហានៅតាមមុខវិជ្ជា ចំណេះដឹងផ្នែកគរុកោសល្យ និងវគ្គសិក្សាដែលបង្កើនកម្រិតសញ្ញាប័ត្ររបស់គ្រូ

បង្រៀន។ ភាគច្រើននៃការអភិវឌ្ឍន៍វិជ្ជាជីវៈគឺផ្អែកលើមូលដ្ឋានសាលារៀន ដែលដឹកនាំដោយអ្នកអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកនៅតាមសាលារៀន។ ការងារនេះត្រូវបានរៀបចំឡើងដើម្បី ដឹងពីបញ្ហាទាំងឡាយដែលកើតមាននៅក្នុងសាលារៀន ឧទាហរណ៍ដូចជា៖ បញ្ហារបស់ក្រុមបច្ចេកទេសតាមមុខវិជ្ជា ការណែនាំការវិធីសាស្ត្របង្រៀន ឬការអនុវត្តថ្មីៗដូចជា៖ ការរៀនមានមូលដ្ឋានផ្អែកលើគម្រោង (project-based learning) ឬការប្រើប្រាស់ ICT ថ្មី។ សាលារៀននីមួយៗក៏មានមូលនិធិផ្ទាល់ខ្លួនសម្រាប់ជួយទ្រទ្រង់ដល់ការបង្កើនគុណវុឌ្ឍិគ្រូបង្រៀន ដូចជា៖ការបង្កើនចំណេះដឹងថ្មីៗ តាមរយៈការទស្សនកិច្ចសិក្សាទៅក្រៅប្រទេសដើម្បីស្វែងយល់ពីទិដ្ឋភាពអប់រំជាដើម។ មជ្ឈមណ្ឌលគ្រូបង្រៀនសិង្ហបុរីបើកនៅឆ្នាំ២០១០ ដើម្បីលើកទឹកចិត្តដល់គ្រូបង្រៀនបន្តចែករំលែកនូវការអនុវត្តល្អៗ។

## ការវាយតម្លៃលើការងារ

ដូចវិជ្ជាជីវៈដទៃទៀតដែរ នៅក្នុងប្រទេសសិង្ហបុរីការបំពេញការងាររបស់គ្រូបង្រៀនត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំដោយក្រុមការងារជាច្រើន និងប្រើប្រាស់វិធានការផ្សេងៗច្រើនផងដែរ រួមទាំងការរួមចំណែករបស់ពួកគេចំពោះការអភិវឌ្ឍការសិក្សារៀនសូត្រ និងការអភិវឌ្ឍបុគ្គលិកលក្ខណៈសិស្សទាំងអស់ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ពួកគេ វាយតម្លៃពីកិច្ចសហការនានាជាមួយឪពុកម្តាយ និងក្រុមសហគមន៍ និងការរួមចំណែករបស់ពួកគេដល់សហសេវិករបស់ពួកគេ និងក៏ដូចជាសាលារៀនទាំងមូល។ គ្រូដែលធ្វើការងារឆ្នើមទទួលបានប្រាក់រង្វាន់ពីសាលា។ ឧបករណ៍វាយតម្លៃមានលក្ខណៈស្តង់ដារដែលរៀបចំឡើងដោយក្រសួងអប់រំ។ ចំណែកឯនៅប្រទេសកម្ពុជាវិញ យន្តការនៃការវាយតម្លៃហាក់មិនដំណើរការសោះ។ ការឡើងកាំប្រាក់គឺឡើងជាទៀងទាត់២ឆ្នាំម្តងៗ ដោយមិនផ្អែកសំខាន់លើការវាយតម្លៃលទ្ធផលបំពេញការងារឡើយ ហើយពេល

ខ្លះ ថែមទាំងមិនដឹងថា ការវាយតម្លៃនេះយកទៅ ប្រើប្រាស់ធ្វើអ្វីផង។ ការអនុវត្តនីតិវិធីមិនច្បាស់បែបនេះ ហាក់មិនបានលើកទឹកពេញលេញដល់គ្រូបង្រៀនដែលយកចិត្តទុកបំពេញការងារខ្លួនបានយ៉ាងល្អ និងជំរុញសន្ទុះនៃការផ្លាស់ប្តូរជាវិជ្ជមាននូវសមត្ថភាព និងឥរិយាបថរបស់ពួកគាត់ចំពោះការងារ។ ផ្ទុយទៅវិញ វានាំទៅរកការបាក់ទឹកចិត្ត កង្វះមនសិការវិជ្ជាជីវៈ មានទម្លាប់ខ្ជិលច្រអូសក្នុងការបំពេញការងារ...។ល។ បើយើងនិយាយឱ្យងាយស្រួលយល់គឺ ទោះខំប្រឹងប្រែង ឬ មិនខំប្រឹងប្រែងក៏លទ្ធផលដូចគ្នា បានឡើងកាំប្រាក់ដូចគ្នា។ ករណីនេះ យើងគួរគិតគួរកែលម្អឡើងវិញ ប្រកបដោយយុទ្ធសាស្ត្រច្បាស់លាស់ ដោយមានមេរៀនពីប្រទេសសឹង្ហបូរីនេះស្រាប់!

## ការអភិវឌ្ឍអាជីព

ទេពកោសល្យត្រូវបានកំណត់ និងអប់រំ ជាជាងទុកចោលរង់ចាំឱកាស។ បន្ទាប់ពីការបង្រៀនរយៈពេល ៣ ឆ្នាំ គ្រូបង្រៀនត្រូវបានគេវាយតម្លៃជារៀងរាល់ឆ្នាំដើម្បីមើលថាតើពួកគេមានសក្តានុពលសម្រាប់គន្លងអាជីពណាមួយក្នុងចំណោម៣ (១)គ្រូបង្រៀនដែលស្ទាត់ជំនាញ អ្នកឯកទេសផ្នែកកម្មវិធីសិក្សា (២)អ្នកស្រាវជ្រាវ ឬ (៣)ថ្នាក់គ្រប់គ្រង និងដឹកនាំសាលារៀន ដែលម្នាក់ៗនឹងទទួលបានប្រាក់ខែពេញ១០០%។ គ្រូបង្រៀនដែលមានសក្តានុពលធ្វើជាថ្នាក់ដឹកនាំសាលាត្រូវបានផ្លាស់ប្តូរទៅកាន់ក្រុមអ្នកគ្រប់គ្រងថ្នាក់កណ្តាលហើយទទួលបានការបណ្តុះបណ្តាលដើម្បីរៀបចំ សម្រាប់តួនាទីថ្មីនេះ។ ការបំពេញការងាររបស់អ្នកគ្រប់គ្រងថ្នាក់កណ្តាលនេះ ត្រូវបានវាយតម្លៃពីសក្តានុពលរបស់ពួកគេដើម្បីក្លាយជាជំនួយការនាយក ហើយក្រោយមកនឹងក្លាយនាយកសាលា។ ដំណាក់កាលនីមួយៗមានបទពិសោធន៍ និងការបណ្តុះបណ្តាលជាច្រើនដើម្បីរៀបចំបេក្ខភាពសម្រាប់ការដឹកនាំ និងការផ្លាស់ប្តូររបស់សាលា។ មានការយល់ដឹង

ច្បាស់លាស់ថាការបង្រៀនដែលមានគុណភាពខ្ពស់ និងលទ្ធផលសិក្សាសិស្សល្អ ទាមទារឱ្យអ្នកដឹកនាំសាលាមានគុណវុឌ្ឍិគ្រប់គ្រាន់។ ដោយសារការជ្រើសរើសអ្នកដែលមានសមត្ថភាពដើម្បីធ្វើជាគ្រូបង្រៀន ការផ្តល់វគ្គបណ្តុះបណ្តាលដ៏មានគុណភាព ការបន្តជួយគាំទ្រ និងយន្តការច្បាស់លាស់ធ្វើឱ្យប្រព័ន្ធអប់រំសឹង្ហបូរីជោគជ័យខ្លាំង[20]។ សម្រាប់ប្រទេសកម្ពុជា ការរៀបចំគោលនយោបាយគន្លងអាជីពគ្រូបង្រៀន និងផែនការអភិវឌ្ឍន៍សមត្ថភាពថ្នាក់ដឹកនាំអប់រំគ្រប់លំដាប់ថ្នាក់ ក៏ដូចគ្នាការប្រឡងជ្រើសរើសបេក្ខជននាយកសាលាដើម្បីទទួលបានការបណ្តុះបណ្តាលសមត្ថភាពនៅវិទ្យាស្ថានជាតិអប់រំដែលអនុវត្តនៅឆ្នាំ២០១៧ថ្មីនេះ គឺយកលំនាំតាមប្រទេសសឹង្ហបូរីនេះឯង។វាជារបត់នៃការផ្លាស់ប្តូរដ៏ធំមួយសម្រាប់លើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ។

## 1.7) សន្និដ្ឋានជារួម

សឹង្ហបូរីបានធ្វើការកំណែទម្រង់អប់រំបានលឿន និងភ្ជាប់ទំនាក់ទំនងមូលធនមនុស្សទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងជាតិក្នុងការបង្កើត និងអនុវត្តគោលនយោបាយអប់រំ។ ដំណើរការកំណែទម្រង់ត្រូវបានរៀបចំ និងអនុវត្តបានទាន់ពេលវេលា និងមានលក្ខណៈល្អប្រសើរជាងប្រទេសកម្ពុជា ហើយតុល្យភាពយេនឌ័រក្នុងវិស័យអប់រំមានលក្ខណៈល្អប្រសើរ ហើយចំណាយសាធារណៈលើវិស័យអប់រំរបស់សឹង្ហបូរីក៏មានចំនួនច្រើនជាងប្រទេសកម្ពុជាដែរ។ សឹង្ហបូរីបានកសាងប្រព័ន្ធអប់រំសមស្របទៅនឹងតម្រូវការនយោបាយ សង្គម ហើយប្រព័ន្ធអប់រំនេះ បាននាំមកនូវភាពជោគជ័យជាច្រើនបម្រើដល់ការរីកចម្រើន និងការអភិវឌ្ឍសង្គមជាតិ ដែលលទ្ធផលស្តែងឡើងតាមរយៈភាពរឹងមាំរបស់សាលារៀន អត្រាបោះបង់ការសិក្សា

ត្រូវបានកាត់បន្ថយ លទ្ធផលសិក្សារបស់សិស្សត្រូវបានលើកកម្ពស់ ការបណ្តុះបណ្តាលគ្រូ និងនាយកសាលារៀនបានល្អ។ ការផ្លាស់ប្តូរចម្បងៗនេះបានរៀបចំយុវជនវ័យក្មេងសម្រាប់សេដ្ឋកិច្ចដែលមានមូលដ្ឋានលើចំណេះដឹង នៅក្នុងដំណើរការដែលធ្វើឱ្យនិរន្តរភាពនៃជំហប្រកួតប្រជែងកម្រិតពិភពលោករបស់សឹង្ហបូរី ពង្រឹងអត្តសញ្ញាណជាតិ (ជាតិនិយម) គុណតម្លៃ និងវិបុលភាពសង្គម នៅក្នុងដំណើរការទ្រទ្រង់សង្គមចម្រុះជាតិសាសន៍ ពហុវប្បធម៌។ ករណីសិក្សារបស់សឹង្ហបូរីបង្ហាញថា ការអប់រំ និងការរៀបចំសម្រាប់ការរៀនសូត្រពេញមួយជីវិតគឺជាអាទិភាពថ្នាក់ជាតិ ភាពជាអ្នកដឹកនាំនយោបាយដ៏រឹងមាំ និងប្រកបដោយធន្ទៈបានដឹកនាំការអភិវឌ្ឍវិស័យអប់រំទាំងអស់ និងបានបង្កើតរចនាសម្ព័ន្ធ និងប្រព័ន្ធមួយដែលមានភាពជាប់ទាក់ទង ព្រមទាំងឆ្លើយតបទៅនឹងបរិបទសេដ្ឋកិច្ច និងសង្គមដែលមានការផ្លាស់ប្តូរជានិច្ច។



## សង្ខេបគំនិតសំខាន់ៗ

### គោលបំណងនៃការអប់រំសឹង្ហបូរី

- **សេដ្ឋកិច្ច៖** ចេញពីសេដ្ឋកិច្ចឃ្លាំងស្តុក ទៅសេដ្ឋកិច្ចនាំចេញ
- **សង្គម៖** ពង្រីកឯកភាពជាតិរវាងក្រុមជនជាតិទាំងឡាយ
- **អប់រំ៖** កសាងប្រព័ន្ធអប់រំសមស្របដែលឆ្លើយតបទៅនឹងតម្រូវការនយោបាយ និងសង្គម

### ដើម្បីជោគជ័យផ្នែកសេដ្ឋកិច្ច ប្រព័ន្ធអប់រំសឹង្ហបូរី បានផ្តោតសំខាន់លើ៖

- ការភ្ជាប់ទំនាក់ទំនងរវាងកម្លាំងពលកម្ម និងអាទិភាពសេដ្ឋកិច្ច
- ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- ការអប់រំភាសាអង់គ្លេសដើម្បីងាយស្រួលទាក់ទងនឹងអ្នកវិនិយោគ និងស្វែងរកទីផ្សារនាំចេញ
- ផលិតកម្លាំងពលកម្មស្របនឹងជំនាញឧស្សាហកម្មដែលទាក់ទង

**ការផ្តួចផ្តើមថ្មីសម្រាប់វិស័យអប់រំ ១៩៨៧-បច្ចុប្បន្ន**

ឆ្ពោះទៅរកភាពឥតខ្ចោះនៃការប្រើប្រាស់នៃការអប់រំ (បង្អួចបើកចំហសម្លឹងមើលពិភពលោក)ពង្រីកកិច្ចប្រឹងប្រែងខ្លួនដើម្បីឈានដល់កម្រិតស្តង់ដារ-ឱ្យសាលារៀនឯករាជ្យ បន្ទាប់មកស្វ័យគ្រប់គ្រងដោយខ្លួនឯង

- **គិតពីសាលា សិក្សាពីជាតិ** (Thinking School, Learning Nation) ៖ណែនាំពីការគិតបែបច្នៃប្រឌិត និងគិតបែបសមហេតុផល ភាពចម្រុះនៃ កម្មវិធីសិក្សា ភាពផ្សេងៗគ្នានៃរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង (សាលារៀនមានភាព ឯករាជ្យ និងស្វ័យភាព ការបង្កើតកម្រងសាលារៀន) ផ្តល់ធនធានដើម្បីលើកទឹកចិត្តច្នៃបង្កើតថ្មី លើកកម្ពស់ការអប់រំគ្រូបង្រៀន លក្ខខណ្ឌការងារ និងសេវាកម្ម។
- **ផែនការគោល បច្ចេកវិទ្យាព័ត៌មាន** (IT Master Plan)៖ ការទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យា ព័ត៌មានវិទ្យា និងសារគមនាគមន៍ ដើម្បីផ្តល់ដល់សិស្សលទ្ធភាពទទួលបានព័ត៌មានថ្មី និងអាចរៀនសូត្របានគ្រប់ទីកន្លែង គ្រប់ពេលវេលា
- **ការអប់រំជាតិ** (National Education)៖ រៀបចំឡើងដើម្បីឱ្យសិស្សមានការយល់ដឹងពីប្រវិត្តសាស្រ្ត ពង្រឹងប្តេជ្ញាចិត្តក្នុងភាពជាពលរដ្ឋ រក្សា និងការពារគុណតម្លៃស្នូលរបស់សឹង្ហបូរី។ សឹង្ហបូរីបានធ្វើការកំណែទម្រង់ប្រព័ន្ធអប់រំពីរឹងត្អឹងទៅប្រព័ន្ធអប់រំមួយដែលមានលក្ខណៈបត់បែន និងផ្តោតលើការទទួលខុសត្រូវវិទ្យាស្ថានអប់រំបច្ចេកទេស (ITE)

**ការកសាងសមត្ថភាពគ្រូបង្រៀន**

- ផ្តល់ឱកាសច្រើនដល់ការសិក្សាថ្នាក់ក្រោយបរិញ្ញាប័ត្រ
- បណ្តាញគ្រូ បង្រៀន បណ្ឌិតសភាពគ្រូបង្រៀន
- គន្លងអាជីពគ្រូបង្រៀន
- ក្លាយជាគ្រូសកម្មក្នុងការសិក្សាស្រាវជ្រាវ
- អភិវឌ្ឍន៍កម្មវិធីសិក្សាផ្អែកលើសាលារៀន
- បណ្តុះបណ្តាលជាប្រព័ន្ធសម្រាប់ថ្នាក់ដឹកនាំសាលារៀន

**លទ្ធផលនៃកំណែទម្រង់ប្រព័ន្ធអប់រំ**

- សឹង្ហបូរីបានបង្កើតនូវប្រព័ន្ធដែលជំរុញឱ្យសិស្សបញ្ចប់មធ្យមសិក្សាបន្តការសិក្សានៅការអប់រំកម្រិតខ្ពស់បានច្រើន ទាំងការបណ្តុះបណ្តាលនិងការអប់រំ
- សិស្សកាន់តែច្រើនមាន ឱកាសសិក្សាជំនាញបច្ចេកទេស វិជ្ជាជីវៈមានទំនាក់ទំនងជិតស្និទ្ធរវាងសេដ្ឋកិច្ច និងការអប់រំ
- សម្រេចលទ្ធផលកម្រិតខ្ពស់ផ្នែកវិទ្យាសាស្ត្រ គណិតវិទ្យា និងការអប់រំភាសា
- កម្លាំងពលកម្មភាពជំនាញច្បាស់លាស់
- វប្បធម៌ស្រាវជ្រាវត្រូវបានបង្កើតឡើង
- សឹង្ហបូរី ផ្តល់ការបណ្តុះបណ្តាល និងបំប៉នឡើងវិញពេញមួយជីវិតសម្រាប់រាល់គ្រូបង្រៀនគ្រប់រូប និងថ្នាក់ដឹកនាំសាលារៀន

❖ ក្រោយឯករាជ្យពីអង់គ្លេស ប្រទេសថ្មីនេះមានបញ្ហាប្រឈមមួយចំនួនរបស់ខ្លួនដូចជា៖ ភាពក្រីក្រភាពតានតឹង និងជំលោះរវាងជនជាតិដើមភាគតិចបង្កការរាំងស្ទះយ៉ាងធ្ងន់ធ្ងរដល់ការសម្រេចគោលដៅគោលដៅរបស់ខ្លួន។ វាស្ថិតនៅក្នុងបរិបទនេះដែលប្រទេសសិង្ហបុរីបានបង្កើតប្រព័ន្ធអប់រំរបស់ខ្លួនដែលមានធាតុចាំបាច់បី។ ទី១គឺផ្តល់ឱ្យសិស្សនូវស្មារតីអត្តសញ្ញាណជាតិខ្លួន និងបញ្ចូលនូវគុណតម្លៃនៃសញ្ជាតិ។ ភាពទំនាស់រវាង អន្តរជាតិនិយម និងភាពចម្រុះផ្សេងៗគ្នា ជា

ផ្នែកមួយនៃការថ្លឹងថ្លែងដែលមានលក្ខណៈទោរទន់រៀងៗខ្លួនសម្រាប់សិស្សភាគច្រើន។ ទី ២- គឺនៅតែជាសង្គមពហុភាសា។ សាលារៀនបានផ្តល់ការបង្រៀនជាភាសាអង់គ្លេស - ភាសាពាណិជ្ជកម្ម និងបច្ចេកវិទ្យាក៏ដូចជាភាសាផ្លូវការមួយក្នុងចំណោមភាសាផ្លូវការបីគឺម៉ាឡេ ចិន ឬតាមីល។ ទី៣ -សាលារៀនបានសង្កត់ធ្ងន់លើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ សិង្ហបុរីខ្វះចន្លោះនិងធនធានធម្មជាតិដើម្បីក្លាយជាសេដ្ឋកិច្ចឧស្សាហកម្ម។ វាត្រូវទាក់ទាញឧស្សាហកម្មចំណេះដឹងដូចជាធនាគារវិស្វកម្ម និងបច្ចេកវិទ្យាដើម្បីធ្វើអាជីវកម្មនៅទីនោះ។ ស្ថិតនៅអាយុមិនដល់៣០ឆ្នាំផង ប្រជាជាតិវ័យក្មេងមួយនេះបានអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ដំបូងរបស់ខ្លួន។ នៅឆ្នាំ ១៩៩៧ អង្គការនេះបានចេញផ្សាយផែនការអប់រំថ្មីមួយដែលមានចំណងជើងថា Thinking Schools, Learning Nation។ វាបានអំពាវនាវឱ្យពង្រឹងកម្លាំងនៃការបង្រៀនរបស់ខ្លួនដោយផ្តល់នូវស្វ័យភាពកាន់តែច្រើនដល់សាលារៀន និងទទួលបានជោគជ័យ។ មេរៀនរៀនសូត្រ៖ ផែនការសិង្ហបុរីត្រូវបានជំរុញដោយសេចក្តីត្រូវការនៃអនាគតមិនមែនជាភាពជាក់ស្តែងពីអតីតកាលទេ។ ពួកគេបានបង្កើតនូវប្រព័ន្ធនៃការរំពឹងទុកយ៉ាងច្បាស់លាស់ដែលអនុញ្ញាតឱ្យមានការរីកចម្រើនជំនាញវិជ្ជាជីវៈនិងទទួលបានជោគជ័យតាមរយៈមធ្យោបាយមួយចំនួន។

- ស្ថេរភាពនយោបាយ ធ្វើឱ្យការរៀបចំ និងអនុវត្តកំណែទម្រង់អប់រំទទួលបានលទ្ធផលជោគជ័យ ប្រកបដោយគុណភាព និងប្រសិទ្ធភាព។
- កំណែទម្រង់ប្រព័ន្ធអប់រំផ្សារភ្ជាប់នឹងស្ថានភាពសេដ្ឋកិច្ច ទីផ្សារការងារ និងតម្រូវការសង្គមជាក់ស្តែង។ ជាទូទៅ សឹង្ហបូរីមានមហិច្ឆិតាធ្វើឱ្យសេដ្ឋកិច្ចខ្លួនរីកចម្រើនខ្លាំង បង្កើតក្តីសង្ឃឹម និងរូបរាងសេដ្ឋកិច្ចខ្លួន

សម្រាប់អនាគត រួចរៀបចំប្រព័ន្ធអប់រំ ឆ្លើយតបទៅនឹងគោលដៅនោះ ។

- ភាសាអង់គ្លេសជាភាសាយានក្នុងការសិក្សា ហើយភាសាកំណើតជាភាសាទី២។ ភាសាអង់គ្លេសជាគន្លឹះនៃទំនាក់ទំនងជាសាកល និងផ្តល់ភាពងាយស្រួលច្រើនដល់សឹង្ហបូរីក្នុងការធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ។
- សឹង្ហបូរីមានផែនការចង់ប្រែក្លាយជាប្រទេសនៃមជ្ឈមណ្ឌលវិទ្យាសាស្ត្រសាកល។
- សឹង្ហបូរីដាក់បញ្ចូលគំនិតជាតិនិយមនៅក្នុងកម្មវិធីសិក្សាដើម្បីរួបរួមជាតិ និងឯកភាពជាតិ ហើយដាក់បញ្ចូលសាកលភាវូបនីយកម្មដើម្បីធ្វើការប្រកួតប្រជែងសេដ្ឋកិច្ចក្នុងតំបន់ និងសាកល។
- សឹង្ហបូរីមិនត្រឹមតែរៀបចំប្រព័ន្ធអប់រំសម្រាប់កម្រិតជាតិប៉ុណ្ណោះ ប៉ុន្តែក៏សម្រាប់កម្រិតអន្តរជាតិផងដែរ ពោលគឺផលិតមូលធនមនុស្សដែលមានសមត្ថភាពអាចធ្វើការកម្រិតអន្តរជាតិបាន។
- សឹង្ហបូរី តម្រង់ទិសវិជ្ជាជីវៈកុមារតាំងពីកម្រិតបឋមសិក្សា ហើយនៅកម្រិតមធ្យមសិក្សាបឋមភូមិ សិស្សរៀននៅក្រុមថ្នាក់រៀនមួយដែលមានការបែងចែកទៅតាមសមត្ថភាព និងឧបនិស្ស័យរបស់ពួកគេ។ នេះមានន័យថា សិស្សពូកែរៀនជាមួយសិស្សពូកែ កម្មវិធីសិក្សាសម្រាប់សិស្សពូកែ សិស្សនិទ្ទេសមធ្យម រៀនជាមួយសិស្សមធ្យម ហើយសិស្សខ្សោយរៀនជាមួយសិស្សខ្សោយដូចគ្នា។
- ចំនួនម៉ោងសិក្សានៅសឹង្ហបូរី តិចជាងប្រទេស និងទីក្រុងនានានៅតំបន់អាស៊ីខាងកើតដែលមានចំណាត់ថ្នាក់លទ្ធផលវាយតម្លៃសិស្ស-និស្សិតកម្រិតអន្តរជាតិ(PISA)ខ្ពស់ តែសឹង្ហបូរីក៏ទទួលបានចំណាត់ខ្ពស់ផងដែរ។ នេះបញ្ជាក់ថា ប្រព័ន្ធអប់រំសឹង្ហបូរីមានគុណភាពខ្ពស់។

- សឹង្ហបូរីលើកកម្ពស់ការសិក្សាពេញមួយជីវិត តាមរយៈដាក់បញ្ចូលការសិក្សាបច្ចេកវិទ្យា ព័ត៌មានវិទ្យាទៅក្នុងប្រព័ន្ធអប់រំ ដែលផ្តល់ឱកាសដល់សិស្ស-និស្សិតមានលទ្ធផលទទួលបានព័ត៌មាន និងការសិក្សារៀនសូត្រនៅគ្រប់ទីកន្លែង និងពេលវេលា ហើយគំនិតនេះ បានផ្តួតផ្តើមតាំងពីឆ្នាំ១៩៩៧។
- សិស្សស្រីចូលសិក្សាការអប់រំកម្រិតខ្ពស់មានជាង៥០%។ យេនឌ័រមានការរីកចម្រើនខ្លាំង។
- សឹង្ហបូរីធ្វើការរួមគ្នាយ៉ាងស្អិតរមួតរវាងក្រសួងអប់រំ ក្រសួងនានា និងអ្នកពាក់ព័ន្ធគ្រប់មជ្ឍដ្ឋានក្នុងការកែទម្រង់ប្រព័ន្ធអប់រំ ឆ្លើយតបទៅនឹងសេដ្ឋកិច្ច និងតម្រូវការសង្គម។
- ឪពុកម្តាយ ឬអ្នកអាណាព្យាបាលសឹង្ហបូរី ភាគច្រើនយកចិត្តទុកដាក់ខ្លាំង និងដាក់សម្ពាធដល់កូនដើម្បីឱ្យកូនទទួលបានលទ្ធផលសិក្សាល្អ ហើយអាចចូលរៀននៅសាលារៀនល្បីៗបាន។ និន្នាការនេះ ត្រូវបានអនុវត្តយ៉ាងទូទៅនៅប្រទេសដែលមានលទ្ធផលតេសPISA ល្អដូចជា ៖ កូរ៉េខាងត្បូង ជប៉ុន និងក្រុងហុងកុងជាដើម។ ពោលគឺដើម្បីសម្រេចបានភាពជោគជ័យនៃការអប់រំ មិនអាចកាត់ផ្តាច់បានពីការដាក់សម្ពាធដែលជាកត្តាជំរុញឱ្យសន្ទុះនៃការខិតខំប្រឹងប្រែងកើនឡើងខ្លាំងក្លា។ នេះជាអ្វីមួយដែលកម្ពុជាត្រូវរៀនសូត្រ។
- សឹង្ហបូរីដែលយកចិត្តទុកដាក់ខ្លាំងក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដើម្បីឆ្លើយតបទៅនឹងតម្រូវការនយោជក ។
- មាននីតិវិធីច្បាស់លាស់ក្នុងការជ្រើសរើស ឬតែងតាំងនាយកសាលាមានការវាយតម្លៃគុណសម្បត្តិការបំពេញការងារ ប្រឡងតេស និងចូលរួមវគ្គបណ្តុះបណ្តាលកសាងសមត្ថភាព។




" យើងត្រូវរៀបចំខ្លួនសម្រាប់អនាគតនៃការប្រកួតប្រជែងដ៏តឹងតែងមួយ ហើយទាញអត្ថប្រយោជន៍ពីវាឱ្យបាន។ អនាគតដែលពោរពេញទៅដោយផ្លាស់ប្តូរកំពុងកើនឡើងជាទីកន្លែងដែលបច្ចេ-កវិទ្យាត្រូវបានទំនើបកម្មថ្មីៗតាមដំណើរដ៏លឿនមួយ។"

**Goh Chok Tong**

**នាយករដ្ឋមន្ត្រី សឹង្ហបូរី**

**១៩៩៧**

## Responses to Globalisation

The new mission of the schools is to prepare students to work at jobs that do not yet exist, creating ideas and solutions for products and problems that have not yet been identified using technologies that have not yet been invented.

**Linda Darling-Hammond**

"បេសកកម្មថ្មីរបស់សាលារៀនគឺ រៀបចំសិស្សឱ្យធ្វើការងារដែលមិនទាន់មាននៅឡើយ បង្កើតគំនិត និងដំណោះស្រាយសម្រាប់ផលិតផល និងបញ្ហាទាំងឡាយដែលមិនទាន់រកឃើញនៅឡើយ ដោយប្រើប្រាស់បច្ចេកវិទ្យាមិនទាន់ច្នៃបង្កើតបាននៅឡើយ។"

**Linda Darling-Hammond**

# II. ប្រព័ន្ធអប់រំប្រទេស ជប៉ុន



## សំណួរត្រិះរិះ

*១-គោលដៅនៃការអប់រំគឺផលិតធនធានមនុស្សប្រកបដោយចំណេះដឹង បំណិន ឥរិយាបថល្អប្រសើរ និងចេះរស់នៅចុះសម្រុងគ្នា -**ហេតុអ្វីបានជាសិស្ស-និស្សិតជប៉ុន បញ្ចប់ការសិក្សានៅកម្រិតមួយស្មើគ្នាមានសមត្ថភាព និងបុគ្គលិកលក្ខណៈរួមភាគច្រើនដូចៗគ្នា? ហើយអ្វីបានជាសិស្ស-និស្សិតកម្ពុជាមួយចំនួនធំ បញ្ចប់ការសិក្សានៅកម្រិតភូមិសិក្សាមួយដូចគ្នាតែសមត្ថភាព និងបុគ្គលិកលក្ខណៈ មិនដូចគ្នា?***

*២-ស្ថិតក្នុងស្ថានភាពប្រទេសខ្ទេចខ្ទាំក្រោយសង្គ្រាមលោកលើកទី ២ សំបូរដោយគ្រោះធម្មជាតិ ក្សត់ធនធានរ៉ែ ធនធានដីសម្រាប់កសិកម្ម និងថាមពល **តើជប៉ុនអភិវឌ្ឍន៍ប្រទេសក្លាយមហាអំណាចពិភពលោកដោយរបៀបណា?***

***៣-តើប្រព័ន្ធអប់រំប្រទេសជប៉ុនមានលក្ខណៈដូចម្ដេច? មានកំណែទម្រង់ប្រព័ន្ធអប់រំអ្វីខ្លះទើបអាចក្លាយជាភាពគំរូមួយរបស់ពិភពលោក?***

***៤-ហេតុអ្វីបានជាប្រទេសជប៉ុនទទួលលទ្ធផលតេស PISA ខ្ពស់?***

***៥-តើប្រទេសកម្ពុជា អាចរៀនសូត្របានអ្វីខ្លះពីប្រព័ន្ធអប់រំប្រទេសជប៉ុន?***

## 2.1) ទិដ្ឋភាពទូទៅរបស់ប្រទេសជប៉ុន

(សង្គម សេដ្ឋកិច្ច និងនយោបាយ)

ប្រទេសជប៉ុន គឺជាកម្រងកោះ(កោះសរុប៦៨៥២កោះ)មានរាងដូចធ្នូស្ថិតនៅអាស៊ីខាងកើត និងស្ថិតនៅប៉ែកខាងលិចនៃមហាស-មុទ្រប៉ាស៊ីហ្វិក។ ប្រទេសជប៉ុនគ្មានព្រំប្រទល់ដីគោកទេ និងហ៊ុមព័ទ្ធទៅដោយសមុទ្រមានសមុទ្រជប៉ុន សមុទ្រចិនខាងកើត សមុទ្រហ្វីលីពីន និងសមុទ្រអុកហុតស្គ៍។ ប្រទេសនៅជិតខាងមានសហព័ន្ធរុស្ស៊ី សហភាពប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (កូរ៉េខាងជើង) សាធារណរដ្ឋកូរ៉េ(កូរ៉េខាងត្បូង) សាធារណរដ្ឋប្រជាមានិតចិន កោះតៃវ៉ាន់ និងសាធារណរដ្ឋហ្វីលីពីន។ ប្រទេសនេះមានផ្ទៃក្រឡា ៣៧៧ ៨៧៣គ.ម$^{២}$ ធំជាងប្រទេសកម្ពុជាប្រហែល២ដង និងមានប្រជាជនប្រហែល១២៨លាននាក់[1] ដែលមានលក្ខណៈដូចគ្នាខាងភាសាជាតិ និងវប្បធម៌[2]។ ក្នុងចំណោមប្រជាជនទាំងអស់ មានសមាសភាពជាជនជាតិជប៉ុន៩៨,៥%[3] និងមានចំនួនពលករបរ-ទេសតិចតួចប៉ុណ្ណោះ។ ចំនួនប្រជាជនជប៉ុនស្ថិតនៅលំដាប់ទី៨ប់លើពិភពលោក ដោយគ្រាន់តែទីក្រុងតូក្យូដែលជារាជធានីមួយមានប្រជាជនប្រមាណ៩,១លាននាក់[4]។ ប្រទេសជប៉ុនមានសេរីភាពសាសនាពេញលេញដោយផ្អែកលើមាត្រា២០ នៃរដ្ឋធម្មនុញ្ញរបស់ខ្លួន។ ការប៉ាន់ប្រមាណខាងលើបានបង្ហាញថាប្រជាជនជប៉ុនពី៨៤% ទៅ៩៦%ជាអ្នកកាន់សាសនាShinto ដែលជាសាសនារបស់ជនជាតិដើមភាគតិច[5]។ ផ្ទៃដីសរុប៧០%គឺជាភ្នំ ហើយផ្ទៃដីព្រៃមាន៦៧%។ ជនជាតិជប៉ុនស្រឡាញ់ធម្មជាតិ និងមិនកាប់បំផ្លាញព្រៃឈើឡើយ។ **ស្ថានភាពសណ្ឋានដី**ជាផ្នែកមួយរបស់ខ្សែក្រវ៉ាត់ភ្នំភ្លើង និងរញ្ជួយដីប៉ាស៊ីហ្វិក។ហេតុនេះហើយទើបប្រទេសនេះសម្បូរគ្រោះរញ្ជួយដី (១០% ទៅ២០%នៃរញ្ជួយដីពិភពលោកកើតឡើងនៅម្តុំប្រទេសជប៉ុន)។ រញ្ជួយដីថ្នាក់លេខ១ និងលេខ២មានកើតនៅប្រទេសជប៉ុនជារៀងរាល់ថ្ងៃ។ ក្រៅពីគ្រោះរញ្ជួយដី ប្រទេសជប៉ុនជួបប្រទះ

គ្រោះធម្មជាតិផ្សេងៗទៀតដែលតែងតែកើតមានជាញឹកញាប់ដូចជា៖ ការផ្ទុះភ្នំភ្លើង ព្យុះទីហ្វុង និងរលកយក្សស៊ូណាមី។ គ្រាន់តែរញ្ជួយដីនៅឆ្នាំ ១៩២៣បានបំផ្លាញទីក្រុងតូក្យូ និងបណ្ដាលឱ្យមានជនរងគ្រោះដល់ទៅជាង ១៥០ ០០០នាក់។ គុណភាពដីរបស់ប្រទេសជប៉ុនមានជីវជាតិល្អព្រោះជាដីបានមកពីសកម្មភាពភ្នំភ្លើង តែ**ខ្សត់ធនធានរ៉ែ និងថាមពល ចំណីអាហារ ធនធានដី (ដីសម្រាប់កសិកម្មមានចំនួនតិចតួច) សម្បូរគ្រោះធម្មជាតិ និងមានប្រជាជនច្រើន**។ រដ្ឋធានីប្រទេសនេះមិនមានកំណត់ច្បាស់លាស់នៅក្នុងច្បាប់ឡើយ តែតាមសភាពជាក់ស្ដែងទីក្រុងតូក្យូជាមណ្ឌលសេដ្ឋកិច្ច នយោបាយ និងជាកន្លែងស្នាក់នៅរបស់ព្រះចៅអធិរាជ។ ល្វែងម៉ោងនៅជប៉ុនគឺUTC + ៩ ហើយលឿនជាងម៉ោងនៅប្រទេសកម្ពុជាចំនួន២ម៉ោង។

ប្រទេសជប៉ុនបែងចែក**ការគ្រប់គ្រង**ជា៤៧អាណាខេត្ត (prefectures) ដែលត្រួតត្រាដោយអភិបាលខេត្តជាប់ឆ្នោតម្នាក់ ហើយអាណាខេត្តនីមួយៗត្រូវបានបែងចែកបន្ថែមទៅជាទីក្រុង (City) ទីប្រជុំជន(Town) និងភូមិ(Village)។ បច្ចុប្បន្ននេះ ប្រទេសកំពុងស្ថិតក្រោមការរៀបចំឡើងវិញនូវរដ្ឋបាលគ្រប់គ្រងដោយបញ្ចូលទីក្រុង ទីប្រជុំជន និងភូមិជាច្រើនបញ្ចូលគ្នាដើម្បីកាត់បន្ថយចំនួនតំបន់រដ្ឋបាលរាយរង ហើយដែលត្រូវបានគេរំពឹងថានឹងកាត់បន្ថយការចំណាយផ្នែករដ្ឋបាលមួយចំនួនធំ(6)។

លក្ខណៈចម្បងនៃ**អាកាសធាតុ**នៅប្រទេសជប៉ុនគឺ ភាពខុសគ្នានៃសីតុណ្ហភាពរដូវទាំងបួន។ នៅរដូវរងារ វាទទួលឥទ្ធិពលពីខ្យល់រដូវដែលបក់ពីស៊ីបីរី ហើយនៅរដូវក្ដៅ វាទទួលឥទ្ធិពលពីខ្យល់រដូវដែលបក់មកពីមហាសមុទ្រប៉ាស៊ីហ្វិក។ ប្រទេសជប៉ុនលាតសន្ធឹងពីជើងទៅត្បូងដោយគ្របដណ្ដប់លើរយៈទទឹងចំនួន២៥ដឺក្រេ ជាហេតុធ្វើឱ្យសីតុណ្ហភាពមានភាពខុសគ្នាខ្លាំងនៅតាមតំបន់នីមួយៗ។ ជប៉ុនជាប្រទេសដែលមានបួនរដូវ

គឺ៖ **រដូវផ្ការីក រដូវក្ដៅ រដូវស្លឹកឈើជ្រុះ** និង**រដូវរងារ**។ រដូវនីមួយៗ ដើរតួនាទីសំខាន់ណាស់នៅក្នុងជីវភាពរស់នៅរបស់ប្រជាជនជប៉ុន។

ជប៉ុនមានសក្ដានុពលយោធាយ៉ាងខ្លាំងក្លានៅចុងស.វទី១៩ និងដើមស.វទី២០ ដោយបានពង្រីកទឹកដីតាមរយៈការឈ្នះក្នុងសង្គ្រាមចិន-ជប៉ុនលើកទី១ សង្គ្រាមរុស្ស៊ី-ជប៉ុន និងពង្រឹងសមត្ថភាពខ្លួនក្រោយឈរមើលឆាកប្រយុទ្ធរបស់ប្រទេសចក្រពត្តិនិយមអឺរ៉ុបក្នុងសង្គ្រាមលោកលើកទី១។

ប្រទេសនេះបានអភិវឌ្ឍវិស័យឧស្សាហកម្មរបស់ខ្លួនយ៉ាងឆាប់រហ័សចាប់តាំងពីឆ្នាំ១៨៦៨ (សម័យ**មីអិយិ**) និងត្រៀមលក្ខណៈធ្វើជាមហាអំណាចនៅអាស៊ី។ តែដោយសារវិបត្តិសេដ្ឋកិច្ចឆ្នាំ១៩២១ ភាពក្សត់ធនធានធម្មជាតិ និងថាមពល ព្រមទាំងគ្រោះធម្មជាតិកើតឡើងជាញឹកញាប់ ពិសេសឆ្នាំ១៩២៣ គ្រោះរញ្ជួយដីប៉ះចំលើតំបន់មានមនុស្សរស់នៅកកកុញ ហើយរាជធានីតូក្យូបានត្រូវខ្ទេចខ្ទីទាំងស្រុង ព្រមទាំងមានមនុស្សចំនួន១៥០០០០នាក់បានបាត់បង់ជីវិត ធ្វើឱ្យមេដឹកនាំជប៉ុនងាកទៅរករបបយោធានិយមបែបថ្មីដើម្បីដោះស្រាយស្ថានភាពងាយរងគ្រោះ និងដើម្បីសម្រេចមហិច្ឆតារបស់ខ្លួនដោយពង្រឹងគោលនយោបាយឈ្លានពានទឹកដីប្រទេសជិតខាង ហើយបង្កើតរចនាសម្ព័ន្ធដឹកនាំបែបចក្រពត្តិអាណានិគមនិយម។

នៅឆ្នាំ១៩២៧ នាយករដ្ឋមន្ត្រីជប៉ុនបានរៀបគម្រោងធំដើម្បីឈ្លានពានប្រទេសនៅក្នុងទ្វីបអាស៊ី។ ដំបូងចូលឈ្លានពានប្រទេសចិន បន្ទាប់មកឥណ្ឌូចិន ភូមា ប្រទេសផ្សេងៗទៀតនៅអាស៊ីអាគ្នេយ៍ និងប្រទេសឥណ្ឌា...។ នៅឆ្នាំ១៩៣១ ប្រទេសជប៉ុនចាប់ផ្ដើមលុកលុយតំបន់ម៉ាន់ជូរី ហើយគម្រោងឈ្លានពានពង្រីកអំណាចជប៉ុនបានចាប់ផ្ដើម។ នៅឆ្នាំ១៩៣២ ជប៉ុនបានកាន់កាប់ខេត្តស៊ើហៃ ហើយបានបើកការវាយលុកតម្រង់ទៅកាន់មហាកំពែងចិន។ នៅឆ្នាំ១៩៣៧ ជប៉ុនបានកាន់កាប់ក្រុង

ប៉េកាំង ក្រុងសៀងហៃ ក្រុងណានជីង និងទីរួមខេត្តជាច្រើនថែមទៀត។ សង្គ្រាមចិន-ជប៉ុនលើកទី២នៅឆ្នាំ១៩៣៧នេះ បានរីកដាលជាសង្គ្រាមលោកលើកទី២ ដែលបានបញ្ចប់ដោយការទម្លាក់គ្រាប់បែកបរមាណូនៅក្រុងហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគីដោយសហរដ្ឋអាមេរិក។

ប្រទេសជប៉ុនប្រកាន់**របបនយោបាយ**រាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញដែលអំណាចព្រះចៅអធិរាជត្រូវបានកម្រិតដែនកំណត់មួយ។ ព្រះអង្គត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញថាជា **"និមិត្តរូបនៃរដ្ឋ និងសាមគ្គីភាពរបស់ប្រជាជន"** ។ អំណាចនីតិប្រតិបត្តិគឺ ត្រូវបានគ្រប់គ្រងដោយនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រីរបស់គាត់ខណៈដែលអធិបតេយ្យភាពជាតិត្រូវបានប្រគល់ជូនប្រជាជនជប៉ុន(7)។ អំណាចនីតិប្បញ្ញត្តិរបស់ប្រទេសជប៉ុន មានសភាតំណាងរាស្ត្រចំនួន៤៦៥អាសនៈ ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយការបោះឆ្នោតរៀងរាល់បួនឆ្នាំម្តង ឬនៅពេលរំលាយ(8)។ ថ្វីបើជប៉ុនបានបោះបង់ចោលជាផ្លូវការអំពីសិទ្ធិរបស់ខ្លួនក្នុងការប្រកាសសង្គ្រាមក៏ដោយក៏ប្រទេសនេះនៅតែរក្សាបាននូវយោធាសម័យទំនើបជាមួយនឹងថវិកាយោធាធំបំផុតទីប្រាំបី(9) ដែលប្រើសម្រាប់ការពារខ្លួន និងថែរក្សាសន្តិភាព។ ប្រទេសជប៉ុនគឺជា ប្រទេសអភិវឌ្ឍន៍ដែលមានស្តង់ដាររស់នៅ និងសន្ទស្សន៍អភិវឌ្ឍន៍មនុស្សកម្រិតខ្ពស់ (Human Development Index-HDI) ព្រមទាំងប្រជាជនមានអាយុសង្ឃឹមរស់ខ្ពស់បំផុត (the highest life expectancy) និងអត្រាមរណភាពទារកទាបបំផុតទីបីនៅលើពិភពលោក។ ប្រទេសជប៉ុនត្រូវបានគេស្គាល់យ៉ាងទូលំទូលាយជាអន្តរជាតិ សម្រាប់ការរួមចំណែកដ៏សំខាន់របស់ខ្លួនចំពោះវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើប(10)។

ប្រទេសជប៉ុនមាន**ទំនាក់ទំនងការទូត**ជាមួយប្រទេសឯករាជ្យស្ទើរតែទាំងអស់ហើយបានក្លាយជាសមាជិកសកម្មរបស់អង្គការសហប្រជាជាតិចាប់តាំងពីខែធ្នូ ឆ្នាំ១៩៥៦។ ប្រទេសជប៉ុនគឺជាសមាជិកនៃ G8-

APEC និងអាស៊ានបូក៣ ហើយជាអ្នកចូលរួមនៅក្នុងកិច្ចប្រជុំកំពូលអាស៊ីខាងកើត។ ជប៉ុនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិសុខជាមួយអូស្ត្រាលីនៅខែមីនាឆ្នាំ២០០៧[11] និងជាមួយឥណ្ឌានៅខែតុលា ឆ្នាំ២០០៨[12]។ នៅសតវត្សរ៍ទី២១នេះ ជប៉ុនក្លាយជាម្ចាស់ជំនួយធំបំផុតទីប្រាំនៃជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ពិភពលោក ដោយបរិច្ចាគថវិកាចំនួន៩,២៣ពាន់លានដុល្លារក្នុងឆ្នាំ២០១៤[13]។ ប្រទេសជប៉ុនមានទំនាក់ទំនងជិតស្និទ្ធទាំងផ្នែកសេដ្ឋកិច្ច និងការពារជាតិជាមួយសហរដ្ឋអាមេរិក ចាប់តាំងពីជប៉ុនបរាជ័យដោយសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តក្នុងសង្គ្រាមលោកលើកទី២។ សហរដ្ឋអាមេរិកគឺជា ទីផ្សារដ៏សំខាន់មួយសម្រាប់ការនាំចេញរបស់ជប៉ុន និងជាប្រភពដ៏ចម្បងនៃការនាំចូលរបស់ជប៉ុនដែរ។ មិនតែប៉ុណ្ណោះ សហរដ្ឋអាមេរិក បានប្តេជ្ញាចិត្តជួយការពារប្រទេសជប៉ុនពីការឈ្លានពានពីបរទេស ដោយបានតាំងមូលដ្ឋានយោធាឈរជើងនៅក្នុងទឹកដីជប៉ុន[14]។ ជប៉ុនមានទំនាស់ការគ្រប់គ្រងរបស់រុស្ស៊ីលើការគ្រប់គ្រងកោះគូរីល ដែលកាន់កាប់ដោយសហភាពសូវៀតតាំងពីឆ្នាំ១៩៤៥ និងជាមួយកូរ៉េខាងត្បូងទាក់ទងនឹងការទាមទារតំបន់ប្រប្រះថ្ម Liancourt ( ជប៉ុន: "Takeshi-ma" កូរ៉េ:"Dokdo" ) ព្រមទាំងជាមួយសាធារណរដ្ឋប្រជាមានិតចិនលើប្រជុំកោះសេនកាគុ[15] និងលើស្ថានភាពអូគីណូតូសូស៊ីម៉ា។ ទំនាក់ទំនងរបស់ជប៉ុនជាមួយកូរ៉េខាងត្បូងបានក្អក់កករ និងប៉ះពាល់ដោយសារតែទង្វើពីអតីតកាលរបស់កងទ័ពជប៉ុននៅអំឡុងការគ្រប់គ្រងរបស់អាណានិគមជប៉ុនលើទឹកដីកូរ៉េ ជាពិសេសការបង្ខំស្ត្រីកូរ៉េរាប់ពាន់នាក់ឱ្យបម្រើផ្លូវភេទដល់កងទ័ពជប៉ុន[16]។ នៅសម័យអាណានិគមជប៉ុន ចន្លោះឆ្នាំ១៩១០-១៩៤៥ រដ្ឋាភិបាលជប៉ុនបានប្រើប្រាស់អំណាចខ្លួនក្នុងការផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធកូរ៉េ បានដាក់បញ្ចូលជនអន្តោប្រវេសន៍ជប៉ុនជាង៨០០.០០០នាក់ទៅកាន់ឧបទ្វីប និងបានធ្វើយុទ្ធនាការបង្ក្រាបវប្បធម៌តាមរយៈកិច្ចប្រឹងប្រែងដើម្បីហាមឃាត់ភាសាកូរ៉េនៅក្នុងសាលារៀន និងបង្ខំប្រជាជនកូរ៉េឱ្យយកឈ្មោះតាមលំនាំបែបជប៉ុន[17]។ ជាមួយនឹងការចុះចាញ់របស់ជប៉ុន និងការ

បិទបញ្ចប់សង្គ្រាមលោកលើកទី២ នៅឆ្នាំ១៩៤៥ ឧបទ្វីបកូរ៉េទទួលបានឯករាជ្យ។ ទោះបីជាមានភាពតានតឹងពីស្នាកស្នាមប្រវត្តិសាស្ត្រនេះ នៅក្នុងខែធ្នូ ឆ្នាំ២០១៥ ប្រទេសជប៉ុនបានយល់ព្រមដោះស្រាយជម្លោះបញ្ហាស្ត្រីទាសករផ្លូវភេទប្រកបដោយភាពកក់ក្តៅជាមួយកូរ៉េខាងត្បូងតាមរយៈការសុំទោសជាផ្លូវការ និងទទួលយកការទទួលខុសត្រូវចំពោះបញ្ហានេះ ព្រមទាំងបង់ប្រាក់ទៅឱ្យស្ត្រីរងគ្រោះទាំងនោះ។ សព្វថ្ងៃនេះ ប្រទេសកូរ៉េខាងត្បូង និងជប៉ុនមានទំនាក់ទំនងរឹងមាំ និងទំនាក់ទំនងសេដ្ឋកិច្ចកាន់តែច្រើនជាមួយគ្នា[(18)]។ ប្រទេសជប៉ុនរក្សាចំណាត់ថ្នាក់ជាប្រទេសដែលមានថវិកាយោធាធំបំផុតមួយក្នុងពិភពលោក[(19)]ដែលកងទ័ពត្រូវបានដាក់កម្រិតដោយមាត្រាទី៩នៃរដ្ឋធម្មនុញ្ញជប៉ុនដោយបានបោះបង់សិទ្ធិរបស់ជប៉ុនក្នុងការប្រកាសសង្គ្រាម ឬប្រើកម្លាំងយោធានៅក្នុងជម្លោះអន្តរជាតិ។ ដូច្នោះហើយកងកម្លាំងការពារខ្លួនឯងរបស់ជប៉ុន គឺជាកងទ័ពមិនធម្មតាមួយដែលមិនធ្លាប់ប្រឡូកក្នុងសង្គ្រាមក្រៅប្រទេសជប៉ុនឡើយ។ ជប៉ុនគឺជាប្រទេសអាស៊ីដែលមានលំដាប់ខ្ពស់បំផុតនៅក្នុងសន្ទស្សន៍សន្តិភាពពិភពលោក (Global Peace Index)[(20)]។ យោធាត្រូវបានគ្រប់គ្រងដោយក្រសួងការពារជាតិ ទាំងកងកម្លាំងស្វ័យការពារជើងគោក កងកម្លាំងជើងទឹក និងជើងអាកាសជប៉ុន[(21)]។ សម្រាប់បេត់នយោបាយបច្ចុប្បន្ន ជប៉ុនចង់ពង្រីកប្រតិបត្តិការរបស់ខ្លួន ដោយប្រើប្រាស់កងទ័ពរបស់ខ្លួននាពេលថ្មីៗនេះក្នុងកិច្ចប្រតិប-ត្តិការរក្សាសន្តិភាពតាមរយៈការដាក់ពង្រាយកងទ័ពទៅកាន់អ៊ីរ៉ាក់ ហើយជាការប្រើកម្លាំងយោធារបស់ជប៉ុនលើកដំបូងនៅក្រៅប្រទេសចាប់តាំងពីសង្គ្រាមលោកលើកទីពីរ[(22)]។ សហព័ន្ធពាណិជ្ជកម្មជប៉ុនបានអំពាវនាវឱ្យរដ្ឋាភិបាលលុបចោលបម្រាបហាមប្រាមការនាំចេញគ្រឿងសព្វាវុធដើម្បីឱ្យជប៉ុនអាចចូលរួមក្នុងគម្រោងចម្រុះជាតិសាសន៍ដូចជា Joint Strike Fighter [(23)]។

សតវត្សរ៍ទី២១ កំពុងបង្ហាញពីការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវតុល្យភាពថាមពលសកលរួមជាមួយនឹងសកលភាវូបនីយកម្ម។បរិយាកាស

សន្តិសុខនៅជុំវិញប្រទេសជប៉ុនបានក្លាយជាចំណុចក្តៅ ដោយសារការអភិវឌ្ឍអាវុធនុយក្លេអ៊ែរ និងមីស៊ីលរបស់កូរ៉េខាងជើង។ ការគំរាមកំហែងឆ្លងដែនដែលផ្អែកលើវឌ្ឍនភាពបច្ចេកវិទ្យារួមទាំងភេរវកម្មអន្តរជាតិ និងការវាយប្រហារអ៊ិនធើណែតក៏កំពុងតែបង្កើនវត្តមានរបស់ពួកគេស្ទើរគ្រប់តំបន់[24]។ ជប៉ុនរួមទាំងកងកម្លាំងស្វ័យការពាររបស់ខ្លួនបានរួមចំណែកដល់ការប្រឹងប្រែងជាអតិបរិមា ដើម្បីរក្សា និងស្តារសន្តិភាព សន្តិសុខអន្តរជាតិដូចជា ប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិជាដើម។ ដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងនាមជារដ្ឋសន្តិភាព រដ្ឋាភិបាលជប៉ុនបាននិងកំពុងយកចិត្តទុកដាក់ជាខ្លាំងលើគោលនយោបាយសន្តិសុខរបស់ខ្លួនដែលរួមមានៈការបង្កើតក្រុមប្រឹក្សាសន្តិសុខជាតិ (NSC) ការអនុម័តយុទ្ធសាស្ត្រសន្តិសុខជាតិ (NSS) និងគោលការណ៍ណែនាំកម្មវិធីការពារជាតិ(NDPG)[24]។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានធ្វើឡើងដោយផ្អែកលើជំនឿថាជប៉ុនជា **"អ្នករួមចំណែកដ៏សកម្មដើម្បីសន្តិភាព"** ចាំបាច់ត្រូវចូលរួមចំណែកយ៉ាងសកម្មចំពោះសន្តិភាព និងស្ថេរភាពនៅក្នុងតំបន់ និងសហគមន៍អន្តរជាតិ ដោយសម្របសម្រួលជាមួយបណ្តាប្រទេសដទៃទៀតរួមទាំងសម្ព័ន្ធមិត្តរបស់ខ្លួនគឺសហរដ្ឋអាមេរិក[24]។

ប្រទេសជប៉ុនគឺជា សមាជិករបស់អង្គការសហប្រជាជាតិ OECD-G7-G8 និងG20 ហើយត្រូវបានគេចាត់ទុកថាជាមហាអំណាចមួយ[25]។ ប្រទេសនេះមានសេដ្ឋកិច្ចធំលំដាប់ទីបីនៅលើពិភពលោកដោយផលិតផលក្នុងស្រុកសរុប(GDP) និងជាប្រទេសនាំចេញធំទីបួន ហើយជាប្រទេសនាំចូលធំជាងគេទីបួនរបស់ពិភពលោកផងដែរ។ ប្រទេសជប៉ុនទទួលបានផលប្រយោជន៍ពីកម្លាំងពលកម្មដែលមានជំនាញខ្ពស់ ហើយស្ថិតនៅក្នុងចំណោមប្រទេសមានការអប់រំខ្ពស់បំផុតក្នុងពិភពលោកដោយពលរដ្ឋដែលមានសញ្ញាប័ត្រឧត្តមសិក្សាមានភាគរយខ្ពស់[26]។

ប្រទេសជប៉ុនមានទំនាក់ទំនងសេដ្ឋកិច្ច និងយោធាជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក។ សម្ព័ន្ធមិត្តសន្តិសុខអាមេរិក - ជប៉ុន ដើរតួនាទីជា

គ្រឹះនៃគោលនយោបាយការបរទេសរបស់ប្រទេស[27]។ ក្នុងនាមជាសមាជិកនៃអង្គការសហប្រជាជាតិចាប់តាំងពីឆ្នាំ១៩៥៦មក ជប៉ុនបានធ្វើជាសមាជិកក្រុមប្រឹក្សាមិនអចិន្ត្រៃយ៍អស់រយៈពេលជាង ២០ឆ្នាំមកហើយ។ វាជាប្រទេសមួយក្នុងចំណោមប្រទេស G4 ដែលស្វែងរកសមាជិកភាពអចិន្ត្រៃយ៍នៅក្នុងក្រុមប្រឹក្សាសន្តិសុខ[28]។ នៅខែឧសភា ឆ្នាំ២០១៤ លោកនាយករដ្ឋមន្ត្រីស៊ីនស៊ូអាបេ (Shinzō Abe) បាននិយាយថា ជប៉ុនចង់លុបចោលភាពអសកម្មរបស់ខ្លួនដែលមានតាំងពីចុងបញ្ចប់នៃសង្គ្រាមលោកលើកទី២ ដោយចង់មានការទទួលខុសត្រូវបន្ថែមទៀតសម្រាប់សន្តិសុខក្នុងតំបន់ និងចង់ដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ជំនួយគាំទ្រដល់ប្រទេសជិតខាង[29]។ នៅប៉ុន្មានឆ្នាំថ្មីៗនេះ ពួកគេបានចូលរួមនៅក្នុងប្រតិបត្តិការថែរក្សាសន្តិភាពអន្តរជាតិរួមទាំងការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ[30]។ ភាពតានតឹងនាពេលថ្មីៗនេះ ជាពិសេសជាមួយកូរ៉េខាងជើង[31] បាននាំឱ្យមានការជជែកវែកញែកឡើងវិញលើស្ថានភាពនៃកងកម្លាំងស្វ័យការពាររបស់ខ្លួន និងទំនាក់ទំនងរបស់វាទៅនឹងសង្គមជប៉ុន[32]។ គោលការណ៍ណែនាំយោធាថ្មីៗដែលបានប្រកាសនៅខែធ្នូ ឆ្នាំ២០១០ នឹងដឹកនាំកងកម្លាំងស្វ័យការពារឱ្យឆ្ងាយពីសង្គ្រាមត្រជាក់របស់ខ្លួនដែលពីមុនផ្តោតលើអតីតសហភាពសូវៀត តែឥឡូវងាកទៅផ្តោតលើប្រទេសចិនវិញ ជាពិសេសទាក់ទងនឹងជម្លោះដែនដីលើកោះសេនកាគូ។

**បើនិយាយពីវិស័យសេដ្ឋកិច្ច**ក្រោយបរាជ័យឆ្នាំ១៩៤៥ សេដ្ឋកិច្ចប្រទេសនេះត្រូវបំផ្លាញទាំងស្រុង។ ប្រទេសជប៉ុនបានងើបឡើងវិញយ៉ាងឆាប់រហ័សក្នុងរយៈពេលតែបីទស្សវត្សរ៍ប៉ុណ្ណោះ ឈានទៅកាន់ឋានៈជាមហាអំណាចពិភពលោក ដោយសារតែជំនួយរបស់សហរដ្ឋអាមេរិកពីខាងដើមទី ប៉ុន្តែក៏ដោយសារការខិតខំប្រឹងប្រែងគួរឱ្យចាប់អារម្មណ៍ និងជម្រើសសេដ្ឋកិច្ចប្រកបដោយវិចារណញ្ញាណរបស់ខ្លួនដែរ។ **តើកត្តាអ្វីដែលធ្វើឱ្យជប៉ុនក្លាយជាមហាអំណាចពិភពលោក?** ជាមួយនឹងបរាជ័យរបស់ខ្លួននៅឆ្នាំ១៩៤៥ ប្រទេសជប៉ុនត្រូវស្ថិតនៅក្រោមការកាន់កាប់របស់សហរដ្ឋអាមេ

រិក ហើយធ្លាក់ក្នុងភាពក្រីក្រ និងមានអតិផរណាទៀតផង។ ជប៉ុនត្រូវព្រមទទួលយករបបគ្រប់គ្រងតាមបែបសភានិយម និងការប្រមូលផ្តុំសេដ្ឋកិច្ច។ ប៉ុន្តែស្ថានភាពសង្គ្រាមត្រជាក់ បានធ្វើឱ្យការគ្រប់គ្រងរបស់សហរដ្ឋអាមេរិកមកលើជប៉ុនមានការផ្លាស់ប្តូរ។ ជ័យជម្នះរបស់ពួកកុំម្មុយយនីស្តនៅប្រទេសចិន បានជំរុញឱ្យសហរដ្ឋអាមេរិកប្តូរនយោបាយមកចងសម្ព័ន្ធភាពជាមួយជប៉ុន ព្រមទាំងជួយលើកស្ទួយសេដ្ឋកិច្ចតាមរយៈជំនួយពិសេស។ សេដ្ឋកិច្ចជប៉ុនទទួលបានជោគជ័យត្រចះត្រចង់ណាស់ ទោះបីវិបត្តិដែលកើតឡើងតាំងពីអតីតកាលរហូតដល់សព្វថ្ងៃឥតត្រាប្រណីយ៉ាងណាក៏ដោយ។ ការខ្ទេចខ្ទាំក្រោយបរាជ័យឆ្នាំ ១៩៤៥ ជប៉ុនបានបោះមួយជំហានមួយយ៉ាងវែងមកកាន់ឋានៈលេខមួយនៅអាស៊ី និងលេខពីរលើពិភពលោក ហើយសព្វថ្ងៃលេខបីបន្ទាប់ពីសហរដ្ឋអាមេរិក និងមហាយក្សចិន។ ជប៉ុនបានកសាងភាពល្បីល្បាញនេះដោយផ្អែកលើ**មូលដ្ឋានឧស្សាហកម្ម** ដោយប្រើប្រាស់យុទ្ធសាស្ត្រសេដ្ឋកិច្ចប្លែកៗជាច្រើន។ វឌ្ឍនភាពសេដ្ឋកិច្ចជប៉ុនគ្មានប្រទេសណាធ្វើបានដូច និងធាប់រហ័សក្នុងការរត់ប្រណាំងសេដ្ឋកិច្ចនៅឡើយទេ។ ក្នុងរយៈពេល១សតវត្សរ៍ផលិតកម្មឧស្សាហកម្មបានកើនឡើងមួយរយដង ហើយចំនួនប្រជាជនតិចជាង ២,៤%នៃប្រជាជនពិភពលោក សម្រេចបាន១៥%នៃផលទុនពិភពលោក។ ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៥០ សេដ្ឋកិច្ចជប៉ុនបានឈានដល់សម័យកាល "**កំណើនដ៏ខ្ពស់មួយ**" មានឧស្សាហកម្មដែកថែប និងសំណង់នានា ហើយបានរីកសាយទៅលើផ្នែកគ្រឿងបរិក្ខារ និងគ្រឿងឧបភោគបរិភោគជាប់លាប់ មានរថយន្ត ដែកថែប គីមី ប្រេងកាត និងគ្រឿងអេឡិចត្រូនិកសម្រាប់មហាជន។ ពីឆ្នាំ ១៩៥៥ ដល់១៩៦១ ការងារថ្មីចំនួន៣លានត្រូវបានបង្កើត ភាពខុសគ្នានៃប្រាក់បៀវត្សន៍ត្រូវបានកាត់បន្ថយ ហើយកម្រិតជីវភាពត្រូវបានលើកកម្ពស់។ ជប៉ុនស្គាល់កំណើនសេដ្ឋកិច្ចពិតប្រាកដចាប់ពីទសវត្សរ៍១៩៦០ ដល់ឆ្នាំ ១៩៨០ ត្រូវបានគេហៅថា**អព្ភូតហេតុសេដ្ឋកិច្ច**សម័យក្រោយសង្គ្រាម។ កំណើនសេដ្ឋកិច្ចជាមធ្យមមាន ៧,៥% ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ និង

១៩៧០ ហើយ៣,២% នៅទសវត្សរ៍១៩៨០ និងដើមទសវត្សរ៍ឆ្នាំ ១៩៩០។ កំណើនសេដ្ឋកិច្ចមានការធ្លាក់ចុះនៅទសវត្សរ៍ឆ្នាំ៩០ ក្នុងអំឡុងពេល "**ទសវត្សរ៍នៃការបាត់បង់** (Lost Decade)" ដោយសារផលប៉ះពាល់ក្រោយពីការកើនឡើងនូវតម្លៃទ្រព្យសកម្មជប៉ុន និងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានបំណងលុបចោលការប៉ាន់ស្មានលើសលុបពីទីផ្សារភាគហ៊ុន និងអចលនទ្រព្យ។ កិច្ចខិតខំប្រឹងប្រែងដើម្បីស្តារកំណើនសេដ្ឋកិច្ចត្រូវបរាជ័យ និងមានឧបសគ្គរាំងបន្ថែមទៀតដោយសារការធ្លាក់ចុះសេដ្ឋកិច្ចសកលនៅឆ្នាំ២០០០[3]។ សេដ្ឋកិច្ចបានស្តារឡើងវិញបន្ទាប់ពីឆ្នាំ២០០៥។ កំណើនផលិតផលក្នុងស្រុកសរុបសម្រាប់ឆ្នាំនោះមានចំនួន ២,៨% លើសពីអត្រាកំណើនសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបក្នុងអំឡុងពេលដូចគ្នានេះ។

ពិភពជនបទជប៉ុនគឺ ពិភពនៃដំណាំស្រូវ។ តែស្ថានភាពបច្ចុប្បន្ន មាននិន្នាការថយចុះនូវចំនួនកសិករ ទោះបីមានគោលនយោបាយរឹតត្បិតការនាំស្រូវចូលក៏ដោយ។ កសិករពឹងផ្អែកលើរបរផ្សេងៗទៀតដែលផ្តល់ប្រាក់កម្រៃខ្ពស់ជាងកំរៃដែលបានមកពីការងារកសិកម្ម។ **វិស័យកសិកម្ម**របស់ជប៉ុនមានប្រហែល១,៤% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេស[33]ដោយមានដីតែ១២% ប៉ុណ្ណោះនៃដីទាំងអស់របស់ជប៉ុនដែលមានលក្ខណៈសមស្របសម្រាប់ការដាំដុះ[34]។ ដោយសារតែ កង្វះដីស្រែចម្ការ ប្រព័ន្ធផ្ទៃរាបស្មើជម្រាលភ្នំ ឬខ្ពង់រាបត្រូវបានប្រើប្រាស់ដើម្បីធ្វើស្រែចំការតូចៗ[35] តែទិន្នផលដំណាំទទួលបានផលខ្ពស់បំផុតក្នុងចំណោមប្រទេសទាំងឡាយនៅលើពិភពលោក។ ភោគទ្រព្យសំខាន់មួយទៀតគឺភោគផលនេសាទ។ ជនជាតិជប៉ុនជា អ្នកបរិភោគត្រីដ៏ធំមួយនៅក្នុងលោក។ ផលិតផលនេសាទ ផ្គត់ផ្គង់បាន៥០%នៃប្រូតេអ៊ីនដែលបានមកពីសត្វ។ សព្វថ្ងៃនេះ ប្រទេសជប៉ុនរក្សាបាននូវកងកម្លាំងនេសាទដ៏ធំបំផុតមួយរបស់ពិភពលោក និងមានចំនួនជិត១៥%នៃការនេសាទនៅទូទាំងពិភពលោក[36] ដែលជំរុញឱ្យមានការអេះអាងខ្លះថា ការនេសាទត្រីរបស់ជប៉ុននាំឱ្យ

មានការថយចុះនៃការស្តុកត្រីជាច្រើនដូចជាត្រីធូណា[37]ជាដើម។ ជប៉ុនក៏បានបង្កឱ្យមានភាពចម្រូងចម្រាសផងដែរដោយការគាំទ្រដល់ការនេសាទត្រីបាឡែន[38]។ ទោះបីជប៉ុនមានប្រភពធនធានស្បៀងមួយចំនួនក្តី ក៏ជប៉ុននៅតែចំណុះប្រទេសផ្សេងៗលើបញ្ហាស្បៀងដដែល។ ជប៉ុនគឺជាប្រទេសនាំចូលផលិតផលកសិកម្មធំជាងគេទី២នៅលើពិភពលោក[39]។ ក្នុងនោះ នាំចូលចំណីអាហារលេខមួយក្នុងពិភពលោក មានធញ្ញជាតិ៧០%នៃការប្រើប្រាស់ ហើយបញ្ហាសុវត្ថិភាពស្បៀងនាំមកនូវក្តីកង្វល់មួយ។ ចំណាយលើចំណីអាហារនៅប្រទេសជប៉ុនគឺខ្ពស់ស្មើនឹង២៦%នៃការចំណាយលើការប្រើប្រាស់ក្នុងគ្រួសារ។ ជាមួយនឹងប្រឈមទៅនឹងភាពលូតលាស់ដ៏ខ្លាំងក្លានៃសេដ្ឋកិច្ច ប្រទេសជប៉ុនត្រូវចំណាយទៅលើការនាំចូលផលិតផលអាហារ ថាមពល និងវត្ថុធាតុដើមដ៏ច្រើនលើសលុប។ ជនជាតិជប៉ុនយល់ច្បាស់ណាស់ថា ការផ្គត់ផ្គង់ទាំងនោះគឺ ពឹងផ្អែកទាំងស្រុងទៅលើការដោះដូរពីក្រៅប្រទេស។ ដើម្បីដោះស្រាយស្ថានភាពនេះ ជប៉ុនបានពង្រឹងវិស័យឧស្សាហកម្មរបស់ខ្លួនឈានដល់កម្រិតកំពូល ដើម្បីដោះដូរពាណិជ្ជកម្មជាមួយប្រទេសនានា។

ប្រទេសជប៉ុនសម្បូរសហគ្រាសធំៗដែលមានការចូលរួមពីសហគ្រាសតូច និងមធ្យម (PME)ដ៏ច្រើនដែលងាយស្រួលក្នុងការរៀបចំផែនការការពារទីផ្សារក្នុងស្រុកទប់ទល់នឹងការប្រកួតប្រជែងពីខាងក្រៅតាមវិធានការមួយចំនួនយ៉ាងប៉ិនប្រសប់ ពិសេសអាចគេសផុតពីហានិភ័យពីវិបត្តិសេដ្ឋកិច្ចពិភពលោកដោយសារភាពរឹងមាំ ការធ្វើការរួមគ្នា ចែករំលែកព័ត៌មាន និងត្រៀមលក្ខណៈបានទាន់ពេលវេលា ប្រសើរជាងសហគ្រាសតូច-មធ្យម និងក្រុមហ៊ុនដែលមានលក្ខណៈគ្រួសារដែលធ្វើការដាច់ៗពីគ្នា ដែលងាយរងគ្រោះខ្លាំងជាង។ សហគ្រាសតូច និងមធ្យមទាំងនោះចំណុះឱ្យក្រុមហ៊ុនធំៗ ព្រោះខ្លួនជាផលិតករតូចតាច ហើយដើម្បីឱ្យឈរជើងបាន ត្រូវតែបង្ខំឱ្យកម្មករព្រមទទួលប្រាក់ខែទាប ស្វែងរកកម្មករដែលស៊ីថ្លៃថោក និងជានិច្ចកាលត្រូវផ្សារភ្ជាប់ទៅនឹងតម្រូវការរបស់ក្រុមហ៊ុន

ធំៗ។ សហគ្រាសពហុសេវា (Sogo Shosha) ជាហាងជំនួញដែលបញ្ចូលគ្នា និងជាក្រុមហ៊ុនដែលសម្រាប់បម្រើសេវាឱ្យក្រុមហ៊ុនដទៃទៀត។ ជនជាតិជប៉ុនបានអភិវឌ្ឍគំរូគ្រប់គ្រងសហគ្រាសមួយដោយផ្អែកលើផលិតភាព និងការស្រុះស្រួលគ្នា។ គំនិតជាតិនិយមជាផ្នែកមួយដ៏សំខាន់ក្នុងការជួយទ្រទ្រង់សេដ្ឋកិច្ចជប៉ុន ដោយជនជាតិភាគច្រើនប្រើប្រាស់ផលិតផលក្នុងស្រុក ធ្វើឱ្យលំហូរទំនិញបរទេសចូលមកក្នុងទីផ្សារជប៉ុនមានការលំបាកគ្រប់ពេល។

ជាទូទៅគេមើលឃើញថា នៅលើឆាកនយោបាយអន្តរជាតិជប៉ុន "**ធំហួសខ្នាតផ្នែកសេដ្ឋកិច្ច តែតូចតឿផ្នែកនយោបាយ**"។ ប្រទេសជប៉ុនគឺជាប្រទេសមហាអំណាចសេដ្ឋកិច្ចធំបំផុតលំដាប់ទីបី នៅលើពិភពលោកបន្ទាប់ពីសហរដ្ឋអាមេរិក និងប្រទេសចិនទាក់ទងនឹងផលិតផលក្នុងស្រុកសរុប(GDP)[(40)] និងជាប្រទេសសេដ្ឋកិច្ចធំបំផុតលំដាប់ទីបួន នៅលើពិភពលោកបន្ទាប់ពីសហរដ្ឋអាមេរិក ចិន និងឥណ្ឌានៅក្នុងលក្ខខណ្ឌនៃការទិញ អំណាចស្មើ (purchasing power parity)។ បច្ចុប្បន្ន ប្រទេសជប៉ុនជាប្រទេសឧស្សាហកម្មលេខពីរក្នុងពិភពលោក បន្ទាប់សហរដ្ឋអាមេរិក និងជាប់ចំណាត់ថ្នាក់លេខមួយខាងសំណង់ រថយន្ត នាវា ទូរទស្សន៍ ម៉ាស៊ីនថតរូប និងមនុស្សយន្ត។ **ប្រទេសជប៉ុនជាប្រទេសតែមួយគត់ដែលបានកសាងឧស្សាហកម្មដ៏ធំមួយនៅលើទឹកដីខ្លួន ដែលមិនឃើញមានធនធានចាំបាច់ជារូបធាតុដើម និងថាមពលអ្វីឡើយ។** ស្ថានភាពនេះ តម្រូវឱ្យជប៉ុនបើកចំហសេដ្ឋកិច្ចយ៉ាងទូលំទូលាយទៅរកប្រទេសក្រៅ ពោលគឺជប៉ុនត្រូវស្ថិតក្នុងភាពចំណុះគេជានិច្ចកាល។ ដោយសារវិបត្តិប្រេងកាត ហើយដើម្បីកាត់បន្ថយស្ថានភាពចំណុះគេ ជប៉ុនបានខិតខំយ៉ាងខ្លាំងក្លាក្នុងការអភិវឌ្ឍវិស័យអគ្គិសនីនុយក្លេអ៊ែរ។ សេរីភាព និងសុវត្ថិភាពនៃការផ្គត់ផ្គង់ថាមពលនេះគឺជាបញ្ហាស្លាប់-រស់របស់ជប៉ុនដែលបានយកចិត្តទុកដាក់បំផុតដើម្បីប្រកួតប្រជែងសេដ្ឋកិច្ច។ ជប៉ុនមានធនធានរ៉ែខ្លះដែរ តែមានចំណុះតិចតួចដូចជា៖ ដែក ទង់ដែង សំណ ឬស្ពាន់ធ័រជាដើម។

គិតត្រឹមឆ្នាំ ២០១៦ **បំណុលសាធារណៈ**របស់ជប៉ុនត្រូវបានគេប៉ាន់ស្មានថាមានចំនួនច្រើនជាង២៣០% នៃផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំរបស់ខ្លួនដែលជាទំហំធំជាងគេបំផុតនៅក្នុងចំណោមប្រទេសទាំងឡាយលើពិភពលោក[41]។ ថ្វីត្បិតជប៉ុនមានបំណុលសាធារណៈធំជាងគេមែន តែជប៉ុនមិនមែនជំពាក់ទីផ្សារហិរញ្ញវត្ថុអន្តរជាតិដូចនៅអឺរ៉ុបទេ គឺជំពាក់ប្រជាជនខ្លួនឯងដែលភាគច្រើនមានការសំចៃធនច្រើនសន្ធឹកសន្ធាប់ ហើយនេះជាលក្ខណៈពិសេសដែលធ្វើឱ្យជប៉ុនមិនងាយរង្គោះរង្គើពេលមានវិបត្តិសេដ្ឋកិច្ចពិភពលោក។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ជប៉ុនបានធ្លាក់ចំណាត់ថ្នាក់ ដោយសារឱនភាពថវិកា និងបំណុលរបស់រដ្ឋាភិបាលចាប់តាំងពីវិបត្តិសេដ្ឋកិច្ចសកលលោកឆ្នាំ២០០៨ និងបន្ទាប់មកដោយសារការរញ្ជួយដី និងរលកយក្សស៊ូណាមីនៅខែមីនាឆ្នាំ ២០១១[42] ក្នុងនោះវិស័យសេវាកម្មមានចំនួន៣ភាគ៤នៃផលិតផលក្នុងស្រុកសរុប[43]។ ប្រទេសជប៉ុនមានសមត្ថភាពឧស្សាហកម្មដ៏ធំមួយ និងជាទីតាំងរបស់ក្រុមហ៊ុនផលិតធំៗ ដែលបច្ចេកវិទ្យាទំនើបទាន់សម័យឈានមុខនៃយានយន្តគ្រឿងអេឡិចត្រូនិច ឧបករណ៍គ្រឿងម៉ាស៊ីន លោហធាតុដែក លោហៈធាតុដែលមិនមែនដែក កប៉ាល់ សារធាតុគីមី វាយនភណ្ឌ និងអាហារកែច្នៃ។ អាជីវកម្មកសិកម្មនៅជប៉ុនដាំដុះបាន១៣%នៃដីរបស់ជប៉ុន ហើយប្រទេសជប៉ុនមានចំនួនជិត១៥%នៃការនេសាទត្រីនៅលើពិភពលោក ដែលនៅបន្ទាប់តែប្រទេសចិនមួយប៉ុណ្ណោះ។ គិតត្រឹមឆ្នាំ២០១៦ កម្លាំងពលកម្មរបស់ជប៉ុនមានចំនួន៦៥,៩ លាននាក់[3]។ ប្រទេសជប៉ុនមានអត្រាគ្មានការងារធ្វើទាបប្រហែល៤%។ ប្រជាពលរដ្ឋប្រមាណ២០ លាននាក់ដែលមានប្រហែល១៧%នៃចំនួនប្រជាជនស្ថិតនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រក្នុងឆ្នាំ២០០៧[44]។ លំនៅដ្ឋាននៅក្នុងប្រទេសជប៉ុនត្រូវបានកំណត់ដោយការផ្គត់ផ្គង់ដីមានកំណត់នៅតាមតំបន់ទីក្រុង[45]។ ការនាំចេញរបស់ប្រទេសជប៉ុនមានចំនួន ៤,២១០ដុល្លារអាមេរិកក្នុងម្នាក់ នៅឆ្នាំ២០០៥ ។ នៅឆ្នាំ២០១៤ ទីផ្សារនាំចេញចម្បងរបស់ជប៉ុនទៅអាមេរិកមាន២០,២%

ទៅចិនមាន១៧,៥% កូរ៉េខាងត្បូង៧,១% ហុងកុង៥,៦ % និងទៅថៃឡង់ ៤,៥%។ ការនាំចេញសំខាន់ៗ គឺមានគ្រឿងបរិក្ខារដឹកជញ្ជូនយានយន្ត ផលិតផលដែក និងដែកថែប គ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច និង គ្រឿងបន្លាស់នានា[3]។ ទីផ្សារនាំចូលសំខាន់ៗរបស់ជប៉ុនគិតត្រឹមឆ្នាំ ២០១៥ គឺចិន(២៤,៨%) សហរដ្ឋអាមេរិក(១០,៥%) អូស្ត្រាលី (៥,៤%) និងកូរ៉េខាងត្បូង(៤,១%)[3] ការនាំចូលសំខាន់ៗរបស់ប្រទេស ជប៉ុនគឺគ្រឿងម៉ាស៊ីន និងបរិក្ខារ គ្រឿងឥន្ធនៈហ្វូស៊ីល ម្ហូបអាហារ (ជា ពិសេសសាច់គោ) សារធាតុគីមី វាយនភណ្ឌ និងវត្ថុធាតុដើមសម្រាប់ ឧស្សាហកម្ម។ ដោយសារវិធានការផ្សារភាគហ៊ុនទីផ្សារក្នុងស្រុកមានការ បើកចំហរតិចតួចបំផុតសម្រាប់ប្រទេសជាសមាជិករបស់ OECD[46]។ រដ្ឋ បាលរបស់លោកជូនីជីរ៉ូ កូយស៊ុមិ (Junichirō Koizumi) បានចាប់ផ្ដើម កំណែទម្រង់ដែលមានលក្ខណៈប្រកួតប្រជែងមួយចំនួនហើយការវិនិយោគ បរទេសនៅក្នុងប្រទេសជប៉ុនបានកើនឡើង[47]។ ជប៉ុនស្ថិតក្នុងលំដាប់ទី ២៧ ក្នុងចំណោមប្រទេសចំនួន១៨៩ ជាប្រទេសដែលមានភាពងាយ ស្រួលក្នុងការធ្វើសន្ទស្សន៍មុខជំនួញឆ្នាំ២០១៤ (Business Index) និង ជាប្រទេសមួយក្នុងចំណោមប្រទេសអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលពន្ធ តិចតួចបំផុត[46]។ សព្វថ្ងៃនេះប្រទេសជប៉ុនមានចំណាត់ថ្នាក់ខ្ពស់ចំពោះ ការប្រកួតប្រជែង និងសេរីភាពសេដ្ឋកិច្ច។ វាត្រូវបានជាប់ចំណាត់ថ្នាក់ទី ប្រាំមួយនៅក្នុងរបាយការណ៍នៃការប្រកួតប្រជែងជាសកលសម្រាប់ឆ្នាំ ២០១៥-២០១៦[48]។

**វិស័យឧស្សាហកម្ម**របស់ប្រទេសជប៉ុនមានប្រហែល២៧,៥% នៃ ផលិតផលក្នុងស្រុកសរុប[49]។ ឧស្សាហកម្មសំខាន់ៗរបស់ជប៉ុនគឺ យាន យន្ត អេឡិចត្រូនិច ឧបករណ៍ម៉ាស៊ីន លោហៈ នាវាកប៉ាល់គីមី និងអាហារ កែច្នៃ។ ក្រុមហ៊ុនឧស្សាហកម្មធំៗ មួយចំនួនរបស់ជប៉ុនរួមមានតូយ៉ូតា ក្រុមហ៊ុនCanonក្រុមហ៊ុន Toshiba និងក្រុមហ៊ុន Nippon Steel [50]។ ជ ប៉ុនគឺជាអ្នកផលិតរថយន្តធំបំផុតទីបី នៅលើពិភពលោកហើយជាទីស្នាក់

ការធំរបស់ក្រុមហ៊ុនតូយ៉ូតាដែលជាក្រុមហ៊ុនផលិតរថយន្តធំបំផុតរបស់ពិភពលោក[51]&[52]។ ឧស្សាហកម្មគ្រឿងអេឡិចត្រូនិកជប៉ុនដែលធ្លាប់ត្រូវបានគេចាត់ទុកថាជាអ្នកខ្លាំងបំផុតនៅលើពិភពលោក បច្ចុប្បន្នកំពុងស្ថិតនៅក្នុងស្ថានភាពធ្លាក់ចុះដោយសារការប្រកួតប្រជែងកើតឡើងនៅក្នុងប្រទេសដូចជាៈ កូរ៉េខាងត្បូង សហរដ្ឋអាមេរិក និងចិន[53]។ បើទោះបីជាមានការប្រឈមប្រហាក់ប្រហែលគ្នាពីកូរ៉េខាងត្បូង និងចិនក៏ដោយក៏ឧស្សាហកម្មផលិតកប៉ាល់របស់ជប៉ុនត្រូវបានគេរំពឹងថានឹងនៅតែរឹងមាំដោយសារតែការផ្តោតការយកចិត្តទុកដាក់លើការរចនាដោយប្រើប្រាស់បច្ចេកវិទ្យា-ឯកទេសកម្រិតខ្ពស់។ មួយវិញទៀត ជប៉ុនជាប្រទេសដែលប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាពសម្រាប់ផលិតកម្មតិចជាងប្រទេសនៅអឺរ៉ុប និងប្រទេសចិនខ្លាំងដោយ រោងចក្រនៅជប៉ុនប្រើប្រាស់ម៉ាស៊ីននិងគ្រឿងយន្តច្រើនជាងប្រើមនុស្ស។ ជានិច្ចកាល តាំងពីសម័យមីអិជិមករដ្ឋតែងតែលូកដៃចូលអន្តរាគមន៍ក្នុងសេដ្ឋកិច្ច ដើម្បីជានាកំណើនសេដ្ឋកិច្ច និងដោះស្រាយវិបត្តិនានា។

**វិស័យសេវាកម្ម**របស់ជប៉ុនមានចំនួនប្រហែល៣ភាគ៤នៃទិន្នផលសេដ្ឋកិច្ចសរុបរបស់ខ្លួន[54]។ ធនាគារ ការធានារ៉ាប់រង អចលនទ្រព្យ លក់រាយ ដឹកជញ្ជូន និងទូរគមនាគមន៍គឺជាឧស្សាហ-កម្មដ៏សំខាន់ និងក្រុមហ៊ុនអាកាសចរណ៍ជប៉ុនត្រូវបានចុះបញ្ជីជាក្រុមហ៊ុនធំបំផុតនៅក្នុងពិភពលោក[55]។ កាសែតចំនួន៤ក្នុងចំណោមកាសែតដែលផ្សាយចំនួន៥ ក្នុងពិភពលោកគឺជា កាសែតជប៉ុន[56]។ ក្រុមហ៊ុន Japan Post Holdings ដែលជាអ្នកផ្តល់សេវាប្រាក់សន្សំ និងធានារ៉ាប់រងធំជាងគេបំផុតរបស់ប្រទេសនេះត្រូវបានគេគ្រោងនឹងធ្វើឯកជនភាវូបនីយកម្មនៅត្រឹមឆ្នាំ ២០១៥[57] ។

ប្រទេសជប៉ុនទាក់ទាញភ្ញៀវ**ទេសចរអន្តរជាតិ**ចំនួន១៩,៧៣ លាននាក់នៅឆ្នាំ២០១៥[58] និងកើនឡើង២១,៨% ដើម្បីទាក់ទាញភ្ញៀវ

ទេសចរអន្តរជាតិចំនួន២៤,០៣ លាននាក់នៅឆ្នាំ២០១៦[59]។ ភ្ញៀវទេសចរបរទេសទៅកាន់ប្រទេសជប៉ុនបានកើនឡើងទ្វេដងនៅក្នុងទសវត្សរ៍ចុងក្រោយ និងឈានដល់១០លាននាក់ជាលើកដំបូងនៅក្នុងឆ្នាំ២០១៣ ដែលនាំមុខដោយភ្ញៀវទេស-ចរអាស៊ាន។ នៅឆ្នាំ២០០៨ រដ្ឋាភិបាលជប៉ុនបានបង្កើតទីភ្នាក់ងារទេសចរណ៍ជប៉ុន និងកំណត់ទិសដៅដំបូងក្នុងការបង្កើនភ្ញៀវទេសចរបរទេសឱ្យបាន២០ លាននាក់នៅឆ្នាំ២០២០។ នៅឆ្នាំ២០១៦ ដែលបានសម្រេចគោលដៅ២០លាននាក់ រដ្ឋាភិបាលបានកែសម្រួលគោលដៅរបស់ខ្លួនឡើងដល់៤០លាននាក់នៅឆ្នាំ២០២០ និងដល់៦០លាននាក់នៅត្រឹមឆ្នាំ២០៣០[60]។ ជប៉ុនមានរមណីយដ្ឋានបេតិកភណ្ឌពិភពលោកចំនួន២០សម្រាប់ទេសចរ[61]។ **រមណីយដ្ឋានទេសចរណ៍**ល្បីល្បាញរួមមាន៖ ទីក្រុងតូក្យូ និងហ៊ីរ៉ូស៊ីម៉ា ភ្នំហ្វូជី រមណីយដ្ឋានជិះស្គី ។ សម្រាប់វិស័យទេសចរណ៍ក្នុងប្រទេសប្រទេសជប៉ុនត្រូវបានជាប់ចំណាត់ថ្នាក់ទី១៦ នៅលើពិភពលោកក្នុងឆ្នាំ២០១៥[62]។ របាយការណ៍ភាពប្រកួតប្រជែងការធ្វើដំណើរ និងទេសចរណ៍ឆ្នាំ២០១៧ ជប៉ុនបានជាប់ចំណាត់ថ្នាក់ទីបួន ក្នុងចំណោមប្រទេសទាំង១៤១ ដែលជាប្រទេសល្អបំផុតនៅទ្វីបអាស៊ី។ ប្រទេសជប៉ុនទទួលបានពិន្ទុខ្ពស់នៅក្នុងស្ទើរតែគ្រប់ទិដ្ឋភាព ជាពិសេសសុខភាព និងអនាម័យ សុវត្ថិភាព និងសន្តិសុខ ធនធានវប្បធម៌ និងការធ្វើដំណើរអាជីវកម្ម[63]។ ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ និងរថភ្លើងល្បឿនលឿនរបស់ប្រទេសជប៉ុនត្រូវបានគេស្គាល់ថា មានសុវត្ថិភាព និងទៀងទាត់ពេលវេលា។

ប្រទេសជប៉ុនគឺជាប្រទេសឈានមុខគេក្នុងការស្រាវជ្រាវ**វិទ្យាសាស្ត្រ និងបច្ចេកទេស**ជាពិសេសនៅក្នុងវិស័យទាក់ទងនឹងវិទ្យាសាស្ត្រធម្មជាតិ និងវិស្វកម្ម។ ប្រទេសនេះស្ថិតនៅលំដាប់ទីពីរ ក្នុងចំណោមបណ្តាប្រទេសច្នៃប្រឌិតថ្មីបំផុតនៅក្នុងសន្ទស្សន៍ច្នៃប្រឌិត Bloomberg[64]។ អ្នកស្រាវជ្រាវជិត៧០០.០០០នាក់បានចែករំលែកថវិកាស្រាវជ្រាវ និងអភិវឌ្ឍន៍ចំនួន១៣០ពាន់លានដុល្លារ[65]។ បរិមាណចំណាយលើការស្រាវជ្រាវ

និងការអភិវឌ្ឍន៍ទាក់ទងនឹងផលិតផលក្នុងស្រុកសរុបខ្ពស់បំផុតទីបីរបស់ខ្លួននៅក្នុងពិភពលោក[66]។ ប្រទេសនេះគឺជាអ្នកដឹកនាំពិភពលោកក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រមូលដ្ឋានដោយបានឈ្នះពានរង្វាន់ណូបែលចំនួន ២២រូប លើផ្នែករូបវិទ្យា គីមីវិទ្យា ឬឱសថ[67] និងមេដាយមាសចំនួនបី[68]។ ឧស្សាហកម្មផលិតគ្រឿងអេឡិចត្រូនិច និងគ្រឿងយន្តរបស់ប្រទេសជប៉ុនត្រូវបានគេស្គាល់ទូទាំងពិភពលោក ហើយផលិតផលអេឡិចត្រូនិច និងអេឡិចត្រូនិចរបស់ប្រទេសនេះមានចំណែកធំនៅក្នុងទីផ្សារពិភពលោក បើប្រៀបធៀបទៅនឹងភាគច្រើននៃបណ្តាប្រទេសដទៃទៀត។ យីហោល្បីៗជាច្រើនមានដូចជា Fujifilm Sony Nintendo Panasonic Toyota Nissan និងHondaសុទ្ធតែល្បីឈ្មោះលើឆាកអន្តរជាតិ[69]។ ប្រទេសជប៉ុនទទួលបានពានរង្វាន់ណូបែលវិទ្យាសាស្ត្រច្រើនបំផុតនៅទ្វីបអាស៊ី និងជាប់ចំណាត់ថ្នាក់លេខប្រាំបី នៅលើពិភពលោក[70]។

**បញ្ហាប្រឈម**ដ៏សំខាន់របស់ជប៉ុនចំពោះសេដ្ឋកិច្ចគឺ ការធ្លាក់ចុះអត្រាកំណើតដែលជះឥទ្ធិពលដល់ស្ថានភាពសេដ្ឋកិច្ច ចំនួនប្រជាជនសកម្មថយចុះ ហើយចំនួនមនុស្សចាស់កើនឡើង។ ការផ្លាស់ប្តូររចនាសម្ព័ន្ធប្រជាសាស្ត្របានបង្កើតបញ្ហាសង្គមមួយចំនួន ជាពិសេសការធ្លាក់ចុះសក្តានុពលនៃកម្លាំងពលកម្ម (ប្រជាជនសកម្ម) និងការបង្កើនចំណាយលើអត្ថប្រយោជន៍របបសន្តិសុខសង្គមដូចជា៖ផែនការសោធនសាធារណៈជាដើម[71]។ ចំនួនប្រជាជនជប៉ុនកាន់តែច្រើនឡើងៗ មិនរៀបការ ឬនៅតែគ្មានកូន[72]។ ការធ្លាក់ចុះនេះត្រូវបានធ្វើឱ្យកាន់តែអាក្រក់ដោយគ្រោះរញ្ជួយដី និងរលកយក្សស៊ូណាមិកាលពីខែមីនាឆ្នាំ២០១១ ដែលសម្លាប់មនុស្សជិត១៦.០០០ នាក់[73]។ ចំនួនប្រជាជនជប៉ុនត្រូវបានគេរំពឹងថានឹងថយចុះដល់៩៥ លាននាក់នៅត្រឹមឆ្នាំ២០៥០[74] ។ ប្រជាសាស្ត្រ និងអ្នកគ្រោងការណ៍របស់រដ្ឋាភិបាលបច្ចុប្បន្នកំពុងស្ថិតនៅក្នុងការពិភាក្សាដ៏ក្តៅគគុកអំពីរបៀបដោះស្រាយបញ្ហានេះ[75]។ ជួនកាល ការលើកទឹកចិត្តជនអន្តោប្រវេសន៍ និងកំណើតគឺត្រូវបានលើកឡើងថាជាដំណោះស្រាយ

មួយដើម្បីផ្តល់ឱ្យកម្មករវ័យក្មេងដើម្បីគាំទ្រដល់ប្រជាជនវ័យចំណាស់របស់ប្រទេស។ ជប៉ុនក៏បានសាកល្បងកែលម្អស្ថានភាពដែរ ដោយពន្យារអាយុចូលនិវត្តន៍ឱ្យដល់អាយុ៧០ឆ្នាំ និងការកម្រិតប្រាក់សោធន។ គេមានគម្រោងឱ្យមនុស្សចាស់ចេញទៅរស់នៅក្នុងប្រទេសក្រៅដែលតម្លៃជីវភាពមិនសូវខ្ពស់។ ជាមួយគ្នានេះ ប្រទេសជប៉ុនក៏ទទួលរងនូវអត្រាការធ្វើអត្តឃាតខ្ពស់ផងដែរ[76]។ ជាក់ស្តែងគ្រាន់តែក្នុងឆ្នាំ២០០៩ ចំនួនអ្នកធ្វើអត្តឃាតបានកើនឡើងលើស៣០,០០០នាក់។ ការធ្វើអត្តឃាត គឺជាមូលហេតុនាំមុខគេនៃការស្លាប់របស់មនុស្សអាយុក្រោម៣០ឆ្នាំ[77]។ មួយវិញទៀត ដោយសារប្រជាជនជប៉ុនភាគច្រើន ចាយលុយតិច និងសន្សំសំចៃច្រើន នាំឱ្យមានការធ្លាក់ចុះនូវតម្លៃទំនិញ និងសេវាកម្មទូទៅ។ នេះមានន័យថា កម្លាំងទិញក្នុងស្រុកមានកម្រិតទាប ដែលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច។ បញ្ហាប្រឈមចុងក្រោយ តាំងពីជប៉ុនធ្លាក់ចំណាត់ថ្នាក់ជាមហាអំណាចសេដ្ឋកិច្ចពិភពលោកពីចំណាត់ថ្នាក់លេខ២ មកជាលេខ៣វិញក្នុងឆ្នាំ២០១០ ដោយត្រូវវ៉ាឈ្នះដោយមហាយក្សចិន ជប៉ុនកាន់តែបារម្ភពីការថមថយនូវតួនាទីរបស់ខ្លួនលើឆាកអន្តរជាតិ នៅចំពោះមុខការលេចត្រដែតឡើងនៃមហាយក្សចិនក្នុងនាមជាមហាអំណាចសេដ្ឋកិច្ច នយោបាយ និងយោធា។ ក្នុងបរិយាកាសប្រកបដោយទុទិដ្ឋិនិយមបែបនេះ ជប៉ុនបារម្ភពីខ្លួនឯងកាន់តែខ្លាំង និងបារម្ភពីការបាត់បង់អរិយធម៌របស់ខ្លួនចំពោះអនាគតមួយមិនជាក់លាក់ ដោយសារការប្រកួតប្រជែង និងគ្រោះភ័យនៃគ្រោះមហន្តរាយដែលជប៉ុនបានជួបប្រទះ ពិសេសបទពិសោធរងគ្រោះពីការរញ្ជួយដី រលកយក្សស៊ូណាមិ និងគ្រោះមហន្តរាយនុយក្លេអ៊ែរនៅផុគុស៊ីម៉ាឆ្នាំ២០១១។

## 2.2) ប្រព័ន្ធអប់រំប្រទេសជប៉ុន

ការរីកចម្រើនសេដ្ឋកិច្ចដ៏ខ្លាំងក្លារបស់ជប៉ុនដូចការរៀបរាប់ខាងលើ មិនអាចកាត់ផ្តាច់ចេញការចូលរួមចំណែកដ៏ធំធេងរបស់សង្គម និងវប្ប

ធម៌ដ៏វិសេសវិសាលនោះទេ។ នេះគឺដោយសារជប៉ុនមានពលរដ្ឋសកម្ម ដែលមានចំណេះដឹងខ្ពស់ និងជំនាញច្បាស់លាស់ច្រើន ដែលទាំងនោះបានមកពីការអប់រំ និងការបណ្តុះបណ្តាលទាំងអស់។ មួយវិញទៀត ជនជាតិជប៉ុនមានវប្បធម៌ដែលឱ្យតម្លៃខ្លាំងទៅលើវិន័យ ការគោរពថ្នាក់ដឹកនាំ គោរពគ្នាទៅវិញទៅមក និងផ្តោតទៅលើប្រយោជន៍សមូហភាពជាធំ។ ទាំងនេះជាគុណតម្លៃដ៏ថ្លៃថ្លាមិនអាចកាត់ថ្លៃបាននៃប្រព័ន្ធអប់រំជប៉ុន។

| | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ***ការអប់រំជាភាគព្វកិច្ច (៦+៣=៩ឆ្នាំ)*** | | | | | | | | | | | | | | | | | | | | | |
| | ការអប់រំបឋមសិក្សា | | | | | | ការអប់រំមធ្យមសិក្សា | | | | | | ការអប់រំជាន់ខ្ពស់ | | | | | | | | | |
| អាយុ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | - |
| ថ្នាក់ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | - |
| កម្រិត | បឋមសិក្សា | | | | | | អនុវិទ្យាល័យ | | | វិទ្យាល័យ | | | សាកលវិទ្យាល័យ | | | | | | | | | |
| | | | | | | | | | | | | | អនុមហាវិទ្យាល័យ | | | | ក្រោយឧត្តមសិក្សា | | | | | |
| | | | | | | | | | | | | | សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈ | | | | | | | | | |
| | | | | | | | | | | | | | សាលាបណ្ដុះបណ្ដាលជំនាញឯកទេស | | | | | | | | | |
| | | | | | | | | | | សាលាបច្ចេកទេស | | | | | | | | | | | | |
| | | | | | | | | | | សាលាបណ្ដុះបណ្ដាលជំនាញឯកទេស | | | | | | | | | | | | |

**ខាងក្រោមគឺជាការសិក្សាយ៉ាងទូលំទូលាយពីប្រព័ន្ធអប់រំរបស់ប្រទេសមួយនេះ។**

**ប្រព័ន្ធអប់រំជប៉ុនបច្ចុប្បន្ន**

## 2.3) ដំណើរវិវត្តន៍-ផ្លាស់ប្តូរប្រព័ន្ធអប់រំជប៉ុន

សម្រាប់ការរៀបរាប់បង្ហាញពីដំណើរវិវត្តន៍ផ្លាស់ប្តូរប្រព័ន្ធអប់រំរបស់ប្រទេសជប៉ុនខាងក្រោម ត្រូវបានសង្ខេបចេញពីសៀវភៅ៖ (Japan International Cooperation Agency (2004), *The History of Japan's Educational Development* JICA)

នៅមុនសម័យ**មីអិជិ** ប្រទេសជប៉ុនមិនទាន់មានប្រព័ន្ធអប់រំ និងស្ថាប័នគ្រប់គ្រងច្បាស់លាស់នៅឡើយទេ។ សាលារដ្ឋបង្កើតឡើងសម្រាប់តែយុវជនវ័យក្មេងរបស់ពួកសាម៉ូរ៉ៃដែលមានឥទ្ធិពលនៅសម័យនោះ។ ចូលដល់សម័យមីអិជី ប្រទេសជប៉ុនបានបើកចំហទ្វារប្រទេសទទួលយកទំនាក់ទំនងពាណិជ្ជកម្ម ទំនាក់ទំនងអន្តរជាតិ និងវិស័យផ្សេងៗទៀតជាមួយពិភពខាងក្រៅ(ប្រទេសផ្សេងៗ) ដើម្បីប្រែក្លាយប្រទេសខ្លួនឱ្យមានជឿនលឿនដូចលោកខាងលិច។ សម្រាប់ប្រព័ន្ធអប់រំ ក៏ដូច្នេះដែរគឺចាប់ផ្តើមធ្វើការផ្លាស់ប្តូរប្រព័ន្ធអប់រំបែបប្រពៃណីទៅរកលំនាំបែបលោកខាងលិច ដែលអ្នកដឹកនាំជប៉ុននៅសម័យនោះយល់ឃើញថា ដើម្បីឱ្យប្រទេសរីកចម្រើនជឿនលឿន ទាល់តែធ្វើទំនើបកម្មប្រព័ន្ធតាមគំរូអរិយប្រទេសដូចសហរដ្ឋអាមេរិកជាដើម។ ប្រព័ន្ធអប់រំជប៉ុននៅសម័យនេះ ត្រូវបានកែលម្អឡើងវិញ ហើយប្រទេសជប៉ុនបានអញ្ជើញអ្នកជំនាញជនជាតិអាមេរិកម្នាក់ឈ្មោះ David Murray ឱ្យមកធ្វើជាទីប្រឹក្សាលើកដំបូង ដោយដើរតួនាទីសំខាន់ធ្វើជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ដំបូន្មានក្នុងការកំណត់ទិសដៅ (Direction) និងរៀបចំគោលការណ៍ណែនាំ (Guideline) សម្រាប់គោលនយោបាយអប់រំ ព្រមទាំងបានបង្កើតឱ្យចេញជារូបរាងនូវក្រសួងអប់រំនៅឆ្នាំ១៨៧១ និងការិយាល័យអធិការកិច្ចយកលំនាំតាមលោកខាងលិច រួមទាំងរៀបចំកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនផងដែរ។ នេះជារបត់ថ្មីរបស់ជប៉ុន ប៉ុន្តែការអនុវត្តនៅជួបប្រទះនូវបញ្ហាប្រឈមច្រើនដោយសារគ្រូបង្រៀនជប៉ុនភាគច្រើនពិបាកសម្របខ្លួនជាមួយប្រព័ន្ធថ្មី និងផ្លាស់ប្តូរទម្លាប់ចាស់ដែលជាប្រពៃណីដ៏យូរលង់របស់

ខ្លួន។ ដោយសារបញ្ហាប្រឈមនេះ ឆ្នាំ១៨៧៨ជប៉ុនបានដាក់ចេញនូវបទបញ្ញត្តិថ្មី ដោយអនុញ្ញាតឱ្យខេត្ត/ក្រុងនីមួយៗអាចរៀបចំកម្មវិធីសិក្សាស្របតាមតម្រូវការ ដោយឡែកៗរបស់ខ្លួនដែលមានភាពផ្សេងគ្នានូវខ្លឹមសារអប់រំ និងសៀវភៅសិក្សាគោល។ នេះជាការអនុវត្តគោលនយោបាយនៃការផ្ទេរអំណាចទៅថ្នាក់ក្រោមជាតិ ដោយការបើកចំហសេរីភាព និងសិទ្ធិចលនាមហាជន ហើយគោលនយោ-បាយបែបនេះ ក្រោយមកនាំឱ្យមានការប្រឈមមុខជាមួយនឹងរដ្ឋាភិបាលមីអិជិ និងប៉ះពាល់ឥទ្ធិពលព្រះចៅអធិរាជ។ ជាក់ស្តែងសមាគមគ្រូបង្រៀន ចាប់ផ្តើមហ៊ានធ្វើការតវ៉ាទាមទារអត្ថប្រយោជន៍នានាពីរដ្ឋាភិបាលជាដើម ដែលបង្កឱ្យមានភាពចលនាចល និងអស្ថេរភាពក្នុងប្រទេស។ ចុងបញ្ចប់នៃភាពចលាចលនេះ នាំឱ្យមានការប៉ះទង្គិចដែលឈានទៅរកការបង្ក្រាប និងធ្វើការកែទម្រង់ប្រព័ន្ធអប់រំដែលមានលក្ខណៈបរទេសចេញដើម្បីទប់ស្កាត់ភាពរញ៉េរញ៉ៃ និងអាណាធិបតេយ្យនៅក្នុងប្រទេស។ នៅសម័យនេះ ថ្វីត្បិតតែមានការផ្ទេរអំណាចខ្លះទៅថ្នាក់ក្រោមជាតិ តែប្រព័ន្ធអប់រំទាំងមូលនៅតែស្ថិតក្រោមការគ្រប់គ្រងរបស់ព្រះចៅអធិរាជដដែល។ ដើម្បីលើកកម្ពស់កិត្យានុ-ភាពព្រះចៅអធិរាជ រាជរដ្ឋាភិបាលជប៉ុនបានចេញបទបញ្ជាអប់រំដែលធ្វើការកែប្រែក្នុងឆ្នាំ១៨៨០ ដោយបានដាក់បញ្ចូលការអប់រំសីលធម៌ទៅក្នុងប្រព័ន្ធអប់រំ ដែលការអប់រំនេះមានការគាំទ្រយ៉ាងពេញទំហឹងលើ**លទ្ធិខុងជឺនិយម**ផ្តោតលើ៖ **មនុស្សធម៌ យុត្តិធម៌** និង**ភាពស្មោះស្ម័គ្រ**។ សម្រាប់កម្រិតបឋមសិក្សា ត្រូវបានកំណត់មានរយៈពេល៨ឆ្នាំ ដោយមានដាក់បញ្ចូលខ្លឹមសារអប់រំលទ្ធិខុងជឺ និងការបង្កើតតួនាទីអប់រំនូវសារៈប្រយោជន៍នៃការអនុវត្តលទ្ធិនេះ។ បន្ទាប់មកនៅឆ្នាំ១៨៨៦ ប្រព័ន្ធអប់រំជប៉ុនមានភាពច្បាស់លាស់ជាងមុន តាមរយៈនៃការកំណត់ដាក់លាក់នូវចំនួនមុខវិជ្ជា ស្តង់ដារមុខវិជ្ជា និងចំនួនម៉ោងបង្រៀន ព្រមទាំងដាក់ឱ្យអនុវត្តនូវប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណលើសៀវភៅសិក្សាគោលតាមខេត្ត/ក្រុងនីមួយៗដោយក្រសួងអប់រំ។ ក្រោយមកប្រទេសជប៉ុនបានរំកិលមកដល់យុគ្គសម័យតៃស៊ុ(១៩១២-១៩២៦)ដែលទ្រឹស្តីអប់រំទំនើបត្រូវបានយកចិត្តទុកដាក់។ ការបង្កើតចលនាការអប់រំប្រកបដោយវឌ្ឍភាព និងចាប់ផ្តើមគិតពីកុមារមជ្ឈមណ្ឌល (Children Centre) ដែលជំរុញឱ្យមានការកែទម្រង់អប់រំ ពិសេសលើទ្រឹស្តីអប់រំ និងវិធីសាស្ត្របង្រៀន។ ទោះបីយ៉ាងណាក៏ដោយ

ការប៉ុនប៉ងទំនើបកម្មនេះមិនបានសម្រេចទេ ព្រោះវាត្រូវបានរាំងខ្ទប់ដោយការត្រួតពិនិត្យពីសំណាក់រដ្ឋាភិបាលថ្នាក់កណ្តាល ដែលព្រួយបារម្ភពីការប៉ះពាល់ដល់ឥទ្ធិពលព្រះចៅអធិរាជនៅក្នុងសង្គមជប៉ុន។ ក្នុងឆ្នាំ១៩២៦ ជប៉ុនឈានដល់យុគសម័យថ្មីមួយទៀតគឺ សម័យស៊្វាដែលគំនិតជាតិនិយមបានជះឥទ្ធិពលដល់ប្រព័ន្ធអប់រំយ៉ាងខ្លាំង ហើយនៅចុងឆ្នាំ១៩៣០ ចលនាឆ្ពោះទៅរកការកែទម្រង់កម្មវិធីសិក្សានៅក្នុងការគ្រប់គ្រង និងរដ្ឋបាលត្រូវបានមើលឃើញច្បាស់។ ឆ្នាំ១៩៣៦ រាជរដ្ឋាភិបាលបានប្រកាសបំណងរបស់ខ្លួនក្នុងការអនុវត្តពេញលេញនូវកំណែទម្រង់សំដៅពង្រឹងប្រព័ន្ធអប់រំដើម្បីត្រៀមលក្ខណៈសម្រាប់ពេលមានសង្គ្រាម (កម្មវិធីសិក្សាដែលបណ្តុះនិន្នាការជាតិនិយមខ្លាំង និងពលីកម្មស្មគ្រស្មោះនឹងព្រះចៅអធិរាជ) ដែលជប៉ុនប្រើប្រាស់សម្រាប់ពង្រឹងស្មារតីជាតិនិយមដល់ជនជាតិជប៉ុន សម្រាប់បម្រើដល់ការធ្វើសង្គ្រាមចក្រពត្តិ ហើយប្រព័ន្ធនេះជះឥទ្ធិពលខ្លាំងដល់យុទ្ធជនជប៉ុនក្នុងសង្គ្រាមលោកលើកទី២ ដែលមានលក្ខណៈមុះមុត ក្លាហាន និងហ៊ានពលីកម្ម...។ ប្រព័ន្ធអប់រំបែបនេះបាននាំជប៉ុនទៅរកសោធនាកម្មដែលកើតឡើងដោយសារសង្គ្រាម ពិសេសការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរពីសំណាក់សហរដ្ឋអាមេរិក។ បន្ទាប់មក ក្រោយសង្គ្រាមលោកលើកទី២បានបញ្ចប់ និងភាពបរាជ័យរបស់ជប៉ុនក្នុងសង្គ្រាម ប្រទេសនេះទាំងមូលត្រូវស្ថិតក្រោមការគ្រប់គ្រងដោយកងទ័ពសម្ព័ន្ធមិត្តដែលឈ្នះសង្គ្រាម រួមទាំងការគ្រប់គ្រងប្រព័ន្ធអប់រំជាតិ។ មកដល់ដំណាក់កាលនេះ ប្រព័ន្ធអប់រំជប៉ុនត្រូវយកតាមលំនាំសហរដ្ឋអាមេរិក ហើយកម្មវិធីសិក្សាជប៉ុនមានទំនោរទៅរកគំនិតអប់រំប្រជាធិបតេយ្យបែបលោកខាងលិច។ នៅសម័យកាលនេះ មានការផ្ទេរអំណាចនៃការគ្រប់គ្រងអប់រំទៅឱ្យថ្នាក់ខេត្ត និងរដ្ឋបាលតំបន់ដើម្បីជៀសវាងការប្រើប្រាស់អំណាចខុសរបស់ក្រសួងអប់រំ ហើយប្រព័ន្ធអធិការកិច្ចកិច្ចត្រូវលុបចោលដាក់ជំនួសដោយប្រព័ន្ធផ្តល់ប្រឹក្សា និងទីប្រឹក្សាបច្ចេកទេសសមត្ថភាពវិញដែលជាអ្នកផ្តល់ទូន្មាន និងសេចក្តីណែនាំ ដោយមិនមានអំណាចរដ្ឋបាល និងគោលនយោបាយមកលាយឡំ។ នេះជាការធ្វើវិមជ្ឈការលើកទី២របស់ជប៉ុន ដែលខុសពីប្រព័ន្ធបច្ចុប្បន្នអនុវត្តបែបមជ្ឈការ។ ឆ្នាំ១៩៤៦ ជប៉ុនរៀបចំរដ្ឋធម្មនុញ្ញថ្មី ហើយសិទ្ធិទទួលបានការអប់រំត្រូវបានបង្កើតដែលជាសិទ្ធិជាមូលដ្ឋានមួយក្នុងចំណោមសិទ្ធិទាំងឡាយ។ ជាមួយគ្នានេះ ជប៉ុនបាន

បង្កើតច្បាប់ជាមូលដ្ឋាននៃការអប់រំ ច្បាប់អប់រំនៅសាលារៀន ក្រុមប្រឹក្សានៃច្បាប់អប់រំ ច្បាប់អប់រំសង្គម និងច្បាប់សាលាឯកជន ព្រមទាំងសម្រេចលុបចោលសេចក្តីថ្លែងការរបស់ព្រះចៅអធិរាជជប៉ុនលើការអប់រំ។ ឆ្នាំ១៩៤៨ ច្បាប់ក្រុមប្រឹក្សាអប់រំ ត្រូវបានគេផ្តល់សិទ្ធិអំណាចដល់ក្រុមប្រឹក្សាអប់រំសម្រាប់ស្វ័យភាពក្នុងសម្រេចចិត្តថ្នាក់តំបន់។ មកដល់នៅឆ្នាំ១៩៥១ ការកាន់កាប់របស់សម្ព័ន្ធមិត្តលើជប៉ុនត្រូវបញ្ចប់ ហើយជប៉ុនទទួលបានបូរណភាពទឹកដីខ្លួនមកវិញ និងចាប់ពិនិត្យឡើងវិញនូវគោលនយោបាយទាំងឡាយដែលបានអនុវត្តអំឡុងពេលកាន់កាប់របស់កងទ័ពសម្ព័ន្ធមិត្ត។ រចនាសម្ព័ន្ធមូលដ្ឋាននៃកំណែទម្រង់អប់រំក្រោយសង្គ្រាមរក្សាទុកនៅដដែល តែប្រព័ន្ធមានការកែសម្រួលឱ្យស៊ីនឹងស្ថានភាពរបស់ជប៉ុន។ ប្រព័ន្ធក្រុមប្រឹក្សាអប់រំត្រូវបានលុបចោល តែក្រោយមកនៅឆ្នាំ១៩៥៦ ជប៉ុនចាប់ផ្តើមសើរើឡើងវិញនូវប្រព័ន្ធក្រុមប្រឹក្សាអប់រំនេះដោយរក្សាទុកឡើងវិញ និងចេញច្បាប់កែទម្រង់រដ្ឋបាលតំបន់។ ឆ្នាំ១៩៥៨ ធ្វើការកែប្រែកម្មវិធីសិក្សាលើកកម្ពស់ការអប់រំសីលធម៌ និងសមត្ថភាពសិក្សាមូលដ្ឋាន ហើយការកំណែទម្រង់កម្មវិធីសិក្សានេះ គឺដើម្បីឆ្លើយតបនឹងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយផ្តោតលើវិទ្យាសាស្ត្រ បច្ចេកទេស និងវប្បធម៌ ពិសេសពង្រឹងការប្រកួតប្រជែងកម្រិតសាកល។ ដោយសារឥទ្ធិពលលទ្ធិខុងជឺ ពិសេសការអប់រំសីលធម៌ នៅក្នុងប្រព័ន្ធអប់រំជប៉ុន ធ្វើឱ្យមានការដាក់សម្ពាធលើការសិក្សាពីសំណាក់មាតាបិតា អាណាព្យាបាលសិស្ស និងគ្រូបង្រៀន មានសភាពធ្ងន់ធ្ងរដែលបណ្តាលឱ្យមានអត្រាធ្វើអត្តឃាតខ្ពស់នៅក្នុងសង្គមជប៉ុន។ កំណែទម្រង់ "ថ្នាក់រៀនសម្រាប់បញ្ច្រកចំណេះដឹង និងជំនាញដល់សិស្សសម្រាប់ការរីកលូតលាស់" ( Yutori =Room to grow) បានលក្ខណៈរឹតបន្តឹងដល់ការសិក្សាសិស្សហួសប្រមាណដើម្បីឱ្យពួកគេទទួលបានចំណេះដឹងពេញលេញនិងជំរុញឱ្យការសិក្សាមានលក្ខណៈប្រកួតប្រជែងគ្នាខ្លាំងក្លា ដែលធ្វើឱ្យការអប់រំជួបប្រទះនូវបញ្ហាប្រឈមច្រើន ពិសេសការកើនឡើងនូវការធ្វើអត្តឃាតក្នុងចំណោមយុវជន។

## 2.4) ការពិភាក្សាពីប្រព័ន្ធអប់រំជប៉ុន

ប្រព័ន្ធអប់រំរបស់ប្រទេសជប៉ុនបានដើរតួសំខាន់នៅក្នុងការងើបឡើងវិញ និងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងប៉ុន្មានទសវត្សរ៍ក្រោយពីសង្គ្រាមលោកលើកទី២បានបញ្ចប់។ នៅឆ្នាំ១៩៤៧ ច្បាប់មូលដ្ឋាននៃការអប់រំ និងច្បាប់អប់រំនៅសាលារៀនត្រូវបានអនុម័ត។ ប្រព័ន្ធអប់រំនៅកម្រិតបឋមសិក្សាមានរយៈពេល៦ឆ្នាំ អនុវិទ្យាល័យ៣ឆ្នាំ វិទ្យាល័យ៣ឆ្នាំ និងសាកលវិទ្យាល័យ២ ឬ៤ឆ្នាំ។ ការអប់រំជាកាតព្វកិច្ចមានរយៈពេល៩ឆ្នាំ (កម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ)ដូចប្រទេសកម្ពុជាដែរ។ ថ្វីបើការអប់រំរយៈពេលបីឆ្នាំនៅថ្នាក់វិទ្យាល័យមិនមែនជាផ្នែកមួយនៃការអប់រំជាកាតព្វកិច្ចក៏ដោយ ក៏រដ្ឋាភិបាលជប៉ុនបានអនុម័ត «**ច្បាប់ស្តីពីតម្លៃសិក្សាឥតគិតថ្លៃនៅវិទ្យាល័យសាធារណៈ និងមូលនិធិគាំទ្រការចុះឈ្មោះចូលរៀននៅវិទ្យាល័យ**» កាលពីខែមេសាឆ្នាំ២០១០។ បទបញ្ញត្តិនេះ តម្រូវឱ្យសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅសាលារដ្ឋមិនគិតថ្លៃ និងបង្កើតប្រព័ន្ធមូលនិធិគាំទ្រការសិក្សានៅវិទ្យាល័យសម្រាប់ការចំណាយបង់ថ្លៃសិក្សាដល់សិស្សនៅសាលាវិទ្យាល័យឯកជន(78)។ ជប៉ុនត្រូវបានគេទទួលស្គាល់ថាជាប្រទេសមួយដែលមានប្រព័ន្ធអប់រំល្អនៅលើពិភពលោក។ នៅក្នុងការប្រកួតប្រជែងគណិតវិទ្យាជាអន្តរជាតិ សិស្សជប៉ុនតែងតែជាប់ចំណាត់ថ្នាក់កំពូលនៅក្នុងតារាងប្រទេសដែលមានចំណាត់ថ្នាក់ខ្ពស់លើសគេ។ ប្រទេសជប៉ុនមានប្រវត្តិសាវតាអប់រំរឹងមាំ និងចូលរួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចជាតិ។ ជាទូទៅ បុគ្គលដែលមានការអប់រំខ្ពស់នៅជប៉ុន មិនសូវរងផលប៉ះពាល់ពីនិន្នាការនៃភាពគ្មានការងារធ្វើទេ ខណៈដែលកម្រិតនៃការអប់រំខ្ពស់ធ្វើឱ្យបុគ្គលនោះមានភាពទាក់ទាញជាកម្លាំងការងារស្នូល។ យុគសម័យសតវត្សរ៍ទី២១ តម្រូវការទីផ្សារការងារដែលមានមូលដ្ឋានផ្អែកលើចំណេះដឹង និងសមត្ថភាព-សម្បទារឹងមាំផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា ជាកម្លាំងពលកម្មមិនអាចអត់បានសម្រាប់ការងារនៅក្នុងសេដ្ឋកិច្ចបច្ចេកវិទ្យាខ្ពស់របស់ប្រទេសជប៉ុន(79)។ ដោយផ្អែកលើលទ្ធផលតេស្តPISA ប្រទេសជប៉ុនគឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសដែលមានដំណើរការកំពូលៗនៃប្រទេសសេដ្ឋកិច្ចជឿនលឿនក្នុងអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច(OECD) សម្រាប់ការអាន គណិតវិទ្យា និងវិទ្យាសាស្ត្រដែលមានពិន្ទុសិស្សជាមធ្យម៥៤០ និងជាប្រទេសដែលមានកម្លាំងពលកម្មប្រកបដោយចំណេះដឹងខ្ពស់

បំផុតក្នុងចំណោមប្រទេសជាសមាជិករបស់OECD(80)។ ប្រជាជនជប៉ុនទទួលការអប់រំយ៉ាងល្អ ហើយសង្គមក៏ឱ្យតម្លៃខ្ពស់ដល់ការអប់រំផងដែរ។ វាត្រូវបានចាត់ទុកថាជាវេទិកាសម្រាប់ជំរុញវឌ្ឍនភាពសង្គម និងដើម្បីទទួលបានការងារនៅក្នុងសេដ្ឋកិច្ចដែលមានបច្ចេកវិទ្យាខ្ពស់ក្នុងការប្រកួតប្រជែងកម្រិតសាកល(81)។ និស្សិតប្រហែល ៧៥,៩%បានបញ្ចប់ការសិក្សានៅវិទ្យាល័យ និងបានចូលរៀននៅសាកលវិទ្យាល័យ មហាវិទ្យាល័យ សាលាពាណិជ្ជកម្ម ឬគ្រឹះស្ថានឧត្តមសិក្សាផ្សេងទៀត(82)។ ថ្វីបើការចំណាយសម្រាប់សិស្សម្នាក់ៗមានកម្រិតខ្ពស់នៅក្នុងប្រទេសជប៉ុនក៏ដោយ ក៏ការចំណាយសរុបទាក់ទងទៅនឹងផលិតផលក្នុងស្រុកសរុប( GDP )នៅតែតិចតួចនៅឡើយ។ នៅឆ្នាំ២០១៥ ការចំណាយសាធារណៈរបស់ប្រទេសជប៉ុនលើវិស័យអប់រំមានចំនួនត្រឹមតែ៣,៥%នៃផលិតផលក្នុងស្រុកសរុប( ផ.ស.ស GDP) របស់ខ្លួនដែលទាបជាងមធ្យមភាគរបស់OECDដែលមានមធ្យមភាគ៤,៧%(83)។ នៅក្នុងឆ្នាំ ២០១៤ ប្រទេសជប៉ុនឈរនៅលំដាប់ទីបួនសម្រាប់ភាគរយខ្ពស់នៃប្រជាជនមានអាយុពី២៥ដល់៦៤ឆ្នាំដែលទទួលបានការអប់រំកម្រិតឧត្តមសិក្សាមាន៤៨%។ លើសពីនេះទៀត ជនជាតិជប៉ុនដែលមានអាយុពី២៥ ដល់៣៤ឆ្នាំមានសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រមាន៥៩% ដែលជាលំដាប់ទីពីរនៅក្នុង OECD បន្ទាប់ពីកូរ៉េខាងត្បូង(84)។ លទ្ធផលល្អរបស់ជប៉ុនវាអាស្រ័យដោយការប្តេជ្ញាចិត្តរបស់សិស្ស-និស្សិតជប៉ុន គុណភាពនៃការបង្រៀន ការគាំទ្ររបស់គ្រួសារ និងជំនឿទុកចិត្តលើការប្រឹងប្រែង ជាអ្វីដែលនាំឆ្ពោះទៅរកភាពជោគជ័យ។ ដើម្បីវិភាគឱ្យដឹងថាហេតុអ្វីបានតេស្តPISA ជប៉ុនទទួលលទ្ធផលល្អប្រសើរ យើងនឹងស្វែងយល់ទិដ្ឋភាពមួយចំនួនដូចជា៖ **ការចំណាយលើវិស័យអប់រំ ទំនាក់ទំនងរវាងសាវតារសេដ្ឋកិច្ច-សង្គម** និង**ការអប់រំ សមធម៌ក្នុងទទួលបានឱកាសសិក្សារៀនសូត្រ ឥរិយាបថសិស្សចំពោះការសិក្សា អក្ខរកម្មបច្ចេកវិទ្យាឌីជីថល និងបរិស្ថានសិក្សា**។

ទាក់ទងនឹងកម្រិតចំណូលជាតិប្រទេសជប៉ុនមានចំណាត់ថ្នាក់ទី១៧ក្នុងចំណោមប្រទេសដែលសេដ្ឋកិច្ចជឿនលឿនទាំង៣៤ដែលជាសមាជិកOECDលើផ្នែក ផ.ស.សសម្រាប់មនុស្សម្នាក់(85)។ នៅពេលដែល ផ.ស.ស សម្រាប់មនុស្សម្នាក់ ឆ្លុះបញ្ចាំងពីធនធានសក្តានុពលដែលអាចផ្តល់ដល់ការអប់រំសម្រាប់ប្រទេសនីមួយៗ វា

មិនមែនវាស់វែងដោយផ្ទាល់ពីធនធានហិរញ្ញវត្ថុដែលវិនិយោគដាក់លាក់លើវិស័យអប់រំទេ។ លទ្ធផលPISA បានបង្ហាញថា ប្រព័ន្ធអប់រំជប៉ុនមានភាពខ្លាំង ទោះបីជាការចំណាយសរុបលើវិស័យអប់រំទាំងរដ្ឋ និងឯកជនតិចជាងប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀតក៏ដោយ។ ការចំណាយសាធារណៈ លើវិស័យអប់រំរបស់ជប៉ុន នៅមានកម្រិតទាបក្នុងឆ្នាំ២០១១គឺមានតែ៩.១% ប៉ុណ្ណោះទាបជាងប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀតមាន១២.៩%[86]។ ក្នុងការប្រៀបធៀបមធ្យមភាគរបស់ប្រទេសទាំងឡាយដែលចំណាយដាក់លាក់លើសិស្សម្នាក់ពីអាយុ៦ឆ្នាំដល់១៥ឆ្នាំ ប្រទេសជប៉ុនមានចំណាត់ថ្នាក់ទី១៤ ក្នុងចំណោម៣៤ប្រទេស។ ប្រទេសមួយចំនួនមានការចំណាយសម្រាប់សិស្សម្នាក់ប្រហាក់ប្រហែលនឹងជប៉ុនដែរដូចជា៖ ប្រទេស**អ៊ីតាលី** និង**ស្លូវ៉ានី** តែលទ្ធផលគេស្ទាវាយតម្លៃទទួលពិន្ទុតិចជាងជប៉ុន។ ផ្អែកតាមការវិភាគនេះ វាបង្ហាញថា៖ "**ជប៉ុនចំណាយតិចលើការអប់រំ តែទទួលលទ្ធផលច្រើន**" (Low invest, high return)។ ***តើកត្តាអ្វីដែលធ្វើឱ្យជប៉ុនទទួលលទ្ធផលល្អប្រសើរជាងប្រទេសផ្សេងៗដែលចំណាយប្រហាក់ប្រហែលគ្នានោះ?***

ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនត្រូវបានកំណត់អាទិភាពសម្រាប់ពង្រឹងគុណភាពអប់រំ។ កត្តាដែលធ្វើឱ្យជប៉ុនទទួលលទ្ធផលល្អជាងគេ គឺភាពទាក់ទងរវាងគុណភាពគ្រូបង្រៀន និងចំនួនសិស្សក្នុងមួយថ្នាក់។ ផ្អែកតាមលទ្ធផលPISA បង្ហាញថា ភាពជោគជ័យនៃការអប់រំកើតឡើងដោយសារអន្តរទំនាក់ទំនងរវាងការយកចិត្តទុករបស់សិស្ស និងប្រាក់បៀវត្សគ្រូបង្រៀន ហើយប្រាក់បៀវត្សនេះវាក៏មានទំនាក់ទំនងនឹងប្រាក់ចំណូលជាតិដែរ។ មួយវិញទៀត ប្រាក់បៀវត្សគ្រូបង្រៀនក៏ទាក់ទងជាមួយទំហំថ្នាក់រៀនផងដែរ។ បើចំណាយប្រហាក់ប្រហែលគ្នា ប្រព័ន្ធអប់រំអាចផ្លាស់ប្តូរគ្នារវាងទំហំថ្នាក់តូច និងប្រាក់ឧបត្ថម្ភគ្រូបង្រៀនច្រើន។ **ប្រព័ន្ធដែលកំណត់អាទិភាពលើប្រាក់បៀវត្សគ្រូបង្រៀន លើទំហំថ្នាក់រៀនកាន់តែតូចមានទំនោរទៅរកការអនុវត្តបានល្អប្រសើរលើលទ្ធផលសិក្សារបស់សិស្ស**។ ការស្រាវជ្រាវនេះចង់បង្ហាញថា ប្រទេសជប៉ុនជោគជ័យដោយសារគោលនយោបាយផ្តល់អត្ថប្រយោជន៍ច្រើនដល់គ្រូបង្រៀន និងផ្តោតលើចំនួនសិស្សតិចក្នុងមួយថ្នាក់ ដែលជាចំណុចលេចធ្លោជោគជ័យខ្លាំងជាងប្រទេសផ្សេងដែលចំណាយប្រហាក់ប្រហែលគ្នា[86]។ *នេះជាមេរៀនរៀន*

*សូត្រមួយសម្រាប់កម្ពុជា ក្នុងការអនុវត្តគោលនយោបាយលើកកម្ពស់គុណវុឌ្ឍិ និងបង្កើនបៀវត្សគ្រូបង្រៀន តែបើចំនួនសិស្សក្នុងមួយថ្នាក់មានចំនួនច្រើន នៅតែជាឧបសគ្គដ៏ធំមួយក្នុងការលើកកម្ពស់គុណភាពអប់រំដដែល។*

ចំណុចមួយទៀតដែលជះឥទ្ធិពលទៅលើភាពជោគជ័យប្រព័ន្ធអប់រំជប៉ុន គឺកម្រិតអប់រំរបស់**ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលរបស់សិស្ស**ជប៉ុនខ្ពស់ជាងប្រទេសផ្សេងៗទៀត[86]។ លទ្ធផលស្រាវជ្រាវបង្ហាញថា៖ អន្តរទំនាក់ទំនងជិតស្និទ្ធរវាងការសិក្សារបស់កូន និងកម្រិតនៃការអប់រំរបស់ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ជាគន្លឹះសំខាន់មួយក្នុងការចូលរួមចំណែកលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ។ ឪពុកម្ដាយជប៉ុន៤៨%មានកម្រិតអប់រំខ្ពស់ ចំណាត់ខ្ពស់លេខពីរបន្ទាប់ពីប្រទេសកាណាដាក្នុងចំណោមប្រទេសសេដ្ឋកិច្ចជឿនលឿនទាំង៣៤[86]។ កម្រិតយល់ដឹងរបស់ឪពុកម្ដាយនេះ ពិតជាមានសារៈសំខាន់ណាស់ក្នុងការជំរុញ លើកទឹកចិត្តកូនឱ្យខិតខំសិក្សារៀនសូត្រ និងចូលរួមចំណែកជួយបង្ហាត់បង្រៀនបន្ថែមដល់ពួកគាត់នៅផ្ទះ។ នៅពេលដែលឪពុកម្ដាយ ឬអ្នកអាណាព្យាបាលយល់ពីគុណតម្លៃ និងអត្ថប្រយោជន៍នៃការអប់រំ ពួកគេនឹងយកចិត្តទុកដាក់តាមដាន ត្រួតពិនិត្យលទ្ធផលសិក្សារបស់កូនៗ។ **នៅប្រទេសកម្ពុជា** ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលមួយចំនួនធំមិនមានការអប់រំខ្ពស់ទេ (ឆ្លងកាត់សង្គ្រាមស៊ីវិលជាច្រើនទស្សវត្សរ៍) មិនតែប៉ុណ្ណោះមួយចំនួនទៀតធ្វើចំណាកស្រុកទុកកូនឱ្យរស់នៅជាមួយជីដូនជីតា ឬញាតិសន្តាន ដែលធ្វើឱ្យមានការលំបាកច្រើនក្នុងការជួយដល់ពួកគាត់ ដើម្បីសម្រេចលទ្ធផលសិក្សា។ មួយវិញទៀត វាក៏មានការលំបាកផងដែរសម្រាប់ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលជួយបង្ហាត់បង្រៀនកូនបន្ថែមនៅផ្ទះ ព្រោះ**វិធីសាស្ត្របង្រៀនពីជំនាន់មុន និងជំនាន់ក្រោយមិនដូចគ្នា** តួយ៉ាងដូចមុខវិជ្ជាគណិតវិទ្យាជាដើម។ **នេះមានន័យថា៖ "ទំនាក់ទំនងរវាងសាលារៀន** និង**សហគមន៍ហាក់ដាច់ពីគ្នាពីមួយជំនាន់ទៅមួយជំនាន់**" ដែលផ្ដល់ឧបសគ្គច្រើនដល់ឪពុកម្ដាយក្នុងការជួយកូនៗរបស់ពួកគាត់។

ចំណុចទី៣ទាក់ទងនឹងគោលនយោបាយយកចិត្តទុកដាក់ខ្លាំងលើ**កុមារមកពីគ្រួសារងាយរងគ្រោះ**ដើម្បីមាន**លទ្ធភាពទទួលបានការអប់រំសម្រាប់ទាំងអស់គ្នាប្រកបដោយសមធម៌ និងគុណភាព**។ សិស្សជប៉ុន១០%មានសាវតាជាជនអន្តោប្រវេ

សន៍ ចំណែកប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀតមានច្រើនជាង១០%។ ជប៉ុនព្យាយាមបរិច្ចាគធនធានប្រកបដោយសមធម៌សម្រាប់សាលារៀនទាំងអស់នៅទូទាំងប្រទេស ដោយផ្តល់នូវការគាំទ្របន្ថែមដល់សិស្សានុសិស្ស និងសាលារៀនដែលងាយរងគ្រោះ។ ករណីនេះ ប្រទេសជប៉ុនខុសពីក្រុងសៀងហៃ (ក្រុងដែលស្ថិតក្នុងតារាងចំណាត់ថ្នាក់PISAខ្ពស់ដែរ) ដែលបានផ្តល់លទ្ធផលភាពឱ្យសាលារៀនធ្វើការប្រកួតប្រជែងគ្នាដោយសេរី ដើម្បីបង្កើនប្រាក់ចំណូល និងកសាងកេរ្តិ៍ឈ្មោះរបស់ខ្លួនដែលជាប្រយោជន៍ក្នុងការទាក់ទាញអតិថិជន(សិស្ស)បានច្រើន។ បើមានសិស្សចូលរៀនច្រើន សាលារៀនក៏នឹងទទួលបានចំណូលច្រើនផងដែរ។ តាមរយៈរូបភាពនៃការប្រកួតប្រជែងគ្នាបែបនេះ បើសាលារៀនណាយកចិត្តទុកដាក់លើកកម្ពស់គុណភាពអប់រំរបស់ខ្លួន និងមានសេវាកម្មល្អ និងធ្វើឱ្យសិស្សសម្រេចលទ្ធផលសិក្សាបានខ្ពស់ សាលារៀននោះនឹងមានកេរ្តិ៍ឈ្មោះល្បីសុះសាយ ហើយអាចស្រូបទាញប្រភពមូលធនបានកាន់តែច្រើនផងដែរតាមរយៈការកើនឡើងនូវចំនួនសិស្សចូលមកសិក្សា (**<u>បញ្ជាក់៖</u>** *សាលារដ្ឋនៅក្រុងសៀងហៃមានថ្នាក់បង់ថ្លៃ-ធ្វើឱ្យសាលារៀនទាំងនោះទទួលបានប្រភពចំណូលសម្រាប់អភិវឌ្ឍន៍ស្ថាប័ន*) ពិសេសសិស្សមកពីគ្រួសារដែលជីវភាពធូរធារ ចំណែកសាលារៀនណាមានគុណភាពអប់រំទាប នឹងកាន់តែខ្សោយទៅៗ ព្រោះខ្សត់អតិថិជន ពោលគឺសិស្សមកពីគ្រួសារអ្នកមាន នឹងចូលរៀននៅសាលារៀនគុណភាពល្អ និងស្តង់ដារខ្ពស់ ហើយសិស្សដែលមកពីគ្រួសារជីវភាពមធ្យម ឬក្រីក្ររៀននៅសាលារៀនធម្មតាៗ។ ខុសពីក្រុងសៀងហៃ ជប៉ុនផ្តល់សេរីភាពដល់ឪពុកម្តាយសិស្សក្នុងសម្រេចចិត្តជ្រើសរើសសាលារៀនណាមួយដែលសមស្របសម្រាប់កូនៗរបស់ពួកគេដោយមិនមានប្រព័ន្ធបង់ថ្លៃ (*ថ្នាក់អប់រំកាតព្វកិច្ច*) សម្រាប់ការចូលរៀនដូចក្រុងសៀងហៃនោះទេ។ នៅក្រុងសៀងហៃ សិស្សមិនអាចផ្លាស់ប្តូរសាលារៀនខុសពីភូមិសិក្សារបស់ខ្លួនបានឡើយ បើសិនខុសភូមិសិក្សា ពួកគេត្រូវរៀនបង់ថ្លៃសិក្សា។ នៅជប៉ុនមិនមានផ្តល់លទ្ធផលឱ្យសាលារៀនទាំងអស់ប្រកួតប្រជែងគ្នាដើម្បីទទួលបានប្រាក់ចំណូលសម្រាប់អភិវឌ្ឍន៍សាលារៀនរៀងៗខ្លួនទេ។ ការបង្ហាញលក្ខណៈឱ្យសាលារៀនមានការប្រកួតប្រជែងបែបនេះរបស់ក្រុងសៀងហៃមានលក្ខណៈជា ***"មូលធនក្រហម"*** (Red Capital) ដែលស្ថិតនៅក្នុងប្រទេសកុំមុយនីស្ត

(មហាយក្សចិន)។ *នៅជប៉ុនមានកំណត់ស្តង់ដារអេប្បមារសម្រាប់សាលារៀនគ្រប់ទីកន្លែងទូទាំងប្រទេស ដើម្បីជានាការអប់រំប្រកបដោយសមធម៌សម្រាប់កុមារទាំងអស់*។ ជាទូទៅ ***សិស្សជប៉ុនរៀននៅសាលារៀនណាក៏មានស្តង់ដារដូចគ្នា ឬប្រហាក់ប្រហែលគ្នាដែរ មិនថានៅទីក្រុង ឬជនបទនោះទេ*** រួមទាំងសាលាអន្តរជាតិឯកជនក៏ដោយ។ មិនត្រឹមតែស្តង់ដារសាលារៀនដូចគ្នាប៉ុណ្ណោះទេ ជប៉ុនក៏ប្រើប្រាស់តេស្តស្តង់ដារសាកលតែមួយដូចគ្នាដើម្បីបង្កើនសមត្ថភាពសិស្សឆ្លើយតបទៅនឹងការប្រកួតប្រជែងអន្តរជាតិផងដែរ។ ដើម្បីសម្រេចគោលនយោបាយនេះ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជប៉ុនផ្តល់នូវការគាំទ្រទំនុកបម្រុងចំពោះសិស្សដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ ឬពិការភាពដែលតម្រូវឱ្យគ្រួសារចំណាយធនធានច្រើន និងសិស្សមកពីតំបន់ជនបទហើយចង់បន្តការសិក្សាដែលមានគុណភាពខ្ពស់។ ជាមួយគ្នានេះ ដោយសារសាលារៀនមានលទ្ធភាពទទួលបានស្មើភាពនូវធនធាន ប្រព័ន្ធសាលារៀននៅជប៉ុនមានការបែងចែកប្រកបដោយសមធម៌នូវធនធានអប់រំទាំងនោះ។ គុណភាព ឬបរិមាណនៃធនធានសាលារៀន វាប្រហែលមិនទាក់ទងទៅនឹងសាវតាសេដ្ឋកិច្ច-សង្គមជាមធ្យមរបស់សាលារៀនឡើយ។ គ្រប់សាលារៀនទាំងអស់ទទួលបានធនធានគាំទ្រប្រហាក់ប្រហែលគ្នា។ ***ជារួម ដោយសារស្តង់ដារតែមួយនៅគ្រប់សាលារៀនបែបនេះហើយ បានជាការផលិតមូលធនមនុស្សរបស់ជប៉ុនមកមានសមត្ថភាព និងបុគ្គលិកលក្ខណៈប្រហាក់ប្រហែលគ្នា ដែលគេមើលឃើញជាទូទៅថាជាជនជាតិដែលមានភាពឈ្លាសវៃ ស្វាហាប់ ស្មោះត្រង់ ម៉ឺងម៉ាត់ និងគោរពវិន័យ...***។បើនិយាយពីស្តង់ដារតែមួយនៅទូទាំងប្រទេស*សម្រាប់កម្ពុជា* យើងវិញនៅមិនទាន់មានភាពច្បាស់លាស់ និងប្រាកដប្រជានៅឡើយទេ ព្រោះការប្រកួតប្រជែងរវាងសាលារៀនឯកជនទាំងឡាយក៏មាន ការប្រកួតប្រជែងរវាងសាលារៀនឯកជន និងសាលារៀនរដ្ឋក៏មាន (***ឧទាហរណ៍.*** សាលារៀនរដ្ឋខ្លះមានការធ្លាក់ចុះនូវចំនួនសិស្សានុសិស្សជាលំដាប់ដោយសារការប្រកួតប្រជែងបែបនេះ ពិសេសស្ថិតនៅតំបន់ដែលមានការប្រកួតប្រជែងខ្លាំងដូចរាជធានីភ្នំពេញជាដើម។ ករណីនេះ វាធ្វើឱ្យតំបន់ទីក្រុងជួបប្រទះបញ្ហាប្រឈមច្រើន ពិសេសការលើសចំនួនគ្រូបង្រៀនច្រើននៅតាមសាលារដ្ឋ) សា-លារៀនឯកជនខ្លះអនុវត្តតាមកម្មវិធីសិក្សារដ្ឋ ឬខ្លះមានកម្មវិធីសិក្សាលក្ខណៈដោយ

ឡែករៀងៗខ្លួន ខ្លះប្របាច់បញ្ចូលគ្នារវាងកម្មវិធីសិក្សារដ្ឋ និងកម្មវិធីសិក្សាប្រទេសផ្សេងៗ សាលារៀនខ្លះសិក្សាជាភាសាខ្មែរ ខ្លះជាភាសាបរទេស ដាក់ប្របាច់បញ្ចូលគ្នា (តាមលំនាំប្រហាក់ប្រហែលក្រុងសៀងហៃ) និងក្រសួងរៀបចំស្តង់ដារកម្មវិធីសិក្សាមួយសម្រាប់សាលារៀនរដ្ឋទូទាំងប្រទេសក៏មាន (តាមលំនាំប្រទេសជប៉ុន)...។ ***នៅចំពោះមុខ តាមរយៈមេរៀនរៀនសូត្ររបស់ប្រទេស និងក្រុងនានា យើងឃើញថាប្រទេសយើងមានលក្ខណៈសម្បូរបែប និងចម្រុះដែលយើងពិបាកវិនិច្ឆ័យច្បាស់លាស់លើគុណភាពអប់រំ និងស្តង់ដារអប់រំ។ តើវាល្អទេដែលយើងត្រូវគិតគូរឡើងវិញចំពោះបញ្ហានេះ ដើម្បីកសាងភាពប្រាកដប្រជា និងទិសដៅមួយច្បាស់លាស់នោះ?***

ចំណុចថ្មីមួយទៀតទាក់ទងនឹងទំនាក់ទំនងរវាងផ្នែកសេដ្ឋកិច្ច-សង្គម និងលទ្ធផលសិក្សា។ សាវតាសេដ្ឋកិច្ច-សង្គមរបស់សិស្សជះផលប៉ះពាល់តិចតួចណាស់ដល់លទ្ធផលសិក្សារបស់សិស្សនៅជប៉ុន៖ ប្រសិនបើវិសមភាពក្នុងសង្គម វាមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងផលប៉ះពាល់នៃភាពមិនទទួលបានអត្ថប្រយោជន៍ពីសេដ្ឋកិច្ច-សង្គមលើលទ្ធផលសិក្សា សមត្ថភាពនៃគោលនយោបាយសាធារណៈដើម្បីលើកកម្ពស់សមធម៌លទ្ធភាពទទួលបានឱកាសប្រហែលជានៅមានកម្រិត យ៉ាងហោចណាស់ក៏រយៈពេលខ្លីដែរ។ ទោះបីយ៉ាងណាក៏ដោយ វាស្ទើរតែមិនមានទំនាក់ទំនងគ្នាទាល់តែសោះរវាងវិសមភាពប្រាក់ចំណូលក្នុងប្រទេស និងផលប៉ះពាល់នៃសាវតារសេដ្ឋកិច្ច-សង្គមលើលទ្ធផលសិក្សានៅជប៉ុន។ ប្រទេសខ្លះជោគជ័យបើទោះជាកំពុងស្ថិតនៅក្នុងស្ថានភាពលំបាកក៏ដោយ។ ***បើនិយាយឱ្យងាយយល់នៅស្ថានភាពជីវភាពគ្រួសារជប៉ុន (មាន ឬក្រ) មិនមានជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់កូនទេ។*** ទោះបីយ៉ាងណាក៏ដោយ បើតាមលទ្ធផលវាយតម្លៃPISA គ្រួសារដែលមានការលែងលះបានជះឥទ្ធិផលផងដែរដល់លទ្ធផលសិក្សារបស់សិស្ស ដែលមានហានិភ័យចំពោះការបំពេញមិនបានល្អ។ នៅជប៉ុន ស្ថានភាពជីវភាពគ្រួសារមិនជះឥទ្ធិផលដល់ការសិក្សារបស់កូនគឺ៖ ដោយសារប្រទេសនេះជាមហាអំណាចសេដ្ឋកិច្ច ហើយជាទូទៅផ.ស.សក្នុងមនុស្សម្នាក់មានកម្រិតខ្ពស់ អាចផ្គត់ផ្គង់ការរស់នៅបានល្អប្រសើរ *តែសម្រាប់ប្រទេសកម្ពុជា*ជាប្រទេសកំពុងអភិវឌ្ឍន៍ អត្រាភាពក្រីក្រនៅខ្ពស់នៅឡើយ ដូច្នេះបញ្ហាអត្ថប្រយោជន៍សេដ្ឋកិច្ច-សង្គមនៅតែប៉ះពាល់ខ្លាំងនៅឡើយ

ដល់លទ្ធផលសិក្សាសិស្ស តួយ៉ាងដូចការចំណាយក្រៅផ្លូវការដូចជាៈ ការរៀនគួរបន្ថែមក្រៅម៉ោង និងការចំណាយផ្សេងៗទៀតជាដើម។ បើសិស្សមិនមានថវិកាគ្រប់គ្រាន់សម្រាប់បង់ថ្លៃរៀនគួរបន្ថែម ពួកគេប្រឈមនឹងឧបសគ្គច្រើនក្នុងការសម្រេចលទ្ធផលសិក្សា។

បន្ថែមពីលើនេះ ចំណុចទាក់ទងនឹង**ឥរិយាបថសិស្សចំពោះការសិក្សា** ដែលការចូលរួមយុទ្ធសាស្ត្រ និងការអនុវត្តរបស់សិស្សក៏មានសារៈសំខាន់នាំទៅរកភាពជោគជ័យនៃលទ្ធផលសិក្សាផងដែរ។ សិស្សជប៉ុន៦៧%និយមចូលចិត្តទៅហាងលក់សៀវភៅ ឬបណ្ណាល័យ និងចូលចិត្តអានសៀវភៅខ្ពស់ជាងប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀតដែលមាន៤២%។ សិស្សជ-ប៉ុន៤៤%ចូលចិត្តជជែកពីសៀវភៅអានជាមួយមិត្តភ័ក្រ ឬអ្នកដទៃទៀត និង៤២%យកការអានសៀវភៅជាទម្លាប់ដែលខ្លួនចូលចិត្តមួយខ្ពស់ជាងប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀតដែលមានត្រឹមតែ៣៣%។ ជប៉ុនមានចំណាត់លេខបួនក្នុងចំណោមប្រទេសសេដ្ឋកិច្ចជឿនលឿនផ្នែកការអានតាមប្រព័ន្ធឌីជីថលដូចជា ក្នុងប្រព័ន្ធកុំព្យូទ័រ និងស្មាតហ្វូនជាដើម ហើយ៥៩%ប្រើប្រាស់កុំព្យូទ័រនៅផ្ទះ។ ជាមួយគ្នានេះ សិស្សជប៉ុនក៏មានភាគរយខ្ពស់ផងដែរក្នុងការចូលរួមសិក្ខាសាលាដើម្បីបង្កើនចំណេះដឹង បន្ទាប់ពីម៉ោងសិក្សានៅក្នុងសាលារៀន។ ***សម្រាប់កម្ពុជា*** និន្នាការនៃការនិយមអានសៀវភៅនៅមិនទាន់រីកចម្រើនខ្លាំងក្លានៅឡើយ។ បើយើងអង្កេតជាទូទៅនៅតាមគ្រួសារខ្មែរមួយចំនួនធំ មិនឃើញមានការដាក់តាំងសៀវភៅក្នុងទូតាំងសៀវភៅ ហើយមហាជនក៏ដូចសិស្ស-និស្សិតភាគច្រើនក៏មិនមានទម្លាប់អានសៀវភៅផុលផុសនៅឡើយដែរ ទោះបីក្រុមហ៊ុនផលិតសៀវភៅសម្រាប់អានរីកចម្រើនជាងមុនក្តី។ នេះយើងមិនទាន់វិភាគជិតដល់ដល់ឥទ្ធិពលនៃការប្រើប្រាស់បច្ចេកវិទ្យា (ស្មាតហ្វូន ឬបណ្តាញសង្គម...) ដែលប៉ះពាល់ការសិក្សា ពិសេសការចំណាយពេលអត់ប្រយោជន៍ច្រើនលើការប្រើប្រាស់បណ្តាញសង្គមជាដើម។ បើនិយាយពីសិក្ខាសាលាវិញ មិនសូវមានច្រើនទេសម្រាប់សិស្ស-និស្សិតចូលរួមដើម្បីបង្កើនចំណេះដឹង និងបទពិសោធ សូម្បីតែការអញ្ជើញវិត្មិនដែលមានចំណេះដឹង បទពិសោធនច្រើន និងឥស្សរជន មានស្នាដៃឆ្នើមៗមកចែករំលែកនៅតាមសាលារៀនទាំងកម្រិតមធ្យមសិក្សា និងការអប់រំកម្រិតខ្ពស់ក៏មិនសូវមានដែរ

(សម្រាប់កម្រិតមធ្យមសិក្សាមានតិចតួចបំផុត) ហើយការបង់ថ្លៃចូលរួមសិក្ខាសាលានៅជាបញ្ហាប្រឈមសម្រាប់ពួកគាត់។ បើសម្រាប់មន្ត្រីរាជការមួយចំនួនធំវិញ ការចូលរួមសិក្ខាសាលាទាល់តែបានថវិកាឧបត្ថម្ភ ទើបពួកគាត់ចូលរួម មិនមែនមានស្មារតីចង់ចេះចង់ដឹង និងអភិវឌ្ឍន៍សមត្ថភាពខ្លួននោះទេ។ ដោយសារការសម្លឹងឃើញតែផលប្រយោជន៍ថវិកាដែលទទួលបានពីវគ្គសិក្ខាសាលារបស់មន្ត្រីមួយចំនួននេះហើយ ទើបកម្រិតនៃផ្លាស់ប្តូររីកចម្រើនផ្នែកចំណេះដឹង ជំនាញ និងឥរិយាបថនៅតែជាឧបសគ្គមួយដដែលក្នុងការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក៏ដូចជាវិស័យអប់រំទាំងមូល ហើយភាពច្របូកច្របល់ និងទំនាស់ផលប្រយោជន៍ទាក់ទងនឹងបញ្ហានេះកើតឡើងជាហូរហែមិនចេះចប់មិនចេះហើយ។

ជប៉ុនមាន**កម្មវិធីសិក្សា**កម្រិតជាតិដែលអនុវត្តដោយសាលារៀនតាមកម្រិតថ្នាក់នីមួយៗទូទាំងប្រទេស និងធ្វើការពិនិត្យកែសម្រួលរវាង១០ឆ្នាំម្តង។ កម្មវិធីសិក្សារបស់ជប៉ុននេះ ខុសពីប្រទេសសេដ្ឋកិច្ចជឿនលឿនមួយចំនួន ពិសេសសហរដ្ឋអាមេរិកដែលរដ្ឋសហព័ន្ធនីមួយៗមានរៀបចំកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលផ្ទាល់ខ្លួន។ កម្មវិធីសិក្សាថ្នាក់ជាតិជប៉ុនមាន៣ផ្នែកដែលការសិក្សាផ្តោតលើ***(១)មុខវិជ្ជាសិក្សា (២)ការអប់រំសីលធម៌ (៣)សកម្មភាពក្រៅម៉ោងសិក្សា***។ *សម្រាប់កម្ពុជា*កន្លងមកយើងឃើញថា ការផ្លាស់ប្តូរកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ឬបន្ថែមកម្មវិធីសិក្សា...ច្រើនផ្តេកផ្តួលទៅតាមអ្នកជំនាញបរទេស ក្រោមជំនួយបរទេស មិនទាន់មានជំហខ្លួនឯងជាក់លាក់នៅឡើយដោយសារកង្វះធនធានមនុស្សដែលមានសមត្ថភាពគ្រប់គ្រាន់ ពិសេសកង្វះឯកសារការសិក្សាស្រាវជ្រាវទាក់ទងការអប់រំនានា។ ចំណុចខ្សោយនេះ នាំទៅរកការយកកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនទាំងនោះ មកពិសោធន៍លេងជាមួយសិស្សានុសិស្សតែប៉ុណ្ណោះ ហើយការបន្ថែមកម្មវិធីច្រើន[87]នាំទៅរកភាពមិនប្រាកដប្រជានៃសមត្ថភាពបុគ្គល ពោលគឺរៀនច្រើន មិនដឹងចេះអ្វីឱ្យប្រាកដ។ ទោះបីជាយ៉ាងណាក៏ ដោយយើងឃើញមានសញ្ញាណវិជ្ជមានច្រើន ទាក់ទងនឹងនិន្នាការនៃផ្លាស់ប្តូររីកចម្រើនមួយចំនួនតាមរយៈកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា និងការយកចិត្តទុកដាក់របស់ក្រសួងអប់រំ យុវជន និងកីឡា ពិសេសស្ថិតក្រោមអណត្តិរដ្ឋមន្ត្រី **ហង់ ជួនណារ៉ុន**។

ការគ្រប់គ្រងវិស័យអប់រំនៅជប៉ុនមានលក្ខណៈជាមជ្ឈការ ហើយមានស្តង់ដារកម្មវិធីសិក្សាតែមួយសម្រាប់ប្រទេសទាំងមូល។ ប្រព័ន្ធនេះមានគុណសម្បត្តិល្អសម្រាប់ជប៉ុនដែលមានស្ថានភាពភូមិសាស្រ្ត និងប្រជាជនមានលក្ខណៈប្រហាក់ប្រហែលគ្នា ហើយគោលដៅផលិតមូលធនមនុស្សមានលក្ខណៈស្តង់ដារតែមួយទាំងចំណេះដឹង បំណិន និងឥរិយាបថដែលជាតម្លៃស្នូលរបស់ខ្លួន។ សម្រាប់សហរដ្ឋអាមេរិក រដ្ឋនីមួយៗមានលក្ខណៈដោយឡែកៗរៀងៗខ្លួន ហើយវិមជ្ឈការឱ្យរដ្ឋទាំងនោះរៀបចំកម្មវិធីសិក្សា សៀវភៅសិក្សាគោល...ផ្តល់ចំណុចវិជ្ជមានច្រើនដល់ការអភិវឌ្ឍវិស័យអប់រំផងដែរ។ សម្រាប់នៅអាស៊ីអាគ្នេយ៍ ប្រទេសហ្វីលីពីនបាននឹងកំពុងអនុវត្តប្រព័ន្ធបែបនេះដែរនៅប៉ុន្មានឆ្នាំថ្មីៗនេះ។ ដើម្បីងាយយល់ច្បាស់ពីអត្ថប្រយោជន៍របស់វាបន្ថែមទៀត យើងសូមធ្វើការឆ្លុះបញ្ចាំងមកប្រទេសកម្ពុជាវិញ ***ឧបមាថាប្រទេសកម្ពុជា*** មានកម្មវិធីសិក្សាកម្រិតថ្នាក់ជាតិរួមមួយ ហើយសៀវភៅសិក្សាគោលត្រូវបានរៀបចំដាច់ដោយឡែកៗពីគ្នានៅតាមតំបន់នីមួយៗ(**ទំនាបកណ្តាល ខ្ពង់រាប តំបន់ភ្នំ មាត់សមុទ្រ**)។ វាផ្តល់ចំណុចល្អច្រើន ព្រោះទោះបីតំបន់នីមួយៗមានលក្ខណៈរួមដូចគ្នា តែក៏មានលក្ខណៈដោយឡែកផ្សេងៗពីគ្នាផងដែរ។ ឧទាហរណ៍ តំបន់ទំនាបកណ្តាលយល់ច្បាស់ពីស្រូវ គប្បីសិក្សាពីស្រូវ ចំណែកឯតំបន់ខ្ពង់រាបគប្បីសិក្សាពីម្រេច កៅស៊ូ...តំបន់សក្តានុពលទេសចរគប្បីយកចិត្តទុកដាក់បណ្តុះគំនិតច្នៃប្រឌិតលើកកម្ពស់ផ្នែកទេសចរ និងការបម្រើសេវាកម្ម...។ល។ ការសិក្សាបែបនេះផ្តល់ភាពច្បាស់លាស់ជាងការសិក្សាចម្រុះទូទៅ ដែលផ្តោតលើច្រើនចំណុច តែមិនប្រាកដណាមួយ។ វាជាការសិក្សាដែលបន្សុីខ្លឹមសារមេរៀនទៅនឹងស្ថានភាព ឬសក្តានុពលតំបន់ (Contextualization of lesson) ហើយការសិក្សាបែបនេះត្រូវបានរៀបចំដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សហគមន៍នីមួយៗ ជាជាងសិក្សាពីអ្វីដែលមិនមាននៅក្នុងតំបន់ នាំឱ្យសិស្សពិបាកយល់ និងយកទៅអនុវត្តមិនបាន។ វាជាការផ្សារភ្ជាប់ផងដែរពីសក្តានុពលការងារដែលមាននៅក្នុងតំបន់ទៅនឹងការសិក្សា ពោលគឺបើតំបន់មានសក្តានុពលអ្វី អភិវឌ្ឍន៍ធនធានមនុស្សដើម្បីបម្រើផ្នែកនឹងតែម្តង ហើយវាផ្តល់ភាពងាយស្រួល និងច្បាស់លាស់សម្រាប់ជំរុញឱ្យវិស័យឯកជនជួយគាំទ្រដល់ការអប់រំ។ មួយវិញទៀត វាផ្តល់ភាពម្ចាស់ការ និងភាពរីក

ចម្រើនដល់ថ្នាក់ក្រោមជាតិ ក្នុងការចូលរួមចំណែករបស់ខ្លួនកាន់តែទូលំទូលាយថែមទៀត ក្នុងការអភិវឌ្ឍវិស័យអប់រំ ដោយងាកចេញពីការរង់ចាំតែទទួលការណែនាំ និងអនុវត្តតាម ព្រមទាំងបង្កើតនូវបរិយាកាសសិក្សារៀនសូត្រ ចែករំលែកចំណេះដឹង និងបទពិសោធពីគ្នាទៅវិញទៅមកកាន់តែស៊ីជម្រៅថែមទៀតពីតំបន់មួយទៅតំបន់មួយដែលជាសន្ទុះនៃភាពរីកចម្រើន និងការអភិវឌ្ឍសមត្ថភាព ពោលវាបង្កើតឱ្យមានលក្ខណៈសម្បូរបែបនៅក្នុងប្រព័ន្ធអប់រំ។ ឧទាហរណ៍នេះ ជាចំណុចវិជ្ជមាន និងគុណសម្បត្តិនៃការធ្វើវិមជ្ឈការក្នុងការរៀបចំកម្មវិធីសិក្សា និងសៀវភៅសិក្សានៅតាមតំបន់ដើម្បីជំរុញការអភិវឌ្ឍជាតិ។ សម្រាប់ជប៉ុនអនុវត្តផ្ទុយស្រឡះពីប្រព័ន្ធបែបនេះ តែទទួលជោគជ័យខ្លាំងផងដែរ។

សាលារៀនជប៉ុនមានរយៈពេលសិក្សា៦ម៉ោងក្នុង១ថ្ងៃ (ព្រឹកម៉ោង៨:៣០ព្រឹក ដល់ម៉ោង៣រសៀល)ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ តែបើបូកបញ្ចូលទាំងសកម្មភាពសិក្សានានាដូចជាៈ ការរៀនគួរបន្ថែម ការធ្វើលំហាត់ និងការចូលរួមក្លឹបសិក្សាមានដល់ទៅ៧០ម៉ោងក្នុងសប្តាហ៍ (ប្រហែល១០ម៉ោង/ក្នុង១ថ្ងៃ)ដែលជាចំនួនម៉ោងដ៏ច្រើនបំផុតមួយនៅលើពិភពលោក។ និន្នាការសិក្សាច្រើនម៉ោងដើម្បីសម្រេចលទ្ធផលសិក្សានេះ ក៏មានផងដែរនៅក្រុងសៀងហៃ ហុងកុង តៃវ៉ាន់...លើកលែងតែ**ប្រទេសសឹង្ហបូរី**ប៉ុណ្ណោះ ដែលប្រទេស និងក្រុងទាំងនេះសុទ្ធតែមានចំណាត់ថ្នាក់PISAខ្ពស់។ វិស្សមកាលនៅជប៉ុនមានតែ៦សប្តាហ៍ប៉ុណ្ណោះគឺតិចជាងកម្ពុជា (មានច្រើនជាង១០សប្តាហ៍)។ ទោះបីស្ថិតអំឡុងពេលវិស្សមកាលក៏ដោយ សិស្សជប៉ុននៅតែបន្តការសិក្សា ចូលរួមសកម្មភាពក្លឹបសិក្សា និងមានកិច្ចការផ្ទះដែលគ្រូដាក់ឱ្យជាច្រើនដែលត្រូវបំពេញ។ ***ដូច្នេះ គ្មានអ្វីចម្លែកទេ ដែលសិស្សជប៉ុនចំណាយពេលវេលាច្រើនសម្រាប់ការសិក្សានៅសាលារៀន ថ្នាក់រៀនគួរ សកម្មភាពក្លឹបសិក្សា និងការសិក្សាដោយខ្លួនឯងពិសេសការហ្វឹកហាត់អនុវត្តលំហាត់ដូចមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រជាដើម*** ហើយជាហេតុផលដ៏សំខាន់មួយដែលធ្វើឱ្យជប៉ុនទទួលបានលទ្ធផលតេសPISAចំណាត់ខ្ពស់។ នេះជាចំណុចល្អមួយដែលកម្ពុជាត្រូវស្វែងយល់ និងរៀបចំយុទ្ធសាស្ត្រក្នុងការជំរុញ និងលើកទឹកចិត្តសិស្សឱ្យយកចិត្តទុកដាក់រៀនសូត្របន្ថែមទៀត ព្រម

ទាំងចំណាយពេលច្រើនលើការសិក្សាដូចសិស្សជប៉ុន ជាជាងសកម្មភាពអត់ប្រយោជន៍ផ្សេងៗទៀត។ គំរូជប៉ុនមានការដាក់សម្ពាធតាមរយៈសិក្សា ការដាក់កិច្ចការផ្ទះច្រើន ការប្រឡង វប្បធម៌នៃការប្រកួតប្រជែងខ្លាំង និងការជួយគាំទ្រដល់សិស្សងាយរងគ្រោះជាដើម។ ***ការជំរុញការសិក្សាតាមបែបដាក់សម្ពាធដើម្បីក្លាយជាធនធានមនុស្សពិតប្រាកដ អាចធន់ទ្រាំនឹងការរងសម្ពាធ កម្ពុជាគួរតែសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់។*** ស្ថានភាពប្រទេសកម្ពុជាដែលមានមូលដ្ឋានសីលធម៌-វិន័យរបស់សិស្សមិនទាន់រឹងមាំខ្លាំង ការសាកល្បងអនុវត្តបែបជប៉ុននេះប្រហែលអាចជួយលើកកម្ពស់គុណភាពធនធានមនុស្សកម្ពុជាបានល្អប្រសើរ ពោលគឺពេលកុមាររៀនដោយស៊ូទ្រាំនឹងការរងសម្ពាធសិក្សា ពេលពួកគេប្រឡូកនឹងការងារ ក៏អាចស៊ូទ្រាំនឹងការរងសម្ពាធនេះដែរ (**ធនធានមនុស្សដែលមានភាពធន់ទ្រាំ**-Resilent human resource)។

ជប៉ុនប្រទេសមួយដែលមានអត្រាសិក្សាខ្ពស់នៅលើពិភពលោក ដោយមានអត្រាចូលរៀន១០០%នៅកម្រិតថ្នាក់បឋមសិក្សាដល់មធ្យមសិក្សាបឋមភូមិ និងមិនមានអនក្ខរជនទេ។ សូម្បីតែថ្នាក់មធ្យមសិក្សាទុតិយភូមិដែលមិនមែនជាកាតព្វកិច្ចអប់រំ ក៏មានអត្រាចូលរៀនកើនឡើងជាបន្តបន្ទាប់ដែរ ក្រោម៦០%ទូទាំងប្រទេស (១៩៦០) ហើយកើនឡើងយ៉ាងលឿនលើស៩០%(១៩៨០) និងឈានដល់ ៩៨,៣% នៅឆ្នាំ២០១២[88] ហើយជិត១០០%នៅតំបន់ទីក្រុង។ ជាមេរៀនរៀនសូត្រមួយដែលកម្ពុជាគប្បីស្វែងយល់ទាក់ទងនឹងការជំរុញកំណើនចូលរៀននេះ ដោយជប៉ុនបានដាក់ចេញនូវគោលនយោបាយដ៏សំខាន់មួយចំនួនឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងការធ្វើឱ្យអត្រាចូលរៀនកើនឡើងយ៉ាងឆាប់រហ័សពីក្រោម ៦០% ទៅ៩០% តែដើម្បីជំរុញពី៩០% ឱ្យដល់៩៨.៣% ជប៉ុនជួបការលំបាកច្រើនដែលតម្រូវឱ្យក្រសួងដាក់ចេញនូវគោលនយោបាយជាច្រើន និងធ្វើការវាយតម្លៃ ឆ្លុះបញ្ចាំងច្រើនលើកច្រើនសារស្វែងរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រ ផ្តល់លទ្ធភាព និងឱកាសឱ្យកុមារដែលងាយរងគ្រោះចូលរៀនបាន។ មួយវិញទៀត ដើម្បីដើរទាន់សម័យបច្ចេកវិទ្យាទំនើប សាលារៀនភាគច្រើនមានភ្ជាប់អ៊ីនធ័រណេតនិងជំរុញឱ្យសិស្សធ្វើការស្រាវជ្រាវ។ ប្រព័ន្ធសិក្សាអប់រំជប៉ុនមានទិសដៅបណ្តុះ

បណ្ដាលធនធានមនុស្សប្រកបដោយសមត្ថភាព ទន់ភ្លន់ ស្ម័គ្របម្រើ ស្មោះត្រង់ និងគោរពវិន័យ។ នៅពេលបំពេញការងារ យុវជនទាំងអស់ទទួលបានការបណ្ដុះបណ្ដាលបន្ថែមទៀតនៅតាមសហគ្រាស។ ជយោជកជប៉ុនយកចិត្តទុកដាក់ខ្លាំងណាស់ចំពោះការអភិវឌ្ឍសមត្ថភាព និងបំណិននយោជិកខ្លួន តាមរយៈការផ្ដល់វគ្គបណ្ដុះបណ្ដាលកសាងសមត្ថភាព វគ្គបំប៉ននានាអំឡុងពេលបំពេញការងារ(In-service training) និងផ្លាស់ប្ដូរតួនាទីនៅក្នុងសង្វាក់ផលិតកម្មជាទៀងទាត់ដើម្បីឱ្យពួកគេយល់ច្បាស់ពីការងាររបស់ក្រុមហ៊ុន ឬសហគ្រាសទាំងមូល។ ជាទូទៅ នយោជកជប៉ុនឱ្យតម្លៃខ្លាំងលើធនធានមនុស្សក្នុងការប្រកួតប្រជែង ព្រោះធនធាននានា (បច្ចេកទេស សម្ភារៈ ...) គេអាចលួចចម្លង ឬអភិវឌ្ឍន៍ដើម្បីប្រកួតប្រជែងបាន ហើយមានតែគុណភាពធនធានមនុស្សទេដែលគេពិបាកលួចចម្លង និងប្រកួតប្រជែងបានដោយងាយ។ ផលិតភាពពលករជប៉ុនមានកម្រិតខ្ពស់ណាស់ ដោយមានរយៈពេលបំពេញការងារយូរ ទោះបីជាមានទំនោរទៅរកការកាត់បន្ថយក្ដី។ ក្នុងមួយសប្ដាហ៍ ការងារជារឿយៗមានច្រើនជាង៥ថ្ងៃ ហើយជាធម្មតាទៅហើយ គេត្រូវធ្វើការបន្ថែមម៉ោងដោយមិនទទួលប្រាក់កំរៃបន្ថែម។ ការឈប់សម្រាករយៈពេលខ្លី (១៥ថ្ងៃ) ប្រព្រឹត្តទៅដោយប្ដូរវេនគ្នាជាច្រើនដង។ អត្រាអវត្តមានមានកម្រិតទាបណាស់ ហើយករណីកូដកម្មក៏កម្រកើតមានដែរ។ នៅតាមសហគ្រាសធំៗបៀវត្សមានកម្រិតខ្ពស់គ្រាន់បើ ប៉ុន្តែតម្លៃជីវភាពក៏ខ្ពស់ដែរ។ អត្រាអត់ការងារទាបបំផុត៣.៤%នៃប្រជាជនសកម្ម[78] (ស្ថិតិឆ្នាំ២០១៤)។ ភាពស្មោះត្រង់ វិន័យ ការមូលមតិគ្នា ការស្វែងរកការស្រុះស្រួលគ្នា ជាចំណុចសំខាន់នៃការគ្រប់គ្រងតាមបែបជប៉ុន។ ជនជាតិជប៉ុនស្វាហាប់ណាស់ចំពោះការងារ ហើយប្រព័ន្ធអប់រំរបស់ប្រទេសជប៉ុនគឺជា "*ចក្រភពនៃការប្រកួតប្រជែង*"។ ការខិតខំប្រឹងប្រែងក្នុងវិស័យអប់រំជាតិមានលក្ខណៈធំធេងណាស់ ហើយមានតែសិស្សឆ្នើមទេ ទើបអាចចូលរៀននៅសាកលវិទ្យាល័យដ៏ល្បីៗបាន។ សាកលវិទ្យាល័យខ្លះការប្រកួតប្រជែងគ្នាយ៉ាងស្វិតស្វាញបំផុត។ ជាក់ស្ដែងខ្ញុំធ្លាប់ចូលរួមប្រឡងប្រជែងអាហារូបករណ៍JDS ជប៉ុននៅឆ្នាំ២០១៧នេះម្ដងដែរ សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ តែត្រូវបរាជ័យនៅដំណាក់កាលចុងក្រោយនៃការសម្ភាសបច្ចេកទេស ដែលត្រូវឆ្លងជាច្រើនដំណាក់កាលរាប់ទាំងតេស្តភាសាអង់គ្លេស តេស្តគណិតវិទ្យា វាយតម្លៃឯកសារ

និងគម្រោងកិច្ចការស្រាវជ្រាវដែលស្នើសុំ តេស្តសុខភាព និងសម្ភាស២ដំណាក់កាលទៀត។ យើងឃើញថា ការជ្រើសរើសមានភាពស្មិតស្មាញ និងសម្រិតសម្រាំងខ្លាំងណាស់ដែលទាមទារការត្រៀមលក្ខណៈឱ្យបានល្អបំផុត ហើយតម្រូវឱ្យបេក្ខជនត្រូវរៀនគណិតវិទ្យាឡើងវិញ ទោះបីអ្វីដែលអ្នកស្នើសុំទៅរៀនជាមុខវិជ្ជាសង្គមក៏ដោយ។ ទោះបីយ៉ាងណាក៏ដោយ អំឡុងសម្ភាសនេះ ខ្ញុំបានទទួលបានអាហារូបករណ៍ពីរួចទៅហើយ គឺថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅវិទ្យាស្ថានជាតិអប់រំដែលគាំទ្រដោយពីអង្គការជប៉ុន និងថ្នាក់អធិការកិច្ចអប់រំតំបន់មួយដែលផ្តល់ឱកាសដល់ខ្ញុំក្នុងការធ្វើការនៅទីក្រុងភ្នំពេញ។

***ជប៉ុនបានយកចិត្តទុកដាក់អភិវឌ្ឍន៍ប្រព័ន្ធអប់រំរបស់ខ្លួន ដើម្បីរៀបចំសិស្សទាំងអស់ ទទួលបានជោគជ័យការងារ និងជីវិតក្នុងសតវត្សរ៍ទី២១។*** បច្ចុប្បន្ននេះ ក្រសួងអប់រំជប៉ុន បានកំពុងអភិវឌ្ឍន៍កម្មវិធីសិក្សាជាតិ ដើម្បីអនុវត្តនៅ ឆ្នាំ២០២០។ ក្រសួងទំនងជាធ្វើកំណែទម្រង់ស្តង់ដារទូទៅរបស់ខ្លួន និងការប្រឡងចូលសាកលវិទ្យាល័យ។ ដើម្បីរៀបចំសម្រាប់ការផ្លាស់ប្តូរទាំងអស់នេះ ជប៉ុនបានដាក់ឱ្យអនុវត្តការបង្រៀនភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា និងកែលម្អស៊ីជម្រៅថែមទៀតលើការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនេះ នៅកម្រិតមធ្យមសិក្សាបឋមភូមិ។ និន្នាការនេះ ខុសពីទសវត្សរ៍ទី៨០ ដែលជប៉ុនផ្តោតសំខាន់លើការសិក្សាភាសាជាតិដែលមានលក្ខណៈជាតិនិយមខ្លាំង ទោះបីនិស្សិតបរទេសដែលមកសិក្សានៅជប៉ុនក៏ត្រូវប្រឡង និងរៀនជាភាសាជប៉ុនដែរ។ ការងាកមកដាក់បញ្ចូលការអប់រំភាសាបរទេស និងការជ្រើសរើសគ្រូបង្រៀនជនជាតិដើមនិយាយភាសាអង់គ្លេសទៅក្នុងប្រព័ន្ធអប់រំជប៉ុន ហាក់មានភាពយឺតពេលបន្តិចទៅហើយ បើប្រៀបធៀបជាមួយប្រទេសកូរ៉េ និងប្រទេសចិនដែលត្រៀមលក្ខណៈបានល្អប្រសើរជាងសម្រាប់បរិបទសាកលភាវូនីយកម្ម និងការប្រកួតប្រជែងកម្រិតសកល ហើយប្រទេសទាំងពីរនេះហាក់ទទួលបានអត្ថប្រយោជន៍ច្រើនជាងជប៉ុនចំពោះការអប់រំភាសាបរទេស ពិសេសសម្រាប់ទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ។ *សម្រាប់កម្ពុជា* យើងមានបញ្ហាប្រឈមច្រើនទាក់ទងនឹងការបង្រៀនពីរភាសានៅក្នុងប្រព័ន្ធអប់រំដែលធ្វើឱ្យធនធានមនុស្សយើងមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើការកម្រិតតំបន់ និងសាកល និងពិបាកប្រកួតប្រជែងជាមួយជន

ជាតិផ្សេងៗណាស់។ ចំណុចពិសេសរបស់ជប៉ុនក្នុងការជួលជនជាតិដើមនិយាយភាសាអង់គ្លេសផ្ទាល់មកបង្រៀនគឺដើម្បីឱ្យសិស្ស អាចប្រើប្រាស់ភាសាបានល្អ ពិសេសការហ្វឹកហាត់បញ្ចេញសម្លេងបានត្រឹមត្រូវ។ សម្រាប់ផ្នែកនេះ យើងគួរពិចារណាបន្ថែមម៉ោងមុខវិជ្ជាភាសាអង់គ្លេស ឬអាចបង្រៀនមុខវិជ្ជាមួយចំនួនជាភាសាអង់គ្លេស ពោលគឺប្រើប្រាស់ប្រព័ន្ធពីរភាសាក្នុងប្រព័ន្ធអប់រំតែម្តង ដូចជាសាលារៀនឯកជនអន្តរជាតិមួយចំនួនបានអនុវត្ត។ បើមិនដូច្នេះទេ យើងពិតជាពិបាកប្រកួតប្រជែងជាមួយគេខ្លាំងណាស់ ពិសេសការប្រឡូកនឹងការងារកម្រិតតំបន់ ឬអន្តរជាតិ។ ជាមួយគ្នា នៅកម្រិតមធ្យមសិក្សា ជប៉ុនរៀបចំវគ្គសិក្សាពីភូមិវិទ្យា និងប្រវត្តិសាស្ត្រដែលរួមបញ្ចូលគ្នា ព្រមទាំងវគ្គសិក្សាថ្មីពីភាពជាពលរដ្ឋសាធារណៈ (public citizen ship) និងការរិះរកវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម (Science inquiry and social science inquiry)។ សមាហរណកម្មមុខវិជ្ជាភូមិវិទ្យា និងប្រវត្តិវិទ្យាបញ្ចូលគ្នា នឹងជួយសិស្សយល់ដឹងពីពិភពលោក តាមរយៈភាពស៊ីជម្រៅនៃខ្លឹមសារភូមិវិទ្យា និងប្រវត្តិវិទ្យាសម័យទំនើបជាជាងវគ្គសិក្សាដែលផ្តោតតែការអង្កេតដែលមានលក្ខណៈទូលំទូលាយ ធ្លាប់បានបង្រៀនកន្លងមក។ ការប្របាច់បញ្ចូលគ្នាបែបនេះ ធ្វើឱ្យចំនួនមុខវិជ្ជាសម្រាប់សិស្សសិក្សារៀនសូត្រមានចំនួនតិច និងមានភាពច្បាស់លាស់ដែលមានលក្ខណៈងាយស្រួលជាងប្រទេសកម្ពុជាយើងច្រើន។ នៅក្នុងកម្មវិធីអប់រំទំនើបមួយចំនួន គ្រាន់តែមុខវិជ្ជាវិទ្យាសាស្ត្រមួយក្តោបមុខវិជ្ជាជាច្រើនដូចជា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា...ដូច្នេះសិស្សរៀនតិចមុខវិជ្ជាណាស់ តែគេផ្តោតជាសំខាន់លើការអប់រំភាសា ដោយក្នុងកម្រិតមធ្យមសិក្សាទាំងមូល សិស្សត្រូវរៀនយ៉ាងតិចក៏ពីរភាសាដែរក្រៅពីភាសាកំណើតរបស់ខ្លួន។ ចំណែកឯវគ្គសិក្សាភាពជាពលរដ្ឋសាធារណៈរបស់ជប៉ុនបង្រៀនសិស្សអំពីការគ្រប់គ្រងទំនាស់ (conflict management) វិធីដោះស្រាយ និងការយល់ដឹងពីសាកលលោក។ សម្រាប់វគ្គសិក្សាពីការរិះរកបែបវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម នឹងជួយសិស្សអភិវឌ្ឍន៍សមត្ថភាពវិភាគ និងយល់ដឹងពីភាពលម្អិតដ៏ស្មុគស្មាញនៃរចនាសម្ព័ន្ធ (complex details of structures) និងប្រព័ន្ធជុំវិញពិភពលោក។ វគ្គសិក្សាទាំងអស់នេះ រួមបញ្ចូលទាំងជំនាញសតវត្សរ៍ទី២១ដូចជា៖ ការគិតប្រកបដោយហេតុផល (critical thinking)

ភាពច្នៃប្រឌិត និងការដោះស្រាយបញ្ហា។ ការកែទម្រង់នេះក៏ផ្តោតសំខាន់លើ ការសិក្សាសកម្ម (active learning) និងការសិក្សាមានមូលដ្ឋានផ្តោតលើគម្រោង (project-based learning) ដែលធ្វើឱ្យសិស្សបញ្ចប់ការសិក្សាមានសមត្ថភាពគ្រប់គ្រាន់ក្នុងសិក្សា និងយល់ដឹងពីពិភពលោកតាមមាគ៌ាមួយដែលមិនធ្លាប់មានមុនពេលផ្លាស់ប្តូរទាំងនេះ[89]។

## 2.5) មត្តេយ្យសិក្សា

នៅប្រទេសជប៉ុនក៏ដូចកម្ពុជាដែរការអប់រំជាកាតព្វកិច្ច(Compulsory) មានរយៈពេល៩ឆ្នាំសម្រាប់កុមារអាយុពី៦ឆ្នាំ ដល់១៥ឆ្នាំ នៅកម្រិតបឋមសិក្សា៦ឆ្នាំ និងអនុវិទ្យាល័យ៣ឆ្នាំ។ ចំនួនសិស្សបឋមសិក្សានៅជប៉ុនមានចំនួន ៣,៥លាននាក់ ក្នុងឆ្នាំ២០១២ ធ្លាក់ចុះជាងមុនដែលមានប្រមាណ៥,៣ លាននាក់កាលពីឆ្នាំ១៩៩០[88]។ ការអប់រំក្នុងរយៈពេលនេះ(បូករួមនឹងសៀវភៅសិក្សា)ត្រូវផ្តល់ជូនដល់សិស្សានុសិស្សដោយឥតគិតថ្លៃ តែត្រូវបង់ការចំណាយផ្សេងៗទៀតរួមមានសម្ភារៈសិក្សាបន្ថែម អាហារថ្ងៃត្រង់ និងទស្សនកិច្ចសិក្សា។ ដោយជាមួយគ្នានេះ ក៏មានការអប់រំលក្ខណៈគ្រួសារតាមខ្នងផ្ទះ និងកម្រិតមត្តេយ្យសិក្សាសម្រាប់កុមារចាប់ពីអាយុ៣ឆ្នាំផងដែរ។ ការអប់រំកុមារតូចនេះ មានសៀវភៅសិក្សា និងកម្មវិធីទូរទស្សន៍ជាច្រើនត្រូវបានបង្កើតដើម្បីជួយឱ្យមាតាបិតា ឬអ្នកអាណាព្យាបាលអប់រំកូនមុនចូលសាលារៀន។ ការអប់រំនៅតាមផ្ទះនេះ មានគោលដៅចម្បងក្នុងការអប់រំពីសីលធម៌ សុជីវធម៌ និងលេខជាដើម។ មាតាបិតាមានការយកចិត្តទុកដាក់ខ្លាំងណាស់ចំពោះការអប់រំមុនចូលសាលាបឋមសិក្សា ហើយកុមារ៩៩%បានចូលរៀននៅសាលាមត្តេយ្យសិក្សា។ នៅដំណាក់កាលដំបូងនេះ កុមារជប៉ុនរៀនពីរបៀបរស់នៅសង្គម ពោលគឺគ្រូយកចិត្តទុកដាក់អប់រំសិស្សឱ្យមានសីលធម៌ ទម្លាប់ និងវិន័យល្អ ទំនាក់ទំនងជាមួយមិត្តភ័ក្រ និងសង្គមជាដើម។ ឧទាហរណ៍ កុមារតាំងពីអាយុ៣ឆ្នាំឡើងទៅចេះទុកដាក់សំរាមបានត្រឹមត្រូវតាមប្រភេទធុងសំរាម ឬកុមារស្គាល់ និងយល់ដឹងពីស្លាកសញ្ញានានានៅតាមទីសាធារណៈ ឬពេលពួកគេធ្វើដំណើរ។ ***នៅកម្ពុជា*** ផ្ទត់គំនិតមាតាបិតាសិស្សមួយចំនួនធំ ផ្តោតតែលើការសិក្សាអក្សរ មិនសូវចាប់អារម្មណ៍ការអប់រំសីលធម៌ និងរបៀប

រស់នៅនោះទេ បើកូនចូលរៀន៣ ឬ៤ខែហើយ មិនឃើញកូនចេះអក្ខរក្រមអីទេ ពួកគាត់នឹងគិតថាការបង្រៀនរបស់គ្រូនោះមិនល្អទេ។ ករណីនេះ នាំឱ្យសាលារដ្ឋ និងឯកជនមួយចំនួន ផ្តោតសំខាន់លើការជំរុញឱ្យកុមារទន្ទេញចាំមាត់នូវអក្ខរក្រម ជាជាងអប់រំផ្នែកសីលធម៌ និងផ្នែកផ្សេងទៀត។ នេះ ជាភាពខុសគ្នារវាងជប៉ុន និងកម្ពុជាទាក់ទងនឹងការអប់រំកុមារតូច។ សាលាមត្តេយ្យសិស្សជប៉ុនត្រូវបានតាមដានត្រួតពិនិត្យដោយក្រសួងអប់រំ និងមិនមែនជាផ្នែកមួយនៃប្រព័ន្ធអប់រំផ្លូវការទេ។ សាលាមត្តេយ្យ៥៨% ជាសាលាឯកជន និងមានសិស្ស៧៧%ចុះឈ្មោះចូលរៀន។ គ្រូនៅសាលាមត្តេយ្យភាគច្រើនជានារីក្មេងៗដែលបញ្ចប់ការសិក្សាពីមហាវិទ្យាល័យវគ្គខ្លី។ ក្រៅពីសាលាមត្តេយ្យ ក៏មានមជ្ឈមណ្ឌលថែទាំកុមារនៅពេលថ្ងៃដែរ ហើយវាត្រូវបានគ្រប់គ្រងយ៉ាងល្អពីក្រសួងការងារ។ មណ្ឌលថែទាំងកុមារមានលក្ខណៈខុសពីសាលាមត្តេយ្យដោយសារមានគោលដៅចម្បងផ្តោតលើការថែទាំដល់កុមារ មិនមែនការអប់រំទេ។ ជាទូទៅ ការយកចិត្តទុកដាក់របស់ស្ត្រីជប៉ុនលើការបីបាច់ថែរក្សា និងការអប់រំកុមារតូច ជាមូលហេតុចម្បងដែលនាំ ឱ្យមានបញ្ហាវិសមភាពយេនឌ័រនៅក្នុងវិស័យការងារ ហើយជាហេតុផលដែលស្ត្រីមួយចំនួនធំ មិនចង់រៀបការ និងមានកូន ដែលនាំទៅរកអត្រាកំណើតធ្លាក់ចុះ និងវិបត្តិសង្គមនាពេលបច្ចុប្បន្ននេះ។ ***សម្រាប់ប្រទេសកម្ពុជា*** អត្រាចូលរៀននៅកម្រិតមត្តេយ្យសិក្សានៅទាបនៅឡើយ៦០%(87) ដោយសារគ្រូបង្រៀន និងសាលារៀនមិនទាន់គ្រប់គ្រាន់ ហើយមួយចំនួនពឹងផ្អែកលើសាលាមត្តេយ្យសហគមន៍។ មួយវិញទៀត ដោយសារភាពក្រីក្រ ការចំណាកស្រុក ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដល់ជីវភាពរស់នៅ ពិសេសនៅតំបន់ជនបទ ធ្វើឱ្យគ្រួសារមួយចំនួនសង្វាតស្វែងរកប្រភពចំណូលផ្គត់ផ្គង់ជីវភាពរស់នៅគ្រួសារ ដោយមិនសូវយកចិត្តទុកដិតដល់ដល់ការអប់រំកូននៅផ្ទះ ក៏ដូចជាការចុះឈ្មោះកូនចូលរៀនសាលាមត្តេយ្យសិក្សា ហើយនៅពេលពួកគេចូលរៀននៅសាលាបឋមសិក្សា ផ្តល់ការលំបាកច្រើនដល់គ្រូបង្រៀនក្នុងការបង្ហាត់បង្រៀនពួកគេឱ្យមានការចេះអាច និងសរសេរ។ តាមការអង្កេតជាទូទៅ កុមារដែលឆ្លងកាត់មត្តេយ្យសិក្សាមានភាពចេះដឹងច្រើនជាងកុមារដែលមិនឆ្លងកាត់ ហើយផ្តល់ភាពងាយស្រួលច្រើនដល់គ្រូក្នុងការបង្រៀននៅដំណាក់កាលចំណេះដឹងមូលដ្ឋានគ្រឹះដ៏សំខាន់នៃភាសាខ្មែរ និងគណិត

វិទ្យា។ ជារួម អត្រាចុះឈ្មោះចូលរៀននៅមត្តេយ្យសិក្សាខ្ពស់ជាចំណុចចាប់ផ្តើមនៃភាពជោគជ័យ និងការសម្រេចលទ្ធផលសិក្សាដ៏ល្អមួយសម្រាប់ជប៉ុនដែលកម្ពុជាគួរសិក្សាស្វែងយល់។

## 2.6) បឋមសិក្សា

នៅកម្រិតបឋមសិក្សា (រយៈពេល៦ឆ្នាំ) កុមារចូលរៀនពីថ្នាក់ទី១ដល់ទី៤ មានលក្ខណៈពិសេសដោយមិនតម្រូវឱ្យប្រឡងតេស្តធំដុំអ្វីទេ រួមទាំងការប្រឡងតេស្តប្រចាំខែដើម្បីវាយតម្លៃលទ្ធផលសិក្សាសិស្សជាដើម។ ប្រព័ន្ធអប់រំនេះ មិនផាប់វិនិច្ឆ័យលើចំណេះដឹងកុមារទេ។ នៅគ្រប់សាលារៀនក្នុងប្រទេសជប៉ុនមិនមានឡើយការប្រឡងរហូតដល់ថ្នាក់ទី៤ ឬពេលដែលសិស្សានុសិស្សមានអាយុ១០ឆ្នាំ ពោលគឺមានត្រឹមតែតេស្តបន្តិចបន្តួចប៉ុណ្ណោះ។ គោលដៅនៃការអប់រំជប៉ុនក្នុងរយៈពេល៣ឆ្នាំដំបូង មិនមែនវាស់វែងនូវចំណេះដឹងនោះទេ ប៉ុន្តែគឺបង្កើតនូវ «**ចរិតលក្ខណៈល្អ**»។ កូនសិស្សទាំងអស់ ត្រូវបានបង្ហាត់បង្រៀនឲ្យចេះគោរពអ្នកដទៃ គោរពវិន័យ និងចេះស្រលាញ់សត្វ និងធម្មជាតិ។ ទំពាំងខ្ចីៗទាំងអស់នោះ ក៏ត្រូវបានបណ្តុះឲ្យមានចេះសណ្តោស មានមហិច្ឆតា និងការយល់ចិត្ត។ លើសពីនេះ ភាពក្លាហាន ការគ្រប់គ្រងខ្លួនឯង និងមានយុត្តិធម៌ ក៏ជាអ្វីដែលជប៉ុនបានបណ្តុះបណ្តាលក្មេងៗរបស់ពួកគេដែរ។ ចំណុចនេះខុសពី***ការអប់រំនៅកម្ពុជា***ដែលកុមារត្រូវធ្វើការប្រឡងតេស្តប្រចាំខែ ប្រឡងឆមាស និងតេស្តផ្សេងៗទៀតចាប់អនុវត្តតាំងពីថ្នាក់ទី១ឡើងទៅ។ ដូចគ្នានេះដែរ វាខុសគ្នាដាច់នឹង***ប្រទេសសឹង្ហបូរី*** មិនត្រឹមតែអនុវត្តការប្រឡង និងតេស្តប៉ុណ្ណោះទេ តែយកចិត្តទុកដាក់ខ្លាំងក្នុងតាមដាន វាយតម្លៃកម្រិតសមត្ថភាព និងឧបនិស្ស័យសិស្សដើម្បីសម្រួច និងតម្រង់ទិសវិជ្ជាជីវៈតាំងពីកម្រិតបឋមសិក្សា និងដើម្បីបែងចែកកម្រិតថ្នាក់ទៅតាមសមត្ថភាពរបស់ពួកគេ ពេលឆ្លងចូលមធ្យមសិក្សា ពោលគឺសិស្សពូកែរៀនជាមួយតែសិស្សពូកែដូចគ្នា កម្មវិធីសិក្សាសម្រាប់តែសិស្សពូកែ សិស្សមធ្យមរៀនជាមួយសិស្សមធ្យម កម្មវិធីសម្រាប់តែសិស្សកម្រិតមធ្យម ហើយសិស្សរៀនយឺតរៀនតែជាមួយសិស្សរៀនយឺតដូចគ្នា (លម្អិតមាននៅមេរៀនការសិក្សាស្វែងយល់ពីប្រព័ន្ធអប់រំសឹង្ហបូរី)។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ទៅទៀតនោះ គឺការយកចិត្តទុកដាក់អប់រំសីលធម៌កុមារនៅដំណាក់កាលមូលដ្ឋានគ្រឹះរបស់ជប៉ុន មានសារៈសំខាន់ខ្លាំង

ក្នុងការអភិវឌ្ឍន៍ឥរិយាបថ និងអាកប្បកិរិយាវិជ្ជមានរបស់កុមារដែលជាគុណតម្លៃស្នូលរបស់ជប៉ុន។ យើងគួរសិក្សាស្វែងយល់ថែមទៀតនៅដំណាក់កាលនេះសម្រាប់កម្ពុជា ព្រោះបើតាមការសង្កេតរយៈពេលជាង១០ឆ្នាំកន្លងមកក្នុងអាជីពជាគ្រូបង្រៀន និងគ្រូឧទ្ទេសសាលាគរុកោសល្យ និងរ៉ាក្រឹតការខេត្ត អធិការអប់រំ ការសង្កេតថ្នាក់រៀន ការសង្កេតសកម្មភាពកុមារសាលាអនុវត្តជាប្រចាំ និងតាមដានគ្រូចេញថ្មី យើងឃើញថា កុមារមួយចំនួនធំ នៅហាក់មិនទាន់ចេះគោរពវិន័យ និងទទួលបានការយកចិត្តទុកដាក់អប់រំផ្នែកវិន័យ សីលធម៌ សណ្តាប់ធ្នាប់ឱ្យបានគ្រប់គ្រាន់នៅឡើយទេ ហើយក្រុមប្រឹក្សាកុមារនៅតាមសាលារៀនហាក់មិនទាន់មានដំណើរការសកម្មនៅឡើយ។ **ឧទាហរណ៍** យើងឃើញមានទិដ្ឋភាពកុមាររត់ជាន់ស្មួនស្មៅ បោះសំរាមពាសវាលពាសកាល ការបង្កដំលោះ ភាពរញ៉េរញ៉ៃអសណ្តាប់ធ្នាប់ និងសកម្មភាពអសកម្មមួយចំនួនទៀត។ ***ចឹង! តើអ្វីជាគុណតម្លៃស្នូលរបស់ធនធានមនុស្សកម្ពុជានាពេលអនាគត ដែលយើងត្រូវដុះខាត់នៅដំណាក់កាលជាមូលដ្ឋាននេះ?***

នៅកម្រិតបឋមសិក្សាគ្រូបង្រៀនបង្រៀនគ្រប់មុខវិជ្ជាក្នុងកម្រិតថ្នាក់មួយដូចនៅកម្ពុជាដែរ( ខុសពីប្រទេសមួយចំនួន ដែលនៅកម្រិតបឋមសិក្សាក៏មានគ្រូបង្រៀនតាមមុខវិជ្ជាឯកទេសដែរដូចជា៖ មុខវិជ្ជាគណិតវិទ្យា សិក្សាសង្គម និងវិទ្យាសាស្ត្រជាដើម)។ ជាទូទៅ សិស្សមានចំនួនក្រោម៤០នាក់ក្នុង១ថ្នាក់តិចជាងនៅកម្ពុជាដែលកំណត់និយាមពី៤០ ទៅ៤៥នាក់ក្នុងមួយថ្នាក់។

កុមារជប៉ុន៩៩%ចុះឈ្មោះរៀននៅបឋមសិក្សាដែលចាត់ទុកថាជាការចូលរៀនដំបូង និងជាព្រឹត្តិការណ៍យ៉ាងសំខាន់នៅក្នុងជីវិតកុមារភាព។ ការសិក្សានៅបឋមសិក្សាភាគច្រើនលើសលុបធ្វើឡើងនៅសាលារដ្ឋ។ មានសាលាបឋមសិក្សាឯកជនតែ១%ប៉ុណ្ណោះនៅប្រទេសជប៉ុន ខុសពីកម្រិតមត្តេយ្យសិក្សាដែលភាគច្រើនជាសាលាឯកជន។ ថ្នាក់រៀនមានទំហំធំ ហើយជាមធ្យមមានសិស្ស៣១នាក់ក្នុងមួយថ្នាក់។ នៅប្រទេសជប៉ុន ស្ទើរតែមិនមានសិស្សបោះបង់ការសិក្សា ព្យួរការសិក្សា ឬមករៀនយឺត។ សិស្ស៩១%ត្រូវបានរាយការណ៍ថា មិនមានសោះតែម្តង និងមួយចំនួនទៀតគ្រាន់តែព្រងើយកន្តើយនឹងការបង្រៀនរបស់គ្រូប៉ុណ្ណោះ។ សម្រាប់នៅកម្ពុជា

ការអប់រំនៅកម្រិតបឋមសិក្សានៅមានបញ្ហាប្រឈមច្រើន ដូចជា៖ ការចូលរៀនយឺត អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានៅទាប អត្រាត្រួតថ្នាក់ និងបោះបង់ចោលការសិក្សាខ្ពស់( ៨៥%នៃកុមារចុះឈ្មោះចូលរៀនបានបញ្ចប់ការសិក្សា )[87]។

**សាលាបឋមសិក្សាមានមុខវិជ្ជា៖** ភាសាជប៉ុន សិក្សាសង្គម គណិតវិទ្យា វិទ្យាសាស្ត្រ និងបំណិតជីវិត( ភ្ជាប់រវាងសិក្សាសង្គម និងវិទ្យាសាស្ត្រហើយសិក្សាតែនៅថ្នាក់ទី១និងទី២ ) តន្ត្រី សិល្បៈ សិប្បកម្ម ហត្ថកម្ម និងការអប់រំកីឡា។ លើសពីនេះ គេយកចិត្តទុកខ្លាំងលើការអប់រំ សីលធម៌។ គ្រូនៅបឋមសិក្សាបង្រៀនគ្រប់មុខវិជ្ជា នៅក្នុងថ្នាក់រៀនដែលគេកាន់ដូចនៅប្រទេសកម្ពុជាដែរ។ យោងតាមបញ្ជីមុខវិជ្ជាសិក្សានៅបឋមសិក្សារបស់ក្រសួងអប់រំ វប្បធម៌កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ( MEXT )គេឃើញមានមុខវិជ្ជាយ៉ាងសម្បូរបែប ទាំងមុខវិជ្ជាទាក់ទងនឹងការសិក្សា មិនទាក់ទងនឹងការសិក្សា និងសកម្មភាពពិសេសផ្សេងៗដែលវាសំដៅលើពេលវេលាសម្រាប់រៀបចំកម្មវិធីនៅក្នុងថ្នាក់រៀន ក៏ដូចជាកម្មវិធីបុណ្យទាននៅសាលារៀនជាដើម។ សកម្មភាពទាំងនេះជួយអោយសិស្សអភិវឌ្ឍន៍បុគ្គលិកលក្ខណៈរបស់ពួកគេ និងយល់ពីសារៈសំខាន់នៃការងារជាក្រុម ព្រមទាំងចេះកិច្ចសហការគ្នា។ **មុខវិជ្ជាស្តង់ដារទាក់ទងនឹងការសិក្សា**មាន៖ ភាសាជប៉ុន សិក្សាសង្គម នព្វន្ធ និងវិទ្យាសាស្ត្រ។ **មុខវិជ្ជាមិនទាក់ទងនឹងការសិក្សាមាន៖** សិល្បៈ សិប្បកម្ម តន្ត្រី មេផ្ទះ កីឡា និងសីលធម៌។ ភាសាជប៉ុនត្រូវបានគេផ្តោតការយកចិត្តទុកដាក់ជាមុខវិជ្ជាចម្បង។ មុខវិជ្ជាផ្សេងទៀតដូចជា ការសិក្សាភាសាបរទេសចាប់ផ្តើមនៅកម្រិតថ្នាក់នេះដែរ ទោះបីចាប់ពីខែមេសា ឆ្នាំ២០១១ ភាសាអង់គ្លេសបានក្លាយជាផ្នែកមួយ( កាតព្វកិច្ច )នៃកម្មវិធីសិក្សារបស់សាលាបឋមសិក្សា។ ក្រសួងទទួលស្គាល់នូវតម្រូវការក្នុងការកែលម្អការបង្រៀនភាសាបរទេសទាំងអស់ ជាពិសេសភាសាអង់គ្លេស។ ដើម្បីកែលម្អការបង្រៀនភាសាអង់គ្លេស រដ្ឋាភិបាលបានអញ្ជើញគ្រូជនជាតិបរទេសដែលមានភាសាដើមកំណើតអង់គ្លេសជាច្រើននាក់មកកាន់ប្រទេសជប៉ុនដើម្បីបម្រើការជាជំនួយការដល់ក្រុមប្រឹក្សាសាលា និងសាលារៀនដែលមានអនុស្សរណៈយោគយល់ក្រោមកម្មវិធីផ្លាស់ប្តូរ និងបង្រៀនរបស់ជប៉ុន។ ចាប់ផ្តើមជាមួយអ្នកចូលរួមចំនួន៨៤៨ នាក់ក្នុងឆ្នាំ១៩៨៧ កម្មវិធីនេះបានកើនឡើងដល់ចំនួនខ្ពស់បំផុតនៃអ្នកចូលរួមចំនួន៦២៧៣ នាក់ក្នុងឆ្នាំ

២០០២[91] ។ ចំនួនសិស្សបឋមសិក្សាកំពុងកើនឡើងផងដែរនៅសាលារៀនឯកជន (juku) សម្រាប់រៀនគួរបន្ថែមនៅពេលល្ងាច និងនៅចុងសប្ដាហ៍។ កម្មវិធីនេះមានការថយចុះក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះដោយសារតែកត្តាជាច្រើនរួមទាំងការកាត់បន្ថយថវិកាសាលារៀននៅតាមសាលារៀន និងការបង្កើនចំនួននៃក្រុមប្រឹក្សាសាលាដែលជួលជនជាតិបរទេសរបស់ពួកគេដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារឯកជនបង់ថ្លៃទាប។ កម្មវិធីនេះកំពុងរីកចម្រើនជាថ្មីម្ដងទៀត ដោយសារតែភាសាអង់គ្លេសក្លាយទៅជាផ្នែកមួយនៃកម្មវិធីសិក្សាសាលាបឋមសិក្សានៅក្នុងឆ្នាំ២០១១[92]។

នៅកម្រិតបឋមសិក្សាក៏ដូចជាមធ្យមសិក្សា សិស្សទាំងអស់គឺជាអ្នកអនាម័យប្រចាំសាលារៀនរបស់ខ្លួន ទាំងបរិវេណសាលារៀន បន្ទប់រៀន បង្គន់ និងគ្រប់កន្លែងទាំងអស់។ ពួកគេបែងចែកជាក្រុមៗ ដើម្បីទទួលខុសត្រូវផ្នែកអនាម័យពេញមួយឆ្នាំ។ ការធ្វើបែបនេះ គឺដើម្បីបង្រៀនពួកគេឲ្យចេះធ្វើការជាក្រុម និងចេះជួយគ្នា។ លើសពីនេះកិច្ចការដុសលាងសម្អាតនេះ បានជួយឲ្យពួកគេចេះគោរព និងមានការទទួលខុសត្រូវចំពោះការងារខ្លួនឯង និងការងារអ្នកដទៃ។ ចំណែកឯនៅសាលារៀនមួយចំនួននៅ*ប្រទេសកម្ពុជា* យើងនៅមានបញ្ហាប្រឈមច្រើនទាក់ទងនឹងបញ្ហាអនាម័យនេះ សាលារៀនខ្លះមានបង្គន់ តែមិនមានទឹក និងមិនបានថែទាំត្រឹមត្រូវ បញ្ហាទុកដាក់សំរាម...។ល។ កត្តាអសកម្មទាំងនេះ មកពីមូលហេតុចម្បងគឺមិនចេះប្រើប្រាស់ និងចាត់ចែងធនធានដែលមានស្រាប់ ដូចនៅប្រទេសជប៉ុននេះឯង។

ប្រព័ន្ធអប់រំរបស់ជប៉ុន គឺជំរុញឱ្យសិស្សានុសិស្សទាំងអស់មានសុខភាពល្អ និងទទួលទានអាហារប្រកបដោយតុល្យភាពបំផុត។ នៅសាលាបឋមសិក្សា និងមធ្យមសិក្សា មុខម្ហូបទាំងអស់គឺដូចគ្នា (ស្តង់ដារតែមួយ) មិនមែនត្រឹមតែកំណត់ដោយចុងភៅដែលមានស្នាដៃនោះទេ គឺរៀបចំដោយ អ្នកជំនាញផ្នែកម្ហូបអាហារតែម្ដង។ ពួកគេទទួលទានអាហារថ្ងៃត្រង់រួមគ្នាជាមួយមិត្តរួមថ្នាក់ និងគ្រូបង្រៀនរបស់ពួកគេ ដែលសកម្មភាពនេះធ្វើឲ្យពួកគេមានទំនាក់ទំនងល្អនឹងគ្នា។ សម្រាប់នៅកម្ពុជាមិនទាន់មានស្តង់ដារបែបនេះនៅឡើយទេ ហើយបញ្ហាកង្វះអាហារូបត្ថម្ភនៅមានសម្រាប់កុមារ ពិសេសនៅតាមជនបទ ព្រមទាំងបញ្ហាសុវត្ថិភាពចំណីអាហារ។ ការ

លក់ដូរចំណីអាហារនៅតាមសាលារៀន និងសហគមន៍នៅតែមានបញ្ហាចោទនៅឡើយចំពោះសុខភាពកុមារ។

ការអប់រំ និងកីឡានៅជប៉ុនត្រូវបានយកចិត្តទុកដាក់ខ្លាំង ដោយដាក់បញ្ចូលក្នុងកម្មវិធីសិក្សា និងមានភាពច្បាស់លាស់បើប្រៀបធៀបនឹងកម្ពុជា។ សិស្សមិនត្រឹមសិក្សាម៉ោងអប់រំកាយប៉ុណ្ណោះទេ តែត្រូវចូលរួមក្នុងសកម្មភាពនានានៅក្នុងក្លឹបកីឡាដែលយើងឃើញពីភាពរីកចម្រើនវិស័យកីឡារបស់ជប៉ុនស្រាប់។ ជាទូទៅនៅតាមសាលាបឋមសិក្សាជប៉ុនមានអាងហែលទឹក សម្រាប់ហ្វឹកហាត់ម៉ោងអប់រំកាយ ដែលធ្វើឱ្យសិស្សភាគច្រើនចេះហែលទឹកតាំងពីកុមារភាព។ចំណែកឯនៅតាមសាលារៀន*ប្រទេសកម្ពុជា*មួយចំនួនវិញ ម៉ោងអប់រំកាយហាក់មិនទាន់ដំណើរការល្អនៅឡើយ ហើយពេលខ្លះវាស្ទើរតែក្លាយជាម៉ោងប្រមូលផលប្រយោជន៍របស់គ្រូបង្រៀនមួយចំនួនក៏មានដែរ។ ជាមួយគ្នានេះ សាលារៀនរដ្ឋ មិនមានអាងហែលទឹកសម្រាប់ហ្វឹកហាត់នោះទេ លើកលែងតែសាលាឯកជនមួយចំនួនប៉ុណ្ណោះ ហើយនេះអាចជាបញ្ហាប្រឈមមួយពេលអនាគតសម្រាប់កុមារដែលភាគច្រើននាពេលបច្ចុប្បន្ននេះ មិនចេះហែលទឹក ហើយអាចប្រឈមនឹងហានិភ័យនៃការលង់ទឹកនៅពេលមានគ្រោះធម្មជាតិ ទឹកជំនន់ ឬមានឧបទ្វវហេតុអ្វីមួយកើតឡើង។ ពីអតីតកាល កុមារខ្មែរមួយចំនួនធំ ចេះហែលទឹកព្រោះធ្លាប់រៀនហែលទឹកនៅតាមស្រះ ត្រពាំង បឹង... ជាមួយនឹងការបណ្តែតបណ្តោយកូនច្រើនរបស់ឪពុកម្តាយនៅសម័យនោះជាជាងពេលបច្ចុប្បន្ន។ ការយកចិត្តទុកដាក់កសាងសមត្ថភាពធន់ទ្រាំ (Resilence) និងត្រៀមបង្ការ (Contingency) ដើម្បីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ (Disaster Risk Reduction) របស់ប្រព័ន្ធអប់រំជប៉ុន ជាវិធានការឆ្លើយតបទៅនឹងស្ថានភាពទីតាំងភូមិសាស្ត្រជប៉ុនដែលសម្បូរដោយគ្រោះធម្មជាតិ ហើយជាអ្វីដែលកម្ពុជាត្រូវសិក្សាស្វែងយល់ និងរៀនសូត្រពីគំរូជប៉ុននេះផងដែរ។

ជាទូទៅកុមារនៅលើពិភពលោក រៀនអក្ខរក្រមចន្លោះពី២៦ ដល់៣៣ ព្យញ្ជនៈ ចំណែកជប៉ុនរៀនលើសពីនេះដោយរៀនមានអក្សរបីប្រភេទកាតាកាណា (មាន៤៦ទម្រង់) ហ៊ីរ៉ូហ្គាណា(៤៦ទម្រង់) និងកាន់ជី(អក្សរចិនមានជាងពីរពាន់ទម្រង់)។ វាពិតជាលំបាកណាស់សម្រាប់កុមារជប៉ុនក្នុងការរៀនគ្រប់ទម្រង់អក្សរទាំង

អស់ ពិសេសអក្សរកាន់ជីដែលមានលំនាំជាអក្សរចិនដែលមានការលំបាកខ្លាំង និងរៀនពីរបៀបប្រើប្រាស់របស់វា។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារវិធីសាស្ត្រប្រកបដោយគុណភាពខ្ពស់នៅពេលកុមារបញ្ចប់ការសិក្សាបឋមសិក្សា កុមារជប៉ុនចេះអក្សរកាន់ជីចំនួន១០០៦ទម្រង់ ហើយនៅអាយុ១៥ឆ្នាំ ពេលបញ្ចប់ថ្នាក់មធ្យមសិក្សាបឋមភូមិ(កម្រិតសិក្សាដែលជាកាតព្វកិច្ចអប់រំ)ពួកគេចេះបន្ថែមចំនួន១១៣០ទម្រង់ទៀត។ ការសិក្សាពីលក្ខណៈលំបាកៗ ទម្រង់ស្មុគស្មាញនៃអក្ខរក្រម (ពិសេសអក្សរកាន់ជិ) និងសេរីភាពនៃការគូរគំនូរ ឬផាត់ពណ៌ (គំនូរសេរី) របស់កុមារចូលរួមចំណែកអភិវឌ្ឍន៍រចនាសម្ព័ន្ធខួរក្បាល និងគំនិតច្នៃប្រឌិតរបស់កុមារជប៉ុន។ ***ការយកចិត្តទុកដាក់ដល់ការសិក្សារបស់កុមារតាមរយៈការគូរគំនូរ និងផាត់ពណ៌សេរីតាមចំណង់ចំណូលចិត្តកុមារជប៉ុន ជាចំណុចល្អមួយដែលកម្ពុជាគួរសិក្សាស្វែងយល់ និងយកចិត្តទុកដាក់បន្ថែមទៀតនៅក្នុងកម្មវិធីសិក្សា។*** កន្លងមកការបង្រៀនគូរគំនូរបែបជប៉ុននេះ មិនសូវផុលផុសទេនៅកម្ពុជា បើមាន មួយចំនួនគ្រាន់តែឱ្យសិស្សផាត់ពណ៌តាម និងគូរគំនូរបែបចម្លងតាមតែប៉ុណ្ណោះ មិនផ្តល់ឱកាសដល់សិស្សសម្រេចចិត្តគូរ និងផាត់ពណ៌អ្វីក៏ដោយ តាមបែបផែនដែលខ្លួនពេញចិត្ត និងប្រកបដោយអត្ថន័យសម្រាប់ពួកគាត់ទេ។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងយុគសម័យបច្ចេកវិទ្យាទំនើបបច្ចុប្បន្ន ជប៉ុនក៏កំពុងតែមានបញ្ហាប្រឈមច្រើនផងដែរទាក់ទងទៅនឹងការសរសេរអក្សរដោយសារសិស្ស-និស្សិតនិយមប្រើប្រាស់កុំព្យូទ័រ ឬស្មាតហ្វូតជាជាងការសរសេរដៃ។

## 2.7) កម្រិតមធ្យមសិក្សា

### ❖ មធ្យមសិក្សាបឋមភូមិ

កម្មវិធីសិក្សាកម្រិតអនុវិទ្យាល័យ(ពីថ្នាក់ទី៧ដល់ទី៩)មានមុខវិជ្ជា៖ ភាសាជប៉ុន សិក្សាសង្គម គណិតវិទ្យា វិទ្យាសាស្ត្រ តន្ត្រីសិល្បៈ វិចិត្រកម្ម សិប្បកម្ម ឧស្សាហកម្ម ភាសាបរទេស និងការអប់រំកាយសម្បទា។ សិស្សទាំងអស់ក៏ត្រូវបានតាំងបង្ហាញនូវសិល្បៈឧស្សាហកម្ម និងការធ្វើផ្ទះគំរូសម្រាប់តាំងបង្ហាញ។ ជាមួយគ្នានេះ ការអប់រំសីលធម៌ និងសកម្មភាពពិសេសត្រូវបានយកចិត្តទុកដាក់ផងដែរ។ សិស្សភាគច្រើនត្រូវចូលរួមជាមួយក្លឹបមួយក្នុងចំណោមក្លឹបនានា (ក្លឹបកីឡា និងក្លឹប

សិល្បៈ ) ដែលពួកគេត្រូវចូលរួមសកម្មភាពជាមួយរហូតដល់ម៉ោងប្រហែល៦ ល្ងាច នៅថ្ងៃសិក្សា (រួមទាំងចុងសប្តាហ៍ និងជាញឹកញាប់មុនពេលចាប់ផ្តើមរៀនផងដែរ)។ ទំនាក់ទំនងក្លឹបសិក្សានេះជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាក្មេងជំទង់។ សិស្សនៅអនុវិទ្យាល័យតែងទៅរៀនគួរបន្ថែម នៅតាមសាលាបំប៉នឯកជននាពេលល្ងាច និងចុងសប្តាហ៍។ មុខវិជ្ជាដែលត្រូវប្រឡងសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិនេះមាន៥មុខវិជ្ជាដូចជា៖ ភាសាជប៉ុន គណិតវិទ្យា វិទ្យាសាស្ត្រ ភាសាអង់គ្លេស ដើម្បីចូលរៀនថ្នាក់នៅកម្រិតវិទ្យាល័យ។ ទម្រង់សិក្សារបស់សិស្សជប៉ុនមានភាពរស់រវើកគ្រប់ផ្នែកទាំងរៀននៅសាលារៀន ជាមួយក្លឹបសិក្សា ថ្នាក់រៀនគួរក្រៅម៉ោង និងការហ្វឹកហាត់អនុវត្តលំហាត់ដោយខ្លួនឯង ការជួយគាំទ្រពីឪពុកម្តាយពោលគឺចំណាយពេលច្រើនរៀនជាមួយគ្រូបង្រៀន ជាមួយមិត្តភ័ក្រ ជាមួយដៃគូ និងជាបុគ្គល ដោយមានការលើកទឹកចិត្តពីឪពុកម្តាយ ទើបលទ្ធផលសិក្សារបស់សិស្សជប៉ុនមានកម្រិតខ្ពស់ទាំងចំណេះដឹង បំណិន និងឥរិយាបថបែបនេះ។ *សម្រាប់កម្ពុជា* ការចំណាយម៉ោងសិក្សា និងស្មារតីយកចិត្តទុកដាក់ខិតខំរៀនសូត្ររបស់សិស្សនៅមានកម្រិតនៅឡើយ ដូច្នេះដើម្បីទទួលបានភាពជោគជ័យដូច ឬប្រហាក់ប្រហែលជប៉ុន ទាល់តែសិស្សយើងផ្លាស់ប្តូរការគិត និងឥរិយាបថចំពោះការសិក្សារៀនសូត្រ ហើយគុណភាពនៃការបង្រៀន និងរៀនត្រូវបានលើកកម្ពស់។ តែអ្វីដែលសំខាន់នៅពេលនេះ តើយើងត្រូវធ្វើម៉េច? វាមិនមែនជាមហិច្ឆិតាទេ តែជាអ្វីដែលត្រូវធ្វើជាជំហានៗ ហើយយើងនឹងសាកល្បងរិះរកដំណោះស្រាយ ឬបទពិសោធពីប្រទេសនានានៅក្នុងជំពូកបញ្ហាប្រឈមនៃការអប់រំនៅប្រទេសកម្ពុជា។

គ្រូបង្រៀននៅអនុវិទ្យាល័យធ្វើការច្រើនម៉ោងជាងគេក្នុងចំណោមប្រទេសទាំងឡាយទាំងម៉ោងបង្រៀន និងធ្វើការងារពាក់ព័ន្ធផ្សេងៗ[(78)] ហើយមានជំនាញតាមមុខវិជ្ជាឯកទេសរៀងៗខ្លួន។ ជាទូទៅគ្រូបង្រៀនធ្វើការពេញម៉ោង បើមិនបង្រៀនតាមកាលវិភាគនៅតាមថ្នាក់រៀនផ្ទាល់ទេ ក៏ពួកគាត់ធ្វើការនៅការិយាល័យទៅលើកិច្ចការផ្សេងៗដូចជា៖ ការស្រាវជ្រាវ រៀបចំកិច្ចរដ្ឋបាលគ្រូ កិច្ចតែងការបង្រៀន ការសិក្សាស្រាវជ្រាវមេរៀន ការប្រជុំក្រុមបច្ចេកទេស ប្រជុំគរុកោសល្យ ការប្រជុំពិភាក្សាពីបញ្ហាផ្សេងៗទៀត...ជាដើម។ គ្រូបង្រៀន៨០% បញ្ចប់ការសិក្សានៅ

មហាវិទ្យាល័យ។ ថ្នាក់រៀនមានទំហំធំ ដោយមានសិស្សមធ្យម៣៨នាក់ក្នុង១ថ្នាក់។ តាមថ្នាក់នីមួយៗ មានគ្រូទទួលបន្ទុកថ្នាក់ម្នាក់ និងធ្វើជាទីប្រឹក្សាសិស្សផងដែរ។ ខុសពីនៅបឋមសិក្សា សិស្សនៅអនុវិទ្យាល័យមានគ្រូខុសៗគ្នាទៅតាមមុខវិជ្ជានីមួយៗ។ គ្រូចល័តពីថ្នាក់មួយទៅថ្នាក់មួយទៅតាមម៉ោងសិក្សា ហើយមួយម៉ោងសិក្សាមានរយៈពេល៥០នាទី។ សម្រាប់*គ្រូបង្រៀននៅកម្ពុជា* ធ្វើការតិចម៉ោងជាងជប៉ុន ហើយមួយចំនួនធំ មកធ្វើការតែនៅតាមម៉ោងដែលខ្លួនបង្រៀនតាមកាលវិភាគប្រចាំសប្តាហ៍ដែលបានកំណត់ ដោយមិនមានធ្វើការនៅការិយាល័យបន្ថែមឱ្យពេញម៉ោងដូចជប៉ុនទេ។ ស្ថានភាពនេះ វាអាចបណ្តាលមកពីកត្តាផ្សេងៗជាច្រើនដូចជា៖ ប្រាក់បៀវត្សប្រចាំខែនៅទាបនៅឡើយ ជីវភាពរស់នៅរបស់គ្រូនៅមានកម្រិត សាលារៀននៅខ្វះបន្ទប់ និងសម្ភារៈឬគ្រឿងបរិក្ខាសម្រាប់គ្រូបង្រៀន សមត្ថភាពគ្រប់គ្រង និងដឹកនាំនៅមានកម្រិត ឬរវល់ធ្វើការងារទី២រកប្រាក់កំរៃបន្ថែមជាដើម។ បញ្ហាចោទសំខាន់នៅចំណុចនេះ គឺ *"បើពេលវេលារបស់គ្រូនៅសាលារៀនកាន់តិច ធ្វើឱ្យឱកាសធ្វើការងាររួមគ្នាដើម្បីអភិវឌ្ឍន៍វិជ្ជាជីវៈក៏កាន់តែតិចដែរ"* តួយ៉ាងដូចការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងការប្រជុំបច្ចេកទេសជាដើម។

### ❖ មធ្យមសិក្សាទុតិយភូមិ

នៅពេលបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ សិស្សានុសិស្សត្រូវធ្វើការប្រឡងដើម្បីចូលរៀនមធ្យមសិក្សាទុតិយភូមិរយៈពេល៣ឆ្នាំ រួចបន្តប្រឡងបញ្ចប់ចូលរៀនការអប់រំកម្រិតខ្ពស់ (សាកលវិទ្យាល័យ-មហាវិទ្យាល័យ) រយៈពេល៤ឆ្នាំ (២ឆ្នាំសម្រាប់មហាវិទ្យាល័យវគ្គខ្លី) និងថ្នាក់ក្រោយឧត្តមសិក្សារយៈពេល៥ឆ្នាំ។ យើងឃើញមាននិន្នាការធ្លាក់ចុះចំនួនសិស្សវិទ្យាល័យ ដោយមានសិស្ស១១,២៧៥នាក់នៅឆ្នាំ១៩៩០ ធ្លាក់មកនៅត្រឹម១០,៦៩៩នាក់ក្នុងឆ្នាំ២០១២។ ប្រហែល៨% នៃសិស្សវិទ្យាល័យចូលរៀននៅវិទ្យាល័យឯកជនដែលមានចំនួនប្រហែល ៧% នៃវិទ្យាល័យទាំងអស់នៅក្នុងប្រទេស។ សាលារៀនឯកជនមានតម្លៃថ្លៃគួរឱ្យកត់សម្គាល់ ៖ គិតត្រឹមឆ្នាំ២០១២ ប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំក្នុងការចូលរៀននៅសាលាបឋមសិក្សាឯកជនមួយនៅក្នុងប្រទេសជប៉ុនមានចំនួន១,២៩៥.១៥-៦យ៉េនស្មើនឹង ១០,០០០ដុល្លារអាមេរិកក្នុងសិស្សម្នាក់ប្រហែល៣ដងនៃតម្លៃសម្រាប់សាលារដ្ឋ

(ចំនួន៤៥០,៣៤០យ៉េន=៣,៧២៨ដុល្លារ)[93]។ សូមបញ្ជាក់ថា ការសិក្សានៅកម្រិតវិទ្យាល័យនេះទាំងសាលារដ្ឋ និងឯកជនសុទ្ធតែត្រូវបង់ថ្លៃដែលខុសពីកម្ពុជា ការសិក្សានៅកម្រិតនេះមិនគិតថ្លៃសិក្សាទេ។ ទោះបីជាការសិក្សានៅកម្រិតនេះក្នុងប្រទេសជប៉ុនមិនបានចាត់ទុកថាជាកាតព្វ ក៏ដោយ ក៏មានសិស្ស៩៤%បានចូលរៀននៅវិទ្យាល័យតាំងពីឆ្នាំ២០០៥មក[93]។ វិទ្យាល័យភាគច្រើនមានកម្មវិធីសិក្សាពេញម៉ោង និងផ្តល់នូវកម្មវិធីសិក្សាទូទៅ (ដែលមានមុខវិជ្ជាគ្រឹះចាំបាច់សម្រាប់បន្តការសិក្សានៅថ្នាក់មហាវិទ្យាល័យ) និងកម្មវិធីសិក្សាជំនាញបច្ចេកទេស (សម្រាប់សិស្សដែលចង់ធ្វើការបន្ទាប់ពីរៀនចប់) ហើយក៏មានសាលារៀនមួយចំនួនតូចផងដែរដែលផ្តល់កម្មវិធីសិក្សាក្រៅម៉ោងពេលល្ងាច។ កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិនេះមានមុខវិជ្ជាដូចជា៖ ភាសាជប៉ុន ភូមិវិទ្យា និងប្រវត្តិសាស្ត្រ ពលរដ្ឋវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រ (រួមទាំងរូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងវិទ្យាសាស្ត្រ ផែនដីវិទ្យា) សុខភាព សិល្បៈ ភាសាបរទេស ភាសាអង់គ្លេស ហត្ថកម្ម បច្ចេកវិទ្យាព័ត៌មានវិទ្យា និងការសិក្សាទូទៅ។ ជាមួយគ្នានេះ កម្មវិធីសិក្សាបច្ចេកទេសក៏ដាក់បញ្ចូលផងដែរនូវមុខវិជ្ជាដូចជា៖ ព័ត៌មានវិទ្យា នាវាចរ នាសាទ កសិកម្ម ភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម សេដ្ឋកិច្ចជាដើម។

ជប៉ុនក៏យកចិត្តទុកដាក់ខ្លាំងក្លាផងដែរដល់ការអប់រំសម្រាប់សិស្សពិការនៅវិទ្យាល័យ ដោយផ្តោតសំខាន់ទៅលើជំនាញនានា ដើម្បីអោយពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរស់នៅដោយខ្លួនឯងក្នុងសង្គម។ ជំនាញទាំងនោះត្រូវបានពិចារណាតាមកម្រិតពិការភាពរបស់ពួកគេ។ រដ្ឋាភិបាលធ្វើការប្រឹងប្រែងក្នុងការបង្កើនជម្រើសសម្រាប់ពួកគេ ដោយជំរុញអោយស្ថាប័នឧត្តមសិក្សាអនុញ្ញាតឱ្យសិស្សពិការចូលរៀនបាន។

ដូចនៅកម្រិតអនុវិទ្យាល័យដែរ សិស្សជប៉ុនត្រូវរៀនបន្ថែមក្រៅម៉ោងសិក្សានៅសាលារៀនគួរ(juku) សម្រាប់ការត្រៀមប្រឡងចូលថ្នាក់ឧត្តមសិក្សា។ ការប្រឡងចូលត្រូវបានរៀបចំឡើងជាចម្បងដើម្បីវាយតម្លៃកម្រិតទូទៅរបស់សិស្សានុសិស្សនៅក្នុងដំណើរការនៃការបញ្ចប់ថ្នាក់វិទ្យាល័យនឹងឆ្លងចូលការអប់រំកម្រិតខ្ពស់។ នៅពេលដែលពួកគេរៀនចប់ថ្នាក់វិទ្យាល័យ សិស្សទាំងអស់ត្រូវតែឆ្លងកាត់ការប្រឡង

មួយដ៏សំខាន់មួយដែលកំណត់ជោគវាសនារបស់ពួកគេម្នាក់ៗ។ សិស្សម្នាក់អាចជ្រើសរើសយកបានតែសាកលវិទ្យាល័យមួយប៉ុណ្ណោះសម្រាប់បន្តការសិក្សា ហើយអាចចូលរៀនបានគឺអាស្រ័យទៅលើពិន្ទុនៃការប្រឡងបញ្ចប់នេះឯង។ ការសិក្សានៅកម្រិតនេះ សិស្សរងសម្ពាធខ្លាំងណាស់ ដោយសារវាជាដំណាក់កាលនៃប្រកួតប្រជែងចូលរៀននៅមហាវិទ្យាល័យ។ ការប្រឡងនោះមានភាពស្វិតស្វាញជាទីបំផុត ហើយមានតែសិស្សចំនួន៧៦% ប៉ុណ្ណោះដែលមានសំណាងបានប្រឡងជាប់រៀនបន្ត។ កំឡុងពេលត្រៀម និងការប្រឡងបញ្ចប់មធ្យមសិក្សានៅជប៉ុន ត្រូវបានគេប្រសិទ្ធនាមថា ***«ការប្រឡងមរណៈ»***។ ក្រោយបញ្ចប់កម្រិតមធ្យមសិក្សា គឺជាពេលវេលាសម្រាកដ៏ល្អបំផុត។ ក្នុងប្រទេសនេះ ថ្នាក់ឧត្តមសិក្សាគឺជាឆ្នាំសិក្សាដ៏ល្អបំផុតសម្រាប់ជីវិត ហើយពេលខ្លះប្រជាជនជប៉ុនហៅកំឡុងពេលនេះថា **«វិស្សមកាល»** មុនពេលការងារ។ *សម្រាប់នៅប្រទេសកម្ពុជា* សិស្សនៅមធ្យមសិក្សាទុតិយភូមិមួយចំនួនហាក់ទាន់មានភាពមិនច្បាស់លាស់នៅឡើយចំពោះការសម្រេចចិត្តការជ្រើសរើសរៀនថ្នាក់សង្គម ឬថ្នាក់វិទ្យាសាស្ត្រ និងការបន្តការសិក្សានៅកម្រិតឧត្តមសិក្សា។ សិស្សមួយចំនួនធ្វើការសម្រេចចិត្តតាមគ្នា ឬស្ថិតក្រោមឥទ្ធិពលខាងក្រៅ ហើយពេលខ្លះមានភាពមិនស៊ីសង្វាក់គ្នារវាងការសិក្សានៅមធ្យមសិក្សា និងនៅមហាវិទ្យាល័យ។ (ឧ.នៅកម្រិតវិទ្យាល័យ សិស្សជ្រើសរើសរៀនថ្នាក់សង្គម តែដល់ពេលបន្តការសិក្សានៅកម្រិតឧត្តមសិក្សាបែរជាជ្រើសរើសរៀនមុខវិជ្ជាឯកទេស វិទ្យាសាស្ត្រទៅវិញ)

## 2.8) ការអប់រំជំនាញវិជ្ជាជីវៈ

**សាលាបណ្តុះបណ្តាលជំនាញឯកទេសជប៉ុន៖** ផ្តោតលើការអប់រំវិជ្ជាជីវៈដោយការអនុវត្តផ្ទាល់ និងជំនាញបច្ចេកវិទ្យាឯកទេស។ សាលាបណ្តុះបណ្តាលជំនាញឯកទេសបែកចែកជា៣ប្រភេទ៖(១)សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ(កម្មវិធីក្រោយមធ្យមសិក្សា)សិស្សដែលបញ្ចប់ការសិក្សាអាចចូលរៀននៅមហាវិទ្យាល័យបាន។ (២)សាលាបណ្តុះបណ្តាលជំនាញឯកទេស (កម្មវិធីសម្រាប់មធ្យមសិក្សាទុតិយភូមិ)ដែលមានប្រហែល៤៦០សាលាពេលបច្ចុប្បន្ននេះ។ សិស្សអាចចូលរៀនបានទាល់តែមានសញ្ញាប័ត្របឋមភូមិ ហើយត្រូវរៀនច្រើនជាង២ឆ្នាំទើបមានសិទ្ធិ

ចូលរៀនមហាវិទ្យាល័យបាន។ (៣)វគ្គសិក្សាទូទៅ ជំនាញឯកទេស៖ សាលាបណ្តុះបណ្តាលនេះ បើកចំហសម្រាប់អ្នករាល់គ្នា ដោយគ្មានលក្ខខណ្ឌចូលរៀនអ្វីទេដែលមានកម្មវិធីផ្សេងៗជាច្រើន ដែលបានផ្តល់ការបណ្តុះបណ្តាលដូចជា៖ កាត់ដេរ សិល្បៈ ការរចនា និងជំនាញចុងភៅ។ នៅប្រទេសកម្ពុជា មានសិស្សបោះបង់ការសិក្សាច្រើននៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ចូលធ្វើការជាកម្មករតាមរោងចក្រ និងកម្មករផ្សេងៗដែលគ្មានជំនាញច្បាស់លាស់។ ដូច្នេះ ការទាក់ទាញពួកគាត់ឱ្យចាប់អារម្មណ៍នឹងការសិក្សាជំនាញវិជ្ជាជីវៈជារឿងចាំបាច់បំផុតមួយ សម្រាប់ដំណាក់កាលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។ គំរូផ្នែកទី៣របស់ជប៉ុន **"វគ្គសិក្សាជំនាញឯកទេស"** វាសមស្របនឹងស្ថានភាពរបស់កម្ពុជា ដែលយើងត្រូវបើកចំហឱ្យបានទូលំទូលាយក្នុងការអនុញ្ញាតឱ្យសិស្សដែលបោះបង់ការសិក្សាទោះកម្រិតណាក៏ដោយ បានសិក្សារៀនសូត្រនិងដាក់ពួកគាត់ចូលក្នុងប្រព័ន្ធមួយច្បាស់លាស់។។

**ការអប់រំជំនាញវិជ្ជាជីវៈជាន់ខ្ពស់៖**មហាវិទ្យាល័យ(junior colleges)ផ្តល់វគ្គសិក្សាបរិញ្ញាបត្ររងដែលត្រូវចំណាយពេលសិក្សាពី០២ឆ្នាំ(=៦២ក្រេឌីត) ទៅ៣ឆ្នាំ(៩៣ក្រេឌីត)តាមរយៈការសិក្សាទ្រឹស្តី និងអនុវត្តន៍ផ្ទាល់ ហើយភាគច្រើនជាសាលាឯកជនដែលជំនាញឯកទេសដូចជា៖ សេដ្ឋកិច្ចគ្រួសារ ការបង្រៀន គិលានុប-ដ្ឋាយិកា និងសិល្បៈ។ និស្សិតចូលរៀនភាគច្រើនជាស្ត្រី។ ដើម្បីចូលរៀនបាន សិស្សត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និងត្រូវប្រឡងចូល។ នៅពេលបញ្ចប់ការសិក្សា និសិត្សអាចបន្តថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យ ឬមហាវិទ្យាល័យបាន។ មហាវិទ្យាល័យបច្ចេកទេស ផ្តល់ការសិក្សាកម្មវិធីជំនាញបច្ចេកទេសរយៈពេល៥ឆ្នាំ សម្រាប់សិស្សដែលបញ្ចប់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ។ កម្មវិធីតម្រូវឱ្យបំពេញ១៦៧ក្រេឌីត និងផ្តល់ជម្រើសសម្រាប់ការចូលរៀនកម្មវិធីសាកលវិទ្យាល័យ។ កម្មវិធីនេះមានការអនុវត្ត(បណ្តុះបណ្តាល និងការពិសោធ) និងមេរៀនទ្រឹស្តី។

## 2.9) ការអប់រំឧត្តមសិក្សា

ការសិក្សាកម្រិតខ្ពស់ (ថ្នាក់មហាវិទ្យាល័យ)៖ សិស្សដែលមានសញ្ញាបត្រថ្នាក់វិទ្យាល័យដែលចង់ទៅសិក្សាបន្តនៅសាកលវិទ្យាល័យជាតិទៀតត្រូវតែប្រឡង

ចូល២ដង ក្នុងនោះ មួយជាលទ្ធផលនៃការប្រឡងថ្នាក់ជាតិ មួយទៀតគឺការប្រឡងចូលដែលតម្រូវដោយសាកលវិទ្យាល័យផ្ទាល់ តាមវិញ្ញាសាផ្សេងៗដែលសាលាបានកំណត់។ តែបច្ចុប្បន្នគ្រឹះស្ថានអប់រំឯកជនជាច្រើនក៏ប្រើប្រាស់លទ្ធផលប្រឡងថ្នាក់ជាតិយកជាមូលដ្ឋានក្នុងការផ្តល់អាហារូបករណ៍ផងដែរ។ ការប្រឡងថ្នាក់ជាតិមាន៦មុខវិជ្ជា៖ ភាសាជប៉ុន គណិតវិទ្យា សិក្សាសង្គម ភូមិវិទ្យា ប្រវត្តិវិទ្យា គណិតវិទ្យា និងភាសាបរទេស។ គ្រឹះស្ថានសិក្សាឯកជនមួយចំនួនប្រើប្រាស់នីតិវិធីជ្រើសរើសនិស្សិតផ្ទាល់ខ្លួនដោយមិនពឹងផ្អែកទាំងស្រុងលើលទ្ធផលប្រឡងបញ្ចប់មធ្យមសិក្សា ដែលនីតិវិធីនោះមានដូចជា៖ ការសម្ភាស កិច្ចការស្រាវជ្រាវ តេស្តអនុវត្តន៍ ឬផ្អែកសកម្មភាពក្រៅម៉ោងសិក្សាដូចជា៖ ការចូលរួមជាមួយក្លឹបសិក្សា ក្រុមប្រឹក្សាសិស្ស និងការចូលរួមប្រកួតប្រជែងស្នាដៃនានា។ ការប្រឡងចូលមហាវិទ្យាល័យត្រូវបានគេចាត់ទុកថាជាតេស្តដែលលំបាកបំផុត។ គ្រឹះស្ថានឧត្តមសិក្សាផ្តល់ការអប់រំថ្នាក់បរិញ្ញាបត្រទូទៅរយៈពេល៤ឆ្នាំ ហើយមុខជំនាញពេញនិយមមាន៖ វិទ្យាសាស្ត្រសង្គម (ពាណិជ្ជកម្ម នីតិសាស្ត្រ និងគណនេយ្យ) វិស្វកម្ម មនុស្សសាស្ត្រ និង គរុកោសល្យ។

ការចំណាយជាមធ្យមនៅមហាវិទ្យាល័យ (ថ្លៃសាលា និងហូបចុក) ក្នុងមួយឆ្នាំ ប្រមាណ១,៤លានយ៉េន (=១ម៉ឺនដុល្លារ)។ ដើម្បីផ្គត់ផ្គង់ការចំណាយទាំងនេះ និស្សិតទាំងឡាយតែងចេញទៅធ្វើការក្រៅម៉ោង ឬខ្ចីប្រាក់ពីសមាគមអាហារូបករណ៍ជប៉ុនដែលជាសមាគមគាំទ្រដោយរាជរដ្ឋាភិបាលជប៉ុន។ ជាមួយគ្នានេះក៏មានជំនួយដែលសិស្សអាចទទួលបានពីរដ្ឋបាលតំបន់ សហគ្រាស និងស្ថាប័ននានាផងដែរ។

ការអប់រំជាន់ខ្ពស់ត្រូវបានបែងចែកជាប្រភេទគ្រឹះស្ថានអប់រំផ្សេងៗដូចជា៖សាកលវិទ្យាល័យ មហាវិទ្យាល័យ (junior colleges) មហាវិទ្យាល័យបច្ចេកវិទ្យា និងមហាវិទ្យាល័យបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដោយផ្អែកលើលក្ខណៈគ្រឹះស្ថានសិក្សា គេបែងចែកជា៣ប្រភេទគឺ៖ គ្រឹះស្ថានសិក្សារដ្ឋ (ស្ថិតិឆ្នាំ២០១២មានចំនួន៨៦) គ្រឹះស្ថានសិក្សាសាធារណៈ(ចំនួន៩២) និងឯកជន(មានចំនួន៦០៥)។ សាកលវិទ្យាល័យផ្តល់កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត។ មហាវិទ្យាល័យផ្តល់ការសិក្សាជំនាញវិជ្ជាជីវៈកម្រិតបរិញ្ញាបត្ររង ហើយមហាវិទ្យាល័យ

បច្ចេកទេសផ្តល់ការសិក្សាដល់សិស្សបញ្ចប់មធ្យមសិក្សាបឋមភូមិ សិក្សាជំនាញវិជ្ជាជីវៈរយៈពេល៥ឆ្នាំ ហើយមហាវិទ្យាបណ្តុះបណ្តាលជំនាញឯកទេសផ្តល់ការសិក្សារយៈពេលពី១ឆ្នាំ ដល់៤ឆ្នាំលើវគ្គសិក្សាអនុវត្ត។ សកលវិទ្យាល័យដែលមានឈ្មោះល្បីល្បាញនៅប្រទេសជប៉ុនមាន៖ សាកលវិទ្យាល័យតូក្យូ និងសាកលវិទ្យាល័យក្យូតុ(94)។

**កម្រិតបរិញ្ញាបត្រ៖** ត្រូវសិក្សារយៈពេល៤ឆ្នាំ ឬ១២៤ក្រេឌីត តែថ្នាក់បរិញ្ញាបត្រវេជ្ជសាស្ត្រ ទន្តសាស្ត្រ និងឱសថសាស្ត្រត្រូវរៀន៦ឆ្នាំ ឬ១៨៨ក្រេឌីត។ ចំណែកឯថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់**ត្រូវសិក្សារយៈពេល២ឆ្នាំ ឬ៣០ក្រេឌីត ឬច្រើនជាងនេះ ដែលនិស្សិតត្រូវចំណាយពេលពាក់កណ្តាលសម្រាប់ការសិក្សារៀនសូត្រ ហើយពាក់កណ្តាលទៀតសរសេរសារណា។ កម្មវិធីសិក្សាក៏ផ្តោតលើវិធីសាស្ត្រទាក់ទងនឹងការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ។ សម្រាប់ថ្នាក់បណ្ឌិត និស្សិតដែលអាចចូលរៀនបានទាល់តែមានសញ្ញាប័ត្របរិញ្ញាបត្រជាន់ខ្ពស់ ធ្វើការប្រឡងចូល និងផ្តល់ការណែនាំពីសាស្ត្រាចារ្យយ៉ាងហោចណាស់០២រូប ឬគ្រូបង្រៀនជាន់ខ្ពស់។ ដំណើរការដើម្បីទទួលបានសញ្ញាប័ត្របណ្ឌិតត្រូវសិក្សារយៈពេល០៣ឆ្នាំ។

សមាមាត្រមនុស្សពេញវ័យនៅជប៉ុនដែលមានការអប់រំកម្រិតឧត្តមសិក្សាមាន៣៤% ដល់៤៧%នៅចន្លោះឆ្នាំ២០០០ ដល់២០១២។ ស្ទើរតែ៨០%នៃនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ។ អត្រាគ្មានការងារធ្វើសម្រាប់និស្សិតបញ្ចប់ឧត្តមសិក្សាបានធ្លាក់ចុះពី៣,៥%ក្នុងឆ្នាំ២០០០ មក៣,២%ក្នុងឆ្នាំ២០១២ ហើយអត្រាគ្មានការងារធ្វើសម្រាប់សិស្សកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សាបានកើនឡើងពី៤,៧%ក្នុងឆ្នាំ២០០០មក៥,១%ក្នុងឆ្នាំ២០១២។ នេះបញ្ជាក់ថាតម្រូវការកម្មករដែលមានកម្រិតជំនាញច្បាស់លាស់មានកើនឡើង និងការប្រកួតប្រជែងសមត្ថភាពកាន់តែខ្លាំង(95)។

ដើម្បីផ្តល់ឱកាសដល់សិស្សបន្តការសិក្សានៅកម្រិតឧត្តមសិក្សា ក្រសួងអវកវប បានធានានូវកម្មវិធីប្រាក់កំចីអាហារូបករណ៍ និងបានណែនាំនូវប្រាក់កំចីអាហារូបករណ៍គ្មានការប្រាក់ជាមួយគោលនយោបាយសងត្រឡប់ពឹងផ្អែកលើប្រាក់ចំណូល(២០១២)។ និស្សិតមិនតម្រូវឱ្យសងត្រឡប់រហូតដល់ពួកគេមានប្រាក់ចំណូល

ប្រចាំប្រមាណ៣លានយ៉េន (ប្រមាណ២០,០០០EUR)បន្ទាប់ពីបញ្ចប់ការសិក្សា។ សម្រាប់កម្ពុជានៅមិនទាន់មានកម្មវិធីជួយគាំទ្រសិស្ស-និស្សិតបែបនេះនៅឡើយទេ។

ជប៉ុនជាកន្លែងទាក់ទាញនិស្សិតបរទេសទៅសិក្សារៀនសូត្រ៣,៣%នៃនិស្សិតបរទេសបានចុះឈ្មោះចូលរៀននៅវិទ្យាស្ថានអប់រំកម្រិតឧត្តមសិក្សានៅជប៉ុនក្នុងឆ្នាំ២០១២។ ក្នុងឆ្នាំ២០១៤ ក្នុងចំណោមនិស្សិតបរទេសទាំងអស់ មាន៩៤%មកពីប្រទេសទាំងឡាយនៅអាស៊ី ជាពិសេស៨១%គឺនិស្សិតមកពីប្រទេសជិតខាង ដែលជាសមាមាត្រធំបំផុតក្នុងចំណោមប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀត[93]។ ទន្ទឹមនឹងនិស្សិតបរទេសចូលមកសិក្សានៅជប៉ុន ឯការបញ្ជូនសិស្សទៅរៀននៅបរទេសវិញរបស់ជប៉ុនបែរជាមានចំនួនតិចតួចនៅឡើយខុសពីប្រទេសសឹង្ហបូរីដែលមាននិស្សិតបរទេសចូលមកសិក្សាក៏ច្រើន ហើយបញ្ជូនចេញទៅរៀននៅបរទេសវិញក៏ច្រើនដែរ។ ការបញ្ជូនសិស្សទៅរៀននៅបរទេសជាមធ្យោបាយមួយសម្រាប់ជួយនិស្សិតក្នុងការរៀបចំខ្លួនទទួលយកទីផ្សារការងារដែលមានអន្តរទំនាក់ទំនងនិងសាកលភាវូបនីយកម្មកំពុងកើនឡើង។ ក្នុងឆ្នាំ២០១១ មាននិស្សិតឧត្តមសិក្សាជប៉ុនតែ១%ប៉ុណ្ណោះទៅសិក្សានៅបរទេស។ ឆ្លើយតបទៅនឹងបញ្ហានេះ ជប៉ុនរៀបចំផែនការយុទ្ធសាស្ត្របង្កើនចំនួននិស្សិតទៅសិក្សានៅបរទេស រួមទាំងបង្កើននូវកម្មវិធីផ្លាស់ប្តូរការសិក្សា[93]។

## 2.10) លក្ខណៈពិសេសនៃការអប់រំ

### ❖ សិស្ស-និស្សិតចំណាយពេលវេលាច្រើនលើការសិក្សា

ទោះបីស្ថិតក្នុងពេលវិស្សមកាល គ្រូបង្រៀន និងសិស្សជប៉ុននៅតែបន្តធ្វើការ ឬសិក្សារៀនសូត្របន្ថែម លើកលែងតែថ្ងៃបុណ្យជាតិប៉ុណ្ណោះដែលគ្រូ និងសិស្សជប៉ុនសម្រាក។ គ្រូ និងសិស្សជប៉ុនមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់គេ ហើយវាក្លាយទៅជាវប្បធម៌របស់ជនជាតិជប៉ុនទៅហើយ។ នៅថ្នាក់អនុវិទ្យាល័យ អំឡុងពេលវិស្សមកាល សិស្សបានចូលរួមជាមួយក្លឹបសិក្សាដែលខ្លួនចូលចិត្ត ហើយនៅបន្តធ្វើការ ឬសិក្សារួមគ្នា ព្រមទាំងចូលរួមការបណ្តុះបណ្តាលកីឡា។ មិនតែប៉ុណ្ណោះ គ្រូបានផ្តល់កិច្ចការផ្ទះជាច្រើនដល់សិស្សដើម្បីដោះស្រាយពេញរដូវវិស្ស

កាល។ សកម្មភាពក្លឹបសិក្សានៅពេលព្រឹក និងបន្ទាប់ពីម៉ោងសិក្សា៖ មុនពេលសិក្សា និងក្រោយពីសិក្សានៅក្នុងថ្នាក់រៀន សិស្សជប៉ុនត្រូវចូលរួមលេងកីឡាដែលជាសកម្មភាពក្លឹបសិក្សា។ ស្តាប់មើលទៅសិស្សជប៉ុនហាក់ធ្វើការច្រើនណាស់ក្រៅពីការសិក្សាតាមមុខវិជ្ជាហើយ និងត្រូវភ្ញាក់ពីព្រឹកព្រលឹម និងត្រឡប់ទៅផ្ទះវិញយឺតពេល ដោយសារចូលរួមសកម្មភាពសិក្សាផ្សេងៗជាច្រើន ដែលតម្រូវឱ្យពួកគេមានការតស៊ូ ការប្តេជ្ញាចិត្ត និងភាពស្វិតស្វាញនឹងការបំពេញការងារ។

❖ **ញ៉ាំអាហារថ្ងៃត្រង់រួមជាមួយគ្នានៅក្នុងថ្នាក់រៀន**

នៅជប៉ុន សិស្សសាលាតម្រូវឱ្យញ៉ាំអាហារថ្ងៃត្រង់ប្រភេទដូចៗគ្នានៅសាលារៀន ដែលវាខុសពីប្រទេសមួយចំនួនដែលផ្តល់លទ្ធផលឱ្យសិស្សអាចទិញអាហារពីអាហារដ្ឋាន ឬយកអាហារមកពីផ្ទះទៅតាមចំណង់ចូលចិត្តរៀងៗខ្លួន។ ជាទូទៅ នៅសាលារៀនគ្មានកន្លែងលក់ចំណីអាហារទេ ប៉ុន្តែសាលារៀនមួយចំនួនតូចក៏មានលក់ដូរដែរ ដោយមានការត្រួតពិនិត្យហ្មត់ចត់បំផុត។ សិស្សជប៉ុនហូបអាហាររួមគ្នានៅក្នុងថ្នាក់រៀន រួចក៏សហការរួមគ្នាធ្វើការសម្អាតអនាម័យដែរព្រោះគ្មានអ្នកបម្រើសម្រាប់ការងារនេះទេ។ សិស្សានុសិស្សមិនអនុញ្ញាតឱ្យញ៉ាំអាហារនៅខាងក្រៅថ្នាក់រៀនទេ។ ការចំណាយនេះមានការឧបត្ថម្ភពីរដ្ឋ តែមិនមែនផ្តល់ដោយឥតគិតថ្លៃទេ។ អាហារថ្ងៃត្រង់មាន៖ បាយ ម្ហូប និងទឹកដោះគោ។ ការផ្តល់អាហារថ្ងៃត្រង់នៅសាលារៀននេះ មិនត្រឹមតែជួយសិស្សឱ្យទទួលទានអាហារមានជីវជាតិ សុវត្ថិភាព និងសុខភាពគ្រប់គ្រាន់នោះទេ តែថែមទាំងជួយឱ្យពួកគេ មានទម្លាប់ល្អក្នុងការទទួលទាន ឥរិយាបថក្នុងសង្គម និងរៀនសូត្រជំនាញជីវិតផងដែរ។

❖ **គ្មានការបណ្តេញសិស្សចេញក្រៅថ្នាក់ទេ**

ដោយសាររដ្ឋធម្មនុញ្ញជប៉ុនមាត្រាទី២៦ចែងថា **"បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការអប់រំដោយស្មើភាព..."** ដូច្នេះគ្រូបង្រៀនមិនដែលដាក់ពិន័យសិស្សដែលមានឥរិយាបថមិនគប្បីចេញក្រៅថ្នាក់ឡើយដូចដែលប្រទេសជាច្រើនបានអនុវត្តនោះទេ ដោយព្យាយាមរកវិធីផ្សេងៗដើម្បីជួយពួកគាត់។ សិស្សជប៉ុនសឹងតែមិនដែលអាក់ខានការសិក្សា ឬក៏មករៀនយឺតនោះទេ។ បន្ថែមពីលើនេះទៅទៀត សិស្សប្រមាណជា ៩១%ត្រូវបានគេរាយការណ៍ថា ពួកគេមានការយកចិត្តទុកដាក់ក្នុងការសិក្សា រៀន

សូត្រ( ស្តាប់គ្រូពន្យល់ដែលនេះជាតួលេខមួយដែលខ្ពស់បំផុតនៅក្នុងពិភពលោក។ សិស្សជប៉ុនស្ទើរតែមិនដែលរៀនត្រួតថ្នាក់សោះទាំងកម្រិតបឋមសិក្សា និងមធ្យមសិក្សា។

### ❖ សិស្សត្រូវបានលើកទឹកចិត្តឱ្យឡើងថ្នាក់

សិស្សជប៉ុនពិតជាសំណាងណាស់ ព្រោះសិស្សទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យឡើងថ្នាក់ដោយមិនគិតពីលទ្ធផលតេស្ត ឬលទ្ធផលសិក្សាអ្វីឡើយ ទោះបីលទ្ធផលតេស្ត ឬលទ្ធផលសិក្សាទាប ពួកគេនៅតែអាចឡើងថ្នាក់បាន។

### ❖ សិស្សគេចសាលាមានតិចតួចបំផុត

សិស្សគេចសាលានៅជប៉ុនមានអត្រាតិចប្រមាណ៨.៩% ទាបជាងប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀតដែលជាសមាជិកOECDដែលអត្រាជាមធ្យម៣៥.៣% ។ ក្នុងឆ្នាំ២០១១ ជប៉ុនបានបង្កើនចំនួនម៉ោងសិក្សាប្រចាំឆ្នាំដើម្បីធ្វើឱ្យធ្លាក់ចុះការពឹងផ្អែកលើថ្នាក់បង្រៀនគួរក្រៅម៉ោង។ កម្រិតបឋមសិក្សាបង្កើនម៉ោងសិក្សាប្រចាំឆ្នាំ ៣០០ម៉ោងចាប់ផ្តើមក្នុងឆ្នាំ២០១២/២០១៣ហើយបង្កើន១០០ម៉ោងសម្រាប់មធ្យមសិក្សាបឋមភូមិ។ ក្នុងឆ្នាំ២០១៤ចំនួនម៉ោងសិក្សាប្រចាំឆ្នាំសម្រាប់កម្រិតអប់រំដែលជាកាតព្វកិច្ច (ពីថ្នាក់ទី១ ដល់ទី៩)បានកើនដល់៤,៥៧៥ម៉ោងនៅបឋមសិក្សា និង ២,៦៨៤ម៉ោងនៅមធម្យមសិក្សាបឋមភូមិ[(86)] ។

### ❖ គ្មានបញ្ហាទេ បើសិស្សដេកនៅក្នុងថ្នាក់ពេលគ្រូកំពុងបង្រៀន

សិស្សដេកនៅក្នុងថ្នាក់រៀនពេលកំពុងបង្រៀនដោយគ្មានបញ្ហា៖ ខុសពីប្រទេសកម្ពុជា បើសិនមានសិស្សដេកនៅក្នុងថ្នាក់រៀនគ្រូបង្រៀននឹងដាក់ឱ្យភ្ញាក់ និងដាក់ពិន័យជាក់ជាមិនខាន តែនៅជប៉ុនគ្មានបញ្ហាទេដោយគ្រូបង្រៀនបណ្តោយឱ្យសិស្សនោះបន្តដេករបស់ខ្លួនតទៅទៀតក្នុងម៉ោងសិក្សា។ នេះដោយសារគ្រូបង្រៀនទាំងអស់មានជំនឿ និងទំនុកចិត្តលើសិស្សខ្លួនក្នុងនាមជាជនជាតិជប៉ុន ចំពោះកិច្ចប្រឹងប្រែងសិក្សារៀនសូត្រ។ ការសម្រាកត្រូវបានចាត់ទុកថាជារឿងសំខាន់បំផុត

ព្រោះសិស្សម្នាក់ៗខិតខំប្រឹងប្រែងខ្លាំងណាស់លើការសិក្សារៀនសូត្រនេះ។ វាពិតជានឿយហត់ណាស់សម្រាប់ការសិក្សានៅជប៉ុនដោយសារក្រៅពីរៀននៅសាលារដ្ឋ ហើយពួកគេត្រូវចូលរួមសកម្មភាពក្លឹបសិក្សាផ្សេងៗទៀត ហើយសិស្សមួយចំនួនធំនៅបន្តការសិក្សានៅថ្នាក់គួរបន្ថែមទៀត។ ជារៀងរាល់ថ្ងៃមានកិច្ចការជាច្រើនសម្រាប់សិស្សជប៉ុន ដែលធ្វើឱ្យសិស្សមានពេលតិចតួចសម្រាប់សម្រាក។ ដូច្នេះ វាអាចធ្វើឱ្យសិស្សងងុយដេក និងដេកក្នុងថ្នាក់អំឡុងពេលគ្រូកំពុងបង្រៀន។

### ❖ ការរៀនគួរបន្ថែមក្រៅម៉ោង

**ការរៀនក្រៅម៉ោងបន្ថែម «រៀនគួរ» ពេញនិយមបំផុតនៅជប៉ុន។** ដើម្បីបានពិន្ទុល្អមុនពេលចូលសិក្សានៅថ្នាក់វិទ្យាល័យ សិស្សជប៉ុនចូលចិត្តចូលរួមវគ្គសិក្សា «**គួរ**» ឬសិក្ខាសាលាតម្រង់ទិសផ្សេងៗនៅសាលាត្រៀម ឬសាលារៀនឯកជន។ សិក្ខាសាលា ឬវគ្គសិក្សាបន្ថែមប្រភេទនេះ តែងតែរៀបចំនៅពេលយប់។ លើសពីនេះ ពួកគេបានសិក្សាជាក្រុមតូចៗ និងបន្ថែមកម្មវិធីសិក្សាលើកម្មវិធីដែលខ្លួនមាន។ សិស្សានុសិស្សនៅជប៉ុនត្រូវបានសិក្សាចំនួន៨ម៉ោងក្នុងមួយថ្ងៃ (កម្មវិធីធម្មតា) និងបានសិក្សាបន្ថែមនៅថ្ងៃចុងសប្តាហ៍ និងនៅថ្ងៃឈប់សម្រាកទៀតផង (សរុបជាទូទៅប្រមាណ៧០ម៉ោង/សប្តាហ៍)ដែលជាចំនួនម៉ោងច្រើនបំផុតស្ទើរតែគ្មានសម្រាកសោះ។ ដូចនេះគ្មានអ្វីដែលយើងត្រូវឆ្ងល់ទេថា ហេតុអ្វីសិស្សជប៉ុនរៀនមិនដែលធ្លាក់ត្រួតថ្នាក់នៅបឋមសិក្សា ឬវិទ្យាល័យ និងមានលទ្ធផលតេស្ត PISA ខ្ពស់នោះ។ សម្រាប់ការរៀនគួរបន្ថែមក្រៅម៉ោង និងការចំណាយពេលសិក្សាជាក្លឹបសិក្សា និងផ្ទាល់ខ្លួនរបស់សិស្សកម្ពុជា គឺនៅតិចតួចណាស់បើប្រៀបធៀបនឹងសិស្សជប៉ុន។ ដូច្នេះ ចំណុចជោគជ័យរបស់សិស្សជប៉ុន គឺការលះបង់ពេលវេលា និងការខិតខំប្រឹងប្រែងខ្លាំងលើការសិក្សា ព្រមទាំងស្មារតីមុះមុតដើម្បីសម្រេចលទ្ធផលសិក្សាដែលសិស្សកម្ពុជាត្រូវសិក្សារៀនសូត្រ។ បើចង់ខ្លាំងដូចជប៉ុនត្រូវសង្វាតប្រឹងប្រែងឱ្យដូចជប៉ុន។

### ❖ ម្ចាស់ការ និងរៀនទទួលខុសត្រូវដោយខ្លួនឯង

ដោយសារទឹកដីជប៉ុនប្រឈមនឹងគ្រោះធម្មជាតិខ្ពស់ និងកើតឡើងញឹកញាប់ ដូច្នេះការដុះខាត់សមត្ថភាព និងស្មារតីដើម្បីដោះស្រាយ និងពង្រឹងភាពធន់

ទ្រាំនឹងបញ្ហាទាំងនោះជារឿងចាំបាច់បំផុតរបស់ជប៉ុនក្នុងប្រព័ន្ធអប់រំទាំងក្នុងគ្រួសារ និងសាលារៀន។ ចាប់តាំងពីកម្រិតបឋមសិក្សា និងមធ្យមសិក្សាកូនសិស្សជប៉ុនធ្វើដំណើរទៅសាលារៀនដោយខ្លួនឯងដោយដើរ ជិះកង់ ឬជិះរថភ្លើង ទៅតាមទីតាំង និងចម្ងាយសាលារៀន ពោលគឺមិនអនុញ្ញាតឱ្យសិស្សជិះម៉ូតូ ឬឡានទេនៅកម្រិតមធ្យមសិក្សាទោះសិស្សនោះគ្រប់អាយុក៏ដោយ និងមិនមានឪពុកម្ដាយ ឬអាណាព្យាបាលជូនទៅជូនមកដូចនៅប្រទេសកម្ពុជា ឬប្រទេសនានាទៀតនោះទេ ។ ទោះបីឪពុកម្ដាយ ឬអាណាព្យាបាលស្រឡាញ់កូនប៉ុណ្ណាក៏ដោយ ក៏ការពិតមួយនេះមិនអាចកែប្រែផ្លាស់ប្ដូរបានឡើយ បើអ្នកកើតនៅជប៉ុន និងជាជនជាតិជប៉ុន។ ចំណុចពិសេសដែលពួកគេអនុវត្តបែបនេះគឺដើម្បីជំរុញឱ្យកុមារមានភាពម្ចាស់ការ ទទួលខុសត្រូវលើខ្លួនឯង និងត្រៀមខ្លួនប្រឈមមុខចំពោះឧបសគ្គទាំងឡាយ ព្រមទាំងដោះស្រាយបញ្ហាទាំងអស់នោះដោយខ្លួនឱ្យឯង។ ផ្នត់គំនិត និងទស្សនៈនេះខុសស្រឡះពីឪពុកម្ដាយនៅប្រទេសជាច្រើនរួមទាំងកម្ពុជាផងដែរ។ ម៉្យាងទៀត ស្ថានភាពសង្គម និងសេដ្ឋកិច្ចស្រុកយើងក៏ពិបាកអនុវត្តដូចជប៉ុននេះណាស់ព្រោះនៅមានបញ្ហាប្រឈមច្រើនពិសេសបញ្ហាសុវត្ថិភាពនេះឯង។ ទោះបីយ៉ាងក៏ដោយក៏យើងអាចរៀនសូត្របានលើចំណុចមួយចំនួនពីប្រទេសជប៉ុនបានផងដែរលើការអភិវឌ្ឍកុមារ។ ***នៅប្រទេសកម្ពុជា*** ឪពុកម្ដាយ ឬអាណាព្យាបាលមួយចំនួនបង្ហាញលក្ខណៈជ្រុលនិយមស្រឡាញ់ជ្រុល ឬអនុវត្តបែបអវិជ្ជមានជ្រុល (ឧ.ប្រើប្រាស់អំពើហិង្សា...) ដោយមិនសូវយកចិត្តទុកដាក់អភិវឌ្ឍន៍ចំណេះដឹងផ្នែកសង្គម បង្កើនភាពម្ចាស់ការ ការទទួលខុសត្រូវដល់កូនដូចជប៉ុនទេ...។ល។ ករណីខ្លះ(មិនទូទៅទេ)សូម្បីតែគ្រូបង្រៀនឱ្យកូនសិស្សដើររើសសំរាមសម្អាតនៅក្នុងទីធ្លាសាលា ក៏ឪពុកម្ដាយមួយចំនួនមិនសប្បាយចិត្តដែរ ព្រោះពួកគាត់មិនចង់ឱ្យកូនៗពួកគាត់ប៉ះពាល់សម្ភារៈកង្វក់ និងកង្វះអនាម័យនោះទេ ឬសូម្បីតែញ៉ាំបាយ ឪពុកម្ដាយ ឬអាណាព្យាបាលមួយចំនួននៅតែបញ្ចុក ឬនៅចាំបម្រើដែរទោះបីកូនមានអាយុ៤ ឬ៥ឆ្នាំទៅហើយក្ដី។ ទង្វើដែលពួកគាត់ធ្វើនេះគឺកំពុងធ្វើបាបកូនទៅវិញទេ។ ជាទូទៅ ពួកគេភ្លេចគិតថា "**ការស្រឡាញ់ថ្នាក់ថ្នមជ្រុល**" វាក៏ប៉ះពាល់ដល់សិទ្ធិកុមារដែរ គឺ**សិទ្ធិអភិវឌ្ឍន៍**។

- **បើកបវេសនកាលខុសពីប្រទេសផ្សេងៗ**

ខណៈពេលដែលសាលារៀននានានៅលើសកលលោកជាទូទៅបើកបវេសនកាលនៅអំឡុងខែកញ្ញា និងខែតុលា សាលារៀននៅប្រទេសជប៉ុនយកខែមេសាជាខែដែលចាប់ផ្តើមបើកវេសនកាល។ ថ្ងៃដំបូងនៃការសិក្សាគួរតែជាថ្ងៃដែលអាចគយគន់ក៏ដូចជាស្រូបយកក្លិនធម្មជាតិដ៏ស្រស់បំព្រង (រដូវផ្កា Cherry រីក)។ ក្នុងមួយឆ្នាំសិក្សាត្រូវបានបែងចែកចេញជា៣ត្រីមាស។ ត្រីមាសទី១ ចាប់ពីថ្ងៃទី១ ខែមេសាដល់ថ្ងៃទី២០ ខែកក្កដា។ ត្រីមាសទី២ គិតចាប់ពីថ្ងៃទី១ ខែកញ្ញា ដល់ថ្ងៃទី២៦ ខែធ្នូ និងត្រីមាសទី៣ គិតចាប់ពីថ្ងៃទី៧ ខែមករាដល់ថ្ងៃទី២៥ ខែមីនា។ សិស្សទទួលបានវិស្សមកាលរយៈពេល៦សប្តាហ៍សម្រាប់ថ្ងៃឈប់សម្រាកក្នុងអំឡុងពេលរដូវក្តៅ និង២សប្តាហ៍នៅក្នុងរដូវនីមួយៗ ពោលគឺឈប់សម្រាកវិស្សមកាលរយៈពេលខ្លីមែនទែនបើប្រៀបធៀបនឹងកម្ពុជា មានច្រើនជាង១០សប្តាហ៍។

### ❖ គ្រូបង្រៀនជាអាជីពពេញនិយម

តាមការស្រាវជ្រាវ សិស្ស-និស្សិតជប៉ុនចង់ចាប់យកអាជីពធ្វើជាគ្រូបង្រៀនជាងអាជីពផ្សេងៗទៀតដោយសារកត្តាសេដ្ឋកិច្ច និងគុណតម្លៃអាជីព។ ជាមួយគ្នានេះ ប្រាក់ខែក៏ជាផ្នែកមួយទាក់ទាញសម្រាប់អាជីពគ្រូបង្រៀននេះផងដែរ។ យោងតាមរបាយការណ៍អប់រំ ប្រាក់ខែគ្រូបង្រៀននៅជប៉ុនគឺខ្ពស់[86]។ ការចាប់ផ្តើមប្រាក់បៀវត្សប្រចាំឆ្នាំសម្រាប់គ្រូមធ្យមសិក្សាបឋមភូមិ មានចំនួន២៧,០៦៧ដុល្លារតិចជាងប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀតដែលមានចំនួន៣០,៧៣៥ដុល្លារ ប៉ុន្តែបន្ទាប់មានបទពិសោធ១៥ឆ្នាំនៅជប៉ុនប្រាក់បៀវត្សកើនដល់៤៧,៦៧១ដុល្លារ និងខ្ពស់បំផុតកើនដល់៥៩,៦៤៨ដុល្លារខ្ពស់ជាងប្រទេសដទៃវិញដែលកើនចន្លោះពី៤០,៥៧០ដុល្លារដល់៤៨,៩៨៣ដុល្លារ[86]។ ការផ្តល់ប្រាក់បៀវត្សខ្ពស់បន្ទាប់ពីបម្រើការក្នុងរយៈពេលមួយកំណត់ ជាយុទ្ធសាស្ត្រដ៏ល្អមួយរបស់ជប៉ុន ក្នុងការបង្កើតក្តីសង្ឃឹមអាជីព និងជាកត្តាជំរុញឱ្យគ្រូបង្រៀនយកចិត្តទុកដាក់ប្រឹងប្រែងធ្វើការងារក្នុងអាជីពរបស់ខ្លួន ក្នុងគោលដៅដើម្បីឈានដល់ដំណាក់កាលមួយថ្មីដែលទទួលបានអត្ថប្រយោជន៍ច្រើន។ ប៉ុន្តែការស្រាវជ្រាវច្រើនពីកម្រិតជាតិ និងអន្តរជាតិបានបង្ហាញថា មានអ្វីលើសពីប្រាក់ខែក្នុងលើកកម្ពស់ភាពទាក់ទាញអាជីពគ្រូបង្រៀន គឺការផ្តល់ភារកិច្ច និងការទទួលខុសត្រូវដល់គ្រូ លើកកម្ពស់ស្ថានភាពរបស់ពួកគេ ផ្តល់នូវ

ទស្សនវិស័យអាជីពពិតប្រាកដ និងធ្វើឱ្យពួកគេជាផ្នែកមួយនៃប្រព័ន្ធអប់រំដែលចូលរួមចំណែកផ្តល់ទស្សនទាន និងបទពិសោធ។ ហេតុដូច្នេះ បញ្ហាពិតប្រាកដគឺជារបៀបដែលយើងប្រព្រឹត្តចំពោះគ្រូបង្រៀនរបស់យើងហើយមិនត្រឹមតែយើងបង់ប្រាក់ឱ្យពួកគេប៉ុណ្ណោះទេ។

### ❖ គ្រូបង្រៀនជាមន្ត្រីសាធារណៈ គោរពតាមការចាត់តាំងឱ្យទៅបម្រើការងារ

គ្រូបង្រៀននៅជប៉ុនជាមន្ត្រីសាធារណៈ ពោរពេញទៅដោយគំនិតជាតិនិយម និងមនសិការវិជ្ជាជីវៈខ្ពស់ ហើយភាគច្រើន (ជាង៨០% បញ្ចប់ការកម្រិតបរិញ្ញាបត្រសិក្សាពីសាកលវិទ្យាល័យ ឬមហាវិទ្យាល័យ)។ ដូច្នេះ វាគ្មានបញ្ហាអ្វីទេសម្រាប់គ្រូបង្រៀនជប៉ុន ដែលត្រូវអនុវត្តតាមការចាត់តាំងឱ្យទៅបម្រើការងារនៅតាមសាលារៀនណាមួយទូទាំងប្រទេសទោះបីនៅទីក្រុង ឬជនបទក៏ដោយ និងមានគោលការណ៍ចល័តទៅបង្រៀនសាលារៀនផ្សេងៗទៀតក្នុងរវាង៣ ឬ៤ឆ្នាំម្តង ហើយគ្រូបង្រៀន១ភាគ៤ត្រូវចាប់ឆ្នោតដើម្បីផ្លាស់ប្តូរកន្លែងធ្វើការ។ បើពួកគេ ចង់ផ្លាស់ប្តូរទៅបង្រៀននៅសាលារៀនណាមួយដែលខ្លួនពេញចិត្ត ឬផ្លាស់ប្តូរខេត្ត ពិសេសនៅតាមទីក្រុង ពួកគេត្រូវឆ្លងកាត់ការប្រឡងជាមុនសិន[(96)]។ ប្រព័ន្ធបែបនេះ បង្ហាញពីភាពស្មើភាព យុត្តិធម៌ តម្លាភាព និងការទទួលខុសត្រូវ...នៅក្នុងអាជីពជាគ្រូបង្រៀន និងការគ្រប់គ្រងដឹកនាំ។ *សម្រាប់កម្ពុជា* បាននឹងកំពុងប្រឈមនឹងបញ្ហានេះច្រើនណាស់ទាក់ទងនឹងករណីនេះដូចជា៖ នៅតាមទីជនបទខ្វះគ្រូបង្រៀន ចំណែកឯនៅតាមទីក្រុង ប្រជុំជនលើសគ្រូច្រើនទៅវិញ[(87)]។ ទាំងនេះវាកើតឡើងដោយសារផ្ទេរ និងភាពចង់បានផលប្រយោជន៍របស់មន្ត្រីអប់រំមួយចំនួន ហើយរុញស្ថានភាពឱ្យពិបាកដោះស្រាយ ទោះបីជាមានគោលនយោបាយផ្តល់ប្រាក់ឧបត្ថម្ភដល់ការពង្រាយគ្រូហើយក៏ដោយ។

### ❖ ប្រព័ន្ធផ្តល់អាជាប័ណ្ណដល់គ្រូបង្រៀន

ប្រឡងជាប់បានធ្វើគ្រូបង្រៀននៅជប៉ុនមិនមែនមានន័យថា អ្នកអាចធ្វើជាគ្រូបង្រៀនមួយជីវិត ហើយជិះសេះលែងដៃបាននោះទេ ព្រោះគ្រូបង្រៀនត្រូវមានអាជ្ញាប័ណ្ណហើយមានសុពលភាពតែ១០ឆ្នាំប៉ុណ្ណោះ ដើម្បីបន្តអាជ្ញាប័ណ្ណ យ៉ាងហោច

ណាស់ត្រូវចូលរួមវគ្គសិក្សាយ៉ាងហោចណាស់៣០ម៉ោង ត្រូវបង្កើនកម្រិតគុណវុឌ្ឍិខ្លួនជាប្រចាំ និងត្រូវធ្វើការប្រឡងឡើងវិញដើម្បីបន្តសុពលភាពអាជ្ញាប័ណ្ណខ្លួន ។ ចំណុចនេះ ផ្តល់ឱកាសដល់គ្រូបង្រៀនបន្តសិក្សាពេញមួយជីវិត និងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍគុណវុឌ្ឍិខ្លួនជាប់ជាប្រចាំ។ ការប្រើប្រាស់***ប្រព័ន្ធអាជីព*** (*)សម្រាប់គ្រូបង្រៀននៅកម្ពុជា បង្ហាញពីចំណុចខ្សោយក្នុងការជំរុញ និងលើកទឹកចិត្តគ្រូបង្រៀនឱ្យបន្តសិក្សាពេញមួយជីវិត ព្រោះបើពួកគាត់ប្រឡងជាប់ធ្វើជាគ្រូបង្រៀនហើយគឺអាចធ្វើការងារនេះរហូតដល់ចូលនិវត្តន៍ លើកលែងប្រព្រឹត្តទោសកំហុសធ្ងន់ធ្ងរពីច្បាប់ធ្ងន់ធ្ងរ។ *សម្រាប់កម្ពុជា* ចំណុចនេះយើងគប្បីសិក្សាស្វែងយល់ពីអត្ថប្រយោជន៍នៃការអនុវត្តយុទ្ធសាស្ត្ររបស់ជប៉ុននេះ និងសាកល្បងចាប់យកចំណុចខ្លាំងរបស់វាយកមកអនុវត្តដើម្បីបម្រើដល់ការអភិវឌ្ឍវិស័យអប់រំក្នុងប្រទេសយើង។ បញ្ជាក់ នេះមិនមែនមានន័យថា យើងធ្វើការផ្លាស់ប្តូរទៅប្រើប្រាស់**ប្រព័ន្ធនិយោជ** (**) បែបថ្មីវិញនោះទេ ព្រោះវាមិនងាយស្រួលឡើយក្នុងផ្លាស់ប្តូរប្រព័ន្ធមួយទាំងមូលដោយវាគ្រាន់តែជាការសិក្សាស្វែងយល់ប៉ុណ្ណោះ។

***កំណត់សម្គាល់៖***

*( * ) **ប្រព័ន្ធអាជីព**=ឧ. បើប្រឡងជាប់គ្រូបង្រៀន ធ្វើគ្រូបង្រៀនមួយជីវិត។*

*( ** ) **ប្រព័ន្ធនិយោជ**=ជាប្រព័ន្ធមួយមានលក្ខណៈដូចមន្ត្រីជាប់កិច្ចសន្យា។ ឧ. បើខ្វះតួនាទីប្រធាន ឬនាយក គេប្រកាសជាសាធារណៈដើម្បីប្រកួតប្រជែងយកតួនាទីនេះ និងមានអណត្តិមួយច្បាស់លាស់ ហើយពេលចប់អណត្តិប្រកាសជ្រើសរើសសារថ្មី។ អ្នកចាស់មានសិទ្ធិដាក់ពាក្យដែរ បើជាប់បន្តកាន់តួនាទី តែបើធ្លាក់ចុះចេញ ឱ្យអ្នកថ្មីចូលមកកាន់ជួសវិញ។*

វាប្រហែលជាល្អប្រសើរជាងនេះ បើសិនយើងអនុវត្តសម្រាប់ថ្នាក់ដឹកនាំរាប់ពីតួនាទីនាយកសាលាឡើងទៅ ដែលត្រូវប្រឡងប្រជែង និងចូលរួមវគ្គបណ្តុះបណ្តាលដូចអ្វីដែលបានអនុវត្តថ្មីៗនេះ តែយើងគប្បីបន្ថែម ការកំណត់អណត្តិមួយច្បាស់លាស់ថែមទៀត ព្រោះសក្តានុពលអភិវឌ្ឍន៍របស់មនុស្សមានសន្ទុះខ្លាំងក្លាត្រឹមតែរង្វង់៥ឆ្នាំ ឬយ៉ាងយូរ១០ឆ្នាំប៉ុណ្ណោះ។ **ការអនុវត្តបែបនេះ ប្រហែលហុចផលវិជ្ជមានច្រើន ដែលជាយុទ្ធសាស្ត្រមួយដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញសន្ទុះគ្រូបង្រៀនវ័យក្មេងឱ្យខិតខំអភិវឌ្ឍន៍សមត្ថភាពដើម្បីត្រៀមលក្ខណៈធ្វើជាអ្នកដឹកនាំនាពេលអនាគត។** បើយើងបន្តឱ្យអ្នកដឹកនាំស្ថាប័នមួយមិនមានកំណត់អណត្តិមួយច្បាស់លាស់ វាអាចធ្វើសង្

វាក់អភិវឌ្ឍន៍មូលធនមនុស្សមិនមានវឌ្ឍភាពខ្លាំងក្លាដើរទាន់បរិបទបច្ចុប្បន្ន ក្នុងសម័យសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងសាកលភាវូបនីយកម្ម។ វាជាច្រកផ្លូវមួយ ដែលបើកចំហប្រកបដោយក្តីសង្ឃឹមសម្រាប់គ្រូបង្រៀនទូទៅ ពិសេសគ្រូបង្រៀនវ័យក្មេងដែលយកចិត្តទុកដាក់អភិវឌ្ឍន៍សមត្ថភាពខ្លួន និងត្រៀមលក្ខណៈសម្បត្តិបានគ្រប់គ្រាន់ក្នុងការធ្វើជាអ្នកដឹកនាំបន្តវេន។ ជាការពិត វាពិតជាពិបាកធ្វើកំណែទម្រង់ស៊ីជម្រៅ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអប់រំណាស់ បើការជ្រើសរើសថ្នាក់ដឹកនាំរាប់ចាប់ពីកម្រិតនាយកសាលារៀនឡើងទៅ ផ្អែកតាមបក្សពួកនិយម និន្នាការនយោបាយ ខ្សែរនិយម និងគ្រួសារនិយមនោះ ហើយយុទ្ធសាស្ត្រកំណែទម្រង់នឹងមិនមានប្រសិទ្ធភាពខ្លាំងក្លាឡើយព្រោះខ្លាចប៉ះពាល់ដល់សម្លេងគាំទ្រ បាត់បង់ផលប្រយោជន៍ អំណាច និងឥទ្ធិពលក្រុមខ្លួន ហើយស្ថានភាពនេះធ្វើឱ្យមានការថ្នាំងថ្នាក់គ្នា និងបែកបាក់សាមគ្គីផ្ទៃក្នុងមិនអាចធ្វើរួមគ្នាឆ្ពងមួយឆ្ពោះទៅគោលដៅរួមឡើយ។

### ❖ គន្លឹះជំរុញ និងលើកទឹកចិត្តគ្រូបង្រៀនឱ្យប្រឹងប្រែងបំពេញការងារ

អត្ថប្រយោជន៍ដ៏ច្រើនសម្រាប់អាជីពគ្រូបង្រៀនបន្ទាប់ពីរយៈពេល១៥ឆ្នាំ និងពេលចូលនិវត្តន៍ ត្រូវបានប្រើប្រាស់ជាមធ្យោបាយ ឬជាធ្នាក់ដើម្បីលើកទឹកចិត្តដល់គ្រូបង្រៀន ឱ្យយកចិត្តទុកដាក់បំពេញការងាររបស់ខ្លួនឱ្យបានល្អប្រសើរ ដោយសង្ឃឹមថានឹងឈានដល់គោលដៅចុងក្រោយមួយ ហើយទទួលបានសំណាង (អត្ថប្រយោជន៍)គួរជាទីពេញចិត្តតួយ៉ាងដូចទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ និងប័ណ្ណសរសើរជាដើម។ ដូច្នេះ ដើម្បីសម្រេចជោគជ័យក្នុងអាជីពការងារជាគ្រូបង្រៀននេះ ពួកគេត្រូវយកអស់កម្លាំងកាយចិត្ត និងស្មារតីក្នុងការបំពេញការងារដូចជា៖ ការបង្រៀន ការស្រាវជ្រាវ ចូលរួមសកម្មភាពសង្គម និងសកម្មភាពនានាទៀតដើម្បីទទួលបានអត្ថប្រយោជន៍ និងកិត្តិយសដ៏ថ្លៃថ្លានេះ។ **បើនិយាយឱ្យងាយស្រួលយល់គឺ ពេលចូលនិវត្តន៍ទៅ គ្រូបង្រៀននឹងក្លាយជាអ្នកមានព្រោះទទួលបានប្រាក់សោធនច្រើនពេលដល់អាយុត្រូវចូលនិវត្តភ្លាម។** បើបែបនេះ នរណាក៏មានទឹកចិត្តដែរ! សម្រាប់កម្ពុជាវិញ មិនមានយុទ្ធសាស្ត្របែបនេះទេ ហើយប្រាក់ឧបត្ថម្ភនៅពេលមានអតីតភាព

ការងារច្រើនឆ្នាំ និងចូលនិវត្តន៍នៅមានចំនួនតិចតួចនៅឡើយ បើប្រៀបធៀបនឹងប្រទេសជប៉ុននេះ។

❖ **ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេស**

**ជប៉ុន** មិនត្រឹមតែបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេសនៅតាមសាលារៀនប៉ុណ្ណោះទេ នៅតាមរោងចក្រ សហគ្រាស ក្រុមហ៊ុន...នយោជកតែងតែយកចិត្តទុកដាក់ក្នុងផ្តល់បណ្តុះបណ្តាលកសាងសមត្ថភាព(On the job training) និងវគ្គបំប៉ននយោជិកខ្លួនទៅលើជំនាញការងារជាក់លាក់នៅក្នុងស្ថាប័នរបស់ខ្លួន ព្រមទាំងអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេសតាមរយៈការអនុវត្តផ្ទាល់ (Learning by doing)។ ភាគច្រើន មានផ្លាស់ប្តូរតួនាទីនយោជិកញឹកញាប់ដើម្បីស្វែងយល់ច្បាស់លាស់ពីការងារ និងតួនាទីភារកិច្ច ការទទួលខុសត្រូវពីមួយកន្លែងទៅមួយកន្លែង ទៅតាមសង្វាក់ផលិតកម្ម ឬដំណើរការស្ថាប័នទាំងមូល។ ចំណុចពិសេសនេះហើយ ដែលធ្វើឱ្យសេដ្ឋកិច្ចជប៉ុនមានភាពរឹងមាំខ្លាំងព្រោះផ្តោតលើគុណភាពធនធានមនុស្ស ដែលគេមិនអាចលួចចម្លង និងប្រកួតប្រជែងបានដោយងាយស្រួលឡើយ ហើយក៏ជាមូលហេតុដែលជយោជិកជប៉ុនភាគច្រើន មិនងាយនឹងធ្វើការផ្លាស់ប្តូរកន្លែងធ្វើការពីមួយទៅមួយដូចប្រទេសផ្សេងៗទៀតឡើយ។

## 2.11) ច្បាប់ទាក់ទងនឹងការបណ្តុះបណ្តាលគ្រូបង្រៀន

ដូចបណ្តាប្រទេសដទៃទៀតដែរ ប្រទេសជប៉ុនបានកែប្រែច្បាប់អប់រំរបស់ពួកគេទាក់ទងនឹងប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាលគ្រូបង្រៀន។ កំណែទម្រង់ចុងក្រោយបំផុតទាំងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធរបស់ពួកគេដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សង្គមសកលភាវូបនីយកម្ម បរិបទសង្គម និងសង្គមដែលពោរពេញទៅដោយភាពចម្រុះ។ យើងនឹងរៀបរាប់ពីកំណែទម្រង់គោលនយោបាយថ្មីបំផុតទាក់ទងនឹងការបណ្តុះបណ្តាលគ្រូបង្រៀននៅប្រទេសជប៉ុន។ គោលការណ៍ស្តីពីអាជ្ញាប័ណ្ណរបស់ប្រទេសជប៉ុនសម្រាប់អាជ្ញាប័ណ្ណគ្រូបង្រៀនបានគូសបញ្ជាក់ថា "គ្រូបង្រៀនត្រូវតែជាបុគ្គលដែលមានអាជ្ញាប័ណ្ណសមស្រប ត្រូវបានផ្តល់ឱ្យដោយ "ច្បាប់អាជ្ញាប័ណ្ណគ្រូបង្រៀន" និងនីតិវិធីទូទៅ

នៃប្រព័ន្ធបើកចំហសម្រាប់អាជាប័ណ្ណគ្រូបង្រៀនបានបញ្ជាក់ថា" ការបណ្តុះបណ្តាលគ្រូបង្រៀននៅប្រទេសរបស់យើងត្រូវបានធ្វើឡើងដោយសកលវិទ្យាល័យទូទៅ និងសាកលវិទ្យាល័យបណ្តុះបណ្តាលគ្រូបង្រៀនដោយអនុវត្តតាមលក្ខណៈរៀងៗខ្លួនរបស់ពួកគេ"។ នៅខែធ្នូឆ្នាំ២០០៦ ច្បាប់មូលដ្ឋានរបស់ជប៉ុនស្តីពីការអប់រំត្រូវបានធ្វើកំណែទម្រង់ជាលើកដំបូងក្នុងរយៈពេល៦០ឆ្នាំកន្លងមកនេះ។ កំណែទម្រង់នេះរួមបញ្ចូលទាំងការផ្លាស់ប្តូរលើច្បាប់អប់រំសាលារៀន ច្បាប់រដ្ឋបាលអប់រំ ច្បាប់ស្តីពីអាជ្ញាប័ណ្ណគ្រូបង្រៀន និងច្បាប់ពិសេសសម្រាប់មន្ត្រីសាធារណៈអប់រំ។ មួយឆ្នាំក្រោយមកនៅខែមីនាឆ្នាំ២០០៧ ផ្នែកមួយចំនួននៃបទបញ្ញត្តិនៃក្រសួងអវបកវ (MEXT)ត្រូវបានកែសម្រួល។ ការកែប្រែនេះបានបង្កើតឡើងមានគោលបំណងចំនួន៣គឺ៖ ការអប់រំគ្រូបង្រៀននូវជំនាញបង្រៀនជាក់ស្តែង អប់រំអ្នកដឹកនាំសាលាដោយកំណត់គោលដៅលើគ្រូបង្រៀនដែលកំពុងបំពេញការងារ និងសម្រួលដល់ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមហាវិទ្យាល័យ និងសាកលវិទ្យាល័យតាមរយៈបង្ហាញពីគំរូប្រព័ន្ធអប់រំសម្រាប់គ្រូបង្រៀនប្រកបជំនាញជាក់លាក់(95) ។

*គំនិតនៃប្រព័ន្ធបណ្តុះបណ្តាលគ្រូថ្មីនៅសាលាវិជ្ជាជីវៈឯកទេស សម្រាប់ការអប់រំគ្រូបង្រៀនផ្អែកលើបទបញ្ញត្តិនេះ ហើយខ្លឹមសារសំខាន់ៗរបស់វាគឺ៖*

- **ការកែប្រែស្តង់ដារសម្រាប់ការបង្កើតសាលាជំនាញវិជ្ជាជីវៈ** ដាក់ឈ្មោះវិទ្យាស្ថានទាំងនេះថាជាសាលាជំនាញវិជ្ជាជីវៈឯកទេសសម្រាប់ការអប់រំគ្រូបង្រៀន បង្កើតរយៈពេលសិក្សាចាប់ពីមួយឆ្នាំទៅពីរឆ្នាំ ឬយូរជាងនេះ តម្រូវឱ្យបញ្ចប់ការសិក្សារយៈពេលពីរឆ្នាំ ឬយូរជាងនេះ ដោយបញ្ចប់ការសិក្សា៤៥ក្រេឌីត ឬច្រើនជាងនេះ(97)។
- **ការកែសម្រួលការណែនាំពីសញ្ញាប័ត្រ:** ការបង្កើតអនុបណ្ឌិតគរុកោ-សល្យជាវិជ្ជាជីវៈឯកទេស
- **បង្កើតគោលនយោបាយថ្មីមួយចំនួន:** ភាគរយនៃគ្រូបង្រៀនដែលមានសញ្ញាប័ត្របរិញ្ញាបត្រនៅតាមសាលារៀនគួរតែមាន៤០% ឬលើសពីនេះ ហើយវគ្គសិក្សាត្រូវមានមុខវិជ្ជា៥មុខសម្រាប់ការរៀបចំវគ្គសិក្សាជាលក្ខ-ណៈប្រព័ន្ធ(97)។

សាលារៀនជំនាញវិជ្ជាជីវៈសម្រាប់ការអប់រំគ្រូបង្រៀនទាំងនេះបានចាប់ផ្តើមជាមួយសាកលវិទ្យាល័យចំនួន១៩ក្នុងឆ្នាំ២០០៨។ នៅខែមេសាឆ្នាំ២០១៤ ចំនួនសាលាបានកើនដល់២៥នៅទូទាំងប្រទេសជប៉ុន។ លក្ខណៈពិសេសមួយរបស់ប្រទេសជប៉ុនគឺជាប្រភេទនៃអាជ្ញាប័ណ្ណខុសៗគ្នាដែលគ្រូបង្រៀនអាចកាន់យកទៅប្រើប្រាស់ដែលយើងនឹងលម្អិតនៅពេលក្រោយ។ ប្រព័ន្ធផ្តល់សុពលភាពថ្មីដល់អាជ្ញាប័ណ្ណគ្រូបង្រៀនត្រូវបានអនុវត្តនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ បន្ទាប់ពីការធ្វើកំណែទម្រង់ច្បាប់ស្តីពីអាជ្ញាប័ណ្ណគ្រូបង្រៀនកាលពីឆ្នាំ២០០៧។ គោលបំណងចម្បងរបស់វាគឺដើម្បីជួយដល់គ្រូបង្រៀនក្នុងការរក្សាសមត្ថភាពបង្រៀនរបស់ពួកគេ តាមរយៈការធ្វើបច្ចុប្បន្នភាពជាមួយនឹងចំណេះដឹង និងជំនាញថ្មីៗ ដើម្បីរក្សាឱ្យពួកគេធ្វើការនៅក្នុងថ្នាក់រៀនប្រកបដោយភាពទុកចិត្ត មោទនភាព និងដើម្បីទទួលបាននូវការគោរពឱ្យតម្លៃ និងជំនឿទុកចិត្តពីសង្គម(98)។ ការផ្លាស់ប្តូរដ៏សំខាន់ដែលត្រូវបានណែនាំថ្មីនោះគឺរយៈពេលសុពលភាពដប់ឆ្នាំសម្រាប់អាជ្ញាប័ណ្ណសាមញ្ញ និងអាជ្ញាប័ណ្ណពិសេស។ អាជ្ញាប័ណ្ណទាំងនោះអាចត្រូវបន្តជាថ្មីនៅពេលដែលគ្រូបង្រៀនបានបញ្ចប់វគ្គសិក្សាផ្តល់សុពលភាពថ្មី ដែលមានច្រើនជាង៣០ម៉ោង បង្រៀនដោយសាស្ត្រាចារ្យសាកលវិទ្យាល័យ ឬអាចបន្តអាជ្ញាប័ណ្ណប្រសិនបើក្រុមប្រឹក្សាភិបាលខេត្ត (PBE) ទទួលយកចំណេះដឹង និងជំនាញរបស់អ្នក (សម្រាប់គ្រូបង្រៀនដែលធ្វើការស្រាវជ្រាវ ព្រមទាំងបានបោះពុម្ព Journal ឬ Research paper និងអាទិភាពផ្សេងទៀតទៅតាមលក្ខខណ្ឌរបស់PBE)។ អ្នកកាន់អាជ្ញាប័ណ្ណគឺជាអ្នកមានអាជីពជាគ្រូបង្រៀន និងមានតែអ្នកដែលទទួលបន្ទុកការងារបង្រៀនទេដែលត្រូវបន្តវគ្គសិក្សាថ្មី។ វាមិនត្រូវបានគ្រោងសម្រាប់អ្នកដែលត្រូវបានគេហៅថា " គ្រូបង្រៀនដែលមានតែនៅលើក្រដាស (Paper Teachers) " ពោលគឺអ្នកដែលមានអាជ្ញាប័ណ្ណគ្រូបង្រៀន ប៉ុន្តែមិនដែលធ្លាប់ធ្វើការជាគ្រូបង្រៀននៅសាលារៀន និងអ្នកដែលត្រូវរៀនវគ្គបណ្តុះបណ្តាលកែលម្អការបង្រៀនរបស់ខ្លួន (សមត្ថភាពនៅមានកម្រិត)។ ការបណ្តុះបណ្តាលអំពីការកែលម្អការបង្រៀនត្រូវបានអនុវត្តទៅលើគ្រូដែលមានការអនុវត្តការបង្រៀនដែលមិនគ្រប់គ្រាន់(សមត្ថភាពនៅមានកម្រិត)ដែលត្រូវបានវិនិច្ឆ័យដោយនាយកក្រុមប្រឹក្សាអប់រំខេត្ត(PBE)។ ការវិភាគចុងក្រោយដែលទាក់ទងនឹងការបណ្តុះបណ្តាលគ្រូត្រូវ

បានធ្វើឡើងនៅក្នុងខែតុលា ឆ្នាំ២០១៣។ ក្រសួងអវបកវ (MEXT) បានបោះពុម្ពរបាយការណ៍អំពីកិច្ចប្រជុំរបស់សហប្រតិបត្តិការឆ្ពោះទៅការអនុវត្តគោលនយោបាយកែលម្អទាក់ទងនឹងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។ ស្ថានភាពសាលារៀន និងបញ្ហាការអប់រំគ្រូបង្រៀនត្រូវបានគូសបញ្ជាក់ដូចតទៅៈ

- វាចាំបាច់ក្នុងការទទួលយកនូវការរៀនសូត្រប្រភេទថ្មី ដោះស្រាយបញ្ហាដែលកើតឡើងនៅសាលារៀននាពេលបច្ចុប្បន្ន ដោះស្រាយជាមួយគ្រូបង្រៀនចូលនិវត្តន៍ និងគ្រូចូលថ្មីដ៏ច្រើន ព្រមទាំងអប់រំអ្នកដឹកនាំសាលា ដើម្បីដោះស្រាយបញ្ហាបរិស្ថានសង្គម។
- ការអប់រំគ្រូបង្រៀនបច្ចុប្បន្នពឹងផ្អែកលើសាកលវិទ្យាល័យនីមួយៗ ដូច្នេះវាមានសារៈសំខាន់ក្នុងការចេញវិញ្ញាបនប័ត្របញ្ជាក់គុណភាពរបស់វា។
- ការអប់រំគ្រូបង្រៀននៅកម្រិតឧត្តមសិក្សាមិនមានប្រសិទ្ធភាពខ្ពស់ក្នុងការលើកកម្ពស់គ្រូបង្រៀនដែលកំពុងបំពេញការងារ និងកង្វះខាតការផ្តល់កម្មវិធីជាប្រព័ន្ធ។

ចាប់តាំងពីរបាយការណ៍បានចង្អុលបង្ហាញពីភាពចាំបាច់ និងបញ្ហាប្រឈមទាំងនេះអាចត្រូវបានដោះស្រាយតាមរយៈការជំរុញសកម្មភាពអប់រំ ជារបៀបធ្វើកំណែទម្រង់និងលើកកម្ពស់កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់និស្សិតបញ្ចប់ឧត្តមសិក្សា រាជរដ្ឋាភិបាលជប៉ុននឹងរៀបចំគោលនយោបាយថ្មីដែលទាក់ទងនឹងការបណ្តុះបណ្តាលគ្រូកំពុងបំពេញការងារ និងគរុនិស្សិត ទាក់ទងនឹងការបោះពុម្ពព័ត៌មានអំពីការអប់រំគ្រូបង្រៀន និងការសម្របខ្លួនទៅសកលភាវូបនីយកម្ម(99)។ ការផ្លាស់ប្តូរមួយទៀតដែលត្រូវបានលើកឡើងក្នុងការបណ្តុះបណ្តាលហ្វឹកហាត់គរុកោសល្យគឺការអនុវត្តវគ្គបណ្តុះបណ្តាលគ្រូចំនួន៤ឆ្នាំក្នុងគោលបំណង "**ធានាគុណភាពគ្រូ**" នៅឆ្នាំ២០១៣(100)។

## 2.12) ដំណើរការជ្រើសរើសគ្រូបង្រៀន

អ្នកស្រាវជ្រាវជាច្រើនបានអះអាងថា ត្រូវតែជ្រើសរើសសិស្សពូកែៗដើម្បីធ្វើជាគ្រូបង្រៀនទើប មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀនសិស្សបានល្អ។ នៅប្រទេសជប៉ុនបេក្ខជនត្រូវបានជ្រើសរើសដោយមហាវិទ្យាល័យ ឬសាកលវិទ្យាល័យនីមួយៗតាមរយៈការប្រឡងចូល ហើយអាជ្ញាប័ណ្ណគ្រូត្រូវបានផ្តល់ដោយ PBE

នីមួយៗនៅពេលវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់។ ការប្រឡងចូលសកលវិទ្យាល័យសាធារណៈត្រូវបានបែងចែកជាពីរជំហាន។ ដំណាក់កាលទី១ គឺជាការធ្វើតេស្តស្តង់ដារ។ នៅគ្រប់មហាវិទ្យាល័យ និងសាកលវិទ្យាល័យនៅទូទាំងប្រទេសជប៉ុនអនុវត្តការប្រឡងមានស្តង់ដារដូចៗគ្នា។ ការប្រឡងស្តង់ដារនេះត្រូវបានគេហៅថា ប្រឡងតេស្តថ្នាក់ជាតិ (NCT) ហើយយោងតាម ក្រសួង MEXT វាត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលជាតិសម្រាប់ការប្រឡងចូលសាកលវិទ្យាល័យ (NCUEE) ។ បទបញ្ញត្តិនៃMEXT ទាក់ទងនឹងNCUEE បានចូលជាធរមាននៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០១។ ដំណាក់ទី២គឺ អាស្រ័យលើលក្ខខណ្ឌមហាវិទ្យាល័យ ឬសាកលវិទ្យាល័យនីមួយៗដែលកំណត់រៀងៗខ្លួន។ ការលំបាក និងភាពងាយស្រួលសម្រាប់ការចុះឈ្មោះចូលរៀនក្នុងផ្នែកនីមួយៗមានភាពខុសគ្នារៀងរាល់ឆ្នាំ។ ផ្ទុយទៅវិញសាកលវិទ្យាល័យ និងមហាវិទ្យាល័យឯកជនមួយចំនួនបានផ្តល់ឱ្យបេក្ខជនរបស់ពួកគេ នូវជម្រើសបន្ថែមទៀតលើនីតិវិធីជ្រើសរើសនិស្សិតចូលរៀន។ ក្រៅពីពិន្ទុប្រឡងថ្នាក់ជាតិពេលបញ្ចប់មធ្យមសិក្សាទុតិយភូមិ ការធ្វើតេស្តផ្សេងទៀតត្រូវបានអនុវត្តនៅតាមគ្រឹះស្ថាននីមួយៗដែលនិស្សិតគួរសិក្សាមុខវិជ្ជាដែលត្រូវគ្នា។ ប្រព័ន្ធផ្សេងទៀតត្រូវបានអនុវត្តផងដែរគឺ ការសម្ភាស ការសរសេរតែងសេចក្តី និងការប្រឡងផ្ទាល់ដែលគ្រប់គ្រងដោយស្ថាប័ននីមួយៗ។ និស្សិតអាចចូលរៀននៅសាកលវិទ្យាល័យ ឬ មហាវិទ្យាល័យលើមុខវិជ្ជាឯកទេសសម្រាប់បម្រើការជាគ្រូបង្រៀនពេលអនាគតបាន ត្រូវមានពិន្ទុសមស្របតាមលក្ខខណ្ឌកំណត់ដើម្បីចូលរៀនមុខវិជ្ជាឯកទេស និងមុខវិជ្ជាសិក្សាអប់រំនៅឆ្នាំទី៣។ បន្ទាប់ពីបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រ និស្សិតត្រូវធ្វើការប្រឡងប្រជែងដើម្បីទទួលបានអាជ្ញាប័ណ្ណគ្រូបង្រៀនទៅតាមនីតិវិធីស្ថាប័នរៀងៗខ្លួន។ នៅប្រទេសជប៉ុន សាលារៀនរដ្ឋ និងឯកជនមានភាពខុសគ្នាក្នុងការជ្រើសរើសបុគ្គលិក។ សាលារៀនឯកជនមានសិទ្ធិស្វ័យភាពស្តីពីរបៀបដែលពួកគេជួលកម្មករផ្ទាល់ខ្លួនរបស់ពួកគេ ហើយ PBE នីមួយៗមានសិទ្ធិជ្រើសរើសគ្រូបង្រៀនរបស់ពួកគេសម្រាប់សាលារៀនសាធារណៈនៅក្នុងស្រុករបស់ខ្លួនដោយការធ្វើតេស្តជ្រើសរើសម្តង ឬពីរដងក្នុងមួយឆ្នាំ។ តេស្តប្រឡងជ្រើសរើសជាទូទៅមានតេស្តសរសេរ និងសម្ភាសរួមទាំងការបង្រៀនសាកល្បងបង្ហាញ។ ជាការលើកលែងសម្រាប់គ្រូកិច្ចសន្យាប្រចាំឆ្នាំ

និងគ្រូក្រៅម៉ោង ត្រូវបានជ្រើសរើសចេញពីបញ្ជីគ្រូរបស់ PBD។ វាអាស្រ័យលើស្រុកថាតើការជម្រើសត្រូវបានធ្វើឡើងតាមរយៈការធ្វើតេស្តសរសេរ ការសម្ភាស និង / ឬការបង្រៀនសាកល្បងបង្ហាញ ឬមិនអនុវត្តវិធីសាស្ត្រទាំងនេះ។ មានតែគ្រូបង្រៀនដែលមានអាជ្ញាប័ណ្ណ ឬនិស្សិតដែលនឹងបញ្ចប់ការសិក្សាដោយមានអាជ្ញាប័ណ្ណគ្រូបង្រៀនប៉ុណ្ណោះអាចដាក់ពាក្យសុំបង្រៀននៅសាលារៀនមិនថាវាជាសាធារណៈ (រដ្ឋ) ឬឯកជន។ *សម្រាប់ប្រទេសកម្ពុជា* សាលាឯកជនមួយចំនួន បានជួលបុគ្គលិកមកបង្រៀន ដែលមួយចំនួនធំមិនមានសញ្ញាប័ត្រជំនាញឯកទេសគរុកោសល្យច្បាស់លាស់នៅឡើយ ទោះបីពួកគេមួយចំនួនបានចូលរួមវគ្គបណ្តុះបណ្តាលបង់ថ្លៃពីវិធីសាស្ត្របង្រៀន និងគរុកោសល្យពីគ្រឹះស្ថានសិក្សានានាក៏ដោយ។ ***ករណីនេះ ហាក់នៅមិនទាន់កំណត់ស្តង់ដារមួយជាក់លាក់ ក្របខណ្ឌច្បាប់ និងការទទួលស្គាល់កម្រិតសញ្ញាប័ត្របែបនេះជាផ្លូវការច្បាស់លាស់នៅឡើយទេ។***

## 2.13) គំរូអប់រំគ្រូបង្រៀនចេញថ្មី

កម្មវិធីបណ្តុះបណ្តាលរបស់ជប៉ុនត្រូវបានរៀបចំឡើងសម្រាប់គ្រប់កម្រិតទាំងអស់ក្នុងទម្រង់ស្របគ្នា។ យ៉ាងណាក៏ដោយ មានករណីលើកលែង ដោយសារតែកង្វះគ្រូដែលបានទទួលសញ្ញាប័ត្រនៅក្នុងតំបន់មួយចំនួន។ គ្រូបង្រៀននាពេលអនាគតក៏អាចមានសមត្ថភាពគ្រប់គ្រាន់ដែរតាមរយៈការធ្វើតេស្ត។ វាត្រូវបានគេហៅថាតេស្តការទទួលស្គាល់សម្រាប់គុណភាពបង្រៀន។ មិនមានសញ្ញាបត្រផ្នែកអប់រំចាំបាច់សម្រាប់ធ្វើតេស្តនោះទេ ប៉ុន្តែអ្នកដាក់ពាក្យសុំត្រូវបំពេញតម្រូវការមួយចំនួន។ មានលក្ខខណ្ឌចំនួនពីរដែលអនុញ្ញាតឱ្យចូលដំណើរការការធ្វើតេស្តនេះ។ ទីមួយៈ គឺត្រូវបានសិក្សានៅសាកលវិទ្យាល័យ ឬមហាវិទ្យាល័យយ៉ាងហោចណាស់ពីរឆ្នាំ ហើយសិក្សា៦២ក្រេឌីត ឬច្រើនជាងនេះមុននឹងដាក់ពាក្យសុំធ្វើតេស្ត។ វិធីទីពីរៈ គឺត្រូវមានអាយុចាប់ពី២០ឆ្នាំឡើងទៅនឹងត្រូវបានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ ឬដើម្បីមានសមត្ថភាពទទួលបានការអប់រំខ្ពស់មុនថ្ងៃទី១ ខែមេសាដែលគាត់នឹងត្រូវធ្វើតេស្ត។ ប្រសិនបើបុគ្គលណាម្នាក់ប្រឡងជាប់ គាត់អាចទទួលបានតែអាជ្ញាប័ណ្ណបណ្តោះអាសន្ននៃអាជ្ញាប័ណ្ណធម្មតាដែលត្រូវបានបង្ហាញលម្អិតនៅក្នុងផ្នែកអំពីប្រភេទអាជ្ញាប័ណ្ណគ្រូបង្រៀន។

## 2.14) ការរៀបចំអប់រំគ្រូបង្រៀន

**(ជប៉ុនៈ អាជ្ញាប័ណ្ណ និងគន្លងខុសៗគ្នា)** អាជ្ញាប័ណ្ណមាន០៣ប្រភេទគឺអាជ្ញាប័ណ្ណធម្មតា អាជ្ញាប័ណ្ណពិសេស និងអាជ្ញាប័ណ្ណបណ្ដោះអាសន្ន។ **អាជ្ញាប័ណ្ណធម្មតា**ត្រូវបានផ្តល់ជូនដល់អ្នកដែលបានបំពេញតាមល័ក្ខខ័ណ្ឌកម្រិតមូលដ្ឋាន ហើយបានបញ្ចប់វគ្គបណ្តុះបណ្តាលគ្រូនៅសកលវិទ្យាល័យ។ វាមានសុពលភាពរយៈពេល១០ឆ្នាំនៅក្នុងគ្រប់អាណាខេត្តទាំងអស់នៅទូទាំងប្រទេសជប៉ុន។ អាជ្ញាបណ្ណធម្មតាត្រូវបានបែងចែកជា ៣កម្រិតផ្សេងគ្នា អាស្រ័យលើតម្រូវការសញ្ញាប័ត្រមូលដ្ឋាន និងវគ្គបណ្តុះបណ្តាលៈ វិញ្ញាបនបត្រជំនាញឯកទេស ពិសេស អាជ្ញាប័ណ្ណបឋមសិក្សា និងអាជ្ញាប័ណ្ណមធ្យមសិក្សា។ លក្ខណៈជាក់លាក់សម្រាប់ពួកគេ ត្រូវបានបង្ហាញនៅលើតារាងទី១ កម្មវិធីត្រូវបានពិពណ៌នាជាមួយពិន្ទុក្រេឌីត។ ពិន្ទុក្រេឌីតគឺជាឯកតាវគ្គសិក្សានៃសាកលវិទ្យាល័យ និងមហាវិទ្យាល័យមួយ ដែលបានកំណត់ដោយបទដ្ឋានសម្រាប់ការបង្កើតមហាវិទ្យាល័យ និងមហាវិទ្យាល័យនៅក្នុងច្បាប់អប់រំសាលារៀន។ មានមធ្យោបាយ និងរយៈពេលខុសៗគ្នាដើម្បីក្លាយទៅជាគ្រូបង្រៀនៈ ការសិក្សានៅមហាវិទ្យាល័យរយៈពេល២ឆ្នាំ (បរិញ្ញាបត្ររង) វគ្គសិក្សាថ្នាក់បរិញ្ញាបត្ររយៈពេល៤ឆ្នាំ និងថ្នាក់អនុបណ្ឌិតរយៈពេល៦ឆ្នាំ (បរិញ្ញា៤ឆ្នាំ+២ឆ្នាំ) គឺចាំបាច់សម្រាប់អាជ្ញាប័ណ្ណមធ្យមសិក្សា អាជ្ញាប័ណ្ណបឋមសិក្សា និងវិញ្ញាបនប័ត្រឯកទេសរៀងៗខ្លួន។ កម្មវិធីសិក្សានៃវគ្គបណ្តុះបណ្តាលគ្រូទាំងនោះត្រូវបានកំណត់នៅក្នុងច្បាប់អាជ្ញាប័ណ្ណគ្រូបង្រៀន។ អាជ្ញាប័ណ្ណទាំងនេះមានភាពខុសប្លែកគ្នាតែឈ្មោះ និងលក្ខខណ្ឌប៉ុណ្ណោះ ប៉ុន្តែមិនមានភាពខុសគ្នាផ្នែកភារកិច្ចវិជ្ជាជីវៈក្នុងចំណោមគ្រូបង្រៀនដែលមានលក្ខ-ណៈសម្បត្តិទាំងនេះ។ **អាជ្ញាប័ណ្ណពិសេស** ត្រូវបានផ្តល់ទៅឱ្យសមាជិកសង្គមទាំងនោះដែលជាប់ការប្រឡងបុគ្គលិកអប់រំ ដែលគ្រប់គ្រងដោយ PBE របស់ពួកគេ។ ប្រព័ន្ធនេះមានគោលបំណងស្វាគមន៍បុគ្គលដែលមានចំណេះដឹង និងបទពិសោធដ៏ល្អបំផុត ប៉ុន្តែមិនមានអាជ្ញាប័ណ្ណគ្រូធម្មតាទេ។ វាក៏មានសុពលភាពផងដែរសម្រាប់រយៈពេល១០ឆ្នាំ។ **អាជ្ញាប័ណ្ណបណ្តោះអាសន្ន**ត្រូវបានផ្តល់ដោយ PBEs ជាការលើកលែងចំពោះ "គ្រូជំនួយ" នៅពេលដែលគ្រូដែលមានអាជ្ញាប័ណ្ណធម្មតាមិនអាចជួលទេ។ វាមានសុពលភាពរយៈពេល៣ឆ្នាំ។ ជារួម អាជ្ញាប័ណ្ណនេះត្រូវប្រើជាពិសេសក្នុង

ករណីដែលគ្រូធម្មតាមិនអាចជួល និងមិនមានគ្រូបង្រៀនគ្រប់គ្រាន់សម្រាប់ជួល។ ទាំងអាជ្ញាប័ណ្ណពិសេស និងអាជ្ញាប័ណ្ណបណ្ដោះអាសន្នមានសុពលភាពត្រឹមតែនៅក្នុងខេត្តដែលអាជ្ញាប័ណ្ណនោះផ្ដល់ឱ្យប៉ុណ្ណោះ។ យោងតាមការស្រាវជ្រាវរបស់ MEXT ក្នុងឆ្នាំ២០១៣ មានសាកលវិទ្យាល័យ និងមហាវិទ្យាល័យសាធារណៈ និងឯកជនចំនួន៧៧០ នៅប្រទេសជប៉ុន ហើយភាគច្រើននៃគ្រឹះស្ថានសិក្សាទាំងអស់នេះមានវគ្គបណ្ដុះបណ្ដាលគ្រូ(101)។ អាជ្ញាប័ណ្ណគ្រូបង្រៀនសម្រាប់សាលាបឋមសិក្សាត្រូវបានរៀបចំឡើងដោយអ្នកដែលបានបញ្ចប់ការសិក្សាជាមួយអ្នកជំនាញផ្នែកអប់រំតែប៉ុណ្ណោះ ហើយប្រឡងជាប់តេស្តទទួលស្គាល់សមត្ថភាពបង្រៀន។ ទោះបីជាយ៉ាងណាក៏ដោយ និស្សិតដែលមានមុខជំនាញផ្សេងទៀតក៏អាចទទួលយកវគ្គបណ្ដុះបណ្ដាលគ្រូបង្រៀន ប្រសិនបើសាកលវិទ្យាល័យ ឬមហាវិទ្យាល័យរបស់ពួកគេត្រូវបានប្រគល់តួនាទី និងភារកិច្ចជាស្ថាប័នបណ្ដុះបណ្ដាលគ្រូតាមរយៈMEXT។ **ដូច្នេះចំនួនអ្នកកាន់អាជ្ញាប័ណ្ណមានចំនួនច្រើនជាងចំនួនគ្រូបង្រៀនពិតប្រាកដ។** *សម្រាប់ប្រទេសកម្ពុជា* បើមានអ្នកកាន់អាជ្ញាប័ណ្ណគ្រូបង្រៀនច្រើន ជាងគ្រូបង្រៀនពិតប្រាកដនៅសាលារដ្ឋបែបនេះ ប្រហែលមានប្រយោជន៍ច្រើនដល់ការបំពេញចំណុចខ្វះខាត និងសេចក្ដីត្រូវការរបស់សាលាឯកជនបាន។ បើទុកឱ្យគ្រូបង្រៀនដែលមានអាជ្ញាប័ណ្ណ (សញ្ញាប័ត្រចេញពីសាលាបណ្ដុះបណ្ដាលគ្រូបង្រៀន) ធ្វើការនៅសាលារៀនរដ្ឋផង និងនៅសាលាឯកជនផង អាចនាំឱ្យប៉ះពាល់ដល់គុណភាព និងប្រសិទ្ធភាពនៃការបំពេញការងារ។

## 2.15) ការអភិវឌ្ឍបំណិនវិជ្ជាជីវៈ និងគុណវុឌ្ឍិគ្រូបង្រៀន

ដោយសារស្វ័យភាពរបស់សាលារៀន និងការទាមទារការទទួលខុសត្រូវកាន់តែខ្ពស់ តួនាទីថ្នាក់ដឹកនាំសាលាបានផ្លាស់ប្ដូរមួយទសវត្សរ៍ចុងក្រោយ។ PISA ២០១២បានបង្ហាញថា សាលារៀនជប៉ុនមានសិទ្ធិស្វ័យសម្រេចក្នុងការបែងចែកធនធានតិចជាងប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀត តែមានកម្រិតខ្ពស់បំផុតនៃស្វ័យសម្រេចលើកម្មវិធីសិក្សា និងការវាយតម្លៃ។ **នេះមានន័យថា ជប៉ុនគ្រប់គ្រងវិស័យអប់រំបែបមជ្ឈការ។** ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការសិក្សាទៅលើប្រវត្តិ

ដំណើរការកំណែទម្រង់ប្រព័ន្ធអប់រំជប៉ុនបានបង្ហាញថា ជប៉ុនក៏ធ្លាប់ធ្វើកំណែទម្រង់បែបវិមជ្ឈការទៅថ្នាក់ក្រោមជាតិដឹកនាំច្រើនលើកច្រើនសារដែរ ដោយពេលខ្លះប្រគល់សិទ្ធិអំណាច ហើយពេលខ្លះដកយកមកវិញ ដើម្បីស្វែងរកគន្លឹះក្នុងការអភិវឌ្ឍវិស័យអប់រំប្រកបដោយប្រសិទ្ធភាពមួយ។ ជាមួយគ្នានេះ នៅប្រទេសជប៉ុនគ្រូបង្រៀនត្រូវប្រឡងដើម្បី ធ្វើជានាយកសាលារដ្ឋនានា។ ដំណើរការជ្រើសរើសនេះ ត្រូវបានរៀបចំដោយក្រុមប្រឹក្សាអប់រំរាជធានី/ខេត្ត។ យោងតាមការអង្កេតអន្តរជាតិពីការបង្រៀន និងរៀន(TALIS)២០១៣ ថ្នាក់ដឹកនាំសាលាជប៉ុនបានចំណាយ២៥%នៃពេលវេលាធ្វើការរបស់ពួកគេលើការកម្មវិធីសិក្សា និងកិច្ចការដែលទាក់ទងនឹងការបង្រៀន ព្រមទាំងការប្រជុំ[86]។

គ្រូបង្រៀននៅប្រទេសជប៉ុនត្រូវតែអនុវត្តសកម្មភាពមួយចំនួនមុនពេលចាប់ផ្តើមបង្រៀន។ គ្រូបង្រៀនធ្វើការច្រើនម៉ោងជាងប្រទេសផ្សេងៗ ប៉ុន្តែមានការរៀបចំតិចជាង ក្នុងបំពេញការងារបង្រៀន។គ្រូបង្រៀនដែលមានសក្តានុពលត្រូវបញ្ចប់ការអប់រំគ្រូដំបូងដែលមានលក្ខណៈប្រហាក់ប្រហែលប្រទេសផ្សេងៗដែរទាក់ទងនឹងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស រយៈពេលសិក្សា និងខ្លឹមសារបំប៉នសមត្ថភាព។ ការបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់គ្រប់កម្រិតទាំងអស់នៃការអប់រំ មានរយៈពេល៤ឆ្នាំ ព្រមទាំងកាតព្វកិច្ចចុះកម្មសិក្សា។ លើសពីនេះ ដើម្បីបានក្លាយជាបេក្ខជនគ្រូបង្រៀនបានត្រូវឆ្លងកាត់ការប្រឡងប្រកួតប្រជែងជាប់ជាស្ថាពរ និងទទួលបានអាជ្ញាប័ណ្ណគ្រូបង្រៀនបន្ទាប់ពីបញ្ចប់ការអប់រំគ្រូ។ គ្រូបង្រៀនជប៉ុនត្រូវធ្វើការច្រើនម៉ោងរួមទាំងការបង្រៀន និងសកម្មភាពក្រៅម៉ោងសិក្សា៨ម៉ោងក្នុង១សប្តាហ៍ ពោលគឺធ្វើការនៅសាលាពេញម៉ោង ចំនួន១,៨៩៩ម៉ោងក្នុង១ឆ្នាំសិក្សា ដែលប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀតមានតែ១,៦០៣ម៉ោងប៉ុណ្ណោះ[86]។ ការធ្វើការពេញម៉ោងនេះរួមបញ្ចូលទាំងការបង្រៀនតាមកាលវិភាគប្រចាំ ការធ្វើការងារផ្សេងៗនៅការិយាល័យ និងការចូលរួមប្រជុំនានា។ ***នៅកម្ពុជា*** គ្រូបង្រៀនធ្វើការតិចម៉ោងឆ្ងាយណាស់បើប្រៀបធៀបនឹងជប៉ុន ហើយភាគច្រើនគ្រូបង្រៀនមកសាលារៀនតែម៉ោងដែលខ្លួនបង្រៀននៅតាមថ្នាក់រៀនប៉ុណ្ណោះ ដែលម៉ោងកំណត់យ៉ាងច្រើន១៦ម៉ោងក្នុង១សប្តាហ៍ (គ្រូបង្រៀនខ្លះមានម៉ោងលើស ហើយខ្លះបង្រៀនមិនគ្រប់ម៉ោង) ចំណែកឯម៉ោងដែល

នៅសល់ ពួកគាត់មិនបានចំណាយពេលនៅសាលារៀនដូចគ្រូជប៉ុនទេ។ បញ្ហានេះមកពីកត្តាផ្សេងៗជាច្រើនទៀត ដែលនឹងមានការបកស្រាយបន្ថែមទៀតនៅជំពូកបញ្ហាប្រឈមការអប់រំនៅកម្ពុជា។

ប្រព័ន្ធបណ្តុះបណ្តាលគ្រូជប៉ុនផ្តល់ជូននូវកម្មវិធីសិក្សាមហាវិទ្យាល័យរយៈពេល២ឆ្នាំ-៤ឆ្នាំ ឬ២ឆ្នាំបរិញ្ញាបត្រជាន់ខ្ពស់ សម្រាប់គ្រូបង្រៀនគ្រប់កម្រិតទាំងអស់ លើកលែងតែគ្រូវិទ្យាល័យដែលត្រូវសិក្សា៤ឆ្នាំនៅមហាវិទ្យាល័យកម្រិតបរិញ្ញាបត្រ ឬ២ឆ្នាំសម្រាប់បរិញ្ញាបត្រជាន់ខ្ពស់ប៉ុណ្ណោះ។ នៅជប៉ុនមួយឆ្នាំសិក្សាមាន៤១ក្រេឌីតសម្រាប់កម្រិតបរិញ្ញាប័ត្រជាន់ខ្ពស់ (ស្មើនឹង១,៨៥៤ម៉ោងក្នុងឆ្នាំ) និងពី១៣ទៅ១៥ក្រេឌីតក្នុង១ឆ្នាំសម្រាប់ការសិក្សានៅកម្រិតបរិញ្ញាបត្រ៤ឆ្នាំ (ស្មើនឹង៥៨៥-៦៧៥ម៉ោងក្នុងឆ្នាំ)។ កម្មវិធីសិក្សា២ឆ្នាំមានចំនួនក្រេឌីតចន្លោះពី៣១សម្រាប់គ្រូបង្រៀនកុមារតូចសិក្សា និង ៣៧ក្រេឌីតសម្រាប់គ្រូបឋមសិក្សា(ម៉ោងសរុបពី១,៣៩៥ម៉ោងដល់១,៦៦៥ម៉ោង) សម្រាប់កម្មវិធីសិក្សានៅមហាវិទ្យាល័យ៤ឆ្នាំមាន៥៩ក្រេឌីត (សរុប២,៦៥៥ម៉ោង) ប៉ុន្តែការបណ្តុះបណ្តាលគ្រូបង្រៀនកុមារតូចមាន៥១ក្រេឌីត (២,២៩៥ម៉ោង)ចំនួនក្រេឌីតច្រើនបំផុតគឺកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ដែលមានពី៧៥ក្រេឌីត (សរុប៣,៣៧៥ម៉ោង) សម្រាប់គ្រូអប់រំកុមារតូច ៨៣ក្រេឌីត (ស្មើនឹង៣,៧៣៥ម៉ោង)សម្រាប់គ្រូបង្រៀននៅអនុវិទ្យាល័យ និងវិទ្យាល័យ។ ការពិតមួយទៀតដែលត្រូវពិចារណាគឺការបែងចែកក្រេឌីតរវាងគរុកោសល្យ និងថ្នាក់ទូទៅ។ នៅប្រទេសជប៉ុនភាគច្រើនបំផុតនៃក្រេឌីតគឺផ្តោតលើការសិក្សាគរុកោសល្យទូទៅ និងមុខវិជ្ជាគរុកោសល្យជាក់លាក់។ វាមានភាពខុសគ្នាពីកម្មវិធីមត្តេយ្យ (៨៧% ទៅ៩២%) ដល់កម្មវិធីអនុវិទ្យាល័យ និងវិទ្យាល័យ (៦៦% ទៅ ៧៥%) ដោយផ្តល់នូវការផ្តោតជាសំខាន់ខ្លាំងដល់កម្មវិធីកម្រិតទាប។

☛ ***មានចំណុចពិសេសមួយទៀត*** របស់ជប៉ុនក្នុងការអភិវឌ្ឍបំណិនវិជ្ជាជីវៈ និងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនគឺ "*ការសិក្សាស្រាវជ្រាវមេរៀន*" (Lesson study) ដែលជាវិធីសាស្ត្រដ៏ល្អមួយ ដែលប្រើប្រាស់ធនធានខាងក្នុងដែលមានស្រាប់ ហើយវិធីសាស្ត្រនេះ ប្រទេសជាច្រើននៅលើពិភពលោកបានយកគំរូតាមរួមទាំងប្រទេសកម្ពុជាផងដែរ។ មេរៀនទាំងនេះ ផ្តោតលើការកសាងជំនាញ ការយល់ដឹង

ដែលគេស្គាល់ថាការស្រាវជ្រាវមេរៀន ដែលត្រូវបានរៀបចំក្រុមគ្រូបង្រៀនដែលធ្វើការរួមគ្នាដោយមានការរៀបចំផែនការច្បាស់លាស់។ សមាជិកម្នាក់នៃក្រុមសិក្សាស្រាវជ្រាវមេរៀន ត្រូវបានចាត់តាំងឱ្យរៀបចំកិច្ចតែងការបង្រៀនមេរៀនមួយ រួចដាក់ឱ្យសមាជិកក្រុមដទៃទៀតជួយកែលម្អ ការឡើងបង្រៀនថ្នាក់និទស្សន៍ឱ្យសមាជិកដទៃទៀតជួយផ្តល់ព័ត៌មានត្រឡប់ និងបង្រៀនសាកល្បងជាមួយថ្នាក់រៀនមួយជាក់លាក់ ហើយសមាជិកដទៃទៀតធ្វើជាអ្នកសង្កេតការណ៍ ចុងបញ្ចប់រៀបចំការប្រជុំពិភាក្សា និងផ្តល់ព័ត៌មានត្រឡប់។ ការប្រជុំពិភាក្សាគឺមានសារៈសំខាន់ណាស់សម្រាប់ក្រុមសិក្សាស្រាវជ្រាវព្រោះវាផ្តល់ឱកាសដល់គ្រូបង្រៀនទាំងអស់លើកឡើងពីចំណុចល្អ ចំណុចកែលម្អ អនុសាសន៍ពីវិធីសាស្រ្តបង្រៀនផ្សេងៗសំដៅធ្វើការបង្រៀន និងរៀនមានប្រសិទ្ធភាព និងគុណភាព។ ដំណើរការទាំងអស់នេះ ត្រូវអនុវត្តដោយស្មារតីជួយគ្នា និងឱ្យតម្លៃគ្នាទៅវិញទៅមកទៅតាមផែនការដែលបានរៀបចំ និងមានគ្រប់គ្រងឯកសារ របាយការណ៍ច្បាស់លាស់។ ដំណើរការនេះនៅបន្តជាប់រហូតក្នុងឆ្នាំសិក្សាមួយទៅ ឆ្នាំសិក្សាមួយទៀតដោយដូរសមាជិកធ្វើកិច្ចតែងការ និងឡើងបង្រៀនសាកល្បងម្តងម្នាក់ៗ។ វិធីសាស្រ្តនេះ ល្អ និងមានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសមត្ថភាពតាមរយៈ ការប្រើប្រាស់ធនធានខាងក្នុង (Internal resources) និងផ្តល់ឱកាសគ្រូបង្រៀនទាំងចាស់ទាំងថ្មីធ្វើការជាក្រុម ជួយគ្នាទៅវិញទៅមក តាមរយៈការចែករំលែកចំណេះដឹង និងបទពិសោធ ព្រមទាំងរៀនសូត្រពីគ្នាទៅវិញទៅមកយ៉ាងទូលំទូលាយ [102]។

**វដ្តនៃការស្រាវជ្រាវមេរៀនមាន៤ជំហានគឺ៖**

- រៀបចំគោលដៅ និងផែនការ រួមទាំងរៀបចំកិច្ចតែងការបង្រៀន
- ការបង្រៀនមេរៀនដែលបានស្រាវជ្រាវ និងការសង្កេតលើការបង្រៀនមេរៀន
- ការពិភាក្សាក្រោយបង្រៀនមេរៀនចប់
- ប្រមូលលទ្ធផលនៃការសិក្សារៀនសូត្រ[103]

**ការសិក្សាស្រាវជ្រាវមេរៀន** ក៏បានយកមកអនុវត្តនៅកម្ពុជាផងដែរតាមរយៈគម្រោង Stepsum ដឹកនាំដោយJICA តែនៅមិនមានដំណើរការល្អនៅឡើយទេនៅតាម

សាលារៀន (ការសង្កេតជាទូទៅ និងសាកសួរព័ត៌មានមិនផ្លូវការ)។ វិធីសាស្ត្រសិក្សាស្រាវជ្រាវមេរៀននេះ ជាយុទ្ធសាស្ត្រល្អបំផុត សម្រាប់ថ្នាក់ដឹកនាំនៅតាមគ្រឹះស្ថានសិក្សាក្នុងការជំរុញ លើកទឹកចិត្តឱ្យគ្រូ បង្រៀនចេះធ្វើការងារក្រុម និងលើកកម្ពស់ការអភិវឌ្ឍការបង្រៀន និងរៀន ។ វិធីសាស្ត្រនេះមានលក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈពិសេសច្រើនជាងបើប្រៀបធៀបនឹងការប្រជុំក្រុមបច្ចេកទេសដែលសាលារៀននីមួយៗធ្លាប់បានអនុវត្ត ហើយវាសមស្របនឹងស្ថានភាពគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជាដែលគ្រូបង្រៀនភាគច្រើនបានទទួលការបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពតិចតួចណាស់បន្ទាប់ពីការបញ្ចប់ការសិក្សានៅតាមសាលាគរុកោសល្យរយៈពេល ២ឆ្នាំ ឬ១ឆ្នាំមក។ គ្រូបង្រៀនមួយចំនួនមិនមានសមត្ថភាព និងលទ្ធភាពបង្កើនសមត្ថភាពរបស់ខ្លួនតាមការសិក្សាស្រាវជ្រាវពី វិធីសាស្ត្របង្រៀន បច្ចេកទេស គរុកោសល្យ និងចំណេះដឹងទូទៅថ្មីៗ តាមរយៈប្រព័ន្ធកុំព្យូទ័រ អ៊ីនធ័រណេតដែលចំណេះដឹងថ្មីៗទាំងនោះមានការវិវត្តទៅមុខមិនឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ។ ដូច្នេះ ការយកវិធីសាស្ត្រសិក្សាស្រាវជ្រាវមេរៀនពិតជាឆ្លើយតបនឹងស្ថានភាពអប់រំនៅកម្ពុជាព្រោះវាប្រើប្រាស់ធនធានខាងក្នុងដែលមានតម្លៃទាប ហើយវាមានអត្ថប្រយោជន៍ឥតគណនាតាមរយៈការផ្តល់ឱកាសដល់គ្រូចាស់ និងគ្រូថ្មី ដែលទើបចេញពីសាលាអាចផ្លាស់ប្តូរមតិយោបល់ បទពិសោធ ចំណេះដឹង និងចេះជួយគ្នាទៅវិញទៅ មកក្នុងការអភិវឌ្ឍការបង្រៀន និងរៀន ប្រកបដោយប្រសិទ្ធភាព និងគុណភាព។ គ្រូទាំងអស់បានខិតជិតគ្នា ដោះស្រាយបញ្ហារួមគ្នា និងជួយកែលម្អគ្នាទាំងលើកិច្ចតែងការបង្រៀន ការបង្រៀនសាកល្បង និង ថ្នាក់និទស្សន៍...ទៅតាមវដ្តPDCA (ផែនការ-សាកល្បង-កែលម្អ និងអនុវត្ត)។ ***យើងមើលឃើញជាទូទៅនៃគុណសម្បត្តិដ៏ច្រើនអនេកបែបនេះ ហើយ តែចន្ទះនៃការអនុវត្តនៅសាលារៀននានានៅក្នុងប្រទេសកម្ពុជាហាក់ដើរទៅមុខមិនលឿនសោះ។***

## 2.16) បញ្ហាប្រឈមការអប់រំរបស់ជប៉ុន

ទន្ទឹមនឹងភាពរីកចម្រើនខ្លាំងនៃវិស័យអប់រំ ប្រព័ន្ធអប់រំជប៉ុនក៏ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ។ ទោះបីជាប្រទេសជប៉ុនជាប់ចំ-ណាត់ថ្នាក់ខ្ពស់ក្នុងការធ្វើតេស្តPISA ប្រព័ន្ធអប់រំរបស់ខ្លួនត្រូវបានរិះគន់ដោយសារតែផ្តោតលើការធ្វើតេ

ស្ត និងការអនុលោមតាមស្តង់ដារ[104] ។ មានការលើកឡើងថា ដោយសារបទបញ្ញត្តិនៃលក្ខណៈវិនិច្ឆ័យប្រឡងចូលរៀនមហាវិទ្យាល័យ ធ្វើឱ្យប្រព័ន្ធអប់រំជប៉ុន ផ្តោតតែលើការសិក្សាបែបទ្រឹស្តីដើម្បីត្រៀមប្រឡង ដោយមិនបានលើកទឹកចិត្តគំនិតច្នៃប្រឌិតរបស់សិស្ស។ ***ចំណេះដឹងរបស់សិស្សផ្អែកលើតែខ្លឹមសារដែលមាននៅក្នុងសៀវភៅសិក្សាគោល*** (Content based know-ledge)។ ការចូលរៀនរបស់សិស្សនៅសាកលវិទ្យាល័យមិនអាស្រ័យលើការបំពេញការសិក្សារបស់សិស្សនៅវិទ្យាល័យទេ គឺមានតែលទ្ធផលប្រឡងចូលទេដែលកំណត់ ថាតើពួកគេអាចបានចូលរៀន ឬអត់។ បញ្ហានេះ វានាំឱ្យសិស្សផ្តោតខ្លាំងតែលើការចងចាំក្នុងកម្មវិធីសិក្សាវិទ្យាល័យ។ សិស្សមានភាពរវល់ច្រើនជាមួយនឹងការរៀនបច្ចេកទេសជាក់លាក់ដើម្បីធ្វើបានល្អពេលប្រឡងចូលមហាវិទ្យាល័យ។ ***ដូច្នេះពួកគេស្ទើរតែមិនចំណាយពេលសោះលើសកម្មភាពសិក្សាផ្សេងៗទៀតដូចជា៖ ការពិភាក្សានៅក្នុងថ្នាក់ ឡើងធ្វើបទបង្ហាញ ឬក៏ការធ្វើពិសោធន៍ដែលសកម្មភាពទាំងអស់នេះ ជាផ្នែកមួយសម្រាប់ការសិក្សារបស់ពួកគេ។*** ឧទាហរណ៍ការពិភាក្សាក្នុងថ្នាក់ និងការឡើងធ្វើបទបង្ហាញជួយដល់សិស្សក្នុងការរៀនសូត្រតាមរយៈការស្វែងយល់ និងបង្ហាញទស្សនៈគំនិតខ្លួនជាសាធារណៈ ហើយការពិសោធត្រូវការការសង្កេត និងវិភាគដែលបណ្តុះបណ្តាលសិស្សឱ្យប្រើប្រាស់ការគិតត្រិះពិចារណាបែបវិភាគស៊ីជម្រៅ។ ដោយមិនមានសកម្មភាពសំខាន់ៗទាំងអស់នេះ ប្រព័ន្ធអប់រំ ជប៉ុននឹងរារាំងសិស្សការអភិវឌ្ឍគំនិតច្នៃប្រឌិតថ្មី។ និន្នាការបែបនេះក៏កើតឡើងនៅ***ប្រទេសកម្ពុជា*** ផងដែរ ដោយសារការយកលទ្ធផលនៃការប្រឡងបញ្ចប់ការសិក្សានៅតាមភូមិសិក្សានីមួយៗជាគោលសម្រាប់ធ្វើការវាយតម្លៃពីភាពជោគជ័យរបស់គ្រឹះស្ថានសិក្សាមួយ (ទាំងរដ្ឋ និងឯកជន) វាផ្តល់ការលំបាកច្រើនសម្រាប់សាលារៀនទាំងនោះ ដាក់បញ្ចូលសកម្មភាពសិក្សានានា ដែលជំរុញគំនិតច្នៃប្រឌិត របស់សិស្ស ហើយដើម្បីប្រកួតប្រជែងទីផ្សារ សាលារៀនទាំងនោះ ពិសេសសាលាឯកជនត្រូវបត់បែនវិធីសាស្ត្របង្រៀនរបស់ខ្លួន ដើម្បីបង្កើនភាគរយសិស្សប្រឡងជាប់សញ្ញាប័ត្រឱ្យបានខ្ពស់ ក្នុងគោលបំណងទាក់ទាញអតិថិជន (សិស្ស)ឱ្យបានច្រើន។

ប្រព័ន្ធអប់រំជប៉ុនបង្កើតឱ្យមានកង្វះទស្សនវិស័យអនាគតក្នុងចំណោមសិស្សសាលា។ ហេតុផលមួយក្នុងចំណោមហេតុផលចម្បងៗដទៃទៀតគឺ ការដាក់សម្ពាធពីគ្រូបង្រៀន។ នៅតាមវិទ្យាល័យនីមួយៗ បើមានភាគរយនិស្សិតចូលរៀនសាកលវិទ្យាល័យ ពិសេសសាកលវិទ្យាល័យល្បីៗ មានឥទ្ធិពលដោយផ្ទាល់ដល់មុខមាត់វិទ្យាល័យនោះ។ ចំនួនសិស្សកាន់តែច្រើនអាចចូលរៀនសាកលវិទ្យាល័យល្បីៗមុខមាត់វិទ្យាល័យកាន់តែល្អ និងមានកិត្យានុភាព ហើយសិស្សកាន់តែច្រើននឹងដាក់ពាក្យមករៀននៅវិទ្យាល័យខ្លួន។ ជាលទ្ធផល គ្រូបង្រៀនជាទូទៅមានបំណង***ចង់ជំរុញសិស្សក្នុងគោលបំណងសម្រាប់ការចូលរៀនសាកលវិទ្យាល័យល្បីជាជាងផ្ដោតលើគោលដៅអាជីពរបស់ខ្លួន***។ ការរងសម្ពាធពីគ្រូបង្រៀន ទាំងនេះធ្វើឱ្យសិស្សមិនអាចរៀបចំទស្សនវិស័យច្បាស់លាស់សម្រាប់អនាគតពួកគេ។ សិស្សមិនមានសេរីភាពច្រើនទេនៅជប៉ុនដោយសារចំនួនកិច្ចសាលា និងការប្រឡងនៅវិទ្យាល័យមានចំនួនច្រើន។ បើប្រៀបធៀបនឹងប្រទេសដទៃទៀតក្នុងកម្រិតថ្នាក់នេះ សិស្សមានសេរីភាព និងសាមញ្ញច្រើនជាង។ ចំនួនសិស្សនៅជប៉ុនមានច្រើនគឺចន្លោះ៣៥ ដល់៤០នាក់ដែលពិបាកសម្រាប់គ្រូក្នុងយកចិត្តទុកដិតដល់សម្រាប់សិស្សម្នាក់ៗ។ ដូច្នេះសិស្សមួយចំនួនមិនអាចទទួលបានការជួយពីគ្រូបង្រៀនបានគ្រប់គ្រាន់ទេពីអ្វីដែលគេត្រូវការ។ ដើម្បីដោះស្រាយបញ្ហានេះ សិស្សជាច្រើនបានចូលរៀនសលាឯកជនក្រៅម៉ោង (Juku or cram school) ដើម្បីស្វែងរកជំនួយបន្ថែម។ ជាការពិតសិស្សជប៉ុន៦០%នៅកម្រិតមធ្យមសិក្សាទុតិយភូមិចូលរៀនសាលារៀនគួរក្រៅម៉ោងនេះ។ វាធម្មតាទេសម្រាប់សិស្សជប៉ុនដែលត្រឡប់ទៅផ្ទះវិញយឺត ហើយពេលខ្លះរហូតដល់ម៉ោង១០យប់ឯណោះនៅពេលគេចូលរៀនគួរក្រៅម៉ោង។ ផ្នែកទាំងពីរនេះ ដែលជាមូលហេតុដែលធ្វើឱ្យសិស្សជប៉ុនកម្រមានពេលទំនេរដើម្បីរក្សាតុល្យភាពជីវិតណាស់។ ដូចគ្នានេះដែរ ជនជាតិជប៉ុនជាច្រើនបានស្តីបន្ទោសសាលារៀនចំពោះការកើនឡើងនៃការមិនប្រក្រតីរបស់កុមារជាពិសេសនៅវិទ្យាល័យ និងក្នុងការធ្វើអត្តឃាតខ្លួនឯង។ ***ជារួមប្រព័ន្ធអប់រំជប៉ុន បានដាក់សម្ពាធផ្នែកសិក្សាដ៏រឹងមាំរបស់ខ្លួនលើសិស្ស***[105]និងរារាំងសិស្សពីការអភិវឌ្ឍគំនិតច្នៃប្រឌិត ភាពរីករាយក្នុងពេលទំនេររបស់ខ្លួន និងរក្សានូវទស្សនវិស័យច្បាស់លាស់របស់ខ្លួន។ ការរងសម្ពាធនៃការខិតខំប្រឹងប្រែង

សម្រាប់ការប្រឡងចូលសាកលវិទ្យាល័យជាបន្ទុកលើសលុបសម្រាប់សិស្សវិទ្យាល័យជាច្រើន។ វាអាចប៉ះពាល់ដល់សុខភាព ដែលការខិតខំសម្រាប់ការប្រឡងចូលរៀនសាកលវិទ្យាល័យគ្រាន់តែ ផ្នែកមួយនៃទទួលឱ្យចូលរៀនប៉ុណ្ណោះ។ ជាលទ្ធផលការប្រកួតប្រជែងចូលសកលវិទ្យាល័យមានកិត្យានុភាពខ្លាំងណាស់ ហើយបង្កើតផលអវិជ្ជមានជាច្រើនទៅលើសិស្សវិទ្យាល័យនៅជប៉ុន។ បញ្ហាចម្បងបីក្នុងចំណោមបញ្ហាចំបង ៗ គឺកង្វះខាតនៃភាពច្នៃប្រឌិតរបស់សិស្ស កង្វះសេរីភាព និងខ្វះទស្សនវិស័យនាពេលអនាគត។ ទី១ប្រព័ន្ធអប់រំរបស់ជប៉ុនមិនបានលើកទឹកចិត្តដល់ការច្នៃប្រឌិតក្នុងចំណោមសិស្ស។ មូលហេតុចម្បងគឺបទបញ្ញត្តិនៃលក្ខខណ្ឌប្រឡងចូលសកលវិទ្យាល័យ។ នៅក្នុងប្រទេសជប៉ុនការចូលរៀនសកលវិទ្យាល័យមិនពឹងផ្អែកទៅលើការលទ្ធផលសិស្សនៅវិទ្យាល័យទេ។ នោះគឺមានតែលទ្ធផលនៃការប្រឡងចូលប៉ុណ្ណោះដែលកំណត់ ថាតើសិស្សអាចចូលរៀននៅសាកលវិទ្យាល័យបាន ឬអត់។ នេះនាំឱ្យមានការសង្កត់ធ្ងន់ទៅលើការចងចាំពីកម្មវិធីសិក្សានៅវិទ្យាល័យ។ សិស្សកំពុងរវល់រៀនបច្ចេកទេសជាក់លាក់ដើម្បីអនុវត្តបានល្អនៅពេលប្រឡងចូលមហាវិទ្យាល័យ ដូច្នេះពួកគេស្ទើរតែមិនចំណាយពេលលើសកម្មភាពផ្សេងៗទៀតដូចជាការពិភាក្សាតាមថ្នាក់ ការធ្វើការក្រុម បទបង្ហាញ ឬពិសោធន៍ដែលត្រូវបានគេសន្មតថាជាផ្នែកនៃការអប់រំរបស់ពួកគេផងដែរ។ ឧទាហរណ៍ការពិភាក្សាក្នុងថ្នាក់រៀន និងការធ្វើបទបង្ហាញជួយសិស្សឱ្យសិស្សអាចបង្ហាញ និងបញ្ចេញមតិយោបល់របស់ពួកជាសាធារណៈហើយពិសោធន៍តម្រូវឱ្យពួកគេសង្កេត និងការវិភាគ ដែលហ្វឹកហាត់សិស្សឱ្យគិតបែបវិភាគ។ តាមរយៈការលុបបំបាត់រាល់សកម្មភាពសំខាន់ៗទាំងអស់នេះប្រព័ន្ធអប់រំរបស់ជប៉ុនបានរារាំងសិស្សពីការបង្កើតភាពច្នៃប្រឌិត។

**ការធ្វើអត្តឃាត**ជាបញ្ហាសង្គមដ៏ធ្ងន់ធ្ងរ និងបញ្ហាសុខភាពផ្លូវចិត្តនៅជប៉ុនពិសេសក្នុងចំណោមយុវជនវ័យក្មេងជប៉ុន។ អត្រាធ្វើអត្តឃាតបានកើនឡើងមិនប្រែប្រួលតាំងពីឆ្នាំ១៩៩៥[106]។ ការធ្វើអត្តឃាតជាមូលហេតុលំដាប់ទី២ដែលធ្វើសម្លាប់យុវជនជប៉ុនពីអាយុ១៥ឆ្នាំ ដល់២៤ឆ្នាំ[107] ។

**ជប៉ុននៅតែមានបញ្ហាប្រឈមទាក់ទងនឹងវិសមភាពស្ត្រីក្នុងវិស័យការងារ។** ក្រុមនិស្សិតដែលមានការអប់រំខ្ពស់ និងមានជំនាញខ្ពស់ជាផ្នែកមួយដ៏ធំក្នុងការចូល

រួមចំណែកកំណើនសេដ្ឋកិច្ចរបស់ប្រទេសជប៉ុន។ ឆ្នាំ២០០០ ស្ត្រី៤៩%អាយុពី២៥-៣៤ឆ្នាំមានបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា។ នៅឆ្នាំ២០១២ ស្ត្រី៦១% ដែលមានអាយុដូចខាងលើបានបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា ច្រើនជាងកម្រិតមធ្យមភាគរបស់ប្រទេសសមាជិកOECD ដែលត្រឹមតែ៤៥% និងធំជាងសមាមាត្របុរសជប៉ុនដែលមានអាយុ និងកម្រិតការអប់រំស្មើគ្នាមានតែ៥៦%។ ប៉ុន្តែអត្រាការងារនៅក្នុងចំណោមស្ត្រីជប៉ុននៅមានកម្រិតទាបជាងបុរសដែលមានកម្រិតអប់រំដូចគ្នា។ ខណៈដែល៩២% នៃបុរសដែលមានបរិញ្ញាប័ត្រ ឬសញ្ញាបត្រស្រាវជ្រាវកម្រិតខ្ពស់មានការងារធ្វើ ហើយស្ត្រីមានតែ៦៩% ប៉ុណ្ណោះមានការងារធ្វើទោះបីមានការអប់រំស្រដៀងគ្នានេះក៏ដោយ។ អត្រានេះគឺស្ថិតនៅក្រោមកម្រិតមធ្យមរបស់ប្រទេសសមាជិក OECD ផ្សេងទៀតដែលមាន៨០%។

សម្ពាធប្រកួតប្រជែងនៅតែមានលក្ខណៈខ្លាំងក្លានៅឡើយនៅប្រទេសជប៉ុនទោះបីមានការកំណែទម្រង់គោលនយោបាយអប់រំថ្មីៗនេះក៏ដោយ។ លទ្ធផលអប់រំខ្ពស់កម្រិតអន្តរជាតិ។ ប៉ុន្តែជប៉ុននៅតែមានបញ្ហាប្រឈមទាក់ទងនឹងការសម្របសម្រួលការភ្ជាប់សាលារៀនទៅនឹងការងារក្នុងបរិបទសាកលភាវូបនីយកម្ម និងការធ្លាក់ចុះនៃអត្រាការងារ។ បញ្ហាប្រឈមមួយទៀតគឺការកើនឡើងនូវចំនួនម៉ោងសិក្សានៅក្នុងសាលាដែលមិនធ្វើឱ្យកាន់ចុះខ្សោយនៃគុណភាពទាំងមូលនៃការបង្រៀនដែលគ្រូបង្រៀនបានផ្តល់។ (ឧ. រៀនច្រើនពេក មិនប្រាកដមួយណា)ការផ្តល់នូវការបង្រៀនប្រកបដោយគុណភាពគ្រូបង្រៀនត្រូវការឱកាសដើម្បីលើកកម្ពស់វិជ្ជាជីវៈ។ ការចូលរួមរបស់សហគមន៍ មូលដ្ឋានសម្រាប់ការអប់រំកុមារជាអាទិភាពបំផុត។ ជប៉ុនមានគោលបំណងរក្សាឱកាសស្មើភាព និងធានាស្តង់ដារនៃគុណភាពអប់រំ សម្រាប់ការអប់រំគ្រប់កម្រិតថ្នាក់លើសពីកម្រិតថ្នាក់កាតព្វកិច្ចអប់រំពីថ្នាក់ទី១ដល់ទី៩) ថែមទាំងធ្វើឱ្យមានស្ថេរភាពនៃមូលនិធិដើម្បីសម្រេចបានតាមចំណុចដៅដែលបានកំណត់(78)។

☛ទោះបីជាប្រទេសជប៉ុននៅតែជាកន្លែងទាក់ទាញសម្រាប់និស្សិតបរទេស...

និស្សិតឧត្តមសិក្សាចំនួន៣.៣% បានចូលរៀននៅក្នុងគ្រឹះស្ថានឧត្តមសិក្សារបស់ជប៉ុនក្នុងឆ្នាំ២០១២ ដែលបង្ហាញពីការកើនឡើង០,១%ពីឆ្នាំ២០០០។ នេះគឺជាភាគហ៊ុនធំបំផុតទី៨ក្នុងចំណោមប្រទេសគោលដៅទាំងអស់។ ក្នុងឆ្នាំ២០១២ និស្សិតបរទេស៩៤%នៅក្នុងប្រទេសជប៉ុនមកពីអាស៊ី ជាពិសេសនិស្សិតបរទេស៨១%នៅប្រទេសជប៉ុនបានមកពីប្រទេសជិតខាងដែលជាសមាមាត្រធំបំផុតក្នុងចំណោមបណ្តាប្រទេសជាសមាជិកនៃអង្គការ OECD។

**☛... មាននិស្សិតជប៉ុនតិចតួចប៉ុណ្ណោះដែលបានសិក្សានៅបរទេស**

ការផ្ញើនិស្សិតទៅសិក្សានៅបរទេស ជាវិធីល្អមួយដើម្បីជួយនិស្សិតឱ្យត្រៀមខ្លួនសម្រាប់ទីផ្សារការងារអន្តរជាតិ និងសាកលភាវូបនីយកម្មដែលកំពុងកើនឡើង។ ប៉ុន្តែមានតែ១%នៃសិស្សថ្នាក់ឧត្តមសិក្សាជប៉ុនប៉ុណ្ណោះដែលបានទៅរៀននៅបរទេសក្នុងឆ្នាំ២០១១។ ឆ្លើយតបទៅនឹងស្ថានភាពនេះរដ្ឋាភិបាលជប៉ុនបានបើកដំណើរការយុទ្ធនាការ "Tobitate! Ryugaku Japan" នៅក្នុងឆ្នាំ២០១៣ ដែលរួមមានកម្រងព្រឹត្តិការណ៍ និងកម្មវិធីអាហារូបករណ៍ថ្មីក្នុងគោលបំណងបង្កើនចំនួនសិស្សជប៉ុនទ្វេរដងទៅសិក្សានៅបរទេសត្រឹមឆ្នាំ២០២០ [(108)] ។

**☛ការពង្រីកលទ្ធភាពទទួលបានការរៀនសូត្រពេញមួយជីវិតអាចជួយកាត់បន្ថយគម្លាតរវាងជំនាញពីជំនាន់មួយទៅជំនាន់មួយទៀត**

ថ្វីបើប្រជាជនដែលមានចំណេះដឹងខ្ពស់ និងមានជំនាញខ្ពស់នៅជប៉ុនមានទំហំធំហើយកំពុងរីកចម្រើន តែវានៅមានគម្លាតរវាងជំនាន់មួយទៅជំនាន់មួយ។ អនុជនវ័យក្មេងថ្មីស្ទើរតែ៦០%មានកម្រិតការអប់រំកម្រិតឧត្តមសិក្សា ខណៈមនុស្សចាស់មានតិចជាង៣៥% វាជាគម្លាតធំបំផុតទី៣ពីមួយជំនាន់ទៅមួយជំនាន់។ ការរៀនសូត្ររបស់មនុស្សពេញវ័យអាចកាត់បន្ថយគម្លាតទាំងនេះនិងជួយមនុស្សពេញវ័យឱ្យទទួលបាន និងអភិវឌ្ឍចំណេះដឹង ជំនាញដែលបង្កើនជីវិតអាជីព និងការរស់នៅរបស់ពួកគេ។

**☛ប្រទេសជប៉ុនកំណត់នូវលក្ខខណ្ឌជាច្រើនដើម្បីធានាគុណភាពនៃគ្រូរបស់ខ្លួន ...**

ដោយមានការយល់ដឹងយ៉ាងទូលំទូលាយថាកត្តាសំខាន់បំផុតដែលជះឥទ្ធិពលដល់ការរៀនសូត្ររបស់សិស្សនៅក្នុងសាលារៀនគឺគ្រូបង្រៀន។ វាច្បាស់ណាស់ថាការជ្រើសរើសគ្រូដែលមានគុណភាពខ្ពស់គឺមានសារៈសំខាន់។ ប្រទេសជប៉ុនកំពុងធ្វើកិច្ចប្រឹងប្រែង ដោយបង្កើតនូវលក្ខខណ្ឌជាច្រើនសម្រាប់អ្នកអនាគតជាគ្រូបង្រៀន និងគ្រូថ្មី។ គ្រូបង្រៀនអនាគតត្រូវបំពេញការអប់រំជាគ្រូបង្រៀនដំបូង ដែលស្រដៀងគ្នានឹងកម្មវិធីដែលផ្តល់ជូននៅប្រទេសដទៃទៀតទាក់ទងនឹងលក្ខណៈវិនិច្ឆ័យការជ្រើសរើសរយៈពេល និងមាតិកា។ ទោះជាយ៉ាងណាក៏ដោយគ្រូបង្រៀនអនាគតនៅក្នុងប្រទេសជប៉ុនមិនត្រូវបានគេផ្តល់ពេលវេលាច្រើនក្នុងការចុះកម្មសិក្សានៅតាមសាលារៀនខុសពីប្រទេសដទៃទៀតទេ។ ការចុះកម្មសិក្សាគ្រូអនុវិទ្យាល័យ នៅប្រទេសជប៉ុនមានរយៈពេលតែ២០ថ្ងៃប៉ុណ្ណោះ បើប្រៀបធៀបរវាងប្រទេសផ្សេងទៀតចន្លោះពី៧០ និង ១២០។ មិនដូចប្រទេសផ្សេងៗទៀតទេ ប្រទេសជប៉ុនតម្រូវឱ្យបេក្ខជនដែលបានបណ្តុះបណ្តាលតម្រូវឱ្យប្រឡងជាប់ការប្រឡងប្រជែងធ្វើគ្រូបង្រៀន និងទទួលបានអាជ្ញាប័ណ្ណបង្រៀនក្រោយពីបានបញ្ចប់ការបណ្តុះបណ្តាលគ្រូដំបូង។

**☛... ប៉ុន្តែការគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈបន្តអាចនឹងត្រូវបានធ្វើឱ្យប្រសើរឡើង**

ថ្វីបើមានតម្រូវការខ្ពស់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈដូចដែលបានរាយការណ៍ដោយគ្រូបង្រៀននៅក្នុង TALIS ឆ្នាំ២០១៣ គ្រូបង្រៀននៅជប៉ុនមិនទទួលបានការគាំទ្រច្រើនដើម្បីចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈដូចជាគ្រូនៅក្នុងប្រទេសដទៃទៀតនៃ OECD។ ជាឧទាហរណ៍ ការគាំទ្រផ្នែកហិរញ្ញវត្ថុដែលគ្របដណ្តប់លើការបង់ថ្លៃសេវាតម្រូវសម្រាប់ការចូលរួមក្នុងវគ្គសិក្សាអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់បច្ចុប្បន្នភាពឡើងវិញនៃវិញ្ញាបនប័ត្រខ្លួនគឺកម្រ ទោះបីយ៉ាងដូច្នេះក្តី តាំងពីឆ្នាំ២០០៩ គ្រូជប៉ុនត្រូវបានតម្រូវឱ្យបញ្ចប់វគ្គសិក្សាពង្រឹងវិញ្ញាបនប័ត្រថ្មីនេះ៣០ម៉ោងរៀងរាល់១០ ឆ្នាំម្តង។

**☛ទំនាក់ទំនងរវាងការអប់រំរបស់មាតាបិតា និងការអប់រំកុមារ និងជំនាញគឺ មានភាពទន់ខ្សោយបន្តិចនៅក្នុងប្រទេសជប៉ុន**

នៅប្រទេសជប៉ុន ចលនាអប់រំពីជំនាន់មួយទៅជំនាន់មួយមានកម្រិតមធ្យមៈ មនុស្សពេញវ័យ៤០%បានទទួលការអប់រំខ្ពស់ជាងឪពុកម្តាយរបស់ពួកគេ( ចលនាចល័តឡើង ) ខណៈដែលមនុស្សពេញវ័យម្នាក់ក្នុងចំណោមពីរនាក់មានកម្រិតអប់រំដូច

ឪពុកម្តាយរបស់ពួកគេ។ នេះអាចឆ្លុះបញ្ចាំងមួយផ្នែកនៃអត្រាកើនឡើងនៃមនុស្សចាស់ដែលមានចំណេះដឹងកម្រិតឧត្តមសិក្សា។ នៅជប៉ុន ពលរដ្ឋ៤៦%អាយុ៤៥-៥៤ឆ្នាំ និង៣២% អាយុ៥៥-៦៤ឆ្នាំមានការអប់រំឧត្តមសិក្សាខ្ពស់ជាងមធ្យមភាគ OECD (២៩% និង២៤%) ហើយកុមារនៃមនុស្សពេញវ័យទាំងនេះអាចជា ទំនងជាមានចំណេះដឹងដូចគ្នានឹងឪពុកម្តាយដែរ។ ជាការពិតណាស់ដែលមានអាយុចាប់ពី ២៥ ដល់៣៤ ឆ្នាំនៅក្នុងប្រទេសជប៉ុនបានទទួលការអប់រំខ្ពស់ដូចឪពុកម្តាយរបស់ពួកគេ (បុរស៣៣% និងស្ត្រី៣៨% បើធៀបនឹងមធ្យមភាគOECD១៩% និង ២៣%)។ នៅប្រទេសជប៉ុនចំណេះដឹងផ្នែកអក្ខរកម្មរបស់កុមារក៏ត្រូវបានទាក់ទងទៅនឹងចំណេះដឹងផ្នែកអប់រំរបស់ឪពុកម្តាយផងដែរទោះបីទំនាក់ទំនងនេះមានភាពទន់ខ្សោយបើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតនៃOECDក៏ដោយ។ខណៈដែល ៣៥%នៃមនុស្សពេញវ័យ (អាយុ២៥-៦៤ឆ្នាំ) ដែលមានឪពុកម្តាយដែលបានទទួលការអប់រំជាន់ខ្ពស់អនុវត្តកម្រិតជំនាញកម្រិតអក្ខរកម្មកម្រិតទី៤ ឬ៥ដូចដែលបានវាស់ដោយការស្ទង់មតិជំនាញមនុស្សពេញវ័យ (មធ្យមភាគOECD គឺ២៣%) មានតែ ១២%ប៉ុណ្ណោះ ឪពុកម្តាយដែលមានកម្រិតខាងវិទ្យាល័យធ្វើដូច្នេះ (មធ្យមភាគ OECD មាន៥%)។ ទន្ទឹមនឹងនេះដែរមនុស្សពេញវ័យតិចជាង២% ដែលឪពុកម្តាយមានចំណេះដឹងកម្រិតទាបមានកម្រិត ឬទាបជាងកម្រិតអក្ខរកម្មកម្រិតទី១(មធ្យមភាគ OECD៧%)ខណៈដែលមនុស្សពេញវ័យ១០%ដែលឪពុកម្តាយមានកម្រិតការអប់រំទាប (មធ្យមភាគOECD គឺ២៥%)។

# III. ប្រព័ន្ធអប់រំកោះតៃវ៉ាន់



☛សំណួរត្រិះរិះ

១-តើប្រព័ន្ធអប់រំតៃវ៉ាន់មានលក្ខណៈដូចម្តេច? មានកំណែទម្រង់ប្រព័ន្ធអប់រំអ្វីខ្លះទើបអាចក្លាយជាភាពគំរូមួយរបស់ពិភពលោក និងធ្វើឱ្យដែនដីកោះរីកចម្រើនក្លាយជាដែនកោះ សេដ្ឋកិច្ចរីកចម្រើន?

២-ហេតុអ្វីបានជាតេស *PISA* តៃវ៉ាន់ ទទួលលទ្ធផលខ្ពស់?

៣-ហេតុអ្វីបានការប្រឡងអូឡាំពិ្យាត តៃវ៉ាន់តែងតែទទួលបានមេដាយមាសច្រើនជាងគេ?

៤-តើ ប្រទេសកម្ពុជា អាចរៀនសូត្រអ្វីខ្លះពីតៃវ៉ាន់? អ្វីដែលអាចឱ្យប្រទេសកម្ពុជាយកជាគំរូបាន ហើយអ្វីដែលមិនអាច?

## 3.1 ) ទិដ្ឋភាពទូទៅរបស់កោះតៃវ៉ាន់

## (សង្គម សេដ្ឋកិច្ច និងនយោបាយ)

កោះតៃវ៉ាន់ដែលគេធ្លាប់តែស្គាល់ថា Formosa ត្រូវបានរស់នៅដោយជនជាតិដើមនៅមុនសតវត្សរ៍ទី១៧ នៅពេលដែលអាណានិគមហូឡង់ និងអេស្ប៉ាញបានបើកចំហសម្រាប់ជនអន្តោប្រវេសន៍ហាន។ តៃវ៉ាន់បានឋិតនៅក្រោមការកាន់កាប់របស់ចក្រភពចិន (រាជវង្សឈិន-រាជវង្សចុងក្រោយចិន) តែជប់ឆ្នាំប៉ុណ្ណោះគឺ ពីឆ្នាំ១៨៨៥ ដល់ឆ្នាំ១៨៩៥។ នៅឆ្នាំ១៨៩៥ បន្ទាប់សង្គ្រាមចិន-ជប៉ុន សន្ធិសញ្ញាមួយដែលមានឈ្មោះថាសន្ធិសញ្ញា Shimonoseki បានផ្ទេរតៃវ៉ាន់ទៅឲ្យជប៉ុន។ និយាយរួម ក្រៅពីភាសាគ្មានឡើយអត្តសញ្ញាណរួមរវាងចិនដីគោក និងចិនតៃវ៉ាន់។ ក្នុងអំឡុងពេលដែលតៃវ៉ាន់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជប៉ុន នៅចិនដីគោកបានបង្កើតសាធារណរដ្ឋចិន (Republic Of China-ROC) នៅឆ្នាំ១៩១២បន្ទាប់ពីការដួលរលំនៃរាជវង្សឈិង។ បន្ទាប់ពីការចុះចាញ់របស់ជប៉ុនក្នុងសង្គ្រាមលោកលើកទីពីរនៅឆ្នាំ១៩៤៥ សាធារណរដ្ឋចិន(ROC) បានកាន់កាប់កោះតៃវ៉ាន់។ ទោះជាយ៉ាងណាក៏ដោយក្រោយសង្គ្រាមលោកលើកទី២ ប្រទេសចិននៅបន្តមានសង្គ្រាមស៊ីវិលស៊ីសាច់ហុតឈាមគ្នា រវាងកងទ័ពអ្នកជាតិនិយមចិនដែលដឹកនាំដោយ **ជាង កាយជៀក** (Chiang Kai-Shek) និងកងកម្លាំងកុម្មុយនិស្តរបស់ **ម៉ៅ សេទុង** (Mao Tsé-Toung) ហើយនៅទីបំផុត កងទ័ពជាតិនិយមបានច្បាំងចាញ់កងកម្លាំងកុម្មុយនិស្ត (ចិនក្រហម) ហើយបានភៀសខ្លួនទៅកោះតៃវ៉ាន់ និងប្រកាសបង្កើត**សាធារណរដ្ឋចិន**(1)។ ចំណែកឯ **ម៉ៅ សេទុង** វិញបានប្រកាសបង្កើត**សាធារណរដ្ឋប្រជាមានិតចិន** (People's Republic of China-PRC)នៅឆ្នាំ១៩៤៩(ចិនដីគោក)នោះដែរ។ ចិនដីគោកមាននិន្នាការងាកទៅខាងពិភពកុម្មុយនីស្ត ចំណែកសាធារណរដ្ឋចិនវិញងាកទៅរកលោកសេរី ជាហេតុធ្វើឲ្យដែនដីទាំងពីរនេះឃ្លាតឆ្ងាយពីគ្នា និងប្រឆាំងគ្នាតរៀងមក ទាំងនៅលើវិស័យរបបនយោបាយ និងវិស័យនយោបាយសេដ្ឋកិច្ច។ នៅខាង

សាធារណរដ្ឋប្រជាមានិតចិនអនុវត្តអំណាចបែបផ្តាច់ការ និងសេដ្ឋកិច្ចផែនការ។ ចំណែកឯនៅខាងសាធារណរដ្ឋចិនវិញ គឺជារបបពហុបក្ស និងសេដ្ឋកិច្ចផ្សារសេរី ហើយប្រមុខរដ្ឋ និងមេបញ្ជាការកងកម្លាំងប្រដាប់អាវុធគឺជាប្រធានាធិបតីដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតប្រជាប្រិយភាពសម្រាប់រយៈពេលអតិបរមាយ៉ាងយូរ២អណត្តិ (១អណត្តិមានរយៈពេល៤ឆ្នាំ)[2]។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៧ គណបក្សកាន់អំណាច (គណបក្សវឌ្ឍនភាពប្រជាធិបតេយ្យ-DPP)របស់សាធារណរដ្ឋចិនបានអនុម័តសេចក្តីសម្រេចមួយស្តីពីការអះអាងអត្តសញ្ញាណដាច់ដោយឡែកពីប្រទេសចិន ហើយបានអំពាវនាវឱ្យមានការអនុម័តរដ្ឋធម្មនុញ្ញថ្មីសម្រាប់ប្រទេសធម្មតាមួយ។ គេក៏បានអំពាវនាវឱ្យប្រើជាទូទៅនូវ **"តៃវ៉ាន់"** ជាឈ្មោះរបស់ប្រទេសខ្លួន ដោយមិនលុបឈ្មោះផ្លូវការរបស់ខ្លួន "**សាធារណរដ្ឋចិន**"នោះទេ[3]។

កោះតៃវ៉ាន់មានប្រជាជនចំនួន២៣,៤លាននាក់[4] ក្នុងនោះ ៩៥% ជាជនជាតិហានដែលភាគច្រើនរួមបញ្ចូលទាំងកូនចៅនៃជនជាតិដើមភាគតិចហានចិនដែលបានមកដល់តៃវ៉ាន់នៅក្នុងចំនួនដ៏ច្រើនចាប់ផ្តើមតាំងពីសតវត្សទី១៨។ ជាទូទៅ ក្រុមជនជាតិភាគតិចតៃវ៉ាន់មានជនជាតិ Hoklo(៧០%) Hakka(១៤%) Waishengren(១៤%) និងជនជាតិដើមភាគតិច(២%)[5] (=៥៣៣៦០០នាក់) ហើយក្នុងចំណោមជនជាតិដើមភាគតិច(២%)មានតែ១៦ក្រុមប៉ុណ្ណោះដែលត្រូវបានទទួលស្គាល់[6]។ ដូចប្រទេសចិនដែរ តៃវ៉ាន់ភាគច្រើនប្រើប្រាស់ភាសាចិនកុកងឺ និងត្រូវបានចាត់ទុកថាជាភាសាជាតិផ្លូវការ។ វាជាភាសាប្រើប្រាស់ជាចម្បងសម្រាប់ទំនាក់ទំនងទូទៅ និងបង្រៀននៅក្នុងសាលារៀនចាប់តាំងពីការបញ្ចប់ការគ្រប់គ្រងរបស់ជប៉ុន[7]។ តៃវ៉ាន់មិនត្រឹមជាដែនកោះសម្បូរជនជាតិភាគតិចប៉ុណ្ណោះទេ ថែមទាំងមានសាសនាច្រើនផងដែរ។ រដ្ឋធម្មនុញ្ញសាធារណរដ្ឋចិន ការពារសេរីភាពខាងជំនឿសាសនា និងការអនុវត្តជំនឿ[8]។ យោងតាមស្ថិតិឆ្នាំ២០០៥ ក្នុងចំណោមប្រជាជនទាំងអស់មានអ្នក

កាន់សាសនាប្រហែល៨១,៣% និង១៤-១៨% ជាអ្នកមិនប្រកាន់យកសាសនាណាមួយ។ យោងតាមការធ្វើជំរឿនក្នុងឆ្នាំ២០០៥ សាសនាចំនួន ២៦ ដែលទទួលស្គាល់ដោយរដ្ឋាភិបាលតៃវ៉ាន់ ដែលធំជាងគេប្រាំគឺ៖ ព្រះពុទ្ធសាសនា(៣៥,១%) តាវនិយម(៣៣%) យូវីយូវេវ(៣,៥%) ប្រូតេស្តង់និយម(២,៦ %) និងរ៉ូម៉ាំងកាតូលិក(១,៣%)[9]។ ផ្ទៃដីសរុបកោះតៃវ៉ាន់មាន៣៥,៨៨៣គីឡូម៉ែត្រការ៉េ ហើយស្ថិតនៅចម្ងាយ១៨០គីឡូម៉ែត្រពីឆ្នេរសមុទ្រអាគ្នេយ៍របស់ចិនដីគោកឆ្លងកាត់ច្រកសមុទ្រតៃវ៉ាន់[10]។ កោះតៃវ៉ាន់ស្ថិតនៅតំបន់ត្រូពិចភាគខាងជើងមានអាកាសធាតុតំបន់ត្រូពិចសមុទ្រ[11] ។ ទឹកភ្លៀងមធ្យមគឺ២,៦០០មីល្លីម៉ែត្រ(100 អ៊ីញ)។ ផ្អែកតាមផែនទីគ្រោះរញ្ជួយដីដោយសហរដ្ឋអាមេរិក ទីតាំងភូមិសាស្ត្រកោះតៃវ៉ាន់ស្ថិតនៅចំណាត់ថ្នាក់ខ្ពស់ដែលប្រឈមនឹងគ្រោះរញ្ជួយដី។ ឧ. នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៩ រញ្ជួយដី៧,៣រិចទ័រ ដែលបានសម្លាប់មនុស្សជាង ២៤០០នាក់[12]។ មុនជនចំណូលស្រុកហានចូលមកកោះតៃវ៉ាន់ មានជនជាតិដើមជាច្រើនរស់នៅលើទឹកដីនេះតាំងទីលំនៅ និងមាន**វប្បធម៌អរិយធម៌**ផ្ទាល់ខ្លួនរួចជាស្រាច់តាំងពីជាច្រើនរយឆ្នាំកន្លងមកហើយ ដែលតំណាងឱ្យប្រជាជនតៃវ៉ាន់២%សរុបចំនួន២៣លាននាក់។ ពួកគេភាគច្រើនស្ថិតនៅក្នុងចង្កោមពួកអូស្ត្រូនេស៊ី អាចយល់ភាសាហ្វីលីពីន ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ឬអូសេអានី។ ពួកគេត្រូវរងការគំរាមកំហែង និងធ្វើទុក្ខបុកម្នេញតាំងពីបួនរយឆ្នាំមុន ពោលគឺនៅពេលដែលជនជាតិហានមកពីប្រទេសចិន ចូលឈ្លានពានយកទឹកដី និងពង្រីកវប្បធម៌។ដើមកំណើតវប្បធម៌ដែលបានរួមផ្សំជាមួយការបែងចែកភូមិសាស្ត្ររាប់រយឆ្នាំ ការបំបែកខ្លួននយោបាយ និងឥទ្ធិពលបរទេស ក៏ដូចជាអរិភាពរវាងគូប្រជែងតៃវ៉ាន់ និងមហាយក្សចិន បានធ្វើឱ្យអត្តសញ្ញាណជាតិក្លាយទៅជាបញ្ហាដ៏ចម្រូងចម្រាសបំផុតមួយដែលមានលក្ខណៈនយោបាយ[13]។ គោលនយោបាយលើកកម្ពស់វប្បធម៌ ពិសេសវប្បធម៌ជនជាតិដើមតៃវ៉ាន់ ចង់បង្ហាញពីភាពមរតវប្បធម៌របស់ខ្លួនដោយឡែកខុសពីចិនដីគោក។

អំឡុងពេលគ្រប់គ្រងដោយអាណានិគមនជប៉ុន តៃវ៉ាន់បានធ្វើឧស្សាហូបនីយកម្មដោយពង្រីកផ្លូវដែក និងបណ្តាញគមនាគមន៍ផ្សេងទៀតបង្កើតប្រព័ន្ធអនាម័យទូលំទូលាយ និងបង្កើតប្រព័ន្ធអប់រំជាផ្លូវការ(14)។ ក្នុងកំឡុងពេលនោះ ធនធានមនុស្ស និងធនធានធម្មជាតិតៃវ៉ាន់ត្រូវបានប្រើដើម្បីជួយដល់ការអភិវឌ្ឍប្រទេសជប៉ុន និងការផលិតដំណាំយកប្រាក់ (cash crop) ដូចជាស្រូវ និងស្ករសបានកើនឡើងយ៉ាងខ្លាំង។ នៅឆ្នាំ ១៩៣៩ តៃវ៉ាន់គឺជាអ្នកផលិតស្ករអំពៅធំបំផុតទី៧នៅលើពិភពលោក(15)។ ស្ថិតក្រោមអាណានិគមជប៉ុន ជនជាតិតៃវ៉ាន់ និងជនជាតិដើមត្រូវបានចាត់ថ្នាក់ជាពលរដ្ឋទី២ និងទី៣ ហើយមានយុទ្ធាការបង្ហូរឈាមជាច្រើនប្រឆាំងលើអ្នកបោះបោរ ពិសេសពួកជនដើមភាគតិចនៅតំបន់ភ្នំ(16)។ បញ្ញាវ័ន្ត និងកម្មករដែលបានចូលរួមនៅក្នុងចលនាឆ្វេងនិយម (និន្នាការកុំម្មុយនីស្ត) នៅក្នុងតៃវ៉ាន់ក៏ត្រូវបានគេចាប់ខ្លួន និងសម្លាប់យ៉ាងរង្គាលផងដែរ។ ប្រហែលឆ្នាំ១៩៣៥ ជនជាតិជប៉ុនបានចាប់ផ្តើមគម្រោងស្រូបយកកោះទាំងមូលដើម្បីចងភ្ជាប់កោះនេះឱ្យកាន់តែរឹងមាំទៅនឹងចក្រភពជប៉ុន ហើយប្រជាជនត្រូវបានគេបង្រៀនថា ខ្លួនគេជាជនជាតិជប៉ុននៅក្រោមចលនា Kominka។ ក្នុងកំឡុងពេលនោះវប្បធម៌ និងសាសនាតៃវ៉ាន់ត្រូវបានគេហាមឃាត់ ហើយប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្ត ដើម្បីទទួលយកនាមត្រកូលជប៉ុន (17)។ នៅឆ្នាំ១៩៣៨ ជនជាតិជប៉ុនចំនួន៣០៩.០០០នាក់បានមកតាំងទីលំនៅនៅតៃវ៉ាន់(18)។ ជាមួយគ្នានេះ ក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ ជនជាតិតៃវ៉ាន់រាប់ពាន់នាក់បានចូលបម្រើនៅក្នុងជួរកងទ័ពជប៉ុន និងពលីជីវិតអស់ជាច្រើននាក់(19)។ ឧទាហរណ៍អតីតបងប្រុសរបស់លោកប្រធានាធិបតី Lee Teng-hui បានបម្រើនៅក្នុងកងនាវាចរជប៉ុនហើយត្រូវបានគេសម្លាប់នៅក្នុងសកម្មភាពមួយនៅក្នុងប្រទេសហ្វីលីពីននៅក្នុងខែកុម្ភៈ ឆ្នាំ១៩៤៥។ កងនាវាចរអធិរាជបានប្រតិបត្តិការយ៉ាងខ្លាំងចេញពីកំពង់ផែតៃវ៉ាន់ ហើយជាទីតាំងប្រឈមនឹងការទម្លាក់គ្រាប់បែកអាមេរិកផងដែរ(20)។ ជាមួយគ្នានេះ ក្នុងអំឡុងពេលនោះ ស្ត្រីជាង២០០០

នាក់ត្រូវបានគេបង្ខំឱ្យធ្វើជាទាសករផ្លូវភេទសម្រាប់កងទ័ពអធិរាជជប៉ុន(21) ។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ នៅពេលជប៉ុនចាញ់សង្គ្រាម ជនជាតិជប៉ុនភាគច្រើនត្រូវបានបណ្ដេញចេញ និងបញ្ជូនទៅប្រទេសជប៉ុនវិញ(22)។ ក្រោយជប៉ុនចាកចេញពីតៃវ៉ាន់ សង្គ្រាមស៊ីវិលនៅក្នុងប្រទេសចិននៅតែបន្តកើតមាន រហូតដល់កងទ័ពក្រហមទទួលបានជ័យជម្នះលើកងទ័ពជាតិនិយមរបស់ **ជាង កាយជៀក** (អ្នកដឹកនាំបក្សគួ **មីនតាង**-KMT) និងបានភៀសខ្លួនទៅកាន់កោះតៃវ៉ាន់។ ប្រជាជនប្រមាណ២លាននាក់ដែលភាគច្រើនជាក្រុមទាហានសមាជិកបក្ស **គួ មីនតាង**កាន់អំណាច ឥស្សរជន បញ្ញវន្ត និងធុរកិច្ចត្រូវបានគេជម្លៀសពីចិនដីគោកទៅកោះតៃវ៉ាន់នៅពេលនោះដោយបន្ថែមចំនួនប្រជាជនប្រមាណពី៦លាននាក់នៅទីនោះស្រាប់។ លើសពីនេះទៅទៀត រដ្ឋាភិបាលសាធារណរដ្ឋចិន(តៃវ៉ាន់) បានយកទ្រព្យសម្បត្តិជាតិជាច្រើនដូចជា៖ មាសបម្រុងទុក និងទុនបម្រុងបរទេសទៅជាមួយផងដែរ(23) ។ មកដល់កោះតៃវ៉ាន់ ច្បាប់អាជ្ញាសឹកដែលបានប្រកាសនៅខែឧសភាឆ្នាំ១៩៤៩(24) បានបន្តមានប្រសិទ្ធភាពរហូតដល់ឆ្នាំ១៩៨៧ និងត្រូវបានគេប្រើជាមធ្យោបាយបង្ក្រាបលើគណបក្សប្រឆាំងក្នុងអំឡុងពេលអន្តរាគមន៍នានា(25)។ តួយ៉ាងដូចកំឡុងពេល White Terror ជារយៈពេលមួយដែលគេដឹងថាមានមនុស្សប្រមាណ១៤០០០០នាក់ត្រូវបានជាប់គុក ឬត្រូវបានគេប្រហារជីវិត ដោយសារតែត្រូវបានគេចាត់ទុកថាជាអ្នកប្រឆាំងនឹងបក្ស គួ មីនតាង ឬអ្នកគាំទ្រកុម្មុយនិស្ត(26)។ ប្រជាពលរដ្ឋជាច្រើននាក់ត្រូវបានគេចាប់ខ្លួន ធ្វើទារុណកម្មចាប់ដាក់គុក និងប្រហារជីវិតដោយសារតែទំនាក់ទំនងពិតប្រាកដរបស់ពួកគេទៅនឹងពួកកុម្មុយនិស្ត។ ដោយសារមនុស្សទាំងនេះភាគច្រើនមកពីពួកឥស្សរជន បញ្ញវន្ត និងអ្នកមានមុខមាត់ក្នុងសង្គម អ្នកដឹកនាំនយោបាយ និងសង្គមយុគសម័យថ្មីទាំងមូលត្រូវបានគេបំផ្លិចបំផ្លាញ។ នៅឆ្នាំ១៩៩៨ តៃវ៉ាន់បានអនុម័តច្បាប់ដើម្បីបង្កើតមូលនិធិសំណងសម្រាប់សាលក្រមមិនត្រឹមត្រូវដែលបានត្រួតពិនិត្យដល់ការផ្ដល់សំណងដល់ជនរងគ្រោះ និងគ្រួសារក្នុងអំឡុងព្រឹត្ត

ការណ៍នោះ។ ប្រធានាធិបតី Ma Ying-jeou បានធ្វើការសុំទោសជាផ្លូវការក្នុងឆ្នាំ២០០៨ ដែលបង្ហាញពីក្តីសង្ឃឹមថានឹងមិនមានសោកនាដកម្មស្រដៀងទៅនឹងព្រឹត្តការណ៍នេះទៀតទេពេលខាងមុខ(27)។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និង១៩៧០ តៃវ៉ាន់បានរក្សារដ្ឋាភិបាលផ្តាច់ការដោយគណបក្សតែមួយ ខណៈសេដ្ឋកិច្ចរបស់ខ្លួនបានក្លាយជាឧស្សាហកម្ម និងតម្រង់ទិសបច្ចេកវិទ្យា។ កំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សនេះ ត្រូវបានគេស្គាល់ថាជា តៃវ៉ាន់ដ៏អស្ចារ្យដែលជាលទ្ធផលនៃរបបសារពើពន្ធឯករាជ្យពីចិនដីគោក ហើយត្រូវបានគាំទ្រពីមូលនិធិអាមេរិក និងគាំទ្រតម្រូវការសម្រាប់ផលិត-ផលតៃវ៉ាន់(28)។ នៅទសវត្សរ៍ឆ្នាំ១៩៧០ កោះតៃវ៉ាន់ជាប្រទេសមានការរីកចម្រើនលូតលាស់លឿនបំផុតទី២ នៅអាស៊ីបន្ទាប់ពីជប៉ុន(29)។ តៃវ៉ាន់រួមជាមួយហុងកុង កូរ៉េខាងត្បូង និងសឹង្ហបូរី ត្រូវបានគេស្គាល់ថាជាសត្វខ្លាមួយក្នុងចំណោមសត្វខ្លាអាស៊ីទាំងបួន។ ដោយសារសង្គ្រាមត្រជាក់ប្រជាជាតិលោកខាងលិច និងអង្គការសហប្រជាជាតិចាត់ទុក តៃវ៉ាន់ជារដ្ឋាភិបាលស្របច្បាប់តែមួយរបស់ប្រទេសចិនរហូតដល់ឆ្នាំ១៩៧០។ ក្រោយមកទៀតជាពិសេសបន្ទាប់ពីការបញ្ចប់សន្ធិសញ្ញា Sino-American Mutual Defense Treaty ប្រជាជាតិភាគច្រើនបានប្តូរការទទួលស្គាល់ខាងការទូតទៅឱ្យសាធារណរដ្ឋប្រជាមានិតចិន ( សូមមើលដំណោះស្រាយមហាសន្និបាតសហប្រជាជាតិលេខ២៧៥៨ )។ រហូតមកដល់ទសវត្សរ៍ឆ្នាំ១៩៧០ រដ្ឋាភិបាលត្រូវបានរិះគន់ ដោយលោកខាងលិចថា តៃវ៉ាន់មិនមានលទ្ធិប្រជាធិបតេយ្យតាមរយៈគាំទ្រដល់ច្បាប់អាជ្ញាសឹក ដោយព្រោះតែមានការគាបសង្កត់យ៉ាងខ្លាំងក្លាចំពោះគណបក្សប្រឆាំង និងគ្រប់គ្រង់ប្រព័ន្ធផ្សព្វផ្សាយ។ **គួ មីនតាង** (KMT) មិនបានអនុញ្ញាតឱ្យមានការបង្កើតគណបក្សថ្មី និងគណបក្សដែលមានស្រាប់មិនមានសមត្ថភាពការប្រកួតប្រជែងខ្លាំងជាមួយ KMT ឡើយ។ ដូចនេះការបោះឆ្នោតតាមបែបប្រជាធិបតេយ្យមិនមានទេ(30)។ យ៉ាងណាក៏ដោយចាប់ពីចុងទសវត្សរ៍ឆ្នាំ១៩៧០ ដល់ទសវត្សរ៍ឆ្នាំ១៩៩០ តៃវ៉ាន់បានឆ្លងកាត់ការកែទម្រង់ និងការ

ផ្លាស់ប្តូរសង្គមដែលបានកែប្រែវាពីរដ្ឋផ្តាច់ការទៅជាលទ្ធិប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៧៩ ការតវ៉ាគាំទ្រលទ្ធិប្រជាធិបតេយ្យដែលគេស្គាល់ថាជាឧប្បត្តិហេតុ Kaohsiung បានកើតឡើងនៅក្នុងទីក្រុង Kaohsiung ដើម្បីប្រារព្ធទិវាសិទ្ធិមនុស្ស។ ទោះបីជាការតវ៉ានេះត្រូវបានអាជ្ញាធរកម្ទេចយ៉ាងឆាប់រហ័សក៏ដោយ ក៏វាត្រូវបានគេចាត់ទុកថាជាព្រឹត្តិការណ៍សំខាន់មួយដែលបានរួបរួមការប្រឆាំងនៅតៃវ៉ាន់[31]។ នៅដើមទសវត្សឆ្នាំ១៩៦០ តៃវ៉ាន់បានឈានដល់យុគសម័យកំណើនសេដ្ឋកិច្ចឆាប់រហ័ស និងឧស្សាហូបនីយកម្មបង្កើតឱ្យមានស្ថេរភាពសេដ្ឋកិច្ចក្នុងឧស្សាហកម្ម។ នៅទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ តៃវ៉ាន់បានផ្លាស់ប្តូរពីរបបផ្តាច់ការយោធាឯកបក្សដែលគ្រប់ដណ្តប់ដោយបក្ស **គួ មីនតាង** ទៅជាលទ្ធិប្រជាធិបតេយ្យពហុបក្សជាមួយប្រព័ន្ធពាក់កណ្តាលប្រធានាធិបតី។ តៃវ៉ាន់គឺជាប្រទេសមហាអំណាចសេដ្ឋកិច្ចលំដាប់ទី២២ នៅក្នុងពិភពលោក ហើយឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់របស់ខ្លួនដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចពិភពលោក។ ជាមួយគ្នានេះ តៃវ៉ាន់ក៏ត្រូវបានគេចាត់ទុកផងដែរថាមានកម្រិតខ្ពស់លើវិស័យសេរីភាពសារព័ត៌មាន ការថែទាំសុខភាព ការអប់រំសាធារណៈ សេរីភាពសេដ្ឋកិច្ច និងការអភិវឌ្ឍន៍មនុស្ស[32]។ ទាំងនេះគឺទទួលផលប្រយោជន៍ពីកម្លាំងពលកម្មដែលមានជំនាញខ្ពស់និងជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានការអប់រំល្អបំផុតដែលមានចំនួនប្រជាពលរដ្ឋបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា[33] ចំនួនដ៏ច្រើន។ ជាមួយគ្នានេះ តៃវ៉ាន់ក៏ប្រឈមនឹង**បញ្ហានយោបាយ**យ៉ាងរ៉ាំរ៉ៃផងដែរជាមួយសាធារណរដ្ឋប្រជាមានិតចិនលើបញ្ហាអធិបតេយ្យភាពទឹកដី និងឯករាជ្យភាព។ ចិនដីគោកបានទាមទារអធិបតេយ្យភាពលើកការគ្រប់គ្រងតៃវ៉ាន់ជាប្រចាំ ហើយបានអះអាងថា តៃវ៉ាន់មិនស្ថិតនៅក្នុងភាពស្របច្បាប់ឡើយ[34]។ ក្រោមគោលនយោបាយចិនតែមួយ ចិនដីគោកបានបដិសេធទំនាក់ទំនងការទូតជាមួយប្រទេសណាដែលទទួលស្គាល់តៃវ៉ាន់។ សព្វថ្ងៃនេះប្រទេសចំនួន ២០ រក្សាទំនាក់ទំនងជាផ្លូវការជាមួយតៃវ៉ាន់ ប៉ុន្តែរដ្ឋជាច្រើនទៀតរក្សាទំ

នាក់ទំនងក្រៅផ្លូវការតាមរយៈការិយាល័យតំណាង ស្ថាប័នដែលមានមុខងារជាស្ថានទូតមិនពេញលេញ និងស្ថានកុងស៊ុល។ ថ្វីបើតៃវ៉ាន់គ្រប់គ្រងខ្លួនឯងយ៉ាងពេញលេញក៏ដោយ ក៏អង្គការអន្តរជាតិភាគច្រើនដែលមានសាធារណរដ្ឋប្រជាមានិតចិនចូលរួមគឺមិនព្រមផ្តល់សមាជិកភាពទៅតៃវ៉ាន់ទេ ឬបានត្រឹមអនុញ្ញាតឱ្យតៃវ៉ាន់ចូលរួមតែជាតួអង្គដែលមិនមែនរដ្ឋអធិប-តេយ្យភាពមួយប៉ុណ្ណោះ។ ចិនដីគោកតែងតែគំរាមកំហែងការប្រើប្រាស់កម្លាំងយោធាដើម្បីឆ្លើយតបទៅនឹងការប្រកាសផ្លូវការឯករាជ្យណាមួយរបស់តៃវ៉ាន់ ឬក៏ប្រសិនបើមេដឹកនាំចិនដីគោក សម្រេចថាការបង្រួបបង្រួមដោយសន្តិភាពនឹងលែងមានទៀតហើយ(35)។ ថ្នាក់ដឹកនាំចិនប្រជាមានិតអះអាងថា នឹងមានអន្តរាគមន៍យោធាភ្លាមមួយរំពេច បើសិនទី(១)-តៃវ៉ាន់ហ៊ានប្រកាសឯករាជ្យ ទី(២)-បើសិនជាតៃវ៉ាន់ហ៊ានបង្កើតកម្មវិធីនុយក្លេអ៊ែរក្នុងគោលដៅផលិតគ្រាប់បែកបរមាណូ និង(៣)បើសិនជាតៃវ៉ាន់នៅតែចចេសមិនព្រមចរចា ដើម្បីបង្រួបបង្រួមចិនទាំងពីរឲ្យទៅជាចិនតែមួយទេនោះ។ ចំពោះថ្នាក់ដឹកនាំចិន អូសទាញតៃវ៉ាន់មកដាក់នៅក្រោមការគ្រប់គ្រងរបស់ខ្លួនជាការណ៍មួយចាំបាច់បំផុតពីព្រោះចិននឹងមិនអាចមានឈ្មោះជាមហាអំណាចតំបន់ ឬជាមហាអំណាចពិភពលោកពិតប្រាកដបានទេ ប្រសិនបើជាមានចិនពីរនៅលើឆាកអន្តរជាតិ។ បញ្ហានយោបាយលេចធ្លោនាពេលបច្ចុប្បន្ននៅតៃវ៉ាន់គឺ ទំនាក់ទំនងរបស់ខ្លួនជាមួយសាធារ-ណរដ្ឋប្រជាមានិតចិន។ អស់រយៈពេលជិត៦០ឆ្នាំមកហើយមិនមានការតភ្ជាប់ដោយផ្ទាល់រួមទាំងជើងហោះហើរត្រង់រវាងតៃវ៉ាន់ និងចិនដីគោកឡើយ។ នេះគឺជាបញ្ហាមួយសម្រាប់ក្រុមហ៊ុនតៃវ៉ាន់ជាច្រើនដែលបានបើករោងចក្រ ឬសាខានៅចិនដីគោក។ អតីតរដ្ឋបាល DPP បារម្ភថាទំនាក់ទំនងបែបនេះនឹងនាំឱ្យមានការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងនយោបាយកាន់តែតឹងរឹងជាមួយចិនដីគោកហើយនៅក្នុងឆ្នាំ២០០៦ សុន្ទរកថាប្រចាំឆ្នាំ លោកប្រធានាធិប-តី Chen Shui-bian បានអំពាវនាវឱ្យមានការបើកតំណភ្ជាប់ជើងហោះហើរត្រង់ចុងសប្តាហ៍ដោយផ្ទាល់រវាងតៃវ៉ាន់ និងចិនដី

គោកបានចាប់ផ្តើមនៅខែកក្កដា ឆ្នាំ២០០៨ ក្រោមរដ្ឋាភិបាលបច្ចុប្បន្ន របស់ KMT ហើយជើងហោះហើរប្រចាំថ្ងៃដោយផ្ទាល់ដំបូងបានចាប់ផ្តើម នៅខែធ្នូ ឆ្នាំ២០០៨(36)។ បញ្ហានយោបាយសំខាន់ៗដទៃទៀតរួមមាន គឺ ការទិញសព្វាវុធ ពីសហរដ្ឋអាមេរិកជាដើម(37)។ នៅឆ្នាំ២០០៨ ទោះជា យ៉ាងណាក៏ដោយអាមេរិកមានការស្ទាក់ស្ទើរក្នុងការបញ្ជូនអាវុធទៅតៃវ៉ាន់ ដោយការភ័យខ្លាចថាវានឹងរាំងស្ទះដល់ការរីកចម្រើនថ្មីៗនៃចំណងទាក់ ទងរវាងចិនដីគោក និងតៃវ៉ាន់ (38)។

នៅលើឆាកអន្តរជាតិ វាមានភាពចម្រូងចម្រាសថាតើ តៃវ៉ាន់នៅ តែមានរដ្ឋ ឬរដ្ឋដែលនៅសល់ (defunct state) ក្នុងច្បាប់អន្តរជាតិ ដោយសារតែខ្វះការទទួលស្គាល់ការទូតយ៉ាងទូលំទូលាយ។ នៅក្នុងការ ស្ទង់មតិមួយទៅលើប្រជាពលរដ្ឋតៃវ៉ាន់ដែលមានអាយុចាប់ពី២០ឆ្នាំឡើង ទៅ ហើយដែលត្រូវបានថតដោយ TVBS នៅខែមីនា ឆ្នាំ២០០៩ បង្ហាញ ថា យុវជន៦៤%ភាគច្រើនជ្រើសរើសយក "ស្ថានភាពបច្ចុប្បន្ន (status quo)" ខណៈ១៩% ពេញចិត្តចំពោះ "**ឯករាជ្យភាព**" និង៥%ពេញចិត្ត "**ការបង្រួបបង្រួមជាមួយចិន**"(39)។

**សម្រាប់ទំនាក់ទំនងការបរទេស** មុនឆ្នាំ១៩២៨ គោលនយោ-បាយការបរទេសនៃសាធារណរដ្ឋចិនមានភាពស្មុគស្មាញដោយកង្វះការ បង្រួបបង្រួមផ្ទៃក្នុងដែលជាមជ្ឈមណ្ឌលប្រកួតប្រជែងអំណាចដែលបាន អះអាងថាស្របច្បាប់។ ស្ថានភាពនេះបានផ្លាស់ប្តូរបន្ទាប់ពីការបរាជ័យ របស់រដ្ឋាភិបាល Peiyang ដោយគួ មីនតាងដែលបាននាំទៅដល់ការទទួល ស្គាល់ជាផ្លូវការទូតនៃសាធារណរដ្ឋចិន(40) បន្ទាប់ពីការចាកចេញរបស់ KMT ទៅតៃវ៉ាន់បណ្តាប្រទេសភាគច្រើនជាពិសេសបណ្តាប្រទេសនៅប្លុក បស្ចិមប្រទេសបានបន្តរក្សាទំនាក់ទំនងជាមួយតៃវ៉ាន់។ ដោយសារតែការ គាបសង្កត់ខាងការទូតពីចិនដីគោក មានការកត់សម្គាល់ឃើញថា ជាបណ្

តើរៗប្រទេសជាច្រើនបានផ្លាស់ប្តូរការទទួលស្គាល់របស់ខ្លួនទៅលើតៃវ៉ាន់ ងាកទៅសាធារណរដ្ឋប្រជាមានិតចិន(PRC)វិញ នៅទសវត្សរ៍ឆ្នាំ១៩៧០ ។ សេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិលេខ២៧៥៨ (ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧១) បានទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិនជាអ្នកតំណាងតែមួយគត់របស់ចិននៅឯអង្គការសហប្រជាជាតិ(41)។ ចិនដីគោកបានបដិសេធមិនមានទំនាក់ទំនងការទូតជាមួយប្រទេសណាដែលទទួលស្គាល់កោះតៃវ៉ាន់ និងទាមទារឱ្យប្រទេសទាំងអស់ដែលមានទំនាក់ទំនងការទូតដើម្បីធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់ការអះអាងរបស់ខ្លួនចំពោះកោះតៃវ៉ាន់(42)។ ជាលទ្ធផលមានតែរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួន១៩ប៉ុណ្ណោះ និងព្រះវិហារបរិសុទ្ធ (Government of Catholic Church) នៅតែរក្សាទំនាក់ទំនងការទូតជាផ្លូវការជាមួយសាធារណរដ្ឋចិន (តៃវ៉ាន់)។ តៃវ៉ាន់រក្សាទំនាក់ទំនងក្រៅផ្លូវការជាមួយបណ្តាប្រទេសជាច្រើនតាមរយៈស្ថានទូត និងស្ថានកុងស៊ុល ហៅថាការិយាល័យតំណាងសេដ្ឋកិច្ច និងវប្បធម៌តៃប៉ិ (TECRO) ដែលមានការិយាល័យសាខា "ការិយាល័យសេដ្ឋកិច្ច និងវប្បធម៌តៃប៉ិ"(TECO)។ ទាំងTECRO និង TECOគឺជា"អង្គភាពពាណិជ្ជកម្មក្រៅផ្លូវការ "របស់តៃវ៉ាន់ ទទួលបន្ទុកថែរក្សាទំនាក់ទំនងការទូតដោយផ្តល់សេវាកុងស៊ុល (ឧទាហរណ៍ការដាក់ពាក្យសុំទិដ្ឋាការ) និងបម្រើផលប្រយោជន៍ជាតិតៃវ៉ាន់នៅក្នុងប្រទេសទាំងនោះ(43)។ សហរដ្ឋអាមេរិកនៅតែជាសម្ព័ន្ធមិត្តសំខាន់មួយរបស់តៃវ៉ាន់ ហើយតាមរយៈច្បាប់ទំនាក់ទំនងតៃវ៉ាន់ដែលបានអនុម័តនៅឆ្នាំ១៩៧៩ សហរដ្ឋអាមេរិកបានបន្តលក់អាវុធ និងផ្តល់ការហ្វឹកហ្វឺនយោធាដល់កងកម្លាំងប្រដាប់អាវុធ(44)។ ទំនាក់ទំនងរវាងអាមេរិក និងតៃវ៉ាន់នេះ នៅតែជាបញ្ហាមួយសម្រាប់សាធារណរដ្ឋប្រជាមានិតចិន(ចិនដីគោក)ដែលចាត់ទុកថា ការចូលរួមរបស់អាមេរិកធ្វើឱ្យមានការរំខានដល់ស្ថេរភាពនៅក្នុងតំបន់។ នៅខែមករាឆ្នាំ២០១០ រដ្ឋបាលលោក**អូបាម៉ា**បានប្រកាសពីចេតនារបស់ខ្លួនក្នុងការលក់ឧបករណ៍យោធាតម្លៃ៦,៤ ពាន់លានដុល្លារទៅឱ្យ

កោះតៃវ៉ាន់។ ជាលទ្ធផល ចិនបានគំរាមកំហែងដល់សហរដ្ឋអាមេរិកដោយដាក់ទណ្ឌកម្មសេដ្ឋកិច្ច ហើយបានព្រមានថាកិច្ចសហប្រតិបត្តិការរបស់ពួកគេទាំងពីរលើបញ្ហាអន្តរជាតិ និងតំបន់អាចរងផលប៉ះពាល់(45)។ ជំហរជាផ្លូវការរបស់សហរដ្ឋអាមេរិកគឺថា ចិនត្រូវបានគេរំពឹងថានឹងមិនប្រើកម្លាំង ឬការគំរាមកំហែងដើម្បីប្រើកម្លាំងប្រឆាំងនឹងកោះតៃវ៉ាន់ឡើយ ហើយតៃវ៉ាន់គឺត្រូវអនុវត្តការប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងគ្រប់ទិដ្ឋភាពទាំងអស់នៃទំនាក់ទំនងឆ្លងកាត់ជ្រោយសមុទ្រ។ សមាសភាគីទាំងពីរត្រូវបញ្ឈប់ការធ្វើសកម្មភាព ឬសេចក្តីថ្លែងការណ៍ដែលអាចធ្វើឱ្យផ្លាស់ប្តូរឋានៈតៃវ៉ាន់ដោយឯកតោភាគី(46)។ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ រដ្ឋបាលលោក**អូបាម៉ា**បានប្រកាសកិច្ចព្រមព្រៀងមួយដើម្បីលក់អាវុធមានតម្លៃ១,៨៣ពាន់លានដុល្លារទៅឱ្យកងកម្លាំងប្រដាប់អាវុធតៃវ៉ាន់(47)។ ចំពោះមុខកិច្ចព្រមព្រៀងនេះ ក្រសួងការបរទេសចិនបានសម្តែងការមិនពេញចិត្តចំពោះការលក់អាវុធនេះ និងបានចេញសារឱ្យអាមេរិកនូវ "ការព្រមានយ៉ាងតឹងរឹង" ដោយនិយាយថា វានឹងប៉ះពាល់ដល់ទំនាក់ទំនងចិន-អាមេរិក(48)។ **ការចូលរួមរបស់តៃវ៉ាន់ជាមួយអង្គការ និងព្រឹត្តការណ៍អន្តរជាតិ**នៅតែជាបញ្ហាប្រឈមដ៏ធំមួយ ដោយសារគោលនយោបាយចិនតែមួយ។ ប្រទេសចិនចូលរួមតែក្នុងអង្គការអន្តរជាតិដែលតៃវ៉ាន់មិនត្រូវបានទទួលស្គាល់ជាប្រទេសអធិបតេយ្យ។ រដ្ឋជាសមាជិកភាគច្រើនរួមទាំងសហរដ្ឋអាមេរិកផងដែរមិនចង់ពិភាក្សាគ្នាពីបញ្ហាស្ថានភាពនយោបាយតៃវ៉ាន់ ដោយសារតែភ័យខ្លាចចំណងទំនាក់ទំនងការទូតជាមួយសាធារណរដ្ឋប្រជាមានិតចិន(49)។ ទោះជាយ៉ាងណាក៏ដោយ ទាំងសហរដ្ឋអាមេរិក និងជប៉ុនគាំទ្រជាសាធារណៈចំពោះប្រកួតប្រជែងរបស់តៃវ៉ាន់សម្រាប់សមាជិកភាពនៅក្នុងអង្គការសុខភាពពិភពលោកជាអ្នកសង្កេតការណ៍(50)។ តៃវ៉ាន់បានព្យាយាមចូលរួមក្នុងអង្គការសុខភាពពិភពលោកចាប់តាំងពីឆ្នាំ១៩៩៧ ក៏ដោយកិច្ចប្រឹងប្រែងរបស់ពួកគេត្រូវបានរារាំងដោយរដ្ឋាភិបាលចិនដីគោករហូតដល់ឆ្នាំ២០១០ នៅពេលដែលពួកគេត្រូវបានគេអញ្ជើញជាអ្នកសង្កេតការណ៍ចូល

រួមមហាសន្និបាតសុខភាពពិភពលោកក្រោមឈ្មោះថា"**ចិនតៃប៉ិ**"(51)។ ដោយសារសម្ពាធពីមហាយក្សចិន តៃវ៉ាន់ត្រូវបានបង្ខំឱ្យប្រើឈ្មោះ "**ចិនតៃប៉ិ**" នៅក្នុងព្រឹត្តិការណ៍អន្តរជាតិដូចជាហ្គេមអូឡាំពិកដែលចិនក៏ជាភាគីមួយដែរ។ ជាទូទៅ តៃវ៉ាន់ត្រូវបានរារាំងមិនឱ្យប្រើប្រាស់ភ្លេងជាតិ និងទង់ជាតិនៅក្នុងព្រឹត្តិការណ៍អន្តរជាតិ។ ទស្សនិកជនរបស់តៃវ៉ាន់ដែលចូលរួមព្រឹត្តិការណ៍ដូចជា ព្រឹត្តិការណ៍អូឡាំពិកត្រូវបានរារាំងមិនឱ្យនាំយកទង់ជាតិតៃវ៉ាន់ចូលទៅកន្លែង(52)។ តៃវ៉ាន់ក៏ចូលរួមផងដែរនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក (ចាប់តាំងពីឆ្នាំ១៩៩១) និងអង្គការពាណិជ្ជកម្មពិភពលោក(ចាប់តាំងពីឆ្នាំ២០០២) ក្រោមឈ្មោះថា "ចិនតៃប៉ិ" ។ តៃវ៉ាន់ អាចចូលរួមជា "ប្រទេសចិន" នៅក្នុងអង្គការនានាដែលចិនមិនបានចូលរួមដូចជា អង្គការចលនាកាយរឹទ្ធិពិភពលោកជាដើម ។

បើនិយាយពីបញ្ហាអត្តសញ្ញាណខ្លួនសម្រាប់ជនជាតិតៃវ៉ាន់ យោងតាមការស្ទង់មតិដែលបានធ្វើឡើងនៅក្នុងខែមីនា ឆ្នាំ២០០៩ អ្នកឆ្លើយសំណួរ៤៩%ចាត់ទុកថាខ្លួនជាជនជាតិតៃវ៉ាន់ប៉ុណ្ណោះហើយ អ្នកឆ្លើយតប៤៤%ចាត់ទុកថាខ្លួនជាជនជាតិតៃវ៉ាន់ និងចិន។ ៣% ចាត់ទុកខ្លួនឯងថាជាជនជាតិចិន(53)។ ការស្ទង់មតិមួយទៀតដែលបានធ្វើឡើងនៅតៃវ៉ាន់កាលពីខែកក្កដា ឆ្នាំ២០០៩ បានបង្ហាញថា អ្នកឆ្លើយសំណួរ៨២,៨%ចាត់ទុកថា តៃវ៉ាន់ និងចិនជាប្រទេសពីរដាច់ដោយឡែកពីគ្នាដោយការអភិវឌ្ឍន៍ដោយខ្លួនឯង។ ការស្ទង់មតិមួយដែលបានធ្វើឡើងនៅខែធ្នូ ឆ្នាំ២០០៩ បានបង្ហាញថាអ្នកឆ្លើយសំណួរ៦៤% គិតថាខ្លួនជាជនជាតិតៃវ៉ាន់តែប៉ុណ្ណោះ និងចំនួន ២២% ឆ្លើយថាខ្លួនគេជាជនជាតិតៃវ៉ាន់ និងចិន ហើយចំនួន៨% ចាត់ទុកខ្លួនឯងថាជាជនជាតិចិន។ ការស្ទង់មតិក៏បង្ហាញផងដែរថា ក្នុងចំណោមអ្នកឆ្លើយសំណួរដែលមានអាយុពី១៨ ទៅ២៩ឆ្នាំ៧៥%ចាត់ទុកខ្លួនគេជាជនជាតិតៃវ៉ាន់តែប៉ុណ្ណោះ។ នៅក្នុងការស្ទង់មតិចុងក្រោយដែលធ្វើឡើងដោយសាកលវិទ្យាល័យ National Chengchi ក្នុងឆ្នាំ២០១៤ ហើយបាន

បោះពុម្ពផ្សាយនៅដើមឆ្នាំ២០១៥ អ្នកឆ្លើយតប៦០,៦% បានកំណត់ថាពួកគេជាជនជាតិតៃវ៉ាន់៣២,៥%បានសម្គាល់ខ្លួនថាជាជនជាតិតៃវ៉ាន់ និងចិនហើយ ៣,៥% បានចាត់ទុកខ្លួនឯងថាជាជនជាតិចិន។

សម្រាប់វិស័យការពារជាតិ សាធារណរដ្ឋចិន( តៃវ៉ាន់ )បានចាក់ឫសគល់របស់ខ្លួននៅក្នុងកងទ័ពបដិវត្តន៍ជាតិដែលត្រូវបានបង្កើតឡើងដោយ**ស៊ុនយ៉ាតសេន**នៅឆ្នាំ១៩២៥នៅក្វាងដុងជាមួយគោលដៅបង្រួបបង្រួមប្រទេសចិនក្រោមបក្ស **គួ មីងតាង**។ នៅពេលកងទ័ពរំដោះប្រជាជនបានឈ្នះសង្គ្រាមស៊ីវិលកងទ័ពបដិ-វត្តន៍ភាគច្រើនបានដកថយទៅតៃវ៉ាន់រួមជាមួយរដ្ឋាភិបាល។ ក្រោយមក វាត្រូវបានធ្វើកំណែទម្រង់ចូលទៅក្នុងសាធារណរដ្ឋចិន។ អង្គភាពដែលបានចុះចាញ់ និងស្នាក់នៅក្នុងប្រទេសចិនដីគោកត្រូវបានរុះរើ ឬដាក់បញ្ចូលទៅក្នុងកងទ័ពរំដោះប្រជាជន។ សព្វថ្ងៃនេះ សាធារណរដ្ឋចិនរក្សានូវទំនើបកម្មយោធា ដែលភាគច្រើនជាការការពារប្រឆាំងនឹងការគំរាមកំហែងជាប្រចាំពី សំណាក់សាធារណៈរដ្ឋប្រជាមានិតចិន( ចិនដីគោក )ក្រោមច្បាប់ប្រឆាំងប្រកាសឯករាជ្យតៃវ៉ាន់(54)។ ចាប់ពីឆ្នាំ១៩៤៩ ដល់ឆ្នាំ១៩៧០ បេសកកម្មចម្បងរបស់យោធាគឺត្រូវ "**ដណ្តើមយកចិនដីគោកឡើងវិញ**"។ នៅពេលដែលបេសកកម្មនេះបានផ្លាស់ប្តូរទៅជាការការពារពីការឈ្លានពាន កងទ័ពតៃវ៉ាន់បានចាប់ផ្តើមប្រែក្លាយកងទ័ពបែបប្រពៃណីរបស់ខ្លួន ឱ្យទៅជាកងទ័ពអាកាស និងកងនាវាចរដ៏មានសក្តានុពល។ តៃវ៉ាន់បានចាប់ផ្តើមកម្មវិធីកាត់បន្ថយកម្លាំង Jingshi An ដើម្បីកែសម្រួលយោធារបស់ខ្លួនពីកម្រិត៤៥០.០០០ ក្នុងឆ្នាំ១៩៩៧ ដល់៣៨០.០០០ នៅឆ្នាំ២០០១(55)។ គិតត្រឹមឆ្នាំ២០០៩ កងកម្លាំងប្រដាប់អាវុធរបស់តៃវ៉ាន់មានចំនួនប្រហែល៣០០.០០០នាក់(56)ដែលមានទ័ពបម្រុងមានចំនួនសរុប៣.៦លាននាក់គិតត្រឹមឆ្នាំ២០០៥(57)។ តៃវ៉ាន់ក៏សម្រេចចិត្តធ្វើទំនើបកម្មទាំងសមត្ថភាពការពារ និងវាយលុក។ តែប៉ុនៅតែរក្សាឧបករណ៍យោធាធំៗ ដែលទាក់ទងទៅនឹងចំនួនប្រជាជននៅលើកោះ ហើយការចំណាយសម្រាប់ការការពារឆ្នាំ២០០៨មានចំនួន៣៣៤ពាន់

លានដុល្លារតៃវ៉ាន់ (ប្រហែល១០,៥៣ន់លានដុល្លារអាមេរិក)ដែលស្មើនឹង ២,៩៤% នៃផលិតផលក្នុងស្រុកសរុប។

ផ្នែកបន្ទាប់នេះ យើងសូមបង្ហាញពី**វិស័យសេដ្ឋកិច្ច និង ឧស្សាហកម្ម**តៃវ៉ាន់។ ឧស្សាហូបនីយកម្ម និងកំណើនយ៉ាងឆាប់រហ័សរបស់តៃវ៉ាន់គឺនៅពាក់កណ្ដាលចុងក្រោយសតវត្សរ៍ទី២០ ត្រូវបានគេហៅថា"**តៃវ៉ាន់អស្ចារ្យ**"។ កោះតៃវ៉ាន់គឺជាផ្នែកមួយនៃ"**ខ្លាអាស៊ីទាំងបួន**" រួមជាមួយហុងកុង កូរ៉េខាងត្បូង និងសិង្ហបុរី។ ការគ្រប់គ្រងរបស់ជប៉ុនមុន និងក្នុងកំឡុងសង្គ្រាមលោកលើកទី២ បាននាំមកនូវការផ្លាស់ប្ដូរនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជនដែលគួរឱ្យកត់សម្គាល់ ជាពិសេសនៅក្នុងវិស័យសាធារណៈដែលអាចឱ្យមានការទំនាក់ទំនងយ៉ាងឆាប់រហ័ស និងសម្រួលដល់ការដឹកជញ្ជូននៅទូទាំងប្រទេស។ ជនជាតិជប៉ុនក៏បានជួយធ្វើឱ្យមានភាពប្រសើរឡើងនូវការអប់រំសាធារណៈ និងបានធ្វើឱ្យការអប់រំជាកាតព្វកិច្ចសម្រាប់សាធារណជនទាំងអស់។ មួយវិញទៀត ការភៀសខ្លួនមកកោះតៃវ៉ាន់បន្ទាប់ពីចាញ់សង្គ្រាមស៊ីវិលជាមួយកងទ័ពក្រហម ពួកគេបាននាំមកជាមួយនូវទ្រព្យសម្បត្តិ មាស និងទុនបម្រុងទុក ព្រមទាំងឥស្សរជនបញ្ញាញាណ និងពាណិជ្ជករឆ្នើមៗរបស់សាធារ-ណរដ្ឋចិនមកជាមួយ ដែលពួកគេនេះដើរតួយ៉ាងយ៉ាងសំខាន់ក្នុងការចូលរួមចំណែកកសាងឿនសេដ្ឋកិច្ចតៃវ៉ាន់[58]។ នៅលើមូលដ្ឋាននៃអំណាចទិញ(PPP) ផលិតផលក្នុងស្រុកសរុបរបស់មនុស្សម្នាក់ក្នុងដើមទសវត្សរ៍ឆ្នាំ១៩៦០ គឺមាន១,៣៥៣ ដុល្លារអាមេរិក។ គិតត្រឹមឆ្នាំ២០១១ តាមGNPដែលត្រូវបានកែតម្រូវដោយសមាមាត្រអំណាចទិញ(PPP)បានកើនឡើងរហូតដល់៣៧០០០ដុល្លារ ដែលរួមចំណែកដល់សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស (HDI) ដែលស្មើទៅនឹងប្រទេសអភិវឌ្ឍន៍ដទៃទៀត។ សន្ទស្សន៍HDI របស់កោះតៃវ៉ាន់ក្នុងឆ្នាំ ២០១២គឺ០,៨៩០(ចំណាត់ទី២៣-ពិន្ទុខ្ពស់ណាស់) នេះបើយោងតាមវិធីគណនា HDIថ្មីដែលត្រូវបានកែសម្រួលដោយអង្គការសហប្រជាជាតិ។ នៅឆ្នាំ១៩៧៤ **ឈៀង ឈីងគីយូ** បានអនុវត្តគម្រោងសំណង់សំខាន់ៗចំនួន

ដប់ដែលជាមូលដ្ឋានគ្រឹះដែលជួយឱ្យកោះតៃវ៉ាន់ក្លាយទៅជាសេដ្ឋកិច្ចនាំចេញបច្ចុប្បន្នរបស់ខ្លួន។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ក្រុមហ៊ុនបច្ចេកវិទ្យាដែលមានមូលដ្ឋាននៅតៃវ៉ាន់មួយចំនួនបានពង្រីកប្រតិបត្តិការរបស់ខ្លួននៅជុំវិញពិភពលោក។ ក្រុមហ៊ុនបច្ចេកវិទ្យាអន្តរជាតិដែលមានមូលដ្ឋាននៅតៃវ៉ាន់រួមមានក្រុមហ៊ុនផលិតកុំព្យូទ័រផ្ទាល់ខ្លួន Acer Inc និង Asus ក្រុមហ៊ុនផលិតទូរស័ព្ទដៃក្រុមហ៊ុន HTC ក៏ដូចជាក្រុមហ៊ុនផលិតគ្រឿងអេឡិចត្រូនិច Foxconn ដែលផលិតទំនិញសម្រាប់ក្រុមហ៊ុន Apple Amazon និង Microsoft។ សព្វថ្ងៃនេះ កោះតៃវ៉ាន់មានសេដ្ឋកិច្ចជំរុញការនាំចេញ មូលធន និងមានភាពរឹងមាំតាមរយៈកាត់បន្ថយជាបណ្តើរៗនូវភាពពាក់ព័ន្ធរបស់រដ្ឋទៅលើការវិនិយោគ និងពាណិជ្ជកម្មបរទេស។ ស្របតាមនិន្នាការនេះ ធនាគារធំៗ និងក្រុមហ៊ុនឧស្សាហកម្មធំៗដែលជាកម្មសិទ្ធិរបស់រដ្ឋមួយចំនួនបានធ្វើឯកជនភាវូបនីយកម្ម(59)។ កំណើនពិតGDP ជាមធ្យម៨%ក្នុងរយៈពេល៣ទសវត្សរ៍កន្លងមក។ ការនាំចេញបានផ្តល់នូវកម្លាំងជំរុញដ៏សំខាន់សម្រាប់ឧស្សាហូបនីយកម្ម។ តៃវ៉ាន់មានទុនបម្រុងបរទេសមានទំហំធំបំផុតទី៥នៅលើពិភពលោក(60)។ សាធារណរដ្ឋចិន( តៃវ៉ាន់) មានរូបិយប័ណ្ណផ្ទាល់ខ្លួនជាប្រាក់ដុល្លារតៃវ៉ាន់ថ្មី។ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ទំនាក់ទំនងសេដ្ឋកិច្ចរវាងតៃវ៉ាន់ និងសាធារណរដ្ឋប្រជាមានិតចិនបានរីកចម្រើនយ៉ាងខ្លាំង។ នៅឆ្នាំ២០០៨ មានទឹកប្រាក់ជាង១៥០ពាន់លានដុល្លារ(61) ត្រូវបានវិនិយោគនៅក្នុងសាធារណរដ្ឋប្រជាមានិតចិនដោយក្រុមហ៊ុនតៃវ៉ាន់ ហើយកម្លាំងពលកម្មតៃវ៉ាន់ប្រមាណ១០%ធ្វើការនៅក្នុងសាធារណរដ្ឋប្រជាមានិតចិន ភាគច្រើនដំណើរការអាជីវកម្មផ្ទាល់ខ្លួន(62)។ ទោះបីសេដ្ឋកិច្ចរបស់កោះតៃវ៉ាន់ទទួលបានអត្ថប្រយោជន៍ពីស្ថានភាពនេះក៏ដោយ ក៏អ្នកខ្លះបានបង្ហាញពីទស្សនៈយល់ឃើញថា៖ កោះនេះកាន់តែពឹងអាស្រ័យលើសេដ្ឋកិច្ចចិនដីគោក។ ឆ្នាំ២០០៨ នាយកដ្ឋានបច្ចេកវិជ្ជាឧស្សាហកម្មថ្លែងថា **"តៃវ៉ាន់គួរតែស្វែងរកការរក្សាទំនាក់ទំនងប្រកបដោយស្ថេរភាពជាមួយចិន ខណៈការបន្តការពារ**

សន្តិសុខជាតិ និងជៀសវាងការធ្វើឱ្យមានភាពតានតឹងនៃសេដ្ឋកិច្ចតៃវ៉ាន់" (63)។ អ្នកផ្សេងទៀតលើកឡើងថា ចំណងសេដ្ឋកិច្ចជិតស្និទ្ធរវាង កោះតៃវ៉ាន់ និងចិនដីគោក ដើម្បីជៀសវាងការធ្វើអន្តរាគមន៍យោធាពីPLA ដើម្បីប្រឆាំងនឹងតៃវ៉ាន់។ កិច្ចអន្តរាគមន៍ណាមួយនឹងនាំឱ្យខូចខាតផលប្រយោជន៍ធំ ពិសេសប្រយោជន៍សេដ្ឋកិច្ច ហើយទំនងជាមានលទ្ធភាពកើតឡើងតិច(64)។ យោងតាមក្រសួងហិរញ្ញវត្ថុតៃវ៉ាន់ឱ្យដឹងថា ពាណិជ្ជកម្មសរុបរបស់កោះតៃវ៉ាន់ក្នុងឆ្នាំ២០១០ បានកើនឡើងដល់៥២៦,០៤ពាន់លានដុល្លារ។ ការនាំចេញ និងនាំចូលទាំងពីរសម្រាប់ឆ្នាំនេះបានកើនឡើងដល់កម្រិតខ្ពស់បំផុតមានចំនួនសរុប២៧៤,៦៤ពាន់លានដុល្លារ និង ២៥១,៤ពាន់លានដុល្លារ(65)។ ក្នុងឆ្នាំ២០០១ វិស័យកសិកម្មបានត្រឹមតែ ២%នៃផលិតផលក្នុងស្រុកសរុប(GDP)ធ្លាក់ចុះពី៣៥% ក្នុងឆ្នាំ១៩៥២ (66)។ ឧស្សាហកម្មដែលប្រើប្រាស់កម្លាំងពលកម្មជាប្រពៃណីកំពុងតែត្រូវបានផ្លាស់ប្តូរ ទៅជាឧស្សាហកម្មបច្ចេកវិទ្យា និងមូលធនច្រើន។ តំបន់ឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់បានរីកចម្រើននៅគ្រប់តំបន់ទាំងអស់នៅតៃវ៉ាន់។ តៃវ៉ាន់បានក្លាយទៅជាអ្នកវិនិយោគទុនបរទេសដ៏សំខាន់នៅក្នុងសាធារណរដ្ឋប្រជាមានិតចិន ថៃ ឥណ្ឌូនេស៊ី ហ្វីលីពីន ម៉ាឡេស៊ី និងវៀតណាម(67)។ ដោយសារតែវិធីសាស្ត្រហិរញ្ញវត្ថុបែបអភិរក្ស និងភាពខ្លាំងសហគ្រិនរបស់ខ្លួន កោះតៃវ៉ាន់បានទទួលរងផលប៉ះពាល់តិចតួចពីវិបត្តិហិរញ្ញវត្ថុអាស៊ីកើតឡើងនៅឆ្នាំ១៩៩៧ បើប្រៀបធៀបនឹងប្រទេសជិតខាងជាច្រើនរបស់ខ្លួន។ មិនដូចអ្នកជិតខាងរបស់ខ្លួនដូចជា៖ កូរ៉េខាងត្បូង និងជប៉ុនទេ សេដ្ឋកិច្ចតៃវ៉ាន់គ្របដណ្តប់ដោយអាជីវកម្មខ្នាតតូច និងមធ្យមជាជាងក្រុមជំនួញធំៗ។ ទោះជាយ៉ាងណាការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោករួមជាមួយនឹងការសម្របសម្រួលគោលនយោបាយមិនល្អដោយរដ្ឋបាលថ្មី និងបង្កើនបំណុលអាក្រក់(bad debts) ក្នុងប្រព័ន្ធធនាគារបានជំរុញឱ្យកោះតៃវ៉ាន់ធ្លាក់ចូលក្នុងវិបត្តិសេដ្ឋកិច្ចឆ្នាំ២០០១ ដែលជាឆ្នាំដំបូងនៃកំណើនអវិជ្ជមានចាប់តាំងពីឆ្នាំ១៩៤៧មក។ ដោយសារការផ្លាស់ប្តូរទីតាំងឧស្សាហកម្ម

ផលិតកម្ម និងឧស្សាហកម្មដែលប្រើកម្លាំងពលកម្មច្រើនទៅសាធារណរដ្ឋប្រជាមានិតចិន ភាពអត់ការងារធ្វើក៏បានឈានដល់កម្រិតមួយដែលមិនធ្លាប់ឃើញចាប់តាំងពីវិបត្តិប្រេងនៅឆ្នាំ១៩៧០។ បញ្ហានេះបានក្លាយជាបញ្ហាសំខាន់មួយនៅក្នុងការបោះឆ្នោតប្រធានាធិបតីឆ្នាំ២០០៤។ កំណើនជាមធ្យមមានច្រើនជាង៤%ក្នុងអំឡុងឆ្នាំ២០០២-២០០៦ ហើយអត្រាអត់ការងារធ្វើបានធ្លាក់ចុះក្រោយ៤%[68]។ តៃវ៉ាន់ជាញឹកញាប់ចូលរួមជាមួយអង្គការអន្តរជាតិ (ជាពិសេសអង្គការមួយដែលមានការចូលរួមពីសំណាក់សាធារណរដ្ឋប្រជាមានិតចិន) ក្រោមឈ្មោះនយោបាយអព្យាក្រឹត្យ។ តៃវ៉ាន់បានក្លាយជាសមាជិកនៃអង្គការពាណិជ្ជកម្មរដ្ឋាភិបាល ដូចជាអង្គការពាណិជ្ជកម្មពិភពលោកក្រោមឈ្មោះដែនដីពន្ធគយដាច់ដោយឡែកពីតៃវ៉ាន់ Penghu, Kinmen, Matsu (ចិនតៃប៉ិ)តាំងពីឆ្នាំ២០០២[69]។ នៅពេលសេដ្ឋកិច្ចតៃវ៉ាន់មានមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទីផ្សារការងារទាមទារឱ្យមានមនុស្សដែលទទួលបាននូវការអប់រំខ្ពស់ជាងមុនជាពិសេសទាក់ទងទៅនឹងវិទ្យាសាស្ត្រ និងវិស្វកម្មដើម្បីទទួលបាននូវការប្រកួតប្រជែងនៅពេលស្វែងរកការងារ។ ក្រោយពីសិក្សាពីស្ថានភាពសង្គម សេដ្ឋកិច្ច និងនយោបាយកោះតៃវ៉ាន់ខាងក្រោម យើងនឹងសិក្សាលម្អិតពីប្រព័ន្ធអប់រំតៃវ៉ាន់ និងទំនាក់ទំនងរបស់វាជាមួយនឹងកិច្ចការអភិវឌ្ឍសេដ្ឋកិច្ចជាតិតៃវ៉ាន់។

## 3.2) ប្រព័ន្ធអប់រំតៃវ៉ាន់

ប្រព័ន្ធអប់រំតៃវ៉ាន់លេចរូបរាងច្បាស់លាស់ក្នុងអំឡុងពេលអាណានិគមជប៉ុន។ ប្រព័ន្ធអប់រំនេះ មានការផ្លាស់ប្តូរវិញ បន្ទាប់ពីអធិរាជជប៉ុនចាញ់សង្គ្រាមលោកលើកទី២ ឆ្នាំ១៩៤៥ ហើយសាធារណៈរដ្ឋចិនចូលកាន់កាប់តៃវ៉ាន់ ដោយដាក់ជំនួសប្រព័ន្ធអប់រំថ្មីដែលមានលក្ខណៈដូចគ្នាទៅនឹងចិនដីគោក ដែលជាល្បាយប្រព័ន្ធអប់រំចិន និងអាមេរិច[70]។ ជាទូទៅ កោះតៃវ៉ាន់ត្រូវបានគេស្គាល់ថា ជាកោះដែលប្រកាន់ភ្ជាប់នូវទ្រឹស្តី**ខុង**

**ជីនិយម** ដែលជាលទ្ធិឱ្យតម្លៃខ្ពស់បំផុតដល់ការអប់រំ និងត្រូវបានចាត់ទុកថាជាមធ្យោបាយដើម្បីកែលម្អជំហារសេដ្ឋកិច្ច-សង្គមរបស់ប្រជាជននៅក្នុងសង្គមតៃវ៉ាន់(71)។ ការវិនិយោគយ៉ាងសម្បើម និងគុណតម្លៃវប្បធម៌ចំពោះការអប់រំបានធ្វើឱ្យដែនកោះមួយនេះឈរលើចំណាត់ថ្នាក់ខ្ពស់ផ្នែកអប់រំកម្រិតពិភពលោក។ តៃវ៉ាន់គឺជាដែនកោះមួយក្នុងចំណោមប្រទេសទាំងឡាយដែលមានដំណើរការល្អបំផុតផ្នែកសមត្ថភាពអាន គណិតវិទ្យា និងវិទ្យាសាស្ត្រ។ នៅឆ្នាំ២០១៥ និស្សិតតៃវ៉ាន់ទទួលបានលទ្ធផលល្អបំផុតលើមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងអក្ខរកម្ម (សមត្ថភាពអាន) តាមរយៈកម្មវិធីវាយតម្លៃសិស្សនិស្សិតអន្តរជាតិ(PISA) ដែលជាការវាយតម្លៃទូទាំងពិភពលោកលើសិស្សសាលាអាយុ១៥ឆ្នាំ(72)។ សង្គមតៃវ៉ាន់ឱ្យតម្លៃខ្លាំងណាស់លើទ្រឹស្តី**ខុងជឺ** ដែលជំរុញឱ្យមនុស្សស្វះស្វែងរកចំណេះវិជ្ជា និងអភិវឌ្ឍន៍បញ្ញាណាណ ហើយឥទ្ធិពលនេះសាបព្រោះយ៉ាងស៊ីជម្រៅដល់មាតាបិតាអាណាព្យាបាលសិស្ស ថ្នាក់ដឹកនាំ និងសិស្ស-និស្សិតទូទាំងប្រទេស។ ដោយសារការខិតខំប្រឹងប្រែងសិក្សារៀនសូត្ររបស់សិស្ស-និស្សិតតៃវ៉ាន់នេះ វាបានជំរុញឱ្យប្រទេសជាតិមួយនេះ មានកម្លាំងពលកម្មដែលមានកម្រិតអប់រំខ្ពស់ច្រើនលើសលុប ពោរពេញទៅដោយសមត្ថភាពផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រដើម្បីដោះស្រាយតម្រូវការទីផ្សារការងារនាសតវត្សរ៍ទី២១(73)។ ប្រព័ន្ធអប់រំតៃវ៉ាន់ទទួលបានការកោតសរសើរជាខ្លាំងលើលទ្ធផលតេស្តខ្ពស់របស់ខ្លួន និងតួនាទីដ៏សំខាន់របស់វាក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចតៃវ៉ាន់ឱ្យមានការរីកចម្រើនខ្លាំង តាមរយៈការផលិតមូលធនមនុស្សប្រកបដោយសមត្ថភាព និងមានកម្រិតអប់រំខ្ពស់បំផុតនៅក្នុងពិភពលោក(74)-(75)។ កោះមួយនេះក៏ទទួលបានការកោតសរសើរផងដែរចំពោះអត្រាចូលរៀននៅសកលវិទ្យាល័យបានកើនឡើងពីចំនួនប្រមាណ ២០% នៅមុនទសវត្សរ៍ឆ្នាំ១៩៧០ ដល់៤៩%នៅឆ្នាំ១៩៩៦ និងជាង៩០ %ចាប់តាំងពីឆ្នាំ២០០៦ ក្នុងចំណោមអត្រាខ្ពស់បំផុតនៅអាស៊ី(76)។ ប្រជាពលរដ្ឋតៃវ៉ាន់អាយុ២៥ដល់៦៤ឆ្នាំ ចំនួន៤៥%មានសញ្ញាបត្រឧត្តមសិក្សា

ខ្ពស់ជាងប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀតដែលសមាជិកអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍(OECD) ដែលមានត្រឹមតែ៣៣% [77]។ ប្រព័ន្ធអប់រំតៃវ៉ាន់មាន៦ឆ្នាំនៅថ្នាក់សាលាបឋមសិក្សា ៣ឆ្នាំនៅអនុវិទ្យាល័យ និង៣ឆ្នាំទៀតនៅវិទ្យាល័យ ហើយ៤ឆ្នាំនៅថ្នាក់ឧត្តមសិក្សា។ រយៈពេលសិក្សា៩ឆ្នាំដំបូង ត្រូវកំណត់ជាកាតព្វកិច្ចចាប់តាំងពីឆ្នាំ១៩៦៨ ហើយបានពង្រីករហូតដល់១២ឆ្នាំនៅរដូវស្លឹកឈើជ្រុះឆ្នាំ២០១៤ថ្មីៗនេះ។ វាគួរឱ្យកត់សម្គាល់ផងដែរសម្រាប់តៃវ៉ាន់ ដែលការចូលរៀននៅកម្រិតមធ្យមសិក្សាត្រូវបានគេចាត់ទុកថា ជាដំណាក់កាលដ៏លំបាកបំផុតមួយនៅក្នុងជីវិតសិក្សារបស់សិស្សតៃវ៉ាន់ដែលត្រូវហែលឆ្លងកាត់។ ហេតុផលនៃភាពលំបាកនោះគឺថា ទោះ បីជាតៃវ៉ាន់មានការអប់រំជាកាតព្វកិច្ច៩ឆ្នាំក៏ដោយ សិស្សានុសិស្សត្រូវព្យាយាមសិក្សារៀនសូត្រខ្លាំងក្លាដើម្បីប្រឡងចូលរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិ(វិទ្យាល័យ) ឬវិទ្យាល័យវិជ្ជាជីវៈ ហើយមានតែសិស្សដែលប្រឡងជាប់ និងមានសមត្ថភាពពេញលេញទេ ទើបអាចចូលរៀននៅកម្រិតវិទ្យាល័យនេះបាន។ ទម្រង់លក្ខណៈដដែលបែបនេះត្រូវអនុវត្តជាថ្មីម្តងទៀត មុនពេលចូលរៀននៅសាកលវិទ្យាល័យ ឬមហាវិទ្យាល័យ។ ការត្រៀមលក្ខណៈសម្រាប់ការប្រឡងចូលគឺជា ប្រភពដ៏សំខាន់នៃការដាក់សម្ពាធធ្ងន់ធ្ងរលើការសិក្សា។ ដើម្បីទទួលបានពិន្ទុខ្ពស់នៅក្នុងការប្រឡងចូលរៀននៅវិទ្យាល័យ ឬសកលវិទ្យាល័យនៅចុងបញ្ចប់នៃថ្នាក់ទី៩ និងទី១២ និស្សិតមានទំនោរស្វែងរកសេវារៀនក្រៅម៉ោង"**ថ្នាក់រៀនគួរបន្ថែម**" រហូតដល់ម៉ោង៨ ឬ៩យប់។ វាច្បាស់ណាស់ថា ប្រព័ន្ធអប់រំបែបនេះគឺជាភ្នាក់ងារសង្គមដ៏សំខាន់មួយសម្រាប់យុវវ័យតៃវ៉ាន់។ ដូចនិស្សិតនៅអាស៊ីជាច្រើនដែរ សិស្សតៃវ៉ាន់ចំណាយពេលវេលាច្រើននៅក្នុងសាលារៀន ពេលខ្លះចាប់ផ្តើមតាំងពីវ័យកុមារភាពរហូតដល់អាយុ២០ឆ្នាំ។ ការសិក្សាច្រើនម៉ោងនៅសាលារៀន *តំណាងឱ្យទស្សនវិជ្ជាអប់រំអាស៊ី* ដែលឱ្យតម្លៃខ្លាំងលើរយៈពេលសិក្សាយូរក្នុងមួយថ្ងៃៗ ឬមួយឆ្នាំសិក្សា ហើយការបង្កើនពេលវេលានេះនៅទីបំផុតវានាំមកនូវភាពជោគជ័យនៃលទ្ធផល

សិក្សា និងទទួលបានពិន្ទុប្រឡងខ្ពស់(78)។ ដូច្នេះ វាគ្មានអ្វីចម្លែកទេដែលសិស្សតៃវ៉ាន់ទទួលបានមេដាយមាសច្រើនក្នុងការប្រឡងអូឡាំព្យ៉ាតអន្តរជាតិផ្នែកវិទ្យាសាស្ត្រសម្រាប់សិស្សមធ្យមសិក្សាបឋមភូមិអាយុក្រោម១៥ឆ្នាំ។ សិស្សតៃវ៉ាន់ចំណាយពេលច្រើនម៉ោងក្នុងការហ្វឹកហាត់អនុវត្តលំហាត់ និងធ្វើការពិសោធនផ្ទាល់ ធ្វើឱ្យសមត្ថភាពការគិតក្នុងការដោះស្រាយបញ្ហាបានលឿន និងរហ័សដែលជាគន្លឹះដ៏សំខាន់ក្នុងការទទួលជោគជ័យពេលប្រឡងអូឡាំព្យ៉ាតអន្តរជាតិ ពិសេសមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ។ ចំណុចមួយទៀត នៅតៃវ៉ាន់ក៏ដូចជានៅក្នុងសង្គមអាស៊ីដទៃទៀតដែរ ឪពុកម្តាយបានវិនិយោគច្រើនលើប្រាក់សន្សំរបស់ពួកគេទៅលើការអប់រំរបស់កូនៗខ្លួន មិនថាចំណាយសាលារៀនគួរក្រៅម៉ោង បង់ថ្លៃសិក្សាថ្នាក់រៀនគួរ ឬសាលាឯកជន ព្រមទាំងសកម្មភាពក្រៅម៉ោងសិក្សា។ ដូច្នេះស្ថានភាពសង្គម និងសេដ្ឋកិច្ចគ្រួសារកាន់តែខ្ពស់ ការរំពឹងទុកខាងការអប់រំក៏ខ្ពស់ដែរ(79)។ យោងតាមលោក Stevenson និង Baker( ១៩៩២) បានបង្ហាញពីភាពផ្សេងគ្នារវាងនិស្សិតជប៉ុន និងតៃវ៉ាន់លើលទ្ធភាពទទួលបានការសិក្សា។ នៅជប៉ុន និស្សិតមានឱកាសច្រើនក្នុងការចូលរៀននៅសកលវិទ្យាល័យ ប្រសិនបើពួកគេមានសាវតារផ្ទាល់ខ្លួនស្ថិតក្នុងលក្ខណៈវិនិច្ឆ័យទទួលបានសិទ្ធិអនុគ្រោះ (ឧ.មានពិការភាព ឬគ្រួសារមានប្រាក់ចំណូលទាប...) ព្រមទាំងទទួលបានការរៀនបន្ថែមក្រៅម៉ោងច្រើនទៀត។ សម្រាប់តៃវ៉ាន់វិញ ប្រើប្រាស់ធនធានរបស់គ្រួសារសុទ្ធ រួមទាំងការចំណាយលើការអប់រំបន្ថែមក្រៅម៉ោង ធនធានសម្រាប់ការគាំទ្រ និងពង្រឹងលទ្ធភាពទទួលបានការអប់រំជាន់ខ្ពស់របស់សិស្ស(80)។ សាលាបង្រៀនគួរក្រៅម៉ោង ឬបំប៉នបន្ថែមក្រៅម៉ោង (Cram schools) " ជាការអប់រំមិនផ្លូវការ និងត្រូវបានគេចាត់ទុកថា ជាការ"**អប់រំស្រមោល**" ដែលអនុវត្តសម្រាប់ការត្រៀមប្រឡង(81) ។ យោងទៅតាមការស្ទង់មតិមួយបង្ហាញថា ជាមធ្យមសិស្សវិទ្យាល័យចំណាយពេលពាក់កណ្តាលថ្ងៃរបស់ពួកគេ (ប្រមាណ១២ម៉ោង) រៀននៅសាលារដ្ឋ និងរៀនសាលាគួរក្រៅម៉ោង(82)។

សិស្សវិទ្យាល័យភាគច្រើនចូលរួមសកម្មភាពទាក់ទងនឹងសាលារៀន (រួមទាំងការរៀបចំប្រឡង) ដោយចំណាយពេលវេលាជីវិតផ្ទាល់ខ្លួន(83)។ សិស្ស៨៥%ដែលបានចុះឈ្មោះចូលរៀនសាលារៀនគួរក្រៅម៉ោងគឺមកពីសាលាបឋមសិក្សា និងមធ្យមសិក្សា។

## តើសាលារៀនគួរក្រៅម៉ោងជួយកែលម្អការអប់រំ ឬគ្រាន់តែជាការស្វែងរកប្រាក់ចំណេញ?

ចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៩០ មកក្រសួងអប់រំតៃវ៉ាន់ (MOE)បានចាប់ផ្ដើមកម្មវិធីកំណែទម្រង់អប់រំជាបន្តបន្ទាប់ដើម្បីកាត់បន្ថយសម្ពាធនៃការប្រឡងប្រជែង និងបង្កើនភាពច្នៃប្រឌិតរបស់សិស្ស-និស្សិត។ ទោះជាយ៉ាងណា ការផ្លាស់ប្ដូរទាំងនេះមិនបានជោគជ័យក្នុងការកាត់បន្ថយភាពតានតឹងរបស់សិស្សទេ ប៉ុន្តែបាននាំឱ្យមានការកើនឡើងកាន់តែច្រើននូវចំនួនសិស្សដែលចូលសាលារៀនគួរក្រៅម៉ោងទៅវិញ។ ជាក់ស្ដែង តៃវ៉ាន់មានសាលារៀនបំប៉នបន្ថែមតែ៥,៨៩១កន្លែងប៉ុណ្ណោះក្នុងឆ្នាំ២០០១ ប៉ុន្តែចំនួននេះបានកើនឡើងច្រើនជាងបីដងដោយមិននឹកស្មានដល់ ក្នុងរយៈពេលមួយទសវត្សរ៍ដោយ៨០%ផ្ដោតទៅលើថ្នាក់រៀនសម្រាប់មុខវិជ្ជាប្រឡងប្រជែង(ផ្អែកតាមរបាយការណ៍ការិយាល័យព័ត៌មានរដ្ឋាភិបាលឆ្នាំ២០១០)។ សាលារៀនបំប៉នក្រៅម៉ោងតៃវ៉ាន់កំពុងរីកសាយភាយដែលចំនួនសាលារៀនដ៏ច្រើននេះត្រូវបានកំណត់តាមតម្រូវការទីផ្សារ។ ដូច្នេះ តម្រូវការរបស់សាធារណជនទូទៅកាន់តែខ្ពស់ ឱកាសកាន់តែច្រើនសម្រាប់ភាពជោគជ័យរបស់សាលារៀនបំប៉នបន្ថែមទាំងនេះ។ នេះបង្ហាញពីតម្រូវការដ៏លើសលុបរបស់សិស្សតៃវ៉ាន់ចំពោះសេវាកម្មសាលាបំប៉នក្រៅម៉ោង (និន្នាការសង្គមដែលផ្ដោតលើចំណេះដឹងជាមូលដ្ឋាន) ហើយការផ្គត់ផ្គង់(សាលារៀនឯកជន) ក៏រីកចម្រើនតាមនឹងដែរ ដូច្នេះស្ថិតក្នុងស្ថានភាពនេះ តៃវ៉ាន់មិនអាចបង្កើតគោលនយោបាយដើម្បី

បំផ្លាញភាពពេញចិត្ត និងតម្រូវការរបស់អតិថិជន (សិស្ស-មាតាបិតា/អាណាព្យាបាល)និងទំនោររបស់សង្គមបាននោះទេ។

**☛មូលហេតុនៅពីក្រោយសន្ទុះរីកចម្រើនខ្លាំងនៃគ្រឹះស្ថានសិក្សាបំប៉នក្រៅម៉ោងគឺមានដូចខាងក្រោម**(84)

- ការបង្រៀនបន្ថែមអាចនឹងបង្កើនការសិក្សា និងពិន្ទុសិក្សារបស់សិស្ស
- ឱ្យតម្លៃខ្លាំងហួសកម្រិតនៃការអភិវឌ្ឍសមត្ថភាព បានបង្កើតនូវសម្ពាធដ៏ធំសម្បើមមួយទៅលើការព្យាយាមសិក្សាដើម្បីការប្រឡងប្រជែង
- ឪពុកម្តាយមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះលទ្ធផលសិក្សារបស់កូនៗ របស់ពួកគេ
- សាលារៀនសាធារណៈមួយចំនួនមិនអាចបំពេញតម្រូវការសិក្សារបស់សិស្សបាន
- មានគម្លាតរវាងការសិក្សារបស់សិស្ស និងអ្វីដែលត្រូវបានធ្វើតេស្តនៅក្នុងការប្រឡងចូល (កម្រិតមធ្យមសិក្សាទុតិយភូមិ និងមហាវិទ្យាល័យ)

ទោះជាយ៉ាងណាក៏ដោយ ក្រុមតម្រង់ទិសសង្គមបានវាយតម្លៃអវិជ្ជមានចំពោះទំនោរសិក្សាគួរក្រៅម៉ោងនេះ និងផលប៉ះពាល់របស់វា។ ពួកគេយល់ឃើញថា ការដាក់សម្ពាធសិក្សាលើសិស្សដែលជាមូលហេតុនាំឱ្យលេចឡើងនូវការឱ្យតម្លៃលើសលុបលើការសិក្សាបន្ថែមទាំងនោះ។ សិស្សានុសិស្សដែលស្ថិតក្រោមសម្ពាធនៃការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវបទដ្ឋានសង្គមជាច្រើន ការលេចឡើងនូវការប៉ាន់ស្មានហួសប្រមាណនូវគុណតម្លៃលើសាលារៀនបំប៉នក្រៅម៉ោងសម្រាប់ភាពជោគជ័យ ដូច្នេះវាធ្វើឱ្យសិស្សដទៃទៀតដើរតាមដោយភាពងងឹតងងុល និងនាំឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ។ ជាទូទៅ ឪពុកម្តាយតៃវ៉ាន់ចំណាយប្រាក់ប្រហែល ២,៦៤០ដុល្លារតៃវ៉ាន់(=៨០ដុល្លារអាមេរិក) ជាមធ្យមសម្រាប់មួយមុខវិជ្ជា

ក្នុងមួយខែដើម្បីឱ្យកូនរបស់ពួកគេចូលរៀននៅសាលារៀនបំប៉នបន្ថែមក្រៅម៉ោង។ ថ្លៃទាំងនេះអាចនឹងកើនឡើងដល់៧,៩២០ដុល្លារតៃវ៉ាន់(=២៤០ដុល្លារអាមេរិក) ក្នុងមួយខែ ដែលករណីនេះបានបន្ថែមបន្ទុកហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរដល់គ្រួសារនៅតៃវ៉ាន់[85]។ ដោយសារតែការជឿទុកចិត្តលើការអប់រំរបស់តៃវ៉ាន់ គ្មានអ្វីគួរឱ្យសង្ស័យទេដែល**ការអប់រំស្រមោល** ឬសាលាបង្រៀនគួរបន្ថែមក្រៅម៉ោងនេះ។ ការរីករាលដាលនៃសាលាបំប៉ននេះ បានបង្កើតបញ្ហាប្រឈមដល់ថ្នាក់ដឹកនាំ និងគ្រប់គ្រអប់រំ និងឪពុកម្តាយដែលមានបានសម្តែងអារម្មណ៍លាយឡំគ្នា អំពីឧស្សាហកម្មអប់រំដែលរកប្រាក់ចំណេញនេះ។ ប្រសិនបើ សាលារៀនបំប៉នក្រៅម៉ោងនៅតែមានអត្ថិភាព និងដំណើរការជាទូទៅបែបនេះ នាំឱ្យមានសំណួរចោទសួរ*ពីតួនាទីសាលារៀនរដ្ឋក្នុងការបំពេញសេចក្តីត្រូវការសិក្សារៀនសូត្ររបស់សិស្សានុសិស្ស។ ថាតើ វាមកពីសាលារៀនសាធារណៈ(រដ្ឋ) មិនអាចបំពេញសេចក្តីត្រូវការសិក្សារបស់សិស្សមែនទេ ដែលធ្វើឱ្យពួកគេស្វះស្វែងរកសេវាបន្ថែមខាងក្រៅបែបនេះ?* ឪពុកម្តាយមានបន្ទុកធ្ងន់ធ្ងរត្រូវដោយត្រូវចំណាយលុយច្រើនសម្រាប់សាលារៀនឯកជនទាំងនេះ។ ប្រសិនបើវត្តមានសាលារៀនគួរក្រៅម៉ោងទាំងនេះនៅតែមានអត្ថិភាពដោយជៀសមិនរួច **តើគុណភាពសាលារដ្ឋអាចត្រូវបានកែលម្អដោយរបៀបណា?** តើសម្ពាធនៃការប្រឡងប្រជែងចូលរៀនរបស់សិស្ស អាចត្រូវបានកាត់បន្ថយដោយរបៀបណា? តើឪពុកម្តាយអាចជឿជាក់ថាកូនៗរបស់ពួកគេមិនគួរត្រូវបានដាក់កំហិតឱ្យសិក្សាហួសកម្រិត និងអាចពូកែនៅក្នុងវិស័យផ្សេងទៀតដោយរបៀបណា? ទាក់ទងនឹងបញ្ហានេះ ***សម្រាប់ប្រទេសកម្ពុជា*** ការបង្រៀនគួរក្រៅម៉ោងនេះក៏កើតឡើងយ៉ាងផុលផុសផងដែរ ហើយពិតណាស់ វាបណ្តាលមកពីសាលារៀនរដ្ឋមិនអាចបំពេញសេចក្តីត្រូវការសិក្សារបស់សិស្សបាន ហើយស្ថានភាពមានលក្ខណៈប្រហាក់ប្រហែលនឹងតៃវ៉ាន់ដែរ តែសម្រាប់កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍មានផលប៉ះពាល់ច្រើនជាងពិសេសទាក់ទងនឹងសេដ្ឋកិច្ចគ្រួសារដែលមានជីវភាពក្រីក្រ។ ជាការពិត

ការបង្រៀនគួរក្រៅម៉ោងនៅកម្ពុជាមានលក្ខណៈខុសគ្នាបន្តិចពីតៃវ៉ាន់ ដោយសារតៃវ៉ាន់មានសាលាឯកជន( private school) ដែលបើកសម្រាប់បង្រៀនគួរបន្ថែមដល់សិស្ស ហើយបើកតែក្រៅម៉ោងសិក្សា ចំណែកឯកម្ពុជា គ្រូបង្រៀននៅតាមសាលារៀនបើកបង្រៀនគួបន្ថែមដោយផ្ទាល់ និងមានសាលាឯកជនបំប៉នក្រៅម៉ោងតិចតួចប៉ុណ្ណោះ ដោយមានតែនៅតាមទីក្រុងធំដូចទីក្រុងភ្នំពេញជាដើម។ ការបើកបង្រៀនគួរគឺនៅចន្លោះម៉ោងសម្រាក និងក្រៅម៉ោងសិក្សារបស់សិស្ស ដែលវាជះខ្លាំងដល់ប្រសិទ្ធភាព និងគុណភាពនៃលទ្ធផលសិក្សារបស់សិស្ស។ សម្រាប់កម្ពុជា ការរៀនគួរក្រៅម៉ោងបែបនេះ ផ្តល់នូវគុណសម្បត្តិផង និងគុណវិបត្តិផង ហើយស្ថានភាពនេះ បង្ហាញពីភាពអវិជ្ជមានច្រើនជាងការរៀនគួរក្រៅម៉ោងនៅតៃវ៉ាន់ដែលរៀននៅតែសាលាឯកជនប៉ុណ្ណោះ។ រហូតមកដល់ពេលនេះ មិនទាន់មានការសិក្សាច្បាស់លាស់នៅឡើយទេទាក់ទងនឹងបញ្ហាខាងលើ ហើយពេលនេះ យើងសាកល្បងធ្វើការសិក្សាពីផលប៉ះពាល់នៃការបង្រៀនគួរនេះតាមរយៈការសង្កេតទូទៅ និងបទពិសោធការងារ១៦ឆ្នាំនៅក្នុងវិស័យអប់រំកម្ពុជាកន្លងមក។ ដោយសារប្រទេសកម្ពុជាមានអត្រាគ្រួសារក្រីក្រនៅខ្ពស់នៅឡើយ ដូច្នេះទិដ្ឋភាពនៃការបង្រៀនគួរក្រៅម៉ោងនេះ នាំឱ្យមានបញ្ហាចោទទៅលើសមធម៌នៃការចូលរៀនរបស់កុមារ និងការចំណាយក្រៅផ្លូវការច្រើនដែលជាឧបសគ្គដល់ការសិក្សា ពិសេសសម្រាប់សិស្ស និងគ្រួសារក្រីក្រទាំងនោះ។ ដោយហេតុផលគ្រូបង្រៀនមានប្រាក់បៀវត្សទាបនៅឡើយ បើប្រៀបធៀបជាមួយប្រទេសទាំងឡាយនៅក្នុងតំបន់ លោកគ្រូ-អ្នកគ្រូបង្រៀនមួយចំនួនបានបង្កើតការបង្រៀនគួរក្រៅម៉ោង និងការគៀបសិស្សតាមមធ្យោបាយផ្សេងៗដើម្បីប្រាក់ចំណូលបន្ថែម។ ជាការពិត យើងទទួលស្គាល់ថា ការបង្រៀនគួរនេះផ្តល់ផលល្អច្រើនដល់ការលើកកម្ពស់គុណភាពអប់រំ តែទន្ទឹមនឹងចំណុចវិជ្ជមានដ៏ច្រើននេះ វាក៏ផ្តល់ចំណុចអវិជ្ជមានជាច្រើនផងដែរសម្រាប់បរិបទប្រទេសកម្ពុជា។ ខាងក្រោមនេះ យើងនឹងសាកល្បងបង្ហាញពីចំណុចអវិជ្ជមាននៃការបង្រៀនគួររបស់លោកគ្រូ-អ្នក

គ្រូដូចខាងក្រោម។ ការបង្រៀនគួរក្រៅម៉ោងហាក់មិនបានផ្ដល់ភាពចំណេញច្រើនដល់សិស្សានុសិស្សប៉ុន្មានទេ បើវាត្រូវបានប្រើប្រាស់ប្រាសចាកពីស្មារតីការអប់រំប្រកបបរិយាប័ន្ននោះ ពោលគឺមិនមានការអនុគ្រោះច្រើនដល់សិស្សដែលងាយរងគ្រោះ (ឧ.ក្រីក្រ កំព្រា ពិការ ឬជនជាតិភាគតិច...)។ ក្នុងករណីប្រើប្រាស់មិនបានត្រឹមត្រូវ និងច្បាស់លាស់ វានឹងបង្កើនបន្ថែមម៉ោងសិក្សាដល់សិស្សច្រើនលើសកំណត់ និងធ្វើឱ្យសិស្សមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការសិក្សាស្រាវជ្រាវ រៀនសូត្រ និងអនុវត្តលំហាត់ដោយខ្លួនឯង ពិសេសគឺប៉ះពាល់ដល់សុខភាពសិក្សារបស់សិស្ស។ មួយវិញទៀត តាមរយៈការបង្រៀនគួរក្រៅម៉ោងនេះ វាអាចឱ្យគ្រូបង្រៀនបែកបាក់ផ្ទៃក្នុងព្រោះទំនាស់ផលប្រយោជន៍ និងភាពច្រណែនគ្នាក្នុងចំណោមគ្រូបង្រៀនគ្នាឯង និងថ្នាក់ដឹកនាំសាលារៀន ពិសេសការអនុវត្តដោយមិនមានមនសិការវិជ្ជាជីវៈរឹងមាំនៅក្នុងម៉ោងសិក្សារដ្ឋ ឬបង្រៀនសិស្សមិនអស់សមត្ថភាព និងច្បាស់លាស់ដោយលាក់ទុកល្បិច ឬគន្លឹះសំខាន់សម្រាប់ការបង្រៀនក្រៅម៉ោង។ នៅក្នុងម៉ោងសិក្សានៅសាលារៀនគ្រូបង្រៀនមិនសូវពន្យល់ក្បោះក្បាយឱ្យសិស្សយល់ដូចនៅថ្នាក់គួរឡើយ ហើយវាស្ទើរតែជាទូទៅទៅហើយដែលយើងសង្កេតឃើញថា គ្រូបង្រៀនយកចិត្តទុកដាក់បង្រៀនសិស្សតែនៅថ្នាក់គួរក្រៅម៉ោងជាជាងបង្រៀននៅក្នុងម៉ោងសិក្សារដ្ឋ។ ចំណុចសំខាន់មួយទៀត ការបង្រៀនគួរនេះ វាអាចធ្វើឱ្យមានភាពអយុត្តិធម៌ក្នុងការដាក់ពិន្ទុសិស្ស។ ពិតណាស់ លោកគ្រូ-អ្នកគ្រូមួយចំនួនធំនឹងបង្ហាញភាពលម្អៀងទៅលើសិស្សដែលរៀនគួរជាមួយខ្លួនដើម្បីរក្សាផលប្រយោជន៍ដែលខ្លួនទទួលបានពីសិស្ស ដែលអាចឱ្យសិស្សដទៃទៀតបាក់ទឹកចិត្ត ហើយលទ្ធផលសិក្សាធ្លាក់ចុះ។ ម្យ៉ាងទៀត ការបង្រៀនគួរនេះ ធ្វើឱ្យសិស្សមានទម្លាប់មិនល្អ មិនយកចិត្តទុកដាក់លើការសិក្សារៀនសូត្រ និងមិនពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ដើម្បីអភិវឌ្ឍន៍ចំណេះដឹង និងបំណិន ហើយសម្លឹងឃើញគុណសម្បត្តិរបស់លុយក្នុងដំណើរការបង្រៀន និងរៀនទៅវិញ ពិសេសគឺឥទ្ធិពលដ៏លើសលុបរបស់វា

ទៅលើដំណើរជីវិតរបស់ពួកគាត់។ លើសពីនេះទៅទៀត វាបង្កើតជាវប្បធម៌ចំណាយប្រាក់ក្នុងការសិក្សា បើទោះបីការចុះឈ្មោះចូលរៀនមិនបង់ប្រាក់ក៏ដោយក៏ការចំណាយក្នុងការរៀនសូត្រសម្រាប់សិស្សពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើង (មន្ត្រីអប់រំអាចបង្កើតឧបករ-ណ៍Survey បានដើម្បីបញ្ជាក់ភស្តុតាងពីបញ្ហានេះ)។ ករណីនេះ នៅពេលវាលដាលធំទៅៗ វាបង្កើតជារនាំងឧបសគ្គសម្រាប់គ្រួសារក្រីក្រ នាំទៅរកការបាក់ទឹកចិត្ត និងបាត់បង់ជំនឿលើការសិក្សា ឧទាហរណ៍ការឱ្យកូនឈប់រៀនទៅធ្វើការងាររោងចក្រជាដើម...។ ផលវិបាកមួយទៀត គឺវាធ្វើឱ្យសិស្សអសកម្ម មិនឱ្យតម្លៃការសិក្សា និងចេះពុករលួកសួកប៉ាន់។ ចំណុចពិសេសមួយទៀត វាធ្វើឱ្យប៉ះពាល់ដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀនតាមរយៈការធ្វើការជាក្រុម ដោយសារគ្រូដែលមានសមត្ថភាព និងបទពិសោធន៍ច្រើន មិនមានស្មារតីចែករំលែកដល់គ្រូផ្សេងៗទៀត ដោយលាក់ទុកល្បិច ឬវិធីសាស្ត្របង្រៀនល្អៗរបស់ខ្លួនក្នុងការទាក់ទាញសិស្សឱ្យរៀនគួរជាមួយខ្លួន ដើម្បីទទួលបានចំណូលច្រើន។ ទាក់ទងនឹងបញ្ហានេះ កម្ពុជាគប្បីស្វែងយល់ឱ្យបានច្បាស់ពីយុទ្ធសាស្ត្រអនុវត្តរបស់តៃវ៉ាន់ក្នុងការបង្កើនគុណភាព និងប្រសិទ្ធភាពអប់រំ តាមរយៈការបង្កើតសាលាឯកជនសម្រាប់បង្រៀនគួរក្រៅម៉ោងនេះ ជៀសវាងការបង្រៀនគួរក្រៅម៉ោងដោយផ្ទាល់ពីសំណាក់គ្រូបង្រៀនរបស់ពួកគេដែលនាំឱ្យមានបញ្ហាប្រឈមច្រើន ពិសេសយុទ្ធសាស្ត្រដើម្បីបន្សុីទៅនឹងស្ថានភាពសេដ្ឋកិច្ច-សង្គមកម្ពុជាដែលជាមាគ៌ានាំឆ្ពោះទៅរកភាពជោគជ័យនាពេលអនាគត។

សម្រាប់ការរៀបរាប់ខាងក្រោមគឺជាចំណុចបន្ថែមទៀតទាក់ទងនឹង**ប្រព័ន្ធគ្រប់គ្រងអប់រំកោះតៃវ៉ាន់**។ នៅតៃវ៉ាន់ កាលពីមុនប្រព័ន្ធគ្រប់គ្រងអប់រំអនុវត្តបែបមជ្ឈការ និងគ្រប់គ្រងដោយរដ្ឋាភិបាលថ្នាក់ជាតិទាំងដំណើរការ និងការផ្តល់ហិរញ្ញវត្ថុគាំទ្រវិស័យអប់រំ។ តែក្រោយមកក្នុងឆ្នាំ ១៩៨០ នយោបាយ សេដ្ឋកិច្ច និងបច្ចេកវិទ្យាមានការផ្លាស់ប្តូរ ក៏ដូចជាតម្រូវការសម្រាប់ដំណើរការបែបពហុភាព និងមូលដ្ឋាននីយកម្ម បានជំរុញ

ឱ្យធ្វើការកំណែទម្រង់ជាបន្តបន្ទាប់ឆ្ពោះទៅការរកផ្ទេរអំណាចគ្រប់គ្រងអប់រំ និងភាពចម្រុះ។ បទពិសោធកំណែទម្រង់រដ្ឋាភិបាលកណ្តាល ចែករំលែកជាបណ្តើរនូវការទទួលខុសត្រូវរបស់ខ្លួន ទៅរដ្ឋបាលថ្នាក់មូលដ្ឋានសាលារៀន និងអ្នកពាក់ព័ន្ធ។ សកម្មភាពលេញធ្លោខ្លាំងនៃការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ គឺក្រោយបាតុកម្មឆ្នាំ១៩៩៤។ ពលរដ្ឋតៃវ៉ាន់បានធ្វើបាតុកម្មទាមទារឱ្យមានការកែទម្រង់ប្រព័ន្ធអប់រំនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៩៤ ក្នុងគោលបំណងដកចេញនូការគ្រប់គ្រងដែលមិនសមហេតុផល និងការបំបិទសិទ្ធិសេរីភាពលើប្រព័ន្ធអប់រំ ហើយដាក់ជំនួសនូវចលនាសេរីភាពការអប់រំសិស្សមជ្ឈមណ្ឌល។ វាជាការទាមទារឱ្យមានការផ្លាស់ប្តូរទស្សនៈគំនិតពីវិមជ្ឈការទៅបុគ្គលនីយកម្ម។ យើងអាចនិយាយបានថាពីមុនប្រព័ន្ធរដ្ឋាភិបាលពីថ្នាក់កំពូលបញ្ជាមកក្រោម(top-down)ពីថ្នាក់កណ្ដាល មកថ្នាក់មូលដ្ឋាន ពីភ្នាក់ងាររដ្ឋាភិបាលទៅសាលារៀននីមួយៗ ដោយជំនួសមកវិញនូវការផ្តល់លទ្ធភាពដល់គ្រូបង្រៀន និងសាលារៀនអាចបង្កើតការគាំទ្រការអប់រំ និងទទួលខុសត្រូវលើបញ្ហាអប់រំ។ ការផ្លាស់ប្តូរដ៏សំខាន់មួយនៃការអប់រំតៃវ៉ាន់បន្ទាប់បាតុកម្ម គឺការចងក្រង និងបោះពុម្ពសៀវភៅសិក្សាគោលសម្រាប់ប្រើប្រាស់នៅតាមសាលាបឋមសិក្សានិងមធ្យមសិក្សា។ កាលពីមុនវាស្ថិតក្រោមអំណាចផ្តាច់មុខរបស់រដ្ឋាភិបាលកណ្តាលក្នុងចងក្រង និងបោះពុម្ពសៀវភៅ តែឥឡូវម៉ាស៊ីនបោះពុម្ពឯកជនត្រូវបានអនុញ្ញាតឱ្យចងក្រងសៀវភៅសិក្សាគោលចេញពីធនធានផ្ទាល់ខ្លួន និងបោះពុម្ពបន្ទាប់ពីមានការអនុម័តយល់ព្រមពីអ្នកជំនាញ។ ការសម្រេចចិត្តក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលឥឡូវស្ថិតក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការដែលមានសមាសភាពគ្រូបង្រៀននៅតាមសាលានីមួយៗ។ គ្រូបង្រៀនក៏អាចសរសេរ និងចងក្រងសម្ភារៈបង្រៀនផ្ទាល់ខ្លួនដើម្បីឆ្លើយតបទៅនឹងតម្រូវការដោយឡែកៗរបស់ពួកគេ។ វាជារបត់ជាប្រវត្តិសាស្ត្រនៃ ការអភិវឌ្ឍប្រព័ន្ធ អប់រំនៅតៃវ៉ាន់(៨៦) ។ សម្រាប់កម្ពុជា ការធ្វើកំណែទម្រង់ធ្វើវិមជ្ឈការ និងវិសហមជ្ឈការប្រព័ន្ធគ្រប់គ្រងអប់រំ ដោយ

ផ្តោតដំបូងលើអនុវិស័យបីគឺ៖ **អប់រំកុមារតូច បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ** ចាប់ផ្តើមផ្ទេរទៅរដ្ឋបាលថ្នាក់ខេត្តដោយអនុវត្តសាកល្បងនៅខេត្តបាត់ដំបងនៅប៉ុន្មានឆ្នាំថ្មីៗនេះ និងមានទិសដៅអនុវត្តទូលំទូលាយនៅទូទាំងប្រទេសនាពេលខាងមុខ។ ចំណុចសំខាន់មួយទៀតសម្រាប់កម្ពុជា ការធ្វើវិមជ្ឈការអភិវឌ្ឍសៀវភៅសិក្សា និងការបោះពុម្ពផ្សាយទៅតាមតំបន់នីមួយៗតាមលំនាំតៃវ៉ាន់ ហាក់នៅឆ្ងាយ និងមិនអាចអនុវត្តបាននៅឡើយដោយសារកង្វះធនធាន( ធនធានមនុស្ស-ថវិកា-សម្ភារៈ)។

យោងតាមរបាយការណ៍ក្រសួងអប់រំតៃវ៉ាន់ឆ្នាំ១៩៩៩ តៃវ៉ាន់នឹងបង្កើនល្បឿនការធ្វើពិពិធកម្ម សេរីភាវូបនីយកម្ម និងអន្តរជាតិនីយកម្ម លើប្រព័ន្ធសាលារៀនសាធារណៈរបស់ខ្លួន។ កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនដែលបានប្រើប្រាស់នៅតាមសាលារៀនគ្រប់កម្រិតថ្នាក់ នឹងធ្វើទំនើបកម្ម ជាមួយនឹងការធ្វើឱ្យប្រសើរឡើងជាចម្បងចំពោះបរិស្ថានអប់រំ។ គោលដៅអប់រំគឺ ពង្រឹងការអនុវត្តបច្ចេកវិទ្យាកុំព្យូទ័រ ដូចជា៖ (១)៧០% នៃគ្រូមត្តេយសិក្សា គ្រូបឋមសិក្សា និងមធ្យមសិក្សា(K-12)ត្រូវមានបំណិនបច្ចេកវិទ្យាកុំព្យូទ័រមូលដ្ឋាន (២)តំលើងផ្នែកទន់( Software)និងផ្លាស់ប្តូរផ្នែករឹង( Hardware)ដែលចាស់ហួសសម័យ ដាក់ជំនួសថ្មីនៅតាមសាលាបឋមសិក្សា (៣)បន្ទប់រៀន៨០%គ្រប់កម្រិតថ្នាក់នឹងប្រើប្រាស់អ៊ីនធ័រណេតសម្រាប់ការបង្រៀន និងរៀន។ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រ គេរំពឹងថាគ្រូបង្រៀន និងសិស្សតៃវ៉ាន់អាចមានលទ្ធភាពទទួលបានព័ត៌មានពីខាងក្រៅមាននៅក្នុងសៀវភៅសិក្សាគោល(87)។ ការអប់រំជាកាតព្វកិច្ចចាប់គិតពីការអប់រំថ្នាក់បឋមសិក្សាដល់អនុវិទ្យាល័យ ដែលចាត់ទុកជា "**ការអប់រំមូលដ្ឋានជាតិ**"។ សម្រាប់កំណែទម្រង់ថ្មីៗ បានដាក់កម្រិតថ្នាក់វិទ្យាល័យចូលទៅក្នុងការអប់រំមូលដ្ឋានជាតិដែលជាមធ្យោបាយបើកចំហលទ្ធភាពទទួលបានការសិក្សាកាន់តែច្រើនសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ។ ការអប់រំនៅវិទ្យាល័យមិនមែនការអប់រំជាកាតព្វកិច្ចទេ ដោយសារវាមិនមែនជាច្បាប់ និងសិក្សាដោយគិតថ្លៃឡើយ ។ ទោះបីជា

យ៉ាងនេះក្ដី វាត្រូវបានគេចាត់ទុកថាសមាភាពសំខាន់ នៅក្នុងប្រព័ន្ធអប់រំមូលដ្ឋានជាតិ ដែលរដ្ឋាភិបាលប្រឹងប្រែងជាខ្លាំង និងវិនិយោគធនធានជាច្រើនដើម្បីដាក់បញ្ចូលជាមួយការអប់រំជាកាតព្វកិច្ច៩ឆ្នាំ។ តាមរយៈការពង្រីកការអប់រំមូលដ្ឋានជាតិនេះ កម្មវិធីសិក្សាដែលមានមូលដ្ឋានផ្អែកសមត្ថភាព ក៏ត្រូវពង្រីកដល់កម្រិតមធ្យមសិក្សាទុតិយភូមិដែរ។ *(**<u>កំណត់សម្គាល់៖</u>** ការអប់រំជាកាតព្វកិច្ចរយៈពេល៩ឆ្នាំនេះ ជាច្បាប់ដែលខុសពីការអប់រំជាមូលដ្ឋានរបស់ប្រទេសកម្ពុជា។ ការអប់រំជាកាតព្វកិច្ចកំណត់ដោយច្បាប់មានន័យថា វាត្រូវបានអនុម័តដោយសភា តម្រូវឱ្យកុមារគ្រប់អាយុចូលរៀនទាំងអស់ត្រូវចូលរៀន ហើយក្នុងករណីឪពុកម្ដាយមានកូនគ្រប់អាយុចូលរៀនហើយ មិនបាននាំកូនទៅចុះឈ្មោះចូលរៀនទេ នឹងត្រូវពិន័យ ឬមានទោសតាមច្បាប់ជាធរមាន។ នៅកម្ពុជា មិនទាន់មានច្បាប់ការអប់រំជាកាតព្វកិច្ចនៅឡើយទេ។)*

ទន្ទឹមនឹងបទបង្ហាញពីគុណសម្បត្តិដ៏ច្រើននៃប្រព័ន្ធអប់រំតៃវ៉ាន់ ប្រព័ន្ធនេះក៏ប្រឈមនឹងបញ្ហាមួយចំនួនផងដែរ ហើយសម្រាប់ផ្នែកបន្ទាប់ យើងសូមបង្ហាញពី**គុណវិបត្តិ**របស់វា។ ប្រព័ន្ធនេះត្រូវបានទទួលរងការរិះគន់ចំពោះការដាក់សម្ពាធខ្លាំងក្លាពេកទៅលើសិស្ស និងកង្វះការជំរុញការច្នៃប្រឌិត ដោយប្រើប្រាស់វិធីសាស្ត្របែបចងចាំ និងទន្ទេញ។ លើសពីនេះទៀត ប្រព័ន្ធនេះត្រូវបានរងការរិះគន់យ៉ាងខ្លាំងផងដែរចំពោះការផលិតលើសលប់នៃនិស្សិតដែលបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ និងអត្រាគ្មានការងារធ្វើខ្ពស់។ ដោយសារមានការផ្គត់ផ្គង់ដ៏ច្រើនលើសលប់នេះ ធ្វើឱ្យនិស្សិតដែលបញ្ចប់ការសិក្សាមានការលំបាកក្នុងការស្វែងរកការងារធ្វើក្នុងពិភពនៃការប្រកួតប្រជែង និងធ្វើការងារដែលទទួលបានប្រាក់បៀវត្សតិចជាងការរំពឹងទុករបស់ខ្លួន[88]។ ជាមួយគ្នានេះ សាកលវិទ្យាល័យតៃវ៉ាន់ត្រូវបានរងការរិះគន់ចំពោះការមិនអាចបំពេញបានពេញលេញនូវលក្ខខណ្ឌ និងតម្រូវការទីផ្សារការងារដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស

ក្នុងសតវត្សរ៍ទី២១របស់តៃវ៉ាន់ដោយលើកឡើងពីភាពមិនស៊ីសង្វាក់គ្នារវាងជំនាញក្នុងចំណោមនិស្សិតដែលបញ្ចប់ការសិក្សា ដែលមិនសមនឹងតម្រូវការរបស់ទីផ្សារពលកម្មតៃវ៉ាន់សម័យទំនើប(89)។ រដ្ឋាភិបាលតៃវ៉ាន់ក៏ត្រូវបានគេរិះគន់ផងដែរចំពោះការធ្វើឱ្យខូចខាតដល់សេដ្ឋកិច្ចដោយសារតែខ្លួនមិនអាចបង្កើតការងារបានគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការរបស់និស្សិតដែលបញ្ចប់ការសិក្សានៅថ្នាក់ក្រោមជាតិ(90) ។

## 3.3) ការអភិវឌ្ឍសមត្ថភាពសតវត្សរ៍ទី២១របស់តៃវ៉ាន់

តៃវ៉ាន់ត្រៀមលក្ខណៈបានល្អសម្រាប់ការអភិវឌ្ឍសមត្ថភាពស.វទី២១។ កម្មវិធីសិក្សារយៈពេល ៩ឆ្នាំ និងកម្មវិធីសិក្សា១២ឆ្នាំគឺជាការច្នៃប្រឌិតអប់រំធំៗពីរក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក និងក្នុងការត្រៀមរៀបចំសម្រាប់ដោះស្រាយបញ្ហាប្រឈមនាពេលអនាគតក្នុងសតវត្សរ៍ថ្មី ក្រសួងអប់រំបានកែប្រែបទដ្ឋានកម្មវិធីសិក្សាសម្រាប់ការអប់រំជាកាតព្វកិច្ច ហើយបន្ទាប់មក បានរៀបចំគោលការណ៍ណែនាំកម្មវិធីសិក្សាចំនួន៩ឆ្នាំនៅដើមសតវត្សរ៍ថ្មី។ នៅពេលជាមួយគ្នានោះក្រសួងអប់រំ( MOE)បានចាប់ផ្តើមធ្វើផែនការកំណែទម្រង់ការអប់រំកាតព្វកិច្ចដែលមានរយៈពេល១២ឆ្នាំដែលពង្រីកការអប់រំជាកាតព្វ-កិច្ចពី៩ឆ្នាំ ដល់១២ឆ្នាំដើម្បីដោះស្រាយបញ្ហាស្មើភាពនិងយុត្តិធម៌។ បន្ទាប់ពីការរៀបចំផែនការ និងត្រៀមលក្ខណៈជាងមួយទសវត្សរ៍ កម្មវិធីអប់រំមូលដ្ឋានចំនួន១២ឆ្នាំត្រូវបានអនុវត្តជាផ្លូវការនៅក្នុងខែកញ្ញា ឆ្នាំ ២០១៤ ហើយគោលការណ៍ណែនាំកម្មវិធីសិក្សាទូទៅសម្រាប់ការអប់រំមូលដ្ឋានក្នុងរយៈពេល១២ឆ្នាំត្រូវបានប្រកាសឱ្យប្រើនៅខែធ្នូ ឆ្នាំ២០១៤ ហើយនឹងត្រូវអនុវត្តន៍ពីថ្នាក់ទី១ ដល់ទី១២ ក្នុងឆ្នាំ២០១៨ ។

ដោយសារកត្តាជំរុញពីប្រភពផ្សេងៗដូចជា៖ ការទាមទារពីពលរដ្ឋតៃវ៉ាន់សម្រាប់ការធ្វើមូលដ្ឋានីយកម្ម និងការទាមទារឱ្យមានការផ្ទេរអំណាចគ្រប់គ្រងអប់រំ ការកើនឡើងនូវសម្ពាធសាកលភាវូបនីយកម្ម និង

ការប្រកួតប្រជែងជាអន្តរជាតិ បានធ្វើឱ្យតៃវ៉ាន់សម្រួចកម្មសិក្សាពីរ។ សម្រាប់ការធ្វើមូលដ្ឋានីយកម្ម ការយល់ដឹងពីសក្តានុពលខ្លួនឯង និងសក្តានុពលអភិវឌ្ឍន៍គឺជាគោលដៅដំបូងនៃកម្មវិធីសិក្សាអប់រំជាកាតព្វកិច្ច៩ឆ្នាំ ដូច្នេះពួកគេផ្តោតចម្បងអំពីសារៈសំខាន់នៃចំណេះដឹងមូលដ្ឋានពីតៃវ៉ាន់។ ចំណែកឯ ការទាមទារឱ្យផ្ទេរអំណាចគ្រប់គ្រងកម្មវិធីសិក្សា៩ឆ្នាំត្រូវបានរៀបចំដោយគោលការណ៍ណែនាំ និងសូចនាករដោយគ្រាន់តែជាគោលការណ៍បង្ហាញផ្លូវ ច្រើនជាងស្តង់ដារជាក់លាក់មួយសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សារបស់សាលារៀន និងការបង្រៀននៅថ្នាក់រៀន។ គោលការណ៍ណែនាំបែបនេះផ្តល់ភាពបត់បែន និងស្វ័យភាពសម្រាប់សាលារៀនក្នុងការអភិវឌ្ឍកម្មវិធីសិក្សាផ្អែកលើមូលដ្ឋានសាលារៀន( school-based curriculum) ស្របតាមតម្រូវការនៅមូលដ្ឋានរបស់ពួកគេ។ លើសពីនេះទៀត កម្មវិធីសិក្សា៩ឆ្នាំបានចូលរួមជាមួយនឹងការកើនឡើងជាសកលនៃការអភិវឌ្ឍកម្មវិធីសិក្សាដែលមានមូលដ្ឋានលើសមត្ថភាព ( competency-based curriculum development) និងបានកំណត់ ″**សមត្ថភាពមូលដ្ឋាន**″ជាចំណេះដឹងស្នូល និងជំនាញដែលសិស្សតៃវ៉ាន់ទាំងអស់គួរតែអភិវឌ្ឍសម្រាប់ជីវិតបែបទំនើបនៅក្នុងសតវត្សរ៍ថ្មី។ ផ្អែកលើ "**សមត្ថភាពជាមូលដ្ឋាន**" ក្នុងកម្មវិធីសិក្សា៩ឆ្នាំនិង "**សមត្ថភាពស្នូល**" នៅក្នុងគោលការណ៍ណែនាំកម្មវិធីសិក្សាទូទៅសម្រាប់វិទ្យាល័យ និងនៅតែស្របតាមការអភិវឌ្ឍន៍សមត្ថភាពអន្តរជាតិ កម្មវិធីសិក្សា១២ឆ្នាំបានផ្តល់នូវក្របខ័ណ្ឌសមត្ថភាពដែលមាន "**សមត្ថភាពស្នូល**" ចំនួន៩ដែលរួមបញ្ចូលសូចនាករនៃកម្រិតថ្នាក់ទាំងអស់ និងភូមិសិក្សា។ កំណែទម្រង់កម្មវិធីសិក្សា៩ឆ្នាំបានផ្លាស់ប្តូរទិដ្ឋភាពផ្សេងៗនៃការអប់រំដូចជា៖ តួនាទីសាលារៀន គ្រូបង្រៀន និងសហគមន៍ ព្រមទាំងរបៀបបង្រៀន និងការរៀន។ យ៉ាងណាក៏ដោយ វាបានបម្រើជាមូលដ្ឋានសម្រាប់ការរៀបចំផែនការ និងការអនុវត្តកំណែទម្រង់កម្មវិធីសិក្សា១២ឆ្នាំ។ កម្មវិធីសិក្សា១២ឆ្នាំរក្សានូវស្មារតីនៃកម្មវិធីសិក្សា៩ឆ្នាំ និងរក្សាទម្រង់គោលការណ៍ណែនាំ និងតម្រង់ទិសសមត្ថភាព

។ ដោយសារតែគោលការណ៍ណែនាំកម្មវិធីសិក្សា១២ឆ្នាំទើបតែបានប្រកាសនៅក្នុងឆ្នាំ២០១៤ហើយនឹងត្រូវបានអនុវត្តនៅក្នុងឆ្នាំ២០១៨ ការពិភាក្សាអំពីការអនុវត្ត និងបញ្ហានៅក្នុងរបាយការណ៍នេះផ្តោតសំខាន់លើកម្មវិធីសិក្សា៩ឆ្នាំ។ កម្មវិធីសិក្សា៩ឆ្នាំនេះបានបង្ហាញពីការផ្លាស់ប្តូរគំរូនៃកំណែទម្រង់កម្មវិធីសិក្សារបស់តៃវ៉ាន់។ វាបានផ្លាស់ប្តូរពីចំណេះដឹងទៅការតម្រង់ទិសសមត្ថភាព បញ្ហាមុខវិជ្ជារួមបញ្ចូលគ្នា និងបញ្ហាចម្បងៗទៅជាមុខវិជ្ជាសិក្សា ផ្លាស់ប្តូរពីស្តង់ដារទៅជាគោលការណ៍ណែនាំ បន្ថែមវគ្គសិក្សាថ្មីដែលឆ្លើយតបទៅនឹងការជំរុញមូលដ្ឋានីយកម្ម និងអន្តរជាតិនីយកម្ម អន្តរាគមន៍ និងកែសម្រួលការប្រឡងចូលថ្នាក់វិទ្យាល័យ។ ការផ្លាស់ប្តូរទាំងនេះ មានគោលបំណងចង់ឱ្យសាលារៀន និងគ្រូបង្រៀនមានស្វ័យភាពវិជ្ជាជីវៈក្នុងការអភិវឌ្ឍកម្មវិធីសិក្សាដែលមានមូលដ្ឋានលើសាលារៀនដើម្បីកសាងសមត្ថភាពដែលជាមូលដ្ឋានគ្រឹះរបស់សិស្សទៅតាមប្រភេទផ្សេងៗនៃសង្គមទំនើបនៅសតវត្សរ៍ទី២១។ បើទោះបីជាមានការផ្លាស់ប្តូរ និងការច្នៃប្រឌិតកម្មវិធីសិក្សា ក៏ការសំយោគកត្តារារាំង និងបញ្ហាប្រឈមក្នុងផ្នែកខាងក្រោមនេះបង្ហាញថាការធ្វើតេស្តស្តង់ដារ ពោលគឺការប្រឡងចូលថ្នាក់វិទ្យាល័យនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតការអនុវត្តកម្មវិធីសិក្សា និងការបង្រៀនជាការត្រៀមរៀបចំការធ្វើតេស្តផ្អែកលើចំណេះដឹង(91)។ នៅចុងឆ្នាំ១៩៩០ ក្រសួងអប់រំតៃវ៉ាន់ (MOE)មានផែនការកែលម្អស្តង់ដារកម្មវិធីសិក្សាដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងប្រទេសឱ្យបានល្អប្រសើរ (ធ្វើមូលដ្ឋាននីយកម្ម) និងបញ្ហាប្រឈមជាសាកលក្នុងសតវត្សរ៍ថ្មី។ កម្មវិធីសិក្សាដែលបានធ្វើកំណែទម្រង់ថ្មីគឺកម្មវិធីសិក្សា៩ឆ្នាំដែលត្រូវបានអនុម័តនៅឆ្នាំ១៩៩៨ បានទទួលការអនុវត្តសាកល្បងនៅឆ្នាំ២០០០ ហើយអនុវត្តជាផ្លូវការក្នុងអំឡុងឆ្នាំ២០០១-២០០២។ នៅសតវត្សរ៍ទី២១ ដោយមានការប្រែប្រួលខ្លាំងផ្នែកបច្ចេកវិទ្យា សេដ្ឋកិច្ច និងសង្គមជាតិទាំងមូល ក្រសួងអប់រំបានចាប់ផ្តើមកំណែទម្រង់កម្មវិធីសិក្សាថ្មីបំផុត នៅឆ្នាំ២០១១គឺកំណែទម្រង់អប់រំជាកាតព្វកិច្ច១២ឆ្នាំ(92)។ ការផ្លាស់

ប្តូរបានប្រាប់បញ្ចូលរវាងបឋមសិក្សា និងមធ្យមសិក្សានៅកម្មវិធីសិក្សា ១២ឆ្នាំ។

ដោយផ្អែកលើទស្សនវិជ្ជានៃការអប់រំទាំងមូល ទាំងកម្មវិធីសិក្សាស្តីពីអ្នកសិក្សាចាប់ផ្តើមសិក្សារៀនសូត្រ និងស្វែងយល់ពីខ្លួនឯង ហើយបន្ទាប់មកភ្ជាប់ទំនាក់ទំនងជាមួយមនុស្សជុំវិញខ្លួនរួមមានសង្គម និងធម្មជាតិ។ កម្មវិធីសិក្សា៩ឆ្នាំបានសង្កត់ធ្ងន់លើគុណតម្លៃ៥គឺៈ ឥរិយាបថភាពជាមនុស្ស សមត្ថភាពសមាហរណកម្ម អក្សរសាស្ត្រ ការយល់ដឹងពីប្រទេសជាតិ និងសកលលោក ព្រមទាំងសមត្ថភាពសម្រាប់ការរៀនសូត្រពេញមួយជីវិត។ ដប់ឆ្នាំក្រោយមក កម្មវិធីសិក្សា១២ឆ្នាំនេះផ្តោតទៅលើគុណតម្លៃបីគឺ ការអភិវឌ្ឍដោយឯកឯង ការធ្វើអន្តរកម្ម និងភាពល្អគ្រប់ផ្នែក។ តារាងខាងក្រោមជាគុណតម្លៃនៃកម្មវិធីសិក្សាទាំងពីរនេះ(91)។

**គុណតម្លៃនៃកម្មវិធីសិក្សាតៃវ៉ាន់**

| កម្មវិសិក្សា៩ឆ្នាំ(93) (MoE ២០០០) | កម្មវិធីសិក្សា១២ឆ្នាំ (94) (MoE ២០១៤) |
|---|---|
| 1) ឥរិយាបថមនុស្សធម៌សម្រាប់ការយល់ដឹងដោយខ្លួនឯង ការគោរពចំពោះអ្នកដទៃ និងគោរពវប្បធម៌ផ្សេងៗ។<br>2) សមត្ថភាពសមាហរណកម្មសម្រាប់ភ្ជាប់អារម្មណ៍នឹងចំណេះដឹង ភ្ជាប់ទ្រឹស្តីនិងការអនុវត្ត និងការបញ្ចូលទស្សនវិទ្យាទៅក្នុងបច្ចេកវិទ្យា។<br>3) ចំណេះដឹងប្រជាធិបតេយ្យសម្រាប់ការសម្តែងមតិដោយខ្លួនឯង ការគិតដោយឯករាជ្យ | 1) អភិវឌ្ឍន៍ដោយខ្លួនឯង<br>2) អន្តរកម្ម<br>3) ល្អគ្រប់ផ្នែក<br>សិស្សត្រូវបានចាត់ទុកថាជាអ្នកសិក្សាដោយខ្លួនឯង ដូច្នេះសាលារៀនគួរតែ (១) ជំរុញការលើកទឹកចិត្ត និងបំផុសចំណង់ចំណូលចិត្ត (២) ណែនាំពួកគេឱ្យអភិវឌ្ឍអន្តរកម្មជាមួយខ្លួនឯងអ្នកដទៃ សង្គម និងធម្មជាតិ។ (៣) ជួយពួកគេអនុវត្តចំណេះដឹងដែលបានពី |

| | |
|---|---|
| ទំនាក់ទំនងសង្គម ភាពអត់ធ្មត់ចំពោះទស្សនៈខុសគ្នា ការងារជាក្រុម សេវាសង្គម និងការគោរពច្បាប់។<br>4) ការយល់ដឹងក្នុងប្រទេស និងសកលលោកសម្រាប់ការស្រឡាញ់ប្រទេសជាតិ ជាតិនិយម និងទស្សនវិស័យសកលលោក (ទាំងវប្បធម៌ និងបរិស្ថាន)។<br>5) សមត្ថភាពសម្រាប់ការរៀនសូត្រពេញមួយជីវិតតាមរយៈដំណើរការសកម្ម សមត្ថភាពដោះស្រាយបញ្ហា និងការប្រើប្រាស់ព័ត៌មាន និងភាសា។ | ការសិក្សានៅក្នុងការអនុវត្តប្រចាំថ្ងៃ ដកពិសោធន៍ពីអត្ថន័យជីវិត បង្កើតការប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍសង្គម ធម្មជាតិ និងវប្បធម៌ប្រកបដោយនិរន្តរភាព។ (៤)ទទួលបានភាពល្អគ្រប់ផ្នែក |

ទោះបីជាបរិបទប្រវត្តិសាស្ត្រខុសគ្នាក៏ដោយ កម្មវិធីសិក្សាទាំងពីរមានទស្សនវិស័យថាសតវត្សរ៍ទី២១ ជាយុគសម័យរៀនសូត្រពេញមួយជីវិត ដែលសិស្សទាំងអស់ត្រូវមានសមត្ថភាពពេញលេញក្នុងការដោះស្រាយការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងបញ្ហាប្រឈមនានាពីគ្រប់មជ្ឈដ្ឋានទាំងអស់នៃពិភពលោកបច្ចុប្បន្ន។ ដើម្បីរៀបចំសិស្សឱ្យក្លាយជាអ្នកសិក្សាអស់មួយជីវិតនៅសតវត្សរ៍ទី២១ កម្មវិធីសិក្សាទាំងពីរនេះបានចាត់ទុកការរៀនសូត្រពេញមួយជីវិតជាផ្នែកមួយនៃទស្សនវិស័យកម្មវិធីសិក្សា។ ដោយទទួលឥទ្ធិពលពីការអប់រំជាទូទៅ កម្មវិធីសិក្សា៩ឆ្នាំបានបង្កើតនូវទស្សនវិស័យចំនួនបី៖ ការអប់រំរួមគ្នាបរិស្ថានសាលាមេត្រី និងការរៀនសូត្រពេញមួយជីវិត។ ភាគច្រើនផ្តោតជាចម្បងលើការបណ្តុះទេពកោសល្យ និងការប្រកួតប្រជែងអន្តរជាតិ កម្មវិធីសិក្សា១២ឆ្នាំបានមើលឃើញដូចខាងក្រោម

៖ ភាពជោគជ័យសម្រាប់កុមារគ្រប់រូប ការអភិវឌ្ឍទេពកោសល្យដែលមានលក្ខណៈសម្របខ្លួន និងការរៀនសូត្រពេញមួយជីវិត។ ដោយផ្អែកលើទស្សនវិស័យទាំងនេះ កម្មវិធីសិក្សាទាំងពីរបានបង្កើតគោលដៅដូចដែលបានបង្ហាញនៅក្នុងតារាងក្រោម៖

| គោលដៅកម្មវិធីសិក្សា៩ឆ្នាំ[93] (MoE ២០០០) | កម្មវិធីសិក្សា១២ឆ្នាំ [94] (MoE ២០១៤) |
|---|---|
| 1. ពង្រឹងការយល់ដឹងពីខ្លួនឯង និងបង្ហាញសក្តានុពលបុគ្គល<br>2. អភិវឌ្ឍន៍គំនិតច្នៃប្រឌិត និងសមត្ថភាពក្នុងបង្កើនគុណតម្លៃនៃភាពល្អឥតខ្ចោះ និងបង្ហាញទេពកោសល្យផ្ទាល់ខ្លួន។<br>3. លើកកម្ពស់សមត្ថភាពទាក់ទងនឹងផែនការអាជីព និងការសិក្សាពេញមួយជីវិត<br>4. ប្រើប្រាស់ចំណេះដឹង និងជំនាញទាក់ទងនឹងការសម្តែងមតិ ទំនាក់ទំនង និងការចែករំលែក<br>5. រៀនសូត្រពីការគោរពអ្នកដទៃយកចិត្តទុកដាក់ចំពោះសហគមន៍ និងសម្របសម្រួលការងារក្រុម<br>6. បង្កើនការសិក្សាពីវប្បធម៌ និងការយល់ដឹងពីអន្តរជាតិ<br>7. ពង្រឹងចំណេះដឹង និងជំនាញទាក់ទងនឹងការធ្វើផែនការដំណើរការរៀបចំ និងអនុវត្ត | 1) បណ្តុះសក្តានុពល<br>2) យកចិត្តទុកដាក់ចំណេះដឹង និងជំនាញសម្រាប់ជីវិត<br>3) ដំណើរឆ្ពោះទៅអភិវឌ្ឍន៍អាជីព និង<br>4) អភិវឌ្ឍន៍ការទទួលខុសត្រូវក្នុងភាពជាពលរដ្ឋ |

| | |
|---|---|
| 8. មានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា និងព័ត៌មាន<br>9. លើកទឹកចិត្តចំពោះឥរិយាបថសិក្សា និងរៀនសូត្រសកម្ម<br>10. លើកកម្ពស់សមត្ថភាពទាក់ទងនឹងការគិតដោយឯករាជ្យ និងដោះស្រាយបញ្ហា | |

ដើម្បីសម្រេចបានទស្សនវិស័យ និងគោលដៅទាំងនេះ កម្មវិធីសិក្សាទាំងពីរបានកំណត់នូវ "**សមត្ថភាពស្នូល**" ដែលបែងចែកជាបីប្រភេទដូចបានបង្ហាញក្នុងតារាងខាងក្រោម។ ក្របខណ្ឌកម្មវិធីសិក្សា៩ឆ្នាំចាប់ផ្ដើមពីសិស្សដែលរំពឹងថានឹងក្លាយជាពលរដ្ឋយុគសម័យទំនើបដែលមានការយល់ដឹងពីប្រទេសជាតិ និងទស្សនវិស័យអន្តរជាតិតាមរយៈការបង្កើត" **សមត្ថភាពមូលដ្ឋានចំនួន១០**" ហើយចែកចេញជា៣ផ្នែក៖ ផ្នែកខ្លួនឯង សង្គមជាតិ និងធម្មជាតិ(93) ( MOE 2000 )។ ក្របខណ្ឌកម្មវិធីសិក្សា១២ឆ្នាំយកចិត្តទុកដាក់ខ្លាំងដល់សិស្សដើម្បីក្លាយជាអ្នកសិក្សាពេញមួយជីវិតដែលអភិវឌ្ឍន៍ "**សមត្ថភាពស្នូលចំនួន៩**" ហើយបែងចែកជាបីផ្នែក៖ ការអភិវឌ្ឍដោយខ្លួនឯង អន្តរទំនាក់ទំនង និងការចូលរួមក្នុងសង្គម(94) ( MOE , 2014 )។

**ក្របខណ្ឌសមត្ថភាព កម្មវិធីសិក្សា៩ឆ្នាំ**(93) ( MOE 2000 )

| ផ្នែក | សមត្ថភាពមូលដ្ឋានទាំង១០ |
|---|---|
| 1. **ទាក់ទងទៅនឹងខ្លួនឯង៖** ការអភិវឌ្ឍរាងកាយ និងផ្លូវចិត្តបុគ្គល | 1. ស្វែងយល់ពីខ្លួនឯង និងអភិវឌ្ឍសក្តានុពល<br>2. ភាពពេញចិត្ត ការអនុវត្ត និងគំនិតច្នៃប្រឌិត<br>3. ផែនការអាជីព និងការសិក្សាពេញមួយជីវិត |

| | |
|---|---|
| | 4. ការទំនាក់ទំនងនឹងសង្គម |
| 2. **ទាក់ទងនឹងសង្គមៈ** សមាហរណកម្មសង្គម និងវប្បធម៌ | 1. ការសម្តែងមតិ ទំនាក់ទំនង និងចែករំលែក<br>2. ការគោរព យកចិត្តទុកដាក់ និងការងារក្រុម<br>3. សិក្សាពីវប្បធម៌ និងយល់ដឹងពីអន្តរជាតិ<br>4. ធ្វើផែនការ រៀបចំដំណើរការ និងយកផែនការមកអនុវត្ត |
| 3. **ទាក់ទងនឹងបរិស្ថានធម្មជាតិៈ** ធម្មជាតិ និងបរិស្ថាន | 1. ការប្រើប្រាស់បច្ចេកវិទ្យា និងព័ត៌មាន<br>2. វិភាគ វាយតម្លៃ និងដំណើរការសកម្ម<br>3. គិតដោយឯករាជ្យ និងដោះស្រាយបញ្ហា |

**ក្របខណ្ឌសមត្ថភាពកម្មវិធីសិក្សា១២ឆ្នាំ**(94) ( MOE, 2014 )

| ផ្នែក | សមត្ថភាព |
|---|---|
| 1. **សកម្មភាពគោលដៅផ្ទាល់ខ្លួន** | 1. រាងកាយ និងផ្លូវចិត្តរឹងមាំ និងលើកកម្ពស់លក្ខណៈសម្បត្តិខ្លួនឯង<br>2. គិតជាប្រព័ន្ធ និងដោះស្រាយបញ្ហា<br>3. ធ្វើផែនការ អនុវត្ត និងភាពបត់បែនប្រកដោយភាពច្នៃប្រឌិត |
| 2. **អន្តរទំនាក់ទំនង** | 1. ប្រើប្រាស់និមិត្តសញ្ញា និងការបង្ហាញពីទំនាក់ទំនង<br>2. បច្ចេកវិទ្យា ព័ត៌មាន និងអក្សរសាស្ត្រផ្សព្វផ្សាយព័ត៌មាន |

| | |
|---|---|
| | 3. សិល្បៈ និងសមត្ថភាពនៃការរចនាសិល្បសោភណ |
| **3. ការចូលរួមសង្គម** | 1. ទំនាក់ទំនងរវាងបុគ្គល-បុគ្គល និងការងារក្រុម<br>2. យល់ដឹងពីពហុវប្បធម៌ និងអន្តរជាតិ<br>3. ការអនុវត្តសីលធម៌ និងការយល់ដឹងពីភាពជាពលរដ្ឋ |

## 3.4) គោលបំណងក្រសួងអប់រំតៃវ៉ាន់សម្រាប់ឆ្នាំ២០១៥

1. អនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍធនធានមនុស្ស និងបង្កើតយន្តការច្នៃបង្កើតថ្មីសម្រាប់ការអភិវឌ្ឍធនធានមនុស្ស ដោយផ្តោតលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ដ៏សកម្មនូវកម្លាំងការងារដែលមានកម្រិតជំនាញខ្ពស់ អាចប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ពហុឯកទេស និងផ្តល់មូលដ្ឋានដ៏គួរឱ្យទុកចិត្ត និងរឹងមាំសម្រាប់ជាតិដើម្បីធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព
2. បង្កើតនូវសាកលវិទ្យាល័យកម្រិតពិភពលោក និងកាត់បន្ថយមជ្ឈមណ្ឌលស្រាវជ្រាវ ផ្តល់រង្វាន់ដល់សាកលវិទ្យាល័យចំពោះស្នាដៃបំពេញការងារល្អក្នុងការបង្រៀន ពង្រឹងការអប់រំ និងការបណ្តុះបណ្តាលនិស្សិតឱ្យមានជំនាញខ្ពស់ទៅតាមវិស័យ( ការអប់រំជាន់ខ្ពស់ )ភ្ជាប់ទំនាក់ទំនងជាមួយតម្រូវការវិស័យឧស្សាហកម្ម ពង្រីកការផ្លាស់ប្តូរនិស្សិតសិក្សា ធ្វើឱ្យប្រសើរឡើងនូវភាពច្នៃប្រឌិតអប់រំ និងផ្តល់ដល់សាកលវិទ្យាល័យ និងមហាវិទ្យាល័យនូវភាពបត់បែននៃប្រតិបត្តិការកាន់តែច្រើន លើកទឹកចិត្តដល់សាកលវិទ្យាល័យក្នុងស្រុកដើម្បីសម្របខ្លួនតាមស្តង់ដារ និងការអនុវត្តលក្ខណៈអន្តរជាតិ

ព្រមទាំងលើកកម្ពស់គុណភាពការបង្រៀននៅតាមសាកលវិទ្យាល័យ ការស្រាវជ្រាវ និងការប្រកួតប្រជែងអន្តរជាតិ។

3. អនុវត្តជំហានទី២នៃផែនការកំណែទម្រង់ការអប់រំវិជ្ជាជីវៈ និងបច្ចេកទេស (second Phase of the Technological and Vocational Education Reform Plan)៖
   - បណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាកម្រិតខ្ពស់
   - កាត់បន្ថយគម្លាតដែលមានស្រាប់រវាងការអប់រំនិងតម្រូវការការងារ
   - បង្កើនការភ្ជាប់ទំនាក់ទំនងការអប់រំវិជ្ជាជីវៈ បច្ចេកទេស និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដើម្បីឆ្លើយតបទៅនឹងតម្រូវការវិស័យឧស្សាហកម្ម
   - អភិវឌ្ឍន៍បន្ថែមសាកលវិទ្យាល័យគំរូសម្រាប់ជំនាញវិទ្យាសាស្ត្រ&បច្ចេកទេស និងបង្ហាញជាក់លាក់ពីភាពពាក់ព័ន្ធក្នុងការអនុវត្តការបណ្តុះបណ្តាលជំនាញវិជ្ជាជី-វៈ
   - កំណត់ឡើងវិញនូវគុណតម្លៃស្នូល និងបង្កើនការប្រកួតប្រជែងអប់រំរបស់ខ្លួន។

4. (ក)លើកកម្ពស់និងអនុវត្តការបណ្តុះបណ្តាលដល់គរុសិស្សមុនពេលក្លាយជាគ្រូបង្រៀន និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្តដល់គ្រូបង្រៀនដែលកំពុងបំពេញការងារ(ខ)ពង្រឹងគុណភាពគ្រូបង្រៀនកម្រិតបឋមសិក្សា និងមធ្យមសិក្សា (គ)អនុវត្តប្រព័ន្ធវាយតម្លៃលទ្ធផលបំពេញការងាររបស់គ្រូបង្រៀន(teacher appraisal system) (ឃ)បង្កើតយន្តការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន (ង)បង្កើតប្រព័ន្ធ និងចាប់ផ្តើមអនុវត្តប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍គ្រូបង្រៀនទាំងផ្នែកច្បាប់ និងការអនុវត្ត (ច)យកចិត្តទុកដាក់ជាសកម្មក្នុងការការពារសិទ្ធិគ្រូបង្រៀន (ឆ)ផ្តល់លទ្ធភាពទទួលបាន

ការអប់រំផ្នែករចនា និងសិល្បៈ រក្សានិងបង្កើនការយល់ដឹងពីផ្នែកសិល្បៈដល់មហាជនទូទៅ។

5. (ក)បន្តអនុវត្តប្រព័ន្ធអប់រំមូលដ្ឋាន១២ឆ្នាំ (ការអប់រំជាកាតព្វកិច្ច) (ខ)អនុវត្តពេញលេញការអប់រំដោយឥតគិតថ្លៃនៅសាលាវិទ្យាល័យបណ្តុះបណ្តាលវិជ្ជាជីវៈ (vocational high schools) និងការអប់រំមិនគិតថ្លៃសម្រាប់សិស្សនៅមធ្យមសិក្សាទុតិយភូមិដែលសមស្របទៅនឹងលក្ខណៈ វិនិច្ឆ័យផ្តល់ភាពអនុគ្រោះ (ការអប់រំ៩ឆ្នាំមិនគិតថ្លៃ តែកម្រិតមធ្យមសិក្សាទុតិយភូមិគិតថ្លៃ និងមានករណីលើកលែងសម្រាប់សិស្សងាយរងគ្រោះ) (គ)ធ្វើឱ្យប្រសើរឡើងនូវភាពបត់បែននៃការផ្តល់ការអនុញ្ញាតឱ្យសិក្សា និងចុះឈ្មោះចូលរៀនតាមភូមិសិក្សាសម្រាប់សិស្សនៅកម្រិតវិទ្យាល័យជំនាញវិជ្ជាជីវៈ និងវិទ្យាល័យធម្មតា (រៀនពីថ្នាក់ទី១០ ដល់ទី១២ មិនផ្តោតលើការសិក្សាជំនាញដូចវិទ្យាល័យជំនាញវិជ្ជាជីវៈទេ) (ឃ)កំណត់គុណភាពខ្ពស់នៃវិទ្យាល័យជំនាញវិជ្ជាជីវៈ និងវិទ្យាល័យធម្មតា (ង)យកចិត្តទុកដាក់សម្រេចឱ្យបាននូវការអភិវឌ្ឍដែលមានតុល្យភាពសម្រាប់វិទ្យាល័យជំនាញវិជ្ជាជីវៈ និងវិទ្យាល័យធម្មតានៅក្នុងតំបន់ទាំងអស់ (ច)ពង្រឹងការបង្រៀនដែលមានការអភិវឌ្ឍធ្វើឱ្យប្រសើរឡើង ដើម្បីជានាគុណភាពនៃការអប់រំមូលដ្ឋាន

6. (ក)កាត់បន្ថយទំហំថ្នាក់រៀន កម្រិតបឋមសិក្សា និងអនុវិទ្យាល័យ (ខ) បង្កើនចំនួនគ្រូបង្រៀននៅសាលាបឋមសិក្សា (គ)បង្កើនចំនួនគ្រូបង្រៀនសម្រាប់សាលារៀនដែលទំហំតូចដើម្បីលុបបំបាត់ការបែងចែកគុណភាពបង្រៀនក្នុងតំបន់ជនបទ និងទីក្រុង (ឃ) កសាងបរិស្ថានប្រកបដោយគុណភាពនៅសាលាបឋមសិក្សា និងអនុវិទ្យាល័យ (ង)បង្កើនចំនួន និងគុណភាពនៃកម្មវិធីថែទាំបន្ទាប់ពីសាលា (ច)បង្កើនការកែលម្អអគារចាស់ៗនៃសាលាបឋមសិក្សា និងអនុវិទ្យាល័យ (ឆ)ដាក់ដំណើរការការផ្តល់អាហារថ្ងៃត្រង់នៅ

តាមសាលា និងការគ្រប់គ្រងសុវត្ថិភាពចំណីអាហារ (ជ)ធ្វើឱ្យប្រសើរឡើងនូវ កម្មវិធីផ្តល់វិញ្ញាបនប័ត្របញ្ជាក់សាលារៀនដែលយកចិត្តទុកដាក់លើកកម្ពស់សុខភាព។

7. (ក).កសាងការអប់រំដែលមានគុណភាព និងបរិស្ថានសិក្សាដែលមានសុវត្ថិភាព សម្រាប់សិស្សសាលាមត្តេយ្យ(ខ).បង្កើនការចូលរួមសាធារណៈក្នុងការអប់រំមត្តេយ្យសិក្សា និងការងារថែទាំ (គ).បង្កើនឱកាសអប់រំ សម្រាប់កុមាររៀននៅមត្តេយ្យសិក្សា (ឃ).ផ្តល់ការអប់រំមិនគិតថ្លៃសម្រាប់កម្រិតមត្តេយ្យសិក្សាដល់កុមារអាយុ៥ឆ្នាំ ដើម្បីកាត់បន្ថយការកើនឡើងនូវបន្ទុកគ្រួសារ និងអ្នកអាណាព្យាបាល

8. (ក).សមាហរណកម្មវិធានការក្នុងការជួយសិស្សដែលមិនទទួលបានផលប្រយោជន៍សេដ្ឋកិច្ច-សង្គម (socio-economically disadvantaged students) ដើម្បីចូលសិក្សារៀនសូត្រតាមសាលារៀន ក្នុងគោលបំណងដោះស្រាយកង្វល់ពីយុត្តិធម៌សង្គម (ខ).ដំណើរការពេញលេញវិធានការបណ្តាញសុវត្ថិភាពអប់រំ (the Education Safety Net measures) (គ)អនុវត្តការអប់រំបញ្ចូលគ្នា (inclusive education)ដល់កុមារពិការ (ឃ).លើកកម្ពស់ការបណ្តាញគាំទ្រគ្រប់គ្រងការអប់រំពិសេស ( the special education administrative support network)

9. (ក)បង្កើនការយកចិត្តទុកដាក់សិស្សជនជាតិដើម (indigenous students) ក្នុងការប្រកួតប្រជែងសិក្សា (ខ)-ការគាំពារសម្រាប់ឱកាសអប់រំសិស្សជនជាតិដើម និងសិទ្ធិរបស់ពួកគេក្នុងការអប់រំ (គ)-បង្កើនការអប់រំ និងបណ្តុះបណ្តាលជំនាញកម្រិតខ្ពស់ដល់សិស្សជនជាតិដើម (ឃ)-បង្កើនចំនួនគ្រូបង្រៀនជនជាតិដើមដែលសមត្ថភាពខ្ពស់ និងបន្តលើកកម្ពស់វគ្គសិក្សាភាសាជនជាតិដើម ការរក្សា និងផ្ទេរភាសា និងវប្បធម៌ជនជាតិបន្ត។

10. (ក)-អនុវត្តប្រកបដោយប្រសិទ្ធភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិត(lifelong learning) និងសកម្មភាពដែលជាប់ទាក់ទងគ្នា (associated activities) (ខ)-សមាហរណកម្មធនធានរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីធ្វើឱ្យសេវាអប់រំតាមគ្រួសារកាន់តែទូលំទូលាយ (គ)-ផ្តល់ការគាំពារ និងរក្សាសិទ្ធិរៀនសូត្ររបស់មនុស្សចាស់ និងធ្វើឱ្យសេវាអប់រំមានដល់តំបន់របស់ពួកគេសម្រាប់គ្រប់ប្រជាពលរដ្ឋ (ឃ)លើកកម្ពស់ការកែលម្អសេវាកម្មដែលផ្តល់ដោយគ្រឹះស្ថានអប់រំសាធារណៈសម្រាប់មហាជន(ង)-ផ្តល់ជម្រើសផ្សេងៗ និងទូលំទូលាយសម្រាប់ធនធានសិក្សាពេញមួយជីវិត និងផ្តោតលើការប្រើប្រាស់គំនិតច្នៃបង្កើតនៃទំហំបណ្ណាល័យ និងគ្រឹះស្ថានសិក្សា ព្រមទាំងបង្កើតបរិស្ថានអានប្រកបដោយគុណភាព និងទិដ្ឋភាពល្អប្រសើរ។

11. (ក)-ពង្រឹងកិច្ចការសិស្ស និងការងារផ្តល់ប្រឹក្សាយោបល់ (ខ)-ដាក់ដំណើរការបទបញ្ញត្តិដើម្បីជានាសមភាពយេនឌ័រ ការអប់រំជីវិត និងសិទ្ធិមនុស្ស និងអនុវត្តការអប់រំបុគ្គលិកលក្ខណៈ (គ)-បង្ការការគំរាមកំហែងនៅក្នុងធ្លាទីសាលា និងការប្រើប្រាស់គ្រឿងញៀន ព្រមទាំងរៀបចំបរិស្ថានសាលារៀនប្រកបដោយបរិយាកាសសុវត្ថិភាពក្នុងការរៀនសូត្រ ផាសុខភាព និងកុមារមេត្រី។

12. (ក)-ធ្វើឱ្យប្រសើរឡើងនូវអំណាចប្រតិបត្តិការរបស់បណ្តាញសិក្សាតៃវ៉ាន់ (Taiwan Academic Network TANet) និងពង្រីកវិសាលភាពសេវាកម្មខ្លួន (ខ)-ពង្រឹងយន្តការសន្តិសុខទិន្នន័យក្នុងបរិវេនសាលារៀន (គ)-ពង្រឹងសមត្ថភាពសិក្សាតាមអេឡិចត្រូនិច (cloud-based e-learning competency) និងពង្រឹងសមត្ថភាពក្នុងការដោះស្រាយកង្វល់របស់សង្គម ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល (ឃ)-លើកកម្ពស់ក្រមសីលធម៌ព័ត៌មាន និងសុវត្ថិភាព Online (ង)-កសាងបរិវេនសាលារៀនឱ្យមានបរិស្ថានល្អប្រកប

ដោយចីរភាព និងបង្កើនចំណេះដឹងពីបរិស្ថានដល់គ្រូបង្រៀន និងសិស្ស ការការពារបរិស្ថាន និងសមត្ថភាពក្នុងការពារគ្រោះមហន្តរាយ និងដោះស្រាយបញ្ហាយថាភាព។

13. (ក)-បង្កើនកិច្ចសហប្រតិបត្តិការ និងផ្លាស់ប្តូរនិស្សិតសិក្សាអន្តរជាតិ (ខ)-ធ្វើឱ្យវគ្គសិក្សានៅតៃវ៉ាន់អាចសិក្សាបានជាលក្ខណៈអន្តរជាតិ (គ)-ពង្រីកជាលក្ខណៈអន្តរជាតិនូវការអប់រំភាសាចិន មាន់ដារិន(កុងងឺ) និងកិច្ចការពាក់ព័ន្ធនានា (ឃ)-លើកកម្ពស់ឧស្សាហកម្មនាំចេញផ្នែកអប់រំកម្រិតឧត្តមសិក្សា( ឱ្យនិស្សិតបរទេសមករៀនបង់ថ្លៃនៅតៃវ៉ាន់ឱ្យបានច្រើនដើម្បីបង្កើនប្រាក់ចំណូលជាតិ) ទាក់ទាញនិស្សិតបរទេសដែលមានសមត្ថភាពមកសិក្សានៅតៃវ៉ាន់ ព្រមទាំងបង្កើតបរិស្ថានសិក្សាមេត្រីភាពសម្រាប់សិស្សអន្តរជាតិ

14. (ក)-ជួយដល់យុវជនវ័យក្មេងដើម្បីបង្ហាញចេញពីជម្រើសអាជីព (ខ)-ធ្វើឱ្យប្រសើរឡើងនូវការប្រកួតប្រជែងសហគ្រិនភាពសម្រាប់សហគ្រិនវ័យក្មេងដែលគំនិតច្នៃបង្កើតថ្មី (គ)-កសាងការភ្ជាប់ទំនាក់ទំនងរឹងមាំជាមួយសាលាមធ្យមសិក្សា មហាវិទ្យាល័យ សាកលវិទ្យាល័យ និងកន្លែងធ្វើការ( ឃ)-លើកទឹកចិត្តយុវជនវ័យក្មេងកាន់តែច្រើនដើម្បីចូលរួមកិច្ចការសហគមន៍ និងកិច្ចការសាធារណៈ (ង)-លើកកម្ពស់យុវជនស្ម័គ្រចិត្ត ការងារសម្បុរធម៌ និងសេវាកម្មសិក្សា (ច)-លើកទឹកចិត្តយុវជនវ័យក្មេងចូលរួមក្នុងព្រឹត្តការណ៍អន្តរជាតិ ទស្សនកិច្ចនៅបរទេស និងពង្រីកបទពិសោធអន្តរជាតិរបស់ពួកគេ

15. ផ្តោតជាសំខាន់លើការអប់រំកាយនៅក្នុងសាលារៀន មហាវិទ្យាល័យ និងសាកលវិទ្យាល័យ និងធ្វើឱ្យប្រសើរឡើងនូវកាយសម្បទាសិស្ស (ខ)-លើកកម្ពស់ការចូលរួមសកម្មភាពកីឡាមហាជន (គ)-អភិវឌ្ឍន៍គម្រោង"Sports Island Project" ដើម្បីលើកទឹកចិត្តប្រជាជនរីករាយនឹងការធ្វើលំហាត់ប្រាណ (ឃ)-បង្កើតបរិយាកាស

ប្រកបដោយគុណភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មកីឡានៅតៃវ៉ាន់បន្ថែមទៀត និងបង្កើនឆន្ទៈរបស់ប្រជាពលរដ្ឋដែលចូលរួមនៅក្នុងវិស័យនេះដើម្បីវិនិយោគនិងចូលរួម។

## 3.5) លក្ខណៈពិសេសនៃការអប់រំតៃវ៉ាន់ដែលយើងអាចរៀនសូត្របាន

- **ឥទ្ធិពលទ្រឹស្តីខុងជឺនៅក្នុងសង្គមតៃវ៉ាន់ ដែលជាកត្តាសំខាន់ក្នុងការជំរុញការសិក្សា**

សង្គមតៃវ៉ាន់ទទួលឥទ្ធិពលយ៉ាងខ្លាំងពីតម្លៃខុងជឺនិយមដូចជា៖ ភាពផ្តាច់ការផ្នែកនយោបាយ រចនាសម្ព័ន្ធសង្គម បណ្តាញមនុស្ស និងការអប់រំ (95) ហេតុដូច្នេះហើយសង្គមតៃវ៉ាន់ផ្តោតខ្លាំងទៅលើការបញ្ជាក់ពីសមត្ថភាព បទពិសោធ និងការអនុវត្តប្រព័ន្ធប្រឡងដែលវាមានកំណើតតាំងពីអធិរាជចិនដែលរយៈពេលជាងមួយពាន់ឆ្នាំ និងសាមសិបឆ្នាំ(៦៩៤-១៨៩៥)។ ប្រព័ន្ធនេះត្រូវបានប្រើជាឧបករណ៍សម្រាប់ការគ្រប់គ្រងសង្គមដោយថ្នាក់ដឹកនាំតាមរយៈការជ្រើសរើសបញ្ញាវន្តសម្រាប់ដឹកនាំប្រទេសដោយអនុវត្តការប្រឡងជាសាធារណៈ។ រហូតមកដល់ពេលបច្ចុប្បន្ននេះសង្គមតៃវ៉ាន់នៅតែស្ថិតក្រោមឥទ្ធិពលប្រពៃណីប្រឡងនេះដែលតម្រូវឱ្យមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងតាមរយៈការហ្វឹកហាត់ និងការអនុវត្ត។ ឪពុកម្តាយ/អាណាព្យាបាលជនជាតិចិន / តៃវ៉ាន់ភាគច្រើនជឿជាក់ថាការខិតខំប្រឹងប្រែងខ្លាំង ធ្វើឱ្យសមត្ថភាពប្រសើរជាងសមត្ថភាពដែលមានពីកំណើត ប្រសិនបើកូនៗរបស់ពួកគេចង់បង្កើនកម្រិតសិក្សារបស់ខ្លួន(96)។ ហេតុដូច្នេះហើយសាលារៀននៅតៃវ៉ាន់ផ្តល់អាទិភាពដល់ការខិតខំប្រឹងប្រែងតស៊ូ និងភាពតឹងតែងដែលតម្រូវឱ្យមានការសិក្សាច្រើនម៉ោង(97) ។ ដើម្បីបញ្ជាក់ពីការឱ្យតម្លៃដ៏លើសលប់ទៅលើចំណេះវិជ្ជា និងប្រាជ្ញវាងវៃនេះយើងអាចធ្វើការវិភាគ និងឆ្លុះបញ្ចាំងបានតាមរយៈសាច់រឿង**សាមកុក** និងសៀវភៅយុទ្ធសាស្ត្រសង្គ្រាមផ្សេងៗទៀតដែលមានឥទ្ធិពលទៅលើផ្នត់

គំនិត និងភាពពេញចិត្តរបស់មនុស្ស។ ដោយសារឥទ្ធិពលនេះហើយ បានជាជនជាតិតៃវ៉ាន់រាល់គ្នាខិតខំប្រឹងប្រែងធ្វើការគ្រប់ពេលវេលា។ កុមាររៀនសូត្រច្រើនណាស់ដែលពួកគេមានពិន្ទុគណិតវិទ្យាល្អបំផុតលើពិភពលោក។ វាមិនត្រឹមសិស្សសាលាទេដែលចំណាយពេលស្ទើរពេញមួយថ្ងៃដើម្បីសិក្សារៀនសូត្រ សូម្បីតែនៅកន្លែងការងារក៏ជនជាតិតៃវ៉ាន់ចំណាយពេលដូចគ្នាដើម្បធ្វើការដែរប្រមាណ៧០ម៉ោងក្នុង១សប្តាហ៍ដែលជាចំនួនម៉ោងដ៏ច្រើនមែនទែន។ ពួកគេស្រឡាញ់ការសិក្សា និងការធ្វើការងារណាស់ដោយសម្រាកតិចបំផុត ហើយភាគច្រើនឱ្យតម្លៃលើភាពស្ងៀមស្ងាត់មិនរំខានអ្នកដទៃ។ នេះក៏ជាតំបន់ដែលមានមនុស្សមានIQខ្ពស់បំផុតនៅលើពិភពលោក។ កោះតៃវ៉ាន់គឺជាមជ្ឈមណ្ឌលមួយសម្រាប់ឧត្តមភាពខាងបច្ចេកទេសអស់ជាច្រើនទសវត្សរ៍មកហើយ។ វាមានស្តង់ដារខ្ពស់ជានិច្ចក្នុងវិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ ការអប់រំតៃវ៉ាន់មានភាពវិសេសជាច្រើនទៀតក្រៅពីជំនាញគណិត និងជំនាញIT។ ប្រព័ន្ធអប់រំតៃវ៉ាន់មានភាពល្បីល្បាញដោយសារលទ្ធផលវាយតម្លៃPISAខ្ពស់ចំពោះមុខវិជ្ជាគណិតវិទ្យា និងវិទ្យាល័យ។ ស្តង់ដាររួមនៃការសិក្សាតៃវ៉ាន់អាចប្រៀបធៀបបានជាមួយប្រទេសសេដ្ឋកិច្ចជឿនលឿននៅក្នុងតំបន់ដូចជា៖ ប្រទេសជប៉ុន និងកូរ៉េខាងត្បូងជាដើម។ កម្រិតអន្ទរកម្មតៃវ៉ាន់មាន៩៨.២%សម្រាប់ប្រជាពលរដ្ឋអាយុ១៥ឆ្នាំឡើងទៅ។ ដូចជប៉ុនដែរ ការដាក់សម្ពាធសិក្សាជាគន្លឹះសំខាន់ក្នុងការជំរុញការសម្រេចបានលទ្ធផលសិក្សា។ កាលវិភាគសាលារៀននៅអាស៊ីខាងកើតហាក់ទុកពេលតិចតួចណាស់សម្រាប់សិស្សក្នុងការលំហែចិត្ត និងកម្សាន្តសប្បាយ។

- **ការយកចិត្តទុកខ្លាំងចំពោះការសិក្សារបស់សិស្សតៃវ៉ាន់**

ប្រព័ន្ធអប់រំតៃវ៉ាន់យកចិត្តទុកខ្លាំងក្នុងការកាត់បន្ថយគម្លាតសមត្ថភាពសិក្សារបស់សិស្ស តាមរយៈការបន្ថែមម៉ោងសិក្សា និងពង្រឹងសមត្ថភាពតាមថ្នាក់។ គេអាចបើកថ្នាក់រៀនមួយបានសម្រាប់ថ្ងៃសៅរ៍-អាទិត្យ បើសិនជាមានសិស្សចាប់ពី១០នាក់ឡើងទៅចង់រៀន ហើយបន្ទុកចំណាយទាំង

អស់ជារបស់រដ្ឋាភិបាល។ មិនតែប៉ុណ្ណោះ ការអភិវឌ្ឍក្នុងមជ្ឈមណ្ឌលប្រកួតប្រជែងក៏ត្រូវបានយកចិត្តទុកដាក់ខ្លាំងផងដែរ តាមរយៈការផ្ដល់ប្រាក់ឧបត្ថម្ភដល់សិស្សឆ្នើម (១០០០០យ៉េន/១នាក់) និងសិស្សពូកែ (៣០០០យ៉េន/១នាក់) ដើម្បីជំរុញសន្ទុះសិក្សារៀនសូត្ររបស់សិស្ស។ (*យោងតាមសាស្ដាចារ្យ Ogawa Yoshikazu មកពីសាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា មកធ្វើបទបង្ហាញសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ២០១៧*) ***នៅកម្ពុជា*** យើងឃើញថាមិនទាន់មានការអនុវត្តបែបនេះនៅឡើយទេ សម្រាប់ការឆ្លើយតបទៅនឹងសំណូមពរ ឬតម្រូវការសិក្សាសិស្ស ដែលយើងត្រូវយកចិត្តទុកដាក់បន្ថែមទៀតក្នុងការជំរុញការសិក្សាសិស្ស ឱ្យមានសន្ទុះទៅមុខខ្លាំងក្លាពិសេសសម្រាប់សិស្សឆ្នើម និងពូកែ។ ឧទាហរណ៍សិស្សពូកែកម្រិតខេត្តនឹងទទួលបានអាហារូបករណ៍រៀននៅមហាវិទ្យាល័យដោយស្វ័យប្រវត្តិ និងរង្វាន់លើកទឹកចិត្តច្រើនគួរជាទីពេញចិត្ត ឱកាសទទួលបានការងារពេលបញ្ចប់ការសិក្សា...ហើយសម្រាប់សិស្សពូកែកម្រិតថ្នាក់ជាតិអាចទទួលបានលើសពីនេះទៅទៀត ដូចជាឱកាសសិក្សានៅបរទេសជាដើម។ បើសិស្ស និងមាតាបិតាសិស្សមើលឃើញលទ្ធផលដែលបានពីការខិតខំប្រឹងប្រែងសិក្សានៅនឹងភ្នែកជាក់ស្ដែងបែបនេះ នោះការឱ្យតម្លៃលើការសិក្សាកាន់តែខ្លាំង ហើយសន្ទុះនៃការប្រឹងប្រែងនឹងកើតមានកាន់តែខ្លាំងជាងមុនផងដែរ។ មិនតែប៉ុណ្ណោះ វាចូលរួមចំណែកដោះស្រាយបញ្ហាវិសមភាពសង្គមលើការសិក្សា និងឱកាសការងារ ដែលប្រជាពលរដ្ឋមួយចំនួន ពិសេសនៅជនបទ តែងតែនិយាយថា ***"ខំរៀនធ្វើអ្វី យើងគ្មានលុយបន្តការសិក្សាថ្នាក់ខ្ពស់ទេ! ការងារល្អៗគេកូនគេដាក់អស់ហើយ"*** នឹងរលុបបាត់ចេញពីផ្នត់គំនិតអវិជ្ជមានពួកគាត់មិនខាន។

- **បញ្ហាជនជាតិដើម និងការយកចិត្តទុកដាក់របស់រដ្ឋាភិបាលតៃវ៉ានលើការអប់រំជនជាតិដើមភាគតិចទាំងនោះ**

នៅក្នុងយុគសម័យសាកលភាវូបនីយកម្មសេដ្ឋកិច្ច និងមូលធននិយមបច្ចេកវិទ្យាព័ត៌មានវិទ្យា សេដ្ឋកិច្ចផ្អែកលើចំណេះដឹង និងទីផ្សារនីយកម្ម

ជានិន្នាការនៃការអភិវឌ្ឍ និងវឌ្ឍនភាពនៅក្នុងប្រទេស និងរដ្ឋជាច្រើន។ រាល់អ្វីៗដែលមានគុណតម្លៃផ្នែកទីផ្សារ(market value) ឬត្រូវបានគេមើលឃើញថាចូលរួមចំណែកសំខាន់ក្នុងការលើកកម្ពស់ចំណេះដឹង ឬបច្ចេកវិទ្យាព័ត៌មានគឺត្រូវបានគេផ្តល់គុណតម្លៃ(98)។ នេះជាមូលហេតុដ៏ចម្បងដែលធ្វើឱ្យភាសាជនជាតិដើមមានការបាត់បង់យ៉ាងគំហុក។ ដោយសារអ្នកជំនាញសេដ្ឋកិច្ចមួយចំនួនបានចង្អុលបង្ហាញថា ភាសាជនជាតិដើមនៅតៃវ៉ាន់ត្រូវបានប្រើប្រាស់តែឪពុកម្តាយជនជាតិដើមភាគតិចមួយចំនួន គ្រូបង្រៀន និងសិស្ស ត្រូវបានគេចាត់ទុកថា វាគ្មានគុណតម្លៃទីផ្សារ និងមិនមានប្រយោជន៍(99)។ សម្រាប់តៃវ៉ាន់ ការរក្សាអត្តសញ្ញាណជនជាតិដើមជារឿងចាំបាច់មួយដែលការរក្សានូវគ្រឹះវប្បធម៌-អរិយធម៌របស់ជនជាតិដើមលើទឹកដីរបស់ខ្លួន ហើយមានលក្ខណៈខុសស្រឡះពីចិនដីគោកនេះជាការបញ្ជាក់មរតកវប្បធម៌ដាច់ដោយឡែកពីចិនដីគោក និងសម្រាប់បញ្ជាក់អធិបតេយ្យភាពមួយរបស់ខ្លួនផងដែរ។ ដើម្បីរក្សាអត្តសញ្ញាណជនជាតិដើមទាំងនេះ តៃវ៉ាន់យកចិត្តទុកដាក់ជាខ្លាំងក្នុងជួយដល់ការការអប់រំប្រកបដោយសមធម៌ដល់ជនជាតិដើមទាំងនោះ។ ស្ថិតិសិស្ស-និស្សិតជនជាតិដើម ដោយមិនគិតពីកម្រិតថ្នាក់ អត្រាសិក្សាមានតែ១៦% ហើយអត្រាសិក្សាកម្រិតវិទ្យាល័យ និងមហាវិទ្យាល័យមានតែ២៥% និង១៦% ប៉ុណ្ណោះដែលនៅដាច់ឆ្ងាយពីអត្រាសិក្សាសរុប។ បើយោងតាមការអង្កេតអប់រំក្នុងឆ្នាំ២០០០ អត្រាបោះបង់ការសិក្សារបស់សិស្សជនជាតិដើមមានអត្រាខ្ពស់ក្នុងសិស្សសរុប។ បើយើងគិតពីយេនឌ័រ អត្រាបោះបង់ការសិក្សាសិស្សជនជាតិដើមមានកម្រិតខ្ពស់ បើប្រៀបធៀងនឹងអត្រាសិស្សបោះបង់សរុបមានចំនួន១៧.០៣% និង២០.៦៣%។ ការអង្កេតក៏រកឃើញផងដែរហេតុផលមកពីគ្រួសារ និងផ្ទាល់ខ្លួនបានចូលរួមចំណែកចំពោះបញ្ហាបោះបង់ការសិក្សា។ ជាមួយគ្នានេះ សិស្សនៅកម្រិតវិទ្យាល័យបានបោះបង់ការសិក្សាទំនងជាដោយសារហេតុផលផ្ទាល់ខ្លួន ហើយសិស្សនៅកម្រិតបឋមសិក្សាដោយសារបញ្ហាគ្រួសារ (បញ្ហាហិរញ្ញវត្ថុ ការផ្លាស់ទី ឬការរំលោភ

បំពាន។ល។) មានអត្រាប្រជាជនជនជាតិដើមតែ៩%ប៉ុណ្ណោះ ដែលប្រកួតប្រជែងចូលរៀននៅមហាវិទ្យាល័យ និងការអប់រំជាន់ខ្ពស់។(100)

**តៃវ៉ាន់បានបង្កើតវិធានការជាច្រើនដើម្បីជួយដល់ការអប់រំសិស្សជនជាតិដើមតាមរយៈការបង្កើតច្បាប់ និងគោលនយោបាយអនុគ្រោះផ្សេងៗជាច្រើនដូចជា៖**

- ឆ្នាំ១៩៩៨ បង្កើតច្បាប់អប់រំសម្រាប់ជនជាតិដើម
- ឆ្នាំ២០០៥ ច្បាប់សិក្សានៅបរទេសដែលផ្តត់ផ្គង់ដោយរដ្ឋ និងសិស្សជនជាតិដើមដែលជាប់ចំណាត់ថ្នាក់ ច្បាប់នេះធ្វើវិសោធនកម្មនៅឆ្នាំ២០០៦
- ឆ្នាំ២០០៤ បង្កើតគោលការណ៍ថ្លៃអាហារ ទឹក ភ្លើង និងប្រាក់ឧបត្ថម្ភសម្រាប់ជនជាតិដើមនៅកម្រិតមធ្យមសិក្សានឹងទទួលការរ៉ាប់រងដោយក្រសួងអប់រំ
- ឆ្នាំ២០០៥ រដ្ឋាភិបាលតៃវ៉ាន់បានអនុម័តច្បាប់មូលដ្ឋានជនជាតិដើមដើម្បីធានាសិទ្ធិស៊ីវិលជនជាតិដើម និងជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍន៍ និងលើកកម្ពស់គោលនយោ-បាយជនជាតិដើម ដើម្បីធានានិរន្តរភាពរបស់ពួកគេ។
- ដើម្បីធានាសិទ្ធិស៊ីវិលស្មើភាព រដ្ឋាភិបាលបានផ្តល់នូវមូលនីធិសម្រាប់បង្កើតកូតាសិក្សានៅកម្រិតខ្ពស់ និងអាចធ្វើឱ្យជនជាតិដើមចូលរួមក្នុងសកម្មភាពផ្លាស់ប្តូរការសិក្សាអន្តរជាតិ។ ក្រោយមកគោលនយោបាយឆ្នាំ២០១១ក៏ផ្តោតចម្បងលើមូលដ្ឋាននីយកម្មដើម្បីអភិរក្ស និងបង្កើនភាពសាយភាយនៃវប្បធម៌និងការអប់រំ ជនជាតិដើម។
- ក្នុងឆ្នាំ២០១១ក្រសួងអប់រំបានបោះពុម្ព"គោលនយោបាយអប់រំជនជាតិដើម"(White Paper on Indigenous Educational Policy) ដើម្បីដោះស្រាយកម្មវិធីអប់រំទាក់ទងនឹងគោលនយោបាយ ប្រព័ន្ធ និងផែនការសម្រាប់ការអប់រំជនជាតិដើម។

(101) អត្រាប្រជាជនជនជាតិដើមតៃវ៉ាន់មានចំនួនច្រើនជាង ៥០០០០០នាក់ ចំនួនសិស្សជនជាតិដើមមានប្រមាណ ៤៥០០០នាក់ស្មើនឹង៣.៥%នៃសិស្សសាលាបឋមសិក្សាទាំងមូល(102) វិធានការពិសេសសម្រាប់ការប្រឡងរបស់សិស្សជនជាតិដើម ដូចជា៖ បូកបន្ថែម២៥ពិន្ទុប្រឡងចូលវិទ្យាល័យ ឬមហាវិទ្យាល័យ ការបង្កើតចំនួនកូតាពិសេសមួយទៅលើចំនួនសិស្សដែលបានកំណត់

- ចំណាយលើថ្លៃអាហារូបករណ៍ផ្សេងៗ( ប្រាក់ឧបត្ថម្ភ និងអាហារ )
- កំណត់ស្តង់ដារធ្វើតេស្តពិសេសសម្រាប់កម្រិតមធ្យមសិក្សា ( ឆ្នាំទី១មាន៤០ពិន្ទុ ឆ្នាំទី២ ៥០ពិន្ទុ និងឆ្នាំទី៣មាន៦០ពិន្ទុ )
- លក្ខណៈពិសេសផ្តោតលើជនជាតិដើម ( ការសិក្សាភាសាជាតិនៅថ្ងៃសៅរ៍ និងថ្ងៃឈប់សម្រាក ការបង្កើតថ្នាក់សិក្សាភាសាជាតិជនជាតិដើមនៅក្នុងសាលារៀន ប្រសិនបើការប្រឡងភាសាជាតិជាប់ ពិន្ទុប្រឡងចូលរៀននឹងថែម៥% សិក្សានៅបរទេសដែលផ្តត់ផ្គង់ដោយរដ្ឋ និងការចាត់ចែង ពិសេសសម្រាប់សិស្សជនជាតិដែលជាប់ចំណាត់ថ្នាក់ ថ្នាក់សិល្បៈរបស់ជនជាតិដើមនៅកម្រិតមធ្យមសិក្សាដើម្បីរក្សាការពារវប្បធម៌ ឱកាសខ្ពស់នៃការចូលរៀន និងការចូលរួមក្នុងបរិយាកាសប្រកួតប្រជែង។
- តៃវ៉ាន់បានកែសម្រួលសេចក្តីណែនាំកម្មវិធីសិក្សាពីថ្នាក់ទី១ ដល់ទី៩ ដោយតម្រូវឱ្យសិស្សរៀនភាសាអង់គ្លេសពីថ្នាក់ទី៣នៅកម្រិតបឋមសិក្សា( ចាប់ផ្តើមឆ្នាំ២០១១ )។ ដូច្នេះ វាបង្ហាញពីការលើកកម្ពស់សមត្ថភាពភាសាអង់គ្លេសរបស់សិស្ស និងពង្រីកវិសាលភាពទូលំទូលាយសម្រាប់អនាគត និងអាទិភាពរបស់ពួកគេ។
- សាលាបឋមសិក្សាជនជាតិដើមភាគច្រើនមានទីតាំងនៅតំបន់ជនបទដែលអ្នកស្ម័គ្រចិត្តអន្តរជាតិត្រូវបានចូលរួមជួយសាលា

រៀនទាំងនោះ។ ក្នុងករណីមានឱកាសច្រើនសម្រាប់ការផ្លាស់ប្តូរការសិក្សាអន្តរជាតិ។(103)

❖ **ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ គ្រូបង្រៀនតាមរយៈបណ្តាញព័ត៌មាន**

បណ្តាញព័ត៌មានសម្រាប់គ្រូបង្រៀនត្រូវបានបង្កើត និងគ្រប់គ្រងដោយស្ថាប័នជាតិមួយ ដើម្បីផ្តល់ឱកាសដល់គ្រូបង្រៀន និងមន្ត្រីអប់រំអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈខ្លួន តាមរយៈនៃការផ្តល់ដល់ពួកគេនូវវេទិកាទំនាក់ទំនងដើម្បីលើកកម្ពស់សមត្ថភាពខ្លួន។ នេះជាការលើកទឹកចិត្តគ្រូបង្រៀនដើម្បីបង្កើនអភិវឌ្ឍន៍សមត្ថភាពបន្តក្នុងការបង្រៀន។ ព័ត៌មានសកម្មភាពអភិវឌ្ឍន៍ និងកំណត់ត្រានៃការចូលរួមរបស់គ្រូបង្រៀនត្រូវបានបង្ហាញដោយវេទិកាឌីជីថល និងកត់ត្រា-គ្រប់គ្រងដោយប្រព័ន្ធស៊ើរវី (server)មួយ។ បណ្តាញនេះ ផ្តល់ព័ត៌មានសកម្មភាព និងកំណត់ត្រារៀនសូត្ររបស់បុគ្គលសម្រាប់គ្រូបង្រៀនពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា។ វេទិកាបច្ចេកវិទ្យាទិន្នន័យ ជាទម្រង់អេឡិចត្រូនិចសម្រាប់កត់ត្រាដំណើរការបណ្តុះបណ្តាលរបស់គ្រូបង្រៀន និងពេលវេលាសិក្សា។ (សម្រាប់ការរៀនសូត្រអស់មួយជីវិតរបស់គ្រូ)។ វាបង្កើតនូវយន្តការជាប្រក្រតីដើម្បីដាក់បញ្ចូលធនធានអប់រំ និងរដ្ឋបាលពីស្ថាប័នអប់រំ និងអាជ្ញាធរអប់រំមូលដ្ឋាន។ ទាំងនេះ ជាកំណែទម្រង់អប់រំមួយដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ បើនិយាយឱ្យងាយយល់ គឺគ្រូបង្រៀនត្រូវប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មានវិទ្យា( ឧ.កុំព្យូទ័រ...)សម្រាប់សិក្សារៀនសូត្រ ដូចជា៖ រៀនតាមរយៈប្រព័ន្ធអ៊ីនធ័រណេត (E-learning) ចែករំលែកព័ត៌មាន ចំណេះដឹងបទពិសោធន៍ និងការស្រាវជ្រាវនានារវាងគ្រូបង្រៀនទាំងឡាយនៅលើបណ្តាញ ព្រមទាំងសកម្មភាពផ្សេងៗជាច្រើនទៀត ហើយសកម្មភាពចូលរួមទាំងអស់នោះត្រូវបានកត់ត្រា និងប្រើប្រាស់សម្រាប់វាយតម្លៃការបំពេញការងាររបស់ពួកគេផងដែរ។ វាជាយន្តការជំរុញការអភិវឌ្ឍន៍សមត្ថភាពជំនាញវិជ្ជាជីវៈគ្រូបង្រៀននិងទម្រង់ការវាយតម្លៃផ្អែកលើភស្តុតាង (Evidence based evaluation) ពោលគឺមានមូលដ្ឋានច្បាស់លាស់ក្នុង

វាយតម្លៃឡើងកាំប្រាក់ ឬឋានៈដោយផ្អែកលើទន្និន័យផ្ទាល់របស់គ្រូម្នាក់ៗ។ ដូច្នេះ គ្មានអ្វីអាចកុហកបានឡើយជាមួយបច្ចេកវិទ្យា ព័ត៌មានពីចំនួនចូលរួមបណ្ដុះបណ្ដាល ការធ្វើសកម្មភាពចែករំលែក រៀនសូត្រ និងស្រាវជ្រាវរបស់គ្រូបង្រៀនត្រូវបានកត់ត្រាច្បាស់លាស់នៅក្នុងប្រព័ន្ធ ហើយក៏ត្រូវបានប្រើប្រាស់ផងដែរក្នុងពេលប្រជុំឆ្លុះបញ្ចាំងប្រចាំត្រីមាសស្ដីពីវឌ្ឍនភាព និងការបំពេញការងារ ដើម្បីធ្វើការកែលម្អ និងអភិវឌ្ឍន៍ឱ្យបានប្រសើរឡើង។ សម្រាប់កម្ពុជា **ការប្រើប្រាស់បណ្ដាញសង្គម បច្ចេកវិទ្យាដើម្បីជាប្រយោជន៍ក្នុងបង្កើនសមត្ថភាព និងអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈនៅមិនទាន់ផុលផុសនៅឡើយទេ** សូម្បីតែការទាញយកធនធាននៅក្នុងគេហទំព័រគ្រូបង្រៀន និងគេហទំព័រផ្សេងៗទៀតដែលមានស្រាប់ដើម្បីបម្រើដល់ការបង្រៀន និងរៀនក៏មិនសូវសកម្មផង។ បញ្ហាចំណេះដឹងICTរបស់គ្រូបង្រៀននៅតែជាបញ្ហាចោទនៅឡើយ ហើយចំណេះដឹងពីវិធីសាស្ត្របង្រៀន និងការអប់រំមានការវិវត្តមិនឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ។ **សម្រាប់សតវត្សរ៍ទី២១ ការលើកកម្ពស់សិក្សារៀនសូត្រពេញមួយជីវិត និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈគ្រូបង្រៀនគឺជារឿងចាំបាច់បំផុត ហើយអ្វីទាំងអស់នោះទាមទារចំណេះដឹង ITCសម្រាប់រៀនសូត្របន្តក្រៅសាលារៀន។** គ្រូបង្រៀននៅកម្ពុជា ទទួលការបណ្ដុះបណ្ដាលវិធីសាស្ត្របង្រៀន គរុកោសល្យ...មានតែរយៈពេល១ឆ្នាំ ឬ២ឆ្នាំពីសាលាគរុកោសល្យ ហើយមិនសូវមានវគ្គបំប៉នសមត្ថភាពបន្ថែមច្រើន រួមផ្សំសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិត អាចធ្វើឱ្យឱកាសសិក្សារៀនពេញមួយជីវិតមិនសូវមានដំណើរល្អ។ អំណោះតទៅ ដើម្បីអភិវឌ្ឍន៍វិស័យអប់រំ គេមិនចង់ឃើញគ្រូបង្រៀនមួយចំនួនដេកស៊ីឡាក់ និងរង់ចាំការតំលើងកាំប្រាក់ដោយស្វ័យប្រវត្តិនោះទេ ព្រោះវាអាចធ្វើឱ្យពួកគាត់ក្លាយជាមនុស្សខ្ជិល មិនសូវយកចិត្តទុកដាក់ប្រឹងប្រែងសិក្សារៀនសូត្រ និងបំពេញការងារដោយផ្ដេកផ្ដួលទៅលើការឡើងកាំប្រាក់ធម្មតាតាមចំនួនឆ្នាំដែលបានកំណត់។ វាដល់ពេលហើយ សម្រាប់ឱកាសគ្រូបង្រៀនទាំងឡាយណាដែលខិតខំបំពេញ

ការងារប្រកបដោយមនសិការវិជ្ជាជីវៈ និងមានស្មារតីរៀនសូត្រពេញមួយជីវិត ព្រមទាំងចែករំលែកចំណេះដឹង និងបទពិសោធទូលំទូលាយដល់អ្នកដទៃសំដៅធ្វើឱ្យរីកចម្រើនដល់វិស័យអប់រំកម្ពុជា ហើយជាអ្វីដែលក្រសួងបាននឹងកំពុងយកចិត្តទុកដាក់ចំពោះបញ្ហានេះ។

- **ពង្រឹងវិន័យយុវជនដោយកាតព្វកិច្ចយោធា**

បទបញ្ញត្តិនៅគ្រឹះស្ថានអប់រំចាប់ពីវិទ្យាល័យឡើងទៅ(រួមទាំងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ)គឺការទទួលខុសត្រូវរបស់**មន្ត្រីយោធា**ដែលមានទីតាំងនៅតាមសាលានីមួយៗ( individual schools ) (ផ្ទុយពីសាលាបឋមសិក្សា និងអនុវិទ្យាល័យដែលគ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលាជាទទួលខុសត្រូវលើវិន័យ)។ បន្ថែមពីលើមុខវិជ្ជាដែលត្រូវរៀនជាធម្មតា សិស្សសាលាតៃវ៉ាន់ក៏តម្រូវឱ្យចូលរៀនសាលាអប់រំផ្នែកយោធាដែលមានដូចជា៖ ការការពារជនស៊ីវិល ការហ្វឹកហ្វឺនយោធា ការការពារជាតិ និងបាញ់កាំភ្លើងមូលដ្ឋាន។ ក្រៅពីកាតព្វកិច្ចដូចខាងលើ វាជាដំណាក់កាលដ៏សំខាន់ក្នុងការលត់ដំសីលធម៌ វិន័យរបស់យុវជន ឱ្យក្លាយជាសរសៃទ្រូងជាតិពិតប្រាកដ ដូច្នេះគ្មានឡើយសិស្សជើងកាង ក្មេងទំនើង បងតូច-បងធំ បង្កអសន្តិសុខសង្គមនោះ។ ទាក់ទងនឹងបញ្ហាសីលធម៌ វិន័យសិស្សសាលាកម្រិតមធ្យមសិក្សាទុតិយភូមិនៅ***ប្រទេសកម្ពុជា*** វិញ យើងឃើញថានៅមានបញ្ហាប្រឈមច្រើនណាស់ ហើយទង្វើអសកម្មជាច្រើននៅតែកើតមានឡើងដូចជា៖ ការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង ក្មេងទំនើង ជើងកាងពាលាអាវ៉ាសែ...។ល។ ដែលកំពុងបំផ្លាញធនធានយុវជនខ្មែរជារៀងរាល់ថ្ងៃ ដោយមិនទាន់មានដំណោះស្រាយប្រកបដោយប្រសិទ្ធភាពនៅឡើយទេ។ ប្រទេសយើងមិនមានច្បាប់កាតព្វកិច្ចយោធាសម្រាប់យុវជនទេ។

### 3.6) ការអប់រំសាធារណៈ ( Public education )

ប្រព័ន្ធអប់រំសាធារណៈតៃវ៉ាន់ចាប់ពីមត្តេយ្យសិក្សាកម្រិតទាប ( nursery school )ដល់សាកលវិទ្យាល័យ។ ការអប់រំសាធារណៈបានដាក់

បញ្ចូលជាកាតព្វកិច្ចអប់រំពីបឋមសិក្សាដល់មធ្យមសិក្សាបឋមភូមិកាលពីឆ្នាំ១៩៦៨។ ក្នុងឆ្នាំ២០០១ ប្រហែល១៦%នៃថវិកាមជ្ឍការត្រូវបានចំណាយលើការអប់រំ។ ប្រធានាធិបតី ម៉ា បានប្រកាសពីផែនការកម្មវិធីអប់រំកាតព្វកិច្ចរយៈពេលពេញ១២ឆ្នាំ នៅឆ្នាំ២០១៤(104)។ លើសពីនេះទៅទៀត ការគាំទ្រថវិកាហិរញ្ញវត្ថុសម្រាប់ការអប់រំមត្តេយ្យសិក្សាបានចាប់ផ្តើមដោយមិនមានបង់ថ្លៃ។(104) ការចូលរៀននៅកម្រិតវិទ្យាល័យ ឬសាកលវិទ្យាល័យត្រូវបានត្រួតពិនិត្យដោយការប្រឡងថ្នាក់ជាតិ។ បទបញ្ញត្តិសាលាសាធារណៈ នៅគ្រប់កម្រិតថ្នាក់ទាំងអស់ ជាទូទៅមានភាពតឹងរឹង ដោយការស្លៀកពាក់ឯកសណ្ឋាន និងសញ្ញាដាស់ឱ្យភ្ញាក់ពេលព្រឹកព្រលឹមដែលជាបទដ្ឋាន (morning reveille being the norm)។ សិស្សានុសិស្សគ្រប់កម្រិតថ្នាក់ទាំងអស់រហូតវិទ្យាល័យមានភារកិច្ចទទួលខុសត្រូវសម្អាតបន្ទប់រៀនរបស់ពួកគេ និងទីធ្លារសាលា។ *ទណ្ឌកម្មរាងកាយត្រូវបានហាមឃាត់ជាផ្លូវការ ប៉ុន្តែរបាយការណ៍ជាច្រើន បានបង្ហាញថាវានៅតែអនុវត្តដោយគ្រូបង្រៀនជាច្រើន ហើយមាតាបិតាសិស្សក៏គាំទ្រសកម្មភាពនេះដែរ។* ករណីនេះ វាប្រហែលធ្វើឱ្យគ្រូបង្រៀនជាច្រើននៅកម្ពុជា មានការយល់ច្រឡំ ហើយគិតថា ប្រហែលប្រទេសដែលមានការរីកចម្រើនផ្នែកវិស័យអប់រំទាំងឡាយនៅអាស៊ីខាងកើតដូចជា៖ តៃវ៉ាន់ កូរ៉េ ជាដើម គេប្រកាន់ភ្ជាប់ការអប់រំបែបវិជ្ជមានបានល្អណាស់ហើយ បានជាការអប់រំគេជោគជ័យខ្លាំង និងផ្សព្វផ្សាយគំរូបែបនេះដល់កម្ពុជា។ ប៉ុន្តែការពិតប្រទេសជាច្រើននៅអាស៊ីខាងកើតទាំងនោះ នៅតែមានការប្រើប្រាស់ការទណ្ឌកម្មលើរាងកាយលើនៅសិស្សនៅឡើយទេ ហើយការដាក់សម្ពាធលើកូនពីសំណាក់ឪពុកម្តាយ និងសិស្សពី សំណាក់គ្រូបង្រៀនមានលក្ខណៈធ្ងន់ធ្ងរជាងកម្ពុជាឆ្ងាយណាស់ ដែលនាំឱ្យអត្រាធ្វើអត្តឃាតខ្ពស់ផងដែរ។

ឆ្នាំសិក្សាតៃវ៉ាន់ត្រូវបានបែងចែកជា២ឆមាស ដោយឆមាសទី១ ចាប់ផ្តើមនៅដើមខែកញ្ញា ដល់បំណាច់ខែមករា ឬដើមខែកុម្ភៈ ហើយវិស្សមកាលរដូវរងាមានរយៈ ពេល២ ឬ៣សប្តាហ៍ និងឆមាសទី២ចាប់

ផ្តើមពីពាក់កណ្តាលខែកុម្ភៈ និងបញ្ចប់នៅចុងខែមិថុនា។

### 3.7) **ការអប់រំបឋមសិក្សា** ( primary education )

សាលាបឋមសិក្សាចាប់គិតពីថ្នាក់ទី១ដល់ទី៦ ហើយរៀនពីថ្ងៃចន្ទដល់ថ្ងៃសុក្រចាប់ពីម៉ោង៧:៣០នាទី ដល់៤រសៀល។ មុខវិជ្ជាដែលត្រូវរៀនមាន៖

- ភាសាចិនកុកងឺ( ភាសាផ្លូវការក្នុងការបង្រៀន )
- គណិតវិទ្យា( ចាប់ពីការរៀនលេខ រហូតដល់រេខាគណិតមាត្រដែលសិក្សាទាក់ទងនឹងលំហ ទំនាក់ទំនងចំណុច បន្ទាត់ ខ្សែកោង និងផ្ទៃ )
- វិទ្យាសាស្ត្រ ( គ្រប់ដណ្តប់លើមុខវិជ្ជា ជីវវិទ្យា រូបវិទ្យា និងគីមីវិទ្យាមូលដ្ឋាន )
- ភាសាអង់គ្លេសៈ ភាសាអង់គ្លេស ជាមុខវិជ្ជាកាតព្វកិច្ចដែលដាក់បញ្ចូលក្នុងកម្មវិធីសិក្សាពីថ្នាក់ទី៣ឡើងទៅ
- ភាសាកំណើតៈ ភាសាតៃវ៉ាន់ និងចិនKakka (ដោយសារតៃវ៉ាន់មានចម្រុះជាតិសាសន៍ )
- សិក្សាសង្គម
- តន្ត្រី
- សិល្បៈ

នៅតៃវ៉ាន់ សិស្សត្រូវបានអនុញ្ញាតឱ្យចូលរៀនសាលាបឋមសិក្សាតាមភូមិសិក្សា ពោលគឺរៀនបានតែជាមួយសាលារៀនណាដែលនៅជិតអាសយ-ដ្ឋានរស់នៅដែលបានចុះបញ្ជីច្បាស់លាស់។ ដើម្បីឱ្យកូនចូលរៀននៅសាលារៀនល្បី នៅឆ្ងាយពីផ្ទះ ឪពុកម្តាយសិស្សមួយចំនួនបានបំពេញសំណុំឯកសារចុះបញ្ជីស្នាក់នៅរបស់កូនជាមួយញាតិសន្តាន ឬមិត្តភ័ក្រ។

### 3.8) **ការអប់រំមធ្យមសិក្សា**( Secondary Educaton )

❖ **កម្រិតមធ្យមសិក្សាបឋមភូមិ ( Lower secondary education )**

អនុវិទ្យាល័យចាប់ពីផ្ដើមពីថ្នាក់ទី៧ ដល់ទី៩ ហើយជាចំណុចកណ្ដាលនៃការអប់រំជាកាតព្វកិច្ច។(តៃវ៉ាន់ ការអប់រំជាកាតព្វកិច្ចមានពីថ្នាក់ទី១ដល់១២)។ ការសិក្សានៅអនុវិទ្យាល័យ នេះ សិស្សមានគោលដៅមួយក្នុងជីវិតគឺបានពិន្ទុខ្ពស់លើការប្រឡងថ្នាក់ជាតិចូលរៀនវិទ្យាល័យនៅចុងបញ្ចប់ថ្នាក់ទី៩។ ដូច្នេះ ការដាក់សម្ពាធលើសិស្សពីគ្រូបង្រៀន និងឪពុកម្ដាយសិស្សមានភាពតឹងតែងខ្លាំង ដោយសារមានតែតេសមួយប៉ុណ្ណោះក្នុងមួយឆ្នាំសិក្សានេះ។ ទោះបីជាការបង្រៀនផ្លូវការបញ្ចប់នៅម៉ោង៥ល្ងាចក៏ដោយជានិច្ចកាលសិស្សនៅតែបន្តនៅសាលារៀនរហូតដល់ម៉ោង៨ឬ៩ យប់ដើម្បីរៀនគួរបន្ថែម។

**មុខវិជ្ជាដែលសិស្សត្រូវសិក្សាមាន៖**

- **អក្សរសាស្ត្រ:**មានអក្សរសាស្ត្រចិនបុរាណ និងទំនើប កំណាព្យតែងសេចក្ដី និងការនិយាយជាសាធារណៈ
- **គណិតវិទ្យា:**ក្រុបដណ្ដប់ ពិជគណិតអថេរ១ និង២ (Single and two variable algebra) ធរណីមាត្រ កត្តវិទ្យា (proofs) ត្រីកោណមាត្រ (trigonometry) និងបុរេគណិតវិទ្យាជាន់ខ្ពស់ (pre-calculus)
- **ភាសាអង់គ្លេស:**មានវេយ្យាករណ៍អង់គ្លេស (Essential English Grammar)
- **វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា:**
  - **ជីវវិទ្យា:** រៀននៅឆ្នាំទី១(=ថ្នាក់ទី៧) រួមបញ្ចូលទាំងការសិក្សាស៊ីជម្រៅ និងការងារបន្ទប់ពិសោធន៍
  - **គីមីវិទ្យា:**រៀននៅឆ្នាំទី២(=ថ្នាក់ទី៨) ការណែនាំយ៉ាងល្អិតល្អន់ជាច្រើនពី អាតូម (atoms) ម៉ូលេគុល (molecule) និងប្រតិកម្មគីមីសាស្ត្រ (chemical reactions) និងការងារពិសោធន៍។

- **រូបវិទ្យាៈ**រៀននៅឆ្នាំទី៣ (=ថ្នាក់ទី៩) ការណែនាំយ៉ាងល្អិតល្អន់ជាច្រើនពីច្បាប់រូបវិទ្យានានា (physical laws) និងសមីការ (equations) រួមទាំងការងារពិសោធន៍
- **ផែនដីវិទ្យាៈ**រៀននៅឆ្នាំទី៣
- **បច្ចេកវិទ្យាៈ**រៀនទាំងបីឆ្នាំ (ពីថ្នាក់ទី៧ដល់ទី៩) មានណែនាំពីបច្ចេកវិទ្យាមូលដ្ឋានមួយចំនួនដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។

- **សិក្សាសង្គម**
  - **ពលរដ្ឋវិជ្ជាៈ**ភាពជាប្រជារាស្ត្រមូលដ្ឋាន នយោបាយ និងសេដ្ឋកិច្ច
  - **ប្រវត្តិវិទ្យាៈ**ផ្តោតលើប្រវត្តិសាស្ត្រតៃវ៉ាន់ និងចិនអំឡុង២ឆ្នាំដំបូង និងប្រវត្តិសាស្ត្រពិភពលោកនៅឆ្នាំទី៣
  - **ភូមិវិទ្យាៈ**ផ្តោតលើភូមិវិទ្យាសិក្សាពីកោះតៃវ៉ាន់នៅឆ្នាំទី១ ភូមិវិទ្យាសិក្សាពីប្រទេសចិន និងអាស៊ីខាងកើតនៅឆ្នាំទី២ និងភូមិវិទ្យាពិភពលោកឆ្នាំទី៣
- **សេដ្ឋកិច្ចនៅផ្ទះ និងសិប្បកម្ម**
- **សិល្បៈ** រួមបញ្ចូលផ្នែកបីគឺៈវិចិត្រសិល្បៈ តន្ត្រី និងល្ខោន
- **ការអប់រំកាយវិទ្ធិៈ**បំណិនជីវិតខាងក្រៅ

នៅចុងឆ្នាំសិក្សាឆ្នាំទី៣ (=ថ្នាក់ទី៩) សិស្សចូលរួមក្នុងការប្រឡងថ្នាក់ជាតិដើម្បីចូលរៀនកម្រិតមធ្យមសិក្សាទុតិយភូមិ ហើយសិស្សត្រូវបានបែងចែកឱ្យចូលរៀនវិទ្យាល័យទៅតាមពិន្ទុរបស់គេ។ សិស្សក៏អាចចូលរួមប្រឡងថ្នាក់ជាតិដាច់ដោយឡែកមួយទៀតដើម្បីចូលរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការប្រឡងចូលរៀនសាលាទាំងពីរនេះ សាលារៀនរដ្ឋមានប្រជាប្រិយភាពបំផុត ខណៈសាលាឯកជនសម្រាប់តែសិស្សណាដែលប្រឡងមិនបានពិន្ទុគ្រប់គ្រាន់ដើម្បីចូលរៀនបាន។ ប្រហែលជា៩៤.៧%នៃ

សិស្សមធ្យមសិក្សាបឋមភូមិ បន្តការសិក្សាទៅមធ្យមសិក្សាទុតិយភូមិ ឬសាលាបណ្តុះបណ្តាលបច្ចេកទេស។

❖ **កម្រិតមធ្យមសិក្សាទុតិយភូមិ** (Upper secondary education)

វិទ្យាល័យគឺចាប់ផ្តើមពីថ្នាក់ទី១០ ដល់ទី១២ ហើយគោលដៅសំខាន់របស់សិស្សមានលក្ខណៈដូចនៅមធ្យមសិក្សាបឋមភូមិដែរគឺយកឱ្យបាននូវពិន្ទុខ្ពស់ក្នុងការប្រឡងចូលរៀនមហាវិទ្យាល័យនៅពេលបញ្ចប់ថ្នាក់ទី១២។ បទបញ្ញត្តិនៅវិទ្យាស្ថានអប់រំពីវិទ្យាល័យឡើងទៅ (រួមទាំងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ)គឺ ត្រូវទទួលខុសត្រូវរបស់**មន្ត្រីយោធា**ដែលមានទីតាំងនៅតាមសាលារៀននីមួយៗ ( indivi-dual schools) (ផ្ទុយពីសាលាបឋមសិក្សា និងអនុវិទ្យាល័យដែលគ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលាជាទទួលខុសត្រូវលើវិន័យ)។ បន្ថែមពីលើមុខវិជ្ជាដែលត្រូវរៀនជាធម្មតា សិស្សសាលាតៃវ៉ាន់ក៏តម្រូវឱ្យចូលរៀនសាលាអប់រំផ្នែកយោធា ដែលមានដូចជា៖ ការការពារជនស៊ីវិល ការហ្វឹកហ្វឺនយោធា ការការពារជាតិ និងបាញ់កាំភ្លើងមូលដ្ឋាន។ កាលពីអតីតកាល សិស្សវិទ្យាល័យ និងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ត្រូវបានគេរំពឹងថានឹងមានកាតព្វកិច្ចការពារជនស៊ីវិល ក្នុងអំឡុងពេលមានព្រឹត្តិការណ៍គ្រោះអាសន្នជាតិបន្ទាន់អ្វីមួយកើតឡើង។ បុរស និងស្ត្រីត្រូវហ្វឹកហាត់ប្រើប្រាស់កាំភ្លើង និងគប់គ្រាប់បែកដៃ។

នៅវិទ្យាល័យជាច្រើន សិស្សអាចជ្រើសរើសប្រភេទថ្នាក់វិទ្យាសាស្ត្រ ឬថ្នាក់សង្គម (liberal arts)អាស្រ័យលើចំណាប់អារម្មណ៍របស់ពួកគេ។ ប្រភេទថ្នាក់ខុសគ្នានេះ ជាទូទៅសំដៅទៅលើក្រុមសិស្ស។ សិស្សថ្នាក់វិទ្យាល័យតៃវ៉ាន់ត្រូវបានបែងចែកជា០៣ក្រុម។ ទី១-គឺក្រុមមុខវិជ្ជាសិក្សាសង្គម សម្រាប់សិស្សដែលបំណិនប្រសប់ផ្នែកវិទ្យាសាស្ត្រសង្គម។ ទី២-គឺក្រុមមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ សម្រាប់សិស្សដែលមានទេពកោសល្យលើមុខវិជ្ជាទាំងនេះ។ ទី៣-គឺក្រុមវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រសម្រាប់សិស្សដែលពូកែមុខវិជ្ជាជីវវិទ្យា និងវិទ្យាសាស្ត្រ។ ការបែងចែកនេះ

ធ្វើឱ្យសិស្សមានប្រាកដប្រជាសម្រាប់ការបន្តការសិក្សានៅសាកលវិទ្យាល័យ និងអាជីពខ្លួនពេលអនាគត(105)។ កម្មវិធីសិក្សាថ្នាក់វិទ្យាសាស្ត្រមានមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យាលំបាកៗ ហើយថ្នាក់នេះជុះខាត់សិស្សសម្រាប់អាជីពវិទ្យាសាស្ត្រ និងវិស្វករ។ ចំណែកឯ ថ្នាក់សង្គមផ្តោតខ្លាំងលើអក្សរសាស្ត្រ និងសិក្សាសង្គម ដើម្បីរៀបចំសិស្សបម្រើការលើវិស័យទាំងនេះនាពេលអនាគត។ ជានិច្ចកាល សិស្សថ្នាក់សង្គមអាចលើកលែងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្របើសិនជាពួកគេចង់ ហើយសិស្សថ្នាក់វិទ្យាសាស្ត្រមិនតម្រូវឱ្យរៀនភូមិវិទ្យា ពលរដ្ឋវិជ្ជា និងប្រវត្តិសាស្ត្រទេ។ ការប្រឡងចូលសាកលវិទ្យាល័យត្រូវបានគ្រប់គ្រងដោយវិធីសាស្ត្រ២យ៉ាង៖ ការបញ្ជាក់លក្ខណៈសម្បត្តិ ឬការប្រឡង។ សម្រាប់អ្នកដែលចូលរួមជាមួយការបញ្ជាក់លក្ខណៈសម្បត្តិ ពួកគេត្រូវតែចូលរួមប្រឡងថ្នាក់ជាតិ និងជ្រើសរើសសាកលវិទ្យាល័យដែលគេពេញចិត្ត រួចដាក់សំណើសុំចូលរៀនទៅសាលាទាំងនោះ។ ដំណាក់កាលដំបូង គេសម្រិតសម្រាំងលទ្ធផលប្រឡងពីបេក្ខជនសម្រាប់ជ្រើសរើសអ្នកដែលសមត្ថភាពពេញលេញ និងសមស្រប។ ដំណាក់កាលទី២ គឺវាអាស្រ័យទៅលើលក្ខខណ្ឌដែលសាលានីមួយៗជ្រើសរើស។ ចំណែកឯ អ្នកដែលមិនជ្រើសរើសដំណើរការនៃការបញ្ជាក់លក្ខណៈសម្បត្តិ ឬសំណើដាក់ពាក្យចូលរៀនមិនទទួលជោគជ័យទេ ពួកគេមានជម្រើសចូលរួមប្រឡងថ្នាក់ជាតិចូលរៀនសាកលវិទ្យាល័យ បន្ទាប់ពីបញ្ចប់ការសិក្សាមធ្យមសិក្សាទុតិយភូមិ។ មានន័យថា គេត្រូវប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិ និងប្រឡងចូលមហាវិទ្យាល័យ។

### 3.9) **សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ** ( Vocational Training School )

បន្ទាប់ពីប្រឡងបញ្ចប់មធ្យមសិក្សាបឋមភូមិ សិស្សត្រូវជ្រើសរើសថាតើគេជ្រើសរើសចូលរៀនបន្តនៅវិទ្យាល័យចំណេះទូទៅ ឬសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ។ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវសិក្សារយៈពេល៣ឆ្នាំ

ប្រហាក់ប្រហែលនឹងការសិក្សានៅវិទ្យាល័យដែរ។ តែអ្វីដែលមិនដូចនឹងវិទ្យាល័យនោះគឺ សិស្សត្រូវសិក្សាដោយផ្តោតខ្លាំងលើជំនាញវិជ្ជាជីវៈ និងការអនុវត្តជាក់ស្តែង។ សិស្សអាចជ្រើសរើសរៀនតែមួយមុខជំនាញដូចជាៈ វិស្វករអគ្គិសនី វិស្វករសំណង់ស៊ីវិល វិទ្យាសាស្ត្រកុំព្យូទ័រ ឬពាណិជ្ជកម្ម។ សាលាបណ្តុះបណ្តាលជំនាញឯកទេសមួយចំនួន ក៏ផ្តល់នូវកម្មវិធីនាវាចរ និងកសិកម្ម។ សិស្សដែលបញ្ចប់ការសិក្សាជំនាញវិជ្ជាជីវៈក៏អាចចូលរួមប្រឡងថ្នាក់ជាតិដើម្បីចូលរៀនសាកលវិទ្យាល័យបានដែរ។ វាជាធម្មតាទេសម្រាប់សិស្សក្នុងការជ្រើសរើសសាលាបណ្តុះបណ្តាលវិជ្ជាជីវៈលើវិទ្យាល័យ និងបន្តសិក្សា៤ឆ្នាំទៅមុខទៀតនៅសាកល ឬមហាវិទ្យាល័យ។ មានស្ថាប័នជាង១០០សម្រាប់ការអប់រំជាន់ខ្ពស់នៅតៃវ៉ាន់។ ប្រមាណ២ភាគ៣ក្នុងចំណោមសិស្សជាង១០០,០០០នាក់ដែលចូលរួមប្រឡងថ្នាក់ជាតិចូលរៀនត្រូវបានសាកលវិទ្យាល័យឬ មហាវិទ្យាល័យទទួលយក។ ប្រព័ន្ធអប់រំជាន់ខ្ពស់នៅតៃវ៉ាន់ប្រហាក់ប្រហែលនឹងអាមេរិកដែរ។ តាំងពីឆ្នាំ១៩៩០មក សាលាពាណិជ្ជកម្ម និងអនុមហាវិទ្យាល័យ (junior colleges)ជាច្រើនត្រូវបានលើកកម្ពស់ធ្វើឱ្យប្រសើរឡើងប្រែក្លាយជាសាកលវិទ្យាល័យដែលអាចទទួលអត្រាចូលរៀនសាកលវិទ្យាល័យខ្ពស់។ ទោះបីយ៉ាងណាក៏ដោយ ពិន្ទុខ្ពស់នៅតែផ្នែកសំខាន់ដែលគេចង់បានជាលក្ខណៈវិនិច្ឆ័យទទួលឱ្យចូលរៀននៅស្ថាប័នដែលកិត្យានុភាពសង្គម និងសេដ្ឋកិច្ច[106]។ ទោះបីតៃវ៉ាន់មានធនធានធម្មជាតិតិច និងជួបប្រទះនឹងការលំបាកផ្នែកនយោបាយការទូត ក៏តៃវ៉ាន់នៅតែរកឃើញផ្លូវជំនះការលំបាកទាំងនោះកសាងតៃវ៉ាន់ប្រកបដោយភាពអស្ចារ្យ និងក្លាយជាកោះមួយដែលមានការរីកចម្រើនសេដ្ឋកិច្ចខ្លាំងជាខ្លានៅអាស៊ី។ ការបណ្តុះបណ្តាលវិជ្ជាជីវៈដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចតៃវ៉ាន់រីកចម្រើន។ រដ្ឋាភិបាលបានយកចិត្តទុកជាខ្លាំងក្នុងការវិនិយោគធនធានមនុស្សតាមរយៈការអភិវឌ្ឍការអប់រំវិជ្ជាជីវៈ និងបច្ចេកទេស។ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការសិក្សានៅសាលាចំណោះទូទៅនៅតៃវ៉ាន់នេះ មានប្រជាប្រិយភាព

ប្រហាក់ប្រហែលគ្នា ដែលខុសស្រឡះពីប្រទេសកម្ពុជាយើងដែលសិស្ស-និស្សិតភាគច្រើនចាប់អារម្មណ៍រៀននៅសាលាចំណេះទូទៅច្រើនជាងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលនាំឱ្យកង្វះធនធានមនុស្សក្នុងបរិបទនៃការប្រកួតប្រជែងសេដ្ឋកិច្ចសតវត្សរ៍ទី២១។

## 3.10) ទំនាក់ទំនងការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិវឌ្ឍការអប់រំវិជ្ជាជីវៈ-បច្ចេកទេស(TVE)

| ឆ្នាំ | ការអភិវឌ្ឍសេដ្ឋកិច្ច | ការអភិវឌ្ឍការអប់រំវិជ្ជាជីវៈ និង បច្ចេកទេស (TVE) | ផលធៀបសិស្ស TVE & សិស្សទូទៅ |
|---|---|---|---|
| ទសវត្សឆ្នាំ ១៩៥០ | ▪ ជោគជ័យលើកំណែទម្រង់ដីធ្លី<br>▪ បង្កើននូវផលិតផលកសិកម្ម | ▪ អប់រំផ្នែកកសិកម្ម និង ពាណិជ្ជកម្ម | ៤:៦ |
| ទសវត្សឆ្នាំ ១៩៦០ | ▪ ពង្រីកពាណិជ្ជកម្មនាំចេញ នាំចូល | ▪ អភិវឌ្ឍន៍ការអប់រំវិជ្ជាជីវៈ ពាណិជ្ជកម្ម និងឧស្សាហកម្ម<br>▪ ពង្រីកកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤:៦ |
| ទសវត្សឆ្នាំ ១៩៧០ | ▪ ផ្តួចផ្តើមកសាងជាតុសំខាន់ទាំង១០ | ▪ លើកកម្ពស់ការអប់រំវិជ្ជាជីវៈ ឧស្សាហកម្ម និងអប់រំនៅអនុមហាវិទ្យាល័យ (ចាប់គិតពីថ្នាក់ទី១០ដល់ឆ្នាំទី២ ថ្នាក់មហាវិទ្យាល័យ ស្មើបរិញ្ញាប័ត្ររង) | ៦:៤ |
| ទសវត្សឆ្នាំ ១៩៨០ | ▪ អភិវឌ្ឍន៍ឧស្សាហកម្មបច្ចេកវិជ្ជាខ្ពស់ | ▪ ធ្វើឱ្យប្រសើរឡើងនូវបរិមាណ និងគុណភាពការអប់រំវិជ្ជាជីវៈឧស្សាហកម្ម | ៧:៣ |

| | | | |
|---|---|---|---|
| | ▪ អភិវឌ្ឍន៍ឧស្សាហកម្មតេលសីលាគីមី (សារធាតុគីមីដែលយកចេញពីប្រេងកាត និងឧស្ម័នធម្មជាតិ) | និងការអប់រំអនុមហាវិទ្យាល័យ | |
| ទសវត្សឆ្នាំ ១៩៩០ | ▪ អភិវឌ្ឍន៍សេដ្ឋកិច្ចចំណេះដឹង<br>▪ កសាងផែនការមជ្ឈមណ្ឌលប្រតិបត្តិការតំបន់អាស៊ី ប៉ាស៊ីហ្វិក | ▪ បង្កើនមហាវិទ្យាល័យបច្ចេកវិទ្យា<br>▪ ប្រែក្លាយមហាវិទ្យាល័យបច្ចេកវិទ្យាទៅជាសាកលវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | **៥:៥** |
| ទសវត្សឆ្នាំ ២០០០ | ▪ អភិវឌ្ឍន៍ឧស្សាហកម្មតារាភ្លោះ និង២សែនកោដិ (Two Trillion & Twin Star industries) | ▪ កំណត់អតិប្បរមា និងអន្តរនីយកម្មការអប់រំវិជ្ជាជីវៈ និងបច្ចេកទេស | **៥:៥** |
| ទសវត្សឆ្នាំ ២០១០ | ▪ អភិវឌ្ឍន៍ឧស្សាហកម្មលេចចេញថ្មី៦ ឧស្សាហកម្មវិទ្យាសាស្ត្រសំខាន់ ១០ និងឧស្សាហកម្មផ្នែកបញ្ញាសំខាន់៤ | ▪ ផ្តោតលើការបន្ស៊ីនឹងតម្រូវការកម្លាំងការងារសម្រាប់ឧស្សាហកម្ម និងសម្បទាសិស្ស | **៦.២:៣.៨** |

**ចំណុចគន្លឹះសម្រាប់ការអប់រំវិជ្ជាជីវៈ និងបច្ចេកទេសជាន់ខ្ពស់**

| ល | ចំណុចគន្លឹះ | ខ្លឹមសារសង្ខេប |
|---|---|---|
| ១ | **កម្មវិធី និងប្រព័ន្ធដែលមានលក្ខណៈទូលំទូលាយ** | ចាប់ពីអនុវិទ្យាល័យ វិទ្យាល័យ អនុមហាវិទ្យាល័យ សាកលវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដើម្បីបញ្ចប់ការសិក្សាកម្មវិធីអនុបណ្ឌិតនិងបណ្ឌិត |
| ២ | **គ្រឹះស្ថានសិក្សាឯកជនដែលមានភាពជឿនលឿន ល្អឥតខ្ចោះ និងសកម្ម** | ដែលមិនត្រឹមតែមានចំនួនលើសពីគ្រឹះស្ថានអប់រំវិជ្ជាជីវៈ និងបច្ចេកទេសសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែធ្វើឱ្យមានភាពស៊ីគ្នារវាងការអប់រំវិជ្ជាជីវៈ និងបច្ចេកទេសជាមួយតម្រូវការ |

| | | |
|---|---|---|
| | | ទីផ្សារដោយសារការអប់រំមានទំនាក់ទំនងជិតស្និទ្ធជាមួយឧស្សាហកម្មនិងសហគ្រាស។ |
| ៣ | **កម្មវិធីចម្រុះ និងបែបបន្សាំ** (Diversified and adaptive programs) | រាប់បញ្ចូលទាំងក្រុមការងារវិជ្ជាជីវៈកម្រិតវិទ្យាល័យ កម្មវិធីវិជ្ជាជីវៈកម្រិតវិទ្យាល័យដែលមានលក្ខណៈទូលំទូលាយ កម្មវិធីផ្នែកសេវាខាងក្នុង (In-Service programs)។ ល។ ដើម្បីធ្វើឱ្យសមស្របទៅនឹងភាពពេញចិត្តរបស់សិស្ស និងដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្សេងៗផ្នែកឧស្សាហកម្ម។ |
| ៤ | **ការអនុវត្តដ៏ល្អឥតខ្ចោះនៅក្នុងកិច្ចសហប្រតិបត្តិការឧស្សាហកម្ម - ការសិក្សា** | ▪ គម្រោងបណ្តុះបណ្តាលវិជ្ជាជីវៈពីរ<br>▪ ផែនការសហប្រតិបត្តិការសិក្សា-ឧស្សាហកម្ម<br>▪ កម្មវិធីអប់រំដែលមានមូលដ្ឋានលើទីផ្សារ (Market-based Education Program ) |
| ៥ | **ការបំពេញការងារឆ្នើមនៅក្នុងការប្រកួតប្រជែងអន្តរជាតិ** | សាកលវិទ្យាល័យបច្ចេកវិទ្យាបានឈ្នះពានរង្វាន់ the iF Product Design Gold Award<br>•សាកលវិទ្យាល័យជាច្រើនទៀតបានទទួលពានរង្វាន់រចនាពណ៌ក្រហម (Red Dot Design Award) |

## គោលនយោបាយសំខាន់ៗសម្រាប់ការអប់រំវិជ្ជាជីវៈ និងបច្ចេកទេស

| ល.រ | គោលនយោបាយ | ខ្លឹមសារសង្ខេប |
|---|---|---|
| ១ | **លើកកម្ពស់ដ៏សកម្មពីគុណភាពបង្រៀន** (Proactively improving teaching quality) | ដោយការអនុវត្ត«គម្រោងការបង្រៀនល្អឥតខ្ចោះសម្រាប់សាកលវិទ្យាល័យ / មហាវិទ្យាល័យបច្ចេកវិទ្យា»តាមរយៈការប្រមូលផ្តុំប្រភពធនធានឧស្សាហកម្មសម្រាប់ការបង្រៀនស្តីពីការអប់រំវិជ្ជាជីវៈ និងបច្ចេកទេសរួមគ្នា តាមរយៈការពង្រឹងសមត្ថភាពបង្រៀនរបស់គ្រូជំនាញនៅក្នុងស្ថាប័នអប់រំវិជ្ជាជីវៈ និងបច្ចេកទេស ព្រមទាំងតាមរយៈការធ្វើឱ្យមាននិរន្តរភាពនៃប្រព័ន្ធវិញ្ញាបនប័ត្រវិជ្ជាជីវៈ។ ល។ |

| | | |
|---|---|---|
| ២ | **លើកកម្ពស់ការវាយតម្លៃសម្រាប់គ្រឹះស្ថានអប់រំ វិជ្ជាជីវៈ និងបច្ចេកទេស** | ដើម្បីជានាគុណភាពអប់រំ និងដើម្បីជួយដល់គ្រឹះស្ថានអប់រំវិជ្ជាជីវៈ និងបច្ចេកទេសជាន់ខ្ពស់ទាំងនេះក្នុងការអភិវឌ្ឍឯកទេសផ្ទាល់ខ្លួនរបស់ពួកគេ |
| ៣ | **ផ្តោតលើការច្នៃប្រឌិត កិច្ចសហប្រតិបត្តិការការសិក្សា-វិស័យឧស្សាហកម្ម ព្រមទាំងការស្រាវ ជ្រាវ និងអភិវឌ្ឍន៍** ( Emphasizing industrial-academic cooperation innovation and R&D ) | តាមរយៈការបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការឧស្សាហកម្ម និងការសិក្សាថ្នាក់តំបន់ និងតាមរយៈការអនុវត្តកម្មវិធីនានាដូចជាៈ កម្មវិធីហាត់ការ ថ្នាក់កិច្ចសហប្រតិបត្តិការការសិក្សា-វិស័យឧស្សាហកម្មពិសេស ព្រមទាំងធនធានមនុស្សសហគ្រិន-វិស័យឧស្សាហកម្ម ដែលគាំទ្រកម្មវិធីជាដើម។ |
| ៤ | **អភិវឌ្ឍភាពជាគំរូសម្រាប់សាកលវិទ្យាល័យបច្ចេកវិទ្យា** ( Developing Technological University Paradigms ) | អភិវឌ្ឍន៍ភាពជាគំរូសម្រាប់សាកលវិទ្យាល័យបច្ចេកវិទ្យាដើម្បីលើកកំពស់ស្តង់ដារការអប់រំវិជ្ជាជីវៈ និងបច្ចេកទេសជាន់ខ្ពស់តាមរយៈការបណ្តុះទេពកោសល្យក្នុងស្រុកជាមួយការបណ្តុះបណ្តាលប្រកបដោយភាពច្នៃប្រឌិត ការលើកកម្ពស់កិច្ចសហប្រតិបត្តិការឧស្សាហកម្ម- ការសិក្សា និងតាមរយៈការពង្រឹងការផ្ទេរបច្ចេកវិទ្យា និងការធ្វើពាណិជ្ជនីយកម្មនៃលទ្ធផលស្រាវជ្រាវ |
| ៥ | **អនុវត្តជំហានទី២នៃការសម្រួលរចនាសម្ព័ន្ធអប់រំវិជ្ជាជីវៈ និងបច្ចេក ទេស** ( Implementing the Phase II of TVE restructure ) | រួមបញ្ចូលទាំងការធ្វើឱ្យប្រសើរឡើងនូវឧបករណ៍ សមាហរណកម្មធនធានសម្រាប់មជ្ឈមណ្ឌលអប់រំថ្នាក់តំបន់ ផ្តល់ជូននូវកម្មវិធីភាពជាដៃគូការសិក្សា និងវិស័យឧស្សាហកម្មឯកទេស និងបង្កើនជំនាញអនុវត្តរបស់គ្រូបង្រៀន។ |

## ចំណុចខ្លាំងនៃការអប់រំជាន់ខ្ពស់នៅតៃវ៉ាន់

| ល.រ | មុខជំនាញ | ការបកស្រាយ |
|---|---|---|
| ១ | **វិស្វកម្មអគ្គីសនីនិងម៉េតាទ័រ** (Electrical & Mechatronic Engineering) | ▪ ដើម្បីអប់រំវិស្វករ និងអ្នកស្រាវជ្រាវដែលមានគុណភាពខ្ពស់សម្រាប់វិស័យឧស្សាហកម្មដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស<br>▪ ផ្តល់នូវបច្ចេកវិទ្យា និងការច្នៃប្រឌិតទំនើបៗ ដល់ឧស្សាហកម្ម<br>▪ ដើម្បីភ្ជាប់គម្លាតរវាងការស្រាវជ្រាវជាមូលដ្ឋាន និងការអនុវត្តវិស័យឧស្សាហកម្ម |
| ២ | **វិទ្យាសាស្ត្រកុំព្យូទ័រនិងព័ត៌មានវិទ្យា** (Computer Science & Information Technology) | ▪ ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានដែលមានប្រយោជន៍និងទំនើប<br>▪ អភិវឌ្ឍន៍ការយល់ដឹងសិស្សឱ្យមានលក្ខណៈទូលំទូលាយ និងសមត្ថភាពប្រកួតប្រជែង ដើម្បីប្រឈមនឹងការរីកចម្រើនខាងបច្ចេកវិទ្យានៅលើពិភពលោក<br>▪ អប់រំអ្នកជំនាញដែលបានបញ្ចប់ការសិក្សាដែលឆ្លើយតបទៅនឹងតម្រូវការវិស័យឧស្សាហកម្មកុំព្យូទ័រ |
| ៣ | **ផលិតកម្មឧស្សាហកម្ម** (Industrial Manufacture) | ▪ ដើម្បីឱ្យសិស្សយល់ច្បាស់អំពីដំណើរការពេញលេញនៃផលិតកម្មវិស័យឧស្សាហកម្មដូចជា៖ ការរចនា ការវិភាគ ការផលិត និងនិម្មិតកម្ម<br>▪ បង្កើនបច្ចេកទេសផលិតដល់សិស្សដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនវិស័យឧស្សាហកម្ម |
| ៤ | **សិល្បៈ & ការរចនា** (Arts & Design) | ▪ ដើម្បីបណ្តុះអ្នករចនាផលិតផលដែលត្រូវបានបំពាក់បំប៉ននូវចំណេះដឹងទាក់ទងនឹងការរចនាទ្រឹស្តីនិងការអនុវត្តការរចនាដើម្បីបង្កើន |

| | | |
|---|---|---|
| | | បច្ចេកទេសផលិតរបស់សិស្ស/និស្សិតដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនវិស័យឧស្សាហកម្ម។<br>▪ បណ្តុះអ្នករចនាប្រកបដោយគំនិតច្នៃប្រឌិត និងអប់រំពួកវាឆ្ពោះទៅរកអ្នកជំនាញខាងរចនាដែលអាចបង្កើត និងចូលរួមក្នុងការស្រាវជ្រាវការរចនា និងការអភិវឌ្ឍ រៀបចំផែនការនិងការគ្រប់គ្រង។ |
| ៥ | **វិស័យកសិកម្ម**<br>(Agriculture) | ▪ ពង្រឹងបច្ចេកទេសផលិតរបស់សិស្ស/និស្សិតដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនវិស័យឧស្សាហកម្ម និងកសិកម្មក្នុងតំបន់<br>▪ អនុញ្ញាតឱ្យនិស្សិតអាចយល់ដឹងអំពីបុប្ផវប្បកម្ម (ការដាំផ្កា)និងបណ្តុះកូនឈើ អាជីវកម្មផ្លែឈើប្រភេទថ្មីតំបន់ត្រូពិក បច្ចេកវិជ្ជាស្វ័យប្រវត្តិ អនុវត្តបច្ចេកវិទ្យាដាំដុះជីវសាស្ត្រ (plant biotechno-logy) ដាំដំណាំរុក្ខជាតិឱសថ |
| ៦ | **ផលិតកម្មនិងការគ្រប់គ្រងជលផល**<br>(Fishery Production & Management) | ▪ ផ្តល់ដល់និស្សិតនូវជំនាញបច្ចេកទេសក្នុងការការពារបរិស្ថានសមុទ្រ ការបង្ការការបំពុល ការវិភាគ ការធ្វើតេស្ត សិក្សាគំរូសំណាក ប្រតិបត្តិការ និងការអភិរក្ស<br>▪ បណ្តុះបុគ្គលិកបច្ចេកទេសដែលមានជំនាញជាក់លាក់ទាក់ទងនឹងផលិតកម្ម និងការគ្រប់គ្រងជលផល វិទ្យាសាស្ត្រអាហារសមុទ្រ វារីវប្បកម្មក៏ដូចជាបច្ចេកវិទ្យាជីវសាស្ត្រសមុទ្រ |
| ៧ | **គ្រប់គ្រងបដិសណ្ឋារកិច្ចនិងទេសចរណ៍**<br>(Hospitality & Tourism Management) | ▪ ដើរតាមនិន្នាការទេសចរណ៍នៅទូទាំងពិភពលោកដើម្បីសហការជាមួយនឹងការរីកចម្រើននៃឧស្សាហកម្មសេវាកម្មបដិសណ្ឋារកិច្ចនៅក្នុងប្រទេសក៏ដូចជាតម្រូវការនៃជំនាញនៅក្នុង |

| | | |
|---|---|---|
| | | ឧស្សាហកម្មដើម្បីជំនះឧបសគ្គនៃការអភិវឌ្ឍផ្នែកសណ្ឋាគារនៅប្រទេស និងបង្កើនគុណភាពនៃការគ្រប់គ្រងសណ្ឋាគារ និងសេវាកម្ម។<br>▪ បណ្ដុះបណ្ដាលបុគ្គលិកផ្នែកគ្រប់គ្រងក្នុងវិស័យសម្រាកលំហែកាយ ការកំសាន្ត រមណីយដ្ឋាន និងកាស៊ីណូ |

**រចនាសម្ព័ន្ធសហប្រតិបត្តិការការសិក្សា និងវិស័យឧស្សាហកម្ម**

## 3.11) ប្រៀបធៀបការបណ្ដុះបណ្ដាល និងទីផ្សារការងាររវាងតៃវ៉ាន់ និងជប៉ុន[107]

ការអប់រំត្រូវបានគេចាត់ទុកជាវិស័យដ៏សំខាន់ក្នុងជំរុញកំណើនសេដ្ឋកិច្ច និងអភិវឌ្ឍន៍សង្គមដែលមានលក្ខណៈសាកល។ ប្រទេសជាច្រើន




បានជឿជាក់ថា ការអប់រំបានជុះខាត់ទេពកោលស្ស និងផលិតកម្មការដែលមានប្រសិទ្ធភាព និងកម្រិតជំនាញច្បាស់លាស់។ ជាលទ្ធផលការផ្ដោតដ៏សំខាន់មួយគឺ ផ្ដល់ដល់ទំនាក់ទំនងរវាងការអប់រំ និងទីផ្សារការងារ។ ទោះបីជាប្រព័ន្ធអប់រំអាចមានឥទ្ធិពលលើរចនាសម្ព័ន្ធទីផ្សារការងារ តែបញ្ច្រាសមកវិញ វាអាចត្រូវបានគេរៀបចំឱ្យស៊ីគ្នានឹងតម្រូវការទីផ្សារការងារ។ ដូច្នេះ

ប្រព័ន្ធអប់រំ និងទីផ្សារការងារមានទំនាក់ទំនងបំពេញគ្នាទៅវិញទៅមក (108)។ នៅតៃវ៉ាន់សាលារៀនវិទ្យាល័យត្រូវបានបង្កើតឡើងភ្លាមៗបន្ទាប់ពីបញ្ចប់សង្គ្រាមលោកលើកទី២ ទោះបីការចូលរៀនបានក្លាយជាកាតព្វកិច្ចក្នុងឆ្នាំ១៩៦៨។ ការចូលរៀននៅថ្នាក់វិទ្យាល័យ មិនមានចំនួនលើសពី ៥០% នៅក្នុងឆ្នាំ១៩៧០ ហើយមានតែ១០% នៅគ្រឹះស្ថានឧត្តមសិក្សា។ ទោះជាយ៉ាងណាក៏ដោយមានការរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រព័ន្ធអប់រំមធ្យមសិក្សា និងឧត្តមសិក្សាបន្ទាប់ពីឆ្នាំ ១៩៨០។ អត្រាចូលរៀននៅវិទ្យាល័យថ្នាក់វិទ្យាល័យបច្ចុប្បន្នមានលើសពី៩០% ហើយការអប់រំកម្រិតឧត្តមសិក្សាក៏ហាក់ឡើងខ្ពស់ជិតស្មើប្រទេសជប៉ុនផងដែរ។ *ការពង្រីកប្រព័ន្ធអប់រំនៅតៃវ៉ាន់ត្រូវបានពន្យារពេលប៉ុន្តែល្បឿននៃការពង្រីកនេះគឺខ្ពស់ជាងប្រទេសជប៉ុន។ រចនាសម្ព័ន្ធវិទ្យាល័យ ឬប្រព័ន្ធតាមដាន មានភាពខុសប្លែកពីគ្នារវាងប្រទេសជប៉ុននិងតៃវ៉ាន់។ ប្រទេសទាំងពីរអនុវត្តតាមប្រព័ន្ធសិក្សាពីរដែលរួមមានវគ្គសិក្សាមួយគ្របដណ្តប់លើមុខវិជ្ជាមិនមែនវិជ្ជាជីវៈសម្រាប់ការចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា និងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយវគ្គសិក្សាមួយទៀតដែលរួមមានការបណ្តុះបណ្តាលដើម្បីជួយសិស្សទទួលបានការងារបន្ទាប់ពីបញ្ចប់ការសិក្សានៅវិទ្យាល័យ។ ទោះបីជាជប៉ុន និងតៃវ៉ាន់មានប្រព័ន្ធអប់រំប្រហាក់ប្រហែលគ្នា តែអត្រាសិស្សចូលរៀនសាលាបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាប់ពីប្រឡងបញ្ចប់ថ្នាក់ទី៩របស់តៃវ៉ាន់មានច្រើនជាងជប៉ុន។ ជប៉ុនមានយុទ្ធសាស្ត្រខុសពីតៃវ៉ាន់ក្នុងអភិវឌ្ឍន៍សមត្ថភាពជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេស ដោយយកចិត្តទុកដាក់អភិវឌ្ឍន៍តាមរយៈការសិក្សាបែបអនុវត្តផ្ទាល់(Learning by doing)។ ទីផ្សារការងារនៅក្នុងប្រទេសជប៉ុនមានក្រុមហ៊ុនធំដែលអាចលៃលកជួយបណ្តុះបណ្តាលដល់នយោជិករបស់ពួកគេបានតាមរយៈការបណ្តុះបណ្តាលអំឡុងពេលបំពេញការងារ (on-the-job training) ចំណែកឯនៅតៃវ៉ាន់មានក្រុមហ៊ុនលក្ខណៈគ្រួសារតូចៗមិនអាចលៃលកបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិកដូចជប៉ុនទេ។

រចនាសម្ព័ន្ធវិស័យឧស្សាហកម្ម និងទីផ្សារការងារប្រទេសទាំងពីរខុសគ្នា។ ទោះបីជាការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសទាំងពីរមានកំណើនដោយការនាំចេញផលិតផលឧស្សាហកម្ម ក៏ការពឹងផ្អែកលើពាណិជ្ជកម្មមានកម្រិតខ្ពស់នៅក្នុងតៃវ៉ាន់។ ក្រុមហ៊ុនគ្រួសារ ឬក្រុមធុរកិច្ចតូចៗមានតួនាទីយ៉ាងសំខាន់ក្នុងវិស័យផលិតកម្មនាំចេញនៅតៃវ៉ាន់។ ម្យ៉ាងវិញទៀតនៅក្នុងប្រទេសជប៉ុនមានបណ្តាញក្រុមហ៊ុនធំៗ ដែលពាក់ព័ន្ធនឹងអាជីវកម្មមិនទាក់ទងគ្នាដែលត្រូវបានចូលរួមដោយធនាគារកណ្តាល ឬក្រុមហ៊ុនពាណិជ្ជកម្មដែលជាស្នាដៃមុនសង្គ្រាមលោកលើកទី២"zaibatsu"។ ក្នុងដំណាក់កាលធ្លាក់ចុះ សេដ្ឋកិច្ច ក្រុមហ៊ុនតូចៗងាយរងគ្រោះពីវិបត្តិសេដ្ឋកិច្ចនេះ។ ម្យ៉ាងវិញទៀតក្រុមហ៊ុនតូចៗទទួលបានព័ត៌មានទាក់ទងនឹងការគ្រប់គ្រងរបស់ពួកគេពីបណ្តាញរបស់កុមហ៊ុនហើយអាចរៀបចំខ្លួនដើម្បីប្រឈមនឹងបញ្ហាទាំងនេះ។ ខណៈក្រុមហ៊ុនតូចតាចនៅតៃវ៉ាន់មិនមានបណ្តាញបែបនេះទេ នោះទស្សនវិស័យអាជីវកម្មរបស់ពួកគេមានកម្រិតទាប។ ដូច្នេះហានិភ័យនៃការក្ស័យធនគឺមានខ្ពស់[109]។

ក្រុមហ៊ុនជប៉ុនមានប្រព័ន្ធបណ្តុះបណ្តាលពិសេសដល់បុគ្គលិក។ កម្មករនិយោជិតដែលធ្វើការអចន្ត្រៃនៅក្នុងក្រុមហ៊ុនធំៗ ត្រូវបានផ្លាស់ប្តូរពីផ្នែកមួយទៅមួយជារៀងរាល់ពីរ/បីឆ្នាំម្តង។ ក្រុមហ៊ុនមានទំនោរបន្ថែមគុណតម្លៃផ្នែកចំណេះដឹង ឬជំនាញសម្រាប់ភាពជាក់លាក់របស់ក្រុមហ៊ុនជាជាងជំនាញជាក់លាក់តាមផ្នែកៗនីមួយរបស់ក្រុមហ៊ុន ដើម្បីឱ្យនិយោជិតទទួលបានបទពិសោធន៍ក្នុងតួនាទីជាច្រើននៅក្នុងក្រុមហ៊ុន ឬស្ថាប័ន។ ដូច្នេះ និយោជកមានទំនោរជ្រើសរើសបុគ្គលិកដែលទើបតែបញ្ចប់ការសិក្សាដែលមិនមានការងារជាទៀងទាត់នៅក្នុងក្រុមហ៊ុនដទៃទៀត។ ការអនុវត្តទាំងនេះបាននាំឱ្យមានការបង្កើតប្រព័ន្ធចម្លងពីសាលារៀនទៅការងាររបស់ជប៉ុនដែលគាំទ្រដោយការភ្ជាប់ទំនាក់ទំនងរវាងសាលារៀន និងនយោជក[110] វាបានលេចឡើងថាមានភាពខុសគ្នាសំខាន់ៗបីរវាងប្រទេសជប៉ុន និងតៃវ៉ាន់ទាក់ទងទៅនឹងប្រព័ន្ធអប់រំ និងទីផ្សារការងារ

(1)សមាមាត្រសិស្សវិទ្យាល័យវិជ្ជាជីវៈគឺនៅតៃវ៉ាន់ខ្ពស់ជាងជប៉ុន។ (2)វគ្គសិក្សានៅវិទ្យាល័យបានផ្ដល់ ជម្រើសអប់រំសម្រាប់សិស្សតៃវ៉ានចាប់ផ្ដើមឆាប់ជាងជប៉ុន។ (3)ដំណើរការផលិតកម្មឧស្សាហកម្មនាំចេញ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចតៃវ៉ាន់។ (4)សមាមាត្រនៃក្រុមហ៊ុនខ្នាតតូច ឬក្រុមគ្រួសារគ្រប់គ្រង គឺខ្ពស់នៅតៃវ៉ាន់ដោយមិនមានបណ្ដាញ ឬទំនាក់ទំនងខ្សែរបណ្ដោយជាមួយក្រុមហ៊ុនផលិតកម្មធំៗ។ ក្រុមហ៊ុនធំៗនិយោជិតមានផែនការច្បាស់លាស់សម្រាប់អនាគត ប៉ុន្តែសម្រាប់ក្រុមហ៊ុនតូចៗនយោជិតពិបាកក្នុងការកំណត់ផែនការជីវិតផ្ទាល់ខ្លួនបានច្បាស់លាស់ ព្រោះវាពឹងផ្អែកលើលក្ខខណ្ឌសេដ្ឋកិច្ច។ ស្ថានភាពបែបនេះ ធ្វើឱ្យបុគ្គលិកនៅតៃវ៉ាន់ឆាប់ផ្លាស់ប្ដូរទីកន្លែងការងារជាងនៅជប៉ុន[109]។

## 3.12) ការអប់រំជាន់ខ្ពស់-សាកលវិទ្យាល័យ មហាវិទ្យាល័យ

កោះតៃវ៉ាន់មានសាកលវិទ្យាល័យច្រើនទាំងរដ្ឋ និងឯកជន។ តម្លៃសិក្សានៅសាកលវិទ្យាល័យរដ្ឋថ្លៃតិចជាងសាកលវិទ្យាល័យឯកជន ដូចប្រទេសលោកខាងលិចជាច្រើនដែរ។ សាកលវិទ្យាល័យរដ្ឋជាច្រើនមានការគាំទ្រហិរញ្ញវត្ថុពីរដ្ឋាភិបាល។ បច្ចុប្បន្ននេះ សាលាឯកជនមួយចំនួនមានការគាំទ្រពីក្រុមអ្នកធ្វើពាណិជ្ជកម្ម ឬស្ថាប័នសាសនា។ វិស្វកម្មមានប្រជាប្រិយ ហើយកម្រិតសញ្ញាប័ត្រវិស្វករមានច្រើនជាង១ភាគ៤នៃសញ្ញាប័ត្របរិញ្ញាបត្រនៅតៃវ៉ាន់។ វាក៏ទាក់ទងទៅនឹងឱកាសការងារពេលអនាគតដោយសារគោលនយោបាយរដ្ឋាភិបាលផ្ដោតលើឧស្សាហកម្មដែលមានសង្វាក់ផលិតកម្មប្រើប្រាស់បច្ចេកវិទ្យាខ្ពស់។ ស្ថានភាពសិក្សានៅកម្រិតឧត្ដមសិក្សាហាក់ផ្ទុយពីការសិក្សាកម្រិតមធ្យមសិក្សា សិស្សនៅមធ្យមសិក្សាមានសម្ពាធច្រើនដោយសារការប្រឡងចូលដែលលក្ខណៈសម្រិតសម្រាំងខ្ពស់។ ចំណែកឯការសិក្សានៅសាកលវិទ្យាល័យជាទូទៅត្រូវបានគេមើលឃើញថា មានលក្ខណៈធូរស្រាលជាង។ ក្រសួងអប់រំតៃវ៉ាន់បានចាប់ផ្ដើមផ្ដល់រង្វាន់ដល់សាកលវិទ្យាល័យដែលមានស្នាដៃល្អលើការ

បង្រៀននិស្សិតក្នុងឆ្នាំ២០០៦។ តាំងពីពេលចាប់ផ្តើមរហូតដល់ពេលនេះ មានតែសាកលវិទ្យាល័យតែ៦ប៉ុណ្ណោះទទួលបានកិត្តិយសពីរង្វាន់នេះរាល់ឆ្នាំ។

នៅឆ្នាំ២០១៤ ក្រសួងអប់រំបានចាប់ផ្តើមគម្រោង"**ពង្រឹងការប្រមូលផ្តុំជាសាកលនូវយុវជនវ័យក្មេង**" ក្នុងគោលបំណងបំពាក់បំប៉នយុវជនវ័យក្មេងទាំងអស់នោះនូវសមត្ថភាពស្នូល០៦យ៉ាងដើម្បីជោគជ័យពេលអនាគត៖

1. ការប្រមូលផ្តុំជាសាកល
2. មានជំនាញ
3. សមត្ថភាពច្នៃបង្កើតថ្មី
4. សមត្ថភាពសិក្សាមុខវិជ្ជាច្រើនពាក់ព័ន្ធគ្នា (cross-disciplinary ability)
5. សមត្ថភាពព័ត៌មានវិទ្យា
6. ពលរដ្ឋល្អ

គម្រោង"**ភាពច្នៃប្រឌិតអប់រំ**"ឆ្នាំ២០១៣ បានផ្តល់ឱ្យសាកល/មហាវិទ្យាល័យភាពបត់បែន និងស្វ័យភាពច្រើនក្នុងការសម្របសម្រួលសមត្ថភាពរបស់ពួកគេ រួមគ្នាបង្កើតបណ្តុះសាខា ឬមហាវិទ្យាល័យដែលភ្ជាប់ទំនាក់ទំនងនឹងសាកលវិទ្យាល័យល្បីនៅបរទេស។ ជាលទ្ធផល សាកលវិទ្យាល័យចំនួន៨បានក្លាយដៃគូជាមួយសាកលវិទ្យាល័យអន្តរជាតិលំដាប់កំពូលក្នុងឆ្នាំ២០១៥។

**គន្លងផ្លូវអប់រំជាន់ខ្ពស់ថ្មីរបស់តៃវ៉ាន់ពីឆ្នាំពីឆ្នាំ២០១៥ ដល់២០២៥ មាន៦ប្រភេទ៖**

1. ភាពឥតខ្ចោះលំដាប់អន្តរជាតិ
2. ភាពច្នៃប្រឌិតនៃការសិក្សា
3. ភាពច្នៃប្រឌិតបច្ចេកវិទ្យា
4. ការចូលរួមរបស់សហគមន៍

5. មជ្ឈមណ្ឌលស្រាវជ្រាវ
6. ផ្តោតលើជំនាញឯកទេស

ប៉ុន្តែគន្លងផ្លូវអប់រំថ្មីត្រូវបានផ្អាកបណ្តោះអាសន្ននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦។ រដ្ឋាភិបាលតៃវ៉ាន់បានអនុវត្តគោលនយោបាយថ្មី "**ទៅភាគខាងត្បូង**(New Go South Policy)"ក្នុងឆ្នាំ២០១៦ ដែលមានគោលបំណងពង្រីកការផ្លាស់ប្តូរទស្សនកិច្ចសិក្សាផ្នែកឧស្សាហកម្ម អប់រំ វប្បធម៌ និងកសិកម្មរវាងតៃវ៉ាន់ និងប្រទេសអាស៊ានដើម្បីទាក់ទាញសិស្សដែលទេពកោសល្យខ្ពស់ ពង្រឹងភាពជាដៃគូជាមួយប្រទេសអាស៊ាន និងផ្តល់ឱកាសសម្រាប់ការទំនាក់ទំនងអ្នកជំនាញ និងប្រទេសអាស៊ាន

**ក្នុងឆ្នាំ២០១៦ មានគម្រោងអប់រំជាន់ខ្ពស់០២ គឺៈ**

1. គម្រោង "ភ្ជាប់ទំនាក់ទំនង(Flagship)" (ខែសីហា ឆ្នាំ២០១៦) ដែលភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ វិស័យឧស្សាហកម្ម និងមជ្ឈមណ្ឌលស្រាវជ្រាវ។ បង្កើតមជ្ឈមណ្ឌលភ្ជាប់ទំនាក់ទំនងកិច្ចសហការរវាងសាកលវិទ្យាល័យ វិស័យឧស្សាហកម្ម និងការស្រាវជ្រាវ។ គោលបំណងគម្រោងគឺៈ
    - ដើម្បីអភិវឌ្ឍន៍ក្រុមស្រាវជ្រាវរយៈពេលយូរ និងបច្ចេកវិទ្យាច្នៃបង្កើតដែលនឹងចូលរួមចំណែកដ៏សំខាន់ដើម្បីសុខុមាលភាពសង្គម និងជាតិ។
    - លើកកម្ពស់សហគ្រិនភាពក្នុងកិច្ចសហការជាមួយអ្នកប្រាជ្ញល្បីៗ វិស័យឧស្សាហកម្ម និងសិស្សបញ្ចប់ការសិក្សាដែលឆ្នើម។
    - ការផ្ទេរបច្ចេកវិទ្យា
    - សាកលវិទ្យាល័យរៀបចំគម្រោងស្រាវជ្រាវ។ គម្រោងចំនួន៥៣របស់សាកលវិទ្យាល័យត្រូវបានជ្រើសរើស។
2. ចងក្រងសាកលវិទ្យាល័យជាក្រុម (University Consortium) (ខែវិច្ឆិកា ឆ្នាំ២០១៦) ផ្តោតលើការចូលរួមថ្នាក់មូលដ្ឋាន និង

ភាពពាក់ព័ន្ធគ្នា។ ក្រុមសាកលវិទ្យាល័យ និងសាកលវិទ្យាល័យបច្ចេកវិទ្យាដែលផ្តោតទៅលើ៖

- នីយកម្មក្នុងតំបន់ និងមូលដ្ឋាននីយកម្ម
- ការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងបណ្តាញជនបទ-ទីក្រុង
- សហគមន៍មូលដ្ឋាន និងវិស័យឧស្សាហកម្ម

**ជារួមការអប់រំជាន់ខ្ពស់តៃវ៉ាន់ផ្តោតទៅលើ៖**

1. សាលកវិទ្យាល័យលំដាប់ថ្នាក់ពិភពលោក និងសហគ្រិនភាព
2. ការស្រាវជ្រាវ និងសហគ្រិនភាព
3. ការទទួលខុសត្រូវ និងស្វ័យភាព
4. ភាពឥតខ្ចោះនៃការសិក្សា និងការធានាគុណភាព

- តៃវ៉ាន់មានប្រព័ន្ធនយោបាយ ប្រព័ន្ធអប់រំខុសពីចិន
- គោលនយោបាយ២ភាសាត្រូវបានអនុវត្តផ្លូវការនៅឆ្នាំ២០០១។ ភាសាមួយគឺភាសាអង់គ្លេសដែលចាប់ផ្តើមសិក្សានៅថ្នាក់ទី៥សាលាបឋមសិក្សា( ចាប់ផ្តើមពីថ្នាក់ទី៣ក្នុងឆ្នាំ២០០៥ដើម្បីបន្សុីគ្នាទៅសេចក្តីណែនាំកម្មវិធីសិក្សាពីថ្នាក់ទី១ដល់ទី៩ ដែលត្រូវបានកែសម្រួលដោយក្រសួងអប់រំ) ហើយភាសាមួយទៀត គឺភាសាក្នុងតំបន់ដែលត្រូវសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ គោលបំណងនៃគោលនយោបាយភាសាគឺដើម្បីអភិរក្សាភាសាជនជាតិដើមដែលវាបានបង្ហាញសញ្ញាណនៃការធ្លាក់នៃការប្រើប្រាស់ភាសាទាំងនេះ ក្នុងចំណោមអនុជនវ័យក្មេងថ្មីជនជាតិដើមទាំងនោះ។
- ដោយសារឥទ្ធិពលសាកលភាវូបនីយកម្ម ភាសាអង់គ្លេសនិយមសិក្សាច្រើន អាចធ្វើឱ្យបាត់បង់នូវភាសាជាតិខ្លួន។តៃវ៉ាន់អភិរក្សភាសាជនជាតិព្រោះរក្សាអត្តសញ្ញាណ។ភាសាជនជាតិដើមមិន

ប្រើប្រាស់ជាទូទៅប្រើប្រាស់សម្រាប់តែទំនាក់ទំនងក្នុងគ្រួសារ និងសហគមន៍ខ្លួន។

- គោលនយោបាយអប់រំតៃវ៉ាន់គិតគូរដល់សិស្សដែលងាយរងគ្រោះ។

## 3.13) សាលារៀនអប់រំឯកជន

### ❖ សាលាបំប៉នបន្ថែមក្រៅម៉ោង (ថ្នាក់រៀនគួរ)

ដោយទទួលរងសម្ពាធពីឪពុកម្តាយដើម្បីទទួលបានលទ្ធផលសិក្សាល្អ សិស្សជាច្រើនបានចូលរៀនគួរក្រៅម៉ោងបន្ថែមក្នុងគោលបំណងបំប៉នសមត្ថភាពបន្ថែមរបស់ពួកគេ។ សាលារៀនសម្រាប់បង្រៀនគួរបន្ថែមនេះជាស្ថាប័នស្វែងរកប្រាក់ចំណូលនៅតៃវ៉ាន់។ ស្ថាប័ននេះក៏ត្រូវបានរិះគន់ដោយអ្នកជំនាញមួយចំនួនផងដែរថា ផ្តោតជ្រុលខ្លាំងពេកទៅលើវប្បធម៌នៃការសម្រេចបានលទ្ធផលសិក្សា។ មុខវិជ្ជាដែលមានប្រជាប្រិយខ្លាំងនៅសាលាឯកជននេះគឺភាសាអង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្ត្រធម្មជាតិ ឬតេស្តត្រៀមប្រឡងសម្រាប់សិស្សមធ្យមសិក្សាជាដើម។ ថ្នាក់រៀនជាទូទៅមានសណ្តាប់ធ្នាប់ និងគ្រប់គ្រងតឹងរ៉ឹង ដោយសិស្សមានចំនួនច្រើនក្នុងមួយថ្នាក់មានដល់២០០នាក់ ឬលើសនេះ ពិសេសនៅតាមសាលាដែលល្បីៗ។ គុណភាពសាលារៀនគួរក្រៅម៉ោងមានកម្រិតខុសៗគ្នា។ សាលាខ្លះធំ រៀបចំកម្មវិធីផ្ទាល់ខ្លួន និងផលិតសៀវភៅសិក្សាគោលដោយខ្លួនឯង។

### ❖ មត្តេយសិក្សាឯកជន

មត្តេយ្យឯកជនមានប្រជាប្រិយភាពណាស់នៅតៃវ៉ាន់។ សាលាមត្តេយ្យឯកជនជាច្រើនផ្តល់វគ្គសិក្សាមុខវិជ្ជាផ្សេងៗដើម្បីប្រកួតប្រជែងជាមួយសាលារដ្ឋ និងប្រមូលទុនពីតម្រូវការមហាជនសម្រាប់ការសម្រេចលទ្ធផលសិក្សា។ កម្មវិធីសិក្សានៅតាមសាលាទាំងនេះមានមុខវិជ្ជា វិទ្យាសាស្ត្រ សិល្បៈ អប់រំកាយ និងគណិតវិទ្យា។ សាលារៀនភាគច្រើនដំណើរការ

ដោយការទិញស្លាកយីហោ( franchise )ពីសាលាធំៗដោយសាលាធំៗ ទាំងនេះ ជាអ្នកផ្គត់ផ្គង់ដល់ការរៀបចំផ្សព្វផ្សាយពាណិជ្ជកម្ម ផ្តល់សៀវភៅសិក្សា សម្ភារៈ ការបណ្តុះបណ្តាល និងសូម្បីតែបុគ្គលិកសម្រាប់សាលានីមួយៗ។ មានការកើនឡើងខ្លាំងនូវចំនួនសាលារៀនឯកជនកម្រិតអន្តរជាតិដែលកម្មវិធីសិក្សាប្រើប្រាស់តែភាសាអង់គ្លេសដោយ ជនជាតិដែលមានដើមកំណើតនិយាយភាសាអង់គ្លេសតាំងពី១៩៩៩។ ទោះបីពេលមានកង្វល់មួយចំនួនទាក់ទងនឹងប្រព័ន្ធអប់រំបែបនេះដែលអាចធ្វើបាត់បង់អត្តសញ្ញាណវប្បធម៌ ពិសេសការធ្លាក់ចុះនៃការចេះភាសាកំណើតខ្លួន និងផលវិបាកនៃការឆាប់ចាប់យកបរិស្ថានអប់រំភាសាបរទេសទាំងវ័យក្មេង ក៏សាលារៀនឯកជនទាំងនោះនៅតែបន្តដំណើរការរីកចម្រើនតទៅទៀត។ ក្នុងឆ្នាំ ២០១៦ រដ្ឋមន្ត្រីអប់រំលោក **ផាន វ៉េន ជុង** ( Pan Wen-chung ) បានមានប្រសាសន៍ថា នាយកប្រតិបត្តិ Yuan នឹងបែងចែកថវិកាជាតិចំនួន៦.២ ពាន់លានដុល្លារដើម្បីបង្កើតសាលាមត្តេយ្យសិក្សាចំនួន១,០០០ក្នុងរយៈពេល៤ឆ្នាំដើម្បីអាចបង្កើនភាគរយនៃកុមារចូលរៀនពី៣០%ទៅ៤០%នៅឆ្នាំ២០២០។(110)

## 3.14) ការបណ្តុះបណ្តាលគ្រូបង្រៀន

ស្ថាប័នអប់រំកម្រិតខ្ពស់ជាច្រើនមានកម្មវិធីអប់រំ។ កម្មវិធីនេះបណ្តុះបណ្តាលរយៈ ពេល៤ឆ្នាំ និងបន្ថែមការអនុវត្តជាក់ស្តែងកន្លះឆ្នាំទៀតដើម្បីនិស្សិតអាចទទួលបានការបញ្ជាក់នៅចុងបញ្ចប់នៃវគ្គសិក្សា។ និស្សិតបញ្ចប់ការសិក្សា ត្រូវប្រឡងដើម្បីធ្វើជាគ្រូបង្រៀននៅតាមសាលារដ្ឋ។ កម្មវិធីអប់រំនៅពេលបច្ចុប្បន្ននេះ សិស្សអាចសិក្សានៅតាមស្ថាប័នឧត្តមសិក្សាបានជាច្រើនកន្លែង។ សម្រាប់អ្នកដែលចង់ធ្វើគ្រូបង្រៀន ពួកគេត្រូវទៅរៀននៅសាកលវិទ្យាល័យអប់រំបើសិនជាពួកគេចង់បង្រៀននៅតាមសាលាបឋមសិក្សា ហើយរៀននៅសាកលវិទ្យាល័យធម្មតាសម្រាប់គ្រូបង្រៀននៅមធ្យមសិក្សា។ កំណែទម្រង់ការអប់រំមានដំណើរការនៅតៃវ៉ាន់អស់រយៈ

ពេលជាងពីរទសវត្សមកហើយ។ វិមជ្ឈការគឺជាលក្ខណៈចម្បងនៃចលនាកំណែទម្រង់អប់រំ។ តៃវ៉ាន់យកចិត្តទុកដាក់ខ្លាំងការអភិវឌ្ឍកម្មវិធីសិក្សាដែលមានមូលដ្ឋាននៅសាលារៀន ហើយបច្ចុប្បន្នគ្រូបង្រៀនត្រូវបានផ្តល់សិទ្ធិអំណាចកាន់តែច្រើននៅលើការសម្រេចចិត្តក្នុងការបង្រៀនរបស់ពួកគេ នាំឱ្យមានការបង្កើនស្វ័យភាពវិជ្ជាជីវៈរបស់ពួកគេ។ វិមជ្ឈការក៏បណ្តាលឱ្យមានការចូលរួមកាន់តែច្រើនឡើងនៃការអប់រំរបស់ឳពុកម្តាយ។ ក្រុមកំណែទម្រង់អប់រំជាច្រើនបានគាំទ្រការបង្កើនសិទ្ធិរបស់មាតាបិតាដើម្បីជះឥទ្ធិពលដល់ការរៀនសូត្រកូនៗរបស់ពួកគេ (111)

## 3.15) ព័ត៌មាន និងធនធានលើកកម្ពស់ការអប់រំ គ្រូបង្រៀនដែលកំពុងបំពេញការងារ

ដោយអនុវត្តតាមកំណែទម្រង់គោលនយោបាយអប់រំនៅតៃវ៉ាន់ ដើម្បីសមាហរណកម្មធនធានលើកកម្ពស់ការអប់រំសម្រាប់គ្រូបង្រៀនដែលកំពុងបំពេញការងារ និងលើកទឹកចិត្តគ្រូដើម្បី ចូលរួមជាវិជ្ជមានក្នុងការអភិវឌ្ឍសមត្ថភាព ក្រសួងអប់រំបានបង្កើតមជ្ឈមណ្ឌលលើកកម្ពស់ការអប់រំគ្រូបង្រៀនដែលកំពុងបំពេញការងារចំនួន១២ក្នុងឆ្នាំ២០០៣។ សាកលវិទ្យាល័យ The National Kaohsiung Normal (NKNU) ត្រូវបានជ្រើសរើសជាស្ថាប័នសម្របសម្រួលទូទៅដែលទទួលខុសត្រូវក្នុងការតំលើង និងរៀបចំ គ្រប់គ្រងបណ្តាញព័ត៌មានអប់រំគ្រូកំពុងបំពេញការងារនៅទូទាំងប្រទេស។បណ្តាញព័ត៌មាននេះ ផ្តល់ដល់គ្រូបង្រៀននូវវេទិកាទំនាក់ទំនងដើម្បីលើកកម្ពស់សមត្ថភាពខ្លួន នៅតៃវ៉ាន់។ នេះ ជាការលើកទឹកចិត្តគ្រូបង្រៀនដើម្បីបង្កើនអភិវឌ្ឍន៍សមត្ថភាពបន្តក្នុងការបង្រៀន។ ព័ត៌មាននៃសកម្មភាពអភិវឌ្ឍន៍ និងកំណត់ត្រាការចូលរួមរបស់គ្រូត្រូវបានបង្ហាញដោយវេទិកាឌីជីថល។ បណ្តាញនេះ ផ្តល់សកម្មភាព និងកំណត់ត្រារៀនសូត្ររបស់បុគ្គលសម្រាប់គ្រូបង្រៀនពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា។ វេទិកាបច្ចេកវិទ្យាទិន្នន័យ ជាទម្រង់អេឡិចត្រូនិចសម្រាប់កត់ត្រា

ដំណើរការបណ្តុះបណ្តាលរបស់គ្រូបង្រៀន និងពេលវេលាសិក្សា។ (សម្រាប់ការរៀនសូត្រអស់មួយជីវិតរបស់គ្រូ)។ វាបង្កើតនូវយន្តការជាប្រក្រតីដើម្បីដាក់បញ្ចូលធនធានអប់រំ និងរដ្ឋបាលពីស្ថាប័នអប់រំ និងអាជ្ញាធរអប់រំមូលដ្ឋាន។ ទាំងនេះ ជាកំណែទម្រង់អប់រំមួយដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន(112) ។

## គោលបំណងនៃការបង្កើតបណ្តាញព័ត៌មានលើកកម្ពស់អប់រំសម្រាប់គ្រូបង្រៀនដែលកំពុងបំពេញការងារទូទាំងប្រទេសគឺមានដូចខាងក្រោម៖

- ផ្តល់នូវវេទិកាអំពីព័ត៌មានអប់រំក្នុងសេវាសម្រាប់គ្រូដែលបង្រៀននៅមត្តេយ្យសិក្សាដល់មធ្យមសិក្សា។ វាក៏មានព័ត៌មានពីម៉ោងវគ្គបណ្តុះបណ្តាលដែលមានសុពលភាព និងកំណត់ត្រាការបណ្តុះបណ្តាលនៅក្នុងទម្រង់អេឡិចត្រូនិច...។ល។ វាអាចឱ្យគ្រូទូទាំងប្រទេសពិនិត្យមើលកំណត់ត្រាការបណ្តុះបណ្តាលក្នុងមួយជីវិតពួកគេ ហើយអាចជួយធ្វើឱ្យប្រសើរឡើងនូវ គោលនយោបាយលើកកម្ពស់ការអប់រំសម្រាប់គ្រូដែលកំពុងបំពេញការងារ(112)។
- បង្កើតនូវយន្តការជាប្រក្រតីសម្រាប់ដាក់បញ្ចូលធនធានអប់រំ និងរដ្ឋបាលពីគ្រឹះស្ថានអប់រំ និងអាជ្ញាធរមូលដ្ឋានផ្នែកអប់រំ។ វានឹងជួយដល់អង្គការដែលធ្វើការផ្នែកបណ្តុះបណ្តាលអាចរៀបចំកម្មភាពបណ្តុះបណ្តាល និងកម្មវិធីដែលឆ្លើយតបទៅនឹងតម្រូវការរបស់គ្រូ ដែលចូលរួមនៅក្នុងសេវាអប់រំ(112)។
- ផ្តល់ព័ត៌មានវគ្គសិក្សា និងការស្នើសុំនានា ព្រមទាំងបើកចំហសម្រាប់ជម្រើសវគ្គបណ្តុះបណ្តាលផ្សេងៗ និងមធ្យោបាយនានាសម្រាប់គ្រូ។ វាជាការជួយដ៏សំខាន់ដល់អ្នកគ្រប់គ្រង ក្នុងការរៀបចំគោលនយោបាយ ហើយគ្រូបង្រៀនអាចទទួលបានសេវាបណ្តុះបណ្តាលសមត្ថភាពដែលនៅជិតពួកគេ(112)។

- ផ្តល់ការប្រឹក្សាដើម្បីលើកកម្ពស់ការអប់រំនៅក្នុងសេវា និងបណ្តាញទំនាក់ទំនងសម្រាប់គ្រូបង្រៀន។ វានឹងជួយដោះស្រាយបញ្ហារបស់គ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព និងបង្កើននូវឱកាសក្នុងការទទួលបានការលើកទឹកចិត្តផ្សេងៗ(111)។
- ផ្តល់នូវកំណត់ត្រាលម្អិតស្តីពីការបណ្តុះបណ្តាលរបស់គ្រូបង្រៀនសម្រាប់ការរៀបចំផ្នែកអប់រំ បង្កើតក្របខណ្ឌឯកសារយោងក្នុងការរៀបចំគោលនយោបាយអប់រំ និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការកំណែទម្រង់ការអប់រំ(112)។

# IV. ប្រព័ន្ធអប់រំប្រទេសកូរ៉េ





**សំណួរត្រិះរិះ**

*១- តើកូរ៉េ វិស័យអប់រំចូលរួមចំណែកអភិវឌ្ឍន៍ប្រទេស ដោយរបៀបណា?*

*២-តើប្រព័ន្ធអប់រំប្រទេសកូរ៉េ មានលក្ខណៈដូចម្តេច? មានកំណែទម្រង់ប្រព័ន្ធអប់រំអ្វីខ្លះ ?*

*៣-តើកត្តាអ្វីខ្លះចូលរួមចំណែកធ្វើឱ្យវិស័យអប់រំប្រទេសកូរ៉េរីកចម្រើន?*

*៤-កាលៈទេសៈដែលប្រទេសកម្ពុជា យកចិត្តទុកដាក់លើកកម្ពស់យេនឌ័រក្នុងការអប់រំ - ប្រទេសកូរ៉េបែរជាមានការអប់រំសម្រាប់ភេទតែមួយ (Single-sex education) ទៅវិញ តើការអប់រំ ដែលសាលារៀនមានសិស្សស្រីសុទ្ធ ឬប្រុសសុទ្ធ មានលក្ខណៈខុសប្លែកនឹងសាលារៀនទាំងពីរភេទដូចម្តេចខ្លះ?*

*៥-ហេតុអ្វីបានជាប្រទេសកូរ៉េទទួលលទ្ធផលតេស្ត PISA ខ្ពស់?*

*៦-តើអ្វីខ្លះដែលប្រទេសកម្ពុជា អាចរៀនសូត្របានពីប្រទេសកូរ៉េ?*

## 4.1) ទិដ្ឋភាពទូទៅរបស់ប្រទេសកូរ៉េ

## (**សង្គម សេដ្ឋកិច្ច និងនយោបាយ**)

**សាធារណរដ្ឋកូរ៉េ** (Republic of Korea) ឬ**កូរ៉េខាងត្បូង** (South Korea) ជាប្រទេសស្ថិតនៅតំបន់អាស៊ីខាងកើត(បូព៌ា) មានផ្ទៃដីលាតសន្ធឹងភាគខាងត្បូងលើឧបទ្វីបកូរ៉េ ដោយមានព្រំដែនគោកជាប់តែប្រទេសកូរ៉េខាងជើងនៅភាគខាងជើង និងមានប្រទេសជប៉ុននៅភាគអាគ្នេយ៍ខ័ណ្ឌចែកដោយសមុទ្រជប៉ុន និងច្រោយឧបទ្វីបកូរ៉េ។ ឧបទ្វីបកូរ៉េគឺជា ប្រទេសប្រវត្តិសាស្ត្រមួយនៅអាស៊ីខាងកើត (បូព៌ា)ដែលជនជាតិកូរ៉េដើមបានមករស់នៅលើឧបទ្វីបនេះប្រហែល៧០០ពាន់ឆ្នាំមុន។ បច្ចុប្បន្ន **ចំនួនប្រជាជនកូរ៉េទាំងពីរ**សរុបរួមមានប្រហែល៧៦លាននាក់ (កូរ៉េខាងជើង២៥លាននាក់ កូរ៉េខាងត្បូង ៥១លាននាក់)។ ប្រទេសកូរ៉េមានប្រជាជនរស់នៅច្រើនជាងគេជាជនជាតិកូរ៉េ ហើយនិយាយភាសាកូរ៉េ[១] ចំនួនជនបរទេសដែលរស់នៅក្នុងប្រទេសកូរ៉េក៏មានការកើនឡើងជាលំដាប់ផងដែរ ចាប់តាំងពីចុងសតវត្សរ៍ទី២០ ជាពិសេសនៅក្នុងប្រទេសកូរ៉េខាងត្បូងដែលមានជនបរទេសច្រើនជាង១លាននាក់[២]ក្នុងឆ្នាំ២០០៦ គេប៉ាន់ប្រមាណថា សហគមន៍ជនជាតិចិនបុរាណមានចំនួន២៦.៧០០ នាក់ដែលកំពុងរស់នៅក្នុងប្រទេសកូរ៉េខាងត្បូង[៣]។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ជនចំណាកស្រុកមកពីចិនដីគោកបានកើនឡើងចំនួនប្រមាណ៦២៤.៩៩៤នាក់បានធ្វើអន្តោប្រវេសន៍ទៅកូរ៉េខាងត្បូងរួមទាំងពូជសាសន៍ដើមកំណើតជនជាតិដើមកូរ៉េចំនួន៤៤៣.៥៦៦នាក់[៤]។ សហគមន៍តូចៗនៃជនជាតិចិន និងជប៉ុនក៏ត្រូវបានគេរកឃើញនៅក្នុងប្រទេសកូរ៉េខាងជើងផងដែរ[៥]។ **ភាសាកូរ៉េ**គឺជាភាសាផ្លូវការរបស់កូរ៉េខាងជើង និងកូរ៉េខាងត្បូង (រួមជាមួយភាសាចិនកុកងឺ)នៃខេត្តស្វយ័ត**យ៉ានប៊ីយិន**នៅក្នុងតំបន់ម៉ាន់ជូរីនៃប្រទេសចិន។ នៅទូទាំង ពិភពលោកមានអ្នកនិយាយ

ភាសាកូរ៉េរហូតដល់៨០លាននាក់។ កូរ៉េខាងត្បូងមានអ្នកនិយាយប្រហែលជា៥០លាននាក់ ខណៈកូរ៉េខាងជើងមានប្រមាណ២៥លាននាក់។ ជាមួយគ្នានេះ ប្រពៃណីខុងជឺបានគ្របដណ្តប់គំនិតរបស់កូរ៉េ រួមជាមួយការរួមចំណែកដោយព្រះពុទ្ធសាសនាពួកតាវនិយម និងសីលធម៌កូរ៉េ។ ទោះជាយ៉ាងណាក៏ដោយ ចាប់តាំងពីពាក់កណ្តាលសតវត្សរ៍ទី២០ គ្រីស្ទសាសនាបានប្រកួតប្រជែងជាមួយនឹងព្រះពុទ្ធសាសនា ខណៈពេលដែលការអនុវត្តផ្នែកសាសនាត្រូវបានបង្ក្រាបនៅក្នុងប្រទេសកូរ៉េខាងជើង។ ឥទ្ធិពលនៃជំនឿប្រពៃណីកូរ៉េ ព្រះពុទ្ធសាសនាមហាយាន ខុងជឺនិយម និងសាសនាតាវនៅតែជាសាសនាគ្រឹះរបស់ប្រជាជនកូរ៉េក៏ដូចជាទិដ្ឋភាពសំខាន់នៃវប្បធម៌របស់ពួកគេ។ ប្រពៃណីទាំងអស់នេះបានរួមរស់ដោយសន្តិភាពអស់រាប់រយឆ្នាំរហូតមកដល់សព្វថ្ងៃនេះ[៦]យោងតាមស្ថិតិឆ្នាំ២០០៥ដែលចងក្រងដោយរដ្ឋាភិបាលកូរ៉េខាងត្បូងប្រហែល៤៦%នៃប្រជាពលរដ្ឋអះអាងថាមិនគោរពសាសនាណាមួយ។ គ្រិស្តបរិស័ទមាន២៩,២% នៃចំនួនប្រជាជន (ដែលមានប្រូតេស្តង់១៨,៣% និងពួកកាតូលិក១០,៩%) និងពុទ្ធសាសនិក២២,៨%[៧]។ សាសនាអ៊ីស្លាមនៅកូរ៉េខាងត្បូងត្រូវបានអនុវត្តដោយជនជាតិដើមប្រហែល៤៥.000នាក់ (ប្រហែល0,0៩%នៃប្រជាជនសរុប) បន្ថែមទៅលើពលករបរទេសប្រហែល១00,000 នាក់មកពីប្រទេសមូស្លីម[៨]។

ប្រទេសកូរ៉េខាងត្បូងបានប្រកាសប្រើរដ្ឋធម្មនុញ្ញដំបូងរបស់ខ្លួននៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ១៩៤៨ ដោយមានការកែប្រែជាប់រហូតមកចំនួន៩លើក។ ប្រទេសកូរ៉េខាងត្បូងជាសាធារណរដ្ឋដែលមានរដ្ឋាភិបាលឡើងកាន់អំណាចជ្រើសតាំងដោយប្រជាពលរដ្ឋ។ ក្នុងរដ្ឋធម្មនុញ្ញសាធារ-ណរដ្ឋកូរ៉េតម្រូវឱ្យរដ្ឋសភាជាតិ (National Assembly) មានអំណាចនិតិបញ្ញត្តិ។ រដ្ឋសភារបស់កូរ៉េខាងត្បូង មានសមាជិកចំនួន២៩៩រូប ដោយ

សមាជិក២ភាគ៣ ជ្រើសរើសដោយផ្ទាល់តាមរយៈការបោះឆ្នោតទូទៅ ចំណែកចំនួនដែលនៅសល់ជ្រើសរើសតាមរយៈការតែងតាំងដោយផ្អែកលើភាគរយនៃសំឡេងគាំទ្រគណបក្សនយោបាយដែលទទួលបាន។ រដ្ឋធម្មនុញ្ញបានចែងច្បាស់អំពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិ និងសេរីភាពខាងជំនឿ ជាពិសេសការគោរពសាសនា។ សមាជិករដ្ឋសភាមានអាណត្តិ៤ឆ្នាំ។ **ប្រធានាធិបតី**ជាអ្នកដឹកនាំប្រទេស គឺជាប្រមុខរដ្ឋ និងជាប្រមុខរដ្ឋាភិបាលដែលជ្រើសតាំងដោយការបោះឆ្នោតមានអណត្តិ៥ឆ្នាំ ដោយមិនអាចឈរឈ្មោះបោះឆ្នោតជាលើកទី២ បានទៀតឡើយ ដើម្បីជៀសវាងការពង្រីកអំណាច។ ប្រធានាធិបតីត្រូវបានតែងតាំងជាប្រមុខរដ្ឋជាអគ្គមេបញ្ជាការកងទ័ព និងជាអ្នកមានអំណាចប្រកាសច្បាប់អយ្យការសឹក និងច្បាប់ផ្សេងៗក្នុងស្ថានភាពអាសន្ន។ ក្រៅពីនេះ ប្រធានាធិបតីមានសិទ្ធិស្នើឱ្យមានការព្រាងច្បាប់ទៅរដ្ឋសភាបានផងដែរ ប៉ុន្តែមិនមានអំណាចក្នុងការរំលាយសភាបានទេ។ **គណៈរដ្ឋមន្ត្រី**រួមមាន៖ នាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ដែលមានការតែងតាំងដោយផ្ទាល់ពីប្រធានាធិបតី ឆ្លងកាត់សំឡេងគាំទ្រសភា។ នាយករដ្ឋមន្ត្រីមានតួនាទីជាជំនួយការប្រធានាធិបតីក្នុងកិច្ចការដឹកនាំប្រទេស រួមទាំងអំណាចក្នុងការចូលរួមពិភាក្សាក្នុងកិច្ចការនយោបាយផ្សេងៗក្នុងប្រទេស និងការចូលរួមប្រជុំក្នុងរដ្ឋសភាផងដែរ។ គណៈរដ្ឋមន្ត្រីមានទាំងអស់ចំនួន២០រូប។ នៅកូរ៉េខាងត្បូងមានគណបក្សនយោបាយច្រើន ក្នុងនោះមានគណបក្សធំពីរគឺ គណបក្សជាតិធំ និងគណបក្សប្រជាធិបតេយ្យ។ **អំណាចតុលាការ**រួមមាន៖ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ប្រធានាធិបតីជាអ្នកតែងតាំងប្រធានតុលាការកំពូលដោយឆ្លងកាត់ការយល់ព្រមពីសភា[៩]។ ចាប់ផ្តើមក្នុងឆ្នាំ ១៨៧១ ប្រទេសជប៉ុនបានចាប់ផ្តើមបញ្ចេញឥទ្ធិពលរបស់ខ្លួនកាន់តែច្រើននៅក្នុងប្រទេសកូរ៉េដើម្បីដកចេញនូវឥទ្ធិពលជាប្រពៃណីរបស់ចិន។

ដោយសារសង្គ្រាមចិន - ជប៉ុន(១៨៩៤-៩៥) រាជវង្ស**ឈិង**ត្រូវបោះបង់ចោលតំណែង បែបនេះយោងតាមមាត្រាទី១នៃសន្ធិសញ្ញាស៊ីម៉ូណូសេគី ដែលត្រូវបានបញ្ចប់រវាងចិន និងជប៉ុននៅឆ្នាំ១៨៩៥ ។ នៅឆ្នាំដដែលនោះ ព្រះមហាក្សត្រី Myeongseong នៃប្រទេសកូរ៉េត្រូវបានសម្លាប់ដោយភ្នាក់ងារជប៉ុន[១០]។ នៅឆ្នាំ១៨៩៧ **រាជវង្សចូអាន**(Joseon) បានប្រកាសចក្រភពកូរ៉េ(១៨៩៧-១៩១០)។ ស្តេច Gojong បានក្លាយជាអធិរាជ។ ក្នុងអំឡុងពេលដ៏ខ្លីនេះប្រទេសកូរ៉េទទួលបានជោគជ័យមួយចំនួនក្នុងការធ្វើទំនើបកម្មយោធា សេដ្ឋកិច្ច ច្បាប់អចលនទ្រព្យ ប្រព័ន្ធអប់រំ និងឧស្សាហកម្មជាច្រើន។ ប្រទេសរុស្ស៊ី ជប៉ុន បារាំង និងសហរដ្ឋអាមេរិចបានវិនិយោគយ៉ាងច្រើននៅក្នុងប្រទេសកូរ៉េ និងព្យាយាមសាបព្រោះឥទ្ធិពលនយោបាយខ្លួន។

នៅឆ្នាំ១៩១០ កូរ៉េត្រូវបានកាន់កាប់ដោយយោធាជប៉ុន ហើយបង្ខំឱ្យមានសន្ធិសញ្ញាភ្ជាប់ជាមួយជប៉ុន - កូរ៉េ។ ទោះជាយ៉ាងណាក៏ដោយ វាមានភាពចម្រូងចម្រាស់សម្រាប់រយៈពេលក្រោយមកលើភាពស្របច្បាប់ និងមិនស្របច្បាប់នៃសន្ធិសញ្ញានេះដោយសារមានការលើកឡើងថា ព្រះចៅអធិរាជកូរ៉េមិនបានផ្តល់សច្ចាប័ននោះទេ និងត្រូវបានចុះហត្ថលេខាស្ថិតក្រោមការបង្គាប់បញ្ជា គំរាមកំហែង និងសំណូក។ នៅក្នុងអំឡុងពេលអាណានិគមនេះ ជប៉ុនបានដាក់ពង្រាយទ័ពនៅតាមទីក្រុងទូទាំងប្រទេសកូរ៉េ។ ជាមួយគ្នានេះ ចលនារំដោះជនជាតិកូរ៉េក៏ត្រូវបានបង្កើតឡើងដើម្បីប្រយុទ្ធប្រឆាំងនឹងជប៉ុនផងដែរ ហើយបានរីករាលដាលទៅដល់តំបន់ជិតខាងម៉ាន់ជូរី និងស៊ីបេរី។ ជានិច្ចកាល ការតស៊ូរបស់កូរ៉េចំពោះការកាន់កាប់របស់ជប៉ុនត្រូវបានបង្ក្រាបយ៉ាងឃោរឃៅ។ ជាក់ស្តែង សោធនកម្មត្រូវបានបង្ហាញនៅក្នុងចលនាហិង្សាលើកទី១ឆ្នាំ១៩១៩ ក្នុងកំឡុងពេលដែលបាតុករ៧.០០០នាក់ត្រូវបានសម្លាប់ដោយប៉ូលីស និងយោធាជប៉ុន[១១]។

ចលនាបោះបោរឆ្នាំ១៩១៩នេះ មិនបានទទួលជោគជ័យឡើយ ប៉ុន្តែគេបានត្រឹមសម្រេចបង្កើតរដ្ឋាភិបាលកូរ៉េ បណ្តោះអាសន្នមួយនៅក្រៅប្រទេសតែប៉ុណ្ណោះ។ នៅក្នុងសម័យអាណានិគម ពួកជប៉ុនបានឆក់ប្លន់ទ្រព្យសម្បត្តិ និងប្រមូលផលិតផលកសិកម្ម ដើម្បីនាំយកទៅប្រទេសជប៉ុនអស់ជាច្រើន[១២]។ ប្រទេសកូរ៉េក្លាយជាមូលដ្ឋានសម្រាប់ផ្គត់ផ្គង់ និងជាទីផ្សាររបស់ពួកជប៉ុន។ ជនជាតិកូរ៉េជាងប្រាំលាននាក់ត្រូវបានគេបង្ខំឱ្យធ្វើការតាំងពីឆ្នាំ១៩៣៩[១៣] ហើយបុរសរាប់ម៉ឺននាក់ត្រូវបានគេបង្ខំឱ្យចូលក្នុងយោធារបស់ជប៉ុន[១៤]។ កម្មករកូរ៉េជិត៤០០.០០០នាក់ត្រូវបានស្លាប់ ហើយអ្វីដែលធ្វើឱ្យកូរ៉េកាន់តែឈឺចាប់គឺ[១៥]ក្មេងស្រី និងស្ត្រីប្រហែល ២០០.០០០នាក់[១៦] ភាគច្រើនមកពីប្រទេសចិន និងកូរ៉េត្រូវបានគេបង្ខំឱ្យធ្វើជាទាសករបម្រើផ្លូវភេទសម្រាប់កងទ័ពអធិរាជជប៉ុន[១៧]។ នៅក្នុងច្បាប់កំណែនឆ្នាំ១៩៣៨ ជប៉ុនបានប្រមូលយកស្បៀង និងកេណ្ឌយុវជនកូរ៉េ ឱ្យចូលធ្វើសង្គ្រាមលោកលើកទី២នៅតាមរណសិរ្សទាំងឡាយក្នុងតំបន់អាស៊ីប៉ាស៊ីភិច ដែលនាំឱ្យពួកគេទាំងនោះរងគ្រោះបាត់បង់ជីវិតអស់ជាច្រើនម៉ឺននាក់។ ករណីនេះ រហូតដល់ឆ្នាំ១៩៩៣ ទើបលោក Yohei Kono ជាលេខាខុទ្ទកាល័យគណៈរដ្ឋមន្ត្រីជប៉ុនបានទទួលស្គាល់ភាពអយុត្តិធម៌ដ៏គួរឱ្យភ័យខ្លាចដែលកើតឡើងចំពោះស្ត្រីទាំងនោះ[១៨]។ មួយវិញទៀត ក្នុងអំឡុងពេលអាណានិគម ប្រទេសជប៉ុន ព្យាយាមលុបបំបាត់អត្តសញ្ញាណជាតិកូរ៉េ និងហាមប្រើប្រាស់ភាសាកូរ៉េ។ ជនជាតិកូរ៉េត្រូវបានគេបង្ខំឱ្យយកនាមត្រកូលជប៉ុនដែលត្រូវបានគេស្គាល់ថាជាចលនា **ស៊ោស៊ីកាយ៉ាមី** (Sōshi-kaimei)[១៩]។ អ្វីដែលធ្ងន់ធ្ងរថែមទៀតនោះ វប្បធម៌ប្រពៃណីរបស់កូរ៉េទទួលរងការខូចខាតយ៉ាងដំណំ ដោយសារវត្ថុបុរាណវប្បធម៌កូរ៉េជាច្រើនត្រូវបានបំផ្លិចបំផ្លាញ[២០] ឬត្រូវបានយកទៅប្រទេសជប៉ុន [២១] រហូតមកដល់សព្វថ្ងៃនេះវត្ថុបុរាណកូរ៉េដ៏មានតម្លៃជាច្រើនអាចត្រូវបានគេ

រកឃើញនៅក្នុងសារមន្ទីរជប៉ុន ឬក្នុងសៀវភៅប្រមូលផ្ដុំឯកជន(២២)។ ការស៊ើបអង្កេតមួយរបស់រដ្ឋាភិបាលកូរ៉េខាងត្បូងបានកំណត់អត្តសញ្ញាណទ្រព្យសម្បត្តិវប្បធម៌ចំនួន៧៥ ៣១១ ដែលត្រូវបានគេយកមកពីប្រទេសកូរ៉េ ក្នុងនោះចំនួន៣៤ ៣៦៩យកនៅក្នុងប្រទេសជប៉ុន និង ១៧ ៨០៣នៅសហរដ្ឋអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ ពួកអ្នកជំនាញប៉ាន់ប្រមាណថាវត្ថុបុរាណជាង១០០០០០ នៅតែមាននៅក្នុងប្រទេសជប៉ុន(២២)។ មន្ត្រីជប៉ុនបានចាត់ទុកការវិលត្រឡប់មកវិញនូវសម្បត្តិវប្បធម៌របស់ប្រទេសកូរ៉េ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ននេះ(២២) វាមិនទាន់បានកើតឡើងទេ។ អំឡុងពេលជប៉ុនកាន់កាប់ទឹកដីប្រទេសផ្សេងៗ ជប៉ុនបានបញ្ជូនជនជាតិខ្លួនទៅតាំងទីលំនៅលើដែនទឹកដីអាណានិគមខ្លួនរួមទាំងកូរ៉េផងដែរ(២៣)។ នៅចុងសង្គ្រាមលោកលើកទី២ មានអ្នកតាំងលំនៅជនជាតិជប៉ុនមានជាង ៨៥០ ០០០នាក់នៅក្នុងប្រទេសកូរ៉េ(២៤)។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ ភាគច្រើននៃជនជាតិជប៉ុនទាំងនេះបានធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសជប៉ុនវិញ។ នៅមានជំលោះមួយចំនួនបន្តដល់បច្ចុប្បន្ន ដូចជាជំលោះលើភាពជាម្ចាស់នៃកោះដុកដូដែលជាកោះតូចៗនៅភាគខាងកើតនៃឧបទ្វីបកូរ៉េ ហើយដោយសារប្រវត្តិសាស្ត្រជូរចត់ជាមួយជប៉ុនបែបនេះហើយទើបវាធ្វើឱ្យជះឥទ្ធិពលមួយចំនួនដល់ប្រព័ន្ធអប់រំកូរ៉េ ពិសេសការបង្កើតឱ្យមានគំនិតជាតិនិយម ហើយសិស្ស-និស្សិតកូរ៉េនិយមរៀនភាសាចិនជាងភាសាជប៉ុន។

នៅឆ្នាំ១៩៤៥ ដោយមានការចុះចាញ់របស់ជប៉ុន អង្គការសហប្រជាជាតិបានបង្កើតគម្រោងគ្រប់គ្រងរដ្ឋបាលដោយភាគខាងជើងខ្សែស្របទី៣៨ គ្រប់គ្រងដោយសហភាពសូវៀត ហើយខាងត្បូងគ្រប់គ្រងដោយសហរដ្ឋអាមេរិក។ បន្ទាប់ពីសង្គ្រាមលោកទី២ ពិភពលោកឈានដល់សម័យសង្គ្រាមត្រជាក់របស់មហាអំណាចឈ្នះសង្គ្រាមទាំងពីរ ក្នុងការដ

ណ្តើមឧត្តមភាពរៀងៗខ្លួន។ នយោបាយនៃសង្គ្រាមនេះ បានបណ្តាលឱ្យមានការបែងចែកកូរ៉េជាពីរ ហើយបង្កើតរដ្ឋាភិបាលដាច់ដោយឡែកពីគ្នាពីរ កូរ៉េខាងជើង និងកូរ៉េខាងត្បូងនៅឆ្នាំ១៩៤៨។ យោងតាម មហាសន្និបាតអង្គការសហប្រជាជាតិបានផ្តល់ការអនុម័តឱ្យមានការបង្រួបបង្រួមប្រទេសកូរ៉េតែមួយ តែសហភាពសូវៀតជំនាស់មិនឱ្យមានការបោះឆ្នោតនៅកូរ៉េខាងជើង ចំណែកឯកូរ៉េខាងត្បូងបានបោះឆ្នោតបង្កើតរដ្ឋាភិបាលមួយ។ ដើម្បីឆ្លើយតប កូរ៉េខាងជើងបានប្រកាសបង្កើតសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េខាងជើង។ ជាលទ្ធផលសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េដែលជាសាធារណរដ្ឋសង្គមនិយមយកលំនាំបែបសូវៀត ហើយសាធារណរដ្ឋកូរ៉េដែលជារបបបែបលោកខាងលិចត្រូវបានបង្កើតឡើងនៅភាគខាងត្បូង។

**សង្គ្រាមកូរ៉េ**បានផ្ទុះឡើងនៅពេលដែលកូរ៉េខាងជើងគាំទ្រដោយប្រទេសសូវៀតបានឈ្លានពានប្រទេសកូរ៉េខាងត្បូង ទោះបីជាមិនមានភាគីណាមួយទទួលបានទឹកដីច្រើនក៏ដោយ។ ឧបទ្វីបកូរ៉េនៅតែត្រូវបានបែងចែកតំបន់គ្មានយោធានៅចន្លោះព្រំដែនជាក់ស្តែងរវាងរដ្ឋទាំងពីរ។ នៅខែមិថុនា ឆ្នាំ១៩៥០ កូរ៉េខាងជើងបានឈ្លានពានភាគខាងត្បូងដោយប្រើរថក្រោះសូវៀត និងសព្វាវុធ។ សង្គ្រាមកូរ៉េជាសង្គ្រាមបង្ហូរឈាមដ៏ធំនៅក្នុងប្រវត្តិសាស្ត្រមនុស្សលោក ដោយសារមហាអំណាចពីរបានបះទង្គិចគ្នាដោយផ្ទាល់នៅលើសមរភូមិ។ ក្នុងកំឡុងសង្គ្រាមកូរ៉េ(១៩៥០-៥៣) មនុស្សជាង ១,២លាននាក់បានស្លាប់ហើយការប្រយុទ្ធគ្នារយៈពេល ៣ឆ្នាំនៅទូទាំងប្រទេស ហើយប្រជាពលរដ្ឋរាប់លាននាក់ទៀតបានបាត់បង់ទីជម្រកដោយសារទីក្រុងជាច្រើនត្រូវបានបំផ្លិចបំផ្លាញ។ ការខូចខាតនៅលើសមភូមិ មានទំហំធំធេងមិនចាញ់សង្គ្រាមលោកលើកទី១ឡើយ។ សង្គ្រាមបានបញ្ចប់នៅក្នុងកិច្ចព្រមព្រៀងយុទ្ធសន្តិសុខមួយ។

ចាប់តាំងពីឆ្នាំ១៩៦០ សេដ្ឋកិច្ចកូរ៉េខាងត្បូងបានរីកចម្រើនយ៉ាងខ្លាំងហើយរចនាសម្ព័ន្ធសេដ្ឋកិច្ចត្រូវបានផ្លាស់ប្តូរយ៉ាងខ្លាំង។ នៅឆ្នាំ១៩៥៧ កូរ៉េខាងត្បូងមានផលិតផលក្នុងស្រុកសរុបទាបសម្រាប់មនុស្សម្នាក់ៗទាបជាងប្រទេសហ្គាណា(២៥) តែមកដល់ឆ្នាំ២០០៨ វាកើនខ្ពស់ជាងប្រទេសហ្គាណា១៧ដងឯណោះ។ កូរ៉េខាងជើងដែលជាផ្លូវការជាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េគឺជា រដ្ឋឯកបក្សតែមួយដែលបច្ចុប្បន្នផ្តោតលើមនោគមវិជ្ជា Juche របស់លោកគីមអ៊ីលស៊ុងជាមួយនឹងសេដ្ឋកិច្ចឧស្សាហកម្មដែលបានគ្រោងទុកថ្នាក់មជ្ឈឹម។ កូរ៉េខាងត្បូងមានឈ្មោះជាផ្លូវការជាសាធារណរដ្ឋកូរ៉េគឺជា រដ្ឋពហុបក្សដែលមានសេដ្ឋកិច្ចទីផ្សារមូលធនរួមជាមួយសមាជិកភាពនៅក្នុងអង្គការដើម្បីកិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច និងG-២០។ រដ្ឋទាំងពីរមានភាពខុសប្លែកទាំងផ្នែកវប្បធម៌ និងសេដ្ឋកិច្ចចាប់តាំងពីការពុះចែកជាពីរ ទោះបីជាពួកគេនៅតែចែករំលែកវប្បធម៌ប្រពៃណី និងប្រវត្តិសាស្ត្រមុនសង្គ្រាមត្រជាក់ក៏ដោយ។ យោងទៅតាមលោក R.J. Rummel ការពលករធ្វើការដោយបង្ខំ ការសម្លាប់ និងជំរុំប្រមូលផ្តុំជាមូលហេតុដ៏សំខាន់ចំពោះការស្លាប់ជាង១លាននាក់នៅក្នុងប្រទេសកូរ៉េខាងជើងពីឆ្នាំ១៩៤៨ ដល់ឆ្នាំ១៩៨៧(២៦) ហើយអ្នកផ្សេងទៀតបានប៉ាន់ប្រមាណថាមានអ្នកស្លាប់៤០០ ០០០នាក់នៅក្នុងជំរុំហ្វឹកហាត់តែឯង(២៧)។ ការប៉ាន់ស្មានផ្អែកលើការធ្វើជំរឿនកូរ៉េខាងជើងថ្មីៗនេះបានបង្ហាញថាមានមនុស្សចំនួនពី២៤០ ០០០ ទៅ៤២០ ០០០ នាក់បានស្លាប់ដោយសារតែគ្រោះទុរភិក្សអត់ឃ្លាននៅឆ្នាំ១៩៩០ ហើយមានចំនួនមនុស្សស្លាប់ខុសពីធម្មតាពី
៦0000 ទៅ៨៥0000 នាក់នៅកូរ៉េខាងជើងចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៨។(២៨)

បន្ទាប់ពីសង្គ្រាម កូរ៉េខាងត្បូងនៅតែជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុតក្នុងពិភពលោកអស់រយៈពេលជាងមួយទសវត្សរ៍។ នៅឆ្នាំ១៩៦០ ផលិតផលក្នុងស្រុកសរុបរបស់មនុស្សម្នាក់ៗមានតម្លៃត្រឹមតែ៧៩ដុល្លារ[២៩]ប៉ុណ្ណោះ ពោលគឺទាបជាងបណ្តាប្រទេសអនុតំបន់សាហារ៉ាមួយចំនួន[៣០]ទៅទៀត។ កំណើនវិស័យឧស្សាហកម្មគឺជាការជំរុញដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកូរ៉េ។ នៅឆ្នាំ១៩៨៦ ឧស្សាហកម្មផលិតមានប្រហែល៣០%នៃផលិតផលក្នុងស្រុកសរុប(GDP) និង២៥%នៃកម្លាំងការងារ។ ដោយទទួលបានការលើកទឹកចិត្តយ៉ាងខ្លាំងទីផ្សារក្នុងស្រុក និងជំនួយបរទេស ឧស្សាហកម្មរបស់ទីក្រុងសេអ៊ូលបានដាក់បញ្ចូលនូវបច្ចេកវិទ្យាទំនើបទៅក្នុងបរិក្ខារផលិតកម្ម និងអគារថ្មីៗ ក្នុងល្បឿនលឿនមួយសម្រាប់បង្កើនផលិតកម្មទំនិញ ជាពិសេសសម្រាប់លក់នៅទីផ្សារបរទេស ហើយបានធ្វើឱ្យប្រាក់ចំណេញត្រឡប់ទៅរកការពង្រីកឧស្សាហកម្មរបស់ខ្លួនបន្ថែមទៀត។ ជាលទ្ធផលឧស្សាហកម្មបានផ្លាស់ប្តូរទស្សនីយភាពរបស់ប្រទេសដែលទាញបានកម្មកររាប់លាននាក់ទៅកាន់មជ្ឈមណ្ឌលផលិតកម្មក្នុងទីក្រុង។ មកដល់ពេលនេះ សេដ្ឋកិច្ចប្រទេសកូរ៉េខាងត្បូងមានទំហំធំជាងគេចំណាត់ថ្នាក់ទី៤នៅអាស៊ី និងជាប្រទេសធំបំផុតទី១១នៅលើពិភពលោក។ វាគឺជាសេដ្ឋកិច្ចចម្រុះ[៣១] ដែលគ្របដណ្តប់ដោយក្រុមហ៊ុនដែលគ្រប់គ្រងជាលក្ខណៈគ្រួសារដែលមានឈ្មោះថា chaebols[៣២]។ ប្រទេសកូរ៉េខាងត្បូងមានភាពល្បីល្បាញខាងការរីកចម្រើនដ៏អស្ចារ្យរបស់ខ្លួនពីប្រទេសក្រីក្របំផុតមួយក្នុងពិភពលោក ទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្នុងមួយជំនាន់។ អព្ភូតហេតុសេដ្ឋកិច្ចនេះ ត្រូវបានគេស្គាល់ជាទូទៅថាជាអព្ភូតហេតុនៅលើទន្លេហាន (Miracle on the Han River)[៣៣] បាននាំកូរ៉េខាងត្បូងទៅលំដាប់ថ្នាក់ខ្ពស់ ក្នុងចំណោមបណ្តាប្រទេសសេដ្ឋកិច្ចជឿនលឿន(OECD) និងG-

២០។ ប្រទេសកូរ៉េខាងត្បូងនៅតែជាប្រទេសមួយក្នុងចំណោមបណ្ដាប្រទេសកំពុងរីកចម្រើនលឿនបំផុតក្នុងពិភពលោកបន្ទាប់ពីវិបត្តិសេដ្ឋកិច្ច។ ទោះបីជា ប្រទេសកូរ៉េជាប្រទេសដែលរងគ្រោះធ្ងន់ធ្ងរដោយសារភ្លើងសង្គ្រាម និងស្ទើរតែគ្មានធនធានធម្មជាតិសោះ ព្រមទាំងត្រូវប្រឈមនឹងការកើនឡើងនៃចំនួនប្រជាជនកាន់តែច្រើននៅក្នុងដែនដីតូចរបស់ខ្លួនយ៉ាងណាក្ដី តែប្រទេសមួយនេះនៅតែអាចអភិវឌ្ឍន៍ខ្លួនក្លាយប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនខ្ពស់ក្នុងរយៈពេលដ៏ខ្លីមួយ។ ដើម្បីរាំងដល់ការកើនឡើងនូវចំនួនប្រជាជន និងការបង្កើតទីផ្សារក្នុងស្រុកដ៏ធំមួយនោះ ប្រទេសកូរ៉េខាងត្បូងបានសម្របសម្រួលយុទ្ធសាស្ត្រសេដ្ឋកិច្ចឆ្ពោះទៅមុខដើម្បីជំរុញសេដ្ឋកិច្ចរបស់ខ្លួនហើយនៅក្នុងឆ្នាំ២០១៤ កូរ៉េខាងត្បូងគឺជាប្រទេសនាំចេញធំលំដាប់ទី៧ និងជាអ្នកនាំចូលធំលំដាប់ទី៧នៅលើពិភពលោក។ ធនាគារកូរ៉េ និងវិទ្យាស្ថានអភិវឌ្ឍន៍កូរ៉េបានបញ្ចេញជាទៀងទាត់នូវសូចនាករសេដ្ឋកិច្ចសំខាន់ៗ និងនិន្នាការសេដ្ឋកិច្ចនៃសេដ្ឋកិច្ចនៃប្រទេសកូរ៉េខាងត្បូង[៣៤]។ សេដ្ឋកិច្ចនៃប្រទេសកូរ៉េខាងត្បូងគឺជាមេដឹកនាំអេឡិចត្រូនិចឈានមុខគេលើពិភពលោក[៣៥] broadband ចល័ត និងស្មាតហ្វូន[៣៦]។ ទូរទស្សន៍អេឡិចត្រូនិកអេក្រង់LCD របស់កូរ៉េខាងត្បូងបានកើនឡើងដល់៣៧ ភាគរយនៅឆ្នាំ២០០៩ ដែលបានកើនពី ២៧ ភាគរយនៅចុងឆ្នាំ២០០៧ ហើយវានឹងជំនួសប្រទេសជប៉ុនក្នុងនាមជាអ្នកផ្គត់ផ្គង់ទូរទស្សន៍ LCD លំដាប់ទី១នៅលើពិភពលោក។ សេដ្ឋកិច្ចនៃប្រទេសកូរ៉េខាងត្បូងស្ថិតនៅលេខរៀងទី១លើពិភពលោកក្នុងសន្ទស្សន៍អភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាននៅឆ្នាំ២០១៥[៣៧] និងសន្ទស្សន៍ការច្នៃប្រឌិតរបស់Bloomberg ឆ្នាំ២០១៥[៣៨]។ អត្រាកំណើនសេដ្ឋកិច្ចរបស់ខ្លួនបានកើនឡើង៦,២% ក្នុងឆ្នាំ២០១០ ដែលជាការងើបឡើងវិញយ៉ាងលឿនពីអត្រាកំណើនសេដ្ឋកិច្ច២,៣% ក្នុងឆ្នាំ២០០៨ និង០,២ % នៅឆ្នាំ២០០៩ នៅពេលមានវិបត្តិ

ហិរញ្ញវត្ថុសកល។ សេដ្ឋកិច្ចកូរ៉េខាងត្បូងបានងើបឡើងវិញជាថ្មីម្តងទៀតជាមួយនឹងកំណើនអតិរេកចំនួន៧០,៧ ពាន់លានដុល្លារនៃគណនីចរន្តនៅចុងឆ្នាំ២០១៣ ពោលគឺកើនឡើង៤៧%ពីឆ្នាំ២០១២ ចំពេលដែលភាពមិនច្បាស់លាស់នៃវិបត្តិសេដ្ឋកិច្ចពិភពលោកជាមួយនឹងទិន្នផលសេដ្ឋកិច្ចដ៏សំខាន់គឺការនាំចេញផលិតផលបច្ចេកវិទ្យា[៣៩]។ សព្វថ្ងៃដោយសារកំណើនសេដ្ឋកិច្ចខ្លាំងក្លា ធ្វើឱ្យប្រទេសមួយនេះកង្វះនូវកម្លាំងពលកម្ម ហើយដើម្បីដោះស្រាយបញ្ហានេះ កូរ៉េបានផ្តល់លទ្ធភាពច្រើនដល់ពលករក្រៅប្រទេសមកធ្វើការនៅប្រទេសកូរ៉េយ៉ាងច្រើនដូចជាប្រទេសកម្ពុជា និងវៀតណាមជាដើម។

ក្នុងឆ្នាំ១៩៨០ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកូរ៉េខាងត្បូងក្នុងមនុស្សម្នាក់ៗមានចំនួន២៣០០ ដុល្លារប្រហែលមួយភាគបីនៃសេដ្ឋកិច្ចអាស៊ីដែលនៅជិតខាងដូចជា៖ សិង្ហបុរី ហុងកុងនិងជប៉ុន។ ចាប់តាំងពីពេលនោះមក កូរ៉េខាងត្បូងបានឈានចូលទៅក្នុងសេដ្ឋកិច្ចអភិវឌ្ឍន៍ដើម្បីទទួលបានផលទុនសរុបក្នុងមនុស្សម្នាក់ៗចំនួន៣០ ០០០ដុល្លាក្នុងឆ្នាំ២០១០ ពោលគឺមានចំនួន ១៣ដងច្រើនជាងកាលពី៣០ឆ្នាំមុន។ ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសទាំងមូលបានកើនឡើងពី៨៨ ពាន់លានដុល្លារទៅ១ ៤៦០ពាន់លានដុល្លារក្នុងពេលតែមួយ[៤០]។ កំណើនសន្ទុះដ៏លឿននៃខឿនសេដ្ឋកិច្ចនេះ មិនអាចកាត់ផ្តាច់ចេញពីគុណតម្លៃដ៏ថ្លៃថ្លានៃប្រព័ន្ធអប់រំកូរ៉េឡើយ ដែលវាដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិខ្លួនឱ្យរីកចម្រើនក្លាយជាអរិយប្រទេសដូចសព្វថ្ងៃនេះបានឡើយ។ ខាងក្រោម ជាការសិក្សាលម្អិតពីប្រព័ន្ធអប់រំប្រទេសកូរ៉េ។

## 4.2) ប្រព័ន្ធអប់រំប្រទេសកូរ៉េខាងត្បូង

ការសិក្សាខាងក្រោមនេះផ្តោតតែប្រព័ន្ធអប់រំប្រទេសកូរ៉េខាងត្បូងប៉ុណ្ណោះ។ ប្រព័ន្ធអប់រំរបស់ប្រទេសនេះដូចនឹងប្រទេសកម្ពុជាដែរ គឺមានប្រាំមួយឆ្នាំនៅសាលាបឋមសិក្សា បីឆ្នាំនៅសាលាមធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) និងបីឆ្នាំទៀតនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ)។ សិស្សត្រូវចូលរៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សាដោយមិនចាំបាច់បង់ថ្លៃសិក្សា លើកលែងតែថ្លៃតិចតួចមួយដែលគេហៅថា "**ថ្លៃឈ្នួលជំនួយប្រតិបត្តិការសាលារៀន**" ដែលខុសគ្នាពីសាលារៀនមួយទៅសាលារៀនមួយទៀត។ ជាទូទៅ សេវាអប់រំនៅប្រទេសកូរ៉េខាងត្បូងត្រូវបានផ្តល់ដោយសាលារៀនរដ្ឋ និងសាលាឯកជន។ សាលារៀនទាំងពីរប្រភេទនេះទទួលបានមូលនិធិគាំទ្រពីរដ្ឋាភិបាល ដោយសាលាឯកជនទទួលបានតិចជាងសាលារដ្ឋ [៤១]។

---

ប្រទេសកូរ៉េខាងត្បូងគឺជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសសមាជិកOECD ដែលមានប្រព័ន្ធអប់រំដំណើរការល្អៗ ហើយលទ្ធផលតេស្ត PISA ដែលផ្តោតលើសមត្ថភាពអាន គណិតវិទ្យា និងវិទ្យាសាស្ត្រ កូរ៉េទទួលបានពិន្ទុជាមធ្យមដល់ទៅ៥៤២ឯណោះ។ ប្រទេសនេះមានកម្លាំងពលកម្មដែលមានការអប់រំខ្ពស់បំផុតមួយក្នុងចំណោមបណ្តាប្រទេសសេដ្ឋកិច្ចជឿនលឿន OECD [៤២]។ នៅឆ្នាំ២០១៤ ចំណាត់ថ្នាក់គណិតវិទ្យា និងវិទ្យាសាស្ត្ររបស់សិស្សកូរ៉េខាងត្បូង បានជាប់ចំណាត់ថ្នាក់ទី២ នៅទូទាំងពិភពលោកបន្ទាប់ពីប្រទេសសិង្ហបុរី[៤៣]។ ការអប់រំខ្ពស់នេះគឺជាបញ្ហាដ៏ធំធេងមួយនៅក្នុងសង្គមកូរ៉េខាងត្បូងដែលវាត្រូវបានគេចាត់ទុកថាជាផ្នែកសំខាន់នៃជីវិតរបស់សិស្ស-និស្សិតកូរ៉េខាងត្បូង។ សង្គមកូរ៉េខាងត្បូង ផ្តល់អាទិភាពបំផុតដល់វិស័យអប់រំ ហើយភាពជោគជ័យនៃការអប់រំ

ដើរតួនាទីយ៉ាងសំខាន់ក្នុងការកែលម្អស្ថានភាពសេដ្ឋកិច្ច-សង្គម(៤៤)។ ជោគជ័យលើការសិក្សាគឺជាប្រភពនៃមោទកភាពសម្រាប់គ្រួសារ ក៏ដូចជាសម្រាប់សង្គមកូរ៉េទាំងមូល។ ប្រជាជនកូរ៉េខាងត្បូងចាត់ទុកការអប់រំជាគន្លឹះក្នុងការជំរុញវឌ្ឍនភាពសង្គមសម្រាប់ខ្លួនឯងផ្ទាល់ និងគ្រួសាររបស់ពួកគេដែលជាច្រកផ្លូវទៅកាន់វណ្ណៈកណ្តាលនៅក្នុងសង្គម។ ការបញ្ចប់ថ្នាក់បរិញ្ញាបត្រពីសាកលវិទ្យាល័យកំពូលៗគឺជាចំណុចសំខាន់បំផុតនៃកិត្យានុភាព ស្ថានភាពសេដ្ឋកិច្ច-សង្គមខ្ពស់ ការសន្យាពីអាពាហ៍ពិពាហ៍ និងគន្លងអាជីពដ៏គួរឱ្យគោរព(៤៥)។ ការសន្យាពីអាពាហ៍ពិពាហ៍នៅទីនេះមានន័យថា អ្នកដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យល្បីៗ ត្រូវបានគេឱ្យតម្លៃ ហើយងាយស្រួលក្នុងការរើសគូស្រករ ចំណែកឯ អ្នកដែលមានកម្រិតសិក្សាទាប ត្រូវបានគេរើសអើង និងពិបាករកគូស្រករ ពិសេសស្ត្រីកូរ៉េតែម្តងដែលមិនឱ្យតម្លៃបុរសដែលមានការសិក្សាទាបទេ។ ជាក់ស្តែង ពលករបរទេសជាច្រើនដែលទៅធ្វើការនៅកូរ៉េជាច្រើន ស្ទើរតែមិនមានសោះឡើងនូវពាក្យថា "**ស្នេហា**" ជាមួយស្ត្រីជនជាតិកូរ៉េ។ សូម្បីតែ ប្រព័ន្ធនយោបាយរបស់កូរ៉េក៏ឱ្យតម្លៃលើអ្នកនយោបាយវណ្ណៈខ្ពស់ដែលមានប្រវត្តិអប់រំពីសាលាល្បីៗដែរ។ ជាក់ស្តែង អ្នកនយោបាយនិយមអភិរក្ស Jeon Yeo-ok បានជំទាស់ជាសាធារណៈចំពោះការតែងតាំងអតីតប្រធានាធិបតី Roh Moo-hyun ដែលមិនបានបញ្ចប់ការសិក្សាពីស្ថាប័នជាន់ខ្ពស់។

ជីវិតកុមារភាពវិលវល់ជុំវិញការអប់រំ និងទទួលរងនូវសម្ពាធធ្ងន់ធ្ងរដើម្បីទទួលបានជោគជ័យក្នុងការសិក្សា ហើយវាចាក់ឫសយ៉ាងស៊ីជម្រៅតាំងពីក្មេងមកម្ល៉េះ។ អ្នកដែលខ្វះការសិក្សានៅសាកលវិទ្យាល័យជាញឹកញាប់ប្រឈមមុខនឹងការរើសអើងដោយសង្គម(៤៦)។ ស្ថានភាពសង្គមបែបនេះ បានជំរុញដល់សិស្ស-និស្សិតកូរ៉េឱ្យខិតខំព្យាយាមសិក្សារៀនសូត្រឱ្យបានខ្ពង់ខ្ពស់ ហើយករណីនេះ វាបង្កឱ្យមានការប្រកួតប្រជែងដ៏ខ្លាំងនៅក្នុង

វិស័យអប់រំ។ ភាពខ្នះខ្នែងរបស់កូរ៉េខាងត្បូងចំពោះការអប់រំ និងបំណងប្រាថ្នារបស់និស្សិតក្នុងការចូលរៀននៅសកលវិទ្យាល័យល្អៗគឺជាផ្នែកមួយខ្ពស់បំផុតនៅក្នុងពិភពលោកដែលជាកតាលីករមួយជួយជំរុញឱ្យប្រទេសកូរ៉េមានអត្រាចូលរៀនកម្រិតឧត្តមសិក្សាខ្ពស់លើសប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀត។ ការចូលសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាគឺដើម្បីឈានទៅរកការងារដែលប្រាក់បៀវត្សខ្ពស់ មានសុវត្ថិភាពអាជីព និងមានកេរ្តិ៍ឈ្មោះល្បីល្បាញតាមរយៈការធ្វើការនៅតាមស្ថាប័នរដ្ឋាភិបាល ធនាគារ ព្រមទាំងក្រុមហ៊ុនកូរ៉េខាងត្បូងសំខាន់ចំនួនដូចជា៖ ក្រុមហ៊ុន Samsung ក្រុមហ៊ុន Hyundai ឬក្រុមហ៊ុន LG អេឡិចត្រូនិចជាដើម[៤៧]។ សម្រាប់សាកលវិទ្យាល័យកំពូលៗនៅកូរ៉េខាងត្បូងដែលមហាជនកូរ៉េទទួលស្គាល់ជាទូទៅមាន ០៣ដូចជា៖ សាកលវិទ្យាល័យជាតិសេអ៊ូល សាកលវិទ្យាល័យកូរ៉េ និង សាកលវិទ្យាល័យយ៉ុនស៊ី[៤៨]។ ភាពតឹងរឹងនៃការប្រឡងចូលរៀននៅសាកលវិទ្យាល័យល្បីៗនាំឱ្យមានការប្រកួតប្រជែងដ៏ខ្លាំងក្លាក្នុងចំណោមសិស្សានុសិស្សទាំងឡាយ ហើយជាទូទៅការដាក់សម្ពាធសិក្សាដើម្បីទទួលបានពិន្ទុខ្ពស់បំផុត ត្រូវបានជ្រួតជ្រាបយ៉ាងជ្រៅនៅក្នុងសន្តានចិត្តរបស់សិស្សកូរ៉េខាងត្បូងតាំងពីកម្រិតបឋមសិក្សាមកម្ល៉េះ[៤៩]។ ជារួម យើងអាចនិយាយបានថា កូរ៉េមានបំរាមវប្បធម៌ដ៏សំខាន់មួយនៅក្នុងសង្គមដែលជាប់ទាក់ទងទៅនឹងអ្នកដែលមិនទទួលបានការអប់រំនៅសាកលវិទ្យាល័យជាផ្លូវការ ប្រឈមនឹងការរើសអើងពីសង្គម ហើយជារឿយៗត្រូវបានមើលងាយដោយអ្នកដទៃទៀត ដែលជាពលរដ្ឋថ្នាក់កណ្តាល ហើយជាលទ្ធផលពួកគេមានឱកាសតិចតួចទទួលបានការងារល្អ ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ច-សង្គម និងអនាគតនៃអាពាហ៍ពិពាហ៍[៥០]។ ទោះបីជាយ៉ាងណាក៏ដោយ មានការទទួលស្គាល់ជាអន្តរជាតិលើប្រព័ន្ធអប់រំរបស់កូរ៉េខាងត្បូងដែលជួយធ្វើឱ្យលទ្ធផលនៃការធ្វើតេស្ត( ឧ.PISA )ទទួលបានខ្ពស់

និងតួនាទីដ៏សំខាន់របស់វាក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការបង្កើតនូវកម្លាំងពលកម្មដែលមានកម្រិតសិក្សាបានខ្ពស់ច្រើនបំផុតក្នុងពិភពលោក[៥១]។ ប្រជាជនកូរ៉េខាងត្បូងដែលមានអាយុពី២៥ឆ្នាំទៅ ៣៤ ឆ្នាំចំនួន៦៨% មានសញ្ញាប័ត្របរិញ្ញាបត្រដែលស្ថិតិនេះខ្ពស់បំផុតនៅក្នុង OECD[៥២]។ ដើម្បីសម្រេចបានភាពជោគជ័យនេះ ប្រទេសកូរ៉េខាងត្បូងក៏បានយកចិត្តទុកយ៉ាងខ្លាំងលើវិស័យអប់រំ តាមរយៈការបង្កើនទុនវិនិយោគជាប្រចាំ។ ការវិនិយោគដ៏រឹងមាំនៅក្នុងវិស័យអប់រំជា កម្លាំងជំរុញដ៏សំខាន់ក្នុងការជួយដល់ការអភិវឌ្ឍប្រទេសពីប្រទេសក្រីក្រ ទទួលរងការបំផ្លិចបំផ្លាញដោយសារភ្នក់ភ្លើងសង្គ្រាមទៅជាប្រទេសមានសេដ្ឋកិច្ចលូតលាស់យ៉ាងឆាប់រហ័សក្នុងរយៈពេល៦០ឆ្នាំ[៥៣]។ នៅឆ្នាំ ២០១៥ ប្រទេសនេះបានចំណាយ៤,៧%នៃផលិតផលក្នុងស្រុកសរុបរបស់ខ្លួនលើគ្រប់កម្រិតនៃការអប់រំដែលស្មើទៅនឹងមធ្យមភាគនៃអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD)[៥៤]។

ទោះបីជាយ៉ាងណាក៏ដោយ ប្រព័ន្ធអប់រំនេះក៏មានការរិះគន់មួយចំនួនផងដែរទៅលើរចនាសម្ព័ន្ធរឹងមាំ និងរឹងត្អឹងរបស់ប្រព័ន្ធដែលរារាំងការច្នៃប្រឌិត និងការច្នៃបង្កើតថ្មីដល់សិស្សានុសិស្ស[៥៥] ព្រមទាំងផ្តោតខ្លាំងទៅលើការរៀនសូត្របែបអកម្ម និងការប្រើប្រាស់វិធីសាស្ត្របែបចងចាំ។ វាត្រូវបានគេពិពណ៌នាថា ជាប្រព័ន្ធអប់រំមួយដែលដាក់សម្ពាធធ្ងន់ធ្ងរខ្លាំងពេកដល់សិស្សានុសិស្សដែលនាំទៅរកការប្រកួតប្រជែងខ្លាំងក្លា និងមានលក្ខណៈ**"ឃោរឃៅ"**[៥៦]។ ប្រព័ន្ធនេះជារឿយៗត្រូវបានស្តីបន្ទោសពីការធ្លាក់ចុះនៃការឱ្យតម្លៃលើគុណភាពជីវិត និងការកើនឡើងខ្ពស់នូវអត្រាធ្វើអត្តឃាតនៅទូទាំងប្រទេស ជាពិសេស ការកើននូវអត្រាអ្នកស្លាប់ក្នុងចំណោមសិស្សានុសិស្សវ័យក្មេងដែលមានអាយុចន្លោះពី១០ ទៅ១៩ឆ្នាំ។ បណ្តាញសារព័ត៌មានជាច្រើនបានលើកឡើងពីអត្រាធ្វើអត្តឃាតខ្ពស់នៅ

តែជាកង្វល់ទូទាំងប្រទេស ពិសេសជុំវិញការប្រឡងចូលមហាវិទ្យាល័យ ដែលកត្តាសំខាន់ក្នុងការកំណត់គន្លងជីវិតទាំងមូលរបស់សិស្ស-និស្សិត និងអាជីព(៥៧)។ អតីតគ្រូបង្រៀនកូរ៉េខាងត្បូងឈ្មោះ Se-Woong Koo បានសរសេរថាប្រព័ន្ធអប់រំរបស់កូរ៉េខាងត្បូងមានការរំលោភបំពានលើកុមារ ហើយថាវាគួរតែត្រូវបាន"**ធ្វើកំណែទម្រង់ និងរៀបចំរចនាសម្ព័ន្ធឡើងវិញដោយគ្មានការពន្យារពេល**"(៥៨)។ ជាមួយគ្នានេះ ប្រព័ន្ធអប់រំនេះក៏ត្រូវបានគេរិះគន់ផងដែរចំពោះការផ្គត់ផ្គង់និស្សិតដែលបញ្ចប់ការសិក្សានៅមហាវិទ្យាល័យលើសតម្រូវការ បង្កើតកម្លាំងពលកម្មដែលមិនឆ្លើយតបទៅនឹងកម្រិតការងារ និងមិនឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ ជាក់ស្តែង នៅត្រីមាសទី១ឆ្នាំ២០១៣ និស្សិតបញ្ចប់ការសិក្សាមានចំនួនជិត ៣,៣ លាននាក់ តែគ្មានការងារធ្វើដែលសមស្របទៅនឹងគុណតម្លៃកម្រិតសញ្ញាប័ត្ររបស់ខ្លួនដែលនាំឱ្យនិស្សិតទាំងនោះងាកទៅធ្វើការងារដែលមានតម្រូវការកម្រិតអប់រំទាបទៅវិញ។ មួយវិញទៀតក៏មានការរិះគន់ផងដែរ ប្រព័ន្ធអប់រំដែលមិនអាចដោះស្រាយបញ្ហាកង្វះខាតកម្លាំងពលកម្មដែលផ្តោតជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ពិសេសពលករដែលធ្វើការដោយប្រើកម្លាំង មិនមែនធ្វើការនៅក្នុងការិយាល័យ ដោយសាទិដ្ឋភាពនៃការរើសអើងក្នុងសង្គម និងមិនមានសញ្ញាប័ត្រពីសាកលវិទ្យាល័យល្បីៗ ហើយបញ្ហានេះ នៅតែបន្តចាក់ឫសគល់យ៉ាងជ្រៅក្នុងសង្គមកូរ៉េខាងត្បូង (៥៨)។

## 4.3) គន្លឹះជោគជ័យនៃប្រព័ន្ធអប់រំកូរ៉េខាងត្បូង

ប្រព័ន្ធអប់រំរបស់កូរ៉េខាងត្បូង ជាប្រព័ន្ធមួយប្រកបដោយគុណភាព និងមានភាពជោគជ័យខ្លាំងដោយបានដាក់ចេញនូវសសរស្តម្ភចំនួនបួនៈ (១)ដាក់ការអប់រំឱ្យស្ថិតនៅកណ្តាលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង (២)ការទទួលយកមនុស្សដែលមានសមត្ថភាពខ្ពស់ដើម្បីធ្វើជា

គ្រូបង្រៀន (៣)ការអភិវឌ្ឍមនុស្សទាំងនេះទៅជាគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព និង(៤)ផ្តល់អាទិភាពដល់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ក្នុងការអប់រំ។ ចតុស្តម្ភខាងលើ ផ្តល់នូវមេរៀនរៀនសូត្រជាច្រើនដែលយើងត្រូវសិក្សាស្វែងយល់ ពិសេសការបណ្តុះបណ្តាល ព្រមទាំងពង្រឹង និងការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងការប្រើបច្ចេកវិទ្យាក្នុងវិស័យអប់រំ។ ភាពជោគជ័យនៃប្រព័ន្ធអប់រំកូរ៉េ គឺកើតឡើងពីគំនិតផ្តួចផ្តើមដើម្បីគាំទ្រដល់គោលនយោបាយអប់រំរយៈពេលវែងដែលរួមមាន ផែនការច្បាស់លាស់ដើម្បីកែលម្អដំណើរការទទួលស្គាល់គុណភាពអប់រំនៃវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ការតំលើងប្រាក់ខែជាបន្តបន្ទាប់ ការបណ្តុះបណ្តាលគ្រូបង្រៀន និងការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងសាលារៀន[៥៩]។

❖ **ដាក់ការអប់រំឱ្យស្ថិតនៅកណ្តាលនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែង**

ការអប់រំគឺជា កត្តាចម្បងមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងរបស់កូរ៉េខាងត្បូង ហើយជាអាទិភាពខ្ពស់សម្រាប់អ្នកធ្វើគោលនយោបាយ។ មានទំនាក់ទំនងយ៉ាងរឹងមាំនៅក្នុងយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចរបស់កូរ៉េខាងត្បូង តម្រូវការទីផ្សារការងារ និងគោលនយោបាយអប់រំ។ រៀងរាល់៥ឆ្នាំម្តង ក្រសួងអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកូរ៉េបានធ្វើបច្ចុប្បន្នភាព និងធ្វើអោយប្រសើរឡើងនូវកម្មវិធីសិក្សាជាតិដោយគិតគូរពីការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ច និងលក្ខខណ្ឌជាតិ[៦០] ព្រមទាំងផ្សារភ្ជាប់ទំនាក់ទំនងក្នុងការបន្តអនុវត្តកែលម្អធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអប់រំពីរដ្ឋាភិបាលមួយទៅរដ្ឋាភិបាលមួយទៀត។

❖ **ការទទួលយកមនុស្សដែលមានសមត្ថភាពខ្ពស់ដើម្បីធ្វើជាគ្រូបង្រៀន**

ភ័ស្តុតាងដែលគួរឱ្យទុកចិត្តបង្ហាញពីគុណភាពប្រព័ន្ធសាលារៀនគឺពឹងផ្អែកជាសំខាន់លើគុណភាពគ្រូបង្រៀន។ ដូច្នេះ ការជ្រើសរើសមនុស្សមានសមត្ថភាពដើម្បីធ្វើជាគ្រូបង្រៀនជាគន្លឹះក្នុងការធ្វើឱ្យប្រព័ន្ធអប់រំមានលក្ខណៈប្រសើរឡើង(៦១)។ ជាក់ស្តែង មានតែនិស្សិតបញ្ចប់ការសិក្សាដែលមានពិន្ទុខ្ពស់តែ៥%ប៉ុណ្ណោះមកពីមហាវិទ្យាល័យអប់រំគ្រូបង្រៀននៅកូរ៉េខាងត្បូងដែលអាចក្លាយជាគ្រូបង្រៀនបាន។ លក្ខខណ្ឌនេះធ្វើឱ្យអាជីពគ្រូបង្រៀនមានកិត្យានុភាព និងជានានូវគុណភាពនៃលក្ខណៈសម្បត្តិ របស់គ្រូបង្រៀន(៦០)។ នៅប្រទេសកូរ៉េខាងត្បូង និស្សិតបញ្ចប់ការសិក្សារយៈពេល៤ឆ្នាំនៅមហាវិទ្យាល័យអប់រំ មានសិទ្ធិត្រឹមបង្រៀននៅសាលាឯកជនប៉ុណ្ណោះ ហើយដើម្បីជាប់ក្របខណ្ឌគ្រូបង្រៀនសាលារដ្ឋ ពួកគេត្រូវឆ្លងកាត់ការប្រឡងប្រជែងដ៏តឹងតែងមួយ។ ការធ្វើតេស្តនេះធានាថា គ្រូបង្រៀន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់មុនពេលចូលប្រឡូកវិជ្ជាជីវៈ។ សរុបមក ការប្រកួតប្រជែងយ៉ាងខ្លាំងក្លាសម្រាប់ការអប់រំគ្រូ និងការប្រឡងចូលតម្រូវឱ្យក្លាយជាគ្រូបង្រៀនដែលធានាថា គ្រូបង្រៀនត្រូវបានជ្រើសរើស សម្រិតសម្រាំងពីក្រុមបេក្ខជនដែលមានស្នាដៃសិក្សាឆ្នើមៗបំផុត(៦២)។ ប្រព័ន្ធអប់រំកូរ៉េបែបនេះ ផ្តល់អត្ថប្រយោជន៍ច្រើនក្នុងការផលិតនូវធនធានគ្រូបង្រៀនសម្បូរបែប និងគ្រប់គ្រាន់ឆ្លើយតបទៅនឹងស្តង់ដារ និងតម្រូវការ ពិសេសសម្រាប់បម្រើឱ្យសាលារៀនឯកជន។ សម្រាប់ស្ថានភាពនៅកម្ពុជាវិញ យើងឃើញថានៅកង្វះគ្រូបង្រៀនច្រើនដែលមានកម្រិតបណ្តុះបណ្តាលច្បាស់លាស់ពីស្ថាប័នផ្លូវការ ហើយក៏មិនទាន់មានមហាវិទ្យាល័យណាដែលមានបញ្ចូលកម្មវិធីសម្រាប់និស្សិតដែលពេលបញ្ចប់ការសិក្សាទៅមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចធ្វើចាប់យកអាជីពជាគ្រូបង្រៀននៅសាលាឯកជនដូចនៅប្រទេសកូរ៉េនៅឡើយ។ ជាក់ស្តែង គ្រូបង្រៀននៅសាលារៀនឯកជនមួយចំនួនមិនមានសញ្ញាប័ត្រគរុកោសល្យ ឬ

មិនមានការបណ្ដុះបណ្ដាលត្រឹមត្រូវទេ ហើយសាលាឯកជនជាច្រើនក៏បានជួលគ្រូបង្រៀនពីសាលារដ្ឋទៅធ្វើការឱ្យសាលារៀនខ្លួន ដែលធ្វើឱ្យប៉ះពាល់ច្រើនដល់ប្រសិទ្ធភាពនៃការបំពេញការងាររបស់គ្រូបង្រៀននៅតាមសាលារៀនរដ្ឋ និងយុទ្ធសាស្ត្រលើកកម្ពស់គុណភាពអប់រំដែលមានលក្ខណៈយូរអង្វែងពេលអនាគត។ ដោយសារស្ថានភាពបែបនេះ ធ្វើឱ្យការបំពេញការងាររបស់គ្រូបង្រៀននៅសាលារៀនរដ្ឋមានការបែកខ្ញែកច្រើន និងមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើការរួមគ្នា ដើម្បីអភិវឌ្ឍន៍វិជ្ជាជីវៈខ្លួន និងស្ថាប័ន។ សម្រាប់កម្ពុជា គប្បីស្វែងយល់ពីយុទ្ធសាស្ត្ររបស់ប្រទេសកូរ៉េក្នុងការផលិតធនធាននិស្សិតដែលមានចំណេះដឹង និងជំនាញដែលអាចធ្វើជាគ្រូបង្រៀន ពេលបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ ពិសេសសម្រាប់យកទៅបំពេញឱ្យការងារនៅតាមសាលារៀនឯកជន។ ជាការពិត យើងប្រហែលជាពិបាកក្នុងការប្រើប្រាស់យន្តការបណ្ដុះបណ្ដាលនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ ឬវិទ្យាស្ថានគរុកោសល្យឱ្យបានច្រើនសម្រាប់បម្រើឱ្យសាលារៀនសាធារណៈផង និងឯកជនផង ព្រោះវាអាចលេចចេញបាតុភូតអវិជ្ជមានកើតឡើងដែលនាំឱ្យមានការតវ៉ា និងទាមទារផ្សេងៗ ដើម្បីទទួលបានក្របខណ្ឌសម្រាប់គរុនិស្សិតទាំងអស់នោះ។ ដូច្នេះ យន្តការបណ្ដុះបណ្ដាលនៅតាមមហាវិទ្យាល័យ ដោយដាក់បញ្ចូលនូវកម្មវិធីសិក្សាពីវិធីសាស្ត្របង្រៀន គរុកោសល្យ និងមុខវិជ្ជាសំខាន់ដទៃទៀតនៅឆ្នាំសិក្សាណាមួយគឺជារឿងល្អបំផុតមួយ។ វាប្រហែលជាផ្ដល់នូវភាពចំណេញច្រើនជាងដល់ការអភិវឌ្ឍវិស័យអប់រំតាមរយៈការបង្កើតការងារបន្ថែមដល់និស្សិតដែលបញ្ចប់ការសិក្សា ការបែងចែក និងការប្រើប្រាស់ធនធានគ្រូបង្រៀនបានត្រឹមត្រូវទាំងសាលារដ្ឋ និងឯកជន។

រដ្ឋាភិបាលកូរ៉េយល់ច្បាស់ណាស់ថា គ្រូបង្រៀនគឺជាធាតុសំខាន់បំផុតដែលប៉ះពាល់ដល់គុណភាពនៃការអប់រំ និងកំណត់ភាពជោគជ័យ ឬ

បរាជ័យរបស់វា។ ហេតុដូច្នេះគំនិតផ្តួចផ្តើមដើម្បីទាក់ទាញទេពកោសល្យមនុស្សដ៏ល្អឥតខ្ចោះដើម្បីវិជ្ជាជីវៈគ្រូបង្រៀន និងដើម្បីអភិវឌ្ឍ ព្រមទាំងរក្សាគ្រូបង្រៀនទាំងនោះត្រូវបានផ្សារភ្ជាប់ជាទូទៅជាមួយការលើកកម្ពស់គុណភាពអប់រំ។ នោះហើយជាមូលហេតុដែលគោលនយោបាយទាក់ទាញចំណេះដឹង និងរក្សាគោលនយោបាយគ្រូបង្រៀនមិនត្រូវបានគេបោះបង់ចោលពីរបៀបវារៈកំណែទម្រង់ការអប់រំដែលអនុវត្តដោយរបបនយោបាយបន្តបន្ទាប់នៃប្រទេសកូរ៉េខាងត្បូង(៦៣)។ កំណែទម្រង់ប្រាក់បៀវត្សគ្រូបង្រៀន ជាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការទាក់ទាញអ្នកដែលមានសមត្ថភាពដើម្បីធ្វើជាគ្រូបង្រៀន។ ពិតណាស់ គ្រូបង្រៀនទទួលបានប្រាក់បៀវត្សខ្ពស់នៅក្នុងប្រទេសកូរ៉េខាងត្បូង ហើយកើនឡើងក្នុងរយៈពេលយូរដោយលើកទឹកចិត្តឱ្យគ្រូបង្រៀនឱ្យប្រឡូកក្នុងវិជ្ជាជីវៈរយៈពេលវែង។ ឧទាហរណ៍ ប្រាក់ខែប្រចាំឆ្នាំសម្រាប់គ្រូបង្រៀនអនុវិទ្យាល័យគឺ **២៧ ៤៧៦** ដុល្លារ។ បន្ទាប់ពីការបង្រៀនរយៈពេល១៥ឆ្នាំប្រាក់ខែគ្រូបង្រៀនកូរ៉េខាងត្បូងកើនឡើងដល់**៤៨១៤៦**ដុល្លារអាមេរិកដែលខ្ពស់ជាងកម្រិតមធ្យមOECD( **៤១ ៦៦៥** ដុល្លារអាមេរិក ) ។ ( OECD 2012 )។ ប្រទេសកូរ៉េខាងត្បូងបានអនុវត្តសកម្មភាពគោលនយោបាយជាច្រើនដើម្បីជំរុញគ្រូដំបូង។ ជាមួយគ្នានេះ ដើម្បីធានាថា គ្រូបង្រៀនមានគុណសម្បត្តិគ្រប់គ្រាន់ វិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀនត្រូវបានពង្រឹងលើការងារគ្រប់គ្រង និងការបណ្តុះបណ្តាលធនធានគ្រូបង្រៀនជាប់គ្នាប្រចាំ។ រៀងរាល់៥ឆ្នាំម្តង វិទ្យាស្ថានអភិវឌ្ឍន៍ការអប់រំកូរ៉េធ្វើការវាយតម្លៃវិទ្យាស្ថានអប់រំគ្រូបង្រៀន ដោយគ្របដណ្តប់លើវិស័យដូចជា៖ **កម្មវិធីសិក្សា ការបង្រៀន និងការរៀន ហិរញ្ញវត្ថុនិងការគ្រប់គ្រង។ លទ្ធផលនៃការវាយតម្លៃត្រូវបានបញ្ជូនទៅស្ថាប័ននីមួយៗ និងបើកចំហដល់សាធារណជនដោយមានបំណងកែលម្អគុណភាព។ កិច្ចប្រឹងប្រែងនេះបង្ហាញពីគំនិតរបស់រដ្ឋាភិបាលកូរ៉េខាងត្បូងថា ការអប់រំ**

**ប្រកបដោយប្រសិទ្ធភាពគឺជាកម្លាំងជំរុញនៃការរីកចម្រើនរបស់ជាតិ ហើយគ្រូបង្រៀនដែលមានសមត្ថភាពគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអប់រំប្រកបដោយជោគជ័យ**(៦៤)។ បន្ថែមពីលើគោលនយោបាយជ្រើសរើសអ្នកមានសមត្ថភាពឱ្យធ្វើជាគ្រូបង្រៀន រដ្ឋាភិបាលកូរ៉េក៏យកចិត្តដទុកដាក់ខ្លាំងផងដែរក្នុងការជ្រើសរើសគ្រូបង្រៀនដែលមានគុណវុឌ្ឍិខ្ពស់ (សញ្ញាប័ត្របណ្ឌិត) និងមានស្នាដៃឆ្នើមក្នុងការងារដើម្បីធ្វើជាអ្នកគ្រប់គ្រង និងដឹកនាំ រាប់ចាប់ពីតួនាទីអ្នកគ្រប់គ្រង និងដឹកនាំកម្រិតសាលារៀនឡើងទៅ។ មួយវិញទៀត អាជីពគ្រូបង្រៀននៅប្រទេសកូរ៉េខាងត្បូង មានកិត្យានុភាពនៅក្នុងសង្គម និងមានប្រជាប្រិយភាពខ្លាំងក្នុងចំណោមអាជីពផ្សេងៗទៀត ដោយសារមានប្រាក់បៀវត្សរ៍ខ្ពស់ មានស្ថេរភាព និងលក្ខខណ្ឌការងារល្អ ហើយសិស្ស-និស្សិតឱ្យតម្លៃ ព្រមទាំងគោរពគ្រូបង្រៀនខ្លាំងណាស់ដែលជាចំណុចលេចធ្លោរក្នុងការទាក់ទាញជនជានមនុស្សល្អៗដើម្បីចាប់អាជីពមួយនេះ។

- **ការអភិវឌ្ឍមនុស្សទាំងនេះទៅជាគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព**

នៅប្រទេសកូរ៉េខាងត្បូង គ្រូបង្រៀនត្រូវចូលរួមសកម្មភាពអភិវឌ្ឍជំនាញវិជ្ជាជីវៈ។ រាជរដ្ឋាភិបាលតម្រូវឱ្យមានការអភិវឌ្ឍន៍វិជ្ជាជីវៈអប្បបរមា២០ម៉ោងសម្រាប់គ្រូម្នាក់ៗជារៀងរាល់ឆ្នាំ។ ទោះជាយ៉ាងនេះក្តី គ្រូបង្រៀនភាគច្រើនចូលរួមក្នុងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈចន្លោះពី៤០ ទៅ៦០ម៉ោងដើម្បីរក្សាការអភិវឌ្ឍថ្មីៗនៅក្នុងវិស័យជំនាញរបស់ពួកគេ។ គ្រូបង្រៀនកូរ៉េផ្លាស់ប្តូរគំនិត និងគាំទ្រគ្នាទៅវិញទៅមក ដោយគ្រូបង្រៀនដែលមានបទពិសោធន៍ច្រើនបានធ្វើការជាមួយគ្រូបង្រៀនដែលទើបចេញថ្មីដើម្បីជួយគាំទ្រពួកគាត់ ព្រមទាំងផ្តល់ជូននូវមេរៀន និងសកម្មភាពថ្នាក់រៀនរៀងរាល់សប្តាហ៍។ សម្ភារៈទាំងអស់ រួមទាំងសន្លឹកកិច្ចការ និងសកម្មភាពដែលមាន

មូលដ្ឋានលើបច្ចេកវិទ្យាត្រូវបានបោះពុម្ពរាល់សប្តាហ៍ និងដាក់បង្ហាញនៅលើវេបសាយពិសេសមួយ ដែលអាចរកបានសម្រាប់គ្រូទាំងអស់ និងប្រើប្រាស់ជាធនធានអភិវឌ្ឍន៍វិជ្ជាជីវៈ។ ជាមួយគ្នានេះ សៀវភៅមគ្គុទ្ទេសត្រូវបានផ្តល់ជូនដល់គ្រូបង្រៀនទាំងអស់ ដើម្បីទុកជាធនធានដែលមានប្រយោជន៍ ដោយបានដាក់បញ្ចូលនូវមេរៀនរៀនសូត្រ និងអនុសាសន៍សកម្មភាពជាក្រុម និងការបញ្ជាក់លម្អិតសម្រាប់ការបង្រៀនស្របតាមគោលដៅកម្មវិធីសិក្សា។ អ្វីដែលពិសេសមួយទៀតគឺ គ្រូបង្រៀននៅប្រទេសកូរ៉េត្រូវផ្លាស់ប្តូរកន្លែងធ្វើការរៀងរាល់៥ឆ្នាំម្តងពោលគឺពួកគេមិនបានធ្វើការនៅសាលារៀនដដែលៗក្នុងអាជីពការងារទាំងមូលរបស់ពួកគេទេ។ គ្រូបង្រៀនត្រូវចល័តទៅសាលារៀនផ្សេងទៀត ដោយមិនខ្វល់ថាអ្នកស្រឡាញ់សាលារៀនបច្ចុប្បន្នរបស់ខ្លួនប៉ុណ្ណាក៏ដោយ។ គ្រូបង្រៀន នាយករង និងនាយក អនុវត្តប្រព័ន្ធចាប់ឆ្នោតដើម្បីដូរសាលា។ ដូច្នេះរៀងរាល់ឆ្នាំសាលាតែងតែមានគ្រូបង្រៀនចំណូលថ្មីជានិច្ច។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើងដើម្បីឱ្យគ្រូមានឱកាសស្មើភាពគ្នាសម្រាប់គ្រូបង្រៀនទាំងអស់បានបង្រៀននៅសាលាល្បី និងសាលាមិនសូវល្បី។ បុគ្គលិកបង្រៀនជាប្រធានបទនៃការវាយតម្លៃ និងទទួលពិន្ទុពីការប្រឡង សិក្ខាសាលាដែលពួកគេចូល ក៏ដូចជាទទួលបានការលើកទឹកចិត្តចំពោះការបំពេញការងារបានល្អនៅក្នុងសាលារៀន។

### ❖ ផ្តល់អាទិភាពដល់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ក្នុងការអប់រំ

ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ក្នុងការអប់រំ អាចជួយផ្តល់ឱកាសអប់រំស្មើគ្នាទាំងសិស្ស និងគ្រូបង្រៀនដោយមិនគិតពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់សហគមន៍ដែលសាលារៀនស្ថិតនៅឡើយ[៦១]។ ការដាក់បញ្ចូល ICTទៅក្នុងការអប់រំមានសារៈសំខាន់សម្រាប់ផលិតធនធានមនុស្សដែលឆ្លើយតបទៅនឹងនិន្នាការសង្គម និងការរីកចម្រើនសេដ្ឋកិច្ច។

វេទិកាសិក្សាអេឡិចត្រូនិចត្រូវបានប្រើដើម្បីពង្រឹងកម្មវិធីសិក្សា បង្កើនការទំនាក់ទំនង និងគម្លាតក្នុងការទទួលបានសេវាអប់រំប្រែកបដោយគុណភាព ពោលគឺសិស្ស-និស្សិតអាចសិក្សាបាននៅគ្រប់ទីកន្លែង និងពេលវេលាតាមតម្រូវការពួកគេ(៦០)។ ថ្មីៗនេះប្រទេសកូរ៉េបានក្លាយជាប្រទេសដំបូងគេបង្អស់ក្នុងពិភពលោកដែលដាក់ជំនួសការសិក្សាដោយប្រើប្រាស់សៀវភៅពុម្ព ទៅប្រើប្រាស់សៀវភៅអេឡិកត្រូនិកដើម្បីឱ្យការសិក្សាមានលក្ខណៈវិទ្យាសាស្ត្រ ក្នុងនោះបានដាក់បញ្ចូលឯកសារឌីជីថលទាំងខ្លឹមសារនៃសៀវភៅសិក្សាដែលមានស្រាប់ និងបញ្ចូលធនធានប្រព័ន្ធផ្សព្វផ្សាយតាមអេឡិចត្រូនិច (ឈុតវីឌីអូ គំនូរជីវចល និងសកម្មភាពពិតជាក់ស្តែងដើម្បីឱ្យការសិក្សាកាន់តែមានលក្ខណៈរូបី)។ ផែនការលើកកម្ពស់សៀវភៅអេឡិចត្រូនិច ត្រូវបានបង្កើតឡើងដើម្បីបង្កើតការសិក្សាបែបបច្ចេកវិទ្យាដែលមានគុណភាពខ្ពស់ ហើយសមស្របសម្រាប់បរិយាកាសអប់រំនាពេលអនាគត និងដើម្បីគាំទ្រគោលដៅលើកកម្ពស់ **'ចំណេះដឹងជនជាតិកូរ៉េ'** ដោយការបង្កើតមូលដ្ឋានទិន្នន័យជាតិសម្រាប់ការបង្រៀន -រៀន និងនាំចេញព័ត៌មានបែបនេះនៅទូទាំងពិភពលោក(៦០)។ ជាមួយគ្នានេះ គ្រូបង្រៀនទាំងអស់នៅកូរ៉េក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកICT តាមរយៈការគាំទ្រដល់ការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាព ហើយភាគច្រើននៃវគ្គសិក្សាទាំងនេះត្រូវបានផ្តល់ជូននៅលើអ៊ីនធឺណិត។ នៅឆ្នាំ២០០៦ ក្រសួងអប់រំ និងធនធានមនុស្ស (MOE និងHRD) បានកែប្រែកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនដើម្បីបញ្ចូលបច្ចេកវិទ្យានៅក្នុងថ្នាក់រៀន។ កម្មវិធីថ្មីនេះបានអនុញ្ញាតឱ្យគ្រូបង្រៀនប្រើបច្ចេកវិទ្យាកាន់តែមានប្រសិទ្ធភាពដើម្បីលើកកម្ពស់ការបង្រៀន និងរៀន។ ស្ថិតិតាំងពីឆ្នាំ២០០៦ បង្ហាញថា គ្រូបង្រៀន៧២% ប្រើបច្ចេកវិទ្យានៅក្នុងថ្នាក់រៀន(៦៥)។ គ្រប់ថ្នាក់រៀននៅប្រទេសកូរ៉េបំពាក់

ដោយគ្រឿងបច្ចេកវិទ្យា (smart classroom) កុំព្យូទ័រ អ៊ីនធ័រណេត (មានល្បឿនលឿនខ្លាំង) LCD Projector និងក្តារខៀនវៃឆ្លាតដើម្បីជួយសិស្សសម្រាប់ដំណើរការបង្រៀន និងរៀនបានល្អ។ បច្ចេកវិទ្យាអាចជួយសិស្សទាំងអស់ រៀនបានលឿន និងអភិវឌ្ឍន៍ជំនាញសិក្សាមូលដ្ឋានបានស៊ីជម្រៅ។ សាលារៀនក៏មានសៀវភៅសិក្សាអេឡិចត្រូនិច (digital textbooks) ដើម្បីងាយស្រួលដល់សិស្សក្រីក្រមានលទ្ធភាពអានតាមប្រព័ន្ធអ៊ីធ័រណេត ដោយប្រើប្រាស់កុំព្យូទ័រ ធេបផ្លេត និងស្មាតហ្វូន។ ជាមួយគ្នានេះ ក្រសួងអប់រំក៏បង្កើតប្រព័ន្ធសិក្សានៅផ្ទះ (Cyber Home Learning System) ដើម្បីជួយសិស្សអាចស្វែងរកធនធានសិក្សា ឬរៀនបន្ថែមនៅតាមផ្ទះបាន។ ចាប់ពីឆ្នាំ២០០៨ កូរ៉េយកចិត្តទុកដាក់លុបបំបាត់គំលាតសិក្សាសិស្សនៅទីក្រុង និងជនបទ តាមរយៈការគាំទ្រហិរញ្ញវត្ថុ ឧបត្ថម្ភកុំព្យូទ័រ អាហារដល់សិស្ស និងកសាងសាលារៀនបន្ថែមដើម្បីសម្រួលដល់លទ្ធភាពការអប់រំរបស់សិស្ស។

ចំណុចមួយទៀតដែលបញ្ជាក់ពីភាពជោគជ័យនៃការអប់រំនៅប្រទេសកូរ៉េ គឺការយកចិត្តទុកដាក់ប្រឹងប្រែងសិក្សារៀនសូត្រពីសំណាក់សិស្សានុសិស្ស និងការគាំទ្រការសិក្សាយ៉ាងពេញទំហឹងពីសំណាក់មាតាបិតា អាណាព្យាបាលសិស្ស ពិសេសការគាំទ្រដល់ការរៀនគួរបន្ថែមក្រៅម៉ោងសិក្សាជាដើម។ ស្ថានភាពបែបនេះ ធ្វើឱ្យកើនឡើងនូវចំនួនគ្រឹះស្ថានសិក្សាឯកជនសម្រាប់រៀនគួរបន្ថែមក្រៅម៉ោង និងវគ្គបណ្តុះបណ្តាលផ្សេងៗក្រៅពីថ្នាក់រៀនធម្មតានៅសាលារដ្ឋ និងបានក្លាយជាផ្នែកសំខាន់នៃការអប់រំនៅប្រទេសកូរ៉េ។ ការស្ទង់មតិមួយដែលបានធ្វើឡើងតាំងពីឆ្នាំ២០០៣ ដោយវិទ្យាស្ថានអភិវឌ្ឍន៍ការអប់រំកូរ៉េ (KEDI) បានរាយការណ៍ថា សិស្សជនជាតិកូរ៉េ៧២,៦% (ក្នុងនោះសិស្សបឋមសិក្សាមាន៨៣,១% សិស្សអនុវិទ្យាល័យ៧៥,៣% និងសិស្សវិទ្យាល័យ៥៦,៤%) កំពុងរៀននៅ

សាលារៀនឯកជនក្រៅម៉ោងបន្ថែមពីលើការសិក្សាធម្មតានៅសាលារៀនរដ្ឋ(៦២)។ ប្រាក់ចំណូលគ្រួសារដ៏ច្រើនដែលវិនិយោគលើការអប់រំបន្ថែមក្រៅម៉ោងនៅប្រទេសកូរ៉េខាងត្បូងបាននាំឱ្យមានវិសមភាពដ៏ធំក្នុងការទទួលបានការអប់រំបន្ថែម រវាងសិស្សដែលមានប្រាក់ចំណូលខ្ពស់ និងមានប្រាក់ចំណូលទាប។ នៅឆ្នាំ២០០៤ រដ្ឋាភិបាលបានព្យាយាមដោះស្រាយបញ្ហានេះ តាមរយៈការបង្កើតប្រព័ន្ធរៀនតាមអ៊ីនធើរណេតដែលមានលក្ខណៈសម្បូរបែប និងឥតគិតថ្លៃដែលផ្តល់ឱកាសច្រើនដល់សិស្សក្នុងការស្វែងរកសេវារៀនបន្ថែមបានគ្រប់ពេលវេលា និងទីកន្លែងដើម្បីបំពេញតម្រូវការសិក្សារបស់ខ្លួន។ កម្មវិធីនេះ មានសារៈសំខាន់ជាខ្លាំងក្នុងការបង្កើនគុណភាពអប់រំសាធារណៈ កាត់បន្ថយចំនួនទឹកប្រាក់ដែលបានចំណាយទៅលើការរៀននៅសាលាឯកជន និងបិទគម្លាតការអប់រំរវាងតំបន់ និងឋានៈសង្គម។ ប្រព័ន្ធនេះផ្តល់ដល់សិស្សនូវធនធានសិក្សាបន្ថែមដើម្បីសិក្សានៅផ្ទះតាមរយៈអ៊ីនធើណែត ដើម្បីកាត់បន្ថយតម្លៃចំណាយលើការរៀនគួរនៅសាលាឯកជន និងដើម្បីលុបបំបាត់គម្លាតនៃការអប់រំនៅក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សា។ ប្រព័ន្ធនេះត្រូវបានប្រើប្រាស់ដោយសិស្ស-និស្សិតជាងបីលាននាក់ដែលពាក់កណ្តាលមកពីតំបន់ក្រៅស្រុក ឬតំបន់ដែលមានចំណូលទាប(៦០)។

មួយវិញទៀត រដ្ឋាភិបាលកូរ៉េខាងត្បូងក៏បានបើកឱ្យដំណើរការនូវវេទិកាបច្ចេកវិទ្យា គ្រប់គ្រងទិន្នន័យរដ្ឋបាលពាក់ព័ន្ធនឹងការអប់រំដូចជាប្រព័ន្ធព័ត៌មានអប់រំជាតិ (the national educa-tional information system (NEIS) និងប្រព័ន្ធព័ត៌មានការបង្ហាញព័ត៌មាន (the school information disclosure system-SIDS)របស់សាលារៀន។ NEIS ត្រូវបានបង្កើតឡើងដើម្បីសម្រួលដល់កិច្ចការរដ្ឋបាលរបស់សាលារៀនដូចជាៈ ការផ្តល់ប្រាក់អត្ថប្រយោជន៍នានា (remu-neration) ព័ត៌មានបុគ្គលិក

ការចូលរៀន និងកិច្ចការសិក្សានានា។ NEIS ដំណើរការ និងរក្សាទុកទិន្និន័យដែលមានប្រយោជន៍សម្រាប់ជួយដល់អ្នករៀបចំគោលនយោបាយក្នុងការសម្រេចចិត្តភ្លាមៗនៅពេលអនុវត្តគោលនយោបាយអប់រំ បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងអប់រំ ធានានូវភាពរឹងមាំក្នុងការអប់រំសាធារណៈ និងការលើកកម្ពស់សេវាកម្មដល់អ្នកប្រើប្រាស់។ ចំណែកឯ SIDSមានព័ត៌មានទាក់ទងនឹងបទបញ្ជារបស់សាលារៀន ស្ថានភាពសិស្ស និងគ្រូបង្រៀន សកម្មភាពអប់រំ សមិទ្ធិផលសាលារៀន លទ្ធផលតេស្ត និងលទ្ធផលតេស្តស្តង់ដារថ្នាក់ជាតិ។ ប្រព័ន្ធនេះជានាដល់សិស្សានុសិស្ស និងមាតាបិតាទទួលបានព័ត៌មានសាលារៀន និងលទ្ធផលសិក្សា ដើម្បីបង្កើនការយកចិត្តទុកដាក់ និងការចូលរួមរបស់មាតាបិតា និងសហគមន៍។ ប្រព័ន្ធនេះក៏មានប្រយោជន៍ផងដែរនៅពេលសិស្ស-និស្សិតធ្វើការផ្លាស់ប្តូរសាលារៀនពីសាលារៀនមួយទៅសាលារៀនមួយទៀត។ ព័ត៌មានរបស់ពួកគេត្រូវបានរក្សាទុកនៅក្នុងទិន្នន័យនៅលើបណ្តាញ និងអាចប្រើបានទៅសាលារៀនណាមួយដែលពួកគេចូលរួម។ SIDS ត្រូវបានគាំទ្រយ៉ាងខ្លាំងដោយទទួលបានអ្នកទស្សនាប្រហែល២០០០០នាក់ក្នុងមួយថ្ងៃ។ ៧,៧ លាននាក់បានចូលមើលគេហទំព័រតាំងពីការចេញផ្សាយនៅឆ្នាំ២០០៨[៦០]។

## 4.4) ដំណើរវិវត្ត និងការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំប្រទេសកូរ៉េខាងត្បូង

នេះជាការបង្ហាញដោយសង្ខេបពីប្រវត្តិនៃការអប់រំប្រទេសកូរ៉េនេះគឺចាប់ពីឆ្នាំ១៩៤៥ រហូតដល់បច្ចុប្បន្ន ដោយរួមទាំងការអប់រំសាធារណៈ (រដ្ឋ) និងឯកជន។

### សម័យក្រោយសង្គ្រាមលោកលើកទី២

បន្ទាប់ពីការរំដោះចេញពីប្រទេសជប៉ុន រដ្ឋាភិបាលកូរ៉េបានចាប់ផ្តើមសិក្សា និងពិភាក្សាផ្តោតលើទស្សនវិជ្ជាថ្មីៗនៃការអប់រំ។ ទស្សនវិជ្ជាអប់រំថ្មីនេះត្រូវបានបង្កើតឡើងក្រោមការគ្រប់គ្រងរបស់កងទ័ពសហរដ្ឋអាមេរិកក្នុងប្រទេសកូរ៉េ (USAMGIK) ដោយផ្តោតលើការអប់រំបែបប្រជាធិបតេយ្យ។ ប្រព័ន្ធថ្មីនេះបានព្យាយាមធ្វើឱ្យការអប់រំមានភាពស្មើគ្នាដល់សិស្សានុសិស្សទាំងអស់ និងលើកកម្ពស់រដ្ឋបាលអប់រំដើម្បីកូរ៉េអាចគ្រប់គ្រងដោយខ្លួនឯងបាន។ គោលនយោបាយដាក់លាក់រួមមាន៖ ការបណ្តុះបណ្តាលគ្រូបង្រៀនឡើងវិញ កាត់បន្ថយគ្រោះមិនចេះអក្សរ ដោយអប់រំមនុស្សពេញវ័យ កែលម្អភាសាកូរ៉េសម្រាប់វាក្យស័ព្ទបច្ចេកទេស និងការពង្រីកស្ថាប័នអប់រំជាច្រើន(៦៦)។ ក្រោយសម័យសង្គ្រាមកូរ៉េ ប្រទេសនេះ ជួបប្រទះបញ្ហាប្រឈមខ្លាំងទាក់ទងនឹងអត្រាអនក្ខរជនខ្ពស់ដែលមានប្រមាណ៧៨% ហើយដើម្បីដោះស្រាយបញ្ហានេះ កូរ៉េបានដាក់ចេញនូវយុទ្ធសាស្ត្រកែលម្អជាបន្តបន្ទាប់។ ក្នុងកំឡុងពេលប៉ុន្មានឆ្នាំដែល Rhee និង Park Chung Hee ឡើងកាន់អំណាចការគ្រប់គ្រងអប់រំត្រូវបានដកចេញបន្តិចម្តងៗចេញពីដៃរបស់ក្រុមប្រឹក្សាសាលាក្នុងស្រុក និងវិមជ្ឈការទៅឱ្យថ្នាក់កណ្តាល (ក្រសួងអប់រំ)។ នៅចុងទសវត្សឆ្នាំ១៩៨០ ក្រសួងទទួលខុសត្រូវលើការគ្រប់គ្រងសាលារៀន ការបែងចែកធនធាន ការកំណត់កូតាចូលរៀន វិញ្ញាបនបត្រសាលារៀន និងគ្រូបង្រៀន ការអភិវឌ្ឍកម្មវិធីសិក្សា (រួមទាំងការចេញសេចក្តីណែនាំសៀវភៅសិក្សា) និងការសម្រេចចិត្តគោលនយោបាយមូលដ្ឋានផ្សេងទៀត។ ក្រុមប្រឹក្សាអប់រំថ្នាក់ក្រុង និងខេត្តនៅតែមាន។ ថ្វីបើគណៈកម្មាធិការនីមួយៗមានសមាជិក៧រូបដែលត្រូវបានជ្រើសរើសដោយស្ថាប័ននីតិប្បញ្ញត្តិដែលបានជាប់ឆ្នោតជាទូទៅក៏ដោយក៏ការរៀបចំនេះលែងដំណើរការបន្ទាប់ពីឆ្នាំ១៩៧៣។ ក្រោយមកសមាជិកក្រុមប្រឹក្សាភិបាលសាលារៀនត្រូវបានអនុម័តដោយរដ្ឋ

មន្ត្រីអប់រំ។ ក្រុមអ្នកសង្កេតការណ៍ភាគច្រើនបានយល់ស្របថា ការរីកចម្រើនដ៏អស្ចារ្យរបស់កូរ៉េខាងត្បូងក្នុងការធ្វើទំនើបភាវូបនីយកម្ម និងកំណើនសេដ្ឋកិច្ចចាប់តាំងពីសង្គ្រាមកូរ៉េគឺ ដោយសារតែមានឆន្ទៈរបស់បុគ្គលម្នាក់ៗក្នុងការវិនិយោគធនធានដ៏ច្រើននៅក្នុងការអប់រំ ពោលគឺការធ្វើឱ្យប្រសើរឡើងនូវ**"ធនធានមនុស្ស"** ។ មួយវិញទៀត ការគោរពប្រពៃណីសម្រាប់បុរសដែលតម្រូវឱ្យមានចំណេះដឹងជ្រៅជ្រះ ឥឡូវនេះពង្រីកដល់អ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេស និងអ្នកផ្សេងទៀតដែលធ្វើការជាមួយចំណេះដឹងឯកទេស។ ធនធានអ្នកបច្ចេកទេស និងសេដ្ឋវិទូដែលមានការអប់រំខ្ពស់ ជាផ្នែកមួយដ៏សំខាន់សម្រាប់ភាពជោគជ័យនៃសេដ្ឋកិច្ចជាតិចាប់តាំងពីឆ្នាំ១៩៦០មក។ នៅឆ្នាំ ១៩៦១ រដ្ឋាភិបាលកូរ៉េបានណែនាំផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចរយៈពេល៥ឆ្នាំ។ ផែនការប្រាំឆ្នាំដំបូងពីរ (១៩៦២-១៩៧១) បានសង្កត់ធ្ងន់ទៅលើកំណើននៃឧស្សាហកម្មនាំចេញកម្លាំងពលកម្មដូចជាឧស្សាហកម្មផលិត (ឧ. សម្លៀកបំពាក់វាយនភ័ណ្ឌ) និងឧស្សាហកម្មទំនិញអេឡិចត្រូនិក (ឧ. ទូរទស្សន៍ និងវិទ្យុ)។ គោលដៅចម្បងនៃផែនការអប់រំគឺដើម្បីផ្តល់កម្លាំងពលកម្មដែលមានចំណេះដឹងដល់សេដ្ឋកិច្ច។ កម្មវិធីសិក្សាក្នុងអំឡុងពេលនេះបានសង្កត់ធ្ងន់លើការអនុវត្តជាក់ស្តែងនៃការអប់រំប្រឆាំងនឹងកុំម្មុយនីស្ត និងការអភិវឌ្ឍសីលធម៌។ កិច្ចប្រឹងប្រែងគោលនយោបាយបានផ្តោតលើការពង្រីកឱកាសអប់រំជាមូលដ្ឋានដល់កុមារដែលមានសិទ្ធិគ្រប់គ្រាន់។ វិធានការរយៈពេលខ្លីដូចជាការបង្កើនទំហំថ្នាក់រៀន និងរៀនពីរវេន ត្រូវបានគេប្រើដើម្បីដោះស្រាយតម្រូវការដែលកំពុងកើនឡើងសម្រាប់ការអប់រំជាមូលដ្ឋាន។ នៅពេលដែលសេដ្ឋកិច្ចបានរីកចម្រើនបន្ថែមទៀតនៅចុងទសវត្សរ៍ឆ្នាំ ១៩៦០ វាចាំបាច់ក្នុងការបង្កើនការផ្គត់ផ្គង់មនុស្សដែលមានជំនាញជាទូទៅ និងជំនាញវិជ្ជាជីវៈនិងបច្ចេកទេសជាពិសេស។ ទំនាក់ទំនងជិតស្និទ្ធរវាង

ផែនការអប់រំ និងសេដ្ឋកិច្ចមានសារៈសំខាន់ក្នុងអំឡុងផែនការប្រាំឆ្នាំលើកទីបី (១៩៧២-១៩៧៦) ដែលបានសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍឧស្សាហកម្មធុនធ្ងន់ដូចជា៖ រោងចក្រផលិតប្រេង និងឧស្សាហកម្មគីមីជាដើម។ ដូច្នេះការអប់រំវិជ្ជាជីវៈនិងបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិត្រូវបានគេសង្កត់ធ្ងន់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៦០ និងត្រូវបានពង្រឹងទូទាំងទសវត្សឆ្នាំ១៩៧០។ កម្មវិធីសិក្សារបស់សាលារៀនបានក្លាយទៅជាវិន័យកាន់តែច្រើនដោយផ្តោតលើការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ឧទាហរ-ណ៍ក្នុងអំឡុងពេលនេះ មុខវិជ្ជាបច្ចេកវិទ្យាបានចាប់ផ្តើមបង្រៀនជាមុខវិជ្ជាគោលជាច់ដោយឡែក នៅកម្រិតអនុវិទ្យាល័យ។ ការស្រាវជ្រាវរបកគំហើញ និងការរុករក Discovery and inquiry ត្រូវបានលើកតំកើង ជាវិធីបង្រៀនដ៏សំខាន់។

**កំណែទម្រង់ឆ្នាំ១៩៨០**

នៅឆ្នាំ១៩៨០ ក្រសួងអប់រំបានអនុវត្តកំណែទម្រង់ជាច្រើនដើម្បីធ្វើឱ្យប្រព័ន្ធកាន់តែមានយុត្តិធម៌ និងបង្កើនឱកាសសម្រាប់ការអប់រំកាន់តែប្រសើរសម្រាប់ប្រជាជនទូទៅ។ តាមរយៈការផ្លាស់ប្តូរដ៏ពេញនិយមនេះ ក្រសួងបានបង្កើនអត្រាចូលរៀនយ៉ាងទូលំទូលាយ(៦៨)។ មកដល់ដំណាក់កាលនេះ ទោះបីជាមានកំណែទម្រង់ច្រើនយ៉ាងណាក្តីក៏សង្គមកូរ៉េនៅតែជួបប្រទះនូវបញ្ហាចោទទាក់ទងនឹងការរើសអើងវណ្ណៈនៅក្នុងសង្គមតាមរយៈការបែងចែករវាងកម្រិតអប់រំរបស់បុគ្គលម្នាក់ៗ។ នៅចុងទសវត្សឆ្នាំ១៩៨០ ការទទួលបានសញ្ញាប័ត្រពីមហាវិទ្យាល័យ ឬសាកលវិទ្យាល័យមួយត្រូវបានចាត់ទុកថា មានភាពចាំបាច់សម្រាប់ការចូលក្នុងវណ្ណៈកណ្តាលរបស់សង្គម។ ជាទូទៅ ក្រៅពីកម្រិតអប់រំខ្ពស់របស់បុគ្គល មិនមានគន្លងផ្លូវជំនួសផ្សេងទៀតទេ សម្រាប់ការឈានទៅវណ្ណៈកណ្តាល លើកលែងតែអាជីពខាងយោធាប៉ុណ្ណោះ។ បុគ្គលដែលមិនមានការអប់រំនៅកម្រិតឧត្តម

សិក្សា រួមទាំងកម្មករជំនាញដែលមានប្រវត្តិសិក្សានៅសាលាបច្ចេកទេស និងវិជ្ជាជីវៈជាញឹកញាប់ត្រូវបានគេចាត់ទុកថាជាពលរដ្ឋលំដាប់ថ្នាក់ទី២ ហើយត្រូវបានបុគ្គលដែលបានបញ្ចប់ការសិក្សាកម្រិតមហាវិទ្យាល័យ មានឱកាសធ្វើជាអ្នកគ្រប់គ្រងពួកគេ ទោះបីជំនាញរបស់ពួកគេមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក៏ដោយ។ និយាយរួម បុគ្គលដែលមិនបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ឬសាកលវិទ្យាល័យ មិនមានឱកាសធ្វើជាអ្នកដឹកនាំ និងគ្រប់គ្រងទេ ទោះមានជំនាញកម្រិតណាក៏ដោយ។ កត្តាទាំងនេះ ធ្វើឱ្យមានការប្រកួតប្រជែងដ៏ស្វិតស្វាញបំផុតសម្រាប់សិស្សានុសិស្ស ដើម្បីចូលរៀននៅតាមមហា ឬសាកលវិទ្យាល័យល្បីៗ ដែលជាច្រកតែមួយគត់នៅក្នុងការផ្លាស់ប្តូរឋានៈសង្គមរបស់ពួកគេ។ ទាំងនេះ មកពីឥទ្ធិពលនៃលទ្ធិខុងជឺនៅក្នុងសង្គមកូរ៉េ ដែលផ្តោតយកចិត្តទុកដាក់ខ្លាំងលើការប្រឡង ទាំងការប្រឡងចូលថ្នាក់មធ្យមសិក្សា និងមហាវិទ្យាល័យ។ ស្ថានភាពសង្គម និងវប្បធម៌បែបនេះ ធ្វើឱ្យប្រទេសកូរ៉េមានការកើនឡើងយ៉ាងគំហុកនៃការចុះឈ្មោះចូលរៀននៅមហាវិទ្យាល័យនៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ហើយយុវជនវ័យក្មេងជាច្រើនបានលះបង់ និងពលីកម្មដ៏ធំធេងដើម្បីបុព្វហេតុនៃការអប់រំ ដើម្បីខ្លួនឯង និងគ្រួសារ ដោយសិស្ស-និស្សិតភាគច្រើនស្នាក់នៅចំណាយពេលវេលាជាច្រើនម៉ោងក្នុងមួយថ្ងៃ ដើម្បីសិក្សារៀនសូត្រ។

នៅទសវត្សរ៍ទី៨០ វិជ្ជាជីវៈវិទ្យាសាស្ត្រ ជាទូទៅត្រូវបានប្រជាជនកូរ៉េចាត់ទុកថាជាវិជ្ជាជីវៈដែលមានកិត្យានុភាពបំផុត។ ចំណុចលេចធ្លោមួយនៃប្រព័ន្ធអប់រំកូរ៉េ គឺការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនអក្ខរជនដោយនៅឆ្នាំ១៩៤៥ អត្រាអក្ខរកម្មសម្រាប់មនុស្សពេញវ័យត្រូវបានប៉ាន់ប្រមាណថាមានតែ២២% តែនៅឆ្នាំ១៩៧០ អក្ខរភាពមនុស្សពេញវ័យកើនដល់ចំនួន៨៧,៦%[៦៧] ហើយនៅចុងទសវត្សឆ្នាំ១៩៨០ ត្រូវបានគេប៉ាន់

ប្រមាណថា កើនឡើងរហូរដល់ប្រមាណ៩៣%[៦៧]។ ទោះបី ប្រព័ន្ធអប់រំកូរ៉េបានកំណត់ការអប់រំនៅកម្រិតសាលាបឋមសិក្សា (ថ្នាក់ទី១ ដល់ទី៦)ជាការអប់រំកាតព្វកិច្ចក៏ដោយក៏ចំនួនភាគរយកុមារ និងយុវវ័យដែលបានចូលរៀនថ្នាក់អនុវិទ្យាល័យមានចំនួនស្មើនឹងអត្រារបស់ប្រទេសឧស្សាហកម្មជឿនលឿនផ្សេងទៀតដែរដូចប្រទេសជប៉ុនជាដើម។ នៅឆ្នាំ១៩៨៥ មានកុមារប្រហែល៤,៨ លាននាក់ស្ថិតក្នុងក្រុមអាយុដែលមានសិទ្ធិទទួលសេវាអប់រំនៅកម្រិតសាលាបឋមសិក្សា ហើយភាគរយសិស្សដែលចូលរៀនកម្រិតមធ្យមសិក្សានៅឆ្នាំដូចគ្នាគឺ មានច្រើនជាង៩៩%។ ដូចគ្នានេះដែរនៅឆ្នាំ១៩៨៧ សិស្សប្រមាណ៣៤%ដែលបញ្ចប់ការសិក្សានៅមធ្យមសិក្សាបានចូលរៀនបន្តនៅកម្រិតឧត្តមសិក្សាដែលជាអត្រាខ្ពស់បំផុតមួយដែលវាប្រហាក់ប្រហែលទៅនឹងប្រទេសជប៉ុនដែរ (ប្រហែល៣០ភាគរយនិងលើសអង់គ្លេសទៅទៀតដែលមានតែ២០ភាគរយប៉ុណ្ណោះ)។ ចំណែកឯ ការចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំវិញ គឺមានលក្ខណៈទូលំទូលាយខ្លាំងណាស់។ នៅឆ្នាំ១៩៧៥ រដ្ឋាភិបាលកូរ៉េបានចំណាយលើវិស័យអប់រំចំនួន២២០ពាន់លានវ៉ុន[៦៧]ស្មើនឹង២,២%នៃផលិតផលជាតិសរុប ឬ១៣,៩%នៃការចំណាយសរុបរបស់រដ្ឋាភិបាល។ ត្រឹមឆ្នាំ ១៩៨៦ ការចំណាយផ្នែកអប់រំបានឈានដល់៣,៧៦សែនកោដិវ៉ុនស្មើនឹង៤,៥% នៃGNP និង ២៧,៣% នៃការចំណាយថវិការបស់រដ្ឋាភិបាល។

## ដំណើរថយក្រោយ (great recession)

ដោយសារវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៧-២០០៨ ធ្វើឱ្យសេដ្ឋកិច្ចកូរ៉េមានដំណើរការយឺត ហើយទីផ្សារការងារក៏មានការផ្លាស់ប្តូរលឿនផងដែរ។ នៅពេលនេះ និស្សិតវ័យក្មេងជាច្រើននាក់ដែលបញ្ចប់ការសិក្សានៅវិទ្យាល័យនៅកូរ៉េខាងត្បូងបានដឹងកាន់តែច្បាស់ថា៖ ពិន្ទុខ្ពស់សម្រាប់ការប្រឡង

ចូលរៀននៅមហាវិទ្យាល័យ និងពិន្ទុខ្ពស់នៃការបញ្ចប់សិក្សាថ្នាក់ឧត្តមសិក្សា ជាមួយនឹងការសន្យាពីភាពជោគជ័យអាជីពសម្រាប់ពេលអនាគតមានការប្រែប្រួល មិនមានទម្ងន់ដូចគ្នាទៅនឹងអ្វីដែលសង្គមកូរ៉េ ធ្លាប់គិតពីមុននោះទេ[៦៩]។ ក្នុងឆ្នាំ២០១៣ ជនជាតិកូរ៉េខាងត្បូងចំនួន៤៣.០០០នាក់ក្នុងវ័យ២០ឆ្នាំ និង២១.០០០នាក់ក្នុងវ័យ៣០ឆ្នាំបានបាត់បង់ការងារ ហើយមួយចំនួនទៀតត្រូវធ្វើការជាមួយការងារដែលទាមទារកម្រិតអប់រំទាបជាង។ យោងតាមការស្ទង់មតិឆ្នាំ២០១៣ ដែលបានធ្វើឡើងដោយវិទ្យាស្ថានស្រាវជ្រាវកូរ៉េសម្រាប់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្ហាញថា៖ ស្ថិតិយុវជនជិត៤ នាក់ក្នុងចំណោមយុវជន១០នាក់ដែលមានអាយុពី២០ ទៅ៣០ឆ្នាំបាននិយាយថា កម្រិតអប់រំរបស់ពួកគេគឺ ខ្ពស់ជាងការងារដែលខ្លួនកំពុងធ្វើ[៧០]។ និន្នាការនេះ ធ្វើឱ្យមានការប្រែប្រួលខុសពីមុននូវចំណាប់អារម្មណ៍សិស្សចំពោះការសិក្សានៅថ្នាក់ឧត្តមសិក្សា។ នៅឆ្នាំ២០១៣ សិស្សានុសិស្សកូរ៉េខាងត្បូងតិចតួចបានជ្រើសរើសយកទៅសិក្សានៅសកលវិទ្យាល័យបន្ទាប់ពីបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា ដោយសារអត្រាអ្នកគ្មានការងារធ្វើសម្រាប់និស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យនៅតែបន្តកើនឡើង ប្រាក់ចំណូលសម្រាប់និស្សិតទាំងនោះបន្តធ្លាក់ចុះផងដែរ ហើយតម្លៃសញ្ញាប័ត្រពីមហាវិទ្យាល័យកាន់តែធ្វើឱ្យពួកគេងឿងឆ្ងល់។ ការបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ ឬសាកលវិទ្យាល័យល្បីៗ ហាក់លែងធានាបាននូវភាពជោគជ័យក្នុងអាជីពដូចពីមុនទៀតហើយ ហើយនិស្សិតកូរ៉េកាន់តែភ្ញាក់ខ្លួនចំពោះបញ្ហានេះ[៧១]។ ដើម្បីដោះស្រាយចំពោះបញ្ហាប្រឈមនេះ រដ្ឋាភិបាលបានដាក់ចេញនូវវិធានការដើម្បីជំរុញលើកទឹកចិត្តដល់និស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យដែលមិនមានការងារធ្វើត្រូវស្វែងរកលទ្ធភាពការងារផ្សេងទៀតដូចជា៖ ការចាប់ផ្តើមអាជីវកម្ម ឬការស្វែងរកឱកាសការងារនៅក្នុងអាជីវកម្មខ្នាតតូច និងមធ្យ

ម។ អតីតប្រធានាធិបតីលីម្យុងបាក់(Lee Myung-Bak)ក៏បានផ្ដល់អនុសាសន៍ដូចគ្នាផងដែរ ដោយជំរុញឱ្យអ្នកស្វែងរកការងារធ្វើវ័យក្មេងចាប់ផ្ដើមសម្លឹងមើលលទ្ធភាពការងារផ្សេងទៀតជាមួយអាជីវកម្មខ្នាតតូច និងមធ្យមក្រៅពីក្រុមហ៊ុនធំៗ[៧២]។ ទីផ្សារការងារដែលទាមទារសមត្ថភាពលើសលុប និងភាពឆ្អែតគ្រប់គ្រាន់ក្នុងទីផ្សារការងារបានបណ្ដាលឱ្យមានការខ្វះខាតកម្លាំងពលកម្មជំនាញ និងកង្វះកម្មករវិជ្ជាជីវៈដែលមានជំនាញសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម ហើយការងារដែលប្រើប្រាស់កម្លាំងកាយភាគច្រើនត្រូវធ្លាក់ទៅលើពលករក្រៅប្រទេស។ ប្រជាជនកូរ៉េខាងត្បូងក្មេងៗឥឡូវនេះដឹងថាសញ្ញាប័ត្រមហាវិទ្យាល័យមួយ មិនធានាបាននូវការងារដូចកាលពីមុនទេ[៧៣]។ ប្រព័ន្ធអប់រំកូរ៉េខាងត្បូងលេចចេញនូវបញ្ហាប្រឈមថ្មី ដោយសារអត្រាចូលរៀនសាកលវិទ្យាល័យខ្ពស់ និងបានបង្កើតកម្លាំងពលកម្មដែលមានកម្រិតអប់រំខ្ពស់លើសពីសមត្ថភាពការងារដែលត្រូវការនៅក្នុងទីផ្សារការងារបច្ចុប្បន្ន។ បញ្ហាប្រឈមនេះ ធ្វើឱ្យពួកគេមិនអាចរកការងារធ្វើបានសមស្របទៅនឹងកម្រិតអប់រំរបស់ពួកគេ[៧៤]។ ប្រទេសនេះក៏បានផលិតលើសលប់នូវចំនួននិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យដែលនៅត្រីមាសដំបូងឆ្នាំ២០១៣ ចំនួននិស្សិតមានជិត ៣,៣ លាននាក់បានបញ្ចប់ការសិក្សានៅសកលវិទ្យាល័យហើយ តែគ្មានការងារធ្វើ ឬបង្ខំចិត្តធ្វើការងារដែលទាមទារការអប់រំកម្រិតទាបជាង[៧៥]។ នៅឆ្នាំ២០១៤ សិស្សដែលបញ្ចប់ការសិក្សាពីវិទ្យាល័យមានចំនួន៧០,៩% បានបន្តចូលរៀននៅកម្រិតឧត្តមសិក្សាដែលជាអត្រានៃការចូលរៀនមហាវិទ្យាល័យខ្ពស់បំផុតក្នុងចំណោមបណ្ដាប្រទេសជាសមាជិកអង្គការសេដ្ឋកិច្ចនិងកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍ (OECD)[៧៦]។ យោងតាមការអង្កេតមួយ បានបង្ហាញថានៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៦ មនុស្សម្នាក់ក្នុងចំណោមបីនាក់ដែលគ្មានការងារធ្វើនៅក្នុងប្រទេសកូរ៉េខាងត្បូង ជានិស្សិត

បញ្ចប់ការសិក្សាពីសកលវិទ្យាល័យដែលជាលទ្ធផលនៃការធ្លាក់ចុះសេដ្ឋកិច្ចដែលអូសបន្លាយ និងអតិផរណានៃការសិក្សា(៧៧)។ ថ្វីត្បិតតែកូរ៉េ បានផលិតធនធានមនុស្សដែលមានកម្រិតអប់រំខ្ពស់បានច្រើនមែន តែអាជីវកម្មខ្នាតតូច និងមធ្យមនៅតែត្អូញត្អែរពីការលំបាកក្នុងការរកកម្មករដែលមានជំនាញគ្រប់គ្រាន់លើការងារប្រើប្រាស់កម្លាំងដើម្បីបំពេញការងារដែលមានសក្តានុពល(៧៨)។ ដោយសារការផ្លាស់ប្តូរតម្រូវការទីផ្សារការងារ និងការធ្លាក់ចុះនូវសេចក្តីរំពឹងទុកចំពោះលទ្ធភាពទទួលបានការងារក្រោយបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សាពីសាកលវិទ្យាល័យ និស្សិតដែលបញ្ចប់ការសិក្សានៅវិទ្យាល័យភាគច្រើនបាននឹងកំពុងងាកមករកការអប់រំជំនាញវិជ្ជាជីវៈវិញដូចជា សាលាបណ្តុះបណ្តាលជំនាញបច្ចេកទេស និងពាណិជ្ជកម្មជាដើម។ អត្រាសិស្សបន្តការសិក្សានៅសាកលវិទ្យាល័យ បានធ្លាក់ចុះមកត្រឹម ៧២% នៅឆ្នាំ២០១២ ដែលជាការធ្លាក់ចុះយ៉ាងខ្លាំងពីកម្រិតខ្ពស់ ៨៤,៦%ក្នុងឆ្នាំ២០០៨។ យោងទៅតាមការសិក្សាស្រាវជ្រាវនិន្នាការការងារឆ្នាំ២០១២ ដែលធ្វើឡើងដោយស្ថិតិកូរ៉េ បានបង្ហាញថា៖ និស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យមានកម្រិតប្រាក់ចំណូលរកបានទាបជាងអ្នកដែលបញ្ចប់ការសិក្សានៅវិទ្យាល័យ។ សិស្សបញ្ចប់ការសិក្សានៅថ្នាក់វិទ្យាល័យមានឱកាសរកប្រាក់បំណូលច្រើនជាងសិស្សបញ្ចប់ពីមហាវិទ្យាល័យ ព្រោះគេមានឱកាសច្រើនជាង និងប្រឡូកក្នុងការងារបានឆាប់ហើយលឿនជាង។

ទោះបីមានការផ្លាស់ប្តូរនិន្នាការការងារ និងតម្រូវការទីផ្សារការងារក៏ដោយ ក៏គ្រួសារជនជាតិកូរ៉េជាច្រើននៅតែបន្តជឿជាក់យ៉ាងមុតមាំថា ការសិក្សានៅមហាវិទ្យាល័យគឺជា ផ្លូវតែមួយគត់សម្រាប់លទ្ធភាពទទួលបានការងារដែលមានប្រាក់ខែខ្ពស់ បើទោះបីជាមានភស្តុតាងរកឃើញផ្ទុយពី

ការយល់ឃើញនេះក៏ដោយ។ ពួកគាត់នៅតែវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់ដល់ការសិក្សារបស់កូនពួកគាត់ ពិសេសការចំណាយលើការអប់រំឯកជនដែលមានតម្លៃថ្លៃ[៧៩]។ បទដ្ឋានវប្បធម៌របស់ឪពុកម្ដាយកូរ៉េ នៅតែបន្តដាក់សម្ពាធលើកូនរបស់ពួកគេឱ្យចូលរៀននៅសាកលវិទ្យាល័យ ដោយមិនគិតពីសម្បទា និងឧបនិស្ស័យរបស់កូន ហើយថែមទាំងមិនយកចិត្តទុកដាក់ចំពោះបាតុភូតធ្លាក់ចុះនៃប្រាក់ចំណូលរបស់និស្សិតបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ មកនៅក្រោមកម្រិតសិស្សបញ្ចប់ការសិក្សាពីវិទ្យាល័យ ក៏ដូចជាការកើនឡើងនូវអត្រាគ្មានការងារធ្វើសម្រាប់និស្សិតបញ្ចប់ការសិក្សា ដែលខ្ពស់ជាងសិស្សដែលបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា[៨០]។ នៅក្នុងឆ្នាំ២០១២ ឪពុកម្ដាយរបស់ប្រទេសកូរ៉េខាងត្បូងចំនួន៩៣ % បានរំពឹងថាកូនៗរបស់ពួកគេនឹងចូលរៀននៅសាកលវិទ្យាល័យ ប៉ុន្តែដោយសារតែការផ្លាស់ប្ដូរឥរិយាបថរបស់សង្គម និងកំណែទម្រង់ប្រព័ន្ធអប់រំកំពុងដំណើរការ ប្រជាជនកូរ៉េខាងត្បូងវ័យក្មេងកាន់តែចាប់ផ្ដើមជឿជាក់ថា៖ ពួកគេត្រូវធ្វើអ្វីដែលពួកគេចូលចិត្ត និងអ្វីដែលពួកគេរីករាយដើម្បីភាពពេញចិត្ត និងជោគជ័យ[៨១]។

ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ លោកប្រធានាធិបតី **ប៉ាក់ គុនហេ** (Park Geun-hye) បានចេញទៅក្រៅប្រទេសជាអន្តរជាតិដូចជាប្រទេសអាល្លឺម៉ង់ ស្វីស និងអូទ្រីសដើម្បីដោះស្រាយតម្រូវការការងាររបស់ប្រទេសកូរ៉េខាងត្បូងដែលកំពុងប្រឈមនឹងអត្រាគ្មានការងារធ្វើខ្ពស់របស់ប្រទេស ក៏ដូចជាការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ[៨២]។ នៅដើមឆ្នាំ២០១៥ លោកស្រីបានធ្វើដំណើរទៅប្រទេសស្វីសដើម្បីសិក្សាពីប្រព័ន្ធហ្វឹកហាត់ការងាររបស់អឺរ៉ុប។ នៅរដូវក្ដៅ រដ្ឋាភិបាលកូរ៉េខាងត្បូងបានអនុញ្ញាតសិស្សទាំងអស់នៅវិទ្យាល័យវិជ្ជាជីវៈមានឱកាសហ្វឹកហាត់ការងារ តាមរយៈការសិក្សាដោយអនុវត្តផ្ទាល់។ រដ្ឋាភិបាលក៏បានកំណត់គោលនយោបាយ

**"ចាប់ផ្តើមការងារមុន សិក្សានៅតាមសាកលវិទ្យាល័យក្រោយ"** "employment first, university later" ដើម្បីលើកទឹកចិត្តដល់និស្សិតបញ្ចប់ការសិក្សាជំនាញវិជ្ជាជីវៈធ្វើការក្នុងវិស័យឧស្សាហកម្ម និងចាំចូលរួមការអប់រំកម្រិតខ្ពស់នៅពេលក្រោយ[៨៣] នេះជាយន្តការដែលជួយបំផុសគំនិតឱ្យសិស្ស-និស្សិតចាប់អារម្មណ៍ពីសាលាវិជ្ជាជីវៈ និងកម្មវិធីហ្វឹកហ្វឺនការងារ (apprentice program) តាមគំរូរបស់ប្រទេសអាល្លឺម៉ង់ និងស្វីស សាលាបណ្តុះបណ្តាលជំនាញ និងបច្ចេកទេសជាច្រើនត្រូវបានបង្កើតឡើងនៅប្រទេសកូរ៉េខាងត្បូងដើម្បីរៀបចំសិស្សសម្រាប់ចាប់យកអាជីពធ្វើការបានឆាប់ មុននឹងបន្តការសិក្សាកម្រិតខ្ពស់។ សាលារៀនផ្តល់ជូននូវការបង្រៀនដល់សិស្សនូវជំនាញឧស្សាហកម្ម និងការបណ្តុះបណ្តាលមុខរបរដើម្បីសម្របតាមតម្រូវការឧស្សាហកម្មរបស់កូរ៉េខាងត្បូងនីមួយៗដូចជាការផលិតយានយន្ត និងគ្រឿងម៉ាស៊ីនផលិតកម្ម និងការសាងសង់នាវាជាដើម[៨៤]។ ជាមួយគ្នានេះ សាលាហ្វឹកហាត់ពីរត្រូវបានដាក់ឱ្យដំណើរការផងដែរ សម្រាប់ឱ្យសិស្សអាចធ្វើការ និងសិក្សារៀនសូត្រនៅពេលតែមួយបាន។ សិស្សវិទ្យាល័យអាចទៅសាលារៀនរយៈពេលពីរថ្ងៃក្នុងមួយសប្តាហ៍ ឬរយៈពេលកំណត់នៃឆ្នាំសិក្សា ឬសិក្សានៅឯសាលារៀននៅពេលសម្រាកដែលសង្កត់ធ្ងន់កាន់តែខ្លាំងឡើងនូវជំនាញការងារជាជាងរៀននៅមហាវិទ្យាល័យ។ ប្រជាជនកូរ៉េខាងត្បូងវ័យក្មេងជាច្រើននាក់ពេលនេះ កំពុងជ្រើសរើសការងាររបស់ពួកគេតាមចំណូលចិត្តរបស់ពួកគេជាជាងទទួលយកជម្រើសអាជីពដែលឪពុកម្តាយរបស់ពួកគេកំណត់ឱ្យ និងជ្រើសរើសការងារក្រៅពីថ្នាក់រៀនធម្មតា[៨៥] ជាមួយនឹងការប្រែប្រួលថាមភាពនៅក្នុងសេដ្ឋកិច្ចសកលលោកក្នុងសតវត្សទី២១ ក៏ដូចជាការអនុវត្តការអប់រំជំនាញវិជ្ជាជីវៈ និងបច្ចេកទេសនៅក្នុងប្រព័ន្ធអប់រំកូរ៉េខាងត្បូងជំនួសឱ្យប្រព័ន្ធអប់រំបែបផ្តល់ជម្រើសទៅតាមគន្លងប្រពៃណី ជម្រើសសិក្សានៅសកលវិទ្យាល័

យដ៏ល្បីល្បាញលែងជានានូវផាសុកភាពជីវិតទៀតហើយ។ ជីវិត និងឋានៈសង្គមក្នុងពេលបច្ចុប្បន្នមិនត្រូវបានធានាដោយសារតាមអប់រំទៀតនោះទេ។ ចាប់តាំងពីការកើនឡើងនូវសាលាបណ្ដុះបណ្ដាលជំនាញ (Meister school) និងការកែទម្រង់សម័យទំនើបនៅក្នុងប្រព័ន្ធអប់រំកូរ៉េខាងត្បូង ប្រជាជនកូរ៉េខាងត្បូងក្មេងៗជាច្រើនឥឡូវនេះយល់ដឹងថាមនុស្សម្នាក់ៗមិនចាំបាច់ត្រូវមានសញ្ញាបត្រមហាវិទ្យាល័យដើម្បីទទួលបានជោគជ័យក្នុងការងារ និងចូលក្នុងវណ្ណៈកណ្ដាលនោះទេ ប៉ុន្តែជំនួសឱ្យជំនាញដែលត្រឹមត្រូវ ។ ការបង្កើតសាលាបណ្ដុះបណ្ដាលជំនាញ (Meister school) ឥឡូវនេះបង្ហាញពីប្រជាជនកូរ៉េខាងត្បូងថា អាចមានផ្លូវច្រើនដើម្បីទទួលបានជោគជ័យផ្នែកសេដ្ឋកិច្ច-សង្គម និងអាជីព ហើយថាអ្នកដែលបញ្ចប់ការសិក្សានៅសាលាវិជ្ជាជីវៈនៅតែអាចទទួលបានជោគជ័យផ្នែកវិជ្ជាជីវៈ និងផ្នែកហិរញ្ញវត្ថុនៅក្នុងសង្គមកូរ៉េខាងត្បូង។ កំណែទម្រង់វិស័យអប់រំដែលមានគំរូពីប្រទេសស្វីស និងអាល្លឺម៉ង់ផ្ដល់នូវជម្រើសអាជីពក្រៅពីផ្លូវសាកលវិទ្យាល័យតាមបែបប្រពៃណីដែលអនុញ្ញាតឱ្យជនជាតិកូរ៉េបង្ហាញពីភាពសម្បូរបែបនៃមុខរបរ និងកំណត់នូវអ្វីដែលជាសមិទ្ធផលពិតប្រាកដនៅក្នុងសង្គមរបស់កូរ៉េខាងត្បូង[៨៦]។

## 4.5) ការបកស្រាយពីប្រព័ន្ធអប់រំប្រទេសកូរ៉េតាមកម្រិតថ្នាក់នីមួយៗ

### កម្រិតថ្នាក់

| កម្រិត/ថ្នាក់ | អាយុ |
|---|---|
| សាលាមើលថែទាំកុមារ Nursery School | ០-៣ ( ១-៤ ) |
| សាលាមត្តេយ្យសិក្សា Kindergarten | ៤-៦ ( ៥-៧ ) |

| បឋមសិក្សា | |
|---|---|
| ថ្នាក់ទី១ | ៧ (៨-គិតតាមឆ្នាំកូរ៉េ) |
| ថ្នាក់ទី២ | ៨ (៩) |
| ថ្នាក់ទី៣ | ៩ (១០) |
| ថ្នាក់ទី៤ | ១០ (១១) |
| ថ្នាក់ទី៥ | ១១ (១២) |
| ថ្នាក់ទី៦ | ១២ (១៣) |
| **មធ្យមសិក្សាបឋមភូមិ** | |
| ថ្នាក់ទី៧ | ១៣ (១៤) |
| ថ្នាក់ទី៨ | ១៤ (១៥) |
| ថ្នាក់ទី៩ | ១៥ (១៦) |
| **មធ្យមសិក្សាទុតិយភូមិ** | |
| ថ្នាក់ទី១០ | ១៦ (១៧) |
| ថ្នាក់ទី១១ | ១៧ (១៨) |
| ថ្នាក់ទី១២ | ១៨ (១៩) |
| **ក្រោយមធ្យមសិក្សាទុតិយភូមិ** | |

| | |
|---|---|
| ការអប់រំកម្រិតឧត្តមសិក្សា Tertiary education ( College or University ) | កម្រិតអាយុផ្សេងៗ |
| Membership Training in Korea | កម្រិតអាយុផ្សេងៗ |

## ការអប់រំមត្តេយ្យសិក្សា ( Kindergarten )

ចំនួនសាលាមត្តេយ្យឯកជនបានកើនឡើងដោយសារស្ត្រីកាន់តែច្រើនចូលក្នុងកម្លាំងពលកម្ម និងកំណើនចំនួនគ្រួសារ (nuclear) ដែលជីដូនជីតាមិនអាចមើលថែរក្សាកុមារបាន។ ការដាក់កូននៅសាលាមត្តេយ្យសិក្សាផ្តល់ឱកាស និងពេលវេលាច្រើនដល់ស្ត្រីក្នុងការប្រឡូកក្នុងអាជីពការងារ។ កុមារជាច្រើននៅប្រទេសកូរ៉េបានចាប់ផ្តើមចូលរៀននៅមត្តេយ្យសិក្សានៅអាយុ៣ឆ្នាំ ហើយបន្តទៅរៀននៅថ្នាក់មត្តេយ្យរយៈពេល៣ ឬ៤ ឆ្នាំមុនពេលចាប់ផ្តើមរៀននៅសាលាបឋមសិក្សា។ សាលាមត្តេយ្យឯកជនជាច្រើនផ្តល់ជូននូវថ្នាក់រៀនភាសាអង់គ្លេសដើម្បីផ្តល់ឱ្យសិស្សនូវ "**ការចាប់ផ្តើមដំបូង**" នៅក្នុងការអប់រំភាសាអង់គ្លេសចាំបាច់ដែលពួកគេនឹងទទួលបាននៅពេលក្រោយ នៅក្នុងសាលារដ្ឋ។ សាលាមត្តេយ្យតែងតែគោរពដល់ការរំពឹងទុករបស់ឪពុកម្តាយជាមួយនឹងព្រឹត្តិការណ៍គួរអោយចាប់អារម្មណ៍ ពិធីបញ្ចប់ការសិក្សាដោយមានសញ្ញាប័ត្រ និងការស្លៀកពាក់បែបប្រពៃណីកូរ៉េ។ សាលាមត្តេយ្យកូរ៉េត្រូវបានគេរំពឹងថានឹងចាប់ផ្តើមបង្រៀនគណិតវិទ្យាមូលដ្ឋាន អាន និងសរសេរដល់កុមាររាប់បញ្ចូលទាំងការអប់រំអំពីរបៀបរាប់ចំនួន ការគណនាបូក ដក ការអាន និងសរសេរជាភាសាកូរ៉េ និងជាញឹកញាប់ជាភាសាអង់គ្លេស និងភាសាចិន។ កុមារនៅសាលាមត្តេយ្យកូរ៉េត្រូវបានបង្រៀនផងដែរដោយប្រើហ្គេមផ្តោតលើការអប់រំ និងការសម្របសម្រួល" ដូចជា "ការលេងហ្គេមគ្រូពេទ្យ" ដើម្បីបង្រៀនផ្នែក

រាងកាយអាហារ អាហារបំប៉ន និងមុខតំណែងការងារសម្រាប់មនុស្សពេញវ័យ។ ចម្រៀង របាំ និងការចងចាំគឺជាផ្នែកមួយដ៏សំខាន់នៃការអប់រំមត្តេយ្យកូរ៉េ។

## ការអប់រំកម្រិតបឋមសិក្សា (Primary Education)

សាលារៀនបឋមសិក្សា មានថ្នាក់ទី១ ដល់ទី៦ និងរៀនមុខវិជ្ជាផ្សេងៗដូចការរៀបរាប់ខាងក្រោម។ កម្មវិធីសិក្សាខុសគ្នាពីថ្នាក់ទី១-២ ទៅថ្នាក់ទី ៣-៦ ។ នៅកម្រិតនេះ សិស្សសិក្សា៥ម៉ោងក្នុង១ថ្ងៃ។ ទោះបីតិចម៉ោង តែសិស្សនៅតែចូលរៀនថ្នាក់ក្រៅម៉ោង បន្ថែមមានមុខវិជ្ជាគណិតវិទ្យា អង់គ្លេស វិទ្យាសាស្ត្រ ការសរសេរសំណេរ ហើយសិស្សមួយចំនួនធំចូលរៀនថ្នាក់ព្យ៉ាណូ។ ការចំណាយសម្រាប់ការសិក្សានេះគឺខ្ពស់ណាស់ (ប្រមាណ ១៧០០ដុល្លារ/១ខែ)

**ថ្នាក់ទី១-២ (Grades 1-2):**

- យើងជាសិស្សថ្នាក់ទីមួយ (សម្រាប់ថ្នាក់ទី១ តែប៉ុណ្ណោះ)
- កូរ៉េ (ការស្តាប់ ការនិយាយ ការអាន និងការសរសេរ)
- គណិតវិទ្យា
- វិន័យជីវិត (Disciplined Life)
- ជីវិតប្រកបដោយសុភវិនិច្ឆ័យ(Sensible Life)
- ជីវិតដែលរីករាយ (Enjoyable Life)
- អប់រំកាយ

**ថ្នាក់ទី៣-៦ (Grades 3-6):**

- កូរ៉េ (ការស្តាប់ការនិយាយការអានការសរសេរ)
- ភាសាអង់គ្លេស

- ការអប់រំសីលធម៌
- សិក្សាសង្គម
- គណិតវិទ្យា
- វិទ្យាសាស្ត្រ
- សិល្បៈ
- តន្ត្រី
- សិល្បៈអនុវត្ត
- អប់រំកាយ

ជាទូទៅគ្រូឈរថ្នាក់ បង្រៀនស្ទើរមុខវិជ្ជាទាំងអស់ លើកលែងតែឯកទេសមួយចំនួនដូចជា មុខវិជ្ជាអប់រំកាយ និងភាសាបរទេស ដូចភាសាអង់គ្លេសជាដើម។ ការដាក់ទណ្ឌកម្មលើរាងកាយដល់សិស្សត្រូវបានហាមឃាត់ជាផ្លូវការនៅក្នុងគ្រប់ថ្នាក់រៀនតាំងពីឆ្នាំ២០១១។ តែទោះបីយ៉ាងណាក៏ដោយ ក៏គ្រូបង្រៀន និងឪពុកម្តាយជាច្រើនបានលើកឡើងពីកង្វល់ពីបញ្ហាវិន័យសិស្សកាន់តែអាក្រក់ ដោយសារការដាក់ទណ្ឌកម្មរាងកាយ (ឧ.វាយដោយរំពាត់)លែងត្រូវបានអនុវត្ត។ ដូច្នេះ គ្រូបង្រៀនមួយចំនួននៅតែបំពានច្បាប់ដោយបន្តប្រើប្រាស់ការដាក់ទណ្ឌកម្មរាងកាយ[៨៧]។ សម្រាប់កម្ពុជា បញ្ហាវិន័យសិស្សក៏ជាបញ្ហាប្រឈមមួយដែរ ហើយសិស្សមួយចំនួនមានបញ្ហាសីលធម៌ធ្លាក់ចុះ។ ឈានដល់សម័យបច្ចេកវិទ្យាទំនើប បណ្តាញទំនាក់ទំនងសង្គមទូលំទូលាយ និងសាកលភាវូបនីយកម្ម បាន និងកំពុងជះឥទ្ធិពលទៅលើយុវជនសម័យថ្មីធ្វើឱ្យឥរិយាបថសិស្សមានការប្រែប្រួលយ៉ាងខ្លាំង។ ស្ថិតក្នុងរបត់នៃការអនុវត្តវិធីសាស្ត្រអប់រំបែបវិជ្ជមាន ដែលការដាក់ទណ្ឌកម្មដល់សិស្ស ពិសេសទណ្ឌកម្មលើរាងកាយ ត្រូវបានហាមឃាត់ ហើយការប្រឈមបញ្ហាវិន័យសិស្សកាន់តែខ្លាំងដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមលើបញ្ហានេះ។

ទាក់ទងនឹងចំនួនម៉ោងនៃការបង្រៀនជាកាតព្វកិច្ចក្នុងមួយឆ្នាំ សម្រាប់សិស្សបឋមសិក្សាប្រទេសកូរ៉េគឺ៧០៣ ម៉ោង។ សិស្សអនុវិទ្យាល័យ មានចំនួន៨៥៩ម៉ោងក្នុងមួយឆ្នាំ (OECD 2012) ។ ចំនួនម៉ោងខាងលើ មិនបានរាប់បញ្ចូលនូវចំនួនម៉ោងដ៏ច្រើនសន្ធឹកសន្ធាប់ផ្សេងទៀតដែលពួក គេសិក្សានៅក្រៅថ្នាក់រៀន។ ឧទាហរណ៍សិស្សវិទ្យាល័យជាញឹកញាប់ត្រូវ បានចូលរួមនៅក្នុងសកម្មភាពសិក្សា និងថ្នាក់រៀនគួរក្រៅម៉ោងរហូតដល់ ពាក់កណ្ដាលយប់[៨៨]។ ចំណែកឯ ម៉ោងសិក្សានៅកម្ពុជាច្រើនមែន តែការ អនុវត្តជាក់ស្ដែងមានការបាត់បង់ម៉ោងសិក្សាច្រើន ដោយសារបញ្ហា អវត្តមាន ការមិនគោរពពេល ម៉ោងធ្វើការរបស់លោកគ្រូ-អ្នកគ្រូមួយចំនួន ឈប់បុណ្យជាតិ និងឈប់ករណីផ្សេងៗទៀត។ ការបង្រៀនភាសា អង់គ្លេសនៅសាលាបឋមសិក្សាកូរ៉េ គឺចាប់ផ្ដើមពីថ្នាក់ទី៣ ដូច្នេះកុមារអាច ចាប់ផ្ដើមរៀនភាសាអង់គ្លេសនៅក្នុងបរិយាកាសបែបកំសាន្តសប្បាយ ប៉ុណ្ណោះ តាមរយៈការផ្លាស់ប្ដូរសន្ទនាជាជាងការរៀនក្បួនវេយ្យាករណ៍ ដែលអនុវត្តភាគច្រើននៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ។ សាលារៀន បឋមសិក្សាបានសង្កត់ធ្ងន់ទៅលើសិល្បៈ តន្ត្រី និងការអប់រំកាយច្រើនជាង កម្រិតមធ្យមសិក្សា។ របាយការណ៍របស់ក្រសួងអប់រំយុវជនឆ្នាំ១៩៩៦ បានលើកឡើងពីគោលបំណងនៃការអប់រំគឺដើម្បី "**បង្កើនសមត្ថភាពមូលដ្ឋាន ជំនាញ និងអាកប្បកិរិយា ដើម្បីអភិវឌ្ឍសមត្ថភាពផ្នែកភាសា និងសីលធម៌ពលរដ្ឋវិជ្ជាដែលត្រូវការចាំបាច់សម្រាប់ការរស់នៅក្នុងសង្គម ក្នុងគោលបំណងបង្កើនស្មារតីនៃកិច្ចសហប្រតិបត្តិការ លើកកម្ពស់ជំនាញគណិតវិទ្យាមូលដ្ឋាន និងជំនាញសង្កេតបែបវិទ្យាសាស្ត្រ ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីជីវិតដែលមានសុខភាពល្អ និងការអភិវឌ្ឍន៍សុខដុមរមនានៃរាងកាយ និងគំនិត**"។ រហូតមកដល់ឆ្នាំ២០០០ កម្មវិធីសិក្សាប្រចាំឆ្នាំលើកទី៧ នៅ

តែរក្សាគោលបំណងមូលដ្ឋានទាំងនេះ ប៉ុន្តែបានធ្វើបច្ចុប្បន្នភាពសមាធាតុជាច្រើនដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរក្នុងសង្គមកូរ៉េ។

**ការអប់រំកម្រិតកណ្តាល (មធ្យមសិក្សាបឋមភូមិ) (Middle school)**

ប្រព័ន្ធអប់រំកម្រិតកណ្តាលនៅក្នុងប្រទេសកូរ៉េខាងត្បូងមានបីថ្នាក់។ សិស្សភាគច្រើនចូលរៀននៅអាយុ១២ ឬ១៣ ឆ្នាំហើយបញ្ចប់ការសិក្សានៅអាយុ១៥ ឬ១៦ឆ្នាំ។ ថ្នាក់ទាំងបីនេះត្រូវគ្នាទៅនឹងថ្នាក់ទី៧-៩ នៅក្នុងប្រព័ន្ធអាមេរិចខាងជើង និងឆ្នាំ៨-១០នៅក្នុងប្រព័ន្ធភាសាអង់គ្លេស។ ដូចនៅសាលាបឋមសិក្សាដែរ សិស្សចំណាយពេលភាគច្រើននៅក្នុងថ្នាក់រៀន។ ទោះជាយ៉ាងណាសិស្សានុសិស្សមានគ្រូបង្រៀនខុសៗគ្នាតាមមុខវិជ្ជាឯកទេសនីមួយៗ ហើយគ្រូបង្រៀនត្រូវផ្លាស់ទីពីថ្នាក់រៀនមួយទៅថ្នាក់រៀនមួយទៀត លើកលែងតែគ្រូបង្រៀនមុខវិជ្ជាពិសេសមួយចំនួនដែលមានបន្ទប់ផ្ទាល់ខ្លួនរបស់ពួកគេដែលតម្រូវឱ្យសិស្សចល័តចូលរៀន។ កម្មវិធីសិក្សានៅកម្រិតនេះមានមុខវិជ្ជា៖ ភាសាកូរ៉េ ពិជគណិត ធរណីមាត្រ ភាសាអង់គ្លេស សិក្សាសង្គម និងវិទ្យាសាស្ត្រ (មុខវិជ្ជាស្នូល) ហើយសិស្សានុសិស្សក៏ត្រូវរៀនមុខវិជ្ជាជ្រើសរើសមួយចំនួនដែរដូចជា៖ តន្ត្រី សិល្បៈ ប្រវត្តិសាស្ត្រកូរ៉េ សីលធម៌ សេដ្ឋកិច្ចគ្រួសារ បច្ចេកវិទ្យា និងហាន់យ៉ា (Hanja)។ សិស្សនៅកម្រិតកណ្តាលនេះ រៀនតែភាសាអង់គ្លេសតែមួយមុខប៉ុណ្ណោះសម្រាប់មុខវិជ្ជាភាសាបរទេសដែលខុសពីកម្រិតមធ្យមសិក្សាទុតិយភូមិសិស្សត្រូវរៀនភាសាបរទេសទី២ទៀតដូចភាសាជប៉ុនជាដើម។ រយៈពេលសិក្សាពីមួយឆ្នាំទៅមួយឆ្នាំមិនដូចគ្នាទេ។ ចាប់ពីឆ្នាំ២០០៨មក កាលវិភាគសិក្សានៅតាមសាលារៀននីមួយៗនៅប្រទេសកូរ៉េគឺ សិក្សាចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ និងត្រូវរៀនរយៈពេលកន្លះថ្ងៃបន្ថែមទៀតនៅថ្ងៃសៅរ៍នៃសប្តាហ៍មួយចំនួនតាមប្រតិទិនសិក្សាដែលបានកំណត់ (សប្តាហ៍ទី

១ និងទី៣)។ ការសិក្សានៅថ្ងៃសៅរ៍ជាទូទៅជាមេរៀនសកម្មភាពក្រុម (CA)ដែលសិស្សអាចចូលរួមក្នុងសកម្មភាពក្រៅម៉ោងសិក្សា។ ទោះបីយ៉ាងណាក៏ នៅឆ្នាំ២០១២ ក្រសួងអប់រំកូរ៉េ បានកំណត់លែងឱ្យមានថ្នាក់រៀនថ្ងៃសៅរ៍ទៀត តែផ្ទុយទៅវិញ សាលារៀនជាច្រើននៅតែបន្តបង្រៀនដោយខុសច្បាប់នៅថ្ងៃសៅរ៍ដដែល ព្រោះតែឪពុកម្តាយចង់ឱ្យកូនរបស់ពួកគេទៅសាលារៀន និងសិក្សា[(៨៩)]។

**ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ (High school)**

វិទ្យាល័យនៅប្រទេសកូរ៉េខាងត្បូងបង្រៀនសិស្សរយៈពេល៣ឆ្នាំ សិស្សមានអាយុចាប់ពី១៥ឆ្នាំទៅ១៩ឆ្នាំ។ សិស្សកម្រិតវិទ្យាល័យនេះ ប្រើប្រាស់រយៈពេលវែងកាន់តែច្រើនក្នុងការសិក្សាពេលឡើងទៅថ្នាក់បន្ទាប់ឆ្ពោះទៅរកការបញ្ចប់ការសិក្សាដើម្បីប្រកួតប្រជែងចូលសាកលវិទ្យាល័យកម្រិតកំពូលៗដែលមានភាពទាក់ទាញដូចជា៖ សាកលវិទ្យាល័យ Seoul សាកលវិទ្យាល័យកូរ៉េ និងសាកលវិទ្យាល័យ Yonsei។ សិស្សវិទ្យាល័យជាច្រើននាក់ភ្ញាក់ពីដំណេក និងចាកចេញពីផ្ទះនៅពេលព្រឹកព្រលឹមនៅម៉ោង៥ព្រឹក ហើយត្រលប់ទៅផ្ទះវិញក្រោយពីរៀននៅសាលារដ្ឋ រួចបន្តនៅសាលាឯកជនដើម្បីរៀនគួរក្រៅម៉ោងរហូតដល់ម៉ោង១០យប់ ឬយូរជាងនេះរហូតដល់ម៉ោង២យប់ក៏មាន ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ហើយពួកគេក៏សិក្សានៅចុងសប្តាហ៍ផងដែរ។ ខាងក្រោមជាពាក្យដែលគេស្គាល់ជាទូទៅនៅក្នុងសង្គមកូរ៉េថា៖ **"ប្រសិនបើអ្នកគេង៣ម៉ោងក្នុងមួយយប់នោះអ្នកអាចឈានដល់កម្រិតកំពូលនៅសាកលវិទ្យាល័យកំពូលៗ (SKY)។ ប្រសិនបើអ្នកគេង៤ម៉ោងរៀងរាល់យប់អ្នកអាចចូលរៀននៅសកលវិទ្យាល័យមួយទៀត។ ប្រសិនបើអ្នកគេងបានប្រាំម៉ោង ឬច្រើនម៉ោងរៀងរាល់យប់ជាពិសេសនៅឆ្នាំសិក្សាចុងក្រោយរបស់អ្នក ចូរបំភ្លេចឱកាសថានឹងបានចូលរៀននៅសកលវិទ្យាល័យណាមួយ។"** ផ្អែកតាមទស្សនៈគំនិតនេះ យើងឆ្លុះ

បញ្ជាំងបានថា សិស្សកូរ៉េស្ថិតក្នុងកម្រិតនៃការប្រកួតប្រជែងខ្លាំងក្លាណាស់។ សិស្សវិទ្យាល័យជាច្រើននៅឆ្នាំចុងក្រោយរបស់ពួកគេមិនមានពេលវេលាទំនេរសម្រាប់ថ្ងៃឈប់សម្រាកសម្រាប់ថ្ងៃខួបកំណើត ឬថ្ងៃឈប់សម្រាកវិស្សមកាលមុនពេលការប្រឡងអាហារូបករណ៍មហាវិទ្យាល័យថ្នាក់ជាតិ CAT ( National College Scholastic Aptitude Test ) ដែលជាការប្រឡងចូលសកលវិទ្យាល័យដែលគ្រប់គ្រងដោយក្រសួងអប់រំ។ សិស្សវិទ្យាល័យជាច្រើនចូលចិត្តស្នាក់នៅជាមួយមិត្តភក្តិ និងសិក្សាជាជាងសម្រាក។ **គំនិតនៃការឈប់សម្រាកដើម្បីសម្រាកលំហែ គឺជារឿងកម្រណាស់នៅប្រទេសកូរ៉េ។** សិស្សកូរ៉េត្រូវចំណាយពេលប្រមាណ២២០ថ្ងៃក្នុងមួយឆ្នាំសិក្សាច្រើនជាងប្រទេសហ្វាំងឡង់ដែលមានប្រមាណ១៩០ថ្ងៃ និងសហរដ្ឋអាមេរិកមាន១៨០ថ្ងៃ។ កម្រិតវិទ្យាល័យនៅប្រទេសកូរ៉េអាចត្រូវបានបែងចែកជាគន្លងឯកទេស ដែលស្របតាមចំណាប់អារម្មណ៍ និងគន្លងអាជីពរបស់សិស្ស។ ឧទាហរណ៍មានវិទ្យាសាស្ត្រ (វិទ្យាល័យវិទ្យាសាស្ត្រ) វិទ្យាល័យភាសាបរទេស និងជំនាញសិល្បៈដែលសិស្សអាចចូលរៀនតាមរយៈការប្រឡងចូល ដែលជាទូទៅ មានការប្រកួតប្រជែងខ្ពស់។ ប្រភេទវិទ្យាល័យផ្សេងទៀតរួមមាន៖ វិទ្យាល័យរដ្ឋ និងវិទ្យាល័យឯកជន ដោយទាំងពីរនេះមាន ឬមិនមានការប្រឡងចូល។ ចំពោះសិស្សដែលមិនចង់រៀននៅមហាវិទ្យាល័យសាលាវិជ្ជាជីវៈដែលមានជំនាញខាងវិស័យដូចជា៖ បច្ចេកវិទ្យាកសិកម្ម ឬហិរញ្ញវត្ថុអាចរកបាន សិស្សរៀនរបស់នេះអាចចូលធ្វើការភ្លាម បន្ទាប់ពីបញ្ចប់ការសិក្សា។ សិស្សវិទ្យាល័យប្រហែល២០% កំពុងរៀននៅវិទ្យាល័យវិជ្ជាជីវៈ[៩០]។ គោលបំណងនៃការអប់រំនៅកម្រិតវិទ្យាល័យគឺ៖ **ដើម្បីលើកកម្ពស់បុគ្គលិកលក្ខណៈ និងសមត្ថភាពរបស់សិស្សម្នាក់ៗដែលត្រូវការដើម្បីថែរក្សា និងពង្រឹងឆ្អឹងខ្នងជាតិ ដើម្បីអភិវឌ្ឍចំណេះដឹង និងជំនាញរបស់សិស្សក្នុងគោលបំណងរៀបចំពួកគេសម្រាប់ការងារដែលត្រូវការនៅ**

**ក្នុងសង្គម លើកកម្ពស់ស្វ័យភាពរបស់សិស្សនីមួយៗ ការអភិវឌ្ឍផ្នែកអារម្មណ៍ និងសមត្ថភាពគិតគូរប្រកបដោយភាពសមហេតុផលដែលត្រូវយកទៅប្រើប្រាស់ក្នុង និងក្រៅសាលារៀន និងដើម្បីលើកកម្ពស់កម្លាំងកាយ និងលើកកម្ពស់ស្មារតី។**

រដ្ឋាភិបាលកូរ៉េបានព្យាយាមបង្ក្រាបលើទម្លាប់សិក្សាដ៏ធ្ងន់ធ្ងរបែបនេះដើម្បីឱ្យមានប្រព័ន្ធមានតុល្យភាពរវាងគុណភាពជីវិត និងកាសិក្សា។ រដ្ឋាភិបាលបានដាក់ពិន័យដល់សាលារៀនឯកជនណាដែលបើកបង្រៀនរហូតដល់ម៉ោង២ព្រឹក ឬលើសនេះ។ សាលារៀនគួរក្រៅម៉ោងមួយចំនួន (hagwons)ក៏ផ្តល់ជូននូវថ្នាក់រៀនព្រឹកព្រលឹម សម្រាប់សិស្ស-និស្សិតដើម្បីចូលរៀនមុនពេលទៅសាលារៀននៅពេលព្រឹក។ កម្មវិធីសិក្សាសាលារដ្ឋជាទូទៅត្រូវបានកត់សម្គាល់ថាមានភាពតឹងរ៉ឹងដែលមានច្រើនជាង១៦ មុខវិជ្ជា។ និស្សិតភាគច្រើនជ្រើសរើសចូលរួមផងដែរនូវវិទ្យាស្ថានរកប្រាក់ចំណេញឯកជន (សាលារៀនគួរក្រៅម៉ោង) ដើម្បីបង្កើនលទ្ធផលសិក្សា។ មុខវិជ្ជាស្នូលរួមមាន៖ ភាសាកូរ៉េ ភាសាអង់គ្លេស និងគណិតវិទ្យាដែលមានការសង្កត់ធ្ងន់គ្រប់គ្រាន់លើមុខវិជ្ជាសង្គម និងរូបវិទ្យា។ ជាទូទៅសិស្សមិនសួរសំណួរនៅក្នុងថ្នាក់រៀនទេ ប៉ុន្តែចូលចិត្តចងចាំព័ត៌មានលម្អិត។ វាចាំបាច់ណាស់ក្នុងការកត់សម្គាល់ថាប្រភេទ និងកម្រិតមុខវិជ្ជាអាចខុសគ្នាពីសាលារៀនមួយទៅសាលារៀនមួយដោយអាស្រ័យលើកម្រិតនៃការជ្រើសរើស និងជំនាញរបស់សាលា។ ការអប់រំនៅថ្នាក់វិទ្យាល័យគឺមិនមែនជាការអប់រំកាតព្វកិច្ចទេ ដូចការអប់រំនៅកម្រិតកណ្តាល (បឋមភូមិ)ទេ។ ទោះជាយ៉ាងណាក៏ដោយ យោងទៅតាមការសិក្សាឆ្នាំ២០០៥ លើបណ្តាប្រទេសជាសមាជិកនៃអង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) មនុស្សពេញវ័យ៩៧%របស់កូរ៉េខាងត្បូងបានបញ្ចប់ថ្នាក់វិទ្យាល័

យ។ នេះគឺជាភាគរយខ្ពស់បំផុតក្នុងចំណោមប្រទេសសេដ្ឋកិច្ចជឿនលឿនដទៃទៀត(៩១)។

សម្រាប់ប្រទេសកូរ៉េ មានលក្ខណៈពិសេសមួយសម្រាប់ការអប់រំនៅកម្រិតមធ្យមសិក្សា ដោយសារមានការបែងចែកការអប់រំភេទតែមួយ (Single-sex education) (សាលារៀនដែលមានតែសិស្សស្រីសុទ្ធ ឬប្រុសសុទ្ធ) និងភេទចម្រុះ (សាលារៀនដែលសិស្សស្រី និងប្រុសរៀនជាមួយគ្នា)។ នៅឆ្នាំ១៩៩៦ នៅប្រទេសកូរ៉េ មានវិទ្យាល័យតែ៥% ប៉ុណ្ណោះដែលមានសិស្សប្រុស និងស្រីរៀនជាមួយគ្នាក្នុងសាលារៀនតែមួយ (Coeducation)។ សមាមាត្រសាលារៀនដែលអនុញ្ញាតឱ្យសិស្សស្រី និងប្រុសរៀនជាមួយគ្នាបានកើនឡើងជិត ១០% ដោយសារគោលនយោបាយគាំទ្ររបស់រដ្ឋាភិបាលកូរ៉េ។ ទោះជាយ៉ាងណាក៏ដោយថ្នាក់រៀននៅតាមវិទ្យាល័យទាំងនោះ នៅតែត្រូវបានបែងចែកតាមភេទ។ កម្មវិធីសិក្សាត្រូវបានធ្វើបទដ្ឋានស្តង់ដារ ដូច្នេះឥឡូវនេះទាំងសិស្សប្រុស និងសិស្សស្រីត្រូវសិក្សាបច្ចេកវិទ្យា និងវិទ្យាសាស្ត្រក្នុងស្រុក។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការអប់រំសម្រាប់ភេទតែមួយ(ស្រីសុទ្ធ ឬ ប្រុសសុទ្ធ)បានទាក់ទាញចំណាប់អារម្មណ៍គោលនយោបាយជាច្រើនដែលជាឧបករណ៍ដ៏មានសក្តានុពល ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងបិទបញ្ចប់ប្រភេទផ្សេងៗនៃគម្លាតយេនឌ័រ។ អ្នកគាំទ្រការអប់រំសម្រាប់ថ្នាក់រៀនភេទតែមួយ បានអះអាងថា បរិយាកាសការអប់រំភេទតែមួយនៅក្នុងថ្នាក់រៀនមានអត្ថប្រយោជន៍ដល់ការសម្រេចលទ្ធផលសិក្សារបស់សិស្ស ពិសេសសិស្សស្រី ដោយសារហេតុផលផ្សេងៗដូចជា៖ ចៀសវាងបានពីការទាក់ទាញពីសិស្សភេទផ្ទុយគ្នា ការរំខាន ឬការឃើយា និងការទទួលរងឥទ្ធិពលនៃការរើសអើងបញ្ហាយេនឌ័រ។ ផ្ទុយទៅវិញ សម្រាប់អ្នកគាំទ្រដល់ការអប់រំចម្រុះភេទ លើកឡើងថា សិស្សប្រុសនឹងមានលទ្ធផលសិក្សាល្អប្រសើរ នៅពេលដែលពួក

គេធ្វើការរួមគ្នាជាមួយសិស្ស ស្ត្រីដែលមានអាកប្បកិរិយាល្អប្រសើរ។ លើសពីនេះទៅទៀត ទាំងសិស្សប្រុស និងសិស្សស្រី បរិស្ថានសិក្សាចម្រុះភេទបែបនេះ ផ្តល់អំណោយផលបន្ថែមទៀតសម្រាប់ការអភិវឌ្ឍជំនាញសង្គម និងការរៀបចំឱ្យកាន់តែប្រសើរឡើងសម្រាប់ "**ពិភពលោកពិតប្រាកដ**" ។ ទោះបីយ៉ាងណាក៏ដោយ ផ្អែកតាមការស្រាវជ្រាវនៅប្រទេសកូរ៉េ បានបង្ហាញថា សិស្សានុសិស្សក្នុងសាលារៀនដែលមានភេទតែមួយធ្វើបានល្អជាងសាលាដែលមានសិស្សចម្រុះភេទគ្នាពី៥ ទៅ១០%នៃគម្លាតគំរូសម្រាប់សិស្សប្រុស និង៤-៧% ចំពោះសិស្សស្រីដែលមានការប៉ាន់ស្មានស្រដៀងគ្នាលើមុខវិជ្ជា (ភាសាកូរ៉េនិងអង់គ្លេស និងគណិត) ។ ជាមួយគ្នានេះ មានការរកឃើញផងដែរថា សិស្សប្រុសមានភាពខុសប្លែកតិចតួចនៅក្នុងលទ្ធផលសិក្សារបស់ពួកគេរវាងថ្នាក់ភេទតែមួយ និងភេទរួមគ្នា។ អ្នកស្រាវជ្រាវបានសន្និដ្ឋានថា "វត្តមានរបស់ក្មេងស្រីនៅក្នុងសាលារៀនតែមួយ (ទោះបីជាមិនស្ថិតក្នុងក្រុមតែមួយក៏ដោយ) ធ្វើឱ្យសិស្សប្រុសមិនសូវចាប់អារម្មណ៍ពីការសិក្សា " ខណៈពេលដែលសិស្សស្រី " មិនសូវរហ័សរហួន "។ ការអប់រំភេទតែមួយបែបនេះមិនមានឡើយនៅកម្ពុជា។

### 4.6) **ការអប់រំវិជ្ជាជីវៈ** (Vocational)

កូរ៉េខាងត្បូងធ្លាប់មានប្រព័ន្ធអប់រំវិជ្ជាជីវៈយ៉ាងរឹងមាំមួយដែលខ្លួនបានកសាងឡើងវិញនូវសេដ្ឋកិច្ចរបស់ខ្លួនបន្ទាប់ពីសង្គ្រាមកូរ៉េ។ ខណៈពេលដែលសញ្ញាប័ត្រពីសាកលវិទ្យាល័យបានរីកចម្រើនយ៉ាងខ្លាំងចំពោះនិយោជកក្នុងអំឡុងឆ្នាំ១៩៧០ និង១៩៨០ ការផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចដោយផ្អែកលើមូលដ្ឋានចំណេះដឹងច្រើនជាងសេដ្ឋកិច្ចឧស្សាហកម្មបណ្តាលឱ្យការអប់រំវិជ្ជាជីវៈមិនសូវពេញនិយម ហើយយុវជនកូរ៉េខាងត្បូងចាប់អារម្មណ៍ខ្លាំងលើការសិក្សានៅសាកលវិទ្យាល័យ ពិសេសសាកលវិទ្យាល័យល្បីៗ។ នៅចន្លោះឆ្នាំនេះ ការអប់រំវិជ្ជាជីវៈនៅប្រទេសកូរ៉េខាងត្បូងគឺមាន

ការទទួលស្គាល់តិចតួចក្នុងសង្គម ហើយនិស្សិតដែលបញ្ចប់ការសិក្សាសាលាបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានគេសើចចំអក និងមើលស្រាលដោយអ្នកគ្រប់គ្រងរបស់ពួកគេដែលមានការអប់រំខ្ពស់ពីមហាវិទ្យាល័យ ទោះបីជាជំនាញរបស់ពួកគេមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក៏ដោយ(៩២)។ ជាមួយនឹងអត្រាចូលរៀនសាកលវិទ្យាល័យខ្ពស់របស់កូរ៉េខាងត្បូង ការយល់ឃើញពីការអប់រំវិជ្ជាជីវៈនៅតែមានការសង្ស័យនៅក្នុងផ្នត់គំនិតរបស់ប្រជាជនកូរ៉េខាងត្បូងជាច្រើន។ នៅឆ្នាំ២០១៣ មានសិស្សត្រឹមតែ ១៨ភាគរយប៉ុណ្ណោះដែលបានចុះឈ្មោះចូលរៀនកម្មវិធីអប់រំវិជ្ជាជីវៈ ដោយសារតែសាកលវិទ្យាល័យល្បីៗនៅតែមានកិត្យានុភាពសម្រាប់ក្រុមគ្រួសារកូរ៉េដែលមានទ្រព្យសម្បត្តិខ្ពស់ អាចលៃលកបង់ថ្លៃសិក្សា។ ជាមួយនឹងការលំអៀងប្រឆាំងនឹងការអប់រំវិជ្ជាជីវៈ សិស្សដែលសិក្សាផ្នែកជំនាញវិជ្ជាជីវៈ ជាទូទៅ ត្រូវបានគេចាត់ទុកជា **"អ្នកស្ថិតក្រោមភាពជោគជ័យ"**( underachievers) ហើយកង្វះសាវតាអប់រំជាន់ខ្ពស់ផ្លូវការនឹងត្រូវបានគេមើលស្រាល ដោយសារការធ្វើការងារជំនាញវិជ្ជាជីវៈដែលសង្គមកូរ៉េគិតថាជាការងារមានលក្ខណៈបែប3Ds ( កខ្វក់ អន់ថោក និងគ្រោះថ្នាក់) (3Ds= dirty, demeaning, and dangerous)។ ជាការឆ្លើយតបនឹងស្ថានភាពកង្វះកម្មករដែលមានជំនាញបច្ចេកទេស វិជ្ជាជីវៈ រដ្ឋាភិបាលកូរ៉េខាងត្បូងបានលើកកម្ពស់រូបភាពវិជ្ជមាននៃការបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈការសហការជាមួយបណ្តាប្រទេសនានាដូចជា៖ ប្រទេសអាល្លឺម៉ង់ ស្វ៊ីស និងអូទ្រីស ដើម្បីពិនិត្យមើលដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត ដើម្បីបង្កើតជម្រើសជំនួសឱ្យផ្លូវប្រពៃណីសម្រាប់យុវជនវ័យក្មេងកូរ៉េដែលមានចំណាប់អារម្មណ៍ចង់ទៅរៀនតែសាកលវិទ្យាល័យ(៩២)។ យោងតាមរបាយការណ៍ស្រាវជ្រាវឆ្នាំ២០១២របស់វិទ្យាស្ថាន McKinsey Globalបានកត់សម្គាល់ថា តម្លៃនៃការរកប្រាក់ចំណូលរបស់និស្សិតដែលបញ្ចប់ការសិក្សានៅមហា

វិទ្យាល័យមិនស្មើភាពទៅនឹងការចំណាយរបស់ពួកគាត់ ដែលត្រូវការដើម្បីទទួលបានសញ្ញាបត្រ និងបានអំពាវនាវឱ្យសិស្សចាប់អារម្មណ៍ចាប់យកការសិក្សាជំនាញវិជ្ជាជីវៈវិញ។ របាយការណ៍ក៏បង្ហាញផងដែរពីអត្រាអត់ការងារធ្វើខ្ពស់ក្នុងចំណោមយុវវ័យដែលមានការអប់រំនៅតាមសាកលវិទ្យាល័យ ឬធ្វើការសម្រាប់ការងារដែលត្រូវការកម្រិតអប់រំទាប។ រដ្ឋាភិបាលកូរ៉េខាងត្បូងសាលារៀន និងឧស្សាហកម្មដោយមានជំនួយពីរដ្ឋាភិបាលស្វីស និងឧស្សាហកម្មកំពុងកែប្រែ និងធ្វើទំនើបកម្មវិស័យអប់រំវិជ្ជាជីវៈដែលមានភាពរឹងមាំជាមួយនឹងបណ្តាញសាលាបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានឈ្មោះថា Meister Schools ។ គោលបំណងសាលា Meister គឺដើម្បីកាត់បន្ថយការខ្វះជំនាញក្នុងវិស័យវិជ្ជាជីវៈរបស់ប្រទេសដូចជា៖ ម៉ាស៊ីនឡានជំនាញតបណ្តាញទឹក ជាងផ្សារលោហៈធាតុ អ្នកផលិតគ្រឿងអគ្គិសនីដាំស្ល អ្នកផលិតគ្រឿងអគ្គិសនី ជាងឈើ ជាងផលិតឧបករណ៍ផ្នែកកិន យន្តការី និងអ្នកផលិតម៉ាស៊ីនប្រតិបត្តិការដែលកំពុងខ្វះខាតជំនាញបែបនេះជាច្រើន[៩២]។ ទោះបីជាអត្រាអ្នកគ្មានការងារធ្វើខ្ពស់ក្នុងប្រទេសកំឡុងពេលវិបត្តិសេដ្ឋកិច្ចយ៉ាងដំណំក៏ដោយ ក៏និស្សិតបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យវិជ្ជាជីវៈបច្ចេកទេសបានទទួលជោគជ័យក្នុងការស្វែងរកការងារធ្វើខណៈពួកគេមានជំនាញពាក់ព័ន្ធដែលមានតម្រូវការខ្ពស់នៅក្នុងសេដ្ឋកិច្ចរបស់ប្រទេសកូរ៉េខាងត្បូង[៩៣]។

ការយល់ឃើញអវិជ្ជមាន និងការស្អប់ខ្ពើមការអប់រំវិជ្ជាជីវៈនៅតែជាបញ្ហាប្រឈមដ៏ធំបំផុតនៅក្នុងប្រទេសកូរ៉េខាងត្បូង។ រដ្ឋាភិបាលកំពុងលើកទឹកចិត្តនិស្សិតវ័យក្មេងឱ្យមកទស្សនា ការតាំងពិពណ៌ និងមើលកម្មវិធីផ្សេងៗ ដើម្បីផ្លាស់ប្តូរទស្សនៈរបស់ពួកគេ។ អ្នកដែលសង្ស័យលើគុណភាពនៃការអប់រំវិជ្ជាជីវៈត្រូវបានលើកទឹកចិត្តឱ្យចំណាយពេលធ្វើការនៅក្នុងឧស្សាហកម្មកំឡុងពេលវិស្សមកាល ដូច្នេះពួកគេមានភាពទាន់

សម័យចំពោះការអនុវត្តក្នុងឧស្សាហកម្មនាពេលបច្ចុប្បន្ន។ សាលារៀន Meister កំពុងបន្តបង្ហាញថាមានឥទ្ធិពលល្អក្នុងការផ្លាស់ប្តូរផ្នត់គំនិតនៃការអប់រំវិជ្ជាជីវៈ តែមានសិស្សវិទ្យាល័យចំនួន១៥ ២១៣នាក់ (បានត្រឹម៥ភាគរយនៃតម្រូវការ) បានចុះឈ្មោះចូលរៀននៅសាលារៀន Meister ជាមួយនឹងកង្វះកន្លែងដែលមិនអាចបំពេញតាមតម្រូវការបានដល់ទៅ១00ភាគរយ។ សិស្សសាលា Meister ឥលូវនេះកំពុងប្រើសាលារៀនទាំងនេះជាផ្លូវជំនួស ក្រៅពីទៅសាកលវិទ្យាល័យ។ ប្រសិនបើ និស្សិតធ្វើការនៅក្នុងឧស្សាហកម្មរយៈពេលបីឆ្នាំបន្ទាប់ពីបញ្ចប់ការសិក្សាពី Meister ពួកគេត្រូវបានគេលើកលែងសម្រាប់ការប្រឡងចូលសកលវិទ្យាល័យដែលមានការលំបាកខ្លាំង(៩២)។ យ៉ាងណាក៏ដោយ ការយល់ដឹងពីការអប់រំវិជ្ជាជីវៈកំពុងតែផ្លាស់ប្តូរ និងកើនឡើងយឺតៗនូវប្រជាប្រិយភាព ខណៈពេលដែលនិស្សិតចូលរួមធ្វើការក្នុងការងារមនុស្សពេញវ័យ និងរៀនជំនាញពិតប្រាកដកាន់តែមានតម្លៃទីផ្សារខ្ពស់នាពេលបច្ចុប្បន្ន ហើយនិស្សិតបញ្ចប់ការសិក្សាពីសាលាវិជ្ជាជីវៈសម្បូរការងារធ្វើ និងរកប្រាក់ចំណូលបានច្រើន(៩២)។ គំនិតផ្តួចផ្តើមរបស់សាលារៀន Meister បានជួយដល់យុវជនតាមរយៈការផ្តល់ការងារដែលមានស្ថេរភាព និងមានស្ថានភាពល្អប្រសើរជាងនិស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យល្បីៗ។ កូរ៉េខាងត្បូងក៏បានធ្វើសមាហរណកម្មវិស័យពាណិជ្ជកម្មខ្នាតតូច និងមធ្យមរបស់ខ្លួនតាមបណ្តាញទំនាក់ទំនង ប្រទេសអាល្លឺម៉ង់ដើម្បីកាត់បន្ថយការពឹងផ្អែកលើក្រុមហ៊ុនធំៗ ដែលធ្លាប់បានចាប់ផ្តើមណែនាំសាលា Meister ទៅក្នុងប្រព័ន្ធអប់រំរបស់ខ្លួន(៩៤)។

បណ្តាញសាលា Meister ត្រូវបានបង្កើតឡើងដើម្បីកែប្រែប្រព័ន្ធអប់រំវិជ្ជាជីវៈ និងរៀបចំយុវជនឱ្យចូលរួមធ្វើការងារផលិតកម្មដែលមានជំនាញខ្ពស់ និងសម្រាប់បម្រើវិស័យផ្សេងទៀត។ សាលារៀននេះ

បង្កើតឡើងដោយយកលំនាំបែបអាល្លឺម៉ង់ដើម្បីបង្រៀនយុវជនវ័យក្មេងៗឱ្យក្លាយជាអ្នកជំនាញផ្នែកបច្ចេកទេស និងដើម្បីដោះស្រាយបញ្ហាអត្រាគ្មានការងារធ្វើរបស់យុវវ័យដែលចេះតែកើនឡើងខ្ពស់ពីមួយថ្ងៃទៅមួយថ្ងៃខណៈដែលការធ្វើពាណិជ្ជកម្ម អាជីវកម្មធុនតូច និងមធ្យមត្អូញត្អែរអំពីកង្វះកម្លាំងពលកម្មដែលមានជំនាញពាណិជ្ជកម្ម និងបច្ចេកទេសសម្រាប់បម្រើឱ្យផលិតកម្មរបស់ខ្លួន។ សាលារៀននេះបានផ្តល់ជូននូវមុខជំនួញ និងមុខវិជ្ជាបច្ចេកទេសជាច្រើនដែលធានាការងារដល់និស្សិតបញ្ចប់ការសិក្សាទៅមានការងារធ្វើ តាមរយៈការផ្សារភ្ជាប់កម្មវិធីសិក្សា និងតម្រូវការទីផ្សារការងារ។ រដ្ឋាភិបាលប្រទេសកូរ៉េខាងត្បូងបានយកគំនិតផ្តួចផ្តើមដើម្បីកែលម្អការយល់ឃើញនៃការបណ្តុះបណ្តាវិជ្ជាជីវៈ និងការប្រយុទ្ធប្រឆាំងនឹងការមាក់ងាយបែបអវិជ្ជមានភ្ជាប់ទៅនឹងការងារដែលធ្វើដោយដៃ និងបច្ចេកទេស។ រដ្ឋាភិបាលកូរ៉េខាងត្បូងបានបង្កើតទស្សនវិជ្ជា "**ធ្វើការងារជាមុន, រៀនមហាវិទ្យាល័យតាមក្រោយ**" លើកទឹកចិត្តសិស្សបញ្ចប់ការសិក្សាប្រឡូកក្នុងការងារមុននឹងបង្កើតផែនការសម្រាប់ចូលរៀនសាកលវិទ្យាល័យ[៩៥]។ ដោយមានការផ្លាស់ប្តូរនូវតម្រូវការកម្លាំងពលកម្មក្នុងយុគសម័យព័ត៌មានវិទ្យា ការព្យាករណ៍ទូទាំងពិភពលោកបង្ហាញថា នៅត្រឹមឆ្នាំ ២០៣០ តម្រូវការជំនាញវិជ្ជាជីវៈនឹងកើនឡើងដែលបញ្ច្រាសគ្នាទៅនឹងការថយចុះតម្រូវការនៃកម្លាំងពលកម្មគ្មានជំនាញដែលបណ្តាលមកពីការជឿនលឿនខាងបច្ចេកវិជ្ជា[៩៦]។ ក្នុងឆ្នាំ២០១០ សាលារៀន Meister បានជ្រើសរើសសិស្សានុសិស្សសរុបចំនួន៣៦០០ នាក់សម្រាប់ការអប់រំបច្ចេកទេស និងការហ្វឹកហាត់ដើម្បីឱ្យពួកគេអាចអភិវឌ្ឍជំនាញក្នុងវិស័យដូចជា៖ ការសាងសង់នាវា វិស្វកម្មមេកានិច ការផលិតឧបករណ៍អេឡិចត្រូនិក និងឧបករណ៍វេជ្ជសាស្ត្រ។ និស្សិតបញ្ចប់ការសិក្សានៅវិទ្យាល័យ Meisterបានទទួលជោគជ័យក្នុងទីផ្សារការងារ និងទទួលបានប្រាក់បៀ

ត្សរ៍ខ្ពស់ពីក្រុមហ៊ុន។ ការជំរុញការងារសម្រាប់មនុស្សវ័យក្មេង តាមរយៈការអប់រំវិជ្ជាជីវៈដែលមានគុណភាពខ្ពស់បានក្លាយជាអាទិភាពកំពូលសម្រាប់រដ្ឋបាលលោកស្រី Park ចាប់តាំងពីភាពអត់ការងារធ្វើរបស់យុវជនមានកម្រិតខ្ពស់ជាងបីដង ខ្ពស់ជាងមធ្យមភាគជាតិ(៩៧)។ និស្សិតបញ្ចប់ការសិក្សានៅវិទ្យាល័យវិជ្ជាជីវៈបានទទួលជោគជ័យក្នុងការស្វែងរកទីផ្សារការងារដែលមានការប្រកួតប្រជែងខ្ពស់ និងការធ្លាក់ចុះនូវទីផ្សារការងាររបស់កូរ៉េខាងត្បូង។ និស្សិតបញ្ចប់ការសិក្សាជាច្រើនទាំងបរិមាណ និងគុណភាពបានរកឃើញឱកាសការងារកាន់តែច្រើននៅក្នុងផ្នែកឧស្សាហកម្ម។ ទោះបីជាមានក្ដីសង្ឃឹមការងារ និងប្រាក់ខែល្អដែលផ្ដល់ជូនសម្រាប់អ្នកដែលទទួលការអប់រំវិជ្ជាជីវៈមានលក្ខណៈប្រហាក់ប្រហែលនឹងនិស្សិតបញ្ចប់ការសិក្សានៅសកលវិទ្យាល័យក៏ដោយ ក៏ឥរិយាបថអវិជ្ជមានរបស់សង្គម និងការរើសអើងចំពោះអ្នកបច្ចេកទេស និងសិស្សវិទ្យាល័យវិជ្ជាជីវៈនៅតែមានអត្ថិភាពនៅឡើយ ។ ជាមួយគ្នានេះ ក៏មានការព្រួយបារម្ភផងដែរអំពីការរើសអើងប្រឆាំងនឹងមនុស្សដែលមានប្រវត្តិសិក្សាទាបដែលជានិន្នាការយូរអង្វែងរបស់និយោជកកូរ៉េខាងត្បូង។ ការរើសអើងសង្គមបែបអវិជ្ជមានទាក់ទងនឹងអាជីពវិជ្ជាជីវៈ និងមិនមានសញ្ញាប័ត្រពីសាកលវិទ្យាល័យក៏នៅតែបន្តចាក់ឫសជ្រៅនៅក្នុងសង្គមកូរ៉េខាងត្បូង(៩៨)។

## 4.7) **ការអប់រំកម្រិតឧត្ដមសិក្សា** (Tertiary education)

ទម្រង់នៃការអប់រំខ្ពស់មួយចំនួនបានកើតមានជាបន្តបន្ទាប់នៅក្នុងប្រទេសកូរ៉េខាងត្បូងតាំងពីសតវត្សទី៤។ ការអភិវឌ្ឍនៃការអប់រំជាន់ខ្ពស់ត្រូវបានទទួលឥទ្ធិពលតាំងពីសម័យបុរាណ។ ក្នុងកំឡុងពេលស្ដេចសូរ៉ារីម (So-Su-Rim) ក្នុងរាជវង្សហ្គូកូរីយ៉ោថេហាក (Goguryeo, Tae-Hak) សាកលវិទ្យាល័យជាតិបានបង្រៀនការសិក្សាអំពីខុងជឺនិយម អក្សរសិល្ប៍

និងក្បាច់គុន។ សព្វថ្ងៃនេះមានមហាវិទ្យាល័យ និងសាកលវិទ្យាល័យដែលមានវគ្គសិក្សាសិក្សារយៈពេលពី៤ទៅ៦ឆ្នាំ។ លើសពីនេះទៀតមានមហាវិទ្យាល័យវិជ្ជាជីវៈ មហាវិទ្យាល័យឧស្សាហកម្ម សាកលវិទ្យាល័យបើកទូលាយ និងសាកលវិទ្យាល័យបច្ចេកវិទ្យា។ មានថ្នាក់រៀនពេញមួយថ្ងៃ និងថ្នាក់សិក្សាពេលល្ងាច ថ្នាក់រៀននៅពេលវិស្សមកាល និងថ្នាក់រៀនពីចម្ងាយ។ ចំនួនវិទ្យាស្ថានឧត្តមសិក្សាមានភាពប្រែប្រួលពីចំនួន៤១៩ នៅឆ្នាំ ២០០៥ មកនៅត្រឹម៤០៥ នៅឆ្នាំ២០០៨ និង៤១១ នៅឆ្នាំ២០១០។ ស្ថានប័នឯកជន មានចំនួនច្រើនគ្រឹះស្ថានសិក្សាសាធារណៈ[៩៩] ។

ដើម្បីបានចូលរៀននៅកម្រិតឧត្តមសិក្សានេះ សិស្សនឹងត្រូវធ្វើតេស្តសមត្ថភាព Scholastic Ability Test។ ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េមានប្រាំផ្នែក: សមត្ថភាពភាសាកូរ៉េ សមត្ថភាពគណិតវិទ្យា សមត្ថភាពភាសាបរទេស (ភាសាអង់គ្លេស) មុខវិជ្ជា«ជម្រើស»ជាច្រើនក្នុងវិស័យវិទ្យាសាស្ត្រសង្គម និងរូបវិទ្យា និងភាសាបរទេសទី២ ឬតួអក្សរចិន។ ដើម្បីបានចូលរៀននៅសាលាល្បីៗ សិស្សកូរ៉េប្រឹងប្រែងសិក្សារៀនសូត្រយ៉ាងខ្លាំង ដើម្បីទទួលបានភាពជោគជ័យលើការប្រឡងសមត្ថភាពចូលរៀនមហាវិទ្យាល័យដែលខ្លួនពេញចិត្តដោយភ្ជាប់មកជាមួយនៅសៀវភៅតាមដានការសិក្សាដែលមានលទ្ធផលសិក្សាខ្ពស់ (student's grade books) និងការប្រឡងបន្ថែមនានាទៀតទៅតាមលក្ខខណ្ឌសាកលវិទ្យាល័យ។ សៀវភៅតាមដានការសិក្សារបស់សិស្ស មានកំណត់ត្រាទូទៅនូវសកម្មភាពនៅវិទ្យាល័យរួមទាំងការងារស្ម័គ្រចិត្ត។ ការធ្វើតេស្តសមត្ថភាពនៅមហាវិទ្យាល័យរួមមានៈភាសាកូរ៉េ គណិតវិទ្យា ភាសាអង់គ្លេស វិទ្យាសាស្ត្រសង្គម និងធម្មជាតិ ការស្រាវជ្រាវ ការងារ និងភាសាបរទេសទី២។ ផ្នែកស្រាវជ្រាវការងារ អនុវត្តតែចំពោះសិស្សនៃសាលាវិជ្ជាជីវៈប៉ុណ្ណោះ។ តម្រូវការភាសាបរទេសទីពីរគឺអនុវត្តចំពោះតែសិស្សដែលបន្តកម្មវិធី

សិក្សាសិល្បៈសេរីដែលផ្ទុយពីវិទ្យាសាស្ត្រធម្មជាតិ។ ដោយសារតែការចូលរៀននៅមហាវិទ្យាល័យពឹងផ្អែកទៅលើចំណាត់ថ្នាក់ខ្ពស់ពីការប្រឡងសិស្សវិទ្យាល័យប្រឈមមុខនឹង "**ឋាននរកនៃប្រឡងប្រជែង**" ដែលជាវិធីសាស្ត្រដ៏គួរឱ្យរន្ធត់ដែលមិនអាចបំភ្លេចបានក្នុងជីវិតអ្នកសិក្សាម្នាក់ៗ[១០០]។ ការចំណាយពេលវេលាដ៏ច្រើនលើការសិក្សា និងសម្ពាធដ៏ធ្ងន់ធ្ងរនៃការប្រឡងជាមូលហេតុសំខាន់នៃការធ្វើអត្តឃាតរបស់យុវជនវ័យក្មេងជាច្រើន[១០១]។ ជារឿយៗអ្នកដែលធ្វើអត្តឃាតខ្លួនឯងគឺជាអ្នកជោគជ័យកម្រិតខ្ពស់បំផុតដែលទទួលរងពីភាពអស់សង្ឃឹម បន្ទាប់ពីបានជួបប្រទះនូវការធ្លាក់ចុះនូវលទ្ធផលធ្វើតេស្តរបស់ខ្លួន[១០២] យុវជនកូរ៉េខាងត្បូងប្រមាណ ៥៣,៤%ដែលគិតចង់ធ្វើអត្តឃាតលើកឡើងពីការប្រកួតប្រជែងហួសប្រមាណជាមូលហេតុចម្បង។ ការធ្វើតេស្តទម្រង់ពហុជម្រើស (multiple choice format) ថ្នាក់វិទ្យាល័យ និងការប្រឡងចូលសាកលវិទ្យាល័យបានធ្វើឱ្យនិស្សិតមានឱកាសតិចតួចក្នុងការអភិវឌ្ឍទេពកោសល្យច្នៃប្រឌិតរបស់ពួកគេ។

រដ្ឋាភិបាល និងសាកលវិទ្យាល័យកូរ៉េខាងត្បូងមានបំណងចង់កែលម្អចំណាត់ថ្នាក់អន្តរជាតិនៃសាកលវិទ្យាល័យក្នុងស្រុក។ ការប៉ុនប៉ងរបស់រដ្ឋាភិបាលកូរ៉េខាងត្បូងកំពុងត្រូវបានធ្វើឡើងដើម្បីកែលម្អស្ថានភាព។ ដំណោះស្រាយមួយផ្សេងទៀតអាចមានលក្ខណៈសាមញ្ញដែលធ្វើឱ្យវាមានភាពទាក់ទាញជាងមុន តាមរយៈការបង្កើតគម្រោងជាតិសំខាន់ៗ[១០៣]។ ក្រសួងអប់រំកូរ៉េខាងត្បូងសង្ឃឹមថានឹងដោះស្រាយបញ្ហានេះតាមរយៈគម្រោង "**គម្រោងជាតិផ្តោះទៅការកសាងសកលវិទ្យាល័យកម្រិតអន្តរជាតិ**" ។ គម្រោងនេះត្រូវបានបង្កើតឡើងដើម្បីទាក់ទាញសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវបរទេសដែលមានគុណវុឌ្ឍិខ្ពស់ដល់សាកលវិទ្យាល័យកូរ៉េខាងត្បូងដើម្បីកែលម្អចំណាត់ថ្នាក់អន្តរជាតិរបស់ពួកគេ[១០៤]។

ជាមួយគ្នានេះ មាតាបិតាសិស្សកូរ៉េក៏មានក្ដីស្រមៃធំធេងផងដែរ ចំពោះការអប់រំរបស់កូនគាត់ ដោយចង់បញ្ជូនពួកគេទៅសិក្សានៅមហាវិទ្យាល័យក្រៅប្រទេសដូចជា៖ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស កាណាដា និងជប៉ុនជាដើម។ ពួកគាត់ចំណាយលុយជាច្រើនលើសាលារៀនឯកជន និងសាលារៀនរដ្ឋ ព្រមទាំងជួលគ្រូមកបង្រៀនកូនគាត់ក្រៅម៉ោងថែមទៀត។ នេះជាហេតុផលដែលសិស្សកូរ៉េខាងក្បួងត្រូវពង្រឹងសមត្ថភាពតាមមុខវិជ្ជា និងភាសាអង់គ្លេស ក្នុងគោលបំណងដើម្បីបានចូលរៀនសាកលវិទ្យាល័យបរទេសទាំងនោះ។ និស្សិតដែលបញ្ចប់ការសិក្សានៅបរទេសមានតម្រូវការច្រើនសម្រាប់នយោជក ជាជាងនិស្សិតដែលបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យក្នុងស្រុក។ តែទោះបីយ៉ាងណាក៏ដោយ ក៏មានក្រុមហ៊ុនក្នុងស្រុកមួយចំនួនផងដែរដែលជួលនិស្សិតដែលបញ្ចប់ការសិក្សាក្នុងស្រុកច្រើនជាងព្រោះតម្លៃពលកម្មការងារថោកជាង។ បច្ចុប្បន្ននេះ ក្រុមហ៊ុនកាន់តែច្រើនត្រូវការនយោជិកដែលមានសមត្ថភាពភាសាអង់គ្លេស និងចិន ខណៈពេលចិនក្លាយជាដៃគូពាណិជ្ជកម្មដ៏សំខាន់។

## 4.8) គ្រូបង្រៀនប្រទេសកូរ៉េ

កម្រិតវប្បធម៌គ្រូបង្រៀនកូរ៉េទាំងអស់នៅគ្រប់ភូមិសិក្សា យ៉ាងហោចណាស់បញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា។ គ្រូបង្រៀនធ្វើការពេញម៉ោង គឺចាប់ផ្ដើមពីម៉ោង៧:៣០ ព្រឹករហូតដល់៥:០០ ល្ងាច ហើយត្រូវធ្វើការនៅថ្ងៃសៅរ៍មួយព្រឹកទៀត។ ក្រៅពីការងារបង្រៀន គ្រូបង្រៀនកូរ៉េនៅតែមានទំនួលខុសត្រូវបន្ថែមទៀត សម្រាប់ការផ្ដល់ប្រឹក្សាដល់សិស្ស និងការគ្រប់គ្រងអាកប្បកិរិយារបស់ពួកគេ (ជំនាញប្រឹក្សា)។ ជាមួយគ្នានេះ វប្បធម៌កូរ៉េផ្ដល់ឱ្យគ្រូបង្រៀននូវសិទ្ធិអំណាចដូចគ្នានឹងឪពុកម្ដាយ និងចាត់

ទុកថាពួកគេ ជាអ្នកទទួលខុសត្រូវធំធេងចំពោះការអភិវឌ្ឍផ្នែកសីលធម៌ និងការសិក្សារបស់កុមារ។

# V. ភាពលេចធ្លោនៃប្រព័ន្ធអប់រំ ក្រុងសៀងហៃ



ចាប់តាំងពីនយោបាយបើកចំហរបស់លោក **តេង ស៊ីវភីង** និងការអនុញ្ញាតឱ្យគ្រូចេញទៅក្រៅប្រទេសដើម្បីរៀនសូត្រ វាជាឫសគល់ដំបូងបំផុតដែលធ្វើឱ្យក្រុងសៀងហៃសម្រេចជោគជ័យដ៏ត្រចះត្រចង់នៃការអប់រំលំដាប់ពិភពលោក។ ភាពភ្លឺស្វាងផ្នែកសេដ្ឋកិច្ច និងសង្គមរបស់មហាយក្សចិនសុទ្ធតែ កើតឡើងសមិទ្ធិផលនយោបាយរបស់លោក តេង ស៊ាវភីងទាំងអស់ដែលបើកទ្វារសម្រាប់ពិភពលោកខាងក្រៅដែលខុសពីនយោបាយ **ម៉ៅសេទុង**។ ជាក់ស្តែង ប្រព័ន្ធអប់រំក្រុងសៀងហៃមានភាពលេចធ្លោខ្លាំង និងសម្រេចជោគជ័យលើសពីការស្មាន។ នៅឆ្នាំ២០០៩ លទ្ធផលPISA បង្ហាញថា ក្រុងសៀងហៃជាប់ចំណាត់ខ្ពស់នៅក្នុងតារាងចំណាត់ការអប់រំពិភពលោក ហើយលទ្ធផល PISA ដែលចេញនៅខែធ្នូ ឆ្នាំ២០១៣ ក៏បានបង្ហាញថា សៀងហៃនៅតែជាប់ចំណាត់ខ្ពស់នៅក្នុងតារាងដដែល ហើយពិន្ទុកើនឡើង៤%បើប្រៀបធៀបនឹងលទ្ធផលពីមុន។ **តើសៀងហៃធ្វើម៉េចទើបទទួលលទ្ធផលបែបនេះ?** ភាគច្រើនប្រហែលជា គេចាប់អារម្មណ៍ខ្លាំងទៅលើសមិទ្ធិផលរបស់ប្រទេសសឹង្ហបុរីដែលខិតខំប្រឹងប្រែងជាខ្លាំងក្នុងការអភិវឌ្ឍវិស័យអប់រំតាំងពីទទួលបានឯករាជ្យឆ្នាំ១៩៦៥ ហើយទទួលចំណាត់ថ្នាក់PISAខ្ពស់ក្នុងឆ្នាំ២០០០។ សម្រាប់សៀងហៃ ក្នុងរយៈពេល

៣១ឆ្នាំតាំងពីពេលដែល **តេង ស៊ាវភីង**ដឹកនាំប្រទេសចិនក្នុងឆ្នាំ១៩៧៨ ទើបសៀងហៃទទួលចំណាត់ខ្ពស់ក្នុងតារាងចំណាត់ថ្នាក់ PISA អន្តរជាតិ។ សឹង្ហបូរីប្រទេសកោះតូចមួយមានអត្រាចំនួនប្រជាជនចាប់ពី២,៥លាននាក់ និងកើនចំនួន៥លាននាក់នាពេលបច្ចុប្បន្ន ចំណែកឯសៀងហៃក្នុងឆ្នាំ ២០១៣ មានចំនួន២៣លាននាក់។ ប្រព័ន្ធអប់រំនៅក្រុងសៀងហៃត្រូវបានគេចាត់ទុកថា ជាប្រព័ន្ធអប់រំល្អជាងប្រព័ន្ធអប់រំតាមខេត្តផ្សេងៗទៀត និងប្រព័ន្ធថ្នាក់ជាតិរបស់ប្រទេសចិនថែមទៀតផង ហើយការបកស្រាយក្នុងអត្ថបទនេះ មិនបានក្តោបប្រព័ន្ធអប់រំចិនទាំងមូលនោះទេ។ ខាងក្រោម គឺការរៀបរាប់ពីគន្លឹះសំខាន់ៗដែលធ្វើឱ្យប្រព័ន្ធសៀងហៃ ជោគជ័យខ្លាំងតាមរយៈនៃសម្ភាសជាមួយអ្នកជំនាញមួយចំនួននៅប្រទេសចិន។ អត្ថបទបកប្រែពីឯកសាររបស់លោក **Marc, S. Tucker** និងសាកល្បងពន្យល់លម្អិតបន្ថែមដើម្បីឱ្យងាយយល់។

**5.1)-លោក Minxuan Zhang** (លោកជាប្រធានសាកលវិទ្យាល័យ Shanghai Normal នាយកមជ្ឈមណ្ឌលសម្រាប់ការសិក្សាអប់រំអន្តរជាតិ និងក្រុមប្រឹក្សាយោបល់ក្រសួងអប់រំចិន ព្រមទាំងជាអ្នកជំនាញជាន់ខ្ពស់ផ្នែកការអប់រំប្រៀបធៀប) លោកបានផ្តល់មតិយោបល់ទាក់ទងនឹងកត្តាដែលធ្វើឱ្យប្រព័ន្ធអប់រំក្រុងសៀងហៃរីកចម្រើនខ្លាំងដូចខាងក្រោម៖

**លោកបានលើកឡើងពីសមាសភាពប្រពៃណីទំនៀមទម្លាប់៣ និងគំនិតច្នៃប្រឌិតទំនើបចំនួន៦[១] ដែលធ្វើឱ្យប្រព័ន្ធអប់រំសៀងហៃទទួលបានជោគជ័យខ្ពស់ដូចការបង្ហាញជាបន្តបន្ទាប់ខាងក្រោម៖**

- **សមាសភាពប្រពៃណីទាំង៣**

- **ទី១៖** ប្រជាជនចិនមានការរំពឹងចិត្តខ្ពស់ និងឱ្យតម្លៃខ្លាំងលើការអប់រំ ទោះមកពួកគេមកពីប្រភេទគ្រួសារណាក៏ដោយ។ គ្រប់គ្រួសារទាំងអស់មានការរឹតបន្តឹងកូនយ៉ាងខ្លាំងក្នុងការសិក្សារៀនសូត្រ ប្រកបដោយការរំពឹងទុកខ្ពស់ថាកូនៗពួកគេនឹងទទួលបានជោគជ័យ

ក្នុងជីវិត និងអាជីពការងារ។ ឥទ្ធិពលខុងជឺនិយម និងអ្នកប្រាជ្ញពីបុរាណផ្សេងៗទៀតបានចាក់ឫសក្នុងផ្នត់គំនិត និងធ្វើឱ្យពួកគេជឿជាក់ខ្លាំងលើការអប់រំនៅគ្រប់ស្រទាប់គ្រួសារចិន។ ឪពុកម្តាយ/អាណាព្យាបាលតែងតែស្វែងរកឱកាសដើម្បីឱ្យកូនៗរបស់ពួកគាត់ទទួលបានការអប់រំមួយល្អ ហើយសូម្បីតែត្រូវធ្វើចំណាស្រុកផ្លាស់ទីលំនៅចេញពីស្រុកកំណើតដែលខ្លួនរស់នៅក៏ដោយ។ ពួកគាត់មានជំនឿយ៉ាងមុតមាំថា ការអប់រំអាចធ្វើឱ្យកូនគាត់ផ្លាស់ប្តូរវាសនា និងជួយជ្រំជ្រែងលើកកិត្តយសគ្រួសារនាពេលអនាគតបាន។

- **ទី២៖** ជនជាតិចិននៅតែមានជំនឿមុតមាំថា ភាពឈ្លាសវៃ ឧស្សាហ៍ព្យាយាម តស៊ូជំនះឧបសគ្គ និងខិតខំប្រឹងប្រែងធ្វើការនឹងនាំមកនូវអនាគតល្អប្រសើរពិតប្រាកដមែន។ នេះជាហេតុផលដែលសិស្សចិនមានការប្រឹងប្រែងសិក្សារៀនសូត្រខ្លាំងណាស់ និងជាទស្សនវិជ្ជាអប់រំមួយរបស់ជនជានចិន។ ក្នុងផ្នត់គំនិតពួកគេយល់ថា គ្មានអ្វីមិនអាចទេសម្រាប់ពួកគេ ឱ្យតែយើងប្រឹងប្រែងតស៊ូជំនះឧបសគ្គទាំងនោះ។ ទស្សនវិជ្ជាដែលធ្វើឱ្យសិស្ស និងឪពុកម្តាយមានជំនឿជឿជាក់ខ្លាំងក្លាលើការសិក្សារៀនសូត្រស្វែងវិជ្ជាបែបនេះសម្រាប់ស្រុកខ្មែរយើង គឺមិនមានឥទ្ធិពលខ្លាំងក្លា និងដើរតួនាទីសំខាន់ក្នុងការជំរុញចលនាសង្គមដូចប្រទេសចិនឡើយ។
- **ទី៣៖** ប្រព័ន្ធប្រឡងជាសាធារណៈ ប្រទេសចិនមានការប្រឡងបែបនេះជិតពីរពាន់ឆ្នាំមកហើយ។ ពីបុរាណកាលដើម្បីក្លាយជាមន្ត្រី គឺគេត្រូវឆ្លងកាត់ប្រឡងទាំងអស់ ពោលគឺមានតែអ្នកចំណេះដឹងខ្ពង់ខ្ពស់ដែលប្រឡងជាប់ប៉ុណ្ណោះអាចធ្វើជាមន្ត្រីបានដែលទិដ្ឋភាពនេះឆ្លុះបញ្ចាំងថា សង្គមចិនឱ្យតម្លៃខ្លាំងណាស់ទៅលើមនុស្សមានសមត្ថភាពពូកែ។ ប្រជាជនចិនមិនថាក្រ ឬមានទេមានជំនឿថា បើសិស្សខិតខំរៀន ពួកគេនឹងប្រឡងជាប់ ហើយនៅពេលគេប្រឡងជាប់ គេនឹងទទួលបានអនាគតល្អជាក់ជាមិនខាន។ ជាការពិតតាំងពីបុរាណ រឿង

មក អ្នកចេះដឹងត្រូវបានគេឱ្យតម្លៃ ហើយការប្រឡងជាប់ជាកត្តាកំណត់គុណតម្លៃមួយនេះ។ ចំណុចនេះ ជនជាតិចិនជឿថា មុនពេលប្រឡង មនុស្សទាំងអស់គឺស្មើគ្នា និងដូចគ្នា តែបើអ្នកប្រឡងជាប់នោះអ្នកនឹងជោគជ័យ ហើយវាសនាអ្នកនឹងផ្លាស់ប្តូរ។ បើអ្នកប្រឡងមិនជាប់ ប្រជាជននឹងសួរអ្នកថា តើអ្នកប្រឹងប្រែងអស់លទ្ធភាពហើយឬនៅ? តើអ្នកសិក្សាប្រកបដោយភាពឈ្លាសវៃដែរឬទេ? តើវិធីសាស្ត្រសិក្សារបស់អ្នកមានប្រសិទ្ធភាពដែរឬទេ? (សំណួរនេះ សង្គមសួរសិស្ស ដោយមិនទម្លាក់កំហុសទៅលើសង្គមវិញបានទេ? គេមានជំនឿលើប្រព័ន្ធប្រឡង) តាំងពីបុរាណមក ប្រជាជនចិននៅតែមានជំនឿថា ទោះមានបញ្ហាអ្វីកើតឡើងក៏ដោយ ជាមួយការប្រឡង បើអ្នកខិតខំប្រឹងប្រែងធ្វើឱ្យសម្រេចជោគជ័យ អ្នកអាចក្លាយជាកូនប្រសាររាជវង្ស ឬមន្ត្រីថ្នាក់ខ្ពស់។ សូម្បីតែនៅក្នុងសង្គមចិនបច្ចុប្បន្ន បើសិនអ្នកចង់ទទួលបានសញ្ញាប័ត្របណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់ ឬបរិញ្ញាបត្រ ឬចង់បានការងារជាមន្ត្រីរាជការគ្រប់ប្រភេទ អ្នកត្រូវឆ្លងកាត់ការប្រឡងជាប់ជាស្ពាពរសិន សូម្បីមន្ត្រីជាន់ខ្ពស់ក៏ដោយ។ និយាយរួមការទទួលបានការងារមន្ត្រីរាជការគ្រប់ប្រទេសទាំងអស់ និងមុខតំណែងនានាត្រូវឆ្លងកាត់ការប្រឡងជាមុនសិន ទាល់តែប្រឡងជាប់ទើបអាចធ្វើការ និងចូលកាន់តួនាទីភារកិច្ចនោះបាន។ ការប្រឡងមិនមែនជាវិធីសាស្ត្រល្អបំផុតទេ តែវាឆ្លុះបញ្ចាំងពីភាពស្មើភាពគ្នា។ វាជានាភាពស្មើភាពក្នុងសង្គម ដែលបញ្ជាក់ថា គ្មាននរណាម្នាក់អាចឡើងតួនាទីឋានៈ ឬអភិវឌ្ឍន៍វិជ្ជាជីវៈក្នុងអាជីព តាមរយៈឥទ្ធិពល និងឋានៈគ្រួសារទេ។ តាមរយៈភាពយុត្តិធម៌ការប្រឡងផ្តល់សេចក្តីសង្ឃឹមដល់គ្រួសារចិនទាំងអស់ ឱ្យមានជំនឿ និងផ្តល់តម្លៃខ្ពស់លើការសិក្សា (បើសិស្សបរាជ័យលើការប្រឡង ពួកគេមិនព្យាយាមទម្លាក់កំហុសទៅកត្តាផ្សេងៗទៀតទេ)។ ក្នុងករណីនេះ អ្នកខ្លះយល់ថា ទំនៀមទម្លាប់នេះហាក់ធ្ងន់ធ្ងរពេក ព្រោះវាធ្វើឱ្យសិស្សធ្វើការខ្លាំង និង

ទទួលបន្ទុកធ្ងន់ធ្ងរ។ គេគួរកាត់បន្ថយសម្ពាធនៃការប្រឡងសាធារណៈ និងការរំពឹងទុកខ្ពស់របស់សិស្សនេះ។ យើងដឹងថា មនុស្សមានលក្ខណៈខុសៗគ្នា ហើយយើងពិតជាមិនអាចនិយាយបានថា រាល់បេក្ខជនដែលប្រឡងជាប់សុទ្ធតែមានប្រយោជន៍ និងជោគជ័យទាំងអស់នោះទេ។ ដូច្នេះ យើងព្យាយាមធ្វើការផ្លាស់ប្តូរ និងកាត់បន្ថយសម្ពាធនៃទំនៀមទម្លាប់នេះ។

❖ **គំនិតច្នៃប្រឌិតទំនើបនាំចូល៖**(១)

- **ទី១-នយោបាយបើកចំហ៖** នយោបាយបើកចំហជាគំនិតច្នៃប្រឌិតដ៏សំខាន់ទីមួយក្នុងរយៈពេល៣០ឆ្នាំចុងក្រោយនេះ ដោយសារបន្ទាប់ពីបដិវត្តវប្បធម៌ ចិនដឹងថាខ្លួនបានដើរថយក្រោយ បើប្រៀបធៀបទៅនឹងពិភពលោកទាំងមូល។ និន្នាការនេះជំរុញឆន្ទៈពួកគេចង់ទទួលបាននូវចំណេះដឹងចុងក្រោយបំផុតអំពីបទពិសោធជោគជ័យ និងវិធីសាស្ត្រទំនើបៗក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំនៅទូទាំងពិភពលោក។ ពួកគេបានបញ្ជូនមនុស្សទៅប្រទេសនៅគ្រប់ទីកន្លែងដើម្បីរៀនសូត្រប្រមូលចំណេះដឹងពីប្រទេសទាំងនោះយកមកប្រើប្រាស់ក្នុងប្រទេសខ្លួនវិញ។ ជាមួយគ្នានេះ ពួកគេក៏បានសិក្សាពីប្រព័ន្ធរបស់ប្រទេសទាំងនោះ និងច្បិចយកចំណុចល្អៗដើម្បីធ្វើកំណែទម្រង់ និងអភិវឌ្ឍន៍ប្រព័ន្ធអប់រំខ្លួន។ ពួកគេបានព្យាយាមទាក់ទាញអ្នកប្រាជ្ញ និងសាស្ត្រាចារ្យមកពីបរទេសមកសិក្សា ឬមកធ្វើការនៅប្រទេសខ្លួន។ ដោយសារនយោបាយបើកចំហនេះ បានជំរុញឱ្យមានការអភិវឌ្ឍវិស័យអប់រំយ៉ាងខ្លាំង។ ប្រជាជនចិនបានផ្តោតលើការសិក្សាភាសាបរទេស ព្រោះពួកគេចង់រៀនសូត្រពីពិភពលោក និងស្វែងយល់ឱ្យបានច្បាស់លាស់ពីប្រទេសដទៃទៀត។ គោលនយោបាយបើកទ្វារគឺជាសញ្ញានៃឆន្ទៈរបស់ជនជាតិចិនក្នុងការប្តេជ្ញាចិត្ត និងបើកចំហចិត្តដើម្បីរៀនសូត្រពីអ្នកដទៃ។ ប្រទេសចិនមិនខ្វល់ថា អ្នកប្រាជ្ញអប់រំជាមនុស្សប្រភេទណា ឬមកពីប្រទេសណានោះទេឱ្យតែទ្រឹស្តី វិធីសាស្ត្រ

ឬបទពិសោធអាចមានប្រយោជន៍ ឬមានចំណាប់អារម្មណ៍ពីសំណាក់ប្រជាជនចិន គេនឹងព្យាយាមណែនាំពួកគេ និងយកគំនិតរបស់ពួកគេទៅប្រើប្រាស់ក្នុងប្រទេសចិន។ ពួកគេព្យាយាមសិក្សាប្រព័ន្ធ ទ្រឹស្តី វិធីសាស្ត្រ បទពិសោធពីប្រទេសនានាដើម្បីកែលម្អប្រព័ន្ធអប់រំខ្លួន។ គន្លឹះជោគជ័យរបស់ចិន ក្នុងការសិក្សាប្រៀបធៀបស៊ីជម្រៅពីប្រព័ន្ធអប់រំ និងការប្រមែប្រមូលចំណេះដឹង បទពិសោធ និងមេរៀនរៀនសូត្រពីប្រទេសទាំងនេះដើម្បីយកមកអភិវឌ្ឍន៍វិស័យអប់រំរបស់ខ្លួននេះ កម្ពុជានៅមាននៅមិនទាន់អនុវត្តទូលំទូលាយដូចចិននៅឡើយ។ ការសិក្សាបែបនេះ វាមានប្រយោជន៍ក្នុងការកែលម្អ និងធ្វើកំណែទម្រង់ប្រព័ន្ធអប់រំខ្លួនឱ្យបានល្អប្រសើរ ហើយកាលណាយើងស្គាល់គេច្បាស់យើងនឹងអាចស្វែងរកវិធីធ្វើឱ្យខ្លួនឯងអភិវឌ្ឍន៍រីកចម្រើន និងប្រកួតប្រជែងនឹងគេបាន។ ចំណេះដឹងបែបប្រៀបធៀបនេះមានតិចតួចនៅឡើយសម្រាប់អ្នកសិក្សាស្រាវជ្រាវនៅកម្ពុជា។ និស្សិតដែលសិក្សានៅបរទេសភាគច្រើន ពេលត្រឡប់មកវិញមិនសូវធ្វើការជាអ្នកសិក្សាស្រាវជ្រាវទេ ច្រើនធ្វើតែគ្រូបង្រៀន ឬសាស្ត្រាចារ្យតាមសាកលវិទ្យាល័យប៉ុណ្ណោះដែលធ្វើឱ្យខ្វះខាតឯកសារស្រាវជ្រាវទាំងនេះ។ មួយវិញទៀតផ្អែកតាមលទ្ធផលPISAរបស់ក្រុងសៀងហៃបង្ហាញថា សិស្សសៀងហៃមិនត្រឹមតែរៀនតាមរយៈការសូត្រ និងទន្ទេញប៉ុណ្ណោះទេ ប៉ុន្តែមានការផ្លាស់ប្តូររបៀបរៀនថ្មីដើម្បីឆ្លើយតបនឹងនិន្នាការអប់រំសតវត្សរ៍ទី២១។ គ្រូបង្រៀនកាន់តែច្រើនដឹងថា គេត្រូវប្រើប្រាស់យុទ្ធសាស្ត្រថ្នាក់រៀន និងយុទ្ធសាស្ត្រផ្សេងៗដ៏សម្បូរបែបដើម្បីជួយសិស្ស ព្រមទាំងផ្តល់ឱកាសឱ្យសិស្សចែករំលែកវិធីសាស្ត្ររៀនសូត្រជោគជ័យដោយខ្លួនគេផ្ទាល់ជាជាងការរៀនតាមរយៈការសូត្រ ឬទន្ទេញដែលជាវិធីសាស្ត្រចាស់គំរិលដែលអនុវត្តតាំងពីបុរាណកាលមក។ គោលនយោបាយបើកចំហមានសារៈសំខាន់ណាស់សម្រាប់ប្រទេសចិន ព្រោះវាមិនត្រឹមតែផ្តល់ជម្រើសគោលនយោបាយថ្មីជាច្រើនប៉ុណ្ណោះ

ទេ ប៉ុន្តែវាចាំបាច់សម្រាប់ការអនុវត្តដែលមានឥទ្ធិពលខ្លាំងលើការបង្រៀន និងរៀនប្រចាំថ្ងៃ។

- **ទី២-កំណែទម្រង់វិធីសាស្ត្របង្រៀននឹងកម្មវិធីសិក្សា៖** ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៨៦មកដល់បច្ចុប្បន្ន ប្រទេសចិនបានធ្វើកំណែទម្រង់បីដងមកហើយទៅលើវិធីសាស្ត្របង្រៀន និងកម្មវិធីសិក្សា។ នៅមុនឆ្នាំ១៩៨៦ ប្រទេសចិនមានសៀវភៅសិក្សាគោល និងកម្មវិធីសិក្សាតែមួយប៉ុណ្ណោះ ហើយត្រូវបានរៀបចំនៅថ្នាក់មជ្ឈឹម(ថ្នាក់ជាតិ)ទាំងអស់សម្រាប់ការអនុវត្តទូទាំងប្រទេស។ ប៉ុន្តែក្រោយមក ប្រទេសចិនបានសិក្សាស្វែងយល់ពីវិធីសាស្ត្រ និងកម្មវិធីសិក្សារបស់ពិភពលោកខាងក្រៅ ពិសេសពីប្រទេសដែលមានប្រព័ន្ធអប់រំល្បីៗដែលអនុវត្តជោគជ័យលើយុទ្ធសាស្ត្រការផ្ទេរវិមជ្ឈការទៅថ្នាក់ក្រោមជាតិក្នុងការរៀបចំកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។ ដោយសារប្រទេសចិនជាប្រទេសធំ មានវប្បធម៌ច្រើន និងមានដំណើរការអភិវឌ្ឍឧស្សាហកម្មច្រើនដំណាក់កាល។ ដូច្នេះចាប់តាំងពីឆ្នាំ១៩៨៦មក ប្រទេសចិនបានផ្តល់ការអនុញ្ញាតឱ្យក្រុងសៀងហៃក្នុងការរៀបចំកម្មវិធីសិក្សាដោយខ្លួនឯង តែត្រូវស្ថិតក្នុងលក្ខខណ្ឌតម្រូវឱ្យស៊ីគ្នានឹងសេចក្តីណែនាំរួមរបស់ប្រទេសទាំងមូល។ ក្រុងសៀងហៃជាក្រុងទី១ដែលមានកម្មវិធីសិក្សាផ្ទាល់ខ្លួន ប៉ុន្តែក្រោយមកខេត្តជាច្រើនក៏ត្រូវបានអនុញ្ញាតឱ្យរៀបចំកម្មវិធីសិក្សាផ្ទាល់ខ្លួនផងដែរ។ ជាការពិតណាស់ គេត្រូវដើរតាមគោលការណ៍ណែនាំ ប៉ុន្តែគេអាចកែសម្រួលកម្មវិធីសិក្សានៅតាមកម្រិតថ្នាក់ខេត្ត ហើយជាតុផ្សំខ្លះទៅក្នុងកម្មវិធីសិក្សាតាមរយៈនៃការធ្វើមូលដ្ឋានីយកម្មបន្ថែមទៀត ពោលគឺធ្វើឱ្យមានលក្ខណៈសមស្របទៅតាមស្ថានភាពនៅក្នុងមូលដ្ឋានដោយឡែកផ្សេងៗគ្នា។ រយៈពេល ១១ឆ្នាំ ក្រោយមកនៅក្នុងឆ្នាំ១៩៩៧ ក្រុងសៀងហៃបានផ្តួចផ្តើមធ្វើការកំណែទម្រង់ជុំទី២របស់ខ្លួនដែលវាមិនត្រឹមតែធ្វើមូលដ្ឋានីយកម្មតែយកចិត្តទុកដាក់ជាសំខាន់ទៅលើលក្ខណៈរបស់បុគ្គល។ គេបាន

បែងចែកកម្មវិធីសិក្សាជាបីផ្នែកដែលផ្នែកទីមួយជាកម្មវិធីសិក្សាស្នូល មានពី៦០%ទៅ៧០%នៃកម្មវិធីសិក្សាទាំងមូល ហើយសិស្សទាំងអស់ត្រូវរៀនផ្នែកនេះជាចាំបាច់។ ផ្នែកទីពីរជាកម្មវិធីសិក្សាពង្រីកចំណេះដឹង ដោយសារពួកយើងយល់ឃើញថា សិស្សមានលក្ខណៈដោយឡែកៗពីគ្នា ដោយសិស្សខ្លះពូកែគណិតវិទ្យា ខ្លះទៀតពូកែវិទ្យាសាស្ត្រ ហើយក៏មានមួយចំនួនទៀតពូកែផ្នែកសិល្បៈ។ ដូច្នេះការកសាងនូវកម្មវិធីសិក្សាដែលចាំបាច់បំផុតក្នុងការផ្ដល់ឱកាសដល់សិស្សអាចពង្រីកចំណេះដឹង បំណិនជាក់លាក់តាមសម្បទា និងជម្រើសរបស់ពួកគេ។ ផ្នែកទីបីនៃកម្មវិធីសិក្សាគឺកម្មវិធីសិក្សាផ្ដោតលើការសិក្សាស្រាវជ្រាវ។ ជាការពិត គម្រោងស្រាវជ្រាវជាអ្វីដែលគេអាចនឹងធ្វើនៅក្នុងពិភពការងារពិតប្រាកដមួយរបស់ពួកគេ។ ដូច្នេះក្រៅពីកម្មវិធីសិក្សា និងកិច្ចការផ្ទះប្រចាំថ្ងៃ ប្រព័ន្ធអប់រំនេះបានផ្ដល់ឱ្យសិស្សនូវកិច្ចការផ្ទះរយៈពេលវែងមួយក្នុងទម្រង់ជាកិច្ចការស្រាវជ្រាវពីគម្រោងអ្វីមួយ។ គម្រោងខ្លះ សិស្សអាចធ្វើជាក្រុម ឬធ្វើជាបុគ្គល។ សិស្សអាចធ្វើគម្រោងស្រាវជ្រាវនៅក្នុងតំបន់គោលដៅមួយជាក់លាក់ ហើយប្រហែលជាទាក់ទងនឹងខ្សែភាពយន្ត ឬទាក់ទងទៅនឹងបាតុភូតសង្គមមួយចំនួន។ល។ សិស្សអាចជ្រើសរើសក្នុងកិច្ចការសិក្សាស្រាវជ្រាវធ្វើម៉ូដែលយន្តហោះ ឬមនុស្សយន្ត ឬអ្វីមួយដែលចង់សិក្សាស្រាវជ្រាវដែលមានប្រយោជន៍ដល់ការសិក្សារៀនសូត្រ។ ស្ថិតក្នុងបរិបទនៃកម្មវិធីសិក្សាថ្មីទាំងបីផ្នែក វិធីសាស្ត្របង្រៀនមានលក្ខណៈផ្សេងៗគ្នាជាច្រើនបានលេចរូបរាងឡើងជំនួសវិធីសាស្ត្រហួសសម័យដែលមិនសមស្របនឹងកម្មវិធីសិក្សាថ្មី។ ទាក់ទងនឹងចំណុចបង្ហា-ញខាងលើនេះ សម្រាប់សិស្សនៅមធ្យមសិក្សាប្រទេសកម្ពុជាមិនឃើញមានកម្មវិធីសិក្សាស្រាវជ្រាវបែបនេះទេ ហើយសូម្បីតែការសិក្សានៅមហា/សាកលវិទ្យាល័យក៏ការសិក្សាស្រាវជ្រាវនេះនៅមានកម្រិតនៅឡើយដែរ ដោយនិស្សិតបញ្ចប់បរិញ្ញាបត្រមួយចំនួនធំជ្រើសរើសការប្រឡងបញ្ចប់ ជា

ជាងសរសេរសារណាស្រាវជ្រាវ។ មិនតែប៉ុណ្ណោះសូម្បីតែគ្រូបង្រៀនមួយចំនួនធំក៏មានការយល់ដឹងតិចតួចពីការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រនេះដែរ។ ចំណុចនេះប្រទេសកម្ពុជា មិនទាន់អាចអនុវត្តបានដូចក្រុងសៀងហៃ ឬដូចប្រទេសនានាជាច្រើនដែលអនុវត្តបាននៅឡើយ ពិសេសនៅកម្រិតមធ្យមសិក្សានេះតែម្តង។ មួយវិញទៀត ការអនុវត្តបែបវិមជ្ឈការដល់ថ្នាក់ក្រោមជាតិដោយផ្តល់ស្វ័យភាពក្នុងការរៀបចំកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលផ្ទាល់ខ្លួនដូចក្រុងសៀងហៃ ក៏មិនទាន់អនុវត្តនៅប្រទេសកម្ពុជាបានដែរ ។

- **កំណែទម្រង់ទីបីគឺចាប់ផ្តើមតាំងពីឆ្នាំ២០១១ បន្តរហូតដល់បច្ចុប្បន្ន** កំណែទម្រង់ជុំនេះចាប់ផ្តើមផ្លាស់ប្តូរដោយផ្តោតលើចំណេះដឹងទៅជាបំណិន (ជំនាញ) ពិសេសបំណិនទាក់ទងនឹងការច្នៃប្រឌិត និងការបង្កើតថ្មី។ ប្រព័ន្ធអប់រំក្រុងសៀងហៃព្យាយាមលើកកម្ពស់ជំនាញដែលត្រូវការសម្រាប់មន្ទីរពិសោធន៍ ឬបច្ចេកវិទ្យាទំនាក់ទំនង និងពត៌មានវិទ្យា ឬតំបន់ផ្សេងទៀតដែលឱ្យតម្លៃលើគំនិតច្នៃប្រឌិត និងការបង្កើតថ្មី។ គំនិតច្នៃប្រឌិតទំនើបទី៣នេះ មានសារៈសំខាន់ខ្លាំងណាស់ពិសេសចូលរួមចំណែកអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនតាមរយៈការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនដោយការអប់រំ និងការបណ្តុះបណ្តាលឱ្យមានជំនាញមួយជាក់លាក់។ បើយើងប្រៀបធៀបក្រុងសៀងហៃកាលពី១៥ឆ្នាំមុន យើងឃើញថា គ្រូបង្រៀនវ័យក្មេងបង្រៀននៅសាលាបឋមសិក្សាបានបញ្ចប់ការសិក្សាត្រឹមថ្នាក់វិទ្យាល័យ ឬអប់រំជាន់ខ្ពស់រយៈពេល២ឆ្នាំប៉ុណ្ណោះ ហើយស្ថានភាពនេះនៅតែមានក្នុងតំបន់មួយចំនួននៅក្នុងប្រទេសចិនបច្ចុប្បន្ន។ រយៈពេល២០ឆ្នាំចុងក្រោយនេះក្រុងសៀងហៃបានយកចិត្តទុកដាក់ជាខ្លាំងដល់ការបណ្តុះបណ្តាលកសាងសមត្ថភាពគ្រូបង្រៀនដោយពួកគេជឿជាក់ថា ការអភិវឌ្ឍគ្រូបង្រៀនជាផ្នែកសំខាន់បំផុតក្នុងការអភិវឌ្ឍការសិក្សារៀនសូត្ររបស់សិស្ស។ មកដល់ពេលបច្ចុប្បន្ននេះ គ្រូបង្រៀននៅកម្រិតបឋមសិក្សា

យ៉ាងហោចណាស់មានសញ្ញាប័ត្របរិញ្ញាបត្រ និងប្រឡងជាប់អាជ្ញាប័ណ្ណធ្វើជាគ្រូបង្រៀនទើបអាចធ្វើជាគ្រូបង្រៀននៅបឋមសិក្សាបាន។ ដូច្នេះ តម្រូវការពីរយ៉ាងដើម្បីក្លាយជាគ្រូបង្រៀនគឺ លក្ខខណ្ឌដែលអាចធ្វើគ្រូបង្រៀន និងសមត្ថភាពពេញលេញក្នុងការបង្រៀន។ គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សានៅក្រុងសៀងហៃជាគ្រូមុខវិជ្ជាឯកទេស ដែលត្រូវបញ្ចប់ការសិក្សាដោយជោគជ័យលើជំនាញឯកទេសពីសាកលវិទ្យាល័យមួយជាក់លាក់ ដូចជា៖ គ្រូមុខវិជ្ជា គណិតវិទ្យា និងវិទ្យាសាស្ត្រជាដើម ដែលត្រូវឱ្យមានបរិញ្ញាបត្រមុខវិជ្ជា គណិតវិទ្យា ហើយមុខវិជ្ជាវិទ្យាសាស្ត្រ បរិញ្ញាបត្ររូបវិទ្យា គីមីវិទ្យា ឬជីវវិទ្យាពីមហាវិទ្យាល័យ។ បន្ទាប់ពីបញ្ចប់បរិញ្ញាបត្រពីសាកលវិទ្យាល័យហើយ និស្សិតដែលចង់ធ្វើគ្រូបង្រៀនត្រូវចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្រៀន និងប្រឡងប្រកួតប្រជែងដើម្បីក្លាយជាគ្រូបង្រៀន។ ចំណុចពិសេសនេះ ខុសពីប្រទេសកម្ពុជា ដែលគ្រូបង្រៀននៅបឋមសិក្សាបង្រៀនគ្រប់មុខវិជ្ជាទាំងអស់មានមុខវិជ្ជា៖ សិក្សាសង្គម ភាសាខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនសៀងហៃមានយ៉ាងហោចណាស់យុទ្ធសាស្ត្របណ្តុះបណ្តាលចំនួន៦សម្រាប់គ្រូបង្រៀនដែលកំពុងបម្រើការ។ យុទ្ធសាស្ត្រសំខាន់ជាងគេ គឺការប្រើប្រាស់យុទ្ធសាស្ត្រចងក្រងក្រុមដើម្បីធ្វើការជាមួយគ្នាក្នុងគោលបំណងអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀនតាមរយៈការចែករំលែកចំណេះដឹង បទពិសោធ និងរៀនសូត្រពីគ្នាទៅវិញទៅមក ក្នុងនោះមានក្រុមស្រាវជ្រាវ និងបង្រៀន និងក្រុមកម្រិតថ្នាក់រៀនដូចគ្នា (Grade group)។ ក្រុមស្រាវជ្រាវ និងបង្រៀនជាក្រុមដែលដាក់បញ្ចូលគ្រូបង្រៀនដែលមានឯកទេសដូចគ្នា ហើយជួបគ្នារាល់មួយសប្តាហ៍ម្តងដើម្បីប្រជុំក្រុមបច្ចេកទេសដោយពិភាក្សាពីបញ្ហាប្រឈមនានាដែលកើតមានទាក់ទងនឹងការបង្រៀន និងរៀន ព្រមទាំងធ្វើការរួមគ្នាដោះស្រាយបញ្ហាទាំងនោះ ចែករំលែកវិធីសាស្ត្រ និងល្បិច

បង្រៀនល្អៗគ្នាទៅវិញទៅមក ការសិក្សាស្រាវជ្រាវនានា ការអនុវត្តជោគជ័យ និងការរៀនសូត្រពីគ្នាទៅវិញទៅមកដើម្បីអភិវឌ្ឍន៍វិជ្ជាជីវៈ។ សម្រាប់ក្រុមកម្រិតថ្នាក់រៀនដូចគ្នាគឺជាក្រុមដែលគ្រូបង្រៀនមុខវិជ្ជាឯកទេសផ្សេងៗគ្នា តែបង្រៀននៅកម្រិតថ្នាក់មួយដូចគ្នា ជួបជុំគ្នាមួយដងក្នុងមួយសប្ដាហ៍។ ដោយសារសិស្សរៀននៅកម្រិតថ្នាក់ដូចគ្នា និងមានអាយុដូចគ្នា ហើយជានិច្ចកាលចែករំលែកសកម្មភាពដូចគ្នា និងជួបប្រទះបញ្ហាប្រហាក់ប្រហែលគ្នា ដូច្នេះគ្រូបង្រៀនផ្សេងគ្នា អាចមានបទពិសោធប្រហាក់ប្រហែលគ្នាជាមួយសិស្សរបស់ពួកគេ និងការចែករំលែកពីចំណេះដឹង និងបទពិសោធទាក់ទងនឹងភាពខុសៗគ្នា ឬដោយឡែកពីគ្នារបស់សិស្សម្នាក់ៗដែលគ្រូបានជួបប្រទះ។ គ្រូបង្រៀននៅក្នុងក្រុមស្រាវជ្រាវចែករំលែកចំណេះដឹងសម្រាប់ការបង្រៀនមុខវិជ្ជាឯកទេស ហើយចំណែកក្រុមកម្រិតថ្នាក់ដូចគ្នាចែករំលែកចំណេះដឹង និងជំនាញក្នុងការដោះស្រាយបញ្ហារបស់សិស្សដែលស្ថិតក្នុងកម្រិតថ្នាក់មួយជាក់លាក់។ ក្នុងន័យនេះ បើសិស្សនៅថ្នាក់ណាមួយមានបញ្ហាប្រឈមទាក់ទងនឹងលទ្ធផលសិក្សារៀនសូត្រ ឬឥរិយាបថ អាកប្បកិរិយាពួកគេនឹងធ្វើការរួមគ្នាក្នុងការជួយដោះស្រាយបញ្ហា និងកែលម្អធ្វើឱ្យប្រសើរឡើង។ ក្រុមទាំងពីនេះត្រូវបានបង្កើតទាំងក្នុងកម្រិតសាលារៀន និងសាកលវិទ្យាល័យ ជាទម្រង់នៃការធ្វើការងារជាប្រព័ន្ធ។ ទាក់ទងនឹងការបែងចែកក្រុមគ្រូបង្រៀនដើម្បីអភិវឌ្ឍន៍វិជ្ជាជីវៈនេះ នៅកម្ពុជា យើងឃើញថា មានតែក្រុមបច្ចេកទេសតាមមុខវិជ្ជាប៉ុណ្ណោះ និងមិនឃើញមានរៀបចំក្រុមកម្រិតថ្នាក់ដូចគ្នានោះទេ។ ចំណុចនេះ យើងគួរសិក្សាស្វែងយល់ពីគុណតម្លៃ និងអត្ថប្រយោជន៍នៃការបែងចែកក្រុមពីរប្រភេទនេះ ដែលវាតួនាទីសំខាន់ណាស់ក្នុងការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀននៅក្រុងសៀងហៃ ដោយប្រើប្រាស់ធនធានខាងក្នុង( Internal resources) សុទ្ធសាធប្រកបដោយប្រសិទ្ធភាពខ្ពស់។

- **គំនិតច្នៃប្រឌិតទំនើបទី៤** គឺការជួយជ្រំជ្រែងសាលារៀនដែលនៅទន់ខ្សោយនៅឡើយ។ ដើម្បីជួយសាលារៀនទាំងនេះ ប្រទេសចិនបានប្រើប្រាស់វិធីសាស្ត្រ" **គ្រប់គ្រងបែបផ្តល់សិទ្ធិអំណាច**" ដែលវិធីសាស្ត្រនេះមានលក្ខណៈខុសប្លែកពីប្រទេសផ្សេងៗ។ ប្រទេសចិនបានផ្តល់សិទ្ធិអំណាចដល់សាលារដ្ឋទាំងឡាយណាដែលមានស្នាដៃបំពេញការងារល្អ ឬអង្គការក្រៅរដ្ឋាភិបាលមួយចំនួនក្នុងការគ្រប់គ្រងសាលារៀនដែលបំពេញការងារនៅមានកម្រិតទាប។ ការផ្តល់សិទ្ធិអំណាចនេះមិនរាប់បញ្ចូលក្រុមហ៊ុនពាណិជ្ជកម្មទេ ដោយក្រុមទាំងនេះផ្តោតតែទៅលើការស្វែងរកប្រាក់ចំណេញ។ រដ្ឋាភិបាលចិនបានលើកទឹកចិត្តសាលារៀន និងនាយកសាលាក្នុងតំបន់ និងអង្គការក្រៅរដ្ឋាភិបាលដែលមានជំនាញអប់រំក្នុងការគ្រប់គ្រងសាលារៀនដែលនៅទន់ខ្សោយទាំងនោះ។ ពួកគេបានបង្កើតយុទ្ធសាស្ត្រជាច្រើនទៀតក្នុងរយៈពេល៣០ឆ្នាំចុងក្រោយនេះដូចជា៖ការព្យាយាមធ្វើឱ្យប្រសើរឡើងនូវសីលធម៌របស់គ្រូបង្រៀននៅតាមសាលារៀនដែលបំពេញការងារមិនទាន់ល្អ ព្យាយាមទាញយកការគាំទ្រពីគ្រួសារ និងឪពុកម្តាយសិស្ស ព្យាយាមបង្កើនវិធីសាស្ត្របង្រៀន និងរៀនរបស់គ្រូបង្រៀន និងសិស្សានុសិស្ស និងព្យាយាមបង្កើនទំនុកចិត្តលើខ្លួនឯង។
- **ទីប្រាំ**គឺជាយុទ្ធសាស្ត្រយកពន្ធពីតំបន់អ្នកមាន និងពីប្រភពផ្សេងៗទៀតទៅជួយតំបន់អ្នកក្រដើម្បីលើកកម្ពស់វិស័យអប់រំ។ ជានិច្ចកាលការអភិវឌ្ឍវិស័យអប់រំ គេត្រូវការថវិកាច្រើន ដូច្នេះគេត្រូវប្រើយុទ្ធសាស្ត្រកៀរគថវិកាឱ្យបានគ្រប់គ្រាន់ដើម្បីជួយធ្វើប្រសើរឡើងជារឿងចាំបាច់។ ប្រព័ន្ធនេះបានផ្តល់ប្រាក់ឧបត្ថម្ភ និងមូលនិធិផ្នែកអប់រំដើម្បីជួយឱ្យតំបន់ក្រីក្រ ទទួលបានសេវាអប់រំល្អដូចតំបន់ទីក្រុងដែរ។ បើសិនតំបន់ក្រីក្រមិនមានសាលារៀនល្អ និងសិស្សល្អទេ គ្រូបង្រៀនដែលមានសមត្ថភាពនឹងចាកចេញ ហើយសាលារៀននៅតំបន់នោះកាន់តែប្រឈមនឹងបញ្ហាជាច្រើន។ ដូច្នេះ ចិនបានយកចិត្តទុកដាក់

ខ្លាំងក្នុងការផ្តល់មូលនិធិប្រកបដោយសមធម៌មិនត្រឹមតែក្រុងសៀងហៃទេគឺនៅទូទាំងប្រទេសចិន។

- **ការច្នៃប្រឌិតទំនើបចុងក្រោយ**គឺថាក្រុងសៀងហៃបម្រុងទុកកូតាកន្លែងខ្លះនៅក្នុងសាលារៀនល្បីៗសម្រាប់សិស្សមកពីសាលារៀនដែលនៅទន់ខ្សោយ (ស្តង់ដារទាប)។ កូតាទាំងនេះអនុញ្ញាតឱ្យឪពុកម្តាយ / អាណាព្យាបាលដែលមានកូនរៀនសាលារៀនស្តង់ដារទាបទាំងនោះ អាចបញ្ជូនកូនៗរបស់ពួកគេ ក្រោយពីបញ្ចប់ការសិក្សាឱ្យទៅបន្តការសិក្សានៅសាលាអនុវិទ្យាល័យជាន់ខ្ពស់ មហាវិទ្យាល័យ និងសាកលវិទ្យាល័យបន្តទៀត។ ពួកគេជឿជាក់ថា ប្រសិនបើសិស្ស-និស្សិតមានលទ្ធផលសិក្សាល្អពីសាលារៀនដែលមានស្តង់ដារទាប ប្រហែលជាពួកគេជាសិស្សមានសមត្ថភាព ភាពឆ្លាតវៃ និងខិតខំប្រឹងប្រែងព្យាយាមសិក្សារៀនសូត្រ ហើយការឈានចូលសាលារៀនស្តង់ដារខ្ពស់កាន់តែផ្តល់ឱកាសដល់ពួកគេទទួលជោគជ័យថែមទៀត។ គំនិតច្នៃប្រឌិតនិងយុទ្ធសាស្ត្រនេះ ដើរតួនាទី និងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការបណ្តុះសក្តានុពល លើកទឹកចិត្តសិស្សពូកែ និងឪពុកម្តាយ អ្នកអាណាព្យាបាលសិស្សនៅតំបន់ក្រីក្រមានឱកាសទទួលបានសេវាអប់រំនៅសាលារៀន ឬសាកលវិទ្យាល័យល្បីៗបាន។

ដូច្នេះ ប្រទេសចិនមានយុទ្ធសាស្ត្រទំនើបចំនួន៦គឺ៖ **(១)គោលនយោបាយបើកចំហ (២)កំណែទម្រង់វិធីសាស្ត្របង្រៀន និងកម្មវិធីសិក្សា (៣)បណ្តុះបណ្តាលបំប៉នសមត្ថភាពគ្រូបង្រៀនដែលកំពុងបម្រើការងារ (៤)ដោះស្រាយបញ្ហាប្រឈមរបស់សាលារៀនដែលមិនទាន់បំពេញការងារបានល្អប្រសើរ (៥)ផ្ទេរមូលនិធិពីតំបន់អ្នកមានទៅតំបន់អ្នកក្រ និង(៦)ទុកកន្លែងសម្រាប់សិស្សមកពីសាលារៀនទន់ខ្សោយ (ស្តង់ដារទាប) អាចចូលរៀនសាលារៀន និងសាកលវិទ្យាល័យល្បីៗបាន។ ដោយសារយុទ្ធសាស្ត្រទំនើបទាំងនេះហើយ ដែលជំរុញឱ្យប្រព័ន្ធអប់រំមានការផ្លាស់ប្តូររីកចម្រើនខ្លាំង។**

## 5.2)-លោក Vivien Stewart មតិយោបល់[១]៖

- ភាពជោគជ័យនៃការអប់រំនៅក្រុងសៀងហៃទាក់ទងនឹងឥរិយាបថតឹងរឹងរបស់ម្ដាយចំពោះកូន។ ម្ដាយកាចដូចខ្លា (Tiger mum) ដាក់សម្ពាធខ្លាំងលើការអប់រំកូន ចង់ឱ្យកូនទទួលបានលទ្ធផលសិក្សាខ្ពស់។ ការចូលរួមរបស់គ្រួសារក្នុងការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់លទ្ធផលសិក្សាកូន។
- ឆ្នាំ១៩៩០នៅសៀងហៃ គេបានលុបចោលការប្រឡងថ្នាក់បឋមសិក្សាដើម្បីកាត់បន្ថយសម្ពាធសិក្សាដោយទុកឱកាសដល់សិស្សសិក្សាស៊ីជម្រៅជាជាងបង្រៀនដើម្បីតែការត្រៀមប្រឡង។ ចំណុចនេះដូចប្រទេសកម្ពុជាដែរ មិនមានការប្រឡងនៅបញ្ចប់កម្រិតបឋមសិក្សាទេ ដែលខុសពីប្រទេសសឹង្ហបូរីដែលការប្រឡងនៅកម្រិតថ្នាក់នេះមានសារៈសំខាន់ណាស់ក្នុងការសម្រួចសមត្ថភាពកុមារ មុនឆ្លងចូលមធ្យមសិក្សាបឋមភូមិ។
- សាលារៀនទាំងអស់ត្រូវបានវាយតម្លៃ និងចាត់ចំណាត់ថ្នាក់។ សាលារៀនលំដាប់ផ្កាយនៅសៀងហៃមានកម្រិតស្តង់ដារខ្ពស់ ហើយសិស្សមានសមត្ថភាពភាសាអង់គ្លេសខ្ពស់អាចជជែកពិភាក្សាជាមួយគ្រូបរទេសជាភាសាអង់គ្លេសបានយ៉ាងស្ទាត់។ វាមានគម្លាតគ្នាខ្លាំងរវាងសាលារៀនលំដាប់ផ្កាយ និងសាលាផ្សេងទៀត។ សាលារៀនព្យាយាមពង្រឹងខ្លួនដើម្បីទទួលបានកេរ្តិ៍ឈ្មោះល្បីល្បាញ ដែលទាក់ទងឱ្យមានការចំណាកស្រុកពីតំបន់ជនបទមកទីក្រុងកម្រិតខ្ពស់ផងដែរ ពិសេសក្នុងគោលដៅស្វែងរកសេវាអប់រំគុណភាពល្អសម្រាប់កូនៗពួកគាត់។
- សាលារៀននៅសៀងហៃទទួលបានចំណាត់ថ្នាក់ខ្ពស់គឺផ្ដោតទៅលើ៖ ការអនុវត្តការងារសម្រេចជោគជ័យខ្ពស់របស់សាលារៀន គុណភាពនៃការដឹកនាំ និងគុណវុឌ្ឍិគ្រូបង្រៀនល្អ។ នាយកសាលាដែលមានស្នាដៃ និងសមត្ថភាពខ្ពស់ត្រូវបានស្នើឱ្យមានការគ្រប់គ្រងសាលាលើសពីមួយ សាលារៀននៅក្នុងតំបន់ដាក់លាក់ ត្រូវបានចងក្រងជា

កម្រងសាលាដើម្បីចែករំលែកធនធាន និងដាក់ឱ្យស្ថិតក្រោមទម្រង់ការគ្រប់គ្រងដែលត្រូវបានផ្តល់សិទ្ធិអំណាច ហើយគ្រូបង្រៀនមានទីផ្សារខ្ពស់ (គ្រូបង្រៀនល្បីៗ) អាចដោះដូរការបង្រៀននៅតាមសាលារៀននានាបាន។ នេះមានន័យថា នាយកសាលាល្អអាចគ្រប់គ្រងសាលារៀនលើសពីមួយបាន។

- ករណីមួយចំនួន គ្រូបង្រៀនមានគន្លងអាជីពច្បាស់លាស់ដែលលើកទឹកចិត្តគ្រូឱ្យមានការប្រឹងប្រែងក្នុងអាជីព។
- សៀងហៃមានប្រព័ន្ធអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនដែលមានលក្ខណៈប្រហាក់ប្រហែលប្រទេសអាស៊ីខាងកើតផ្សេងៗទៀតដែរ។ ប្រព័ន្ធនេះជាយុទ្ធសាស្ត្រមួយដ៏សំខាន់ដើម្បីសម្រេចបាននូវស្តង់ដារខ្ពស់របស់សាលារៀន
- គ្រូបង្រៀនរៀបចំការប្រជុំប្រចាំសប្តាហ៍ (ប្រជុំក្រុមបច្ចេកទេស) ដោយមានប្រធានបទច្បាស់ និងធ្វើការរួមគ្នាកែលម្អបញ្ហាប្រឈមនានាឱ្យបានទាន់ពេលវេលា
- ផ្តល់ឱកាសយ៉ាងទូលំទូលាយក្នុងការរៀនសូត្រពីគ្នាទៅវិញទៅមកដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ពិសេសពីគ្រូបង្រៀនដែលមានស្នាដៃឆ្នើម។
- គ្រូបង្រៀនជាន់ខ្ពស់ (Senior Teacher)ធ្វើគម្រោងស្រាវជ្រាវដោយធ្វើការជ្រើសរើសបញ្ហាដោយឡែកនានាទាក់ទងនឹងការអប់រំ រំពឹកទ្រឹស្តី និងការសាកល្បងធ្វើតេស្តវិធីសាស្ត្រខុសគ្នា និងបង្ហាញលទ្ធផល។ គ្រូជាន់ខ្ពស់នេះ មានប្រមាណ៩០០នាក់នៅសៀងហៃ ហើយធ្វើការរួមគ្នាជាក្រុម និងចែករំលែកលទ្ធផលដល់សាលារៀននានា (ចំណែកឯនៅកម្ពុជា គ្រូជាន់ខ្ពស់ដែលធ្វើការផ្នែកស្រាវជ្រាវមិនមានច្រើនទេ ហើយនិស្សិតដែលបញ្ចប់ការសិក្សាពីបរទេសភាគច្រើន ធ្វើការងារជាគ្រូបង្រៀន ឬសាស្ត្រាចារ្យមហាវិទ្យាល័យ មិនសូវមានអ្នកចាប់អារម្មណ៍ធ្វើការសិក្សាស្រាវជ្រាវ)

- វាមានកិត្តិយសធំសម្បើមណាស់ក្នុងការក្លាយជាគ្រូបង្រៀនជាន់ខ្ពស់ (Master teacher) និងមានការទទួលខុសត្រូវចាំបាច់ដោយសារគ្រូបង្រៀនទាំងនេះ ធ្វើការយ៉ាងខ្លាំងក្លាទាំងក្នុងសាលារៀនដែលខ្លួនបង្រៀន និងសាលារៀនផ្សេងទៀត។ ប៉ុន្តែអ្វីដែលលើសពីគ្រូបង្រៀនជាន់ខ្ពស់ គ្រូបង្រៀនទាំងអស់ព្យាយាម អភិវឌ្ឍន៍ខ្លួនតាមគន្លងអាជីពដែលមានន័យថា មិនត្រឹមតែលើកកម្ពស់សមត្ថភាពបង្រៀនរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏ចូលរួមចំណែកអភិវឌ្ឍវិជ្ជាជីវៈដល់គ្រូបង្រៀនផ្សេងទៀត និងធ្វើឱ្យប្រសើរឡើងនូវគុណភាពបង្រៀននៅសាលារៀនទាំងអស់។
- គណកម្មការអប់រំសៀងហៃ បានផ្តល់មូលនិធិគាំទ្រដល់សាលារៀនស្នាដៃល្អដើម្បីជួយដល់សាលារៀនដែលមិនទាន់បំពេញតួនាទីបានល្អ។
- ប្រទេសចិនចាប់អារម្មណ៍នឹងPISA ដែលវាជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងកំណែទម្រង់កម្មវិធីសិក្សារបស់ខ្លួន ដោយព្យាយាមផ្លាស់ប្តូរប្រព័ន្ធរបស់ខ្លួនពីរបៀបផ្ទេរចំណេះដឹងបែបបុរាណទៅប្រព័ន្ធមួយ ដែលលើកកម្ពស់ការដោះស្រាយ និងជំរុញការត្រិះពិចារណាប្រកបដោយហេតុផល (Critical thinking)។ បើប្រៀបធៀបតេស្តជាប្រពៃណីរបស់ចិន យើងឃើញថា តេស្តPISAមានលក្ខណៈលំបាកខ្លាំង និងជំរុញក្នុងការដោះស្រាយបញ្ហា និងការយកចំណេះដឹងទៅប្រើប្រាស់។ ដូច្នេះ នៅសៀងហៃប្រើប្រាស់សំណួរ PISA មិនត្រឹមតែជាតេស្តផ្តល់គំរូដល់សិស្សក្នុងការប្រៀបធៀបលក្ខណៈអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែវាប្រើសម្រាប់សិស្សទាំងអស់។
- សៀងហៃមិនតំណាងឱ្យចិនទាំងមូលទេ វាជាខេត្តមួយរបស់ចិនដែលដឹកនាំសេដ្ឋកិច្ចក៏ដូចជាវិស័យអប់រំដោយខ្លួនឯង។ ខេត្តមួយចំនួនទៀតនៅភាគខាងកើត វិស័យអប់រំក៏មានការរីកចម្រើនលឿនផងដែរ ប៉ុន្តែខេត្តនៅភាគកណ្តាល និងខាងលិចនៅតែក្សត់ខ្សោយនៅឡើយ។

- ក្នុងបរិបទប្រទេសចិនទាំងមូលនៅតែជួបប្រទះដូចជា៖
  - កង្វះសមធម៌នៃការអប់រំរវាងទីក្រុងតំបន់ឆ្នេរសមុទ្រដែលមានការអភិវឌ្ឍ និងតំបន់ភាគខាងលិច តំបន់ជនបទ។ ស្ថានភាពនេះ វាអាចគំរាមកំហែងស្ថេរភាពចិនពេលអនាគត។ ដូច្នេះហើយរដ្ឋាភិបាលចិន បានបោះទុនថវិកាដ៏ច្រើនលានដុល្លារដើម្បីលើកកម្ពស់គុណភាពការអប់រំនៅតាមជនបទ តាមរយៈជ្រើសរើស ផ្តល់ការបណ្តុះបណ្តាល និងគាំទ្រគ្រូបង្រៀន។ ទោះបីចិនប្រឹងប្រែងយ៉ាងណាក៏ដោយគំលាតអប់រំនៅតែមានកម្រិតធំនៅឡើយ។
  - ប្រព័ន្ធប្រឡងសាកលវិទ្យាល័យត្រូវបានគ្រប់គ្រងដោយសាក-លវិទ្យាល័យ ហើយវាជាការប្រឡងបែបប្រពៃណីបំផុត។ វាបានដាក់សម្ពាធដល់សិស្សក្នុងចូលរៀនសាកលវិទ្យាល័យពិសេសសាកលវិទ្យាល័យដែលល្បីៗ។ វាមានន័យថា មានផលប៉ះពាល់ដ៏ខ្លាំងលើវិទ្យាល័យ និងកាត់បន្ថយកិច្ចប្រឹងប្រែងរបស់ក្រុងសៀងហៃ និងទីក្រុងផ្សេងទៀតក្នុងការធ្វើទំនើបកម្មកម្មវិធីសិក្សា។ ការប្រឡងនេះតំណាងឱ្យទម្ងន់ដ៏ធ្ងន់លើប្រព័ន្ធ និងសិស្ស។
  - ការកសាងសមត្ថភាពដែលចាំបាច់ដើម្បីផ្លាស់ប្តូរពីថ្នាក់បង្រៀនវិជ្ជាជីវៈគ្រូបង្រៀនតាមបែបប្រពៃណីរបស់ចិនទៅជាគំរូសម័យទំនើបគឺជាបញ្ហាប្រឈមដ៏ធំមួយទៀត
  - ការសម្រេចចិត្តចូលរួមជាមួយPISAដោយសារគេមើលថា វាជាឧបករណ៍មួយដែលគេអាចប្រើប្រាស់ដើម្បីធ្វើទំនើបកម្មកម្មវិធីសិក្សា និងគរុកោសល្យ។ គ្រូបង្រៀនអាចប្រើប្រាស់តេស្ត PISA ជាមធ្យោបាយមួយដើម្បីជួយគ្រូបង្រៀនយល់ដឹង ថាតើត្រូវបង្រៀនសិស្សយ៉ាងម៉េចដើម្បីឆ្លើយតបទៅនឹងកម្រិតស្តង់ដារ។

**ទោះបីយ៉ាងណាក៏ដោយ ប្រទេសចិនមានបញ្ហាជាច្រើនត្រូវធ្វើទាក់ទងនឹងការអប់រំ(១)៖**

- កម្មករចំណាកស្រុកជាបាតុភូតសង្គមថ្មី។ គ្រួសារចំណាកស្រុកនៅក្រុងសៀងហៃ ជាគ្រួសារដែលមកពីតំបន់ជនបទដើម្បីស្វែងរកឱកាសការងារ។ ដោយសារឃើញកំណើនជនចំណាកស្រុកនេះ ប្រទេសចិនបានផ្លាស់ប្តូរគោលនយោបាយទាក់ទងនឹងកុមារគ្រួសារចំណាកស្រុកនៅប៉ុន្មានឆ្នាំថ្មីៗនេះ។ កាលពីអតីតកាល គេអនុញ្ញាតឱ្យតែកុមារមកពីគ្រួសារដែលមានអាសយដ្ឋានផ្លូវការនៅក្រុងសៀងហៃប៉ុណ្ណោះអាចចូលរៀននៅសាលារដ្ឋនៅក្នុងទីក្រុងបាន។ សម្រាប់គ្រួសារចំណាកស្រុកជាច្រើនដែលចេញពីស្រុកកំណើតនៅជនបទមករស់នៅក្នុងក្រុងសៀងហៃ មិនអាចចុះបញ្ជីអាសយដ្ឋានផ្លូវការនៅក្នុងក្រុងសៀងហៃបានឡើយ ហើយកូនៗរបស់ពួកគេក៏មិនអាចចូលរៀននៅសាលារៀនក្នុងទីក្រុងនេះបានដែរ។ ប៉ុន្តែស្ថានភាពនេះបានផ្លាស់ប្តូរហើយពេលបច្ចុប្បន្នក្នុងអំឡុងឆ្នាំ២០០៨ ហើយសៀងហៃបានបើកចំហទ្វារសាលារៀនសម្រាប់ជនចំណាកស្រុកផងដែរ។ កុមារចំណាកស្រុកត្រូវបានគេផ្តល់នូវកាតព្វកិច្ចអប់រំ ( Compulsory education ) ក្នុងសាលារដ្ឋដែរ។ នៅក្នុងឆ្នាំ២០០៩ ក្រុងសៀងហៃបានចូលរួមតេសPISA តែមានកុមារមកពីគ្រួសារចំណាកស្រុកតិចតួចនៅឡើយបានចូលរៀន ហើយក្រោយមកចំនួននេះបានកើនឡើងជាបន្តបន្ទាប់។ កាលពីឆ្នាំមុននៅក្នុងឆ្នាំ២០១២ នៅក្នុងសាលាបឋមសិក្សាសិស្សចំណាកស្រុកកាន់តែមានចំនួនច្រើនជាងកុមារក្នុងស្រុកដែលមានការចុះបញ្ជីគ្រួសារនៅសៀងហៃ។ និន្នាការនេះនឹងបន្តកើនឡើងថែមទៀត។ បច្ចុប្បន្ន រដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងដើម្បីផ្តល់ឱកាសស្មើៗគ្នាដល់កុមារពិសេសសម្រាប់គ្រួសារចំណាកស្រុក និងគ្រួសារកសិករ។ វាជាអ្វីដែលហៅថា ការអប់រំសម្រាប់ទាំងអស់គ្នា មិនមែនមានន័យថាសម្រាប់កុមារដែលចុះបញ្ជីស្នាក់ការផ្លូវការនៅក្រុងសៀងហៃ តែ

សម្រាប់កុមារទាំងអស់នៅក្រុងសៀងហៃ រួមបញ្ចូលកុមារមកពីគ្រួសារចំណាកស្រុកផងដែរ។ វាជាបញ្ហាសិទ្ធិមនុស្ស។

- នៅមានបញ្ហាប្រឈមធ្ងន់ធ្ងរមួយទៀតដែលទាក់ទងនឹងប្រព័ន្ធកត់ត្រាស្ថិតិខ្នងផ្ទះ(Hukou) របស់ប្រទេសចិនដែលជាគោលនយោបាយតម្រូវឱ្យប្រជាពលរដ្ឋចិនទាំងអស់ត្រូវចុះបញ្ជីនៅក្នុងខេត្តជាក់លាក់មួយ ហើយមិនមានសិទ្ធិទទួលបានសេវាកម្មរបស់ខេត្តណាមួយផ្សេងទៀតទេ ទោះបីជាពួកគេធ្វើការនៅទីនោះពេញម៉ោងក៏ដោយ។ ការអប់រំគឺជាសេវាកម្មមួយក្នុងចំណោមសេវាកម្មទាំងនោះ។ ក្រោមច្បាប់វិន័យនេះកុមារដែលមានចំណេះដឹងតិចតួចនិងមិនមានចំណេះដឹងដែលមកធ្វើការនៅសៀងហៃមិនមានសិទ្ធិចូលសាលារៀនសាធារណៈនៅសៀងហៃឡើយ។ វានាំមកនូវការអប់រំដែលមិនមានលក្ខណៈសមធម៌ អយុត្តិធម៌ សិស្សមិនអាចឆ្លងភូមិសិក្សាបានខុសពីកម្ពុជា។ ការធ្វើបែបនេះ ជំរុញឱ្យមានការប្រកួតប្រជែងទាំងកម្រិតសាលារៀនឡើងទៅ។ គោលនយោបាយកំណត់ត្រាច្បាស់លាស់តាមខ្នងផ្ទះប៉ះពាល់ដល់ជនចំណាកស្រុកភាគច្រើនរាប់រយលាននាក់ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងសង្គមចិនទំនើបទទួលរងភាពអយុត្តិធម៌ និងការឈឺចាប់។ វាជារំលោភសិទ្ធិមនុស្សជាមូលដ្ឋាន។
- កូនរបស់ជនចំណាកស្រុកទាំងអស់នោះ ជាកម្លាំងពលកម្មដ៏សំខាន់ពេលអនាគត បើពួកគេមិនទទួលបានការអប់រំដែលស្តង់ដារដូចគ្នានាំឱ្យមានហានិភ័យសម្រាប់សេដ្ឋកិច្ចនាពេលខាងមុខផងដែរ។

### 5.3)-ប្រព័ន្ធការអភិវឌ្ឍគ្រូបង្រៀននៅក្រុងសៀងហៃ (២)

ប្រព័ន្ធអភិវឌ្ឍគ្រូបង្រៀននៅសៀងហៃមាន៣សមាសភាពគឺៈ ការតំលើងឋានន្តរសក្តិ អភិវឌ្ឍន៍ និងបណ្តុះបណ្តាលគ្រូបង្រៀនក្នុងប្រព័ន្ធ និងការវាយតម្លៃការងាររបស់គ្រូបង្រៀន។ ឋានន្តរសក្តិគ្រូបង្រៀនជាការផ្តល់ប្រាក់លើកទឹកចិត្ត និងការតំលើងឋានន្តរសក្តិអាជីពកាន់តែខ្ពស់។ (កម្ពុជាៈ យន្តការនេះ អាចធ្វើឱ្យគ្រូផ្លាស់ការងារខ្លួនតាមជំនាញ និងឧបនិស្ស័យ ទឹក

ចិត្តក្នុងការស្វែងរកចំណេះដឹង បទពិសោធថ្មីៗ ជៀសវាងការធ្វើការងារដដែលធុញ និងសុញ)។ ការបណ្ដុះបណ្ដាលគ្រូបង្រៀនដែលកំពុងបំពេញការងារដើម្បីអភិវឌ្ឍន៍សមត្ថភាពឆ្លើយតបទៅនឹងគន្លងអាជីព ហើយកាលណាសមត្ថភាពគាត់ត្រូវបានលើកកម្ពស់ គាត់នឹងដើរតាមគន្លងអាជីពបានល្អ។ ប្រព័ន្ធវាយតម្លៃការបំពេញការងារគឺវាយតម្លៃ និងផ្ដល់ការលើកទឹកចិត្តដល់គ្រូបំពេញការងារទៅតាមដំណាក់កាលនៃគន្លងអាជីពរបស់ខ្លួន។ ការឡើងពីមួយកាំទៅមួយកាំនៃគន្លងអាជីពសុទ្ធតែឆ្លងកាត់ការវាយតម្លៃការបំពេញការងារទាំងអស់។ ប្រព័ន្ធទាំងបីនេះ ប្របាច់ចូលគ្នាក្នុងគោលបំណងលើកទឹកចិត្ត និងផ្ដល់រង្វាន់ដល់អាជីពគ្រូបង្រៀនទាំងមូល។

**១)ឋាន្តរសក្តិអាជីពគ្រូបង្រៀន[២]**

យន្តការនេះចាប់ផ្តើមនៅចុងខែឆ្នាំ១៩៨០ និងមានការកែសម្រួល៣-៤ដងមកដល់បច្ចុប្បន្ននេះ។ បច្ចុប្បន្ននេះមាន១៣កម្រិតដោយដាក់បន្ថែមថ្មីៗនូវកម្រិតសាស្ត្រាចារ្យ ដែលផ្តល់ឱកាសដល់គ្រូបង្រៀននៅមហាវិទ្យាល័យ។ នៅពេលដែលគ្រូផ្លាស់ប្តូរឋាន្តរស័ក្តិកាន់តែខ្ពស់ ការទទួលខុសត្រូវរបស់គាត់ក៏កាន់តែធំផងដែរដូចជាក្លាយជាគ្រូណែនាំ ឬគ្រូឧទ្ទេសសម្រាប់គ្រូបង្រៀនផ្សេងទៀត។ ឋាន្តរសក្តិសម្រាប់នាយកសាលាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩០ដែលមាន៥កម្រិត។ នាយកសាលាទាំងអស់ត្រូវតែជាគ្រូឆ្នើម និងមានស្នាដៃការងារល្អ ហើយទោះបីជាត្រូវបានគេតែងតាំងធ្វើនាយកហើយក៏ដោយ ក៏គេតម្រូវឱ្យបន្តការបង្រៀនដែរ។ គ្រូបង្រៀន និងនាយកសាលាអាចឡើងកម្រិតឋាន្តរសក្តិបានសុទ្ធតែ ឆ្លងកាត់ការវាយតម្លៃលទ្ធផលបំពេញការងារ ការវាយតម្លៃភាពពេញចិត្តនៃការចូលរួមវគ្គបណ្តុះបណ្តាល សកម្មភាពស្រាវជ្រាវ ការបំពេញការងារជាគ្រូណែនាំ និងគ្រូឧទ្ទេសប្រកបដោយជោគជ័យ ការចំណាយពេលវេលាជួយសាលារៀនផ្សេងៗទៀតនៅតំបន់ជនបទ។

**២)ការអភិវឌ្ឍ និងការបណ្ដុះបណ្ដាលគ្រូបង្រៀនក្នុងប្រព័ន្ធ[២]**

ការបណ្តុះបណ្តាលគ្រូបង្រៀនដែលកំពុងបំពេញការងារប្រៀប ដូចជាជំរកាសម្រាប់បិទប្រព័ន្ធទាំងបីនេះឱ្យជាប់គ្នា។ គ្រូបង្រៀនត្រូវចូល រួមហ្វឹកហាត់វិជ្ជាជីវៈរយៈពេល១ឆ្នាំពេញមុនពេលទទួលស្គាល់ជាគ្រូបង្រៀ ន។ អំឡុងពេលចូលរួមហ្វឹកហាត់ គេត្រូវចូលរួមវគ្គបណ្តុះបណ្តាល១២០ ម៉ោងដែលផ្តល់ដោយគ្រូណែនាំជាន់ខ្ពស់ដែលមានឯកទេសបណ្តុះបណ្តា ល។ គ្រូណែនាំត្រូវចំណាយពេលក្រៅពីម៉ោងបង្រៀនរបស់ខ្លួនសម្រាប់ ការងារបណ្តុះបណ្តាលនេះ។ ការងាររបស់គ្រូណែនាំ ត្រូវបានគេវាយតម្លៃ ហើយខ្លួនគាត់ផ្ទាល់ក៏ចូលរួមវាយតម្លៃគ្រូបង្រៀនចេញថ្មីដែរ។ នៅពេល ទទួលស្គាល់ គ្រូបង្រៀននៅសៀងហៃតម្រូវឱ្យចូលរួមវគ្គបណ្តុះបណ្តាល ហើយប្រធានបទនៃវគ្គបណ្តុះបណ្តាលគ្រូជាសម្រេចជ្រើសរើសដោយខ្លួន ឯងក្រោមការប្រឹក្សាយោបល់ជាមួយនាយកសាលា។ នៅតាមសាលារៀន មានការបង្កើតក្រុមអភិវឌ្ឍន៍វិជ្ជាជីវៈផ្អែកលើមូលដ្ឋានសាលារៀន ហើយត្រូវ បានបែងចែកជាបីប្រភេទគឺ៖ (១)ក្រុមស្រាវជ្រាវ និងបង្រៀន (២)ក្រុម រៀបចំ មេរៀន និង(៣)ក្រុមមានកម្រិតថ្នាក់ដូចគ្នា។ ក្រុមទាំងនេះ រៀបចំ មេរៀន អង្គុយធ្វើការជាមួយគ្នា និងវាយតម្លៃថ្នាក់រៀន ចែករំលែកបទ ពិសោធអប់រំ ពិភាក្សាពីបញ្ហាបង្រៀន អនុវត្តសកម្មភាពស្រាវជ្រាវស្តីបញ្ហា នៅក្នុងសាលារៀនរបស់គេ និងរៀនពីបច្ចេកវិទ្យា និងជំនាញបង្រៀនថ្មី។ ពេលវេលាចាំបាច់អំឡុងពេលថ្ងៃគឺការប្រជុំ។ គ្រូបង្រៀនក៏ចំណាយចូលរួម ការបណ្តុះបណ្តាលពីខាងក្រៅដែរដូចជា សិក្ខាសាលា ឬវគ្គសិក្សាជាក់លាក់ មួយដែលសម្រេចចិត្តរួមគ្នាជាមួយនាយកសាលា។ សូម្បីតែគ្រូបង្រៀន និង នាយកជាន់ខ្ពស់ក៏ត្រូវបានគេរៀបចំឱ្យមានការបណ្តុះបណ្តាលបន្ថែមជា ប្រចាំដែរដើម្បីប្រែក្លាយសាលារៀនមួយក្លាយជាគំរូ ជួនកាលបញ្ជូនទៅរៀន នៅបរទេសថែមទៀត។

**៣)ការវាយតម្លៃការបំពេញការងារ[២]**

ប្រព័ន្ធវាយតម្លៃការបំពេញការងារត្រូវភ្ជាប់គ្នានឹងគន្លងអាជីព និងការបណ្តុះបណ្តាលក្នុងប្រព័ន្ធ។ គណៈកម្មការអប់រំក្រុងសៀងហៃបាន

រៀបចំក្រុមខណ្ឌការងារវាយតម្លៃនាយក និងគ្រូបង្រៀនប្រចាំឆ្នាំ ប៉ុន្តែនាយកសាលា និងគ្រូបង្រៀនមានអំណាចពេញលេញក្នុងការអនុវត្ត និងប្រើប្រាស់លទ្ធផលរបស់ការវាយតម្លៃនេះ។ គ្រូបង្រៀនត្រូវបានគេវាយតម្លៃចរិយាមាយាទ មនសិការការងារ ចំណេះដឹងការងារ ការបណ្តុះបណ្តាលក្នុងប្រព័ន្ធ ការសិក្សាស្រាវជ្រាវ បន្ទុកការងារ គុណភាពនៃការបង្រៀន និងសមត្ថភាពក្នុងណែនាំគ្រូថ្មី។ គន្លងអាជីពជាស្តង់ដារវិជ្ជាជីវៈ សម្រាប់គ្រូបង្រៀន និងនាយកសាលាដែលមាននៅក្នុងការវាយតម្លៃការបំពេញការងារ។ ពិន្ទុវាយតម្លៃ៥០%គឺទាក់ទងនឹងមនសិការការងារគ្រូបង្រៀន និងការបង្រៀនដែលត្រូវបានវាយតម្លៃដោយសាលារៀន ហើយ៥០%ទៀតទាក់ទងនឹងសមិទ្ធផលស្រាវជ្រាវ ការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួន និងឥទ្ធិពលដែលត្រូវបានវាយតម្លៃដោយអ្នកជំនាញស្រុកនីមួយៗ។ មានប្រព័ន្ធចំណាយផ្អែកលើការបំពេញការងារដែលភ្ជាប់ទៅនឹងការវាយតម្លៃដែលប្រាក់បៀវត្ស( ៧០%នៃបៀវត្សសរុប )ដែលឆ្លុះបញ្ចាំងពីការចំណាយសម្រាប់ការរស់នៅ ចំនួនឆ្នាំនៃការបំពេញការងារ កម្រិតទទួលខុសត្រូវ និងប្រាក់បៀវត្សផ្អែកលើការបំពេញការងារ( ៣០%នៃបៀវត្សសរុប )រៀបចំដោយសាលារៀនដោយសហការជាដៃគូជាមួយសម្ព័ន្ធ។

# VI. លទ្ធផល PISAទាប! ហេតុអ្វីនៅដែលធ្វើឲ្យអ៊ីស្រាអែលអាចជាប់ចំណាត់ថ្នាក់លេខ២ជាកន្លែងដ៏ល្អបំផុតសម្រាប់ការច្នៃប្រឌិត ?

*ដកស្រង់ពីអត្ថបទប្រែសម្រួល៖ ស្រីពៅ*

**ទិន្នន័យប្រចាំឆ្នាំ២០១៦ដល់ឆ្នាំ២០១៧របស់វេទិកាសេដ្ឋកិច្ចពិភពលោក ឬ WEF បានចង្អុលបង្ហាញថា ប្រទេសអ៊ីស្រាអែលបានជាប់ចំណាត់ថ្នាក់លេខ ២ ជាទីកន្លែងដ៏ល្អបំផុតនៅលើពិភពលោកសម្រាប់ការច្នៃប្រឌិត។ ជាប្រទេសនាំមុខមួយនៅក្នុងវិស័យបច្ចេកវិទ្យា នៅក្នុងចំណោមប្រជាជនសរុបជាង៨លាននាក់ តួលេខប្រមាណ៣,០០០គឺជាក្រុមហ៊ុនបច្ចេកវិទ្យារបស់អ៊ីស្រាអែល ហើយក៏មានមនុស្សតិចតួចណាស់ដែលដឹងថា ១នៅក្នុងចំណោមបច្ចេកវិទ្យាដំណោះស្រាយបញ្ហាជីវិតចំនួន៤ មិនថាជាការរកឃើញឱសថព្យាបាលមហារីក និងរោគបេះដូងជាដើម សុទ្ធតែមានឫសគល់ចេញមកពីអ្នកស្រាវជ្រាវអ៊ីស្រាអែល។**

នរណាក៏ដឹងពីការពិតរបស់ប្រទេសក្មេងខ្ចីមួយនេះ ដែលធ្លាប់ឆ្លងកាត់ប្រវត្តិសាស្ត្របាត់បង់ទឹកដីអស់រយៈពេលកន្លងយូរមកហើយ ទើបនឹងមានមុខមាត់នៅក្នុងប្រវត្តិសាស្ត្រពិភពលោកវិញនៅក្នុងឆ្នាំ១៩៤៨ បានខិតខំកសាងប្រទេសខ្លួនពីបាតដៃទទេរហូតក្លាយមកជាប្រទេសដែលតូចតែខ្លឹមដែលអាចយកឈ្នះគេស្ទើរតែគ្រប់សសរគ្រឹះសំខាន់ៗដែលទ្រទ្រង់ប្រទេសជាតិ។ យើងក៏ចង់ដឹងថា តើអ៊ីស្រាអែលកសាងធនធានមនុស្សរបស់ពួកគេដោយរបៀបណា ?

សមិទ្ធផលរបស់អ៊ីស្រាអែលជាប្រទេសដ៏ល្អបំផុតទី២ក្នុងការច្នៃប្រឌិត រួមជាមួយនឹងស្មារតីរបស់ពួកគេជាអ្នកជំនួញ អាចជាកញ្ចក់ឆ្លុះបញ្ចាំងពី

សមត្ថភាពដ៏ឈ្លាសវៃរបស់ពួកគេនៅក្នុងផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រ ដែលជាជីពចរដ៏សំខាន់នៅក្នុងភាពជឿនលឿននៃការច្នៃប្រឌិត និងការធ្វើជំនួញ។ យ៉ាងណាមិញ នៅក្នុងរបាយការណ៍ពីកម្មវិធីសម្រាប់វាយតម្លៃសិស្សជាអន្តរជាតិ ឬ PISA សិស្សអ៊ីស្រាអែលទទួលបានតែ៤០%ទៅលើមុខវិជ្ជាផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រតែប៉ុណ្ណោះ។ តើពួកគេអាចក្លាយជាប្រទេសដែលមានបច្ចេកវិទ្យាជឿនលឿនប្រកួតជាមួយពួកមហាអំណាចខាងលិចដូចម្តេចបាន បើពួកគេមិនមានសមត្ថភាពខ្ពស់ក្នុងចំណេះដឹងដែលជាគ្រឹះមូលដ្ឋានដើម្បីជោគជ័យផ្នែកនេះផង ? ដូច្នេះតើប្រព័ន្ធអប់រំរបស់អ៊ីស្រាអែលមានលក្ខណៈខុសប្លែកពីគេដូចម្តេចវិញ ?
ប្រព័ន្ធអប់រំស្តង់ដារដែលគេទទួលស្គាល់ជាផ្លូវការនៅលើសកលលោក បង្រៀនសិស្សពីផ្លូវជាក់លាក់មួយដែលត្រូវដើរដើម្បីឆ្ពោះទៅដល់ចម្លើយសម្រាប់បញ្ហាអ្វីមួយ។ គ្រប់សិស្សទាំងអស់ត្រូវតែចេះស្ទាត់ជំនាញ និងដឹងគ្រប់សព្វទៅលើចំណេះដឹងដែលមាននៅក្នុងប្រព័ន្ធអប់រំដែលបានកំណត់មកស្រាប់នោះ។ ពួកគេត្រូវតែធ្វើតាមបែបនេះឬបែបនោះដោយឥតមានការសង្ស័យឡើយ។

ដោយឡែក ការលើកទឹកចិត្តសិស្សឲ្យគិតក្រៅប្រអប់គឺជាលក្ខណៈដ៏ពិសេសមួយរបស់ប្រព័ន្ធអប់រំអ៊ីស្រាអែល។ គ្រូបង្រៀន គ្រាន់តែបង្រៀនចំណេះដឹងមូលដ្ឋានដល់ពួកគេប៉ុណ្ណោះ បន្ទាប់មកនឹងឲ្យពួកគេចេះដោះស្រាយបញ្ហាលំបាកៗ រុញពួកគេឲ្យជាប់គាំងនៅក្នុងបញ្ហា រួចរៀនរកដំណោះស្រាយដោយខ្លួនឯង។ នៅពេលពួកគេព្យាយាមរកផ្លូវចេញពីចំណោទបញ្ហា ពួកគេនឹងបានរៀនអ្វីថ្មីមួយមិនខាន។ អ្វីដែលសំខាន់គឺស្ថិតនៅលើថាតើពួកគេចេះអ្វីមួយដោយរបៀបណា ពុំមែនត្រឹមតែអ្វីដែលពួកគេចេះនោះទេ។

សិស្សអ៊ីស្រាអែលប្រហែលជាមិនមានចំណេះដឹងជាក់លាក់ ដែលមានលក្ខណៈងាប់ក្រឡា អាចដោះស្រាយបានតែក្នុងស្ថានភាពជាក់លាក់មួយនោះទេ ដែលជាមូលហេតុមួយធ្វើឲ្យពួកគេធ្វើមិនបានល្អនៅក្នុងតេស្តរបស់ PISA។ ការគិតក្រៅប្រអប់បែបនេះនឹងបង្រៀនពួកគេឲ្យចេះប្រើប្រាស់អ្វីដែលពួកគេចេះ យកទៅប្រើប្រាស់នៅក្នុងស្ថានភាពផ្សេងពីគ្នាបាន។ ពួកគេក៏បានបង្កើតកម្មវិធីសិក្សាក្រៅប្រព័ន្ធអប់រំទៅលើវិទ្យាសាស្ត្រកុំព្យូទ័រ និងការចេះប្រើប្រាស់អ៊ីនធឺណិត ដែលផ្តល់ចំពោះសិស្សគ្រប់គ្នាចាប់ពីអាយុ១២ឆ្នាំដល់១៨ឆ្នាំ។ គ្រូគ្រាន់តែបង្រៀនទៅលើចំណេះដឹងមូលដ្ឋានអំពីការសរសេរកូដ បន្ទាប់មកសិស្សនឹងត្រូវរៀនដោះស្រាយលំហាត់លំបាកៗដូចជាបង្កើតហ្គេមអុក ដោយពុំមាននរណាចាំប្រាប់ពីរបៀបធ្វើនោះឡើយ។ អ្វីដែលកាន់តែគួរឲ្យលើកសរសើរពីរបៀបដែលអ៊ីស្រាអែលបណ្តុះទំពាំងរបស់ពួកគេទៅទៀតនោះគឺជាការជំរុញសិស្សឲ្យជួបបទពិសោធន៍នូវភាពបរាជ័យ។ Adi Sharabani ជាគ្រូបង្រៀនអ៊ីស្រាអែលមួយបាននិយាយថា៖ "**បើអ្នកអាចដោះស្រាយលំហាត់ចំនួន២០បានសម្រេច ខ្ញុំដែលជាគ្រូបង្រៀនកំពុងតែបង្ខាតពេលវេលាអ្នកហើយ។ ក៏ព្រោះតែអ្នកដឹងថាត្រូវដោះស្រាយលំហាត់ទាំងនោះដូចម្តេចហើយ ដូច្នេះអ្នកនឹងមិនបានអភិវឌ្ឍអ្វីតទៅមុខទៀតនោះទេ ហើយអ្នកក៏មិនបានរៀនអ្វីទាំងអស់**"។

ក្រៅពីនេះ អ៊ីស្រាអែលក៏ជាប្រទេសមួយដែលសម្បូរទៅដោយជនអន្តោប្រវេសន៍ចម្រុះជាតិសាសន៍ ដែលភាពខុសប្លែកគ្នានេះបានជំរុញឲ្យមានភាពច្នៃប្រឌិត បានរួមគ្នាឆ្លើយនឹងសំណួរថា ហេតុអ្វីអ៊ីស្រាអែលជាប្រទេសដែលឈានមុខគេទៅលើការច្នៃប្រឌិត។

## VII- ហេតុអ្វីវៀតណាមមានភាពលេចធ្លោខ្លាំងលើលទ្ធផលតេស្ត PISA អន្តរជាតិ?



វាមិនមែនចៃដន្យឡើយដែលក្រុមហ៊ុនបច្ចេកវិទ្យាល្បីៗនៅលើពិភពលោករបស់អាមេរិក កូរ៉េ ជប៉ុន និងប្រទេសរីកចម្រើនដទៃចូលទៅវិនិយោគនៅក្នុងប្រទេសវៀតណាម ក្នុងនោះមានក្រុមហ៊ុនធំៗដូចជា Intel, Samsung និងប៊ូអីញជាដើម។ សួនឧស្សាហកម្មផ្នែកបច្ចេកវិទ្យាជាច្រើនត្រូវបានបង្កើត និងផ្តល់ការងាររាប់ម៉ឺនសែននាក់ដល់យុវជនពេញកម្លាំងរបស់វៀតណាមដែលកាលានុវត្តភាពមួយក្នុងការធ្វើឱ្យប្រទេសមួយនេះរីកចម្រើនខ្លាំងនៅអាស៊ីអាគ្នេយ៍។ តើកត្តាអ្វីដែលធ្វើឱ្យក្រុមហ៊ុនទាំងនោះចូលចាប់អារម្មណ៍មកវិនិយោគនៅទៅទីនេះ? ជាការពិតស្ថានភាពនេះ គឺវាបណ្តាលមកពីសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងប្រទេសចិន ដែលធ្វើឱ្យក្រុមហ៊ុនជាច្រើនបានចាកចេញពីប្រទេសចិន មកបង្កើតរោងចក្រនៅ

ប្រទេសផ្សេងៗដែលមានកម្លាំងពលកម្មទាប តួយ៉ាងដូចប្រទេសវៀតណាមជាដើម។ អ្វីដែលសំខាន់លើសពីតម្លៃពលកម្មទាបទៅទៀតនោះ គឺធនធានមនុស្សដែលមានចំនួនគ្រប់គ្រាន់ និងមានជំនាញវិជ្ជាជីវៈខ្ពស់សមស្របទៅនឹងតម្រូវការទីផ្សារការងារ ពិសេសលើជំនាញបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ។ លទ្ធផលតេស្ត PISA ខ្ពស់របស់វៀតណាម ជាគន្លឹះដ៏សំខាន់ក្នុងការចូលរួមចំណែកទាក់ទាញវិនិយោគិនទាំងអស់នោះឱ្យមកវិនិយោគនៅក្នុងប្រទេសវៀតណាម។ ជាការពិតមិនអាចប្រកែកបាន វៀតណាមបានត្រៀមលក្ខណៈបានយ៉ាងល្អបំផុត ក្នុងការឆក់យកឱកាសមាសមួយនេះពោលគឺតាំងពីមុនឆ្នាំ២០១២មកម្លេះ។ និយាយរួម ប្រព័ន្ធអប់រំប្រទេសវៀតណាមដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេចបាននូវគោលដៅធំៗក្នុងការអភិវឌ្ឍន៍ជាតិឱ្យរីកចម្រើនខ្លាំង និងឆាប់រហ័ស។ ប្រទេសវៀតណាមចូលរួម PISA លើកដំបូងនៅឆ្នាំ២០១២ប៉ុន្តែការបំពេញរបស់វៀតណាមគឺខ្ពស់ជាងប្រទេសកំពុងអភិវឌ្ឍមួយចំនួនដែលបានចូលរួម។ មានប្រទេសកំពុងអភិវឌ្ឍន៍តិចតួចប៉ុណ្ណោះដែលចូលរួមក្នុងកម្មវិធីនេះ ហើយប្រហែលជាប្រទេសទាំងនោះ មានលទ្ធផលតេស្តទាបជាងឆ្ងាយពីប្រទេសដែលជាសមាជិកអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD)។ មានប្រទេសចំនួន៧ផ្សេងទៀតពីវៀតណាមដែលមានផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ (GPP per Capita) ទាបជាងមួយម៉ឺនដុល្លារ (១0,000ដុល្លារ) ក៏បានចូលរួមជាមួយកម្មវិធីនេះដែរ។ ប្រទេសទាំងនោះមាន៖ អាល់បានី កូឡុំប៊ី ឥណ្ឌូនេស៊ី ស៊ូដង់ ប៉េរូ ថៃឡង់ និងទុយនេស៊ី។ ក្នុងចំណោមប្រទេសដែលមានផ.ស.សក្នុងមនុស្សម្នាក់ទាបនេះ

ប្រទេសវៀតណាមទាបជាងគេគឺមានតែ៤ ០៩៨ដុល្លារ ប៉ុណ្ណោះ (GPP in PPP 2010)។ លទ្ធផល PISA បង្ហាញថា ប្រទេសវៀតណាមទទួលបានលទ្ធផលខ្ពស់ជាងប្រទេសកំពុងអភិវឌ្ឍន៍ទាំង៧នេះលើផ្នែកវិទ្យាសាស្ត្រ និងសមត្ថភាពអំណាន។ តើអ្វីចំណុចលេចធ្លោដែលធ្វើលទ្ធផលរបស់វៀតណាមខ្ពស់ជាងគេ? **ខាងក្រោម កត្តាសំខាន់ៗដែលធ្វើឱ្យវៀតណាមទទួលបានលទ្ធផលល្អជាងប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត។**



- ភាគរយកុមារចូលរៀនមត្តេយ្យសិក្សាខ្ពស់ ប្រមាណ ៩១.២០% ចំណែកប្រទេសកំពុងអភិវឌ្ឍន៍ទាំង០៧ផ្សេងទៀតមានត្រឹមតែ ៧៨,៨៨%
- អត្រារៀនត្រួតថ្នាក់នៅវៀតណាមតិចជាងបីដងនៃប្រទេសទាំង៧ (៦.៧៩% និង១៩.១៥%)

- ការរកឃើញទាក់ទងនឹងលទ្ធភាពកុមារទទួលការអប់រំនៅមត្តេយ្យសិក្សា និងអត្រារៀនត្រួតថ្នាក់ បានបញ្ជាក់ពីសារៈសំខាន់ពីគន្លងផ្លូវសម្រាប់សិស្សឈានឆ្ពោះទៅមុខ មុនពេលចូលរៀននៅវិទ្យាល័យ។ ជាការពិតអត្រារៀនត្រួតថ្នាក់របស់សិស្ស វាពិតពិបាកក្នុងការយកវាមកធ្វើជាសូចនាករប្រៀបធៀបទៅលើគុណភាពប្រព័ន្ធអប់រំរបស់ប្រទេសមួយ និងប្រទេសមួយទៀតពីព្រោះវាមានការប្រែប្រួលទៅតាមកម្មវិធីសិក្សា និងស្តង់ដារប្រទេសនីមួយៗ។ ឧទាហរណ៍ បើប្រទេសមួយកំណត់លទ្ធផលសិក្សារបស់សិស្ស និងកម្រិតស្តង់ដារខ្ពស់នាំឱ្យសិស្សធ្លាក់ច្រើន។ ទោះបីជាយ៉ាងណា អត្រាត្រួតថ្នាក់នេះ ជាការប្រែប្រួលគួរឱ្យចាប់អារម្មណ៍របស់វៀតណាម និងអាចជាភស្តុតាងដែលបញ្ជាក់ពីលទ្ធផលល្អរបស់វៀតណាមសម្រាប់សមត្ថភាពអំណាន។
- ដូចវប្បធម៌ប្រទេសទាំងឡាយនៅអាស៊ីខាងកើតផ្សេងទៀតដែរ ដូចជា៖កូរ៉េ តៃវ៉ាន់ និងជប៉ុនជាដើម ឪពុកម្តាយ និងអាណាព្យាបាលវៀតណាមការរំពឹងទុកខ្ពស់ការខិតខំសិក្សារៀនសូត្ររបស់កូន។ ពួកគេមានជំនឿមុតមាំលើការសិក្សា ដែលផ្លូវនាំជីវិតកូនគាត់ទៅរកភាពជោគជ័យ និងចូលរួមចំណែកដ៏សកម្មក្នុងការគាំទ្រការសិក្សារបស់ពួកគេ។
- ដើម្បីធ្វើការវិភាគឱ្យបានស៊ីជម្រៅ គេធ្វើការសិក្សាប្រៀបធៀបរវាងប្រទេសកំពុងអភិវឌ្ឍន៍ទាំង៧ និងប្រទេសវៀតណាមតាមរយៈ ការសិក្សាពីបុគ្គលិកលក្ខណៈរបស់សិស្ស និងកត្តាជះឥទ្ធិពលពីខាងក្រៅដូចជា៖ ស្ថានភាព និងប្រវត្តិឪពុកម្តាយជាដើម។ ជាលទ្ធផលបាន

បង្ហាញថាៈ (១) សិស្សវៀតណាមមានអត្រាគេចសាលា ឬអវត្តមានពីសាលាទាបជាងប្រទេសកំពុងអភិវឌ្ឍន៏ទាំង ៧ (មធ្យមភាគសម្រាប់វៀតណាម០.៣៦៣ ហើយប្រទេសកំ.៧ មាន ០.៥២៥)។ នេះបញ្ជាក់ថា សិស្សវៀតណាមមានការទំនួលខុសត្រូវលើខ្លួនឯងខ្ពស់លើការសិក្សារៀនសូត្រ។ (២)ផ្តោតលើប្រវត្តិ និងទ្រព្យធនរបស់ឪពុកម្តាយធនជានវប្បធម៌ និងសៀវភៅសិក្សានៅផ្ទះដែលជាផ្នែកដ៏សំខាន់ក្នុងការលើកទឹកចិត្ត និងអភិវឌ្ឍន៍សតិប្រាជ្ញា។ អាជីពវិជ្ជាជីវៈឪពុកម្តាយរបស់ប្រទេសកំ៧ ខ្ពស់ជាងវៀតណាម (ប្រទេសកំ.៧ មាន ៤០.៤២ ប្រទេសវៀតណាម ២៦.៦០)។ បើយោងតាមការបែងចែកចំណាត់ថ្នាក់ស្តង់ដារអន្តរជាតិនៃការអប់រំ (the International Standard Classification of Education=ISCED)ដែលរៀបចំដោយអង្គការ UNESCO ទិន្និន័យបានបង្ហាញថា កម្រិតធម្យមភាគនៃការអប់រំម្តាយសម្រាប់ប្រទេសកំ.៧ ខ្ពស់ជាងវៀតណាម។ ប្រទេសកំ.៧ ទទួលបានពិន្ទុលើ ៣ ដែលមានន័យថាម្តាយបានស្ថិតក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ ចំណែកឯវៀតណាមមានពិន្ទុ ២ មានន័យថាកម្រិតអប់រំរបស់ម្តាយស្ថិតនៅក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ។ ចំណុចទ្រព្យធនរបស់ឪពុកម្តាយត្រូវបានកំណត់ដោយមធ្យមនៃសូន្យ "0" (Mean of 0) និងគម្លាតគំរូ នៃមួយ"១" (Standard deviation of 1) ដែលជាបែបផែននៃស្ថិតិ (Statistic) របស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD)។ កម្រិតទ្រព្យធនរបស់ប្រទេសកំ.៧ គឺ-១.៥ ហើយប្រទេសវៀតណាមគឺ-២.១ ដែលតួលេខនេះ វាស៊ីគ្នានឹងទិន្និ

ន័យទាក់ទងនឹងការបែងចែកអាជីពការងារឪពុកម្តាយ និងកម្រិតអប់រំរបស់ម្តាយ។ ការរកឃើញទាំងនេះ បង្ហាញថា អន្តរទំនាក់ទំនងជិតស្និទ្ធនៃទិន្និន័យទាំងឡាយខាងលើ និងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់។ ការរកឃើញគួរឱ្យចាប់អារម្មណ៍មួយទៀតគឺ មរតកវប្បធម៌ (CULTPOS) និងធនធានអប់រំនៅផ្ទះ (HEDRES) ព្រមទាំងចំនួនសៀវភៅសម្រាប់សិក្សារៀនសូត្រនៅផ្ទះ(BOOK N)។ មរតកវប្បធម៌ មានដូចជា៖អក្សរសិល្ប៍បុរាណ សៀវភៅកំណាព្យ និងការងារសិល្បៈ។ ធនធានអប់រំនៅផ្ទះសំដៅលើសៀវភៅដែលអាចប្រើប្រាស់ជាឯកសារយោង និងសៀវភៅទាំងឡាយណាដែលជួយសិស្សធ្វើកិច្ចការសាលា និងការអានបង្កើនចំណេះដឹង។ ចំណុចរកឃើញទាំងបីខាងលើ វាត្រូវតែដើរស្របគ្នាជាមួយនឹងប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ៗ។ ជាការពិត តួលេខបានបង្ហាញថា ប្រទេសកំ.៧ មាន ផ.ស.ស (GDP) សម្រាប់មនុស្សម្នាក់កម្រិតទាបជាងប្រទេសសមាជិកអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍ ហើយប្រទេសវៀតណាមមានកម្រិតទាបជាងប្រទេសកំ.៧។ ទាក់ទងនឹងចំណុចនេះ វានាំឱ្យមានចម្ងល់ថាតើហេតុអ្វីបានជា វាមិនសុីគ្នារវាងលទ្ធផល PISA ដែលប្រទេសវៀតណាមទទួលបាន និងប្រទេសកំ.៧ទៀតទទួលបាន បើប្រទេសទាំងនេះ មានផសស(GDP) សម្រាប់មនុស្សម្នាក់ខ្ពស់ជាងវៀតណាម ហើយការចំណាយរបស់គ្រួសារវៀតណាមលើធនធានសិក្សារបស់កូនតិចជាងនោះ?

# ផ្នែកទី២

## សាលារៀនស្តង់ដារលំដាប់ខ្ពស់ (កម្រិតអន្តរជាតិ)

ផ្នែកនេះអ្នកនិពន្ធធ្វើការសាកល្បងបកស្រាយបង្ហាញពីស្តង់ដារសាលារៀនលំដាប់អន្តរជាតិដែលផ្តល់សេវាអប់រំកម្រិតគុណភាពខ្ពស់ក្នុងការផលិតមូលធនមនុស្សដែលសមត្ថភាពពេញលេញគ្រប់គ្រាន់សម្រាប់ប្រឡូកនឹងការងារនៅសតវត្សរ៍ទី២១នេះ។ ការបកស្រាយនេះសោតគឺផ្អែកតាមការបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ និងបទពិសោធការងារផ្ទាល់ខ្លួនមួយចំនួនតែប៉ុណ្ណោះដោយមិនមានដាក់បញ្ចូលប្រភពឯកសារយោងច្បាស់លាស់ណាមួយឡើយ។ គោលបំណងនៃការបកស្រាយនេះ ដើម្បីឱ្យអ្នកអាន-អ្នកសិក្សាទាំងអស់ ពិសេសអ្នកដែលធ្វើការងារក្នុងវិស័យអប់រំទាំងផ្នែកឯកជន និងគ្រឹះស្ថានសិក្សាសាធារណៈស្វែងយល់ពីស្តង់ដារផ្តល់សេវាអប់រំ ការបង្រៀន និងរៀន របៀបរបបធ្វើការងារ និងការគ្រប់គ្រងដឹកនាំសាលារៀនដែលលំដាប់ខ្ពស់ ថាតើវាមានលក្ខណៈដូចម្តេចខ្លះ? ហើយដើម្បីងាយស្រួលក្នុងការឆ្លុះបញ្ចាំងពីចំណុចល្អ បញ្ហាប្រឈម និងមេរៀនរៀនសូត្រនានាដែលអាចយកទៅប្រើប្រាស់ក្នុងការកែលម្អ និងអភិវឌ្ឍន៍ស្ថាប័នខ្លួនឱ្យកាន់តែរីកចម្រើនថែមទៀត។ អ្នកនិពន្ធជឿជាក់យ៉ាងមុតមាំថា តាមរយៈចំណុចទាំងឡាយដែលលើកមកបង្ហាញនេះ យើងពិតជាអាចធ្វើបានដូចគេទោះក្នុងកម្រិតណាមួយក៏ដោយ ឬយ៉ាងហោចណាស់ធ្វើឱ្យអ្នកអប់រំអាចសិក្សាស្វែងយល់បានពីគន្លឹះសំខាន់ៗនៃប្រព័ន្ធអប់រំលំដាប់ខ្ពស់មួយចំនួនផងដែរ។ យើងខ្ញុំមានជំនឿថា ប្រព័ន្ធអប់រំយើងនឹងរីកចម្រើនលូតលាស់ល្អប្រសើរជាងមុន បើអ្នកអប់រំម្នាក់ៗមានឆន្ទៈ ការប្តេជ្ញាចិត្ត និងមនសិការវិជ្ជាជីវៈ

ខ្ពស់ក្នុងការកែលម្អ និងអភិវឌ្ឍធ្វើឱ្យប្រសើរឡើង។ ជាមួយគ្នានេះ អ្នកនិពន្ធក៏យល់ផងដែរថា យើងពិតជាមិនអាចធ្វើការសិក្សាប្រៀបធៀបពីគ្រឹះស្ថានសិក្សាមួយដែលទទួលបានមូលនិធិគាំទ្រច្រើន ទៅប្រៀបធៀបនឹងគ្រឹះស្ថានសិក្សាមួយទៀតដែលមានតិចតួច ហើយវាយតម្លៃបែបអន្តោម៉ត ទៅលើគុណសម្បត្តិរបស់សាលារៀនស្តង់ដារខ្ពស់ និងរិះគន់វាយប្រហារសាលារៀនស្តង់ដារទាបនោះទេ។ ជាការពិត យើងពិបាកវាយតម្លៃឱ្យបានត្រឹមត្រូវណាស់ថា ប្រព័ន្ធដឹកនាំសាលារៀនមួយល្អជាងសាលារៀនមួយទៀត ដោយមិនគិតពីកម្រិតគុណវុឌ្ឍិ អត្ថប្រយោជន៍ និងគុណតម្លៃដែលទទួលបានខុសគ្នានោះ។ យ៉ាងណាមិញ វាមិនមានន័យឡើយ បើយើងយកលទ្ធផលការងាររបស់គ្រូបង្រៀនដែលប្រាក់បៀវត្សខ្ពស់ទៅប្រៀបធៀបនឹងគ្រូបង្រៀនដែលទទួលបានតិចតួចនោះទេ ហើយទម្លាក់កំហុសដល់ពួកគាត់ទៅលើការសម្រេចលទ្ធផលការងារមិនសូវបានល្អ។ លទ្ធផលការងារវាក៏មានអន្តរទំនាក់ទំនងនឹងស្ថានភាពជីវភាពរស់នៅខុសគ្នារបស់គ្រូបង្រៀន និងអ្នកអប់រំផងដែរ ហើយការពិតគ្រូបង្រៀនដែលមានបៀវត្សទាបតែងទទួលរងឥទ្ធិពលពីកត្តាខាងក្រៅដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព និងគុណភាពនៃការបំពេញការងារ ដូចជាការបំពេញការងារស្ទួលមិនបានល្អ ដោយលៃលកពេលវេលាស្វះស្វែងរកប្រភពចំណូលបន្ថែមសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅជាដើម ឬបង្កើតការងារទីពីរថែមទៀត។ ទោះបីយ៉ាងណាក៏ដោយ ចេទនារបស់អ្នកនិពន្ធគឺមានសុទិដ្ឋិនិយមថា អ្វីដែលលើកយកមកជាទឡ្ហីករនេះ យើងអាចយកទៅអនុវត្ត និងប្រើប្រាស់បាន បើលោកគ្រូ-អ្នកគ្រូ និងថ្នាក់អប់រំគ្រប់លំដាប់ថ្នាក់មានមនសិការខ្ពស់ក្នុងការកែលម្អប្រព័ន្ធអប់រំរបស់ប្រទេសយើង។

## 1. ការងារគ្រប់គ្រង និងដឹកនាំ

- សាលារៀនលំដាប់ខ្ពស់នេះមានការរៀបចំ និងកំណត់ច្បាស់លាស់នូវទស្សនវិជ្ជា ទស្សនៈវិស័យ បេសកកម្មរួមទាំងផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ ផែនការប្រតិបត្តិ គោលនយោបាយផ្ទៃក្នុងនានាមានលក្ខណៈដោយឡែកដែលប្រើប្រាស់សម្រាប់សាលារៀននីមួយៗផ្ទាល់ និងរៀបចំគណៈកម្មការនានាដូចសាលារៀនកម្រិតធម្មតាដែរ តែខុសគ្នាត្រង់ថាអ្វីៗទាំងអស់ដែលបានបង្កើត និងរៀបចំឡើងហើយមានដំណើរការសកម្ម និងទៀងទាត់ដូចជា ការប្រជុំ និងការចូលរួមសកម្មភាពផ្សេងៗជាដើម ដោយមិនមែនគ្រាន់តែបង្កើតឱ្យតែមានៗហើយគ្មានសកម្មភាពនោះទេ។ សាលារៀនមានស្វ័យភាពក្នុងការរៀបចំគោលនយោបាយនានារបស់ខ្លួនផ្ទាល់សម្រាប់ប្រើប្រាស់ផ្ទៃក្នុងដើម្បីធ្វើឱ្យសាលារៀនមានរីកចម្រើនទៅមុខ ក្នុងនោះមានតាំងពីគោលនយោបាយគាំពារកុមារ លើកកម្ពស់សុខភាពសិក្សា ការរក្សាការសម្ងាត់ស្ថាប័ន ការប្រើប្រាស់ និងអភិវឌ្ឍន៍ភាសា នីតិវិធី និងការអនុវត្តការដាក់កិច្ចការផ្ទះដល់សិស្ស...ជាដើម។
- សាលារៀនទទួលមូលនិធិគាំទ្រគ្រប់គ្រាន់សម្រាប់ដំណើរការសាលារៀន ការបង្រៀន និងរៀន ការរៀបចំបរិស្ថានបែបកុមារមេត្រីប្រកបដោយភាពទាក់ទាញ ស្រស់ស្អាត និងសុវត្ថិភាព។ ជាទូទៅ សាលារៀនទាំងនេះយកចិត្តទុកដាក់ខ្លាំងលើសុវត្ថិភាពកុមារ សូម្បីតែម៉ោងសិស្សសម្រាកចេញលេង ក៏ពួកគេចាត់តាំងគ្រូបង្រៀន ឬបុគ្គលិកអប់រំឱ្យទទួលខុសត្រូវតាមដាន និងមើលការខុសត្រូវលើសកម្មភាពលេងកម្សាន្ត និងសម្រាករបស់សិស្សនៅក្នុងសាលារៀនផងដែរ។ ជាមួយគ្នានេះ សាលារៀនក៏មាន

ហ្វឹកហាត់ត្រៀមបង្ការហានិភ័យនានាដែលអាចកើតឡើងផងដែរ ដូចជាគ្រោះអគ្គីភ័យ ឬរញ្ជួយដីជាដើម។

- សាលារៀនមានធនធានអគារ និងសម្ភារៈគ្រប់គ្រាន់ដូចជា៖ បណ្ណាល័យធំទូលាយ និងមានសៀវភៅឯកសារច្រើន បរិយាកាសស្ងប់ស្ងាត់ និងត្រជាក់ល្អ អំណោយផលដល់ការអានសៀវភៅ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់តន្ត្រី បន្ទប់ប្រជុំសម្រាប់គ្រូបង្រៀន បន្ទប់សម្រាប់សិស្សជួបជុំគ្នា (Assembly) សួនច្បារ វាលស្មៅខៀវស្រងាត់ ម្លប់ឈើត្រជាក់ត្រឈឹងត្រឈៃ ទីធ្លាលេងកីឡា តារាងបាល់ និងអាងហែលទឹកជាដើម។
- មានការបែងចែកភារកិច្ចតួនាទីទទួលខុសត្រូវ និងលំហូរការងារច្បាស់លាស់ ដោយមិនមានបែងចែកការងារជាន់គ្នា និងរំលោភបំពានដែនសមត្ថកិច្ចគ្នាឡើយ។ បើមានបញ្ហាប្រឈមអ្វីមួយកើតឡើង ពួកគេធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហាទាំងនោះភ្លាមៗ ដោយមិនមើលបំណាំគ្នា បែងជើងគ្នា ឬមិនអើពើ និងនិយាយបរិហារកេរ្តិ៍គ្នាពីក្រោយខ្នងនោះទេ។ ឥរិយាបថអវិជ្ជមានបែបនេះ ជាទូទៅត្រូវបានគេចាត់ទុកថា មិនមានវិជ្ជាជីវៈក្នុងការបំពេញការងារ(Professional) សម្រាប់ស្ថាប័នដែលស្តង់ដារខ្ពស់។
- បន្ថែមពីការប្រជុំក្រុមបច្ចេកទេសគ្រូបង្រៀនតាមមុខវិជ្ជា ប្រជុំគ្រូបង្រៀនតាមកម្រិតថ្នាក់ ប្រជុំគរុកោសល្យ ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងប្រជុំគណៈកម្មការនានា សាលារៀនតែងតែមានការប្រជុំរួមមួយក្នុងរយៈពេលខ្លីត្រឹមតែ១៥នាទី ឬ២០នាទីប៉ុណ្ណោះដោយគ្រូបង្រៀនខ្លះអង្គុយ និងខ្លះទៀតឈរ ពិសេសធ្វើនៅថ្ងៃសុក្រមុនឈប់សម្រាកចុងសប្តាហ៍ដើម្បីបង្ហាញពីផែនការនានាសម្រាប់សប្តាហ៍បន្ទាប់ និងបញ្ហានានា ហើយសកម្មភាព

ប្រជុំនេះត្រូវបានធ្វើឡើងរៀងរាល់សប្តាហ៍។ និយាយឱ្យខ្លី និងងាយយល់គឺសាលារៀនមានរៀបចំប្រជុំសប្តាហ៍ច្រើនណាស់ទៅតាមផ្នែកៗរបស់ខ្លួន ហើយអនុវត្តយ៉ាងទៀងទាត់ទៀតផង ឧទាហរណ៍ប្រជុំគណៈគ្រប់គ្រងសាលា និងប្រធានការិយាល័យ ប្រជុំជាមួយក្រុមគណៈគ្រប់គ្រង ឬប្រជុំក្រុមគ្រូបង្រៀនតាមភូមិសិក្សា...ជាដើម។

- អ្វីដែលគួរឱ្យចាប់អារម្មណ៍មួយទៀតគឺរបៀបរបបធ្វើការងាររបស់បុគ្គលិក គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនលំដាប់អន្តរជាតិនេះគឺពួកគេធ្វើការងារលឿនប្រកបដោយប្រសិទ្ធភាព និងមានវិជ្ជាជីវៈខ្ពស់។ ក្នុងពេលមានបញ្ហាអ្វីមួយកើតឡើង ពួកគេប្រជុំគ្នាដោះស្រាយភ្លាមៗមិនទុកបង្អែបង្អង់យូរឡើយ រួមទាំងការរៀបចំផែនការគ្រប់គ្រងហានិភ័យដែលអាចកើតឡើងនានា បញ្ហាលទ្ធផលសិក្សាសិស្ស ការជួយសិស្សរៀនយឺត ឬបញ្ហាវិន័យសណ្តាប់ធ្នាប់ និងបញ្ហាផ្សេងៗទៀត។ ជាទូទៅ យើងអាចនិយាយបានថា ឥរិយាបថធ្វើការរបស់ពួកគេមិនចូលចិត្តពាក្យថា **"រង់ចាំសិន"** នោះទេ។ ពួកអ្នកធ្វើការទាំងនេះ ប្រកាន់យកមនសិកាការងារខ្ពស់ ម៉ត់ហ្មត់ និងប្រឹងប្រែង ព្រមទាំងបើកចំហចិត្តចែករំលែក និងបង្កើតបរិយាកាសរៀនសូត្រពីគ្នាទៅវិញទៅមក។ តាមរយៈការសង្កេតជាទូទៅ យើងឃើញថា សមត្ថភាពឯកទេសរបស់គ្រូបង្រៀនទាំងអស់នោះហាក់មិនលើសពីគ្រូបង្រៀនខ្មែរយើងប៉ុន្មាននោះទេ ដោយខុសគ្នាត្រង់ឥរិយាបថនៃការបំពេញការងារ និងផលប្រយោជន៍ដែលគ្រូបង្រៀនយើងទទួលបានប៉ុណ្ណោះ។
- សាលារៀនមានប្រព័ន្ធវាយតម្លៃការបំពេញការងារប្រចាំឆ្នាំរបស់គ្រូបង្រៀន និងបុគ្គលិកនានា ព្រមទាំងគណៈគ្រប់គ្រងសាលា

រៀន និងមានប្រព័ន្ធបណ្តុះបណ្តាលកសាងអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀនច្បាស់លាស់។ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងបុគ្គលិកនានា គេប្រើប្រាស់ធនធានខាងក្នុង និងខាងក្រៅ។ ធនធានខាងក្នុងគឺអនុវត្តតាមរយៈការប្រជុំក្រុមបច្ចេកទេស ក្រុមកម្រិតថ្នាក់ដូចគ្នា ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ការប្រជុំពិភាក្សាគ្នា...ដោយប្រើប្រាស់ធនធានគ្រូបង្រៀន ឬគ្រូបង្រៀនជាន់ខ្ពស់ដែលមានស្រាប់នៅក្នុងសាលា ដើម្បីចែករំលែកចំណេះដឹង បទពិសោធ និងរៀនសូត្រពីគ្នាទៅវិញមក។ ចំណែកឯធនធានខាងក្រៅគឺតាមរយៈការចូលរួមសិក្ខាសាលា វគ្គបំប៉ន និងវគ្គបណ្តុះបណ្តាលនានាដែលជាទូទៅដែលរៀបចំដោយភ្នាក់ងារមកពីខាងក្រៅសាលារៀន ទាំងការចូលរួមផ្ទាល់ ឬពីចម្ងាយ។ ជារួម គ្រូបង្រៀន និងបុគ្គលិកធ្វើការទាំងអស់តែងតែទទួលបានការបណ្តុះបណ្តាលបំប៉នសមត្ថភាពជាប្រចាំ។

- ជាទូទៅ សាលារៀនលំដាប់ខ្ពស់ទាំងនេះ តែងតែមានគិលានុបដ្ឋាយិកាសម្រាប់តាមដាន ពិនិត្យ និងថែទាំសុខភាពសិស្សានុសិស្សជាប់ជាប្រចាំ។ មួយវិញទៀត គ្រូបង្រៀន បុគ្គលិក និងគណៈគ្រប់គ្រងសាលាទាំងអស់សុទ្ធទទួលបានការបណ្តុះបណ្តាលសង្គ្រោះបឋម(CPR)ហើយសាលារៀននីមួយៗក៏មានឧបករណ៍សង្គ្រោះបន្ទាន់ផ្សេងៗជាច្រើនផងដែរ។ ក្នុងករណីមានសិស្សនៅក្នុងសាលារៀនមានបញ្ហាអ្វីមួយកើតឡើងទាក់ទងនឹងសុខភាព ឬគ្រោះថ្នាក់អ្វីមួយ គេនឹងអន្តរាគមន៍ភ្លាមៗតាមជំនាញដែលខ្លួនបានបណ្តុះបណ្តាល និងរង់ចាំរហូតដល់ឡានសង្គ្រោះមកដល់។
- ចំណុចចុងក្រោយមួយទៀតទាក់ទងនឹងការចែករំលែកព័ត៌មានសាលារៀនទាំងនេះយកចិត្តទុកដាក់ខ្លាំងណាស់លើការចែក

រំលែកព័ត៌មានទាន់ពេលវេលា ដោយប្រើប្រាស់មធ្យោបាយផ្សេងៗដូចជា អ៊ីម៉ែលសម្រាប់ព័ត៌មានផ្លូវការ បណ្តាញទំនាក់ទំនង Whatup Telegram ឬកម្មវិធីផ្សេងៗទៀត សម្រាប់ការងារបន្ទាន់ ឬត្រូវការដោះស្រាយភ្លាមៗ។ ក្រុមបណ្តាញទំនាក់ទំនងសំខាន់ៗ ក៏ត្រូវបានបង្កើតផងដែរ ហើយពួកគេប្រើប្រាស់សម្រាប់តែចែករំលែកព័ត៌មានផ្លូវការរបស់សាលារៀនប៉ុណ្ណោះ ដោយមិនតម្រូវឱ្យឆ្លើយតបទៅវិញឡើយ ឬដាក់មេដៃទៅវិញច្រើនស្តេកស្តាស់នោះទេ លើកលែងករណីសំខាន់ ឬបន្ទាន់ដែលត្រូវឆ្លើយតប។ ពួកគេធ្វើបែបនេះដើម្បីងាយស្រួលដល់អ្នកទទួលព័ត៌មានសំខាន់បានភ្លាមៗដោយមិនឡូកឡំនឹងសារអត់ប្រយោជន៍ផ្សេងៗច្រើន។

## 2. ការបង្រៀន និងរៀន

- កម្មវិធីសិក្សាសាលារៀនលំដាប់អន្តរជាតិទាំងនេះ បានអនុវត្តតាមប្រព័ន្ធស្តង់ដារអន្តរជាតិមួយច្បាស់លាស់ មានសូចនាករសម្រាប់វាស់វែង និងវាយតម្លៃត្រឹមត្រូវ ដែលអាចបង្ហាត់បង្រៀនសិស្សក្លាយជាធនធានមនុស្សពេញលេញអាចធ្វើការក្នុងកម្រិតអន្តរជាតិបាន។ ខ្លឹមសារមេរៀនមានភាពផ្សារភ្ជាប់គ្នាជាប្រព័ន្ធតាំងពីបរិបទពិភពលោក តំបន់ និងមូលដ្ឋានីយកម្ម។ កម្មវិធីសិក្សា មេរៀនសម្រាប់បង្រៀនសិស្ស ទំនាក់ទំនងមេរៀនពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត ផែនការបង្រៀនមេរៀន ការវាយតម្លៃ និងឆ្លុះបញ្ចាំងការបង្រៀនរបស់ខ្លួន ធនធានឯកសារសម្រាប់បង្រៀន និងរៀន ត្រួតពិនិត្យវត្តមានសិស្ស វាយតម្លៃលទ្ធផល និងឥរិយាបថ អាកប្បកិរិយាសិស្ស ការផ្តល់ព័តមានត្រឡប់ដល់សិស្ស...ត្រូវបានរៀបចំ និងអនុវត្តជាប្រព័ន្ធនៅក្នុងកម្មវិធីកុំ

ព្យូទ័រមួយច្បាស់លាស់ដែលគ្រូបង្រៀន និងអ្នកពាក់ព័ន្ធនានាអាចទទួលព័ត៌មានបានទាន់ពេលវេលា និងឆាប់រហ័ស។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ គ្រូបង្រៀនទាំងនោះហាក់មិនរវល់ច្រើនក្នុងការសរសេរកិច្ចតែងការបង្រៀនរៀងរាល់ថ្ងៃ និងស្មុគស្មាញដូចយើងទាល់តែសោះ។ កិច្ចតែងការបង្រៀនរបស់ពួកគេមានលក្ខណៈសាមញ្ញាបំផុត និងទៅតាមគ្រូបង្រៀនរៀងៗខ្លួន។ អ្វីដែលគ្រូបង្រៀនត្រូវចាប់អារម្មណ៍ខ្លាំងនោះគឺប្លង់មេរៀនដែលត្រូវបានរៀបចំនៅក្នុងកម្មវិធីកុំព្យូទ័រដែលប្រើប្រាស់សម្រាប់សាលារៀនទាំងមូល ដោយមេរៀនមួយមានរយៈពេល២០ម៉ោង ឬច្រើនជាង៣០ម៉ោងសិក្សាក៏មាន។ ប្លង់មេរៀននេះមានលក្ខណៈដូចប្លង់គម្រោងសំណើ (Project Proposal) មួយដែលដាក់បញ្ចូលព័ត៌មានគ្រប់ជ្រុងជ្រោយនូវវិធីសាស្ត្របង្រៀនដើម្បីឱ្យសិស្សសម្រេចលទ្ធផលសិក្សា វិធីសាស្ត្របង្រៀនសម្រាប់សិស្សដែលមានលក្ខណៈដោយឡែកពីគ្នា ឬរបៀបរៀនខុសៗគ្នា វត្ថុបំណងការប្រើប្រាស់សម្ភារឧបទេស ធនធានឯកសារប្រើប្រាស់សម្រាប់បង្រៀន-រៀន ការវាយតម្លៃ ការឆ្លុះបញ្ចាំងការបង្រៀន-រៀន និងលទ្ធផលសិស្ស ព័ត៌មានត្រឡប់លើខ្លឹមសារមេរៀនដែលបានរៀបចំ តារាងកត់ត្រាមេរៀនរៀនសូត្រសម្រាប់ប្រើនៅឆ្នាំសិក្សាក្រោយ...។ កម្រងព័ត៌មានទិន្នន័យសិស្សត្រូវបានគ្រប់គ្រងដោយប្រព័ន្ធមួយច្បាស់លាស់ មានការកត់ត្រាយ៉ាងត្រឹមត្រូវនូវរបាយការណ៍វឌ្ឍនភាព និងមានព័ត៌មានសិក្សាគ្រប់ជ្រុងជ្រោយ។

- គ្រូបង្រៀនត្រូវចូលរួមប្រជុំក្រុមបច្ចេកទេសរៀងរាល់សប្តាហ៍ដោះស្រាយរួមគ្នានូវបញ្ហាប្រឈមនានាដែលជួបប្រទះទាក់ទង

នឹងការបង្រៀន និងរៀន និងចែករំលែកចំណេះដឹង បទពិសោធល្អៗឱ្យគ្នាទៅវិញទៅមក។

- ដើម្បីលើកកម្ពស់ជំនាញវិជ្ជាជីវៈ គ្រូបង្រៀនទាំងអស់តម្រូវឱ្យអនុវត្តការសិក្សាស្រាវជ្រាវមេរៀន ការប្រជុំគរុកោសល្យ និងការប្រជុំពិភាក្សានានាដែលរៀបចំយ៉ាងទៀងទាត់។
- ប្រធានក្រុមបច្ចេកទេស ឬគ្រូជាន់ខ្ពស់ផ្តល់ប្រឹក្សាដល់គ្រូបង្រៀនជាបុគ្គលិកក្រោមឱវាទតាមពេលវេលាកំណត់ណាត់ជួបណាមួយជាក់លាក់ ដើម្បីជួយបន្ថែម ឬបំពេញកង្វះខាតដោយផ្ទាល់សម្រាប់បុគ្គលិកម្នាក់ៗ ឬក៏ពិភាក្សាពីការងារដែលបានអនុវត្តកន្លងមក។
- ការទទួលខុសត្រូវដ៏សំខាន់បំផុតរបស់គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់ក្នុងមួយឆ្នាំសិក្សាគឺការខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរឡើងនូវព្រឹត្តិការណ៍ និងកម្មវិធីធំៗនានាដែលរៀបចំប្រចាំឆ្នាំនៅក្នុងសាលារៀន ដោយមានអញ្ជើញចូលរួមពីភ្ញៀវកិត្តិយស ថ្នាក់ដឹកនាំ មាតាបិតាសិស្ស សហគមន៍ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីចូលរួមកម្មវិធីដូចជា៖ កម្មវិធីប្រកួតកីឡា កម្មវិធីស្វាគមន៍ទទួលបុណ្យចូលឆ្នាំ បុណ្យគ្រីសស្មាស់ ឬកម្មវិធីបិទបញ្ចប់ការសិក្សាប្រចាំឆ្នាំជាដើម ដើម្បីបង្ហាញដល់អ្នកចូលរួមពីភាពអស្ចារ្យ សមិទ្ធិផលសម្រេចបាន ភាពលេចធ្លោ និងការរីកចម្រើនរបស់សាលារៀន ហើយដែលព្រឹត្តិការណ៍ទាំងនេះជាការឆ្លុះបញ្ចាំង ឬវាយតម្លៃលទ្ធផលការងាររបស់ស្ថាប័ន ហើយក៏ជាការធ្វើទីផ្សារទាក់ទាញអ្នកចូលរួមគាំទ្រ ការកើនឡើងនូវការចុះឈ្មោះចូលរៀនរបស់សិស្ស និងភាពពេញចិត្តរបស់ថ្នាក់ដឹកនាំផងដែរ ។

- សាលារៀនជុំវិញ និងលើកទឹកចិត្តឱ្យមានការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ។ កម្មវិធីនេះ សិស្សត្រូវរៀបចំគម្រោងវិទ្យាសាស្ត្រនានាផ្ទាល់ខ្លួនដោយមានការជួយគាំទ្រពីសំណាក់គ្រូបង្រៀន ក្នុងគោលបំណងដើម្បីបំផុសសិស្សឱ្យចេះស្រាវជ្រាវ បង្កើតស្នាដៃ និងចូលរួមប្រកួតប្រជែង ឬចូលរួមតាំងពិពណ៌ស្នាដៃក្នុងសាលា និងព្រឹត្តិការណ៍ពិពណ៌នានាដែលមានសាលារៀនជាច្រើនចូលរួម។
- សិស្សមានទស្សនកិច្ចសិក្សានៅក្នុងប្រទេស ឬក្រៅប្រទេសដើម្បីដកស្រង់បទពិសោធ រៀនសូត្រ និងដើរកម្សាន្ត ហើយត្រឡប់មកវិញ ពួកគេត្រូវធ្វើបទបង្ហាញពីលទ្ធផលដំណើរទស្សនកិច្ចខ្លួនដល់សិស្សកម្រិតថ្នាក់ដទៃទៀត។
- កាលវិភាគប្រចាំសប្តាហ៍មានដាក់បញ្ចូលម៉ោង សេវាសង្គម និងម៉ោងជួបជុំសិស្ស (assembly) សម្រាប់ចែករំលែកចំណេះដឹង និងមេរៀនល្អៗ សំខាន់ៗ និងការចូលរួមសកម្មភាពទាក់ទងនានានឹងសេវាសង្គមដូចជាកម្មវិធីមនុស្សធម៌ សកម្មភាពជួយសហគមន៍ក្រីក្រ... និងការជួបជុំចែករំលែកចំណេះដឹងថ្មីៗ តាមរយៈការធ្វើការរួមគ្នា សហការគ្នារវាងសិស្ស និងសិស្ស ឬការធ្វើបទបង្ហាញដែលរៀបចំដោយគ្រូបង្រៀន ឬគណៈគ្រប់គ្រងសាលា។
- ដើម្បីលើកកម្ពស់ការសិក្សារៀនសូត្រ សាលារៀនមានការអញ្ជើញវាគ្មិន ឬឥស្សរជនល្បីៗពីខាងក្រៅមកធ្វើបទបង្ហាញចែករំលែកបទពិសោធផ្សេងៗដល់សិស្សានុសិស្សនៅក្នុងសាលា។
- ជាទូទៅ ផ្នត់គំនិតគ្រូបង្រៀនភាគច្រើនបើកចំហចិត្ត និងធ្វើការងារប្រកបដោយវិជ្ជាជីវៈខ្ពស់ ឈរលើស្មារតីជួយគ្នាទៅវិញទៅមក

ដើម្បីរីកចម្រើនទាំងអស់គ្នា។ ពួកគេបានបង្កើតបរិយាកាសចែករំលែកចំណេះដឹង និងរៀនសូត្រពីគ្នាដើម្បីលើកកម្ពស់គុណវុឌ្ឍិប្រកបដោយភាតរភាព និងសាមគ្គីភាព។ រាល់បញ្ហាប្រឈមទាំងអស់ ពួកគេដាក់លើតុធ្វើការដោះស្រាយរួមគ្នា ដោយមិនមានពុតត្បុតលាក់ល្បិច ឬមានគំនិតបែងជើងគ្នាឡើយ។ ចំណុចមួយទៀត ពួកគេមិនពេញចិត្តសោះឡើយបើមានអ្នកដែលមិនសូវចេះ ឬមិនសូវយល់កិច្ចការច្បាស់លាស់ ហើយបន្តព្យាយាមធ្វើកិច្ចការទាំងខុស ដោយមិនស្វែងរកជំនួយខាងក្រៅ ឬមិនសួរនាំអ្នកដទៃ។ ជារួម បុគ្គលិកអប់រំទាំងអស់ត្រូវបានផលិតដោយប្រព័ន្ធអប់រំមួយ ឱ្យក្លាយជាជាមនុស្សប្រឹងប្រែងនឹងការងារ ប្រកួតប្រជែង បើកចំហចិត្ត និងមានមនសិការវិជ្ជាជីវៈការងារខ្ពស់។

- ដោយសារសាលារៀនមានថ្នាក់តន្ត្រី ដូច្នេះជាទូទៅ សិស្សចេះលេងឧបករណ៍ភ្លេងនានា ហើយនៅពេលមានរៀបចំកម្មវិធីនានានៅក្នុងសាលារៀនដូចជា៖ បុណ្យគ្រីសស្មាស់ បុណ្យចូលឆ្នាំ ឬកម្មវិធីបិទបញ្ចប់ឆ្នាំសិក្សា សិស្សតែងតែរួមគ្នាប្រជុំតន្ត្រី និងច្រៀងកម្សាន្តយ៉ាងសប្បាយ។ អ្វីដែលគួរកត់សម្គាល់នោះគឺ មិនត្រឹមតែសិស្សភាគច្រើនចេះលេងឧបករណ៍តន្ត្រីនោះទេ សូម្បីតែគ្រូបង្រៀនស្ទើរតែទាំងអស់ចេះលេងឧបករណ៍ទាំងនោះផងដែរ ដោយសារពួកគាត់ម្នាក់ៗសុទ្ធតែបានរៀនសូត្រពីសាលារៀនខ្លួនកាលពីសិក្សានៅបឋម និងមធ្យមសិក្សា។
- សិស្សានុសិស្សនៅក្នុងសាលារៀនតែមួយមានបែងចែកជា៤ក្រុមផ្សេងៗគ្នា សម្រាប់គ្រប់កម្រិតថ្នាក់ដើម្បីអនុវត្តគម្រោងផ្សេងៗ ការប្រកួតប្រជែងគម្រោងស្រាវជ្រាវ សកម្មភាពសង្គម ឬសម្រាប់ប្រកួតកីឡានៅក្នុងសាលា ពោលគឺបង្កើតកម្មវិធីប្រកួតប្រជែងជា

ក្រុមនៅក្នុងសាលារៀនតែមួយ។ វិធីសាស្ត្រនេះធ្វើឱ្យសិស្សចេះសហការគ្នាធ្វើការជាក្រុម ដើម្បីភាពជោគជ័យ។ ជាមួយគ្នានេះសាលារៀនក៏មានក្រុមជម្រើសនានានៅក្នុងសាលារៀនផ្ទាល់ខ្លួនសម្រាប់ប្រកួតជាមួយសាលារៀនដទៃទៀតផងដែរ។

- សិស្សនៅថ្នាក់ចុងក្រោយនៃមធ្យមសិក្សាទុតិយភូមិមានសរសេរគម្រោងស្រាវជ្រាវ និងគម្រោងផ្ទាល់ខ្លួន ( Personnel Project ) ដែលជាផែនការអាជីពនាពេលអនាគតសម្រាប់តម្រង់ទិស និងបន្តការសិក្សានៅថ្នាក់មហាវិទ្យាល័យ ដែលគម្រោងទាំងនេះមិនមានសោះឡើយនៅក្នុងប្រព័ន្ធអប់រំប្រទេសយើង។
- ក្រៅពីវាយតម្លៃលទ្ធផលសិក្សាសិស្សតាមរយៈតេស្ត ឬប្រឡងផ្ទៃក្នុង សាលារៀនលំដាប់នេះក៏មានរៀបចំវាយតម្លៃសមត្ថភាពសិស្សដែលផ្សារភ្ជាប់ទៅកម្មវិធីកម្រិតអន្តរជាតិណាមួយផ្សេងទៀត ដើម្បីងាយស្រួលវាយតម្លៃស្តង់ដារសមត្ថភាពសិស្សខ្លួនធៀបនឹងលំដាប់ស្តង់ដារកម្រិតខ្ពស់មួយ។ នេះជាយន្តការ និងនីតិវិធីវាយតម្លៃលទ្ធផលសិក្សាសិស្សមួយមានភាពច្បាស់លាស់ និងត្រឹមត្រូវ។
- គ្រូបង្រៀនធ្វើការពេញម៉ោង ក្រៅពីបង្រៀនតាមកាលវិភាគប្រចាំសប្តាហ៍ដែលបានកំណត់ ពួកគេត្រូវធ្វើការនៅការិយាល័យដូចជាធ្វើការសិក្សាស្រាវជ្រាវ រៀបចំមេរៀន ស្វែងរកធនធានឯកសារនានា ឬចូលរួមប្រជុំផ្សេងៗ...ជាដើម ពោលគឺបុគ្គលិកអប់រំ និងសិស្សានុសិស្សទាំងអស់ មិនសម្រាកដេកថ្ងៃឡើយដូចយើងឡើយ។ ពេលវេលាសម្រាកអាហារថ្ងៃត្រង់ត្រឹមតែ៣០នាទី ទៅ៤៥នាទីប៉ុណ្ណោះ។

- សាលារៀនមានធនធានថវិកាគ្រប់គ្រាន់សម្រាប់គ្រូបង្រៀន ទិញសម្ភារឧបទេសដើម្បីលើកកម្ពស់ការបង្រៀន និងរៀនរបស់ខ្លួន ពោលគឺគ្រូបង្រៀនអាចទិញនូវធនធានសម្ភារៈបានគ្រប់យ៉ាងសម្រាប់បម្រើដល់ការងាររបស់ខ្លួន។
- ការបង្រៀន និងរៀនភ្ជាប់នឹងបច្ចេកវិទ្យាបង្រៀនពីចម្ងាយ។ ទោះបីជាមានសកម្មភាពបង្រៀន និងរៀននៅថ្នាក់ជាមួយគ្រូបង្រៀនហើយក៏ដោយ ក៏មានថ្នាក់រៀនអនឡាញបន្ថែមទៀតផងដែរ ពិសេសសម្រាប់ករណីសិស្សអវត្តមានត្រូវរៀនពីផ្ទះ ការផ្ញើព័ត៌មាន ឯកសារមេរៀន ឬកិច្ចការផ្ទះជាដើម។ សិស្សត្រូវបានលើកទឹកឱ្យប្រើប្រាស់បច្ចេកវិទ្យាក្នុងការស្រាវជ្រាវ និងសិក្សារៀនសូត្រសម្រាប់បរិបទការអប់រំសតវត្សរ៍ទី២១។ ជាទូទៅ សិស្សមានការយល់ដឹង និងចេះប្រើប្រាស់កម្មវិធីកុំព្យូទ័រមួយចំនួនដូចជា Ms. Word, Ms. Excel, PowerPoint, Google doc…សម្រាប់វាយអត្ថបទ ធ្វើកិច្ចការជាក្រុម និងធ្វើបទបង្ហាញជាដើម។
- គ្រូបង្រៀនអនុវត្តបច្ចេកវិទ្យាក្នុងការបង្រៀនយ៉ាងទូលំទូលាយ ដូចជាការទាញយកឯកសារ ការប្រើប្រាស់ Google Classroom, Google form, Google meet, Google doc, Hangout, zoom, ឬសមត្ថភាពក្នុងការប្រើប្រាស់ LCD projector។
- សិស្សានុសិស្សមិនអនុញ្ញាតឱ្យប្រើប្រាស់ទូរស័ព្ទនៅក្នុងសាលារៀនឡើយចាប់ពីកម្រិតបឋមសិក្សាដល់មធ្យមសិក្សា។ សម្រាប់កម្រិតបឋមសិក្សា សិស្សអាចប្រើប្រាស់ Tablet ឬIPad បានសម្រាប់សកម្មភាពបង្រៀន និងរៀនប៉ុណ្ណោះ ហើយសិស្សចាប់ពី

ថ្នាក់ទី៦ឡើងទៅអាចប្រើប្រាស់កុំព្យូទ័របានសម្រាប់សកម្មភាពសិក្សារៀនសូត្រ។

- ជាទូទៅ គ្រូបង្រៀនដាក់កិច្ចការផ្ទះច្រើនដល់សិស្ស ហើយតែងតែកែ និងផ្តល់ព័ត៌មានត្រឡប់ទៅសិស្សវិញជាប្រចាំ។
- គ្រូបង្រៀនយកចិត្តទុកដាក់ជាខ្លាំងទៅលើភាពដោយឡែកៗពីគ្នារបស់សិស្សម្នាក់ទៅសិស្សម្នាក់ទៀត ដោយដាក់បញ្ចូលនូវវិធីសាស្ត្របង្រៀន និងដោះស្រាយទៅតាមភាពដោយឡែកផ្សេងៗគ្នានេះ ដែលការរៀបចំបែបនេះខុសពីកិច្ចតែងការបង្រៀនរបស់ខ្មែរយើង ដោយមិនបានដាក់បញ្ចូល ឬបញ្ជាក់ច្បាស់លាស់ពីចំណុចលក្ខណៈដោយឡែករបស់សិស្សផ្សេងៗគ្នា និងសូចនាករសម្រាប់វាស់វែងសមត្ថភាពសិស្សជាក់លាក់។ ដើម្បីសម្រេចវត្ថុបំណងមេរៀនមួយ គ្រូបង្រៀនគិតគូរខ្លាំងណាស់ទៅលើសមត្ថភាព របៀបរៀន ចំណាប់ចំណូលចិត្តសិស្ស ពោលគឺព្យាយាមរកវិធីធ្វើយ៉ាងណាដើម្បីធ្វើឱ្យសិស្សសម្រេចលទ្ធផលសិក្សាប្រកបដោយជោគជ័យបានទាំងអស់គ្នា។ ការរៀបចំប្លង់មេរៀនបែបនេះមានលក្ខណៈងាយស្រួល ច្បាស់លាស់ និងជួយសិស្សបានគ្រប់ជ្រុងជ្រោយជាងការរវល់ខ្លាំងជាមួយតែនឹងការសរសេរកិច្ចតែងការដោយខ្វះការសិក្សាស្រាវជ្រាវចំណេះដឹងមេរៀនបន្ថែម និងខ្លឹមសារមេរៀនធ្វើបច្ចុប្បន្នថ្មី។
- សិស្សចូលរៀនចាប់ពីម៉ោង៨ព្រឹករហូតដល់ម៉ោង៣ ដោយមិនសម្រាកចន្លោះថ្ងៃត្រង់ទេដូចយើងទេ។ សិស្សមានពេលពី៣០នាទីទៅ៤៥នាទីសម្រាប់អាហារពេលថ្ងៃប៉ុណ្ណោះ។ សិស្សនៅក្នុងសាលារៀនរហូតដល់ម៉ោងចេញទៅផ្ទះ ដោយសិក្សា៥ថ្ងៃក្នុងមួយសប្តាហ៍។ ការប្រើប្រាស់ពេលវេលាសិក្សាបែបនេះ ធ្វើឱ្យ

សិស្សានុសិស្ស ព្រមទាំងបុគ្គលិកអប់រំទាំងអស់ចំណេញពេលវេលាបីម៉ោងនៅចន្លោះពេលថ្ងៃ (គឺពីម៉ោង១២ដល់ម៉ោង២រសៀល)។

- ពេលញ៉ាំបាយថ្ងៃត្រង់ហើយនៅសល់ម៉ោង គេបណ្តោយឱ្យសិស្សរត់លេង កម្សាន្តតាមចិត្ត ដោយមានសិស្សខ្លះលេងកីឡា ឬចូលបណ្ណាល័យអានសៀវភៅ....។
- សម្រាប់សិស្សដែលមានឥរិយាបថ អាកប្បកិរិយាមិនល្អ ឬមានបញ្ហាសុខភាពផ្លូវចិត្ត សាលារៀនគ្រូប្រឹក្សាយោបល់ដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់សម្រាប់ជួយសិស្សទាំងនោះ។
- សិស្សនៅសាលារៀនលំដាប់អន្តរជាតិទាំងនេះ ហាក់ចំណាយពេលរៀនច្រើនជាងយើងទាំងក្នុងសាលារៀន ក្រៅសាលា ហើយជានិច្ចកាលតែងតែមានកិច្ចការផ្ទះដែលគ្រូដាក់ឱ្យថែមទៀត។
- ម៉ោងសិល្បៈ គំនូរ តន្ត្រី និងកាយសិក្សាត្រូវបានសាលារៀនយកចិត្តទុកដាក់ខ្លាំងផងដែរ។ សិស្សភាគច្រើនអាចលេងឧបករណ៍ភ្លេងបាន ចេះគូរគំនូរ និងមានសមត្ថភាពផ្នែកកីឡា។
- គ្រូកីឡាមានសមត្ថភាព ជំនាញឯកទេស និងមានសម្ភារៈគ្រប់គ្រាន់។ សិស្សហាត់ជាមួយសម្ភារៈកីឡា និងលេងកីឡា ធ្វើឱ្យសិស្សចូលចិត្ត និងចាប់អារម្មណ៍ខ្លាំងជាមួយសកម្មភាពលេងកីឡានេះ។ ជាមួយគ្នានេះ សាលារៀនមានអាងហែលទឹក និងមានគ្រូបង្វឹកសម្រាប់ហ្វឹកហាត់សិស្សរៀនហែលទឹកគ្រប់ៗគ្នា។ ជាទូទៅ ឆ្លងកាត់ការហ្វឹកហាត់ទាំងនេះពីមួយឆ្នាំសិក្សាទៅមួយឆ្នាំសិក្សា សិស្សទាំងអស់ចេះហែលទឹកបានគ្រប់ៗគ្នា។

- ជាទូទៅ សាលារៀនយកចិត្តទុកដាក់ខ្លាំងក្នុងការជំរុញ និងលើកទឹកចិត្តសិស្សឱ្យនិយមចូលចិត្តអានសៀវភៅទាំងនៅក្នុង និងក្រៅសាលារៀន ពោលគឺគេបណ្តុះសិស្សឱ្យអានសៀវភៅជាច្រើនក្រៅពីសៀវភៅសិក្សាគោលដែលបង្រៀននៅក្នុងសាលារៀន។ ការអានសៀវភៅក្លាយជាទម្លាប់ ឬជាផ្នែកមួយជីវិតសិក្សារបស់សិស្ស។ ជាមួយគ្នានេះ សាលារៀនខ្លះ មិនមានសៀវភៅសិក្សាគោលជាក់លាក់នោះទេ មានតែមេរៀន ឬគម្រោងមេរៀនដោយប្រើប្រាស់ធនធានឯកសារពីប្រភពខាងក្រៅជាច្រើនសម្រាប់បង្រៀន និងរៀន ឬការចងក្រងខ្លឹមសារមេរៀនដែលបានមកពីការសិក្សាស្រាវជ្រាវរបស់សិស្ស ឬខ្លឹមសារមេរៀនឆ្លងកាត់ការពិភាក្សាគ្នាយ៉ាងទូលំទូលាយនៅក្នុងថ្នាក់តែម្តង។
- គ្រូបណ្ណាល័យ ឬបណ្ណារក្សមានសមត្ថភាពខ្ពស់ទាំងការងារគ្រប់គ្រងសៀវភៅ ការកត់ត្រា រៀបចំសៀវភៅ ស្វែងរកធនធានឯកសារជាE-books ដាក់កិច្ចការឱ្យសិស្ស សកម្មភាពទាក់ទាញសិស្សឱ្យចាប់អារម្មណ៍ចង់អានសៀវភៅ និងសកម្មភាពលេងកម្សាន្តសប្បាយនៅក្នុងបណ្ណាល័យជាដើម។
- សាលារៀនមានកម្មវិធីបំប៉នសិស្សបន្ថែមសម្រាប់សិស្សរៀនយឺត ឬតាមរយៈការស្នើសុំរបស់សិស្សក្នុងចំនួនជាក់លាក់ណាមួយ។
- មុខវិជ្ជាវិទ្យាសាស្ត្រ (Science) តែមួយមុខត្រូវបានដាក់បញ្ចូលមុខវិជ្ជារងផ្សេងៗជាច្រើនក្នុងនោះមាន ជីវវិទ្យា គីមីវិទ្យា រូបវិទ្យា ផែនដីវិទ្យា...ជាដើម។ ដូច្នេះសិស្សសាលារៀនស្តង់ដារខ្ពស់ទាំងនេះ ហាក់មិនរៀនច្រើនមុខវិជ្ជានោះទេ ដោយមុខវិជ្ជាវិទ្យាសាស្ត្រមួយក្តោបមុខវិជ្ជារងជាច្រើនបញ្ចូលគ្នា ហើយមុខវិជ្ជាដូចជា តន្ត្រី

សិល្បៈគំនូរ កីឡា ត្រូវបានយកចិត្តខ្លាំង ដែលមុខវិជ្ជាទាំងអស់នេះ ខ្មែរយើងមិនសូវចាប់អារម្មណ៍ឡើយ។

- សិស្សត្រូវរៀនបន្ថែមពីរភាសាទៀតក្រៅពីភាសាកំណើត ពីថ្នាក់ទី៦ដល់ទី១០ សិស្សតម្រូវឱ្យជ្រើសរើសរៀនភាសាបរទេសមួយ ហើយចាប់ពីថ្នាក់ទី១១ដល់១២ សិស្សនឹងត្រូវដូររៀនភាសាបរទេសថ្មីផ្សេងមួយទៀត។
- ថ្នាក់រៀនមានបំពាក់បច្ចេកវិទ្យា LCD Projector, Router ផ្តល់សេវាWifi ដល់សិស្ស និងគ្រូបង្រៀន កុំព្យូទ័រសម្រាប់ស្រាវជ្រាវ ...។ សិស្សនៅកម្រិតថ្នាក់ទី៦ចេះរៀបចំស្លាយ និងធ្វើបទបង្ហាញ។ ប្រព័ន្ធអប់រំនេះយកចិត្តទុកដាក់បណ្តុះសេចក្តីក្លាហានសិស្សឱ្យហ៊ានឡើងបកស្រាយ និងពន្យល់មានលក្ខណៈដូចកម្មវិធីTED TALKដូច្នេះដែរ។
- មានគ្រូបង្រៀនផ្លាស់ចូលថ្មីជារៀងរាល់ឆ្នាំ ហើយតែងតែពាំនាំបទពិសោធការងារល្អដែលបានអនុវត្ត ឬរៀនសូត្រពីស្ថាប័នចាស់មកចែករំលែកដល់ស្ថាប័នថ្មីដែលជាកត្តាដ៏សំខាន់ធ្វើឱ្យសាលារៀនមានការរីកចម្រើន និងភាពសម្បូរបែបពីមួយឆ្នាំទៅមួយឆ្នាំ។

### 3. លទ្ធផលសិក្សារបស់សិស្ស

- គ្មានសិស្សណាម្នាក់ត្រូវបានទុកចោលឡើយ។ បុគ្គលិកអប់រំទាំងអស់ផ្តោតទៅលើម្នាក់ៗខ្លាំង ពិសេសពេលមានសិស្សណាម្នាក់ជួបប្រទះនូវបញ្ហាប្រឈមអ្វីមួយទាំងវិបត្តិអាកប្បកិរិយា បញ្ហាសុខភាពផ្លូវចិត្ត ការរៀនយឺត... ពួកគេទាំងអស់រួមគ្នាដោះស្រាយ និងកែលម្អភ្លាមៗ ដោយមិនទុកយូរឡើយ។

- សិស្សប្រើប្រាស់បច្ចេកវិទ្យានៅថ្នាក់ទី៦ឡើងទៅ សិស្សប្រើប្រាស់កុំព្យូទ័រយ៉ាងទូលំទូលាយសម្រាប់រៀបចំខ្លឹមសារមេរៀន ធ្វើកិច្ចការក្រុម ស្រាវជ្រាវ ឬធ្វើបទបង្ហាញ ពេលគឺការសិក្សាផ្សារភ្ជាប់នឹងបច្ចេកវិទ្យា។
- សិស្សមានយល់ដឹងទូលំទូលាយនូវខ្លឹមសារមេរៀន ព្រោះមេរៀននីមួយៗបានផ្សារភ្ជាប់ទៅនឹងបរិបទសាកល (Global Context) តំបន់ និងមូលដ្ឋានផ្ទាល់ដែលសិស្សរស់នៅ ឆ្លើយតបទៅនឹងការអប់រំនៅសតវត្សរ៍ទី២១។ ជាមួយគ្នា ក៏មានភាពទាក់ទងគ្នានឹងមុខវិជ្ជាផ្សេងៗដែរ។
- សិស្សចូលរួមសកម្មភាពសង្គម សិក្សាស្វែងយល់ពីបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងសង្គម និងសកម្មភាពនៃការចូលរួមជួយសង្គមផ្សេងៗ។ សិស្សប្រើប្រាស់ទ្រឹស្តីដែលរៀនពីសាលារៀនយកទៅប្រើប្រាស់ផ្សារភ្ជាប់ទៅតថភាពសង្គមជាក់ស្តែង ជីវភាពរស់នៅប្រចាំថ្ងៃ និងអនុវត្តជាក់ស្តែង។ សិស្សរៀនសូត្រយ៉ាងទូលំទូលាយពីបញ្ហាសង្គម ពិសេសសិក្សាពីភាពក្រីក្រ និងវិបត្តិសង្គម ក្នុងគោលបំណងធ្វើឱ្យទាំងអស់នោះមានស្មារតីមនុស្សធម៌ ចេះជួយគ្នាទៅវិញទៅមក បើកចំហចិត្ត លុបបំបាត់ការរើសអើង និងជំរុញភាពជាពលរដ្ឋសាកល។ សាលារៀនស្តង់ដារខ្ពស់ទាំងនេះផ្តល់ដល់សិស្សនូវការសិក្សាស្វែងយល់ជាច្រើនពីជីវិតប្រជាជនក្រីក្រ ដែលផ្ទុយពីសិស្សរៀននៅសលារៀនស្តង់ដារទាបបានសិក្សាស្វែងយល់តិចតួចបំផុតពីភាពទូលំទូលាយនៃពិភពលោកនាពេលបច្ចុប្បន្ន និងបរិបទសង្គមសម័យទំនើប។

## 4. ការវាយតម្លៃ និងកិច្ចសហការ

- មានកម្មវិធីជួបជុំរវាងសិស្ស មាតាបិតាសិស្ស និងលោកគ្រូ-អ្នកគ្រូ ដើម្បីពិភាក្សាពីលទ្ធផលសិក្សា និងការចែករំលែកព័ត៌មាននានា
- ការធ្វើតេស្ត ឬប្រឡងប្រចាំខែមិនមានអនុវត្តនោះទេ ការវាយតម្លៃត្រូវបានអនុវត្តក្នុងរង្វង់បីខែម្តងប៉ុណ្ណោះ(Term) ហើយក៏មិនមានចាត់ចំណាត់ថ្នាក់អ្វីដែរ ពោលគឺមានតែពិន្ទុជាអក្សរ និងមតិយោបល់របស់គ្រូបង្រៀនតាមមុខវិជ្ជា។ ជាទូទៅគ្រូបង្រៀនផ្តោតទៅលើការធ្វើ formative assessment ជាប្រចាំបន្ទាប់បង្រៀនមេរៀនមួយរួច ការផ្តល់កិច្ចការផ្ទះដល់សិស្ស និងផ្តល់ព័ត៌មានត្រឡប់ទៅសិស្សវិញ ហើយចំណែកឯ Summative assessment ធ្វើឡើងក្នុងរង្វង់បីខែម្តងប៉ុណ្ណោះ។ ការមិនដាក់ចំណាត់ថ្នាក់នេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ដើម្បីយល់ពីតម្លៃនៃការសិក្សា ចេះជួយគ្នា ធ្វើការរួមគ្នាជាក្រុម... ដោយមិនធ្វើការប្រកួតប្រជែងគ្នាដើម្បីតែចំណាត់ថ្នាក់។ ការវាយតម្លៃ គ្រាន់តែដើម្បីស្វែងរកចំណុចល្អ និងចំណុចខ្វះខាតដែលត្រូវពង្រឹង និងជួយគាំទ្រដល់ការសិក្សារបស់សិស្សប៉ុណ្ណោះ។
- កិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរ សហគមន៍ មាតាបិតាសិស្ស...មានលក្ខណៈស្អិតរមួតមានទាំងការចែករំលែកព័ត៌មានសិក្សា និងកិច្ចសហការដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើងបានទាន់ពេលវេលា។ ជាទូទៅ មានការណាត់ជួបជាមួយមាតាបិតា ឬអាណាព្យាបាលសិស្សជាប្រចាំ ពិសេសសិស្សដែលត្រូវការជំនួយបន្ថែម។

# ផ្នែកទី៣

# ដំណើរវិវត្តន៍និងបញ្ហាប្រឈមនានានៃការអប់រំនៅកម្ពុជា

## I- ប្រវត្តិអប់រំសង្ខេបនៅកម្ពុជា

(*សង្ខេបពីសៀវភៅកំណែទម្រង់វិស័យអប់រំនៅកម្ពុជា របស់ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន ២០១៦*)

ប្រព័ន្ធអប់រំខ្មែរក្រោយសម័យអង្គរ គឺជាប្រព័ន្ធអប់រំបែបព្រះពុទ្ធសាសនា។ វត្តអារាមមានតួនាទី យ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សឱ្យមកបម្រើក្នុងរាជការ។ ភាសាយានគឺភាសាបាលី ដែលជាភាសាកម្រិតខ្ពស់ និងភាសាខ្មែរដែលជាភាសាសម្រាប់ប្រជាជនសាមញ្ញ។ ក្នុងអំឡុងសតវត្សរ៍ទី១៩ ប្រព័ន្ធអប់រំខ្មែរត្រូវបំផ្លាញដល់ឫសគល់ វត្តអារាមត្រូវបានកម្ទេច និងបំផ្លាញចោល ដោយសារការឈ្លានពាន កាន់កាប់ពីសំណាក់ប្រទេសសៀម និងវៀតណាម និងការបោះបោរក្នុងស្រុក។[១] ប្រព័ន្ធអប់រំកម្ពុជាមុនសតវត្សរ៍ទី២០ ជាប្រព័ន្ធមួយដែលឈរលើមូលដ្ឋាននៃរចនាសម្ព័ន្ធសង្គម ដែលមិនមែនស្ថាប័នទេ តែគឺបុគ្គលដែលដើរតួនាទីឈានមុននៅក្នុងរដ្ឋបាល។ ប្រព័ន្ធអប់រំប្រពៃណីនេះ ព្រះសង្ឃរាជ បព្វជិត ព្រាហ្មណ៍ អ្នកប្រាជ្ញ កវីនិពន្ធ គឺជាសសរស្តម្ភនៃប្រព័ន្ធអប់រំបែបប្រពៃណី។ ប្រព័ន្ធអប់រំបែបប្រពៃណីនេះ បានដួលរលំពេលបាត់បង់ធនធានមនុស្សទាំងអស់នេះ ។

រហូតមកដល់រជ្ជកាលព្រះអង្គឌួង ព្រះអង្គបានខិតខំប្រឹងប្រែងក្នុងការស្តារឡើងវិញនូវព្រះពុទ្ធសាសនា និងសាលាវត្ត។ ព្រះអង្គបានចាត់ទុកវិស័យព្រះពុទ្ធសាសនាជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើឱ្យមានសន្តិភាព និងការរស់ឡើងវិញនៃកម្ពុជា។ សម្រាប់កំណែទម្រង់វិស័យអប់រំ ព្រះអង្គបានកសាងឡើងវិញនូវបណ្ណាល័យ និងការប្រមូលគម្ពីរព្រះពុទ្ធសាសនាដែលបានបាត់បង់ឬក៏ត្រូវបំផ្លាញក្នុងអំឡុងសង្គ្រាម ការប្រមូលកុមារឱ្យចូលរៀននៅតាមសាលាវត្ត។ ការអប់រំនៅសាលាវត្តមានលក្ខណៈជាការទន្ទេញចាំមាត់មិនមានគោលវិធី ឬគោលការណ៍គរុកោសល្យអ្វីឡើយ ដោយផ្តោតតែមូលដ្ឋានច្បាប់ដំបូន្មានដែលដកស្រង់យកចេញពីច្បាប់ផ្សេងៗ ការអាន សរសេរភាសាខ្មែរ គម្ពីរព្រះពុទ្ធសាសនា ច្បាប់កម្មសិទ្ធិ និងលេខនព្វន្តមួយចំនួន។ សាលាវត្តមិនមានរៀបចំកម្មវិធីសិក្សា គ្មានពេលម៉ោងសិក្សារៀនសូត្រច្បាស់លាស់ និងគ្មានការប្រឡងអ្វីទាំងអស់ ហើយគ្រូក៏គ្មានការបណ្តុះបណ្តាលឱ្យបានត្រឹមត្រូវដែរ។

ឈានដល់សម័យ**អាណានិគមនិយមបារាំង** បារាំងបានធ្វើទំនើបកម្មប្រព័ន្ធអប់រំខ្មែរតាមរយៈវិធានការពីរ (ទីមួយ)ការបញ្ជូននិស្សិតកម្ពុជាឱ្យទៅរៀននៅតាមគ្រឹះស្ថានសិក្សានៅបារាំង និងនៅវៀតណាម និង( ទីពីរ )ការបង្កើតប្រព័ន្ធអប់រំផ្លូវការតាមរយៈការបង្កើតសាលារដ្ឋបារាំង-ខ្មែរនៅកម្ពុជា។ ជាមួយនឹងការបង្កើតសាលារដ្ឋបារាំង-ខ្មែរ បារាំងក៏បានយកចិត្តទុកដាក់ផងក្នុងការពង្រឹងការអប់រំតាមសាលាវត្តដើម្បីលើកកម្ពស់ការអប់រំជាខេមរភាសា។ ស្ថិតក្នុងសម័យអាណានិគមនិយមបារាំង ការអភិវឌ្ឍវិស័យអប់រំរដ្ឋនៅកម្ពុជាគឺបានចាប់ផ្តើមក្នុងរាជ្យព្រះបាទស៊ីសុវត្ថិ។ នៅក្នុងឆ្នាំ ១៩១១ ព្រះបាទស៊ីសុវត្ថិ ចុះហត្ថលេខាលើព្រះរាជក្រឹត ដោយតម្រូវឱ្យក្មេងប្រុសដែលមានអាយុចាប់ពី៨ឆ្នាំឡើងទៅ ត្រូវទៅចូលរៀននៅសាលាវត្តបែបថ្មី។ វិធានការនេះគឺជាកំណែទម្រង់ដ៏ធំមួយដើម្បីបង្កើតឱ្យមានការ

អប់រំជាកាតព្វកិច្ច (compulsory) នៅកម្ពុជា។ សាលាវត្តត្រូវបានកំណែទម្រង់បែបថ្មី ដោយគ្រូបង្រៀនត្រូវបានផ្ដល់ប្រាក់បៀវត្ស និងទទួលបានការបណ្ដុះបណ្ដាលពីវិធីសាស្ត្របង្រៀន កម្មវិធីសិក្សាត្រូវបានបន្ថែមមុខវិជ្ជាលេខនព្វន្ត ភាសាបារាំង និងភូមិសាស្ត្រ បន្ថែមពីមុខវិជ្ជាប្រពៃណីដែលមានស្រាប់ឱ្យសមស្របទៅនឹងការវិវត្ត និងតម្រូវការរបស់កម្ពុជា ហើយអធិការសាលាវត្តត្រូវបានបង្កើត និងទទួលបានការបណ្ដុះបណ្ដាលបំប៉នសមត្ថភាពផងដែរ។ នៅដើមសតវត្សរ៍ទី២០ ប្រព័ន្ធអប់រំខ្មែរមិនទាន់មានការអភិវឌ្ឍនៅឡើយ ព្រោះនៅមានសាលាតិចតួចនៅឡើយ មិនអាចផ្ដល់លទ្ធភាពឱ្យកុមារចូលរៀនបានច្រើនទេ។ យើងអាចបែងចែកប្រព័ន្ធអប់រំខ្មែរនៅពាក់កណ្ដាលទី១នៃសតវត្សរ៍ទី២០ជាបីផ្នែកគឺៈ ការអប់រំបែបសាសនា ការអប់រំបែបប្រពៃណី និងការអប់រំចំណេះទូទៅ[២]។ ក្នុងអំឡុងពេលបីទសវត្សរ៍ដំបូងនៃសតវត្សរ៍ទី២០ ស្ថាប័នអប់រំព្រះពុទ្ធសាសនាចំនួន ៤ ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាៈ សាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងក្រុមជំនុំប្រែគម្ពីរព្រះត្រៃបិដក។

មកដល់សម័យ**សង្គមរាស្ត្រនិយម** ប្រព័ន្ធអប់រំបានចាប់ផ្ដើមរីកចម្រើនជាបណ្ដើរៗ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០ តាមរយៈការពង្រីកការអប់រំកម្រិតបឋមសិក្សា និងការបង្កើតគ្រឹះស្ថានឧត្តមសិក្សា។ ដោយឡែក ការអប់រំកម្រិតមធ្យមសិក្សានៅមានកម្រិតនៅឡើយ ដោយសារប្រព័ន្ធអប់រំមានលក្ខណៈជាសាជីកំពូលស្រួចដែលផ្ដោតលើតែគុណភាពដោយមិនគិតពីសមធម៌ ក្នុងគោលបំណងបណ្ដុះបណ្ដាលឥស្សរជនឆ្នើម មានសមត្ថភាពខ្ពស់ សម្រាប់បម្រើការងាររាជការ។ ប្រព័ន្ធអប់រំសម័យនេះ ចំរាញ់តែមនុស្សមានសមត្ថភាពខ្ពស់ ដែលធ្វើឱ្យអត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ ហើយវាបង្កើតឱ្យមានវិសមភាពនៅក្នុងសង្គម។ មាន

សិស្សនៅមធ្យមសិក្សាទុតិយភូមិ៣%ប៉ុណ្ណោះដែលបានប្រឡងជាប់ និង បន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា។ អ្វីដែលជាការកែទម្រង់ដ៏ធំនោះគឺការ យកចិត្តទុកដាក់ខ្លាំងក្នុងការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងការផ្តល់ ប្រាក់បៀវត្សដ៏ច្រើនសន្ធឹកសន្ធាប់។ ជាទូទៅយើងឃើញថា វិជ្ជាជីវៈគ្រូ បង្រៀនត្រូវបានគេចាត់ទុកថាមានកិត្យានុភាពខ្ពស់ជាងគេបំផុត និងត្រូវ បានគោរពយ៉ាងខ្លាំងនៅក្នុងសង្គម។ គ្រូបង្រៀនទទួលបានការគាំទ្រពេញ លេញពីរាជរដ្ឋាភិបាល និងមានគន្លងអាជីពខ្ពង់ខ្ពស់ អាចក្លាយជាឧត្តមមន្ត្រី ឬជាអ្នកនយោបាយ។ ជាមួយគ្នានេះ គេក៏បានមើលឃើញពីលទ្ធផល សិក្សារបស់សិស្ស និស្សិតប្រកបដោយគុណភាពផងដែរ។ ជាទូទៅគេអាច វាយតម្លៃថា សិស្ស-និស្សិតបញ្ចប់ការសិក្សានៅមធ្យមសិក្សា ឬឧត្តមសិក្សា និងគ្រូបង្រៀនសុទ្ធតែមានសមត្ថភាពខ្ពស់ជាធនធានដ៏មានសក្តានុពលពិត ប្រាកដក្នុងការអភិវឌ្ឍប្រទេស។ ទោះបីជាយ៉ាងណាក៏ដោយ ប្រព័ន្ធអប់រំ សម័យសង្គមរាស្ត្រនិយមនេះ ទទួលបានសរសើរជាជាងការស្តីបន្ទោស។

ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា បានចូលដល់ទីបញ្ចប់នៅពេល ដែល**រដ្ឋប្រហារ**របស់លោកសេនាប្រមុខ **លន់ នល់** ដើម្បីផ្តួលរំលំសម្តេច សីហនុបានធ្វើឱ្យសង្គ្រាមស៊ីវិលបានផ្ទុះឡើងនៅឆ្នាំ១៩៧០។ គ្រូបង្រៀន ជាច្រើននាក់បានឆ្លើយតបទៅនឹងការអំពាវនាវរបស់សម្តេច សីហនុ និង បានរត់ទៅចូលរួមក្នុងចលនាទ័ពព្រៃដឹកនាំដោយខ្មែរក្រហម[៣]។ សាកល វិទ្យាល័យ និងសាលារៀននៅកម្ពុជាស្ទើរតែទាំងអស់ត្រូវបានបិទទ្វារជា ស្ថាពរ និងមានតែគ្រឹះស្ថានសិក្សានៅ ភ្នំពេញប៉ុណ្ណោះ ដែលបន្តដំណើរការ ។ សាធារណៈរដ្ឋខ្មែរ ដែលប្រសូតចេញមកពីការធ្វើរដ្ឋប្រហារ ត្រូវបានញាំញីដោយភ្លើងសង្គ្រាមដែលរីករាលដាលទាំងនៅក្រៅទីក្រុងភ្នំពេញ និងនៅ ទីរួមខេត្តមួយចំនួន ហើយរដ្ឋលែងមានឱកាសក្នុងការអភិវឌ្ឍវិស័យអប់រំ ទៀតហើយ។

ក្រោយ**បរាជ័យ**របស់កងទ័ពសេនាប្រមុខ **លន់ នល់** កងទ័ព**ខ្មែរក្រហម**ចូលមកកាន់កាប់ប្រទេសជំនួសវិញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ហើយជាយុគសម័យដែលវិស័យអប់រំត្រូវបានបំផ្លិតបំផ្លាញស្ទើរទាំងស្រុង។ របបខ្មៅងងឹតខ្មែរក្រហមបានកាប់សម្លាប់គ្រូបង្រៀន បំផ្លាញអគារសិក្សា រចនាសម្ព័ន្ធអប់រំ បណ្ណាល័យ សៀវភៅសិក្សា និងសម្ភារៈសិក្សាដទៃទៀត។ល។ គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាចំនួន៧៥% សាស្ត្រាចារ្យនៅសាកលវិទ្យាល័យចំនួន៩១%ព្រមទាំងសិស្សានុសិស្សនៅបឋមសិក្សា និងមធ្យមសិក្សា៦៧% និងនិស្សិតសាកលវិទ្យាល័យចំនួន ៩៦%ត្រូវបានសម្លាប់ ឬស្លាប់ដោយអត់អាហារ(៤)។ ប្រព័ន្ធអប់រំនៅសម័យនោះត្រូវបំផ្លាញដល់ឫសគល់ ហើយបញ្ញវន្តនៅសល់តែប្រមាណតែ១៥% ប៉ុណ្ណោះ។

ក្រោយ**ដួលរលំ**របបឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ **ប៉ុលពត** នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដោយរណសិរ្សសង្គ្រោះជាតិកម្ពុជា រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកយ៉ាងខ្លាំងក្នុងការ**ស្តារវិស័យអប់រំឡើងវិញ**។ ស្ថិតនៅក្នុងដំណាក់កាលស្តារនេះ ប្រព័ន្ធអប់រំនៅពេលនោះត្រូវបានបែងចែក៣ ដំណាក់កាល៖

| **ដំណាក់កាល** | **ចន្លោះឆ្នាំ** | **ប្រព័ន្ធអប់រំ** | **ចំនួនឆ្នាំសិក្សា** | **កំណត់សម្គាល់** |
|---|---|---|---|---|
| **ទីមួយ** | ពីឆ្នាំ **១៩៧៩** ដល់ឆ្នាំ **១៩៨៥** | ៤-៣-៣ | ១០ឆ្នាំ | ❖ បឋមសិក្សា |
| **ទីពីរ** | ពីឆ្នាំ **១៩៨៦** ដល់ឆ្នាំ **១៩៩៥** | ៥-៣-៣ | ១១ឆ្នាំ | ❖ មធ្យមសិក្សាបឋមភូមិ |
| **ទីបី** | ពីឆ្នាំ **១៩៩៦** ដល់បច្ចុប្បន្ន | ៦-៣-៣ | ១២ឆ្នាំ | ❖ មធ្យមសិក្សាទុតិយភូមិ |

នៅដំណាក់កាលទី១នេះ ក្រសួងអប់រំទទួលយកអ្នកណាក៏ដោយឱ្យតែស្ម័គ្រចិត្តមកបង្រៀន ទោះបីជាពួកគេគ្មានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីក្លាយជាគ្រូបង្រៀនក៏ដោយ។ អ្នកដែលស្ម័គ្រចិត្តភាគច្រើន មានកម្រិតសិក្សាមិនលើសពីបឋមសិក្សាឡើយ ហើយដើម្បីក្លាយជាគ្រូបង្រៀន ពួកគាត់ទទួលបានការបណ្តុះបណ្តាលខ្លីពីមួយសប្តាហ៍ទៅបួនខែប៉ុណ្ណោះ។[៦]

[៨៩] នៅឆ្នាំ១៩៨៣ ស្តង់ដារគ្រូបង្រៀនមត្តេយ្យ និងបឋមសិក្សាត្រូវបានបង្កើតឡើងដោយអនុវត្តទៅតាមរូបមន្ត៧+១សម្រាប់ខេត្តតំបន់វាលរាប ប៉ុន្តែសម្រាប់ខេត្តជួបការលំបាក និងតំបន់ដាច់ស្រយាលអនុវត្តតាមបទ ដ្ឋាន៣+១។ នៅឆ្នាំ១៩៨៤ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ត្រូវបានបង្កើតដើម្បីបណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិ ដោយប្រើរូបមន្ត៧+៣ ហើយដើម្បីក្លាយជាគ្រូបង្រៀននៅវិទ្យាល័យ គ្រូមធ្យមសិក្សាបឋមភូមិត្រូវបណ្តុះបណ្តាលរយៈពេល១ខែកន្លះរយៈពេល២ឆ្នាំជាប់គ្នា។

សម្រាប់ដំណាក់កាលទី២រូបមន្តគុណវុឌ្ឍិគ្រូបង្រៀនត្រូវបានអនុវត្តសម្រាប់គ្រូមត្តេយ្យ និងបឋមសិក្សានៅតំបន់វាលរាបត្រូវជ្រើសរើសពីអ្នកដែលប្រឡងធ្លាក់ថ្នាក់ទី១១ ហើយត្រូវសិក្សារយៈពេល២ឆ្នាំ ចំណែកឯខេត្តជួបការលំបាក ឬដាច់ស្រយាលអនុវត្តតាមរូបមន្ត៩+២។ សម្រាប់គ្រូមធ្យមសិក្សាបឋមភូមិគឺថ្នាក់ទី១១+២ ចំណែកគ្រូមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១១+៣។

ដំណាក់កាលទី៣ ចាប់តាំងពីឆ្នាំ១៩៩៦ ប្រព័ន្ធអប់រំ១២ឆ្នាំត្រូវបានអនុវត្តដើម្បីគោរពតាមស្តង់ដារអន្តរជាតិ។ គុណវុឌ្ឍិដើម្បីក្លាយជាគ្រូបឋមសិក្សាគឺថ្នាក់ទី១២+២ និង៩+២ សម្រាប់ខេត្តជួបការលំបាក និងខេត្តដាច់ស្រយាល។ ចំណែកគ្រូមធ្យមសិក្សាបឋមភូមិត្រូវជ្រើសរើសពីក្នុងចំណោមសិស្សបញ្ចប់ការសិក្សាថ្នាក់ទី១២ បន្ទាប់មកទទួលការបណ្តុះបណ្តាលរយៈពេល២ឆ្នាំ។ គ្រូមធ្យមសិក្សាទុតិយភូមិត្រូវអនុវត្តរូបមន្ត១២+៤ ឬបរិញ្ញាបត្រ+១ដែលត្រូវបណ្តុះបណ្តាលនៅមហាវិទ្យាល័យគរុកោសល្យ និងក្រោយមកមានឈ្មោះជាវិទ្យាស្ថានជាតិអប់រំ (NIE)។

## តារាងសង្ខេបគុណវុឌ្ឍិគ្រូបង្រៀន

| | ចន្លោះឆ្នាំ | គ្រូបង្រៀន | គុណវុឌ្ឍិគ្រូបង្រៀន |
|---|---|---|---|

| **ដំណាក់កាល** | | | **ខេត្តវាលរាប** | **ខេត្តជួបការលំបាក/ដាច់ស្រយាល** |
|---|---|---|---|---|
| **ទីមួយ** | ពីឆ្នាំ **១៩៧៩** ដល់ឆ្នាំ **១៩៨៥** | បឋមសិក្សា | រើសអ្នកស្ម័គ្រចិត្ត ៧+១ | រើសអ្នកស្ម័គ្រចិត្ត (១៩៧៩) ៣+១ (១៩៨៣) |
| | | មធ្យមសិក្សាបឋមភូមិ | ៧+៣ | ៧+៣(១៩៨៤) |
| | | មធ្យមសិក្សាទុតិយភូមិ | គ្រូមធ្យមសិក្សាបឋមភូមិត្រូវបណ្ដុះបណ្ដាលរយៈពេល១ខែកន្លះរយៈពេល២ឆ្នាំជាប់គ្នា | |
| **ទីពីរ** | ពីឆ្នាំ **១៩៨៦** ដល់ឆ្នាំ **១៩៩៥** | បឋមសិក្សា | ប្រឡងធ្លាក់ថ្នាក់ទី ១១+២ | ៩+២ |
| | | មធ្យមសិក្សាបឋមភូមិ | ១១+២ | ១១+២ |
| | | មធ្យមសិក្សាទុតិយភូមិ | ១១+៣ | ១១+៣ |
| **ទីបី** | ពីឆ្នាំ **១៩៩៦** ដល់ បច្ចុប្បន្ន | បឋមសិក្សា | ជាប់ ឬធ្លាក់ថ្នាកទី ១២+២ | ៩+២ |
| | | មធ្យមសិក្សាបឋមភូមិ | ជាប់ថ្នាក់ទី១២+២ | ជាប់ថ្នាក់ទី១២+២ |
| | | មធ្យមសិក្សាទុតិយភូមិ | ១២+២ ឬបរិញ្ញា+ ១ | ១២+២ ឬបរិញ្ញា+១ |

## II- អត្ថប្រយោជន៍នៃការអប់រំសម្រាប់កម្ពុជា

ការអប់រំមានតួនាទីកសាងធនធានមនុស្សប្រកបដោយសមត្ថភាពពេញលេញគ្រប់គ្រាន់ មានចំណេះដឹង ចំណេះធ្វើ ឥរិយាបថវិជ្ជមាន និងស្មារតីរួមរស់ជាមួយគ្នា ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គម។ជាការពិតណាស់ ការអប់រំមានអត្ថប្រយោជន៍ជាច្រើនដល់សង្គមមានដូចជា៖

### ក) កាត់បន្ថយភាពក្រីក្រ

ប្រជាពលរដ្ឋដែលទទួលបានការអប់រំគ្រប់គ្រាន់ នឹងមានសមត្ថភាពក្នុងការរិះរកវិធីដោះស្រាយបញ្ហាជីវភាពរស់នៅរបស់ខ្លួន ចេះច្នៃប្រឌិតដោះស្រាយបញ្ហាជីវិត លើកកម្ពស់ជីវភាពរស់នៅ និងអាចចូលរួមជួយអ្នកដទៃទៀតបានផងដែរដោយប្រើប្រាស់ធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធ

ភាព (ឧទា.បន្ទាប់ពីសិក្សាជំនាញកសិកម្ម កសិករអាចដាំដំណាំលើស្រែចំការរបស់ខ្លួនដែលមានស្រាប់បាន២ដងក្នុង១រដូវ និងទទួលបានទិន្នផលខ្ពស់)។

### ខ) បង្កើនប្រាក់ចំណូល

តាមរយៈការអប់រំធ្វើឱ្យសិស្សានុសិស្ស និស្សិតមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើការងារ ឬបង្កើតការងារដោយខ្លួនឯង ដែលជាប្រភពសំខាន់សម្រាប់ចំណូលប្រចាំថ្ងៃក្នុងការដោះស្រាយជីវភាពរស់នៅ ហើយតាមរយៈការប្រឡូកនឹងការងារធ្វើឱ្យសមត្ថភាពរបស់ពួកគេកាន់តែរីកចម្រើន និងកាន់តែមានលទ្ធភាពក្នុងការបង្កើនប្រាក់ចំណូលឱ្យបានច្រើនផងដែរ។

### គ) សុខុមាលភាព

ការអប់រំផ្តល់ឱ្យសិស្សមានការយល់ដឹងពីសុខភាព អនាម័យ និងបរិស្ថានដូចជា៖ ការអនុវត្តអនាម័យល្អ លាងដៃនឹងសាប៊ូ បន្ទោរបង់ក្នុងបង្គន់ ញុំាទឹកស្អាត...ការចូលរួមថែរក្សាបរិស្ថានទាំងក្នុងផ្ទះ សាលារៀន និងសហគមន៍ដូចជា ការសម្អាតទីធ្លា ដាំដើមឈើឡើងវិញ...ជាដើម។ ទាំងអស់នេះសុទ្ធចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់សុខុមាលភាព។

### ឃ) កំណើនសេដ្ឋកិច្ច

ការអប់រំ ជំរុញឱ្យមានកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព តាមរយៈភាពសំបូរបែបនៃធនធានមនុស្សក្នុងការបំពេញសេចក្តីត្រូវការនៃទីផ្សារការងារ។ កាលណាមានការងារធ្វើនាំឱ្យមានប្រាក់ចំណូលសម្រាប់គ្រួសារ ជាហេតុនាំឱ្យជីវភាពគ្រួសារមានការរីកចម្រើន ហើយពេលជីវភាពគ្រួសារជាច្រើនរីកចម្រើន ក៏នាំឱ្យសេដ្ឋកិច្ចជាតិទាំងមូលរីកចម្រើនផងដែរ។ ប្រភពចំណូលនៃភ្នាក់ងារសេដ្ឋកិច្ចមួយនឹងយកទៅចំណាយក្នុងទីផ្សារ ហើយវានឹងក្លាយចំណូលនៃភ្នាក់ងារសេដ្ឋកិច្ចមួយទៀត ជំរុញកំណើនសង្វាក់សេដ្ឋកិច្ច។ មួយវិញទៀត តាមរយៈការអប់រំ គេអាចផលិត

ធនធានមនុស្សបានគ្រប់គ្រាន់ ប្រកបសមត្ថភាពពេញលេញ ចេះច្នៃប្រឌិតបង្កើតថ្មី និងប្រើប្រាស់ធនធានសក្តានុពលជាតិ (ធនធានធម្មជាតិ និងធនធានវប្បធម៌) ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព។

**ង) ធ្វើឱ្យជីវិតរស់នៅកុមារបានល្អប្រសើរ**

កុមារជាអ្នកបន្តវេនពីមនុស្សចាស់។ កាលណាកុមារទាំងអស់បានចូលរៀន ពួកគេនឹងក្លាយជាធនធានមនុស្សដ៏មានសក្តានុពលនាពេលអនាគត សម្រាប់អភិវឌ្ឍន៍សង្គមជាតិ។ ជាមួយគ្នា ការអប់រំធ្វើឱ្យមាតាបិតាមានការយល់ដឹងពីរបៀបថែទាំ និងអប់រំទូន្មានកូនឱ្យក្លាយជាកូនល្អ និងដើរតួយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយបាននូវអត្រាមរណភាពកុមារក្រោម៥ឆ្នាំ។

**ច) គាំទ្រដល់សន្តិភាព**

ការអប់រំមិនត្រឹមតែធ្វើឱ្យសិស្សមានចំណេះដឹង ចំណេះធ្វើ ប៉ុណ្ណោះទេ តែធ្វើឱ្យពួកគេមានឥរិយាបថវិជ្ជមាន និងមានស្មារតីរួមរស់ជាមួយគ្នាក្នុងសង្គមដែលសំដៅដល់ការជួយគាំទ្រដល់សន្តិភាព និងភាពរស់នៅសុខដមរមៀនាជាមួយគ្នា។ ការអប់រំ ធ្វើឱ្យសិស្សចេះដោះស្រាយបញ្ហាដោយសន្តិវិធី និងចេះជួយគ្នាទៅវិញទៅមកឈរលើស្មារតីមនុស្សធម៌ និងអហិង្សាធម៌ ព្រមទាំងកាត់បន្ថយបាននូវបទឧក្រិដ្ឋ និងអសន្តិសុខសង្គម។

**ឆ) កាត់បន្ថយអត្រាកំណើត**

កំណើនមនុស្សច្រើនលើសលប់បង្កផលប៉ះពាល់ដល់បរិស្ថាន និងការរស់នៅ។ នៅពេលប្រជាពលរដ្ឋមានការយល់ដឹងច្រើនពីសុខភាពបន្តពូជ ធ្វើឱ្យអត្រាកំណើតធ្លាក់ចុះ ព្រោះពួកគេចេះរៀបចំផែនការគ្រួសារ និងចង់បានកូនតាមក្តីប្រាថ្នា។

**ជ) ការកើនឡើងនូវទិន្និផលកសិកម្ម**

ការអប់រំធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹង និងមានជំនាញច្បាស់លាស់ក្នុងការលើកកម្ពស់ការងារបង្កបង្កើនផលឱ្យទទួលបានជោគជ័យ។ ៤.ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ កសិករចេះប្រើប្រាស់បច្ចេកទេសកសិកម្មដែលបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ធ្វើឱ្យមានទិន្នផលខ្ពស់ និងឆ្លើយតបនឹងតម្រូវការទីផ្សារ។

**ឈ) កាត់បន្ថយការរៀបការវ័យក្មេង**

ការយល់ដឹងពីច្បាប់អាពាហ៍ពិពាហ៍ និងសុខភាពបន្តពូជ អាចកាត់បន្ថយអត្រារៀបការទាំងវ័យក្មេង និងបង្ការគ្រោះថ្នាក់ពីការរៀបការវ័យក្មេងបាន។

**ញ) កាត់បន្ថយអត្រាមរណៈមាតានិងទារក**

ការអប់រំផ្តល់អត្ថប្រយោជន៍យ៉ាងសំខាន់ក្នុងការកាត់បន្ថយអត្រាមរណភាពមាតានិងទារក។តាមរយៈការអប់រំស្ត្រីនឹងមានការយល់ដឹងពីសុខភាពពេលមានផ្ទៃពោះ និងទៅពិនិត្យផ្ទៃពោះបានទៀងទាត់ ទទួលទានថ្នាំជីវជាតិដែកចាក់ថ្នាំបង្កា និងសម្រាលនៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យ កាត់បន្ថយការឆ្លងទន្លេនៅផ្ទះ និងជាមួយឆ្មបបុរាណដែលមានហានិភ័យខ្ពស់។

**ដ) លើកកម្ពស់យ៉ែនឌ័រ**

ការអប់រំផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ការលើកកម្ពស់យ៉ែនឌ័រនៅក្នុងសង្គម ដោយបញ្ឈប់បាននូវការរើសអើងប្រឆាំងនឹងនារីភេទ។ តាមរយៈការអប់រំធ្វើឱ្យស្ត្រី និងបុរសចេះឱ្យតម្លៃ និងគោរពគ្នាទៅវិញទៅមក និងរួមគ្នាកសាងសុភមង្គលគ្រួសារ ក៏ដូចជាធ្វើការងារជាមួយដើម្បីអភិវឌ្ឍន៍សង្គមជាតិ។

**ឋ) ប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង**

នៅពេលប្រជាពលរដ្ឋមានការយល់ដឹងពីការថែរក្សាសុខភាព ពួកគេមានស្មារតីចូលរួមប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងផ្សេងៗបានទាន់ពេលវេលាតាមរ

យៈការអនុវត្តអនាម័យ ការចែករំលែកព័ត៌មាន និងសហការជាមួយស្ថាប័នជំនាញដើម្បីទប់ស្កាត់ជំងឺទាំងនោះ។

## III- ដំណើរវិវត្តិ ស្ថានភាពវិស័យអប់រំ និងកំណែទម្រង់

### 1) គោលនយោបាយក្រសួងអប់រំ យុវជន និងកីឡា (១៩៩៦)

វិស័យអប់រំនៅប្រទេសកម្ពុជាមានការផ្លាស់ប្តូរជាបន្តបន្ទាប់ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះដែលឆ្លុះបញ្ចាំងពីការប្រឹងប្រែងកសាងប្រព័ន្ធអប់រំមួយឡើងវិញ បន្ទាប់ពីត្រូវបំផ្លាញខ្ទេចខ្ទីក្នុងរបបខ្មែរក្រហម។ បន្ទាប់ពីការចុះកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ប្រទេសកម្ពុជាឈានទៅរកការបោះឆ្នោត និងដំណើរការកសាងសន្តិភាព(៥)។ តាមរយៈកិច្ចព្រមព្រៀងនេះ ផ្តល់ឱកាសដល់ប្រទេសកម្ពុជាទទួលបានការជួយជ្រោមជ្រែងពីសំណាក់ភ្នាក់ងារអភិវឌ្ឍអន្តរជាតិជាច្រើនដូចជា៖ ធនាគារអភិវឌ្ឍអាស៊ី ធនាគារពិភពលោក អង្គការអន្តរជាតិ កម្មវិធីសហប្រតិបត្តិការទ្វេរភាគី រួមទាំងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនទៀត។ នៅឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តដាក់បញ្ចូលមាត្រាមួយចំនួនទាក់ទងនឹងការអប់រំ។ មាត្រាទី៦៨នៃរដ្ឋធម្មនុញ្ញចែងថា "**រដ្ឋផ្តល់ការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ**"។ មិនតែប៉ុណ្ណោះ កម្ពុជាក៏ជាប្រទេសហត្ថលេខីលើលិខិតូបករណ៍អន្តរជាតិដែលទទួលស្គាល់សិទ្ធិពីការអប់រំផងដែរដូចជា៖ (១)**សេចក្តីប្រកាសជាសាកលឆ្នាំ១៩៤៨ ស្តីពីសិទ្ធិមនុស្ស** (២)**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌** (៣)**អនុសញ្ញាស្តីពីសិទ្ធិកុមារ** (៤)**អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងនារីភេទ** (CEDAW)

។ នៅឆ្នាំ១៩៩៦ ក្រសួងអប់រំ យុវជន និងកីឡាបានចេញនូវគោលនយោបាយដោយផ្តោតលើះ (១)ធ្វើសាកលកម្មនូវការអប់រំមូលដ្ឋានចំនួនប្រាំបួនឆ្នាំ និងបង្កើតឱកាសសម្រាប់មុខងារអក្ខរកម្ម (Functional literacy) (២)ធ្វើទំនើបកម្ម និងកែលម្អគុណភាពអប់រំតាមរយៈកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព (៣)ផ្សារភ្ជាប់ការអប់រំ/ការបណ្តុះបណ្តាលជាមួយទីផ្សារការងារ និងសង្គម និង(៤)ស្តារ និងអភិវឌ្ឍន៍វិស័យយុវជន និងកីឡា។ អ្វីដែលជាការផ្លាស់ប្តូរចម្បងចាប់តាំងពីឆ្នាំ១៩៩៦មកគឺ ប្រព័ន្ធអប់រំ១២ឆ្នាំ(៦-៣-៣) ត្រូវបានដាក់ឱ្យអនុវត្តនៅប្រទេសកម្ពុជា ដើម្បីគោរពតាមស្តង់ដារអន្តរជាតិ។

## 2) **ការអប់រំសម្រាប់ទាំងអស់គ្នា២០០៣-២០១៥**(២០០៣)

ដោយសារការអនុវត្តដោយជោគជ័យនូវនយោបាយ "**ឈ្នះ-ឈ្នះ**" របស់រាជរដ្ឋាភិបាលកម្ពុជា អង្គការចាត់តាំងខ្មែរក្រហមត្រូវបានរំលាយទាំងស្រុងនៅឆ្នាំ១៩៩៨ ដោយនាំមកនូវសុខសន្តិភាពពេញផ្ទៃប្រទេស និងការផ្លាស់ប្តូរទិដ្ឋភាពសង្គម និងសេដ្ឋកិច្ច។ សង្គ្រាមស៊ីវិលដែលអូសបន្លាយជិតបីទសវត្សរ៍នៅប្រទេសកម្ពុជាត្រូវបានបញ្ចប់ តែផលវិបាករបស់វានៅតែបន្តប៉ះពាល់យ៉ាងខ្លាំងដល់ដំណើរការអភិវឌ្ឍន៍ប្រទេស ជាពិសេសលើវិស័យអប់រំ។ យោងតាមការអង្កេតអក្ខរកម្មនៅឆ្នាំ២០០០របស់អង្គការ UNESCO /UNDPបានប៉ាន់ប្រមាណថាមានប្រជាជនតែ**៣៦%** ប៉ុណ្ណោះដែលមានចំណេះដឹងទាក់ទងនឹងសមត្ថភាពអក្ខរកម្ម (ចេះអក្សរ)ដែលអាចប្រើប្រាស់សម្រាប់ជីវិតប្រចាំថ្ងៃ និងការបង្កើតប្រាក់ចំណូលបាន ចំណែកឯប្រជាជនចំនួន**៣៦%**ផ្សេងទៀត (មនុស្សពេញវ័យមានប្រមាណជា២,៦លាននាក់) គឺជាអនក្ខរជន (មិនចេះអក្សរ) ហើយប្រជាជន**២៧%** ទៀតចេះអក្សរខ្លះៗ(មនុស្សពេញវ័យប្រមាណ១,៩លាននាក់)។ ជាមួយគ្នានេះ

របាយការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា(MoEYS) នៅឆ្នាំ ២០០០ក៏បានបង្ហាញផងដែរពីអត្រាអក្ខរកម្មជាតិ ដោយលើកឡើងថា មាន**ស្ត្រី៤៥,១%** និងបុរស**២៤,៨%** មិនចេះអក្សរក្នុងចំណោមប្រជាជនសរុប៦,៥លាននាក់ដែលមានអាយុ១៥ឆ្នាំឡើង។ ប្រជាជនប្រមាណ **២,៣៦លាននាក់ជាអនក្ខរជនទាំងស្រុង** ហើយ១,៧លាននាក់ផ្សេងទៀតចេះអក្សរខ្លះៗ។ ចំណែកឯ២,៤១លាននាក់ទៀតចេះអាន និងសរសេរប្រើការបានសម្រាប់ជីវភាពរស់នៅ។ មួយវិញទៀត យោងតាមរបាយការណ៍ក្រុមវាយតម្លៃថ្នាក់ជាតិគម្រោងការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ១៩៩៩ បានរកឃើញលទ្ធផលសិក្សាសិស្សមានកម្រិតទាបនៅតាមតំបន់ដាច់ស្រយាល ហើយក្មេងស្រីៗបោះបង់ការសិក្សាច្រើនជាងក្មេងប្រុស។ តំបន់ដាច់ស្រយាលជាទូទៅជួបការលំបាកខ្លាំងក្នុងការផ្តល់សេវាអប់រំ សូចនាករអប់រំទាំងអស់មានកម្រិតទាប អក្ខរកម្ម និងការអប់រំក្រៅប្រព័ន្ធមិនទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់ទេ។ សម្រាប់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈនៅតាមទីក្រុងក៏ជួបប្រទះនូវបញ្ហាប្រឈមច្រើនផងដែរដោយសារវគ្គបណ្តុះបណ្តាលនៅមិនទាន់មានភាពទាក់ទាញយុវជនឱ្យចូលរៀនបានច្រើន និង ភាពមិនស៊ីសង្វាក់គ្នារវាងជំនាញដែលបានបណ្តុះបណ្តាល និងតម្រូវការទីផ្សារការងារ។ គុណភាពនៃការអប់រំមូលដ្ឋានជាទូទៅ និងលទ្ធភាពទទួលបានសេវានេះនៅមានកម្រិតនៅឡើយ[៦]។ សម្រាប់ការបកស្រាយពី**បញ្ហាប្រឈម**បន្ថែមទៀត យើងសូមធ្វើការបង្ហាញពីការប្រៀបធៀបស្ថិតិអប់រំរវាងឆ្នាំ១៩៩០ និងឆ្នាំ២០០១ នៅមុនការដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-២០០៥។

**ស្ថិតិសាលារៀន ផលធៀបសិស្ស-គ្រូ (ប្រៀបធៀបឆ្នាំ១៩៩០-២០០១)**

| ឆ្នាំសិក្សា | សាលាបឋមសិក្សា | សិស្សបឋមសិក្សា | ចំនួនគ្រូ | ផលធៀបសិស្ស-គ្រូ | មធ្យមភាគសិស្ស/សាលា |
|---|---|---|---|---|---|
| ១៩៩០-៩១ | ៤,៦៦៥ | ១,៣៧១,៦៩៤ | ៤០,៦៣១ | ៣៤ | ២៩៤ |
| ២០០១-០២ | ៥,៤៦៨ | ២,៧០៥,៤៥៣ | ៥៤,៥១៩ | ៥០ | ៤៩៤ |

| | | | | | |
|---|---|---|---|---|---|
| **អត្រាកើន** | ៨០៣ | ១,៣៣៣,៧៥៩ | ១៣,៨៨៨ | ១៦ | ២០០ |

យោងតាមតារាងខាងលើ វាបង្ហាញថា ចំនួនសាលារៀនបានកើនចំនួន**៨០៣**សាលា និងគ្រូបង្រៀនកើនឡើងចំនួន**១៣,៨៨៨**នាក់ពីឆ្នាំ ១៩៩០ ដល់២០០១ តែចំនួនសិស្សកើនឡើងទ្វេរដងក្នុងរវាងដប់ឆ្នាំនេះ (កើនឡើងប្រមាណ**១,៣៣៣,៧៥៩**នាក់)។ បើយើងប្រៀបធៀបអត្រាកើនឡើងនូវចំនួនសាលារៀន ចំនួនគ្រូបង្រៀន និងចំនួនសិស្ស យើងឃើញថា ចំនួនសាលារៀន និងគ្រូបង្រៀនកើនតិចតួច មិនអាចផ្គត់ផ្គង់គ្រប់គ្រាន់ទៅនឹងការកើនឡើងនូវចំនួនសិស្សដ៏ច្រើនសន្ធឹកសន្ធាប់ ហើយអតុល្យភាពនេះ នាំឱ្យកើនឡើងនូវអត្រាផលធៀបសិស្ស-គ្រូ និងមធ្យមភាគសិស្សក្នុងមួយសាលា ពោលគឺចំនួនសិស្សក្នុងមួយថ្នាក់កើនឡើង។ យោងតាមការស្រាវជ្រាវរបស់លោក Tan (២០០៧) ក៏បានបង្ហាញផងដែរពីបញ្ហាប្រឈមវិស័យអប់រំមួយចំនួនទាក់ទងនឹងចំនួនសិស្សច្រើនក្នុងមួយថ្នាក់ដែលឆ្លុះបញ្ចាំងពីការកើនឡើងនូវផលធៀបសិស្ស-គ្រូខាងលើ ការធ្លាក់ចុះនូវគុណភាពបង្រៀន-រៀន និងបញ្ហាកង្វះសៀវភៅសិក្សាគោលនៅតាមសាលារៀន[៧]។ មួយវិញទៀត យើងក៏ឃើញមានការស្រាវជ្រាវមួយចំនួនទៀតផងដែរ ដែលបានលើកឡើងពីបញ្ហាប្រឈមទាក់ទងនឹងជំនាញគ្រប់គ្រង និងដឹកនាំរបស់នាយកសាលា សមត្ថភាពបង្រៀនរបស់គ្រូ ថវិកា និងធនធានគាំទ្រតួយ៉ាងដូចះ ការស្រាវជ្រាវរបស់អង្គការUNESCO (២០០០) លោក Courtney (២០០៧) និងលោក Kim & rouse (២០១១)។ របាយការណ៍ UNESCO បានបង្ហាញថា ទោះបីជាកម្ពុជាមានគោលនយោបាយអប់រំ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ១៩៩៥/២០០០ ក្នុងការកែលម្អគុណភាព និងលទ្ធភាពទទួលបានសមធម៌ត្រូវបានចាត់ទុកថាជាគោលដៅគោលនយោបាយសំខាន់ៗ។ សាលារៀនភាគច្រើននៅប្រទេសកម្ពុជានៅតែខ្វះខាតសម្ភារៈរូបវន្ត ដូចជា៖ សៀវភៅសិក្សា បណ្ណាល័យ បន្ទប់ពិសោធន៍ និងសម្ភារៈសិក្សាដទៃទៀតទាំងបរិមាណ និងគុណ

ភាព។ សាលារៀនជាច្រើនខ្វះសម្ភារឧបទេសបង្រៀន និងរៀនមានលក្ខណៈស្តង់ដារ ហើយបណ្ណាល័យមិនមានឯកសារគ្រប់គ្រាន់[៨]។ លោក Courtney (២០០៧) បានបង្ហាញក្នុងរបាយការណ៍លោកថា សមត្ថភាពគណៈគ្រប់គ្រងសាលាលើការគ្រប់គ្រង និងដឹកនាំនៅមានកម្រិតទាប ការបង្រៀន និងរៀនមិនមានគុណភាព ព្រមទាំងកង្វះធនធានគាំទ្រដល់ការអភិវឌ្ឍន៍វិស័យអប់រំទាំងមូលក៏ដូចជាសាលារៀន[៩]។ ជាមួយគ្នានេះ លោក Kim & rouse (២០១១) ក៏បានបង្ហាញផងដែរថា ទោះបីអត្រាចូលរៀនខ្ពស់ក៏ភាពជោគជ័យកើតចេញពីការអប់រំនៅតែមានកម្រិតដោយមានអត្រាបោះបង់ការសិក្សាខ្ពស់ស្មើតែ៥០%ដែលនេះមានន័យថា មានតែជាងពាក់កណ្តាលប៉ុណ្ណោះបានបញ្ចប់ការសិក្សាកម្រិតបឋមសិក្សា[១០]។

ការទទួលបានការអប់រំមូលដ្ឋានប្រកបដោយសមធម៌ និងគុណភាពបានក្លាយជាក្តីកង្វល់កាន់តែខ្លាំងឡើង សម្រាប់ទាំងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា។ អត្រាបោះបង់ការសិក្សាខ្ពស់ និងអត្រារៀនត្រួតថ្នាក់នៅក្នុងការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញបានចោទសួរប្រទេសកម្ពុជាអំពីគុណភាពនៃការផ្តល់ និងការទទួលបានសេវាអប់រំ។ ការយកចិត្តទុកដាក់ត្រូវបានផ្តោតទៅការបញ្ចប់បឋមសិក្សា និងការអភិវឌ្ឍសកម្មភាពអប់រំក្រៅប្រព័ន្ធដូចជា៖ អក្ខរកម្ម ការចូលរៀនឡើងវិញ ការអប់រំពហុភាសា(multilingual education) និងកម្មវិធីសមមូលដើម្បីឈានទៅដល់ក្រុមដែលពិបាកទៅដល់ (the hard-to-reach groups)។

**ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ** រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ជាខ្លាំងក្នុងការអភិវឌ្ឍន៍វិស័យអប់រំ ស្របតាមកិច្ចប្រឹងប្រែងជាសាកលដែលអនុវត្តនៅតាមប្រទេសជាច្រើននៅលើសាកលលោក។ នៅឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមក្នុងសេចក្តីថ្លែងការទីក្រុងដាកា ដោយគាំទ្រដល់ការអនុវត្តគោលដៅនៃ**ការអប់រំទាំងអស់គ្នា**

(Education For All-EFA)។ ការអប់រំសម្រាប់ទាំងអស់គ្នាគឺជាត្រីវិស័យមួយសម្រាប់តម្រង់ទិសគោលនយោបាយ និងជាវេទិកាមួយសម្រាប់ប្រមូលផ្តុំរាល់សកម្មភាពអប់រំទាំងអស់ឱ្យស្ថិតនៅក្រោមដំបូលតែមួយ។ ក្នុងឆ្នាំ២០០០ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តបង្កើនការវិនិយោគលើវិស័យអប់រំ ឱ្យស្របនឹងចរន្តពិភពលោកស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា(៦) និងឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ខ្លួន។ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ **២០០៣-២០១៥** ផ្តល់នូវក្របខ័ណ្ឌការងារយ៉ាងទូលំទូលាយដើម្បីសម្រេចឱ្យបាននូវគោលដៅអប់រំ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនផងដែរក្នុងការធ្វើឱ្យសម្រេចបាននូវការអប់រំសម្រាប់ទាំងអស់គ្នា (EFA) ដោយធានាថា កុមារ និងយុវវ័យកម្ពុជាទាំងអស់មានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំត្រឹមឆ្នាំ២០១៥(១១)។ ផែនការអប់រំសម្រាប់ទាំងអស់គ្នានេះ រួមបញ្ចូលទាំងផែនការបច្ចេកទេស និងហិរញ្ញវត្ថុយ៉ាងទូលំទូលាយដោយផ្តោតលើ៖ (ក)**យុទ្ធសាស្ត្រឆ្លើយតបយេនឌ័រ** (ខ)**ការថែទាំ និងការអភិវឌ្ឍកុមារតូចៗ** (គ)**ការអប់រំមូលដ្ឋានជាផ្លូវការ** (ឃ)**ការអប់រំក្រៅប្រព័ន្ធ និងអក្ខរកម្មមនុស្សពេញវ័យ**។ ផែនការនេះសង្កត់ធ្ងន់លើការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពសេវាអប់រំ និងការពង្រីកលទ្ធភាពទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ពិសេសប្រជាពលរដ្ឋដែលងាយរងគ្រោះ ក្រុមទទួលបានផលប្រយោជន៍សង្គមតិចតួច (disadvantaged group)និងនៅតំបន់ជនបទដាច់ស្រយ៉ាល។ វាតំណាងឱ្យគោលការណ៍ដែលការផ្តល់ការអប់រំជាមូលដ្ឋានទាំងការអប់រំផ្លូវការ ឬក្រៅផ្លូវការគឺជាការទទួលខុសត្រូវចម្បងរបស់រដ្ឋ។ អាទិភាពសំខាន់គឺពង្រីកថ្នាក់អក្ខរកម្មសម្រាប់មនុស្សពេញវ័យ ជាពិសេសសម្រាប់ក្រុមដែលជួបការលំបាកនៅតាមតំបន់ដែលមិនសូវមានការងារ។ ក្រសួងអប់រំ យុវជន និងកីឡាកំពុងរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំដើម្បីបង្កើនអក្ខរជនពី**៣៦%** ទៅ**៥៦%** ក្នុងរយៈ

ពេល៥ឆ្នាំ។ ដើម្បីសម្រេចបានជោគជ័យនៃការអបរំសម្រាប់ទាំងអស់គ្នានេះ យុទ្ធសាស្ត្រមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តរួមមាន៖ គម្រោងផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅតាមជនបទ ដើម្បីបង្កើនអត្រាឆ្លងភូមិសិក្សាពីថ្នាក់បឋមសិក្សាទៅអនុវិទ្យាល័យ ការកសាងសមត្ថភាពគ្រូបង្រៀនតាមរយៈការបណ្តុះបណ្តាលមុនពេល និងក្នុងអំឡុងពេលបំពេញការងារ ការត្រួតពិនិត្យលទ្ធផលសិក្សាសិស្សជាដើម។ មួយវិញទៀត ដើម្បីពង្រីកលទ្ធភាពទទួលបានការអប់រំកម្រិតបឋមសិក្សាប្រកបដោយសមធម៌ ជាពិសេសកុមារមកពីគ្រួសារក្រីក្រ និងកុមារី រាជរដ្ឋាភិបាលកម្ពុជាបានពិភាក្សាយ៉ាងទូលំទូលាយជាមួយភ្នាក់ងារអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដោយបានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួនថែមទៀតដូចជា៖ (១)កាត់បន្ថយរបាំងឧបសគ្គនៃការចំណាយសម្រាប់ការអប់រំមូលដ្ឋាន។ (២)ការកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា ជាពិសេសនៅថ្នាក់ទី១-៦ និង(៣)លុបបំបាត់សាលាបឋមសិក្សាដែលមិនពេញលេញ រួមទាំងពង្រីកថ្នាក់ទី៧-១២[១២]។ ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រខាងលើ ជំនួយជាច្រើនត្រូវបានផ្តល់ដល់ប្រទេសកម្ពុជា។ នៅចន្លោះឆ្នាំ១៩៩៣ និង២០០៥ ភ្នាក់ងារផ្តល់ជំនួយបានផ្តល់៥ពាន់លានដុល្លារ រួមទាំងថវិកា៥០៤លានដុល្លារដែលបានសន្យាផ្តល់សម្រាប់តែឆ្នាំ២០០៥[១៣]។ ម្ចាស់ជំនួយធំៗពីរគឺ ធនាគារពិភពលោក (WB) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានបង្កើនការចំណាយចរន្តរបស់ខ្លួនផងដែរលើវិស័យអប់រំ ដោយកើនពី ១៦.២០%ក្នុងឆ្នាំ២០០១ ទៅ២០%ក្នុងឆ្នាំ២០០៥ និងពី១.៧១%ទៅ ២.៤៨%បើធៀបនឹងផលិតផលក្នុងស្រុកសរុប (GDP)។

កំណែទម្រង់វិស័យអប់រំនាពេលបច្ចុប្បន្ននៅកម្ពុជាកើតចេញពីការប្តេជ្ញាចិត្តខាងនយោបាយ និងការដាក់សម្ពាធ ឬនិន្នាការសកលលោក ជាពិសេសនៅក្នុងសហគមន៍អ្នកផ្តល់ជំនួយ នៅពេលក្លាយជាសមាជិកនៃ

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (the Association of South-East Asian Nations) អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organization) និងសំណើជាបន្តបន្ទាប់របស់ម្ចាស់ជំនួយ និងភ្នាក់ងារបច្ចេកទេសដូចជា៖ ធនាគរពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី យូនីសែហ្វ យូនីស្កូ និងគណៈកម្មការអឺរ៉ុប។ មានការផ្លាស់ប្តូរដ៏សំខាន់ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរបស់កម្ពុជា (MDGs) និងគោលដៅ EFA ដែលកំណត់ត្រឹមឆ្នាំ២០១៥។ ជាមួយគ្នានេះ មានការព្រួយបារម្ភខ្លាំងពីសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការស្រូបយក និងយល់ដឹងស៊ីជម្រៅពីទស្សនៈ គំនិត និងមូលនិធិសកលដើម្បីបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រដែលមានលក្ខណៈឆ្លើយតប ការអនុវគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួនដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (Education Strategic Plan-ESP) និង គម្រោងគាំទ្រវិស័យអប់រំ (Education Sector Support Project-ESSP)។ ការផ្លាស់ប្តូរជាសកលបានជំរុញប្រទេសកម្ពុជាឱ្យរៀបចំឡើងវិញ និងកែទម្រង់ប្រព័ន្ធអប់រំរបស់ខ្លួន និងការគ្រប់គ្រងសាលារៀន។ ខណៈសេដ្ឋកិច្ច និងបច្ចេកវិទ្យារីកចម្រើនខ្លាំង ទីផ្សារទាមទារឱ្យមានតម្រូវការកម្លាំងពលកម្មដែលមានកម្រិតអប់រំខ្ពស់ និងសមត្ថភាពក៏បង្កើនវិសាលភាពរបស់ខ្លួន ដូច្នេះការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិតត្រូវពង្រឹងជាមូលដ្ឋាន។ ការពង្រឹងសមត្ថភាពនៃកម្លាំងពលកម្មនៅតាមកម្រិត ដើម្បីផ្តួចផ្តើម រៀបចំបង្កើត គិតស៊ីជម្រៅ អនុវត្ត និងវាយតម្លៃគោលនយោបាយអប់រំនៅក្នុងវិស័យរដ្ឋាភិបាលនឹងមិនទទួលបានជោគជ័យឡើយ ប្រសិនបើស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់គ្រូបង្រៀន និងថ្នាក់ដឹកនាំសាលាមិនត្រូវបានគេយកចិត្តទុកដាក់។ ស្ថានភាពសេដ្ឋកិច្ច និងសង្គមទាបក្នុងចំណោមបុគ្គលិកបង្រៀន និងមិនបង្រៀន រាំងខ្ទប់ដល់ការជ្រើសរើស និងរក្សាបេក្ខជនដែលមានសមត្ថភាពឱ្យនៅក្នុងប្រព័ន្ធ។

**លទ្ធផលនៃការអនុវត្តផែនការអប់រំសម្រាប់ទាំងអស់គ្នា**បាន លេចចេញជាផ្លែផ្កាតាមរយៈការកើនឡើងនៃអត្រាចុះឈ្មោះចូលរៀន ដែលជាការផ្លាស់ប្តូរមួយដ៏ធំក្នុងចំណោមការផ្លាស់ប្តូរដទៃទៀត។ លទ្ធផលនេះបានមកពីការខិតខំប្រឹងប្រែងរួមគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់៖ កម្រិតបុគ្គលម្នាក់ៗ ម្ចាស់ជំនួយភ្នាក់ងារអន្តរជាតិ និងរាជរដ្ឋាភិបាល។ ការកើនឡើងនៃការចុះឈ្មោះចូលរៀនអាចត្រូវបានកំណត់គុណសម្បត្តិដូចខាងក្រោម៖

1. ការលុបបំបាត់រាល់ទម្រង់នៃការបង់ថ្លៃចុះឈ្មោះ ថ្លៃវិភាគទាន និងថ្លៃឈ្នួលផ្សេងៗ។ ការបង់ថ្លៃទាំងនេះគឺជាឧបសគ្គចំពោះការរៀនសូត្រសម្រាប់កុមារនៅតាមជនបទ និងដាច់ស្រយាលជាច្រើន ។ នាយកសាលា និងអ្នកតំណាងគណៈកម្មាធិការទ្រទ្រង់សាលារៀនដែលបានសម្ភាសន៍សម្រាប់ការសិក្សាស្រាវជ្រាវ បានកត់សម្គាល់ថាសកម្មភាពធ្វើកសិកម្មនៅចុងរដូវវស្សា និងកង្វះថវិកាបានបណ្តាលឱ្យឪពុកម្តាយជាច្រើននៅតំបន់ដាច់ស្រយាល និងជនបទក្រីក្រពន្យារពេលចុះឈ្មោះចូលរៀនកូន ឬឪពុកម្តាយខ្លះមិនចុះឈ្មោះកូនចូលរៀនតែម្តង។ ការលុបបំបាត់ថ្លៃចុះឈ្មោះចូលរៀន និងប្រភេទផ្សេងៗទៀតដែលបានចូលរួមលើភាពជោគជ័យក្នុងការបង្កើនការចុះឈ្មោះចូលរៀន[១៤]។
2. យុទ្ធនាការយ៉ាងទូលំទូលាយ និងជាប្រចាំ អំពីគោលនយោបាយរបស់រដ្ឋាភិបាល និងការប្តេជ្ញាចិត្តក្នុងការផ្តល់ការអប់រំដល់កុមារទាំងអស់ដែលមានអាយុចូលរៀន នៅមុនថ្ងៃចុះឈ្មោះចូលរៀនក៏បាននាំមកនូវការកើនឡើងនូវចំនួនសិស្សចូលរៀននៅដើមឆ្នាំសិក្សាផងដែរ។ ការពិភាក្សាជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ (key informants) ដូចជា៖ នាយកសាលា និងអ្នកតំណាងសហគមន៍បានលើកឡើងថាការផ្សព្វផ្សាយអំពីកំណែទម្រង់

គោលនយោបាយ និងយុទ្ធនាការអប់រំអំពីការលុបបំបាត់ការបង់ថ្លៃសិក្សានៅដើមឆ្នាំសិក្សា និងការបង់ថ្លៃផ្សេងៗទៀតមានលក្ខណៈទូលំទូលាយ និងមានប្រសិទ្ធភាពជាង៩០% នៃសំណាកគំរូក្នុងការស្ទង់មតិ PAP បានដឹងពីគោលនយោបាយលុបបំបាត់ការបង់ថ្លៃសិក្សា[១៤]។ យុទ្ធនាការ និងការផ្សព្វផ្សាយព័ត៌មានត្រូវបានធ្វើឡើងតាមទម្រង់ផ្សេងៗគ្នា ឧទាហរណ៍តាមរយៈសិស្សានុសិស្ស ឪពុកម្ដាយ អ្នកដឹកនាំសហគមន៍ ផ្ទាំងរូបភាពប្រព័ន្ធផ្សព្វផ្សាយ និងនៅតាមឱកាសផ្សេងៗដូចជា ពិធីបុណ្យប្រពៃណីនៅទូទាំងសហគមន៍ ពិធីបើកបវេសនកាលនៅតាមសាលារៀន ពិធីបុណ្យផ្កា និងថ្ងៃបុណ្យព្រះពុទ្ធសាសនាផ្សេងៗទៀត។ ព័ត៌មានត្រូវបានផ្សព្វផ្សាយនៅតាមការជួបជុំសហគមន៍តាមទីផ្សារ ក្រុមប្រឹក្សាឃុំ វត្តអារាម និងតាមសាលារៀន។

3. ការកសាងសាលាបឋមសិក្សាបន្ថែមនៅទូទាំងប្រទេសបានធ្វើឱ្យការអប់រំកាន់តែមានកម្រិតដល់កុមារមួយចំនួន ជាពិសេសកុមារដែលរស់នៅតាមជនបទ និងតំបន់ដាច់ស្រយាល។
4. ការផ្លាស់ប្ដូរអាកប្បកិរិយារបស់មាតាបិតាសិស្ស ទៅលើការអប់រំកុមារ ជាពិសេសកូនស្រី ដែលមានភាពវិជ្ជមានច្រើន។ ខណៈដែលការអប់រំកាន់តែមានភាពងាយស្រួលជាមួយនឹងការកសាងសាលារៀនកាន់តែច្រើន ឪពុកម្ដាយមានការប្ដេជ្ញាចិត្តថែមទៀតក្នុងការបញ្ជូនកូនៗ របស់ពួកគេទៅសាលារៀន ទាំងក្មេងប្រុសនិងក្មេងស្រី ព្រមផ្ដល់លទ្ធភាពដល់ពួកគេនៅទទួលសេវាអប់រំឱ្យបានយូរតាមដែលអាចធ្វើបាន។
5. យុទ្ធសាស្ត្រមួយចំនួនផ្សេងទៀតដែលគាំទ្រដោយអង្គការជាតិនិងអន្តរជាតិដូចជាកម្មវិធីអាហារូបករណ៍ កម្មវិធីផ្ដល់អាហារដែលផ្ដល់ដោយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលក៏បាន

រួមចំណែកដល់ការចុះឈ្មោះចូលរៀន និងការរក្សាទុកកុមារឱ្យនៅជាមួយការអប់រំផងដែរ។

**សម្រាប់ការបង្ហាញបន្តទៅទៀតនេះ គឺការសិក្សាប្រៀបធៀបសូចនាករលទ្ធផលសម្រេចបាន និងចំណុចដៅ ឆ្នាំ២០០០-២០០៥។**

**ស្ថិតិអត្រាចូលរៀនថ្មី និងអត្រាពិតនៃការសិក្សា** [៧](ប្រភព MoEYS (២០០៥) និងTan, C. (២០០៧))

| **សូចនាករ** | **លទ្ធផលជាក់ស្តែង ២០០០-២០០១** | | **លទ្ធផលជាក់ស្តែង ២០០៤-២០០៥** | | **ចំណុចដៅ ២០០៤-២០០៥** | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| អត្រាចូលរៀនថ្មី | ៧៦.៤% | ៧៤.៩% | ៨១.០% | ៧៩.៥% | ៩០% | ៩០% |
| **អត្រាពិតចុះឈ្មោះចូលរៀន** | | | | | | |
| បឋមសិក្សា (ទូទាំងប្រទេស) | **៨៣.៥%** | **៨០.៧%** | **៩១.៩%** | **៩០.៧%** | **៩២%** | **៩១%** |
| បឋមសិក្សា (តំបន់ទីក្រុង) | ៨៦.៤% | ៨៣.២% | ៩១.៦% | ៩០.៤% | ៩៥% | ៩៤% |
| បឋមសិក្សា (តំបន់ជនបទ) | ៨៤.១% | ៨១.០% | ៩២.៤% | ៩១.២% | ៩២% | ៩១% |
| បឋមសិក្សា (តំបន់ដាច់ស្រយ៉ាល) | ៦២.៣% | ៥៨.២% | ៨២.៥% | ៧៩.៤% | ៧៦% | ៧៥% |
| មធ្យមសិក្សាបឋមភូមិ(ទូទាំងប្រទេស) | **១៦.៦%** | **១៣.៧%** | **២៦.១%** | **២៤.៨%** | **៤០%** | **៣៩%** |
| មធ្យមសិក្សាបឋមភូមិ (តំបន់ទីក្រុង) | ២៩.៥% | ២៦.៨% | ៤១.៣% | ៤០.៥% | ៥០% | ៥០% |
| មធ្យមសិក្សាបឋមភូមិៈ(តំបន់ជនបទ) | ១៤.១% | ១១.០% | ២៣.៧% | ២២.២% | ៣៥% | ៣៤% |
| មធ្យមសិក្សាបឋមភូមិៈ(តំបន់ដាច់ស្រយ៉ាល) | ១.២% | ១.០% | ៣.៩% | ៤.១% | ១៥% | ១៥% |
| មធ្យមសិក្សាទុតិយភូមិ | **៧.៧%** | **៥.៤%** | **៩.៣%** | **៧.៩%** | **១៥%** | **១៤%** |

ផ្អែកតាមតារាងខាងលើ យើងឃើញថា អត្រាចូលរៀនថ្មីមានការកើនឡើងពី ៧៦.៤% នៅឆ្នាំសិក្សា២០០០-២០០១ ទៅ ៨១.០% ឆ្នាំសិក្សា ២០០៤-២០០៥ តិចជាងចំណុចដៅ៩% អត្រាពិតនៃការសិក្សា កម្រិតបឋមសិក្សាទូទៅប្រទេសមានការកើនឡើងពី៨៣.៥% ទៅ៩១.៩% សម្រេចបានតាមចំណុចដៅ។ សម្រាប់មធ្យមសិក្សាបឋមភូមិកើនឡើងពី១៦.៦% ទៅ២៦.១% ទាបជាងចំណុចដៅ១៣.៩% ហើយមធ្យមសិក្សាទុតិយភូមិកើនពី៧.៧% ទៅ៩.៣% ទាបជាង

ចំណុចដៅ៥.៧%។ ជាទូទៅ យើងសង្កេតឃើញថា អត្រាពិតនៃការសិក្សាកម្រិតបឋមសិក្សាខ្ពស់ ប្រមាណ៩១.៩% សម្រេចតាមចំណុចដៅ តែការអប់រំនៅកម្រិតមធ្យមសិក្សានៅទាបនៅឡើយ បានសម្រេចត្រឹមតែ២៦.១% សម្រាប់មធ្យមបឋមភូមិ និង៩.៣% **សម្រាប់**ទុតិយភូមិ។ នេះមានន័យថា **សិស្សភាគច្រើនបញ្ចប់ការសិក្សាត្រឹមកម្រិតបឋមសិក្សា ហើយការឆ្លងភូមិសិក្សាទៅធម្យមសិក្សាមានចំនួនតិចតួចបំផុត។** ដោយសារអត្រាបោះបង់ការសិក្សាច្រើន យើងឃើញថា ការអនុវត្តការអប់រំជាមូលដ្ឋានរយៈពេល៩ឆ្នាំមិនបានជោគជ័យទេ ហើយធនធានមនុស្សភាគច្រើននៅតែមានកម្រិតអប់រំទាបនៅឡើយ។

ទោះបីជាយ៉ាងណាក៏ដោយ យើងឃើញសញ្ញាណជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រការអប់រំសម្រាប់ទាំងអស់គ្នា តាមរយៈនៃការកៀរគកុមារដែលគ្រប់អាយុឱ្យចូលរៀន និងជំរុញលើកទឹកចិត្តកុមារលើសអាយុផ្សេងៗទៀតឱ្យទទួលបានសេវាអប់រំ។ ផ្អែកតាមស្ថិតិអត្រារួម និងអត្រាពិតនៃការសិក្សា កម្រិតបឋមសិក្សា បង្ហាញថា អត្រាពិតក្នុងឆ្នាំសិក្សា២០០៤-២០០៥ មាន៩១.៩% ដែលនេះមានន័យថា កុមារគ្រប់អាយុចូលរៀន(អាយុ៦ឆ្នាំ)បានចុះឈ្មោះចូលរៀនទាន់ពេលបានច្រើន។ ជាមួយគ្នានេះ អត្រារួមនៃការសិក្សាមានការថយចុះពី ១២៥.១% នៅឆ្នាំសិក្សា២០០១-២០០២ មកត្រឹម១១៩.៩%នៅឆ្នាំសិក្សា២០០៤-២០០៥ ដែលនេះមានន័យថា កុមារដែលលើសអាយុចុះឈ្មោះចូលរៀនយឺតពេលមានការថយចុះ។

(☞**<u>បញ្ជាក់៖</u>***អត្រារួម មានចំនួនភាគរយលើស ដោយសារការចុះឈ្មោះចូលរៀនមានទាំងកុមារគ្រប់អាយុចូលរៀន និង កុមារលើសអាយុ-ឧទាហរណ៍ ក្នុងភូមិមានកុមារអាយុ៦ឆ្នាំ គ្រប់អាយុចូលរៀនចំនួន១០០នាក់ បានចុះឈ្មោះចូលរៀនថ្នាក់ទី១ តែនៅដើមសិក្សាក៏មានកុមារលើសអាយុ៦ឆ្នាំចំនួន៣០នាក់ផង*

*ដែរ ដែលមិនបានចុះចូលរៀនឆ្នាំកន្លងមក បានមកចុះឈ្មោះចូលរៀនដែរ។ ស្ថិតិសិស្សចុះឈ្មោះចូលរៀនមាន១៣០នាក់ ដោយមានអត្រាពិត១០០នាក់ បូកនឹងអត្រាកុមារលើសអាយុ៣០នាក់។ ដូច្នេះ**ភាគរយអត្រាសរុបនៃកុមារចុះឈ្មោះចូលរៀនក៏កើនលើសផងដែរ***)

បើតាមរបាយការណ៍ស្រាវជ្រាវរបស់ World Bank (២០០៥) បានបង្ហាញថា កុមារកម្ពុជាចំនួន**១១%** មិនបានចូលរៀន និងកុមារ**៥៦%** អាយុចន្លោះពី១៥ ទៅ១៨ឆ្នាំចូលរៀននៅបឋមសិក្សា និងបញ្ចប់ការសិក្សាត្រឹមកម្រិតនេះ ហើយមានត្រឹម៣៥% ប៉ុណ្ណោះដែលបានបញ្ចប់ឆ្នាំសិក្សាអប់រំមូលដ្ឋាន(៩ឆ្នាំ)[១៥]។

ទោះបីជា វិស័យអប់រំមានការរីកចម្រើនទៅមុខយ៉ាងឆាប់រហ័សក៏ដោយ ការបោះបង់ការសិក្សានៅតែជាបញ្ហាប្រឈមមួយដដែល។ អត្រារៀនត្រួតថ្នាក់ និងការបោះបង់ការសិក្សាចាប់ពីថ្នាក់ទី១ ដល់ទី៩ ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៥ ។ ជាទូទៅ គេកត់សម្គាល់ឃើញថា អត្រាត្រួតថ្នាក់ ត្រូវបានកាត់បន្ថយប្រហែល៥០% នៅគ្រប់កម្រិតថ្នាក់ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០០៥។ ទោះបីយ៉ាងណាក៏ដោយ អត្រានេះនៅតែស្ថិតក្រោមចំណុចដៅដែលចែងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ។ លើសពីនេះទៅទៀត អត្រាបោះបង់ការសិក្សានៅតែមិនប្រែប្រួលនៅគ្រប់ថ្នាក់ទាំងអស់ ពោលគឺនៅតែខ្ពស់ដដែលលើកលែងតែថ្នាក់ទី៩ ចាប់តាំងពីឆ្នាំ១៩៩៧មក។

### 3) ផែនការយុទ្ធសាស្ត្រ២០០៦-២០១០ (២០០៥)

ក្រោយអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០០០-២០០៥ និងគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នាបានបញ្ចប់នៅចុងឆ្នាំ២០០៥។ ក្រសួងរៀបចំធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំខ្លួន ដោយមានការចូលរួមយ៉ាងទូលំទូលាយពីភាគីពាក់ព័ន្ធនានា។ ការអនុវត្តកន្លងបង្ហាញពីភាពវិជ្ជមានច្រើនទាក់ទងការរីកចម្រើនវិស័យអប់រំគួរឱ្យកត់

សម្គាល់។ វិស័យអប់រំគឺជាវិស័យមួយដែលត្រូវបានទទួលស្គាល់ថាសម្រេចបានជោគជ័យនៅក្នុងទិដ្ឋភាពសេដ្ឋកិច្ច-សង្គមកិច្ចរបស់កម្ពុជា ទាំងក្នុងការងារកំណែទម្រង់ ទាំងនៅក្នុងការសម្រេចបាននូវសមិទ្ធិផលទាំងឡាយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមជាច្រើននៅតែកើតមានឡើងនៅឡើយ ហើយនៅក្នុងចំណោមបញ្ហាប្រឈមទាំងនោះ មានជាអាទិ៍ ភាពចាំបាច់ និងបន្ទាប់ក្នុងការលើកកម្ពស់គុណភាពអប់រំ (ក្រសួងអយក ២០០៥)។

ចាប់តាំងពីផែនការយុទ្ធសាស្ត្រវិស័យអប់រំដំបូង (ESP ២០០០-២០០៥) បានបង្ហាញនូវសញ្ញាគួរឱ្យភ្ញាក់ផ្អើលក្នុងការចុះឈ្មោះចូលរៀន អត្រារៀនត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សានៅចន្លោះឆ្នាំ ២០០០ និង ២០០៥ ។ តែទោះយ៉ាងណាក៏ដោយ ក៏លទ្ធផលជាក់ស្តែងមួយចំនួនធំមិនបានសម្រេចឆ្លើយតបទៅតាមចំណុចដៅដែលបានកំណត់ ។ **ផលធៀបសិស្ស-គ្រូ**ក្នុងឆ្នាំ២០០៤-២០០៥នៅតែច្រើន (ប្រមាណ ៥៣.៥) ដែលបញ្ជាក់ថា ចំនួនសិស្សច្រើនក្នុងមួយថ្នាក់ ហើយស្ថិតិខ្ពស់នេះធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់គុណភាពអប់រំ។ សម្រាប់ផលធៀបសិស្ស-គ្រូនៅកម្រិតមធ្យមសិក្សាក៏ដូចគ្នាដែរ គឺមិនបានឆ្លើយតបទៅនឹងចំណុចដៅទេ។ ជាមួយគ្នានេះ ផ្អែកតាមស្ថិតិក្នុងតារាងខាងលើក៏បានបង្ហាញផងដែរពីអត្រារៀនត្រួតថ្នាក់សម្រាប់ថ្នាក់ទី១ ទី២ និងទី៣មានការរីកចម្រើនតិចតួចបំផុត។

ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០០-២០០៥ ដោយជោគជ័យគួរឱ្យកត់សម្គាល់លើអត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សា និងសម្រេចលទ្ធផលតាមចំណុចដៅដែលបានកំណត់ ពោលគឺកើនឡើងពី**៨៣.៥០%** នៅឆ្នាំសិក្សា២០០០-២០០១ ដល់**៩០.៧០%** នៅឆ្នាំសិក្សា២០០៤-២០០៥ ធៀបនឹងចំណុចដៅត្រឹម**៩២%**។ ទោះបីយ៉ាងណាក៏ដោយ អត្រាពិតនៃការសិក្សា នៅកម្រិតមធ្យមសិក្សាទាំងបឋមភូមិ

និងទុតិយភូមិនៅតិចតួចបំផុតតាំងពីឆ្នាំ២០០០ ដល់២០០៥ គឺស្ថិតកម្រិតមធ្យមភាគដោយមធ្យមសិក្សាបឋមភូមិសម្រេចបានត្រឹម**២៦.១០%** និងទុតិយភូមិមានតែ**៩.៣០%**ប៉ុណ្ណោះ។ ផ្អែកស្ថិតិនេះ បង្ហាញថាសិស្សបន្តការសិក្សានៅកម្រិតមធ្យមសិក្សានៅមានចំនួនតិច ហើយអត្រាបោះបង់ការសិក្សាមានខ្ពស់ ជាពិសេសសិស្សស្រី។

ផ្អែកតាមអត្រារួម និងអត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបង្ហាញថា ការចូលរៀនរបស់កុមារលើសអាយុចូលរៀននៅតាមកម្រិតថ្នាក់នីមួយៗមានអត្រាខ្ពស់ដដែល មិនមានការប្រែប្រួលច្រើនទេ។ **នេះមានន័យថា កុមារចូលរៀនយឺតពេលនៅមានចំនួនច្រើន**។ អត្រាចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា បានកើនឡើងពី **១០៩.៨%** នៅឆ្នាំសិក្សា២០០០-២០០១ ដល់**១២៤.០%** នៅឆ្នាំសិក្សា ២០០៥-២០០៦។ ចំណែកឯ កម្រិតមធ្យមសិក្សាបឋមភូមិកើនពី **៣២.៧%** នៅឆ្នាំសិក្សា២០០០-២០០១ ដល់**៦០.០%** ឆ្នាំសិក្សា២០០៥-២០០៦ ហើយកម្រិតមធ្យមសិក្សាទុតិយភូមិកើនឡើងពី**១០.៩%**នៅឆ្នាំសិក្សា២០០០-២០០១ដល់**១៩.៣%**ឆ្នាំសិក្សា២០០៥-២០០៦។ **ទោះបីជា ក្រសួងអប់រំបានកំណត់សូចនាករវិជ្ជមាន ក៏ទិន្នន័យខាងលើបានបង្ហាញថា ក្រសួងមិនបានបំពេញតាមគោលដៅភាគច្រើនដែលចែងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០១-២០០៥**(៧)។

**អាទិភាពដែលបានកំណត់ក្នុងវិស័យអប់រំ ២០០៦-២០១០** ឆ្លុះបញ្ចាំងពីសូចនាករដែលមិនទាន់បានសម្រេច និងទិសដៅនៃកំណែទម្រង់អប់រំនៅក្នុងផែនការមុនទាំងពីរ។ អាទិភាពមិនទាន់សម្រេចរួមៈ មានការទទួលបានសេវាអប់រំប្រកបដោយសមធម៌ គុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ ការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពសម្រាប់វិមជ្ឈការ និងយុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហាដែលមានទំនាក់ទំនងគ្នា(១២)។ ក្រសួងអប់រំយុវជននិងកីឡាកម្ពុជាបានកំណត់លទ្ធភាពទទួលបានការអប់រំ

ប្រកបដោយសមធម៌ សម្រេចការអប់រំមូលដ្ឋាន៩ឆ្នាំសម្រាប់កុមារទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ក្រសួងបានព្យាយាមលុបបំបាត់វិសមភាពយេនឌ័ររវាងតំបន់ជនបទ និងតំបន់ទីក្រុងនៅក្នុងការអប់រំមូលដ្ឋាន (ថ្នាក់ទីមួយ រហូត ដល់ថ្នាក់ទីប្រាំបួន) និងការអប់រំកម្រិតមធ្យម (ថ្នាក់ទី១០ រហូតដល់ថ្នាក់ទី១២)[៧]។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាក់ទងនឹងគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់នូវគោលដៅនៃការបង្កើនប្រាក់ខែជូនគ្រូបង្រៀន លើកកម្ពស់ការបណ្តុះបណ្តាលគ្រូមុនចូលបម្រើការងារ និងក្នុងអំឡុងពេលបម្រើការងារ ការអនុវត្តបទដ្ឋានកម្មវិធីសិក្សា និងការផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលតេស្តស្តង់ដារប្រចាំឆ្នាំ នៅពាក់កណ្តាលឆ្នាំ២០០៨។ **ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៦-២០១០** ផ្តោតលើវិស័យចំនួន០៣ គឺការទទួលបានសេវាអប់រំប្រកបដោយសមធម៌ គុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ ព្រមទាំងការអភិវឌ្ឍស្ថាប័នដែលសង្កត់ធ្ងន់លើការកសាងសមត្ថភាពសម្រាប់វិមជ្ឈការ។ ផ្តោតលើការអប់រំតាមមធ្យមសិក្សាបឋមភូមិ ផែនការយុទ្ធសាស្ត្រអប់រំបានកំណត់ទិសដៅដូចខាងក្រោម: (១)**កាត់បន្ថយរនាំងឧបសគ្គសម្រាប់សិស្សានុសិស្ស** (២)**បង្កើនគុណភាព និងប្រសិទ្ធភាព** (៣)**បង្កើនអត្រាគង់វង្ស (survival rates) ថ្នាក់ទី៧-៩ និងអត្រាឆ្លងភូមិសិក្សាចូលរៀន ថ្នាក់ទី១០ តាមរយៈកម្មវិធីអាហារូបករណ៍ ការពង្រឹងសមត្ថភាពបង្រៀន និងរៀន / និងពង្រឹងប្រព័ន្ធប្រឡងនិង** (៤)**ណែនាំបទដ្ឋានអប្បបរមាសម្រាប់ការសិក្សារបស់សិស្ស។ ចំពោះការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ គោលនយោបាយស្រដៀងគ្នានេះត្រូវបានអនុវត្តដើម្បីធានាថាចំនួនសិស្សកាន់តែច្រើនឡើង** (ជាពិសេសសិស្សដែលមកពីតំបន់ក្រីក្រនៅជនបទ) មានលទ្ធភាពទទួលបានការអប់រំនៅកម្រិតថ្នាក់វិទ្យាល័យ និងកម្រិតលើសពីនេះ។ ESP ក៏កំណត់គោលដៅបរិមាណលម្អិតសម្រាប់សូចនាករដែលបានជ្រើសរើស។ ចំពោះលទ្ធភាពទទួលបានសេវាអប់រំ វាមានបំណងសម្រេចបានត្រឹម

ឆ្នាំ២០០៩/២០១០ អត្រារួមនៃការចូលរៀនមាន ៥០% សម្រាប់ការអប់រំអនុវិទ្យាល័យនៅទូទាំងប្រទេស (៦០% សម្រាប់ទីក្រុងទីប្រជុំជន ៥០% សម្រាប់តំបន់ជនបទ និង៤០% សម្រាប់តំបន់ដាច់ស្រយាល) និងអត្រាបញ្ចប់ ៧៥% ។ ចំពោះថ្នាក់វិទ្យាល័យវិញកំណត់អត្រារួមនៃការចូលរៀន ២៨%ក្នុងរយៈពេលដូចគ្នានឹងចំណុចដៅ។ អត្រាឆ្លងភូមិសិក្សាពីកម្រិតបឋមសិក្សាទៅកម្រិតមធ្យមសិក្សាបឋមភូមិ៩៧% និងពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិអាចឈានដល់៩៨% ។

**ចំណុចដៅ និងសូចនាករឆ្នាំ២០០៥-២០១០** [១២]

| ចំណុចដៅ និងសូចនាករ | | សូចនាករ ២០០៥ | ចំណុចដៅ ២០១០ |
|---|---|---|---|
| ១ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា(%) | ៩១.៩ | ១០០ |
| ២ | អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ(%) | ២៦.១ | ៧៥ |
| ៣ | អត្រាគង់វង្ស-ថ្នាក់ទី១ដល់ទី៦ | ៥៣.១ | ១០០ |
| ៤ | អត្រាគង់វង្ស-ថ្នាក់ទី១ ដល់ទី៩ | ៣០.១៨ | ៥០ |
| ៥ | អក្ខរកម្មអ្នកដែលមានអាយុពី១៥-២៤ឆ្នាំ (%) | ៨៣.៤ | ៩៥ |

ក្រសួងបានកំណត់ចំណុចដៅនៅចុងឆ្នាំ២០១០នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ខ្លួន ដោយកំណត់សូចនាករសម្រេចឱ្យបាន១០០%នៃអត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សា៧៥% សម្រាប់មធ្យមសិក្សា និងបង្កើនអត្រាគង់វង្ស ព្រមទាំងបង្កើនអត្រាអក្ខរកម្មមនុស្សពេញវ័យពីអាយុ១៥ ដល់២៤ឆ្នាំ ឱ្យដល់៩៥%។

☞ ***ដើម្បីសម្រេចចំណុចដៅខាងលើនេះ យុទ្ធសាស្ត្រចម្បងៗ និងសកម្មភាពសំខាន់ ត្រូវបានដាក់ចេញឱ្យអនុវត្តរួមមាន[១២]៖***

- បង្កើនចំនួនកុមារថ្នាក់មត្តេយ្យសិក្សា ដែលចូលរៀនក្នុងកម្មវិធីអប់រំកុមារតូចដែលបានរៀបចំឡើងនៅក្នុងសាលា សហគមន៍ និងតាមផ្ទះ។

- បង្កើនចំនួនសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ជាពិសេសនៅតំបន់ដាច់ស្រយាល និងតំបន់ដែលទទួលសេវាកម្មមិនគ្រប់គ្រាន់។
- បង្កើនចំនួនគ្រូបង្រៀន ទាំងគ្រូប្រុស និងគ្រូស្រីនៅគ្រប់កម្រិតសិក្សាទាំងនោះ ដើម្បីលើកកម្ពស់ផលធៀបសិស្ស-គ្រូ និងសមាមាត្របុគ្គលិកស្រី ជាពិសេស ការផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់បំពេញការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។
- លើកកម្ពស់គុណភាពគ្រូបង្រៀន តាមរយៈការអភិវឌ្ឍមុខរបរវិជ្ជាជីវៈដែលផ្សារភ្ជាប់ទៅនឹងការផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់ការបំពេញការងារ។
- យកចិត្តទុកដាក់ជាពិសេសក្នុងការបង្កើនប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន(បាននឹងកំពុងដំណើរការ) និងបើកប្រាក់បៀវត្សរ៍ឱ្យទាន់ពេលវេលា។
- ធានាគុណភាពអប់រំ តាមរយៈការកែលម្អការផ្តល់នូវសៀវភៅសិក្សា សម្ភារៈ សិក្សា បរិក្ខារអប់រំ បណ្ណាល័យ និងមន្ទីរពិសោធន៍។
- រៀបចំឱ្យមានស្តង់ដារគុណភាពគ្រប់កម្រិត និងប្រព័ន្ធវាយតម្លៃថ្នាក់ជាតិមួយសម្រាប់ការអប់រំមូលដ្ឋាន។
- បង្កើនចំនួនអន្តេវាសិកដ្ឋានដែលមានសុវត្ថិភាពសម្រាប់សិស្សស្រីដែលមកពីតំបន់ឆ្ងាយៗ ដើម្បីមករៀននៅសាលាមធ្យមសិក្សាបឋមភូមិដែលជិតបំផុត នៅលើមូលដ្ឋាននៃគម្រោងសាកល្បងគំរូដែលបាន និងកំពុងដំណើរការរួចហើយ។
- កាត់បន្ថយបន្ទុកចំណាយរបស់សិស្សក្រីក្រ ជាពិសេសសិស្សស្រីតាមរយៈការផ្តល់អាហារូបករណ៍ (នៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា) និងការលុបបំបាត់ការបង់ប្រាក់ក្រៅផ្លូវការគ្រប់ប្រភេទទៅឱ្យគ្រូ។

- ពង្រីក និងកំណត់មុខសញ្ញាឱ្យបានល្អជាងមុនសម្រាប់កម្មវិធីផ្តល់អាហារសម្រន់នៅបឋមសិក្សា និងកម្មវិធីលើកទឹកចិត្តសម្រាប់សិស្សថ្នាក់ទី៧ ដល់ទី៩។
- បន្តធានាឱ្យមានការវិភាជន៍ឱ្យបានគ្រប់គ្រាន់ និងការផ្តល់ឱ្យបានទាន់ពេលវេលានូវថវិកាចរន្ត សម្រាប់វិស័យអប់រំ ជាពិសេសសម្រាប់ការអប់រំ មូលដ្ឋាន។
- បង្កើន និងកែលម្អកម្មវិធីអក្ខរកម្មសម្រាប់មនុស្សពេញវ័យ ជាពិសេសសម្រាប់ស្ត្រី។

សម្រាប់កម្រិតឧត្តមសិក្សា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ២០០៦-២០១០ បានកំណត់យុទ្ធសាស្ត្រថា ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការកើនឡើងយ៉ាងឆាប់រហ័សនូវការអប់រំកម្រិតឧត្តមសិក្សា នាយកដ្ឋានឧត្តមសិក្សានៅក្នុងក្រសួងអប់រំយុវជន និងកីឡាបានផ្លាស់ប្តូរតួនាទីរបស់ខ្លួនជាភ្នាក់ងារត្រួតពិនិត្យទៅរកអ្នកផ្តល់សេវាកម្មជំនាញវិជ្ជាជីវៈក្នុងការត្រួតពិនិត្យ ការវិភាគ និងការបង្កើតគោលនយោបាយ។ ជាលទ្ធផល តួនាទីដ៏សំខាន់របស់នាយកដ្ឋានឧត្តមសិក្សាត្រូវបានកំណត់ដូចខាងក្រោម៖

1. បង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់វិស័យឧត្តមសិក្សា
2. អាជ្ញាបណ្ណស្ថាប័នឧត្តមសិក្សាសម្រាប់ប្រតិបត្តិការរបស់ពួកគេ
3. ជួយដល់គ្រឹះស្ថានអប់រំឧត្តមសិក្សាដើម្បីបង្កើតកម្មវិធីសិក្សា និងឧបករណ៍គ្រប់គ្រងដែលត្រូវការដើម្បីជួយបំពេញតាមស្តង់ដារនៃការទទួលស្គាល់គុណភាពអប់រំ
4. បង្កើនគុណភាព និងប្រសិទ្ធភាពនៃការអប់រំកម្រិតខ្ពស់នៅទូទាំងប្រទេស[១២]

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃគោលនយោបាយអភិវឌ្ឍន៍ជាតិ និងជាចំណុចអាទិភាព។ សារសំខាន់ៗ

មួយចំនួនត្រូវបានបង្ហាញក្នុងផែនការរួមទាំង (១)ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីបង្កើត និងអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា (សង្កត់ធ្ងន់លើគុណភាព និងក្រមសីលធម៌ខ្ពស់) ដើម្បីអភិវឌ្ឍសង្គមដែលមានមូលដ្ឋានផ្អែកលើចំណេះដឹងនៅក្នុងប្រទេស និង (២)បេសកកម្មរបស់ក្រសួងអប់រំយុវជន និងកីឡាដើម្បីដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំយុវជន និងវិស័យកីឡាឆ្លើយតបទៅនឹងវិមជ្ឈការសេដ្ឋកិច្ចសង្គម និងវប្បធម៌[១២]។

ការដាក់ចេញផែនការយុទ្ធសាស្ត្រវិស័យអប់រំសម្រាប់ការអប់រំកុមារ និងយុវវ័យកម្ពុជា ជាសញ្ញាមួយនៃការប្ដេជ្ញាចិត្តរបស់ក្រសួងអប់រំដើម្បីធ្វើកំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា។ ផែនការនេះកំណត់អាទិភាព និងយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់ការអប់រំជាបន្តបន្ទាប់ និងរក្សាលទ្ធផលទទួលបានការអប់រំប្រកបដោយសមធម៌ និងគុណភាពអប់រំខ្ពស់ជាអាទិភាពខ្ពស់បំផុត។ នៅពេលដែលបានណែនាំជាផ្លូវការនូវផែនការថ្មីនេះនៅខែធ្នូ ឆ្នាំ២០០៥ ឯកឧត្ដម **ករុណ ផេខ** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានសំដៅដល់កំណែទម្រង់ការអប់រំនៅកម្ពុជាថា **"នៅតែស្ថិតក្នុងដំណើរដ៏វែងឆ្ងាយ"**

- **កំណែទម្រង់កម្មវិធីសិក្សា២០០៥-២០០៩** (Curriculum Reform)[១៦]

មុនកំណែទម្រង់ កម្មវិធីសិក្សាកម្រិតបឋមសិក្សា និងមធ្យមសិក្សាត្រូវបានបង្កើត និងអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡាក្នុងឆ្នាំ ១៩៩៧។ សៀវភៅសិក្សាត្រូវបានរៀបចំនិងបោះពុម្ពផ្សាយនៅថ្នាក់កណ្តាល និងចែកចាយដល់សាលារៀននៅទូទាំងប្រទេសដោយឥតគិតថ្លៃ។ ដើម្បីបង្កើនភាពពាក់ព័ន្ធនៃកម្មវិធីសិក្សាមុខវិជ្ជាជំនាញបំណិនជីវិតត្រូវបានរៀបចំឡើងដែលគ្របដណ្តប់លើជំនាញជាច្រើន។ ការិយាល័យអប់រំស្រុក និងសាលារៀនដែលពាក់ព័ន្ធអាចធ្វើការជាមួយគ្នាដើម្បីជ្រើសរើសប្រធាន

បទដែលគ្របដណ្តប់ និងបង្រៀននៅក្នុងប្រធានបទអាស្រ័យលើតម្រូវការរបស់សាលារៀននៅក្នុងតំបន់នីមួយៗ។ គោលបំណងនៃកម្មវិធីសិក្សាបឋមសិក្សា បឋមភូមិគឺផ្តល់ជូនដល់សិស្សទាំងអស់នូវចំណេះដឹង និងជំនាញទូលំទូលាយដូចជា៖ ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ ការសិក្សាសង្គម បំណិនជីវិតជំនាញសិក្សា និងការអប់រំវិជ្ជាជីវៈ។ កម្មវិធីសិក្សាក៏ផ្តោតទៅលើការអភិវឌ្ឍបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនដែលចាំបាច់ដើម្បីឱ្យសិស្សអាចចូលរួមចំណែកក្នុងនាមជាសមាជិកដែលមានផលិតភាពនៃសង្គមកម្ពុជាហើយអាចសិក្សាបន្ថែមទៀតនៅថ្នាក់ខ្ពស់ ឬចូលរួមក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស។ កម្មវិធីសិក្សាថ្នាក់វិទ្យាល័យមានគោលបំណងផ្តល់ជូនដល់សិស្សនូវចំណេះដឹងកម្រិតខ្ពស់អំពីអក្សរសិល្ប៍ខ្មែរ និងគណិតវិទ្យា។ ចំណេះដឹងជ្រៅជ្រះអំពីអត្តសញ្ញាណជាតិ និងការយល់ដឹងទូលំទូលាយពីសីលធម៌ និងការទទួលខុសត្រូវស៊ីវិល ជំនាញជីវិតប្រចាំថ្ងៃដែលអាចឱ្យមានការចូលរួមក្នុងជីវិតសហគមន៍ និងសង្គម ការយល់ដឹងទូលំទូលាយអំពីពិភពធម្មជាតិ និងគោលការណ៍វិទ្យាសាស្ត្រ និងសមត្ថភាពទំនាក់ទំនងខ្ពស់ក្នុងភាសាបរទេស

ក្រោយរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០០៦-២០១០ កម្មវិធីសិក្សាត្រូវបានកំណែទម្រង់ថ្មី និងដាក់ឱ្យអនុវត្តសាកល្បងមួយដើម្បីធ្វើឱ្យទាន់សម័យកម្មវិធីសិក្សាដែលបោះពុម្ពនៅក្នុងឆ្នាំ១៩៩៧ ដោយក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីសិក្សាដែលបានកែសម្រួលត្រូវបានគេរំពឹងថានឹងត្រូវបានដាក់ឱ្យប្រើប្រាស់នៅទូទាំងប្រទេសក្នុងឆ្នាំសិក្សា ២០០៧-២០០៨ សម្រាប់កម្រិតអប់រំមូលដ្ឋាន។ ជាមួយគ្នានេះ ស្តង់ដារកម្មវិធីសិក្សា និងស្តង់ដារតាមមុខវិជ្ជាត្រូវបានបង្កើត ក្នុងនោះស្តង់ដារទី១ (សម្រាប់ថ្នាក់ទី១-៣) ស្តង់ដារទី២ (សម្រាប់ថ្នាក់ទី៤-៦) និងស្តង់ដាទី៣ (សម្រាប់ថ្នាក់ទី៧-៩) ។ សេចក្តីណែនាំនៃកម្មវិធីសិក្សាថ្មីសម្រាប់កម្រិតក្រោយអប់រំមូលដ្ឋាន (ថ្នាក់ទី១០-១២) នៅតែមិនទាន់បានរៀបចំ

នៅឡើយ។ កំណែទម្រង់កម្មវិធីសិក្សានៅពេលនោះគឺផ្តោតទៅលើការចាប់ផ្តើមអនុវត្តនូវប្រព័ន្ធតាមដានដែលតម្រូវឱ្យ "**សិស្សត្រូវបានផ្តល់ជម្រើសយកជំនាញខាងវិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គមសម្រាប់មធ្យមសិក្សាទុតិយភូមិ**"។ ការអនុវត្តបែបនេះ សិស្សអាចផ្តោតលើតំបន់ជាក់លាក់ មានចំណាប់អារម្មណ៍ និងធ្វើឱ្យចំណេះដឹងរបស់ពួកគេកាន់តែស៊ីជម្រៅតាមរយៈការពង្រីកមេរៀនសិក្សា និងការអនុវត្ត។ លក្ខណៈពិសេសមួយផ្សេងទៀតនៃកម្មវិធីសិក្សាថ្មីនេះគឺការផ្តល់ជូននូវសំណុំឯកសារសិក្សា និងបង្រៀនដ៏ទូលំទូលាយ។ សំណុំនេះរួមមាន: (១)គោលនយោបាយកម្មវិធីសិក្សាសម្រាប់ការអប់រំមូលដ្ឋាន (២)កម្មវិធីសិក្សាលម្អិតសម្រាប់គ្រប់មុខវិជ្ជា។ (៣)គំរូនៃការវាយតម្លៃលទ្ធផលសិក្សាសិស្ស។ (៤)សៀវភៅសិស្ស និង (៥)សៀវភៅគ្រូបង្រៀន។ នៅដំណាក់កាលនេះ គេឃើញមានការបោះពុម្ពសៀវភៅគ្រូសម្រាប់គ្រូបង្រៀនប្រើប្រាស់ និងស្វែងយល់ដើម្បីពង្រឹងការបង្រៀន និងរៀនរបស់ខ្លួន ហើយនៅដំណាក់កាលក្រោយមកទៀត យើងមិនឃើញក្រសួងបោះពុម្ពសៀវភៅគ្រូសម្រាប់តម្រង់ទិស និងណែនាំគ្រូជាច់ដោយឡែកទៀតទេ។ ជាមួយគ្នានេះ ប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សាសិស្សត្រូវបានរៀបចំច្បាស់លាស់ ដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យមួយជាក់លាក់ និងគំរូដែលបានកំណត់នៅក្នុងសម្ភារៈសម្រាប់មេរៀន និងមុខវិជ្ជាទាំងអស់។ ទាក់ទងនឹងការធ្វើមូលដ្ឋានីយកម្មនៃមាតិកាកម្មវិធីសិក្សា កម្មវិធីសិក្សាដែលបានកែសម្រួលនេះត្រូវបានបង្កើតឡើងដោយសមាសភាគបទដ្ឋានជាតិ និងសមាសធាតុបំណិនជីវិតក្នុងមូលដ្ឋានរបស់សិស្ស។ កម្មវិធីសិក្សាថ្នាក់ជាតិត្រូវសិក្សារយៈពេល៣០ម៉ោងក្នុងមួយសប្តាហ៍ ដោយកម្មវិធីសិក្សាបំណិនជីវិតមានរយៈពេល២ ទៅ៥ ម៉ោងក្នុងមួយសប្តាហ៍សម្រាប់កម្រិតស្តង់ដារទី ៣(កម្រិតមធ្យមសិក្សាបឋមភូមិ )។

ផែនការយុទ្ធសាស្ត្រអប់រំ(ESP) សម្រាប់ឆ្នាំ ២០០៦-២០១០ គ្របដណ្តប់លើតំបន់យុទ្ធសាស្ត្រចំនួនបី ដោយមានសូចនាករច្បាស់លាស់

មួយចំនួន។ តំបន់យុទ្ធសាស្ត្ររបស់ ESP គឺការទទួលបានការអប់រំ គុណភាពនៃការអប់រំ និងសមត្ថភាព។ មានវឌ្ឍនភាពដ៏រឹងមាំសម្រាប់តំបន់យុទ្ធសាស្ត្រនៃការទទួលបានការអប់រំកម្រិតបឋមសិក្សា និងការអប់រំកម្រិតខ្ពស់។ ការអប់រំមត្តេយសិក្សា និងមធ្យមសិក្សាឥឡូវនេះត្រូវការការយកចិត្តទុកដាក់បន្ថែមទៀតលើផ្នែកគោលនយោបាយ។ ភាពរីកចម្រើនគួរឱ្យចាប់អារម្មណ៍បំផុតក្នុងការបង្កើនលទ្ធភាពទទួលបានការអប់រំកម្រិតបឋម ដោយសារអត្រាចុះឈ្មោះចូលរៀនមានប្រហែល៩៥% នៅក្នុងឆ្នាំ ២០១០។ គោលដៅនៃការចុះឈ្មោះចូលរៀនបានកើនឡើងនៅថ្នាក់វិទ្យាល័យ (មធ្យមសិក្សាទុតិយភូមិ) តែវឌ្ឍនភាពនៃការអប់រំកុមារតូច(អាយុ៣-៥ឆ្នាំ) និងកម្រិតមធ្យមសិក្សាបឋមភូមិ មានភាពយឺតយ៉ាវ។ វិធានការគោលនយោបាយទំនងជាត្រូវការការយកចិត្តទុកដាក់ទាំងការកសាងសាលារៀន ការផ្គត់ផ្គង់សាលារៀន និងកាត់បន្ថយបន្ទុកចំណាយសម្រាប់មាតាបិតា។ ការកែសម្រួលនាពេលអនាគតនៃ ESP គួរតែផ្តល់នូវការវិភាគអំពីមូលហេតុដែលសូចនាករជាក់លាក់មួយចំនួនដូចជាអត្រាចូលរៀនមធ្យមសិក្សាអនុវត្តមិនបានសម្រេចគោលដៅ និងកំណត់នូវវិធានការកែតម្រូវ។

### ខណៈពេលអត្រាសិក្សានៅកម្រិតបឋមសិក្សាមានការកើនឡើង (១៧)

ក្នុងពេលជាមួយគ្នាដែរ ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិបានកើនឡើងប្រមាណ៥០% ប៉ុន្តែការគ្របដណ្តប់នៅតែមានកម្រិតទាបនៅឡើយគឺតិចជាង២០%នៃចំនួនប្រជាជន។ ប្រទេសកម្ពុជាអាចទទួលបានអត្ថប្រយោជន៍ពី "ការបែងចែកប្រជាសាស្ត្រ" នេះ ទាក់ទងនឹងទំហំតូចសម្រាប់កម្រិតបឋមសិក្សា ប៉ុន្តែតម្រូវឱ្យមានការបណ្តុះបណ្តាលដល់គ្រូបឋមសិក្សាឡើងវិញ និងការកែសម្រួលសម្រាប់មត្តេយសិក្សា ឬមធ្យមសិក្សា។ ការអប់រំកុមារតូចតម្រូវឱ្យមានការយកចិត្តទុកដាក់ពីគោលនយោបាយថ្មីដោយសារតែមានផលប្រយោជន៍សេដ្ឋកិច្ច សមធម៌ និងប្រសិទ្ធភាព

ច្រើនក្នុងការវិនិយោគនៅក្នុងកម្រិតនេះ។ ការរៀបចំអ្នកថែទាំកុមារតូចដែលមានគុណភាពល្អ ជាពិសេសស្ត្រីដែលមានប្រាក់ចំណូលទាបអាចឱ្យពួកគេធ្វើការនៅខាងក្រៅផ្ទះ។ កុមារដែលទទួលបានអត្ថប្រយោជន៍ពីការអប់រំកុមារតូចក៏ទំនងជាធ្វើបានល្អប្រសើរនៅក្នុងកម្រិតខ្ពស់ដែរ។ ភ័ស្តុតាងពីការថយចុះសមត្ថភាពនៃការយល់ដឹងរបស់កុមារដោយសារតែកង្វះកម្មវិធីថែទាំកុមារដែលមានគុណភាពគឺមានលក្ខណៈអវិជ្ជមាន និងគួរឱ្យព្រួយបារម្ភ ពិសេសកុមារដែលស្ថិតនៅក្នុងគ្រួសារដែលប្រាក់ចំណូលទាប។

- ***ភាពមិនស៊ីសង្វាក់គ្នានៃតម្រូវការគឺជាឧបសគ្គចម្បងមួយដល់ការចូលរួមក្នុងការអប់រំកម្រិតមធ្យមសិក្សា***[១៧]

តម្លៃឱកាសនៃការចំណាយពេលវេលានៅសាលាមាននិន្នាការកើនឡើងយ៉ាងខ្លាំងសម្រាប់កុមារនៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ឧបករណ៍គោលនយោបាយមួយដើម្បីដោះស្រាយបញ្ហានេះគឺ កម្មវិធីអាហារូបករណ៍របស់រដ្ឋាភិបាលបានទទួលជោគជ័យយ៉ាងខ្លាំងក្នុងការរក្សាកុមារនៅក្នុងការអប់រំ។ ការវាយតម្លៃផលប៉ះពាល់យ៉ាងហ្មត់ចត់ដែលធ្វើឡើងដោយជំនួយគាំទ្រពីធនាគារពិភពលោកបង្ហាញពីផលប៉ះពាល់ (impact) ដ៏ធំធេងនៃកម្មវិធីអាហារូបករណ៍ដែលផ្តល់ការឧបត្ថម្ភ (ពី៤៥ ទៅ៦០ដុល្លារក្នុងមួយឆ្នាំ) ដល់សិស្សកម្រិតអនុវិទ្យាល័យ។ អ្នកទទួលអាហារូបករណ៍២០% ច្រើនជាងអ្នកដែលមិនបានទទួលអាហារូបករណ៍ចុះឈ្មោះចូលរៀន។ ការយកចិត្តទុកដាក់លើគោលនយោបាយ តម្រូវឱ្យរក្សាកម្រិតនៃការផ្តល់មូលនិធិសម្រាប់កម្មវិធីអាហារូបករណ៍ និងរក្សាផលប្រយោជន៍ដែលពិបាកទទួលបាន សម្រាប់កុមារមកពីគ្រួសារក្រីក្រ ជាពិសេសក្មេងស្រី។

- ***វឌ្ឍនភាពគុណភាពដែលជាតំបន់យុទ្ធសាស្ត្រទីពីរនៃESP បង្ហាញពីភាពមិនមានការវិវត្តរីកចម្រើនលឿនសម្រាប់លទ្ធភាពទទួលបានការអប់រំ ដោយសារអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សាបន្តកើនឡើងខ្ពស់***[១៧]

មានតែកុមារ៣៨% ប៉ុណ្ណោះដែលចុះឈ្មោះចូលរៀនថ្នាក់ទី១ បន្តរៀនរហូតដល់ថ្នាក់ទី៩។ នេះមានន័យថាអត្រាបោះបង់ការសិក្សាខ្ពស់។ ផលធៀបសិស្ស-គ្រូ មិនមានការផ្លាស់ប្តូរច្រើនទេ ដែលមានសិស្សប្រមាណ៥០នាក់សម្រាប់គ្រូបង្រៀនម្នាក់ដែលជាចំនួនដ៏ច្រើនពិបាកគ្រប់គ្រងថ្នាក់ និងធ្វើឱ្យការបង្រៀន និងរៀនមិនសូវមានប្រសិទ្ធភាព។ មានការកែលម្អមួយចំនួន អត្រារៀនត្រួតថ្នាក់ ប៉ុន្តែការអត្រារៀនត្រួតថ្នាក់នៅតែខ្ពស់ដដែល ជាពិសេសនៅថ្នាក់ទី១ ។ ការវាយតម្លៃសិស្សមិនទាន់មានមូលដ្ឋានរឹងមាំនៅកម្ពុជាទេ នេះដោយសារកម្រិតយល់ដឹងរបស់គ្រូនៅមានកម្រិត។ នៅដំណាក់កាលនេះ កម្ពុជាមិនទាន់បានចូលរួមក្នុងការវាយតម្លៃជាអន្តរជាតិដូចជា PISA ឬ TIMSS ទោះបីជាប្រទេសកម្ពុជាចូលរួមក្នុងការពង្រីកតំបន់អាស៊ីអាគ្នេយ៍នៃការវាយតម្លៃរបស់ PASEC។

- ***ការវាយតម្លៃបឋមលើសូចនាករបរិមាណសម្រាប់ការអភិវឌ្ឍស្ថាប័-ន និងសមត្ថភាពដែលជាវិស័យយុទ្ធសាស្ត្រទី៣នៃESP បង្ហាញពីភាពមិនរីកចម្រើនចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០***[១៧]

ការចំណាយផ្នែកអប់រំបានធ្លាក់ចុះពី១៨,៥% នៃការចំណាយសរុបរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០០៦ទៅ១៧%នៅឆ្នាំ២០០៩និងមានចំនួន២,៥%នៃផសសក្នុងឆ្នាំ២០០៩។ កម្រិតចំណាយលើវិស័យអប់រំរបស់ប្រទេសកម្ពុជាគឺនៅពីក្រោយប្រទេសភាគច្រើនដែលមានកម្រិតប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ និងកម្រិតសេដ្ឋកិច្ចស្រដៀងគ្នានៅអាស៊ីបូព៌ា ។ កម្មវិធីសកម្មភាពអាទិភាព (PAP) ត្រូវបានជំនួសដោយថវិកាកម្មវិធី (PB) ក្នុងអំឡុងឆ្នាំESP២០០៦-២០១០ ដែលជាផ្នែកមួយនៃកំណែទម្រង់ទាំងមូលរបស់រាជរដ្ឋាភិបាលលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ អត្រាប្រតិបត្តិ PB បានកើនឡើងពី៦២,១% ក្នុងឆ្នាំ២០០៧ ទៅដល់៩០%នៅក្នុងឆ្នាំ២០០៩។ ការពឹងផ្អែកលើដៃគូអភិវឌ្ឍន៍សម្រាប់ជំនួយបច្ចេកទេសបានធ្លាក់ចុះតិចជាងគោលដៅដែលគ្រោងក្នុងESP២០០៦-២០១០។ការវិភាគ

បែបប្រៀបធៀបនៃកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP) និងកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ (UNEP) បានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជាទី១៣១ ក្នុងចំណោមប្រទេសចំនួន១៧៧ នៅក្នុងរបាយការណ៍អភិវឌ្ឍន៍មនុស្សអង្គការសហប្រជាជាតិ (UNHDR) ឆ្នាំ២០០៧-២០០៨។ របាយការណ៍នេះឆ្លុះបញ្ចាំងពីស្ថានភាពជាក់ស្តែងនៃស្ថានភាពអប់រំ សុខភាព និងអាហារូបត្ថម្ភ ព្រមទាំងពិនិត្យមើលលទ្ធភាពទទួលបានសេវាថែទាំសុខភាព និងទឹកស្អាតនៅកម្ពុជា។ យោងទៅតាមរបាយការណ៍សន្ទស្សន៍អភិវឌ្ឍន៍សង្គមឆ្នាំ២០០៧-២០០៨កម្ពុជាស្ថិតនៅក្រោមសាធារ-ណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងនៅពីលើប្រទេសភូមា ។

## 4) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣

នៅឆ្នាំ២០០៨ រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ របស់សភាជាតិបានពិនិត្យមើលឡើងវិញលើផែនការនានារបស់ខ្លួន ដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដោយរក្សាទុក "ការពង្រឹងគុណភាពអប់រំ" ជាមុំទី១ ក្នុងចតុកោណទី៤ដែលមាន "**ការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស**"ជាស្នូល។ ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ឱ្យមានប្រសិទ្ធភាពខ្ពស់របៀបវារៈកំណែទម្រង់សំខាន់ៗក្នុងវិស័យអប់រំត្រូវបានផ្តោតទៅលើការអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិជាជំហានៗ។ ជាមួយនោះក្រសួងខិតខំលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យអប់រំ ដោយពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលនានា(១៨)។ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា វិស័យអប់រំមានផ្លាស់ប្តូររីកចម្រើនគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងការរីកចម្រើននេះ ក៏នៅមាន**បញ្ហា**

**ប្រឈម**ជាច្រើន ដែលត្រូវយកចិត្តទុកដាក់កែលម្អក្នុងអណត្តិរាជរដ្ឋាភិបាលថ្មី និងរៀបចំផែនការយុទ្ធសាស្ត្រថ្មីដើម្បីដោះស្រាយបញ្ហាទាំងអស់នោះ។

ផ្អែកតាមរបាយការណ៍ធនាគារពិភពលោកឆ្នាំ២០០៩ បង្ហាញថា ប្រជាជនកម្ពុជាប្រមាណ៥០% រស់នៅដោយប្រើប្រាស់លុយតិចជាង២ដុល្លារក្នុងមួយថ្ងៃ។ ដោយសារកម្រិតប្រាក់ចំណូលទាបនេះ វាធ្វើឱ្យលទ្ធភាពទទួលបានការអប់រំនៅតែជាបញ្ហាប្រឈមដ៏ធំមួយ។ ទោះបីជាការអប់រំសាធារណៈដោយឥតគិតថ្លៃ សម្រាប់មនុស្សគ្រប់រូបក៏ដោយ ក៏គ្រួសារដែលកំពុងរស់នៅក្នុងភាពក្រីក្រតស៊ូដើម្បីចំណាយផ្សេងៗសម្រាប់ការអប់រំកូនៗពួកគេដូចជា៖ ឯកសណ្ឋាន មធ្យោបាយធ្វើដំណើរ និងសម្ភារៈសិក្សាជាមូលដ្ឋាន[១៩]។

ផ្អែកតាមគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា (CMDGs) ភាគច្រើនដែលកម្ពុជាបានអនុម័តតាំងពីឆ្នាំ ២០០០មក យើងឃើញថា ការអនុវត្តហាក់ដូចជាមិនបានឆ្លើយតបទៅនឹងគោលដៅជាច្រើន ហើយស្ថានភាពនេះ តម្រូវឱ្យភាគីពាក់ព័ន្ធចាត់វិធានការឱ្យខ្លាំងថែមទៀត។ ប្រទេសកម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងសូចនាករសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ហើយអាចសម្រេចគោលដៅរបស់ខ្លួនសម្រាប់ការចុះឈ្មោះចូលរៀនជាសកល។ទោះជាយ៉ាងណាក៏ដោយការសម្រេចគោលដៅរបស់ខ្លួនសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា អត្រាចុះឈ្មោះចូលរៀន និងអត្រាបញ្ចប់ការសិក្សារបស់សិស្សស្រីហាក់មិនសម្រេចតាមគោលដៅដែលកំណត់ឡើយ។ មានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីលើកកម្ពស់គុណភាព និងលទ្ធភាពនៃការអប់រំ ហើយកម្ពុជាទំនងជាមិនសម្រេចបានគោលដៅCMDGដែលកាត់បន្ថយចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិទេ[២០]។ មានបញ្ហាមួយចំនួនទៀតដែលទាក់ទងនឹងការអប់រំត្រូវបានលើកឡើងនៅ

កិច្ចប្រជុំលើកទីមួយនៃទីស្ដីការគណៈរដ្ឋមន្ត្រីដែលប្រព្រឹត្តទៅនៅរាជធានីភ្នំពេញនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ នាយករដ្ឋមន្ត្រីកម្ពុជាបានលើកឡើងពីបញ្ហាប្រឈមសំខាន់ចំនួន១៧ ដែលរដ្ឋាភិបាលបច្ចុប្បន្នកំពុងជួបប្រទះ ក្នុងនោះក៏មានបញ្ហាទាក់ទងនឹងវិស័យអប់រំដែរ។ ក្នុងចំណោមបញ្ហាប្រឈមទាំងនេះមាន បញ្ហាកង្វះកម្មករជំនាញបច្ចេកទេសគឺជាឧបសគ្គចម្បងមួយចំពោះការអភិវឌ្ឍសេដ្ឋកិច្ច ហើយបញ្ហាគុណភាពអប់រំនៅទាបសម្រាប់កម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សានៅតែជាក្ដីបារម្ភយ៉ាងខ្លាំង។ ការផលិត និងការជួញដូរគ្រឿងញៀនខុសច្បាប់បានក្លាយជាបញ្ហាសង្គមដែលកំពុងកើនឡើង ហើយគុណភាពនៃការផ្ដល់សេវាសុខាភិបាលសាធារណៈនៅមានកម្រិតដែលបញ្ហាទាំងនេះប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលចំពោះវិស័យអប់រំ។ ជាមួយគ្នានេះ ក៏មានលើកឡើងផងដែរទាក់ទងនឹងសមត្ថភាពនៅមានកម្រិតរបស់ស្ថាប័នរាជរដ្ឋាភិបាល ដោយសារកម្រិតគុណវុឌ្ឍិបុគ្គលិកសាធារណៈនៅទាប ក្នុងនោះក៏មានគ្រូបង្រៀនផងដែរ និងប្រាក់ឈ្នួលមន្ត្រីរាជការក៏មានកម្រិតទាប ព្រមទាំងកង្វះគម្រោងលើកទឹកចិត្តនៅតែជាប្រភពនៃបញ្ហា។ មួយវិញទៀត កិច្ចសហប្រតិបត្តិការរវាងភ្នាក់ងាររាជរដ្ឋាភិបាលនៅតែទន់ខ្សោយ ហើយឯកសារច្បាប់ជាច្រើនមិនទាន់មានផែនការអនុវត្តនៅឡើយ ព្រមទាំងកង្វះខាតធនធានក្នុងការអនុវត្តគោលនយោបាយ និងផែនការរបស់រដ្ឋាភិបាលផងដែរ(២១)។ ជាមួយគ្នានេះ ក៏មានការលើកឡើងផងដែរទាក់ទងអត្រាភាពក្រីក្រខ្ពស់សម្រាប់គ្រួសារនៅតាមជនបទ ការរាលដាលនៃការប្រើប្រាស់គ្រឿងញៀន និងបទឧក្រិដ្ឋអនីតិជន គ្រោះថ្នាក់នៃមេរោគអេដស៍ គម្លាតរវាងការអប់រំ និងការងារ កង្វះការយល់ដឹងអំពីការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព កង្វះសមភាពយេនឌ័រ និងកង្វះការចូលរួមរបស់យុវជនក្នុងការធ្វើសេចក្ដីសម្រេចចិត្តទូទៅ។ លើសពីនេះទៅទៀតក៏មានការសិក្សាស្រាវជ្រាវជាច្រើនផងដែរ ដែលសិក្សាពីបញ្ហាប្រឈមទាក់ទងនឹងវិស័

យអប់រំ តួយ៉ាងដូចះ លោក Launey (២០០៧) ដែលលោកសម្តែងការព្រួយបារម្ភខ្លាំងទាក់ទងនឹងអត្រាសិស្សបោះបង់ការសិក្សាខ្ពស់នៅគ្រប់ភូមិសិក្សា ដែលបណ្តាលមកភាពក្រីក្រ ការអប់រំតិចតួច រួមទាំងអំពើពុករលួយក្នុងវិស័យអប់រំ ពិសេសការយកលុយសិស្សពីសំណាក់គ្រូបង្រៀន និងការចំណាកស្រុក។ ដោយសារប្រាក់បៀវត្សគ្រូនៅទាប គ្រូបង្រៀនភាគច្រើនព្យាយាមប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីស្វែងរកប្រភពចំណូលបន្ថែមសម្រាប់ផ្គត់ផ្គង់ការរស់នៅរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ដែលករណីនេះនាំឱ្យអំពើពុករលួយកើតមានយ៉ាងផុលផុសក្នុងវិស័យអប់រំ និងការធ្លាក់ចុះនូវគុណភាពអប់រំ។ យោងតាមរបាយការណ៍ NEP (២០០៧) បានបង្ហាញថាសិស្សភាគច្រើនត្រូវចំណាយកម្រៃក្រៅផ្លូវការកាន់តែច្រើនទៅៗពីមួយឆ្នាំទៅមួយឆ្នាំដែលកម្រៃទាំងនេះរួមមាន៖ "**ថ្លៃសិក្សា**" សម្រាប់បង្រៀនគួរក្រៅម៉ោង ឯកសារពេលប្រឡង និងសម្ភារៈសិក្សាផ្សេងៗទៀត "**ថ្លៃឈ្នួលពេលចាប់ផ្តើមចូលរៀន**" សម្រាប់ឯកសណ្ឋានសាលារៀន និងទិញសម្ភារៈសិក្សាពេលចាប់ផ្តើមចូលរៀន "**ថ្លៃឈ្នួលប្រចាំថ្ងៃ**" សម្រាប់ម្ហូបអាហារ និងផ្ញើកង់-ម៉ូតូ ព្រមទាំង "**ការចំណាយផ្សេងៗ**" ដូចជាថ្លៃចំណាយសម្រាប់អំណោយឬរៀបចំកាដូជូនគ្រូបង្រៀន ដាក់សៀវភៅតាមដានការសិក្សា និងពិធីវែអង្គាសប្រាក់ផ្សេងៗនៅក្នុងសាលា(២២)។ យោងតាមការស្រាវជ្រាវរបស់លោក Walter Dawson (២០០៩) ក៏បានបានអះអាងដូចគ្នាផងដែរថា៖ ការបង្រៀនគួរក្រៅម៉ោងគឺជាផ្នែកមួយនៃប្រព័ន្ធពុករលួយដ៏ទូលំទូលាយរលួយដោយបង្ខំ នៅក្នុងប្រទេសកម្ពុជាដែលត្រូវបានផ្សារភ្ជាប់ទៅនឹងប្រាក់បៀវត្សរ៍ទាបរបស់បុគ្គលិកសាធារណៈ។ ដើម្បីបន្ថែមប្រាក់ចំណូលរបស់ពួកគេ គ្រូបង្រៀនត្រូវ"**បង្ខំចិត្ត**" រកប្រភពប្រាក់ចំណូលផ្សេងបន្ថែមទៀត ដូចជា៖ ការបង្រៀនគួរក្រៅម៉ោង ឬការបង់កម្រៃក្រៅផ្លូវការរបស់សិស្ស (ឧទាហរណ៍ ថ្លៃចំណាយសម្រាប់ការថតចម្លងឯកសារប្រឡងប្រចាំខែ ជារៀងរាល់ខែ និងចំណាយថ្លៃផ្ញើយានយន្តប្រចាំថ្ងៃ ករណីខ្លះចំណាយលើថ្លៃ

សម្រាប់លុបអវត្តមាន ទទួលបានចម្លើយវិញ្ញាសា ឬបង្ខំសិស្សឱ្យទិញចំណីអាហារជាដើម)[២៣]។ យោងតាមការស្ទង់មតិពីអង្គការ VSO ឆ្នាំ ២០០៨ បានឱ្យដឹងថា គ្រូបង្រៀន៩៣% ត្រូវការការងារបន្ថែមដើម្បីជីវភាពរស់នៅ[២៤] ហើយរបាយការណ៍របស់ Benveniste et al (២០០៨) ក៏បានអះអាងប្រហាក់ប្រហែលគ្នាផងដែរ ដែលថាគ្រូបង្រៀនប្រមាណ៧០%មានការងារទី២[២៥]។ នេះគឺជាហេតុផលមួយក្នុងចំណោមហេតុផលដែលគ្រូបង្រៀនខ្វះពេលវេលា និងការបំផុសគំនិតដើម្បីឱ្យសិស្សមានចំណាប់អារម្មណ៍ក្នុងការទទួលបានលទ្ធផលសិក្សាល្អ[២៦]ដូចជាការទទួលខុសត្រូវចំពោះការអប់រំ និងសីលធម៌។ មូលហេតុមួយទៀតដែលបណ្ដាលឱ្យមានគុណភាពអប់រំទាបគឺថា រដ្ឋាភិបាលព្យាយាមកែលម្អវិស័យអប់រំដោយផ្ដល់ការអប់រំដោយឥតគិតថ្លៃ និងការប្រឡងដែលមិនសូវមានការពិបាកដើម្បីបង្កើនចំនួនសិស្សដែលបានបញ្ចប់ការសិក្សាយ៉ាងហោចណាស់ត្រឹមកម្រិតវិទ្យាល័យ[២៧]។ បើផ្អែកតាមការស្រាវជ្រាវរបស់លោក Tan (២០០៧)[៧] លោកបានលើកឡើងថា ថ្វីបើបច្ចុប្បន្ននេះផែនការយុទ្ធសាស្ត្រច្បាស់លាស់កំពុងដាក់ឱ្យដំណើរការសម្រាប់ EFA ក៏ដោយក៏ព្រះរាជាណាចក្រកម្ពុជានៅតែប្រឈមនឹងបញ្ហាមួយចំនួនក្នុងការបំពេញគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា។ បញ្ហាប្រឈមទាំងនេះរួមមាន៖ ការខ្វះលទ្ធភាពទទួលបានការអប់រំសម្រាប់កុមារ និងយុវវ័យមកពីគ្រួសារក្រីក្រ ការខ្វះខាតធនធានហិរញ្ញវត្ថុសម្រាប់គ្រួសារជាច្រើនក្នុងប្រទេសកម្ពុជាដែលស្វែងរកការសិក្សា និងភាពចាំបាច់របស់កុមារក្មេងៗដែលធ្វើការដើម្បីជួយដល់ក្រុមគ្រួសារ។ លើសពីនេះទៀត ការស្រាវជ្រាវរបស់លោកក៏បានរកឃើញពាក់ព័ន្ធនឹងករណីមួយចំនួនដូចអ្នកស្រាវជ្រាវខាងលើដែរដូចជា៖ អត្រាសិស្សបោះបង់ការសិក្សា និងអត្រារៀនត្រួតថ្នាក់ខ្ពស់[៧]ការអនុវត្តយ៉ាងទូលំទូលាយរបស់គ្រូបង្រៀនក្នុងការគិតកម្រៃពីសិស្សដើម្បីសិស្សអាចទទួលបានសំណៅឯកសារ ឬទិញចម្លើយវិញ្ញាសាក្នុងគោលបំណងដោះដូរនឹង

លទ្ធផលសិក្សាល្អ។ ជារួម ការអនុវត្តបែបបង់ថ្លៃដើម្បីជាប់ការធ្វើតេស្ត ឬមានលទ្ធភាពបញ្ចប់កម្មវិធីសិក្សាពេញលេញត្រូវបានកំណត់ដោយប្រាក់ខែទាបរបស់គ្រូបង្រៀននៅកម្ពុជា។ មួយវិញទៀត ដោយផ្អែកលើព័ត៌មានដែលប្រមូលបានដោយអ្នកស្រាវជ្រាវនេះនៅឆ្នាំ២០០៦ និង២០០៧ ព្រមទាំងបានបញ្ជាក់ដោយធនាគារពិភពលោក (World Bank ២០០៥) គ្រូបង្រៀននៅប្រទេសកម្ពុជារកប្រាក់បាន៣៥-៤០ដុល្លារអាមេរិកក្នុងមួយខែនៅក្នុងសាលាបឋមសិក្សា និង៦០ដុល្លារនៅវិទ្យាល័យ។ យោងតាមធនាគារពិភពលោកគេប៉ាន់ប្រមាណថាគ្រូបង្រៀនត្រូវការប្រាក់ខែអប្បបរមាចំនួន១៥០ដុល្លារអាមេរិកដើម្បីគាំទ្រដល់គ្រួសារកម្ពុជាធម្មតាដែលមានសមាជិក ៥នាក់។

លទ្ធផលសម្រេចនៃការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០០៥-២០១០ស្តីពីសមធម៌នៃការចូលរៀនទទួលជោគជ័យលើសូចនាករមួយចំនួនប៉ុណ្ណោះ បើធៀបនឹងចំណុចដៅ ក្នុងនោះមាន៖ (១) អត្រាពិតនៃការចូលរៀនថ្មីសម្រេចបាន៩២.៤%ឆ្នាំសិក្សា២០០៩-២០១០ ធៀបនឹងចំណុចដៅ៩២.៨% (២)អត្រាពិតនៃការសិក្សាកម្រិតបឋមសិក្សាសម្រេចបាន៩៤.៨% ឆ្នាំសិក្សាដូចគ្នា បើធៀបនឹងចំណុចដៅ៩៦% តែសម្រាប់មធ្យមសិក្សាបឋមភូមិ មិនបានសម្រេចតាមចំណុចដៅទេដោយសម្រេចបានតែ៣២.៦% ធៀបនឹងចំណុចដៅ៤៣% ហើយសម្រាប់មធ្យមសិក្សាទុតិយភូមិបានជោគជ័យសម្រេចលើសចំណុចដៅប្រមាណ១.៤%។

**ការកើនឡើងនូវចំនួនសាលារៀន** (១៨)

| ល.រ | កម្រិតភូមិសិក្សា | ២០០៥-២០០៦ | ២០០៩-២០១០ | ចំនួនសាលាកើន |
|---|---|---|---|---|
| ១ | បឋមសិក្សា | 6277 | 6665 | **388** |
| ២ | អនុវិទ្យាល័យ | 911 | 1172 | **261** |
| ៣ | វិទ្យាល័យ | 252 | 383 | **131** |

## លទ្ធផលសម្រេចបានជាក់ស្តែងធៀបនឹងចំណុចដៅ គុណភាពនិងប្រសិទ្ធភាពនៃការអប់រំ

ផ្អែកតាមតារាងខាងលើ យើងឃើញថា លទ្ធផលសម្រេចនៃការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០០៥-២០១០ ស្តីពីគុណភាព និងប្រសិទ្ធភាពនៃការអប់រំ ទទួលជោគជ័យលើសូចនាករតិចតួចបំផុត បើធៀបនឹងចំណុចដៅ ក្នុងនោះមាន៖ (១)ផលធៀបសិស្ស-គ្រូមធ្យមសិក្សាបឋមភូមិសម្រេចលើសចំណុចដៅដោយមានសិស្សត្រឹម២៤.៨នាក់ សម្រាប់គ្រូម្នាក់ ដែលចំនួននេះតិចជាងការចំណុចដៅដែលកំណត់ថា ធ្លាក់ចុះពី៣១.៨នាក់ មកនៅ២៨.៥នាក់សម្រាប់គ្រូម្នាក់។ ចំណែកឯ កម្រិតបឋមសិក្សាមិនបានអនុវត្តជោគជ័យទេ ដោយផលធៀបប្រែប្រួលតិចតួចបំផុតពីឆ្នាំសិក្សា២០០៥-២០០៦ ដល់ឆ្នាំសិក្សា២០០៩-២០១០ បើទោះបីមានការកើនឡើងចំនួនសាលារៀនចំនួន៣៨៨ក៏ដោយ (ផលធៀបសិស្ស-គ្រូ ៥០.៨នាក់ធ្លាក់ចុះមកនៅ៤៩.២នាក់សម្រាប់គ្រូម្នាក់) (២)អត្រាបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ទទួលជោគជ័យគួរឱ្យកត់សម្គាល់ បើធៀបនឹងចំណុចដៅ ក្នុងនោះមធ្យមសិក្សាបឋមភូមិសម្រេចបាន៤៨.៧%ធៀបនឹងចំណុចដៅ៥១% ហើយទុតិយភូមិសម្រេចបានលើសចំណុចដៅ៣.១% (ចំណុចដៅ ២៣% សម្រេចបាន២៦.១%)។ ការកើនឡើងនៃអត្រាបញ្ចប់ការសិក្សានៅកម្រិតទាំងពីរនេះគឺដោយសារភាពធូរលុងនៃការប្រឡង(៣)ចំនួនសាលារៀនមិនគ្រប់កម្រិតសម្រេចបាន១២០៣សាលា ធៀបនឹងចំណុចដៅ១២០០។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៩-២០១៣ ត្រូវបានកសាងឡើងដើម្បីបង្កើនកិច្ចប្រឹងប្រែងរបស់វិស័យអប់រំ ឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា និងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០០៣-២០១៥ ជាពិសេសដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា(១៨)។ **ក្រសួងបានកំណត់គោលនយោបាយអាទិភាពចម្បងៗដូចខាងក្រោម៖**

- **ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌**
- **លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ**
- **អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ។**

ការបង្កើតផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០០៩-២០១៣ គឺដើម្បីធ្វើការពិនិត្យមើលឡើងវិញនូវ ESP ២០០៦-២០១០ និងសូចនាករដែលអនុវត្តមិនបានសម្រេច ធ្វើការកែលម្អ និងដោះស្រាយដើម្បីផ្លាស់ប្តូរប្រព័ន្ធអប់រំឈានឆ្ពោះទៅមុខ។ ក្រសួងនេះប្រកាន់ខ្ជាប់យ៉ាងមុតមាំចំពោះជំនឿថាអនាគតសេដ្ឋកិច្ចរបស់ប្រទេសនេះពឹងផ្អែកលើគុណភាពនៃការអប់រំ។ ជាមួយនឹងការរីកចម្រើននៅក្នុងសេដ្ឋកិច្ចជាតិ ជាពិសេសនៅរាជធានីភ្នំពេញវិស័យអប់រំបានក្លាយទៅជាទំនិញដ៏មានតម្លៃ ហើយសាលាឯកជនត្រូវបានបើកយ៉ាងព្រោងព្រាតរួមជាមួយនឹងការកើនឡើងនូវចំនួនសាលារៀនសាធារណៈ។ សម្រាប់អ្នកដែលបោះបង់ការសិក្សាដោយមិនបានបញ្ចប់ការសិក្សាថ្នាក់មូលដ្ឋាន (ថ្នាក់ទី១ដល់៩) មានឱកាសចូលរួមកម្មវិធីអក្ខរកម្ម និងកម្មវិធីបំណិនជីវិតក៏ដូចជាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លីដែលផ្តល់ដោយក្រសួងអប់រំយុវជននិងកីឡាក្រសួងកិច្ចការនារី (MoWA) និងអង្គការមិនមែនរដ្ឋាភិបាល។ បន្ទាប់ពីបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ សិស្សានុសិស្សមានជម្រើសក្នុងការបន្តការសិក្សា

ថ្នាក់វិទ្យាល័យ ឬចូលរៀនកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតមធ្យមសិក្សា ដែលផ្តល់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT)។ បន្ទាប់ពីបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ សិស្សានុសិស្សចូលរៀននៅសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ឬការអប់រំថ្នាក់ឧត្តមសិក្សា។

**ផ្អែកតាមការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០០៩-២០១៣ យើងឃើញសម្រេចលទ្ធផលមួយចំនួនដូចខាងក្រោម៖**

| | គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ |
|---|---|
| 1 | ចំនួនកុមារអាយុ ៥ ឆ្នាំក្នុងកម្មវិធី អប់រំកុមារ តូចតាមគ្រប់រូបភាព - សរុប - ស្រី |
| 2 | អត្រាពិតចូលរៀនថ្មី - ទូទាំងប្រទេស - សរុប - ស្រី - ចំនួនសាលារៀនគ្រប់កម្រិតដែលសម្រេចបាន > 95% |
| 3 | អត្រាពិតនៃការសិក្សានៅបឋមសិក្សា - ទូទាំងប្រទេស - ចំនួនសាលារៀនគ្រប់កម្រិតដែលសម្រេចបាន > 95% |
| 4 | អត្រារួម និងអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ - ទូទាំងប្រទេស - សរុប - ស្រី |
| 5 | អត្រារួម និងអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ - ទូទាំងប្រទេស - សរុប - ស្រី |
| 6 | ចំនួននិស្សិតនៅគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ និងឯកជន - សរុប - ស្រី |
| 7 | អត្រាអក្ខរភាព អាយុពី 15-24 ឆ្នាំ |

| | គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ |
|---|---|
| 8 | ផលធៀប សិស្ស-ថ្នាក់ នៅបឋមសិក្សា |
| 9 | ផលធៀប គ្រូ-ថ្នាក់ នៅបឋមសិក្សា |
| 10 | អត្រាត្រួតថ្នាក់ - បឋមសិក្សា - មធ្យមសិក្សាបឋមភូមិ - មធ្យមសិក្សាទុតិយភូមិ - សរុប - ស្រី |
| 11 | អត្រាបោះបង់ការសិក្សា - បឋមសិក្សា - មធ្យមសិក្សាបឋមភូមិ - មធ្យមសិក្សាទុតិយភូមិ - សរុប - ស្រី |
| 12 | អត្រាបញ្ចប់ការសិក្សា - បឋមសិក្សា - មធ្យមសិក្សាបឋមភូមិ - មធ្យមសិក្សាទុតិយភូមិ - សរុប - ស្រី |
| 13 | ចំនួនសិស្សចូលរៀនឡើងវិញ នៅថ្នាក់ទី ៣ ដល់ ទី ៩ |
| 14 | ចំនួនសាលារៀនបឋមសិក្សាមិនគ្រប់កម្រិត |
| 15 | ផលធៀបសៀវភៅសិក្សា-សិស្សនៅបឋមសិក្សា ( ១ សម្រាប់ មាន ៤ ក្បាល) |
| 16 | ភាគរយសិស្សសម្រេចបានតាមស្តង់ដាការសិក្សាលើមុខវិជ្ជា ភាសាខ្មែរ ដោយផ្អែកលើតែសនៅថ្នាក់ទី ៣ និងទី ៦ |
| 17 | ភាគរយសិស្សសម្រេចបានតាមស្តង់ដាការសិក្សាលើមុខវិជ្ជាគណិតវិទ្យាដោយផ្អែកលើតែសនៅថ្នាក់ទី៣ និងទី ៦ |
| 18 | ភាគរយគ្រឹះស្ថានឧត្តមសិក្សា សាធារណៈនិងឯកជន គោរពតាមលក្ខខណ្ឌនៃការបង្កើត |

| | គោលនយោបាយទី ៣ ៖ អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ |
|---|---|
| 19 | ចំណែកថវិកាជាតិចរន្តសម្រាប់វិស័យអប់រំ |
| 20 | ភាគរយចំណាយថវិកាកម្មវិធីជាក់ស្តែងធៀបនឹងថវិកាកម្មវិធីសរុប |
| 21 | ភាគរយ អង្គភាពអនុវត្តថវិកា ដែលត្រូវធ្វើសវនកម្មផ្ទៃក្នុង ក្នុង ១ ឆ្នាំ |
| 22 | ភាគរយសាលារៀននិងគ្រឹះស្ថានសិក្សាដែលត្រូវធ្វើសវនកម្មផ្ទៃក្នុង ក្នុង ១ ឆ្នាំ |
| 23 | ជំនួយការបច្ចេកទេស (Person-month) ថ្នាក់ជាតិ និងអន្តរជាតិ |
| 24 | ភាគរយមន្ត្រីអប់រំជាស្ត្រី - បុគ្គលិកបង្រៀន - មន្ត្រីគ្រប់គ្រងថ្នាក់មធ្យម - ថ្នាក់ដឹកនាំ |

### ❖ ការអភិវឌ្ឍ និងថែទាំកុមារតូច (Early Childhood Care and Development)

ពង្រីក និងលើកកម្ពស់ការថែទាំកុមារ និងការអភិវឌ្ឍកុមារតូចៗ ជាពិសេសសម្រាប់កុមារដែលងាយរងគ្រោះ និងកុមារដែលមិនសូវទទួលបានផលប្រយោជន៍។ នៅប្រទេសកម្ពុជាមានសេវាអប់រំកុមារតូចៗចំនួន៤ សម្រាប់កុមារដែលមានអាយុចាប់ពី៣ ទៅ៥ឆ្នាំ ... ទាំងនេះគឺជា: ១) សាលាមត្តេយ្យផ្លូវការ ២) សាលាមត្តេយ្យឯកជន (PPS) ៣) សាលាមត្តេយ្យសហគមន៍ (CPS) ៤) កម្មវិធីអប់រំតាមផ្ទះត្រូវបានផ្តោតសំខាន់លើឪពុកម្តាយជាងកុមារ។ កម្មវិធីបែបនេះត្រូវបានរៀបចំដោយម្តាយនៅក្នុងមូលដ្ឋានដោយការស្ម័គ្រចិត្ត។ ក្រុមទាំងពីរបានជួបជុំគ្នាក្រោមការដឹកនាំរបស់ម្តាយដែលជាជនបង្គោល ដើម្បីពិភាក្សាគ្នាពីរបៀបថែទាំសុខុមាលភាព និងការអប់រំកូនរបស់ពួកគេពីអាយុ ០ ទៅ ៦ ឆ្នាំ។ ម្តាយដែលជាជនបង្គោលត្រូវបានបណ្តុះបណ្តាល និងគាំទ្រសម្ភារៈដែលផ្តល់ដោយក្រសួងអប់រំយុវជន និងកីឡា និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត។ ភាគរយកុមារ (ពី ៣ ទៅ ៥ឆ្នាំ) ដែលបានចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យបានកើនឡើងពី៦,៥% ដល់៣៣% រវាងឆ្នាំសិក្សា២០០០-២០០១ និង២០១២-២០១៣ ហេតុផលសម្រាប់ការកើនឡើងនេះគឺដោយសារតែ ពង្រីកថ្នាក់មត្តេយ្យសិក្សានៅក្នុងសាលាបឋមសិក្សាដែលបានចាប់ផ្តើមនៅឆ្នាំ២០០៩ ។ ការពង្រីកសាលាមត្តេយ្យសហគមន៍ និងកម្មវិធីអប់រំដែលមានមូលដ្ឋាននៅតាមផ្ទះនៅតំបន់ដាច់ស្រយាល និងតំបន់ដែលមិនមានសេវាអប់រំកុមារតូច។ កុមារអាយុ៥ឆ្នាំចុះឈ្មោះចូលរៀនកម្រិតមត្តេយ្យសិក្សាបានកើនឡើងពី១៨% នៅឆ្នាំ២០០៤-២០០៥ ដល់៥៦% នៅឆ្នាំ២០១២-២០១៣ ដែលជាលទ្ធផលលើសចំណុចដៅនៃផែនការយុទ្ធសាស្ត្រអប់រំ២០០៩-២០១៣ ដែលកំណត់ត្រឹម៥៥%។

- **ការអប់រំជាសាកលកម្រិតបឋមសិក្សា**-(Universalization of Primary Education)

**ធានាថានៅឆ្នាំ២០១៥ កុមារកម្ពុជាគ្រប់រូប ជាពិសេសកុមារី កុមារក្នុងស្ថានភាពលំបាក និងកុមារដែលជាជនជាតិភាគតិចអាចទទួលបានការអប់រំពេញលេញដោយឥតគិតថ្លៃ និងជាកាតព្វកិច្ចនៃការអប់រំដែលមានគុណភាពល្អ។** គោលនយោបាយ បទបញ្ញត្តិ និងសមិទ្ធផលសំខាន់ៗដូចខាងក្រោមត្រូវបានបង្កើតឡើងដោយផ្នែកផ្សេងៗ ពីនាយកដ្ឋានអប់រំរបស់ក្រសួងអប់រំសហការជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់។ សមិទ្ធិផលសំខាន់ៗទាំងនោះមានដូចខាងក្រោម៖

1. ចំនួនសាលារៀនដែលឈានដល់កម្រិតមធ្យមនៃលក្ខណៈសាលាកុមារបានកើនឡើងពី២៩,៦០% ដល់៣៩,៤៥% ។ សាលារៀនដែលឈានដល់កម្រិតខ្ពស់បានកើនឡើងពី២៨,៧៧% ដល់៣៣,២៦% រវាងឆ្នាំសិក្សា២០០៦-២០០៧ និងឆ្នាំសិក្សា២០១២-២០១៣ រៀងៗខ្លួន។
2. គោលនយោបាយស្តីពីការអប់រំសម្រាប់កុមារពិការត្រូវបានអនុម័ត និងត្រូវបានអនុវត្តតាំងពីឆ្នាំ២០០៧ ។ ម៉ូឌុលស្តីពីការទទួលស្គាល់ និងណែនាំក្មេងៗដែលមានបញ្ហាការស្តាប់ ការមើលឃើញ និងការយល់ដឹងគឺជាផ្នែកមួយនៃការបណ្តុះបណ្តាលមុនពេល និងក្នុងពេលបំពេញការងាររបស់គ្រូបង្រៀន។ ការរកឃើញបានបង្ហាញថាពីគំរូតំណាងត្រឹមត្រូវនៃស្ថិតិដែលជាពិការភាពទូទៅបំផុតរបស់កុមារដែលមានអាយុពី ២-៩

- **អត្រារួមនៃការចូលរៀនថ្មី (បូកបញ្ចូលកុមារអាយុ៦ឆ្នាំ និងលើសអាយុ៦ឆ្នាំបានចុះឈ្មោះចូលរៀន)**- (Gross Admission Rate)

ឆ្នាំសិក្សា២០០១-២០០២ អត្រារួមចូលរៀនថ្មីសរុបគឺ១៨៨,៩០% ។ ភាគរយនៃការអត្រារួមនៃការចូលរៀនថ្មីនេះខ្ពស់នៅកម្រិតបឋមសិក្សា គឺដោយសារមានកុមារលើសអាយុចំនួនច្រើនបានចុះឈ្មោះចូលរៀន បន្ថែមពី**អត្រាពិត**នៃកុមារគ្រប់អាយុចូលរៀន។ អត្រាខ្ពស់បំផុតនេះគឺដោយសារតែរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមផ្តល់នូវការអប់រំកម្រិតបឋមសិក្សាដោយឥតគិតថ្លៃ។ អត្រានេះបានថយចុះ២៥% រវាងឆ្នាំសិក្សា២០០០-២០០១ និងឆ្នាំសិក្សា២០១២-២០១៣។ លទ្ធផលនេះបង្ហាញពីភាពប្រសើរឡើងនៃការចូលរៀនទាន់ពេលសម្រាប់សិស្សដែលគ្រប់អាយុចូលរៀន ការអនុវត្តកម្មវិធីសាលារៀនកុមារមេត្រី កម្មវិធីសិក្សាថ្នាក់ពន្លឿន ការអប់រំបញ្ចូលគ្នា ការរៀបចំផែនទីសិក្សា កម្មវិធីអាហារូបករណ៍ និងអាហានៅតាមសាលារៀន និងការសាងសង់សាលាបឋមសិក្សាថ្មីៗនៅជិតប្រជាជន។ ឆ្នាំ ២០០១-២០០២ អត្រាអត្រារួមនៃចុះឈ្មោះចូលរៀនថ្មីមានដល់ ១៨៨,៩០% នៅឆ្នាំ២០១២-២០១៣ មកត្រឹម១២៩% ការចុះឈ្មោះចូលរៀនអាយុយឺតកាន់តែមានលក្ខណៈល្អជាងមុន)

❖ **អត្រាពិតនៃការចូលរៀនថ្មី** (Net Admission Rate)

ក្នុងឆ្នាំសិក្សា២០១២-២០១៣ បានកើនឡើង១៧,៩០% ធៀបនឹងអត្រាក្នុងឆ្នាំសិក្សា២០០០-២០០១ ។ ការកើនឡើងនេះឆ្លុះបញ្ចាំងពីលទ្ធផលនៃការចុះឈ្មោះដោយឥតគិតថ្លៃ ការចូលរួមរបស់សហគមន៍កាន់តែប្រសើរ យុទ្ធនាការចូលរៀនដ៏ទូលំទូលាយ និងការបង្កើតសាលាបឋមសិក្សាថ្មីនៅជិតផ្ទះរបស់ប្រជាជនដែលអាចឱ្យក្មេងៗភាគច្រើនចុះឈ្មោះចូលរៀននៅពេលគ្រប់អាយុចូលរៀន។ នេះបានផ្តល់មូលដ្ឋានគ្រឹះដ៏ល្អសម្រាប់ភាពប្រសើរឡើងនៃសមភាពនិងគុណភាពនៅក្នុងការអប់រំបឋមសិក្សា។ លើសពីនេះក្រសួងអប់រំយុវជននិងកីឡាបានណែនាំកម្មវិធីអប់រំពហុភាសាសម្រាប់ក្មេងៗមកពីក្រុមជនជាតិភាគតិចហើយបានចាប់ផ្តើមនូវគំនិតផ្តួចផ្តើមអប់រំបញ្ចូលគ្នាដើម្បីលើកទឹកចិត្តដល់ការចូលរួមពីកុមារពិការ។(កើន

ពី៧៦,៤% នៅឆ្នាំ២០០០-២០០១ ដល់៩៤,៣% នៅឆ្នាំ២០១២-២០១៣)

❖ **អត្រារួមនៃការសិក្សា** (Gross Enrollment Rate)

អត្រារួមនៃការសិក្សា ឆ្នាំ២០០១-២០០២ មាន១២៥.១% ធ្លាក់ចុះមកនៅ ១២៣.៤% នៅឆ្នាំ២០១២-២០១៣ ដែលស្ថិតិនេះមានការថយចុះតិចតួចត្រឹម១,៧០%។ អត្រាសិក្សាក្មេងប្រុសថយចុះ៥,១០% ក្នុងអំឡុងពេលដូចគ្នា។ និន្នាការថយចុះនេះ គឺមកពី៖ (ក) ការកាត់បន្ថយការចុះឈ្មោះចូលរៀនកុមារដែលមានអាយុច្រើន។ ចំនួនកុមារដែលមានអាយុច្រើនជាងមុនបានធ្លាក់ចុះដោយសារតែការកើនឡើងចំនួនអគារសិក្សាដែលបានផ្តល់លទ្ធភាពកាន់តែងាយស្រួល (ខ)ការអនុវត្តគំនិតផ្តួចផ្តើមផែនទីសាលារៀនបានជួយសាលារៀនកំណត់អត្តសញ្ញាណកុមារដែលមានអាយុចូលរៀនទាំងអស់ និងលើកទឹកចិត្តឱ្យចុះឈ្មោះចូលរៀនពេលកុមារគ្រប់អាយុចូលរៀន។ (គ)ការណែនាំពីកម្មវិធីសិក្សាពន្លឿន ជួយដល់សិស្សដែលលើសអាយុ ចូលរៀនឡើងវិញនៅកម្រិតថ្នាក់ដែលស្របនឹងអាយុពួកគេ។ (ឃ)ពង្រឹង និងពង្រីកការអប់រំទាក់ទងនឹងផ្នែកសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសការបង្កើនចំនួនសាលាបឋមសិក្សាដែលផ្តល់ជូននូវរយៈពេលប្រាំមួយឆ្នាំសម្រាប់ការអប់រំ។

❖ **អត្រាពិតនៃការសិក្សា** (Net Enrollment Rate)

អត្រាពិតនៃសិក្សាក្នុងឆ្នាំសិក្សា២០១២-២០១៣ បានកើនឡើង១៣,២០% បើប្រៀបធៀបទៅនឹងឆ្នាំសិក្សា២០០១-២០០១ ។ ការកើនឡើងនេះគឺដោយសារកម្មវិធីត្រៀមសម្រាប់សិស្សដែលមានអាយុ ៥ឆ្នាំ កម្មវិធីអប់រំសុខភាព កម្មវិធីអប់រំពន្លឿន កម្មវិធីអប់រំសហគមន៍សម្រាប់ឪពុកម្តាយ ការផ្តល់កម្មវិធីអាហារនៅតាមសាលារៀនបឋមសិក្សា ការធ្វើឱ្យប្រសើរឡើងនូវសិក្សានៅបឋមសិក្សា និងកម្មវិធីអប់រំពហុភាសា និងជាពិសេសអត្រាឡើងថ្នាក់នៅសាលាបឋមសិក្សាមានលក្ខណៈល្អប្រសើរ។

- **អត្រារៀនត្រួតថ្នាក់តាមកម្រិតថ្នាក់** (Repetition Rate by Grade)

អត្រារៀនត្រួតថ្នាក់សម្រាប់ថ្នាក់ទាំងអស់បានថយចុះ ជាពិសេសសម្រាប់ថ្នាក់ទី១ ដល់ទី៣។ វាគួរឱ្យកត់សម្គាល់ថា អត្រារៀនត្រួតថ្នាក់ សម្រាប់សិស្សថ្នាក់ទី១ មានចំនួន២៨,៥០% ក្នុងឆ្នាំសិក្សា២០០០-២០០១ និង ១០,៤០% ក្នុងឆ្នាំសិក្សា២០១២-២០១៣។ ការថយចុះ១៨,១០% អំឡុងពេល១២ឆ្នាំ។ នេះមានន័យថាវាមានការថយចុះ១,៥០% ជារៀងរាល់ឆ្នាំ។ ការថយចុះអត្រានៃការត្រួតថ្នាក់នៅថ្នាក់ទី ១ គឺដោយសារតែការអនុវត្តកម្មវិធីត្រៀម (school readiness program) សម្រាប់សិស្សដែលមានអាយុ ៥ ឆ្នាំ កម្មវិធីវាយតម្លៃការអានថ្នាក់ដំបូង ជួយសិស្សរៀនយឺតក្នុងអំឡុងពេលបង្រៀន អាហារូបករណ៍ និងកម្មវិធីអាហារនៅតាមសាលារៀន កម្មវិធីរៀនពន្លឿន និងការធ្វើតេស្តបន្ថែមនៅដើមឆ្នាំសិក្សាថ្មីនីមួយៗ សម្រាប់សិស្សានុសិស្សដែលបានបរាជ័យក្នុងការធ្វើតេស្តឡើងថ្នាក់ នៅចុងបញ្ចប់នៃឆ្នាំសិក្សាមុន ៗ។

- **អត្រាបោះបង់ការសិក្សាតាមកម្រិតថ្នាក់** (Dropout Rate by Grade)

ក្នុងអំឡុងឆ្នាំ២០០០-២០១២ អត្រាបោះបង់ការសិក្សានៅថ្នាក់ទីនីមួយៗ បានថយចុះក្នុងថ្នាក់ទី៤-៦ ។ អត្រាបោះបង់ចោលនៅថ្នាក់ទី៦ ថយចុះ ៥,២០%។ អត្រាថយចុះនេះបណ្តាលមកពីការអន្តរាគមដូចខាងក្រោមដូចជា៖ ការអនុវត្តកម្មវិធីអាហារូបករណ៍ដែលផ្តល់ជូនទាំងសាច់ប្រាក់ និងការគាំទ្រថ្លៃអាហារ ការផ្តល់អាហារនៅតាមសាលារៀន ការកសាងសាលាបឋមសិក្សាថ្មី ការបង្កើនចំនួនសាលាបឋមសិក្សាដែលមានទាំង៦កម្រិតថ្នាក់ និងការបង្កើនការចូលរួមពីសហគមន៍ដើម្បីជួយកុមារដែលប្រឈមនឹងការលំបាកគ្រប់ប្រភេទ ជាពិសេសក្មេងស្រី ដើម្បីអាចចូលរៀនវិញ។ សាលារៀនខ្លះមានអត្ថប្រយោជន៍បន្ថែមទៀតពីក្រុមប្រឹក្សាសិស្ស ក្រុមមិត្តជួយមិត្ត

និងក្រុមប្រឹក្សាកុមារី។ ទាំងអស់នេះបានជួយកាត់បន្ថយការបោះបង់ការសិក្សា។

❖ **អត្រាបញ្ចប់ការសិក្សា** (Completion Rate)

អត្រាបញ្ចប់ការសិក្សាបានកើនឡើងគួរឱ្យកត់សម្គាល់។ អត្រាបញ្ចប់ការសិក្សាសរុបគឺ៤៥,៨០% ក្នុងឆ្នាំសិក្សា២០០៤-២០០៥ និង៨៧,៣៥% ក្នុងឆ្នាំសិក្សា២០១២-២០១៣។ នេះមានន័យថាមានការកើនឡើង ៤០,៥៥%។ កំណើននេះឆ្លុះបញ្ចាំងពីការអនុវត្តសមាសធាតុគោលនយោបាយសាលារៀនកុមារមេត្រី ក្នុងការពង្រឹងគុណភាពនៃការរៀនសូត្រ និងការបង្រៀន ការពង្រឹងការគ្រប់គ្រងរបស់នាយកសាលាដើម្បីបង្កើនប្រសិទ្ធភាពនៃដំណើរការរៀន និងបង្រៀន ព្រមទាំងលើកទឹកចិត្តដល់ការចូលរួមរបស់សហគមន៍។ ក្រសួងអប់រំ យុវជន និងកីឡាក៏បានចេញសេចក្តីណែនាំស្តីពីតួនាទី និងមុខងាររបស់គណៈកម្មាធិការទ្រទ្រង់សាលារៀន ដែលផ្តោតលើការសហការគ្នារវាងសាលារៀន និងសហគមន៍ក្នុងការទទួលខុសត្រូវក្នុងការគាំទ្រដល់ការដឹកនាំ និងការគ្រប់គ្រងសាលារៀន។

❖ **អក្ខរកម្មមនុស្សពេញវ័យ**- (Adult Literacy)

**ដើម្បីធានាបាននូវការរីកចម្រើននៃអក្ខរកម្មមនុស្សពេញវ័យ ៥០% នៅឆ្នាំ ២០១៥ ជាពិសេសសម្រាប់ស្ត្រី និងឱកាសស្មើគ្នាទៅនឹងការអប់រំជាមូលដ្ឋានក៏ដូចជាការអប់រំបន្តសម្រាប់មនុស្សពេញវ័យទាំងអស់។**

យោងតាមជំរឿនប្រជាជនដែលអនុវត្តដោយក្រសួងផែនការក្នុងឆ្នាំ២០០៨ បង្ហាញថា នៅឆ្នាំ១៩៩៨ អត្រាអក្ខរកម្ម (ចេះអក្សរ)នៃមនុស្សពេញវ័យដែលមានអាយុចាប់ពី១៥ឆ្នាំឡើងមានចំនួន៦៧.៣៤% (ក្នុងនោះ ៧៩,៤៨% សម្រាប់បុរស និង៥៩,៩៩%សម្រាប់ស្ត្រី)។ ក្នុងឆ្នាំ២០០៨ អក្ខរភាពមនុស្សពេញវ័យមានចំនួន៧៧,៥៩% (បុរស៨៥,០៨% និងស្ត្រី ៧០,៨៦%)។ យោងតាមជំរឿននៅក្នុងឆ្នាំ២០១៣ របាយការណ៍ថ្មីបំផុតបានបង្ហាញថា អត្រាអក្ខរកម្មនៃមនុស្សពេញវ័យដែលមានអាយុចាប់ពី១៥

ឆ្នាំឡើងទៅមាន៧៩,៧% (បុរស៨៦,៤% និងស្ត្រី៧៣,៦%)។ ការធ្វើជំរឿនប្រជាជនក្នុងឆ្នាំ១៩៩៨ និងការអង្កេតរវាងជំរឿននៅក្នុងឆ្នាំ២០១៣ នៃក្រសួងផែនការបង្ហាញថា ក្នុងអំឡុងពេល១៥ឆ្នាំអត្រាអក្ខរកម្មរបស់មនុស្សពេញវ័យបានកើនឡើង១២,៤%។ យើងនៅរងចាំ លទ្ធផលជំរឿនឆ្នាំ២០១៩ទៀតដើម្បីដឹងថា តើមកដល់ពេលនេះ អត្រាអក្ខរកម្មកើនឡើងបានប៉ុន្មាន។

សម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដោយសារកម្មករភាគច្រើននៅកម្ពុជាមិនមានជំនាញ ឬពាក់កណ្តាលជំនាញ និងខ្វះលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ(TVET)។ ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)បានគាំទ្រកម្មវិធីធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃកម្លាំងពលកម្មក្រោមកម្មវិធីតតាមរយៈការផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានរយៈពេលខ្លីនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ខេត្ត (PTCs)។ ការបណ្តុះបណ្តាលក្រោមកម្មវិធី VSTP បានបណ្តុះបណ្តាល់ដល់សិស្ស និស្សិតជាមធ្យមជាង២០.០០០នាក់ក្នុងមួយឆ្នាំក្នុងកំឡុងឆ្នាំ ២០០៦-២០១៣ ដើម្បីបង្កើនជំនាញផ្នែកកសិកម្ម សិប្បកម្ម និងគ្រឿងម៉ាស៊ីនមូលដ្ឋាន។ ទោះបីយ៉ាងណាក៏ដោយ ការចុះឈ្មោះចូលរៀននៅ PTCs មានកម្រិតទាបជាងការចុះឈ្មោះចូលរៀននៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈក្រៅប្រព័ន្ធ ដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់ការបណ្តុះបណ្តាលឯកជនដែលផ្តល់ការបណ្តុះបណ្តាលដូចគ្នា។ ក្នុងឆ្នាំ២០១០-២០១១ ការចុះឈ្មោះចូលរៀនPTC សរុបមានចំនួន៣៧,៤១៤ នាក់ (ស្រី ៥៩%)។ សិក្ខាកាមជាង៧០% បានបញ្ចប់វគ្គសិក្សាក្នុងការអភិវឌ្ឍជំនាញកសិកម្មដែលសមាមាត្រទៅនឹងចំណែកនៃកម្លាំងពលកម្មដែលចូលរួមក្នុងវិស័យកសិកម្ម។ វគ្គសិក្សាគ្រឿងយន្តមូលដ្ឋាន និងកាត់ដេរក៏មានតម្រូវការខ្ពស់ផងដែរ។ មានតែអ្នកស្វែងរកការងារធ្វើ ៣០% ប៉ុណ្ណោះដែលមានលិខិតបញ្ជាក់ពី TVET ផ្លូវការ។ កម្មវិធីបណ្តុះ

បណ្តាលផ្លូវការនៅថ្នាក់សញ្ញាប័ត្រមធ្យមសិក្សា និងបរិញ្ញាបត្រនៅមានកម្រិត។ វិទ្យាស្ថានបច្ចេកទេសមានតែផ្តល់វគ្គសិក្សា វិញ្ញាបនបត្របញ្ចក់ការសិក្សា និងសញ្ញាប័ត្រក្នុងការជួសជុលម៉ាស៊ីនត្រជាក់ យន្តមេកានិក និងការងារអេឡិចត្រូនិចប៉ុណ្ណោះ

## 5) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨

ប្រទេសកម្ពុជា បានខិតខំប្រឹងប្រែងអនុវត្តដើម្បីសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រប្រហែល១%ក្នុងមួយឆ្នាំ និងសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍(MDG) ត្រឹមឆ្នាំ២០១៥។ ជាលទ្ធផល អត្រាភាពក្រីក្របានថយចុះពី៤៧,៨%ក្នុងឆ្នាំ២០០៧មកត្រឹម១៩,៨%នៅក្នុងឆ្នាំ២០១១ (NSDP២០១៤-ឆ្នាំ២០១៨) និងអត្រាពិតនៃការសិក្សាសម្រាប់សិស្សស្រីនៅកម្រិតបឋមសិក្សាសម្រេចបាន៩៧%ក្នុងឆ្នាំសិក្សា ២០១២-២០១៣។ អត្រាអក្ខរកម្មសម្រាប់ប្រជាពលរដ្ឋដែលមានអាយុ១៥ឆ្នាំ និងអាយុលើសពីនេះនៅក្នុងប្រទេសកម្ពុជាបានឈានដល់៧៩,៧%ក្នុងឆ្នាំ២០១៣។ មួយវិញទៀត មានការកើនឡើងជាង៣ដងនូវប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ពី៣២៨ដុល្លារនៅឆ្នាំ២០០២ ទៅដល់ប្រមាណ១,០៣៧ដុល្លារក្នុងឆ្នាំ២០១៣[២៨]។ ជាមួយនឹងការកើនឡើងប្រាក់ចំណូលនេះ ការងារក៏មានការកើនឡើងផងដែរ នៅតាមរោងចក្រ និងសេវាកម្ម។ ដោយសារសេដ្ឋកិច្ចកើនឡើងជាលំដាប់ បានបង្កើតការងារប្រមាណ៣០០,០០០កន្លែងរៀងរាល់ឆ្នាំ។ កម្ពុជាត្រូវការភាពចម្រុះនៃសេដ្ឋកិច្ចដែលរក្សាបាននូវអត្រាកំណើតខ្ពស់ ដែលមានអត្ថប្រយោជន៍សម្រាប់ប្រព័ន្ធអប់រំ និងទីផ្សារការងារ។ ប្រព័ន្ធអប់រំ និងការបណ្តុះបណ្តាលដែលមានលក្ខណៈឆ្លើយតប និងកាន់តែមានភាពពាក់ព័ន្ធ ត្រូវការសម្រាប់បំពាក់បំប៉នដល់សិស្សនូវចំណេះដឹង និងជំនាញដើម្បីក្លាយជាសមាជិកផ

លិតដែលជាកម្លាំងការងារ(២៩)។ ទោះបីជាមានអត្រាកំណើនជាច្រើនដូច បង្ហាញខាងលើ ដែលកំពុងជួយដល់ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងកំពុងតែផ្ដល់វិភាគទានដ៏មានតម្លៃដល់សមិទ្ធផលនៃស្ថានភាពប្រទេសអភិវឌ្ឍ ក៏ប្រទេសកម្ពុជានៅតែមានបញ្ហាប្រឈមជាច្រើនទៀតផងដែរដែលត្រូវជំនះសម្រាប់បរិបទបច្ចុប្បន្ន ជាពិសេសវិស័យអប់រំ។ ខាងក្រោម គឺជាការបកស្រាយបង្ហាញពី**បញ្ហាប្រឈម**ទាក់ទងនឹងវិស័យអប់រំ មុនកំណែទម្រង់ស៊ីជម្រៅឆ្នាំ២០១៤ ដោយរដ្ឋមន្ត្រីថ្មី ឯកឧត្តមបណ្ឌិត **ហង់ ជួនណារ៉ុន**។

### ❖ ការបាត់បង់ព្រលឹងក្នុងការសិក្សារបស់សិស្សានុសិស្សខ្មែរ

ដោយសារនៅដំណាក់កាលនេះ ការសិក្សាមានលក្ខណៈធូររលុង មិនសូវចាប់អារម្មណ៍ពង្រឹងគុណភាពអប់រំ ទស្សនៈយល់ឃើញរបស់សិស្សានុសិស្សមួយចំនួនធំ មិនបានយកចិត្តទុកសិក្សារៀនសូត្រ និង ពឹងផ្អែកលើសមត្ថភាពខ្លួនឯងទេ។ ការសម្រេចលទ្ធផលសិក្សាភាគច្រើនទទួលឥទ្ធិពលពីការចំណាយថវិកា ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សមធម៌នៃអប់រំ។ ទាំងនេះគឺដោយសារឥទ្ធិពលដ៏លើសលប់នៃអំពើពុករលួយស៊ីសំណូកសូកប៉ាន់នៅក្នុងវិស័យអប់រំ។ ស្ថិតក្នុងស្ថានភាពនេះ សិស្សានុសិស្សមួយចំនួនទៀតងាកទៅពឹងផ្អែកលើកម្លាំងក្រៅខ្លួនដើម្បីសម្រេចបានភាពជោគជ័យក្នុងការសិក្សាដូចជា៖ ចម្លងតាមព្រុយយ៉ុង ការសូកប៉ាន់ពេលប្រឡង បង់លុយដើម្បីទទួលបានពិន្ទុ និងដើម្បីឱ្យគ្រូលុបអវត្តមានជាដើម...។ល។ ចំណែកឯសិស្សមួយចំនួនទៀតបែរជាទៅបន់ស្រន់ដើម្បីឱ្យប្រឡងជាប់ទៅវិញ។ ទាំងអស់នេះ បង្ហាញថា សិស្សលែងឱ្យតម្លៃលើចំណេះដឹង ដែលនៅជាប់នឹងខ្លួនរបស់គេទៀតហើយ ដែលនេះបញ្ជាក់ថា មនុស្សខ្មែរជំនាន់ក្រោយកំពុងតែបាត់បង់ព្រលឹងរបស់ខ្លួន និងភាពជឿជាក់លើខ្លួនឯងហើយ សកម្មភាពនេះកំពុងតែកើនឡើងយ៉ាងផុលផុសនៅក្នុងសង្គមកម្ពុជា

បច្ចុប្បន្ន។ មួយវិញទៀត ទំនុកចិត្តលើការសិក្សានៅក្នុងស្រទាប់សង្គមខ្មែរកាន់តែខ្សោយទៅៗ ពិសេសសិស្សានុសិស្ស និងឪពុកម្តាយ អាណាព្យាបាលនៅតាមជនបទ ដោយសារភាពអយុត្តិធម៌សង្គម និងដោយសារគំនិតបក្សនិយម គ្រួសារនិយម ខ្សែរនិយម និងអំពើពុករលួយ ដែលស្ថានភាពនេះធ្វើឱ្យសង្គមខ្មែរផុយស្រួយបំផុត។ សិស្សានុសិស្សនៅតាមជនបទភាគច្រើនមិនមានសេចក្តីសង្ឃឹម និងមានជំនឿចិត្តលើការសិក្សាទេ ព្រោះកង្វះគោលនយោបាយជាក់លាក់ក្នុងការជួយ និងលើកទឹកចិត្តដល់ពួកគាត់ ។ ពួកគាត់ភាគច្រើនមើលមិនឃើញពីអនាគត តាមរយៈការសិក្សាទេ ព្រោះឥទ្ធិពលដ៏លើសលប់នៃអំពើអសកម្មទាំងអម្បាលម៉ានខាងលើនៅក្នុងសង្គម ។

## ❖ គុណភាពអប់រំ មានកម្រិតទាប

យោងតាមការសិក្សាមួយនៅឆ្នាំ២០១០ បានធ្វើការប៉ាន់ប្រមាណសមត្ថភាពអានថ្នាក់ទាប ពីថ្នាក់ទី១ដល់ថ្នាក់ទី៦ បានរកឃើញថា កុមារប្រមាណ ៣៣% មិនអាចអានបាន ហើយ៤៧%ក្នុងចំណោមអ្នកទាំងនោះមានការពិបាកនឹងយល់អំពីអ្វីដែលពួកគេបានអាន។ ជាមួយគ្នា ការវាយតម្លៃផលប៉ះពាល់សម្រាប់សិស្សថ្នាក់ទី៩ ក៏បានរកឃើញផងដែរពីការអនុវត្តមិនបានល្អលើមុខវិជ្ជាគណិត និងវាក្យសព្ទ[៣០] ទាក់ទងនឹងគុណភាពអប់រំនេះផងដែរ មានការស្ទង់មតិថ្នាក់ជាតិមួយស្តីពីគ្រូបង្រៀនក្នុងឆ្នាំ២០១១បានរកឃើញថា គ្រូដែលមានបទពិសោធច្រើនជាងដប់ឆ្នាំមានការយល់ឃើញថា គុណភាពនៃការអប់រំមានភាពល្អប្រសើរជាងពេលដែលពួកគេបានចាប់ផ្តើមបង្រៀនដំបូង ខណៈដែលអ្នកដែលមានបទពិសោធន៍តិចជាងដប់ឆ្នាំមានអារម្មណ៍ថា គុណភាពអប់រំគ្មានអ្វីការផ្លាស់ប្តូរទេ ហើយក៏មានអ្នកខ្លះយល់ឃើញថា គុណភាពអប់រំមានការធ្លាក់ចុះជាងមុនទៅទៀត។ ផ្អែកតាមរបាយការណ៍ស្ទង់មតិនេះ បង្ហាញពីភាពអវិជ្ជមានច្រើនទាក់ទងនឹងគុណ

ភាពវិស័យអប់រំ ពិសេសក្នុងចំណោមគ្រូបង្រៀនវ័យក្មេង[៣១]។ ផ្អែកតាមរបាយការណ៍វាយតម្លៃរបស់អង្គការតម្លាភាពអន្តរជាតិ បានបង្ហាញពិន្ទុទាបរបស់ប្រទេសកម្ពុជា(២០/១០០) និងទទួលបានចំណាត់ថ្នាក់ទី១៦០ ក្នុងចំណោមប្រទេសចំនួន១៧៧ស្តីពីការយល់ឃើញអំពើពុករលួយក្នុងឆ្នាំ ២០១៣។ នេះបញ្ជាក់ថា អំពើពុករលួយនៅក្នុងប្រទេសកម្ពុជាមានកម្រិតខ្ពស់ដែលវាប៉ះពាល់យ៉ាងខ្លាំងដល់គុណភាពវិស័យអប់រំ។ របាការណ៍នេះក៏បានបង្ហាញផងដែរពីកម្រិតប្រាក់បៀវត្សទាប និងការបើកមិនទៀងទាត់របស់គ្រូបង្រៀន ជំរុញឱ្យពួកគេជាច្រើន ស្វែងរកការងារបន្ថែមដើម្បីបន្ថែមប្រាក់ចំណូលរបស់ពួកគេសម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅ[៣២]។ មួយវិញទៀត ផ្អែកតាមតេស្តវាយតម្លៃលទ្ធផលសិក្សាសិស្ស និងការសិក្សាស្រាវជ្រាវទាក់ទងនឹងគុណភាពអប់រំ បានបង្ហាញឱ្យឃើញពីផលវិបាកនៃការធ្វើកំណែទម្រង់កម្មវិធីសិក្សាដែលអនុវត្តចាប់តាំងពីឆ្នាំសិក្សា២០០៧-២០០៨។ *កំណែទម្រង់ទាំងនេះ ភាគច្រើនរៀបចំដោយ អ្នកជំនាញបរទេស ក្រោមជំនួយគាំទ្រពីភ្នាក់ងារអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលបង្ហាញពីចំណុចអវិជ្ជមាននៃការធ្វើទំនើបកម្មកម្មវិធីសិក្សា ការកំណត់ស្តង់ដារកម្មវិធីសិក្សា ស្តង់ដារតាមមុខវិជ្ជា មិនមានមូលដ្ឋានស្រាវជ្រាវច្បាស់លាស់ ដែលនាំឱ្យគុណភាពអប់រំធ្លាក់ចុះ និងប៉ះពាល់ដល់ទំនាក់ទំនងរវាងសហគមន៍ និងសាលារៀន ពោលគឺការផ្លាស់ប្តូរវិធីសាស្ត្របង្រៀនដែលធ្វើឱ្យមានការខុសគ្នារវាងការសិក្សាជំនាន់ឪពុកម្តាយ និងកូន។ ករណីនេះ បង្ហាញពីកង្វះការសិក្សាស្រាវជ្រាវច្បាស់លាស់ ក្នុងការធ្វើកំណែទម្រង់កម្មវិធីសិក្សា។*

### ❖ ឥរិយាបថអវិជ្ជមានរបស់គ្រូបង្រៀន

ដូចគ្នានេះ ឥរិយាបថអវិជ្ជមានរបស់គ្រូបង្រៀនភាគច្រើននៅដំណាក់កាលនេះ ទាក់ទងនឹងសកម្មភាពអប់រំ បង្ហាញពីសភាពគួរឱ្យព្រួយបារម្ភបំផុត

សម្រាប់ការអប់រំនាពេលអនាគត។ ដោយហេតុផលគ្រូបង្រៀនមានប្រាក់បៀវត្សទាប លោកគ្រូ-អ្នកគ្រូ មួយចំនួនបានចាប់សិស្សជាចំណាប់ខ្មាំង ដើម្បីប្រាក់ តាមរយៈការបង្កើតការបង្រៀនគួរក្រៅម៉ោង និងការគៀបសិស្សតាមមធ្យោបាយផ្សេងៗ។ ការបង្រៀនគួរក្រៅម៉ោង និងការចំណាយក្រៅផ្លូវការផ្សេងៗទៀត បានបង្កើនការចំណាយរបស់គ្រួសារសម្រាប់ការសិក្សារបស់កូនៗខ្លួន ហើយក៏ជាមូលហេតុដែលនាំឱ្យមានការបោះបង់ការសិក្សាខ្ពស់ផងដែរ។ តាមរយៈការសង្កេតជាទូទៅ យើងឃើញថា ការបង្រៀនគួក្រៅម៉ោងជះផលអវិជ្ជមានមួយចំនួនក្នុងចំណោមគ្រូបង្រៀនទាំងឡាយ ដែលវាបណ្តាលឱ្យបែកបាក់ផ្ទៃក្នុងព្រោះទំនាស់ផលប្រយោជន៍ និងភាពច្រណែនគ្នា ពិសេសមិនមានមនសិការការងាររឹងមាំនៅក្នុងម៉ោងសិក្សារដ្ឋ ឬបង្រៀនសិស្សមិនច្បាស់លាស់ មិនអស់សមត្ថភាពដោយលាក់ទុកល្បិចសម្រាប់ការបង្រៀនក្រៅម៉ោង ។ វាជាការពិតណាស់ ស្ថានភាពបែបនេះគ្រូយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្សខ្លាំងតែថ្នាក់គួរក្រៅម៉ោង ជាជាងបង្រៀននៅក្នុងម៉ោងរដ្ឋ។ មួយវិញទៀត ការបង្រៀនគួរនេះ វាអាចធ្វើឱ្យមានភាពអយុត្តិធម៌ក្នុងការដាក់ពិន្ទុដើម្បីវាយតម្លៃលទ្ធផលសិក្សាសិស្ស។ពិតណាស់ លោកគ្រូ-អ្នកគ្រូមួយចំនួនធំ នឹងមានភាពលម្អៀងទៅលើសិស្សដែលរៀនគួរជាមួយខ្លួន ដែលអាចឱ្យសិស្សដទៃទៀតបាក់ទឹកចិត្ត និងបណ្តាលឱ្យលទ្ធផលសិក្សាធ្លាក់ចុះ។ ម្យ៉ាងទៀត ការបង្រៀនគួរនេះ ធ្វើឱ្យសិស្សមានទម្លាប់មិនល្អ មិនយកចិត្តទុកដាក់ក្នុងសិក្សារៀនសូត្រ និងមិនពឹងផ្អែកលើសមត្ថភាពខ្លួនឯងដើម្បីអភិវឌ្ឍន៍ចំណេះដឹង ហើយសម្លឹងឃើញគុណសម្បត្តិរបស់លុយក្នុងដំណើរការបង្រៀន និងរៀនទៅវិញ ពិសេសគឺឥទ្ធិពលដ៏លើសលុបរបស់វា ទៅលើដំណើរជីវិតរបស់គាត់។ លើសពីនេះទៅទៀត វាបានបង្កើតជាវប្បធម៌ចំណាយប្រាក់ក្នុងការសិក្សា បើទោះបីការចុះចូលរៀនមិនបង់ប្រាក់ក៏ដោយក៏ការចំណាយក្នុងការរៀនសូត្រសម្រាប់សិស្សមួយឆ្នាំទៅ មួយឆ្នាំមានការកើនឡើង និងរាលដាលធំ

ទៅៗ បង្កើតបានជារនាំងឧបសគ្គសម្រាប់គ្រួសារក្រីក្រ ដែលនាំទៅរកការបាក់ទឹកចិត្ត និងបាត់បង់ជំនឿលើការសិក្សា ឧទាហរណ៍ការឱ្យកូនឈប់រៀន ទៅធ្វើការងាររោងចក្រ និងធាប់ប្រឡូកការងារផ្សេងៗទៀតដើម្បីទទួលបានប្រាក់កំរៃជួយគ្រួសារជាដើម...។ ផលវិបាកមួយទៀត គឺវាធ្វើឱ្យសិស្សអសកម្ម មិនឱ្យតម្លៃការសិក្សា និងចេះពុករលួកសួកប៉ាន់។ បើសង្កេតជាទូទៅលើការអប់រំ តាំងពីបឋមសិក្សា រហូតដល់ មធ្យមសិក្សា យើងឃើញមានវប្បធម៌នៃអំពើពុករលួយ ត្រូវបានដាក់បញ្ចូលដោយឥតដឹងខ្លួនក្នុងដំណើរបង្រៀន និងរៀនដែរ។ ឧទាហរណ៍ កុមារនៅសាលាបឋមសិក្សាទៅរៀនក្នុងសាលារដ្ឋហើយលោកគ្រូ-អ្នកគ្រូ មួយចំនួនតម្រូវឱ្យបង់ប្រាក់ប្រចាំថ្ងៃឬ ឪពុកម្តាយបានដាក់លុយមួយចំនួនក្នុងសៀវភៅតាមដានការសិក្សារបស់កូនឱ្យគ្រូដាក់ច្រើនកូនរៀនបានចំណាត់ថ្នាក់ល្អឬជូនកាដូជាដើម...។ សកម្មភាពទាំងនេះ ពួកគេកំពុងតែដុះខាត់កុមារឱ្យចេះពុករលួយ ស៊ីសំណូកសូកប៉ាន់។ ស្ថិតក្នុងរូបភាពខាងលើនេះ វាធ្វើឱ្យឪពុកម្តាយ អាណាព្យាបាលរបស់សិស្សានុសិស្សបាត់បង់ទំនុកចិត្តលើការសិក្សានៅសាលារដ្ឋ ហើយសម្រាប់គ្រួសារដែលមានជីវភាពធូរធារ ពួកគេបានបញ្ជូនកូនទៅរៀនសាលាឯកជន។ សម្រាប់តំបន់ជនបទ ស្ថានភាពសេដ្ឋកិច្ចគ្រូបង្រៀន និងឪពុកម្តាយ អាណាព្យាបាលនៅទាប គ្រូគ្មានជម្រើសក្នុងការប្រមូលលុយសិស្សដូចបង្ហាញខាងលើឡើយ ប៉ុន្តែ វាលេចចេញនូវភាពមិនសូវយកចិត្តទុកដាក់លើការបង្រៀន និងរៀន ដែលធ្វើឱ្យការសិក្សារបស់សិស្សធ្លាក់ចុះ។

សម្រាប់នៅតាមសាលាអនុវិទ្យាល័យ-វិទ្យាល័យមួយចំនួនវិញ មានលោកគ្រូ-អ្នកគ្រូមួយចំនួនផ្តោតទៅលើផលប្រយោជន៏ផ្ទាល់ខ្លួនតាមរយៈការស្វះស្វែងរកឱកាសក្នុងការទាញយកប្រយោជន៍ពីសិស្សដែលវាបានប្រែក្លាយការអប់រំមានទិសដៅឆ្ពោះទៅរកផលប្រយោជន៍( លុយ )ទៅវិញដែលជះឥទ្ធិពលអាក្រក់បំផុតដល់សិស្ស។ បញ្ហានេះវាបានប្រែក្លាយសកម្មភាពអប់រំ ទៅជាការប្រកួតប្រជែងអាជីវកម្មយ៉ាងគគ្រឹកគគ្រេង ស្មើរគ្រប់មុខវិជ្ជា។

ឧទាហរណ៍បើសិស្សមិនចង់រៀនម៉ោងកាយសិក្សាអាចបង់លុយដើម្បីយកពិន្ទុ បង់លុយច្រើន អាចនឹងទទួលបានពិន្ទុច្រើន ហើយបង្កើតឱ្យមានការបង្រៀនគួរក្រៅម៉ោងស្ទើរគ្រប់មុខវិជ្ជា ដែលវាគួរឱ្យអស់សំណើចបំផុត។ សម្រាប់ស្ថានភាពបែបនេះ បើសិស្សានុសិស្សអាចទិញពិន្ទុបាន ទិញចំណាត់ថ្នាក់បាន និងទិញអវត្តមាន សួរថា តើពួកគេមានកម្លាំងចិត្តឯណាខំរៀន? ឥទ្ធិពលនៃអំពើពុករលួយនេះ ធ្វើឱ្យមាតាបិតា និងអាណាព្យាបាលសិស្សមួយចំនួនធំ ពិសេសគ្រួសារក្រីក្រ មិនមានសង្ឃឹមថាកូនៗរបស់ពួកគេ នឹងក្លាយជាសិស្សពូកែបានទេ បើមិនមានលុយគ្រប់គ្រាន់សម្រាប់ចំណាយឱ្យកូនគាត់ក្នុងការរៀនសូត្រនោះ។ យើងអាចវាយតម្លៃបានថាសិស្សានុសិស្សដែលមកពីគ្រួសារក្រីក្រងាយទទួលរងភាពអយុត្តិធម៌ក្នុងសម្រេចលទ្ធផលសិក្សា ហើយការអប់រំប្រកបដោយសមធម៌មានតែនៅលើក្រដាស។ ជារួម រយៈពេល១២ឆ្នាំ សិស្សានុសិស្សទទួលរងឥទ្ធិពលពីអំពើពុករលួយ និងសូកប៉ាន់ខ្លាំងជាងការសម្រេចលទ្ធផលសិក្សា។ ដោយសារឥទ្ធិពលអវិជ្ជមានបែបនេះ ក្នុងប្រព័ន្ធគំនិតរបស់សិស្ស-និស្សិតភាគច្រើនផ្តោតតែទៅលើ "**លុយ**" ជាសំខាន់ ពោលគឺពួកគេរៀនគឺដើម្បីមានការងារល្អ ប្រាក់ខែខ្ពស់ និងមានលុយច្រើន មុននឹងមានគំនិតស្នេហាជាតិមាតុភូមិ និងស្រឡាញ់សច្ចភាព យុត្តិធម៌ដែលជាគុណតម្លៃដ៏សំខាន់សម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ។ មកដល់នាទីចុងក្រោយនៃការបញ្ចប់ការសិក្សាគឺការប្រឡង ទាំងការប្រឡងបញ្ចប់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិនៅតែវត្តមានលុយសំខាន់ដដែល ហើយរលកនៃការចំណាយលុយរបស់សិស្សសម្រាប់ការប្រឡងបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ និងរាលដាលតាំងពីទីក្រុងរហូតដល់ជនបទដល់ឆ្នាំ២០១៣ មុនកំណែទម្រង់។ យើងពិតជាឆ្ងល់ហើយចោទជាសំណួរថា បើសិស្សអាចទិញវិញ្ញាសាបានតើប្រឡងដើម្បីអ្វី? តើការប្រឡងទាំងនេះ គ្រាន់តែសម្រាប់ផ្តល់ឱកាសដល់គ្រូបង្រៀនរកចំណូលបន្ថែមមែនទេ? តើវាជាយុទ្ធសាស្ត្រដើម្បីបង្កើនអត្រានៃ

ការសិក្សាមែនទេ? *ស្ថានភាពប្រឡងដែលពោរពេញទៅ ដោយអំពើពុករលួយបែបនេះ ជះឥទ្ធិពលយ៉ាងខ្លាំងដល់គុណភាពអប់រំ និងភាពអស់ជំនឿលើការសិក្សារបស់ស្រទាប់គ្រួសារក្រីក្រ*។ នេះជាមូលហេតុដ៏ចម្បងដែលធ្វើឱ្យ អត្រាបោះបង់ការសិក្សា ដើម្បីធ្វើការងារកើនឡើង ផងដែរដូចជាចំណាកស្រុកទៅធ្វើការនៅប្រទេសជិតខាង ធ្វើកម្មកររោងចក្រ កម្មករសំណង់... ដែលភាគច្រើនជាពលករប្រើកម្លាំង និងគ្មានជំនាញ។ ដោយសារកង្វះការអប់រំប្រកបដោយគុណភាព និងការបោះបង់ការសិក្សា ធ្វើឱ្យកម្លាំងពលកម្មកម្ពុជាមិនមានជំនាញច្បាស់លាស់ ហើយអាចធ្វើការបានតែការងារណាដែលមិនត្រូវការកម្រិតជំនាញ ដែលជាប្រភេទការងារមានកំរៃទាប។ ភស្តុតាងដែលបញ្ជាក់ពីគុណភាពអប់រំទាប គឺតាមរយៈការធ្វើកំណែទម្រង់ស៊ីជម្រៅការប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៤ ដែលលទ្ធផលសិស្សប្រឡងជាប់សញ្ញាប័ត្របានត្រឹមតែ**២៦%**ប៉ុណ្ណោះនៅពេលក្រសួងមានវិធានការរឹតបន្តឹងការប្រឡង ដោយមិនអនុញ្ញាតឱ្យមានការលួចមើលសំណៅឯកសារ ទប់ស្កាត់ការលេចធ្លាយវិញ្ញាសា មិនអនុញ្ញាតឱ្យប្រើប្រាស់ទូរស័ព្ទដៃ ម៉ាស៊ីនគិតលេខ ឬសកម្មភាពលួចចម្លងនានា។ ដំណើរការប្រឡងនៅពេលនោះមានការចូលរួមពីអ្នកស្ម័គ្រចិត្តរាប់ពាន់នាក់ និងអង្គភាពប្រឆាំងអំពើពុករលួយ[៣៣]។ លទ្ធផលប្រឡងមធ្យមសិក្សា២០១៤ មានតែសិស្ស១១នាក់ប៉ុណ្ណោះទទួលបាននិទ្ទេស "A" ហើយជាប់តែ២៦% ក្នុងចំណោមសិស្សប្រមាណ៧៥០០០នាក់ដែលទិន្នន័យខុសស្រឡះពីឆ្នាំកន្លងទៅមានប្រមាណ**៨៧%**ឯណោះ[៣៤]។

## ❖ កង្វះភាពជាគំរូរបស់មាតាបិតា ឬអាណាព្យាបាលសិស្ស

ជាទូទៅ មាតាបិតាសិស្សមួយចំនួនមិនទម្លាប់អានសៀវភៅ ឬឯកសារនានានៅផ្ទះសម្រាប់បង្កើនចំណេះដឹងផ្ទាល់ខ្លួនទេ ហើយក៏មិនសូវអាន ឬនិទានសម្រាប់ឱ្យកូនស្តាប់ដែរ ដែលវាធ្វើឱ្យវប្បធម៌នៃការអានសៀវភៅនៅតិចតួច

នៅឡើយមកដល់ពេលបច្ចុប្បន្នះ។ ទង្វើរបស់ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលវាជះឥទ្ធិពលដល់កូនៗ ដាហេតុធ្វើឱ្យពួកគេមិនមានចំណង់ចំណូលចិត្តអានសៀវភៅដូចឪពុកម្ដាយ ដែរ។ មួយវិញទៀតនៅតាមខ្នងផ្ទះភាគច្រើន ពិសេសនៅតាមជនបទមិនឱ្យតម្លៃលើសៀវភៅ មិនយកចិត្តទុកថែទាំ ឬក៏ដាក់តាំងក្នុងទូសៀវភៅ ដែលករណីនេះវាបង្ហាញពីភាពមិនសូវចិត្តទុកដាក់ និងមិនឱ្យតម្លៃពីគុណសម្បត្តិរបស់សៀវភៅដែលជាប្រភពសំខាន់ក្នុងការអភិវឌ្ឍចំណេះដឹង និងសមត្ថភាព។ ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល គួររៀបចំទុកដាក់សៀវភៅ ឱ្យបានច្រើនទោះបីមិនមានពេលវេលាអានគ្រប់គ្រាន់ក៏ដោយ នេះជាមធ្យោបាយមួយក្នុងការលើកកម្ពស់ការនិយមចូលចិត្តអានរបស់កូនៗ និងការបណ្ដុះគំនិតស្រឡាញ់ការសិក្សារៀនសូត្រ។ ចំណុចសំខាន់មួយទៀត គឺការលើកកម្ពស់មោទនភាពគ្រួសារតាមរយៈការដាក់គ្រឿងឥស្សរយស សញ្ញាប័ត្រ រូបថតកិត្តយស ប័ណ្ណសរសើរ ឬមេដាយស្នាដៃការងារផ្សេងបើមាន សម្រាប់ឱ្យកូនបានមើលឃើញ ព្រោះវាមានប្រយោជន៍ច្រើនក្នុងការអប់រំទូន្មានដោយប្រយោលក្នុងការតម្រង់ទិសកូនទៅរកផ្លូវល្អតាមរយៈភាពជាគំរូរបស់ឪពុកម្ដាយ ឬអ្នកអាណាព្យាបាលនេះ។ ការបង្ហាញទាំងនេះ វាអាចជាថាមពលអរូបី និងអាចំកំបាំងមួយ ដែលជួយដាស់តឿនកូនៗបានមួយចំនួន ពេលដែលគេដើរផ្លូវខុស ព្រោះវាអាចបង្កើតជាសម្លេងនៅក្នុងសតិសម្បជញ្ញៈរបស់គាត់ ហើយពេលខ្លះ វាអាចក្លាយកត្តាជំរុញធ្វើឱ្យមានភាពអៀនខ្មាស់លើទង្វើខ្លួនឯងដោយស្វ័យប្រវត្តិ តាមរយៈការឆ្លុះបញ្ចាំងពីភាពជាគំរូល្អរបស់ឪពុកម្ដាយ ឬធ្វើឱ្យឆាប់មានភាពភ្ញាក់រឭកដាងពេលឪពុកម្ដាយឬអ្នកអាណាព្យាបាលធ្វើការអប់រំប្រៀនប្រដៅ។ ចំណុចអសកម្មមួយចំនួនទៀតគឺឪពុកម្ដាយមួយចំនួនបាន បំបាក់ទឹកចិត្តកូនដើម្បីទាញយកផលប្រយោជន៍ពីកូន ដោយជំរុញកូនឱ្យឈប់រៀនដើម្បី ចូលធ្វើការរកប្រាក់សម្រាប់ជាចំណូលគ្រួសារពិសេសការលើកយកហេតុផលពីភាពអយុត្តិធម៌ក្នុងសង្គមមកធ្វើលេស ឬ

ឧបសគ្គ និងផ្តល់ភាពអស់សង្ឃឹមដល់កូន ដូចជា៖ រៀនបានប្រយោជន៍អី យើងគ្មានលុយសូកគេធ្វើការងារទេ ឬគ្មានលុយរៀនមហាវិទ្យាល័យទេ ឬ បង្ហាញថា និស្សិតបញ្ចប់មហាវិទ្យាល័យច្រើនណាស់នៅទីក្រុងរកការងារធ្វើ មិនបានផង កន្លែងការងារល្អៗគេដាក់កូនគេអស់ហើយ...។ ពិសេសករណី នេះ កើតឡើងចំពោះគ្រួសារដែលមានជីវភាពក្រីក្រលំបាក។ ស្ថានភាពក្រី ក្រលំបាក ធ្វើឱ្យពួកគាត់យល់ថា បញ្ហាក្រពះ សំខាន់ជាងការសិក្សា ហើយ ទង្វើនេះ បានរុញកូនគាត់ចូលទៅក្នុងវដ្តនៃភាពក្រីក្រ ព្រោះការដែលគាត់ បោះបង់ការសិក្សា ធ្វើឱ្យទទួលបានការងារដែលប្រើកម្លាំង និងកំណត់ ដោយការងារដែលទទួលបានប្រាក់បៀវត្សទាប។ ដូច្នេះ គាត់បាត់បង់ ឱកាសរំដោះខ្លួនពីភាពក្រីក្រ ហើយមានការលំបាកច្រើនក្នុងគេចចេញពី នឹមនៃភាពក្រីក្រ។ ថ្វីត្បិតតែការចុះឈ្មោះចូលរៀនមិនបង់ថ្លៃ តែគ្រួសារ នីមួយៗមានការចំណាយច្រើនសម្រាប់ការសិក្សារបស់កូន ហើយគ្រួសារ ដែលក្រីក្រពិបាកលៃលកឱ្យកូនបន្តការសិក្សា ពិសេសចំណាយសម្រាប់ការ បង្រៀនគួរក្រៅម៉ោង ហើយបើកូនសិស្សមិនបានរៀនគួរបន្ថែមទេ សិស្ស មានការលំបាកក្នុងការប្រកួតប្រជែងក្នុងទទួលបានជោគជ័យលើការសិក្សា ។ លើសពីនេះទៅទៀត ស្ថានភាពអំពើហឹង្សាក្នុងគ្រួសារនៅតែកើតមាន ច្រើននៅឡើយនៅក្នុងប្រទេសកម្ពុជា ដែលវាប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការ សិក្សារបស់កុមារនិងយុវជន។ទង្វើរបស់ឪពុកម្តាយ អាណាព្យាបាលទាំង អស់នេះ ហើយធ្វើឱ្យការអប់រំនៅកម្ពុជាធ្លាក់ទាប ។

### ❖ បណ្តុះបណ្តាលវិជ្ជាជីវៈ (៣៦)-(៤៧)

តម្រូវការកម្រិតជំនាញនៅប្រទេសប្រាក់ចំណូលទាប មិនដូចគ្នានឹង ប្រទេសអភិវឌ្ឍន៍ទេ ហើយសូម្បីតែប្រទេសតែ មួយគ្រឹះស្ថានអប់រំ អាច ពេញចិត្តចំពោះជំនាញដែលពួកគេផ្តល់ដល់យុវជន ប៉ុន្តែនិយោជកអាច មើលឃើញផ្សេងថាយុវជនទាំងនោះនៅខ្វះជំនាញធ្វើការ ដោយសារភាព

មិនស៊ីគ្នារវាងការបណ្តុះបណ្តាលជំនាញ ការសិក្សា និងការងារ។ ជំនាញរបស់នយោជិត ត្រូវបានបែងចែកជា៣សមាសភាពសំខាន់ គឺ (១)ការយល់ដឹង (២)សតិអារម្មណ៍សង្គម និងឥរិយាបថ (៣)បច្ចេកទេស(៣៥)

- **ជំនាញនៃការយល់ដឹង**គឺជាសមត្ថភាពក្នុងការស្វែងយល់ពីគំនិតស្មុគស្មាញ សម្របខ្លួនប្រកបដោយប្រសិទ្ធភាពទៅនឹងបរិស្ថានរៀនសូត្រពីបទពិសោធន៍ ចូលរួមក្នុងទម្រង់ផ្សេងៗនៃការផ្តល់ហេតុផល និងចាត់វិធានការកែតម្រូវបញ្ហា។ អក្ខរកម្មទាំងភាសា និងកុំព្យូទ័រ / អក្ខរកម្មព័ត៌មានវិទ្យា និងលេខគឺជាផ្នែកមួយនៃជំនាញយល់ដឹង។
- **ជំនាញសតិអារម្មណ៍សង្គម**ដែលត្រូវបានគេស្គាល់ផងដែរថាជាជំនាញចរិតលក្ខណៈអាកប្បកិរិយា ឬជំនាញទន់ទាក់ទងនឹងលក្ខណៈដែលគ្របដណ្តប់លើដែនជាច្រើនដូចជា៖ ទំនាក់ទំនងសង្គម ការសំដែងផ្លូវចិត្ត បុគ្គលិកលក្ខណៈ អាកប្បកិរិយា និងឥរិយាបថ។ ទាំងនេះរួមមានភាពបើកចំហចំពោះបទពិសោធន៍ថ្មីៗការយកចិត្តទុកដាក់ ការបំពេញបន្ថែម ការយល់ព្រម និងស្ថិរភាពអារម្មណ៍។
- **ជំនាញបច្ចេកទេស**គឺពឹងផ្អែកសមត្ថភាពប្រើប្រាស់សម្ភារៈ និងឧបករណ៍បច្ចេកទេសដែលមានលក្ខណៈស្មុគស្មាញ មានចំណេះដឹងឯកទេសច្រើនក្នុងវិស័យជាច្រើនដូចជា៖ វិទ្យាសាស្ត្រ វិស្វកម្ម ឱសថ សេដ្ឋកិច្ច ហិរញ្ញវត្ថុ គណនេយ្យ វិទ្យាសាស្ត្រសង្គម និងនយោបាយ(៣៥)។ ជំនាញបច្ចេកទេស អាចត្រូវបានបែងចែកទៅជាជំនាញទាក់ទងនឹងការងារ និងជំនាញការងារជាក់លាក់(៣៦)
- ការប្រោបាច់បញ្ចូលគ្នានូវជំនាញទាំង៣៖ ការយល់ដឹង និងជំនាញសង្គម និងជំនាញបច្ចេកទេសទាក់ទងនឹងការងារ រួមចំណែកដល់ភាពមានការងារធ្វើរបស់មនុស្ស។ ទោះយ៉ាងណាក៏ដោយនៅ

ពេលដែលត្រូវបានគេជួល និយោជិកត្រូវមានជំនាញការងារជាក់លាក់ដើម្បីឱ្យពួកគេអាចបំពេញការងាររបស់ពួកគេបានល្អ និងបំពេញនូវទំនួលខុសត្រូវលើការងាររបស់ពួកគេ។ ជំនាញដែលទាក់ទងនឹងការងារ ជួយឱ្យនិយោជិកធ្វើបានល្អនៅក្នុងការងារ ប៉ុន្តែមិនអាចជំនួសជំនាញការងារជាក់លាក់បានទេ។ ជំនាញបច្ចេកទេសទទួលបានភាគច្រើនពីការសិក្សា ពិសេសនៅកម្រិតមហាវិទ្យាល័យ ឬ ការបណ្តុះបណ្តាល និងអប់រំវិជ្ជាជីវៈ បច្ចេកទេស និងការសិក្សាក្នុងអំឡុងពេលធ្វើការ[៣៥]

❖ **បញ្ហាប្រឈមនៃការគំលាតជំនាញនៅកម្ពុជា** [៤៧]

មានការយល់ស្របកាន់តែច្រើនឡើងថា កម្ពុជាកំពុងប្រឈមនឹងគម្លាតកាន់តែខ្លាំងឡើងរវាងជំនាញដែលឧស្សាហកម្ម និងពាណិជ្ជកម្មត្រូវការ និងអ្វីដែលយុវជនសិក្សានៅស្ថាប័នអប់រំ ឬសាលាបណ្តុះបណ្តាល វិជ្ជាជីវៈ។[៣៧] យោងតាមការស្ទង់មតិឆ្នាំ២០១១ ពីនិយោជកចំនួន៧៨ នាក់ដែលអនុវត្តដោយក្រុមហ៊ុនសេវាកម្មធនធានមនុស្សក្នុងស្រុក HR Inc. (ប្រទេសកម្ពុជា) នយោជក៧៣%បានរាយការណ៍ថា និស្សិតបញ្ចប់ការសិក្សានៅ**មហាវិទ្យាល័យ**នៅកម្ពុជាមិនមានជំនាញត្រឹមត្រូវ[៣៨] ហើយនយោជកច្រើនជាង ៦២%ក៏បានកត់សម្គាល់ផងដែរថា និស្សិតបញ្ចប់**សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ**មិនមានជំនាញត្រឹមត្រូវផងដែរ។ បើយើងប្រៀបធៀបស្ថិតិទាំងពីរនេះ យើងឃើញថា មានតែ១២% ប៉ុណ្ណោះសម្រាប់និស្សិតបញ្ចប់ការសិក្សាពីសកលវិទ្យាល័យ និង៣៨% និស្សិតបញ្ចប់ការសិក្សាពីសាលាបណ្តុះបណ្តាលវិជ្ជាជីវៈមានជំនាញសមស្រប។ ផ្អែកតាមស្ថិតិនេះ វាហាក់បីដូចជាបង្ហាញពីភាពមិនស៊ីសង្វាក់គ្នារវាងការសិក្សា និងទីផ្សារការងារ ដែលនិស្សិតបញ្ចប់ការសិក្សាពីមហាវិទ្យាល័យមានភាពមិនស៊ីសង្វាក់ខ្ពស់ជាង និស្សិតបញ្ចប់ការសិក្សានៅTVET។ ជាងនេះទៀត

និយោជកចំនួន៣១% បានលើកឡើងថា វាពិបាកក្នុងការបណ្ដុះបណ្ដាល ឬបង្កើនសមត្ថភាពជំនាញលើកម្លាំងពលកម្មដែលមានស្រាប់ ដោយសារពួកគេបានលើកឡើងពីគុណភាពទាបនៃកម្មវិធីបណ្ដុះបណ្ដាលដែលន-យោជិកទទួលបាន និងជំនាញមូលដ្ឋានគ្រឹះរបស់បុគ្គលិកមានកម្រិតទាបពេក[៣៨]។ វាដូចគ្នានេះដែរទៅនឹងការស្ទង់មតិឆ្នាំ២០១៤ ដែលឧបត្ថម្ភដោយអង្គការពលកម្មអន្តរជាតិ (ILO) របស់អ្នកដឹកនាំធុរកិច្ច និងនិយោជិកមកពីប្រទេសអាស៊ានចំនួន ៧ ដែលរួមមាន៖ ប្រទេសកម្ពុជា ឥណ្ឌូនេស៊ីឡាវ ម៉ាឡេស៊ី ភូមា ហ្វីលីពីន និងសិង្ហបុរី[៣៩]។ សមាមាត្រអ្នកឆ្លើយសំណួរស្ទង់មតិ បានបង្ហាញថាពួកគេ ″**យល់ស្រប**″ថា ប្រទេសកម្ពុជាមានកម្រិតទាបបំផុតទី២ នៃភាពស៊ីគ្នារវាងជំនាញនិស្សិតបញ្ចប់ការសិក្សាពីកម្រិតផ្សេងៗគ្នា និងតម្រូវការសហគ្រាស ដោយនាំមុខតែប្រទេសភូមាមួយប៉ុណ្ណោះ។ ការឆ្លើយតបរបស់និយោជកបានបង្ហាញថា មានតែសិស្ស២០% ប៉ុណ្ណោះដែលបញ្ចប់ការសិក្សាពីកម្រិតមធ្យមសិក្សា ហើយនិស្សិត៤០% បញ្ចប់ការសិក្សានៅមហាវិទ្យាល័យ និង សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈមានជំនាញដែលបំពេញតម្រូវការរបស់សហគ្រាសបាន[៣៩]។ លើសពីនេះទៅទៀតមានតែនិយោជកប្រហែល១០%ប៉ុណ្ណោះដែលបានវាយតម្លៃគុណភាពអ្នកផ្ដល់សេវាអប់រំសាធារណៈនៅកម្ពុជាថាជា "**ល្អ និងល្អណាស់**"[៣៩]។ ផ្អែកតាមការស្រាវជ្រាវបង្ហាញថា ប្រទេសកម្ពុជាមានគំលាតសម្រាប់វិជ្ជាជីវៈកម្រិតខ្ពស់ដូចជា៖ **អ្នកគ្រប់គ្រង វិស្វករ និងវេជ្ជបណ្ឌិត** ។ នៅក្នុងការស្ទង់មតិរបស់ HRINC ឆ្នាំ២០១១ លើការខ្វះខាតជំនាញច្បាស់លាស់បំផុតបានបង្ហាញថា និយោជក៧០%បានលើកឡើងពីកង្វះខាតដ៏សំខាន់លើផ្នែកគ្រប់គ្រង[៣៩]។ ការសិក្សាថ្មីមួយទៀតបានប៉ាន់ប្រមាណថាប្រសិនបើប្រទេសកម្ពុជាចង់ទាក់ទាញការវិនិយោគដោយផ្ទាល់ពីបរទេសក្នុងចន្លោះពី ៦ ទៅ៨% នៃGDPសម្រាប់ឆ្នាំ២០១៤ និងឆ្នាំ២០២០ គេត្រូវការមេវិស្វកម្មប្រហែល៣៥ ០០០ នាក់ និងអ្នកបច្ចេកទេសចំនួន៤៦ ០០០នាក់ទៀត

នៅឆ្នាំ២០១៨[៤០]។ សម្រាប់ស្ថានភាពឆ្នាំ២០១៤ ការផ្គត់ផ្គង់បុគ្គលិកទាំងនេះនៅឆ្ងាយពីតួលេខត្រូវការខ្លាំងណាស់ ហើយសម្រាប់គោលដៅក្លាយជាប្រទេសប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ គឺកាន់តែត្រូវការមូលធនមនុស្សដែលមានជំនាញបែបនេះកាន់តែច្រើន។ មួយវិញទៀត វាត្រូវបានគេដឹងជាទូទៅថា ប្រទេសកម្ពុជាប្រឈមនឹងកង្វះគ្រូពេទ្យដែលមានសមត្ថភាពគ្រប់គ្រាន់ជាច្រើន ហើយសម្រាប់ឆ្នាំ២០១៣ កម្ពុជាមានវេជ្ជបណ្ឌិតតែ២.៣ប៉ុណ្ណោះក្នុងចំណោមប្រជាជន១ម៉ឺននាក់[៤១] ដែលសមាមាត្រគ្រូពេទ្យនេះ មានកម្រិតទាបខ្លាំងណាស់ ពោលគឺតិចជាងពាក់កណ្ដាលតួលេខជាមធ្យមសម្រាប់បណ្ដាប្រទេសអាស៊ាន[៤២]។ កង្វះខាតជំនាញទាំងនេះ គឺដោយសារអត្រាសិក្សាទាបសម្រាប់វគ្គបណ្ដុះបណ្ដាលជំនាញឯកទេស។ ក្នុងឆ្នាំ២០០៩/២០១០ ក្នុងចំណោមសិស្សដែលបានចុះឈ្មោះចូលរៀនសម្រាប់សញ្ញាបត្រឧត្តមសិក្សានៅក្នុងប្រទេស សិស្សប្រមាណ១០%បានចុះឈ្មោះចូលរៀនមុខវិជ្ជាគ្រប់គ្រងធុរកិច្ច ប្រមាណ៦%ទៀតលើផ្នែកវេជ្ជសាស្ត្រថែទាំ និងឱសថសាស្ត្រ ប្រហែល ៦% សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រកុំព្យូទ័រ និងតិចជាង៣% សម្រាប់វិស្វកម្ម១,៤% សម្រាប់វិទ្យាសាស្ត្រ និង១,៣%សម្រាប់គណិតវិទ្យា[៣៨]។ គុណភាពអប់រំមានកម្រិតទាប បើទោះជាមាននិស្សិតបញ្ចប់ការសិក្សាផ្នែកទាំងនេះនៅតិចតួចក៏ដោយ គឺជាបញ្ហាចម្បងមួយ ដែលនាំឱ្យមានភាពគំលាតជំនាញទាំងនេះ។ ឧទាហរណ៍និយោជកផ្នែកឯកជនមួយចំនួនកត់សម្គាល់ថា វិស្វករដែលមានសញ្ញាបត្របញ្ចប់ការសិក្សាពីប្រទេសកម្ពុជាមានកម្រិតជំនាញស្មើនឹងនិស្សិតវិស្វករឆ្នាំទី១ ឬទី២ នៅប្រទេសជិតខាងមួយចំនួន។

❖ **គំលាតជំនាញ ក្នុងវិស័យទេសចរ-Skill gaps in the tourism sector**

ខណៈកង្វះជំនាញនៅក្នុងវិស័យឧស្សាហកម្មបានទទួលការយកចិត្តទុកដាក់ជាច្រើនផងដែរនៅក្នុងប្រទេសកម្ពុជា វគ្គមានគម្លាតជំនាញនៅក្នុង

វិស័យសេវាកម្មរបស់ប្រទេសនេះ ជាពិសេសនៅក្នុងវិស័យទេសចរណ៍បានទាក់ទាញការយកចិត្តទុកដាក់តិចតួច។ ការកាត់បន្ថយគម្លាតជំនាញក្នុងវិស័យទេសចរណ៍ជារឿងចាំបាច់សម្រាប់ប្រទេសកម្ពុជាត្រូវយកចិត្តទុកដាក់ឱ្យបានមុតមាំបន្ថែមទៀត ព្រោះវានៅតែជាប្រភពដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចជាតិ និងជាប្រភពប្រាក់ចំណូលជាតិ។ ជាមួយនឹងការមកដល់របស់ភ្ញៀវទេសចរជាង៤លាននាក់នៅឆ្នាំ២០១៣ វិស័យទេសចរណ៍អាចរួមចំណែកយ៉ាងសំខាន់ដល់ការបង្កើតការងារ និងការបង្កើតចំណូលនៅក្នុងប្រទេស[៣៧]។ សារៈសំខាន់ផ្នែកសេដ្ឋកិច្ចនៃវិស័យទេសចរនៅកម្ពុជាគឺខ្ពស់ជាងប្រទេសជិតខាង[៣៧]។

### ❖ **ផលប៉ះពាល់នៃគំលាតជំនាញ**-Impacts of the skill gap

នៅកម្រិតក្រុមហ៊ុន គំលាតជំនាញរាំងដល់ការអភិវឌ្ឍសមត្ថភាព ការច្នៃប្រឌិត ចែកចាយផលិតផល និងសេវាកម្មទាន់ពេលវេលា និងបំពេញតាមស្តង់ដារគុណភាពនៃផលិតផលរបស់ពួកគេ[៤៣]។ ការចង្អុលបង្ហាញពីផលប៉ះពាល់ផ្សេងៗមួយចំនួននៅក្នុងប្រទេសកម្ពុជាអាចត្រូវបានគេយកមកពិចារណាពីផលប៉ះពាល់ការងារដែលពិបាកបំពេញ ដោយនិយោជកក្នុងការស្ទង់មតិនិយោជកឆ្នាំ២០១២ របស់ILO[៤៤]។ ប្រហែល២ ភាគ៣នៃក្រុមហ៊ុនដែលចូលរួមនៅក្នុងការស្ទង់មតិនោះបានរាយការណ៍ថា ពួកគេមានការលំបាកក្នុងការជ្រើសរើសបុគ្គលិកថ្មីដើម្បីបំពេញការងារដែលនាំឱ្យមានការពន្យារពេលការអភិវឌ្ឍផលិតផល និងសេវាកម្មថ្មីរបស់ពួកគេ។ ការពន្យារពេលក្នុងការអភិវឌ្ឍន៍ផលិតផលថ្មី និងការខាតបង់អាជីវកម្មដោយសារការប្រកួតប្រជែងគឺជាផលប៉ះពាល់ដ៏ធ្ងន់ធ្ងរបំផុតសម្រាប់ឧស្សាហកម្មកាត់ដេរ សំលៀកបំពាក់ និងស្បែកជើង ហើយការបង្កើនការងារហួសប្រមាណដល់បុគ្គលិកដែលមានស្រាប់ វាធ្វើឱ្យប៉ះពាល់ដល់គុណភាព សេវាកម្ម អតិថិជន ជាបញ្ហាចម្បងដែលអាជីវកម្មសណ្ឋាគារ និងផ្ទះសំណាក់

បានជួបប្រទះ[៤៤]។ ក្នុងករណីធ្ងន់ធ្ងរក្រុមហ៊ុនជាច្រើនត្រូវបានបង្ខំឱ្យដកផលិតផល និងសេវាកម្មមួយចំនួនចេញពីទីផ្សារ។ ភាពមិនស៊ីសង្វាក់នៃគម្លាតជំនាញត្រូវបានលេចឡើងនៅដំណាក់កាលដ៏សំខាន់មួយសម្រាប់ប្រទេសកម្ពុជាៈ នៅពេលដែលប្រទេសនេះត្រៀមខ្លួន ប្រែក្លាយពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ទៅមធ្យមកម្រិតខ្ពស់ និង ដំណាក់កាលបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។ បទពិសោធន៏នៅកន្លែងផ្សេងទៀតបង្ហាញថាសម្រាប់ប្រទេសដែលវិវត្តខ្លួនដោយជោគជ័យពីមធ្យមកម្រិតទាបទៅឋានៈមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ គឺប្រែក្លាយកម្លាំងពលកម្មដែលគ្មានជំនាញ ទៅជំនាញកម្រិតទាប រួចកម្រិតមធ្យម ចុងក្រោយទៅជំនាញកម្រិតខ្ពស់[៤៥]។ សម្រាប់គម្រោងសមាហរណកម្មក្នុងតំបន់បង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន(AEC)ចុងឆ្នាំ២០១៥ បាននាំមកនូវឱកាស និងបញ្ហាប្រឈមសម្រាប់ប្រទេសជាសមាជិករបស់ខ្លួន ពិសេសទាក់ទងនឹងលំហូរកម្លាំងពលកម្ម[៤៦]។ ការផ្តល់ឱ្យមានលំហូរដោយសេរីនូវកម្លាំងពលកម្មជំនាញខ្ពស់កាន់តែច្រើនក្នុងវិស័យជំនាញធំ ៗ ចំនួនប្រាំបីដូចជា៖ វេជ្ជបណ្ឌិត ពេទ្យធ្មេញ គិលានុបដ្ឋាយិកាវិស្វករ ស្ថាបត្យករ គណនេយ្យករ អ្នកស្ទង់មតិ និងអ្នកជំនាញឧស្សាហកម្មទេសចរណ៍ ទំនងជាមានផលប៉ះពាល់យ៉ាងខ្លាំងដល់គម្លាតជំនាញ និងកំណែទម្រង់ការអប់រំនៅកម្ពុជា។ ជាទូទៅបណ្តាប្រទេសជាសមាជិកអាស៊ានអាចទទួលបានផលប្រយោជន៍ពីលំហូរដោយសេរីនៃកម្លាំងពលកម្មដែលមានជំនាញខ្ពស់នៅកម្រិតខុសៗ គ្នាព្រោះពួកគេអាចបំពេញគំលាតជំនាញ និងភាពមិនស៊ីចង្វាក់គ្នានៃជំនាញថ្នាក់ជាតិដោយការហូរចូលជំនាញងាយស្រួលជាងមុនពីប្រទេសមួយទៅប្រទេសមួយ និងនាំចេញកម្លាំងពលកម្មដែលលើសទៅប្រទេសដទៃទៀតដែលខ្វះ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អត្ថប្រយោជន៍សម្រាប់ប្រទេសក្រីក្រនៅក្នុងតំបន់អាស៊ាននៅមានកម្រិត ដោយសារតែមិនបានដាក់បញ្ចូលលំហូរកម្លាំងពលកម្មដែលគ្មានជំនាញ។

មួយវិញទៀត ការកំណត់លំហូរកម្មករដែលមានជំនាញខ្ពស់នៅក្នុង AEC នៅតែមានភាពងាយស្រួលសម្រាប់ប្រទេសមួយចំនួនដូចជា ប្រទេសកម្ពុជាក្នុងការនាំចូលកម្មករមានជំនាញខ្ពស់។ លំហូរនេះ វាអាចជួយប្រទេសកម្ពុជាក្នុងការដោះស្រាយបញ្ហាកង្វះខាតកម្មករជំនាញ និងគម្លាតជំនាញ។ ជាការពិត និយោជកប្រហែល៧០% មកពីប្រទេសកម្ពុជានៅក្នុងការស្ទង់មតិទីផ្សារពិគ្រោះយោបល់បាននិយាយថា លំហូរពលករដែលមានជំនាញខ្ពស់នៅក្រោមសហគមន៍សេដ្ឋកិច្ចអាស៊ាននឹងមានផលវិជ្ជមាន លើផលប្រយោជន៍របស់សហគ្រាស តួលេខខ្ពស់បំផុតក្នុងចំណោមបណ្តាប្រទេសចំនួន៧។[៣៩]ទោះយ៉ាងណាក៏ដោយ បើគ្មានវិធានការចាំបាច់ដើម្បីលើកកម្ពស់កម្លាំងពលកម្មវ័យក្មេងរបស់ខ្លួនទេ ការចល័តពលករដែលមានជំនាញខ្ពស់របស់AECអាចធ្វើឱ្យប្រទេសកម្ពុជាពឹងផ្អែកខ្លាំងលើកម្មករជំនាញដែលនាំចូល[៣៦]។ ការពឹងផ្អែកលើការនាំចូលជំនាញជាជាងការផលិតក្នុងស្រុកខ្លួនឯង អាចក្លាយជាឧបសគ្គដល់ការងារយុវជនកម្ពុជាចំនួនដ៏ច្រើន និងកម្មករជំនាញដែលមិនមានជំនាញគ្រប់គ្រាន់ដើម្បីប្រកួតប្រជែងជាមួយពលករជំនាញខ្ពស់ដែលនាំចូលពីប្រទេសនានាដែលជាសមាជិករបស់សហគមសេដ្ឋកិច្ចអាស៊ាន។ តាមរយៈទស្សនវិស័យសេដ្ឋកិច្ច-សង្គមដ៏ទូលំទូលាយ យុវជនដែលមានជំនាញជាមួយ ការងារប្រកបដោយផលិតភាព និងការងារសមរម្យ ដូចជាសង្គមសុខុមាលភាពគឺជាកត្តាកំណត់ និងជាផ្នែកមួយនៃការអភិវឌ្ឍមនុស្ស ឬការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាទូទៅ។ ការដោះស្រាយបញ្ហាជំនាញដែលកំពុងរីកចម្រើនដោយផ្តល់នូវជំនាញដែលត្រឹមត្រូវដល់យុវជនក៏ជាការបញ្ជាប់ដោយខ្លួនឯងផងដែរដែលជាមធ្យោបាយដើម្បីសំរេចបាននូវកំណើនលូតលាស់ប្រកបដោយនិរន្តរភាព ។

សម្រាប់បញ្ហាប្រឈមមួយទៀតទាក់ទងនឹងអត្រាចូលរៀនជំនាញវិជ្ជាជីវៈ ទោះបីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបាន

ដំឡើងកម្រិតPTCs ចំនួន៥ ទៅជាមជ្ឈមណ្ឌលបណ្ដុះបណ្ដាលភូមិភាគ ដែលផ្ដល់ជូននូវសញ្ញាបត្រ វិញ្ញាបនប័ត្រ និងវគ្គសិក្សាកម្រិតសញ្ញាបត្រក៏ដោយ ក៏ការទាក់ទាញសិស្សថ្នាក់ទី ៩ ឱ្យចុះឈ្មោះចូលរៀនវគ្គសិក្សាជំនាញ បច្ចេកទេស វិជ្ជាជីវៈនៅគ្រឹះស្ថានសាធារណៈនៅតែ ជាបញ្ហាប្រឈមដ៏ធំមួយដោយសារតែ (១)ការខ្វះព័ត៌មានអំពីកម្មវិធី TVET និងភាពទាក់ទងការបណ្ដុះបណ្ដាលទៅនឹងការងារ (២)ភាពសង្ស័យទាក់ទងនឹងគុណភាពនៃការបែងចែកការងារ និង (៣)ការមិនមានមធ្យោបាយសម្រាប់បន្តការសិក្សានៅអប់រំជាន់ខ្ពស់ (ឧត្ដមសិក្សា)។

**និយាយជារួម**ប្រទេសកម្ពុជាកំពុងប្រឈមនឹងឱនភាពជំនាញដ៏ធំសូម្បីតែវិស័យដែលពឹងផ្អែកលើជំនាញតិចតួចដូចជាសម្លៀកបំពាក់ បដិសណ្ឋារកិច្ច ទេសចរណ៍ និងសំណង់ជាដើម។ កង្វះជំនាញសម្រាប់វិស័យដែលមានជំនាញច្រើនដូចជាគ្រឿងបន្លាស់រថយន្ត អេឡិចត្រូនិច និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ហើយសូម្បីតែជំនាញកម្រិតខ្ពស់ ដូចជាអ្នកគ្រប់គ្រង វិស្វករ និងគ្រូពេទ្យជាដើម[៤៧]។ កង្វះខាតជំនាញសម្រាប់វិស័យឧស្សាហកម្មបានទទួលការយកចិត្តទុកដាក់ជាច្រើននៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយកង្វះខាតជំនាញសម្រាប់វិស័យទេសចរណ៍ របស់ប្រទេសបានទទួលការយកចិត្តទុកដាក់តិចតួចនៅឡើយ។ គួរឱ្យចាប់អារម្មណ៍វិស័យទេសចរណ៍ដែលរួមចំណែកយ៉ាងធំធេងចំពោះកំណើនប្រាក់ចំណូល និងបង្កើតការងារ (និងមានសក្ដានុពលកាន់តែធំនាពេលអនាគត) កំពុងប្រឈមនឹងកង្វះខាតជំនាញយ៉ាងធ្ងន់ធ្ងរដែលជាវិស័យឧស្សាហកម្ម[៤៧]។កង្វះខាតជំនាញទូទៅដែលគ្របដណ្ដប់លើប្រភេទជំនាញធំទូលាយទាំងបីគឺ ការយល់ដឹង បច្ចេកទេស និងជំនាញទន់ កំពុងជះឥទ្ធិពលអវិជ្ជមានដល់ធុរកិច្ចនៅតាមវិស័យជាច្រើន។ ប្រសិនបើគម្លាតជំនាញមិនត្រូវបានធ្វើឱ្យរួមតូចទេ កំណើនសេដ្ឋកិច្ចរបស់ប្រទេស និងថាមភាពអាជីវកម្មនឹងត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនាពេលអនាគត។

លើសពីនេះទៅទៀតពីទស្សនវិស័យសេដ្ឋកិច្ច-សង្គមដ៏ទូលំទូលាយការជួយយុវជនក្នុងការលើកកម្ពស់ភាពមានការងារធ្វើរបស់ពួកគេមានសារៈសំខាន់ជាពិសេសសម្រាប់ការផ្តល់អំណាចដល់ពួកគេ និងសម្រេចបាននូវគោលដៅធំធេងនៃការអភិវឌ្ឍមនុស្ស(៤៧)។ គម្លាតជំនាញគឺជាផ្នែកមួយនៃបញ្ហា។ ក៏មានភាពមិនស៊ីសង្វាក់ជំនាញច្រើននៅក្នុងប្រទេសផងដែរ។ សូម្បីតែផ្នែកធុរកិច្ច ប្រឈមនឹងកង្វះខាតនូវជំនាញដែលត្រូវការក្នុងការធ្វើឧស្សាហូបនីយកម្ម និងធ្វើទំនើបកម្មសេដ្ឋកិច្ចដ៏ឆាប់រហ័សក្តី ក៏មានយុវជនដែលមានការអប់រំពីមហាវិទ្យាល័យធំៗ ដែលមានជំនាញមិនត្រូវគ្នានឹងតម្រូវការរបស់និយោជក និងសហគ្រាស។ ភាពមិនស៊ីសង្វាក់គ្នានេះបានធ្វើឱ្យយុវជនមានចំណេះដឹងការងារ និងមានសក្តានុពលបង្កឱ្យមានចលាចលយុវជន ការគំរាមកំហែងដល់ស្ថិរភាពសង្គម និងនយោបាយ(៤៧)។ ការគិតឡើងវិញអំពីរបៀបដោះស្រាយគំលាតជំនាញ និងភាពមិនស៊ីគ្នានៃជំនាញ និងទីផ្សារការងារគឺត្រូវការចាំបាច់ ប្រសិនបើប្រទេសកម្ពុជា ធ្វើដំណើរទៅជាប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងទទួលបានជោគជ័យក្នុងការធ្វើសមាហរណកម្មជាមួយសហគមន៍សេដ្ឋកិច្ចអាស៊ាននៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ ជាទូទៅបញ្ហានេះបានធ្វើឱ្យមនុស្សម្នាក់ៗទទួលបាននូវការអប់រំត្រឹមត្រូវដើម្បីឱ្យពួកគេបានត្រៀមខ្លួនជាមួយនឹងជំនាញនិងចំណេះដឹងត្រឹមត្រូវដើម្បីសម្របខ្លួនទៅនឹងទីផ្សារដែលមានការផ្លាស់ប្តូរ និងមានការប្រកួតប្រជែង(៤៧)។ របៀបដែលប្រព័ន្ធអប់រំរបស់ប្រទេសនេះអាចរួមចំណែកក្នុងការកាត់បន្ថយគម្លាតជំនាញ និងភាពមិនស៊ីគ្នានិងការកែទម្រង់ដែលទាមទារអោយមានដូចជាកំណែទម្រង់ចាប់ពីថ្នាក់ឧត្តមសិក្សារហូតដល់ការមត្តេយ្យសិក្សា និង អភិវឌ្ឍន៍កុមារតូចតាមរយៈការអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាព្រមទាំង TVET ត្រូវបានគេពិនិត្យឡើងវិញ ។

**សរុបសេចក្តីមក វិស័យអប់រំប្រទេសកម្ពុជានៅដំណាក់កាលនេះជួបប្រទះនូវបញ្ហាប្រឈមជាច្រើន។** ទោះបីជាមានការពង្រីកកន្លែងសិក្សានៅប៉ុន្មានឆ្នាំចុងក្រោយនេះយ៉ាងណាក៏ដោយ ក៏ចន្លោះប្រហោងនៃ វិសាលភាពកម្រិតមធ្យមសិក្សានៅតែមាន ហើយការរីកចម្រើនឆាប់រហ័សនៃប្រព័ន្ធនេះ ក៏នាំមកនូវកង្វះខាតគ្រូបង្រៀន ការបណ្តុះបណ្តាលលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនបានតិចតួច ប្រាក់ខែគ្រូបង្រៀនមិនគ្រប់គ្រាន់ និងថ្លៃចំណាយក្រៅផ្លូវការជាញឹកញាប់ដែលជះឥទ្ធិពលអវិជ្ជមានដល់ការរៀនត្រួតថ្នាក់ អត្រាបោះបង់ចោលការសិក្សា និងរួមចំណែកធ្វើឱ្យគុណភាពអប់រំធ្លាក់ចុះ។ បញ្ហាប្រព័ន្ធសំខាន់ៗនៃការបណ្តុះបណ្តាលវិជ្ជាជីវៈ គឺ (១) ការមិនផ្តោតទៅលើសហគ្រិនភាព (២)កង្វះប្រព័ន្ធធានាគុណភាព និងព័ត៌មានទីផ្សារការងារ (៣)ការត្រួតពិនិត្យគុណភាពវគ្គបណ្តុះបណ្តាល និងស្ថាប័នអប់រំមិនល្អ (៤)ការផ្សារភ្ជាប់ទន់ខ្សោយជាមួយសហគ្រាស និងក្រុមហ៊ុន។ (៥)កង្វះលទ្ធភាពទទួលបានឱកាសបណ្តុះបណ្តាល បច្ចេកទេស វិជ្ជាជីវៈជាផ្លូវការនៅតាមជនបទ (៦)ខ្វះការប្រៀបធៀប និងភាពបត់បែនក្នុងការផ្តល់ការបណ្តុះបណ្តាល និង (៧)មិនមានប្រភពហិរញ្ញវត្ថុគ្រប់គ្រាន់។

**ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងឡាយនៅដំណាក់កាលនេះ** រដ្ឋាភិបាលនឹងបន្តអនុវត្តគោលការណ៍អប់រំសម្រាប់ទាំងអស់គ្នាដើម្បីធានាឱ្យមានការទទួលបានការអប់រំប្រកបដោយសមធម៌កែលម្អគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិតទាំងអស់ និងបន្តធ្វើឱ្យប្រសើរឡើងនូវស្ថាប័ន និងសមត្ថភាពបុគ្គលិកអប់រំ។ ទាំងនេះត្រូវបានបង្ហាញក្នុងផែនការយុទ្ធសាស្ត្រអប់រំ២០១៤ - ២០១៨ ដែលរួមមានអាទិភាពដូចខាងក្រោមដោយផ្តោតទៅលើ៖

- លើកកម្ពស់ការយល់ដឹង និងសមត្ថភាពមនុស្សក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ជាពិសេសវិស័យអាទិភាពដូចជាកសិកម្ម រួម

មានដំណាំកសិកម្ម សត្វចិញ្ចឹម និងវារីវប្បកម្ម ឧស្សាហកម្ម ថាមពល វិស័យសំណង់ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត វិស័យបច្ចេកវិទ្យា គមនាគមន៍ព័ត៌មានវិទ្យា និងសុខាភិបាល និង បញ្ហាបរិស្ថាន

- បង្កើនលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ តាមរយៈបង្កិតទីតាំងសាលាបឋមសិក្សាក្នុងភូមិទាំងអស់យ៉ាងហោចណាស់ឱ្យមានសាលាអនុវិទ្យាល័យមួយក្នុងមួយឃុំ ពង្រីកចំនួនសាកលវិទ្យាល័យ ឬសាខាដើម្បីជានាឱ្យមានមួយនៅក្នុងខេត្តនិមួយៗ ពង្រាយគ្រូបង្រៀនដើម្បីធានាថាការគ្របដណ្តប់ពេញលេញនៅគ្រប់តំបន់ ទាំងតំបន់ដែលមិនសូវទទួលបានផលប្រយោជន៍ (disadvantaged areas) តាមរយៈការបង្កើនចំនួនអន្តេវាសិកដ្ឋាន ផ្តល់មធ្យោបាយធ្វើដំណើរ កាត់បន្ថយការចំណាយរបស់មាតាបិតាសម្រាប់ការអប់រំ បង្កើនថវិកាតាមសាលារៀនក៏ដូចជាបង្កើនការចូលរួមពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ក្នុងការអភិវឌ្ឍវិស័យអប់រំ។
- បង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិត និងការបណ្តុះបណ្តាលទាំងជំនាញបច្ចេកទេស និងមុខងារនៅក្នុងស្ថាប័នសាធារណៈ និងឯកជនស្របតាមស្តង់ដារអន្តរជាតិ និងតម្រូវការអភិវឌ្ឍន៍របស់ប្រទេស។
- បន្តការកែលម្អការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការអប់រំ និងការអភិវឌ្ឍន៍យុវជនសម្រាប់ជំនាញបច្ចេកទេស និងទន់ភ្លន់ដើម្បីធ្វើការជាក្រុម ដើម្បីពង្រឹងវិន័យ និងធានានូវក្រមសីលធម៌វិជ្ជាជីវៈនៅកន្លែងធ្វើការ។

ទន្ទឹមនឹងនេះដែរ គំនិតផ្តួចផ្តើមកំណែទម្រង់របស់ក្រសួងអប់រំយុវជននិងកីឡា (MoEYS) នៅក្នុងបរិបទនៃ EFA នឹងត្រូវបានគាំទ្រនិងពង្រឹងតាមរ

យៈការអនុវត្តច្បាប់ និងបង្កើនស្តង់ដារអប់រំ។ រដ្ឋធម្មនុញ្ញកម្ពុជាចែងថា សាលារៀនសាធារណៈត្រូវផ្តល់ការអប់រំមូលដ្ឋានដោយឥតគិតថ្លៃរយៈពេលប្រាំបួនឆ្នាំ។ ការបង្កើតច្បាប់ទូលំទូលាយស្តីពីការអប់រំនឹងបង្កើតនូវស្តង់ដារអប់រំដោយមានចេតនាច្បាស់លាស់ដើម្បីធ្វើការឆ្ពោះទៅរកការទទួលបាននូវសេវាអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត។ មួយវិញទៀត ចក្ខុវិស័យវិស័យអប់រំរយៈពេលវែងរបស់កម្ពុជាទទួលស្គាល់ថា ការទទួលបានការអប់រំកុមារតូចគឺជាមូលដ្ឋានដ៏រឹងមាំមួយសម្រាប់គ្រប់កម្រិតនៃការអប់រំ។ ក៏មានការយកចិត្តទុកដាក់ផងដែរ លើការផ្តល់ការគាំទ្របន្ថែមលើការអាន និងគណិតវិទ្យាដល់សិស្សានុសិស្សនៅថ្នាក់ដំបូងនៃការអប់រំកម្រិតបឋមសិក្សា។ សិស្សបញ្ចប់ការសិក្សាកម្រិតមូលដ្ឋានគួរមានឱកាសសម្រាប់ការរៀនបន្តថ្នាក់មធ្យមសិក្សាបឋមភូមិ រួចឈានទៅមធ្យមសិក្សាទុតិយភូមិ ឬថ្នាក់ជំនាញបច្ចេកទេស វិជ្ជាជីវៈនិងថ្នាក់ខ្ពស់ជាងនេះទៀត។ ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៤-២០១៨ទទួលស្គាល់បញ្ហាប្រឈមទាំងនេះ និងស្វះស្វែងរកវិធីដោះស្រាយ។ គុណភាពនៃការអប់រំនឹងត្រូវបានពង្រឹងដោយផ្តោតលើការលើកកម្ពស់ការបង្រៀន ការរៀន និងលទ្ធផលសិក្សារបស់សិស្ស។ គុណសម្បត្តិរបស់គ្រូបង្រៀននឹងត្រូវបានតម្លើងពី១២ + ២ ដល់ ១២ + ៤ នៅត្រឹមឆ្នាំ២០២០។ វាក៏នឹងផ្តោតលើការធានាផងដែរថា កម្មវិធីសិក្សានៃការអប់រំចំណេះទូទៅ និងការអប់រំកម្រិតខ្ពស់ ឆ្លើយតបនឹងបទដ្ឋានគុណភាពអាស៊ាន។

ការអប់រំគឺជាគន្លឹះក្នុងការសម្រេចចក្ខុវិស័យយូរអង្វែងរបស់ប្រទេសកម្ពុជាក្នុងការកសាងប្រទេសដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់ កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងសមធម៌ កែលម្អជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រ។ ការអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការអប់រំត្រូវ

បានកំណត់ថាជាអាទិភាពមួយក្នុងចំណោមអាទិភាពរបស់រដ្ឋាភិបាលទាំងបួនដែលនឹងជានាឱ្យមានការប្រកួតប្រជែងនៅក្នុងទីផ្សារការងារក្នុងតំបន់ដែលកំពុងបើកទូលាយ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើកត្តា៤គឺ: (១)ការបណ្តុះបណ្តាលពលកម្មជំនាញ និងផលិតភាពដើម្បីបំពេញតម្រូវការទីផ្សារ និងបង្កើនគុណតម្លៃបន្ថែម (added value) (២)បង្កើតក្របខណ្ឌគតិយុត្តិ និងកែលម្អស្ថាប័នបណ្តុះបណ្តាលអប់រំ និងវិជ្ជាជីវៈ (៣)ជំរុញការចូលរួមរបស់វិស័យឯកជនក្នុងវិស័យអប់រំ (៤)ការពង្រឹងគុណភាពនៃការអប់រំលើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្រ្ត ការអភិវឌ្ឍបច្ចេកវិទ្យា និងការច្នៃប្រឌិត។ បញ្ហាប្រឈមចម្បងគឺដើម្បីអភិវឌ្ឍបរិយាកាសអប់រំដែលកុមារម្នាក់ៗត្រូវបានគេអប់រំតាមអាយុរបស់ពួកគេ សម្បទា និងសមត្ថភាពដើម្បីបង្កើតកម្លាំងពលកម្មដែលមានជំនាញខ្ពស់។

ជាមួយគ្នានេះ ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងក៏ដាក់ចេញនូវកំណែទម្រង់ស៊ីជម្រៅ១៥ចំណុច ដូចខាងក្រោម៖

**កំណែទម្រង់១៥ចំណុច៖ (បទបង្ហាញរបស់បណ្ឌិត ហង់ ជួន ណារ៉ុន ២០១៥)**

1. **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** (អនុវត្តប្រព័ន្ធព័ត៌មានក្នុងគ្រប់គ្រង បណ្តុះបណ្តាលមន្រ្តីលទ្ធកម្ម ធ្វើប្រតិបត្តិការសវនកម្មផ្ទៃក្នុង)
2. **ការពង្រាយគ្រូបង្រៀន**(កែសម្រួលលក្ខខណ្ឌឡើងវិញ វាយតម្លៃ និងស្វ័យប្រកាសពីស្ថានភាពលើស និងខ្វះគ្រូ បញ្ចូលសាលាសហគមន៍ពហុភាសា៥០ឱ្យចូលជាសាលារដ្ឋ បញ្ចូលគ្រូអ៊ីស្លាម ១៤០០នាក់ គ្រូជនជាតិដើម២០នាក់ក្នុងក្របខណ្ឌ)

3. **កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន** (អភិវឌ្ឍន៍មជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងបាត់ដំបងទៅជាវិទ្យាស្ថានគរុកោសល្យ។ អនុម័តស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ រៀបចំស្តង់ដារគ្រូបង្រៀន និងឯកសារទស្សនៈទានស្តីពីគន្លងអាជីព។)
4. **លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន** (អនុវត្តប្រព័ន្ធក្រេឌីត សម្រាប់វាយតម្លៃសមត្ថភាពបុគ្គលិកអប់រំ បង្កើតការិយាល័យគាំទ្រគ្រូបង្រៀន និងរៀបចំគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀនប្រព័ន្ធពន្លឿន)
5. **ការងារអធិការកិច្ច** (រៀបចំសៀវភៅស្តីពីអធិការកិច្ចតាមកាលកំណត់ និងឧបករណ៍អធិការកិច្ច អភិវឌ្ឍន៍សមត្ថភាពអធិការកិច្ច រៀបចំរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិជា៨តំបន់អធិការកិច្ច សាកល្បងអធិការកិច្ចតាមកាលកំណត់៧០សាលា
6. **រង្វាយតម្លៃលទ្ធផលសិក្សា** (ផ្សព្វផ្សាយលទ្ធផលតេសថ្នាក់ជាតិថ្នាក់ទី៣ ទី៦ និងទី៨មុខវិជ្ជាភាសាខ្មែរ រូបវិទ្យា និងគណិតវិទ្យា ធ្វើតេសវាយតម្លៃថ្នាក់តំបន់សាកល្បង៣៥សាលា ធ្វើតេសវាយតម្លៃ តម្រិតអន្តរជាតិសាកល្បងសម្រាប់ការអភិវឌ្ឍ៥៦សាលា ធ្វើតេសល្បឿនអំណាន)
7. **កំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិ** (កែលម្អយន្តការកំណែ និងប្រព័ន្ធពិនិត្យតាមដាន កែលម្អសង្ខេបមេរៀនកំណែលម្អយន្តការបូកស្រង់ អនុម័តមេរៀនសង្ខេបប្រវត្តិសាស្ត្រថ្នាក់ទី១២)
8. **កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល**(ដាក់ឱ្យប្រើប្រាស់សៀវភៅសិក្សាអង់គ្លេស ផ្សព្វផ្សាយក្របខណ្ឌកម្មវិធី

ចំណេះទូទៅ និងអប់រំបច្ចេកទេស រៀបចំកម្មវិធីសិក្សាលម្អិត និងស្តង់ដារមុខវិជ្ជាឯកទេស រៀបចំ គំរូតែងសេចក្តី)

9. **សាងសង់អគារសិក្សា និងការជុសជុលៈ** (ជុសជុល និងកែលម្អមណ្ឌលប្រឡងមធ្យមសិក្សាទុតិយភូមិ ដាក់ដំណើរការសាលាជំនាន់ថ្មីនៅវិទ្យាល័យស៊ីសុវត្ថិ សាងសង់បង្គន់អនាម័យ កន្លែងលាងដៃ ប្រព័ន្ធទឹកស្អាត ប្រព័ន្ធទឹកស្អាត)
10. **វាយតម្លៃ គ្រឹះស្ថានឧត្តមសិក្សា** (កែលម្អនីតិវិធី និងដំណើរការទទួលគុណភាព អភិវឌ្ឍន៍ប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា ព្រាងឯកសារស្តីពី ការធានាគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធីសិក្សា)
11. **លើកកម្ពស់វិស័យកីឡា** (រៀបចំការប្រកួតកីឡាជាតិ ផ្សព្វផ្សាយការអនុវត្តសៀវភៅអប់រំកាយកម្រិតបឋមសិក្សា អនុម័តកម្មវិធីសិក្សាអប់រំកាយនៅមធ្យមសិក្សាបឋមភូមិ ជុសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡា បណ្តុះបណ្តាលធនធានមនុស្សថ្នាលកីឡាករក្រុមជម្រើសជាតិ)
12. **ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន** (ក្រុមប្រឹក្សាយុវជន និងកុមារដើម្បីជំរុញបង្កើតក្លឹបសិក្សាតាមសាលាវិទ្យាល័យ អនុវត្តកម្មវិធី បណ្តុះបណ្តាលជំនាញខ្លី ដំណើរការមជ្ឈមណ្ឌលព័ត៌មានទីផ្សារ អនុវត្តកម្មវិធីសហគ្រាសសហគមន៍ និងកម្មវិធីសហគ្រិនភាព)
13. **ការអប់រំបច្ចេកទេស** (អនុម័តក្របខណ្ឌកម្មវិធីអប់រំ បំណិនជីវិតថ្នាក់ទី៤ដល់ទី៩និងកម្មវិធីសិក្សាផ្នែកបំណិនជីវិត អនុម័តឯកសារការផ្តល់ប្រឹក្សាអាជីព និងព័ត៌មានសិក្សាជំនាញ កែលម្អកម្មវិធី សិក្សាឱ្យស្របនឹងតម្រូវការទីផ្សារការងារលើជំនាញមេកានិច

អគ្គសនី អេឡិចត្រូនិក ក្សេត្រសាស្ត្រ និងបសុវប្បកម្ម ពង្រីកវិទ្យាល័យចំណេះដឹង និងបច្ចេកទេសថ្មី៣)

14. **ការបង្កើតសាលារៀនជំនាន់ថ្មី** (អនុម័តគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី ដំណើរការសាលារៀនជំនាន់ថ្មីវិទ្យាល័យស៊ីសុវត្ថិ)
15. **រៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា** (អភិវឌ្ឍន៍ឯកសារទស្សនទានស្តីពីគន្លងអាជីពគ្រូ បង្រៀន រៀបចំសៀវភៅមគ្គុទេសន៍នាយកសាលា បំប៉ននាយកសាលាគ្រប់កម្រិតលើការងារអធិការកិច្ច គ្រប់គ្រង ដឹកនាំ និងប្រព័ន្ធអធិការកិច្ចអប់រំ រៀបចំប្រព័ន្ធសន្ទុំក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈនាយកសាលា)

***☞ក្រសួងបានអនុវត្តដាក់ចេញវិធានការកំណែទម្រង់១៥ចំណុច ដោយឈរលើមូលដ្ឋានសរសរស្តម្ភ៥គឺ៖***

1. **ការអនុវត្តសកម្មភាពគោលនយោបាយគ្រូបង្រៀន** (បណ្តុះបណ្តាលគ្រូមូលដ្ឋានទៅជាគ្រូ បង្រៀនកម្រិតឧត្តម កំពុងអភិវឌ្ឍន៍មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទៅជាវិទ្យាស្ថានគរុកោសល្យ អនុម័តស្តង់ត្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងស្តង់ដារនាយកសាលា កំពុងរៀបចំស្តង់ដារគ្រូ បង្រៀន និងគន្លងអាជីពគ្រូបង្រៀន)
2. **ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថាន** (អនុម័តនិងផ្សព្វផ្សាយក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំ បច្ចេកទេស ដាក់ដំណើរការសាលាជំនាន់ថ្មីវិទ្យាល័យស៊ីសុវត្ថិ អនុម័ត និងផ្សព្វផ្សាយឱ្យប្រើប្រាស់គោលការណ៍អនុវត្តលក្ខខណ្ឌអប្បរមាស្តីពី ទឹកស្អាត និងអនាម័យនៅ

តាមសាលារៀន អនុម័ត និងសេចក្ដីណែនាំស្ដីពីចលនាប្រឡងប្រណាំងសាលារៀនស្អាត សាងសង់អគារសិក្សាមត្តេយ្យសហគមន៍ សាលាមត្តេយ្យសិក្សាធនធាន ផ្ទះគ្រូ ស្នាក់នៅ និងអគារការិយាល័យអប់រំ ជុសជុលនិងកែលម្អមណ្ឌលប្រឡង )

3. **ការដាក់ឱ្យអនុវត្តអធិការកិច្ច** (អនុម័តបញ្ញត្តិជានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ រៀបចំឧបករណ៍សម្រាប់អធិការកិច្ច សៀវភៅជំនួយស្មារតីអធិការកិច្ច និងទម្រង់របាយការណ៍អធិការកិច្ច បណ្ដុះបណ្ដាលអធិការអប់រំ )
4. **ការពង្រឹងវង្វាយតម្លៃការសិក្សា** (បំប៉នមន្ត្រីជំនាញអំពីការងារតេសវង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ធ្វើតេសល្បឿនអំណាន ធ្វើតេសវង្វាយតម្លៃកម្រិតតំបន់ថ្នាក់បឋមសិក្សា និងរៀបចំ តេសវង្វាយតម្លៃកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ )
5. **កំណែទម្រង់ឧត្តមសិក្សា** (កែលម្អនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំ ព្រាងស្តង់ដារទទួលស្គាល់គុណភាពអប់រំកម្រិតបណ្ឌិត ពង្រឹង និងពង្រីកការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ត្រៀមបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រកម្ពុជាសម្រាប់ការស្រាវជ្រាវ និងការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត និងបង្កើតសាលាថ្នាក់បណ្ឌិត។)

សម្រាប់ការបកស្រាយបន្ថែមខាងក្រោម គឺជាបង្ហាញពីទស្សនវិស័យថ្មីសម្រាប់ការអប់រំសម្រាប់ឈានឆ្ពោះទៅមុន៖

### ❖ ទស្សនវិស័យអប់រំថ្មីសម្រាប់ការឈានឆ្ពោះទៅមុន

#### ការអភិវឌ្ឍ និងថែទាំកុមារតូច-Early Childhood Care and Development

1. បង្កើនការចុះឈ្មោះចូលរៀននៅគ្រប់ទិដ្ឋភាពទាំងអស់នៃកម្មវិធី ECE ចាប់ពី៦%ក្នុងឆ្នាំ១៩៩៩ ដល់៧៥%នៅឆ្នាំ២០១៥ ។
2. បង្កើនការចូលរួមរបស់កុមារក្នុងកម្មវិធីសុខភាពសហគមន៍ អាហារូបត្ថម្ភ ការអភិវឌ្ឍគុណភាព និងការអប់រំកុមារពីកំណើតរហូតដល់អាយុសិក្សា។
3. លើកកម្ពស់ការត្រៀមខ្លួនរបស់កុមារកម្ពុជាឱ្យចូលរៀននៅអាយុ៦ឆ្នាំ។
4. បង្កើតផែនការសកម្មភាពជាតិស្តីពីការថែទាំនិងការអភិវឌ្ឍកុមារនៅឆ្នាំ២០១៤
5. បង្កើតគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងដំណើរការមជ្ឈមណ្ឌលធនធានមត្តេយ្យក្នុងឆ្នាំ២០១៤ ។
6. ពិនិត្យឡើងវិញនូវកម្មវិធីសិក្សាសម្រាប់សាលាមត្តេយ្យរដ្ឋ មត្តេយ្យតាមសហគមន៍ និងកម្មវិធីតាមផ្ទះនៅឆ្នាំ២០១៤ ។
7. បង្កើតគោលការណ៍សម្រាប់ការបង្កើនក្របខណ្ឌគ្រូបង្គោលសម្រាប់គ្រូបង្រៀនមត្តេយ្យសិក្សា ឆ្នាំ២០១៤ ។
8. ពិនិត្យមើលតួនាទី និងដំណើរការនៃការអប់រំកុមារតូចនៅថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០១៤ ។
9. បង្កើតគោលនយោបាយអភិបាលកិច្ចល្អសម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សាឆ្នាំ២០១៤ ។
10. បង្កើតគោលការណ៍ណែនាំស្តីពីការគ្រប់គ្រង និងដំណើរការសាលាមត្តេយ្យសិក្សា និងកម្មវិធីតាមខ្នងផ្ទះនៅឆ្នាំ២០១៥ ។
11. បង្កើតសេចក្តីណែនាំសម្រាប់វិស័យឯកជន កសិដ្ឋាន និងសហគ្រាសធំៗ ដោយលើកទឹកចិត្តឱ្យពួកគេចូលរួមក្នុងគ្រប់ទម្រង់នៃការអប់រំកុមារតូចៗ។

- **សាកលនីយកម្មការអប់រំមូលដ្ឋាន**-Universalization of Basic Education

1. ធានាថារហូតដល់ឆ្នាំ២០៣០ កុមារទាំងអស់ជាពិសេសកុមារី និងក្មេងប្រុសដែលកំពុងរស់នៅក្នុងស្ថានភាពជួបការលំបាក និងកុមារនៃក្រុមជនជាតិដើមភាគតិចទទួលបានការអប់រំរយៈពេល ៩ឆ្នាំពេញប្រសិនបើការអប់រំមូលដ្ឋានដោយឥតគិតថ្លៃ នៅសាលាបឋមសិក្សាប្រកបដោយគុណភាព
2. បំបាត់គំលាតរវាងយេនឌ័រនៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សានៅឆ្នាំ២០១៥ ដោយផ្តោតការយកចិត្តទុកដាក់លើការធានាឱ្យក្មេងស្រីទទួលបានការអប់រំពេញលេញ និងស្មើភាពគ្នា និងសម្រេចបាននូវការអប់រំមូលដ្ឋានប្របកដោយ គុណភាព។
3. កែលម្អគុណភាពអប់រំ ជាពិសេសទាក់ទងនឹងអក្ខរកម្ម គណិតវិទ្យា និងជំនាញចាំបាច់សម្រាប់រកប្រាក់ចំណូល។
4. បង្កើនប្រសិទ្ធភាពផ្ទៃក្នុងនៃការអប់រំមូលដ្ឋានតាមរយៈការកាត់បន្ថយអត្រារៀនត្រួតថ្នាក់ នៅកម្រិតដំបូងនៃការអប់រំកម្រិតបឋមសិក្សា កាត់បន្ថយអត្រាបោះបង់ចោលការសិក្សានៅកម្រិតថ្នាក់បឋមសិក្សានិងការអប់រំកម្រិតមធ្យមបឋមភូមិ។
5. ពង្រីកវិសាលភាពនៃកម្មវិធីអាហារនៅតាមសាលារៀនបឋមសិក្សា។
6. លើកទឹកចិត្តដល់ការបង្រៀនភាសាបរទេសសម្រាប់សាលាបឋមសិក្សាចាប់ពីថ្នាក់ទី៤
7. បង្កើតក្របខ័ណ្ឌធានាគុណភាពអប់រំនៅកម្រិតសាលារៀន។
8. ធ្វើការសាកល្បងការបង្រៀននិងរៀនពេញមួយថ្ងៃ។
9. កែលម្អសំណង់ និងឧបករណ៍សម្ភារៈនៅតាមគ្រឹះស្ថានអប់រំដើម្បីបំពេញតាមស្តង់ដារគុណភាពសាលាបឋមសិក្សា

10. កែសម្រួលកម្មវិធីសិក្សាបឋម និងពិនិត្យឡើងវិញជាទៀងទាត់។
11. រៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយគ្រូបង្រៀន។

**ការសិក្សា និងបំណិនជីវិតសម្រាប់យុវជន និងមនុស្សពេញវ័យ-** Learning and Life Skills for Youths and Adults

1. ធានាថាតម្រូវការរៀនសូត្ររបស់យុវវ័យ និងមនុស្សពេញវ័យត្រូវបានបំពេញតាមរយៈការទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ប្រកបដោយសមធម៌(បំណិនជីវិត)។
2. លើកកម្ពស់គ្រប់ទិដ្ឋភាពទាំងអស់នៃគុណភាពអប់រំ និងធានានូវគុណភាពល្អនូវគ្រប់ទិដ្ឋភាពសម្រាប់ប្រជាពលរដ្ឋទាំងអស់ជាមួយនឹងលទ្ធផលសិក្សាដែលត្រូវបានគេទទួលស្គាល់ និងអាចវាស់វែងនិងទទួលបាន ជាពិសេសជំនាញអក្ខរកម្ម លេខនព្វ និងជំនាញជីវិត។
3. ផ្សព្វផ្សាយគោលនយោបាយស្តីពីបំណិនជីវិត និងការសិក្សារៀនសូត្រពេញមួយជីវិត។
4. បង្កើនការផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ក្រសួងពាក់ព័ន្ធនានា និងភាគីពាក់ព័ន្ធផ្សេងៗទៀត។
5. កសាងអគារសិក្សាឱ្យគ្រប់គ្រាន់ និងមជ្ឈមណ្ឌលសិក្សាសហគមន៍សម្រាប់តំបន់ដាច់ស្រយាល។
6. បង្កើនការផ្ទេរអំណាចដល់ទីក្រុង / ខេត្ត / ខណ្ឌ / ខណ្ឌដើម្បីគ្រប់គ្រងសេវាកម្មបំណិនជីវិត។
7. កែលម្អគោលការណ៍ណែនាំស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍

8. ជានាការសិក្សាគុណភាពសម្រាប់យុវវ័យ និងមនុស្សពេញវ័យ ដែលអាចឱ្យពួកគេទទួលបានបំណិនជីវិតជាក់លាក់ក្នុងការឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។
9. ផ្សព្វផ្សាយមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យមានដំណើរការពេញលេញ និងផ្តល់ការអប់រំពេញមួយជីវិត។
10. លើកកម្ពស់សិទ្ធិរបស់មនុស្សគ្រប់រូបដើម្បីទទួលបានការអប់រំបន្ត។

- **អក្ខរភាពមនុស្សពេញវ័យ**-Adult Literacy
  1. ពង្រឹង និងលើកកម្ពស់សកម្មភាព និងកម្មវិធីអប់រំក្រៅប្រព័ន្ធ។
  2. បង្កើនសកម្មភាពស្ម័គ្រចិត្តរបស់យុវជនទៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ និងអភិវឌ្ឍន៍សហគមន៍
  3. ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលឱ្យសមស្របទៅតាមក្រុមគោលដៅ។
  4. ពង្រឹងការអនុវត្តសេចក្តីណែនាំស្តីពីការអប់រំក្រៅប្រព័ន្ធ។
  5. ពង្រឹងការតាមដាន វាយតម្លៃ និងសមត្ថភាពដើម្បីអនុវត្តការងារអប់រំក្រៅប្រព័ន្ធប្រកបដោយប្រសិទ្ធភាព។
- **គំលាត និងសមភាពយែនឌ័រ**-Gender Parity and Equality
  1. លើកទឹកចិត្តសសិស្សស្រីចូលរួមក្នុងការអប់រំដោយស្មើភាពជាមួយសិស្សប្រុស
  2. កាត់បន្ថយគំលាតយែនឌ័ររវាងសិស្សស្រី និងសិស្សប្រុសតាមរយៈការគាំទ្រកម្មវិធី យែនឌ័រដោយភាគីពាក់ព័ន្ធនានា
  3. លើកទឹកចិត្តស្ត្រីក្នុងការចូលរួមសម្រេចចិត្ត
- **គុណភាពអប់រំ និងភាពពាក់ព័ន្ធ**-Quality Education and relevance

1. លើកកម្ពស់សកម្មភាពបង្រៀន និងរៀនតាមរយៈការអនុវត្តគោលនយោបាយកុមារមេត្រីនៅបឋមសិក្សា និងមធ្យមសិក្សា ដើម្បីធ្វើឱ្យប្រសើរឡើង និងអនុវត្តប្រកបដោយគុណភាពនៃ កម្មវិធីទប់ស្កាត់សិស្សបោះបង់ការសិក្សា
2. ធ្វើឱ្យប្រសើរឡើងនូវបរិស្ថានសិក្សាតាមរយៈការពិនិត្យឡើងវិញនូវវិធានបុគ្គលិកអប់រំនៅបឋមសិក្សា និងមធ្យមសិក្សា
3. វាយតម្លៃ លទ្ធផលសិក្សាសិស្សតាមរយៈការអនុវត្តតេស្តស្តង់ដារជាតិប្រកបដោយចីរភាព នៅថ្នាក់ទី៣ ទី៦ និងទី៨
4. បង្កើនការវិនិយោគលើវិស័យអប់រំ ដើម្បីកែលម្អការដាក់បញ្ចូលធាតុចូល (inputs) ប្រកបដោយគុណភាព និងអនុវត្តការវាយតម្លៃសាលារៀន (school self-assessment) ដែលជាយុទ្ធសាស្ត្រលើកកម្ពស់គុណភាពអប់រំ។ សាលារៀនអាចធ្វើការឆ្លុះបញ្ចាំងលើការប្រតិបត្តិរបស់ខ្លួនតាមរយៈរបាយការណ៍វាយតម្លៃសាលារៀនប្រចាំឆ្នាំដោយសាលារៀនផ្ទាល់
5. អភិវឌ្ឍន៍ប្រព័ន្ធតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល (result-based monitoring and evaluation system)
6. អនុវត្តគោលនយោបាយកម្មវិធីកុមារមេត្រីនីកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំ
7. លើកទឹកចិត្តគ្រូបង្រៀនបឋមសិក្សាដែលសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និងបទពិសោធច្រើន ឱ្យចូលរួមវគ្គបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដើម្បីក្លាយជាគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ
8. កសាងសមត្ថភាពនាយកសាលា និងប្រធានក្រុមបច្ចេកទេស ដើម្បីលើកកម្ពស់ការអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាព

ផែនការយុទ្ធសាស្ត្រអប់រំរបស់ក្រសួងអប់រំយុវជននិងកីឡាឆ្នាំ២០១៤-២០១៨ ដែលបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ បានផ្តល់នូវក្របខ័ណ្ឌបង្រួបបង្រួមដើម្បីដឹកនាំរដ្ឋាភិបាលទាំងអស់និងកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍ ។ ផែនការនេះកំណត់គោលបំណងរយៈពេលមធ្យមក្នុងវិស័យគោលនយោបាយចំនួន៣: *(១)ធានានូវលទ្ធភាពទទួលបានសមស្របសម្រាប់សេវាកម្មអប់រំទាំងអស់ (២) ការលើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធនៃការរៀនសូត្រ និង (៣)ធានានូវភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃបុគ្គលិកអប់រំនៅគ្រប់កម្រិត។* មកដល់ឆ្នាំ២០១៨ ដែលជាឆ្នាំចុងក្រោយនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ(២០១៤-២០១៨)វិស័យអប់រំ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ទោះបីជានៅជួបប្រទះបញ្ហាប្រឈមមួយចំនួនក៏ដោយ។ ដើម្បីស្វែងយល់បន្ថែមពីលទ្ធផលសម្រេចបាននៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨ យើងសូមបង្ហាញសូចនាករទាំងនោះជាបន្តបន្ទាប់ដូចខាងក្រោម។ ដំបូងយើងសូមលើកយកមកបង្ហាញពីទិដ្ឋភាពរួមនៃស្ថានភាពវិវត្តរបស់វិស័យអប់រំ ដែលដកស្រង់ចេញពី**របាយការណ៍សង្ខេបស្តីពីសមិទ្ធិផលសំខាន់ៗ**

**របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣-២០១៧**[៤៨]
បេញខែមេសា ឆ្នាំ២០១៨៖

ក្រសួងអប់រំ យុវជន និងកីឡា មានបុគ្គលិកអប់រំទូទាំងប្រទេសបានកើនឡើងដល់ ១១៩ ៣៦៨ នាក់ (ស្រី ៤៥ ,៥%) ក្នុងនោះថ្នាក់ជាតិ ៣ ២៣៧នាក់ (ស្រី ២៧,២៧%) និងថ្នាក់ក្រោមជាតិ ១១៦ ១៣១នាក់ (ស្រី ៤៦%) ក្នុងនោះក្របខណ្ឌគ្រូមត្តេយ្យ ៣ ៥៧៨នាក់ (ស្រី ៩៨,២៩%) គ្រូបឋមសិក្សា ៥៦ ៣២៥នាក់ (ស្រី៥០,២២%) គ្រូកម្រិតមូលដ្ឋាន ៤៣ ៤៧១នាក់ (ស្រី ៤១,០៨%) គ្រូកម្រិតឧត្តម ១៥ ៦៨២នាក់ (ស្រី ២៩,១៤%) និងក្របខណ្ឌគ្រូបច្ចេកទេស ២១៤នាក់ (ស្រី ២៤,៧៦%) អធិការបឋម ៥៧នាក់ (ស្រី ២១,០៥%) អធិការមធ្យម ៤១នាក់ (ស្រី ២៦,៨២%)។

ក្នុងឆ្នាំសិក្សា២០១៧-២០១៨ កុមារអាយុពី០ទៅ៥ឆ្នាំ បានទទួលសេវាអប់រំគ្រប់រូបភាពមាន ៤៣១ ៥១០នាក់ ស្រី ៥០,៦៣%។ កុមារអាយុ៥ឆ្នាំបានទទួលសេវាអប់រំតាមគ្រប់រូបភាព ២០១ ០៤៦ នាក់ ស្រី ៥០,៦៣%។ សិស្សបឋមសិក្សាសាធារណៈសរុប ២ ០២៨ ៦៩៤នាក់ ស្រី ៤៨,០៨%។ សិស្សមធ្យមសិក្សាបឋមភូមិសរុប ៦០៥ ១៧៣នាក់ ស្រី ៥២% និងសិស្សមធ្យមសិក្សាទុតិយភូមិសរុប ៣០៣ ៨៩៣នាក់ ស្រី ៥២,៣%។ សិស្សបច្ចេកទេស ១ ៤៦៩នាក់ ស្រី ៥១៣នាក់។

**ក-ការអប់រំចំណេះទូទៅ**

| មត្តេយ្យសិក្សា (រដ្ឋ) | | | | | |
|---|---|---|---|---|---|
| ឆ្នាំសិក្សា | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ | ២០១៧-២០១៨ |
| សាលា | ៣ ១៨៤ | ៣ ៤៤៣ | ៣ ៧០៦ | ៤ ០១៤ | ៤ ១៧៦ |
| សិស្ស (នាក់) | ១៥៧ ២៨៨ | ១៦៣ ៤៦៨ | ១៧៣ ៨៩៣ | ១៩០ ១៤៨ | ២០៥ ៤៩២ |
| គ្រូបង្រៀន(នាក់) | ៤ ៧១៧ | ៥ ០២៧ | ៤ ៧២២ | ៥ ០៨៤ | ៥ ៣៩៨ |
| មត្តេយ្យសិក្សា (ឯកជន) | | | | | |
| សាលា | ២២១ | ២៣៥ | ៣២១ | ៣៩៣ | ៤៥៦ |
| សិស្ស (នាក់) | ២៣ ៣៨៤ | ២៤ ០៤១ | ២៩ ៨៩០ | ៣៨ ៤៨៩ | ៤៧ ២៥១ |

ដំណើរវិវត្តន៍ និងបញ្ហាប្រឈមនានានៃការអប់រំនៅកម្ពុជា

| | | | | | |
|---|---|---|---|---|---|
| បឋមសិក្សា(រដ្ឋ) | | | | | |
| សាលា | ៦ ៩៩៣ | ៧ ០៥១ | ៧ ០៨៥ | ៧ ១៤៤ | ៧ ១៨៩ |
| សិស្ស (នាក់) | ២ ០៧៣ ៨១១ | ២ ០១២ ១៧៥ | ២ ០១០ ៦៧៣ | ២ ០២១ ៤៦០ | ២ ០២៨ ៦៩៤ |
| គ្រូបង្រៀន(នាក់) | ៥៥ ៩៥៨ | ៥៥ ៧៨៨ | ៥៦ ៤២១ | ៥៧ ៨៤៤ | ៥៧ ៩១៥ |
| បឋមសិក្សា(ឯកជន) | | | | | |
| សាលា | ២៤៣ | ២៩៧ | ៣៥៧ | ៤១៧ | ៤៣២ |
| សិស្ស (នាក់) | ៥៤ ៨២២ | ៧៣ ៧៩៤ | ៩៥ ២៣០ | ៨៩ ៥៧០ | ១១១ ៧៩៨ |
| មធ្យមសិក្សាបឋមភូមិ(រដ្ឋ) | | | | | |
| អនុវិទ្យាល័យ | ១ ២៤៤ | ១ ២៤៩ | ១ ២៥១ | ១ ៦៩៨ | ១ ៧១៦ |
| សិស្ស (នាក់) | ៥៣៨ ៦២៦ | ៥៤៦ ៨៦៤ | ៥៥៨ ៦២១ | ៥៨៥ ៩៥៥ | ៦០៥ ១៧៣ |
| គ្រូបង្រៀន(នាក់) | ៣២ ៦១៦ | ៣២ ៥២៥ | ៣៣ ១៦៤ | ៣៣ ៧៦៤ | ៣៣ ១៨១ |
| មធ្យមសិក្សាបឋមភូមិ(ឯកជន) | | | | | |
| សាលា | ៣៥ | ៤៦ | ៤៣ | N/A | ១៦៨ |
| សិស្ស (នាក់) | ១ ៨២៨ | ៣ ៦១៥ | ២៨ ២៣៥ | N/A | ២៥ ៩២៨ |
| លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | | | | |
| បេក្ខជនមកប្រឡង (នាក់) | ១១២ ៥៨១ | ១១៧ ១៤២ | ១២៣ ៩៤២ | ១២៥ ៩៥៥ | ១៤១ ៩២៨ |
| បេក្ខជនប្រឡងជាប់ (នាក់) | ១០៤ ៧០៨ | ១០៩ ៦៤៩ | ១១៦ ០០៤ | ១១៨ ០៣០ | ១៣៤ ១១៩ |
| មធ្យមសិក្សាទុតិយភូមិ(រដ្ឋ) | | | | | |
| វិទ្យាល័យ | ៤៤៤ | ៤៥៥ | ៤៦៣ | ៤៨៦ | ៥១១ |
| សិស្ស (នាក់) | ២៦៦ ២៩៣ | ២៦២ ០៧២ | ២៦៦ ៤៤៩ | ២៧៩ ៤៧៩ | ៣០៣ ៨៩៣ |
| គ្រូបង្រៀន(នាក់) | ១៣ ៣៣០ | ១៤ ០៥៥ | ១៤ ៤៣៨ | ១៤ ៤៥៧ | ១៥ ១៧៦ |
| មធ្យមសិក្សាទុតិយភូមិ(ឯកជន) | | | | | |
| សាលា | ៨៧ | ៨៧ | ១០៨ | N/A | ១២២ |
| សិស្ស (នាក់) | ២៧ ៦៤៤ | ២៦ ៩៤០ | ៨ ៦៩១ | N/A | ១៨ ១០៧ |

| ឆ្នាំសិក្សា | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ |
|---|---|---|---|---|
| ឧត្តមសិក្សាឯកជន | | | | |
| សាលា | ៦៧ | ៧២ | ៧៣ | ៧៣ |
| សិស្ស (នាក់) | ១៥៥ ៥៦១ | ១៤៦ ៥០១ | ១៤០ ៨៨១ | ១៤០ ៧៩១ |
| ឧត្តមសិក្សា(រដ្ឋ និងឯកជន) | | | | |
| គ្រឹះស្ថានរដ្ឋ (១) | ៤៣ | ៤៦ | ៤៨ | ៤៨ |
| គ្រឹះស្ថានឯកជន(២) | ៦៧ | ៧២ | ៧៣ | ៧៣ |
| សរុប ១+២ | ១១០ | ១១៨ | ១២១ | ១២១ |
| និស្សិតថ្នាក់បរិញ្ញាបត្ររង(នាក់) | ១៥ ៦៣៥ | ២៤ ៩៧០ | ២៣ ៧៤៦ | ២០ ៥៧០ |
| និស្សិតថ្នាក់បរិញ្ញាបត្រ (នាក់) | ២១៤ ២៦៦ | ១៨២ ៩៨៧ | ១៧៤ ១៤២ | ១៦៥ ៣៥៩ |
| និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់(នាក់) | ១៨ ០១០ | ១៨ ២៥៣ | ១៨ ៧២៣ | ២០ ២៧២ |
| បណ្ឌិត (នាក់) | ១ ១៨១ | ១ ១៧៥ | ១ ២២៩ | ១ ២២២ |

នៅឆ្នាំ២០១៧ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររងសរុប ២០ ៥៧០នាក់ (ស្រី ៥១,០៦%) ក្នុងនោះនិស្សិតអាហារូបករណ៍ ១ ៧២៤នាក់ (ស្រី ៤៦,២២%)។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រសរុប ១៦៥ ៣៥៩នាក់ (ស្រី ៤៧,៨៧%)។ និស្សិតកំពុងសិក្សាលើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា(STEAM[1]) សរុប ៤៤ ៣៦៦នាក់ (ស្រី ២៩,៨%)។ និស្សិតអាហារូបករណ៍សរុប ២៤ ០០៩នាក់ (ស្រី ៤៦,៨%)។ និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រសរុប ២១ ៤៩៤នាក់ (ស្រី ២១,២៤%) ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ២០ ២៧២នាក់ (ស្រី ២២,២%) និងថ្នាក់បណ្ឌិត ១ ២២២នាក់ (ស្រី ៥,១៦%)។

### ខ-គ្រឹះស្ថានសិក្សាឯកជនភាសាខ្មែរ និងបរទេស

| គ្រឹះស្ថានសិក្សាឯកជនភាសាខ្មែរ និងបរទេស (ឆ្នាំសិក្សា ២០១៥-២០១៦) | | | | | | | |
|---|---|---|---|---|---|---|---|
| ប្រភេទសាលា/ភាសា | ខ្មែរ | ចិន | ម៉ូស្លីម | អង់គ្លេស | វៀតណាម | ផ្សេងទៀត | សរុប |
| សាលាមត្តេយ្យ | ២០៤ | ២១ | ២ | ៩២ | ១ | ១ | ៣២១ |
| សាលាបឋមសិក្សា | ២៤៤ | ៣១ | ៩ | ៧២ | ១ | ០ | ៣៥៧ |
| អនុវិទ្យាល័យ | ២៧ | ៨ | ១ | ៦ | ០ | ១ | ៤៣ |
| វិទ្យាល័យ | ៨៧ | ២ | ៥ | ១៤ | ០ | ០ | ១០៨ |

## ការបកស្រាយសង្ខេបពីលទ្ធផលសម្រេចតាមកម្រិតសិក្សានីមួយៗ

❖ **ការអប់រំកុមារតូច-Early Childhood Education (ECE)**

ECE ត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជាជាមធ្យោបាយដ៏សំខាន់ក្នុងការលើកកម្ពស់ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា និងជាមធ្យោបាយមួយសម្រាប់កសាងគ្រឹះនៃការអប់រំដែលនឹងជួយបង្កើននូវលទ្ធផលសិក្សារបស់កុមារ កាត់បន្ថយអត្រារៀនត្រួតថ្នាក់ និងកាត់បន្ថយការបោះបង់ការសិក្សា[៥០]។ ការរីកចម្រើនក្នុង ECE ត្រូវបានបញ្ជាក់ដោយភាគរយកុមារអាយុ៥ឆ្នាំ ចូលរួមក្នុងការអប់រំ កុមារតូចគ្រប់រូបភាពបានកើនឡើង ដែលមានត្រឹមតែ៣៥% នៅឆ្នាំសិក្សា២០០៨-២០០៩ ឈានដល់៦៤,០៧% នៅឆ្នាំសិក្សា២០១៤-២០១៥ និងកើនដល់ ៦៨,៥០% នៅឆ្នាំសិក្សា២០១៧-២០១៨[៥១]។ យ៉ាងណាក៏ដោយ កុមារ

ដែលមានអាយុ៣-៥ ឆ្នាំចូលរួមក្នុងការអប់រំកុមារតូចនៅទាបនៅឡើយ ជាពិសេសចំពោះកុមារនៅតំបន់ដាច់ស្រយាល កុមារជនជាតិភាគតិចកុមារពិការ និងកុមារមកពីគ្រួសារក្រីក្រ[៥២]។ ដើម្បីបង្កើនការចូលរួមក្នុងការអប់រំកុមារតូចនេះ ទាមទារការគាំទ្របន្ថែមទៀត ផ្នែកបទដ្ឋានគតិយុត្តិ បង្កើនការផ្តល់មូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា និងលើកកម្ពស់សមត្ថភាពសម្រាប់ការគ្រប់គ្រងសេវាកម្មECE និងបណ្តុះបណ្តាលគ្រូបង្រៀន (៥៣)

- **លទ្ធភាពទទួលបានការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ-Access to Education at Primary and Lower Secondary Schools**

ការចុះឈ្មោះចូលរៀន មានវត្តមានទៀងទាត់ និងការបញ្ចប់នៅសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតែជាបញ្ហាប្រឈម។ ឧទាហរណ៍ អត្រាពិតនៃការចូលរៀនថ្មី ឆ្នាំ២០១៤-២០១៥ សម្រាប់ក្មេងស្រីនៅក្នុងសាលាបឋមសិក្សារដ្ឋ និងឯកជនមានចំនួន៩៥,៤% ហើយនៅឆ្នាំ ២០១៦-២០១៧ ធ្លាក់ចុះមកនៅ៩៤,0% តែនៅឆ្នាំ២០១៧-២០១៨ មានការកើនឡើងវិញ៩៥,១% ដែលស្ថិតិនេះមិនមានការប្រែប្រួលច្រើនទេ។ លើសពីនេះទៅទៀត អត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាមាននិន្នាការថយចុះ បើយើងប្រៀបធៀបពីឆ្នាំ២០១៤ ដែលមាន៨៤% ហើយនៅឆ្នាំ២០១៥ បានថយចុះមកនៅត្រឹម៨០,៦២% ព្រមទាំងបន្តធ្លាក់ចុះមក ៧៩,៩%នៅឆ្នាំ២០១៦ និងធ្លាក់ថែមទៀត៧៩,១%ឆ្នាំ២០១៧។ ការព្យាករណ៍បង្ហាញថា និន្នាការធ្លាក់ចុះនេះនឹងបន្ត បើសិនជាលទ្ធភាពទទួលបានការអប់រំ និងគុណភាពអប់រំមិនត្រូវបានដោះស្រាយ។ ទោះបីជាកុមារទទួលបានការអប់រំ ៩ឆ្នាំ ដោយឥតគិតថ្លៃ តែ បើតាមការស្រាវជ្រាវក្នុងឆ្នាំ ២០១២ បានរកឃើញថាសិស្ស៥៣% និងអ្នកឆ្លើយសំណួរ៦៧% ជាឪពុកម្តាយសិស្សបាននិយាយថា ពួកគេបានចំណាយលើមុខវិជ្ជាដែលពួក

គេរំពឹងទុកថាវាជាការទទួលខុសត្រូវរបស់សាលារៀន និងក្រសួងអយក [៥៤]។ ការចំណាយត្រូវបានប៉ាន់ប្រមាណថាមានប្រហែល១១៩ ដុល្លារក្នុងមួយឆ្នាំ សម្រាប់សិស្សម្នាក់ ដែលជាកត្តាជំរុញសម្រាប់ការបោះបង់ការសិក្សា ជាពិសេសសម្រាប់គ្រួសារក្រីក្រ និងគ្រួសារដែលមានកូនច្រើនក្នុងសាលារៀន។ និន្នាការចំណាយប្រាក់នេះ ហាក់មិនទាន់មានដំណោះស្រាយអ្វីមួយគួរឱ្យកត់សម្គាល់ទេរហូតមកដល់ពេលនេះ។

❖ **គុណភាពអប់រំ-Quality of Education**

អត្រាពិតនៃការចុះឈ្មោះ និងអត្រានៃការបញ្ចប់ការសិក្សាកម្រិតបឋមសិក្សាខ្ពស់ មិនមានលទ្ធផលល្អក្នុងការសិក្សារៀនសូត្រសម្រាប់កុមារ ដែលបង្ហាញពីបញ្ហាទាក់ទងនឹងគុណភាពអប់រំដែលត្រូវបានផ្តល់ឱ្យ។ គុណភាពនៃការអប់រំនៅថ្នាក់បឋមសិក្សានៅកម្ពុជាត្រូវបានគេដាក់ពិន្ទុ២,៩ ក្នុងចំណោម៧ពិន្ទុដោយវេទិកាសេដ្ឋកិច្ចពិភពលោក (ចំណាត់ថ្នាក់ទី១១៤ ក្នុងចំណោម១៤០ ប្រទេស)[៥៥] នេះជាភស្តុតាងបញ្ជាក់បន្ថែមដោយការរកឃើញនាពេលថ្មីៗនេះថា មានតែកុមារ៣០% ដែលមានអាយុពី៣-៥ ឆ្នាំប៉ុណ្ណោះកំពុងស្ថិតចូលរួមក្នុងដំណើរការអភិវឌ្ឍអក្សរ និងលេខ។ ការវាយតម្លៃសមត្ថភាពអាននៅថ្នាក់ដំបូង (Early Grade Reading Assessment-EGRA) ក្នុងឆ្នាំ២០១០ សិស្សថ្នាក់ទី១ ចំនួនពីរភាគបី មិនអាចអានពាក្យបាន ហើយសិស្សថ្នាក់ទី៣ ស្ទើរតែពាក់កណ្តាលស្រដៀងគ្នានេះដែរមិនអាចអានពាក្យបាន[៥៦]។ ការវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៦ នៅឆ្នាំ២០១៥ បង្ហាញថាសិស្សានុសិស្សមានចំនួន៤៥,៧% បានជាប់ការធ្វើតេស្តវាយតម្លៃមុខវិជ្ជាភាសាខ្មែរ និង៤៣,៤%មុខវិជ្ជាគណិតវិទ្យា។ ពិន្ទុនៃការវាយតម្លៃ អក្ខរភាពទាប អាចត្រូវបានចាត់ទុកថាជាផ្នែកមួយបណ្តាលមកពីកង្វះលទ្ធភាពប្រើប្រាស់ធនធានសម្រាប់អាន ជាពិសេសតំបន់ជនបទនៅតែក្រីក្រ។ ការសិក្សាថ្មីមួយរបស់អង្គការទស្សនៈពិភពលោកបានរកឃើញថាមានតែ២៥% នៃសាលារៀនមានសៀវភៅគ្រប់គ្រាន់ និងធនធាន

អានតាមស្តង់ដារផ្លូវការរបស់ក្រសួងអប់រំយុវជននិងកីឡាដែលត្រូវបានបង្កើតនៅឆ្នាំ២០១១[៥៧]។ បើប្រៀបធៀបទៅនឹងប្រទេសជិតខាងរបស់ខ្លួន ប្រទេសកម្ពុជាមានអត្រាផលធៀបសិស្សនិងគ្រូខ្ពស់បំផុតនៅក្នុងអាស៊ានដែលមាន៤៧:១ បើប្រៀបធៀបទៅនឹងប្រទេសឡាវគឺ២៦: ១ វៀតណាមនៅ១៩:១ និងមីយ៉ាន់ម៉ានៅ២៨:១ ដែលអាចប៉ះពាល់អវិជ្ជមានដល់គុណភាពនៃការអប់រំ[៥៨]។ លើសពីនេះទៀត គ្រូបង្រៀនដែលមានស្រាប់តែ៥៨% ប៉ុណ្ណោះដែលបង្រៀននៅបឋមសិក្សាបានបញ្ចប់ការសិក្សាថ្នាក់ទី១២ ដែលរឹតត្បិតសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយភារកិច្ចប្រកបដោយវិជ្ជាជីវៈ និងកែលម្អការអនុវត្តគរុកោសល្យ[៥៩]។ម៉ោងបង្រៀនផ្លូវការនៅកម្ពុជាមានចំនួន៦៨៤-៧៦០ ម៉ោងនៅក្នុងឆ្នាំសិក្សា[៦០] ដែលតួលេខនេះមានចំនួនតិចជាងកម្រិត អន្តរជាតិដែលមានចាប់ពី៨៥០-១០០០ ម៉ោងក្នុងមួយឆ្នាំ[៦១]។ គុណភាពអប់រំនៅកម្ពុជាត្រូវបានរងផលប៉ះពាល់ដោយការបាត់បង់ម៉ោងបង្រៀនក្រៅផ្លូវការ: ជាមធ្យមក្នុងឆ្នាំ២០១៣ ម៉ោងបង្រៀន២៧%( ៥០,៥ថ្ងៃ )បានបាត់បង់ដោយសារតែថ្ងៃបុណ្យជាតិ បន្ថែមដោយអវត្តមានគ្រូបង្រៀន និងវគ្គបង្រៀនខ្លីៗ។ និន្នាការបាត់បង់ម៉ោងនេះនៅតែបន្តរហូតមកដល់បច្ចុប្បន្ន។

- **គម្លាតនៃការអនុវត្តគោលនយោបាយអប់រំ-Gaps in Education Policy Implementation**

ប្រទេសកម្ពុជាមានក្របខ័ណ្ឌគោលនយោបាយយ៉ាងទូលំទូលាយសម្រាប់ការអប់រំកុមារ។ ទោះយ៉ាងណាក៏ដោយមានគម្លាតគួរឱ្យកត់សម្គាល់ផងដែររវាងគោលនយោបាយ និងការអនុវត្ត។ ឧទាហរណ៍ក្នុងគោលនយោបាយសាលាកុមារមេត្រី(CFS)ឆ្នាំ២០០៧ នៅតែមិនទាន់ត្រូវបានអនុវត្តយ៉ាងពេញលេញនៅឡើយ។ ធនធានមូលដ្ឋានដែលលើកកម្ពស់ការចូលសាលារៀនដូចជាៈ បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ និងទឹកស្អាតមិនត្រូវ

បានលើកកម្ពស់ឱ្យបានល្អ ប្រសើរនៅឡើយទេ[៦២]។ បច្ចុប្បន្ននេះ សាលារៀនស្ទើរតែ៥០% ខ្វះការផ្គត់ផ្គង់ទឹកនិង៣០% ខ្វះបង្គន់អនាម័យ។ អវត្តមាននៃគ្រឿងបរិក្ខារបែបនេះនាំឱ្យមានការបោះបង់ការសិក្សា និងអវត្តមានជាពិសេសសម្រាប់ក្មេងស្រី។ លើសពីនេះទៀត ការស្រាវជ្រាវថ្មីៗបានបង្ហាញថាសាលារៀនមិនមែនជាកន្លែងដែលមានសុវត្ថិភាពសម្រាប់កុមារទេ។ សិស្ស៧៣% (ក្មេងប្រុស៧៦% និងក្មេងស្រី៧០%) រាយការណ៍ថាមានអំពើហឹង្សាយ៉ាងហោចណាស់មួយនៅក្នុងសាលារៀន។ សិស្សពាក់កណ្តាល ទាំងក្មេងប្រុស និងក្មេងស្រីបានវាយតម្លៃថា សាលារៀនរបស់ពួកគេ (រួមទាំងបន្ទប់រៀន និងទីធ្លាលេង) មិនមានសុវត្ថិភាព ឬមិនមានសុវត្ថិភាព[៦៣]។ ជាចុងក្រោយ គោលនយោបាយអប់រំសម្រាប់កុមារពិការត្រូវបានអនុម័តតាំងពីឆ្នាំ២០០៨ មក តែទោះជាយ៉ាងណាក៏ដោយកុមារពិការពិសេសកុមារពិការធ្ងន់ធ្ងរ និងពិការផ្នែកបញ្ញានៅតែមានលទ្ធភាពទទួលបានការអប់រំ។ នេះដោយសារតែកង្វះខាតសមត្ថភាពគ្រូបង្រៀន ធនធានសម្ភារៈ ឬសម្ភារៈសមស្រប ឬអាគារដែលអាចចូលដំណើរការបាន[៦៤] គេប៉ាន់ប្រមាណថាមានកុមារ ២៥% នៅក្នុងប្រទេសកម្ពុជាដែលមានពិការភាពមិនដែលទទួលបានការអប់រំណាមួយឡើយ[៦៥]។

### ❖ ការបណ្តុះបណ្តាលវិជ្ជាជីវៈ (TVET)

សម្រាប់ផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ TVET សម្រាប់ឆ្នាំ ២០១៤-២០១៨ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីអភិវឌ្ឍធនធានមនុស្សដើម្បីជានានូវការប្រកួតប្រជែងនៅក្នុងទីផ្សារការងារក្នុងស្រុក និងក្នុងតំបន់។ សេចក្តីព្រាងផែនការនេះកំណត់គោលដៅរបស់អនុក្រឹត្យរយៈពេលមធ្យមរបស់រដ្ឋាភិបាលដូចជា (១)លទ្ធភាពទទួលបានសមភាពនៃ

TVET (២) បង្កើនគុណភាព និងភាពពាក់ព័ន្ធនៃ TVET និង (៣) ពង្រឹងអភិបាលកិច្ចនិងការគ្រប់គ្រង TVET ។

## 6) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣

### ចក្ខុវិស័យវិស័យអប់រំ Education Vision

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាអប់រំពលរដ្ឋឱ្យមានលក្ខណសម្បត្តិពេញលេញប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិ ដើម្បីអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជានៅក្នុងតំបន់។

### គោលនយោបាយអប់រំ Education policy

១. ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត។

២. ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

### យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១។

**☛ផ្តល់អាទិភាពលើ**

១-ការយកចិត្តទុកដាក់លើគ្រូបង្រៀន

**☛ផ្តល់អាទិភាពលើ**

១-ការយកចិត្តទុកដាក់លើគ្រូបង្រៀន

២-ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត

៣-ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន

៤-ជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ

៥-អប់រំបំណិនឱ្យស្របតាមទីផ្សារការងារ

៦-ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគ្រប់ជ្រុងជ្រោយ

៧-ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣

## IV- សាកល្បងសិក្សាពីបញ្ហាប្រឈមនៃការអប់រំ

មុននឹងធ្វើការបកស្រាយបង្ហាញ យើងជឿជាក់ថានឹងមានប្រតិកម្មតបជាក់ជាមិនខាន ពិសេសចង់ដឹងថា តើអ្នកសំអាងលើអ្វីបានជាសរសេរបែបនេះ? តើមានការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រច្បាស់លាស់ដែរឬទេ? ជាការពិត យើងជឿជាក់ថា អត្ថបទខ្លឹមសារដែលមានទម្ងន់ អាចយកជាការបានទាល់តែរៀបចំឡើងដោយឆ្លងការស្រាវជ្រាវបែបវិទ្យាសាស្ត្រត្រឹមត្រូវ។ យើងសូមបញ្ជាក់ថា នេះជាកាសិក្សាសាកល្បងប៉ុណ្ណោះព្រោះយើងមិនមានធនធានគ្រប់គ្រាន់ក្នុងស្រាវជ្រាវស្វែងរកភស្តុតាងបែបវិទ្យាសាស្ត្ររឹងមាំឡើយ។ វាគ្រាន់តែជាសម្មតិកម្ម លើកឡើងតាមរយៈការសិក្សារៀនសូត្រ

និងបទពិសោធមួយចំនួនពីការប្រឡូកនឹងការងារក្នុងវិស័យអប់រំជាក់ស្តែងរយៈពេលជិតម្ភៃឆ្នាំកន្លងមកនេះ។ បញ្ហាប្រឈមមួយចំនួន វាមានភាពស៊ីជម្រៅពេក ការសិក្សាស្រាវជ្រាវធម្មតាពិតជាពិបាករកឃើញចម្លើយណាស់ ពេលខ្លះវាពោរពេញទៅដោយភាពលម្អៀងដែលពិបាកធ្វើសេចក្តីសន្និដ្ឋាន ។

គោលបំណងរបស់យើងក្នុងការចែករំលែកព័ត៌មាន ចំណេះដឹង និងតថភាពមួយចំនួនពេលនេះ គឺដើម្បីទុកជាគតិបណ្ឌិតសម្រាប់ត្រិះរិះពិចារណា សិក្សារៀនសូត្រ និងស្វែងយល់ប៉ុណ្ណោះ ពោលគឺសរសេរជាលក្ខណៈទូទៅ មិនសំដៅដោយផ្ទាល់ដល់ស្ថាប័នណាមួយជាក់លាក់ឡើយ។ យើងសង្ឃឹមថា អត្ថបទនេះ នឹងចូលរួមចំណែកបង្កើនចំណេះដឹងដល់អ្នកអាន-អ្នកសិក្សាបន្ថែមទៀត។

## 1) *បញ្ហាទំនាស់ផលប្រយោជន៍ និងបញ្ហាបក្សពួកនិយម*

ឥទ្ធិពលនៃបក្សពួកនិយម នៅតែជាឧបសគ្គដ៏ចម្បងក្នុងការអភិវឌ្ឍន៍វិស័យអប់រំ។ បញ្ហានេះរាប់ចាប់តាំងពីនៅក្នុងស្ថាប័នកំពូលរហូតដល់កម្រិតសាលារៀន។ បក្សពួកនៅក្នុងស្ថាប័ននេះអាចត្រូវបានបង្កើតឡើង ក្នុងចេតនា និងគោលបំណងការពារផលប្រយោជន៍របស់បក្សពួក ឬក្រុមខ្លួន ដែលវាបង្កើតឱ្យមាននាំងឧបសគ្គសម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិកក្រោមឱវាទទាំងអស់បំពេញការងារប្រកបដោយប្រសិទ្ធភាព និងគុណភាព។ ទិដ្ឋភាពនៅកន្លែងធ្វើការដែលមានជំងឺបក្សពួកនិយម យើងនឹងមើលឃើញនូវសកម្មភាពមួយចំនួនដូចជាការបែងចែក និងចាត់ចែងការងារ ភារកិច្ច និងការទទួលខុសត្រូវមិនត្រឹមត្រូវដោយមានភាពលម្អៀងទៅលើបក្សពួករៀងៗខ្លួន និងភាពមិនទុកចិត្តគ្នា។ សកម្មភាពនេះ អាចបណ្តាលឱ្យបុគ្គលិកខ្លះមានការងារធ្វើច្រើន និងទទួលបានផលប្រយោជន៍ច្រើន

ចំណែកឯខ្លះទៀតមានការងារ ឬបេសកកម្មតិច ព្រមទាំងទទួលបានផល ប្រយោជន៍តិចផងដែរ។ ស្ថានភាពនេះ វារុញឱ្យបុគ្គលិកខ្លះសកម្ម ហើយខ្លះ ទៀតមិនសូវសកម្ម។ ទោះបី បុគ្គលិកមួយចំនួនមានកម្រិតអប់រំខ្ពស់ក៏ ដោយ បើស្ថិតក្នុងស្ថានភាព ឬបរិយាកាសការងារបែបនេះដដែលៗ នឹងធ្វើ ឱ្យពួកគេក្លាយជាមនុស្សហៃអើ តែស្ករៗតាមគេ បាត់បង់មនសិការការងារ និងមិនបញ្ចេញសមត្ថភាពខ្លួនឱ្យអស់ពីសក្តានុពលដែលខ្លួនមានឡើយ។ ចង្កោមនៃឥទ្ធិពលបក្សពួកនិយមនេះ បង្កើតឱ្យមានវប្បធម៌នៃការចាំមើល បំណាំគ្នា ចាំជាន់ពន្លិច ប៉ែងជើងគ្នា ច្រណែនគ្នា និងរិះគន់វាយប្រហារគ្នា ក្រោយខ្នងជាដើម ហើយសកម្មភាពនៃការបំពេញការងារហាក់ធ្វើការដើម្បី ការពារផលប្រយោជន៍ និងកសាងឥទ្ធិពលក្រុមខ្លួន ឬបក្សពួកខ្លួនប៉ុណ្ណោះ។ គ្មានឡើយទិសដៅរួម វប្បធម៌ធ្វើការរួមគ្នា និងវប្បធម៌លើកទឹកចិត្ត នៅក្នុងស្ថាប័នដើម្បីភាពរីកចម្រើននោះ។ បុគ្គលិកអប់រំទាំងឡាយណា ដែលជួបប្រទះបរិយាកាសធ្វើការងារបែបនេះនឹងបាក់ទឹកចិត្ត មិនមានឆន្ទៈ បំពេញការងារមុតមាំ ទម្លាក់ការងារចោល ឬបណ្តែតបណ្តោយតាមដំណើរ ហើយពេលខ្លះងាកទៅចាប់យកឱកាសរកការងារបន្ថែមផ្សេងទៀតដើម្បី បង្កើនជីវភាពរស់នៅ ពោលគឺពោរពេញទៅដោយទិដ្ឋភាពអាត្មានិយម និង អត្តទត្ថភាព។ ភាពច្រណែនចំពោះផលប្រយោជន៍ដែលបុគ្គលម្នាក់ៗទទួល បាន ភាពមិនស្មើភាព និងមិនមានសមធម៌ក្នុងការបែងចែកការងារ និង ភាគលាភ នាំឱ្យសកម្មភាពនានានៃការបំពេញការងារផ្តេកផ្តួលទាំងស្រុង ទៅលើផលប្រយោជន៍ដែលមាន ឬផ្តល់ឱ្យប៉ុណ្ណោះ។ នេះមានន័យថា អ្នក ទទួលប្រយោជន៍ធ្វើកិច្ចការ ចំណែកឯអ្នកមិនសូវទទួលបានផលប្រយោជន៍មិនសូវធ្វើកិច្ចការអ្វី ហើយស្ថានភាពនេះយូរៗទៅ វាក្លាយទៅជាវប្បធម៌ នៃភាពខ្ជិលនៅក្នុងស្ថាប័ន ពោលគឺនៅពេលមានការងារច្រើនបន្តិច ពួក គាត់ចាប់ផ្តើមធុញទ្រាន់ និងត្អូញត្អែរ ហើយបើមិនបានទទួលផលប្រយោជន៍អ្វីបន្ថែមក្រៅលើប្រាក់ខែខ្លួនមានស្រាប់ទេ ពួកគេមិនយកចិត្តទុកដាក់

ឬមិនចាប់អារម្មណ៍ធ្វើការងារទាំងនោះតែម្តង។ ការបំពេញការងារបែបនេះ គឺគ្មានវិជ្ជាជីវៈ(Professional) អ្វីបន្តិចសោះឡើយ បើយើងនិយាយពីស្តង់ដារការងារ។ ទិដ្ឋភាពខ្លះ វាបង្កើតឱ្យមានបរិយាកាសការងារបែបផ្លែល្វា បានតែល្អមើលប៉ុណ្ណោះ ឬបែបសង្កតភាពសម្បកក្រៅចំពោះមុខផលប្រយោជន៍រៀងៗខ្លួន ពោលគឺមើលពីក្រៅស្ងប់ស្ងាត់តែខាងក្នុងពោរពេញទៅដោយភាពច្រណែន និងទំនាស់ដណ្តើមផលប្រយោជន៍ ព្រមទាំងមិនមានគតិបណ្ឌិតថ្មីក្នុងការដោះស្រាយបញ្ហាប្រឈម និងអភិវឌ្ឍន៍ស្ថាប័នក្នុងទិសដៅរួមតែមួយឡើយ។

ភាពមិនច្បាស់លាស់ និងប្រាកដប្រជាក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខ វាពិតជាបង្កការលំបាកច្រើនណាស់ក្នុងជំនះឧបសគ្គទាំងនេះដើម្បីធ្វើឱ្យវិស័យអប់រំមានការរីកចម្រើនទៅមុខ។ ទោះបីបញ្ហាប្រឈមជាច្រើនត្រូវបានរកឃើញហើយក៏ដោយ តែការដោះស្រាយនៅមានកម្រិតនៅឡើយ។ បញ្ហាខ្លះត្រូវបានទុកចោលមិនដោះស្រាយក៏មានដោយសារតែវាមានភាពស្មុគស្មាញពេកដែលពិបាកក្នុងការដោះស្រាយ។ បញ្ហាខ្លះអាចជះផលប៉ះពាល់ច្រើន ឬជះឥទ្ធិពលមិនល្អដល់ផលប្រយោជន៍ ឬការគាំទ្ររបស់ក្រុម ឬបក្សពួកខ្លួន។ ភាពមិនហ៊ានជំនះទៅមុខនេះ គឺដោយសារខ្លាចបាត់បង់សម្លេងគាំទ្រ និងស្ថេរភាពស្ថាប័ន។ បញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលពិបាកដោះស្រាយមានដូចជា បញ្ហាលើសគ្រូបង្រៀនច្រើននៅតំបន់ទីក្រុង និងបុគ្គលិកនៅតាមអង្គភាពមួយចំនួន បញ្ហាអសកម្មរបស់បុគ្គលិក បញ្ហាការប្រមូលលុយពីសិស្សក្នុងម៉ោងសិក្សារដ្ឋ ការតែងតាំងតួនាទី និងបញ្ហាគ្រូបង្រៀនធ្វើការងារក្រៅបន្ថែម...ជាដើម។ ភាពមិនដាច់ស្រាច់ និងប្រាកដប្រជាក្នុងការដោះស្រាយបញ្ហា ព្រមទាំងបញ្ហាបក្សពួកនិយមដូចការបកស្រាយខាងលើ ប៉ះពាល់ជាខ្លាំងដល់គោលនយោបាយកែទម្រង់ស៊ីជម្រៅរបស់ខ្លួន បើទោះជាត្រូវចំណាយពេលយូរ

ប៉ុណ្ណា និងអស់ទឹកប្រាក់ច្រើនប៉ុណ្ណាក៏ដោយក៏ស្ថានភាពអប់រំនៅតែមិនរីកចម្រើនផ្លាស់ប្តូរច្រើន និងទៅមុខលឿនដូចបំណងប្រាថ្នារបស់ខ្លួនដែរ។

## 2) យន្តការនៃការតែងតាំង ឬតំលើងតួនាទីមុខតំណែង

ការតែងតាំងតួនាទីសម្រាប់ថ្នាក់ដឹកនាំស្ថាប័ន និងអង្គភាព ឬធនធានមនុស្សសំខាន់ៗដែលចូលរួមចំណែកជួយធ្វើឱ្យវិស័យអប់រំមានការអភិវឌ្ឍរីកចម្រើន ពិតជាមានសារៈសំខាន់ណាស់។ ជាការពិត វាមានការលំបាកខ្លាំងណាស់ក្នុងការតែងតាំង ឬផ្តល់តួនាទីដល់អ្នកដែលមានសមត្ថភាព និងចំណេះដឹងខ្ពស់នៅពេលអត្ថប្រយោជន៍ដែលស្ថាប័នផ្តល់ជូនពួកគាត់នៅមានតិចតួចនៅឡើយ។ ដូច្នេះ បញ្ញវន្តអ្នកចេះដឹងដែលមានសញ្ញាប័ត្រខ្ពស់ទាំងនេះប្រហែលជាមិនលះបង់បញ្ញាណាណ ប្រាជ្ញាស្មារតី ពេលវេលា និងកម្លាំងកាយចិត្តធ្វើការឱ្យស្ថាប័នបានយូរឡើយ ហើយនៅចុងបញ្ចប់ពួកគេនឹងផ្លាស់ចេញទៅធ្វើការកន្លែងផ្សេងដែលមានអត្ថប្រយោជន៍ច្រើនជាងជាក់ជាមិនខានឡើយ លើកលែងតែអ្នកដែលចង់បានឋានៈតួនាទី និងកិត្តិយសមុខមាត់ក្នុងសង្គមប៉ុណ្ណោះ។ សម្រាប់យន្តការតែងតាំងតួនាទីដល់បុគ្គលដែលមានទ្រព្យធនច្រើនស្រាប់ហើយ ផ្អែកតាមតថភាពសង្គមជាក់ស្តែងហាក់ផ្តល់ប្រយោជន៍ច្រើនជាងដល់អង្គភាពព្រោះបុគ្គលដែលមានប្រាក់កាសទ្រព្យសម្បត្តិច្រើនហើយ ពួកគេនឹងត្រូវការកិត្តិយសក្នុងសង្គមជាងផលប្រយោជន៍នានា។ ករណីនេះ អាចទប់ស្កាត់អំពើពុករលួយបានមួយចំនួនធំ ហើយមិនតែប៉ុណ្ណោះពួកគាត់អាចនឹងចូលបដិភាគបានច្រើនក្នុងការជួយដល់សកម្មភាពឃោសនានៅមូលដ្ឋានដើម្បីកៀរគសម្លេងគាំទ្របានថែមទៀតផង។ ទោះបីយ៉ាងណាក៏ដោយ ការតំលើងតួនាទីដោយផ្តល់តម្លៃខ្លាំងពេកទៅលើទ្រព្យធនបែបនេះ ក៏ជះឥទ្ធិពលមិនល្អដល់ការបំពេញការងារ និងគុណតម្លៃរបស់មនុស្សផងដែរ។ ជាការពិត នៅក្នុងស្ថាប័នមួយពិតជាមានបុគ្គលិកមួយចំនួនបានខិតខំប្រឹងប្រែងធ្វើការ មានបទពិសោធ

យូរឆ្នាំមកហើយ មានសមត្ថភាពបំពេញការងារគ្រប់គ្រាន់ និងមានមនសិការវិជ្ជាជីវៈខ្ពស់ផងដែរ តែមិនមានទ្រព្យធនច្រើន ឬសញ្ញាប័ត្រខ្ពង់ខ្ពស់។ បើអនុវត្តការតំលើងតួនាទីដោយប្រើប្រាស់យុទ្ធសាស្ត្រខាងលើនេះ វាអាចធ្វើឱ្យឥទ្ធិពលលុយត្រូវបានលើកតំកើងខ្លាំងនៅក្នុងសង្គម ហើយពាក្យថា "មានលុយ នឹងមានអ្វីៗទាំងអស់ នឹងមានឥទ្ធិពលក្នុងក្របខណ្ឌនៃការបំពេញការងារ"។ ជាមួយគ្នានេះ វាអាចប្រែក្លាយទិសដៅរបស់បុគ្គលិកម្នាក់ៗឆ្ពោះទៅរកផលប្រយោជន៍ជាជាងរក្សាឧត្តមគតិ គុណតម្លៃ និងមនសិការការងារ។ មិនតែប៉ុណ្ណោះ វារឹតតែអាក្រក់មើលថែមទៀត បើការតំលើងតួនាទីតែងតាំងឡើងដោយស្វ័យប្រវត្តិតាមខ្សែបណ្ដោយបក្សពួកខ្លួនឱ្យធ្វើជាអ្នកដឹកនាំគ្រប់គ្រង ហើយសម្រាប់អង្គភាពផ្សេងទៀតដែលមិនមានបក្សពួកខ្លួន ត្រូវអនុវត្តនីតិវិធីបែបផ្សេងទៅវិញ ឬការប្រឡងប្រជែងស្និតស្នាញ។ ជាទូទៅ ការតែងតាំង និងតំលើងបែបនេះគ្មានអ្វីក្រៅពីដើម្បីពង្រឹង និងការពារឥទ្ធិពល ឬផលប្រយោជន៍បក្សពួកខ្លួនប៉ុណ្ណោះ។ ភាពមិនប្រាកដប្រជា និងច្បាស់លាស់បែបនេះ នាំឱ្យមានការសង្ស័យគ្នា និងជំរុញ ឱ្យមានការប្រើប្រាស់ល្បិចកលយុទ្ធសាស្ត្រយកឈ្នះគ្នាទៅវិញទៅមក ជាជាងយុទ្ធសាស្ត្រដើម្បីភាពជោគជ័យនៃការអនុវត្តការងារ និងសម្រេចគោលដៅរួមរបស់ស្ថាប័ន។ មួយវិញទៀត ទិន្នាការតែងតាំងផ្អែកលើគុណសម្បត្តិការចូលរួមក្នុងសកម្មភាពនយោបាយ ក៏ជះឥទ្ធិពលអវិជ្ជមានមួយចំនួនផងដែរដល់ឥរិយាបថនៃការបំពេញការងារ និងលទ្ធផលការងារដែលសម្រេចបាន។ ដោយសារការឱ្យតម្លៃខ្លាំងពេកទៅលើសកម្មភាពនេះ ធ្វើឱ្យបុគ្គលិកមួយចំនួនផ្ដោតតែលើការងារបក្សជាចម្បង ចេះអែបអប និងយកមុខយកមាត់ដើម្បីបានផលប្រយោជន៍ខ្លួនជាជាងប្រឹងប្រែងបំពេញការងារស្នូលរបស់ខ្លួននៅក្នុងស្ថាប័នដែលត្រូវអនុវត្តជាប្រចាំ។ ពួកគេមួយចំនួនយល់ឃើញថា បើចូលរួមសកម្មជាមួយការងារបក្ស និងបង់បដិភាគថវិកាច្រើន នោះតួនាទីឋានៈខ្លួនដែលកំពុងមាននាពេលនេះ និងតទៅអនាគតក៏រឹងមាំ

ល្អប្រសើរផងដែរ បើទោះជាការបំពេញការងារស្នូលប្រចាំមិនសូវបានល្អក៏ដោយ។ បរិបទការងារបែបនេះ វាបង្កើតជាវប្បធម៌អែបអប និងលន់តួដើម្បីរក្សាតួនាទីអំណាច និងផលប្រយោជន៍ខ្លួនបានយូរអង្វែង ដែលជះឥទ្ធិពលខ្លាំងភាពជោគជ័យនៃការអនុវត្តការងារក្នុងស្ថាប័ន។ វប្បធម៌បែបនេះ ជាវប្បធម៌អន់ថយក្នុងយុគសម័យថ្មី។ ផ្នត់គំនិត និងឥរិយាបថរបស់បុគ្គលិកគ្រប់លំដាប់បែបនេះ ជារនាំងឧបសគ្គធំណាស់ក្នុងការអនុវត្តកំណែទម្រង់ស៊ីជម្រៅ ហើយដំណើរនៃការអភិវឌ្ឍរីកចម្រើនហាក់មានភាពរប៉ាក់រពើក និងមិនទៅមុខលឿនឡើយ ហើយទោះបីស្ថានភាពដូចរៀបរាប់ខាងលើនេះមានការដឹងឮច្រើនហើយក៏ដោយ ក៏កំណែទម្រង់មានតែនៅលើក្រដាសឱ្យតែល្អមើលប៉ុណ្ណោះ គ្មានឡើយគតិបណ្ឌិតថ្មីចូលមកកែលម្អ និងអភិវឌ្ឍន៍នោះ។ សម្រាប់កាលៈទេសៈនៃការអនុវត្តយុទ្ធសាស្ត្រធ្វើកំណែទម្រង់ស៊ីជម្រៅមួយ បើអ្នកអនុវត្ត ឬអ្នកដឹកនាំអនុវត្តសកម្មភាព មានចិត្តមិនដាច់ស្រាច់ ជំហរច្បាស់លាស់ ឬមានភាពទើសទាល់ច្រើនពេក និងមិនហ៊ានជំនះទៅមុខ ឬមិនហ៊ានអារកាត់ដោះស្រាយឱ្យបានទាន់ពេលវេលានោះទេ ការអនុវត្តការងារកំណែទម្រង់នឹងមិនទទួលជោគជ័យឡើយ។

### 3) *ការសរសេររបាយការណ៍*

ចំណុចនេះយើងចង់បង្ហាញពីកម្រិតគុណភាពនៃការសរសេររបាយការណ៍ដោយយើងឃើញថា របាយការណ៍មួយចំនួនដែលបានរៀបចំឡើងហាក់មិនទាន់បានល្អនៅឡើយ ពិសេសការសរសេររបាយការណ៍ដែលមានមូលដ្ឋានផ្អែកលើលទ្ធផល(Result Based Report)។ តាមរយៈការអានរបាយការណ៍ជាច្រើនកន្លង យើងសង្កេតឃើញថា វាហាក់មិនបានបង្ហាញពេញលេញពីលទ្ធផលសម្រេចបាននៃការអនុវត្តសកម្មភាព ឬគម្រោងដោយបង្ហាញតែកម្រិតសកម្មភាពប៉ុណ្ណោះ។ លទ្ធផលនៃការអនុវត្តគម្រោងគឺ ជាលទ្ធផលនៃការផ្លាស់ប្តូរ ឬភាពរីកចម្រើនបន្ទាប់ពីអនុវត្តសកម្មភាព

នានា មិនមែនជាការលើកឡើងពីសកម្មភាពដែលបានអនុវត្តកន្លងមកទេ។ ដើម្បីឱ្យកាន់តែច្បាស់ យើងសូមលើកឧទាហរណ៍មួយចំនួនដូចខាងក្រោមមកបញ្ជាក់។ ឧ. របាយការណ៍សិក្ខាសាលាមួយលើកឡើងពីលទ្ធផលសម្រេចបាន ដោយបង្ហាញតែពីចំនួនសិក្ខាសាលាដែលរៀបចំ និងចំនួនសិក្ខាកាមដែលបានលរួម តែមិនមានបង្ហាញពីលទ្ធផលនៃការផ្លាស់ប្តូរ ឬភាពរីកចម្រើនបន្ទាប់អនុវត្តសកម្មភាពគម្រោង។ នេះមិនមែនរបាយការណ៍លទ្ធផលទេ វាគ្រាន់តែជារបាយការណ៍សកម្មភាពធម្មតាៗប៉ុណ្ណោះ។ របាយការណ៍ដែលឆ្លុះបញ្ចាំងលទ្ធផលគឺ គួរតែបង្ហាញជាក់លាក់ដោយមានភស្តុតាងបញ្ជាក់ពីវឌ្ឍនភាពរីកចម្រើន និងការផ្លាស់ប្តូរជាបន្តបន្ទាប់។ ជាក់ស្តែងក្នុងរបាយការណ៍គួរតែបង្ហាញពីលទ្ធផលមួយចំនួនដែលបញ្ជាក់ថា ចំណោមសិក្ខាកាមដែលបានចូលរួមសិក្ខាសាលា មានការផ្លាស់ប្តូររីកចម្រើនប៉ុន្មាននាក់? បានអនុវត្តអ្វីខ្លះ និងទទួលបានលទ្ធផលដូចម្តេច? តើមានការផ្លាស់ប្តូរអ្វីខ្លះ?...។ល។ របាយការណ៍ដែលរៀបរាប់ពីសកម្មភាពខាងលើហាក់គ្រាន់តែជារបាយការណ៍បង្គប់កិច្ចដើម្បីជំរះបញ្ជីការប្រើប្រាស់ថវិកាប៉ុណ្ណោះ។ ចំណុចបន្ថែមមួយទៀត ការភូតកុហក និងបំប៉ោងទិន្នន័យតួលេខក្នុងរបាយការណ៍នៅតែជាបញ្ហាចម្បងមួយដែរ។ ដោយសារមិនមានយន្តការតាមដាន និងត្រួតពិនិត្យច្បាស់លាស់លើភាពត្រឹមត្រូវនៃរបាយការណ៍ វាអាចជាចន្លោះប្រហោងដែលអ្នករៀបចំ និងសរសេររបាយការណ៍មួយចំនួនងាយស្រួលក្លែងបន្លំ ឬភូតកុហកថ្នាក់លើខ្លួន ហើយពេលខ្លះ របាយការណ៍មួយចំនួនពីថ្នាក់ក្រោមដល់ថ្នាក់លើគឺជារបាយការណ៍កុហក និងបំប៉ោងតួលេខតគ្នាខុសពីការពិត ដែលបញ្ហានេះបង្កការលំបាកសម្រាប់អ្នករៀបចំយុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈមទាំងនោះ។ ពួកគេនឹងមិនអាចកំណត់បានជាក់លាក់ពីស្ថានភាពជាក់ស្តែងរបស់បញ្ហាប្រឈមដែលបានជួបប្រទះដើម្បីស្វែងរកដំណោះស្រាយ។ ស្ថានភាពនេះ ហាក់ដូច

ជាការភូតកុហកពីរោគសញ្ញាជំងឺ វិនិច្ឆ័យជំងឺផ្តេសផ្តាស ដែលពិបាកដាក់ព្យាបាលឱ្យជាសះស្បើយអីចឹងដែរ។

## 4) *អំពើពុករលួយ*

អំពើពុករលួយក្នុងសាលារៀនតាមរយៈការគ្រប់គ្រងមិនមានតម្លាភាព គណនេយ្យភាព និងការចូលរួមទូលំទូលាយទាក់ទងនឹងចំណូល-ចំណាយ។ ការប្រើប្រាស់វិក្ក័យប័ត្រក្លែងក្លាយដើម្បីជំរះបញ្ជី ការកែតម្រូវចំណាយលើសកម្មភាព ការកាត់តម្រឹមថវិកា ការកិបកេងក្លែងបន្លំ (Fraud) ការយកថវិកាសម្បុរជន សហគមន៍ និងមាតាបិតាសិស្សមកឡប់ឡែជាមួយថវិកាអាទិភាព(PB) រួចបង្កើតសំណុំឯកសារក្លែងក្លាយដើម្បីជំរះបញ្ជី។ អំពើពុករលួយទាំងនេះនាំមកនូវទំនាស់ផលប្រយោជន៍ ភាពច្រណែនគ្នា និងបែកបាក់ផ្ទៃក្នុង ព្រមទាំងធ្វើឱ្យបរិយាកាសបំពេញការងារក្នុងស្ថាប័នមានភាពអាប់អួរ បាត់បង់មនសិការវិជ្ជាជីវៈ និងធ្វើឱ្យគោលដៅរបស់ស្ថាប័នមិនបានសម្រេច។ ជាទូទៅ គ្រឹះស្ថានសិក្សាដែលប្រព្រឹត្តអំពើពុករលួយលើថវិការដ្ឋ និងថវិកាដទៃទៀត មិនសូវបើកចំហទូលាយពីព័ត៌មានទាក់ទងនឹងចំណូល-ចំណាយទេ (ដូចជា៖ ចំណូលពីការផ្ញើកង់ម៉ូតូ កុងទីន ចំណូលពីសម្បុរសជន ការរៃអង្គាសផ្សេងៗ មូលនិធិពីខាងក្រៅថវិកាអភិវឌ្ឍន៍សាលារៀន...) ហើយពេលខ្លះគណៈគ្រប់គ្រងសាលាមិនសូវត្រូវគ្នាដោយបញ្ហាបែងចែកផលប្រយោជន៍ និងភាគលាភនេះឡើយ។ សម្រាប់ករណីនេះ នៅប្រទេសនានាដែលមានប្រព័ន្ធគណនេយ្យរឹងមាំពិបាកអនុវត្តការកេងបន្លំនេះខ្លាំងណាស់ ដោយសារការពង្រឹងការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃសនវកម្ម។ ជាការពិត វាងាយស្រួលណាស់សម្រាប់ពួកគេក្នុងការតាមដាន និងវាយតម្លៃពីសុក្រឹតភាពនៃការចាយវាយរបស់សាលារៀនថាតើវាត្រឹមត្រូវ ឬអត់ តាមរយៈការពិនិត្យទៅលើវិក័យប័ត្រ ការផ្ទៀងផ្ទាត់ជាមួយអ្នកផ្គត់ផ្គង់ (Supplier) និងការចាត់វិធានការតឹង

រឹង។ កន្លងមក នីតិវិធីអនុវត្តសវនកម្មរបស់យើង ភាគច្រើនគ្រាន់តែពិនិត្យមើលព័ត៌មាននៅលើវិក័យប័ត្រ ឬទម្រង់ឯកសារដទៃទៀត ថាតើ វាមានគ្រប់គ្រាន់ ឬអត់ ត្រឹមត្រូវ ឬអត់ បើមិនគ្រប់គ្រាន់ ត្រូវធ្វើថ្មីដើម្បីបំពេញបន្ថែម និងដាក់ជំនួសឯកសារដែលខុសតែប៉ុណ្ណោះ ព្រមទាំងមិនបានផ្ទៀងផ្ទាត់ថាតើ ការចំណាយនោះត្រឹមត្រូវតាមកូដសកម្មភាពដែរឬទេ មានការដោះដូរសកម្មភាពដែរឬទេ។ និន្នការបែបនេះ គឺស្ថិតក្នុងរូបភាពនៃការបែងចែកផលប្រយោជន៍គ្នា ចំណែកឯ ការចំណាយដាក់ស្តែងតិចជាងថវិកាដែលរដ្ឋទម្លាក់ឱ្យខ្លាំងណាស់។ ចំណែកឯ ភាពយឺតយ៉ាវនៃការទម្លាក់ថវិកាដល់សាលារៀន កាន់តែបង្កភាពងាយស្រួលដល់ពួកគាត់ក្នុងការឆ្លៀតឱកាសរៀបចំឯកសារជំរះបញ្ជីតែម្តង ដែលនេះជារូបភាពនៃអំពើពុករលួយក្រោមលេសភាពយឺតយាវនៃការទម្លាក់ថវិកា ហើយដំណើរការសវនកម្មក៏មានភាពប្រថុចញ៉ុចពេកមិនអាចអនុវត្តបាន។

ករណីខ្លះ អំពើពុករលួយកើតឡើងដោយការអនុវត្តនីតិវិធីខុសនៃការធ្វើលទ្ធកម្ម ហើយយន្តការនេះមិនមានសម្រាប់កម្រិតសាលារៀនឡើយ ព្រោះសាលាអាចអនុវត្តបានត្រឹមការជុសជុលកម្រិតតូចតាច។ សម្រាប់ការបង្ហាញនេះ គ្រាន់តែចូលរួមចំណែកជាមតិយោបល់ និងការយល់ឃើញប៉ុណ្ណោះ ព្រោះឃើញដំណើរការសាងសង់ និងជុសជុលនៅតាមសាលារៀនមួយចំនួនកន្លងមកដែលមិនស្ថិតក្រោមដែនសមត្ថកិច្ចរបស់សាលា មិនមានលក្ខណៈសមស្របតាមគម្រោងចំណាយដែលលើកឡើងសោះ ហើយការបង្ហាញជាបន្តទៅទៀតនេះ ជាការសាកល្បងសិក្សាដើម្បីជាទុនមួយក្នុងការស្វែងយល់តែប៉ុណ្ណោះ។ ការជាពិត ដើម្បីទប់ស្កាត់អំពើពុករលួយ គេបង្កើតឱ្យមានការធ្វើលទ្ធកម្ម ដែលមានលក្ខណៈជាប្រព័ន្ធធ្វើការរួមគ្នាដោយចងក្រងជាគណៈកម្មការលទ្ធកម្ម ធ្វើការប្រជុំពិភាក្សា និងសម្រេច ពីដំណើរការធ្វើលទ្ធកម្ម។ គណៈកម្មការជាអ្នកសម្រេចប្រកាសឱ្យដេញថ្លៃ

ការផ្សព្វផ្សាយដំណឹងដេញថ្លៃឱ្យបានទូលំទូលាយ និងធ្វើជាសាធារណៈ ការវិនិច្ឆ័យលក្ខណៈសម្បត្តិ អ្នកផ្គត់ផ្គង់ ឬអ្នកសាងសង់ ការកំណត់កាលបរិច្ឆេទដេញថ្លៃ នីតិវិធីដេញថ្លៃ (ដាក់ស្រោមសំបុត្រ ឬជាសាធារណៈ ) និងការពិភាក្សាសម្រេចជ្រើសរើសរកក្រុមហ៊ុនសមស្រប។ ជាទូទៅនៅក្នុងជួរគណៈកម្មការលទ្ធកម្ម មានជំនាញច្បាស់ណាស់ពីបច្ចេកទេស ដើម្បីកំណត់តម្លៃប៉ាន់ស្មាន ដែលសមស្របតាមបច្ចេកទេស ធានាបានទាំងគុណភាព និងប្រសិទ្ធភាព។ ការកំណត់សម្រេចជ្រើសរើសក្រុមហ៊ុនណាមួយសម្រាប់ផ្គត់ផ្គង់ ជុសជុល ឬសាងសង់ គឺអាស្រ័យដោយនីតិវិធីរបស់គណៈកម្មការពេលខ្លះ មិនបានទៅលើក្រុមហ៊ុនដែលដេញថ្លៃទាបជាងគេនោះទេ ព្រោះវាស្ថិតក្រោមការវាយតម្លៃកម្រិតគុណភាព សំណង់ ឬសម្ភារៈដែលសមស្រប តាមតម្លៃប៉ាន់ស្មាន។ បន្ទាប់មកគឺ ការចុះកិច្ចសន្យាការងារ និងផែនការការងារ។ ស្ថិតក្នុងដំណើរការជាប្រព័ន្ធបែបនេះ បើប្រព្រឹត្តអំពើពុករលួយពិតជាពិបាក លុះត្រាតែ ធ្វើជាប្រព័ន្ធដែរ ទើបវាអាចទៅរួច។ ទិដ្ឋភាពនេះនាំឱ្យមានបង្កើតធាកល្បែនលទ្ធកម្ម ដោយបានកំណត់ក្រុមហ៊ុនរួចស្រេចទៅហើយ ព្រោះវាងាយរកបានប្រាក់ចំណេញ។ ក្នុងជួរគណៈកម្មការប្រហែលជាអាចរស់ពី ការបែងចែកភាគលាភពីសកម្មភាពនេះ ហើយសំណុំឯកសារមិនជាពិបាកទេ ព្រោះអាចសហការគ្នាធ្វើបាន។ មួយវិញទៀត ក្រុមហ៊ុនដាក់ដេញថ្លៃ ប្រហែលជាទុកមួយកញ្ចប់ឱ្យពួកគេមិនខាន។ នេះជាការខ្ជះខ្ជាយលុយរដ្ឋ ក្រោមរូបភាពនៃ អំពើពុករលួយ។

ចំណុចមួយទៀតទាក់ទងនឹងការអនុវត្តមិនមានប្រសិទ្ធភាព និងគុណភាពនៃកញ្ចប់ថវិកាសម្រាប់ដំណើរការលើកកម្ពស់វិស័យអប់រំ ពិសេសការចុះតាមដាននៅតាមសាលារៀន។ មន្ត្រីអប់រំមួយចំនួន មិនបានចុះទៅបំពេញការងារដោយផ្ទាល់ទេ គ្រាន់តែផ្ញើលិខិតឧទ្ទេសនាម និងទិដ្ឋាការដើម្បីសុំការចុះហត្ថលេខាពីនាយកសាលាតែប៉ុណ្ណោះ ឬចុះទៅតាមដានតែ

ម្នាក់ តែក្នុងលិខិតឧទ្ទេសនាមមាន ពីរ ឬបីនាក់។ នេះយើងមិនបាននិយាយដល់ការជប់របាយការណ៍ឬធ្វើរបាយការណ៍មិនមានគុណភាពសម្រាប់ចូលរួមចំណែកកែលម្អសាលារៀនឡើយ។ រូបភាពនេះ ជាការចាយវាយខ្ជះខ្ជាយនូវថវិការដ្ឋ និងឆ្លុះបញ្ចាំងពីភាពអសកម្មនៃការបំពេញការងាររបស់មន្ត្រីអប់រំមួយចំនួន។

ចំណុចបន្ថែមមួយទៀត ការកំណត់អាទិភាពលើបញ្ហាប្រឈមដើម្បីរៀបចំផែនការឆ្លើយតប ហាក់នៅមានកម្រិតនៅឡើយទាំងកម្រិតសាលារៀន ការិយាល័យអប់រំស្រុក និងមន្ទីរ។ ការលើកផែនការថវិកាមួយចំនួន ច្រើនរៀបចំឡើងក្នុងរូបភាពដដែលៗ តាមគំរូឆ្នាំចាស់ ដោយគ្មានគំនិតច្នៃប្រឌិតបង្កើតថ្មី ដោះស្រាយបញ្ហាជាក់ស្តែងនោះទេ ហើយពេលខ្លះគ្រោងសកម្មភាពណាដែលបង្កភាពងាយ ស្រួលក្នុងការកិបកេង និងទទួលបានផលប្រយោជន៍តែប៉ុណ្ណោះ ដោយមិនផ្តោតជាចម្បងលើបញ្ហាជាអាទិភាព ដែលត្រូវដោះស្រាយនោះទេ ហើយបញ្ហាសំខាន់មួយចំនួនទៀតត្រូវបានទុកចោល មិនទទួលការគាំទ្រឡើយ។ មិនតែប៉ុណ្ណោះ មានករណីខ្លះការកំណត់ថា សកម្មភាពដែលគ្រោងជាអាទិភាព ឬមិនអាទិភាព វាអាស្រ័យទៅលើទំនាក់ទំនងល្អជាមួយការិយាល័យគណនេយ្យ ផែនការ។

ចំណុចចុងក្រោយ គឺការចំណាយខ្ជះខ្ជាយថវិការដ្ឋលើសិក្ខាសាលាបំប៉នសមត្ថភាពគ្រូបង្រៀន និងមន្ត្រីអប់រំដែលអនុវត្តមិនមានប្រសិទ្ធភាព និងគុណភាព ដោយសារកង្វះយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពប្រកបដោយភាពជោគជ័យ។ ការលើកឡើងនេះ សម្រាប់តែសិក្ខាសាលាមួយចំនួនប៉ុណ្ណោះ ដែលផលទទួលបាន មិនស័ក្តិសមនឹងការចំណាយ ពោលគឺធ្វើឱ្យតែរួចពីដៃ ពេលខ្លះបំព្រួញពេលវេលាសិក្ខាសាលាថែមទៀត។ ស្ថិតក្នុងបរិបទនៃការកើនឡើងថវិកាគាំទ្រដល់សិក្ខាកាម គ្រូឧទ្ទេស និងអ្នកសម្របសម្រួល ពួកគេពិតជារីករាយណាស់ក្នុងការ

ចូលរួមកម្មវិធីនេះ ព្រោះវាបានទាំងចំណេះ និងលុយ។ សិក្ខាសាលាមួយចំនួនទាមទារកម្រិតជំនាញ និងវិធីសាស្ត្រផ្ទេរចំណេះដឹងខ្ពស់ ឧទាហរណ៍ដូចជា ការបម្រែបម្រួលអាកាសធាតុ និងយែនឌ័រជាដើម តែគ្រូឧទ្ទេសហាក់មិនមានជំនាញ និងបទពិសោធន៍ច្បាស់លាស់លើផ្នែកនេះសោះ ហើយវិធីសាស្ត្រផ្ទេរចំណេះដឹងហាក់នៅមានកម្រិតនៅឡើយ ដែលធ្វើឱ្យលទ្ធផលសិក្ខាសាលាទទួលបានតិចតួចបំផុត។ ចំណែកឯការវាយតម្លៃសិក្ខាសាលានោះសោត សិក្ខាកាមមិនបានឆ្លុះបញ្ចាំងគុណភាពសិក្ខាសាលាទេ គឺវាយតម្លៃផ្អែកលើផលប្រយោជន៍ថវិកាដែលទទួលបាន។

## 5) *ការដណ្តើមទីផ្សារការងារក្នុងវិស័យអប់រំ*

ស្ថិតក្នុងបរិបទនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិមានមូលដ្ឋានផ្អែកលើចំណេះដឹង ការអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សដើម្បីបំពេញតម្រូវការទីផ្សារការងារ និងសង្គម។ ប្រទេសមួយចំនួនបានប្រើប្រាស់យុទ្ធសាស្ត្រវិនិយោគលើធនធានមនុស្សដើម្បីទទួលបានផលចំណេញផ្នែកសេដ្ឋកិច្ច តាមរយៈការស្រូបទាញប្រាក់ចំណូលពីការងារទាំងក្នុង និងក្រៅប្រទេស។ សហគមន៍សេដ្ឋកិច្ចអាស៊ាន ជានិន្នាការថ្មី ផ្តល់ឱកាសដល់ប្រទេសជាសមាជិក ធ្វើលំហូរកម្លាំងពលករជំនាញដោយសេរី ដែលធ្វើឱ្យការប្រកួតប្រជែងធនធានមនុស្សកាន់តែខ្លាំងក្លាថែមទៀត។ នេះមានន័យថាពលករជំនាញអាចចូលទៅធ្វើការនៅតាមប្រទេសជាសមាជិកនានាដែលកំពុងខ្វះខាតជំនាញទាំងនោះ ហើយប្រទេសណាដែលមានលំហូរចេញច្រើន ប្រទេសនោះទទួលបានផលចំណេញពីសមារណកម្មនេះកាន់តែច្រើន។ ដោយសារ ភាសាអង់គ្លេសត្រូវបានកំណត់ជាភាសាផ្លូវការរបស់អាស៊ាន និងអត្ថប្រយោជន៍សម្រាប់ទំនាក់ទំនងលក្ខណៈអន្តរជាតិព្រមទាំងការធ្វើពាណិជ្ជកម្មទាំងក្នុងតំបន់ និងសាកល ធ្វើឱ្យការសិក្សាភាសាអង់គ្លេសមានប្រជាប្រិយភាពខ្លាំងក្នុងទីផ្សារអប់រំ ពិសេសវិស័យអប់រំ

សាលារៀនឯកជនតួយ៉ាងដូចប្រទេសកម្ពុជាជាដើម។ បើយើងសាកល្បងសម្លឹងមើលនិន្នាការអប់រំនាពេលបច្ចុប្បន្ន និងតទៅអនាគត យើងឃើញថាប្រទេសដែលប្រើប្រាស់ភាសាអង់គ្លេសជាភាសាផ្លូវការសម្រាប់ការសិក្សាទាំងកម្មវិធីសិក្សារដ្ឋ និងឯកជន ហាក់ទទួលបានផលចំណេញច្រើនផ្នែកសេដ្ឋកិច្ច ច្រើនជាងគេ ដូចប្រទេសសឹង្ហបូរី និងហ្វីលីពីនជាដើម។

ប្រទេសកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់ខ្លាំងក្នុងការធ្វើកំណែទម្រង់ និងអភិវឌ្ឍន៍វិស័យអប់រំ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់បន្ថែមទៀតលើការសិក្សាភាសាអង់គ្លេសដោយដាក់បញ្ចូលភាសានេះ ក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សានៅឆ្នាំ២០១៧។ ជាមួយគ្នានេះ ការអប់រំដោយប្រើប្រាស់ពីរភាសាកាន់តែមានប្រជាប្រិយភាពសម្រាប់មាតាបិតាសិស្ស និងសង្គមដែលជំរុញឱ្យសាលារៀនឯកជនដែលអនុវត្តការបង្រៀនពីរភាសានេះមានការកើនឡើង និងរីកចម្រើនជាលំដាប់។ ទន្ទឹមនឹងការកើនឡើងនូវតម្រូវការទីផ្សារអប់រំ តម្រូវការគ្រូបង្រៀនសម្រាប់បង្រៀនមុខវិជ្ជាផ្សេងៗជាភាសាអង់គ្លេសដូចជា៖ មុខវិជ្ជាវិទ្យាសាស្ត្រ គណិតវិទ្យា ភាសាអង់គ្លេស...ក៏មានការកើនឡើងផងដែរ។ មកដល់ពេលនេះ យើងឃើញមានហានិភ័យកាន់តែខ្លាំងឡើងសម្រាប់គ្រូបង្រៀនជនជាតិខ្មែរ ដែលបញ្ចប់ការសិក្សាមុខវិជ្ជាភាសាអង់គ្លេស ឬឯកទេសផ្សេងៗ ដោយសារឱកាសការងារកាន់តែចង្អៀតទៅៗនៅតាមសាលារៀនឯកជននានា។ នេះគឺដោយសារគ្រូបង្រៀនមកពីប្រទេសជាសមាជិកអាស៊ានដែលប្រើប្រាស់ភាសាអង់គ្លេសជាយាន ពិសេសហ្វីលីពីនចូលមកប្រកួតប្រជែងការងារ និងទទួលយកប្រាក់ខែប្រហាក់ប្រហែលនឹងគ្រូបង្រៀនជនជាតិខ្មែរដែរ ហើយដើម្បីអត្ថប្រយោជន៍ទីផ្សារ ប្រាកដណាស់សាលារៀនឯកជន

ទាំងនោះនឹងទទួលយកគ្រូបង្រៀនដែលជាជនបរទេស ប្រសើរជាងជនជាតិខ្លួនឯង។ ស្ថិតក្នុងបរិបទនៃកំណើនសេដ្ឋកិច្ចជាតិ កំណើនប្រាក់ចំណូលមធ្យមសម្រាប់មនុស្សម្នាក់ និន្នាការគ្រួសារតូច (គ្រួសារមានកូនតិច) ការវិនិយោគលើការអប់រំកូនកាន់តែច្រើនទៅៗនាពេលអនាគត ហើយទីផ្សារអប់រំឯកជនកាន់តែទូលំទូលាយ ជាមួយនឹងឱកាសការងារកាន់តែច្រើនសម្រាប់គ្រូបង្រៀនជាជនបរទេសដែលប្រើប្រាស់អង់គ្លេសជាយាន។ ជាមួយគ្នានេះ វាក៏ធ្វើឱ្យសាច់ប្រាក់ជាច្រើនហូរចេញពីប្រទេសផងដែរ។ ទោះបីជាណាក៏ដោយ ការពង្រឹងការអប់រំនៅតាមគ្រឹះស្ថានសិក្សាសាធារណៈចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមទាំងនេះបានមួយចំនួន។

### 6) *កម្មវិធីសិក្សាថ្នាក់កម្រិតឧត្តមសិក្សាមួយចំនួននៅសតវត្សរ៍ទី២០នៅឡើយ*

កម្មវិធីសិក្សាថ្នាក់ឧត្តមសិក្សាមួយចំនួនហាក់នៅមិនទាន់សម័យ និងនៅសតវត្សរ៍ទី២០នៅឡើយ។ ឈានដល់យុគ្គសម័យបដិវត្តន៍ឧស្សាហកម្មទី៤ ដោយផ្ដោតខ្លាំងលើបច្ចេកវិទ្យា និងនវានុវត្តន៍ថ្មីៗ ដូចជាបច្ចេកវិទ្យាបញ្ញាសប្បនិមិត្ត និងរ៉ូបូតជាដើម ដែលជះឥទ្ធិពលខ្លាំងលើគ្រប់ទិដ្ឋភាពជីវិតរស់នៅរបស់មនុស្ស។ និន្នាការអប់រំសតវត្សរ៍ទី២១ ការផ្លាស់ប្ដូរជាខ្លាំងដើម្បីផលិតធនធានមនុស្សឆ្លើយតបទៅនឹងដំណើរវិវត្តន៍របស់សង្គមនេះ និងការប្រកួតប្រជែង។ សម្រាប់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់ជាខ្លាំងលើការកែទម្រង់ប្រព័ន្ធអប់រំតាមរយៈការបង្កើនថវិកាចំណាយប្រចាំឆ្នាំដល់វិស័យអប់រំពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីផលិតធនធានមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពេញលេញក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេស។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា បានប្ដេជ្ញាចិត្តធ្វើឱ្យសម្រេចនូវគោលដៅរួមរបស់ SDG 4 គឺជានា

ឱ្យបាននូវការអប់រំប្រកបដោយគុណភាពបរិយាប័ន្ន សមធម៌ និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ប្រទេសកម្ពុជាមានគោលដៅប្រែក្លាយប្រទេសទៅប្រទេសឧស្សាហកម្មនៅឆ្នាំ២០២៥ តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ ២០១៥-២០២៥ និងជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ដើម្បីសម្រេចគោលដៅនេះការអប់រំនៅឧត្តមសិក្សាដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិតធនធានមនុស្សឱ្យបានគ្រប់គ្រាន់និងឆ្លើយតបទៅនឹងជំនាញដែលត្រូវការជាចាំបាច់នាពេលអនាគត។ ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់ជាខ្លាំងក្នុងការជំរុញឱ្យគ្រឹះស្ថានសិក្សាកម្រិតឧត្តមសិក្សាអភិវឌ្ឍន៍ស្ថាប័នខ្លួនតាមរយៈផ្តល់ឱកាសឱ្យមានការប្រកួតប្រជែងគ្នា និងភាពម្ចាស់ការក្នុងការរៀបចំកម្មវិធីសិក្សាដោយខ្លួនឯង។ ដោយសារគ្រឹះស្ថានឧត្តមសិក្សានីមួយៗត្រូវរៀបចំកម្មវិធីសិក្សាដោយខ្លួនឯងបែបនេះហើយទើបខ្ញុំមានឱកាសចូលរួមជាមួយមហាវិទ្យាល័យមួយដែលគេអញ្ជើញឱ្យចូលរួមពិគ្រោះយោបល់ ក្នុងនាមជាសាស្ត្រាចារ្យបង្រៀនក្រៅម៉ោងលើឯកទេសអក្សរសាស្ត្រខ្មែរ ហើយជាឱកាសដ៏ល្អមួយចង់ចែករំលែកទស្សនៈយោបល់របស់ខ្លួន ដើម្បីចូលរួមចំណែកកែលម្អកម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរលើចំណុចមួយចំនួនតែគួរឱ្យស្តាយឱកាសហាក់ចង្អៀតពេកសម្រាប់ខ្ញុំ មិនបានបញ្ចេញអ្វីឱ្យអស់ពីចិត្តដែលខ្លួនចង់បង្ហាញទើបឆ្លៀតឱកាសនេះ សរសេរពីអ្វីដែលខ្លួននិយាយនៅពេលនោះ។ការបកស្រាយបង្ហាញនៅពេលនេះ ផ្តោតតែលើឯកទេសអក្សរសាស្ត្រខ្មែរប៉ុណ្ណោះ ហើយវាជាការសិក្សាសាកល្បងមួយ។ វាជាការពិតណាស់ ការរៀបចំកម្មវិធីសិក្សាឱ្យបានសមស្របទៅនឹងបរិបទ (Context) ក្នុងគោលបំណងផលិតធនធានមនុស្សដើម្បីជំរុញការអភិវឌ្ឍប្រទេសឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងផ្អែកលើធនធាន បទពិសោធដែលខ្លួនមានគឺជារឿងចាំបាច់បំផុតដែលគ្រប់គ្រឹះស្ថានឧត្តមសិក្សាត្រូវយកចិត្តទុកដាក់។ តាមរយៈការពិនិត្យ

ជាទូទៅ យើងឃើញថា កម្មវិធីសិក្សាបានបែងចែកជា២ផ្នែកសំខាន់គឺ កម្មវិធីសិក្សាទូទៅ និងចាំបាច់។ ជាទស្សនៈផ្ទាល់ខ្លួន សម្រាប់កម្មវិធីសិក្សាទូទៅ យើងអាចនិយាយបានថា វាហាក់នៅមិនទាន់សម័យ និងប្រៀបដូចស្ថិតនៅសតវត្សរ៍ទី២០នៅឡើយ ដោយសារវាមិនមានដាក់បញ្ចូលនូវមេរៀនសំខាន់ៗនៅសតវត្សរ៍ទី២១ ដូចបណ្ដាប្រទេសនានានៅលើពិភពលោកគេចាប់អារម្មណ៍នោះទេ។ កម្មវិធីសិក្សាទូទៅរបស់យើងមានដាក់បញ្ចូលតែមុខវិជ្ជាមួយចំនួនដូចជា៖ គណិតវិទ្យា រដ្ឋបាលសាធារណៈ មូលដ្ឋានគ្រឹះនៃការអប់រំ គ្រឹះទស្សនវិជ្ជា ចិត្តវិទ្យា សេចក្ដីផ្ដើមនៃសង្គមវិទ្យា ប្រវត្តិសាស្ត្រខ្មែរ...ដោយយើងមិនឃើញមុខវិជ្ជាទាន់សម័យមួយចំនួនត្រូវបានដាក់បញ្ចូលសោះដូចជា៖ ការគិតប្រកបដោយហេតុផល (Critical Thinking Skill) ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ (Information for research study) សាកលភាវូបនីយកម្ម និងមូលដ្ឋាននីយកម្ម (Globalization and localization) សេដ្ឋកិច្ចសង្គម (Social Economy) ភាពជាអ្នកដឹកនាំ (Leadership)វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍ (Science and technology for development) ភាពជាពលរដ្ឋសាកល (Global citizenship) ការថែរក្សាបរិស្ថាន (Environmental Conservation) បរិយាប័ន្ន (inclusive) វប្បធម៌ខ្មែរ និងសីលធម៌ (Khmer culture and Ethics) ការអភិវឌ្ឍប្រកបដោយចីរភាព(Sustainable Development) ជំនាញកុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មានវិទ្យា សម្រាបនិស្សិត (Computer skill and information technology for student)...។ល។ គោលដៅរបស់យើង ចង់ផលិតធនធានមនុស្សសម្រាប់បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិនៅសតវត្សរ៍ទី២១ ដែលត្រូវការជាចាំបាច់នូវមុខវិជ្ជាសំខាន់ៗខាងលើនេះ ដែលចូលរួមចំណែកលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព តែដាក់ស្ដែងកម្មវិធីសិក្សាយើងហាក់នៅសតវត្សរ៍ទី២០នៅឡើយ។ តើដើម្បីឱ្យនិស្សិតទាំង

នោះក្លាយជាធនធានមនុស្សមានសមត្ថភាពគ្រប់គ្រាន់ពេញលេញទាំងជំនាញរឹង និងទន់ ( Hard & Soft Skill) ជាអ្នកសិក្សាពេញមួយជីវិត តើពួកគេគួរតែត្រូវបានបណ្តុះបណ្តាលនូវមុខវិជ្ជាអ្វីខ្លះ? ទោះបីជាយ៉ាងណាក៏ដោយ យើងឃើញថា ការបណ្តុះបណ្តាលមុខវិជ្ជាទាំងនេះ នៅតែជួបប្រទះបញ្ហាប្រឈមនៅឡើយ ទាំងនេះអាចមកពីនៅគ្រឹះស្ថានសិក្សាទាំងនោះនៅខ្វះខាតធនធានសាស្ត្រាចារ្យដែលមានសមត្ថភាពលើជំនាញឯកទេសទាំងនេះនៅឡើយ។ ចំណែកឯ កម្មវិធីសិក្សាចាំបាច់ (Major Course) ហាក់មានលក្ខណៈស្មុគស្មាញច្រើន និងធ្វើនិស្សិតមិនសូវចាប់អារម្មណ៍ខ្លាំងក្នុងការសិក្សារៀនសូត្រ។ និស្សិតរៀនមុខវិជ្ជាច្រើនពេក ដោយមិនប្រាកដប្រជាអ្វីមួយដែលជាមូលហេតុសំខាន់ធ្វើឱ្យពួកគាត់រៀនដើម្បីតែរៀន ឬរៀនដើម្បីតែសញ្ញាប័ត្រប៉ុណ្ណោះ។ ពួកគាត់រៀនជាច្រើនក្រេឌីតនូវមុខវិជ្ជាដូចៗគ្នាដូចជា៖ភាសាវិទ្យា វេយ្យាករណ៍ បាលី សំស្ក្រឹត អក្សរខ្មែរបុរាណ សិលាចារឹក អក្សរសិល្ប៍...ដែលធ្វើឱ្យនិស្សិតយល់ថា រៀនហាក់ដដែលៗ និងស្មុគស្មាញ មិនគួរជាទីចាប់អារម្មណ៍ ព្រមទាំងមិនឆ្លើយតបទៅនឹងបរិបទសង្គម តម្រូវការសិក្សា និងជីវភាពរស់នៅជាក់ស្តែង។ ជាមួយគ្នានេះ កម្មវិធីសិក្សាកម្រិតឧត្តមសិក្សាក៏មិនស៊ីគ្នានឹងកម្រិតមធ្យមសិក្សាផងដែរដោយវាមិនផ្តោតលើអភិវឌ្ឍន៍បន្ថែមលើបំណិនទាំង៤ (ស្តាប់ និយាយ អាន និងសរសេរ)។ ជាទូទៅ យើងមិនឃើញមានដាក់បញ្ចូលមុខវិជ្ជាសំខាន់ៗដែលជួយអភិវឌ្ឍន៍កាន់តែខ្លាំងក្លាថែមទៀតលើសមត្ថភាពទាំង៤ខាងលើនេះដូចជា៖ គោលការណ៍គ្រឹះនៃការសរសេរ ស្តាប់ និងនិយាយ ការសរសេរ និងអានសម្រាប់គោលបំណងពិសេសផ្សេងៗ វិធីសាស្ត្រស្រាវជ្រាវភាសាខ្មែរ...ជាដើម។ ដូចគ្នានេះដែរ ការសិក្សាអក្សរសាស្ត្ររបស់ប្រទេសមួយចំនួនតួយ៉ាងដូចប្រទេសថៃឡង់ជាដើម គេដាក់បញ្ចូលមុខវិជ្ជាដែលមានលក្ខណៈស្មុគស្មាញ និងមិនប្រើប្រាស់ចាំបាច់ក្នុងជីវភាពរស់នៅជាក់ស្តែងនៅក្នុងមុខវិជ្ជាជម្រើសដូចជា៖ អក្សរបុរាណ បាលីសំស្ក្រឹត សិលា

ចារឹក...ពោលគឺសម្រាប់តែនិស្សិតជ្រើសរើសជំនាញឯកទេសលើមុខវិជ្ជាទាំងនេះតែប៉ុណ្ណោះ។ មួយវិញទៀត កត្តាដែលចូលរួមចំណែកធ្វើឱ្យនិស្សិតមិនសូវចាប់អារម្មណ៍សិក្សារៀនសូត្រថ្នាក់មហាវិទ្យាល័យគឺដោយសារចំណេះដឹងទាំងនោះមិនបានយកមកប្រើប្រាស់ក្នុងការប្រឡងប្រជែងការងារនានាឡើយ ដូចប្រឡងជ្រើសរើសគ្រូបង្រៀនជាដើម។ មួយវិញទៀត កម្មវិធីសិក្សារបស់យើងនេះ ជំរុញឱ្យនិស្សិតសូត្រតាមថាតាម និងរៀនសូត្រតែពីក្បួនខ្នាតដែលមានស្រាប់ ដែលតម្រូវឱ្យអនុវត្តតាមដោយមិនមានគតិបណ្ឌិតថ្មី ទស្សនវិជ្ជាថ្មី ឬសមត្ថភាពនៃការច្នៃបង្កើតថ្មីនោះទេ។ ពួកគេត្រូវបានបង្រៀនឱ្យទទួលយក ឬអភិរក្សនិយម ដែលមិនបង្កលក្ខណៈឱ្យនិស្សិតក្លាហានហ៊ានបង្កើតថ្មី ដើម្បីភាពរីកចម្រើនឡើយ។ ជាក់ស្តែងគ្រាន់តែខ្ញុំបញ្ចេញទស្សនៈយល់ឃើញថ្មីទាក់ទងនឹងអក្សរសាស្ត្រខ្មែរតែបន្តិចសោះត្រូវបានសង្គមបញ្ញវន្តដែលស្រឡាញ់អក្សរសាស្ត្ររិះគន់ និងវាយប្រហារយ៉ាងខ្លាំង។ ដូច្នេះបន្ទាប់ពីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញទៅចំណេះដឹងខ្ញុំត្រូវបានទុកចោលតែម្តង ព្រោះអ្វីៗដូនតាមានគ្រប់អស់ហើយ ។

## 7) ការសិក្សាពីចម្ងាយ

តាមការអង្កេតជាទូទៅ លោកគ្រូ អ្នកគ្រូយើងមិនទាន់ចេះប្រើប្រាស់ឱ្យអស់សក្តានុពលនៃបច្ចេកវិទ្យានៅឡើយ។ ការសិក្សាពីចម្ងាយ (E-learning) ជារបត់ថ្មីមួយដែលវាបត់លឿនពេកសម្រាប់គ្រូបង្រៀនយើង ហើយវាធ្វើឱ្យយើងរត់តាមវាមិនទាន់។ មកដល់ដំណាក់កាលនេះ វាពិតណាស់ យើងនៅមានបញ្ហាប្រឈមជាច្រើនទាក់ទងនឹងចំណេះដឹងនៃការប្រើប្រាស់បច្ចេកវិទ្យារៀន និងបង្រៀនពីចម្ងាយទាំងអស់នេះដោយសារមកពីកត្តាផ្សេងៗដូចជា កង្វះធនធានមនុស្ស ធនធានសម្ភារៈ និងថវិកាជាដើម។ ការសិក្សានៅសតវត្សរ៍ទី២១ ផ្តល់ភាពងាយស្រួលច្រើនដល់អ្នកសិក្សា

ក្នុងការទាក់ទងពីចម្ងាយ ក្នុងការស្វែងរកព័ត៌មាន ស្វែងរកដំណោះស្រាយបញ្ហានានាទាក់ទងនឹងចំណេះដឹង របៀប ឬវិធីសាស្ត្រក្នុងការធ្វើកិច្ចការអ្វីមួយដែលកំពុងជួបប្រទះ ការចែករំលែកចំណេះដឹង បទពិសោធ និងការសិក្សារៀនសូត្រដើម្បីបង្កើនចំណេះដឹងជាដើម។ អន្តរទំនាក់ទំនងទៅវិញទៅមក (two way communication) ជានិន្នាការ ឬការវិវត្តនៅក្នុងយុគសម័យថ្មី និងមានលក្ខណៈពេញនិយមបំផុតរបស់ពិភពលោកបច្ចុប្បន្ន ដែលប្រទេសយើងហាក់ដើរទាន់តែផ្នែកមួយចំនួនប៉ុណ្ណោះនៃបច្ចេកវិទ្យាទាំងនេះ។ ចំពោះការស្ដាប់វិទ្យុ មើលទូរទស្សន៍ មើលវីឌីអូ...ជាទំនាក់ទំនងបែបជាអ្នកទទួលព័ត៌មានតែប៉ុណ្ណោះ (one way communication) ព្រោះយើងមិនអាចបង្ហាញចេញនូវមតិយោបល់ ការយល់ឃើញ គំនិតប្រតិកម្មតប ព័ត៌មានត្រឡប់...របស់យើងត្រឡប់ទៅវិញចំពោះព័ត៌មាន ឬការផ្សព្វផ្សាយនោះ ដែលវាផ្ទុយស្រឡះពីបណ្ដាញទំនាក់ទំនងផ្សេងៗដូចជា facebook, Tik tok, telegram, whatup, instagram....ជាដើមដែលអាចដោះដូរមតិយោបល់គ្នាទៅវិញទៅមកបាន។ អាស្រ័យដោយធនធានយើងនៅមានកម្រិត ស្ថានភាពនៃការសិក្សាពីចម្ងាយរបស់យើងនៅពេលនេះ ភាគច្រើនមានលក្ខណៈជាទំនាក់ទំនងបែបចាំតែទទួលព័ត៌មាន ពោលគឺសិស្សអាចសិក្សារៀនសូត្របានពីការបង្ហោះវិឌីអូមេរៀន ការស្វែងរកធនធានឯកសារផ្សេងៗតែប៉ុណ្ណោះ ពោលគឺគ្មានទម្រង់ជាថ្នាក់រៀនពីចម្ងាយ ដែលសិស្ស និងគ្រូមានទំនាក់ទំនងគ្នាទៅវិញទៅមកនោះទេ លើកលែងសាលារៀនដែលមានលក្ខណៈស្តង់ដារខ្ពស់មួយចំនួនប៉ុណ្ណោះ។
សិស្សយើងភាគច្រើននៅមធ្យមសិក្សាមានកុំព្យូទ័រ និងចេះប្រើប្រាស់វាតិចតួចនៅឡើយ ទោះបីពួកគាត់ភាគច្រើនយល់ដឹងយ៉ាងទូលំទូលាយលើផ្នែកបណ្ដាញទំនាក់ទំនងសង្គម និងការលេងហ្គេមក៏ដោយ ដែលចំណេះដឹងទាំងនេះមិនមែនជាចំណេះដឹងសម្រាប់លើកកម្ពស់ការបង្រៀន និងរៀនឡើយ។ ការយល់ដឹងពីការប្រើប្រាស់ google classroom, google meet,

hangout, google doc, google form…សម្រាប់បម្រើដល់ការសិក្សារៀនសូត្រ ការបង្រៀន ក៏ដូចជាបង្កភាពងាយស្រួលក្នុងការធ្វើការងារឱ្យមានប្រសិទ្ធភាពនៅមានកម្រិតខ្លាំងណាស់ ដែលចំណេះដឹងទាំងនេះ តាមពិតទៅយើងអាចរៀនសូត្របានដោយងាយពីyoutubeសោះ។ Google classroom អាចឱ្យយើងបង្កើតថ្នាក់រៀនមួយ ដែលបង្កលក្ខណៈឱ្យសិស្សចូលរួមសិក្សារៀនសូត្របានងាយស្រួល ដោយគ្រូអាចដាក់កិច្ចការឱ្យសិស្សធ្វើ ផ្តល់ឯកសារមេរៀនពីប្រភពផ្សេងៗយ៉ាងសម្បូរបែបទាំងវិឌីអូ រូបភាពដាក់បញ្ចូលឯកសារមេរៀនធ្វើឱ្យសិស្ស ការទាញយកឯកសារពីគេហទំព័រណាមួយ ផ្តល់ព័ត៌មានត្រឡប់កែលម្អកិច្ចការសិស្ស ដាក់កិច្ចការផ្ទះ កែកិច្ចការសិស្ស ឱកាសនៃការសួរ និងឆ្លើយសំណួរផ្សេងៗ។ល។ យើងអាចបង្រៀនសិស្សដោយប្រើប្រាស់ google classroom រួមជាមួយនឹង Hangout ដែលប្រើប្រាស់ទំនាក់ទំនងជាសម្លេង វិឌីអូឆ្លងឆ្លើយរវាងសិស្សក្នុងថ្នាក់ទាំងមូល និងគ្រូ ព្រមទាំងធ្វើកិច្ចការផ្សេងៗជាច្រើនទៀតជាមួយគ្នា។ សម្រាប់ google doc មានទម្រង់ដូច Ms word ដែរតែវាផ្តល់ការអនុញ្ញាតឱ្យមនុស្សច្រើនគ្នាធ្វើការលើសន្លឹកកិច្ចការតែមួយរួមគ្នា ដំណាលគ្នាបាន ពីទីកន្លែងផ្សេងគ្នារួមទាំងបញ្ចេញមតិយោបល់ កែលម្អខ្លឹមសារ ការពិភាក្សាលើឯកសារនោះ....ដែលបង្កលក្ខណៈឱ្យធ្វើកិច្ចការបានលឿន និងស្រុះស្រួលគ្នា មិនបាច់ផ្ញើទៅផ្ញើមក។ ចំណែកឯ google form ប្រើប្រាស់សម្រាប់បង្កើតកម្រងសំណួរគ្រប់ប្រភេទ ដោយវាអាចកែដោយស្វ័យប្រវត្តិ និងអាចវិភាគចម្លើយសិស្សដោយស្វ័យប្រវត្តិ មិនលំបាកដល់គ្រូក្នុងការកែសន្លឹកកិច្ចការឡើយ។ សង្ឃឹមថា ចំណេះដឹងទាំងនេះ នឹងចូលរួមចំណែកការយល់ដឹងរបស់លោកគ្រូ អ្នកគ្រូទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាបង្រៀន និងរៀនពីចម្ងាយបានខ្លះ។ សម្រាប់ការយល់ដឹងបន្ថែម យើងស្រាវជ្រាវបានពីgoogle search engine ឬពីYoutube។

## 8) <u>*បញ្ហាប្រឈមមួយចំនួននៅកម្រិតសាលារៀន*</u>

ថ្វីត្បិតតែវាមិនមែនជាការស្រាវជ្រាវបែបវិទ្យាសាស្ត្រ តែវាត្រូវបាន រៀបចំឡើងផ្អែកតាមទិដ្ឋភាពពិតជ្រុងមួយនៃវិស័យអប់រំ ហើយចងក្រង ឡើងទុកជាទុនមួយសម្រាប់អ្នកអាន អ្នកសិក្សា និងអ្នកស្រាវជ្រាវផ្នែកអប់រំ សិក្សាស្វែងយល់ឱ្យបានទូលំទូលាយលើវិស័យនេះតាំងពីកម្រិតទាប ដល់ កម្រិតខ្ពស់។

ដើម្បីចូលរួមចំណែកដល់ការលើកកម្ពស់អប់រំនៅកម្ពុជា ក្រសួង អប់រំយុវជន និងកីឡាបានដាក់ចេញនូវប្រព័ន្ធអធិការកិច្ច ក្នុងការចុះតាម ដាន គុណភាពអប់រំនៅតាមសាលារៀនដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្វះខាតដែលត្រូវកែលម្អបន្ថែម ដើម្បីអភិវឌ្ឍន៍សាលារៀនឱ្យ ឈានទៅរកជាស្តង់ដារអប់រំជាតិ ប្រកបដោយគុណភាពខ្ពស់។ ការអធិការ កិច្ចគឺដើម្បីធ្វើការប្រមូលព័ត៌មាន និងទិន្នន័យសាលារៀន ជួបសម្ភាស ជាមួយនាយកសាលា នាយករង លោកគ្រូ អ្នកគ្រូ មាតាបិតាសិស្ស សហ គមន៍ និងសិស្សានុសិស្ស យកមកវិភាគរកឱ្យឃើញនូវចំណុចខ្លាំង និង ចំណុចត្រូវកែលម្អដើម្បីធ្វើឱ្យសលារៀនមួយនេះ មានការអភិវឌ្ឍកាន់តែ ខ្លាំងទៅថ្ងៃអនាគត។ ក្នុងការចុះយកព័ត៌មាននេះ មានការបែងចែកជាប្រាំ មួយជំណាក់កាល។ **ទីមួយ**សេចក្តីផ្តើម ធ្វើការបកស្រាយអំពីសាវតារប្រវត្តិ អធិការកិច្ចក្នុងវិស័យអប់រំ និងគោលបំណងអធិការកិច្ច។ **ទីពីរ** វិធីសាស្ត្រធ្វើ អធិការកិច្ចតាមរយៈការចុះដល់សាលាគោលដៅ និងការប្រមូលព័ត៌មាន ដែលពាក់ព័ន្ធ មានការសម្ភាសជាមួយគណៈគ្រប់គ្រងសលារៀន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មាតាបិតាសិស្ស និងអាណាព្យាបាលសិស្ស សហ គមន៍ និងគ្រប់អ្នកពាក់ព័ន្ធ ការសង្កេតសកម្មភាពបង្រៀនរបស់គ្រូ និងរៀន របស់សិស្ស។ **ទីបី**លទ្ធផលអធិការកិច្ច និងការពិភាក្សា មានតារាងសង្ខេប លទ្ធផលអធិការកិច្ច ការដឹកនាំ និងគ្រប់គ្រងក្នុងនោះមាន រចនាសម្ព័ន្ធចាត់ តាំង ប្រសិទ្ធភាពនៃ ការរៀបចំការងារ ធនធាន ការបង្រៀន និងរៀន បរិស្

ឋានសាលារៀន។ ការបង្រៀន និងរៀនមានបួនចំណុចតូចៗ ដូចជា៖ ការអនុវត្តកម្មវិធីសិក្សា គរុកោសល្យ និងវិធីសាស្ត្របង្រៀន បរិយាកាសថ្នាក់រៀន ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ លទ្ធផលសិក្សារបស់សិស្សមាន វឌ្ឍនភាពនៃលទ្ធផលសិក្សាសិស្ស កម្មវិធីគាំទ្រការសិក្សារបស់សិស្ស ការវាយតម្លៃ និងដាក់ពិន្ទុ។ ស្វ័យវាយតម្លៃសាលារៀនរួមមាន ប្រព័ន្ធ និងដំណើរការស្វ័យវាយតម្លៃសាលារៀន ផែនការអភិវឌ្ឍន៍សាលារៀន និងការសហការជាមួយអ្នកពាក់ព័ន្ធ។ **ទីបួន**ការវាយតម្លៃជារួមមានចំណុចខ្លាំង និងចំណុចត្រូវកែលម្អ។ ទីប្រាំ អនុសាសន៍សម្រាប់គណៈគ្រប់គ្រងសាលារៀន សម្រាប់គ្រូបង្រៀន សម្រាប់សហគមន៍ និងសម្រាប់អ្នកពាក់ព័ន្ធផ្សេងទៀត និងទីប្រាំមួយ គឺសេចក្តីសន្និដ្ឋាន និងឧបសម្ព័ន្ធ។ ជាលទ្ធផលចុងក្រោយរកឱ្យឃើញនូវគុណភាពអប់រំសម្រាប់អនុវត្តប្រកបដោយប្រសិទ្ធភាពដល់សិស្សានុសិស្ស និងអភិវឌ្ឍសមត្ថភាពគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ អ្នកពាក់ព័ន្ធផ្សេងៗ។

ជាបទពិសោធជាក់ស្តែង យើងប្រហែលជាពិបាកក្នុងការស្វែងរកព័ត៌មានជាក់លាក់ដើម្បីធ្វើការវិភាគ បើយើងប្រមូលព័ត៌មានមិនបានស៊ីជម្រៅជាមួយអ្នកពាក់ព័ន្ធនានា។ ការសម្ភាសគណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស មាតាបិតា អាណាព្យាបាលសិស្ស សហគមន៍... ដែលរៀបចំដោយគណៈគ្រប់គ្រងសាលា ពេលខ្លះមិនទទួលបានព័ត៌មានពិតទាំងស្រុង និងគ្រប់ជ្រុងជ្រោយទេ។ ដូច្នេះ ការសម្ភាសបន្ថែមដោយចៃដន្យ និងការអង្កេតជាទូទៅ ជារឿងចាំបាច់ដើម្បីទទួលបានព័ត៌មានទូលំទូលាយបន្ថែម ងាយស្រួលក្នុងការវិភាគ ពិសេសការស្វែងរកចំណុចដែលគួរកែលម្អ។ អធិការកិច្ចជាប្រព័ន្ធនាពេលបច្ចុប្បន្ននេះ ដើរតួជាអ្នកប្រឹក្សា ផ្តល់មតិយោបល់ និងជួយគាំទ្រជាជាងការចាប់តែកំហុស ពោលគឺធ្វើយ៉ាងណាដើម្បីឱ្យសាលារៀនមានការកែលម្អប្រសើរឡើង។ ខាងក្រោមនេះគឺជា

អ្វីដែលបានរកឃើញទាក់ទងនឹង ការដឹកនាំ និងគ្រប់គ្រង ការបង្រៀន និងរៀន លទ្ធផលសិក្សាសិស្ស និងស្វ័យវាយតម្លៃសាលារៀន សម្រាប់ប្រើប្រាស់ក្នុងការសិក្សាស្វែងយល់ ដោយលើកយកតែការវិភាគពីបញ្ហាប្រឈមកម្រិតសាលារៀនតែប៉ុណ្ណោះ មិនមានដាក់បញ្ចូលផ្នែកផ្សេងទៀតដូចក្នុងរបាយការណ៍ទេដូចជា៖ ចំណុចខ្លាំង មេរៀនរៀនសូត្រ អនុសាសន៍...ជាដើម។ យើងប្រកាន់គោលជំហនៃការរក្សាការសម្ងាត់ព័ត៌មានរបស់សាលារៀន និងអ្នកពាក់ព័ន្ធ ដោយមិនបានបង្ហាញអត្តសញ្ញាណ ដោយគ្រាន់តែដកស្រង់ចំណុចសំខាន់សម្រាប់ទុកជាការចែករំលែកចំណេះដឹង បទពិសោធ និងមេរៀនរៀនសូត្រជាទូទៅសម្រាប់បម្រើដល់ផលប្រយោជន៍នៃការកែលម្អគុណភាពអប់រំនៅកម្ពុជា។ គោលបំណងចម្បងនៃការបង្ហាញនេះ គឺដើម្បីទុកជាទស្សនទានសម្រាប់អ្នកអាន-អ្នកសិក្សាសម្រាប់ត្រិះរិះពិចារណា និងសិក្សាស្វែងយល់តែប៉ុណ្ណោះ មិនមានចេទនាវាយប្រហារ និងបន្តុះបង្អាប់ប្រព័ន្ធមួយឡើយ។ យើងប្រើប្រាស់បញ្ហាប្រឈមដែលរកឃើញនេះ ដើម្បីសាកល្បងធ្វើការសិក្សាពីកម្រិតសាលារៀនមួយ ទៅធ្វើការឆ្លុះបញ្ចាំងកម្រិតប្រព័ន្ធទាំងមូល។ សូមបញ្ជាក់ថា ឯកសារនេះមិនមែនបានធ្វើការវាយតម្លៃជាទូទៅទៅលើស្ថានភាពអប់រំនៅទូទាំងប្រទេសនោះទេ តែយើងក៏ជឿជាក់ដែរថា បញ្ហាទាំងនេះក៏អាចកើតមាននៅតាមសាលារៀនទីតាំងផ្សេងៗទៀតផងដែរ។ វាមិនទាន់ជាឯកសារស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រគ្រប់ជ្រុងជ្រោយនោះទេ ដោយគ្រាន់តែឯកសារសាកល្បងសិក្សាមួយប៉ុណ្ណោះ។ ដោយសារប្រទេសយើង ការសិក្សាស្រាវជ្រាវនៅមានកម្រិតនៅឡើយ ដូច្នេះការចងក្រងឯកសារនេះគឺដើម្បីជាវិភាគទាន និងសម្មតិកម្មចូលរួមចំណែកផ្នែកស្រាវជ្រាវ។ ជាមួយគ្នានេះ យើងក៏មិនចង់ឃើញការប្រតិកម្មតបពីបញ្ហាខាងក្រោម ដោយចូលចិត្តលើកជាយោបល់ដដែលៗថា " **បញ្ហាកើតឡើងនៅឯណា? សាលារៀនណា គ្រូណាដែលធ្វើប្រព្រឹត្តបែបនេះ បង្ហាញឱ្យចំៗមកងាយស្រួលគេដោះស្រាយ**" និងទម្លាក់

កំហុសទៅលើអ្នកដែលរកឃើញបញ្ហានោះទៅវិញ។ ខ្ញុំគិតថាពាក្យទាំងនេះហួសសម័យហើយ។ វាដល់ពេលហើយ ដែលយើងគប្បីបើកចំហបេះដូងទទួលស្គាល់ការពិតមួយចំនួន និងត្រូវចូលរួមចំណែកទាំងអស់គ្នាដោះស្រាយវា ប្រកបដោយស្មារតីទទួលខុសត្រូវ។ ការបកស្រាយខាងក្រោម ត្រូវបានបែងចែកជាផ្នែកៗ (**ទី១**) ឆ្លុះបញ្ចាំងបញ្ហាប្រឈមតាមរយៈរបាយការណ៍អធិការកិច្ច និង (**ទី២**) តាមរយៈការសង្កេតជាទូទៅលើប្រព័ន្ធអប់រំក្នុងអាជីពជាគ្រូបង្រៀន គ្រូឧទ្ទេស និងអ្នកកាន់កម្មវិធីអប់រំអង្គការជាតិ និងអន្តរជាតិរយៈពេល១៥ឆ្នាំកន្លងមកនេះ និងព័ត៌មានពីប្រភពឯកសារផ្សេងៗ។

តាមរយៈព័ត៌មានដែលទទួលបានពីការចុះអធិការកិច្ច យើងធ្វើការបកស្រាយពីបញ្ហាប្រឈមជាលក្ខណៈទូទៅ ដោយបែងចែកជា៤ផ្នែកៈ **ការដឹកនាំ និងគ្រប់គ្រង ការបង្រៀន និងរៀន លទ្ធផលសិក្សាសិស្ស និងស្វ័យវាយតម្លៃសាលារៀន**។ ជាការពិត របាយការណ៍រកឃើញជាក់ស្តែង មិនមានការបកស្រាយចំៗបែបនេះនោះទេ ដោយយើងបានសម្រួលខ្លឹមសារឱ្យមានភាពវិជ្ជមានច្រើនតាមលក្ខណៈជំនាញវិជ្ជាជីវៈត្រឹមត្រូវ ដើម្បីឱ្យភាគីពាក់ព័ន្ធទាំងអស់អាចទទួលយកបាន និងមានអារម្មណ៍កក់ក្តៅសម្រាប់ដំណើរការកែលម្អសាលារៀន។ ជាការពិត វាមិនមានប្រយោជន៍ទេ ដែលយើងលើកយកបញ្ហាទាំងអស់ដែលបានរកឃើញមកប្រឹក្សាជាមួយពួកគាត់ ហើយអ្វីដែលគួរធ្វើការថ្លឹងថ្លែងដោយប្រើទស្សនវិជ្ជាអប់រំ និងលើកទឹកចិត្តគាត់ តាមរយៈការបង្ហាញចំណុចខ្លាំងឱ្យបានច្រើន និងច្បិចយកតែបញ្ហាប្រឈមជាអាទិភាពតែប៉ុណ្ណោះ។ យើងមិនអាចកែលម្អបញ្ហាប្រឈមម្តងទាំងអស់បានទេ។ ប៉ុន្តែសម្រាប់ការបកស្រាយខាងក្រោម យើងលើកយកបញ្ហាទាំងអស់យកមកដាក់លើតុតែម្តងដោយប្រើភាសាស្មោះត្រង់ជាមួយ

គ្នា បង្ហាញការពិតសម្រាប់ត្រិះរិះពិចារណារៀនសូត្រ ពោលគឺអេះឱ្យចំរមាស់តែម្តង និងចាប់ផ្តើមធ្វើរោគវិនិច្ឆ័យ រួចព្យាបាលវា។

### *ក. ការដឹកនាំ និងគ្រប់គ្រង*

ជាទូទៅ យើងឃើញថា សាលារៀនមានបំណែងចែកតួនាទី ភារកិច្ច និងការទទួលខុសត្រូវបុគ្គលិក និងគណៈគ្រប់គ្រងសាលា ព្រមទាំងគណៈកម្មការ ក្រុមប្រឹក្សានានា...បានត្រឹមត្រូវច្បាស់លាស់តែនៅលើក្រដាស តែការអនុវត្តជាក់ស្តែង នៅមានបញ្ហាប្រឈមច្រើន។ តាមរយៈសម្ភាសអ្នកពាក់ព័ន្ធ (គណៈគ្រប់គ្រងសាលា គ្រូបង្រៀន សិស្សានុសិស្ស មាតាបិតាអាណាព្យាបាលសិស្ស សហគមន៍...) និងការសង្កេតជាទូទៅ យើងឃើញថា ការអនុវត្តតាមតួនាទី និងភារកិច្ចដូចមានចែង មិនបានត្រឹមត្រូវ មានលក្ខណៈប្របូកប្រល់គ្នា និងមិនដាច់ស្រាច់ ព្រមទាំងមានការរំលោភបំពានដែនសមត្ថកិច្ចគ្នាទៅវិញទៅមក។ ការដឹកនាំ និងគ្រប់គ្រងមិនមានលក្ខណៈតម្លាភាព គណនេយ្យភាព ការចូលរួម...ដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ ភាពច្រណែន និងការបែកបាក់សាមគ្គីភាពផ្ទៃក្នុងជួរ គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន។ ស្ថានភាពបែបនេះ យើងអាចមើលតាមរយៈភាពអសកម្មរបស់គណៈគ្រប់គ្រងសាលា (នាយក នាយករង) និងការបំពេញការងារមិនស្មើដៃគ្នាដើម្បីសម្រេចលទ្ធផលការងារ ក្នុងនោះ អ្នកទទួលបានផលប្រយោជន៍ច្រើន មានការប្រឹងប្រែង និងយកចិត្តទុកដាក់ធ្វើការខ្លាំង ហើយអ្នកខ្លះទៀតដែលទទួលបានផលប្រយោជន៍តិចតួច ក៏ប្រឹងប្រែងការងារទៅតាមទំហំផលប្រយោជន៍នឹងទៅ ដោយមិនផ្តោតទៅលើគោលដៅរួមនៃការអប់រំទេ។ ដោយសារបញ្ហានេះ ធ្វើឱ្យពួកគេផ្តោតតែទៅលើផលប្រយោជន៍ពោរពេញទៅដោយភាពអាត្មានិយម និងអត្តទត្ថភាព ប៉ះពាល់យ៉ាងខ្លាំងទៅលើកិច្ចសហការ និងទំនាក់ទំនងក្នុងការបំពេញ

ការងារ។ បើនិយាយឱ្យងាយស្រួលយល់គឺ "**នាយក និងនាយករង ព្រមទាំងលោកគ្រូ-អ្នកមួយចំនួន មិនសូវត្រូវគ្នាទេ**"។ ករណីខ្លះ វានាំទៅរកការបែងចែកបក្សពួកនៅក្នុងសាលារៀន (បក្សពួកនាយកផ្សេង និងបក្សពួកនាយករងផ្សេង) ខ្លះអង្គុយចាំចាប់តែកំហុសគ្នា និងមើលបំណាំគ្នា ដែលស្ថានភាពនេះរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍សាលារៀនយ៉ាងខ្លាំង។

សម្រាប់ការធ្វើបំណែងចែកភារកិច្ចបុគ្គលិក លោកគ្រូ-អ្នកគ្រូមួយចំនួនបង្ហាញការមិនពេញចិត្តនឹងការបែងចែកនេះទាក់ទងនឹងចំនួនម៉ោងថ្នាក់រៀន និងរៀបចំកាលវិភាគបំពេញការងារ។ គ្រូខ្លះមានម៉ោងបង្រៀនតិច ឬកាលវិភាគបង្រៀនមានចំនួនថ្ងៃតិច ដើម្បីបង្កភាពងាយស្រួលដល់គាត់ក្នុងការបង្រៀននៅសាលាឯកជន ឬធ្វើការងារទី២ផ្សេងទៀត។ គ្រូខ្លះទៀតលាក់ឈ្មោះមិនបានមកបង្រៀនទេ ពេលគឺចេញធ្វើការងារក្រៅតែម្តង ហើយយូរៗម្តងមកបង្ហាញខ្លួននៅសាលា។ ចំណែកឯ ខ្លះទៀតចង់បានថ្នាក់រៀនដែលមានសិស្សល្អៗដើម្បីងាយស្រួលរកលុយពីការបង្រៀនគួរក្រៅម៉ោង។ បើយើងសង្កេតជាទូទៅ យើងឃើញថា ដំណើរការអប់រំហាក់ផ្តោតតែលើផលប្រយោជន៍រៀងៗខ្លួន បើអ្នកចង់បានថ្នាក់រៀនល្អ ដើម្បីបានការបង្រៀនគួរក្រៅម៉ោង មិនចង់មកសាលាដោយសារជាប់ធ្វើការងារក្រៅ ឬចង់បានម៉ោងបង្រៀនតិច...គឺត្រូវសូកប៉ាន់ ឬផ្តល់ផលប្រយោជន៍ឱ្យទៅថ្នាក់ដឹកនាំសាលា។ សកម្មភាពទាំងនោះ នាំការអប់រំទៅរកការប្រកួតប្រជែងអាជីវកម្ម ស្វែងរកផលប្រយោជន៍ និងប្រាសចាកគោលដៅអប់រំ។ ជាមួយគ្នានេះ ការអនុវត្តបែបនេះ ក៏ផ្តល់ភាពចំណេញដល់គណៈគ្រប់គ្រងសាលាវិញដែរ គឺមិនសូវមានអ្នករំខានច្រើនដល់សកម្មភាពនៃការប្រើប្រាស់កញ្ចប់ថវិកា PB ដែលធ្វើផ្តល់ភាពងាយស្រួលច្រើនដល់ពួកគាត់ក្នុងការធ្វើអ្វីបានតាមចិត្ត។ មួយវិញទៀត យើងក៏រកឃើញផងដែរពីបញ្ហានិយ័តភាពរបស់គ្រូបង្រៀន។ បើតាមសម្ភាសជាមួយសិស្ស ពួកគាត់បានលើកឡើងពី

ការអវត្តមានច្រើន និងការបង្រៀនមិនបានទៀងទាត់របស់គ្រូមួយចំនួន ហើយម៉ោងកាយសិក្សាគ្រូមិនសូវបានហ្វឹកហាត់ទេ ជួនកាលគ្រូប្រមូលលុយដើម្បីដាក់ពិន្ទុសម្រាប់មុខវិជ្ជានេះតែម្តង។ ទំនាក់ទំនងរវាងគ្រូ និងគ្រូ ព្រមទាំងគ្រូ និងគណៈគ្រប់គ្រងមានបញ្ហាច្រើន ហើយការធ្វើការរួមគ្នាហាក់នៅមានកម្រិត ព្រោះពួកគាត់រវល់ច្រើននឹងការងាររកប្រាក់ចំណូលបន្ថែមខាងក្រៅ។ ការប្រជុំក្រុមបច្ចេកទេសរបស់ក្រុមមួយចំនួន គ្រាន់តែជាការសម្តែងឆាកល្ខោន មិនបានដាក់ចេញបញ្ហាប្រឈមដាក់ស្តែង និងដោះស្រាយបញ្ហាទាំងនោះរួមគ្នា ចែករំលែក និងរៀនសូត្រពីគ្នាទៅវិញទៅមក ដើម្បីអភិវឌ្ឍន៍បំណិនវិជ្ជាជីវៈទេ។ ពេលខ្លះ វាគ្រាន់តែជាការជួបជុំ និងរួមគ្នាប្រឌិតកំណត់ហេតុឡើង ឬកំណត់របៀបវារៈដដែលៗ ដោយមិនផ្តោតលើអ្វីដែលជាបញ្ហាប្រឈមចាំបាច់ ចំណែកឯការពិភាក្សាដ៏មានប្រយោជន៍មិនសូវផុលផុសអីទេ។ យើងអាចវិភាគបញ្ហានេះ បានតាមរយៈការពិនិត្យមើលកំណត់ហេតុប្រជុំក្រុមបច្ចេកទេស និងសំណុំឯកសារមួយចំនួន ព្រមទាំងវិភាគលើចម្លើយលម្អិតស្តីពីដំណើរការរៀបចំការប្រជុំក្រុមបច្ចេកទេស

មួយវិញទៀត យើងឃើញសាលាបានរៀបចំផែនការបានល្អទាក់ទងនឹងការចុះធ្វើអធិការកិច្ចតាមថ្នាក់រៀន ដែលតម្រូវឱ្យគណៈគ្រប់គ្រងសាលា និងប្រធានក្រុមបច្ចេកទេសចុះ អធិការកិច្ចយ៉ាងទៀងទាត់តាមកាលកំណត់ តែការអនុវត្តបានតិចតួចណាស់ ដែលយើងឃើញបញ្ហាប្រឈមច្រើនទាក់ទងនឹងវិធីសាស្ត្របង្រៀន និងការរៀបចំរដ្ឋបាល និងបរិស្ថានថ្នាក់រៀនជាដើម។

ជាមួយគ្នានេះ យើងក៏រកឃើញផងដែរថា សាលារៀនខ្វះសម្ភារឧបទេសសម្រាប់ការបង្រៀន និងរៀន ពិសេសសម្រាប់មុខវិជ្ជាវិទ្យាសាស្រ្ត។ វិទ្យាល័យនេះ មិនមានសម្ភារពិសោធន៍ និងបន្ទប់ពិសោធន៍ទេ ។ ជាមួយគ្នានេះ ទោះបីមានសម្ភាសឧបទេសតិចតួចសម្រាប់មុខវិជ្ជាវិទ្យាសា

ស្ត្រ ក៏មានសម្ភារឧបទេសមួយចំនួនសម្រាប់មុខវិជ្ជាផងទៃដែរ តែគ្រូមួយចំនួនមិនសូវយកទៅប្រើប្រាស់ព្រោះខ្លាចខូច ហើយសម្ភារៈខ្លះមិនចេះប្រើប្រាស់។ ព្រមជាមួយនឹងកង្វះបន្ទប់ពិសោធន៍ សាលាក៏នៅមានបញ្ហាប្រឈមផងដែរទាក់ទងបន្ទប់ពហុមេឌារ និងកុំព្យូទ័រសម្រាប់សិស្សអនុវត្ត ដោយសាលាមានកុំព្យូទ័រតិច ដែលផ្តល់ការលំបាកខ្លាំងដល់ការបង្ហាត់បង្រៀនសិស្សទាក់ទងនឹងចំណេះដឹងICT។

## *ខ. ការបង្រៀន និងរៀន*

ការប្រើប្រាស់គរុកោសល្យ និងវិធីសាស្ត្របង្រៀន ជាចំណុចមួយដែលសាលា ត្រូវយកចិត្តទុកដាក់បន្ថែម ដោយសារមានការត្អូញត្អែរពីសិស្ស ទាក់ទងនឹងការយកចិត្តទុកដាក់របស់គ្រូក្នុងការបង្រៀននៅក្នុងម៉ោងសិក្សារដ្ឋ។ តាមរយៈការសម្ភាស បញ្ជាក់ថា គ្រូមួយចំនួនយកចិត្តទុកដាក់ខ្លាំងលើថ្នាក់ម៉ោងរៀនគួរច្រើនជាងម៉ោងរដ្ឋ ហើយសិស្សមួយចំនួន ផ្តល់យោបល់ អវិជ្ជមានទាក់ទងនឹងការចេញវិញ្ញាសាប្រឡងប្រចាំខែ និងប្រចាំឆមាសដែលប្រហាក់ប្រហែលនឹងលំហាត់ ឬសំណួរដែលបានរៀនគួររួចហើយ ដែលករណីនេះ វានាំទៅរកការបាក់ទឹកចិត្តសម្រាប់សិស្សដែលមិនមានលទ្ធភាពរៀនគួរបន្ថែមក្រៅម៉ោង។ មួយវិញទៀត តាមរយៈការសង្កេត យើងឃើញថា នៅតាមថ្នាក់រៀនភាគច្រើន មិនមានបិទតារាងទាំង ៩ ឱ្យបានគ្រប់ទេ ខ្លះដាច់រយីរយាក ហើយការប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀន និងរៀនមិនសូវផុលផុសនៅឡើយទេ ពិសេសមុខវិជ្ជា វិទ្យាសាស្ត្រ ហើយជារួម សិស្សខ្សោយមុខវិជ្ជានេះ។ ទាក់ទងនឹងបញ្ហាសិស្សខ្សោយ សាលាហាក់មិនមានផែនការ និងសកម្មភាពផុលផុសក្នុងការជួយសិស្សរៀនយឺតឡើយ។ ជាមួយគ្នានេះ ការប្រមូលលុយថ្លៃក្រដាសប្រឡងប្រចាំខែនៅតែមាន ហើយការចំណាយរបស់សិស្សទៅលើគ្រូលើមុខវិជ្ជាមួយចំនួនក៏

មានផង ពិសេសមុខវិជ្ជាកាយសិក្សាជាដើម។ បញ្ហានេះ កើតឡើងដោយសារកង្វះប្រព័ន្ធអធិការកិច្ចផ្ទៃក្នុងឱ្យបានទៀងទាត់។

### គ.លទ្ធផលសិក្សារបស់សិស្ស

តាមរយៈការសម្ភាស យើងរកឃើញថា គ្រូបង្រៀនភាគច្រើនមានការយល់ដឹងពីច្បាប់អប់រំ គោលនយោបាយអប់រំ និងឯកសារគតិយុត្តិនៅតិចតួចបំផុត ។ ពួកគាត់ភាគច្រើនមិនសូវចាប់អារម្មណ៍ស្វែងយល់ពីឯកសារទាំងនោះទេ ដែលករណីនេះ គណៈគ្រប់គ្រងសាលា គប្បីរៀបចំផ្សព្វផ្សាយឱ្យបានទូលំទូលាយថែមទៀត។ ការវាយតម្លៃ និងការដាក់ពិន្ទុសិស្ស ធ្វើឡើង មិនទាន់សុក្រឹតនៅឡើយទេ ដោយសារមានការត្អូញត្អែរច្រើនពីសិស្សទាក់ទងនឹងភាពលំអៀងក្នុងការដាក់ពិន្ទុ រវាងសិស្សរៀនគួរ និងមិនបានរៀនគួរ។ មួយវិញទៀត សិស្សមានឱកាសតិចតួចក្នុងការតវ៉ាពិន្ទុនិង មើលពីកំហុសឆ្គងរបស់ពួកគេ ហើយការវាយតម្លៃនោះសោតផ្តោតតែមួយជ្រុងប៉ុណ្ណោះគឺ ប្រឡងប្រចាំខែ ដោយសរសេរ ឬសួរផ្ទាល់មាត់។ ជាទូទៅ គ្រូបង្រៀនដាក់កិច្ចការផ្ទះឱ្យសិស្សអនុវត្ត និងកែកិច្ចការតិចតួចបំផុត ។ ចំណុចទាំងអស់ខាងលើនេះ ទាមទារឱ្យគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ-អ្នកគ្រូ ទាំងសហការគ្នាកែលម្អ ដើម្បីជំរុញលើកទឹកចិត្តសិស្សឱ្យសម្រេចលទ្ធផលសិក្សាបន្ថែមទៀត។

### ឃ. ស្វ័យវាយតម្លៃសាលារៀន

តាមរយៈនៃការសម្ភាស រកឃើញថា ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃគុណភាពការងារ ដែលអនុវត្តតាមរយៈគណៈនាយក និងប្រធានក្រុមបច្ចេកទេស បានអនុវត្តនៅតិចតួចនៅឡើយ និងមិនទាន់ឆ្លើយតបទៅនឹងផែនការអធិការកិច្ចដែលបានកំណត់។ សាលារៀនមិនបានអនុវត្តស្វ័យ

វាយតម្លៃសាលារៀនឱ្យបានទៀងទាត់ ហើយផែនការភាគច្រើនរៀបចំឡើង ដោយគណៈគ្រប់គ្រងសាលាតែប៉ុណ្ណោះ។

## 9) *ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន*

រាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់ខ្លាំងក្នុងការធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍសាលារៀនតាមរយៈការបង្កើនថវិកាពីមួយឆ្នាំទៅមួយឆ្នាំ។សម្រាប់រយៈពេល៥ឆ្នាំចុងក្រោយនេះ ថវិកាសម្រាប់វិស័យបានកើនឡើងជាគំហុកពី១.៧៧%នៃផសស (GDP) ក្នុងឆ្នាំ២០១៣ ដល់៣.០៨%ក្នុងឆ្នាំ២០១៧ និងបន្តកើនឡើងបន្ថែមទៀតនៅ ឆ្នាំ២០១៨ ដែលផ្តោតលើគ្រូបង្រៀន និងសាលារៀន។ ស្របនឹងការវិនិយោគថវិកាដ៏ច្រើននេះ ការរៀបចំផែនការអភិវឌ្ឍសាលារៀននីមួយៗ ដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកធ្វើឱ្យប្រសើរឡើងនូវការអប់រំ ក្នុងបរិបទការអប់រំប្រកបដោយបរិយាប័ន្ន។ ផែនការអភិវឌ្ឍសាលារៀនជាផែនទីបង្ហាញផ្លូវដែលរៀបចំឡើងដើម្បីធ្វើការផ្លាស់ប្តូរ កែលម្អធ្វើប្រសើរឡើងនូវលទ្ធផលសិក្សារបស់សិស្ស ឆ្លើយតបទៅនឹងទស្សនវិស័យ និងបេសកកម្មរបស់សាលារៀន។ ផែនការអភិវឌ្ឍសាលារៀនបានរួមបញ្ចូលនូវព័ត៌មានសំខាន់ៗទាក់ទងនឹងប្រវត្តិសាលារៀន សហគមន៍ ការវិភាគតម្រូវការ និងតម្រូវការ គោលដៅ គោលបំណង ស្តង់ដារ និងចំណុចដៅ ផែនការអនុវត្ត (Implementation work plan) ផែនការប្រតិបត្តិ (Operational plan) ផែនការតាមដានត្រួតពិនិត្យ និងវាយតម្លៃ (M&E plan) ផែនការទំនាក់ទំនង និងការស្វែងរកការគាំទ្រ (Communication and advocacy plan)...។ជាទូទៅផែនការអភិវឌ្ឍសាលារៀននៅប្រទេសកម្ពុជាត្រូវបានរៀបចំមួយឆ្នាំម្តង និងមិនមានរៀបចំផែនការយុទ្ធសាស្រ្ត (Strategic plan)សម្រាប់កម្រិតសាលារៀនទេ។ **ផែនការអភិវឌ្ឍសាលារៀន ខុសពីផែនការការងារប្រចាំឆ្នាំរបស់សាលារៀន**[៦៩]។ មុននឹងធ្វើការបកស្រាយពី

ផែនការអភិវឌ្ឍសាលារៀន យើងសូមលើកយកការធ្វើផែនការការងារសាលារៀនមកបង្ហាញជាមុនសិនដើម្បី ជៀសវាងការច្រឡំគ្នា។ ផែនការការងារប្រចាំឆ្នាំត្រូវបានរៀបចំដើម្បីជៀសវាងនូវការងារជាន់គ្នាដដែលៗ កង្វះការទទួលខុសត្រូវច្បាស់លាស់ និងដើម្បី ឱ្យមានគំនិតត្រៀមទុកជាមុនក្នុងការអនុវត្តសកម្មភាព។ ការងារដដែលៗនោះមានដូចជា៖ ការផ្សព្វផ្សាយឱ្យមាតាបិតានាំកូនទៅចុះឈ្មោះចូលរៀន ការចុះឈ្មោះទទួលសិស្សថ្មី និងសិស្សចាស់ ការបែងចែកសិស្សទៅតាមថ្នាក់ ការធ្វើពលកម្មសម្អាតថ្នាក់ និងសាលារៀន ការរៀបចំ និងបើកបវេសនកាល ការធ្វើរបាយការណ៍បវេសនកាល ឆមាស ប្រចាំឆ្នាំ ។ល។ សកម្មភាពនានារបស់សាលារៀនអាចបែងចែកជា៥ប្រភេទ៖

- **រដ្ឋបាលសាលារៀនៈ** ការប្រែក្លាយឱ្យទៅជាជាក់ស្តែងនូវវត្ថុបំណង គោលនយោបាយអប់រំជាតិ ការទទួលសិស្សថ្មីឱ្យចូលរៀន ការលើកផែនការសកម្មភាពធម្មតារបស់សាលារៀន ការរៀបចំគម្រោងកែលម្អសាលារៀន ការប្រមូលទិន្នន័យ ការសរសេររបាយការណ៍។ល។
- **សម្ភាររូបវន្តសាលារៀនៈ** ការរៀបចំថ្នាក់រៀន ការជុសជុលតូចតាច ការទទួល និងបែងចែកសៀវភៅសិក្សា ការរៀបចំសម្ភារឧបទេស សម្ភារៈបង្រៀន និងបណ្ណាល័យ ការរៀបចំឱ្យមានប្រភពទឹកស្អាត និងអនាម័យការរៀបចំទីលានកីឡា កិច្ចការពារបរិស្ថានសាលារៀន។ល។
- **ការសិក្សារបស់សិស្សៈ** ការរៀបចំផែនការបែងចែក និងអនុវត្តកម្មវិធីសិក្សា ប្រចាំ ឆមាស ប្រចាំខែ ការរៀបចំប្រជុំក្រុមបច្ចេកទេស ការអភិវឌ្ឍវត្ថុបំណងជាក់លាក់ និងការធ្វើកិច្ចតែង

ការបង្រៀន សកម្មភាពអភិវឌ្ឍសមត្ថភាពសិស្ស ការតាមដានការរីកចម្រើនរបស់សិស្ស ការវាយតម្លៃ ។ល។

- **សកម្មភាពសិស្ស:** គម្រោង និងសកម្មភាពរបស់សិស្សម្នាក់ៗ ការប្រកួតកីឡាសិស្ស សកម្មភាពសិល្បៈ ហត្ថកម្ម ថែទាំសួនច្បារសាលារៀន ការធ្វើដំណើរកំសាន្ត និងទស្សនកិច្ចសិក្សា សុខភាព និងអនាម័យសិក្សា ការចូលរួមការពារបរិស្ថាន ។ល។
- **ការទ្រទ្រង់សាលារៀន:** ជាការងារដែលទាក់ទងនឹងយុទ្ធនាការប្រមូលសិស្សឱ្យចូលរៀនដោយសហការជាមួយគណៈកម្មការទ្រទ្រង់សាលារៀន ឬសមាគមន៍មាតាបិតាសិស្ស ការរៀបចំចាត់ចែងពិធីកំសាន្តសប្បាយផ្សេងៗរបស់សាលារៀន ការគ្រប់គ្រងថវិកាសាលារៀន ការចុះបញ្ជីគណនេយ្យ។ល។

ផែនការអភិវឌ្ឍសាលារៀន ជាគម្រោងដែលខុសពីការងារធម្មតា ពីព្រោះការងារធម្មតាអនុវត្តស្រដៀងៗគ្នាជារៀងរាល់ថ្ងៃដោយគ្រាន់តែផ្លាស់ប្តូរបន្តិចបន្តួចប៉ុណ្ណោះ ចំណែកឯគម្រោងវិញគឺត្រូវសម្រេចលទ្ធផលជាក់ស្តែងដែលអាចមើលឃើញ ឬផ្ទៀងផ្ទាត់បាន។ លទ្ធផលរបស់គម្រោងអាចឱ្យយើងយកទៅប្រើប្រាស់បាន នៅក្នុងរយៈពេលមួយកំណត់គឺក្នុងករណីនេះហើយដែលគម្រោងមិនអាចធ្វើឡើងដដែលៗនោះទេ។ មានន័យថា ក្រោយពី អនុវត្តគម្រោងមួយចប់ហើយ យើងត្រូវតែរៀបចំ និងដំណើរការគម្រោងមួយថ្មីផ្សេងទៀត។ ការអនុវត្តនានានៅក្នុងគម្រោងចាស់ នឹងផ្តល់នូវបទពិសោធន៍នានាសម្រាប់គម្រោងថ្មី ។ ឧទាហរណ៍ គម្រោងលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ការកសាងអគារសិក្សា កែលម្អទិដ្ឋភាពសាលារៀនដើម្បីឱ្យបរិស្ថានល្អ មានទីលានកីឡា ទឹកស្អាត និងសួនច្បារ ការកែលម្អវិធីសាស្ត្រ និងសម្ភារឧបទេសបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ លើកកម្ពស់លទ្ធផលសិក្សាសិស្សដើម្បីឱ្យមានការកើនឡើងនូវចំនួនសិស្សទទួលនិទ្ទេសល្អពេលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ...

។ល។ សូមបញ្ជាក់ថាឧទាហរណ៍គម្រោងលើកកម្ពស់សមត្ថភាពគ្រូបង្រៀន អាចធ្វើឱ្យយើងមានការច្រឡំថាវាជាការងារដែលធ្វើដដែលៗព្រោះវាមាន នៅក្នុងការប្រជុំបច្ចេកទេស ដែលបានរៀបចំនៅក្នុងផែនការការងារប្រចាំឆ្នាំដែរ។ គម្រោងលើកកម្ពស់សមត្ថភាពគ្រូបង្រៀននេះ មានលក្ខណៈច្បាស់លាស់ជាងហើយការប្រជុំបច្ចេកទេសអាចជាផ្នែកមួយនៃការលើកកម្ពស់សមត្ថភាពប៉ុណ្ណោះ។ ជាឧទាហរណ៍គម្រោងលើកកម្ពស់សមត្ថភាពគ្រូបង្រៀននេះ អាចជាការលើកគម្រោងស្នើសុំកញ្ចប់ថវិកាដើម្បីឱ្យគ្រូទទួលបានវគ្គបណ្តុះបណ្តាលជំនាញអ្វីមួយជាក់លាក់ ស្ថិតក្នុងពេលមួយកំណត់ដែលចាំបាច់សម្រាប់អភិវឌ្ឍន៍សមត្ថភាព និងដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់សិស្ស ឬអាចជាគម្រោងស្វែងរកមូលនិធិនានាគាំទ្រដល់ការបន្តការសិក្សារបស់គ្រូបង្រៀន។គម្រោងនេះ មិនមែនធ្វើដដែលៗនោះទេ នៅពេលសមត្ថភាពគ្រូបង្រៀនមានការរីកចម្រើនហើយយើងអាចលើកគម្រោងផ្សេងទៀតដើម្បី ឆ្លើយតបទៅនឹងតម្រូវការចាំបាច់ដើម្បីលើកឧត្តមភាព និងកិត្យានុភាពសាលារៀនដូចជាគម្រោងលើកកម្ពស់លទ្ធផលសិក្សាសិស្សដើម្បីឱ្យបានជាប់និទ្ទេសAឱ្យបានច្រើនជាដើម។ **ចំណុចសំខាន់ដែលយើងត្រូវចាំនោះគឺ គម្រោងត្រូវរៀបចំ និងអនុវត្តដើម្បីឱ្យមានការផ្លាស់ប្តូររីកចម្រើន។ ចុងបញ្ចប់នៃការអនុវត្តគម្រោងគឺគេចង់ឃើញការផ្លាស់ប្តូរ។** ថ្នាក់ដឹកនាំសាលារៀនដែលល្អ គឺជាអ្នកដែលមានសមត្ថភាពគ្រប់គ្រាន់ និងមានការយល់ដឹងទូលំទូលាយពីការរៀបចំផែនការអភិវឌ្ឍសាលារៀន ព្រោះវាទាមទារសមត្ថភាពយល់ដឹងខ្ពស់ និងជំនាញជាក់លាក់តួយ៉ាងដូចសមត្ថភាពក្នុងការរៀបចំតារាងអភិក្រមក្របខណ្ឌសមហេតុផល(Logical framework) ជាដើម ដែលទាមទារឱ្យមានការបណ្តុះបណ្តាលច្បាស់លាស់ និងសិក្សារៀនសូត្រ ដកស្រង់បទពិសោធនៃការអនុវត្តការងារផ្ទាល់ខ្លួនជាប្រចាំ។

ការរៀបចំផែនការអភិវឌ្ឍសាលារៀនមានសារៈសំខាន់ណាស់ព្រោះវាធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសាលារៀននាពេលអនាគត[៦៩]។

ទោះយ៉ាងណាយើងឃើញជួបប្រទះបញ្ហាប្រឈមជាច្រើនក្នុងដំណើរការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍសាលារៀននេះ មានដូចជា៖

- ការរៀបចំផែនការអភិវឌ្ឍសាលារៀន ទាមទារអ្នកដែលចំណេះដឹងខ្ពស់ ទូលំទូលាយ និងជំនាញច្បាស់លាស់ក្នុងការរៀបចំ។ ជាទូទៅយើងឃើញថាការរៀបចំ និងសរសេរគម្រោងផែនការអភិវឌ្ឍសាលារៀននេះ មានលក្ខណៈស្មុគស្មាញខ្លាំង ដែលបុគ្គលធម្មតាមិនអាចរៀបចំបានល្អឡើយ វាទាមទារការបណ្តុះបណ្តាលជំនាញច្បាស់លាស់ និងការសិក្សារៀនសូត្រជាប្រចាំពីបទពិសោធនៃការអនុវត្តការងាររបស់ខ្លួន ពិសេសការវិភាគបញ្ហា និងការរៀបចំតារាងអភិក្រមក្របខណ្ឌសមហេតុផលជាដើម។ ឧបសគ្គនៃសមត្ថភាពក្នុងការរៀបចំនេះធ្វើឱ្យការលើកគម្រោងមានលក្ខណៈដដែលៗ មិនមានគំនិតច្នៃប្រឌិតថ្មីដើម្បីឱ្យមានការផ្លាស់ប្តូរ ឬលើកគម្រោងមិនមានលក្ខណៈសមស្រប និងមិនឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ស្ថាប័ន...។ល។
- អ្នកលើកគម្រោងភាគច្រើនទាំងកម្រិតថ្នាក់ជាតិ រហូតដល់កម្រិតសាលារៀនហាក់មិនបានបង្ហាញច្បាស់លាស់ពីពាក្យថា "**ផ្លាស់ប្តូរ**"នៅក្នុងគម្រោងកម្រិតសមិទ្ធិផល(Outcome)ហើយភាគច្រើនធ្វើការបកស្រាយបានតែនៅក្នុងកម្រិតលទ្ធផល(Output) ដែលពិបាកមើលឃើញពីការផ្លាស់ប្តូរ។ ដើម្បីឱ្យបានច្បាស់លាស់ យើងសូមលើកឧទាហរណ៍មកបញ្ជាក់ដូចតទៅ៖ មានគម្រោងផ្តល់វគ្គបំប៉ននាយកដល់គ្រូបង្រៀនចំនួន៥០០នាក់ ប៉ុន្តែយើងមិនអាចវាស់វែងបានថា តើបន្ទាប់ពីទទួលបានការបណ្តុះបណ្តាល ពួកគាត់មានការផ្លាស់ប្តូរអ្វីខ្លះ

ឱ្យបានជាក់លាក់? ការសរសេរបាយការណ៍សម្រាប់ផ្នែកនេះ មិនបានប្រើប្រាស់វិធីសាស្រ្តសរសេរបាយការណ៍ផ្អែកលើលទ្ធផលទេ។

- ការយល់ដឹងពីនីតិវិធីក្នុងរៀបចំផែនការអភិវឌ្ឍសាលារៀននៅមានកម្រិត ព្រោះការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំនៅមានចំនួនតិចតួចនៅឡើយ។ ភាគច្រើនគម្រោងត្រូវបានរៀបចំដោយគណៈគ្រប់គ្រងសាលា និងមានការចូលរួមមួយចំនួនពីគ្រូបង្រៀន។ ជាទូទៅយើងឃើញមានការចូលរួមតិចតួចណាស់ពីគណៈកម្មការទ្រទ្រង់សាលា មាតាបិតា ឬអ្នកអាណាព្យាបាល និងតំណាងសិស្សានុស្ស។ កង្វះការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ អាចធ្វើឱ្យកង្វះព័ត៌មានគ្រប់ជ្រុងជ្រោយ និងតម្លាភាពក្នុងការរៀបចំគម្រោង ហើយវាអាចមិនឆ្លើយតបទៅនឹងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែង ឬចាំបាច់របស់សាលារៀន និងសហគមន៍
- ការរៀបចំផែនការសកម្មភាព និងថវិកាគប្បីអនុវត្តតាមបែបគ្រប់គ្រងដោយផ្អែកមូលដ្ឋានលើសាលារៀន (school based management) ដើម្បីឱ្យសាលារៀននីមួយៗមានភាពម្ចាស់ការ ការទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចចិត្ត ផ្អែកតាមតម្រូវការជាក់ស្តែង និងបញ្ហាប្រឈមដោយឡែកៗរបស់សាលារៀននីមួយៗ។ក្នុងន័យនេះ គេមិនគួរកំណត់ជាមុនទាំងស្រុងនូវកូដ សកម្មភាព ឬលេខគណនីទេ ព្រោះវាធ្វើឱ្យរាំងស្ទះដល់គំនិតច្នៃប្រឌិតរបស់ថ្នាក់ក្រោមជាតិក្នុងការដោះស្រាយបញ្ហាជាក់ស្តែងរបស់គេ។

☞ ជាទស្សនទាន តើយើងត្រូវរៀបចំផែនការអភិវឌ្ឍសាលារៀនយ៉ាងដូចម្តេច?

បច្ចេកទេសរៀបចំផែនការត្រូវបើកចំហឱ្យមានការចូលរួមបានទូលំទូលាយពីអ្នកពាក់ព័ន្ធដូចជា៖ គណៈកម្មការអភិវឌ្ឍសាលារៀន គណៈគ្រប់គ្រង

សាលារៀន គ្រូបង្រៀន មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស និងតំណាងសិស្សានុសិស្ស។ ស្ថិតក្នុងបរិបទនៃការអប់រំប្រកបដោយគុណភាព និងបរិយាប័ន្ន ការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធគ្រប់ភាគីមានសារៈសំខាន់ណាស់ព្រោះវាបានលើកយកបញ្ហាគ្រប់ជ្រុងជ្រោយពីអ្នកទាំងនោះ ធ្វើឱ្យផែនការត្រូវបានរៀបចំ ឆ្លើយតបត្រឹមត្រូវទៅនឹងតម្រូវការជាក់ស្តែងរបស់ពួកគេ។ វាជាចំណុចចូលរួមដ៏សំខាន់ ប្រកបដោយអត្ថន័យនៃការអប់រំបែបបរិយាប័ន្ន ដោយគ្មាននរណាម្នាក់ត្រូវបានទុកចោលទេ រួមទាំងជនងាយរងគ្រោះ។ សមិទ្ធផលផែនការអភិវឌ្ឍសាលារៀនដែលមានការចូលរួមនេះ នាំទៅរកការអភិវឌ្ឍប្រកបដោយចីរភាព និងគ្មានការរើសអើងដូចជា៖ជាតិសាសន៍ សាសនា ភេទ ពណ៌សម្បុរ ជនជាតិភាគតិច វណ្ណៈ និន្នាការនយោបាយ ពិការភាព...ជាដើម។ ឧទាហរណ៍ បើលើកគម្រោងសាងសង់បង្គន់នៅតាមសាលារៀន គេនឹងសាងសង់បង្គន់ដែលបង្កភាព ងាយស្រួលដល់កុមារី ឬជនពិការជាដើម។ ជាទូទៅយើងឃើញថា ការលើកផែនការអភិវឌ្ឍសាលារៀនជាច្រើន ដើម្បីបម្រើផលប្រយោជន៍ដល់កុមារ តែគេមិនដែលសួរកុមារទេថា តើពួកគេចង់បានអ្វី? ចង់បានយ៉ាងម្តេចទេ? ថ្នាក់ដឹកនាំសាលារៀន ជាអ្នកសម្រេចចិត្តជួសទាំងអស់។ ជាក់ស្តែង យោងតាមការចុះប្រមូលទិន្នន័យសម្រាប់សរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញា-បត្រជាន់ខ្ពស់ស្តីពីស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននៅកម្រិតវិទ្យាល័យក្នុងខេត្តស្វាយរៀងឆ្នាំ២០១៨ យើងឃើញថា វិទ្យាល័យស្ទើរតែទាំងអស់មិនបានអនុវត្តការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ដែលមានការចូលរួមពីភាគីពាក់ព័ន្ធទេ ហើយភាគីច្រើនអនុវត្តវិធីសាស្ត្របែប គណៈគ្រប់គ្រងសាលាជាអ្នករៀបចំរួចប្រជុំផ្សព្វផ្សាយ និងសួរយោបល់តែប៉ុណ្ណោះ។ និន្នការបែបនេះ ប្រហែលនឹងកើតមានសម្រាប់សាលារៀនទូទាំងប្រទេស។

ផែនការអភិវឌ្ឍសាលារៀនគប្បីរៀបចំតាមនីតិវិធីមួយច្បាស់លាស់ប្រកបដោយតម្លាភាព។ ជំហានដំបូងត្រូវមានការប្រជុំរៀបចំធ្វើផែនការ (ToR) ដោយមានដាក់បញ្ចូលនូវ គោលបំណង នីតិវិធីនៃដំណើរការរៀបចំធ្វើផែនការអភិវឌ្ឍសាលារៀន ពេលវេលាអនុវត្ត អ្នកទទួលខុសត្រូវ... ជាដើម។ បន្ទាប់មកប្រជុំបង្កើតក្រុមរៀបចំផែនការអភិវឌ្ឍសាលារៀន ប្រជុំប្រឹក្សាយោបល់ ការប្រមូលព័ត៌មាន បញ្ហាប្រឈម និងតម្រូវការ ការវិភាគបញ្ហា និងការកំណត់អាទិភាពបញ្ហា បន្ទាប់មករួមគ្នាស្វែងរកដំណោះស្រាយ និងផែនការយុទ្ធសាស្ត្រដោយផ្អែកលើធនធានដែលបានកំណត់។ នៅក្នុងដំណោះស្រាយ គេត្រូវធ្វើការរួមគ្នាផងដែរពីការរៀបចំយុទ្ធសាស្ត្រធ្វើឱ្យសម្រេចជោគជ័យ ការរៀបចំតារាងអភិក្រមក្របខណ្ឌសមហេតុផល (Logical framework) ដែលមានបញ្ជាក់ពីគោលដៅរួម គោលបំណង លទ្ធផលរំពឹងទុក សកម្មភាពអនុវត្ត អាំងឌីកាទ័រច្បាស់លាស់ដែលអាចវាស់វែងបាន មធ្យោបាយផ្ទៀងផ្ទាត់ និងការសន្មត់ (ការគ្រប់គ្រងហានិភ័យដែលអាចកើតមានឡើង)។ ចំណុចចុងក្រោយគឺរៀបចំផែនការអនុវត្ត ផែនការប្រតិបត្តិការ និងផែនការថវិកា។ សម្រាប់យុទ្ធសាស្ត្រដើម្បីអនុវត្តផែនការឱ្យបានជោគជ័យគប្បីត្រូវកំណត់ឱ្យបានច្បាស់លាស់ មានយន្តការក្នុងការអនុវត្ត ដូចជា៖ កិច្ចសហការ ការបង្កើតក្រុមការងារដូចក្រុមតាមដាន វាយតម្លៃ គណៈកម្មការលទ្ធកម្មដើម្បីតម្លាភាព និងគណៈកម្មការដទៃទៀតតាមភាពចាំបាច់។ សម្រាប់ដំណាក់កាលចុងក្រោយ គឺការប្រជុំបង្ហាញលទ្ធផលនៃការរៀបចំផែនការអភិវឌ្ឍសាលារៀន និងការផ្តល់ព័ត៌មានត្រឡប់ មុនពេលសរសេរសម្រេច និងអនុម័ត។

## 10) ការបង្រៀនគួរក្រៅម៉ោង

នៅពេលដែលការសិក្សានៅសាលារដ្ឋមិនអាចបំពេញសេចក្តីត្រូវការសិក្សារៀនសូត្ររបស់សិស្សបានគ្រប់គ្រាន់ សិស្សភាគច្រើនងាកមករកការរៀនគួរក្រៅម៉ោងដើម្បីសម្រេចលទ្ធផលសិក្សារបស់ខ្លួន។ នៅពេលដែលស្ថានភាពរស់នៅរបស់គ្រូបង្រៀនមិនទាន់ល្អប្រសើរ ពួកគាត់អនុវត្តការបង្រៀនគួរក្រៅម៉ោងដើម្បីបង្កើនប្រាក់ចំណូលបន្ថែម និងលើកកម្ពស់ជីវភាពរស់នៅ។ ការបង្រៀនគួរក្រៅម៉ោងនៅប្រទេសកម្ពុជា ភាគច្រើនសិស្សរៀនផ្ទាល់ជាមួយគ្រូបង្រៀនដែលបានបង្រៀនពួកគេនៅរដ្ឋ ដែលខុសពីការរៀនគួរនៅប្រទេសនានានៅអាស៊ីខាងកើតដែលសិស្សត្រូវរៀនជាមួយគ្រូនៅសាលាឯកជនដែលមិនមែនជាគ្រូបង្រៀនពួកគេផ្ទាល់នៅសាលារៀនរដ្ឋទេ។ នេះមានន័យថា គ្រូបង្រៀននៅរដ្ឋផ្សេង គ្រូបង្រៀននៅសាលាឯកជនផ្សេង។ ទោះបីយ៉ាងណាក៏ដោយ ការបង្រៀនគួរក្រៅម៉ោងនេះ ផ្តល់ចំណេញផង និងការខាតបង់ផងសម្រាប់បរិបទកម្ពុជា។ តើការបង្រៀនគួរនេះផ្តល់គុណសម្បត្តិ និងគុណវិបត្តិដូចម្តេចខ្លះ?

### ☞គុណសម្បត្តិ

- វាបំពេញតម្រូវការសិក្សារបស់សិស្សបន្ថែមដែលធ្វើឱ្យសម្រេចលទ្ធផលសិក្សា។ តាមបទពិសោធន៍ប្រទេស និងក្រុងដែលមានលទ្ធផល PISA ខ្ពស់ដូចជា៖ កូរ៉េ តៃវ៉ាន់ ហុងកុង សៀងហៃ និងប្រទេសជប៉ុនជាដើម ចំនួនម៉ោងសិក្សានៅសាលារដ្ឋ និងឯកជនច្រើនជាងកម្ពុជាឆ្ងាយណាស់ ប្រមាណជាង៧០ម៉ោងក្នុងមួយសប្តាហ៍ ឬច្រើនជាងនេះ ពិសេសប្រទេសកូរ៉េ និងក្រុងសៀងហៃ សិស្សរៀនតាំងពីម៉ោង៨ព្រឹក រហូតដល់ម៉ោង១០ និង១១យប់ឬយូរជាងនេះក៏មាន ទើបត្រឡប់មកផ្ទះនៅកណ្តាលអធ្រាត្រ។ ការសិក្សាស្ថិតក្នុងរូបភាពនៃការប្រកួតប្រជែងដ៏ខ្លាំងក្លាមួយ។

- ភាពជោគជ័យនៃការផលិតមូលធានមនុស្សរបស់ប្រទេសទាំងនេះ សុទ្ធតែមានការចូលរួមចំណែកយ៉ាងសំខាន់ពីការរៀនគួរបន្ថែមក្រៅម៉ោង ដែលវាជំរុញការអនុវត្ត និងហ្វឹកហាត់ធ្វើលំហាត់ជាប់ជាប្រចាំ ដើម្បីអភិវឌ្ឍន៍ចំណេះដឹង និងបំណិន។
- ការសិក្សារៀនសូត្រដោយការរងសម្ពាធ ការស៊ូទ្រាំ និងតស៊ូប្រឹងប្រែង ព្រមទាំងចំណាយពេលច្រើនម៉ោងលើការសិក្សា អាចជុះខាត់ពួកគេក្លាយជាមូលធនមនុស្សដែលមានភាពធន់ទ្រាំនឹងការរងសម្ពាធការងារ និងជំនះភាពតានតឹងផ្លូវចិត្តខ្លួនឯងនៅពេលពួកគេប្រឡូកនឹងការងារ និងជួបប្រទះនូវបញ្ហាជីវិត។

### ☞គុណវិបត្តិ

- ដោយហេតុផលគ្រូបង្រៀនមានប្រាក់បៀវត្សទាប លោកគ្រូ-អ្នកគ្រូ មួយចំនួនបានចាប់សិស្សជាចំណាប់ខ្មាំង ដើម្បីប្រាក់ តាមរយៈការបង្កើតការបង្រៀនគួរក្រៅម៉ោង និងការគៀបសិស្សតាមមធ្យោបាយផ្សេងៗ។ ការបង្រៀនគួក្រៅម៉ោងមិនបានផ្តល់ភាពចំណេញដល់សិស្សទេ ព្រោះវាបានបន្ថែមម៉ោងសិក្សាដល់សិស្សលើសកំណត់ និងមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់សិស្សក្នុងការសិក្សាស្រាវជ្រាវរៀនសូត្រខ្លួនឯង។
- តាមរយៈការបង្រៀនគួក្រៅម៉ោង វាអាចឱ្យគ្រូបង្រៀនបែកបាក់ផ្ទៃក្នុងព្រោះទំនាស់ផលប្រយោជន៍ និងភាពច្រណែនគ្នា (ឧ. ច្រណែនដោយសារគ្រូបង្រៀនខ្លះបានថ្នាក់ល្អ មានសិស្សរៀនគួរច្រើន ឯខ្លះទៀតបានថ្នាក់អន់មិនសូវមានសិស្សរៀនច្រើន ឬគិតគួរតែខ្សែរបក្សពួកខ្លួនជាដើម)

- ធ្វើឱ្យគ្រូបង្រៀនមិនមានមនសិការការងាររឹងមាំនៅក្នុងម៉ោងសិក្សារដ្ឋ ឬបង្រៀនសិស្សមិនច្បាស់លាស់នៅក្នុងថ្នាក់ ដោយលាក់ទុកល្បិចសម្រាប់ការបង្រៀនក្រៅម៉ោងវិញ។ ជាទូទៅយើងសង្កេត គ្រូយកចិត្តទុកដាក់បង្រៀនសិស្សខ្លាំងថ្នាក់គួរក្រៅម៉ោងជាជាងបង្រៀននៅក្នុងម៉ោងរដ្ឋ។
- មួយវិញទៀត ការបង្រៀនគួរនេះ វាអាចធ្វើឱ្យមានភាពអយុត្តិធម៌ក្នុងការដាក់ពិន្ទុ ដល់ការសិក្សារបស់សិស្ស។ ពិតណាស់ លោកគ្រូ-អ្នកគ្រូមួយចំនួនធំ នឹងមានភាពលម្អៀងទៅលើសិស្សដែលរៀនគួរជាមួយខ្លួន ដែលអាចឱ្យសិស្សដទៃទៀតបាក់ទឹកចិត្ត ហើយការសិក្សាធ្លាក់ចុះ។
- ម្យ៉ាងទៀត ការបង្រៀនគួរនេះ ធ្វើឱ្យសិស្សមានទម្លាប់មិនល្អ មិនយកចិត្តទុកដាក់ក្នុងសិក្សារៀនសូត្រ និងមិនពឹងផ្អែកលើសមត្ថភាពខ្លួនឯងដើម្បីអភិវឌ្ឍន៍ចំណេះដឹង ហើយសម្លឹងឃើញគុណសម្បត្តិរបស់លុយក្នុងដំណើរការបង្រៀន និងរៀនទៅវិញ ពិសេសគឺឥទ្ធិពលដ៏លើសលុបរបស់វា ទៅលើដំណើរជីវិតរបស់គាត់។
- លើសពីនេះទៅទៀត វាបានបង្កើតជាវប្បធម៌ចំណាយប្រាក់ក្នុងការសិក្សា បើទោះបីការចុះចូលរៀនមិនឥតគិតថ្លៃក៏ដោយ ក៏ការចំណាយក្នុងការរៀនសូត្រសម្រាប់សិស្សមួយឆ្នាំទៅ មួយឆ្នាំមានការកើនឡើង ជាលំដាប់។ ករណីនេះ នៅពេលវាលដាលធំទៅៗ វាបង្កើតជានាំងឧបសគ្គសម្រាប់គ្រួសារក្រីក្រ នាំទៅរកការបាក់ទឹកចិត្ត និងបាត់បង់ជំនឿលើការសិក្សា ឧទាហរណ៍ការឱ្យកូនឈប់រៀន ទៅធ្វើការងាររោងចក្រជាដើម...។
- ផលវិបាកមួយទៀត គឺវាធ្វើឱ្យសិស្សអសកម្ម មិនឱ្យតម្លៃការសិក្សា និងចេះពុករលួកសូកប៉ាន់។ ( សាកល្បងសង្កេតទៅលើ

ការអប់រំតាំងពីបឋមសិក្សា រហូតដល់មធ្យមសិក្សា តើយើងឃើញមានវប្បធម៌នៃអំពើពុករលួយ ត្រូវបានដាក់បញ្ចូលដោយឥតដឹងខ្លួនក្នុងដំណើរបង្រៀន និងរៀនដែរឬទេ? ឧទាហរណ៍ បើកុមារនៅសាលាបឋមសិក្សាទៅរៀនក្នុងសាលារដ្ឋហើយលោកគ្រូ-អ្នកគ្រូមួយចំនួនតម្រូវឱ្យបង់ប្រាក់ប្រចាំថ្ងៃឬ ឪពុកម្ដាយបានដាក់លុយមួយចំនួនក្នុងសៀវភៅតាមដានការសិក្សារបស់កូនឱ្យគ្រូការបង្រៀនគួរបន្ថែមក្រៅម៉ោង/ក្នុងម៉ោង ឬជូនកាដូផ្សេងៗ ...តើនេះ មិនមែនយើងកំពុងតែដុះខាត់កុមារឱ្យចេះ ពុករលួយ ស៊ីសំណូកសូកប៉ាន់ទេឬ? ស្ថិតក្នុងរូបភាពខាងលើ វាធ្វើឱ្យឪពុកម្ដាយ ឬអ្នកអាណាព្យាបាលរបស់សិស្សានុសិស្សមួយចំនួនបានបាត់បង់ទំនុកចិត្តលើការសិក្សានៅសាលារដ្ឋ ហើយងាកមកចាប់អារម្មណ៍ឱ្យកូនរៀននៅសាលាឯកជនវិញ បើគង់តែចំណាយលុយដូចគ្នា។

០ បើសិននៅតាមសាលាអនុវិទ្យាល័យ-វិទ្យាល័យមួយចំនួន មានលោកគ្រូ-អ្នកគ្រូមួយចំនួនផ្ដោតទៅលើផលប្រយោជន៍ ផ្ទាល់ខ្លួនតាមរយៈការស្វះស្វែងរកឱកាសក្នុងការទាញយកប្រយោជន៍ពីសិស្សនោះ វានាំឱ្យការអប់រំមានទិសដៅឆ្ពោះទៅរកការរកលុយទៅវិញ ដែលជះឥទ្ធិពលអាក្រក់បំផុតដល់សិស្ស។បញ្ហានេះវាបានប្រែក្លាយសកម្មភាពអប់រំ ទៅជាការប្រកួតប្រជែងអាជីវកម្មយ៉ាងគគ្រឹកគគ្រេង ស្ទើរគ្រប់មុខវិជ្ជា។ ឧទាហរណ៍បើសិស្សមិនចង់រៀនម៉ោងកាយសិក្សាអាចបង់លុយដើម្បីយកពិន្ទុ បង់លុយច្រើនបានពិន្ទុច្រើន ហើយបង្កើតឱ្យមានការបង្រៀនគួរក្រៅម៉ោងស្ទើរគ្រប់មុខវិជ្ជា ដែលវាគួរឱ្យអស់សំណើចបំផុត។ មុខវិជ្ជាខ្លះមិនគួរបើកបង្រៀនគួរតែបែរជាមានបើកដែរ។

- គុណភាពអប់រំធ្លាក់ចុះ ហើយភាពអស់ជំនឿលើការសិក្សារបស់ស្រទាប់គ្រួសារក្រីក្របាន និងកំពុងកើនឡើង ហើយអត្រាឈប់រៀនដើម្បីធ្វើការងារកើនឡើង ផងដែរដូចជាចំណាកស្រុកទៅធ្វើការនៅប្រទេសជិតខាង ធ្វើកម្មកររោងចក្រ កម្មករសំណង់... ដែលភាគច្រើនជាការងារប្រើកម្លាំង និងមានកំរៃទាប។
- នាំឱ្យសង្គមមានវិសមភាពក្នុងការទទួលបានសេវាអប់រំ ពោលគឺកូនអ្នកមានលុយច្រើនរៀននៅសាលាល្អ ទទួលបានសេវាអប់រំដែលមានគុណភាពល្អ និងមានលទ្ធភាពគ្រប់គ្រាន់បំពេញសេចក្ដីត្រូវការផ្នែកសិក្សារបស់ខ្លួនបាន ព្រមទាំងងាយចាប់យកឱកាសការងារល្អបាន ចំណែកកូនអ្នកក្រ រៀននៅសាលាធម្មតា មិនមានធនធានគ្រប់គ្រាន់ដើម្បីបំពេញកង្វះខាតផ្នែកសិក្សារបស់ខ្លួនបាន។
- បញ្ហាបង្រៀនគួរក្រៅម៉ោងអាចក្លាយជាជំងឺមហារីក ហើយឥរិយាបថអវិជ្ជមានគ្រូបង្រៀនមួយចំនួនបានប្រែក្លាយពីទម្លាប់ឆ្ពោះទៅរកវប្បធម៌ហើយ ហើយបើទោះបីជារាជរដ្ឋាភិបាលតំលើងប្រាក់បៀវត្សសមរម្យក៏ដោយ ក៏សកម្មភាពអសកម្មមួយចំនួនធំប្រហែលនៅតែមានអត្ថិភាពដដែលដូចជា៖ ការគៀបសិស្សដើម្បីរៀនគួរជាដើម។

### ☞ ការពិភាក្សា និងសំយោគ

សម្រាប់បរិបទកម្ពុជាបច្ចុប្បន្នដែលសេវាអប់រំនៅមានកម្រិតមិនទាន់អាចបំពេញបាននូវតម្រូវការសិក្សារបស់សិស្សបាន ដើម្បីប្រកួតប្រជែងសេដ្ឋកិច្ចក្នុងតំបន់ និងដើម្បីសម្រេចជោគជ័យនៃកំណែទម្រង់វិស័យអប់រំ ការបង្រៀនគួរបន្ថែមនេះ ជារឿងចាំបាច់បំផុតមិនអាចអត់បាន។

ការបង្រៀនគួរនេះ ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេចលទ្ធផលសិក្សារបស់សិស្ស។ តែទោះបីជាយ៉ាងណាក៏ដោយ យើងគប្បីរិះរកវិធីសាស្ត្រនានាដើម្បីធានាការអប់រំ ប្រកបដោយសមភាព និងសមធម៌ ពិសេសសម្រាប់កុមារងាយរងគ្រោះ តាមរយៈការគាំទ្រដល់ការបង្រៀនបន្ថែមដល់ពួកគាត់ដោយប្រើប្រាស់ថវិកាផ្ទាល់របស់ក្រសួង។ បើមានសិស្សដែលងាយរងគ្រោះមានចំនួនមួយសមស្រប (សម្រាប់កុមារមកពីគ្រួសារក្រីក្រ កំព្រា គ្រួសារមានជំងឺរ៉ាំរ៉ៃ...) ស្នើសុំឱ្យមានការបង្រៀនបន្ថែមនៅថ្ងៃចុងសប្តាហ៍ ឬពេលណាមួយសមស្រប យើងគប្បីបើកថ្នាក់បង្រៀននោះដល់ពួកគេដូចការអនុវត្តរបស់កោះតៃវ៉ាន់។ មួយវិញទៀត ការបង្កើតបណ្ណាល័យឌីជីថល (Digital Library) និងបង្កើតកម្មវិធីបង្ហាត់បង្រៀនមុខវិជ្ជាផ្សេងៗដូចជា៖ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា...នៅក្នុងបណ្តាញសង្គម ឬ youtbube អាចជួយដល់សិស្សច្រើនដល់ការសិក្សានៅសតវត្សរ៍ទី២១នេះ ហើយបង្កលក្ខណៈងាយស្រួលដល់សិស្សអាចរៀនបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ព្រមទាំងជំរុញការសិក្សាពេញមួយជីវិត ដូចការអនុវត្តរបស់ប្រទេសទាំងឡាយនៅ អាស៊ីខាងកើត ពិសេសប្រទេសកូរ៉េខាងត្បូង។ ចំណុចចុងក្រោយ ដើម្បីជៀសវាងផលប៉ះពាល់ដោយផ្ទាល់ពីការបង្រៀនគួរក្រៅម៉ោងដល់លទ្ធផលសិក្សាសិស្ស សាលាគប្បីប្រើប្រាស់វិញ្ញាសាប្រឡងមួយដែលត្រូវបានជ្រើសរើសពីវិញ្ញាសាស្នើសុំទាំងឡាយរបស់គ្រូទាំងអស់ ហើយអនុវត្តសម្រាប់ការប្រឡងឆមាស។ ការអនុវត្តបែបនេះ គឺដើម្បីកាត់បន្ថយការប្រើប្រាស់ឥទ្ធិពលអវិជ្ជមានរបស់គ្រូបង្រៀនតាមមុខវិជ្ជាមកលើសិស្សដូចជា៖ ការគៀបសិស្ស និងភាពលម្អៀងក្នុងការដាក់ពិន្ទុសិស្សជាដើម។ មួយវិញទៀត ការបណ្តុះបណ្តាលធនធាននិស្សិតដោយដាក់បញ្ចូលនូវមេរៀនវិធីសាស្ត្របង្រៀន និងគរុកោសល្យ ហើយនៅពេលដែលពួកគាត់បញ្ចប់ការសិក្សានៅកម្រិតឧត្តមសិក្សា អាចធ្វើការដោយ

ស្របច្បាប់នៅសាលាឯកជនដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្រៀន គួរបន្ថែមលើមុខវិជ្ជាឯកទេសសំខាន់ៗ។

11) **បញ្ហាខ្វះ និងលើសគ្រូបង្រៀន**

ដោយសារនីតិវិធីក្នុងការផ្ទេរ មានភាពមិនច្បាស់លាស់ ផ្តល់ភាពចន្លោះប្រហោងច្រើនក្នុងការអនុវត្តការបែងចែក និងពង្រាយគ្រូប្រកបដោយប្រសិទ្ធភាព។ ដោយសារបក្សពួកនិយម និងអំពើពុករលួយ ស៊ីសំណូក ធ្វើឱ្យបញ្ហាកង្វះគ្រូបង្រៀននៅតាមតំបន់ជនបទ និងលើសគ្រូបង្រៀននៅតំបន់ទីក្រុងនេះ ជាបញ្ហាប្រឈមខ្លាំង និងពិបាកដោះស្រាយ។ មន្ត្រីអប់រំមួយចំនួនដែលមានទទួលខុសត្រូវលើការងារនេះ មិនបានគិតដល់ផលវិបាកនៃការអនុវត្តនីតិវិធីខុសរបស់ខ្លួនទេ ដោយសារកង្វះមនសិការវិជ្ជាជីវៈ ភាពអាត្មានិយម និងអត្តទត្ថភាព ចង់បានតែផលប្រយោជន៍ពីការសូកប៉ាន់សម្រាប់ការផ្ទេរ ឬផ្លាស់ទៅកាន់កន្លែងការងារថ្មី បើទោះបីពេលខ្លះដឹងថា គ្រឹះស្ថានសិក្សានោះលើសគ្រូហើយក៏ដោយ។ ចំនួនគ្រូផ្ទេរ និងផ្លាស់ប្រចាំឆ្នាំ និងការចំណាយក្រោមតុ នឹងក្លាយជាចំណូលក្រៅផ្លូវការ ហើយចុងបញ្ចប់វាជាប្រយោជន៍សម្រាប់បុគ្គល។ ជាមួយគ្នានេះ ក៏មានការប្រើប្រាស់ឥទ្ធិពលតួនាទី និងឋានៈសង្គម និងខ្សែរនិយម ដើម្បីទទួលបានការងារកន្លែងល្អផងដែរ។ ជាទូទៅ យើងឃើញមានការផ្ទេរ ឬផ្លាស់កន្លែងធ្វើការច្រើននៅពេលផ្លាស់ប្តូរតួនាទីប្រធានស្ថាប័នម្តងៗ។ សម្រាប់ករណីនេះ ប្រទេសជាច្រើននៅអាស៊ីខាងកើត ដូចជា៖ ជប៉ុន និងកូរ៉េជាដើម មិនមានបញ្ហាចោទបែបនេះធ្ងន់ធ្ងរទេ ដោយសារប្រព័ន្ធអប់រំប្រទេសទាំងនេះ បានបណ្តុះគំនិតជាតិនិយមខ្លាំងដល់គ្រូបង្រៀនចេញថ្មីទាំងអស់ ទោះត្រូវបំពេញការងារនៅតំបន់ណាក៏ដោយ ក៏ពួកគេគោរពតាមការចាត់តាំងប្រកបមនសិការការងារខ្ពស់។ មួយវិញទៀត

ការអនុវត្តប្រព័ន្ធចល័តគ្រូបង្រៀន និងនាយកសាលាក្នុងរវាង៣ ឬ៥ឆ្នាំម្តង ជាយុទ្ធសាស្ត្រសំខាន់ក្នុងការទប់ស្កាត់អំពើពុករលួយ និងបក្សពួកនិយម នៅក្នុងសាលា ការបែងចែកការងារប្រកបដោយប្រសិទ្ធភាព និងគុណភាព នៅគ្រប់តំបន់។ ជាទូទៅ រៀងរាល់ឆ្នាំសាលារៀនតែងតែមានគ្រូផ្លាស់ចេញ និងគ្រូចំណូលថ្មី ហើយការចល័តនេះ នាំឱ្យសាលារៀនទាំងអស់ ទទួល បានធនធានគ្រូបង្រៀនស្មើភាពក្នុងការលើកកម្ពស់គ្រឹះស្ថានឱ្យមានភាពល្អ ប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។ អ្វីដែលសំខាន់មួយទៀត គឺគ្រឹះស្ថានសិក្សា មួយចំនួនបានអនុវត្តបែប "ការគ្រប់គ្រងមានមូលដ្ឋានផ្អែកលើសាលារៀន" (School Based Management) ដែលផ្តល់សិទ្ធិស្វ័យសម្រេចពេញ លេញក្នុងការជ្រើសរើសគ្រូ តាមតម្រូវការសាលារៀន។ នេះជាការបែងចែក ការទទួលខុសត្រូវច្បាស់លាស់ ក្នុងចាត់បែងប្រើប្រាស់ធនធានគ្រូនៅក្នុង សាលារៀន ហើយក្នុងករណីកង្វះ ឬលើសគ្រូ ជាការទទួលខុសត្រូវរបស់ សាលា មិនមែនទម្លាក់កំហុសដាក់គ្នាទៅវិញទៅមក ដោយមិនមាននរណា ទទួលខុសត្រូវច្បាស់លាស់នោះទេ។

## 12) *ការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន*

តាមរយៈទ្រឹស្តីគោលវិធីសិស្សមជ្ឈមណ្ឌល ការលើកទឹកចិត្តសិស្សឱ្យធ្វើ ការងារពិភាក្សាក្រុម គឺជាធាតុសំខាន់មួយដែលជួយជំរុញឱ្យសិស្សចេះធ្វើ ការរួមគ្នា ចេះសហការនិង ជួយគ្នាទៅវិញទៅមក ដើម្បីលើកកម្ពស់ចំណេះ ដឹង ចំណេះធ្វើ សីលធម៌ និងភាពចេះរស់នៅ ចុះសម្រុងនឹងសង្គម។ ការ ដែលកុមារ និងយុវសិស្សរួមគ្នា ធ្វើកិច្ចការអ្វីមួយជាមួយគ្នា ធ្វើឱ្យពួកគាត់ មានទំនាក់ទំនងល្អនឹងគ្នា ចេះពិភាក្សាដោះដូរ យោបល់គ្នា យោគយល់គ្នា រៀនសូត្រពីគ្នាទៅវិញទៅមកនិងចេះស្តាប់មតិយបល់អ្នកដទៃ។ អ្វីដែល ជា

គុណសម្បត្តិធំ របស់ការងារក្រុមគឺ ការផលិតចេញនូវធនធានមនុស្សដែលមានសមត្ថភាព ពេញលេញក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គម។ ទ្រឹស្តីខាងលើ មានលោកគ្រូ-អ្នកគ្រូ ជាច្រើនបានទន្ទេញចាប់មាត់ទៅហើយនៅឡើយតែការអនុវត្តប៉ុណ្ណោះ។ ការខ្វះឆន្ទៈ និងភាពមិនយល់ពីគុណសម្បត្តិរបស់វា ធ្វើឱ្យប្រសិទ្ធភាពនិងគុណភាពនៃការអប់រំធ្លាក់ចុះ។ មានលោកគ្រូ-អ្នកគ្រូមួយចំនួនយល់ខុសពីការឱ្យសិស្សធ្វើការ ងារក្រុមនេះថា ជំរុញឱ្យសិស្សមានភាពរញ៉េរញ៉ៃក្នុងម៉ោងបង្រៀន និងពិបាកក្នុងការគ្រប់គ្រងសិស្ស។ នេះជាការយល់ច្រឡំមួយយ៉ាងធំ និងបង្ហាញពីសមត្ថភាពអប់រំនៅមានកម្រិត។ មួយវិញទៀត យើងសង្កេតឃើញថា ជាទូទៅមានការជំរុញឱ្យសិស្សធ្វើការងារក្រុម ប៉ុន្តែចំពោះលោកគ្រូ-អ្នកគ្រូមួយចំនួនវិញ ការធ្វើការងារក្រុមហាក់នៅមានកម្រិតហើយវាជាចំណុចរសើបធំបំផុតមួយ។ ស្ថិតក្នុងន័យនេះ បើជនគំរូ មិនអាចអនុវត្តបានផង តើឱ្យសិស្សអនុវត្តតាមបានយ៉ាងម៉េច? ដោយសារហេតុផលកត្តាប្រាក់បៀវត្សទាប គ្រូបង្រៀនត្រូវស្វះស្វែងបន្ថែមទៀតក្នុងការរកប្រាក់ចំណូល សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ដូចជា៖ ការបង្រៀនគួរក្រៅម៉ោង ការធ្វើការងារទី២ជាដើម ធ្វើឱ្យគ្រូមានភាពរវល់នឹងប្រយោជន៍ផ្ទាល់ខ្លួននិងមិនសូវចាប់អារម្មណ៍នឹងប្រយោជន៍ក្រុម។ នាពេលខាងមុខ នៅពេលដែលអង្គការក្រៅរដ្ឋាភិបាលនិងក្រសួងខិតខំលើកកម្ពស់ការអនុវត្តវិធីសាស្ត្រ **"ការសិក្សាស្រាវជ្រាវមេរៀន"** ដល់លោកគ្រូ-អ្នកគ្រូ គ្រប់ភូមិសិក្សា តើអាចផ្លាស់ការគិតរបស់គ្រូបង្រៀន ហើយការអប់រំអាចអភិវឌ្ឍន៍រីកចម្រើនបានទេ? វិធីសាស្ត្រសិក្សាស្រាវជ្រាវមេរៀននេះជាយុទ្ធសាស្ត្រល្អបំផុត សម្រាប់ថ្នាក់ដឹកនាំនៅតាមគ្រឹះស្ថានសិក្សា ក្នុងការជំរុញ លើកទឹកចិត្តឱ្យគ្រូ បង្រៀនចេះធ្វើការងារក្រុម និងលើកកម្ពស់ការអភិវឌ្ឍការបង្រៀន និងរៀន។ វិធីសាស្ត្រនេះមាន

លក្ខណៈជាប្រព័ន្ធ និងមានលក្ខណៈពិសេសច្រើនជាងបើប្រៀបធៀបនឹងការប្រជុំក្រុមបច្ចេកទេសដែលសាលានីមួយៗធ្លាប់អនុវត្ត ហើយវាសមស្របនឹងស្ថានភាពគ្រូ បង្រៀននៅក្នុងប្រទេសកម្ពុជាដែលគ្រូបង្រៀនភាគច្រើនបានទទួលការបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពតិចតួចណាស់បន្ទាប់ពីការបញ្ចប់ការសិក្សានៅតាមសាលាគរុកោសល្យរយៈពេល២ឆ្នាំ ឬ១ឆ្នាំមក។ គ្រូបង្រៀនមួយចំនួនមិនមានសមត្ថភាពនិងលទ្ធភាពបង្កើនសមត្ថភាពរបស់ខ្លួនតាមការសិក្សាស្រាវជ្រាវពី វិធីសាស្ត្របង្រៀន បច្ចេកទេសគរុកោសល្យ និងចំណេះដឹងទូទៅថ្មីៗ តាមរយៈប្រព័ន្ធកុំព្យូទ័រ អ៊ីនធ័រណេតដែលចំណេះដឹងថ្មីៗទាំងនោះមានការវិវត្តទៅមុខមិនឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ។ ដូច្នេះ ការយកវិធីសាស្ត្រសិក្សាស្រាវជ្រាវមេរៀនពិតជាឆ្លើយតបនឹងស្ថានភាពអប់រំនៅកម្ពុជា ព្រោះ វាផ្តល់ឱកាសដល់គ្រូចាស់ និងគ្រូថ្មីដែលទើបចេញពីសាលាអាចផ្លាស់ប្តូរមតិយោបល់ បទពិសោធ ចំណេះដឹង និងចេះជួយគ្នាទៅវិញទៅ មកក្នុងការអភិវឌ្ឍការបង្រៀន និងរៀន ប្រកបដោយប្រសិទ្ធភាព និងគុណភាព។ គ្រូទាំងអស់បានខិតជិតគ្នា ដោះស្រាយបញ្ហារួមគ្នា និងជួយកែលម្អគ្នាទាំងលើកិច្ចតែងការបង្រៀន ការបង្រៀនសាកល្បង និង ថ្នាក់និទស្សន៍...ទៅតាមវដ្តPDCA ( ផែនការ-សាកល្បង-កែលម្អ និងអនុវត្ត )។ ទោះបីយ៉ាងណាក៏ដោយគំនិតវិភាគពីបញ្ហានេះ គឺ ចង់សាកល្បងបកស្រាយបង្ហាញពីឧបសគ្គដែលរារាំងដល់ដំណើរការអនុវត្តវិធីសាស្ត្រខាងលើ ។ តើការអនុវត្តវិធីសាស្ត្រថ្មីនេះបានកម្រិតណា បើលោកគ្រូ-អ្នកគ្រូមួយចំនួនធំមិនបានផ្លាស់ប្តូរការគិតរបស់ខ្លួននោះ? បើអ្នកអប់រំភាគច្រើនសម្លឹងមើលតែផលប្រយោជន៍បុគ្គលជាធំ ដោយលើកហេតុផលមកពីកត្តាសេដ្ឋកិច្ចគ្រួសារនៅទាប តើអ្នកទាំងនោះអាចចូលរួមសកម្មក្នុងសកម្មភាពការងារក្រុមបានទេ? តើគ្រូដែលមានសមត្ថភាព ពិតជាអាច

មានស្មារតីចែករំលែកចំណេះដឹង បទពិសោធដល់គ្រូដទៃមែនឬទេ បើទាំងអស់នោះ គឺជាល្បិចបង្រៀន និងជាឆ្នាំងបាយរបស់គាត់ក្នុងការអូសទាញសិស្សមករៀនគួរឱ្យបានច្រើននោះ? ចម្លើយគឺមិនអាចទៅរួចឡើយ បើផ្នត់គំនិតពួកគាត់នៅតែបែបនេះនោះ។ យោងតាមបទពិសោធន៍ជោគជ័យលើវិស័យអប់រំរបស់ប្រទេសជាច្រើន ពួកគេផ្តោតយកចិត្តទុកដាក់ជាខ្លាំងដល់ការអភិវឌ្ឍន៍កម្រិតគុណវុឌ្ឍិ និងជំនាញវិជ្ជាជីវៈគ្រូបង្រៀនតាមរយៈការប្រើប្រាស់ធនធានខាងក្នុង និងខាងក្រៅ។ ដោយសារម៉ោងធ្វើការរបស់គ្រូបង្រៀន៨ម៉ោងក្នុងមួយថ្ងៃ ដូច្នេះគ្រូបង្រៀននៅប្រទេសទាំងអស់នោះមានពេលវេលាគ្រប់គ្រាន់ក្នុងប្រជុំពិភាក្សាចែករំលែកចំណេះដឹង បទពិសោធន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមក ការធ្វើការរួមគ្នាក្នុងការដោះស្រាយបញ្ហាប្រឈមនានា ការអនុវត្តការស្រាវជ្រាវមេរៀន ថ្នាក់និទស្សន៍ និងការស្រាវជ្រាវនានា។ ការធ្វើការរួមគ្នារវាងគ្រូ និងគ្រូ យុទ្ធសាស្ត្រគ្រូជួយគ្រូនេះឆ្លុះបញ្ចាំងពីការប្រើប្រាស់ធនធានខាងក្នុងប្រកបដោយប្រសិទ្ធភាព ហើយចំណែកឯ ការចូលរួមវគ្គសិក្ខាសាលា វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពនានា ទស្សនកិច្ចសិក្សា ការសិក្សាស្រាវជ្រាវ និងចែករំលែកការរៀនសូត្រតាមរយៈប្រព័ន្ធឌីជីថល និងលើបណ្តាញអ៊ីនធ័រណេត...ជាសិក្សាពីពិភពខាងក្រៅដើម្បីអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈ។

## 13) វិធីសាស្ត្របង្រៀន

ចំណុចសំខាន់មួយទៀតដែលយើងខ្ញុំចង់លើកកយកមកបង្ហាញនៅពេលនេះ គឺ សំដៅទៅលើវិធីសាស្ត្របង្រៀនរបស់លោកគ្រូ-អ្នកគ្រូ មួយចំនួននៅមានកម្រិតពិសេសទាក់ទងនឹងការជំរុញការគិតបែបរិះរករបស់សិស្ស។ ការបំផុសការគិតនេះ មានសារៈសំខាន់ណាស់ក្នុងហ្វឹកហាត់ខួរក្បាលរបស់

សិស្សឱ្យមានការរីកចម្រើន និងភាពវាងវៃ។ ការគិតនេះជាការរិះរកគំនិតថ្មី ដោយខ្លួនគេផ្ទាល់ និងជាសមត្ថភាពនៃការវិភាគ សំយោគ និងសន្និដ្ឋាន... មិនមែនជាការចំឡងតាមទេ។ ផ្អែកតាមរយៈការសង្កេតការបង្រៀន និងរៀនកន្លងមក យើងឃើញថាគ្រូបង្រៀនមួយចំនួន សមត្ថភាពក្នុងថ្នៃប្រឌិតបង្កើតសំណួរ ដើម្បីបំផុសការគិតរបស់សិស្សហាក់នៅមានកម្រិត។ សកម្មភាពបង្រៀន និងរៀនមួយចំនួនផ្អែកតាមសៀវភៅសិក្សាគោលទាំងស្រុង ហើយសកម្មភាពខ្លះមើលទៅដូចជា អនុវត្តតាមទម្រង់គោលវិធីសិស្សមជ្ឈមណ្ឌលសុទ្ធសាធ ប៉ុន្តែខ្លឹមសារវិញប្រាសចាកអត្ថន័យដើមរបស់វា ឧទាហរណ៍ដូចជាការបែងចែកសិស្សពិភាក្សាក្រុម ដោយដាក់សំណួរក្នុងសៀវភៅសិក្សា ដែលភាគច្រើនមានកំណែលក់នៅតាមទីផ្សារ ដែលធ្វើឱ្យសិស្សភាគច្រើនមិនបានប្រើប្រាស់ការគិត ដោយចំឡងតាមតែម្តង។ ការខ្វះខាតការយល់ដឹងជាក់លាក់ នៃគោលវិធីសិស្សមជ្ឈមណ្ឌលធ្វើឱ្យការអនុវត្តមិនបានត្រឹមត្រូវតាមខ្លឹមសារពិតប្រាកដរបស់វា ហើយនេះជាចំណុចខ្សោយមួយដ៏ធំសម្រាប់ការអភិវឌ្ឍការអប់រំ។ ចំណុចសំខាន់មួយទៀត បើតាមសាកសួរព័ត៌មានពីគណៈគ្រប់គ្រងសាលា និងលោកគ្រូ-អ្នកគ្រូនៅតាមវិទ្យាល័យនានាក្នុងខេត្តស្វាយរៀងអំឡុងពេលចុះប្រមូលទិន្នន័យសរសេរសារណាបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ ពួកគាត់មួយចំនួនធំបានលើកឡើងថា ការផ្លាស់ប្តូរវិធីសាស្ត្របង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិដែលអនុវត្តដោយគ្រូបង្រៀនភាគច្រើន ចូលរួមចំណែកនាំឱ្យសិស្សបោះបង់ការសិក្សានៅថ្នាក់ទី៧ និងទី៨ ពិសេសសិស្សដែលមានសមត្ថភាពខ្សោយស្រាប់មកពីកម្រិតបឋមសិក្សាដែលមិនមានទម្លាប់សរសេរតាមការហៅរបស់គ្រូជាប្រចាំបែបនេះ។ វិធីសាស្ត្រហៅឱ្យសិស្សកត់បែបនេះ មិនគួរចំណាយពេលច្រើនទេ ព្រោះវាមិនមានប្រើប្រាស់ការគិតរបស់សិស្ស។

**14) <u>ស្ថានភាពអប់រំកុមារនៅជនបទ</u>**

ការអប់រំកុមារនៅតាមតំបន់ជនបទបាននឹងកំពុងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដែលធ្វើឱ្យគុណភាពអប់រំធ្លាក់ចុះគួរឱ្យព្រួយបារម្ភបំផុត។ កុមារជាទំពាំងស្នងឫស្សីហើយការអប់រំនៅបឋមសិក្សាជាថ្នាក់មូល ដ្ឋានសំខាន់ក្នុងការកសាងធនធានមនុស្សជាពេលអនាគតពិសេសក្លាយជាមនុស្សពេញលេញដូចចែងក្នុងគោលនយោបាយអប់រំជាតិ។ បើមូលដ្ឋានមិនរឹងមាំទេ នោះពួកគេពិបាកសម្រេចបានជោគជ័យណាស់ក្នុងការសិក្សាថ្នាក់មធ្យមសិក្សា និងថ្នាក់មហាវិទ្យាល័យ។ បញ្ហាប្រឈមសំខាន់ៗសម្រាប់ការអប់រំរបស់កុមារនៅជនបទមានដូចខាងក្រោម៖

- ឪពុកម្តាយឬអាណាព្យាបាលសិស្សមួយចំនួនធំបានចំណាកស្រុកទៅទីក្រុង ឬប្រទេសជិតខាងដើម្បីស្វែងរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពរស់នៅ ហើយភាគច្រើនទុកកូនរស់នៅជាមួយជីដូនជីតាឬពូមីង...។ករណីនេះ ធ្វើឱ្យកូនបាត់បង់ភាពកក់ក្តៅក្នុងគ្រួសារ កង្វះការថ្នាក់ថ្នម ការថែទាំជិតដល់លើផ្នែកសុខភាព និងអនាម័យ ពិសេសការចូលរួមចំណែកបង្ហាត់បង្រៀនកូនបន្ថែមនៅផ្ទះ និងទំនាក់ទំនងជាប់លាប់ជាមួយគ្រូបង្រៀនក្នុងការដោះស្រាយបញ្ហាការសិក្សារបស់កូនឱ្យបានទាន់ពេលវេលា។ កង្វះការចូលរួមនេះ បានដាក់បន្ទុកធ្ងន់ធ្ងរ និងផ្តល់ការលំបាកច្រើនដល់គ្រូបង្រៀនក្នុងការជួយបង្ហាត់បង្រៀនបន្ថែម និងជួយសិស្សរៀនយឺត។ សម្រាប់ស្ថានភាពនេះ យើងអាចនិយាយបានថា លោកគ្រូ អ្នកគ្រូមួយចំនួននៅតែមិនមានមនសិការវិជ្ជាជីវៈរឹងមាំក្នុងការជួយសិស្សរៀនយឺតដើម្បីឱ្យពួកគេសម្រេចលទ្ធផលសិក្សា។
- នៅតែមានគ្រូបង្រៀនដែលលួចម៉ោងរដ្ឋដូចជា៖ មកបង្រៀនយឺត ឬចេញមុន ឬឱ្យសិស្សចេញលេងយូរ មិនគោរពតាមម៉ោងកំណត់របស់ក្រសួង ពិសេសភាពមិនសូវយកចិត្តទុកដាក់បង្រៀនសិស្ស

និងបង្រៀនតាមតែបាន ដែលយូរៗទៅ វាស្ទើរតែប្រែក្លាយទៅជាទម្លាប់របស់គ្រូមួយចំនួនទៅហើយ។

- មានបញ្ហាខ្វះគ្រូច្រើននៅតំបន់ជនបទ តែយើងឃើញលើសគ្រូ ច្រើននៅតំបន់ទីក្រុង ដែលឆ្លុះបញ្ចាំងពី ប្រសិទ្ធភាព និងគុណភាពនៃការបែងចែកធនធានគ្រូបង្រៀន។
- កង្វះការសហការ និងគាំទ្រពីអាជ្ញាធរមូលដ្ឋាន គណៈកម្មការទ្រទ្រង់សាលា មន្ត្រីអប់រំតាមស្រុក សហគមន៍ មាតាបិតា និងអាណាព្យាបាលសិស្ស ពិសេសលើករណីមត្តេយ្យសហគមន៍ជាដើម។ អាជ្ញាធរមូលដ្ឋាន និងគណៈកម្មការទ្រទ្រង់សាលាមួយចំនួនមិនសូវយកចិត្តទុកដាក់ និងជួយគាំទ្រដល់សាលាមត្តេយ្យសហគមន៍ទេ ដូចជាការគាំទ្រដល់ថវិកាប្រាក់លើកទឹកចិត្តប្រចាំខែរបស់គ្រូបង្រៀនឱ្យបានគ្រប់គ្រាន់ គាំទ្រថវិកាសម្រាប់ប្រើប្រាស់ក្នុងការទិញសម្ភារៈបង្រៀន និងរៀន សម្ភារអនាម័យ ទឹកស្អាត ការចុះតាមដានត្រួតពិនិត្យ ការកៀរគសម្បុរសជន ក៏ដូចជារៀបចំកម្មវិធីផ្សេងៗដើម្បីរៃអង្គាសជួយដល់ដំណើរការអប់រំកុមារតូចទេ។ ចំណែក ការជួយគាំទ្រ និងសហការពីមន្ត្រីជំនាញវិញក៏ឃើញថា មានបញ្ហាប្រឈមមួយចំនួនដែរ ព្រោះការចុះជួយភាគច្រើនអនុវត្តតែជាមួយសាលាមត្តេយ្យសហគមន៍ណាដែលនៅជិត និងមិនសូវបានទៀងទាត់។

### 15) ជំនាញទន់(Soft skill) របស់គ្រូបង្រៀន

យោងតាមស្ថិតិ និងសូចនាករឆ្នាំ២០១៥-២០១៦ បានបង្ហាញថា មានគ្រូ ១,០៤%គ្មានសញ្ញាប័ត្រគរុកោសល្យ១,៨២% គ្មាន សញ្ញាប័ត្រត្រឹមមធ្យមសិក្សាបឋមភូមិ ២៣,១៨% គ្មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង ៥៥,៧៦% បញ្ចប់ការសិក្សា និងមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ។ ទន្ទឹមនឹងកម្រិតគុណវុឌ្ឍិគ្រូទាប គ្រូបង្រៀនភាគច្រើនក៏កង្វះជំនាញទន់

ផងដែរ។ មានករណីមួយចំនួនដែលបញ្ជាក់ពីកង្វះជំនាញទន់ (Soft skill) របស់លោកគ្រូ-អ្នកគ្រូ ដូចខាងក្រោម៖

- *ការតំលើងតួនាទី ឋានៈនៅក្នុងស្ថាប័ន*

ការតំលើងតួនាទីឋានៈរបស់មន្ត្រីរាជការស៊ីវិលនៅតាមស្ថាប័នសាធារណៈ មានសារៈសំខាន់ក្នុងជំរុញសង្វាក់នៃការអនុវត្តការងារ និងលើកទឹកចិត្តមន្ត្រីរាជការស៊ីវិលក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តសិទ្ធ។ ការជ្រើសរើសបេក្ខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សមស្របនឹងមុខតំណែងគឺជារឿងចាំបាច់ដែលគេត្រូវយកចិត្តដាក់ ដើម្បីរក្សាបានស្ថេរភាពការងារ បរិស្ថានការងារល្អ កិច្ចសហការនិងទំនាក់ទំនងល្អ និងវឌ្ឍនភាពនៃការអនុវត្តការងារ ព្រមទាំងសម្រេចបាននូវលទ្ធផលតាមការគ្រោងទុកគួរជាទីមោទនៈ។ ដើម្បីឱ្យដំណើរការនៃការបំពេញការងារនៅតាមស្ថាប័នមួយចំនួន មានភាពរលូន និងមានភាព រីកចម្រើន ការប្រើប្រាស់នីតិវិធីសមស្របក្នុងការតំលើងតួនាទីឋានៈ គឺជាគន្លឹះសំខាន់ក្នុងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងារ និងអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់ជាគ្រឹះនៃការអភិវឌ្ឍប្រទេស។ មន្ត្រីរាជការស៊ីវិលជាអ្នកធ្វើការបម្រើរាស្ត្រ និងរដ្ឋ បើពួកគាត់ពេញចិត្ត មានមនសិការការងារ និងសមត្ថភាពគ្រប់គ្រាន់ពេញលេញ តាមរយៈនៃបំពាក់បំប៉ន និងការលើកទឹកចិត្តនានា នាំឱ្យការអនុវត្តការងារប្រកបដោយជោគជ័យ ហើយប្រជាពលរដ្ឋ និងប្រទេសជាតិមានការរីកចម្រើនសំបូរសប្បាយជាក់ជាមិនខាន។ ស្ថិតក្នុងស្ថានភាពមួយចំនួននៅក្នុងស្ថាប័នសាធារណៈបច្ចុប្បន្ន ដំណើរការតំលើងតួនាទីឋានៈតាមរយៈការវាយតម្លៃ និងការជ្រើសតាំង បានផ្តល់ផលអវិជ្ជមានមួយចំនួនដល់បញ្ហាចិត្តសាស្ត្រការងាររបស់មន្ត្រីរាជការមួយចំនួនផ្សេងទៀតនៅក្នុងស្ថាប័នការងារតែមួយ។ ជាទូទៅ មន្ត្រីរាជការដែលបំពេញការងារនៅ តាមស្ថាប័នសាធារណៈនីមួយៗភាគច្រើន សុទ្ធតែត្រូវ

ការលើកទឹកចិត្តតាមរយៈការតំលើងតួនាទីឋានៈ ការសរសើរ និងការផ្តល់រង្វាន់ផ្សេងៗ។ មន្ត្រីរាជការមួយចំនួន នៅក្នុងស្ថាប័នមួយចំនួនបានយកលក្ខណៈសម្បត្តិខ្លួនឯងដូចជា៖ អតីតភាពការងារយូរ សញ្ញាប័ត្រខ្ពស់ មានចំណេះដឹងនិងបទពិសោធន៍ច្រើន ប្រឹងប្រែងការធ្វើការងារយូរមកហើយ... ទៅធៀបនឹងផលប្រយោជន៍ដែលសមទទួលបាន ហើយសម្លឹងមើលនូវគុណវិបត្តិរបស់អ្នកដទៃ ដែលជាហេតុធ្វើឱ្យម្នាក់ៗប្រកួតប្រជែងដើម្បីទទួលបានផលប្រយោជន៍នោះ ដូចជា៖ ការតំលើងតួនាទីឋានៈ និងការទទួលបានលាភសក្ការៈផ្សេងៗ។ មិនថានរណាទទួលបានផលប្រយោជន៍នេះទេ សុទ្ធតែជះឥទ្ធិពលអវិជ្ជមានទៅអ្នកធ្វើការដទៃផ្សេងទៀត ដែលជំរុញឱ្យមានភាពល្អក់កករនៅក្នុងទំនាក់ទំនងការងារ និងភាពច្រណែនកើតឡើង ព្រោះអ្នកទាំងអស់នោះ សុទ្ធតែយល់ថា ខ្លួនឯងគួរតែឡើងតួនាទីធំ។ ទាំងអស់នេះ ដោយសារភាពមិនអស់ចិត្ត ភាពគ្មានតម្លាភាពនៃការតំលើង ភាពមិនទុកចិត្តគ្នាពីការងារក្រោមតុ និងការប្រកួតប្រជែងគ្នាដាច់បង្ហៀរពេកក្នុងការដណ្តើមអំណាច និងតួនាទី។ ស្ថិតក្នុងស្ថានភាពនេះ មន្ត្រីរាជការទាំងនោះ បើទោះជាការសម្រេចបានលេចជារូបរាងហើយក៏ដោយ ក៏បានប្រែក្លាយពួកគេទៅជាមនុស្សមុខពីរក្នុងទំនាក់ទំនងការងារក្នុងស្ថាប័ន។ ចំពោះអ្នកដែលមិនទទួលបានផលប្រយោជន៍នេះនឹងកកើតនូវភាពច្រណែន ដែលនាំឱ្យកើតមាននូវភាពអសកម្ម ក្នុងការបំពេញការងារ ឬបាត់បង់ឆន្ទៈក្នុងការបំពេញការងារ ដែលជាចំណុចគួរឱ្យព្រួយបារម្ភបំផុតសម្រាប់អនាគតនៃវាសនាប្រទេសជាតិ។ ស្ថិតក្នុងស្ថានភាពនេះ តើគេមានយុទ្ធសាស្ត្រអ្វីល្អជាងនេះ ដើម្បីកែលម្អនីតិវិធីក្នុងការតំលើងតួនាទីឋានៈរបស់មន្ត្រីរាជការស៊ីវិលនាពេលអនាគតដែលមើលទៅត្រឹមត្រូវ មានយុត្តិធម៌ តម្លាភាព និងអាចទទួលយកបាន? បើការឡើងតួនាទីបានការសូកលុយ ឬបក្សពួកនិយម ខ្សែរនិយម វានឹងបំផ្លាញចិត្តសាស្ត្រស្ថាប័នការងារទាំងស្រុងដែលធ្វើសង្វាក់ និងសន្ទុះនៃការអនុវត្តការងារមានការ

អភិវឌ្ឍឃើត ហើយអ្នកដែលទទួលបានតំណែងដោយការចំណាយលុយសូកគេ នោះគេនឹងក្លាយជាមេដឹកនាំដែលពុករលួយជាក់ជាមិនខាន!

- *ភាពងាយបាត់បង់មនសិការវិជ្ជាជីវៈពេលបាត់បង់ប្រយោជន៍ និងចម្ងល់ទម្ងាប់អាក្រក់ពីអ្នកដទៃ*

ទាក់ទងនឹងបញ្ហានេះ ខ្ញុំសូមលើកយកករណីសិក្សាជាក់ស្តែងមួយរបស់គ្រូបង្រៀនម្នាក់ដែលធ្លាប់ជាគរុសិស្សដែលខ្ញុំបានបង្ហាត់បង្រៀនមុនពេលចេញទៅបំពេញការងារ។ ពេលចុះទៅសហគមន៍ ដើម្បីធ្វើការស្រាវជ្រាវពីការអប់រំ និងតាមដានគ្រូចេញថ្មី ខ្ញុំបានជួបនឹងនាយកបឋមសិក្សាម្នាក់ដោយចៃដន្យពេលកំពុងហូបភេសជ្ជៈ ខ្ញុំក៏សាកសួរព័ត៌មានគាត់ពីនេះ ពីនោះទាក់ទងនឹងវិស័យអប់រំនៅតំបន់គាត់ (តំបន់ជនបទ) ដោយគាត់មិនបានដឹងថា ខ្ញុំជាគ្រូឧទ្ទេសនៅសាលាគរុកោសល្យទេ។ គាត់ត្អូញត្អែរពីការបំពេញការងាររបស់គ្រូបង្រៀននៅសាលារៀនគាត់ ដែលមានការផ្លាស់ប្តូរឥរិយាបថនៃការបំពេញការងារ បន្ទាប់ពីក្រសួងបានផ្លាស់ប្តូរនីតិវិធីសម្រាប់គ្រូបង្រៀនពីរពេល ដោយជ្រើសរើសគ្រូកិច្ចសន្យាបង្រៀនជំនួសវិញ។ ការបាត់បង់ផលប្រយោជន៍នេះ ធ្វើឱ្យគាត់អន់ចិត្តចំពោះសាលា និងគណៈគ្រប់គ្រងសាលា ដោយបានបង្ហាញពីការបាត់បង់មនសិការវិជ្ជាជីវៈ និងបំពេញការងារបែបរយីរយាក ដូចជា៖ ការមកបង្រៀនសិស្សយឺតពេល ចេញមុនម៉ោង និងមិនសូវយកចិត្តទុកដាក់បង្រៀនសិស្សជាដើម។ ខ្ញុំស្គាល់គ្រូបង្រៀននេះច្បាស់ណាស់ ព្រោះគាត់ជាកូនសិស្សខ្ញុំ ហើយមកដល់សាលាវិញ ខ្ញុំក៏បានបើកមើលលទ្ធផលសិក្សាគាត់ ខ្ញុំឃើញថា លទ្ធផលសិក្សាគាត់ល្អ ព្រមទាំងខ្ញុំបានកត់សម្គាល់ឃើញថា ពេលគាត់នៅរៀន គាត់មានការយល់ដឹងច្រើនពីវិធីសាស្ត្របង្រៀន និងជាគរុសិស្សដែលខិតខំសិក្សារៀនសូត្រ។ ចុះ ហេតុអ្វីបានជាពេលនេះ គណៈគ្រប់គ្រងសាលា ក៏

ដូចសហគមន៍ និងមាតាបិតាសិស្សធ្វើការរិះគន់ធនធានមនុស្សដែលចេញពីសមិទ្ធិផលដែលខ្លួនបានផលិតបែបនេះទៅវិញ។ ខ្ញុំបានលើកករណីនេះទៅបង្ហាញក្នុងអង្គប្រជុំ ពីចំណុចខ្សោយរបស់ស្ថាប័នដែលយើងយកចិត្តទុកដាក់បណ្ដុះតែជំនាញរឹង និងយកចិត្តទុកដាក់តិចតួចពេកលើជំនាញទន់ ហើយកម្មវិធីក៏មានតិចតួចផងដែរ ដែលធ្វើឱ្យធនធានគ្រូបង្រៀនដែលចេញមកខ្វះជំនាញទន់ ងាយបាត់បង់មនសិការវិជ្ជាជីវៈ។ ដូចគ្នានេះដែរមានការលើកឡើងមួយចំនួនថែមទៀតទៅលើការប្រតិបត្តិរបស់គ្រូបង្រៀនចេញថ្មី មួយចំនួន ពេលចេញទៅបំពេញការងារ ភាគច្រើនយកចិត្តទុកដាក់រៀបចំកិច្ចតែងការបង្រៀនតែ១ឆ្នាំ ឬ២ឆ្នាំដំបូងតែប៉ុណ្ណោះ តែដោយឃើញចាស់ៗមួយចំនួនបង្រៀនមិនមានកិច្ចតែងការបង្រៀន ក៏លែងរៀបចំសម្រាប់ខ្លួនឯងទៅ ដែលនេះបញ្ជាក់ពីការខ្វះការទទួលខុសត្រូវក្នុងអាជីពរបស់ខ្លួន និងភាពបាត់បង់មនសិការវិជ្ជាជីវៈទៅតាមមជ្ឈដ្ឋានជុំវិញ។

## V- និន្នាការអប់រំថ្មីសម្រាប់កម្ពុជា

កម្ពុជាខិតខំប្រឹងប្រែងថែមទៀតលើការបង្កើនប្រសិទ្ធភាព និងគុណភាពអប់រំក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដើម្បី "*ធានាឱ្យការអប់រំ មានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាឆ្នាំ២០៣០*"។ ក្រសួងបាននឹងកំពុងរៀបចំមូលដ្ឋាននីយកម្មគោលដៅអប់រំថ្មីនេះ តាមរយៈការរៀបចំចក្ខុវិស័យអប់រំកម្ពុជា២០៣០ ជាមួយនឹងអភិវឌ្ឍន៍ធនធានមនុស្សស្របទៅនឹង" គោលដៅអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥ ២០២៥"ដែលជាជំហានថ្មីមួយទៀតក្នុងការតម្រង់ទិសការអភិវឌ្ឍកម្ពុជាឆ្លើយតបទៅនឹងមហិច្ឆតាកម្ពុជាក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងចំណូលខ្ពស់២០៥០។ ការ

អភិវឌ្ឍធនធានមនុស្សដែលមានជំនាញប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌គឺជាអាទិភាពចម្បងសម្រាប់ប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថា កម្ពុជានឹងឈានដល់ស្ថានភាពប្រទេសមានប្រាក់ចំណូលមធ្យមនៅត្រឹមឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍ត្រឹមឆ្នាំ ២០៥០ ។ ក្នុងការឆ្ពោះទៅគោលដៅនេះ វិស័យអប់រំនៅតែបន្តផ្តល់អាទិភាពដល់ការលើកកម្ពស់គុណភាពអប់រំ និងភាពពាក់ព័ន្ធទៅតាមតម្រូវការរបស់ទីផ្សារការងារ។ ទីភ្នាក់ងារបញ្ញាថ្នាក់កណ្តាលឆ្នាំ២០១៣ (2013 Central Intelli-gence Agency) បានបង្ហាញថា ចំនួនប្រជាជនកម្ពុជាកំពុងកើនឡើងក្នុងអត្រាប៉ាន់ស្មាន១.៦៧%។ **អាយុជាមធ្យមគឺ ២៣,៧ ឆ្នាំ ដែលជាប្រជាជនមានក្មេងជាងគេនៅក្នុងតំបន់**។ ដើម្បីឆ្លុះបញ្ចាំងពីប្រជាសាស្ត្រនេះ ក្រសួងអប់រំយុវជន និងកីឡាបានបណ្តាក់ទុនយ៉ាងខ្លាំងទៅលើការអប់រំចាប់ពីថ្នាក់មត្តេយ្យដល់ឧត្តមសិក្សា ជាពិសេសក្នុងអំឡុងពេលទសវត្សរ៍ឆ្នាំ ២០០៤ ដល់២០១៤។ ជាមួយគ្នានេះ ក៏មានការកើនឡើងនូវការអប់រំក្រៅប្រព័ន្ធ និងឱកាសសម្រាប់យុវជន និងមនុស្សពេញវ័យ ដើម្បីទទួលបានជំនាញបច្ចេកទេសសំខាន់ៗក្នុងការបង្កើនឱកាសការងារ។ រាជរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងដើម្បីទាញយកប្រយោជន៍ពីសក្តានុពលនៃការបែងចែកប្រជាសាស្ត្ររបស់ប្រជាជនដើម្បីធានាបរិយាកាសអំណោយផលសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផងដែរក្នុងការអភិវឌ្ឍវិស័យអប់រំ តាមរយៈបង្កើនថវិកាចំណាយសម្រាប់វិស័យនេះជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ និងការគៀងគថវិកា និងជំនួយគាំទ្រពីខាងក្រៅសម្រាប់គម្រោងធ្វើឱ្យប្រសើរឡើងដល់វិស័យអប់រំយ៉ាងផុលផុស ដែលស្ថិតិនៃការចំណាយ និងជំនួយទាំងនោះមានដូចការបង្ហាញក្នុងក្រាហ្វិកខាងក្រោម៖

## 1. និន្នាការទូទៅផ្នែកសង្គម សេដ្ឋកិច្ច និងបញ្ហាប្រឈម

ប្រទេសកម្ពុជាបានឆ្លងកាត់នូវបទពិសោធន៍ផ្លាស់ប្តូររបបជាច្រើន ដូចជារដ្ឋប្រហារ ទំនាស់នយោបាយ សង្គ្រាមស៊ីវិល ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នាំឱ្យមានការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ សង្គម និងសេដ្ឋកិច្ចយ៉ាងធ្ងន់ធរ។ កិច្ចព្រមព្រៀងទីក្រុងបារីស និងការបោះឆ្នោត១៩៩៣ បានកែទម្រង់នយោបាយពីសេដ្ឋកិច្ចផែនការ ទៅសេដ្ឋកិច្ចទីផ្សារ និងក្លាយជាសមាជិកអាស៊ាន(ASEAN) នៅឆ្នាំ១៩៩៩ និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅឆ្នាំ២០០៤។ ប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាមានសេដ្ឋកិច្ចរីកចម្រើនខ្លាំង និងមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ព្រមទាំងផ្តល់ការងារឱ្យប្រជាជនធ្វើបានច្រើន។ ប្រទេសកម្ពុជាមានធនធានសក្តានុពលជាច្រើនសម្រាប់អភិវឌ្ឍន៍ជាតិដូចជា ធនធានមនុស្សវ័យក្មេងច្រើន ធនធានធម្មជាតិ និង ធនធានវប្បធម៌សំបូរបែប... ហើយវិស័យអាទិភាពដែលជួយជំរុញកំណើនសេដ្ឋកិច្ចមានដូចជា៖ វិស័យកសិកម្ម ទេសចរ សំណង់ វាយតនភណ្ឌ និងឧស្សាហកម្ម។ យុគសម័យនៃ សាកលភាវូបនីយកម្ម កម្ពុជាធ្វើកំណែទម្រង់សេដ្ឋកិច្ច ការប្តេជ្ញាចិត្តកសាងសន្តិភាព និងកំណែទម្រង់ប្រជាធិបតេយ្យ។ ក្នុងរង្វង់១០កន្លងមកនេះ បើប្រៀបធៀបនឹងប្រទេសអាស៊ានដទៃទៀត ប្រទេសកម្ពុជាទើបតែ ជាដំណាក់កាលចាប់ផ្តើមនៃការធ្វើឧស្សាហកម្ម ដែលមានស្ថានភាពដូចគ្នានឹងប្រទេសឡាវ និងភូមាផងដែរ។ នៅដំណាក់កាលនេះ ប្រទេសទាំងនេះផ្តោតលើវិស័យកសិកម្មជាផ្នែកសំខាន់ក្នុងសេដ្ឋកិច្ចជាតិ។ ប៉ុន្តែសម្រាប់ទិសដៅថ្មីនាពេលអនាគត ប្រទេសកម្ពុជាចង់ប្រែក្លាយខ្លួនជាប្រទេសឧស្សាហកម្មនៅឆ្នាំ២០២៥ ដែលចង់ឱ្យវិស័យនេះអាចបន្ថែមគុណតម្លៃបន្ថែមទៀតដល់កំណើនសេដ្ឋកិច្ចជាតិ។

រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសមាហរណកម្មប្រទេសកម្ពុជាក្នុងកម្រិតសាកល និងតំបន់ ពិសេសកាត់បន្ថយគម្លាតអភិវឌ្ឍន៍ប្រទេសជាសមាជិកអាស៊ាន តាមរយៈការលើកកម្ពស់ភាពជាដៃគូក្នុងការចូលរួមជាសមាជិកសហគមន៍សេដ្ឋកិចអាស៊ាន ការចូលរួមកម្មវិធីអនុ តំបន់ទន្លេមេគង្គ (Greater Mekong Sub region Program) គម្រោងតំបន់ត្រីកោណអភិវឌ្ឍន៍ (Development Triangle Zones) ដែលមានប្រទេសកម្ពុជា ឡាវ និងវៀតណាម តំបន់ត្រីកោណអភិវឌ្ឍន៍ដែលមានប្រទេសកម្ពុជា ឡាវ និងថៃឡង់ ការរៀបចំយុទ្ធសាស្រ្តសហប្រតិបត្តិការសេដ្ឋកិច្ចដែលមានកម្ពុជា ឡាវ ថៃ និងភូមា "Economic Cooperation Strategy"។ សេដ្ឋកិច្ចទីផ្សារសេរីជានាសេរីភាពនៃការធ្វើពាណិជ្ជកម្មតាមរយៈលំហូដោយសេរីនូវទំនិញ និងសេវាកម្មពីប្រទេសនានានៅក្នុងតំបន់ និងពិភពលោក បានជួយកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។ ទីផ្សារទាក់ទាញវិនិយោគិន បង្កើតការងារ បង្កើនប្រាក់ចំណូល និងលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ។ ជាការពិតការចូលរួមរបស់កម្ពុជាជាមួយអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោកជាជំហានប្រវត្តិសាស្រ្ត និងយុទ្ធសាស្រ្តដើម្បីស្តារ និងអភិវឌ្ឍកម្ពុជា។ **ទោះបីយ៉ាងណាក៏ដោយ កន្លងមកប្រទេសកម្ពុជា នៅជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដែលរាំងស្ទះដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដែលមានបង្ហាញដូចខាងក្រោម៖**

- អត្រាភាពក្រីក្រនៅខ្ពស់នៅឡើយ
- វិសមភាព (រវាងអ្នកមាន និងអ្នកក្រ តំបន់ទីក្រុង និងជនបទ ដោយសារកង្វះបណ្តាញការងារ និងសុវត្ថិភាពសង្គម ជនក្រីក្រងាយរងគ្រោះ ធ្លាក់ចូលទៅក្នុងភាពក្រីក្រកាន់តែខ្លាំង

- ហេដ្ឋរចនាសម្ព័ន្ធមិនគ្រប់គ្រាន់ (ផលវិបាកមកពីសង្គ្រាម ទំនាស់នយោបាយ ភាពឯកោពីអន្តរជាតិ...ជាឧបសគ្គក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ កម្ពុជាកង្វះធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុដែលសំខាន់ក្នុងការកសាងហេដ្ឋរចនាសម្ព័ន្ធ។ហេដ្ឋារចនារូបវន្ថមិនគ្រប់គ្រាន់ដូចជា ផ្លូវថ្នល់ អគ្គិសនី ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្លូវទឹក កំពង់ផែ...ជារបាំងដ៏សំខាន់ដែលរាំងស្ទះដល់ដំណើរអភិវឌ្ឍន៍សេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ តម្លៃដឹកជញ្ជូនថ្លៃ ភ្លើងថ្លៃ...ជាឧបសគ្គក្នុងការទាក់ទាញវិនិយោគិន។
- ទំនាស់ដីធ្លី (តម្រូវការវិនិយោគ និងកសិកម្មកើនឡើង។ អ្នកក្រ និងកសិករងាយរងគ្រោះជាងគេ ដោយសារលក់ដោះស្រាយបញ្ហាផ្ទាល់ខ្លួនដូចជា ដោះបំណុល ការព្យាបាលជំងឺ និងថែទាំសុខភាព ការដណ្តើមដីធ្លីពីសំណាក់អ្នកមានអំណាច ដីសម្បទានសេដ្ឋកិច្ចមួយចំនួនមានទំនាស់...)
- កង្វះព័ត៌មាន និងការយល់ដឹងពីសមាហរណកម្មសេដ្ឋកិច្ច (សហគ្រិនខ្នាតតូច និងមធ្យមរបស់កម្ពុជាពិបាក ប្រកួតប្រជែងក្នុងទីផ្សារនាំចេញ។ កង្វះព័ត៌មានធ្វើឱ្យពួកគាត់មិនដឹងថា តើទីផ្សារអន្តរជាតិមានតម្រូវការអ្វីខ្លះ មានស្តង់ដារយ៉ាងម៉េច គុណភាព និងរៀបចំរចនាយ៉ាងម៉េចដើម្បីឆ្លើយតបនឹងលក្ខខណ្ឌរបស់ទីផ្សាររបស់អន្តរជាតិ។ ផ្នែកឯកជនដឹងតិចតួចពីផលប្រយោជន៍នៃសមាហរណកម្មសេដ្ឋកិច្ច។ កង្វះចំណេះដឹង ធ្វើឱ្យបាត់បង់ឱកាសក្នុងការប្រកួតប្រជែងនាំចេញ ក្នុងបរិបទនៃទីផ្សារសេរី។ ផ្នែកឯកជនកង្វះការគាំទ្រពី រាជរដ្ឋាភិបាល។
- កង្វះសកម្មភាពលើកកម្ពស់ពាណិជ្ជកម្ម (កម្ពុជាមានមូលនិធិតិចតួច ក្នុងការអនុវត្តសកម្មភាពលើកកម្ពស់ពាណិជ្ជកម្មឱ្យបានទូលំ

ទូលាយខុសពី ប្រទេសថៃ វៀតណាម ចិន តៃវ៉ាន់ កូរ៉េ និងប្រទេសដទៃទៀតនៅក្នុងតំបន់។កម្ពុជាកង្វះបទពិសោធន៍ក្នុងការដោះស្រាយជាមួយទីផ្សារអន្តរជាតិ។ការជ្រើសរើសអ្នកដឹកនាំផ្នែកពាណិជ្ជកម្មល្អ អាចស្វែងរកដៃគូពាណិជ្ជកម្ម និងបង្ហាញឱកាសក្នុងការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា។

- ការិយាធិបតេយ្យស្មុគស្មាញសម្រាប់ការធ្វើពាណិជ្ជកម្មនៅកម្ពុជា (នីតិវិធីស្មុគស្មាញ ចំណាយពេលយូរធ្វើឱ្យខកទំនិញ) ឧ. ទំនិញនឹងចុះនៅកំពង់ផែវៀតណាមច្រើនជាង បើការិយាធិបតេយ្យច្រើន និងកម្រិតអំពើពុករលួយខ្ពស់ក្នុងការនាំចេញផលិតផលនៅកម្ពុជា ...។
- ចំណាយច្រើនសម្រាប់ការធ្វើពាណិជ្ជកម្មនៅកម្ពុជា (អំពើពុករលួយក្នុងផ្នែករដ្ឋបាល ពិសេសក្នុងប្រតិបត្តិការពាណិជ្ជកម្មរួមបញ្ចូលទាំងសកម្មភាពការនាំចេញ នាំចូល ថ្លៃភ្លើងថ្លៃ សេវាអ៊ីនធ័រណេត ទូរស័ព្ទ កង្វះហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មដឹកជញ្ជូនថ្លៃ នីតិវិធីជំរះពន្ធគយប្រើពេលយូរ ប្រឈមមុខនឹងការដាច់ភ្លើងញឹកញាប់ ប្រភពអគ្គិសនីមិនគួរឱ្យទុកចិត្ត និងការផ្គត់ផ្គង់មិនគ្រប់គ្រាន់។
- មូលដ្ឋានផលិតទាប (ការផលិតតិច មិនគ្រប់គ្រាន់សម្រាប់ការនាំចេញ ភាគច្រើនកសិករផលិតជាលក្ខណៈគ្រួសារ កសិកម្មតាមរដូវកាល មិនមានលក្ខណៈពេញមួយឆ្នាំដែលពិបាកក្នុងការផ្គត់ផ្គង់ទីផ្សារពេញមួយឆ្នាំ ។)
- បច្ចេកវិជ្ជានៅមានកម្រិតទាប (កម្ពុជាមានមូលដ្ឋានផលិតនៅមានកម្រិត ពិសេសដំណើរការឧស្សាហកម្ម នេះដោយសារកង្វះការគាំទ្រពី រដ្ឋ និងស្ថានភាព កង្វះធនធានមនុស្ស។ កសិករ អនុវត្តតាម

ទម្លាប់ក្នុងការផលិត៖.ស្រូវ ។បច្ចេកទេសនៅមានកម្រិតទាប នាំឱ្យសមត្ថភាពផលិតមិនអាចប្រកួតប្រជែងក្នុងទីផ្សារតំបន់ និង អន្តរជាតិ។

- កង្វះលទ្ធភាពទទួលឥណទាន និងការធានារ៉ាប់រង (កសិករមិនអាចទទួលបានប្រាក់កំចីដោយគ្មានលក្ខខណ្ឌទ្បើយ ការយល់ដឹងពីការប្រើប្រាស់កំចីនៅទាបនៅឡើយ គ្មានការធានារ៉ាប់រងដល់កសិករធ្វើឱ្យងាយរងគ្រោះ ឥណទានរីកចម្រើនតែកសិកម្មមិនរីកចម្រើន...)
- ការប្រមូលពន្ធមានកម្រិតទាបបើប្រៀបធៀបនឹងប្រទេសអាស៊ានផ្សេងទៀត

# សន្និដ្ឋានរួម

ឆ្លងតាមការបកស្រាយបង្ហាញពីប្រព័ន្ធអប់រំរបស់ប្រទេសនានានៅលើពិភពលោក ស្តង់ដារសាលារៀនលំដាប់អន្តរជាតិ ដំណើរវិវត្តន៍ និងបញ្ហាប្រឈមនានានៃការអប់រំនៅកម្ពុជាខាងលើ យើងឃើញថា វាពិតជាផ្តល់នូវចំណេះដឹង បទពិសោធ និងមេរៀនរៀនសូត្រជាច្រើនដល់យើងពិតប្រាកដមែន។ ទឡ្ហីករមួយចំនួននៅក្នុងអត្ថបទស្រាវជ្រាវនេះអាចឱ្យយើងដឹងពីចំណុចខ្លាំង ចំណុចខ្សោយ និងលក្ខណៈពិសេសនៃប្រព័ន្ធអប់រំរបស់ប្រទេសដែលទទួលភាពជោគជ័យខ្លាំងក្នុងការកសាងមូលធនមនុស្សសម្រាប់ចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ ផ្តល់ភាពជាគំរូ និងចំណុចល្អៗដែលយើងអាចយកមកអនុវត្តតាមបានសម្រាប់បម្រើដល់រីកចម្រើនលូតលាស់ប្រព័ន្ធអប់រំខ្លួន។ តាមរយៈការសិក្សាប្រៀបធៀប យើងឃើញថាប្រព័ន្ធអប់រំរបស់ប្រទេសយើងនៅមានកម្រិតនៅឡើយ ដែលស្ថានភាពនេះជាចំណុចខ្សោយដែលធ្វើឱ្យយើងពិបាកក្នុងប្រកួតប្រជែងជាមួយប្រទេសនានាក្នុងបរិបទសេដ្ឋកិច្ចសតវត្សរ៍ទី២១នាពេលបច្ចុប្បន្ន និងប្រឡូកក្នុងការងារកម្រិតតំបន់ និងសាកល។ វាជាដំណើរដ៏វែងឆ្ងាយមួយនាពេលអនាគតក្នុងការយកចិត្តទុកដាក់ធ្វើកំណែទម្រង់ប្រព័ន្ធអប់រំ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍ថ្មីរបស់ពិភពលោក និងប្រកួតប្រជែងក្នុងបរិបទសេដ្ឋកិច្ចមានមូលដ្ឋានផ្អែកលើចំណេះដឹង។ ដូច្នេះ ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធអប់រំឱ្យបានរីកចម្រើន វាទាមទារឱ្យមានកិច្ចសហការ និងធ្វើការរួមពីគ្រប់ភាគីទាំងអស់ដូចជាលោកគ្រូ-អ្នកគ្រូ ថ្នាក់ដឹកនាំអប់រំ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់សហគមន៍ មាតាបិតា និងអាណាព្យាបាលសិស្សពោលគឺទាំងផ្នែករាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីសម្រេចគោលដៅរួមនេះ គឺប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសឧស្សាហកម្ម និងប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០៕

# Endnote

## ប្រទេសសិង្ហបុរី


(1)-World Financial Center 7, London, March 2010

(2)-Lili, Rassel (January 10, 2008) Singapore maintains its title as the busiest port in the world "New channel of South Asia (Singapore)

(3)-Population 2010, Statistic 1 Provided, Democratic Front, Language and Religion" . 2010.

(4)-The education in Singapore, The Key to its success, Madrid, Spain, Nov 2011, Prof S Gopinathan, Curriculum, Teaching & Learning, Academic Group

(5)-Education in Singapore, Wikipedia

(6)-The Statistics of the Year, Singapore. Singapore Tourism Commission

(7)-( Boon, G.,Gopinathan, S.(2006 June). The development of education in Singapore since 1965. Background paper prepared for the Asia Education Study Tour for African policy makers. Singapore: NIE

(8)-( Law S. (2008) Vocational technical education and economic development-The Singapore experience. In toward a better future: Education and training for economic development in Singapore since 1965 (pp. 113-134). World bank and NIE, Singapore

(9)-រាជរដ្ឋាភិបាលកម្ពុជា, (2014) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ 2014-2018 រាជធានីភ្នំពេញ

(10)-Rizvi, F.& Lingard, B. (2010) Globalizing education policy. New York, NY: Routledge

(11)-Singapore students top in maths, science and reading in Pisa international benchmarking test". The Straits Times. 6 December 2016.

(12)& (18)-ក្រសួងអប់រំ យុវជន និងកីឡា ស្ថិតិ និងសូចការអប់រំ២០១៥-២០១៦

( 13)-Law, S. 2010. Case study on "National policies linking TVET with economic expansion" Lesson from Singapore. Paper commissioned for EFA Global Monitoring report 2012

(14)-"Singapore students top in maths, science and reading in Pisa international benchmarking test". The Straits Times. 6 December 2016.

(15)-"Over half of International Baccalaureate top scorers from Singapore". The Straits Times. 5 January 2016.

(16)-Singaporean student clinches prestigious Angus Ross Prize". Channel News Asia. July 6, 2017.

(17)-Education in Singapore (Ministry of Singapore, 2012)

(19)-Summary report, The 21st CENTURY TEACHER EDUCATION, NATIONAL INSTITUTE OF EDUCATION, SINGAPORE, May 2017, Prof.Dr. Neu Vira, NIE Cambodia
(20)-How Singapore Developed a High-Quality Teacher Workforce, The Centre for global education, ASEA Society, website: https://asiasociety.org/education

## ប្រទេសជប៉ុន

(1)-World Population Prospects: The 2017 Revision". ESA.UN.org (custom data acquired via website). United Nations Department of Economic and Social Affairs, Population Division. Retrieved 10 September 2017.

(2)-"'Multicultural Japan' remains a pipe dream". Japan Times. March 27, 2007. Archived from the original on April 14, 2011. Retrieved January 16, 2011.

(3) CIA Factbook: Japan". Cia.gov. Retrieved November 9, 2011.

(4)-Tokyo Metropolitan Government (JPN). Retrieved March 20, 2014.)

(5)- "A View of Religion in Japan". Archived from the original on January 23, 2016. Retrieved January 29, 2017.

(6) McCargo, Duncan (2000). Contemporary Japan. Macmillan. pp. 84–85. ISBN 0-333-71000-2

(7)-"The Constitution of Japan". Prime Minister of Japan and His Cabinet. November 3, 1946. Archived from the original on December 14, 2013. Retrieved February 14, 2014.)

(8)-"Japan lowers voting age from 20 to 18 to better reflect young people's opinions in policies". The Straits Times. June 20, 2015. Retrieved August 28, 2017.

(9)-"SIPRI Yearbook 2012–15 countries with the highest military expenditure in 2011". Sipri.org. Archived from the original on March 28, 2010. Retrieved April 27, 2013.)

(10)-"WHO Life expectancy". World Health Organization. June 1, 2013. Retrieved June 1,2013.)

(11)-"Japan-Australia Joint Declaration on Security Cooperation". Ministry of Foreign Affairs. Retrieved August 25, 2010.

(12)-Joint Declaration on Security Cooperation between Japan and India". Ministry of Foreign Affairs. October 22, 2008. Retrieved August 25, 2010.

(13)-"Statistics from the Development Co-operation Report 2015". OECD. Retrieved November 15, 2015.

(14)-"Japan's Foreign Relations and Role in the World Today". Asia for Educators. Retrieved November 13, 2016.

(15)- MOFA, The Basic View on the Sovereignty over the Senkaku Islands

(16)-Japan and South Korea agree WW2 'comfort women' deal". BBC News. December 28, 2015. Retrieved July 8, 2017.

(17)-Japanese Colony 1910–1945". Korean history.info. Retrieved July 8, 2017.

(18)-Ju, Hyujung (2014). "Transformations of the Korean Media Industry by the Korean Wave: The Perspective of Glocalization". Korean Popular Culture in Global Context – via ProQuest ebrary.

(19)- "The 15 countries with the highest military expenditure in 2009". Stockholm International Peace Research Institute. Archived from the original on February 17, 2011. Retrieved January 16, 2011.

(20)- Institute for Economics and Peace (2015). Global Peace Index 2015. ArchivedOctober 6, 2015, at the Wayback Machine. Retrieved October 5, 2015

(21)- "About RIMPAC". Government of Singapore. Archived from the original on August 6, 2013. Retrieved March 2, 2014.

(22)- "Tokyo says it will bring troops home from Iraq". International Herald Tribune. June 20, 2006. Archived from the original on April 16, 2007. Retrieved March 28, 2007.

(23)- "Japan business lobby wants weapon export ban eased". Reuters. July 13, 2010. Retrieved April 12, 2011.

(24)- "Japan's Security Policy". Ministry of Foreign Affairs of Japan.

(25)-"The Seven Great Powers". American-Interest. Retrieved July 1, 2015)

(26)-"OECD.Stat Education and Training > Education at a Glance > Educational attainment and labor-force status > Educational attainment of 25–64 year-olds". OECD.)

(27) Michael Green. "Japan Is Back: Why Tokyo's New Assertiveness Is Good for Washington". Real Clear Politics. Retrieved March 28, 2007.

(28) UK backs Japan for UNSC bid". Central Chronicle. Archived from the original on February 21, 2007. Retrieved March 28, 2007.

(29)- "Abe offers Japan's help in maintaining regional security". Japan Herald. Retrieved May 31, 2014.

(30)- "Japan – Introduction". Globalsecurity.org. Retrieved March 5, 2006.

(31)- "Japan fires on 'intruding' boat". BBC. December 22, 2001.

(32)- Herman, Steve (February 15, 2006). "Japan Mulls Constitutional Reform". Tokyo: Voice of America. Archived from the original on February 16, 2006.

(33)- Japan Country Report". Global Finance. Retrieved November 16, 2013.

(34)- As Farmers Age, Japan Rethinks Relationship With Food, Fields". PBS. June 12, 2012. Archived from the original on November 21, 2013. Retrieved November 21, 2013.

(35)-Nagata, Akira; Chen, Bixia (May 22, 2012). "Urbanites Help Sustain Japan's Historic Rice Paddy Terraces". Our World. Retrieved November 21, 2013.

(36)- "The World Factbook". Central Intelligence Agency. Retrieved February 1, 2014.

(37)- "UN tribunal halts Japanese tuna over-fishing". Asia Times. August 31, 1999. Retrieved February 1, 2014.

(38)-Black, Richard (June 22, 2005). "Japanese whaling 'science' rapped". BBC News. Retrieved February 1, 2014.]

(39)- Japan – Agriculture". Nations Encyclopedia. Retrieved November 21, 2013.

(40)- Inman, James (January 21, 2011). "China confirmed as World's Second Largest Economy". The Guardian. London. Retrieved January 21, 2011.

(41)- "World Factbook, Country comparison: Public debt". CIA. Retrieved August 20, 2017.

(42)- "Moody's cuts Japan's debt rating on deficit concerns". BBC News. August 24, 2011.

(43)- "Manufacturing and Construction". Statistical Handbook of Japan. Statistics Bureau. Retrieved January 16, 2011.

(44)- Fackler, Martin (April 21, 2010). "Japan Tries to Face Up to Growing Poverty Problem". The New York Times. Retrieved January 16, 2011.

(45)- "2008 Housing and Land Survey". Statistics Bureau. Retrieved January 20, 2011.

(46)- "Economic survey of Japan 2008". OECD. Archived from the original on November 9, 2010. Retrieved August 25, 2010.

(47)- "Foreign investment in Japan soars". BBC. June 29, 2005. Retrieved January 16, 2011

(48)- "Competitiveness Rankings". World Economic Forum. Retrieved February 24, 2016.

(49)- "Japan". CIA World Factbook. November 3, 2016. Retrieved November 13, 2016.

(50)-Forbes Global 2000". Forbes. Retrieved November 14, 2016.]

(51)- OICA (2016). "Production Statistics". Retrieved November 13, 2016.

(52)- “2015 Global 2000: The World's Biggest Auto Companies". Forbes. May 6, 2015. Retrieved November 13, 2016.

(53)-"The era of Japanese consumer electronics giants is dead". cnet. Retrieved November 13, 2016. [168]

(54)- Japan Country Report". Global Finance. Retrieved November 16, 2013.

(55)-"Fortune Global 500". CNNMoney. Retrieved November 16, 2013.

(56)- "National Newspapers Total Circulation 2011". International Federation of Audit Bureaux of Circulations. Retrieved February 2, 2014.

(57)-Fujita, Junko (October 26, 2013). "Japan govt aims to list Japan Post in three years". Reuters. Retrieved November 16, 2013.

(58)- Otake, Tomoko (January 19, 2016). "Visitors to Japan surge to record 19.73 million, spend all-time high ¥3.48 trillion" – via Japan Times Online.

(59)- "2016 Foreign Visitors & Japanese Departures" (PDF). Retrieved January 29, 2017 – via Japan National Tourism Organization.

(60)- "Number of visitors to Japan". Retrieved January 29, 2017 – via Japan Macro Advisors.

(61)- Japan Properties inscribed on the World Heritage List". January 29, 2017 – via UNESCO.

(62)-UNWTO Tourism Highlights 2015 Edition" (Press release). UNWTO. June 25, 2015. Retrieved July 3, 2015.

(63)- The Travel & Tourism Competitiveness Report 2017" (PDF). World Economic Forum. April 2017.

(64)-The Bloomberg Innovation Index". Bloomberg.

(65)- *McDonald, Joe (December 4, 2006). "China to spend $136 billion on R&D". BusinessWeek.*

(66)-Invest in Israel – Where Breakthroughs Happen" (PDF). Investment Promotion Center. Industry, Trade and Labor Ministry. December 4, 2011. p. 17. Retrieved October 14, 2012.

(67)-"Japanese Nobel Laureates". Kyoto University. 2009. Retrieved November 7, 2009.

(68)-Japanese Fields Medalists". Kyoto University. 2009. Archived from the original on March 10, 2010. Retrieved November 7, 2009.

(69)-"Japan wants citizens to donate their old phone to make 2020 Olympics medals".

(70)-"Nobel Laureates and Country of Birth".

(71)-Gonzalo Garland et al. "Dynamics of Demographic Development and its impact on Personal Saving : case of Japan", with Albert Ando, Andrea Moro, Juan Pablo Cordoba, in Ricerche Economiche, Vol 49, August 1995

(72)-Ogawa, Naohiro. "Demographic Trends and their implications for Japan's future". Transcript of speech delivered on 7 March 1997. Ministry of Foreign Affairs. Retrieved May 14, 2006.

(73)-Ryall, Julian (January 3, 2012). "Japan's population contracts at fastest rate since at least 1947". The Telegraph. Retrieved October 29, 2013.

(74)-"Statistical Handbook of Japan 2013: Chapter 2—Population". Statistics Bureau. Retrieved February 14, 2014.

(75)-Ogawa, Naohiro. "Demographic Trends and their implications for Japan's future". Transcript of speech delivered on 7 March 1997. Ministry of Foreign Affairs. Retrieved May 14, 2006.

(76)- Lewis, Leo (June 19, 2008). "Japan gripped by suicide epidemic". The Times. Retrieved September 20, 2008.

(77)-Ozawa-de Silva, Chikako (December 2008). "Too Lonely to Die Alone: Internet Suicide Pacts and Existential Suffering in Japan". Cult Med Psychiatry. 32 (4): 516–551. doi:10.1007/s11013-008-9108-0. PMID 18800195.

(78)-Education policy outlook Japan OECD 2015

(79)-Japan" (PDF). OECD. Retrieved October 28, 2016.

(80)-"Education OECD Better Life". OECD. Archived from the original on May 31, 2016. Retrieved May 29, 2016.

(81)- Japan" (PDF). OECD. Retrieved October 28, 2016

(82) "School Education" (PDF). MEXT. Archived from the original (PDF) on January 2, 2008. Retrieved March 2, 2014.

(83) Tomoko Otake. "Public education spending in Japan lowest in OECD for sixth straight year". The Japan Times. Retrieved October 28, 2016.

(84)- "OECD.Stat Education and Training > Education at a Glance > Educational attainment and labor-force status > Educational attainment of 25–64 year-olds". OECD.

( 85)-OECD 2010

( 86)-OECD Education at a glance 2014

(87)-កំណែទម្រង់វិស័យអប់រំនៅកម្ពុជា-មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព ២០១៦ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន

(88)-"MEXT : Statistics". Ministry of Education, Culture, Sports, Science and Technology.

(89)-Why Japan Must 'Change the Minds of a Million Teachers' December 16th, 2016 by Anne Hilto, Center for Global Education/Asia Society

(90)-Recent Trends In Education Reform by Dr. Robert Fish (Centre for Global Education)

(91)- Archived February 26, 2007, at the Wayback Machine.]

(92)-"Times get tough for teachers | The Japan Times Online". Search.japantimes.co.jp. 2006-03-28. Retrieved 2013-01-19.

(93)-Ministry of Education, Culture, Sports, Science and Technology]

(94)-STATISTICAL ABSTRACT 2006 edition<"Archived copy". Archived from the original on 2008-06-17. Retrieved 2008-06-04.>

(95)- Bhattacharjya, Samhati (May 17, 2016). "Japan to offer 10-year multi-entry visas for Chinese as part of tourism push". International Business Times. Retrieved May 17, 2016.

(96)-Formulation and development of pedagogy college, Ogawa Yoshikazu, Hiroshima University of Education, Japan 2017.08)

(97)-MINISTRY OF EDUCATION, CULTURE, SPORTS, SCIENCE AND TECHNOLOGY (2007a): Establishment of the System of Professional Schools for Teacher

(98)-MINISTRY OF EDUCATION, CULTURE, SPORTS, SCIENCE AND TECHNOLOGY (2007b): Revise of the Three Education Acts. Tokyo, Japan. (In Japanese)

(99)-MINISTRY OF EDUCATION, CULTURE, SPORTS, SCIENCE AND TECHNOLOGY (2013): Revision and Improvement of Teacher Education at the graduate level: The Report of the Collaborators' Meeting toward Policy Implementation of Improvement Concerning Teachers' Professional Development. Tokyo, Japan. (In Japanese)

(100)-YOSHIDA, N. (2013): Teacher Education Reform in Oldenburg. Bulletin Part 3 of Education and Human Science, Graduate School of Educatio, Hiroshima University Educational, 62 ,pp. 31-39. (In Japanese)

(101)-MINISTRY OF EDUCATION, CULTURE, SPORTS, SCIENCE AND TECHNOLOGY (2014b): Teacher Training and Licensing System. Tokyo, Japan. (In Japanese)

(102)-( Lewis, C. (2002). A handbook of teacher-led instructional change. Philadelphia: Research for Better Schools. )

(103)-( Lewis, C. (2002). A handbook of teacher-led instructional change. Philadelphia: Research for Better Schools. )

(104)-Wright, Rebecca (September 1, 2015). "Japan's worst day for teen suicides". CNN. Retrieved August 30,2016.

(105)-Winner, Rhiannon (December 2, 2015). "Japan's Education Disaster". The Huffington Post. Retrieved August 30, 2016.

(106)-OECD (2011a): Education at a Glance report on Japan. OECD Publishing

(107)-Desapriya and Iwase, 2003)

(108)-MINISTRY OF EDUCATION, CULTURE, SPORTS, SCIENCE AND TECHNOLOGY (2014a): Act on free tuition fee at public high schools and high school enrolment support fund. Tokyo, Japan. (In Japanese)

## ប្រព័ន្ធអប់រំកោះតៃវ៉ាន់

(1)- Kubek, Anthony (1963). How the Far East was lost: American policy and the creation of Communist China. ISBN 0-85622-000-0.

(2)-Chapter 4: Government". The Republic of China Yearbook. Government Information Office, Republic of China (Taiwan). 2011. pp. 55–65. Archived from the original (PDF) on 12 May 2008.

(3)-"AP, Taiwan Party Asserts Separate Identity From China".]

(4)-Exec. Yuan (2014), p. 36

(5)-CIA World Factbook". United States Central Intelligence Agency.

(6)-"Indigenous People". MOI Statistical Information Service. February 2012. Retrieved 14 April 2012.

(7)-"Chapter 2: People and Language" (PDF). The Republic of China Yearbook 2011. Government Information Office, Republic of China (Taiwan). Archived from the original(PDF) on 14 May 2012.

(8)-Zeitoun, Elizabeth; Yu, Ching-Hua. "The Formosan Language Archive: Linguistic Analysis and Language Processing" (PDF). Computational Linguistics and Chinese Language Processing. 10 (2): 168. Retrieved 4 August 2012

(9)-"Taiwan Yearbook 2006". Government of Information Office. 2006. Archived from the original on 8 July 2007.

(10)- "Number of Villages, Neighborhoods, Households and Resident Population". MOI Statistical Information Service. Archived from the original on 29 March 2014. Retrieved 2 February 2014.

(11)- CIA World Factbook". United States Central Intelligence Agency.

(12)- "USGS seismic hazard map of Eastern Asia". Seismo.ethz.ch. Archived from the original on 3 March 2000. Retrieved 30 May 2011

(13)-Shambaugh, David L. (2006). Power shift. University of California Press. pp. 179–183. ISBN 0-520-24570-9

(14)-"History of Taiwan". Windows on Asia. Asian Studies Center, Michigan State University. Archived from the original on 1 September 2006. Retrieved 3 December 2014.

(15)-Chou, Chuing Prudence; Ho, Ai-Hsin (2007). "Schooling in Taiwan". In Postiglione, Gerard A.; Tan, Jason. Going to school in East Asia. Greenwood Publishing Group. pp. 344–377. ISBN 978-0-313-33633-1. Archived from the original on 19 April 2010.

(16)- Tierney, Robert (2010). Tropics of Savagery: The Culture of Japanese Empire in Comparative Frame. University of California Press. pp. 8–9. ISBN 978-0-520-94766-5

(17)- Chou, Chuing Prudence; Ho, Ai-Hsin (2007). "Schooling in Taiwan". In Postiglione, Gerard A.; Tan, Jason. Going to school in East Asia. Greenwood Publishing Group. pp. 344–377. ISBN 978-0-313-33633-1. Archived from the original on 19 April 2010.

(18)- Grajdanzev, A. J. (1942). "Formosa (Taiwan) Under Japanese Rule". Pacific Affairs. 15(3): 311-324. doi:10.2307/2752241. JSTOR 2752241.

(19)- "History". Oversea Office Republic of China (Taiwan). 2007. Archived from the original on 28 March 2007. Retrieved 2 July 2007.

(20)-"Shu LinKou Air Station: World War II". Shu LinKou Air Station: World War II. Ken Ashley, U.S. military photo archives. Retrieved 14 June 2011

(21)- "Protesters demand justice from Japan on 'comfort women' (update) | Society | FOCUS TAIWAN – CNA ENGLISH NEWS". Focustaiwan.tw. 14 August 2013. Retrieved 30 December 2013.

(22)- "Taiwan history: Chronology of important events". Chinadaily.com.cn. Archived from the original on 16 April 2016. Retrieved 20 April 2016.

(23)- Dunbabin, J. P. D. (2008). The Cold War. Pearson Education. p. 187. ISBN 0-582-42398-8. In 1949 Chiang Kai-shek had transferred to Taiwan the government, gold reserve, and some of the army of his Republic of China.

(24)- [III. Decree to establish martial law in Taiwan] (in Chinese). National Archives Administration, National Development Council. 2 October 2009. Retrieved 23 May2012.

(25)-"28 February 1947 – Taiwan's Holocaust Remembered – 60th Commemoration". New Taiwan, Ilha Formosa. 2007. Retrieved 2 July 2009.

(26)- "28 February 1947 – Taiwan's Holocaust Remembered – 60th Commemoration". New Taiwan, Ilha Formosa. 2007. Retrieved 2 July 2009.

(27)- Gluck, Caroline (16 July 2008). "Taiwan sorry for white terror era". London: BBC News.

(28)-"Taiwan Timeline – Cold war fortress". BBC News. 2002. Retrieved 2 July 2009

(29)- "China: Chiang Kai-shek: Death of the Casualty". Time. 14 April 1975. p. 3. Retrieved 16 December 2009.

(30)- Fung (2000), p. 85: "The response to national emergency, critics argued, was not merely military, it was, even more important, political, requiring the termination of one-party dictatorship and the development of democratic institutions."

(31)- Copper, John Franklin (2005). Consolidating Taiwan's democracy. University Press of America. p. 8. ISBN 0-7618-2977-6. Also, the "Temporary Provisions" (of the Constitution) did not permit forming new political parties, and those that existed at this time did not seriously compete with the Nationalist Party. Thus, at the national level the KMT did not permit competitive democratic elections.

(32)- Human Development Index (HDI)]. National Statistics, Republic of China (Taiwan) (in Chinese). Directorate General of Budget, Accounting and Statistics, Executive Yuan, R.O.C. 15 September 2014.ប្រទេស

(33)- Tang, Pei-chun (12 March 2016). "Undergraduate degree holders in Taiwan exceed 5 million".

(34)- BBC News, "Taiwan Flashpoint", "But Taiwan's leaders say it is clearly much more than a province, arguing that it is a sovereign state. It has its own constitution, democratically elected leaders, and 400,000 troops in its armed forces."

(35)- "Full text of Anti-Secession Law". People's Daily. 14 March 2005. Retrieved 10 April2012.

(36)- Yu, Sophie; Jane Macartney (16 December 2008). "Direct flights between China and Taiwan mark new era of improved relations". The Times. London. Retrieved 4 June 2009.

(37)- Michael S. Chase (4 September 2008). "Caliber – Asian Survey – 48(4):703 – Abstract". Caliber.ucpress.net. doi:10.1525/as.2008.48.4.703. Retrieved 29 May 2009.

(38)- David Isenberg. "US Keeps Taiwan at Arm's Length". Cato.org. Retrieved 29 May 2009.

(39)-"ECFA issues and the nationality identification" (PDF). TVBS. Archived from the original (PDF) on 21 May 2009.

(40)- "Countries – China". US Department of State, Office of the Historian. Retrieved 28 May2009.

(41)-Eyal Propper. "How China Views its National Security," The Israel Journal of Foreign Affairs, May 2008.

(42)- Henckaerts, Jean-Marie (1996). The international status of Taiwan in the new world order. Martinus Nijhoff Publishers. pp. 96–97. ISBN 90-411-0929-3.

(43)- Vang, Pobzeb (2008). Five Principles of Chinese Foreign Policies. AuthorHouse. p. 46. ISBN 978-1-4343-6971-0.

(44)- Yates, Stephen J. (16 April 1999). "The Taiwan Relations Act After 20 Years: Keys to Past and Future Success". The Heritage Foundation. Archived from the original on 22 July 2009. Retrieved 19 July 2009.

(45)- "China: US spat over Taiwan could hit co-operation". Google News. Google. Agence France-Presse. 2 February 2010. Archived from the original on 6 February 2010. Retrieved 17 July 2014.

(46)- Kelly, James A. (21 April 2004). "Overview of US Policy Towards Taiwan" (Press release). United States Department of State. Archived from the original on 10 April 2008. Retrieved 17 July 2014.

(47)- "US to sell arms to Taiwan despite Chinese opposition". BBC News. 16 December 2015.

(48)- "China warns against first major US-Taiwan arms sale in four years". The Guardian. Reuters. 16 December 2015.

(49)- Tkacik, John (13 May 2009). "JOHN TKACIK ON TAIWAN: Taiwan's 'undetermined' status". Taipei Times. Retrieved 28 May 2009.

(50)- Su, Joy (19 May 2004). "WHO application: a question of health or politics?". Taipei Times.

(51)- "Taiwan delegation to participate in WHA". Taiwan Today. 14 May 2010. Retrieved 2 January 2015.

(52)- "Taiwan flags in Salt Lake ruffle a few feelings". The Deseret News. 10 February 2002.

(53)- "ECFA issues and the nationality identification" (PDF). TVBS. Archived from the original (PDF) on 21 May 2009.

(54)- "2004 National Defense Report" (PDF). ROC Ministry of National Defense. 2004. pp. 89–90. Archived from the original (PDF) on 11 March 2006. Retrieved 5 March 2006. The PRC refusal to renounce using military power against Taiwan, its current emphasis on 'enhancing preparation for military struggle', its obvious intention of preparing a war against Taiwan reflected in operational deployment, readiness efforts, and annual military exercises in the Southeast China coastal region, and its progress in aerospace operations, information warfare, paralyzing warfare, and non-conventional warfare, all of these factors work together so that the ROC Armed Forces face an increasingly complicated and difficult situation in terms of self-defense and counterattack. These multiple daunting challenges are testing our defense security.

(55)- "Taiwan Yearbook 2004". Government Information Office, Republic of China. Archived from the original on 6 January 2012. Retrieved 28 May 2009.

(56)- Bishop, Mac William (1 January 2004). "Women Take Command". Government Information Office, Republic of China. Archived from the original on 28 April 2011. Retrieved 5 June 2009.

(57)- "Taiwan Yearbook 2005". Government Information Office, Republic of China. Archived from the original on 27 January 2010. Retrieved 28 May 2009.

(58)- Roy, Denny (2003). Taiwan: A Political History. Ithaca, NY: Cornell University Press. pp. 76, 77. ISBN 0-8014-8805-2.

(59)- Her, Kelly (12 January 2005). "Privatization Set in Motion". Taiwan Review. Archived from the original on 30 April 2011. Retrieved 5 June 2009

(60)- "Reserves of foreign exchange and gold". World Fact Book. CIA. 4 September 2008. Archived from the original on 13 June 2007. Retrieved 3 January 2011. Rank 5 Taiwan $274,700,000,000 31 December 2007

(61)- Harding, Phil (23 January 2010). "Taiwan's Grand Hotel welcome for Chinese visitors". BBC News.

(62)- DoIT 2008, p. 5 "Notably, cross-strait political tensions have not prevented Taiwanese firms from investing heavily in China. The cross-strait investments

now exceed US$ 100 billions. Four Taiwanese-owned firms rank among China's top 10 biggest exporters. 10% of the Taiwanese labor force now works in China."

(63)- DoIT 2008, p. 5 "Although used-to-be-hostile tension between Taiwan and China has been eased to a certain degree, Taiwan should seek to maintain stable relation with China while continuing to protect national security, and avoiding excessive "Sinicization" of Taiwanese economy. Strategies to avoid excessive "Sinicization" of the Taiwanese economy could include efforts to increase geographic diversity of overseas Taiwanese employment, diversifying Taiwan's export markets and investment.

(64)- BBC News, "Taiwan Flashpoint", "Some Taiwanese worry their economy is now dependent on China. Others point out that closer business ties makes Chinese military action less likely, because of the cost to China's own economy."

(65)- Wang, Audrey (10 January 2011). "Taiwan's 2010 trade hits record high". Taiwan Today.

(66)- "US-Taiwan FTA would have limited impact". bilaterals.org. Archived from the originalon 10 May 2006. Retrieved 28 May 2009.

(67)- Morris, Peter (4 February 2004). "Taiwan business in China supports opposition". Asia Times Online.

(68)- "Coping with Asian financial crisis: The Taiwan experience | Seoul Journal of Economics". Find Articles at BNET. 28 April 2009. Archived from the original on 8 June 2009. Retrieved 28 May 2009.

(69)"Separate Customs Territory of Taiwan, Penghu, Kinmen and Matsu (Chinese Taipei) and the WTO". World Trade Organization. Retrieved 7 June 2009.

(70)-Postiglione, Gerard A.; Grace C. L. Mak (1997). Asian higher education. Greenwood Publishing Group. pp. 346–348. ISBN 0-313-28901-8.

(71)-"Fears over over-education in Taiwan". The Australian. 3 September 2012.

(72)-Kiersz, Andy (16 December 2016). The latest ranking of top countries in math, reading, and science is out — and the US didn't crack the top 10.

(73) Garver, John (2011). Taiwan's Democracy: Economic and Political Challenges. Routledge.

(74)-"TIMSS Math 2003" (PDF)

(74)-""TIMSS Science 2003" (PDF).

(76)-Chou, Chuing (12 November 2014). "Education in Taiwan: Taiwan's Colleges and Universities".

(77)- "5 mil. Taiwanese hold degrees from higher education institutions". 13 March 2016.

(78)-Ellis, T. I. (1984). "Extending the School Year and Day," ERIC Digest, 7.

(79) -( Chou, C. P. and J. K. S. Yuan (2011). "Buxiban in Taiwan." IIAS Newsletter, Spring.)

(80) -( Chou, C. P. (2008a). "The Impact of Neo-Liberalism on Taiwanese Higher Education." International Perspectives on Education and Society, 9: 297–311.)

(81)- ( Chou, C. P. and J. K. S. Yuan (2011). "Buxiban in Taiwan." IIAS Newsletter, Spring.)

(82) -( Chou, (2008b). Mr. President: How Are You Going to Deal with Education in Taiwan? Taipei: Psychology.)

(83)-( Chou, C. P. and Ching, G. (2012). Taiwan Education at the Cross-Road: When Globalization Meets Localization. New York: Palgrave Macmillan.)

(84) -( Chou, C. P. and J. K. S. Yuan (2011). "Buxiban in Taiwan." IIAS Newsletter, Spring.):

(85) -( Chou, C. P. and J. K. S. Yuan (2011). "Buxiban in Taiwan." IIAS Newsletter, Spring.)

(86) ( Taiwan's Education Reform and The future of Taiwan Tu Cheng-Sheng Jan 10, 2007)

(87)-( MoE 1999)

(88)- "Fears over over-education in Taiwan". The Australian. 3 September 2012

(89) -"Taiwan's higher education enrolment starts a downward slide". ICEF Monitor. 16 August 2016.

(90) -Chou, Chuing (12 November 2014). "Education in Taiwan: Taiwan's Colleges and Universities".

(91) -Advancing 21st Century Competencies in Taiwan February 2017, Case Study Authors: Hsiao-Lan Sharon Chen and Hsuan-Yi Huang, National Taiwan Normal University

(92) -(MOE, 2011), Taiwan

(93) -(MOE, 2010), Taiwan

(94) -(MOE, 20114), Taiwan

(95) -(Yao, 2000) Yao, Xin-Zhong (2000). An Introduction to Confucianism. Cambridge: Cambridge University Press.

(96) -( Hwang, K.K. (2012). Foundations of Chinese Psychology: Confucian Social Relations. New York: Springer)

(97)-( Zhou, Yu-Wen (2000). "Confucianism and Competition of Education" in S. W. Yang (ed.) International Conference for a Study on the Competition of Education in Confucian Asia for Center for Educational Research, pp. 204–210. Taipei: National Taiwan University.)

(98) -Hung, W. J. (2009). Localization movements and its implications for local education. Journal of Education Research, 187, 39-51.)

(99) -Huang, M. J. (2009). Indigenous language teaching in Taiwan: Past and future. Journal of Ching-Yun University, 29, 139-166.

(100) - Keo 2000 (1999 Indigenous educational survey in Taiwan. Council of Indigenous people. Taipei.)

(101)- Ministry of Education. (2011a). A white paper on international education for primary &secondary schools. Taipei: MOE.

(102) -Census and Statistics Department of MOE. (2014). 2013 Indigenous students' summary in Taiwan. Retrievedfrom https://stats.moe.gov.tw/files/analysis/102native.pdf

(103) -World Volunteer Web. (2014). Volunteerism worldwide: News, views & resources. Retrievedfromhttp://www.worldvolunteerweb.org/iyv-10/stakeholders/ngos.html

(104)- TIMSS Math 2003

(105)-http://english.moe.gov.tw/ct.asp?xItem=15742&CtNode=11434&mp=1 Taiwan ministry of Taiwan: Education system (Education Ministry of Taiwan, 2013)

(106)-(Technology and Vocational Education in Taiwan) Dr. Yen Yi (Nicole) Lee, Director General Department of Technological & Vocational Education Ministry of Education Taiwan

(107)-Training and the Labor Market: A Comparison between Taiwan and Japan, Wataru Nakazawa (Graduate School of Human Sciences, Osaka University) Institute of Social Sciences, University of Tokyo, Panel Survey Project Discussion Paper Series No.82, August, 2014

(108)-Kerckhoff, Alan C. 2001. "Education and Social Stratification Process in Comparative Perspective," Sociology of Education, Extra Issue: 3-18.

(109)- (Hamilton and Biggart, 1988) Hamilton, Gary G and Nicole Woolsey Biggart. 1988. "Market, Culture, and Authority: A Comparative Analysis of Management and Organization in the Far East," American Journal of Sociology, 94: S52-S94.

( 110)-Cabinet approves Taipower break up - Taipei Times

(111)-Kariya, Takehiko and James E. Rosenbaum. 1995. "Institutional Linkages between Education and Work as Quasi-Internal Labor Markets," Research in Social Stratification and Mobility, 14: 99-134.

(112) -Teacher-Parent Interactions in Taiwan: A Qualitative Investigation of Teachers' Perspectives Pi-Ju Wu Graduate Institute of Education, National Changhua University of Education, Taiwan Copyright © 2015 Horizon Research Publishing All rights reserved.

## ប្រព័ន្ធអប់រំប្រទេសកូរ៉េ

(១)-"Korea's ethnic nationalism is a source of both pride and prejudice, according to Gi-Wook Shin". Aparc. Stanford. Retrieved 3 November2009

(២)-Glionna, John M. (24 February 2009), "Trying to teach South Korea about discrimination", The Los Angeles Times

(៣)-Kim, Hyung-jin (29 August 2006). "No 'real' Chinatown in S. Korea, the result of xenophobic attitudes". Yonhap News. Retrieved 8 December 2006.

(໔)- "More Than 1 Million Foreigners Live in Korea". Chosun Ilbo. 6 August 2009. Retrieved 16 August 2009.

(໕)-"Korea, North". The World Factbook. CIA. Retrieved 3 November 2009.

(໖)- "Religion". About Korea. Korea. Archived from the original on 31 July 2008. Retrieved 3 November 2009.

(໗)-"Korea, Republic of". International Religious Freedom Report. US: Department of State. 2008. Retrieved 3 November 2009.

(໘)-"The Korea Times: Islam takes root and blooms". Islam awareness. 22 November 2002. Retrieved 3 November 2009.

(໙)-Wikipedia (Korea)

(໑໐)-"Murder of Empress Myeongseong", Japan rape, Kim soft, 2002, archived from the original on 9 October 2004

(໑໑)-"March 1st Movement". Encyclopædia Britannica. 1 March 1919. Retrieved 3 November2009.

(໑໒)-"Korea". Encarta. MSN. Archived from the original on 1 November 2009.

(໑໓)- "Statistics of Japanese Genocide and Mass Murder". Hawaii. Retrieved 3 November2009.

(໑໔)- Modern Japan and Foreign Laborers: Chinese and Korean Labourers in the late 1890s and early 1920s], et al., 明石書店 Akashi-shoten, ISBN 978-4-7503-0568-4

(໑໕)- Gruhl, Werner (2007). Imperial Japan's World War Two: 1931–1945. Transaction Publishers. p. 111. ISBN 978-1-4128-0926-9

(໑໖)-Yoshiaki, Yoshimi (2001) [岩波書店, 1995], Comfort Women: Sexual Slavery in the Japanese Military During World War II, O'Brien, Suzanne transl, Columbia University Press, ISBN 0-231-12032-X

(១៧)-"Japanese comfort women ruling overturned". CNN. 29 March 2001. Archived from the original on 16 December 2008.

(១៨)-"Comfort Women". Retrieved 3 November 2009.

(១៩)-"Koreans in Japan: Past and Present". HAN. Retrieved 3 November 2009.

(២០)-"Gyeongbok Palace". Seoul City. South Korea: Life in Korea. Archived from the original on 26 September 2009. Retrieved 3 November 2009.

(២១)-Itoi, Kay; Lee, BJ (17 October 2007). "Korea: A tussle over treasures — who rightfully owns Korean artifacts looted by Japan?" Newsweek. Retrieved 6 June 2008.

(២២)-"Who rightfully owns Korean artifacts looted by Japan?" Newsweek, MSNBC, archived from the original on 25 September 2010

(២៣)-"Japanese Periodicals in Colonial Korea". Columbia. Retrieved 3 November 2009.

(២៤)-"The Life Instability of Intermarried Japanese Women in Korea". USC. Archived from the original on 13 October 1999. Retrieved 3 November 2009.

(២៥)- "Africa has to spend carefully", The Independent (leading article), UK, 13 July 2006

(២៦)- Rummel, RJ (1997), "10. Statistics of North Korean Democide: Estimates, Calculations, and Sources", Statistics of Democide, Hawaii

(២៧)-Omestad, Thomas, "Gulag Nation" Archived 9 May 2005 at the Wayback Machine., U.S. News & World Report, 23 June 2003.

(២៨)- Spoorenberg, Thomas; Schwekendiek, Daniel,"Demographic Changes in North Korea: 1993–2008" (PDF), Population and Development Review (online ed.), Wiley, 38 (1): 133–58, doi: 10.1111/j.1728-4457.2012.00475.x

(២៩)-Seung-Hun Chun (19 April 2010). "Strategy for Industrial Development and Growth of Major Industries in Korea" (PDF). Korea Institute for Development

Strategy. Archived from the original (PDF) on 11 October 2013. Retrieved 31 July 2012

(៣០)-Ann Sasa List-Jensen (2008). Economic Development and Authoritarianism - A Case Study on the Korean Developmental State (PDF) (Report). Aalborg University. ISSN 1902-8679. Retrieved 31 July 2012

(៣១)-Kerr, Anne; Wright, Edmund (1 January 2015). "A Dictionary of World History". Oxford University Press – via Google Books

(៣២)-http://www.eria.org/ERIA-DP-2015-78.pdf

(៣៣)- Kleiner, JüRgen (2001). Korea, A Century of Change. ISBN 978-981-02-4657-0

(៣៤)- "Economic Statistics System". bok.or.kr

(៣៥)-http://www.thomaswhite.com/pdf/emerging-markets-spotlight-south-korea-and-taiwan-consumer-electronics-march-2011.pdf

(៣៦)-http://www.samsung.com/global/business/business-images/resource/RR-CS/2012/10/TES_1210_LTE_In_Korea_CS-0.pdf

(៣៧)- ITU - 2015 Global ICT Development Index

(៣៨)- The Bloomberg Innovation Index". Retrieved 11 June 2016

(៣៩)- Economy ended 2013 on a high". joins.com

(៤០)- Korea: Gross domestic product based on purchasing-power-parity (PPP)". International Monetary Fund. Retrieved 2010-10-16

[៤១]- "South Korea". National Center on Education and the Economy. Retrieved December 4, 2013.

[៤២]- "What the world can learn from the latest PISA test results". 10 December 2016.

[໔໓]-Diamond, Anna (November 17, 2016). "Why South Korea Is So Fixated With the College-Entrance Exam".

[໔໔]- Lee, Ji-Yeon (September 26, 2014). "Vocational Education and Training in Korea: Achieving the Enhancement of National Competitiveness" (PDF). KRIVET. KRIVET.

[໔໕]-"South Korean education ranks high, but it's the kids who pay". March 30, 2015.

[໔໖]-Na Jeong-ju (23 May 2012). "Meister schools fight social prejudice". The Korea Times. Retrieved 15 July 2016.

[໔໗] -"South Koreans Consider The Trades Over University Education". Public Radio International.

[໔໘]-David Santandreu Calonge (March 30, 2015). "South Korean education ranks high, but it's the kids who pay". Retrieved 3 July 2015.

[໔໙]-WeAreTeachers Staff. "South Korea's School Success". WeAreTeachers. Archived from the original on 5 July 2015. Retrieved 3 July 2015.

[໕໐]"Korea Awash with the Under-Skilled and Overeducated © This is copyrighted material owned by Digital Chosun Inc. No part of it may be reproduced or transmitted in any form or by any means without prior written permission". Chosun. 8 December 2011. Retrieved 23 October 2016.

[໕໑]-Reeta Chakrabarti (2 December 2013). "South Korea's schools: Long days, high results". BBC. Retrieved 28 October 2016.

[໕໒]-OECD.Stat Education and Training > Education at a Glance > Educational attainment and labor-force status > Educational attainment of 25-64 year-olds". OECD.

[໕໓]-"High performance, high pressure in South Korea's education system". ICEF Monitor. 23 January 2014. Retrieved 29 May 2016.

[໕໔]-Tomoko Otake. "Public education spending in Japan lowest in OECD for sixth straight year". The Japan Times. Retrieved 28 October 2016.

[៥៥] "South Korean students wracked with stress". 8 December 2013.

[៥៦]-Thomas, Tanya (27 April 2010). "Intensely Competitive Education In South Korea Leads to Education Fever". Medindia. Retrieved December 4, 2013.

[៥៧]-Janda, Michael (October 22, 2013). "Korea's Rigorous Education System Has Delivered Growth, but It is Literally Killing the Country's Youth". ABC. Retrieved December 4, 2013.

[៥៨]-Koo, Se-Woong (August 1, 2014). "An Assault upon Our Children". The New York Times. Retrieved August 19, 2015.

[៥៨]-"Meister schools fight social prejudice". The Korea Times. Retrieved July 15, 2016.

(៥៩)-Kim-Renaud, Y.-K. (2005). Korean education (introduction). The Sigur Center Asia Papers, 4(1), 5–7.)

(៦០)-Severin, E., & Capota, C. (2011). The use of technology in education: Lessons from South Korea. N_10- August 2011. Briefly Noted. Inter-American Development Bank.

(៦១)-Sami, F. (2013). South Korea: A success story in mathematics education. MathAMATYC Educator, 4(2), 22–28.

(៦២)-Park, K. (2004). Factors contributing to Korean students' high achievement in mathematics. Korea sub-commission of ICMI: The report on mathematics education in Korea. Seoul: ICMI

(៦៣)-Kim, E.-F., & Han, Y.-K. (2002). Attracting, developing and retaining effective teachers. Background report for Korea. Seoul: Korean Educational Development Institute

(៦៤)-International Bureau of Education, IBE, and United Nations Educational Scientific and Cultural Organization, UNESCO. (2011). World data on education. Profile of the Republic of Korea (7th Ed). 2010/11.

UNESCO.)

(៦៥)-KERIS. (2006). Main achievements for ICT use in education in Korea 1996–2006. Seoul: Korea Education and Research Information Service)

[៦៦]-Encyclopedia of Korean Culture (in Korean). Academy of Korean Studies. Retrieved January 22, 2014.

[៦៧]-Andrea Matles Savada and William Shaw, editors. ''South Korea: A Country Study''. Washington: GPO for the Library of Congress, 1990.

[៦៨]-Lee, Ji-Yeon (September 26, 2014). "Vocational Education and Training in Korea: Achieving the Enhancement of National Competitiveness" (PDF). KRIVET. KRIVET.

[៦៩]-FACKLER, MARTIN (July 6, 2009). "With Wounded Pride, Unemployed Koreans Quietly Turn to Manual Labor".

[៧០]-"South Korea Votes in a Changing Region". Stratfor. April 13, 2016.

[៧១]-"Fewer Young People Go On to University". The Chosun. Retrieved 29 May 2016.

[៧២]-"Lee urges job seekers to look for opportunities at smaller companies". The Korea Herald. 30 March 2010. Retrieved 26 October 2016.

[៧៣]-Ng Jing Yng (24 July 2015). "Earlier introduction of vocational education 'could have prevented' S Korea's grad glut". Today. Retrieved 2 October 2016.

[៧៤]-Park Yoon-bae (January 30,2013). n/2014/02/164_129722.html "Overeducated,underemployed" Check |url= value (help). Korea Times.

[៧៥]-"Voc-tech grads get jump on jobs". Korean Joonang Daily. Retrieved 2 October 2016.

[៧៦]-Diamond, Anna (November 17, 2016). "Why South Korea Is So Fixated With the College-Entrance Exam".

[៧៧]-c, ed. (October 17, 2016). "One in three unemployed people have bachelor's degrees". The Korea Times.

[៧៨]-"Tackling Youth Unemployment". McKinsey on Society. Retrieved 29 May 2016

[៧៩]-Choi, Wonsik (April 2013). "Beyond Korean style: Shaping a new growth formula". McKinsey Global Institute.

[៨០]-Naomi Rovnick (26 April 2013). "Why South Korea is under stress and college graduates there earn less than if they didn't have a degree". Quartz. Retrieved 26 October 2016.

[៨១]-"The other arms race". Time. 23 October 2016. Retrieved 2 October 2016.

[៨២]-"Park throws support behind vocational schools". 15 April 2014. Retrieved 14 July 2016.

[៨៣]-"Students, with their own dreams, choose not to take College Scholastic Aptitude Test". Arirang News. Retrieved 21 September 2016.

[៨៤]-Oliver, Christian; Buseong, Kang (11 June 2010). "South Korea faces problem of 'over-education'". Financial Times. Retrieved 29 May 2016.

[៨៥]-"For South Korean Youth, an Education Crossroads". Voice of America. Retrieved 29 May 2016.

[៨៦]-"Lee calls for end to prejudices against non-college graduates". Yonhap. Retrieved 2 October 2016.

[៨៧]-Kwaak, Jeyup S. (28 June 2014). "Extreme Corporal Punishment Case in Seoul School Sparks Debate". The Wall Street Journal.

[៨៨]-Ripley, A. (2011). Teacher, leave those kids alone. Time, 25 September. http://content.time.com/time/ magazine/article/0, 9171, 2094427, 00.htm.)

[៨៩]-"South Korea: An end to Saturday classes | Thomas White International". Thomaswhite.com. 2011-09-26.

[៩០]-Kuczera, Małgorzata; Kis, Viktória; Wurzburg, Greg (May 2009). OECD review of vocational education and training in Korea (PDF) (Report). Organization for Economic Co-operation and Development

[៩១]-"South Korea's education success". BBC News. 13 September 2005.

[៩២]-Singmaster, Heather (2016). "How Vocational Education Can Be an Economic Driver". Education Week.

[៩៣]-"Tech-centered vocational school opens in Daejeon". Korea Jooang Daily. 14 March 2015. Retrieved 15 July 2016.

[៩៤]-"South Korea: Role model Germany". DW News.

[៩៥]-Lee, Ji-Yeon (September 26, 2014). "Vocational Education and Training in Korea: Achieving the Enhancement of National Competitiveness" (PDF). KRIVET. KRIVET

[៩៦]-Murisa, Tendai (2015). Beyond the crises: Zimbabwe's prospects for transformation. Weaver Press. p. 332. ISBN 9781779222855.

[៩៧]-"Over 90 pct of public firms adopt wage peak system". The Korea Observer. 4 November 2015. Retrieved 15 July 2016.

[៩៨]-Lee, Ji-Yeon (September 26, 2014). "Vocational Education and Training in Korea: Achieving the Enhancement of National Competitiveness" (PDF). KRIVET. KRIVET.

[៩៩]-Korean Council for University Education. Retrieved 11 December 2011

[១០០]-"Exams in South Korea: The one-shot society". The Economist. 17 December 2011

[១០១]-Youth No. 1 cause of death is suicide]. Women's Newspaper (in Korean). 20 May 2011.

[១០២]-"Exam Pressure Making S.Korean Students Contemplate Suicide". Medindia.

[១០៣]-Jambor, Paul Z. (Summer 2009). "Why South Korean Universities Have Low International Rankings - Part II: The Student Side of the Equation". Academic Leadership. 7 (3).

[១០៤]-Jambor, Paul Z. (Winter 2009). "Why South Korean Universities Have Low International Rankings". Academic Leadership. 7 (1).

## ក្រុងសៀងហៃ

(១)-Marc, S. Tucker, Introduction. (2014) Chinese Lessons: Shanghai's Rise to The top of the PISA League table. The National Center of Education and The Economy (pp.1-7)

(២)-Copyright© 2016 by the National Center on Education and the Economy®. Minxuan Zhang, Xiaojing Ding and Jinjie Xu January 2016

## ប្រព័ន្ធអប់រំវៀតណាម

(April 2016) Unraveling a Secret: Vietnam's Outstanding

Performance on the PISA Test

Suhas D. Parandekar

Elisabeth K. Sedmik

Global Practice for Education, the World Bank

## ដំណើរវិវត្តន៍ និងបញ្ហាប្រឈមនៃការអប់រំកម្ពុជា

(១)-ឃីង ហុកឌី ៧.ទំ ១៩ទីសតវត្សអក្សរសិល្ប៍ខែរមាលីបទ(២០០៣)

(២)-ស៊ន សំណាង ទិដ្ឋភាពទូទៅនៃការបណ្តុះបណ្តាលធនធានមនុស្សនៅប្រទេសកម្ពុជាពីដើមសវទី២០ដល់ឆ្នាំ១៩៧៥ទំ២៤ដល់១.

(៣)-អ៊ិតសារិនស្រណោះព្រលឹងខ្មែរ ១៩៧៣ ទំ៤

(៤)-ក្រសួងអប់រំ ១៩៩០ UNESCO 1991

(៥)-ហង់ ជួនណារ៉ុន (២០១៦) កំណែទម្រង់វិស័យអប់រំនៅកម្ពុជា-មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិនិងវិបុលភាព ឯកឧត្តមបណ្ឌិតសភាចារ្យ

(៦)-National EFA Assessment Group, 1999-National EFA Assessment Group, Ministry of Education, Youth and Sport. (1999). Kingdom of Cambodia. Retrieved from http://datatopics.worldbank.org/hnp/files/edstats/KHMefapr00.pdf).

(៧)-Tan 2007-Tan, C. (2007) Education reform in Cambodia: Issues and concerns, Educational Research policy practice 6:1, 15-20

(៨)-UNESCO, 2000-UNESCO. (2000). Education for All 2000 Assessment: Country Report; Cambodia. Retrieved from http://unesdoc.unesco.org/images/0012/001215/121540Eo.pdf

(៩)-Courtney, J. (2007) Do Monitoring and Evaluation tools, Designed to Measure the improvement in the quality of primary school, internal journal of educational development, 28 (2008) 546-559)

(១០)-Kim, C.Y &rouse, M (2011) Reviewing of the role of teacher in Achieving Education for all Cambodia, prospects, 41, 415-428

(១១)-MoEYS & UNICEF (2005). Expanded Basic Education Programme (EBEP) (Phase II) 2006-2010: A joint MoEYS/UNICEF proposal submitted to Sida. Phnom Penh: Authors.

(១២)-ក្រសួងអយក (២០០៥) ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ ភ្នំពេញ MoEYS

១៣ ))-Mathews, V. (2006). Cambodia: Positioning for 2008. In D. Singh & L.C. Salazar (Eds.), Southeast Asian Affairs 2006 (pp. 73-89). Institute of Southeast Asian Studies: Singapore.

(១៤)-Chhinh, S. (2005). Priority Action Program, Impact Survey 2005. Phnom Penh: MoEYS

(១៥)-The World Bank ( .(2005Cambodia: Quality Basic Education for All. Washington: Author.Thomas, C.J.(.(2002 Education Notes: Achieving Education for All in Post-Conflict. Cambodia. Washington: The World Bank.

(១៦)-កំណែទម្រង់កម្មវិធីសិក្សា ២០០៥-២០០៩

(១៧)-Cambodia, More Efficient Government Spending for Strong and Inclusive Growth,

Integrated Fiduciary Assessment and Public Expenditure Review (IFAPER), Achievements and Challenges of the Education Strategic Plan, Poverty Reduction and Economic Management Unit East Asia and Pacific Region

(១៨)-ក្រសួងអយក ២០១០ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០០៨-២០១៣)

(១៩)-Bray, M., and Seng, B. (2005). Balancing the Books: Household financing of basic education in Cambodia. Hong Kong: Comparative Education Research Centre, Faculty of Education, University of Hong Kong

(២០)-World Bank's Report: Managing Risk and Vulnerability in Cambodia: An Assessment and Strategy for Social Protection, June 2006)

(២១)-14First Meeting of the Council of Ministers, 26th September 2008)

(២២)-NGO Education Partnership. (2007). the impact of informal school fees on family expenditures. NGO Education Partnership, Education Operational Research. Retrieved from http://www.nepcambodia.org/images/stories/Informal_School_ Fee_Report_2nd_Version_in_English.pdf)

(២៣)-Dawson, 2009-Dawson, W. (2009). The tricks of the teacher: Shadow education and corruption inCambodia. In S. P. Heyneman (Ed.), Buying your way into heaven: Education and corruption in international perspective (pp. 51–74). Rotterdam, Netherlands: Sense Publishers.)

(២៤)-VSO. Teaching Matters: A policy report on the Morale of Teachers in Cambodia. 2008, pp23.

(២៥)- Benveniste, L., Marshall, J., & Araujo, M. C. (2008). Teaching in Cambodia. Washington, DC: World Bank ទំ.38)

២៦ ))-VSO, (2008) របាយការណ៍ស្ទង់មតិ

(២៧)-The Cambodian Center for the Protection of Children's Right. Primary and Community Education, 2012.)

(២៨)-ADB. 2014. Asian Development Outlook 2014. Manila

(២៩)-S. Damico. 2010. Higher Education and Skills for the Labor Market in Cambodia. Phnom Penh

៣០ ))-Tandon, P. And Fukao, T. (2015). Educating the Next Generation: Improving Teacher Quality in Cambodia (Washington, DC: IBRD/ The World Bank)

(៣១)-CITA, 2011CITA (2011). 'Report on the CITA National Survey 2011' (Phnom Penh: CITA)

៣២ ))-Brehm, Silvoa, & Tuot, 2012- Brehm, W.C., Silova, I., And Tuot, M. (2012) 'Hidden Privatization of Public Education in Cambodia: the Impact and Implications of Private Tutoring', Education Support Program Working Paper Series, Open Society Foundations).

(៣៣)- Brehm, W. C. and Silova, I. (2014). 'Hidden privatization of public education in Cambodia: Equity implications of private tutoring', Journal for Educational Research Online, 6 (1), 94-116.

(៣៤)-Ponniah, K. and Heng, C. (2014). 'Three quarters of students receive a failing mark', The Phnom Penh Post, 30 August

៣៥ ))- World Bank. 2013. Skilling Up Vietnam: Preparing the Workforce for a Modern Market Economy. Main Report, Vietnam Development Report 2014. Washington, DC: World Bank.)

(៣៦)-Madhur, Srinivasa. 2014. Cambodia's Skill Gap: An Anatomy of Issues and Policy Options, CDRI Working Paper 98. Phnom Penh: CDRI.

៣ )៧)-CDRI (2013) Cambodia Development Resource Institute. 2013. Cambodia's Development Dynamics: Past Performance and Emerging Priorities. Phnom Penh: CDRI

៣៨ ))-World Bank. 2012. Matching Aspirations: Skills for Implementing Cambodia's Growth Strategy. Phnom Penh: World Bank.

៣៩ ))-EMC, Emerging Markets Consulting. 2014. Survey of ASEAN Employers on Skills and Competitiveness. Bangkok: ILO

(៤០)- JICA, Japan International Cooperation Agency. 2012. The Preparatory Study Program for Human Resource Development for Industry in the Kingdom of Cambodia. Mimeo/unpublished.

៤១ ))-Campbell, J., G. Dussault, J. Buchan, F. Pozo-Martin, M. Guerra Arias, C. Leone, A. Siyam and G. Cometto. 2013. "A Universal Truth: No Health without a Workforce." Geneva: World Health Organization.

៤២ ))-Kanchanachitra, Churnrurtai, Magnus Lindelow, Timothy Johnston, Piya Hanvoravongchai, Fely Marilyn Lorenzo, Nguyen LanHuong, Siswanto Agus Wilopo and Jennifer Frances dela Rosa. 2011. "Human Resources for Health in Southeast Asia: Shortages, Distributional Challenges, and International Trade in Health Services." The Lancet 377 (9767): 769-81.

(៤៣)-Aring, Monika. 2012. "Paper Commissioned for the EFA Global Monitoring Report 2012, Youth and Skills: Putting Education to Work." Accessed 16 Jan 2015. www.unesdoc.unesco.org/images/0021/002178/217874e.pdf.

(៤៤)-Bruni, Michele, Likanan Luch and Somean Houch. 2013. Skills Shortages and Skill Gaps in the Cambodian Labour Market: Evidence from Employer Skills Needs Survey. ILO Asia-Pacific Working Paper Series. Bangkok: ILO Country Office for Thailand, Cambodia and Laos.

(៤៥)-Del Carpio, Ximena. 2013. "Developing Skills for a Productive Workforce: Issues and Potential Solutions." PowerPoint presentation, The World Bank, East Asia and Pacific Region Human Development Department Social Protection and Labor Unit, 7 November 2013.

(៤៦)-Das et al. 2013- Das, Sanchita Basu, Jayant Menon, Rodolfo Severino and Omkar Lal Shrestha, eds. 2013. The ASEAN Economic Community: A Work in Progress. Singapore: Institute of Southeast Asian Studies and Asian Development Bank.

(៤៧)-Cambodia's Skill Gap: An Overview- CDRI, 2015

(៤៨)-របាយការណ៍សង្ខេបស្ដីពីសមិទ្ធិផលសំខាន់ៗរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣-២០១៧

(៤៩)-ក្រសួងអយក របាយការណ៍សន្និបាតបូកសរុបការងារអប់រំ ឆ្នាំ២០១៨

(៥០)-NEP (2008). The Impact of Preschool on Early Childhood Education in Cambodia: A Study of Six NGO-Sponsored Preschools in Battambang, Kampong Chhnang and Phnom Penh.

(៥១)- MoEYS. Early Childhood Education. Available at http://www.moeys.gov.kh/en/early-childhood-education.html. See also ESWG (2015). Joint Government-Development Partners Cambodia Education Sector Review.

(៥២)- MoEYS (2016). Education Congress – p. 18.

(៥៣)-MoEYS (2015). The National Education for All: 2015 Review Report.

(៥៤)-NEP (2012). Promoting Rights in Schools: The State of Children's Rights in Cambodian Primary Schools

(៥៥)- WEF (2015). Global Competitiveness Report, World Economic Forum, available at http://reports.weforum.org/global-competitiveness-report-2015-2016/economies/#economy=KHM

(៥៦)-USAID (2015). Data for Education Programming in Asia and Middle East: Assessment of Early Grade Reading in the Education Sector in Cambodia.

(៥៧)-World Vision (2016). Current Situation & Use of Primary School Libraries: A snapshot across 5 provinces in Cambodia.

(៥៨)-UNDP (2015). Human Development Report 2015.

(៥៩)- CDRI (2015). Cambodia Education 2015 - Employment and Empowerment.

(៦០)- MoEYS (2004): Policy for Curriculum Development (2005-2009).

(៦១)- NEP (2015): Teaching Hours in Primary Schools in Cambodia.

(៦២)-UNESCO, VSO, NEP (2014). Right to Education in Cambodia: Community Level Research as well as ESWG (2015). Joint Government-Development Partners Cambodia Education Sector Review.

(៦៣)- International Center for Research on Women (ICRW) & Plan International (2014). Are Schools Safe and Gender Equal Spaces: Finding from a Baseline Study of School Related Gender-based Violence in Five Countries in Asia.

(៦៤)- Plan International (2014). Vulnerable and Marginalised Children's Access to, Learning and Participation in School: Understanding the Challenges.

(៦៥)-NGOCRC (2013). UPR Submission on Cambodian Child Rights.

(៦៦) ទីស្តីការគណៈរដ្ឋមន្ត្រី (២០១៨) របាយការណ៍សង្ខេប ស្តីពី សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣២០១៧-

(៦៧) រាជរដ្ឋាភិបាលកម្ពុជា (២០១៥) គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥

(៦៨)-វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការវិស័យអប់រំនៅកម្ពុជា ថ្ងៃទី២២ - ២៥ ខែកុម្ភៈ ឆ្នាំ២០១៦-ការវិភាគវិស័យអប់រំ

(៦៩)- ការគ្រប់គ្រងនិងរដ្ឋបាលនាយកដ្ឋានបប២០០៩-ទំ១៤៦

(៦៣)- International Center for Research on Women (ICRW) & Plan International (2014). Are Schools Safe and Gender Equal Spaces: Finding from a Baseline Study of School Related Gender-based Violence in Five Countries in Asia.

(៦៤)- Plan International (2014). Vulnerable and Marginalised Children's Access to, Learning and Participation in School: Understanding the Challenges.

(៦៥)-NGOCRC (2013). UPR Submission on Cambodian Child Rights.

(៦៦) ទីស្ដីការគណៈរដ្ឋមន្ត្រី (២០១៨) របាយការណ៍សង្ខេប ស្ដីពី សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣២០១៧-

(៦៧) រាជរដ្ឋាភិបាលកម្ពុជា (២០១៥) គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥

(៦៨)-វគ្គបណ្ដុះបណ្ដាលស្ដីពីការរៀបចំផែនការវិស័យអប់រំនៅកម្ពុជា ថ្ងៃទី២២ - ២៥ ខែកុម្ភៈ ឆ្នាំ២០១៦-ការវិភាគវិស័យអប់រំ

(៦៩)- ការគ្រប់គ្រងនិងរដ្ឋបាលនាយកដ្ឋានបប២០០៩-ទំ១៤៦

សៀវភៅថ្មីដែលមានចំណងជើង "**បណ្តុំគំនិតនៃការអភិវឌ្ឍ -មិនបញ្ឈប់ភាពក្រីក្រ កសាងវឌ្ឍនភាពសង្គម**" នឹងចេញនៅពេលឆាប់នេះ! វាជាបណ្តុំគំនិតពីសៀវភៅល្បីៗនៅលើពិភពលោកជាង៥០ក្បាលមកជាសៀវភៅសរសេរជាភាសាខ្មែរមួយក្បាលដោយយកទ្រឹស្តីអភិវឌ្ឍន៍ទាំងនោះ មកផ្ទុះបញ្ចាំងនឹងតថភាពសង្គមខ្មែរជាក់ស្តែង





## អំពីអ្នកនិពន្ធ

លោក **ចៅ ឧស្សាហ៍** អតីតសិស្សពូកែអក្សរសាស្ត្រខ្មែរចំណាត់ថ្នាក់លេខ១ប្រចាំខេត្តស្វាយរៀង។ លោកបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ២០០២ផ្នែកអក្សរសាស្ត្រខ្មែរ គ្រូបង្រៀនកម្រិតឧត្តមនៅមហាវិទ្យាល័យគរុកោសល្យផ្នែកអក្សរសាស្ត្រខ្មែរ សីលធម៌ ពលរដ្ឋវិជ្ជាក្នុងឆ្នាំ២០០៣ អធិការអប់រំ និងបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំឆ្នាំ២០១៨នៅវិទ្យាស្ថានជាតិអប់រំ។ លោកមានបទពិសោធធ្វើការជិតម្ភៃឆ្នាំនូវតួនាទីជាច្រើនលើវិស័យអប់រំដូចជា ធ្វើជាគ្រូបង្រៀននៅសាលារដ្ឋ និងឯកជនអន្តរជាតិ គ្រូឧទ្ទេសសាលាគរុកោសល្យ និងវិក្រឹតការ សាស្ត្រាចារ្យមហាវិទ្យាល័យ ព្រមទាំងធ្វើជាជំនួយការនាយកប្រតិបត្តិ ទីប្រឹក្សា និងប្រធានគ្រប់គ្រងកម្មវិធីអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។ លោកមានបទពិសោធច្រើនទាក់ទងនឹងការអប់រំយុវជន និងកុមារ ការគ្រប់គ្រងគម្រោង និងការអភិវឌ្ឍសហគមន៍ ការសរសេរគម្រោងសំណើ ដែលចំណេះដឹង និងបទពិសោធជាច្រើនត្រូវបានដាក់បញ្ចូលទៅក្នុងសៀវភៅនេះ។ លោកបានទទួលវគ្គបណ្ដុះបណ្ដាលជាច្រើនផងដែរដូចជា៖ ការបង្រៀនដោយប្រើបច្ចេកវិទ្យា កម្មវិធីសិក្សាអន្តរជាតិIB - TESOL និងវិធីសាស្ត្រប្រឹក្សា។ បច្ចុប្បន្ននេះលោកធ្វើជាអធិការអប់រំ នៅតំបន់មួយ។

*“ ទុកឱ្យខ្ញុំដេកលក់សិនចុះ ចាំខ្ញុំភ្ញាក់ ខ្ញុំនឹងរត់តាមក្រោយ ។ ”*